សាកលវិទ្យាល័យភូមិន្ទកសិកម្ម

Royal University of Agriculture

# វចនានុក្រម បច្ចេកស័ព្ទកសិកម្ម (អង់គ្លេស~ខ្មែរ និង ខ្មែរ~អង់គ្លេស)

# Agricultural Technical Dictionary

## (English-Khmer & Khmer-English)

វចនានុក្រមបច្ចេកស័ព្ទកសិកម្ម Agricultural Technical Dictionary RUA 2015

Funded by

ACIAR | Australian Centre for International Agricultural Research

ACIAR

aciar.gov.au

Australian Government

Australian Centre for International Agricultural Research

ISBN 978-9-9249-0200-3




ក្រុមអ្នករៀបរៀង និងពិនិត្យករនៅក្នុងសិក្ខាសាលាវាយតម្លៃ
នាថ្ងៃទី ១៦ ខែ មិថុនា ឆ្នាំ ២០១៥ នៅសាកលវិទ្យាល័យភូមិន្ទកសិកម្ម

**The development team and editorial team during the final evaluation workshop on 16th June 2015 at the Royal University of Agriculture**

# វចនានុក្រមបច្ចេកស័ព្ទកសិកម្ម
## ( អង់គ្លេស ខ្មែរ/ខ្មែរ អង់គ្លេស )

**ចងក្រងបោះពុម្ពដោយ៖**
គម្រោងសហការណ៍រវាងសាកលវិទ្យាល័យភូមិន្ទកសិកម្ម និង ACIAR ប្រទេសអូស្ត្រាលី
មជ្ឈមណ្ឌលភាសា, ប្រអប់សំបុត្រលេខ ២៦៩៦ ខ័ណ្ឌដង្កោ, ភ្នំពេញ
សារអេឡិចត្រូនិច៖ languagecenter@rua.edu.kh គេហទំព័រ៖ www.rua.edu.kh
លេខ ISBN:  978 9-9249 0200-3
បោះពុម្ពដោយ៖ មជ្ឈមណ្ឌលឯកសារ

ការចងក្រងពាក្យ និងកន្សោមពាក្យសម្រាប់វចនានុក្រមនេះ ត្រូវបានដកស្រង់ពីប្រភពផ្សេងៗ ជាមួយនឹងការតបស្នងដោយសេចក្តីថ្លែងអំណរគុណ ដែលមានបង្ហាញតាមរយៈបញ្ជីឯកសារយោងនៅខាងក្រោយ។ សូមកត់សម្គាល់ថាវចនានុក្រមនេះមិនមែនផលិតសម្រាប់ធ្វើអាជីវកម្ម និងជាចម្បងសម្រាប់ការអប់រំ ការស្រាវជ្រាវ និងការផ្សព្វផ្សាយ ដែលចូលរួមចំណែកដល់ការកសាងធនធានមនុស្ស និងស្របតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា។

ព័ត៌មាននៅក្នុងវចនានុក្រមនេះត្រូវចងក្រង និងពិនិត្យយ៉ាងម៉ត់ចត់តាមដែលអាចធ្វើទៅបាន ដើម្បីធានាឱ្យបាននូវភាពសុក្រឹតនៅពេលបោះពុម្ព។ ដោយយោងទៅតាមធនធាន និងកាលវេលា នោះកំហុសដោយអចេតនាអាចនឹងមានក្នុងវចនានុក្រមនេះ។ អ្នកនិពន្ធ និងអ្នកបោះពុម្ព នឹងមិនទទួលខុសត្រូវតែម្នាក់ឯងលើអសុក្រឹតភាពផ្សេងៗ នៃខ្លឹមសារខ្លះនៃសៀវភៅទាំងមូល។

រាល់កិច្ចការដកស្រង់ទាំងអស់ត្រូវធ្វើឡើងដោយមានប្រភពច្បាស់លាស់ និងគោរពរាល់កម្មសិទ្ធិបញ្ញា។ ទោះបីជាយ៉ាងណាក៏ដោយ ប្រសិនបើមានការរំលោភកម្មសិទ្ធិបញ្ញាដោយអចេតនាណាមួយ នោះក្រុមការងារចងក្រង សូមទទួលនូវសេចក្តីសណ្តោសប្រោសប្រណី និងម្ចាស់កម្មសិទ្ធិបញ្ញាអាចទំនាក់ទំនងមកបាន។

**ពិនិត្យករសម្រាប់ទំនាក់ទំនង**
សាស្ត្រាចារ្យបណ្ឌិត **សេង មុំ**
សាកលវិទ្យាការរង នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ភ្នំពេញ
សារអេឡិចត្រូនិច៖ mseng@rua.edu.kh

បណ្ឌិត **ចន ស្ទីលល័រ**
សាស្ត្រាចារ្យកិត្តិយស ប្រចាំនៅ សាលាដី និង សាលាវិទ្យាសាស្ត្រ នៃសាកលវិទ្យាល័យឃ្វីនស្ល៍ឡេនដ៍ ប្រទេសអូស្ត្រាលី
សារអេឡិចត្រូនិច៖ j.schiller@uq.edu.au

លោក **ហួត ចាន់ធី**
ប្រធានមជ្ឈមណ្ឌលភាសា នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ភ្នំពេញ
សារអេឡិចត្រូនិច៖ languagecenter@rua.edu.kh

# AGRICULTURAL TECHNICAL DICTIONARY
# (English-Khmer/Khmer-English)

**Published by**
RUA-ACIAR Project, 2015

Royal University of Agriculture (RUA)
Language Center, P.O.Box. 2696, Dangkor District,
Phnom Penh, Cambodia. E-mail: languagecenter@rua.edu.kh; Website: www.rua.edu.kh

ISBN: 978 9-9249 0200-3
Printed by Documentary Centre, RUA

The compilation of this dictionary included the use of reference materials taken from various sources, these sources being acknowledged in the reference list in the book. The aim of the production of the dictionary to provide a bi-lingual dictionary reference, which would become freely available for education, research, extension and general policy use, and which would help with human resource development within Cambodia.

The information contained in this dictionary has been compiled and reviewed to ensure its accuracy at the time of publication. However, it is also acknowledged that further updating of the dictionary will be required in the future. The authors and publisher take no responsibility with regards to the accuracy of the information contained in this book.

Every effort has been made to trace and acknowledge copyrights. However, should any infringements have occurred, the publishers tender their apologies and invite copyright holders to contact them.

**Correspondents**
Professor Dr SENG Mom
Vice-Rector,
Royal University of Agriculture, P.O.Box. 2696, Dangkor District, Phnom Penh, Cambodia.
E-mail: mseng@rua.edu.kh

Dr John SCHILLER
Honorary Senior Fellow, School of Land and School Sciences,
The University of Queensland, St. Lucia, Brisbane. Australia 4072.
E-mail: j.schiller@uq.edu.au

Mr HUOT Chanthy
Head, Language Center
Royal University of Agriculture, P.O.Box. 2696, Dangkor District, Phnom Penh, Cambodia.
E-mail: huotchanthy@rua.edu.kh

**អ្នកផ្តួចផ្តើមគម្រោង**

| | |
|---|---|
| ឯ.ឧ សាស្ត្រាចារ្យបណ្ឌិត ង៉ោ ប៊ុនថាន | សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| សាស្ត្រាចារ្យបណ្ឌិត សេង មុំ | សាកលវិទ្យាធិការរង នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |
| បណ្ឌិត ចន ស្ទីលល័រ | សាស្ត្រាចារ្យកិត្តិយស ប្រចាំនៅ សាលាដី និង សាលាវិទ្យាសាស្ត្រ នៃសាកលវិទ្យាល័យឃ្វីនស្ស៍ឡេនដ៍ ប្រទេសអូស្ត្រាលី |
| លោក ថេង ឌីណា | គ្រូឧត្តម នៅមហាវិទ្យាល័យវិស្វកម្មកសិកម្ម នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម |

**អ្នករៀបរៀង និងចងក្រង**

| **នាម និងគោត្តនាម** | **ឯកទេស** | |
|---|---|---|
| លោក ហួត ចាន់ធី | សាកវប្បកម្ម និង ភាសាអង់គ្លេស | ប្រធានក្រុម |
| លោក ខៀវ សុធី | ព័ត៌មានវិទ្យា | អ្នកបង្កើត Software និង រចនា |
| លោក លឹម មករា | ក្សេត្រសាស្ត្រ និង ភាសាអង់គ្លេស | ជំនួយការ |
| លោក ឈុន សេងហាក់ | កសិ-ឧស្សាហកម្ម | - |
| លោក សំអឿន បូរ៉ា | កសិ-ឧស្សាហកម្ម និង ភាសាអង់គ្លេស | - |
| លោក ធាម ប៉េងហៀង | ក្សេត្រសាស្ត្រ | - |
| កញ្ញា នៅ ករុណា | ក្សេត្រសាស្ត្រ | អ្នកវាយអត្ថបទ |
| កញ្ញា ជា មករា | ក្សេត្រសាស្ត្រ | - |
| លោក ហេង ចេងហ៊ុយ | ក្សេត្រសាស្ត្រ | - |

**Initiators:**

| | |
|---|---|
| H.E Prof. Dr NGO Bunthan | Rector, Royal University of Agriculture |
| Professor Dr SENG Mom | Vice-Rector, Royal University of Agriculture |
| Dr John SCHILLER | Honorary Senior Fellow, School of Land and School Sciences, The University of Queensland. Australia |
| Mr THENG Dyna | Lecturer, Faculty of Agricultural Engineering, RUA |

## Development Team (Language Centre)

| **Name** | **Field** | |
|---|---|---|
| Mr HUOT Chanthy | Horticulture & English | Team Leader |
| Mr KHIEV Sothy | Information Technology | Software developer & designer |
| Mr LIM Makara | Agronomy & English | Assistant |
| Mr CHHUN Senghak | Agro-Industry | - |
| Mr SAMOEUN Bora | Agro-Industry & English | - |
| Mr THEAM Penghieng | Agronomy | - |
| Ms NOV Karuna | Agronomy | Typist |
| Ms CHEA Markara | Agronomy | - |
| Mr HENG Chhenghuy | Agronomy | - |

**ពិនិត្យករ**

| នាម និង គោត្តនាម | អង្គភាពបម្រើការ | |
| --- | --- | --- |
| ឯ.ឧ សាស្ត្រាចារ្យបណ្ឌិត ង៉ោ ប៊ុនថាន | សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | ប្រធាន |
| សាស្ត្រាចារ្យបណ្ឌិត សេង មុំ | សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | សមាជិក |
| សាស្ត្រាចារ្យបណ្ឌិត សុក គន្ធី | សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| សាស្ត្រាចារ្យបណ្ឌិត ម៉ែន សារ៉ុម | សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក ទី ចាន់ណា | សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក ឃួន អៀង | មហាវិទ្យាល័យកៅស៊ូ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក តែ គុយហោ | មហាវិទ្យាល័យវិទ្យាសាស្ត្រសត្វ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក គង់ ថុង | មហាវិទ្យាល័យកសិ-ឧស្សាហកម្ម សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក ហេង ចំរើន | មហាវិទ្យាល័យវិទ្យាសាស្ត្រព្រៃឈើ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក ឡោ លីគួ | មហាវិទ្យាល័យវិស្វកម្មកសិកម្ម សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| បណ្ឌិត ខែ សត្យា | វិទ្យាស្ថានស្រាវជ្រាវ និងអភិវឌ្ឍន៍កសិកម្មកម្ពុជា ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| បណ្ឌិត ប៊ុនតុង បូរ៉ារិន | មហាវិទ្យាល័យកសិ-ឧស្សាហកម្ម សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| បណ្ឌិត កែវ សាធ | មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| បណ្ឌិត ហុក លីដា | មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក ហុក សែនសម្ភា | មហាវិទ្យាល័យវិទ្យាសាស្ត្រជលផល សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក ធីម សុខា | មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| កញ្ញា អុង សុជាតិ | មហាវិទ្យាល័យវិទ្យាសាស្ត្រកសិកម្ម សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |

| | | |
|---|---|---|
| លោក ជា ប៊ុនណា | មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក យឿន សុគុណ | មហាវិទ្យាល័យវេជ្ជសាស្ត្រសត្វ សាកលវិទ្យាល័យភូមិន្ទកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក ហុង សម្បត្តិ | ក្រសួងបរិស្ថាន | - |
| លោក អ៊ិន ចាន់ថា | អគ្គនាយកដ្ឋានកសិកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោកស្រី ឈុន ណារី | នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក ថោង សំណាង | នាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក ឈួយ សំអុល | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោកស្រី លី សុខតា | រដ្ឋបាលជលផល ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក សូ ថន | រដ្ឋបាលព្រៃឈើ ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ | - |
| លោក ខេង សេង | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា | - |
| លោក ស្រី វីរៈ | វិទ្យាស្ថានបណ្តុះបណ្តាល និងស្រាវជ្រាវដើម្បីអភិវឌ្ឍន៍កម្ពុជា | - |

**Editorial Team**

| Name | Institution | Role |
|---|---|---|
| H.E Prof. Dr NGO Bunthan | Royal University of Agriculture (RUA), MAFF | Leader |
| Prof. Dr SENG Mom | Royal University of Agriculture (RUA), MAFF | Member |
| Prof. Dr SOK Kunthy | Royal University of Agriculture (RUA), MAFF | |
| Prof. Dr MEN Sarom | Royal University of Agriculture (RUA), MAFF | |
| Mr TY Channa | Royal University of Agriculture (RUA), MAFF | |
| Mr KHUON Eang | Faculty of Rubber, RUA, MAFF | |
| Mr TE Kuyhor | Faculty of Animal Science, RUA, MAFF | - |
| Mr KONG Thong | Faculty of Agro-Industry, RUA, MAFF | - |
| Mr HENG Chamroeun | Faculty of Forestry, RUA, MAFF | - |
| Mr LOR Lytour | Faculty of Agricultural Engineering, RUA, MAFF | - |
| Dr KHAY Sathya | Cambodia Agricultural Research and Development Institute, MAFF | - |
| Dr BUNTONG Borarin | Faculty of Agro-Industry, RUA, MAFF | - |
| Dr KEO Sath | Faculty of Veterinary Medicine, RUA, MAFF | - |
| Dr HOK Lyda | Faculty of Agronomy, RUA, MAFF | - |
| Mr HOK Sensamphea | Faculty of Fisheries, RUA, MAFF | - |
| Mr THIM Sokha | Faculty of Veterinary Medicine, RUA, MAFF | - |
| Ms ONG Socheat | Faculty of Agronomy, RUA, MAFF | - |
| Mr CHEA Bunna | Faculty of Veterinary Medicine, RUA, MAFF | - |
| Mr KHOEUN Sokun | Faculty of Veterinary Medicine, RUA, MAFF | - |
| Mr HONG Sabath | Ministry of Environment | - |
| Mr IN Chantha | General Department of Agriculture, MAFF | - |
| Ms CHHUN Navy | Department of Animal Health and Production, MAFF | - |
| Mr THONG Samnang | Department of Animal Health and Production, MAFF | - |
| Mr CHHUOY Samol | Fisheries Administration, MAFF | - |
| Ms LY Sokta | Fisheries Administration, MAFF | - |
| Mr SO Than | Forestry Administration, MAFF | - |
| Mr KHENG Seng | Cambodia Development Resource Institute (CDRI) | - |
| Mr SREY Vireak | Cambodia Development Resource Institute (CDRI) | - |

# អារម្ភកថា

ការចងក្រងវចនានុក្រមបច្ចេកស័ព្ទកសិកម្ម (អង់គ្លេស-ខ្មែរ និងខ្មែរ-អង់គ្លេស) ត្រូវបានធ្វើឡើងក្នុងគោលបំណងដើម្បីផ្តល់ជាឯកសារយោងសម្រាប់អ្នកសិក្សាស្រាវជ្រាវ អ្នកធ្វើគោលនយោបាយ និងនិស្សិតក្នុងការសិក្សាស្វែងយល់ និងបកប្រែពាក្យក៏ដូចជាកន្សោមពាក្យបច្ចេកទេសពីភាសាអង់គ្លេសទៅខ្មែរ ឬពីខ្មែរទៅអង់គ្លេស ក្នុងភាពដ៏ជាក់លាក់មួយ និងមិនមានភាពខុសគ្នារវាងបុគ្គល។ ការរីកសាយភាយនៃសាកលភាវូបនីយកម្មលើការផ្លាស់ប្តូរព័ត៌មានស្តីពីការស្រាវជ្រាវពាក់ព័ន្ធទៅនឹងវិស័យកសិកម្ម និងការអប់រំបានបង្កើតឱ្យមានតម្រូវការជាចាំបាច់នូវឯកសារយោងផ្សេងៗដែលចាំចាច់ត្រូវបកប្រែ និងយល់ជាភាសាខ្មែរ ឬអង់គ្លេស។ ដើម្បីសម្រួល និងចៀសវាងនូវបញ្ហាទាំងអស់ខាងលើ វចនានុក្រមបច្ចេកស័ព្ទកសិកម្មថ្មីមួយត្រូវបានចងក្រងដោយការធ្វើសមាហរណកម្ម និងការដកស្រង់ពាក្យ ក៏ដូចជាកន្សោមពាក្យបច្ចេកទេសភាគច្រើនពីរបាយការណ៍ ឬឯកសារវិទ្យាសាស្ត្រ និងសន្ទានុក្រមដែលត្រូវបានបោះពុម្ពមួយចំនួន ដោយក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ ក្រសួងបរិស្ថាន គ្រឹះស្ថានអប់រំឧត្តមសិក្សា និងវិទ្យាស្ថានស្រាវជ្រាវមួយចំនួនដែលបានធ្វើការងារទាក់ទងទៅនឹងកសិកម្ម។ ការបកប្រែខ្លះក៏មានបន្ថែមនូវសេចក្តីពន្យល់អធិប្បាយ អមជាមួយពាក្យ ឬកន្សោមពាក្យគន្លឹះខ្លះដែលត្រូវបានធ្វើទំនើបកម្មឱ្យស្របតាមការប្រើប្រាស់ជាទូទៅ និងស្របតាមខេមរយានកម្មភាសាខ្មែររបស់រាជបណ្ឌិតសភាកម្ពុជា។ បន្ថែមពីលើការបោះពុម្ពជាសៀវភៅហើយក៏ជាលើកដំបូងផងដែរ ដើម្បីឱ្យទាន់សម័យកាលក្នុងបរិបទនៃការប្រើប្រាស់បច្ចេកវិទ្យា កម្រងពាក្យទាំងអស់នៅក្នុងវចនានុក្រមនេះត្រូវបានរៀបរៀងជាកម្មវិធីកុំព្យូទ័រ (Software) ដែលអាចដំឡើងឱ្យដំណើរការលើប្រព័ន្ធប្រតិបត្តិការរបស់ Windows។ ការរៀបរៀងទាំងមូលត្រូវធ្វើឡើងដោយក្រុមការងាររបស់មជ្ឈមណ្ឌលភាសា នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម ដោយថវិកាហិរញ្ញបទានរបស់មជ្ឈមណ្ឌលអូស្ត្រាលីសម្រាប់ការស្រាវជ្រាវកសិកម្មអន្តរជាតិ ឬ Australian Center for International Agricultural Research (ACIAR)។

គ្រប់ទម្រង់នៃវចនានុក្រមដែលបានបោះពុម្ពនេះ មានការចែកជូនក្នុងគោលបំណងអប់រំ និងស្រាវជ្រាវ ដោយឥតគិតថ្លៃ ឬអាចទាញយកបានតាមរយៈគេហទំព័ររបស់សាកលវិទ្យាល័យភូមិន្ទកសិកម្ម (www.rua.edu.kh) និងគេហទំព័ររបស់ Australian Center for International Agricultural Research (http://aciar.gov.au)។

ផលិតកម្មនៃវចនានុក្រមបច្ចេកស័ព្ទកសិកម្ម ដោយគ្រឹះស្ថានឧត្តមសិក្សាមួយនេះនៃព្រះរាជាណាចក្រកម្ពុជា ក្រោមការឧបត្ថម្ភហិរញ្ញវត្ថុពីស្ថាប័នស្រាវជ្រាវអូស្ត្រាលីមួយនេះ បានឆ្លុះបញ្ចាំងពីចំណងសហប្រតិបត្តិការដ៏រឹងមាំមួយក្នុងកាអភិវឌ្ឍវិស័យកសិកម្ម និងការអប់រំរវាងប្រទេសទាំងពីរ។

សាស្ត្រាចារ្យបណ្ឌិត **ម៉ៅ ម៉ុនថាន** 
សាកលវិទ្យាធិការ នៃសាកលវិទ្យាល័យភូមិន្ទកសិកម្ម

បណ្ឌិត **និក អូស្ទិន** 
អគ្គនាយកប្រតិបត្តិ នៃACIAR

## Foreword

The production of this bi-lingual Agricultural Technical Dictionary will provide Cambodian researchers, policy makers, teachers and students with a reference for the consistent translation of agricultural technical words and phrases between the Khmer and English languages. The increasing use of English as an international language in the agricultural research and education sectors within Cambodia has created the need for appropriate reference materials to assist with the translation of materials from English to Khmer, and vice-versa.

To facilitate an understanding and translation of technical words and phrases in the Khmer and English languages this dictionary has integrated content from existing dictionaries, glossaries and reference materials commonly used in agriculture and related fields. In addition to this printed version of the dictionary a software application has also been created to enable users to install the dictionary on computers.

The production of this dictionary by a Cambodian institution with the support of an Australian research organisation reflects the strong collaborative links for agricultural development and education between Cambodia and Australia.

This dictionary has been developed by the Language Centre, Royal University of Agriculture (RUA) of Cambodia, with the support of the Australian Center for International Agricultural Research (ACIAR)

Free access to this dictionary is available on the websites of the Royal University of Agriculture (**http://rua.edu.kh)** and the Australian Centre for International Agricultural Research (**http://aciar.gov.au**).

Prof. Dr Ngo Bunthan,
Rector, Royal University of Agriculture
RUA

Dr Nick Austin
Chief Executive Officer
ACIAR

# សេចក្ដីណែនាំក្នុងការប្រើប្រាស់

វចនានុក្រមនេះ ត្រូវបានបែងចែកជាពីរផ្នែកធំៗ។ ផ្នែកទី១ ជាវចនានុក្រមបច្ចេកសព្ទកសិកម្ម (អង់គ្លេស-ខ្មែរ) ដែលមានប្រមាណជាង ១៤.០០០ ពាក្យមេ និងកន្សោមពាក្យភ្ជាប់ជាមួយ។ ផ្នែកទី២ ជាវចនានុក្រមខ្មែរ អង់គ្លេស ដែលមានប្រមាណជាង ៧.០០០ ពាក្យ និងកន្សោមពាក្យ។ បន្ថែមពីលើនេះ ផ្នែកខាងចុងនៃសៀវភៅនេះ ជាឯកសារយោង ដែលត្រូវបានយកមកប្រើប្រាស់ក្នុងការចងក្រងមួយនេះ។ នៅក្នុងផ្នែកទី១ ពាក្យមេ ជាភាសាអង់គ្លេសនៅដើមបន្ទាត់ បន្ទាប់មកមាននិមិត្តសញ្ញានៃសូរស័ព្ទ ថ្នាក់ពាក្យ ពាក្យប្រែសម្រួលជាខេមរភាសា និងការពន្យល់នៅក្នុងវង់ក្រចក (ចំពោះពាក្យមួយចំនួន) ដែលមានការបង្ហាញដូចក្នុងឧទាហរណ៍ខាងក្រោម។ ក្នុងពេលខ្លះពាក្យមេ អាចត្រូវស្វែងរកជាពាក្យនៅខាងចុងនៃកន្សោមពាក្យ។ ក្នុងផ្នែកនេះផងដែរ ចំពោះពាក្យមេដែលមានកន្សោមពាក្យជាកម្លាយនៃពាក្យ នោះកន្សោមពាក្យ ត្រូវបានសរសេរនៅពីខាងក្រោមពាក្យមេ ព្រមទាំងមានការចូលបន្ទាត់បន្តិចពិសេសចាប់ផ្ដើមដោយសញ្ញា «•» ដែលត្រូវបានបង្ហាញដូចឧទាហរណ៍ខាងក្រោម។

<u>**ករណីពាក្យមេនៅខាងចុង៖**</u>

ពាក្យមេ → **abatement** /əˈbeɪtm(ə)nt/ [n] ការកាត់បន្ថយ, ការបញ្ចុះ

- pollution abatement /pəˈluːʃ(ə)n əˈbeɪtm(ə)nt/ [n] ការកាត់បន្ថយការបំពុល

កន្សោមពាក្យដែលមានពាក្យមេ → 

- water pollution abatement /ˈwɔːtə pəˈluːʃ(ə)n əˈbeɪtm(ə)nt/ [n] ការកាត់បន្ថយការបំពុលទឹក

<u>**ករណីពាក្យមេនៅខាងដើម៖**</u>

ពាក្យមេ → **accession** /əkˈsɛʃ(ə)n/ [n] បញ្ជិក (រាល់អាជីវករ ឬពូជដែលត្រូវបានចុះបញ្ជី)

កន្សោមពាក្យដែលមានពាក្យមេ → 

- accession number /əkˈsɛʃ(ə)n ˈnʌmbə/ [n] លេខបញ្ជិក (លេខបញ្ជីនៃជីវករ ឬពូជ)

រីឯករណីខ្លះទៀត កន្សោមពាក្យត្រូវបានតម្រៀបតាមលំដាប់អក្ខរក្រមនៃពាក្យខាងដើម ដែលអាចជានាម ឬគុណនាម ព្រោះគ្មានពាក្យមេចាំបាច់ដែលត្រូវពន្យល់ ហើយកន្សោមពាក្យទាំងមូលគឺមានអត្ថន័យពិសេសមួយដែលពេលខ្លះការយល់ពាក្យនីមួយៗនៅក្នុងកន្សោមពាក្យ គឺមិនអាចធ្វើឱ្យអ្នកប្រើប្រាស់យល់ខ្លឹមសារទាំងស្រុងបានទេ។

លើសពីនេះ ចំពោះពាក្យដែលមានន័យលើសពីមួយ និមិត្តសញ្ញាជាលេខ ១ ២ ឬ ៣ ត្រូវបានប្រើសម្រាប់ការប្រែសម្រួលជាខេមរភាសាក្នុងបរិបទផ្សេងៗគ្នា ដែលមានការបង្ហាញដូចក្នុងឧទាហរណ៍ខាងក្រោម។

**abdomen** /ˈabdəmən/ [n]

១. ពោះ (ផ្នែកទីបី ឬផ្នែកគូទនៃសរីរាង្គសត្វល្អិត ដែលជាទូទៅផ្គុំឡើងពី ៩ ឬ១០កង់ ហើយផ្នែកនេះគ្មានជុះជើងឡើយ នៅពេលសត្វល្អិតពេញវ័យ ឬគ្រប់លក្ខណៈ)

២. សាច់ពោះ

៣. សត្វល្អិត (នៅក្នុងវដ្ដនៃ arthropod)

នៅក្នុងផ្នែកទី ២ មិនមានពាក្យមេជាភាសាខ្មែរសរសេរនៅដើមបន្ទាត់ទេ តែបន្ទាប់មកមានថ្នាក់ពាក្យ និងពាក្យប្រែសម្រួលជាភាសាអង់គ្លេស។

## លំដាប់ពាក្យ

លំដាប់ពាក្យមេអង់គ្លេស និងកន្សោមពាក្យក្នុងសៀវភៅនេះ ត្រូវបានអនុវត្តតាមក្បួនព្យញ្ជនៈភាសាអង់គ្លេស ដែលមានបង្ហាញដូចខាងក្រោម៖

Aa Bb Cc Dd Ee Ff Gg Hh Ii Jj Kk Ll Mm Nn Oo Pp Qq Rr Ss Tt Uu Vv Ww Xx Yy Zz

លំដាប់ពាក្យមេខ្មែរក្នុងសៀវភៅនេះ ត្រូវបានអនុវត្តតាមក្បួនវចនានុក្រមខ្មែររបស់សម្ដេចព្រះសង្ឃរាជ **ជួន ណាត** ដែលត្រូវបានបង្ហាញតាមលំដាប់ព្យញ្ជនៈ ស្រៈនិស្ស័យ និងស្រៈពេញតួដូចខាងក្រោម៖

ក្ក ខ្ខ គ្គ ឃ្ឃ ង្ង   ច្ច ឆ្ឆ ជ្ជ ឈ្ឈ ញ្ញ   ដ្ដ ឋ្ឋ ឌ្ឌ ឍ្ឍ ណ្ណ   ត្ត ថ្ថ ទ្ទ ធ្ធ ន្ន

ប្ប ផ្ផ ព្ព ភ្ភ ម្ម   យ្យ រ្រ ល្ល វ្វ ស្ស ហ្ហ ឡ្ឡ អ្អ

ា ិ ី ឹ ឺ ុ ូ ួ ើ ឿ ៀ េ ែ ៃ ោ ៅ ុំ ំ ាំ ះ ុះ េះ ោះ

ឥ ឦ ឧ ឪ ឫ ឬ ឭ ឮ ឯ ឰ ឱ

## គន្លឹះនៃការអានពាក្យជាភាសាអង់គ្លេស

ការប្រើនិមិត្តសញ្ញាត្រូវបានធ្វើឡើង តាមគេហទំព័រនៃវចនានុក្រមភាសាអង់គ្លេស Oxford ដែលមានអាសយដ្ឋានគេហទំព័រ (http://www.oxforddictionaries.com/words/key-to-pronunciation)។ ពាក្យភាគច្រើន មាននិមិត្តសញ្ញាសម្រាប់អាន ប៉ុន្តែមិនមានសម្រាប់ពាក្យឡាតាំងខ្លះ និងគ្រប់ឈ្មោះវិទ្យាសាស្ត្រទាំងអស់។ នៅក្នុងភាសាអង់គ្លេសព្យញ្ជនៈ b, d, f, h, k, l, m, n, p, r, s, t, v, w និង z គឺមានសម្លេងក្នុងការអានធម្មតា ប៉ុន្តែនិមិត្តសញ្ញាមួយចំនួនបង្ហាញឱ្យការបញ្ចេញសម្លេងផ្សេងៗគ្នាដូចខាងក្រោម។

**<u>សម្លេងព្យញ្ជនៈ</u>**

| និមិត្តសញ្ញា | ឧទាហរណ៍ |
|---|---|
| g | get |
| tʃ | chip |
| ʤ | jar |
| x | loch |
| ŋ | ring |
| θ | thin |
| ð | this |
| ʃ | she |
| ʒ | decision |
| j | yes |

**<u>សម្លេងស្រៈ</u>**

ស្រៈខ្លី

| | |
|---|---|
| a | cat |
| ɛ | bed |
| ə | ago |
| ɪ | sit |
| i | copy |
| ɒ | hot |
| ʌ | run |
| ʊ | rut |

ស្រៈវែង

ɑː arm
ɛː hair
əː her
iː see
ɔː saw
uː too

ទ្វេស្រៈ

ʌɪ my
aʊ how
eɪ day
əʊ no
ɪə near
ɔɪ boy
ʊə poor

ត្រីស្រៈ

ʌɪə fire
aʊə sour

ចំពោះពាក្យដែលច្រើនព្យាង្គ និមិត្តសញ្ញា «ˈ» ត្រូវបានប្រើសម្រាប់បង្ហាញថាសង្កត់សម្លេង នៅព្យាង្គបន្ទាប់ ឧទាហរណ៍ដូចជាក្នុង /kəˈbal/។ ចំណែកឯនិមិត្តសញ្ញា «ˌ» គឺបញ្ជាក់ពី ការសង្កត់សម្លេងនៅលើព្យាង្គទី២ ឧទាហរណ៍ដូចជាក្នុង /ˌkaləˈbriːs/។ រីឯ (ə) ដែលតែងតែជួបប្រទះជាញឹកញាប់នៅខាងមុខព្យញ្ជនៈ /l/ /m/ ឬ /n/ បញ្ជាក់ថាសម្លេងស្រៈគឺមិនសូវសំខាន់ដូចការសង្កត់ទៅលើសម្លេងប្រកបរវាងស្រៈ និងព្យញ្ជនៈ ជាជាងការសង្កត់តែទៅលើសម្លេង **l**, **m** ឬ **n** ឧទាហរណ៍ដូចជាក្នុង /ˈbʌt(ə)n/ ដែលមិនមែន /ˈbʌtən/ ទេ។ ចុងក្រោយគឺព្យញ្ជនៈ (r) បង្ហាញពី *r* ដែលមានសម្លេងតែពេលខ្លះ ជាពិសេសពេលនៅពីក្រោយស្រៈ ឧទាហរណ៍ដូចជាក្នុងពាក្យ drawer។

## អក្សរកាត់ និងនិមិត្តសញ្ញា

### ភាសាខ្មែរ

| | |
|---|---|
| កិ | កិរិយាស័ព្ទ |
| គុ | គុណនាម |
| គុ.កិ | គុណកិរិយា |
| ស.ន | សន្ធានស័ព្ទ |
| ន | នាម |
| ឈ.វិ | ឈ្មោះវិទ្យាសាស្ត្រ |

### ភាសាអង់គ្លេស

| | |
|---|---|
| abbr | abbreviation |
| adj | adjective |
| adv | adverb |
| conj | conjunction |
| n | noun (singular) |
| n.pl | noun (plural) |
| prefix | prefix |
| prep | preposition |

| | |
|---|---|
| sci.n | scientific name |
| suffix | suffix |

# ផ្នែកទី ១ អង់គ្លេស ~ ខ្មែរ

# SECTION I ENGLISH - KHMER

**A**

**a-** /ə/ [prefix] (ដូចៈ an-) បុព្វបទមានន័យថា គ្មាន

**AC (medicine)** /ə siː/ [abbr] សូមមើលពាក្យៈ ante cibum

**abalone** /ˌabəˈləʊni/ [n] អាបាឡូន (ខ្យងសមុទ្រម្យ៉ាង)

**abandon** /əˈband(ə)n/ [v] បោះបង់ចោល, ឈប់ធ្វើអ្វីមួយ

**abatement** /əˈbeɪtm(ə)nt/ [n] ការកាត់បន្ថយ, ការបញ្ចុះ

- pollution abatement /pəˈluːʃ(ə)n əˈbeɪtm(ə)nt/ [n] ការកាត់បន្ថយការបំពុល
- water pollution abatement /ˈwɔːtə pəˈluːʃ(ə)n əˈbeɪtm(ə)nt/ [n] ការកាត់បន្ថយការបំពុលទឹក

**abattoir** /ˈabətwɑː/ [n] សូមមើលពាក្យៈ slaughterhouse

**abaxial** /abˈaksɪəl/ [adj] ចាកអ័ក្ស, ដែលចាកចេញឆ្ងាយពីអ័ក្ស

**abscess** /ˈabsɪs/ [n] បូស, ដំបៅ

**abdomen** /ˈabdəmən/ [n]

១. ពោះ (ផ្នែកទីបី ឬផ្នែកគូទនៃសរីរាង្គសត្វល្អិត ដែលជាទូទៅផ្គុំឡើងពី ៩ ឬ១០កង់ ហើយផ្នែកនេះគ្មានជុះជើងឡើយ នៅពេលសត្វល្អិតពេញវ័យ ឬគ្រប់លក្ខណៈ)

២. សាច់ពោះ

៣. សត្វល្អិត (នៅក្នុងវគ្គនៃ arthropod)

**abdominal** /abˈdɒmɪn(ə)l/ [adj] នៃពោះ

**abdominous** /əbˈdɒmɪnəs/ [adj] ដែលរីកធំ

**abductor** /əbˈdʌktə/ [n] សាច់ដុំដែលធ្វើចលនា (កាលណាគេលើកដៃចេញពីចំហៀងខ្លួន)

***Abelmoschus moschatus*** [sci.n] សូមមើលពាក្យៈ abelmosk

**abelmosk** /ˈeɪb(ə)lbɒsk/ [n] ម្ជូរព្រឹកព្រៃ (ឈ្មោះវិទ្យាសាស្ត្រ *Abelmoschus moschatus*)

**ability** /əˈbɪlɪti/ [n] សមត្ថភាព

- combining ability /kəmˈbʌɪnɪŋ əˈbɪlɪti/ [n] លទ្ធភាពផ្សំផ្គុំ (សមត្ថភាពរបស់មេបាមួយ ក្នុងការបង្កាត់ជាមួយមេបាផ្សេងៗទៀត ដើម្បីចម្លងពន្ធុក្នុងកម្រិតណាមួយនៃការសម្តែងលក្ខណៈ)
- cross ability /krɒs əˈbɪlɪti/ [n] លទ្ធភាពកាត់, លទ្ធភាពបង្កាត់ (លទ្ធភាពអាចសម្រេចជោគជ័យក្នុងការបង្កាត់បានកូនចៅ តាមវិធីបង្កាត់លម្អង ជាពិសេសចំពោះពួកពូជអន្តរប្រភេទ)
- general combining ability (GCA) /ˈdʒɛn(ə)r(ə)l kəmˈbʌɪnɪŋ əˈbɪlɪti/ [n] លទ្ធភាពផ្សំទូទៅ (ការសម្តែងឡើងជាមធ្យមរបស់កូននៃឯកត្តៈមួយ ពេលដែលវាផ្សំផ្គុំជាមួយឯកត្តៈមួយចំនួនផ្សេងទៀតនៅ ក្នុងក្រុមពូជនេះ)
- self-pruning ability /sɛlfpruːnɪŋ əˈbɪlɪti/ [n] លទ្ធភាពក្រីមែកដោយខ្លួនឯង (សមត្ថភាពរបស់ដើមឈើមួយជម្រុះមែកតូចខាងក្រោម។ លក្ខណៈនេះអាចតពូជបាន និងគេជ្រើសរើសយក ចំពោះប្រភេទពូជមួយចំនួន។)
- specific combining ability /spəˈsɪfɪk kəmˈbʌɪnɪŋ əˈbɪlɪti/ [n] លទ្ធភាពបង្កាត់មធ្យមជាក់លាក់, លទ្ធភាពផ្សំផ្គុំមធ្យមជាក់លាក់ (តម្លៃខាងស្ថិតិ បង្ហាញពីសមត្ថភាពរបស់មេបាមួយ ក្នុងការបង្កាត់ជាមួយមេបាផ្សេងៗទៀត ដើម្បីចម្លងពន្ធុក្នុងកម្រិតណាមួយនៃការសម្តែងលក្ខណៈ។ លទ្ធភាពផ្សំគ្នាទូទៅល្អ (Good general combining ability)នៃមេបាមួយបង្ហាញនូវការសម្តែងចេញជាមធ្យមភាគខ្ពស់នៃកូនរបស់វាក្នុងការបង្កាត់ផ្សេងៗ បើប្រៀបធៀបទៅនឹងកូនផ្សេងៗទៀតរបស់មេបាផ្សេងនៅក្នុងការសាកល្បងដូចគ្នា។ តម្លៃនៃការបង្កាត់ (Breeding value) នៃមេបាមួយ គឺ២ដងនៃ GCA របស់វា។ លទ្ធភាពផ្សំគ្នាល្អជាក់លាក់ (Breeding value) អាស្រ័យទៅនឹងមេបា២ ដែលនៅពេលកាត់បញ្ចូលគ្នា ផលិតកូនបានល្អជាងដែលគេរំពឹងទុកផ្អែកលើតម្លៃមេបា GCA។)
- submergence ability /səbˈməːdʒəns əˈbɪlɪti/ [n] លទ្ធភាពលង់ទឹក (ភាពដែលរុក្ខជាតិ ឬជីវករអាចទ្រាំក្នុងការលិចលង់)
- tillering ability /ˈtɪlərɪŋ əˈbɪlɪti/ [n] លទ្ធភាពបែកគុម្ព

**abiotic** /ˌeɪbʌɪˈɒtɪk/ [adj] ដែលគ្មានជីវិត, អាប្យូទិច (អាកាសធាតុ ដីជាដើម ដែលជាកត្តាគ្មានជីវិត)

**ablactation** /ablakˈteɪʃ(ə)n/ [n] ការឈប់ផលិតទឹកដោះ

**ablation** /əˈbleɪʃ(ə)n/ [n]

១. (ចំពោះសត្វ) ដំណក (ការកាត់ ឬចៀរសាច់មួយដុំ)

២. (ចំពោះដី) ការបកចោល, ការកាត់ចោល

**abnormal** /əbˈnɔːm(ə)l/ [adj] មិនធម្មតា, មិនប្រក្រតី

**abnormity** /abˈnɔːmɪti/ [n] ភាពខុសប្រក្រតី, ភាពខុសពីធម្មតា

**abomasum** /ˌabəʊˈmeɪsəm/ [n] (សទិសន័យៈ stomach) ស្រទាប់ពោះវៀនជាន់ទី៤, ពោះរំអិល, ក្រពះ

**aboriculture** /ˈɑːb(ə)rɪˌkʌltʃə/ [n] រុក្ខវប្បកម្ម (ការដាំដើមឈើ និងព្រៃគុម្ពោត)

**aborigine** /abəˈrɪdʒɪniː/ [n] អ្នកស្រុកដើម

**abort** /əˈbɔːt/ [v] រំលូតកូន, ពន្លូតកូន

**abortion** /əˈbɔːʃ(ə)n/ [n]
១. (ចំពោះរុក្ខជាតិ) ការលែងលូតលាស់, ការជ្រុះ
២. (ចំពោះសត្វ) ការរំលូតកូន, ការរលូតកូន
៣. ការមិនបានសម្រេចបំណង

**abrasion** /əˈbreɪʒ(ə)n/ [n] ការធ្វើឱ្យសឹក ឬឱ្យកកិតគ្នា, អាប្រាសិយ៉ុង

**abscess** /ˈabsɪs/ [n] បូស, ខ្ទុះ

**abscission** /əbˈsɪʃ(ə)n/ [n] (ចំពោះរុក្ខជាតិ) ការជម្រុះស្លឹក ផ្កា ផ្លែ, ការជ្រុះ, ជរាភាព (ការជម្រុះតាមធម្មជាតិនូវស្លឹក ផ្កា និងផ្លែ ចេញពីដើមរបស់វា។ ជាទូទៅ វាទាក់ទងនឹងការបំផ្លាញនូវស្រទាប់ ពិសេសនៃជញ្ជាំងកោសិកាដែលមានភ្នាសស្តើងដែលហៅថា តំបន់ផ្តាច់ (abscission zone)។)

**absence** /ˈabs(ə)ns/ [n] អវត្តមាន

**absent** /ˈabs(ə)nt/ [adj] ដែលមិនមានមុខនៅ

**absentee** /ˌabs(ə)nˈtiː/ [n] អ្នកមិនមក, អ្នកអវត្តមានក្នុងកន្លែងណាមួយ

**absorb** /əbˈzɔːb/ [v] ស្រូប, ជ្រាប, បឺត

**absorbent** /əbˈzɔːb(ə)nt/ [n] (សទិសន័យ៖ absorbing power) ឥទ្ធិពលជញ្ជក់, ឥទ្ធិពលចាប់យក

**absorption** /əbˈzɔːpʃ(ə)n/ [n] សម្រូប (យកទឹក ឬឧនិជ), ស្រូបកម្ម (គឺជាដំណើរការនៃការស្រូបយកសារធាតុគីមីដែលក្នុងនោះសារធាតុមួយជ្រៀត ឬឆ្លងកាត់ពីប្រព័ន្ធមួយ (ឬពីសរីរាង្គ) ចូលទៅក្នុងប្រព័ន្ធ ឬសរីរាង្គមួយទៀត ឧ. ពីសារធាតុខនិជនៃដីទៅក្នុងកោសិកានៃឫសរុក្ខជាតិ ឬពីផ្ទៃលើនៃស្លឹកទៅក្នុងកោសិកាស្លឹក)

- heat absorption /hiːt əbˈzɔːpʃ(ə)n/ [n] សម្រូបកម្តៅ
- light absorption /lʌɪt əbˈzɔːpʃ(ə)n/ [n] សម្រូបពន្លឺ
- moisture absorption /ˈmɔɪstʃə əbˈzɔːpʃ(ə)n/ [n] សម្រូបសំណើម
- solar energy absorption /ˈsəʊlə ˈɛnədʒi əbˈzɔːpʃ(ə)n/ [n] សម្រូបថាមពលព្រះអាទិត្យ
- sound absorption /saʊnd əbˈzɔːpʃ(ə)n/ [n] សម្រូបសំឡេង
- thermal absorption /ˈθəːm(ə)l əbˈzɔːpʃ(ə)n/ [n] សម្រូបកម្តៅ
- water absorption /ˈwɔːtə əbˈzɔːpʃ(ə)n/ [n] សម្រូបទឹក

***Abutilon indicum*** [sci.n] សូមមើលពាក្យ៖ Indian mallow

**abyss** /əˈbɪs/ [n] អន្លង់ជ្រោះ, អន្លង់ជ្រៅ

**acacia** /əˈkeɪʃə/ [n] អាកាស្យា (សណ្តាន) (ឈ្មោះវិទ្យាសាស្ត្រ *Acacia* sp.)

***Acacia auriculoformis*** [sci.n] ស្មាច់ទេស

***Acacia insuavis*** [sci.n] ស្អំ

***Acacia* sp.** [sci.n] សូមមើលពាក្យ៖ acacia

**academic achievement** /akəˈdɛmɪk əˈtʃiːvm(ə)nt/ [n] ប្រវត្តិការសិក្សា (ជីវប្រវត្តិនៃការសិក្សាកន្លងមក)

***Acalypha indica*** [sci.n] សូមមើលពាក្យ៖ Indian acalypha

**acanth-** /əˈkanθ/ [prefix] (សទិសន័យ៖ acantho-) បុព្វបទមានន័យថា បន្លា

**acantho-** /əˈkanθəʊ/ [prefix] សូមមើលពាក្យ៖ acanth-

**acanthosis** /akən 'θəʊsɪs/ [n] ជំងឺក្រិនស្បែក

***Acantopsis* sp.** [sci.n] សូមមើលពាក្យ៖ speckletail horseface loach, striped horseface loach, spotted horseface loach

**acariasis** /ˌakə ˈrɪəsɪs/ [n] (សទិសន័យ៖ Acarid) ដេម៉ូដិច (ពពួកប៉ារ៉ាសិតម្យ៉ាងដែលបង្កជំងឺ)

**acaricide** /ˈakərɪsʌɪd/ [n] ថ្នាំសម្លាប់សត្វល្អិត លំដាប់ Acarina (មានជើងប្រាំបី)ដូចជាចៃ ពីងពាង សង្កើចជាដើម

**acarid** /ˈakərəd/ [n] ដេម៉ូដិច (ពពួកប៉ារ៉ាសិតម្យ៉ាងដែលបង្កជំងឺ)

**acarpous** /ˈakɑːpəs/ [adj] មិនមានផ្លែ, ដែលគ្មានផ្លែ

**acceptor** /əkˈsɛptə/ [n] អ្នកចាប់យក, អង្គទទួល

- $CO_2$ acceptor /ˌsiːˈəʊ tuː əkˈsɛptə/ [n] អ្នកចាប់យកឧស្ម័នកាបូនិច
- hydrogen acceptor /ˈhʌɪdrədʒ(ə)n əkˈsɛptə/ [n] ធ្នូលអ៊ីដ្រូសែន (ភាគល្អិតដែលអាចទទួលយកអ៊ីដ្រូសែនពីភាគល្អិតផ្សេងៗទៀត)

**access** /ˈaksɛs/ [n] លទ្ធភាពទទួលបាន (ឧទាហរណ៍ (ចំពោះអាហារ) កម្រិតនៃស្បៀងដែលមាន និងអាចរកបានតាមរយៈទីផ្សារ ផលិតកម្មផ្ទាល់ខ្លួន ឬតាមរយៈមធ្យោបាយផ្សេងៗទៀត។ លទ្ធភាពរបស់គ្រួសារ ឬខ្នងផ្ទះនីមួយៗ ឬបុគ្គលដើម្បីជាធនធានគ្រប់គ្រាន់សម្រាប់ទទួលបានស្បៀងសមស្រប (ក្នុងន័យដែលអាចទទួលយកបានទាំងផ្នែកម៉ាក្រូសារជាតិ ពពួកមីក្រូសារជាតិ និងខាងផ្នែកវប្បធម៌) ដើម្បីឱ្យបានរបបអាហារមួយដែលសំបូរទៅដោយសារធាតុចិញ្ចឹម។)

- access to water /ˈaksɛs tə ˈwɔːtə/ [n] ការប្រើប្រាស់ទឹក
- food access /fuːd ˈaksɛs/ [n] ការទទួលបានស្បៀង

**accession** /əkˈsɛʃ(ə)n/ [n] បញ្ជិក (រាល់អាជីវករ ឬពូជដែលត្រូវបានចុះបញ្ជី)

- accession number /əkˈsɛʃ(ə)n ˈnʌmbə/ [n] លេខបញ្ជិក (លេខបញ្ជីនៃជីវករ ឬពូជ)

**accident** /ˈaksɪd(ə)nt/ [n] គ្រោះថ្នាក់

**acclimation** /akləˈmeɪʃ(ə)n/ [n] បន្សាំនឹងលក្ខខណ្ឌថ្មី

**acclimatise** /əˈklʌɪmətʌɪz/ [v] ផ្សាំអាកាសធាតុ, បន្សាំអាកាសធាតុ

**acclimatization** /əˈklʌɪmətʌɪˈzeɪʃ(ə)n/ [n] បន្សាំនឹងអាកាសធាតុថ្មី

**accommodation** /əkɒməˈdeɪʃ(ə)n/ [n] ១. (ចំពោះបរិស្ថាន) បម្រែបម្រួលមិនតពូជ ២. (ចំពោះជីវវិទ្យា) សម្របតម្រូវ

**accomplish** /əˈkʌmplɪʃ/ [v] សម្រេចបាន (ទទួលបានជោគជ័យក្នុងការធ្វើអ្វីមួយ)

**accountability** /əˌkaʊntəˈbɪlɪti/ [n] គណនេយ្យភាព (ភាពដែលទទួលខុសត្រូវនូវអ្វីដែលខ្លួនឯងបានអនុវត្ត ឬភាពនូវអ្វីដែលអាចរស់បាន ឬបន្សល់បាន)

**accrescent** /akrɛz(ə)nt/ [adj] លូតធំ (ទម្រង់របស់រុក្ខជាតិដូចជាកញ្ចុំត្របក)

**accretion** /əˈkriːʃ(ə)n/ [n] ដីដុះ

**accumulation** /əkjuːmjʊˈleɪʃ(ə)n/ [n]
១. (ចំពោះជីវវិទ្យា) បណ្តុំជីវៈ, បង្គរ
២. (ចំពោះដី) ការប្រមូលផ្តុំវត្ថុធាតុអ្វីមួយនៅកន្លែងណាមួយ, គំនរ, ពំនូក

- clay accumulation /kleɪ əkjuːmjʊˈleɪʃ(ə)n/ [n] ការកកនៃដីឥដ្ឋ (នៅក្នុងស្រទាប់ដីណាមួយដោយការហូរច្រោះទៅក្រោម)

**accumulator** /əˈkjuːmjʊleɪtə/ [n] រុក្ខជាតិបង្កើនសារធាតុចិញ្ចឹម

**accuracy** /ˈakjʊrəsi/ [n] ភាពច្បាស់លាស់

**accustom** /əˈkʌstəm/ [v] ទម្លាប់ខ្លួនឱ្យស៊ាំនឹងអ្វីមួយ, ធ្វើឱ្យធ្លាប់

**acellular** /eɪˈsɛljʊlə/ [adj] អកោសិកា

**Acetabularia** /ˌasɪˈtabjuːləriə/ [n pl] អាសេតាប៊ុយឡារីយ៉ា (ពួកមួយនៃសារាយសមុទ្រ)

**acetabulum** /ˌasɪˈtabjʊləm/ [n] ប្រហោងសន្លាក់ឆ្អឹងត្រគាក

**acetone** /ˈasɪtəʊn/ [n] អាសេតូន

**acetyl** /ˈasɪtʌɪl/ [n] អាសេទីល

- acetyl CoA /ˈasɪtʌɪl kəʊ ə/ [n] អាសេទីលកូអង់ស៊ីម CoA

***Achaea janata*** [sci.n] ដង្កូវល្ហុងប្រេង

**ache** /eɪk/ [n] ការចុកចាប់, ឈឺ, ឈឺអូចៗ

**achene** /əˈkiːn/ [n] ប្រភេទផ្លែទោលស្ងួត (ផ្លែតូច ស្ងួតដែលមានគ្រាប់តែមួយគត់ ហើយមិនប្រេះ ឬបែកចេញគ្រាប់)

***Acherontia styx*** [sci.n] សូមមើលពាក្យ៖ eastern death's-head hawk moth

***Achiroides leucorhynchos*** [sci.n] ត្រីអណ្តាតឆ្កែ

***Achiroides melanorhynchus*** [sci.n] ត្រីអណ្តាតឆ្កែ

**achlamydeous** /ˌakləˈmɪdɪəs/ [adj] (អំពីផ្កា) គ្មានទាំងត្របក ហើយគ្មានទាំងស្រទាប់

**achondroplasia** /əˌkɒndrə(ʊ)ˈpleɪzɪə/ [n] ភាពតឿ

**achromatic** /ˌakrə(ʊ)ˈmatɪk/ [adj] គ្មានពណ៌, ពិបាកបន្សីពណ៌

***Achyranthes aspera*** [sci.n] សូមមើលពាក្យ៖ devil's horsewhip, prickly chaff flower

**acicular** /əˈsɪkjʊlə/ [adj] ទម្រង់បន្ទះស្លឹករាងម្ជុល

**acid** /ˈasɪd/ [adj] ដែលមានជាតិអាស៊ីត, ដែលជូរ

**acid** /ˈasɪd/ [n] អាស៊ីត (សារធាតុដែលបែកធាតុជាអ៊ីយ៉ុងអ៊ីដ្រូសែននៅពេលរលាយក្នុងទឹក), សារធាតុជូរ

- amino acid /əˈmiːnəʊ ˈasɪd/ [n] អាមីណូអាស៊ីត, អាស៊ីតអាមីនេ
- anhydride acid /anˈhʌɪdrʌɪd ˈasɪd/ [n] អានីឌ្រីតអាស៊ីត
- ascorbic acid /əˈskɔːbɪk ˈasɪd/ [n] (សទិសន័យ៖ vitamin C) អាស៊ីតអាស្កប៊ិច, វីតាមីនសេ
- carbolic acid /kɑːˈbɒlɪk ˈasɪd/ [n] សូមមើលពាក្យ៖ phenol
- cholic acid /ˈkəʊlɪk ˈasɪd/ [n] អាស៊ីតទឹកប្រមាត់, អាស៊ីតកូលិច
- conjugate acid /ˈkɒndʒʊgeɪt ˈasɪd/ [n] អាស៊ីតឆ្លាស់
- deoxyribonucleic acid **(**DNA**)** /dɪˌɒksɪrʌɪbəʊnjuːˈkleɪɪk ˈasɪd/ [n] អាស៊ីតដេអុកស៊ីរីបូនុយក្លេអ៊ិច (DNA)
- essential amino acids /ɪˈsɛnʃ(ə)l əˈmiːnəʊ ˈasɪdz/ [n pl] អាស៊ីតអាមីនេដែលមិនត្រូវបានបង្កើតដោយខ្លួនមនុស្សផ្ទាល់ ប៉ុន្តែពួកវាមានប្រភពក្នុងចំណីអាហារ
- ethanoic acid /ˌɛθəˈnəʊɪk ˈasɪd / [n] (សទិសន័យ៖ acetic acid) អាស៊ីតអេតាណូអ៊ិច
- mineral acid /ˈmɪn(ə)r(ə)l ˈasɪd/ [n] អាស៊ីតរ៉ែ, អាស៊ីតខនិជ
- nucleic acid /njuːˈkliːɪk ˈasɪd/ [n] អាស៊ីតនុយក្លេអ៊ិច
- organic acid /ɔːˈganɪk ˈasɪd/ [n] អាស៊ីតសរីរាង្គ
- prussic acid /ˈprʌsɪk ˈasɪd/ [n] អាស៊ីតស៊ីយ៉ានីឌ្រិច
- uric acid /ˈjʊərɪk ˈasɪd/ [n] អាស៊ីតអ៊ុយរិច

**acidification** /əsɪdɪfɪˈkeɪʃ(ə)n/ [n] អាស៊ីតកម្ម, ការនាំចេញទៅនៃខនិជ(បាស) ធ្វើឱ្យដីកាន់តែអាស៊ីត

- aquatic acidification /əˈkwatɪk əsɪdɪfɪˈkeɪʃ(ə)n/ [n] អាស៊ីតកម្មទឹក
- artificial acidification /ɑːtɪˈfɪʃ(ə)l əsɪdɪfɪˈkeɪʃ(ə)n/ [n] អាស៊ីតកម្មដោយមនុស្ស
- natural acidification /ˈnatʃ(ə)r(ə)l əsɪdɪfɪˈkeɪʃ(ə)n/ [n] អាស៊ីតកម្មធម្មជាតិ
- soil acidification /sɔɪl əsɪdɪfɪˈkeɪʃ(ə)n/ [n] អាស៊ីតកម្មដី

**acidity** /əˈsɪdɪti/ [n] ភាពជូរ, ភាពអាស៊ីត (លក្ខណៈអាស៊ីតនៃអង្គធាតុ)

- acidity of soil /əˈsɪdɪti ɒv sɔɪl/ [n] ភាពអាស៊ីតរបស់ដី
- atmospheric acidity /atməsˈfɛrɪk əˈsɪdɪti/ [n] ភាពអាស៊ីតរបស់បរិយាកាស

**acidophil** /əˈsɪdə(ʊ)fɪl/ [adj] ចូលចិត្តអាស៊ីត (អាចសរសេរ acidophilc ក៏បាន)

**acidosis** /ˌasɪˈdəʊsɪs/ [n] ជំងឺឡើងអាស៊ីត

**acne** /ˈakni/ [n] មុន (រោគសើស្បែកមុខ)

**acoustics** /əˈkuːstɪks/ [n] អាកូស្ទិច

**acriflavine** /ˌakrɪˈfleɪvɪn/ [n] អាគ្រីផ្លាវីន

**acrosyl** /ˈakrəsil/ [n] សូមមើលពាក្យ៖ lysol

**Actinium** /akˈtɪnɪəm/ [n] អាក់ទីញ៉ូម (និមិត្តសញ្ញាគីមី Ac)

**actinobacillus** /ˈaktinəʊbəˈsɪləs/ [n] អាក់ទីណូបាស៊ី

**actinomyces** /ˈaktinəʊ mʌɪsəs/ [n] សូមមើលពាក្យ៖ actinomycosis

**actinomycosis** /ˈaktinəʊ mʌɪˈkəʊsɪs/ [n] (សទិសន័យ ៖ actinomyces) ជំងឺពីអាក់ទី (ពពួកមេរោគក្នុងក្រុមផ្សិតដែលធ្វើឱ្យមានមេរោគផ្សេងៗចំពោះមនុស្ស និងសត្វ)

**action** /ˈakʃ(ə)n/ [n] សកម្មភាព

**activate** /ˈaktɪveɪt/ [v] ធ្វើឱ្យសកម្ម, ដាស

**activation** /aktɪˈveɪʃ(ə)n/ [n] ទង្វើឱ្យសកម្ម

- acid activation /ˈasɪd aktɪˈveɪʃ(ə)n/ [n] ទង្វើឱ្យសកម្មដោយអាស៊ីត
- charcoal activation /ˈtʃɑːkəʊl aktɪˈveɪʃ(ə)n/ [n] ទង្វើឱ្យសកម្មដោយធ្យូងឈើ
- light activation /lʌɪt aktɪˈveɪʃ(ə)n/ [n] ទង្វើឱ្យសកម្មដោយពន្លឺ
- thermal activation /ˈθəːm(ə)l aktɪˈveɪʃ(ə)n/ [n] ទង្វើឱ្យសកម្មដោយកម្ដៅ

**active** /ˈaktɪv/ [adj] សកម្មរស់រវើក, នៅរស់សកម្ម

- active compound /ˈaktɪv ˈkɒmpaʊnd/ [n] សមាសធាតុសកម្ម

- active ingredient (a.i) /ˈaktɪv ɪnˈgriːdɪənt/ [n] ធាតុសកម្ម (សមាសធាតុគីមីនៃថ្នាំដែលមានអំពើ ឬប្រតិកម្មទៅសត្វល្អិត ឬរុក្ខជាតិ។ ភាគរយធាតុសកម្ម (% a.i) ត្រូវបានប្រើប្រាស់ដើម្បីប្រៀបធៀបភាពពុលខ្លាំង ឬពុលខ្សោយនៃថ្នាំពុល។)

**acuity** /əˈkjuːɪti/ [n] ភាពច្បាស់, គំហើញច្បាស់

**acuminate** /əˈkjuːmɪnət/ [adj] ទម្រង់ចុងស្លឹករាងស្រួច, រាងរាវស្រួច

**acupuncture** /ˈakjʊˌpʌŋ(k)tʃə/ [n] ព្យាបាលដោយម្ជុល, ម្ជុលវិទ្យាសាស្ត្រ

**acute** /əˈkjuːt/ [adj]
១. (ចំពោះជំងឺ) ខ្លាំងក្លាម, ខ្លាំង, ធ្ងន់ធ្ងរ
២. (ចំពោះរុក្ខជាតិ) ទម្រង់ចុងស្លឹកមុំស្រួច, ស្រួចខ្លាំង

- acute disease /əˈkjuːt dɪˈziːz/ [n] ជំងឺសាហាវ
- acute pest /əˈkjuːt pɛst/ [n] សមាសភាពចង្រៃសាហាវ, ទុរករខ្លាំងក្លា (ប្រភេទទុរករដែលអាចបំផ្លាញ និងរាលដាលបានយ៉ាងឆាប់រហ័ស)
- acute rodenticide /əˈkjuːt rəˈdɛntɪsʌɪd/ [n] ថ្នាំកណ្ដុរខ្លាំង (ជាថ្នាំបំពុលចំពោះកណ្ដុរដែលមានប្រតិកម្មយ៉ាងលឿនក្នុងការធ្វើឱ្យវាស្លាប់យ៉ាងទាន់ហាន់បន្ទាប់ពីបានលេបចូល ឧទាហរណ៍ ហ្សីងហ្វូសហ្វីដ, តាល្យូមស៊ុលហ្វាត, ណរបូមីដ និងសូដ្យូមម៉ូណូភ្លុយអររ៉ូអាសេតាត (Sodium mono Fluoroacetate))

**ad hoc** /ad ˈhɒk/ [adj] ដែលពិសេសសម្រាប់ករណីមួយ

**ad lib** /ad ˈlɪb/ [v] តាមចំណង់

**adapt** /əˈdapt/ [v] តម្រូវ, ផ្សាំ

**adaptability** /ədaptəˈbɪləti/ [n] លទ្ធភាពបន្សាំ (ជាលទ្ធភាពដែលឯកត្តៈអាចកែប្រែរូបរាង ឬមុខនាទី ដើម្បីរស់នៅបានល្អប្រសើរនៅកន្លែងកំណត់ណាមួយ)

**adaptation** /adəpˈteɪʃ(ə)n/ [n] ការបន្សាំ (១. ជាដំណើរការដែលរុក្ខឯកត្តៈត្រូវកែប្រែរូបរាង ឬមុខនាទីដើម្បីរស់នៅបានល្អប្រសើរ នៅកន្លែងកំណត់ណាមួយ។ ២. ជាដំណាក់កាលដំបូង ឬជាការសាកល្បងក្នុងការផ្ដល់បច្ចេកទេសថ្មីទៅឱ្យកសិករដែលត្រូវបន្សាំនឹងលក្ខខណ្ឌបរិយាកាសក្នុងតំបន់ និងជំរុញឱ្យមានការទទួលយកពីកសិករ។)

- dark adaptation /dɑːk adəpˈteɪʃ(ə)n/ [n] បន្សាំងងឹត (ការបង្កើតភាពរួសទៅនឹងរបស់ភ្នែក ដែលបណ្ដាលមកពីការស្ថិតនៅទីងងឹត។ វាជាពេលដែលកោសិកាដំបងត្រូវការដើម្បីបង្កើតឡើងវិញនូវរ៉ូដុបស៊ីន)

**adapted** /əˈdaptɪd/ [adj] ស៊ាំបាន

**adaptive** /əˈdaptɪv/ [adj] ដែលអាចសម្របសម្រួលបាន

**adaxial** /adˈaksɪəl/ [adj] ចូលអ័ក្ស, ដែលឆ្ពោះទៅរកអ័ក្ស

**addict** /ˈadɪkt/ [v] ញៀន

**addiction** /əˈdɪkʃ(ə)n/ [n] ការញៀន

**adductor** /əˈdʌktə/ [n] អាត់ឌុចទ័រ (សាច់ដុំដែលធ្វើចលនាទាញដៃមកអបនឹងខ្លួន)

**aden-** /ˈeɪd(ə)n/ [prefix] (សទិសន័យ៖ adeno-) បុព្វបទមានន័យថា ក្រពេញ

**adenine** /ˈadɪniːn/ [n] អាដេនីន

**adenitis** /ˌadəˈnitəs/ [n] រលាកកូនកណ្ដុរទឹករងៃ

***Adenium obesum*** [sci.n] ផ្កាចំប៉ីសៀម

**adeno-** /ˈadɪnəʊ/ [prefix] សូមមើលពាក្យ៖ aden-

**adenoid** /ˈadɪnɔɪd/ [n] ដុំសាច់ដុះនៅក្នុងប្រហោងច្រមុះ ឬក្នុងបំពង់ក

**adenoma** /ˌadɪˈnəʊmə/ [n] ពកក្រពេញ, សាច់ពកម៉្យាងដែលដុះពីក្រពេញឬដូចជាក្រពេញ

**adenosine diphosphate** /əˈdɛnə(ʊ)siːn dɪfɒsfeɪt/ [n] អាដេណូស៊ីនឌីផូស្វាត (ADP)

**adenosine monophosphate** /əˈdɛnə(ʊ)siːn ˈmɒnəʊˈfɒsfeɪt/ [n] អាដេណូស៊ីនម៉ូណូផូស្វាត (AMP)

**adenosine triphosphatase** /əˈdɛnə(ʊ)siːn trʌɪˈfɒsfəteɪz/ [n] អាដេណូស៊ីនទ្រីផូស្វាតាស (ATPase)

**adenosine triphosphate** /əˈdɛnə(ʊ)siːn trʌɪˈfɒsfeɪt/ [n] អាដេណូស៊ីនទ្រីផូស្វាត (ATP)

**adhere** /ədˈhɪə/ [adj] សូមមើលពាក្យ៖ adhesive

**adhesion** /ədˈhiːʒ(ə)n/ [n] ការជាប់ស្អិត, ការជាប់ផ្នែកមួយនៃខ្លួន ទៅនឹងផ្នែកមួយទៀត ខុសពីធម្មតា

**adhesive** /ədˈhiːzɪv/ [adj] (សទិសន័យ៖ adhere, sticky) ដែលជាប់ស្អិត

**adipose** /ˈadɪpəʊz/ [n] ជំងឺចុកខ្លាញ់

**adjuvant** /ˈadʒʊv(ə)nt/ [n] ប្រសិទ្ធករ, សារធាតុជំនួយ

**admit** /ədˈmɪt/ [v] ទទួលស្គាល់, ទទួលសារភាព, ទទួលអនុញ្ញាតឱ្យចូលមន្ទីរពេទ្យ, ការកត់សេចក្ដីផ្សេងៗដែលទើបមកដេកពេទ្យ

**adobe** /əˈdəʊbi/ [n] ប្រភេទដីឥដ្ឋម្យ៉ាង

**adolescence** /adəˈlɛs(ə)ns/ [n] តរុណវ័យ, វ័យកំទ្បោះក្រមុំ

**adoption** /əˈdɒpʃ(ə)n/ [n] ការទទួលយក (ការទទួលយកនូវបច្ចេកវិទ្យាថ្មីៗ ដោយកសិករ។ ក្រោយពីការ សាកល្បង និងយល់ថាបច្ចេកវិជ្ជាមានលក្ខណៈសមស្រប និងអាចផ្តល់ផលចំណេញកសិករសម្រេចផ្លាស់ប្តូរបច្ចេកទេសដែលមានស្រាប់ ហើយទទួលយកបច្ចេកវិទ្យាថ្មីវិញ។)

**adrenal** /əˈdriːn(ə)l/ [n] កន្សោមតម្រង (នោម), តម្រងមូត្រ, ក្បាលវក្កំគ្រន្ថី

**adrenalectomy** /əˌdriːnəˈlektəmi/ [n] ការវះកាត់យកគ្រន្ថីចេញ

**adrenaline** /əˈdrɛn(ə)lɪn/ [n] អាដ្រេណាលីន (អ័រម៉ូន), ទឹកដែលបញ្ចេញពីគ្រន្ថី

**adrift** /əˈdrɪft/ [adj] បណ្តោយតាមយថាកម្ម, រសាត់ ឬអណ្តែតតាមចិត្ត

**adroit** /əˈdrɔɪt/ [adj] ដែលប៉ិនប្រសប់, ដែលស្ទាត់

**adsorb** /ədˈsɔːb/ [n] សម្រូបសើៗ

**adsorption** /ədˈzɔːpʃ(ə)n/ [n]

១. សម្រូប, ការស្រូបយក

២. ឆក់ទាញកម្ម (ការស្រូបយកម៉ូលេគុល ឬអ៊ីយ៉ុងមកលើផ្ទៃកខាងក្រៅៗ ឬផ្ទៃខាងលើៗ រាប់បញ្ចូលទាំងបំលាស់ប្តូរកាចុង និងអាញ៉ុងរបស់ដី)

**adult** /ˈadʌlt/ [n] សត្វពេញវ័យ (ដំណាក់កាលសត្វពេញវ័យដែលកើតឡើងបន្ទាប់ពីកូន ឬដុកឌឿ ហើយមានសរីរាង្គបន្តពូជ)

**adult** /ˈadʌlt/ [adj] ដែលពេញវ័យ

**adulterate** /əˈdʌltəreɪt/ [v] បន្លំ, បំភាន់

**advanced pay** /adˈvɑːnstd peɪ/ [n] ការបណ្តាក់ (ជាការរកស៊ីរបស់ឈ្មួញ និងកសិករ ជាទូទៅ ឈ្មួញទៅទាក់ទងជាមួយកសិករអំពីផលិតផលកសិកម្មដែលខ្លួនចង់ទិញ មានស្រូវ ពោត ស្ពៃក្តោបជាដើម រួចក៏បង់លុយកាក់មួយភាគធំទៅឱ្យកសិករមុនពេលទិញ និងមុនរដូវប្រមូលផល)

**advantage** /ədˈvɑːntɪdʒ/ [n] ឧត្តមភាព, ការធ្វើឱ្យមានអត្ថប្រយោជន៍

**adventitious** /ˌadv(ə)nˈtɪʃəs/ [adj]

១. (ចំពោះគ្រាប់រុក្ខជាតិ) ដែលដុះដោយចៃដន្យ, ដែលដុះដោយឯកឯង

២. (ចំពោះរុក្ខជាតិ) នៃពន្លកត្រួយ, នៃឫស, ឫសព្រយោង

**adze** /adz/ [n] ចបចាំង, ដែកចាំង

**aerate** /ˈɛːreɪt/ [v] ធ្វើអាកាសកម្ម, ដាក់ឱ្យត្រូវខ្យល់, បញ្ចូលខ្យល់, ធ្វើឱ្យមានខ្យល់

**aeration** /ɛːˈreɪʃ(ə)n/ [n] ការបញ្ចូលខ្យល់, អាកាសកម្ម

- sewage aeration /ˈsuːɪdʒ ɛːˈreɪʃ(ə)n/ [n] អាកាសកម្មទឹកលូសម្អុយ
- soil aeration /sɔɪl ɛːˈreɪʃ(ə)n/ [n] អាកាសកម្មដី
- stage aeration /steɪdʒ ɛːˈreɪʃ(ə)n/ [n] អាកាសកម្មទឹកលូសម្អុយច្រើនដំណាក់
- surface aeration /ˈsəːfɪs ɛːˈreɪʃ(ə)n/ [n] អាកាសកម្មតាមផ្ទៃ

**aerial** /ˈɛːrɪəl/ [adj] នៃអាកាស, ពីលើអាកាស

**aerobe** /ˈɛːrəʊb/ [n] ភាវៈនិយមខ្យល់, សារពាង្គកាយនិយមខ្យល់, ការដកដង្ហើមត្រូវការអុកស៊ីសែន, ខ្យល់ភាព (ការត្រូវការអុកស៊ីសែន រស់នៅ ឬកើតឡើងនៅទីកន្លែងដែលមានអុកស៊ីសែន។) ពាក្យផ្ទុយ anaerobe ការដកដង្ហើមមិនត្រូវការអកស៊ីសែន)។

**aerobic** /ɛːˈrəʊbɪk/ [adj] ដែលមានខ្យល់, ដែលត្រូវការខ្យល់, ខ្យល់ភាព (ដែលត្រូវការម៉ូលេគុលអុកស៊ីសែននៅជាមួយសម្រាប់ការលូតលាស់របស់ ឬការកើតមាននៅសរីរាង្គណាមួយ នៅក្នុងវត្តមាននៃម៉ូលេគុលអុកស៊ីសែន។)

**aerobiology** /ˌɛːrə(ʊ)bʌɪˈɒlədʒi/ [n] ជីវវិទ្យាបរិយាកាស

**aerobiosis** /eəˈrəʊ.bɪksɪs/ [n] ជីវិតនិយមខ្យល់

**aerology** /ɛːˈrɒlədʒi/ [n] អាកាសវិទ្យា

**aerophil** /ɛːˈrəʊfɪl/ [n] និយមខ្យល់

**aerophoto** /ˈɛːrəʊˈfəʊtəʊ/ [n] រូបថតពីលើអាកាស

**aerophotogrammetry** /ˈɛːrəʊˈfəʊtə(ʊ)ˈgramɪtri/ [n] ផូតូលេខមាត្រអាកាស

**aerophotograph** /ˈɛːrəʊˈfəʊtəgrɑːf/ [n] រូបថតពីលើអាកាស

**aerophotography** /ˈɛːrəʊfəˈtɒgrəfi/ [n] តំហតពីលើអាកាស

**aerophyte** /ˈɛːrəʊfʌɪt/ [n] រុក្ខជាតិអាកាស

**aeroplankton** /ˈɛːrəʊˈplaŋ(k)t(ə)n/ [n] ប្លង់តុងអាកាស, ខ្យល់ប្លង់តុង (ភាវរស់ទាំងឡាយណា ដូចជាគ្រាប់លម្អង ស្ប៉រ សត្វល្អិតតូចៗ ដែលហើរតាមខ្យល់)។

**aeroponics** /ˌɛːrə(ʊ)ˈpɒnɪks/ [n] ផើងខ្យល់ (ជាបច្ចេក-ទេសដាំដុះរុក្ខជាតិមួយដែលនៅទីនោះ ដំណាំទទួលបាន ឬស្រូបយកសារធាតុចិញ្ចឹមនិងទឹកពីអ័ព្ទនៃសំណើមខ្យល់ និងសូលុយស្យុងរាវដែលមកប៉ះជាមួយឫសរបស់រុក្ខជាតិ)

**aerosol** /ˈɛːrəsɒl/ [n] ភាគល្អិតរឹង ឬរាវអណ្តែតក្នុងខ្យល់, អាអេរ៉ូសូល

- acid aerosol /ˈasɪd ˈɛːrəsɒl/ [n] អាអេរ៉ូសូលអាស៊ីត

**aerotaxis** /ˈɛːrəʊˈtaksɪs/ [n] ចលនាតាមទិសខ្យល់

**aerothorax** /ɛːˈrəʊ ˈθɔːraks/ [n] (សទិសន័យ៖ pneumothorax) មានខ្យល់នៅតាមចន្លោះស្រោមសួត

**aerotropism** /ˈɛːrəʊˈtrəʊpɪz(ə)m/ [n] តំណាបរំញោចខ្យល់, ខ្យល់ទំនោរទិស

***Aeschynomene americana*** [sci.n] សូមមើលពាក្យ៖ shyleaf

***Aeschynomene aspara*** [sci.n] សូមមើលពាក្យ៖ sola pith plant

***Aeschynomene indica*** [sci.n] សូមមើលពាក្យ៖ Indian joint-vetch

**aesthetics** /iːsˈθɛtɪks/ [n] សោភ័ណវិទ្យា, សោភ័ណភាព

**aestivation** /ˌiːstɪˈveɪʃ(ə)n/ [n]

១. (សទិសន័យ៖ estivation) ជីវិតក្រាំង, ក្រាំកម្ម (ដំណាក់កាលគ្មានសកម្មភាព ឬក្រាំងរបស់ជង្លុវនៅក្នុងរដូវក្តៅ)

២. ការតម្រៀបនៃគល់ត្របកផ្កា

**afebrile** /eɪˈfiːbrʌɪl/ [adj] ឥតគ្រុន

**affair** /əˈfɛː/ [n] កិច្ចការ

**affect** /əˈfɛkt/ [v] មានឥទ្ធិពល, ធ្វើឱ្យប្រែប្រួលដល់

**afferent** /ˈaf(ə)r(ə)nt/ [adj] អាទែចូល, ប្រជុំចូល

**affinity** /əˈfɪnɪti/ [n]

១. (ចំពោះសត្វ ឬរុក្ខជាតិ) ភាពដូចគ្នា, សៃស្រឡាយ

២. (ចំពោះគីមីវិទ្យា) ចំណូល

**affirm** /əˈfəːm/ [v] អះអាង, និយាយបញ្ជាក់យ៉ាងច្បាស់លាស់

**affirmative** /əˈfəːmətɪv/ [adj] ដែលបញ្ជាក់ថាមែន, ដែលជាប្រក្រតី

**affluent** /ˈaflʊənt/ [n] ដៃ (ទន្លេ ស្ទឹង)

**afforestation** /əfɒrɪˈsteɪʃ(ə)n/ [n] ការដាំព្រៃ (ការដាំដុះព្រៃឈើឡើងវិញ នៅតំបន់ដែលពីមុនមិនមានព្រៃឈើ ឬដីដែលមិនមានព្រៃឈើដុះលូតលាស់)

**afterbirth** /ˈɑːftəbəːθ/ [n] សូមមើលពាក្យ៖ placenta

**after-ripening (pre-curing)** /ˈɑːftə ˈrʌɪp(ə)nɪŋ/ [adj] បន្ទុំ (ផ្លែ គ្រាប់) (ដំណើរវិវត្តន៍ទុំខាងសរីរៈ ដែលកើតឡើងចំពោះផ្លែ គ្រាប់ បន្ទាប់ពីគេប្រមូលផលឬជ្រុះ។ ការបន្ទុំនេះត្រូវធ្វើចំពោះគ្រាប់ដែលផ្លែវាមិនទាន់ទុំល្អ ដើម្បីឱ្យគ្រាប់វាអាចដុះបាន។)

**agalactia** /ˌagəˈlaktɪə/ [adj] គ្មានទឹកដោះ

**agamogenesis** /ˈɑːgəməʊˈdʒɛnɪsɪs/ [n] ការបន្តពូជគ្មានឈ្មោល

**agamospecies** /ˈɑːgəməʊˈspiːʃiːz/ [n] ប្រភេទបន្តពូជដោយគ្មានឈ្មោល

**agamospermy** /ˈagəmə(ʊ)ˌspəːmi/ [n] ការបន្តពូជដោយគ្មានស្ពែម

***Aganonerion polymorphum*** [sci.n] វល្លិខ្ទឹង

**agar** /ˈeɪgɑː/ [n] សារាយ

**age** /eɪdʒ/ [n] អាយុ, យុគ, សម័យ

- bronze age /brɒnz eɪdʒ/ [n] យុគលង្ហិន
- copper age /ˈkɒpə eɪdʒ/ [n] យុគទង់ដែង
- glacial age /ˈgleɪsɪəl eɪdʒ/ [n] សម័យទឹកកក
- ice age /ʌɪs eɪdʒ/ [n] សម័យទឹកកក
- iron age /ˈʌɪən eɪdʒ/ [n] យុគដែក
- reproductive age /ˌriːprəˈdʌktɪv eɪdʒ/ [n] អាយុបន្តពូជ (ឧ. ចំពោះរុក្ខជាតិ វាជាអាយុដែលដើមឈើចេញផ្លែលើកដំបូង ពោលគឺជាការកំណត់ព្រំដែនពីអាយុក្មេងខ្ចីទៅដល់អាយុពេញវ័យយោងទៅតាមការបន្តពូជ)

**agent** /ˈeɪdʒ(ə)nt/ [n] ភ្នាក់ងារ, មេ

- agricultural extension agent /agrɪˈkʌltʃərəl ɪkˈstɛnʃ(ə)n ˈeɪdʒ(ə)nt/ [n] ភ្នាក់ងារផ្សព្វផ្សាយកសិកម្ម
- alkylating agent /ˈalkɪleɪtɪŋ ˈeɪdʒ(ə)nt/ [n] ភ្នាក់ងារភ្ជាប់អាល់គីល

- antibacterial agent /ˌantɪbakˈtɪərɪəl ˈeɪdʒ(ə)nt/ [n] ភ្នាក់ងារប្រឆាំងបាក់តេរី
- antifungal agent /antɪˈfʌŋg(ə)l ˈeɪdʒ(ə)nt/ [n] ភ្នាក់ងារប្រឆាំងផ្សិត
- antiviral agent /antɪˈvʌɪr(ə)l ˈeɪdʒ(ə)nt/ [n] ភ្នាក់ងារប្រឆាំងវីរុស
- catalytic agent /ˌkatəˈlɪtɪk ˈeɪdʒ(ə)nt/ [n] សូមមើលពាក្យ៖ catalyst
- causal agent /ˈkɔːz(ə)l ˈeɪdʒ(ə)nt/ [n] ភ្នាក់ងារបង្កជំងឺ
- erosion agent /ɪˈrəʊʒ(ə)n ˈeɪdʒ(ə)nt/ [n] មេសំណឹក
- pollination agent /pɒlɪˈneɪʃ(ə)n ˈeɪdʒ(ə)nt/ [n] សត្វនាំលម្អង, សត្វចម្លងលម្អង
- pollution agent /pəˈluːʃ(ə)n ˈeɪdʒ(ə)nt/ [n] សារធាតុបំពុល, ភ្នាក់ងារបំពុល
- toxic agent /ˈtɒksɪk ˈeɪdʒ(ə)nt/ [n] សារធាតុពុល

***Ageratum conyzoides*** [sci.n] សូមមើលពាក្យ៖ goat weed, tropic ageratum

**agglutination** /əˌgluːtɪˈneɪʃən/ [n] សម្អិតជាប់គ្នា

**aggregation** /agrɪˈgeɪʃ(ə)n/ [n] ឧន្ទ (ជាការផ្គុំគ្នានៃបំណែកតូចៗឱ្យធំឡើង)

**aggression** /əˈgrɛʃ(ə)n/ [n] ការរំលោភឈ្លានពាន

**aging** /ˈeɪdʒɪŋ/ [n] ការឡើងចាស់, ភាពឡើងចាស់

- accelerated aging /əkˈsɛləreɪtɪd ˈeɪdʒɪŋ/ [n] បន្ទុំ (អាយុ), បង្កើនអាយុ

**agitate** /ˈadʒɪteɪt/ [v] កូរ, ធ្វើឱ្យរំជួល

**agitation** /adʒɪˈteɪʃ(ə)n/ [n] ការរញ្ជួយ, ការជ្រួលច្រាល់ចិត្ត

**agony** /ˈagəni/ [n] ស្លូឈាម

**agrarian** /əˈgrɛːrɪən/ [adj] នៃកសិកម្ម, ដែលទាក់ទងនឹងដីធ្វើកសិកម្ម

**agribusiness** / ˈagrɪbɪznəs/ [n] កសិពាណិជ្ជកម្ម, កសិទុរកិច្ច

**agricultural** /agrɪˈkʌltʃərəl/ [adj] ខាងកសិកម្ម

- agricultural credit /agrɪˈkʌltʃərəl ˈkrɛdɪt/ [n] ឥណទានកសិកម្ម
- agricultural economist /agrɪˈkʌltʃərəl ɪˈkɒnəmɪst/ [n] សេដ្ឋវិទូកសិកម្ម
- agricultural household /agrɪˈkʌltʃərəl ˈhaʊshəʊld/ [n] គ្រួសារកសិករ
- agricultural officer /agrɪˈkʌltʃərəl ˈɒfɪsə/ [n] មន្ត្រីកសិកម្ម
- agricultural rite /agrɪˈkʌltʃərəl rʌɪt/ [n] កសិទំនៀម (ទំនៀមទម្លាប់ដែលទាក់ទងនឹងកសិកម្ម)
- agricultural service /agrɪˈkʌltʃərəl ˈsəːvɪs/ [n] សេវាកសិកម្ម

**Agricultural Mortgage Corporation (AMC)** /agrɪˈkʌltʃərəl ˈmɔːgɪdʒ /kɔːpəˈreɪʃ(ə)n/ [n] សារជីវកម្មឱ្យខ្ចីលុយសម្រាប់ធ្វើកសិកម្ម

**Agricultural Training Board (ATB)** /agrɪˈkʌltʃərəl ˈtreɪnɪŋ bɔːd/ [n] ក្រុមបណ្តុះបណ្តាលខាងកសិកម្ម

**agriculturalist** /agrɪˈkʌltʃ(ə)rəlɪst/ [n] អ្នកកសិកម្ម (ឧ. កសិករ, អ្នកថែសួន)

**agriculture** /ˈagrɪkʌltʃə/ [n] កសិកម្ម

- commercial agriculture /kəˈməːʃ(ə)l ˈagrɪkʌltʃə/ [n] កសិកម្មបែបជំនួញ
- intensive agriculture /ɪnˈtɛnsɪv ˈagrɪkʌltʃə/ [n] កសិកម្មអតិផល (ប្រភេទកសិកម្មអយថាផល ដែលក្នុងនោះគេប្រើប្រាស់ឱ្យអស់លទ្ធភាព និងសមត្ថភាពដែលអាចធ្វើបាន ដើម្បីទទួលបាននូវចំណូលខ្ពស់)។ ពាក្យផ្ទុយ៖ extensive agriculture។
- nomadic agriculture /nəʊˈmadɪk ˈagrɪkʌltʃə/ [n] កសិកម្មពនេចរ
- sedentary agriculture /ˈsɛk(ə)nd(ə)ri ˈagrɪkʌltʃə/ [n] (សទិសន័យ៖ sedentary farming) ការធ្វើកសិកម្មនៅមួយកន្លែង
- sustainable agriculture /səˈsteɪnəb(ə)l ˈagrɪkʌltʃə/ [n] កសិកម្មនិរន្តរភាព, កសិកម្មសមស្រប (ប្រភេទកសិកម្មដែលជំរុញឱ្យមានការរក្សានិរន្តកម្មយូរអង្វែងក្នុងផលិតកម្មកសិកម្ម ព្រមទាំងអាចឱ្យកសិករទទួលបាននូវថវិកាសមស្របមួយ)
- traditional agriculture /trəˈdɪʃ(ə)n(ə)l ˈagrɪkʌltʃə/ [n] កសិកម្មប្រពៃណី

**agriculturist** /agrɪˈkʌltʃ(ə)rɪst/ [n] កសិកម្មវិទូ, អ្នកសិក្សាស្រាវជ្រាវវិទ្យាសាស្ត្រកសិកម្ម

***Agriocnemis femina*** [sci.n] កន្ទុំរុយ

***Agriocnemis pygmaea*** [sci.n] កន្ទុំរុយ

**agrisilviculture** /agrɪ ˈsɪlvɪˌkʌltʃə/ [n] កសិរុក្ខវប្បកម្ម (ទម្រង់នៃកសិរុក្ខកម្ម ដែលរួមមានដើមឈើ និងដំណាំកសិកម្ម)

***Agrius convolvuli*** [sci.n] ដង្កូវខ្នាយចំនុច, ដង្កូវដំឡូងជ្វា

**agro-** /ˈagrəʊ/ [prefix] (សទិសន័យ៖ agri) កសិ, កសិកម្ម

**agroalimentary** /ˈagrəʊalɪˈmɛnt(ə)ri/ [n] កសិម្ហូបអាហារ

**agrobiology** /agrəʊbʌɪˈɒlədʒi/ [n] ជីវវិទ្យាកសិកម្ម

**agrochemistry** /ˈagrəʊˈkɛmɪstri/ [n] (សទិសន័យ៖ agricultural chemistry) គីមីកសិកម្ម

**agroclimatic** /ˈagrəʊ klʌɪˈmatɪk/ [adj] ក្សេត្រអាកាសធាតុ (ទំនាក់ទំនងអាកាសធាតុ និងការងារដាំដុះដំណាំដូចជាទឹកភ្លៀង សីតុណ្ហភាព និងសំណើមអាកាស)

- agroclimatic environment /ˈagrəʊ klʌɪˈmatɪk ɪnˈvʌɪrənm(ə)nt/ [n] ក្សេត្របរិយាកាសធាតុ (ទីកន្លែងដែលមានលក្ខខណ្ឌក្សេត្រអាកាសធាតុស្រដៀងគ្នា ប៉ុន្តែមិនចាំបាច់នៅជិតគ្នានោះទេ)
- agroclimatic variable /ˈagrəʊ klʌɪˈmatɪk ˈvɛːrɪəb(ə)l/ [n] វិបរិតរូបនៃក្សេត្រអាកាសធាតុ (កត្តាទាំងឡាយដែលមានឥទ្ធិពលលើការដាំដុះរបស់ដំណាំក្រោមលក្ខខណ្ឌក្សេត្រអាកាសធាតុ)

**agroclimatology** /ˈagrəʊklʌɪməˈtɒlədʒi/ [n] (សទិសន័យ៖ agricultural climatology) អាកាសធាតុវិទ្យាកសិកម្ម

**agroecology** /ˈagrəʊ ɪˈkɒlədʒi/ [n] ក្សេត្របរិស្ថានវិទ្យា (១. វិទ្យាសាស្ត្រសិក្សាអំពីតំបន់ដែលបានបែងចែកទៅតាមលក្ខខណ្ឌសមស្របសម្រាប់ការដាំដុះ និងលូតលាស់នៃរុក្ខ-ជាតិ ២. ជាការសិក្សាអំពីបាតុភូតនៃបរិស្ថាននៅក្នុងស្រែចម្ការដូចជាទំនាក់ទំនងរវាងដំណាំ និងស្មៅ អំពីសត្វរំពា និងសត្វចំណីជាដើម ៣. ជាបណ្តុំនៃកត្តាបរិស្ថាន និងសង្គមដែលផ្តល់ឥទ្ធិពលដល់ផលិតកម្មកសិកម្ម)

**agroforestry** /agrəʊˈfɒrɪstri/ [n] (សទិសន័យ៖ farm forestry) កសិរុក្ខកម្ម (ជាឈ្មោះនៃប្រព័ន្ធប្រើប្រាស់ដី និងបច្ចេកវិទ្យា ដែលប្រភេទឈើត្រូវបានប្រើប្រាស់សម្រាប់ការគ្រប់គ្រងដី ដូចជាដំណាំកសិកម្ម សត្វក្នុងទម្រង់ជាការរៀបចំ)

**agro-industry** /ˈagrəʊ ˈɪndəstri/ [n] កសិឧស្សាហកម្ម

**agrometeorology** /ˈagrəʊˌmiːtɪəˈrɒlədʒi/ [n] ឧតុភូតវិទ្យាកសិកម្ម

**agronomic feature** /agrəˈnɒmɪk ˈfiːtʃə/ [n] លក្ខណៈក្សេត្រសាស្ត្រ

**agronomist** /əˈgrɒnəmist/ [n] ក្សេត្រវិទូ, អ្នកជំនាញក្សេត្រសាស្ត្រ

**agronomy** /əˈgrɒnəmi/ [n] ក្សេត្រសាស្ត្រ, ក្សេត្រវិទ្យា

**agrosilvopastoralism** /ˈagrəʊsɪləʊvˈpɑːst(ə)r(ə)lɪz(ə)m/ [n] ទម្រង់នៃកសិរុក្ខកម្ម ដែលរួមមាន ដើមឈើ ដំណាំកសិកម្ម និងការចិញ្ចឹមសត្វ

**agrowaste** /ˈagrəʊweɪst/ [n] សំណល់កសិកម្ម

**aid** /eɪd/ [n] ជំនួយ

- first aid /fəːst eɪd/ [n] ជំនួយបឋម, ការជួយសង្គ្រោះជាបន្ទាន់
- food aid /fuːd eɪd/ [n] សូមមើលពាក្យ៖ food assistance

**aiguille** /ˈeɪgwiːl/ [n] កំពូលស្រួច

**aim** /eɪm/ [n] ទិសដៅ (មុខសញ្ញាដែលនឹងត្រូវធ្វើ)

**air** /ɛː/ [n] ខ្យល់, អាកាស

- ambient air /ˈambɪənt ɛː/ [n] ខ្យល់ជុំវិញ, ខ្យល់ក្នុងបរិយាកាស, បរិយាកាសជុំវិញ
- antarctic air /anˈtɑːktɪk ɛː/ [n] ខ្យល់អង់តាទិច
- arctic air /ˈɑːktɪk ɛː/ [n] ខ្យល់អាកទិច
- clean air /kliːn ɛː/ [n] ខ្យល់ស្អាត
- cold air /kəʊld ɛː/ [n] ខ្យល់ត្រជាក់
- contaminated air /kənˈtamɪneɪtɪd ɛː/ [n] ខ្យល់កខ្វក់
- continental air /kɒntɪˈnɛnt(ə)l ɛː/ [n] ខ្យល់ទ្វីប
- dead air /dɛd ɛː/ [n] (សទិសន័យ៖ foul air) ខ្យល់អាប់អួ, ខ្យល់មានឧស្ម័នកាបូនិចច្រើន
- dissolved air /dɪˈzɒlvd ɛː/ [n] ខ្យល់ (ក្នុងវត្ថុរាវ)
- dry air /drʌɪ ɛː/ [n] ខ្យល់ស្ងួត
- dust-free air /dʌst friː ɛː/ [n] ខ្យល់គ្មានធូលី
- equatorial air /ˌɛkwəˈtɔːrɪəl ɛː/ [n] ខ្យល់អេក្វាទ័រ
- foul air /faʊl ɛː/ [n] សូមមើលពាក្យ៖ dead air
- free air /friː ɛː/ [n] ខ្យល់សេរី
- fresh air /frɛʃ ɛː/ [n] ខ្យល់ថ្មី, ខ្យល់បរិសុទ្ធ

- humid air /ˈhjuːmɪd ɛː/ [n] ខ្យល់សើម
- maritime air /ˈmarɪtʌɪm ɛː/ [n] ខ្យល់សមុទ្រ
- moist air /mɔɪst ɛː/ [n] ខ្យល់សើម
- moisture-laden air /ˈmɔɪstʃə ˈleɪd(ə)n ɛː/ [n] ខ្យល់នាំសំណើម
- polar air /ˈpəʊlə ɛː/ [n] ខ្យល់តំបន់ប៉ូល
- polluted air /pəˈluːtɪd ɛː/ [n] ខ្យល់ពុល
- pure air /pjʊə ɛː/ [n] ខ្យល់ស្អាត
- saturated air /ˈsatʃəreɪtɪd ɛː/ [n] ខ្យល់ឆ្អែត, ខ្យល់សើម, ខ្យល់មានសំណើមឆ្អែត
- soil air /sɔɪl ɛː/ [n] ខ្យល់ក្នុងដី
- surface air /ˈsəːfɪs ɛː/ [n] ខ្យល់ស្រទាប់ក្បែរផ្ទៃដី
- tropical air /ˈtrɒpɪk(ə)l ɛː/ [n] ខ្យល់ត្រូពិច
- upper air /ˈʌpə ɛː/ [n] ខ្យល់ស្រទាប់លើនៃបរិយាកាស
- warm air /wɔːm ɛː/ [n] ខ្យល់ក្ដៅ

**air layering** /ɛː ˈleɪərɪŋ/ [n] សូមមើលពាក្យ៖ marcotting

**airway** /ˈɛːweɪ/ [n] ផ្លូវខ្យល់

**air compressor** /ɛː kəmˈprɛsə/ [n] ប្រេសខ្យល់ (ឧបករណ៍សង្កត់ប្រើដោយកម្លាំងខ្យល់)

**air drying** /ɛː drʌɪˈɪŋ/ [n] សម្ងួតដោយខ្យល់ (ការហាល ឬសម្ងួតគ្រាប់រុក្ខជាតិនៅក្នុងម្លប់ដោយខ្យល់)

**akinesia** /ˌakɪˈniːsɪə/ [n] តំហាយចលនា, អំណាស់ចលនា

**akinete** /eɪˈkʌɪ nit/ [n] អាគីណែត (កោសិកាក្រាំងមានភ្នាសក្រាស់ ដែលមានប្រភពពីកោសិកាលូតលាស់របស់រុក្ខជាតិ)

**alar** /ˈeɪlə/ [adj] នៃស្លាប, ទាក់ទងនឹងស្លាប

**albedo** /alˈbiːdəʊ/ [n] អាល់បេដូ (កាំរស្មីចំណាំងផ្លាតពីផែនដីទៅ ដែលជាពពួករលកវិទ្យុសកម្មខ្លី)

**albedometer** /alˈbiːdəʊˈmiː.tər/ [n] អាល់បេដូម៉ែត្រ

**albinism** /ˈalbɪnɪz(ə)m/ [n] ភាពផឿក, អលប៊ីនិសឹម (អវត្តមានទាំងស្រុងឬស្ទើរតែទាំងស្រុងនូវជាតិពណ៌ (pigment) នៅក្នុងរុក្ខជាតិមួយ ឬផ្នែកផ្សេងៗ របស់រុក្ខជាតិ។ កន្លែងដែលរងរបួសនេះ គឺមានពណ៌ស ឬប្រហាក់ប្រហែលនេះ។ ជាធម្មតា រុក្ខជាតិក្លាយជាពណ៌សអាចនឹងស្លាប់ភ្លាម។)

**albino** /alˈbiːnəʊ/ [n] ផឿក, ឃ្លៀច

***Albulichthys albuloides*** [sci.n] ត្រីឆ្កោកទីទុយ

**albumen** /ˈalbjʊmɪn/ [n] ផ្នែកសរបស់ស៊ុត (អាល់ប៊ុយមីន) (ក្រុមឬបណ្ដុំនៃជាលិកាទ្រទ្រង់ដែលនៅចន្លោះអំប្រីយ៉ុង និងសម្បកគ្រាប់ ដែលខាងក្នុងនោះ មានភេរីស្ពែម (perisperm) និងអែនដូស្ពែម(endosperm)។)

**albumin** /ˈalbjʊmɪn/ [n] អាល់ប៊ុយមីន, ជាតិសនៅក្នុងស៊ុត

**alcohol** /ˈalkəhɒl/ [n] អាល់កុល, ស្រា (ស្រាបិតដែលមានកម្រិតអាល់ខ្ពស់)

- methyl alcohol /ˈmiːθʌɪl ˈalkəhɒl/ [n] មេទីលអាល់កុល

**alcoholism** /ˈalkəhɒlɪz(ə)m/ [n] ញៀនស្រា

**aldehyde** /ˈaldɪhʌɪd/ [n] អាល់ដេអ៊ីត

**aldose** /ˌɔːldəʊz/ [n] អាល់ដូស, ម៉ូណូសាក់ការីតដែលមានបង្គុំអាល់ដេអ៊ីត

**aldrin** /ˈɔːldrɪn/ [n] អាល់ឌ្រីន

**allergy** /ˈalədʒi/ [n] ប្រតិកម្មចំពោះវត្ថុអ្វីមួយ, ទាស់

**alfalfa** /alˈfalfə/ [n] សណ្ដែកអាល់ហ្វាហ្វា

**alga** /ˈalgə/ [n] (ពហុវចនៈ៖ algae) ស្លែ, សារាយ (រុក្ខជាតិមីក្រូសរីរាង្គរស្មីសំយោគ ដែលកោសិកាគ្មានណ្វៃយ៉ូ គ្មានឬស ដើម ស្លឹកពិតប្រាកដ។ រូបរាងរបស់វាមានទម្រង់ជាកោសិកាទោល ឬសវាមានពណ៌លឿង ស្រដៀងបៃតង ត្នោត ឬស្មៅ។ គេអាចប្រើប្រាស់វាជាជីស្រស់។)

- blue-green algae /bluː griːn ˈalgə/ [n pl] សារាយបៃតងចាស់ (ជាឈ្មោះដើមរបស់ស្យាណូបាក់តេរី)
- brown alga /braʊn ˈalgə/ [n] សារាយត្នោត

**algicide** /ˈaldʒɪsʌɪd/ [n] ថ្នាំសម្លាប់សារាយ

**algology** /alˈgɒlədʒi/ [n] សារាយវិទ្យា

**aliment** /ˈalɪm(ə)nt/ [n] អាហារ, ការផ្គត់ផ្គង់ចំណី

**alimentation** /ˌalɪm(ə)nˈteɪʃ(ə)n/ [n] របៀបឱ្យអាហារ, ចំណីអាហារ

**alisphenoid** /ˌalɪˈsfiːnɔɪd/ [n] ឆ្អឹងដែលកើតមាននៅចំកណ្ដាលលលាដ៏ក្បាលថនិកសត្វ

**alkali** /ˈalkəlʌɪ/ [n] សូលុយស្យុងបាស, អាល់កាលី (កាល់ស្យូមកាបូណាត ឬ ប៉ូតាស្យូមកាបូណាត ដែលមានជាតិល្វីងប្រៃ ដែលមាននៅតំបន់ arid និង semiarid។)

- alkali metal /ˈalkəlʌɪ ˈmɛt(ə)l/ [n] លោហៈអាល់កាឡាំង

- alkali soil /ˈalkəlʌɪsɔɪl/ [n] សូមមើលពាក្យ៖ saline soil

**alkalic** /alˈkalɪk/ [adj] មជ្ឈដ្ឋានបាស ឬអាល់កាឡាំង (១. សំដៅទៅលើសូលុយស្យុង ដែលមាន pH ពី ៧ ទៅ ១៤ ២. មានគុណភាពជាបាស ជួនកាលមានលើថ្មសម្រាប់បង្កើតភ្លើង)

**alkalify** /ˈalkəlɪfi/ [v] បំប្លែងទៅជាបាស

**alkaline** /ˈalkəlʌɪn/ [n] អាល់កាឡាំង, បាស (សារធាតុដែលបំបែកធាតុជាបណ្ដុំ $OH^-$ នៅពេលរលាយក្នុងទឹក)

**alkalinity** /alkəˈlɪnɪti/ [n] ក្បុងភាព, បាសភាព (ភាពដែលមាន pH>៧.0)

**alkalization** /ˈalkəlʌɪˈzeɪʃ(ə)n/ [n] បំប្លែងជាបាស, បាសកម្ម

**alkaloid** /ˈalkəlɔɪd/ [n] អាល់កាឡូអ៊ីត, វត្ថុធាតុជាតិក្បុង

**alkalophile** /ˈalkəleu fʌɪl/ [n] ភាវរស់ចំណូលបាស

**alkalosis** /ˌalkəˈləʊsɪs/ [n] មានជាតិក្បុងច្រើនពេក

**alkane** /ˈalkeɪn/ [n] អាល់កាន

**alkyne** /ˈalkʌɪn/ [n] អាល់គីន

***Allamanda cathartica*** [sci.n] សូមមើលពាក្យ៖ desert rose

**allantois** /əˈlantəʊɪs/ [n] អាឡង់តូអ៊ីត

**allele** /ˈali:l/ [n] អាលែល, សម្ពន្ធករ (ភាគីមួយនៃទម្រង់គូ (ជាខ្សែ) របស់ពន្ធុដែលមានភាពបន្តពូជផ្លាស់ ដោយវាស្ថិតនៅចំណុចដូចគ្នាក្នុងសហក្រូម៉ូសូម)

- multiple allele /ˈmʌltɪp(ə)l ˈali:l/ [n] ពហុអាលែល, អាលែលច្រើន (ស៊េរី ឬ ក្រុម មួយនៃអាលែលរបស់ពន្ធុ ឬសែនពិសេសណាមួយ។)
- recessive allele /rɪˈsɛsɪv ˈali:l/ [n] អាលែលអន់, អាលែលខ្សោយ (ការពិពណ៌នាអំពីអាលែលមួយថា វាអាចនឹងសម្ដែងលក្ខណៈវាទៅបាន នៅពេលវាជាអូម៉ូស៊ីកូត។ ក្នុងករណីភាគច្រើន ពួកវាត្រូវបានគេចាត់ទុកជាទម្រង់បរិវត្តរូបនៃអាលែលលប់ (លក្ខណៈរបស់វាប្រែប្រួលតាមអាលែលលប់)។ នៅក្នុងការបង្កាត់ពូជ អាលែលអន់គេតាងដោយអក្សរតូច (a..) និងអាលែលលប់ តាងដោយអក្សរធំ (A..)។)

**allelopathy** /ˌaliːˈlɒpəθi/ [n] សង្កត់កម្ម (ការបង្អាក់លើការលូតលាស់នៃអម្បូររុក្ខជាតិមួយដោយអម្បូររបស់រុក្ខជាតិមួយទៀតដែលមានជាតិពុល)

**allergen** /ˈalədʒ(ə)n/ [n] អាល់លែស៊ី, ធាតុបង្កប្រតិកម្ម, ប្រតិកម្មតំណប, ការមានប្រតិកម្មចំពោះវត្ថុអ្វីមួយ (ទាស់,ចាញ់)

**allergy** /ˈalədʒi/ [n] អាល់លែហ្ស៊ី

**alleviate** /əˈliːvɪeɪt/ [v] សម្រាល, ធ្វើឱ្យធូរស្រាល

**allit** /əˈlɪt/ [n] ដីដែលផលធៀបស៊ីលិស ($SiO_2$) ឬ ដែកអុកស៊ីដ, អាលុយមីញ៉ូមអុកស៊ីដតូចជាង ១ ឡាតេរីត

**allite** /ɔlʌɪt/ [n] សូមមើលពាក្យ៖ laterite

**allitization** /əˈlɪttˈzeɪʃ(ə)n/ [n] ការធ្វើឱ្យកើតជាឡាតេរីត

***Allium cepa*** [sci.n] សូមមើលពាក្យ៖ onion

***Allium cepa* var.*aggregatum*** [sci.n] សូមមើលពាក្យ៖ shallot

***Allium fistulosum*** [sci.n] សូមមើលពាក្យ៖ bunching onion, welsh onion

***Allium sativum*** [sci.n] សូមមើលពាក្យ៖ garlic

***Allium tuberosum*** [sci.n] សូមមើលពាក្យ៖ Chinese chives

**allochthonic** /ˌɛksə(ʊ)ˈdʒɛnɪk/ [adj] សូមមើលពាក្យ៖ allogenic

**allochthonous** /əˈlɒkθənəs/ [adj] សូមមើលពាក្យ៖ allogenic

**alloenzyme** /ˈaləʊ ˈɛnzʌɪm/ [n] ប្រភេទអង់ស៊ីមម៉្យាង (ជាអង់ស៊ីមមួយដែលខុសប្លែកពីប្រភេទចម្រុងៗដោយសារតែមានភាពខុសគ្នានៃអាលែល ពោលគឺ អង់ស៊ីមផ្សេងៗ កំណត់ក្រមសំងាត់នៅលើទីតាំងពន្ធុតែមួយ)

**allogamy** /əˈlɒgəmi/ [n] (សទិសន័យ៖ cross-fertilization) ការបង្កកំណើតកាត់របស់រុក្ខជាតិ, ការបង្កកំណើតកាត់, អាឡូកាមី (ការបង្កើតកូនចៅ ដោយការលាយចូលគ្នារវាងកាម៉េតញី និងកាម៉េតឈ្មោលដែលមានប្រភពមកពីរុក្ខជាតិផ្សេងគ្នា។)

**allogenic** /ˌaləˈdʒɛnɪk/ [adj]
១. (ចំពោះដីវិទ្យា) រងឥទ្ធិពលពីខាងក្រៅ
២. (ចំពោះធរណីវិទ្យា) (សទិសន័យ៖ allochthonous, allochthonic, exogenic) ដែលមានដើមកំណើតពីក្រៅ (ឧ. សម្ភារនាំមកពីក្រៅដូចជាល្បាប់ ឬប្រជាជនដើមកំណើតពីក្រៅ)

**allograft** /ˈaləgrɑːft/ [n] សូមមើលពាក្យ៖ homograft

**allopatric** /ˌaləˈpatrɪk/ [adj] តាមតំបន់ខុសៗគ្នា, ដែលកើតឡើងនៅកន្លែងផ្សេងៗគ្នា, ដើមឈើ (រុក្ខជាតិ) នៅឯកោ

**alluvial** /əˈl(j)uːvɪəl/ [adj] នៃល្បាប់ភក់

**alluvial fan** /əˈl(j)uːvɪəl fan/ [n] (សទិសន័យ៖ dry delta) ល្បាប់ដែលនាំមកផ្តុំជារាងសាជី

**alluviation** /ɪˌl(j)uːvɪˈeɪʃ(ə)n/ [n] ដំណុះល្បាប់

**alluvium** /əˈl(j)uːvɪəm/ [n] (ពហុវចនៈ alluvia) ល្បាប់, ល្បប់ភក់, ល្បាប់ទន្លេ (កើតដោយជំនន់ទឹកទន្លេ ស្ទឹងបឹងបួ)
- old alluvium /əʊld əˈl(j)uːvɪəm/ [n] ល្បាប់ចាស់
- undifferenciated alluvium /ˌʌndɪfəˈrɛnʃɪeɪtɪd əˈl(j)uːvɪəm/ [n] (សទិសន័យ៖ young valley filling soil) ល្បាប់ដែលគ្មានការបញ្ជាក់ឱ្យច្បាស់, ល្បាប់ថ្មី

**alopecia** /ˌaləˈpiːʃə/ [n] ជំងឺជ្រុះរោម

**alpha-amylase** /ˈalfə ˈamɪleɪz/ [n] អាមីឡាសអាល់ហ្វា

**alpha-glucose** /ˈalfə ˈgluːkəʊs/ [n] គ្លុយកូសអាល់ហ្វា

**alpine** /ˈalpʌɪn/ [n] តំបន់ត្រជាក់នៅលើកំពូលភ្នំខ្ពស់

**alteration** /ɔːltəˈreɪʃ(ə)n/ [n] ដំណើរមិនប្រក្រតី
- downward alteration /ˈdaʊnwəd ɔːltəˈreɪʃ(ə)n/ [n] ការផុយបែក (ថ្ម) ដែលចាប់ពីលើចុះក្រោម
- upward alteration /ˈʌpwəd ɔːltəˈreɪʃ(ə)n/ [n] ការផុយបែក (ថ្ម) ពីក្រោមឡើងលើ

**altered** /ˈɔːltəd/ [adj] ដែលផុយបែក ឬប្រែក្លាយ

***Alternanthera sessilis*** [sci.n] សូមមើលពាក្យ៖ sessile joyweed

**alternate** /ˈɔːltəneɪt/ [adj] របៀបតម្រៀបស្លឹកលើមែកឆ្លាស់គ្នា

**alternate disjunction** /ˈɔːltəneɪt dɪsˈdʒʌŋ(k)ʃ(ə)n/ [n] អេតេរ៉ូស៊ីកូតបម្លាស់ទី

**alternative** /ɔːlˈtəːnətɪv/ [n] ជម្រើសផ្សេងទៀត

**altimeter** /ˈaltɪmiːtə/ [n] អាល់ទីម៉ែត្រ (ឧបករណ៍សម្រាប់កំនត់រយៈកម្ពស់ ធៀបនឹងកម្ពស់ទឹកសមុទ្រ)

**altitude** /ˈaltɪtjuːd/ [n] (សទិសន័យ៖ elevation) រយៈកម្ពស់, រយៈកម្ពស់ធៀបទៅនឹងកម្រិតទឹកសមុទ្រ (ចម្ងាយតាមខ្សែត្រង់ (បញ្ឈរ) រវាងចំនុច និងផ្ទៃចំនុចគោល (datum surface) ជាទូទៅគឺកម្រិតផ្ទៃទឹកសមុទ្រ។ កម្រិតកម្ពស់តំបន់ធៀបនឹងកម្រិតកម្ពស់ផ្ទៃទឹកសមុទ្រ។)
- absolute altitude /ˈabsəluːt ˈaltɪtjuːd/ [n] (សទិសសន័យ៖ absolute elevation) រយៈកម្ពស់ដាច់ខាត
- relative altitude /ˈrɛlətɪv ˈaltɪtjuːd/ [n] រយៈកម្ពស់ធៀប

**altricial** /əlˈtrɪʃ(ə)l/ [adj] កើតមុនកំណត់

**alumina** /əˈluːmɪnə/ [n] អាលុយមីន (អុកស៊ីដ Al)

**Aluminum** /al(j)ʊˈmɪnɪəm/ [n] អាលុយមីញ៉ូម (និមិត្តសញ្ញាគីមី Al)

**alumisol** /əˈlʌmis(ə)l/ [n] ដីដែលមានជាតិសាច់ជូរច្រើន

**alveolus** /alˈvɪələs/ [n] កូនថង់សួត (ពហុវចនៈ៖ alveoli)

***Alysicarpus monilifer*** [sci.n] ដើមសន្ទះឪម៉ាល់

**amaranth** /ˈamərанθ/ [n] ពួកផ្ទី, សណ្តានផ្ទី

***Amaranthus spinosus*** [sci.n] សូមមើលពាក្យ៖ pigweed, spiny amaranth

***Amaranthus viridis*** [sci.n] សូមមើលពាក្យ៖ slender amaranth

***Amauromorpha accepta metathoracicia*** [sci.n] ពួកឪម៉ាល់ (បរាសិតលើដង្កូវស៊ីរូងដើម)

**amb-** /amb-/ [prefix] (សទិសន័យ៖ both) បុព្វបទមានន័យថា ទាំងពីរ

**ambarella** /ˌæm bəˈrɛl ə/ [n] ម្កាក់ (ឈ្មោះវិទ្យាសាស្ត្រ *Spondias dulcis*)

**amber codon** /ˈambə ˈkəʊdɒn/ [n] កូដុងបញ្ចប់

***Amblyrhynchichthys truncatus*** [sci.n] ត្រីកំបុតច្រមុះ

**ambulant** /ˈambjʊl(ə)nt/ [adj] ដែលអាចដើរបាន, ដែលអាចដើរទៅមកបាន

**amebiasis** /ˌamiːˈbʌɪəsɪs/ [n] រោគរាកមួល

**amelioration** /əˌmiːlɪəˈreɪʃ(ə)n/ [n] សូមមើលពាក្យ៖ improvement

**amenorrhea** /əˌmɛnəˈriːə/ [n] ការរាំងរដូវ

**Americium** /ˌaməˈrɪsjəm/ [n] អាមេរីស្យូម (និមិត្តសញ្ញាគីមី Am)

**amid** /ˈeɪmʌɪd/ [n] អាមីដ

**amine** /ˈeɪmiːn/ [n] អាមីន

**aminopeptidase** /əˈmiːnəʊ ˈpɛptɪdeɪz/ [n] អង់ស៊ីម អាមីណូអាស៊ីតប៉ិបទីដាស

**aminotransferase** /əˈmiːnəʊ ˈtransf(ə)reɪz/ [n] អង់ស៊ីមអាមីណូត្រង់ស្វ៊ែរ៉ាស

**amiocenthesis** [n] ការពិសោធទឹកភ្លោះ (ការបូមទឹកចេញពីពោះមកពិនិត្យមើលអាការៈទារកក្នុងឧទរ)

**amitosis** /ˌeɪmʌɪˈtɒtɪs/ [n] អាមីតូស (ចំណែកកោសិកាដោយការបែងចែកណ្វៃយ៉ូ និងស៊ីតូប្លាសយ៉ាងសាមញ្ញ ដោយគ្មានបំប្លែងឯកទេសនៃក្រូម៉ូសូមទេ)

**amixis** [n] គ្មានការបង្កកំណើត, គ្មានក្រពេញភេទ

**ammonia** /əˈməʊnɪə/ [n] អាម៉ូញាក់ (១. ឧស្ម័នឈ្ងួលគ្មានក្លិន និង ងាយរលាយក្នុងទឹក។ ប្រើប្រាស់ក្នុង ទូទឹកកក ការផលិតជី សារធាតុផ្ទុះ និងប្លាស្ទិច។ រូបមន្ត $NH_3$ ២. សូលុយស្យុងអាម៉ូញ៉ាក់ ប្រើ ធ្វើជាថ្នាំសម្អាតផ្ទះ និងវាយនភ័ណ្ឌ។)

- quaternary ammonia /kwəˈtəːn(ə)ri əˈməʊnɪə/ [n] អាម៉ូញាក់ទី៤

**ammonification** /əˌmɒmoʊ fɪˈkeɪ ʃən/ [n] អាម៉ូញាក់កម្ម (ដំណើរការបំបែកអាម៉ូញាក់)

**ammonisation** /ˈamən ˈzeɪʃ(ə)n/ [n] អាម៉ូញាក់កម្ម (ការប្រែក្លាយអាសូតសរីរាង្គជាអាសូតអាម៉ូញាក់)

**ammonotelic** /əˌmɒmoʊnoʊteɪlɪk/ [adj] បញ្ចេញអាសូត (ការបញ្ចេញសំណល់អាសូតជាសំខាន់ ដូចជាអាម៉ូញាក់)

**amniocentesis** /ˌamnɪəʊsɛnˈtiːsɪs/ [n] វិធីបូមយកទឹកភ្លោះ, បំណូមទឹកភ្លោះ

**amnion** /ˈamnɪən/ [n] ថង់ទឹកភ្លោះ, ស្រោមទឹកភ្លោះ

- amnion fluid /ˈamnɪən ˈfluːɪd/ [n] ទឹកភ្លោះ

**amniote** /ˈamnɪəʊt/ [n] សត្វមានទឹកភ្លោះ

**amoeba** /əˈmiːbə/ [n] (ពហុវចនៈ៖ ameba) អាមីប

**amoebocyte** /əˈmi bəˌsaɪt/ [n] កោសិកាអាមីប

**amorphous** /əˈmɔːfəs/ [adj] និសណ្ឋាន (ដែលគ្មានរាងពិតប្រាកដ)

**amount of exchangeable bases (s-value)** /əˈmaʊnt əv ɪkstʃeɪn.dʒə.bl beɪ.sɪz/ [n] កន្សោមខនិជដោះដូរ

**amphi-** /amˈfɪ [prefix] បុព្វបទមានន័យថា ទាំងពីរប្រភេទ, ជុំវិញ, ប្រហែល

**amphibia** /amˈfɪbɪə/ [n] អម្ពូរកង្កែប

**amphibian** /amˈfɪbɪən/ [n] ថលជលិក

**amphiblastic** /ˈamfiˈblastɪk/ [adj] អំភីប្លាស (អំប្រ៊ីយ៉ុងវិទ្យា), ជាកាម៉េតញីដែលធ្វើចំណែកមិនស្មើគ្នា (ម្ខាងតូចឯម្ខាងទៀតធំ)

**amphimixis** /ˌamfɪˈmɪksɪs/ [n] ការបន្តពូជដោយភេទ

**amphitrichous** /amˈfɪ trɪ kɪt/ [adj] ប្រភេទបាក់តេរីដែលកោសិកាមានកន្ទុយមួយនៅចុងសងខាង

***Amphotistius imbricatus*** [sci.n] ត្រីបបែល

***Amphotistius laosensis*** [sci.n] ត្រីបបែល

**amplify** /ˈamplɪfʌɪ/ [v] ពង្រីក

**amputate** /ˈampjʊteɪt/ [v] កាត់ (ដៃ-ជើង)

**amputation** /ampjʊˈteɪʃ(ə)n/ [n] ការកាត់ដៃជើង ឬសរីរាង្គអ្វីមួយ

**amputee** /ampjʊˈtiː/ [n] មនុស្សកំបុតដៃ ឬជើង

**amylase** /ˈamɪleɪz/ [n] អាមីឡាស, អង់ស៊ីមម៉្យាងនៃប្រព័ន្ធរំលាយអាហារជួយឱ្យម្សៅធញ្ញជាតិទៅជាមានជាតិស្ករ

**amylopectin** /ˌamɪləʊˈpɛktɪn/ [n] អាមីឡូប៉ិកទីន (សមាសធាតុអាមីដុង ឬម្សៅដែលមានម៉ាសម៉ូលេគុលធំ និងរចនាសម្ពន្ធម៉ូលេគុលខ្នែងច្រើន ហើយមិនមានភាពស្អិតនៅក្នុងសូលុយស្យុងទឹកទេ)

**amylose** /ˈamɪləʊz/ [n] អាមីឡូស, ប៉ូលីគ្លុយស៊ីត, ការរំលាយបដ្ឋជាតិ

**amyotonin** /ˌeɪ maɪ əˈtoʊ nin/ [n] ការគ្មានសាច់ដុំ

**an-** /ən/ [prefix] (សទិសន័យ៖ ana-) បុព្វបទមានន័យថា គ្មាន, លើ, នៅខាងលើ, ទៀត, ខ្នង, ក្រោយ, ថយក្រោយ

**ana-** /ˈanə/ [prefix] សូមមើលពាក្យ៖ an-

***Anabas testudineus*** [sci.n] សូមមើលពាក្យ៖ climbing perch

**anabolism** /əˈnabəlɪz(ə)m/ [n] ជីវសំយោគ, អាណាបូលីស, អសមាណកម្ម (ផ្នែកនៃមេតាបូលីសដែលប្រើថាមពលដើម្បីបង្កើតម៉ូលេគុលធមជាង សាំញ៉ាំជាងចេញពីម៉ូលេគុលងាយជាង)

***Anacardium occidentale*** [sci.n] សូមមើលពាក្យ៖ cashew

**anadromous** /əˈnadrəməs/ [adj] (សទិសន័យ៖ catadromous) ផ្លាស់លំនៅឡើងពង (អំពីត្រីដែលប្ដូរទីពីបឹង ឬសមុទ្រទៅស្ទឹង ឬទន្លេដើម្បីពង)

**anaemia** /əˈniːmɪə/ [n] កង្វះឈាមក្រហម, ភាពស្លេកស្លាំង (បញ្ហាកង្វះមីក្រូសារជាតិដែលកើតមានជាទូទៅ និងធ្ងន់ធ្ងរ គឺជាលក្ខខណ្ឌដែលកំហាប់អេម៉ូក្លូប៊ីន (ចំនួនគ្រាប់ឈាមក្រហម) មានកម្រិតទាបជាងកម្រិតធម្មតាដោយសារតែមានជំងឺ ឬក៏ជាលទ្ធផលនៃបញ្ហាកង្វះសារជាតុចិញ្ចឹមមួយ ឬលើសពីមួយដូចជាកង្វះជាតិដែក និងកង្វះវីតាមីន $B_{12}$។)

**anaerobe** /ˈanərəʊb/ [n] ភាវៈមិននិយមខ្យល់ (ដំណើរនៃគីមីជីវសាស្ត្រដែលមិនត្រូវការឧស្ម័នអកស៊ីជែន ឧ.ការឡើងមេ។ ពាក្យផ្ទុយ aerobe។)

- obligate anaerobe /ˈɒblɪgeɪt ˈanərəʊb/ [n] បាក់តេរីមិនត្រូវការខ្យល់ចាំបាច់ (បាក់តេរីមិនត្រូវការខ្យល់ ដែលត្រូវបានបំពុលដោយអុកស៊ីសែន)

**anaerobic** /ˌanɛːˈrəʊbɪk/ [adj] គ្មានខ្យល់, គ្មានអុកស៊ីសែន, (ចំពោះគ្រាប់រុក្ខជាតិ) ដកដង្ហើមមិនត្រូវការអុកស៊ីសែន

**anaerobic** /ˌanɛːˈrəʊbɪk/ [n] ភាវៈមិននិយមខ្យល់, សារពាង្គកាយមិនត្រូវការខ្យល់, អខ្យល់ភាព (១. អវត្តមាននៃម៉ូលេគុលអុកស៊ីសែន។ ២. ការដុះលូតលាស់របស់ឯកត្តៈ ឬភាវរស់ណាមួយនៅក្នុងអវត្តមាននៃអុកស៊ីសែន។)

**anaerobiosis** /ˌanɛərəʊbaɪˈəʊsɪs/ [n] ជីវិតមិននិយមខ្យល់

**anagenesis** /ˌanəˈdʒɛnɪsɪs/ [n] ការវិវឌ្ឍជាលំដាប់

***Anagrus flaveolus*** [sci.n] ឪម៉ាល់ (បរាសិតលើពងមមាច)

***Anagrus optabilis*** [sci.n] ឪម៉ាល់ (បរាសិតលើពងមមាច)

**anal** /ˈeɪn(ə)l/ [adj] នៃរន្ធគូទ, នៃទ្វារធំ

**analgesia** /ˌan(ə)lˈdʒiːzɪə/ [n] ការស្ពឹក, ការបាត់ស្មារតី

**analgesic** /ˌan(ə)lˈdʒiːsɪk/ [adj] ស្ពឹក

**analgesic** /ˌan(ə)lˈdʒiːsɪk/ [n] (សទិសន័យ៖ anesthetic) ថ្នាំស្ពឹក

**analogue** /ˈanəlɒg/ [adj] សទិស, ដូច

**analyse** /ˈan(ə)lʌɪz/ [v] វិភាគ

**analysis** /əˈnalɪsɪs/ [n] ការវិភាគ, ការសិក្សាស្រាវជ្រាវ

- bacteriological analysis /bakˌtɪərɪəˈlɒdʒɪk(ə)l əˈnalɪsɪs/ [n] ការវិភាគបាក់តេរី
- chemical analysis /ˈkɛmɪk(ə)l əˈnalɪsɪs/ [n] ការវិភាគគីមី
- comparative analysis /kəmˈparətɪv əˈnalɪsɪs/ [n] ការវិភាគប្រៀបធៀប
- cost-benefit analysis /kɒst ˈbɛnɪfɪt əˈnalɪsɪs/ [n] ការវិភាគកំហាតបង់ និងប្រយោជន៍, ការវិភាគចំណាយចំណេញ (ការវិភាគទៅលើចំណាយ និងចំណូលដើម្បីចង់ដឹងថាចំណេញ ឬខាត)
- environmental analysis /ɪnvʌɪrənˈmɛnt(ə)l əˈnalɪsɪs/ [n] សូមមើលពាក្យ៖ environmental impact assessment
- ex-ante analysis /ɛks ˈanti əˈnalɪsɪs/ [n] ការវិភាគគម្រោងមុនពេលប្រតិបត្តិ (ការវិភាគលើការចំណាយទុនទាំងឡាយនៃដំណើរប្រព័ន្ធមួយ មុនពេលប្រព័ន្ធនោះចាប់ប្រតិបត្តិ)
- field analysis /fiːld əˈnalɪsɪs/ [n] ការវិភាគដល់កន្លែង
- gender analysis /ˈdʒɛndə əˈnalɪsɪs/ [n] ភេទវិភាគ (ការវិភាគទៅលើភេទ ហើយភ្ជាប់ទំនាក់ទំនងរបស់វាទៅនឹងការរស់នៅ)
- gravimetric analysis /ˌgravɪˈmɛtrɪk əˈnalɪsɪs/ [n] ការវិភាគដោយថ្លឹង
- immediate analysis /ɪˈmiːdɪət əˈnalɪsɪs/ [n] ការវិភាគភ្លាម, វិភាគបន្ទាន់
- mechanical analysis /mɪˈkanɪk(ə)l əˈnalɪsɪs/ [n] (សទិសន័យ៖ particle size analysis) ការវិភាគយន្តសាស្ត្រ, ការវិភាគមើលទំហំគ្រាប់ដី
- noise analysis /nɔɪz əˈnalɪsɪs/ [n] ការវិភាគសូរ
- observational analysis /ɒbzəˈveɪʃ(ə)n(ə)l əˈnalɪsɪs/ [n] ការវិភាគដោយសង្កេតពិនិត្យ
- particle size analysis /ˈpɑːtɪk(ə)l sʌɪz əˈnalɪsɪs/ [n] សូមមើលពាក្យ៖ mechanical analysis
- physical analysis /ˈfɪzɪk(ə)l əˈnalɪsɪs/ [n] ការវិភាគរូប
- qualitative analysis /ˈkwɒlɪtətɪv əˈnalɪsɪs/ [n] ការវិភាគគុណភាព
- quantitative analysis /ˈkwɒntɪtətɪv əˈnalɪsɪs/ [n] ការវិភាគបែបបរិមាណ
- rapid analysis /ˈrapɪd əˈnalɪsɪs/ [n] ការវិភាគភ្លាមៗ

- risk analysis /rɪsk əˈnalɪsɪs/ [n] ការវិភាគពីហានិភ័យ (វិធីសាស្ត្រដើម្បីធ្វើការវិភាគពីហានិភ័យដ៏មានសក្តានុពល និងការវាយតម្លៃចំពោះលក្ខខណ្ឌ ដែលមានស្រាប់នៃភាពងាយរងគ្រោះ ដែលជាមួយគ្នានេះអាចនឹងធ្វើឱ្យអន្តរាយយ៉ាងខ្លាំងក្លាទៅលើប្រជាជនដែលប្រឈមនឹងវាទ្រព្យសម្បត្តិ សេវាកម្មជីវភាពរស់នៅ និងបរិស្ថានដែលពួកគេអាស្រ័យទៅលើវា)
- sample analysis /ˈsɑːmp(ə)l əˈnalɪsɪs/ [n] ការវិភាគសំណាក
- sedimentation analysis /sɛdɪmɛnˈteɪʃ(ə)n əˈnalɪsɪs/ [n] ការវិភាគយន្តសាស្ត្រដោយអវសាទកម្ម (ដាក់ក្នុងទឹកឱ្យធ្លាក់បន្តិចម្តងៗ)
- statistical analysis /stəˈtɪstɪk(ə)l əˈnalɪsɪs/ [n] ការវិភាគស្ថិតិ
- textural analysis /ˈtɛkstʃərəl əˈnalɪsɪs/ [n] ការវិភាគវាយនភាពដី
- water analysis /ˈwɔːtə əˈnalɪsɪs/ [n] ការវិភាគទឹក

**analysis of variance (ANOVA)** /əˈnalɪsɪs (ə)v ˈvɛːrɪəns/ [n] ការវិភាគវារីយ៉ង់ (ដំណើរការវិភាគដើម្បីបញ្ជាក់អំពីភាពខុសគ្នានៃបច្ច័យ ឬសារ)

**analyst** /ˈan(ə)lɪst/ [n] អ្នកវិភាគ

**anamniote** /anˈamniˌoʊt/ [n] គ្មានថង់ទឹកភ្លោះ

**anamorph** /ˈɑːnəmɔːf/ [n] អាណាម័ហ្វ (ដំណាក់កាលមិនបន្តពូជដោយភេទរបស់ផ្សិត, ទម្រង់គ្មានភេទរបស់ផ្សិត ផ្ទុយគ្នាជាមួយតេលេអូម័ហ្វ)

***Ananas sativus*** [sci.n] សូមមើលពាក្យ៖ pineapple

**anandrous** /əˈnan drəs/ [adj] (ចំពោះផ្កា) គ្មានកញ្ចុំកេសរឈ្មោល

**anaphylactic shock** /ˌanəfɪˈlaktɪk ʃɒk/ [n] ការប្រតិកម្មខ្លាំងដោយវត្ថុធាតុម៉្យាង (ដូចជាថ្នាំពេនិស៊ីលីន) ដែលអាចនាំឱ្យ ស្លាប់ក៏មាន

**anaphylaxis** /ˌanəfɪˈlaksɪs/ [n] អាណាភីឡាក់ស៊ី

**anaplasmosis** /əˌnapləsməʊsɪs/ [n] អាណាប្លាស្មូល (ជំងឺ), ជំងឺបង្កឡើងដោយ Anaplasma

**anastomose** /əˈnastəməʊz/ [v] ភ្ជាប់បណ្តាញ

**anastomosis** /əˌnastəˈməʊsɪs/ [n] អាណាស្តូម៉ូស

**anatomy** /əˈnatəmi/ [n] កាយវិភាគវិទ្យា (វិទ្យាសាស្ត្រដែលសិក្សាអំពីរាងកាយ និងផ្នែកផ្សេងៗនៃរាងកាយមនុស្ស សត្វ ឬរុក្ខជាតិ)

***Anaxipha longipennis*** [sci.n] ចង្រិត

**ancestor** /ˈansɛstə/ [n] បុព្វករ (ឯកត្តៈដើមមួយដែលឯកត្តៈថ្មីមានប្រភពចេញពីវា, បុព្វជន/បុព្វបុរស (ចំពោះមនុស្ស), បុព្វសត្តករ (ចំពោះសត្វ), បុព្វរុក្ខករ (ចំពោះរុក្ខជាតិ))

**androecium** /anˈdriːsɪəm/ [n] (ពហុវចនៈ androecia) កញ្ចុំកេសរឈ្មោល (ជាពាក្យសមូហនាមដែលប្រើសំដៅទៅលើកេសរឈ្មោលទាំងអស់ដែលមាននៅក្នុងផ្កាមួយ។ ពាក្យផ្ទុយ Gynoecium (កញ្ចុំកេសរញី)។ )

**androgen** /ˈandrədʒ(ə)n/ [n] អ័រម៉ូនភេទឈ្មោល

**anemia** /əˈniːmɪə/ [n] កង្វះឈាមក្រហម, ការស្លេកស្លាំង

**anemochory** /əˈnɛm əˌkɔr i/ [n] ការពង្រាយគ្រាប់តាមខ្យល់

**anemometer** /ˌanɪˈmɒmɪtə/ [n] អាណេណូម៉ែត្រ, ឧបករណ៍វាស់ល្បឿនខ្យល់

**anencephalic** /ˌanɛnsɪˈfalɪk/ [adj] ដែលគ្មានលលាដ៍ និង ខួរក្បាល, ដែលទាក់ទងលលាដ៍និងខួរក្បាល

**anorexia nervosa** /ˌanəˈrɛksɪə nəːˈvəʊsə/ [n] ការអត់ឃ្លានអាហារប្លែកពីធម្មតាដោយព្រោះខ្លាចធាត់ដែលបណ្តាលឱ្យស្គមស្គាំង ឬខ្វះជីវជាតិ

**anesthesia** /ˌanɪsˈθiːzɪə/ [n] ភាពស្ពឹក, ការចាក់ថ្នាំសន្លប់ ឬសណ្តំ

**anesthetic** /ˌanɪsˈθɛtɪk/ [n] (សូមមើលពាក្យ៖ analgesic) ថ្នាំសម្រាប់ធ្វើឱ្យស្ពឹក ឬសណ្តំ

**anesthetize** /əˈniːsθətʌɪz/ [v] ធ្វើឱ្យស្ពឹក, ធ្វើឱ្យសណ្តំ

**aneuploidy** /ˈanjʊplɔɪdi/ [n] សារពាង្គកាយមានក្រូម៉ូសូមមិនធម្មតា (លក្ខខណ្ឌមួយដែលចំនួនក្រូម៉ូសូមទាំងអស់នៃសារពាង្គកាយមួយមិនមែនជាចំនួនតំឡើងទ្វេរនៃចំនួនអាប្លូ-អ៊ីតរបស់វា។ បញ្ហានេះកើតមានឡើងដោយការបំបែកក្រូម៉ូ-សូមខុសក្នុងដំណើរការមេយ៉ូស ដូច្នេះកាម៉េតមួយអាចនឹងខ្វះ ឬលើសក្រូម៉ូសូមចម្លងមួយ។)

**aneurysm** /ˈanjʊrɪz(ə)m/ [n] ពកអាទែ, ការប៉ោងសរសៃឈាមក្រហម, ប្រដាប់ធ្វើឱ្យរាវឈាម

**angiography** /ˌandʒɪˈɒgrəfi/ [n] ការពិនិត្យមើលសរសៃឈាម ដោយប្រើកម្មរស្មីអ៊ិក្ស

**angiology** /ˈandʒɪəʊlaugi/ [n] វិទ្យាសាស្ត្រខាងសរសៃឈាម

**angiosperm** /ˈandʒɪə(ʊ)spəːm/ [n] ពួករុក្ខជាតិមានផ្កា, ពួករុក្ខជាតិគ្រាប់ជិត, ចន្ទបុប្ផាណ្ឌរុក្ខជាតិ (ប្រភេទរុក្ខជាតិដែលគ្រាប់របស់វាស្ថិតក្នុងសាច់ផ្លែ)

**angled luffa** /ˈaŋg(ə)ld ˈluːfə/ [n] (សទិសន័យ៖ ridged gourd) ននោងជ្រុង (ឈ្មោះវិទ្យាសាស្ត្រ *Luffa acutangula*)

**angstrom** /ˈaŋstrəm/ [n] អង់ស្ត្រុម (ខ្នាតប្រវែង)

***Anguilla bicolor*** [sci.n] សូមមើលពាក្យ៖ shortfin eel

**angular gravelly** /ˈaŋgjʊlə ˈgrav(ə)li/ [adj] ដែលមានក្រួស (ក្រួសរឹងជ្រុងមុត)

**angustiseptate** [adj] អង់គូស្ទីសិបថេត (អំពីផ្លែឈើ ដែលមានសន្ទះខណ្ឌកាត់ទទឹងនៅត្រង់ចំណុចតូចបំផុត)

**anhydrase** /anˈhʌɪdreɪz/ [n] អានីដ្រាស (អង់ស៊ីមសម្រាប់ការបំបែកទឹកចេញពីសមាសធាតុណាមួយ)

**animal** /ˈanɪm(ə)l/ [n] សត្វ

- burrowing animal /ˈbʌrəʊɪŋ ˈanɪm(ə)l/ [n] សារពាង្គកាយ ឬសត្វកកាយដី
- colonial animal /kəˈləʊnɪəl ˈanɪm(ə)l/ [n] សត្វកូឡូនី (សមាគមន៍សត្វ ដែលឯកត្តៈទាំងអស់មានទំនាក់ទំនងរូបទៅវិញទៅមក ដូចជាក្នុងករណីអ៊ីដ្រូសូអ៊ែ និងប៉ូលីសូអ៊ែ ហើយគេមិនប្រើពាក្យជាមួយសត្វថ្នាក់ខ្ពស់ ដែលរស់នៅជាកូឡូនី ដូចជាបក្សីទេ)
- domestic animal /dəˈmɛstɪk ˈanɪm(ə)l/ [n] សត្វស្រុក, សត្វចិញ្ចឹម
- domesticated animal /dəˈmɛstɪkeɪtɪd ˈanɪm(ə)l/ [n] បសុសត្វ (សត្វដែលទទួលបានការបន្សាំង ឬសត្វដែលចិញ្ចឹម)
- draft animal /drɑːft ˈanɪm(ə)l/ [n] សត្វប្រើជាកម្លាំងអូសទាញ, សត្វអូសទាញ (សត្វដែលយកមកប្រើធ្វើជាកម្លាំងអូសទាញក្នុងការភ្ជួររាស់ដី)
- male animal /meɪl ˈanɪm(ə)l/ [n] សត្វឈ្មោល

**anion** /ˈanʌɪən/ [n] អាញ៉ុង (អ៊ីយ៉ុងដែលមានបន្ទុកអគ្គិសនីអវិជ្ជមាន)

**aniso-** /ˈɑːni/ [prefix] បុព្វបទមានន័យថា ខុសគ្នា, មិនស្មើគ្នា

**anisogamy** /ˌanʌɪˈsɒgəmi/ [n] អានីសូកាមី (ភាពដែលកាម៉េតឈ្មោល និងកាម៉េតញីមានលក្ខណៈខុសគ្នា ផ្ទុយពីអ៊ីសូកាម៉េត្រ)

**ankle** /ˈaŋk(ə)l/ [n] កជើង, ខ្នងជើង

**ankylosis** /ˌaŋkɪˈləʊsɪs/ [n] សន្លាក់រឹង

**ankylostoma** /ˌaŋkɪˈləʊstˈstəʊmə/ [n] កង្វះឈាមក្រហមដោយអង់គីឡូស្តូម

**ankylostome** [n] ព្រូនតូចម៉្យាង មានខ្លួនមូល រាងកោងដូចទំពក់ចូលតាមស្បែក ជាពិសេសតាមបាតជើងកាលណាដើរជើងទទេ

**annealing** /əˈniːlɪŋ/ [n] អ៊ីប្រ៊ីតកម្មម៉ូលេគុល

***Annona muricata*** [sci.n] សូមមើលពាក្យ៖ soursop

***Annona squamosa*** [sci.n] សូមមើលពាក្យ៖ custard apple

**annual** /ˈanjʊəl/ [adj] ប្រចាំឆ្នាំ, ដែលមានជារៀងរាល់ឆ្នាំ

- annual allowable cut /ˈanjʊəl əˈlaʊəbl kʌt/ [n] សិទ្ធិកាប់ប្រចាំឆ្នាំ (បរិមាណឈើហ៊ុប ដែលអនុញ្ញាតឱ្យ កាប់ជាប្រចាំឆ្នាំនៅក្នុងតំបន់ជាក់លាក់ណាមួយ។ ACC ត្រូវបានប្រើប្រាស់សម្រាប់ជាច្បាប់ក្នុងការ ប្រមូលផលប្រៃឈើដើម្បីធានា នូវការផ្គត់ផ្គង់ឈើប្រកបដោយនិរន្តរ៍ភាព។)
- annual weed /ˈanjʊəl wiːd/ [n] ឯកវត្សរស្មៅ (ស្មៅដែលបញ្ចប់វដ្តជីវិតរបស់ខ្លួនក្នុងមួយឆ្នាំ ឬតិចជាង)

**annulation** /anjʊˈleɪʃ(ə)n/ [n] ការខណ្ឌជាកង់ (ការបែងចែកដងខ្លួនដែលមានរាងដូចជាដង្កូវជាស៊េរីកងខាងក្រៅ)

**annulus** /ˈanjʊləs/ [n]

១. ថ្មេរ (វង់កោសិកាក្នុងកាប់ស៊ុបរបស់ស្លែ ឬរបស់បណ្ណង្គជាតិ ដែលបែកដើម្បីបញ្ចេញស្ប៉ូ)

២. វណ្ឌ (វង់ជាលិកានៅព័ទ្ធជុំវិញទងម្ជូករបស់ផ្សិតបាស៊ីដ្យូមីកូតា)

**anode** /ˈanəʊd/ [n] អាណូត (អេឡិចត្រូតបន្ទុកអវិជ្ជមានដែលអ៊ីយ៉ុងអវិជ្ជមានមានរំកិលទៅរក)

***Anodontostoma chacunda*** [sci.n] សូមមើលពាក្យ៖ chacunda gizzard shad

***Anodontostoma thailandae*** [sci.n] សូមមើលពាក្យ៖ Thai gizzard shad

**anom-** [prefix] (សទិសន័យ៖ anomo-) បុព្វបទមានន័យ ថា មិនស្មើ ឬមិនទៀងទាត់

**anomaly** /əˈnɒm(ə)li/ [n] ភាពមិនប្រក្រតី, ភាពមិនធម្មតា

***Anomis* sp.** [sci.n] សណ្ដានដង្កូវបាក់ខ្នង

**anomo-** [prefix] សូមមើលពាក្យ៖ anom-

**anonymous** /əˈnɒnɪməs/ [adj] អណាមិក

**anopheles** /əˈnɒfɪliːz/ [n] មូសដែកគោល

***Anoplocnemis phasiana*** [sci.n] ស្រឹងជញ្ជក់ផ្លែសណ្ដែក

**anoplura** /ˌanə(ʊ)ˈplʊərə/ [n] ក្រុមចៃជញ្ជក់ឈាម

**anorexia** /ˌanəˈrɛksɪə/ [n] កង្វះចម្ងាញ់ (ការបាត់បង់ចំនង់បរិភោគអាហារ)

**anoxia** /aˈnɒksɪə/ [n] អាណុកស៊ី, ខ្វះអុកស៊ីសែន, អ៊ីប៉ុកស៊ី

**anoxygenic** /ˈɒk sɪ dʒənɪk/ [adj] គ្មានផលិតអុកស៊ីសែន

**ant** /ant/ [n] ស្រមោច, ស្រមោចភ្លើង (ឈ្មោះវិទ្យាសាស្ត្រ *Solenopsis geminata*)

- red ant /rɛd ant/ [n] ស្រមោចក្រហម

**antacid** /anˈtasɪd/ [n] អង់ទីអាស៊ីត

**antacid** /anˈtasɪd/ [adj] ដែលគ្មានជាតិជូរ (គ្មានអាស៊ីត)

**antagonism** /anˈtag(ə)nɪz(ə)m/ [n] បដិបក្ខភាព, ភាពផ្ទុយគ្នា, អន្តរអំពើបន្សាបគ្នា, ភាពផ្ទុយគ្នារវាងសាច់ដុំមួយចំនួន

- pollutants antagonism /pəˈl(j)uːt(ə)nts anˈtag(ə)nɪz(ə)m/ [n] អន្តរអំពើបន្សាបគ្នារបស់សារធាតុពុល

**antagonistic pair** /anˌtag(ə)ˈnɪstɪk pɛː/ [n] គូបដិបក្ខ

**antagonistic effect** /anˌtag(ə)ˈnɪstɪkɪˈfɛkt/ [n] ផលបន្សាប

**ante-** /ˈanti/ [prefix] (សទិសន័យ៖ before, in front of) បុព្វបទមានន័យ ពីមុខ, នៅខាងមុខ

**ante cibum** /ˈanti ˈsiːbəm/ [n] មុនពេលអាហារ

**anteater** /ˈantiːtə/ [n] សត្វស៊ីស្រមោច

**antenna** /anˈtɛnə/ [n] (ពហុវចនៈ៖ antennae)

១. ពុកប្រមោយ, អង់តែន (ផ្នែកមួយនៃសរីរាង្គដែលមានចលនា (ផ្សំឡើងពីកង់ៗ) របស់សត្វល្អិត ដែលជាធម្មតាមានមួយគូស្ថិតនៅលើក្បាលរបស់វា ហើយមានតួនាទី)

២. អង់តែន (ខ្នែងវិញ្ញាណរបស់អាកត្រូប៉ូតដែលមានថ្នាំង) សម្រាប់ប៉ះផ្ទាល់ជាមួយនឹងវត្ថុ និងសម្រាប់ដឹងនូវរសជាតិនៃវត្ថុនោះ)

**antennule** /anˈtɛnjuːl/ [n] អង់តែនមុខ

**antepartum** /antɪˈpɑːtəm/ [adj] មុនពេលកើត, ការកើតហេតុនៅមុនពេល ឬនៅពេលសម្រាលកូន

**anterior** /anˈtɪərɪə/ [adj] ខាងមុខ, (ចំពោះរុក្ខជាតិ) ផ្នែករបស់ផ្កា ដែលស្ថិតនៅឆ្ងាយជាងគេបង្អស់ពីទង

**antesepalous** [adj] ឈមនឹងត្របកផ្កា (ផ្នែករបស់រុក្ខជាតិ)

**anthelmintic** /ˌanθ(ə)lˈmɪntɪk/ [n] ថ្នាំដង្កូវបរាសិត

**anther** /ˈanθə/ [n] កញ្ចុំលម្អង, ថ្លោកលម្អង, ថង់លម្អង (ផ្នែកមួយនៃកេសរឈ្មោល ដែលក្នុងនោះមានពេញទៅដោយលម្អង)

**antheridiophore** [n] អង់តេរីដ្យូផរ (ទងផ្ទុកអង់តេរីឌីនៃរុក្ខជាតិអេប៉ាទិចមួយចំនួន)

**antheridium** /ˌanθəˈrɪdɪəm/ [n] (ពហុវចនៈ៖ antheridia) អង់តេរីដ្យូម (ទម្រង់ផលិតស្ពែម៉ាតូសូអ៊ីតរបស់រុក្ខជាតិមួយចំនួន)

**antherozoid** /ˌanθ(ə)rə(ʊ)ˈzəʊɪd/ [n] អង់តេរ៉ូសូអ៊ីត (ស្ពែម៉ាតូសូអ៊ីត)

**anthesis** /anˈθiːsɪs/ [n] ដំណាក់កាលនៃផ្ការីក, ផ្ការីក, រយៈពេលចាប់ពីពេលចេញផ្កា រហូតដល់ចាប់ផ្ដើមកកើតផ្លែ, បុប្ផាណកម្ម (ដំណើរការចេញផ្កា ជាពេលដែលលម្អងទុំបែកអាចនឹងធ្វើឱ្យមានពហុពលកម្មជាមួយនឹងកេសរញី)

**antho-** /ˈanθəʊ/ [prefix] បុព្វបទមានន័យថា កញ្ចុំផ្កា, ត្រួយពន្លក

***Anthocephalus indicus*** [sci.n] ថ្កូវ

**anthocyan** /ˈanθəʊˈsʌɪən/ [n] អង់តូស្យាន (ជាតិពណ៌សំខាន់នៃផ្នែករុក្ខជាតិ មានពណ៌ខៀវ និងក្រហម ឧ.ផ្លែ ផ្កា)

**anthocyanescence** [n] ការឡើងពណ៌ស្វាយលើស្លឹករុក្ខជាតិ

**anthocyanin pigment** /ˌanθə(ʊ)ˈsʌɪənɪn ˈpɪgm(ə)nt/ [n] ជាតិពណ៌អង់តូស៊ីនីន

**anthoxanthins** [n] អង់តូសង់ទីន (ជាតិពណ៌ដែលមានចាប់ពីពណ៌សស្រអាប់ ទៅលឿងចាស់។ ជាតិពណ៌នេះមានទាំងផ្កា និងសត្វល្អិត។ សត្វល្អិតស្រូបយកពណ៌នេះពីរុក្ខជាតិដែលវាស៊ី)

***Anthozoa* spp.** [sci.n] សណ្ដានផ្កាថ្ម

**anthracite** /ˈanθrəsʌɪt/ [n] អង់ត្រាស៊ីត

**anthracnose** /anˈθraknəʊs/ [n] ជំងឺអុចស្លឹក (បង្កដោយផ្សិត *Colletotrichun lagenarium*), ជំងឺអុចមូលលើផ្លែ (កើតលើម្ទេស)

**anthrax** /ˈanθraks/ [n] ជំងឺអង់ត្រាក់, ជំងឺឈាមខ្មៅ (គ្រុនផាលមានចំពោះសត្វពាហនៈ និងចៀម បង្កដោយជាតិពុលបង្ករបស់បាក់តេរី *Bacillus anthracis*។ ជំងឺនេះអាចឆ្លងមកមនុស្សបាននៅពេលមានការប៉ះផលិតផលរបស់សត្វឈឺ ដូចជារោម ដោយបង្កឱ្យមានដំបៅស្បែក និងពងខ្ទុះអាចបណ្ដាលឱ្យស្លាប់បាន)

**anthropo-** /ˈanθrəpəʊ/ [prefix] បុព្វបទមានន័យថាមនុស្ស

**anthropogenesis** /ˈanθrəpəʊˈdʒɛnɪsɪs/ [n] ការវិវឌ្ឍរបស់មនុស្ស

**anthropology** /ˌanθrəˈpɒlədʒi/ [n] មនុស្សជាតិវិទ្យា, នរវិទ្យា (វិជ្ជាទាក់ទងនឹងការវិវត្តន៍នៃមនុស្ស)

**anthropometry** /ˌanθrəˈpɒmɪtri/ [n] នរមាត្រ, មនុស្សមាត្រ (ជាការវាស់វែងផ្ទៃករាងកាយនូវទំហំ ទម្ងន់ កម្ពស់ និងសមាមាត្រនៃរាងកាយរបស់មនុស្ស។ មនុស្សមាត្រ គឺជាដំណើរការមួយដែលចាំបាច់សម្រាប់ធ្វើការអង្កេតពីអាហារូបត្ថម្ភឱ្យបានត្រឹមត្រូវតែតខ្វះ ចំពោះការធ្វើតេស្តរង្វាស់ជុំវិញពាក់កណ្ដាលដើមដៃ (MUAC) គឺត្រូវបានគេប្រើជាញឹកញាប់តែទោះជាយ៉ាងណាក៏ដោយ ក៏ការប្រមូលទិន្នន័យពីកម្ពស់ ទម្ងន់ និងអាយុរបស់បុគ្គលម្នាក់ៗទាំងអស់ត្រូវបានប្រើប្រាស់ជាទូទៅផងដែរ។ ញឹកញាប់បំផុតនោះ កុមារអាយុ៥ឆ្នាំ និងស្ត្រីក្នុងវ័យបន្តពូជ (តាមការពីការប៉ាន់ស្មានអាយុ ១៥ ដល់ ៤៩ឆ្នាំ) ត្រូវបានវាស់វែងដោយប្រើរង្វាស់មនុស្សមាត្រ។)

**anti-** /ˈanti/ [prefix] (សទិសន័យ៖ opposed to, opposite) ប្រឆាំង, ផ្ទុយពី

**antiauxin** /ˈantiˈɔːksɪn/ [n] អង់ទីអុកស៊ីន (សារធាតុទាំងឡាយណា ដែលបង្អាក់សកម្មភាពអុកស៊ីន)

**antibiosis** /ˌantɪbʌɪˈəʊsɪs/ [n] បដិបក្ខប្រាណ (ភាពប្រឆាំងគ្នារវាងសារពាង្គកាយរស់ទាំងឡាយដែលនៅក្នុងនោះរុក្ខជាតិជម្រកមានឥទ្ធិពលអាក្រក់លើការលូតលាស់របស់សត្វល្អិតមួយពួក)

**antibiotic** /ˌantɪbʌɪˈɒtɪk/ [n] អង់ទីប្យូទិច (សារធាតុផលិតនៅក្នុងភាវរស់ដែលបង្អាក់ការលូតលាស់ ឬបំផ្លាញបាក់តេរី និងអតិសុខុមប្រាណផ្សេង)

**antibody** /ˈantɪbɒdi/ [n] អង់ទីករ (ប្រូតេអ៊ីនអ៊ីមម្យូណូគ្លូប៊ុយលីន ដែលផលិតក្នុងការឆ្លើយតបទៅនឹងការភ្ញោចរបស់អង់ទីសែនជាមួយនឹងសមត្ថភាពដែលអាចភ្ជាប់យ៉ាងពិសេសទៅនឹងអង់ទីសែន។ កុំផ្លិចទាំងនេះត្រូវបានចាប់ និងត្រូវបានបំផ្លាញយ៉ាងងាយដោយកោសិកានៃប្រព័ន្ធភាពស៊ាំ។)

**anticlinal** /antɪˈklʌɪn(ə)l/ [adj] អង់ទីគ្លីណាល់ ((អំពីចំណែកកោសិការុក្ខជាតិ) តាមបណ្ដោយប្លង់ចាប់ពីមុំខាងស្ដាំរហូតដល់ផ្ទៃខាងក្រៅ)

**anticoagulant** /ˌantɪkəʊˈagjʊl(ə)nt/ [n]

១. សារធាតុប្រឆាំងកំណកឈាម, ធាតុបង្ការកក

២. ថ្នាំពុលមិនធ្វើឱ្យឈាមកក (ថ្នាំគីមីម្យ៉ាងប្រើសម្រាប់កម្ចាត់កណ្ដុរដែលធ្វើឱ្យកណ្ដុរហូរឈាមរហូតដល់ស្លាប់ក្រោយពេលស៊ី)

**anticyclone** /antɪˈsʌɪkləʊn/ [n] អង់ទីស៊ីក្លូន, មណ្ឌលសម្ពាធខ្លាំង

***Antidesma ghaesembilla*** [sci.n] ដង្កៀបក្ដាម

**antidote** /ˈantɪdəʊt/ [n] ថ្នាំបន្សាបពិសពុល (ថ្នាំបន្សាបជាតិពុលនៃថ្នាំកម្ចាត់សត្វល្អិត)

**antifeedant** /ˌantɪˈfiːdant/ [n] ថ្នាំគីមីការពារសត្វល្អិតស៊ីបំផ្លាញដំណាំ

**antifungal** /antɪˈfʌŋg(ə)l/ [n] ថ្នាំបំផ្លាញផ្សិត, ថ្នាំសម្លាប់ផ្សិត

***Antigastra catalaunalis*** [sci.n] ដង្កូវមូរស្លឹកល្ង

**antigen** /ˈantɪdʒ(ə)n/ [n] អង់ទីសែន, ម៉ូលេគុលចំឡែកធំៗដែលស្ថិតនៅក្នុងសារពាង្គកាយ (ភាគច្រើនជាប្រូតេអ៊ីនលើផ្ទៃកោសិកា ឬកាបូនអ៊ីត្រាត) ដែលបណ្ដាលឱ្យមានចម្លើយតបមួយពីប្រព័ន្ធការពារដែលរួមមានការបង្កើតអង់ទីករ

**antihelminthic** /ˈantihɛlˈmɪnθɪk/ [n] ថ្នាំទម្លាក់ដង្កូវបរាសិត

**antihistamine** /antɪˈhɪstəmiːn/ [n] អង់ទីអ៊ីស្តាមីន (សារធាតុប្រឆាំងនឹងឥទ្ធិពលរបស់អ៊ីស្តាមីនលើសារពាង្គកាយ)

**Antimony** /ˈantɪməni/ [n] អង់ទីម៉ាន់ (និមិត្តសញ្ញាគីមី Sb)

**antiport** /ˈantipɔːt/ [n] ដំណឹកនាំច្រាសទឹក

**antipruritic** /ˌantɪprʊˈrɪtɪk/ [adj] ការពារ ឬធ្វើឱ្យបាត់រមាស់, ថ្នាំបំបាត់រមាស់

**antiseptic** /antɪˈsɛptɪk/ [n] ថ្នាំសម្លាប់មីក្រុប

**antiserum** /ˈantɪˌsɪərəm/ [n] អង់ទីសេរ៉ូម (សេរ៉ូមឈាមប្រឆាំងនឹងជំងឺណាមួយ)

**antisporulant** [n] ថ្នាំបង្អាក់ការផលិតស្ប៉ូរ

**antitoxin** /antɪˈtɒksɪn/ [n] អង់ទីតុកស៊ីន, ប្រឆាំងជាតិពុល (ប្រភេទអង់ទីករ ដែលបន្សាបជាតិពុល)

**antivenom** /ˌantɪˈvɛnəm/ [n] ថ្នាំប្រឆាំងនឹងពិសសត្វ

**antrum** /ˈantrəm/ [n] ប្រហោងក្នុងឆ្អឹង, ប្រហោងមុខទ្វារក្រោម, បន្ទប់ ឬផតជិតនឹងបិទ ជាពិសេសនៅក្នុងឆ្អឹង, ភាគនៃក្រពះជាប់នឹងពោះវៀនតូច

**anucleate** /ɪˈnjuːklɪeɪt/ [adj] គ្មានណ្វៃយ៉ូ

**anuria** /əˈnjʊərɪə/ [n] ទាស់នោម, អមូត្រភាព (ការដែលវក្កមិនបញ្ចេញទឹក នោម)

**anus** /ˈeɪnəs/ [n] រន្ធគូទ, ទ្វារធំ, ទ្វារលាមក

**anxiety** /aŋˈzʌɪəti/ [n] ការភ័យបារម្ភ, កង្វល់, អន្ទះអន្ទែង

**aorta** /eɪˈɔːtə/ [n] អាអក, សរសៃនាំឈាមចេញពីបេះដូងទៅសួត, សរសៃឈាមក្រហមធំកោង

**ap-** /əp/ [prefix] (ដូច៖ aph-, apo-) បុព្វបទមានន័យថាឃ្លាតពី

***Apanteles angustibasis*** [sci.n] (សទិសន័យ៖ *Cotesia angustibasis* ) ពួកឪម៉ាល់ (បរាសិតលើដង្កូវ)

***Apanteles flavipes*** [sci.n] (សទិសន័យ៖ *Cotesia flavipes* ) ពួកឪម៉ាល់ (បរាសិតលើដង្កូវមូរស្លឹក)

**aperture** /ˈapətj(ʊ)ə/ [n] ប្រហោងចំហ, រន្ធចំហ

**apetalous** /eɪˈpɛt(ə)ləs/ [adj] គ្មានស្រទាប់ផ្កា

**apex** /ˈeɪpɛks/ [n]

១. កំពូល (ចុងបេះដូង)

២. (ចំពោះរុក្ខជាតិ) ចុង, កំពូល (ផ្នែកចុងកំពូលដែលនៅចុងវត្ថុអ្វីមួយ។ ចំពោះពន្លកត្រួយ និងឫស ចុងរបស់វាមានផ្ទុកកោសិកាដុះលូតលាស់ បង្កើត ជាលិកាថ្មី (apical meristem)។)

**apex beat** /ˈeɪpɛks biːt/ [n] ស្នូរចលនាបេះដូងនៅចុងដង្ហើម

**aph-** [prefix] សូមមើលពាក្យ៖ ap-

**aphan-** [prefix] បុព្វបទមានន័យថា ស្រអាប់, ងងឹត, មិនច្បាស់

**aphid** /ˈeɪfɪd/ [n] ចៃជញ្ជក់រុក្ខរស

***Aphis craccivora*** [sci.n] ចៃសណ្ដែក

***Aphis glycines*** [sci.n] ចៃសណ្ដែកសៀង

**aphotic** /əˈfɛtɪk/ [adj] គ្មានពន្លឺ

**aphyllous** /eɪˈfɪl əs/ [adj] គ្មានស្លឹក

**apiary** /ˈeɪpɪəri/ [n] សម្បុកឃ្មុំចិញ្ចឹម

**apical** /ˈeɪpɪk(ə)l/ [adj] នៃកំពូល, នៃចុង, ចុង, ខាងចុង, នៅខាងចុង

**apical dominance** /ˈeɪpɪk(ə)l ˈdɒmɪnəns/ [n] ពន្លកលុប, លុបកំពូល (ការថយចុះនូវការលូតលាស់ពន្លកមែកបណ្ដាលមកពីវត្តមាននៃពន្លកត្រួយ)

**apical region** /ˈeɪpɪk(ə)l ˈriːdʒ(ə)n/ [n] តំបន់ក្បាលឫស, តំបន់ត្រួយ

**apiculture** /ˈeɪpɪˌkʌltʃə/ [n] ការចិញ្ចឹមឃ្មុំ

**apiculus** /əˈpɪk yə ləs/ [n] ចុងនៃគ្រាប់ស្រូវ (ផ្នែកមួយនៃគ្រាប់ស្រូវដែលអាចមានរាង និងពណ៌ខុសគ្នាពីពូជមួយទៅពូជមួយទៀត)

***Apis cerana*** [sci.n] សូមមើលពាក្យ៖ *Apis dorsata*

***Apis dorsata*** [sci.n] (សទិសន័យ៖ *Apis cerana*, *Apis florea*) សត្វឃ្មុំព្រៃ

***Apis florea*** [sci.n] សូមមើលពាក្យ៖ *Apis dorsata*

***Apium graveolens*** [sci.n] សូមមើលពាក្យ៖ Chinese celery

**aplanospore** /aplanəʊ spɔː/ [n] អឺប្លែនណូស្ប៉ូរ, ស្ប៉ូរអភេទគ្មានចលនា (ដែលមានចំពោះសារាយ និងផ្សិតមួយចំនួន)

**aplastic** /əˈplastɪk/ [adj] ក្រិន, មិនលូតលាស់

***Aplocheilus panchax*** [sci.n] សូមមើលពាក្យ៖ blue panchax

**apnea** /apˈniːə/ [n] អំណាត់ដង្ហើម

**apneustic** /æpˈnu stɪk/ [adj] គ្មានរន្ធដង្ហើម, រន្ធដង្ហើមបិទ

**apnoea** /apˈniːə/ [n] ការអត់ដង្ហើម

**apo-** /ˈapəʊ/ [prefix] សូមមើលពាក្យ៖ ap-

**apocarpous** /ˌapəˈkɑːpəs/ [adj] មានកាប៉ែលមិនជាប់គ្នា (អំពីផ្ការបស់រុក្ខជាតិ)

**apocarpy** /ˌap əˈkɑr pəs/ [n] កេសរញីរលាយជាប់គ្នាបន្តិច, អូវែរលាយជាប់គ្នាបន្តិច (ប្រភេទនៃកេសរញីសមាស) (ដែលមានកេសរញីដាច់ពីគ្នា និងជាប់គ្នាដោយផ្នែក។ ជាធម្មតា កេសរញីសមាសបង្កើតឱ្យទៅជាប្រភេទផ្លែចង្កោម ឧ. Magnolia និង Manglietia។)

**apodous** /ˈapədəs/ [adj] ដែលគ្មានអវយវៈ

**apollo sharkminnow** /əˈpɒl oʊ ʃɑːk ˈmɪnəʊ/ [n] ត្រីចង្វានោង, ត្រីដងដាវ (ឈ្មោះវិទ្យាសាស្ត្រ *Luciosoma setigerum*)

**apomixis** /ˌapəˈmɪksɪs/ [n] អាប៉ូមីស៊ីស, ការបន្តពូជគ្មានភេទ, ការបន្តពូជគ្មានការបង្កកំណើត (ការផលិតគ្រាប់ពូជដោយគ្មានការបង្កកំណើតជាមុន។ ជារឿយៗ គេប្រើពាក្យនេះសំដៅទៅលើការផលិតគ្រាប់ដែលមិនបានទទួលការបង្កកំណើត។ អាស្រ័យទៅតាមប្រភេទនៃអាប៉ូមីស៊ីស ជាធម្មតា សរីរាង្គដែលផលិតពីការបន្តពូជគ្មានភេទមានលក្ខណៈដូចគ្នាសុទ្ធសាធខាងសេនេទិច ដូចនឹងប្រភពដើមរបស់វា (ortet-ដើមមេសម្រាប់ផលិតកូនក្លូន)។)

**apomorphic** /əˈpɒmɔːfɪk/ [adj] នៃលក្ខណៈប្រែប្រួល

**apparatus** /ˌapəˈreɪtəs/ [n] គ្រឿងឧបករណ៍

- egg apparatus /ɛg ˌapəˈreɪtəs/ [n] ធាតុបង្ករបស់កាម៉េតញី

**appearance** /əˈpɪər(ə)ns/ [n] អាការក្រៅ, លក្ខណៈរូបរាង

- physical appearance /ˈfɪzɪk(ə)l əˈpɪər(ə)ns/ [n] លក្ខណៈរូបរាង, កាយសម្បទា

**appeasement display** /əˈpiːzm(ə)nt dɪˈspleɪ/ [n] អាកប្បកិរិយាញ៉ម

**appendage** /əˈpɛndɪdʒ/ [n] ខ្នែង

**appendectomy** /ˌap(ə)nˈdɛktəmi/ [n] ការវះកាត់យកខ្នែងពោះវៀន

**appendicularia** /ˌap(ə)nˈdɪkjʊlə/ [n] (សទិសន័យ៖ tadpole larva) កូនក្អុក

**appendix** /əˈpɛndɪks/ [n]

១. ខ្នែងពោះវៀន

២. ផ្នែក (គ្រឿង) បន្ថែម, បរិសិដ្ឋ (អ្វីដែលគេដាក់ភ្ជាប់នៅពីខាងក្រោយអ្វីមួយទៀត)

**appetite** /ˈapɪtʌɪt/ [n] សេចក្ដីឃ្លាន, ចំណង់បរិភោគអាហារ, ចំណង់ស៊ី

**apple** /ˈap(ə)l/ [n] ផ្លែប៉ោម

**application** /aplɪˈkeɪʃ(ə)n/ [n] ការអនុវត្តន៍, ការបាច (ជី), ការបាញ់ (ថ្នាំ)

- basal application /ˈbeɪs(ə)l aplɪˈkeɪʃ(ə)n/ [n] ជីទ្រាប់បាត (ការបាចជីក្នុងវាលស្រែមុនពេលដាំ)
- fertilizer application /ˈfəːtɪlʌɪzə aplɪˈkeɪʃ(ə)n/ [n] ការដាក់ជី, ការបាចជី

**applied biological insect control** /əˈplʌɪd bʌɪə(ʊ)ˈlɒdʒɪk(ə)l ɪnsɛkt kənˈtrəʊl/ [n] វិធានការកម្ចាត់សត្វល្អិតតាមបែបជីវសាស្ត្រ (នេះជាការប្រើសត្វមានប្រយោជន៍ ឬសត្រូវធម្មជាតិឱ្យបំផ្លាញសត្វល្អិតចង្រៃ)

**apply** /əˈplʌɪ/ [v] ដាក់, លាប, ផ្ទឹប, អនុវត្ត, រុំ, បាច, បាញ់

**apposition** /apəˈzɪʃ(ə)n/ [n] កំណើនកម្រាស់ភ្នាសគ្រោង

**apprentice** /əˈprɛntɪs/ [n] កូនជាង

**apprenticeship** /əˈprɛntɪ(s)ʃɪp/ [n] ពេលរៀនជំនាញ, កម្មសិក្សា

**appressed** /əˈprɛst/ [adj] ប្រកិតគ្នា

**approach** /əˈprəʊtʃ/ [n] អភិក្រម, កត្តវិធី, វិធីដោះស្រាយ (របៀបដោះស្រាយបញ្ហាអ្វីមួយ)

- ecosystem approach /ˈiːkəʊsɪstəm əˈprəʊtʃ/ [n] អភិក្រមប្រព័ន្ធបរិស្ថាន (ជាយុទ្ធសាស្ត្រសម្រាប់ការគ្រប់គ្រងលើដីធ្លី ទឹក និងធនធានដែលមានជីវិត ដែលជម្រុញការអភិរក្ស និងការប្រើប្រាស់ដោយនិរន្តភាពប្រកបដោយសមធម៌)

- integrated food chain approach [n] សមាហរណកម្មយុទ្ធវិធីខ្សែសង្វាក់ស្បៀង (ជាយុទ្ធវិធីមួយសម្រាប់ផលិតកម្មស្បៀងដែលត្រូវធ្វើការពិនិត្យពិចារណាពីទំនាក់ទំនងនីមួយៗ ឬគ្រប់ទំនាក់ទំនងទាំងអស់ទៅនឹងដំណើរការផលិតស្បៀងដែលនឹងធ្លាក់ទៅដល់ដៃអ្នកប្រើប្រាស់ ឬអ្នកបរិភោគចាប់ពីរបៀបដែលស្បៀងត្រូវបានដាំដុះ ឬចិញ្ចឹមរហូតទៅដល់របៀបដែលស្បៀត្រូវបានគេធ្វើការប្រមូលផលទុកដាក់ កែច្នៃ វេចខ្ចប់ ចេញលក់ និងប្រើប្រាស់ ឬបរិភោគ។ អ្នកពាក់ព័ន្ធរួមមានអ្នកផ្គត់ផ្គង់ ផ្នែកធាតុចូលកសិករ អ្នកកែច្នៃស្បៀង អ្នកដឹកជញ្ជូន អ្នកចែកចាយ (រួមទាំងអ្នកលក់ដុំ និងអ្នកលក់រាយ) និងអ្នកប្រើប្រាស់ ឬអ្នកបរិភោគព្រមទាំង រដ្ឋាភិបាលទាំងអស់ដែលមានកតព្វកិច្ចត្រូវការពារសុខភាពសាធារណៈ។ តែទោះជាយ៉ាងណាក៏ដោយជារឿយៗវាត្រូវបានគេប្រើនៅក្នុងបរិបទនៃផលប្រយោជន៍ផ្នែកអនាម័យ និងសុវត្ថិភាពស្បៀង យុទ្ធវិធីខ្សែសង្វាក់ស្បៀង ក៏អាចធ្វើឱ្យប្រសើរឡើងនូវមាត្រដ្ឋានសេដ្ឋកិច្ច គាំទ្រដល់ការធ្វើសមាហរណកម្មទៅតាមខ្សែបន្ទាត់ផ្គត់ផ្គង់ តាមខ្សែបណ្ដោយ និងខ្សែទទឹងបានកាន់តែល្អប្រសើរ និងធ្វើឱ្យប្រសើរឡើងនូវទីផ្សារ និងភ័ស្តុភារនៃស្បៀងដែលបានផលិត។)
- logical framework approach /ˈlɒdʒɪk(ə)l ˈfreɪmwəːk əˈprəʊtʃ/ [n] តក្កវិធីនៃគម្រោងការងារ (វិធីសាស្ត្រមួយដែលរួមមានការវិភាគអំពីការអនុវត្ត ដើម្បីឈានទៅដល់ការសម្រេចលទ្ធផលតាមទិសដៅ និងគោលបំណងចម្បងរបស់កម្មវិធី ឬស្ថាប័នមួយ ហើយនិងវិធីបង្ហាញអំពីដំណើរការទាំងនោះ)

**approach grafting** /əˈprəʊtʃ grɑːftɪŋ/ [n] (សទិសន័យ៖ inarching ) ការផ្សាំផ្ដោបមែក

**approval** /əˈpruːv(ə)l/ [n] ការយល់ព្រម (ការឆ្លើយតបជាវិជ្ជមានលើការស្នើសុំអ្វីមួយ)

**apricot** /ˈeɪprɪkɒt/ [n] អាព្រីខុត (ផ្លែឈើ)

***Aproaerema modicella*** [sci.n] ដង្កូវស៊ីញ៉ៀស្លឹកសណ្ដែកដី

**aqua-** /ˈakwə/ [prefix] បុព្វបទមានន័យថា ទឹក

**aquaculture** /ˈakwəkʌltʃə/ [n] (សទិសន័យ៖ aquafarming) វារីវប្បកម្ម

**aquafarming** /ˈakwə ˈfɑːmɪŋ/ [n] សូមមើលពាក្យ៖ aquaculture

**aquatic** /əˈkwɒtɪk/ [adj] វារីជាតិ, ជលជាតិ, ដែលដុះនៅក្នុងទឹក, វារីជាតិ (រុក្ខជាតិដែលដុះលូតលាស់ ឬរស់នៅក្នុងទឹក)

- aquatic plant /əˈkwɒtɪk plɑːnt/ [n] រុក្ខជាតិក្នុងទឹក

**aqueous** /ˈeɪkwɪəs/ [adj] ជាតិទឹក

**aquifer** /ˈakwɪfə/ [n] (សទិសន័យ៖ water-bearing formation) ស្រទាប់ទឹកក្នុងដី, ដង្ហើមទឹក, ជលសិលា (ស្រទាប់ថ្មក្រោមដីដែលអាចផ្ទុកទឹកបាន)

**arable** /ˈarəb(ə)l/ [adj] ដែលអាចដាំបាន (ដី)

- arable soil /ˈarəb(ə)l sɔɪl/ [n] ដីដែលអាចភ្ជួរបាន

***Arachis hypogea*** [sci.n] សូមមើលពាក្យ៖ groundnut, peanut

**arachnida** /əˈraknɪdə/ [n] អដ្ឋបាទិសត្វ, អារ៉ាគ្នីត (ពពួកសត្វដែលមានជើងសមប្បមាណដូចជា ពីងពាង ខ្ទួយ)

**arachnoid** /əˈraknɔɪd/ [n] កលាស្តើងរុំខួរ, អដ្ឋបាទិក, ដូចសំណាញ់ពីងពាង, ស្រទាប់ស្ដើងៗនៅចន្លោះស្រោមរុំខួរក្បាល និងខួរឆ្អឹងខ្នង

***Araneus inustus*** [sci.n] ពីងពាង

**araucaria** /ˌarɔːˈkɛːrɪə/ [n] ដើមឈើនៅអាមេរិចខាងត្បូង

**arboreal** /ɑːˈbɔːrɪəl/ [adj] ព្រឹក្ស (ទាក់ទងនឹងឈើ)

**arbovirus** /ˈɑːbə(ʊ)ˌvʌɪrəs/ [n] វីរុសអាត្រូប៉ូត, អាបូវីរុស

**arch-** /ɑːtʃ/ [prefix] (ដូច៖ archaeo-, arche-, archi-) បុព្វបទមានន័យថាបុរាណ ឬសម័យដើម (វីរុសទាំងឡាយណាដែលផ្ទុកដោយពពួកអាត្រូប៉ូត)

**archaeo-** /ˈɑːkɪəʊ/ [prefix] សូមមើលពាក្យ៖ arch-

**archaeology** /ˌɑːkɪˈɒlədʒi/ [n] បុរាណវត្ថុវិទ្យា

**arche-** /ˈɑːkɪə/ [prefix] សូមមើលពាក្យ៖ archaeo-

**archegonium** /ˌɑːkɪˈgəʊnɪəm/ [n] (ពហុវចនៈ៖ archegonia) អាឃីហ្គោនៀម, សរីរាង្គផ្ទុកអូវុល (នៅក្នុងពពួករុក្ខជាតិគ្រាប់ស្រាត (Gymnosperms) និងរុក្ខជាតិបង្កើតស្ប៉ររដូចជាស្លែ និងបណ្ណង្គជាតិ គឺជាសរីរាង្គភេទញីដែលផ្ទុកអូវុល)

**archesporium** /ɑːtʃɪzpərɪəm/ [n] អាកេស្ប៉ររ (ជាកោសិកាឬក្រុមកោសិកា ដែលស្ប៉ររមានប្រភពមកពី)

**archi-** /ˈɑːkɪ/ [prefix] បុព្វបទមានន័យថាបុរាណ សម័យដើម, មានរាងកោង (ដូចធ្នូ)

**arcuate** /ˈɑːkjʊət/ [adj] ដែលកោង, មានសភាពកោងដូចធ្នូ

**area** /ˈɛːrɪə/ [n] ផ្ទៃក្រឡា, តំបន់, បរិវេណដី, ផ្ទៃដី, ជំនាញ

- agricultural area /agrɪˈkʌltʃərəl ˈɛːrɪə/ [n] តំបន់កសិកម្ម
- buffer area /ˈbʌfə ˈɛːrɪə/ [n] តំបន់ទ្រនាប់ (ជាតំបន់មួយដែលហ៊ុំព័ទ្ធតំបន់ផលិតគ្រាប់ពូជនៅក្នុងចម្ការឈើ ដើម្បីកំណត់ព្រំដែនចម្លងលម្អងពីប្រភពខាងក្រៅ។ តំបន់ទ្រនាប់នេះ បង្កើតឡើងពីប្រភេទឈើតែមួយ ដូចក្នុងតំបន់ផលិតគ្រាប់ពូជដែរ ដូច្នេះ វារួមចំណែកក្នុងការពោយលម្អង ឬបង្កាត់លម្អងជាមួយដើមពូជដែរ។ តំបន់ទ្រនាប់ ជារុក្ខជាតិអន់ជាង បើផ្អែកទៅតាមលក្ខណៈវិនិច្ឆ័យដូចគ្នានឹងក្នុងតំបន់ផលិតគ្រាប់ពូជ ប៉ុន្តែគេមិនយកចិត្តទុកដាក់លើការចេញផ្កាផ្លែរបស់វាទេ ព្រោះថាគ្រាប់របស់វាមិនត្រូវបានគេប្រមូលយកទេ។)
- built-up area /bɪltˈʌp ˈɛːrɪə/ [n] សូមមើលពាក្យ៖ urban
- catchment area /ˈkatʃm(ə)nt ˈɛːrɪə/ [n] (សទិសន័យ៖ catchment basin, watershed) ទីជម្រាល, ផ្ទៃរងទឹកភ្លៀង, អាងរងទឹកភ្លៀង, អាងធម្មជាតិ, ដែនរងទឹកភ្លៀង
- core area /kɔː ˈɛːrɪə/ [n] តំបន់ស្នូល
- cultivated area /ˈkʌltɪveɪtɪd ˈɛːrɪə/ [n] ផ្ទៃដីដាំដុះ, ទីដែលដាំដំណាំ
- deepwater rice areas /diːpˈwɔːtə rʌɪs ˈɛːrɪəs/ [n pl] តំបន់ស្រូវទឹកជ្រៅ (តំបន់ដែលដាំដំណាំស្រូវ អាស្រ័យដោយទឹកភ្លៀងពី ១ ទៅ ៣ខែ ហើយបន្ទាប់មកត្រូវបានលិចទឹកក្នុងជម្រៅជ្រៅជាង ៥០ ស.ម ក្នុងរយៈពេល ១ ខែ ឬច្រើនជាងនេះ)
- disposal area /dɪˈspəʊz(ə)l ˈɛːrɪə/ [n] តំបន់ទុកដាក់សំណល់
- downstream area /daʊnstriːm ˈɛːrɪə/ [n] តំបន់ខាងក្រោមខ្សែទឹក
- drainage area /ˈdreɪnɪdʒ ˈɛːrɪə/ [n] ផ្ទៃរងទឹកភ្លៀង, តំបន់បង្ហូរទឹកចេញ
- environmentally fragile area /ɛnvʌɪrənˈmɛnt(ə)li ˈfradʒʌɪl ˈɛːrɪə/ [n] តំបន់ដែលងាយរងការខូចខាតបរិស្ថាន
- eroded area /ɪˈrəʊdɪd ˈɛːrɪə/ [n] ផ្ទៃសំណឹក
- existing fishing lot area /ɪgˈzɪstɪŋ ˈfɪʃɪŋ lɒt ˈɛːrɪə/ [n] ឡូត៍នេសាទដែលនៅមាន
- flooded area /flʌdɪd ˈɛːrɪə/ [n] តំបន់លិចទឹក
- harvested area /ˈhɑːvɪstɪd ˈɛːrɪə/ [n] ផ្ទៃដីប្រមូលផល
- high-risk area /hʌɪ rɪsk ˈɛːrɪə/ [n] កន្លែង ឬតំបន់គ្រោះថ្នាក់
- multiple use area /ˈmʌltɪp(ə)l juːz ˈɛːrɪə/ [n] តំបន់ប្រើប្រាស់ច្រើនយ៉ាង
- natural area /ˈnatʃ(ə)r(ə)l ˈɛːrɪə/ [n] តំបន់ធម្មជាតិ
- non harvested area /nɒn ˈhɑːvɪstɪd ˈɛːrɪə/ [n] ផ្ទៃដីប្រមូលផលមិនបាន
- protected area /prəˈtɛktɪd ˈɛːrɪə/ [n] តំបន់ការពារធម្មជាតិ
- remote area /rɪˈməʊt ˈɛːrɪə/ [n] តំបន់ដាច់ស្រយាល
- rice growing area /rʌɪs grəʊwɪŋ ˈɛːrɪə/ [n] ផ្ទៃដីដំណាំស្រូវ
- seed collection area /siːd kəˈlɛkʃ(ə)n ˈɛːrɪə/ [n] តំបន់ប្រមូលផលគ្រាប់ពូជ (ជាតំបន់មួយមានព្រំប្រទល់ច្បាស់លាស់ និងរយៈកម្ពស់កំណត់ ដែលនៅក្នុងនោះមានប្រភេទដី និងអាកាសធាតុ)
- seed production area (SPA) /siːd prəˈdʌkʃ(ə)n ˈɛːrɪə/ [n] តំបន់ផលិតគ្រាប់ពូជ (ដើមពូជវិជ្ជមាន ដែលជាទូទៅ បង្កើនគុណភាព និងបើករហាលដោយការកាប់ដកហូតនូវដើមណាដែលគេមិនចង់បាន ហើយបន្ទាប់មកថែទាំពួកវាឱ្យផលិតគ្រាប់ពូជឱ្យបានឆាប់ និងច្រើន)
- transition area /tranˈzɪʃ(ə)n ˈɛːrɪə/ [n] (សទិសន័យ៖ ecotone) អន្តរតំបន់
- undulating area /ˈʌndjʊleɪtɪŋ ˈɛːrɪə/ [n] ទីមិនរាបស្មើ
- upstream area /ˈʌpstriːm ˈɛːrɪə/ [n] តំបន់ខាងលើខ្សែទឹក

***Areca catechu*** [sci.n] សូមមើលពាក្យ៖ betel nut palm

**arecoline** /ˈarɪkəʊlʌɪn/ [n] អារេកូលីន

**arenaceous** /ˌarɪˈneɪʃəs/ [adj] សូមមើលពាក្យ៖ sandy

**arenose** /əˈriːnəʊz/ [adj] ដែលចូលចិត្តខ្សាច់

**argil** /ˈɑːdʒɪl/ [n] ដីឥដ្ឋ

**argillous** /ˈɑːdʒɪləs/ [adj] ដែលជាដីឥដ្ឋ (យ៉ាងតិចណាស់ ឥដ្ឋ ១៥%)

**arginine (R, Arg)** /ˈɑːdʒɪniːn/ [n] អាហ្គីនីន (ជាប្រភេទអាស៊ីតអាមីនេមួយក្នុងចំណោមអាស៊ីតអាមីនេទាំង ២០ នៅក្នុងប្រូតេអ៊ីន)

***Argiope catenulata*** [sci.n] ពីងពាង

**Argon** /ˈɑːgɒn/ [n] អាហ្គុង (និមិត្តសញ្ញាគីមី Ar)

***Argyrophylax nigrotibialis*** [sci.n] រុយ (បរាសិតលើដង្កូវផ្ដោបស្លឹក)

**arhythmia** /eɪˈrɪðmɪə/ [n] វិបត្តិចង្វាក់បេះដូង

**arid** /ˈarɪd/ [adj] ដែលជាវាលខ្សាច់, ដែលគ្មានជីជាតិ, ដែលស្ងួតខ្លាំង, តំបន់ហួតហែង (តំបន់ ដែលមានកម្រិតទឹកភ្លៀង តិចជាង ២៥.៤ សង់ទីម៉ែត្រ (១០ អ៊ីញ) ដែលទាមទារនូវប្រព័ន្ធធារាសាស្ត្រ សម្រាប់ការដាំដុះដំណាំ ដូចជា តំបន់ក្ដៅ ដែលរុក្ខជាតិមិនអាចផ្ដល់ផលបាន ដោយតែកម្រិត សីតុណ្ហភាព។)

- arid soil /ˈarɪd sɔɪl/ [n] ដីស្ងួត
- semi-arid /ˈsɛmi ˈarɪd/ [adj] នៃតំបន់ពាក់កណ្ដាលរាំងស្ងួត (សំដៅលើតំបន់ទទួល ម្រិតភ្លៀងប្រចាំឆ្នាំទាប (២៥ ទៅ ៥០ ស.ម) និងសម្បូរស្មៅដុះច្រើនដែលមានកម្ពស់ភ្លៀង ២០០ ទៅ ៤០០ ម.ម ក្នុង១ឆ្នាំ)

**aridification** /ərɪdɪfɪˈkeɪʃ(ə)n/ [n] ការធ្វើឱ្យទៅជាស្ងួតហួតហែងដោយធម្មជាតិ

**aridisol** /əˈrɪdɪsɒl/ [n] ដីស្ងួតហែង (ខ្សត់សារធាតុសរីរាង្គប្រែ និងស្ងួតជាប្រចាំ)

**aridity** /əˈrɪdəti/ [n] ភាពស្ងួតសោះកក្រោះ (សូមមើលពាក្យ៖ drought)

**aril** /ˈarɪl/ [n] សណ្ដាង់គ្រាប់ (ក្ដគ្រាប់), សាច់ជាប់នឹងគ្រាប់, ក្បាលគ្រាប់, ក្រមួនគ្រាប់, អារីល (ទម្រង់សាច់ ដែលមានផ្នែកខ្លះស្រោបជាប់)

**arista** /əˈrɪsta/ [n] អារីស្ដា (ពោមនៅគល់អង់តែនរបស់សត្វល្អិត ឬទម្រង់ដូចជាពោមនៅក្នុងផ្កាស្មៅ)

**aristate** /əˈrɪstat/ [adj] មានអារីស្ដា

***Arius caelatus*** [sci.n] សូមមើលពាក្យ៖ engraved sea catfish

***Arius maculatus*** [sci.n] សូមមើលពាក្យ៖ spotted sea catfish

***Arius sagor*** [sci.n] សូមមើលពាក្យ៖ sagor sea catfish

***Arius sona*** [sci.n] សូមមើលពាក្យ៖ sona sea catfish

***Arius stormi*** [sci.n] សូមមើលពាក្យ៖ armoured sea catfish

***Arius thalassinus*** [sci.n] សូមមើលពាក្យ៖ giant sea catfish

***Arius truncatus*** [sci.n] ត្រីក្អុក

***Arius venosus*** [sci.n] សូមមើលពាក្យ៖ veined catfish

**aroma** /əˈrəʊmə/ [n] (សទិសន័យ៖ fragrance, odor) ក្លិនក្រអូបប្រហើរ (ក្លិនប្រហើររបស់រុក្ខជាតិ ឬគ្រាប់របស់វា (ឧ. ក្លិនក្រអូបប្រហើរនៃគ្រាប់អង្ករ))

**aromatic** /arəˈmatɪk/ [adj] ក្រអូប, ឈ្ងុយ, ប្រហើរ

**array** /əˈreɪ/ [n] រៀបរយ, លំដាប់ជួរ

**arrowleaf sida** /ˈarəʊliːf ˈsʌɪdə/ [n] កន្ទ្រាំងបាយសញ្ញើ (ឈ្មោះវិទ្យាសាស្ត្រ *Sida rhombifolia*)

**arrowroot** /ˈarə(ʊ)ruːt/ [n] សាគូ (ឈ្មោះវិទ្យាសាស្ត្រ *Maranta arundinacea*)

**Arsenic** /ˈɑːs(ə)nɪk/ [n] អាសេនិច (និមិត្តសញ្ញាគីមី As)

**artefact** /ˈɑːtɪfakt/ [n] មិនធម្មជាតិ

**arterial blood gas (ABG)** /ɑːˈtɪərɪəl blʌd gas/ [n] ជាតិឧស្ម័នតាមសរសៃឈាម ឬក៏ឧស្ម័នឈាម

**arteriogram** /ɑːˈtɪərɪəʊgram/ [n] ការពិនិត្យមើលរូបភាពសរសៃឈាមក្រហម (តូច)

**arteriole** /ɑːˈtɪərɪəʊl/ [n] កូនអាកទែ, អាកទែតូច

**arteriosclerosis** /ɑːˌtɪərɪəʊsklɪəˈrəʊsɪs/ [n] ការធ្វើឱ្យបំពង់សរសៃឈាមក្រហមក្រាស់ ឬរឹង

**artery** /ˈɑːtəri/ [n] សរសៃឈាមក្រហម, អាកទែ (សរសៃឈាមដែលមានផ្ទៃសាច់ដុំក្រាស់ និងយឺត ដឹកនាំឈាមចេញពីបេះដូង)

**arthritis** /ɑːˈθrʌɪtɪs/ [n] រលាកសន្លាក់, ជំងឺចុកសន្លាក់ឆ្អឹង

**arthro-** /ˈɑːθrəʊ/ [prefix] បុព្វបទមានន័យថា សន្លាក់

**arthropod** /ˈɑːθrəpɒd/ [n] អាត្រូប៉ូដ (ប្រភេទមួយនៃសត្វឥតឆ្អឹងកង ហើយជើងរបស់វាផ្សំដោយកង់ៗ ហើយក្នុងនោះមានពពួកបាណកសត្វដូចជាពីងពាង ក្ដាម)

**arthrospore** /ˈɑːθrəʊspɔː/ [n] អាត្រូស្ប៉, ច្រវាក់ស្ប៉របស់ផ្សិត

**articul-** [prefix] (ដូច៖ articulo-) បុព្វបទមានន័យថា សន្លាក់

**articulate** /ɑːˈtɪkjʊlət/ [adj] ជាប់សន្លាក់, ជាប់គ្នាដោយសារសន្លាក់

**articulation** /ɑːˌtɪkjʊˈleɪʃ(ə)n/ [n] សន្លាក់ឆ្អឹង

**articulo-** [prefix] សូមមើលពាក្យ៖ articul-

**artificial** /ɑːtɪˈfɪʃ(ə)l/ [adj] នៃសិប្បនិម្មិត, ក្លែងបន្លំ, ខុសពីធម្មជាតិ

- artificial obsolescence /ɑːtɪˈfɪʃ(ə)l ˌɒbsəˈlɛs(ə)ns/ [n] ការកែច្នៃផលិតផលប្រើការលែងកើតជាផលិតផលថ្មី

**artio-** /ɑːtɪə/ [prefix] បុព្វបទមានន័យថា លេខគូ

**Artiodactyla** /ˌɑːtɪə(ʊ)ˈdaktɪlə/ [n] (លំដាប់) សត្វមានក្រចកជើងគូ

**artisan** /ɑːtɪˈzan/ [n] ជាងហត្ថករ, អ្នកសូនរូប, សិប្បករ

***Artocarpus integrifolia*** [sci.n] សូមមើលពាក្យ៖ jackfruit

**asbestos** /azˈbɛstɒs/ [n] អាស្បេស ( រូបធាតុម្យ៉ាងដែលមិនឆេះ)

**ascaris** /ˈaskərɪd/ [n] ព្រូន

**ascending** /əˈsɛndɪŋ/ [adj] ដុះឡើងលើ (ជាសណ្ឋានរបស់រុក្ខជាតិណាដុះមានទម្រង់កោងឡើងលើ)

**ascites** /əˈsʌɪtiːz/ [n] មានទឹកក្នុងភ្នាសពោះ, ការប្រមូលទឹកនៅក្នុងពោះ

**-ase** [suffix] បច្ច័យដែលប្រើដើម្បីបញ្ជាក់ថាសារធាតុនោះជាអង់ស៊ីម

**asepsis** /eɪˈsɛpsɪs/ [n] បង្ការមីក្រុប, ការស្អាត, គ្មានមេរោគសោះ

**aseptic** /eɪˈsɛptɪk/ [adj] ដែលស្អាតមិនមានការឆ្លងរោគ (បាក់តេរី ផ្សិត វាវិជាតិ ប៉ុន្តែមិនរាប់បញ្ចូលវីរុសទេ និងមិនមែនជា Symbionts)។)

**asexual** /eɪˈsɛkʃʊəl/ [adj] អភេទ, ឥតមានការសេពមេថុន

**ash** /aʃ/ [n] ផេះ

- slip in volcanic ash /slɪp ɪn vɒlˈkanɪk aʃ/ [n] សូមមើលពាក្យ៖ ash slide
- volcanic ash /vɒlˈkanɪk aʃ/ [n] កំទេរភ្នំភ្លើង, ផេះភ្នំភ្លើង

**ashy** /ˈaʃi/ [adj] ជាផេះ, ដូចផេះ

**ashy-like** /ˈaʃi lʌɪk/ [adj] ជាផេះ, ដូចផេះ

**Asian bonytongue** [n] ត្រីតាពត, ត្រីនាគ (ឈ្មោះវិទ្យាសាស្ត្រ *Scleropages formosus*)

**Asian giant terrapin** /ˈeɪʒ(ə)n ˈdʒʌɪənt ˈtɛrəpɪn/ [n] អណ្តើកសោម (ឈ្មោះវិទ្យាសាស្ត្រ *Heosemys grandis*)

**Asian palmyra palm** /ˈeɪʒ(ə)n palˈmʌɪrə pɑːm/ [n] (សទិសន័យ៖ sugar palm) ត្នោត (ឈ្មោះវិទ្យាសាស្ត្រ *Borassus flabellifer*)

**Asian pigeonwing** /ˈeɪʒ(ə)n ˈpɪdʒɪn wɪŋ/ [n] ស្មៅអញ្ចន់ (ឈ្មោះវិទ្យាសាស្ត្រ *Clitoria ternatea*)

**Asn** [abbr] អក្សរកាត់របស់អាស៊ីតអាមីនេអាស្បារ៉ាជីន

**Asp** /asp/ [abbr] អក្សរកាត់របស់អាស៊ីតអាស្បាទិច

**asparagus** /əˈsparəgəs/ [n] ទំពាំងបារាំង (ឈ្មោះវិទ្យាសាស្ត្រ *Asparagus officinalis*)

***Asparagus cochinchinensis*** [sci.n] មើមសាមសិប (អាស្ប៉ារ៉ាគុសម្យ៉ាង)

***Asparagus officinalis*** [sci.n] សូមមើលពាក្យ៖ asparagus

**Aspergillus** /ˌaspədʒɪˈləʊsɪs/ [n] អាស្ពែស៊ិល (ពពួកផ្សិតដែលមានពពួកខ្លះធ្វើឱ្យកើតរោគ)

**aspermia** /eɪˈspəːmɪə/ [n] គ្មានស្ពែម៉ាតូសូអ៊ីត

**asperous** /azpəːrəs/ [adj] គ្រោត

**asphyxia** /əsˈfɪksɪə/ [n] ការថប់ខ្យល់, ការស្ទះខ្យល់, ការស្ទះដង្ហើម, ការគ្រោះថ្នាក់ដោយថប់ខ្យល់

**aspirate** /ˈaspəreɪt/ [v] បឺតខ្យល់ ជក់ទឹក, បូមយកទឹកឬឈាម, ដកដង្ហើម

**aspirin** /ˈasp(ə)rɪn/ [n] អាស្ពីរីន, អាស៊ីតអាសេទីលសាលីស៊ីលិច (ថ្នាំបំបាត់ការឈឺចាប់ដោយមិនធ្វើឱ្យសន្លប់)

**assay** /əˈseɪ/ [n] ការធ្វើវិភាគ, ការធ្វើតេស្ត

**assemble** /əˈsɛmb(ə)l/ [v] ផ្តុំ, ដំឡើង, ប្រមូលផ្តុំ

**assembly** /əˈsɛmbli/ [n] ការដំឡើង, ការផ្តុំ, ការប្រមូលផ្តុំ

- assembly plant /əˈsɛmbli plɑːnt/ [n] រោងចក្រដំឡើង

**assessment** /əˈsɛsmənt/ [n] ការវាស់ស្ទង់, ការស្ទាបស្ទង់ (ការស្ទាបស្ទង់យល់ដឹងជាមុន), ការវាយតម្លៃ, ការប្រមាណ

- economic impact assessment /ˌiːkəˈnɒmɪk ˈɪmpakt əˈsɛsmənt/ [n] ការវាយតម្លៃហេតុប៉ះពាល់សេដ្ឋកិច្ច
- environmental impact assessment /ɪnvʌɪrənˈmɛnt(ə)l ˈɪmpakt əˈsɛsmənt/ [n] (សទិសសន័យ៖ environmental analysis) ការវាយតម្លៃផលប៉ះពាល់បរិស្ថាន
- initial assessment /ɪˈnɪʃ(ə)l əˈsɛsmənt/ [n] ការវាយតម្លៃជំហានដំបូង (ការវាយតម្លៃជំហានដំបូងត្រូវបានដឹកនាំធ្វើឡើងបន្ទាប់ពីមាន៖ (១) វិបត្តិបន្ទាន់ភ្លាមៗ (២) របាយការណ៍ថាវិបត្តិនេះកាន់តែមានសភាពធុនធាបយ៉ាប់ទៅៗ រយៈពេលយូរអង្វែង ឬ (៣) ភាពល្អប្រសើរឡើងនូវលទ្ធភាពផ្នែករូបវន្ត ក្នុងការចូលដល់តំបន់ដែលកំពុងតែឆ្លងកាត់វិបត្តិដែលកំពុងតែកើតមានជាបន្ត។ គោលបំណងបឋមនៃការវាយតម្លៃជំហានដំបូង គឺដើម្បីផ្តល់នូវព័ត៌មានសំខាន់ៗបំផុតសម្រាប់ធ្វើការរៀបចំឱ្យបានជាក់លាក់នូវផែនការចុះជួយសង្គ្រោះស្ថានភាពបន្ទាន់ ការអំពាវនាវរកជំនួយថវិកា និងការរចនាច្នៃការចុះវាយតម្លៃជាបន្តឱ្យបានកាន់តែលម្អិតថែមទៀត។ គ្រប់ទិដ្ឋភាពទាំងអស់នៃការចុះធ្វើការវាយតម្លៃជំហានដំបូងពីការចុះតាមភូមិរហូតដល់ការផលិតរបាយការណ៍ជាបញ្ចប់ត្រូវតែ បំពេញឱ្យបានចប់សព្វគ្រប់ក្នុងរយៈពេលពី ៦ ទៅ១០ថ្ងៃ។)
- integrated assessment /ˈɪntɪgreɪtɪd əˈsɛsmənt/ [n] ការប៉ាន់ប្រមាណចម្រុះ
- need assessment /niːd əˈsɛsmənt/ [n] ការវាស់ស្ទង់អំពីតម្រូវការ (ការសិក្សាជាប្រព័ន្ធដើម្បីកំណត់ និងបង្ហាញពីសេចក្តីត្រូវការ)
- rapid assessment /ˈrapɪd əˈsɛsmənt/ [n] ការអង្កេតដោយត្រួសៗអំពីស្ថានភាពទូទៅ (ការអង្កេតរហ័ស និងមិនបានពេញលេញដោយផ្អែកទៅលើការរួមបញ្ចូលគ្នារវាងទិន្នន័យដែលមានស្រាប់ និងទិន្នន័យដំបូង (ពីការអង្កេត)។ ជារឿយៗ វាត្រូវបានធ្វើឡើងបន្ទាប់ពីមានការអង្កេតជំហានដំបូងមួយនៅក្នុងពេលមានវិបត្តិបន្ទាន់ ភ្លាមៗ ឬក៏ជាសមាសភាគនៃការវាយតម្លៃឡើងវិញ។ ដោយសារតែក្របខ័ណ្ឌនៃពេលវេលារយៈពេលខ្លី ការវាយតម្លៃ ឬការអង្កេតរហ័សជាញឹកញាប់បំផុត គឺផ្តោតទៅលើការប្រមូលទិន្នន័យតាមបែបគុណភាព។)
- vulnerability assessment /vʌln(ə)rəˈbɪlɪti əˈsɛsmənt/ [n] ការប៉ាន់ប្រមាណភាពងាយរងគ្រោះ (កំណត់អំពីអ្នកដែល ឬអ្វីដែលរងឥទ្ធិពល ឬ ងាយខូចខាតដោយសារតែការប្រែប្រួលនៃមជ្ឈដ្ឋានខាងក្រៅ។)

**asset** /ˈasɛt/ [n] ទ្រព្យសម្បត្តិ

- fixed assets /fɪkst ˈasɛts/ [n pl] អចលនទ្រព្យ

**assimilate** /əˈsɪmɪleɪt/ [v] ធ្វើសមានកម្ម

**assimilation** /əsɪmɪˈleɪʃ(ə)n/ [n] សមានកម្ម, ការសំយោគម៉ូលេគុលសរីរាង្គ (ដំណើរសរីរៈដែលប្រព្រឹត្តទៅនៅក្នុងភាវរស់ ដោយវាបំប្លែងចំណីអាហារឱ្យទៅជាម៉ូលេគុលយថាប្រភេទដែលភាវរស់នោះត្រូវការ)

- chlorophyl assimilation /ˈklɔːrəfɪl əsɪmɪˈleɪʃ(ə)n/ [n] សមានកម្មក្លរ៉ូភីល, រស្មីសំយោគ

**association** /əsəʊʃɪˈeɪʃ(ə)n/ [n] សមាគមន៍, ការរួមផ្គុំ, គុម្ពោតព្រៃ

- farmer association /ˈfɑːmə əsəʊʃɪˈeɪʃ(ə)n/ [n] សមាគមន៍កសិករ
- soil association /sɔɪl əsəʊʃɪˈeɪʃ(ə)n/ [n] ការរួមផ្គុំដីច្រើនប្រភេទ

**Association of Official Seed Analysis (AOSA)** /əsəʊʃɪˈeɪʃ(ə)n ɒv əˈfɪʃ(ə)l siːd əˈnalɪsɪs/ [n] សមាគមអ្នកវិភាគគ្រាប់ពូជជាផ្លូវការ

**assumption** /əˈsʌm(p)ʃ(ə)n/ [n] សូមមើលពាក្យ៖ hypothesis

**Astatine** /ˈastətiːn/ [n] អាស្តាត (និមិត្តសញ្ញាគីមី At)

**aster-** /ˈastə/ [prefix] (ដូចៈ astero-) បុព្វបទមានន័យថាផ្កាយ

**astero-** /ˈastərəʊ/ [prefix] សូមមើលពាក្យ៖ aster-

**asthma** /ˈasmə/ [n] ជំងឺហឺត

**astringen** /əˈstrɪn(d)ʒ(ə)n/ [adj] ដែលធ្វើឱ្យជាលិការួញ ឬស្វិត, ដែលអាចទប់ឈាម,ភ្នាក់ងារមានឥទ្ធិពលធ្វើ ឱ្យជាលិការួញឬស្វិតឬអាចឃាត់ឈាមបាន, បង្រួញជាលិកា

**astronomy** /əˈstrɒnəmi/ [n] តារាវិទ្យា

**asymmetrical** /eɪsɪˈmɛtrɪk(ə)l/ [adj] មិនស៊ីមេទ្រី, រាងមិនស្មើគ្នា, មិនស៊ីគ្នា

**atavism** /ˈatəvɪz(ə)m/ [n] ការលេចឡើងជាថ្មី

**ataxia** /əˈtaksɪə/ [n] អាតាស៊ី, រោគឃើតសរសៃ, ការស្ទះចង្វាក់អំពីចលនាសាច់ដុំ, អសមត្ថភាពសំរបសម្រួលសកម្មភាពសាច់ដុំ

**atheroma** /ˌaθəˈrəʊmə/ [n] អាធ័រ៉ូម៉ា (ការខូចភ្នាសក្នុងរបស់អាកទៃ បង្កដោយការកកើតនៃស្រទាប់ខ្លាញ់ និងជាលិកាសម្លាក)

**athlete's foot** /ˌæθ.liːtsˈfʊt/ [n] (សទិសន័យ៖ ringworm) ស្រែង

**atlas** /ˈatləs/ [n] ឆ្អឹងខ្នងនៃកង់ទីមួយរិតសរសៃប្រសាទការបន្ទោរលាមក, ឆ្អឹងកងទ្រ (កង់ទី ១ នៃឆ្អឹងដែលទ្រលលាដ៍ក្បាល)

**atmometer** /atˈmɒm ɪ tər/ [n] អាត់ម៉ូម៉ែត្រ

**atmosphere** /ˈatməsfɪə/ [n] បរិយាកាស (ស្រទាប់ឧស្ម័ន ឬខ្យល់ដែលនៅជុំវិញខ្លួនយើង), មណ្ឌលអាកាស

- global **at**mosphere /ˈgləʊb(ə)l ˈatməsfɪə/ [n] បរិយាកាសពិភពលោក
- lower atmosphere /ˈləʊə ˈatməsfɪə/ [n] បរិយាកាសស្រទាប់ក្រោម
- marine atmosphere /məˈriːn ˈatməsfɪə/ [n] បរិយាកាសលើសមុទ្រ
- middle atmosphere /ˈmɪd(ə)l ˈatməsfɪə/ [n] បរិយាកាសស្រទាប់មធ្យម
- soil atmosphere /sɔɪl ˈatməsfɪə/ [n] បរិយាកាសដី
- upper atmosphere /ˈʌpə ˈatməsfɪə/ [n] បរិយាកាសស្រទាប់លើ

**atoll** /ˈatɒl/ [n] ផ្កាថ្មអាតូល (ជាប្រភេទផ្កាថ្ម ដែលដុះរុំព័ទ្ធជុំវិញកោះ រាងជាកង)

**atom** /ˈatəm/ [n] អាតូម

**atomic** /əˈtɒmɪk/ [adj] នៃអាតូម, នៃអគ្គិសនីបរមាណូ

- atomic formula /əˈtɒmɪk ˈfɔːmjʊlə/ [n] និម្មិតសញ្ញានៃធាតុ
- atomic fuel /əˈtɒmɪk fjuː(ə)l/ [n] ឥន្ធនៈបរមាណូ
- atomic mass /əˈtɒmɪk mas/ [n] ម៉ាសអាតូម
- atomic mass unit /əˈtɒmɪk mas ˈjuːnɪt/ [n] ឯកតាម៉ាសអាតូម
- atomic number /əˈtɒmɪk ˈnʌmbə/ [n] លេខអាតូម, លេខលំដាប់
- atomic plant /əˈtɒmɪk plɑːnt/ [n] រោងចក្រអគ្គិសនីបរមាណូ
- atomic power /əˈtɒmɪk ˈpaʊə/ [n] ថាមពលបរមាណូ
- atomic weight /əˈtɒmɪk weɪt/ [n] ទម្ងន់អាតូម

**atopic dermatitis** /eɪˈtɒpɪk ˌdəːməˈtʌɪtɪs/ [n] រោគរមាស់រលាកស្បែកចំទ្បែក (ដោយរោគប្រតិកម្មអង្គបដិបក្ខប្រាណតង់ស្យុងឈាម)

**atopy** /eɪˈtɒpi/ [n] រោគប្រតិកម្មអង្គបដបិក្ខប្រាណតាមពូជ (មានដើម្បីឱ្យដឹងកម្រិតជាតិស្ករក្នុងឈាម)

**atrichous** [adj] ប្រភេទបាក់តេរីដែលកោសិកាគ្មានកន្ទុយ

**atrium** /ˈeɪtrɪəm/ [n] ថតលើបេះដូង

**atrophy** /ˈatrəfi/ [n] ស្វិតតូច

**atrophy** /ˈatrəfi/ [v] ឈប់លូតលាស់, រួញ, ស្វិត

**atropine** /ˈatrəpiːn/ [n] អាត្រូពីន, អង់ត្រូពីន (សារធាតុគីមីពុលដែលមាននៅក្នុងរុក្ខជាតិឈ្មោះ *Atropa belladonna* ដែលបង្អាក់ការបញ្ជូនសារនៅត្រង់ស៊ីណាប់។ គេអាចប្រើវាធ្វើជាថ្នាំសម្រាប់សម្រួលសាច់ដុំ)

**atropous** /ˈatrəpɒs/ [adj] សូមមើលពាក្យ៖ orthotropous

**attach** /əˈtatʃ/ [v] ចងភ្ជាប់

**attachment** /əˈtatʃm(ə)nt/ [n] ជើងជំនាប់ (ការរីកធំនៃផ្នែកបាតរបស់សារាយ សម្រាប់ភ្ជាប់ទៅនឹងស៊ុបស្ត្រាត)

**attainable** /əˈteɪnəbl/ [adj] ដែលអាចសម្រេចបាន (ការងារដែលអាចធ្វើទៅបាន)

**attenuate** /əˈtɛnjʊeɪt/ [adj] រួមតូច (អំពីស្លឹក និងទម្រង់របស់រុក្ខជាតិ), កាន់តែស្រួចទៅៗ, ទម្រង់គល់ស្លឹកស្គម

**attenuate** /əˈtɛnjʊeɪt/ [v] បន្ថយ

**attenuation** /ətɛnjʊˈeɪʃ(ə)n/ [n] ការបាត់បង់លទ្ធភាពបង្កជំងឺ

**attitude** /ˈatɪtjuːd/ [n] អាកប្បកិរិយា (ដំណើរ ឬលំនាំនៃរាងកាយ ឬនៃឫកពា)

**attrition** /əˈtrɪʃ(ə)n/ [n] ការចង្អៀតគ្នា, ការកកិតគ្នា

***Atypena formosana*** [sci.n] (សទិសន័យ៖ *Callitrichia formosana*) ពីងពាងកន្ទុល

**atypical** /aˈtɪpɪk(ə)l/ [adj] មិនតួយ៉ាង, មិនដូចធម្មតា, ដែលប្លែកពីធម្មតា

**aubergine** /ˈəʊbəʒiːn/ [n] សូមមើលពាក្យ៖ egg plant

**audience** /ˈɔːdɪəns/ [n] អ្នកស្ដាប់ (អ្នកដែលចូលរួមស្ដាប់ការបង្ហាញ ឬបកស្រាយអ្វីមួយ)

**audio** /ˈɔːdɪəʊ/ [n] សំឡេង

**audiovisual** /ˈɔːdɪəʊ ˈvɪʒ(j)ʊəl/ [adj] សោតទស្សន៍ (ឧបករណ៍ដែលមានរូបភាព និងសំឡេង)

**auditory** /ˈɔːdɪt(ə)ri/ [adj] សោតវិញ្ញាណ

**auger** /ˈɔːgə/ [n] (សទិសន័យ៖ earth-borer, boring-tube) ឧបករណ៍ខួងដី (ឧបករណ៍សម្រាប់ខួងយកសំណាកដី), ប្រដាប់បុក

***Aulacophora similis*** [sci.n] អណ្ដើកមាសលើល្ពៅ, អណ្ដើកមាសកង់វែង

**aura** /ˈɔːrə/ [n] អាការៈ

**aural** /ˈɔːr(ə)l/ [adj] នៃត្រចៀក (ដែលទាក់ទងនឹងសោតវិញ្ញាណ)

**auricle** /ˈɔːrɪk(ə)l/ [n]

១. (ចំពោះរុក្ខជាតិ) ត្រចៀកស្លឹក (ព្រុយមួយគូស្ថិតនៅគែមសងខាងផ្នែកគល់ខាងក្រោយនៃបន្ទះស្លឹកស្រូវ)

២. (ចំពោះសត្វ) ស្លឹកត្រចៀក, ទងត្រចៀក, ភាគខាងលើនៃបេះដូង

***Auricularia polytricha*** [sci.n] សូមមើលពាក្យ៖ cloud ear fungus

**auscultation** /ˌɔːsk(ə)lˈteɪʃ(ə)n/ [n] វិធីស្ដាប់សំឡេងនៅក្នុងខ្លួន ដូចជានៅដើមទ្រូងដើម្បីចង់ដឹងពីជំងឺសួត បេះដូង

**Australian pine** /ɒˈstreɪlɪən pʌɪn/ [n] ស្វាវ, ដើមស្វាវ

**autecology** /ˌɔːtɪˈkɒlədʒi/ [n] ឯកត្តៈអេកូឡូស៊ី

**authigenic** /ˌɔːθɪˈdʒɛnɪk/ [adj] (សទិសន័យ៖ autochthonic, endogenetic, primary) ដែលមានដើមកំណើតនៅនឹងកន្លែង, នៃតំបន់ដើម

**autism** /ˈɔːtɪz(ə)m/ [n] មនោវិកត (ការវង្វេងវង្វាយនិងភាន់វិញ្ញាណ)

**auto-** /ˈɔːtəʊ/ [prefix] (សទិសន័យ៖ self) បុព្វបទមានន័យថា ស្វ័យ, ដោយខ្លួនឯង ឬដោយឯករាជ្យ

**autocatalytic** /ˈɔːtəʊˌkatəˈlɪtɪk/ [adj] ស្វ័យកាតាលីកម្ម (អំពីសារធាតុ) (ការជំរុញផលិតកម្មដោយខ្លួនឯង។ កាលណាមានការបង្កើតសារធាតុបានកាន់តែច្រើន នោះក៏មានកាតាលីករកាន់តែច្រើនដែរ ដើម្បីផលិតបន្តទៀត)

**autochthonous** /ɔːˈtɒkθənəs/ [adj] សូមមើលពាក្យ៖ authigenic

**autoclave** /ˈɔːtə(ʊ)kleɪv/ [n] គ្រឿងសម្រាប់ចំហុយដើម្បីសម្លាប់មេរោគ, ឆ្នាំងចំហុយសីតុណ្ហភាពខ្ពស់, ឡកម្ដៅ (ឡសម្រាប់សម្លាប់មេរោគដោយសីតុណ្ហភាពខ្ពស់ និងសម្ពាធខ្ពស់)

**autoecious** /ɔːˈdeɪʃəs/ [adj] ឯកធ្នូល (មួយវដ្ដជីវិតរបស់ពពួកផ្សិត)

**autogamy** /ɔːˈtɒgəmi/ [n] (សទិសន័យ៖ self-fertilization) ការបង្កកំណើតដោយលម្អងខ្លួនឯង, កំណកកំណកើតឯង, ស្វ័យពហុពលកម្ម (ការរួមសង្វាសនៃកាម៉េតញីជាមួយកាម៉េតឈ្មោលដោយខ្លួនឯងផ្ទាល់)

**autogenic** /ˌɔːtə(ʊ)ˈdʒɛnɪk/ [adj] អូតូសែន (អំពីតំណរុក្ខជាតិ)(ធ្វើឱ្យប៉ះពាល់បរិស្ថានដោយសហគមន៍រុក្ខជាតិខ្លួនឯង)

**autograft** /ˈɔːtəgrɑːft/ [n] ស្វ័យផ្សាំ

**autohemotherapy** /ˈɔːtəʊhiːməˈθɛrəpi/ [n] ព្យាបាលដោយឈាមខ្លួនឯង, វិធីព្យាបាលដោយបូមឈាមពីអ្នកជំងឺហើយចាក់បញ្ចូលទៅឱ្យអ្នកជំងឺជាម្ចាស់ឈាមខ្លួនឯងវិញ

**autoinfection** /ˈɔːtəʊɪnˈfɛkʃ(ə)n/ [n] ស្វ័យបង្កជំងឺ, ជំងឺដែលកើតឡើងដោយសារមេរោគ ដែលនៅក្នុងខ្លួនស្រេចហើយ ព្រមទាំងធ្វើឱ្យឈឺជាថ្មីទៀត

**autolysis** /ɔːˈtɒlɪsɪs/ [n] ស្វ័យបំបែក

**automatic** /ɔːtəˈmatɪk/ [adj] ដោយស្វ័យប្រវត្ត, ដោយខ្លួនឯង

**autonomous** /ɔːˈtɒnəməs/ [adj] ស្វ័យភាព, ដែលម្ចាស់ការ

**autopsy** /ɔːˈtɒpsi/ [n] ការវះពិនិត្យសាកសព

**autopurification** /ˈɔːtəʊpjʊərɪfɪˈkeɪʃ(ə)n/ [n] ស្វ័យសម្អាតកម្ម, ស្វ័យបន្សុទ្ធកម្ម

**autosexing** /ˈɔːtəʊsɛksɪŋ/ [n] ស្វ័យកំណត់ភេទ (បច្ចេកទេសដែលភេទរបស់កូន អាចត្រូវបានកំណត់ដោយមិនចាំបាច់ពិនិត្យមើលសរីរាង្គភេទ)

**autosome** /ˈɔːtəʃəʊm/ [n] ក្រូម៉ូសូមធម្មតា (ក្រូម៉ូសូមទាំងឡាយណាដែលមិនមែនជាក្រូម៉ូសូមភេទ)

**autotomy** /ɔːˈtɒtəmi/ [n] ស្វ័យផ្ដាច់ចេញ

**autotroph** /ˈɔːtə(ʊ)trəʊf/ [n] (សទិសន័យ៖ holotroph) អ្នកផលិត, ភាវស្វ័យជីព

**autotrophy** /ˈɔːtəʊˈtrəʊfi/ [n] ស្វ័យជីព

**auxiliary** /ɒgˈzɪlɪəri/ [n] ជំនួយ

**auxin** /ˈɔːksɪn/ [n] អ័រម៉ូនអូស៊ីន (ប្រភេទអ័រម៉ូនរុក្ខជាតិដែលមានឥទ្ធិពលសំខាន់ទៅការពន្លូតវែងរបស់ត្រួយ និងឫស។ ភាគច្រើននៃប្រភេទ អ័រម៉ូនអូស៊ីនធម្មជាតិ គឺ indole 3-acetic (អាស៊ីតអាសេទិកពាគ្មានពណ៌)។ អ័រម៉ូនសំយោគស្រដៀងគ្នានេះ ដូចជា IBA និង NAA ត្រូវបានប្រើប្រាស់យ៉ាងទូលំទូលាយសម្រាប់បណ្ដុះឫស ក្នុងការផលិតកូនឈើដោយកាត់មែក។)

**availability** /əveɪləˈbɪlɪti/ [n] ភាពទំនេរ, ភាពដែលអាចមាន

- food availability /fuːd əveɪləˈbɪlɪti/ [n] ការមានស្បៀង (បរិមាណសរុបនៃស្បៀងដែលបង្ហាញឱ្យឃើញមាននៅក្នុងតំបន់តាមផ្នែករូបវន្តនៃការបារម្ភ តាមរយៈផលិតផល ក្នុងស្រុក នាំចូលតាមផ្នែកពាណិជ្ជកម្ម និងជំនួយជាស្បៀង។ នេះអាចជាការប្រមូលរួមគ្នានៅកម្រិតតំបន់ ជាតិ ស្រុក ឬសហគមន៍។ ភាពមានស្បៀងតែឯកឯងគឺមិនគ្រប់គ្រាន់ក្នុងការធានារ៉ាប់រងដល់សន្តិសុខស្បៀងឡើយ។)
- net domestic availability /nɛt dəˈmɛstɪk əveɪləˈbɪlɪti/ [n] បរិមាណស្រូវដែលមាននៅក្នុងស្រុក (ចំនួនសរុបនៃស្បៀងដែលមានមកពីគ្រប់ប្រភពទាំងអស់ រួមមានផលិតកម្មក្នុងស្រុក ស្បៀងបម្រុងរបស់រដ្ឋាភិបាល ស្បៀងនាំចូលតាមផ្នែកពាណិជ្ជកម្ម និងជំនួយជាស្បៀង។ ស្បៀងអាហារដែលប្រើសម្រាប់គោលបំណងឧស្សាហកម្ម ចំណីអាហារ សត្វ និងការបាត់បង់ ត្រូវបានដកចេញពីចំនួនសរុបនេះ។ ត្រូវគណនានៅកម្រិតថ្នាក់ជាតិ។)

***Avena sativa*** [sci.n] សូមមើលពាក្យ៖ oat

**average** /ˈav(ə)rɪdʒ/ [n] មធ្យមភាគ, ជាមធ្យម

***Averrhoa bilimbi*** [sci.n] សូមមើលពាក្យ៖ bilimbi

***Averrhoa carambola*** [sci.n] សូមមើលពាក្យ៖ carambola

**avian** /ˈeɪvɪən/ [adj] បក្សី (ដែលទាក់ទងនឹងសត្វស្លាប)

- avian influenza /ˈeɪvɪən ɪnflʊˈɛnzə/ [n] (សទិសន័យ៖ bird flu) ជំងឺផ្ដាសាយបក្សី

**avirulent** /aˈvɪrjʊl(ə)nt/ [adj] មិនសាហាវ (គ្មានអនុភាពនឹងធ្វើឱ្យឈឺបាន), មិនបង្កជំងឺ, គ្មានលទ្ធភាពបង្កជំងឺ

**avitaminosis** /eɪˌvʌɪtəmɪˈnəʊsɪs/ [n] ជំងឺខ្វះវីតាមីន

**avocado** /ˌavəˈkɑːdəʊ/ [n] ផ្លែបឺរ

**award** /əˈwɔːd/ [n] រង្វាន់ (ប្រាក់ ឬវត្ថុសម្រាប់លើកទឹកចិត្ត)

**award letter** /əˈwɔːd ˈlɛtə/ [n] លិខិតផ្ដល់អាហារូបករណ៍

**awareness** /əˈwɛːnəs/ [n] ការយល់ដឹង

- environmental awareness /ɪnvʌɪrənˈmɛnt(ə)l əˈwɛːnəs/ [n] ការយល់ដឹងពីបរិស្ថាន

**awn** /ɔːn/ [n] កន្ទុយសម្បក (ចំពោះរុក្ខជាតិក្រាមីនេ ជទម្រង់ដូចរោមដែលដុះលូតចេញពីទ្រនុងនៃសម្បកខ្នងគ្រាប់), កន្ទុយនៃគ្រាប់ស្រូវ (ផ្នែកមួយដែលដុះបន្តចែពីសម្បកជំនៃគ្រាប់ស្រូវ តែអត្ថិភាពរបស់វាអាស្រ័យទៅលើពូជ)

**axe** /aks/ [n] ពូថៅ

**axenic** /eɪˈzɛnɪk/ [adj] ពូជសុទ្ធ

**axil** /ˈaksɪl/ [n] ក្លៀក (ស្លឹក), មុំស្លឹក (ជ្រុងកែងខាងលើរវាងដើម និងទងស្លឹក ឬមុំផ្គុំឡើងពីទងស្លឹក មែក និងក្លៀក)

**axile** /ˈaksɪl/ [adj] នៃមុំផ្គុំដោយទងស្លឹក និងមែក, នៅលើអ័ក្ស (ទីតាំងរបស់ផ្លាសេនតានៅក្នុងអូវ៉ែ)

**axilla** /akˈsɪlə/ [n] ក្លៀក

**axillary** /akˈsɪləri/ [adj] នៅគល់ស្លឹក

**axion** /ˈaksɪɒn/ [n] មូលដ្ឋានប្រព័ន្ធនៃសរសៃវិញ្ញាណ

**axis** /ˈaksɪs/ [n] អ័ក្ស, ឆ្អឹងកងស្នូល, ឆ្អឹងខ្នងកង់ទីពីរ, ឆ្អឹងខ្នង, ស្នូល

**axon** /ˈaksɒn/ [n] អាក់សូន (ខ្នែងវៀវែងរបស់ណឺរ៉ូន ដែលដឹកនាំចរន្តប្រសាទចេញពីតួកោសិកា)

**axoplasm** /ˈaksə(ʊ)plaz(ə)m/ [n] អាកសូប្លាស (ស៊ីតូប្លាសរបស់ណឺរ៉ូន)

***Azadirachta indica*** [sci.n] សូមមើលពាក្យ៖ neem

**azimuth** /ˈazɪməθ/ [n] អាស៊ីមុត

- astronomic azimuth /astrəˈnɒmɪk ˈazɪməθ/ [n] អាស៊ីមុតពិត, អាស៊ីមុតតារាសាស្ត្រ
- geographic**(al)** azimuth /dʒiːəˈgrafɪk(ə)l ˈazɪməθ/ [n] អាស៊ីមុតភូមិសាស្ត្រ
- reference azimuth /ˈrɛf(ə)r(ə)ns ˈazɪməθ/ [n] អាស៊ីមុតយោង, អាស៊ីមុតដើម
- true azimuth /truː ˈazɪməθ/ [n] អាស៊ីមុតពិត, អាស៊ីមុតតារាសាស្ត្រ

**azolla** /ˌazə(ʊ)lə/ [n] បាយទា (បណ្ណាង្គជាតិម្យ៉ាងតូចៗស្រដៀងចកទឹក ហើយមានលក្ខណៈពិសេសអាចចាប់យកអាសូតពីបរិយាកាស ដោយសារការសហប្រាណគ្នាជាមួយសារាយខៀវ ដែលរស់នៅក្នុងក្រហូងនៃស្លឹករបស់វា), អាសូឡា (ឈ្មោះវិទ្យាសាស្ត្រ *Azolla pinnata*)

***Azolla pinnata*** [sci.n] សូមមើលពាក្យ៖ azolla

**azoturia** /ˌazə(ʊ)ˈtjʊərɪə/ [n] បរិមាណអាសូតក្នុងទឹកកាម (ការកើនចំនួនអាសូតក្នុងទឹកកាម)

**B**

**BCG (medicine)** [abbr] (BCG=Bacille de Calmette et Guérin) ថ្នាំការពារជំងឺរបេង

**BD (bid) (medicine)** [abbr] (BD (bid) = bis in die) មួយថ្ងៃពីរដង

**BM (medicine)** [abbr] (BM=bowel movement) ការបត់ជើងធំ នៅពេលមានចលនាឥតបង្ខំ, វចិ

**BP (medicine)** [abbr] សូមមើលពាក្យ៖ blood pressure

**BSR (medicine)** [abbr] សូមមើលពាក្យ៖ blood sugar ratio

**BUN (medicine)** [abbr] សូមមើលពាក្យ៖ blood uria nitrogen

**babesiasis** /bəˌbiːzɪˈəʊsɪs/ [n] បាបេស៊ីយ៉ូស (ជំងឺបណ្ដាលមកពីមេរោគបាបឹស្យា (Babesia) ដែលចម្លងតាមតុកកែខាំ)

**baby** /ˈbeɪbi/ [n] ទារក, កូនតូច

**bacillus** /bəˈsɪləs/ [n] (ពហុវចនៈ៖ bacilli) បាស៊ី (បាក់តេរីរាងជាដំបង), បាក់តេរីមានរាងត្រង់ដូចចង្កេះ ឬកោង

- colon bacillus /ˈkəʊlən bəˈsɪləs/ [n] បាក់តេរីរាងដំបងក្នុងពោះវៀនធំ

**back** /bak/ [n] ខ្នង

- back rest /ˈbak rɛst/ [n] បង្អែកកំណល់ខ្នង (ឱ្យអង្គុយស្រួល)
- backbone /ˈbakbəʊn/ [n] (សទិសន័យ៖ spine) ទ្រនុងឆ្អឹងខ្នង, ឆ្អឹងខ្នង
- backyard /bakˈjɑːd/ [n] ទីធ្លាក្រោយផ្ទះ

**bacon** /ˈbeɪk(ə)n/ [n] សាច់ជ្រូកបីជាន់, សាច់ជ្រូកបេកខុន

**bacteremia** /ˌbaktəˈriːmɪə/ [n] វត្តមានបាក់តេរីក្នុងឈាម

**bacteria** /bækˈtɪə.ri.ə/ [n pl] (ឯកវចនៈ៖ bacterium) បាក់តេរី

- acetic acid bacteria /əˈsiːtɪk ˈasɪd bækˈtɪə.ri.ə/ [n pl] បាក់តេរីអាស៊ីតអាសេទិច
- agrobacteria /ˈagrəʊbækˈtɪə.ri.ə/ [n pl] អាគ្រូបាក់តេរី (ជាបាក់-តេរីស្ថិតនៅក្នុងក្រុមបាក់តេរីពណ៌ស្វាយ)
- ammonifying bacteria /əˈmɒn əˌfaɪ ɪŋ /bakˈtɪəriə/ [n pl] បាក់តេរីអាម៉ូញ៉ាក់កម្ម
- Coliform bacteria /ˈkɒlɪfɔːm bakˈtɪərɪəm/ [n pl] បាក់តេរីកូលីផម (បាក់តេរីក្រាមអវិជ្ជមាន រាងដំបង)
- denitrifying bacteria /diːˈnʌɪtrɪfʌɪ bækˈtɪə.ri.ə/ [n pl] បាក់តេរីបំប្លែងនីត្រាត
- filamentous bacteria /fɪləˈmɛntəs bakˈtɪəriə/ [n pl] បាក់តេរីដែលមានរាងជាសរសៃឆ្មារៗ
- green non-sulphur bacteria /griːn nɒnˈsəlfər bækˈtɪəriə/ [n pl] បាក់តេរីមិនមែនស្ពាន់ធ័របៃតង
- green sulphur bacteria /griːn ˈsəlfər bækˈtɪəriə/ [n pl] បាក់តេរីស្ពាន់ធ័របៃតង
- iceminus bacteria /ʌɪsˈmʌɪnəs bækˈtɪəriə/ [n pl] បាក់តេរីរារាំងទឹកកក
- nitrogenfixing bacteria (free living) /ˈnʌɪtrədʒ(ə)nˈfɪksɪŋ bakˈtɪəriə (friː ˈlɪvɪŋ)/ [n pl] បាក់តេរីភ្ជាប់អាសូតដែលរស់នៅដោយសេរី
- nitrogenfixing bacteria (symbiotic) /ˈnʌɪtrədʒ(ə)nˈfɪksɪŋ bakˈtɪəriə (ˌsɪmbɪˈɒtɪk)/ [n pl] បាក់តេរីភ្ជាប់អាសូតសហប្រាណ
- purple bacteria /ˈpəːp(ə)l bækˈtɪə.ri.ə/ [n pl] សូមមើលពាក្យ៖ Proteobacteria

**bacterial exudate** /bakˈtɪərɪəl ˈɛgzjʊdeɪt/ [n] សូមមើលពាក្យ៖ bacterial ooze

**bacterial lawn** /bækˈtɪə.ri.ə lɔːn/ [n] ស្រទាប់បាក់តេរី (បាក់តេរីបណ្ដុះដែលលូតលាស់ពីលើមជ្ឈដ្ឋានបណ្ដុះ)

**bacterial leaf streak** /bakˈtɪərɪəl liːf striːk/ [n] ជំងឺឆ្នូតស្លឹកបាក់តេរី (ជំងឺបាក់តេរីលើស្លឹកស្រូវបង្កដោយ *Xanthomonas campestris* pv. *oryzae translecens* = *X. oryzae* pv. *oryzicola* វាបណ្ដាលឱ្យមានដំបៅឆ្នូតៗតាមចន្លោះៗរវាងសរសៃវ៉ែននៃស្លឹក)

**bacterial ooze** /bakˈtɪərɪəl uːz/ [n] (សទិសន័យ៖ bacterial exudate) សម្បុកបាក់តេរី

**bactericidal** /baktɪərɪˈsʌɪd(ə)l/ [adj] (សទិសន័យ៖ bacteriocidal) ដែលអាចសម្លាប់បាក់តេរីបាន

**bactericide** /bakˈtɪərɪsʌɪd/ [n] ថ្នាំសម្លាប់បាក់តេរី

**bacterin** /baktə·rin/ [n] ថ្នាំចាក់ការពារជំងឺបាក់តេរី, វ៉ាក់សាំងការពារជំងឺបាក់តេរី

**bacterio-chlorophyll** /bakˈtɪərɪəʊ ˈklɔːrəfɪl/ [n] ក្លរ៉ូភីលបាក់តេរី

**bacteriocidal** /baktɪərɪəʊˈsʌɪd(ə)l/ [adj] សូមមើលពាក្យ៖ bactericidal

**bacteriology** /bakˌtɪərɪˈɒlədʒi/ [n] (សទិសន័យ៖ microbiology) បាក់តេរីវិទ្យា, មីក្រុបវិទ្យា

**bacteriostat** /bakˈtɪərɪə(ʊ)stat/ [n] ការទប់សំនាយបាក់តេរី

***Bagarius bagarius*** [sci.n] សូមមើលពាក្យ៖ dwarf goonch

***Bagarius suchus*** [sci.n] សូមមើលពាក្យ៖ crocodile catfish

***Bagarius yarrelli*** [sci.n] សូមមើលពាក្យ៖ goonch

***Bagrichthys macracanthus*** [sci.n] សូមមើលពាក្យ៖ black lancer catfish

***Bagrichthys macropterus*** [sci.n] សូមមើលពាក្យ៖ false black lancer catfish

**bait** /beɪt/ [n] នុយ (ចំណីលាយជាមួយថ្នាំពុលដើម្បីទាក់ទាញឱ្យសត្វល្អិតស៊ី)

**bait shyness** /beɪt ˈʃʌɪnəs/ [n] រអានុយ (ភាពដែលកណ្ដុរដឹងថាមានថ្នាំពុលនៅក្នុងនុយ ហើយកណ្ដុរឈប់ស៊ីនុយនោះតទៅទៀត)

**bakanae** [n] ជំងឺស្រូវឈ្មោល (ជំងឺស្រូវដែលបង្កដោយអ័រម៉ូនរបស់ផ្សិតឈ្មោះ *Gibberella fujikuroi* ហើយរោគសញ្ញាគឺធ្វើឱ្យស្លឹក ឬដើមលូតលាស់វែងមិនធម្មតាដែលបង្កពីអ័រម៉ូន Gibberellin)

**bala sharkminnow** /ˈbeɪ lə ʃɑːk ˈmɪnəʊ/ [n] ត្រីកៀតស្រង់ (ឈ្មោះវិទ្យាសាស្ត្រ *Balantiocheilos melanopterus*)

**balance** /ˈbal(ə)ns/ [n] លំនឹង, តុល្យភាព, ជញ្ជីង

- acid-base balance /ˈasɪd beɪs ˈbal(ə)ns/ [n] លំនឹងអាស៊ីតបាស
- balance of nature /ˈbal(ə)ns ɒv ˈneɪtʃə/ [n] លំនឹងធម្មជាតិ
- biological balance /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˈbal(ə)ns/ [n] លំនឹងជីវៈ
- ecological balance /iːkəˈlɒdʒɪk(ə)l ˈbal(ə)ns/ [n] លំនឹងបរិស្ថានរស់នៅ, លំនឹងអេកូឡូស៊ី

**balanitis** /ˌbaləˈnʌɪtɪs/ [n] រលាកលិង្គ

**balanoposthitis** [n] រលាកលិង្គ និងស្បែកគម្រប

**balantidium** [n] បាឡង់ទីឌីយ៉ូម (ពពួកមេរោគដែលមានកន្ទុយ ប្រមោយបង្កើតជំងឺមួល)

***Balantiocheilos melanopterus*** [sci.n] សូមមើលពាក្យ៖ bala sharkminnow

**ball** /bɔːl/ [n]

១. (ចំពោះសត្វ) ថ្នាំគ្រាប់មូល

២. (ចំពោះដី) ដុំដែលដាច់ចេញមកតាមឧបករណ៍

**ballast** /ˈbaləst/ [n] (សទិសន័យ៖ crushed stone) កម្ទេចថ្ម

**balling gun** /bɔːlɪŋ gʌn/ [n] ឧបករណ៍បញ្ចុកថ្នាំសត្វ

**balloon vine** /bɔːlɪŋ vʌɪn/ [n] អំបែងបែក (ឈ្មោះវិទ្យាសាស្ត្រ *Cardiospermum halicacabum*)

**ballottement** /ˈbalət'm(ə)nt/ [n] ការស្ទង់ស្ទាបទារកក្នុងផ្ទៃ

**balm** /bɑːm/ [n] ថ្នាំរឹត (ប្រេងកូឡាជាដើម)

**balsam** /ˈbɔːlsəm/ [n] ថ្នាំរឹត (ឱសថផ្សំដោយជ័រឈើដែលមានក្លិនក្រអូប ប្រហើរប្រើសម្រាប់រឹត)

**bamboo** /bamˈbuː/ [n] ឫស្សី (ឈ្មោះវិទ្យាសាស្ត្រ *Bambusa spp.* ឬ *Phyllostachys spp.*)

- bamboo basket /bamˈbuː ˈbɑːskɪt/ [n] កញ្ច្រែងឫស្សី
- bamboo forest /bamˈbuː ˈfɒrɪst/ [n] ព្រៃឫស្សី (១. ជាទូទៅ គឺជាប្រព័ន្ធអេកូឡូស៊ី ដែលមានឫស្សី ដុះលូតលាស់ច្រើនជាងគេ ២. ទម្រង់ព្រៃ ដែលមានឫស្សីដុះលប់មានកម្ពស់ ៥ ម៉ែត្រ និងកន្សោមស្លឹកនៅចន្លោះ ៣. តំបន់ដែលមានឫស្សីដុះជិតៗគ្នាច្រើនលាយជាមួយប្រភេទផ្សេងៗទៀត)
- bamboo shoot /bamˈbuː ʃuːt/ [n] ទំពាំងឫស្សី

***Bambusa* spp.** [sci.n] សូមមើលពាក្យ៖ bamboo

**banana** /bəˈnɑːnə/ [n] ចេក (ឈ្មោះវិទ្យាសាស្ត្រ *Musa* spp.)

- banana trunk /bəˈnɑːnə trʌŋk/ [n] ដើមចេក

**band** /band/ [n] បន្ទះ

**bandage** /ˈbandɪdʒ/ [n] បង់សម្រាប់រុំរបួស, សំពត់រុំ, ប៉ង់ស៊ីម៉ង់

***Bangana behri*** [sci.n] ត្រីប៉ាវ៉ាមុខពីរ

**Bangkok river sprat** /ˈbaŋkɒkˈrɪvə sprat/ [n] ត្រីបណ្ដូលល្មៅ (ឈ្មោះវិទ្យាសាស្ត្រ *Corica laciniata*)

**bank** /baŋk/ [n]

១. (សទិសន័យ៖ embankement, dump) (ចំពោះដី) ដីចាក់បំពេញ, ដីលើកឱ្យខ្ពស់, ការចាក់ដីបំពេញ, ការលើកដីឱ្យខ្ពស់

២. ធនាគារ

- agricultural bank /agrɪˈkʌltʃərəl baŋk/ [n] ធនាគារកសិកម្ម
- clonal bank /ˈkləʊn(ə)l baŋk/ [n] (សទិសន័យ៖ clone bank) ធនាគារកូនឈើបំប៉ៅ (ការប្រមូលទុកនូវដើមឈើ ឬពូជជម្រើសដែលគេបង្កើតឡើងសម្រាប់បង្កាត់ពូជ។ ការប្រមូលនេះគឺគេធ្វើ និងរក្សាទុកតាមវិធីបណ្ដុះសរីរាង្គលូតលាស់។)
- clone bank /kləʊn baŋk/ [n] សូមមើលពាក្យ៖ clonal bank
- food bank /fuːd baŋk/ [n] ធនាគារស្បៀង (ជាយន្តកម្មមួយនៅថ្នាក់សហគមន៍ ដើម្បីនឹងរៀបចំទុកស្បៀងបម្រុងសម្រាប់ការប្រើប្រាស់នៅក្នុងសហគមន៍ដោយផ្អែកលើមូលដ្ឋានរយៈពេលមួយកំណត់ ឬក៏ជាបណ្ដោះអាសន្ន។ នៅទូទាំងអាស៊ីអាគ្នេយ៍ មុខងារនេះគឺមានសម្ព័ន្ធភាពជារួមជាមួយ នឹងរោងម៉ាស៊ីនកិនស្រូវនៅថ្នាក់ភូមិ ឬថ្នាក់ស្រុក។)
- pond bank /pɒnd baŋk/ [n] ធនាគារត្រី
- river bank /ˈrɪvə baŋk/ [n] ច្រាំងទន្លេ
- sand bank /sand baŋk/ [n] (សទិសន័យ៖ shoal, shingle) គំនរ ឬផ្នូក (ខ្សាច់ ឬតដ្ឋជាដើម)
- seed bank /siːd baŋk/ [n] ធនាគារគ្រាប់ពូជ, មជ្ឈមណ្ឌលរក្សាទុកគ្រាប់ពូជ, ស្តុកគ្រាប់ (ការប្រមូលផ្តុំគ្រាប់ដែលមិនទាន់ចេញពន្លកប៉ុន្តែអាចលូតលាស់បានដែលមាននៅក្នុងកន្លែងធម្មជាតិក្នុងដី)

**bank-cutting** /baŋk-ˈkʌtɪŋ/ [n] ការហូរច្រោះ ឬស៊ីច្រាំង

**barb** /bɑːb/ [n] ព្រុយស្លាប, ទ្រនិចឃ្មុំ

- beardless barb /ˈbɪədləs bɑːb/ [n] ត្រីស្រកាក្តាម, ត្រីក្រុស (ឈ្មោះវិទ្យាសាស្ត្រ *Cyclocheilichthys apogon)*
- bonylip barb /ˈbəʊni lɪp bɑːb/ [n] ត្រីក្រុស (ឈ្មោះវិទ្យាសាស្ត្រ *Osteochilus microcephalus*)
- giant barb /ˈdʒʌɪənt bɑːb/ [n] ត្រីកាហោ (តូច), ត្រីគល់រាំង (ធំ) (ឈ្មោះវិទ្យាសាស្ត្រ *Catlocarpio siamensis*)
- goldfin tinfoil barb /ˈgəʊld(ə)n ˈtɪnfɔɪl bɑːb/ [n] ត្រីឆ្ពិន (ឈ្មោះវិទ្យាសាស្ត្រ *Hypsibarbus malcolmi*)
- mad barb [n] ត្រីប្រឡឹង ឬក្ដួច (តូច), ត្រីព្រលូង (ធំ) (ឈ្មោះវិទ្យាសាស្ត្រ *Leptobarbus hoeveni*)
- redtail barb [n] ត្រីកន្ទុយក្រហម (ឈ្មោះវិទ្យាសាស្ត្រ *Discherodontus ashmeadi*)
- seven-line barb /ˈsɛv(ə)n lʌɪn bɑːb/ [n] ត្រីត្រសក់ (ឈ្មោះវិទ្យាសាស្ត្រ *Probarbus jullieni*)
- swamp barb /swɒmp bɑːb/ [n] ត្រីអង្កត់ប្រាក់ (ឈ្មោះវិទ្យាសាស្ត្រ *Puntius brevis*)
- thilip barb [n] ត្រីត្រសក់ (ឈ្មោះវិទ្យាសាស្ត្រ *Probarbus labeamajor*)
- thinlip barb [n] ត្រីត្រសក់ (ឈ្មោះវិទ្យាសាស្ត្រ *Probarbus labeaminor*)
- tinfoil barb [n] ត្រីកាហែ, ត្រីកាហែលឿង (ឈ្មោះវិទ្យា-សាស្ត្រ *Barbodes schwanefeldi*)
- tricklip barb /trɪklɪp /bɑːb/ [n] ត្រីត្រសក់ស (ឈ្មោះវិទ្យាសាស្ត្រ *Probarbus labeamajor*)

***Barbichthys nitidus*** [sci.n] ត្រីអណ្ដាតមុខពីរ, ត្រីព្រួល, ត្រីផ្ទាគ

**barbital** /ˈbɑːbɪt(ə)l/ [n] សូមមើលពាក្យ៖ barbiturate

**barbiturate** /bɑːˈbɪtjʊrət/ [n] (សទិសន័យ៖ barbital) ថ្នាំសរសៃប្រសាទ, ប៉ាប៊ីទុរិច (ម្សៅពណ៌សមានជាតិអំបិលប្រើសម្រាប់សម្រន់ការឈឺចាប់)

***Barbodes altus*** [sci.n] ត្រីកាហែ, ត្រីកាហែក្រហម

***Barbonymus gonionotus*** [sci.n] សូមមើលពាក្យ៖ tawes

***Barbodes schwanefeldi*** [sci.n] សូមមើលពាក្យ៖ tinfoil barb

**barbone** /ˈbɛːbəʊn/ [n] សូមមើលពាក្យ៖ hemorrhagic septicemia

**barbules** /ˈbɑːbjuːls/ [n] កូនព្រុយស្លាប

**Barium** /ˈbɛːrɪəm/ [n]
១. បារ្យ៉ូម (និមិត្តសញ្ញាគីមី Ba)
២. ថ្នាំបញ្ចូលតាមមាត់ ឬបាតមុននឹងពិនិត្យតាំងពីនៅទារក ឬតាំងពីនៅតូច

**bark** /bɑːk/ [n] សម្បកឈើ, សម្បក (ផ្នែកខាងក្រៅរបស់ដើម ដែលមានសរសៃ cambium កើតពីចំណែកកោសិកានៃ phellogen), សូរព្រួស (ឆ្កែ)

**bark** /bɑːk/ [v] ព្រុស (ឆ្កែ, ចចក)

**barking** /ˈbɑːkɪŋ/ [n] ការបកសម្បកឈើ

**barley** /ˈbɑːli/ [n] ស្រូវបាលី (ប្រភេទស្រូវសាលីម្យ៉ាង)

**barn** /bɑːn/ [n] ជង្រុក
- barnyard /bɑːn jɑːd/ [n] ក្រោល, ទ្រុង

**barnacle** /ˈbɑːnək(ə)l/ [n] ពពួកគ្រំ ឬលៀស

**barometer** /bəˈrɒmɪtə/ [n] បារ៉ូម៉ែត្រ (ឧបករណ៍វាស់សម្ពាធ)

**barrage** /ˈbarɑːʒ/ [n] ទំនប់ទឹក, ធ្នួស

**barramundi** /ˌbar əˈmʌn di/ [n] ត្រីស្ពង (ឈ្មោះវិទ្យាសាស្ត្រ *Lates calcarifer*)

**barrel** /ˈbar(ə)l/ [n] ធុងបារ៉ែល

**barren** /ˈbar(ə)n/ [adj] ដែលមិនមានជីជាតិ, ដែលមិនបង្កើតផល, ដែលអារ (មិនមានកូន)
- barren sandy waste /ˈbar(ə)n ˈsəndi weɪst/ [n] ព្រៃដុះឡើងវិញម្យ៉ាងទាបៗដុះលើដីស្ងួត, ដីស្ងួតគ្មានជីជាតិដែលគេបោះបង់ចោល

**barrier** /ˈbarɪə/ [n] របាំង (របងការពារស្រែ ឬទីកន្លែងពិសោធ)
- geographic barriers /dʒiːəˈgrafɪk ˈbarɪəz/ [n pl] របាំងភូមិសាស្ត្រ

***Barringtonia acutangula*** [sci.n] រាំងទឹក

**basal** /ˈbeɪs(ə)l/ [adj] នៅលើបាត (ទីតាំងរបស់ផ្កាសេនតានៅក្នុងអូវ៉ែ)

**basal disk** /ˈbeɪs(ə)l dɪsk/ [n] ជើងទម្រ

**basalt** /ˈbasɔːlt/ [n] ថ្មបាសាល្ត៍ (ថ្មប្រផេះខ្មៅ ឧ. នៅក្រុងកំពង់ចាម)

**base pair (bp)** /beɪs pɛː/ [n] គូបាស (នុយក្លេអូទីតបំពេញគ្នាមួយគូ)

**base** /beɪs/ [n] បាត, មូលដ្ឋាន, បាស, គល់ (ស្លឹក)
- base insertion /beɪs ɪnˈsəːʃ(ə)n/ [n] បន្ថែមបាស
- conjugate base /ˈkɒndʒʊgeɪt beɪs/ [n] បាសឆ្លាស់
- panicle base /ˈpanɪk(ə)l beɪs/ [n] កកួរ

***Basella rubra*** [sci.n] សូមមើលពាក្យ៖ ceylon spinach

**basement** /ˈbeɪsm(ə)nt/ [n] ជាន់ក្រោមដី (អគារ)

**basidium** /bəˈsɪdɪəm/ [n] បាស៊ីត (ទម្រង់បន្តពូជរាងដំបង ដែលបង្កើតស្ប៉ររចំពោះផ្សិតមួយចំនួន)

**basifixed** /ˈbeɪsɪfɪkst/ [adj] (អំពីល្អោកលម្អង) ជាប់តាមគល់ (ជាប់នៅត្រង់គល់ និងមិនមានចលនាដោយសេរីទេ)

**basil** /ˈbaz(ə)l/ [n] ជីរនាងវង (ឈ្មោះវិទ្យាសាស្ត្រ *Ocimum basilcum*)

**basin** /ˈbeɪs(ə)n/ [n]
១. តំបន់ដីសណ្ត, ទំនាបបឹង
២. អាងស្រោចស្រព, ជលសីមា, តំបន់ជម្រាលទន្លេស្ទឹងដែលទឹកហូរចុះទៅ (ឧ. ទន្លេសាប), អាងទឹក (ស្ទឹង, ទន្លេ, បឹងបួ)
- artesian basin /ɑːˈtiːzɪən ˈbeɪs(ə)n/ [n] អាងទឹកផុស
- catchment basin /ˈkatʃm(ə)nt ˈbeɪs(ə)n/ [n] សូមមើលពាក្យ៖ catchment area
- clarifying basin /ˈklarɪfʌɪɪŋ ˈbeɪs(ə)n/ [n] អាងសម្អាតទឹកដោយរង
- closed basin /kləʊzd ˈbeɪs(ə)n/ [adj] អាងបិទ
- drainage basin /ˈdreɪnɪdʒ ˈbeɪs(ə)n/ [n] អាងរងទឹកភ្លៀង
- eolian erosion basin /iːˈəʊlɪən ɪˈrəʊʒ(ə)n ˈbeɪs(ə)n/ [n] អាង ឬបាសាំងដែលកើតពីការច្រោះនៃខ្យល់
- flood basin /flʌd ˈbeɪs(ə)n/ [n] អាងស្តុកទឹកជំនន់
- groundwater basin /ˈgraʊn(d)wɔːtə ˈbeɪs(ə)n/ [n] អាងទឹកក្នុងដី
- irrigation basin /ˈɪrɪgeɪtʃ(ə)n ˈbeɪs(ə)n/ [n] បាសាំងស្រោចស្រព, ផ្ទៃដីដែលគេបញ្ចូលទឹកឱ្យលិចនៅចន្លោះភ្លឺស្រែ
- presedimentation basin /ˈpriːsɛdɪmɛnˈteɪʃ(ə)n ˈbeɪs(ə)n/ [n] អាងសម្អាតទឹកដោយរងដំណាក់កាលដំបូង
- river basin /ˈrɪvə ˈbeɪs(ə)n/ [n] អាងទន្លេ

- salt lake basin /sɔːlt leɪk ˈbeɪs(ə)n/ [n] ផ្ទាំងរឹងនៃអំបិលដែលកកក្នុងតំបន់ទំនាប (បឹង)

**basis** /ˈbeɪsɪs/ [n] មូលដ្ឋាន, គ្រឹះ, គោលការណ៍

**basophil** /ˈbeɪsə(ʊ)fɪl/ [n] កោសិកាឈាមសម្បាំង

**bat** /bat/ [n] ប្រជៀវ

**batholith** /ˈbaθəlɪθ/ [n] បាតូលីត

**bathymeter** /bəˈθɪmɪtə/ [n] បាទីម៉ែត្រ

**bathypelagic** /ˌbaθɪpɪˈladʒɪk/ [n] តំបន់សមុទ្រជ្រៅ

**bathyplankton** /ˈbaθiˈplaŋ(k)t(ə)n/ [n] បាទីប្លង់តុង

**batrachian** /bəˈtreɪkɪən/ [n] នៃកង្កែប ឬគីង្គក់

***Batrachocephalus mino*** [sci.n] សូមមើលពាក្យ៖ froghead sea catfish

**battery** /ˈbat(ə)ri/ [n] អាគុយ, ថ្មពិល

- battery solution /ˈbat(ə)ri səˈluːʃ(ə)n/ [n] អេឡិចត្រូលីតអាគុយ

**bauxite** /ˈbɔːksʌɪt/ [n] បុកស៊ីត (អុកស៊ីត Al)

**bay** /beɪ/ [n] ឆកសមុទ្រ

**bay leaves** /beɪ liːvz/ [n pl] ស្លឹករុក្ខជាតិដែលអាចចម្អិនទទួលទានបាន

**beach** /biːtʃ/ [n] ឆ្នេរខាងលើ

- high beach /hʌɪ biːtʃ/ [n] ឆ្នេរខាងលើ
- low beach /ləʊ biːtʃ/ [n] ឆ្នេរខាងក្រោម

**beak** /biːk/ [n]
 ១. (ចំពោះសត្វ) ចំពុះ
 ២. (ចំពោះដី) ស្រទាប់ថ្មក្រោមដី

**bean** /biːn/ [n] សណ្ដែក, គ្រាប់ (សណ្ដែក កាហ្វេ)

- bean curd /biːn kəːd/ [n] តៅហ៊ូដុំ
- castor bean /ˈkɑːstə biːn/ [n] គ្រាប់ល្ហុងខ្វង
- faba bean /ˈfɑːvə biːn/ [n] សណ្ដែកផាបា
- hyacinth bean /ˈhʌɪəsɪnθ biːn/ [n] ពពាយស្បែក (ឈ្មោះវិទ្យាសាស្ត្រ *Lablab purpureus*)
- mung bean /mʌŋ biːn/ [n] សណ្ដែកបាយ (ឈ្មោះវិទ្យាសាស្ត្រ *Vigna radiata*)
- snap bean /snap biːn/ [n] សណ្ដែកបារាំង (ឈ្មោះវិទ្យាសាស្ត្រ *Phaseolus vulgaris*)
- soya bean /ˈsɔɪə biːn/ [n] សូមមើលពាក្យ៖ soybean
- soybean /ˈsɔɪbiːn/ [n] (សទិសន័យ៖ soya bean) សណ្ដែកសៀង (ឈ្មោះវិទ្យាសាស្ត្រ *Glycine max*)
- winged bean /wɪŋd biːn/ [n] ពពាយជ្រុង (ឈ្មោះវិទ្យាសាស្ត្រ *Psophocarpus tetragonolobus*)
- yam bean /jam biːn/ [n] ប៉ិគក្វៈ, ដំឡូងរលួស (ឈ្មោះវិទ្យាសាស្ត្រ *Pachyrhizus erosus*)
- yardlong bean /jɑːd lɒŋ biːn/ [n] សណ្ដែកទ្រើង (ឈ្មោះវិទ្យាសាស្ត្រ *Vigna unguiculata* subsp. *sesquipedalis*)

**bean noodle** /biːn ˈnuːd(ə)l/ [n] មីសួ

**bear** /bɛː/ [v] (ចំពោះរុក្ខជាតិ) កាន់ (ផ្លែ), ផ្ដល់ផល, បង្កើតផល

**bear** /bɛː/ [n] ខ្លាឃ្មុំ

**bearing** /ˈbɛːrɪŋ/ [n] កងគ្រាប់ (ចលករជួយសម្រួលដល់រង្វិល)

**beat** /biːt/ [n] ចង្វាក់បេះដូង

***Beauveria bassiana*** [sci.n] ជំងឺផ្សិត

**bed** /bɛd/ [n] ថ្នាលបណ្ដុះ (រុក្ខជាតិ), ស្រទាប់, កម្រាល, បាត

- bone-bed /bəʊn bɛd/ [n] ស្រទាប់ឆ្អឹងផូស៊ីល
- capillary bed /kəˈpɪləri bɛd/ [n] បណ្ដាញសរសៃឈាមល្អិត
- flower bed /ˈflaʊə bɛd/ [n] ថ្នាលដាំផ្កា, រងផ្កា
- hard siliceous bed /hɑːd sɪˈlɪʃəs bɛd/ [n] កម្ទេចថ្មរឹងស៊ីលីសជាស្រទាប់ៗ
- impervious bed /ɪmˈpəːvɪəs bɛd/ [n] សូមមើលពាក្យ៖ impermeable level
- lower bed /ˈləʊə bɛd/ [n] (សទិសន័យ៖ underlying substratum, subjacent bed) ស្រទាប់ក្រោម, ស្រទាប់ក្រោមបន្ទាប់
- mist irrigation bed /mɪst ˈɪrɪgeɪʃ(ə)n bɛd/ [n] (សទិសន័យ៖ mist irrigation bench) រានដាំដំណាំដែលបំពាក់ដោយប្រព័ន្ធស្រោចស្រពផ្សែងក្រួច ឬតំណក់ចំហាយទឹក
- seagrass bed /ˈsiːgrɑːs bɛd/ [n] ស្រទាប់ស្មៅសមុទ្រ, វាលស្មៅសមុទ្រ
- seed bed /siːd bɛd/ [n] ថ្នាលបណ្ដុះកូនរុក្ខជាតិ

- subjacent bed /səbˈdʒeɪs(ə)nt bɛd/ [n] សូមមើលពាក្យ៖ lower bed
- superincumbent bed /ˌsuːp(ə)rɪnˈkʌmb(ə)nt bɛd/ [n] សូមមើលពាក្យ៖ overlying stratum
- test-bed /tɛst bɛd/ [n] ចម្ការពិសោធន៍, ស្រែពិសោធន៍
- water bearing bed /ˈwɔːtə ˈbɛːrɪŋ bɛd/ [n] ស្រទាប់ទឹកជ្រៅក្នុង, ស្រទាប់មានទឹក

**bed load** /bɛd ləʊd/ [n] ល្បាប់បាត (គំន ឬការប្រមូលផ្តុំល្បប់កក់នៅបាត )

**bed out** /bɛd aʊt/ [v] ដកកូនរុក្ខជាតិទៅដាំ (ពីថ្នាលបណ្តុះ)

**bed rest** /bɛd rɛst/ [n] សំរាកសំរាន្តឱ្យបានច្រើន

**bed sore** /bɛd sɔː/ [n] ដំបៅ ឬការរលួយសាច់ ដោយព្រោះការសំរាន្តមិនប្រែខ្លួន

**bedded** /ˈbɛdɪd/ [adj] ដែលជាស្រទាប់ៗ

**bedding** /ˈbɛdɪŋ/ [n] ភាពជាស្រទាប់ៗ

- cross bedding /krɒs ˈbɛdɪŋ/ [n] ភាពជាស្រទាប់ៗខ្វែងគ្នា

**bedrock** /ˈbɛdrɒk/ [n]

១. ស្រទាប់ថ្មមិនជ្រាបទឹក

២. (សទិសន័យ៖ deep subsoil, underlaying substratum) ស្រទាប់ដែលនៅជ្រៅក្នុងដី (ស្រទាប់ C ឬ R)

**bee** /biː/ [n] ឃ្មុំ

- beekeeper /ˈbiːkiːpə/ [n] អ្នកចិញ្ចឹមឃ្មុំ
- male bee /meɪl biː/ [n] សូមមើលពាក្យ៖ drone
- queen bee /kwiːn biː/ [n] រាជនីឃ្មុំ, ស្តេចឃ្មុំ
- worker bee /ˈwəːkə biː/ [n] ឃ្មុំញីដែលមិនមានសមត្ថភាពបង្កកំណើតពេញលេញ និងក្រោមការគ្រប់គ្រងរបស់មេឃ្មុំ (queen bee)

**beet** /biːt/ [n] មើមបន្លែ (ផែថាវម្យ៉ាង)

**beetle** /ˈbiːt(ə)l/ [n] សត្វល្អិតស្លាបរឹង (ពួកសត្វល្អិតនៃលំដាប់ Coleoptera ឧ. ខ្មូត, កន្ទេះឡង់, អណ្តើកមាស, កញ្ចៃជាដើម)

- ground beetle /graʊnd ˈbiːt(ə)l/ [n] ខ្ទួតដី (សត្វរំពាស្ថិតក្នុងលំដាប់ Coleoptera គ្រួសារ Carabidae)
- rove beetle /rəʊv ˈbiːt(ə)l/ [n] ខ្ទួតដីគូទស្រួច (ប្រភេទសត្វរំពាស្ថិតក្នុងលំដាប់ Coleoptera គ្រួសារ Staphylinidae អម្បូរ *Paederus fuscipes*)

**beetroot** /ˈbiːtruːt/ [n] មើមផ្អែម (វាស្ថិតក្នុងគ្រួសារ Chenopodiaceae អម្បូរ *Beta vulgaris* spp. *vulgaris* ហើយមានប្រភពដើមនៅអាស៊ី និងអឺរ៉ុបខាងត្បូង)

**behavior** /bɪˈheɪvjə/ [n] អាកប្បកិរិយា, ឥរិយាបទ, ចរិយា (របៀបនៃសកម្មភាពរស់នៅ ផ្លូវ ឬគន្លងនៃចរិយា)

**belch** /bɛltʃ/ [v] ភើ, ខ្ពុរ, ព្រោះចេញដោយកម្លាំង

**belladonna** /ˌbɛləˈdɒnə/ [n] បេឡាដូន (រុក្ខជាតិម្យ៉ាងដែលមានជាតិពុល)

**belly** /ˈbɛli/ [n] ពោះ

- white belly /wʌɪt ˈbɛli/ [n] សពោះ (ផ្នែកពោះពណ៌សជាឆ្នូត ឬអុតពណ៌សនៅលើផ្នែកពោះនៃគ្រាប់អង្ករ និងជាម្សៅ ឬអាមីដុងដែលមានភាពទន់ផុះៗ)

**bellyache bush** /ˈbɛliˌeɪk bʊʃ/ [n] ល្ហុងខ្វងក្រហម (ឈ្មោះវិទ្យាសាស្ត្រ *Jatropha gossypiifolia*)

***Belodontichthys dinema*** [sci.n] ត្រីក្ដាំងហាយ

**belt** /bɛlt/ [n] ក្រវាត់, ចម្ការដំណាំធំៗ

- green belt /griːn bɛlt/ [n] ក្រវាត់បៃតង

**belt transect** /bɛlt tranˈsɛkt/ [n] ខ្នាត់ទទឹង

***Bemisia tabaci*** [sci.n] រុយថ្នាំជក់

**bench** /bɛn(t)ʃ/ [n] ទ្រនើរ (តុ ឬគ្រែសម្រាប់ទ្រជើងពិសោធដំណាំ), បង់កែតជាថ្នាក់ (នៅលើជម្រាល)

- solifluction bench /ˌsɒlɪˈflʌkʃ(ə)n bɛn(t)ʃ/ [n] ទ្រនុងដែលកើតដោយការរអិលដី ពេលដីសើមខ្លាំង

**benchmark** /ˈbɛn(t)ʃmɑːk/ [n] គំរុយ, ចំណុចយោង

- biological benchmark /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˈbɛn(t)ʃmɑːk/ [n] គំរុយជីវៈ

**benefit** /ˈbɛnɪfɪt/ [n] អត្ថប្រយោជន៍ (អ្វីៗដែលមានប្រយោជន៍, ប្រយោជន៍ដែលគួរប្រាថ្នា ឬចង់បាន)

- incremental net benefit /ɪŋkrɪˈmɛnt(ə)l nɛt ˈbɛnɪfɪt/ [n] ចំណេញសុទ្ធដោយកើនតាមកម្រិត

- marginal net benefit /ˈmɑːdʒɪn(ə)l nɛt ˈbɛnɪfɪt/ [n] ផលចំណេញសុទ្ធបន្ទាប់បន្សំ (កំណើនក្នុងប្រាក់ចំណេញសុទ្ធដែលអាចទទួលបានដោយការប្រែប្រួលពីជម្រើសយកផលិតកម្មមួយទៅផលិតកម្មមួយផ្សេងទៀត។ ជានិច្ចកាល វាត្រូវបានវាស់ដោយផលធៀបទៅនឹងការបន្ថែមឯកតានៃប្រាក់ដែលធ្វើវិនិយោគ។)

**benign** /bɪˈnʌɪn/ [adj] មិនបង្កគ្រោះថ្នាក់ (អំពីកោសិកា), ស្រាល (ជំងឺ)

***Benincasa hispida*** [sci.n] សូមមើលពាក្យ៖ wax gourd, winter gourd

**benthic** /ˈbɛnθɪk/ [adj] បាតសមុទ្រ

**benthos** /ˈbɛnθɒs/ [n] ភាវរស់បាតសមុទ្រ, បង់គូស

**benzene** /ˈbɛnziːn/ [n] (សទិសន័យ៖ benzol) បង់សែន (ជាតិគីមីម្យ៉ាងដែលរាវ ងាយហួតតាមខ្យល់ហើយអាចរំលាយជាតិខ្លាញ់បាន)

**benzocaine** /ˈbɛnzə(ʊ)keɪn/ [n] បង់សូកាអ៊ីន (ថ្នាំប្រើសម្រាប់ឱ្យស្ពឹកសាច់មួយកន្លែង)

**benzol** /ˈbɛnzɒl/ [n] សូមមើលពាក្យ៖ benzene

**beriberi** /ˌbɛrɪˈbɛri/ [n] រោគស្ពឹក (កើតមកពីខ្វះជាតិវីតាមីន)

**Berkelium** /bəːˈkiːlɪəm/ [n] ប៊ែកេល្យ៉ូម (និមិត្តសញ្ញាគីមី Bk)

**berm** /bəːm/ [n] (សទិសន័យ៖ backshore terrace, marine terrace) តេរ៉ាស់តាមឆ្នេរសមុទ្រ

**berry** /ˈbɛri/ [n] ផ្លែឈើតូចៗមានសាច់ច្រើន, ប្រភេទផ្លែសាច់ច្រើន និងគ្រាប់ច្រើន, ផ្លែដែលមានលក្ខណៈបេរី (ឧ. ផ្លែសាច់ ដែលមានគ្រាប់តូចៗ ដូចជា ទំពាំងបាយជូ ឬផ្លែបេរីជាដើម)

**Beryllium** /bəˈrɪlɪəm/ [n] បេរីល្យូម (និមិត្តសញ្ញាគីមី Be)

**beta-carotene** /ˈbiːtə ˈkarətiːn/ [n] ការ៉ូតែន-B (ជាការ៉ូតែនដែលជាសារធាតុដើមរបស់វីតាមីន A ហើយក្នុងមួយម៉ូលេគុល ការ៉ូតែន-B ផលិតបានពីរម៉ូលេគុល វីតាមីន A)

**betel leaf** /ˈbiːt(ə)l liːf/ [n] ម្លូ (ឈ្មោះវិទ្យាសាស្ត្រ *Piper betle*)

***Betta splendens*** [sci.n] សូមមើលពាក្យ៖ Siamese fighting fish

**beyond** /bɪˈjɒnd/ [prep] (សទិសន័យ៖ ultra-) ហួស, លើស

**bi-** /bʌɪ/ [prefix] បុព្វបទមានន័យថា ពីរ

- bi-annual /bʌɪˈanjʊəl/ [adj] ដែលផ្ដល់ផលពីរដងក្នុងមួយឆ្នាំ

**bicep** /ˈbʌɪsɛp/ [n] សាច់ដុំដើមដៃ

**bicuspid** /bʌɪˈkʌspɪd/ [n] សន្ទះ ឬអណ្ដាតនៅថតបេះដូងឆ្វេង

**biennial** /bʌɪˈɛnɪəl/ [adj] ទោវត្ស (ដែលបំពេញវដ្ដជីវិតក្នុងកំឡុងពេលពីរឆ្នាំម្ដង), នៃរុក្ខជាតិ ដែលត្រូវការរយៈពេលពីរឆ្នាំ សម្រាប់ខួបជីវិតរបស់ពួកវា

- biennial plant /bʌɪˈɛnɪəl plɑːnt/ [n] រុក្ខជាតិទោវត្ស (ដែលបំពេញវដ្ដជីវិតវាក្នុងកំឡុងពេលពីរឆ្នាំ)

**bifid** /ˈbʌɪfɪd/ [adj] ព្រែក, ដែលបែកចេញជាពីរ

**bifurcation** /bʌɪfəˈkeɪʃ(ə)n/ [n] បំណែកជាពីរ, ចម្លាម

**big headfly** /bɪg hɛd flʌɪ/ [n] រុយក្បាលធំ (បរាសិតស្ថិតក្នុងលំដាប់ Diptera គ្រួសារ Pipunculidae ហើយរុយនេះបរាសិតលើពួកមមាចបៃតង)

**bigeye ilisha** [n] ត្រីភ្នែកធំ (ឈ្មោះវិទ្យាសាស្ត្រ *Ilisha megaloptera*)

**bigmouth sea catfish** /ˈbɪgˌmaʊθ si ˈkatˌfɪʃ/ [n] ត្រីក្អក (ឈ្មោះវិទ្យាសាស្ត្រ *Ketengus typus*)

**bilabiate** /bʌɪˈləʊbeɪt/ [adj] នៃប្រភេទផ្កាមានត្របកជាប់រាងបបូរមាត់

**bilateral** /bʌɪˈlat(ə)r(ə)l/ [adj] ពីរខាង, ទាំងសងខាង, ទ្វេភាគី

**bile** /bʌɪl/ [n] ទឹកប្រមាត់

**bilimbi** [n] ទ្រលឹងទឹង (ឈ្មោះវិទ្យាសាស្ត្រ *Averrhoa bilimbi*)

**bilirubin** /ˌbɪlɪˈruːbɪn/ [n] ប៊ីលីរុយប៊ីន (ពណ៌ក្រហមនៃទឹកប្រមាត់ដែលបណ្ដាលឱ្យស្បែក និងភ្នែកអ្នកជំងឺឡើងលឿង)

**bill** /bɪl/ [n] ចំពុះ

**binocular** /bɪˈnɒkjʊlə/ [adj] ទ្វេចក្ខុ

**binucleate** /bʌɪˈnjuːklɪət/ [adj] មានណ្វៃយ៉ូពីរ (ក្នុងកោសិកា)

**bio-** /bʌɪə(ʊ)/ [prefix] បុព្វបទមានន័យថា ជីវ
- bioaccumulation /ˈbʌɪəʊəkjuːmjʊˈleɪʃ(ə)n/ [n] (សូមមើលពាក្យ៖ bioconcentration) បណ្ដុំជីវៈ, កំហាប់ជីវសាស្ត្រ
- bioaeration /ˈbʌɪəʊɛːˈreɪʃ(ə)n/ [n] អាកាសកម្មជីវៈ
- bioassay /ˌbʌɪəʊəˈseɪ/ [n] តេស្តជីវៈ, ជីវវិភាគ, សំណាកជីវៈ
- biocatalyst /ˈbʌɪəʊˈkadələst/ [n] កាតាលីករជីវៈ, ជីវប្រតិកម្មគីមី
- biocenology /ˌbaɪ oʊ sɪˈnɒl ə dʒi/ [n] ប្យូសេណូស វិទ្យា
- biocenose /ˌbʌɪə(ʊ)sɪˈnəʊsɪs/ [n] ប្យូសេណូស, សហគមន៍ជីវៈ
- biochemistry /bʌɪə(ʊ)ˈkɛmɪstri/ [n] គីមីជីវៈ
- biocide /ˈbʌɪəsʌɪd/ [n] ថ្នាំសម្លាប់ជីវៈ, ថ្នាំជីវសាស្ត្រ ឬថ្នាំការពារដំណាំពីជំងឺ និងសមាសភាពចម្រៃដ៏ទៃទៀត
- bioclimatology /ˈbʌɪəʊˌklīməˈtäləjē/ [n] ជីវ អាកាសធាតុវិទ្យា
- bioconcentration /ˈbʌɪəʊkɒns(ə)nˈtreɪʃ(ə)n/ [n] សូមមើលពាក្យ៖ bioaccumulation
- biocontamination /ˈbʌɪəʊkənˌtamɪˈneɪʃ(ə)n/ [n] កង្វក់សរីរាង្គ, កង្វក់មណ្ឌលជីវៈ
- biocontrol /bʌɪəʊkənˈtrəʊl/ [n] ជីវគ្រប់គ្រង, ការគ្រប់គ្រងជីវសាស្ត្រ
- bioconversion /ˈbʌɪəʊk(ə)nˌvəːʃ(ə)n/ [n] បំប្លែង-ជីវថាមពល
- biocorrosion /ˈbʌɪəʊkəˈrəʊʒ(ə)n/ [n] កំណកូតជីវៈ
- biodegradability /ˌbʌɪə(ʊ)dɪˌgreɪdəˈbɪlɪti/ [n] សមត្ថភាពបំបែកធាតុជីវៈ
- biodegradable /ˌbʌɪə(ʊ)dɪˈgreɪdəb(ə)l/ [adj] ដែលអាចបំបែកធាតុជីវៈ
- biodegradation /ˌbʌɪəʊdɛgrəˈdeɪʃ(ə)n/ [n] ការបំបែកធាតុជីវៈ
- biodeterioration /bʌɪə(ʊ)dɪˌtɪərɪəˈreɪʃn/ [n] ជីវ បំផ្លាញ
- biodiversity /ˌbʌɪə(ʊ)dʌɪˈvəːsɪti/ [n] (សទិសន័យ៖ biology diversity) ជីវចម្រុះ
- bioenergetics /ˌbʌɪəʊɛnəˈdʒɛtɪks/ [n] ជីវថាមពល វិទ្យា
- bioenergy /ˌbʌɪəʊˈɛnədʒi/ [n] ជីវថាមពល
- bioengineering /ˌbʌɪəʊɛndʒɪˈnɪərɪŋ/ [n] ជីវវិស្វកម្ម
- biofilm /ˈbʌɪəʊfɪlm/ [n] ជីវស្រទាប់
- biofilter /ˌbʌɪəʊˈfɪltə/ [n] តម្រងជីវៈ
- biofiltration /ˌbʌɪəʊfɪlˈtreɪʃn/ [n] ចម្រោះជីវៈ
- biogas /ˈbʌɪə(ʊ)gas/ [n] ជីវឧស្ម័ន
- biogeography /ˌbʌɪəʊdʒɪˈɒgrəfi/ [n] ភូមិវិទ្យាជីវៈ
- biogeosphere /ˌbʌɪəʊˈdʒiːə(ʊ)sfɪə/ [n] មណ្ឌលជីវ ភូគព្ភ
- bioindicator /ˌbʌɪəʊˈɪndɪkeɪtə/ [n] សូមមើលពាក្យ ៖ biological indicator

**biological** /bʌɪə(ʊ)ˈlɒdʒɪk(ə)l/ [adj] នៃជីវវិទ្យា, នៃជីវសាស្ត្រ
- biological magnification /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˌmagnɪfɪˈkeɪʃ(ə)n/ [n] ការពង្រីកជីវៈ (ការបង្កើនកំហាប់សារធាតុក្នុងជាលិការបស់ភាវរស់ នៅពេលដែលវាឆ្លងកាត់ច្រវ៉ាក់ចំណីអាហារ)
- biological oxygen demand /bʌɪə(ʊ)ˈlɒdʒɪk(ə)lˈɒksɪdʒ(ə)ndɪˈmɑːnd/ [n] តម្រូវការអុកស៊ីសែនជីវៈ(នៅក្នុងទឹក)
- biological warfare /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˈwɔːfɛː/ [n] ចម្បាំងជីវៈ

**biologicals** /bʌɪə(ʊ)ˈlɒdʒɪk(ə)lz/ [n] វ៉ាក់សាំង, សេរ៉ូម (ពាក្យប្រើទូទៅចំពោះថ្នាំដែលផ្សំឡើងអំពីអ្វីៗដែលមានជីវិត ដូចជាវ៉ាក់សាំងជាដើម)

**biologist** /bʌɪˈɒlədʒɪst/ [n] ជីវវិទូ, អ្នកជីវសាស្ត្រ

**biology** /bʌɪˈɒlədʒi/ [n] ជីវវិទ្យា, ជីវសាស្ត្រ, (ការសិក្សាដំណើរជីវិត)
- cell biology /sɛl bʌɪˈɒlədʒi/ [n] ជីវវិទ្យាកោសិកា
- marine biology /məˈriːn bʌɪˈɒlədʒi/ [n] ជីវវិទ្យាសមុទ្រ
- molecular biology /məˈlɛkjʊlə bʌɪˈɒlədʒi/ [n] ជីវវិទ្យាម៉ូលេគុល
- population biology /pɒpjʊˈleɪʃ(ə)n bʌɪˈɒlədʒi/ [n] ជីវវិទ្យាបណ្ដាភាវៈ

**bioluminescence** /ˌbʌɪə(ʊ)luːmɪˈnɛs(ə)ns/ [n] ជីវពន្លឺ (លទ្ធភាពបញ្ចេញពន្លឺរបស់ភាវរស់ ឧ. អំពិលអំពែក)

**biolysis** /ˈbʌɪəʊˈlʌɪsɪs/ [n] ប្យូលីស

**biomass** /ˈbʌɪə(ʊ)mas/ [n] ជីវម៉ាស

- biomass product /ˈbʌɪə(ʊ)mas ˈprɒdʌkt/ [n] ផលដុលជីវៈ (ផលិតផលនៃបរិមាណរូបធាតុដែលមានប្រភពពីជីវរស់បានផ្តល់ឱ្យក្នុងតំបន់មួយ)

**biome** /ˈbʌɪəʊm/ [n] ប្យូម

**biometeorology** /ˌbʌɪəʊˌmiːtɪəˈrɒlədʒi/ [n] ឧតុភូតវិទ្យាជីវៈ

**biometrics** /bʌɪə(ʊ)ˈmɛtrɪks/ [n] សូមមើលពាក្យ៖ biometry

**biometry** /bʌɪˈɒmɪtri/ [n] (សទិសន័យ៖ biometrics) ជីវមាត្រ (វិទ្យាសាស្ត្រដែលប្រើស្ថិតិសម្រាប់ការវាស់វែងក្នុងជីវវិទ្យា)

**biomonitoring** /ˈbʌɪəʊˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានជីវសាស្ត្រ (ការអង្កេតតាមដានដោយប្រើភាវរស់)

**bio-oxidation** /ˈbʌɪəʊ ɒksɪˈdeɪʃ(ə)n/ [n] ជីវអុកស៊ីតកម្ម

**biophysics** /bʌɪə(ʊ)ˈfɪzɪks/ [n] រូបវិទ្យាជីវៈ

**biopoiesis** /ˈbʌɪɒpsi/ [n] ជីវកំណើ (ការកកើតជីវិតចេញពីរូបធាតុគ្មានជីវិត)

**bioproductivity** /bʌɪə(ʊ)prɒdʌkˈtɪvɪti/ [n] ផលិតភាពជីវសាស្ត្រ

**biopsy** /ˈbʌɪɒpsi/ [n] ការកាត់សាច់ពិនិត្យ (ដើម្បីរកប្រភេទជំងឺ)

**biosafety** /ˈbʌɪə(ʊ)seɪfti/ [n] ជីវសុវត្ថិភាព

**biosphere** /ˈbʌɪə(ʊ)sfɪə/ [n] មណ្ឌលជីវៈ, ជីវមណ្ឌល

**biosynthesis** /bʌɪə(ʊ)ˈsɪnθɪsɪs/ [n] សំយោគជីវៈ

**biota** /bʌɪˈəʊtə/ [n] ភាវរស់, សារពាង្គកាយមានជីវិត (រួមទាំងពពួកសត្វ និងពពួករុក្ខជាតិនៅក្នុងតំបន់ណាមួយ)

- soil biota /sɔɪl bʌɪˈəʊtə/ [n] ភាវរស់ក្នុងដី
- terrestrial biota /təˈrɛstrɪəl bʌɪˈəʊtə/ [n] ភាវរស់លើគោក
- aquatic biota /əˈkwatɪk bʌɪˈəʊtə/ [n] ភាវរស់ក្នុងទឹក

**biotechnology** /ˌbʌɪə(ʊ)tɛkˈnɒlədʒi/ [n] បច្ចេកវិទ្យាជីវសាស្ត្រ (វិទ្យាសាស្ត្រទំនើបប្រើក្នុងជីវវិទ្យា ដូចជាវិស្វកម្មសែនជាដើម ឬការអនុវត្តគោលការណ៍វិទ្យាសាស្ត្រ និងវិស្វកម្មដើម្បីកែច្នៃសំភារៈដោយភ្នាក់ងារជីវសាស្ត្រ ដើម្បីសម្រេចបានជាទំនិញ និងសេវាកម្ម។ ជីវបច្ចេកវិជ្ជារួមមានបច្ចេកទេសដែលប្រើប្រាស់សារពាង្គកាយមានជីវិតដើម្បីផលិត ឬកែច្នៃផលិតផល ដើម្បីបង្កើនគុណភាពរុក្ខជាតិ ឬសត្វ ឬដើម្បីអភិវឌ្ឍន៍អតិសុខុមប្រាណសម្រាប់គោលបំណងជាក់លាក់។)

**biotic** /bʌɪˈɒtɪk/ [adj] ដែលមានជីវិត (ឧ. សត្វល្អិតចង្រៃ និងសត្វ សុទ្ធតែជាកត្តាមានជីវិត)

**biotite** /ˈbʌɪətʌɪt/ [n] ប៊ីយ៉ូទីត, មីកាខ្មៅ

**biotope** /ˈbʌɪətəʊp/ [n] ប្យូតូប

**biotransformation** /ˌbʌɪəʊtransfəˈmeɪʃ(ə)n/ [n] ជីវបំប្លែង

**biotrophic** /ˈbʌɪəʊˈtrəʊfɪk/ [adj] ដែលស៊ីរបស់រស់

**biotype** /ˈbʌɪəʊtʌɪp/ [n] ជីវប្រភេទ (ប្រភេទក្រុមជីវករ ដែលរាល់ឯកត្តៈរបស់វាមានសេណូទីបដូចគ្នា តែខុសពីក្រុមដទៃទៀត (ឧ. ប្រភេទបាណកសត្វខ្លះ អាចរស់នៅ និងបំផ្លាញលើពូជរុក្ខជាតិមួយដែលធន់នឹងប្រភេទផ្សេងទៀត)។ ប្រភេទទាំងនេះអាចមានរូបរាងដូចគ្នា ប៉ុន្តែមានសេរីលក្ខណៈខុសគ្នា (ឧ. ពូជស្រូវ IR ២៦ និងIR២៨ ធន់នឹងមមាចត្នោត *Nilaparvata lugens* (ជីវប្រភេទ I) តែមិនធន់នឹង *Nilaparvata lugens* (ជីវប្រភេទ II))

**biozone** /ˈbʌɪəʊzəʊn/ [n] តំបន់ជីវៈ

**bipedal** /bʌɪˈpiːd(ə)l/ [adj] ទ្វេបាទ, ដែលដើរដោយជើងពីរ

**bi-pinnate** /baɪˈpɪn eɪt/ [adj] ចែកស្លឹកជាចំណែក (សំដៅទៅលើស្លឹកដែលត្រូវបានចែកជាចំណែក)

**bi-pinnately compound leaves** /bʌɪ'pɪneɪtlɪ ˈkɒmpəʊnd liːvz/ [n pl] ស្លឹកសមាសស្លាបពីរ

**biramous** /bʌɪˈreɪməs/ [adj] ទ្វេមែក, បែកមែកជាពីរ

**bird** /bəːd/ [n] សកុណជាតិ, បក្សី សត្វស្លាប

- bird flu /bəːd flu/ [n] សូមមើលពាក្យ៖ avian influenza
- bird of prey /bəːd ɒv preɪ/ [n] បក្សីពា (សត្វស្លាបដែលសម្លាប់សត្វស្លាបតូចៗឯទៀតជាអាហារខ្លួន)

**birth** /bəːθ/ [n] កំណើត

**bisexual** /bʌɪˈsɛkʃʊəl/ [adj] (សទិសន័យ៖ hermaphroditic, monoclinous) ទ្វេភេទ, មានភេទពីររួមគ្នា

**Bismuth** /ˈbɪzməθ/ [n] ប៊ីស្មុត (និមិត្តសញ្ញាគីមី Bi)

**bistoury** /ˈbɪstʊri/ [n] កាំបិតវះកាត់

**bit** /bɪt/ [n] ផ្លែស្វាន (ផ្លែដែកសម្រាប់ខួងឈើ ឬដែក)

**bite** /bʌɪt/ [n] របួសដោយខាំ

**bite** /ˈbɪtə/ [adj] ល្វីង (ថ្នាំ), ជូរចត់ (ផ្លែឈើ), ហាង

**bitter lemon** /ˈbɪtə ˈlɛmən/ [n] សូមមើលពាក្យ៖ bitter gourd

**black** /blak/ [adj] ខ្មៅ

- black adobe /black əˈdəʊbi/ [n] (សទិសន័យ៖ tropical black soil, black humus earth) ដីខ្មៅតំបន់ត្រូពិច ឬស្ទើរតែត្រូពិច
- black bees /blak biːs/ [n pl] ឃ្មុំខ្មៅ
- black death /blak dɛθ/ [n] អ័ព្ភមរណៈ (ជាជំងឺរាតត្បាតម៉្យាងបានកើតនៅទ្វីបអឺរ៉ុប នាសម័យដើម)
- black sharkminnow /blak ʃɑːk ˈmɪnəʊ/ [n] ត្រីក្អែក (ឈ្មោះវិទ្យាសាស្ត្រ *Morulius chrysophekadion*)
- black tongue /blak tʌŋ/ [n] ពេឡាក (ជំងឺ)

**Blackleg** /ˈblaklɛg/ [n] ជំងឺបូសខ្យល់

**blackwater fewer** /blakˈwɔːtə fjuːə/ [n] រោគគ្រុនទឹកនោមឈាម (គ្រុនទឹកនោមខ្មៅ ជំងឺនេះអាចស្លាប់បាន បើគ្មានឈាមបញ្ចូលឱ្យ)

**bladder** /ˈbladə/ [n] ប្លោកនោម, ប្លោកមូត្រ

- bladder catheter /ˈbladə ˈkaθətə/ [n] ទុយោបង្ហូរទឹកនោម
- gall bladder /gɔːl ˈbladə/ [n] ថង់ប្រមាត់
- gas bladder /gas ˈbladə/ [n] ប្លោកខ្យល់

**blade** /bleɪd/ [n]

១. (ចំពោះរុក្ខជាតិ) ផ្ទៃស្លឹក, តួស្លឹក, បន្ទះស្លឹក

២. ផ្លែ (ឧ. ផ្លែកាំបិត)

**blast** /blɑːst/ [n] ជំងឺរលាក (ស្លឹករុក្ខជាតិ), ជំងឺប្លាស់

**blasto-** /ˈblastəʊ/ [prefix] បុព្វបទមានន័យថា អំប្រីយ៉ុង, ត្រួយពន្លក ឬដំណើរចេញពន្លក

**Blattodea** [n] ពពួកកន្លាត

**bleed** /bliːd/ [v] ចេញឈាម

**bleeding** /ˈbliːdɪŋ/ [n] ការហូរជ័រ (ពីជាលិកាដែលត្រូវរបួស ឬជាលិកាកើតជំងឺ), ការចេញឈាម

**blepharal** /blefˈərəl/ [n] ត្របកភ្នែក

**blight** /blʌɪt/ [n] ក្រាលភ្លើង (ក្រហមស្លឹក ឬដើមរុក្ខជាតិ), ជំងឺរុក្ខជាតិម្យ៉ាង (ជំងឺរុក្ខជាតិផ្សេងៗ ដែលបង្កដោយអតិសុខុមប្រាណ នៅពេលមានការឆ្លងរុក្ខជាតិទាំងមូល វានឹងស្លាប់យ៉ាងលឿន)

- bacterial leaf blight (BLB) /bakˈtɪərɪəl liːf blʌɪt/ [n] ជំងឺរលាកដោយបាក់តេរី, ជំងឺស្រពោនស្លឹកបាក់តេរី (ជំងឺស្រូវដែលបង្កឡើងដោយពួកបាក់តេរី *Xanthomonas campestris* pv. *oryzae* = *Xamthomonas oryzae* pv. *oryzae*។ រោគសញ្ញារបស់វាមាននៅលើស្លឹក ហើយដំណាក់កាលដំបូង មានពណ៌លឿង និងស្នាមរបួសដូចរលាកទឹកនៅតាមបណ្ដោយគែមស្លឹក ជាពិសេសនៅផ្នែកពាក់កណ្ដាលខាងចុងនៃតួស្លឹក។ ស្នាមរបួសរាលដាលយ៉ាងឆាប់រហ័សនៅតាមបណ្ដោយនៃសរសៃស្លឹក ហើយករណីធ្ងន់ធ្ងរ តួស្លឹកទាំងមូលបានរាលដាលដោយជំងឺ ហើយប្រែពណ៌ទៅជលឿង ឬកខ្វក់ ហើយងាប់តែម្ដង)
- early blight /ˈəːli blʌɪt/ [n] ជំងឺអុចលើផ្លែ ឬស្លឹករាងជារង្វង់ (ជំងឺនេះបង្កដោយផ្សិត *Alternaria solani* ភ្នាក់ងារបង្កជំងឺ អាចរស់នៅក្នុងកាកសំណល់រុក្ខជាតិ ដំណាំប៉េងប៉ោះដុះមួរ និងដំណាំអំបូរប៉េងប៉ោះព្រៃ និងអាចជាជំងឺគ្រាប់ពូជ។ ស្លឹកសើមយូរជាលក្ខខណ្ឌសមស្របបំផុតសម្រាប់ការរាលដាលនៃជំងឺ។)
- gummy stem blight /ˈgʌmi stɛm blʌɪt/ [n] ជំងឺស្លោកដើម និងស្លឹក (ជំងឺនេះបង្កដោយផ្សិត *Didymella bryoniae* ភាគច្រើននៅតំបន់ត្រូពិច។ ភ្នាក់ងារបង្កជំងឺរស់នៅលើកម្ទេចកំទីដំណាំត្រសក់ និងស្ពៅ ព្រមទាំអាចឆ្លងតាមគ្រាប់ពូជ ការធ្លាក់ភ្លៀងជាប់គ្នា។)
- sheath blight /ʃiːθ blʌɪt/ [n] ជំងឺរលាកស្រទប (ប្រភេទជំងឺផ្សិត *Ustitaginoidea virens*)
- stem rot southern blight /stɛm rɒt ˈsʌð(ə)n blʌɪt/ [n] ជំងឺរលួយដើម (ជំងឺនេះបង្កដោយផ្សិត *Sclerotinia rolfsii* ភ្នាក់ងារបង្កជំងឺរស់នៅលើកាកសំណល់រុក្ខជាតិ ហើយរស់នៅក្នុងដីមានលក្ខណៈក្រាំង និងមានជម្រកជាច្រើនទៀត។ សីតុណ្ហភាព និងសំណើមខ្ពស់ជាលក្ខខណ្ឌប្រសើរដល់ការរាលដាលជំងឺ។ ដីស្រស់ដែលមិនទាន់ពុកផុយបានផ្ដល់សារធាតុចិញ្ចឹមជាសំខាន់ដល់ផ្សិត និងធ្វើឱ្យរាលដាលកាន់តែខ្លាំងឡើង។)

- web blight /wɛb blʌɪt/ [n] ជំងឺឆេះស្លឹកមែកដូចសំណាញ់ (ជំងឺបង្កដោយផ្សិត *Rhizoctornia solani*)

**blind** /blʌɪnd/ [adj] ខ្វាក់

**blinding** /ˈblʌɪndɪŋ/ [n] ការស្ទះកញ្ច្រែងផែង

**blink** /blɪŋk/ [v] ពព្រិចភ្នែក, ព្រិចភ្នែក

**blister** /ˈblɪstə/ [n] ពងទឹករងៃ, ពងសាច់ (តាមធម្មតាមានទឹកថ្លាៗ)

**bloat** /bləʊt/ [v] ហើមពោះ, ឡើងប៉ោង

**block** /blɒk/ [n] ការបង្ខាំង, ប្លុក

- erratic block /ɪˈratɪk blɒk/ [n] ដុំថ្មដែលនាំមកពីកន្លែងផ្សេងទៀត (ឧ. ដោយទឹកកក)
- perched block /pəːtʃt blɒk/ [n] ដុំថ្មនៅកន្លែងខ្ពស់ (សម្ភារនាំមកដោយផ្ទាំងទឹកកក)

**blood** /blʌd/ [n] ឈាម

- blood grouping /blʌd ˈgruːpɪŋ/ [n] ការចាត់ក្រុមឈាម
- blood pressure /blʌd ˈprɛʃə/ [n] ប្រដាប់វាស់សម្ពាធឈាម
- blood smear /blʌd smɪə/ [n] កំណៀសឈាម
- blood transfusion /blʌd transˈfjʊːʒ(ə)n/ [n] ការបញ្ចូលឈាម
- blood urea nitrogen /blʌd jʊˈriːə ˈnʌɪtrədʒ(ə)n/ [n] ជំងឺពុលទឹកនោម, ការពិសោធឈាមម្យ៉ាងមើលជាតិអាសូត
- blood vessel /blʌd ˈvɛs(ə)l/ [n] សរសៃឈាម

**bloodline** /ˈblʌdlʌɪn/ [n] ពង្សាវលី, ខ្សែស្រលាយ

**blood-rain** /blʌdreɪn/ [n] ព្យុះធូលី

**bloom** /bluːm/ [n] កំណើតយ៉ាងរហ័ស (ចំនួនអតិសុខុមប្រាណក្នុងទឹក), ការរីកយ៉ាងរហ័ស (ផ្កា)

**bloom** /bluːm/ [v] មានផ្កា, បញ្ចេញផ្កា, រីក

**blossom** /ˈblɒs(ə)m/ [n] ផ្កា

**blow fly** /bləʊ flʌɪ/ [n] សូមមើលពាក្យ៖ calliphora

**blowout** /bləʊn aʊt/ [n] ការរំជួលដោយខ្យល់, ការនាំចេញទៅដោយខ្យល់, តំបន់វាលដោយខ្យល់ (តំបន់ដីវាលដែលបណ្ដាលមកពីខ្យល់បក់យក

**blubber** /ˈblʌbə/ [n] ស្រទាប់ខ្លាញ់

**blue ginger** /bluː ˈdʒɪndʒə/ [n] សូមមើលពាក្យ៖ galangal

**blue panchax** /bluˈpantʃaks/ [n] ត្រីចង្វារនោង (ឈ្មោះវិទ្យាសាស្ត្រ *Aplocheilus panchax*)

**blue water lily** /bluːˈwɔːtəˈlɪli/ [n] ព្រលិតខៀវ (ឈ្មោះវិទ្យាសាស្ត្រ *Nymphaea stellata*)

**bluebottle** /ˈbluːbɒt(ə)l/ [n] សូមមើលពាក្យ៖ calliphora

**bluetongue** /bluː tʌŋ/ [n] ជំងឺអណ្ដាតខៀវ

**blunt** /blʌnt/ [adj] ទាល, រឹល

**blunt** /blʌnt/ [n] ជើងដំរី (ឧបករណ៍សម្រាប់បុក)

**blunt end** /blʌnt ɛnd/ [n] ចុងទាល, ចុងស្មើ

**blur** /bləː/ [n] ព្រិលភ្នែក, ស្រវាំងភ្នែក

**BOD5** [n] តម្រូវការអុកស៊ីសែនជីវៈក្នុងរយៈពេលប្រាំថ្ងៃ

**body** /ˈbɒdi/ [n] ខ្លួន, រាងកាយ, តួ, សព, វត្ថុ, អង្គ, អង្គធាតុ

- compound body /ˈkɒmpaʊnd ˈbɒdi/ [n] អង្គធាតុសមាស
- fluid body /ˈfluːɪd ˈbɒdi/ [n] សូមមើលពាក្យ៖ fluid
- fruiting body /fruːtɪŋ ˈbɒdi/ [n] កន្សោមស្ប៉ រ
- heterogeneous body /ˌhɛt(ə)rə(ʊ)ˈdʒiːnɪəs ˈbɒdi/ [n] អង្គធាតុមិនស្មើសាច់
- homogeneous body /ˌhɒmə(ʊ)ˈdʒiːnɪəs ˈbɒdi/ [n] អង្គធាតុស្មើសាច់
- perennial water body /pəˈrɛnɪəl ˈwɔːtəbɒdi/ [n] តំបន់មានទឹកជាប្រចាំ
- polar body /ˈpəʊlə ˈbɒdi/ [n] អង្គកំពូល
- pure body /pjʊə ˈbɒdi/ [n] អង្គធាតុសុទ្ធ
- simple body /ˈsɪmp(ə)l ˈbɒdi/ [n] អង្គធាតុទោល
- solid body /ˈsɒlɪd ˈbɒdi/ [n] អង្គធាតុរឹង
- water body /ˈwɔːtəbɒdi/ [n] ផ្ទៃទឹក
- foreign body /ˈfɒrɪn ˈbɒdi/ [n] វត្ថុចំឡែកនៅក្នុងខ្លួន, ធាតុមិនសុទ្ធ (ឧ. គ្រាប់គ្រួសក្នុងអំពៅ)

**body opening** /ˈbɒdi ˈəʊp(ə)nɪŋ/ [n] រន្ធធម្មជាតិ (រន្ធច្រមុះ រន្ធត្រចៀកជាដើម)

***Boehmeria nivea*** [sci.n] សូមមើលពាក្យ៖ ramie

***Boerhavia diffusa*** [sci.n] សូមមើលពាក្យ៖ punarvana

***Boesemania microlepis*** [sci.n] សូមមើលពាក្យ៖ smallscale croaker

**bog** /bɒg/ [n]

១. (សទិសន័យ៖ slough, quagmire) ទំនាបដែលមានភក់ និងទឹក

២. (សទិសន័យ៖ peat bog) ដីទំនាបដែលមមោកជាប្រភេទពើកណ ឬតួប ឬម័រ

៣. (សទិសន័យ៖ morass) វាលភក់ល្បាប់

៤. កន្លែងធ្យូងតួបអាស៊ីត

៥. ទីដក់ទឹក

- blanket bog /ˈblaŋkɪt bɒg/ [n] វាលដក់ទឹក
- flat bog /flatbɒg/ [n] កន្លែងកើតពើកលើទីរាបស្មើ
- half bog /hɑːfbɒg/ [n] (សទិសន័យ៖ transitional peatland) កន្លែងកើតពើកអន្តរការ
- high peat bog /hʌɪ piːt bɒg/ [n] (សទិសន័យ៖ peatland, turf moss, peat moss) កន្លែងកើតពើក
- lime bog /lʌɪm bɒg/ [n] (សទិសន័យ៖ shell-marl) ទំនាបបឹងដែលមានកំបោរ, ថ្មម៉ានដែលកើតពីកំបោរសម្បកខ្យង ឬលៀស
- peat bog /piːt bɒg/ [n] សូមមើលពាក្យ៖ marshy waste land
- peat bog /piːt bɒg/ [n] សូមមើលពាក្យ៖ bog
- raised bog /reɪzd bɒg/ [n] តួប ឬពើកកើតលើទួល
- ropy peat-bog /ˈrəʊpi piːt-bɒg/ [n] តួប ឬពើកកើតលើជម្រាល
- silty bog /ˈsɪlti bɒg/ [n] សូមមើលពាក្យ៖ meadow bog soil
- swing moor quaking bog /swɪŋ mɔː kweɪkɪŋ bɒg/ [n] ទំនាបបឹងដែលមានរុក្ខជាតិរលួយជាប់គ្នាជាផ្ទាំងអណ្តែតលើទឹក

**Bohrium** /ˈbɔːrɪəm/ [n] បូរ្យ៉ូម (និមិត្តសញ្ញាគីមី Bh)

**boil** /bɔɪl/ [v] ពុះ

**boil** /bɔɪl/ [n] សូមមើលពាក្យ៖ carbuncle

***Bolboschoenus maritimus*** [sci.n] សូមមើលពាក្យ៖ saltmarsh bulrush

**bole** /bəʊl/ [n] តួដើមឈើ, កូនឈើ, ដើមគល់ (ដើមរុក្ខជាតិគិតចាប់ពីគល់រហូតដល់មែកទី១)

**bolt** /bəʊlt/ [n] ប៊ូឡុង (ដែកមូលវែងមានខ្សែខ្ចៅសម្រាប់មួល)

**bolting** /bəʊltɪŋ/ [n] ចន្លោះថ្នាំងវែង

**bolus** /ˈbəʊləs/ [n] ថ្នាំគ្រាប់មូល, ដុំអាហារ (សម្រាប់សត្វ)

***Bombax malabaricum*** [sci.n] សូមមើលពាក្យ៖ kapok

**bond** /bɒnd/ [n] សម្ពន្ធ

- coordinate covalent bond /kəʊˈɔːdɪneɪt kəʊˈveɪl(ə)nt bɒnd/ [n] សម្ពន្ធកូវ៉ាឡង់ស្មើគ្នា
- covalent bond /kəʊˈveɪl(ə)nt bɒnd/ [n] សម្ពន្ធកូវ៉ាឡង់
- double bond /ˈdʌb(ə)l bɒnd/ [n] សម្ពន្ធទ្វេ

**bone** /bəʊn/ [n] (សទិសន័យ៖ os) ឆ្អឹង

- angular bone /ˈaŋgjʊlə bəʊn/ [n] ឆ្អឹងអង់គូឡា, ឆ្អឹងមុំ
- collar bone /ˈkɒlə bəʊn/ [n] ឆ្អឹងដងកាំបិត
- fish bone /fɪʃ bəʊn/ [n] ឆ្អឹងត្រី
- ring bone /rɪŋ bəʊn/ [n] ពកឆ្អឹងនៅកកែបសេះ
- side bone /sʌɪd bəʊn/ [n] អដ្ឋិកម្មឆ្អឹងខ្ចី
- splint bone /splɪnt bəʊn/ [n] ឆ្អឹងកំភួនជើង

**bony** /ˈbəʊni/ [adj] នៃឆ្អឹង, ចម្អឹង

**booklet** /ˈbʊklɪt/ [n] កូនសៀវភៅ

**boondocks** /ˈbuːndɒks/ [n] តំបន់ដាច់ស្រយាល

**booster** /ˈbuːstə/ [n] ចំណាក់ថ្នាំលើកទីពីរ

**booting stage** /buːtɪŋ steɪdʒ/ [n] ដំណាក់កាលផើម (ការឡើងប៉ោងនៃស្រទបស្លឹកទង់ជ័យ ដោយការរីកធំនៃកួរនៅពេលនោះនៅក្នុងស្រទបនៃស្លឹកទង់ជ័យមានកួរ)

***Borassus flabellifer*** [sci.n] សូមមើលពាក្យ៖ Asian palmyra palm

**earth-borer** /əːθ ˈbɔːrə/ [n] (សទិសន័យ៖ auger, boring-tube) ឧបករណ៍សម្រាប់ស្ទង់ ឬខួងមើលដី

**boring-tube** /ˈbɔːrɪŋ-tjuːb/ [n] សូមមើលពាក្យ៖ auger

**born** /bɔːn/ [adj] កើត

**borneo river sprat** /ˈbɔːnɪəʊ ˈrɪvə sprat/ [n] ត្រីបណ្តូលល្ពៅ (ឈ្មោះវិទ្យាសាស្ត្រ *Clupeoides borneensis*)

**borneo threadfin** /ˈbɔːnɪəʊ ˈθrɛdˌfɪn/ [n] ត្រីព្រាមលឿង (ឈ្មោះវិទ្យាសាស្ត្រ *Polynemus borneensis*)

**Boron** /ˈbɔːrɒn/ [n] បរ (និមិត្តសញ្ញាគីមី B)

***Borreria alata*** [sci.n] ម្អមភ្នំញី

**boss** /bɒs/ [n] បូក (គោ)

**bot** /bɒt/ [n] កូនញាស់

**botanical name** /bəˈtanɪkl neɪm/ [n] ឈ្មោះវិទ្យាសាស្ត្ររុក្ខជាតិ

**botany** /ˈbɒt(ə)ni/ [n] រុក្ខវិទ្យា (វិទ្យាសាស្ត្រដែលសិក្សាពីការរៀបចំបែងចែករុក្ខជាតិជាលំដាប់ថ្នាក់)

**Bothriocephalus** [n] (សទិសន័យ៖ Diplyllobothrium) ដង្កូវសំប៉ែត

***Bothrogonia ferruginea*** [sci.n] មមាចស្លឹកពណ៌ក្រហម

***Botia beauforti*** [sci.n] សូមមើលពាក្យ៖ chameleon botia

***Botia eos*** [sci.n] សូមមើលពាក្យ៖ sun loach

***Botia helodes*** [sci.n] សូមមើលពាក្យ៖ tiger botia

***Botia lecontei*** [sci.n] សូមមើលពាក្យ៖ silver botia

***Botia modesta*** [sci.n] សូមមើលពាក្យ៖ redtail botia

***Botia morleti*** [sci.n] សូមមើលពាក្យ៖ skunk botia

***Botia* sp.** [sci.n] សូមមើលពាក្យ៖ speckletail botia

**botia** /ˈbəʊ tiə/ [n] ពពួកត្រីកញ្ជ្រូក

- chameleon botia /kəˈmiliən ˈbəʊ tiə/ [n] ត្រីកញ្ជ្រូក (ឈ្មោះវិទ្យាសាស្ត្រ *Botia beauforti*)
- redtail botia /rɛd teɪl ˈbəʊ tiə/ [n] ត្រីកញ្ជ្រូកក្រហម (ឈ្មោះវិទ្យាសាស្ត្រ Botia modesta)
- silver botia /ˈsɪlvə ˈbəʊ tiə/ [n] ត្រីកញ្ជ្រូកលឿង (ឈ្មោះវិទ្យាសាស្ត្រ *Botia lecontei*)
- speckletail botia /ˈspɛk(ə)l teɪl ˈbəʊ tiə/ [n] ត្រីកញ្ជ្រូក (ឈ្មោះវិទ្យាសាស្ត្រ *Botia sp.*)
- tiger botia /ˈtʌɪgə ˈbəʊ tiə/ [n] ត្រីកញ្ជ្រូកឆ្នូត (ឈ្មោះវិទ្យាសាស្ត្រ *Botia helodes*)
- skunk botia /skʌŋk ˈbəʊ tiə/ [n] ត្រីកញ្ជ្រូក (ឈ្មោះវិទ្យាសាស្ត្រ *Botia morleti*)

**botte** /bɒt/ [n] បាត

**bottle** /ˈbɒt(ə)l/ [n] ដប

- small bottle /smɔːl ˈbɒt(ə)l/ [n] សូមមើលពាក្យ៖ vial

**bottleneck** /ˈbɒt(ə)lnɛk/ [n] ភាពរាំងស្ទះ, ភាពកកកុញ

**bottom** /ˈbɒtəm/ [n] បាត (បឹង ទន្លេជាដើម), ចំណុចទាបបំផុត

- bottom of hole /ˈbɒtəm ɒv həʊl/ [n] បាតរណ្ដៅ
- first bottom /fəːst ˈbɒtəm/ [n] វាលល្បាប់, ទំនាបល្បាប់ដែលអាចលិចទឹកបាន, ផ្នែកបាតស្ទឹងឬទន្លេដែលមានទឹកតែក្នុងរដូវជំនន់

**botulism** /ˈbɒtjʊlɪz(ə)m/ [n] ជំងឺបូទុយលិច (ជំងឺពុលដោយការបរិភោគម្ហូបទុកមិនស្អាត ឬដាក់ក្នុងកំប៉ុងមិនស្អាត ដោយបាក់តេរី Botulinium)

***Bouea burmanica*** [sci.n] សូមមើលពាក្យ៖ mariaum tree

***Bouea macrophylla Griffith*** [sci.n] សូមមើលពាក្យ៖ gandaria

**bougainvillea** /ˌbuːg(ə)nˈvɪlɪə/ [n] ផ្កាក្រដាស (ឈ្មោះវិទ្យាសាស្ត្រ *Bougainvillea spectabilis*)

***Bougainvillea spectabilis*** [sci.n] សូមមើលពាក្យ៖ bougainvillea

**boulder** /ˈbəʊldə/ [n] ដុំថ្ម, ផ្ទាំងថ្ម

**boundary** /ˈbaʊnd(ə)ri/ [n] ព្រំប្រទល់, ព្រំដែន

- drainage boundary /ˈdreɪnɪdʒ ˈbaʊnd(ə)ri/ [n] ព្រំប្រទល់អាងរងទឹកភ្លៀង

**bovine** /ˈbəʊvʌɪn/ [adj] សណ្ឋានគោ, គោ

- Bovine Spongiform Encephalo-pathy /ˈbəʊvʌɪn ˈspʌndʒɪfɔːm ɛnˈsɛf(ə)ləʊ pəθi/ [n] ជំងឺគោឆ្កួត

**bowel** /ˈbaʊəl/ [n] សូមមើលពាក្យ៖ intestine

- bowel obstruction /ˈbaʊəl əbˈstrʌkʃ(ə)n/ [n] ការស្ទះពោះវៀន
- bowel resection and anastomosis /ˈbaʊəl rɪˈsɛkʃ(ə)n ənd əˌnastəˈməʊsɪs/ [n] ការវះយកពោះវៀនមួយដុំចេញរួចភ្ជាប់វិញ
- bowel wash out /ˈbaʊəl wɒʃ aʊt/ [n] ការលាងសម្អាតពោះវៀន

**brachi-** [prefix] (ដូច៖ brachio-) បុព្វបទមានន័យថា ដៃ

**brachial** /ˈbreɪkɪəl/ [adj] នៃដៃ, ដែលទាក់ទងអវយវៈមុខ

***Brachiaria mutica*** [sci.n] សូមមើលពាក្យ៖ paragrass

***Brachiaria reptans*** [sci.n] សូមមើលពាក្យ៖ creeping panic grass

**brachio-** [prefix] សូមមើលពាក្យ៖ brachi-

**brachy-** /ˈbraki/ [prefix] បុព្វបទមានន័យថា អ្វីមួយខ្លី

***Brachymeria excarinata*** [sci.n] ពួកឪម៉ាល់ (បរាសិតលើដង្កូវដុកដឿ)

***Brachymeria lasus*** [sci.n] ពួកឪម៉ាល់ (បរាសិតលើដង្កូវដុកដឿ)

***Brachymeria* sp.** [sci.n] ពួកឪម៉ាល់ (បរាសិតលើដង្កូវដុកដឿ)

***Brachyplatys subaeneus*** [sci.n] ស្រឹងសណ្តែកពណ៌ខ្មៅ

**bract** /brakt/ [n] សូមមើលពាក្យ៖ bracteole

**bracteole** /ˈbrak tiˌoʊl/ [n] (សទិសន័យ៖ bract) តំបារស្លឹកក្រោមផ្កា, ស្លឹកទម្រត្របកផ្កា, ទ្រនាប់ផ្កា, កូនស្នប (ផ្កា) (ជាស្លឹកក្លាយមួយដែលនៅពីក្រោមផ្កា ឬអ័ក្សផ្កានៅក្នុងពួករុក្ខជាតិគ្រាប់ជិត ឬជាស្រកានៅក្នុងកោនញីនៃពួករុក្ខជាតិគ្រាប់ស្រាត)

**brady-** /ˈbradi/ [prefix] បុព្វបទមានន័យថា យឺត

**bradycardia** /ˌbradɪˈkɑːdɪə/ [n] តំហាយចង្វាក់បេះដូង

**brain** /breɪn/ [n] ខួរក្បាល

**brainstorming** /ˈbreɪnstɔːmɪŋ/ [n] ការបង្កើតមតិ (ការនិយាយភ្លាមៗពីប្រធានបទអ្វីមួយដោយមិនបានគិតឱ្យបានម៉ត់ចត់ជាមុនថាត្រូវ ឬខុស)

**brake** /breɪk/ [n] ហ្វ្រាំង (ឧបករណ៍សម្រាប់ទប់ ឬបន្ថយចលនានៃចលករ)

**bran** /bran/ [n] កន្ទក់ (លទ្ធផលបានមកពីការបុក កិនយកគ្រាប់អង្ករចេញពីស្រូវ)

- rice bran /rʌɪs bran/ [n] កន្ទក់

**branch** /brɑːn(t)ʃ/ [n] មែកឈើ, មែកធាង, សាខា

- inclined branch /ɪnˈklʌɪnd brɑːn(t)ʃ/ [n] មែកទ្រេត
- leafy branch /ˈliːfi brɑːn(t)ʃ/ [n] មែកឈើដែលមានស្លឹកច្រើន
- primary branch /ˈprʌɪm(ə)ri brɑːn(t)ʃ/ [n] ស្មែងទីមួយ
- primary panicle branch /ˈprʌɪm(ə)ri ˈpanɪk(ə)l brɑːn(t)ʃ/ [n] ស្មែងកួរទីមួយ (ស្មែងដែលបែកចេញពីអ័ក្សនៃកួរស្រូវ (អ័ក្សមេនៃកួរស្រូវ) ហើយស្មែងទី១នេះ ជាកន្លែងដែលស្មែងទី ២ ត្រូវដុះចេញពីវា)
- secondary panicle branch /ˈsɛk(ə)nd(ə)ri ˈpanɪk(ə)l brɑːn(t)ʃ/ [n] ស្មែងទីពីរនៃកួរស្រូវ (ស្មែងដែលដុះចេញពីស្មែងទីមួយ ហើយកាន់ទ្រគ្រាប់)

**branchi-** /ˈbraŋkɪ/ [prefix] បុព្វបទមានន័យថា ស្រកី

**branchia** /ˈbraŋkɪə/ [n] ស្រកី

**branchial** /ˈbraŋkɪəl/ [adj] ដែលទាក់ទងនឹងស្រកី

**branchial arches** /ˈbraŋkɪəl ɑːtʃɪz/ [n pl] ធ្នូស្រកី, ស្និតស្រកី (ឆ្អឹងខ្ចី ឬម៉ាសឆ្អឹង ដែលផ្តល់ភាពរឹងមាំដល់ស្រកីត្រីជាធម្មតាមានធ្នូប្រាំគូ)

**brand** /brand/ [n] យីហោ, ម៉ាក, សញ្ញា

**brand name** /brand neɪm/ [n] ឈ្មោះយីហោ

***Brassica juncea*** [sci.n] សូមមើលពាក្យ៖ mustard greens

***Brassica juncea* var. *rugosa*** [sci.n] សូមមើលពាក្យ ៖ swatow mustard

***Brassica oleracea*** [sci.n] សូមមើលពាក្យ៖ cabbage

***Brassica oleracea* var. *alboglabra*** [sci.n] សូមមើលពាក្យ៖ Chinese broccoli, Chinese kale

***Brassica oleracea* var. *botrytis*** [sci.n] សូមមើលពាក្យ៖ cauliflower

***Brassica oleracea* var. *capitata*** [sci.n] សូមមើលពាក្យ៖ cabbage

**Brazil pusley** /brəˈzɪl pʌsleɪ/ [n] ម្អមភ្នំឈ្មោល (ឈ្មោះវិទ្យាសាស្ត្រ *Richardia brasiliensis*)

**breadfruit** /ˈbrɛdfruːt/ [n] ខ្នុរសម្ល, ផ្លែសាកេ

**break down** /breɪk daʊn/ [n] ការរលំ, ការបរាជ័យ

**breakish** /ˈbriːkɪʃ/ [adj] ភ្លាវ (ទឹកសាបលាយនឹងទឹកសមុទ្រ)

**breast** /brɛst/ [n] ដោះ

**breath** /brɛθ/ [n] ខ្យល់ចេញពីសួត

**breathe** /briːð/ [v] ដកដង្ហើម

**breathing** /ˈbriːðɪŋ/ [n] សូមមើលពាក្យ៖ respiration

**breathless** /ˈbrɛθləs/ [adj] ដង្ហក់, អស់ដង្ហើម

**breccia** /ˈbrɛtʃə/ [n] ប្រហោង geols, ក្រួសជ្រុងៗផ្សាជាប់គ្នាជាដុំ "ប្រែស"

- calcic breccia /ˈkalsɪk ˈbrɛtʃə/ [n] ថ្មប្រែសដែលកើនពីកូនក្រួសកំបោរផ្សាភ្ជាប់គ្នា

**brecciation** /brɛtʃˈeɪʃ(ə)n/ [n] (សទិសន័យ៖ breccia-like structure) ទម្រង់ដូចជាដុំថ្មកិនផ្សាភ្ជាប់គ្នាជាផ្ទាំង, ទម្រង់ ប្រែស

**breech** /briːtʃ/ [n] រង្វះភ្លៅ

- breech birth /briːtʃ bəːθ/ [n] (សទិសន័យ៖ breech resentation) ការកើតកូនច្រាស់ជើង, កូនកើតច្រាស់ជើង
- breech resentation /briːtʃ rɛz(ə)nˈteɪʃ(ə)n/ [n] សូមមើលពាក្យ៖ breech birth

**breed** /briːd/ [v] បង្កាត់ពូជ, ចិញ្ចឹម

**breed** /briːd/ [n] សូមមើលពាក្យ៖ race

- breed true /briːd truː/ [v] បង្កាត់ពូជសុទ្ធ, ជម្រើសពូជសុទ្ធ (ក្រុមពូជមួយនៃឯកត្តៈអូម៉ូស៊ីកូតដែលបានមកពីការបង្កាត់ក្នុងដែលនៅពេលបង្កាត់គ្នាទៅវិញទៅមកផលិតបានជំនាន់ថ្មីមួយនៃឯកត្តៈអូម៉ូស៊ីកូត)
- foreign breed /ˈfɒrɪn briːd/ [n] ពូជពីបរទេស, ពូជនាំចូល
- local breed /ˈləʊk(ə)l briːd/ [n] (សទិសន័យ៖ native breed) ពូជក្នុងស្រុក
- native breed /ˈneɪtɪv briːd/ [n] សូមមើលពាក្យ៖ local breed
- pure breed /pjʊə briːd/ [n] ពូជសុទ្ធ

**breeder** /ˈbriːdə/ [n] អ្នកបង្កាត់ពូជ, អ្នកជម្រើសវិទូ

**plant breeder** /plɑːnt ˈbriːdə/ [n] រុក្ខជម្រើសវិទូ

**breeding value** /ˈbriːdɪŋ ˈvaljuː/ [n] តម្លៃបង្កាត់ពូជ, តម្លៃជម្រើសពូជ (តម្លៃមេ-បាមួយត្រូវបានវិនិច្ឆ័យដោយការសម្តែងឡើងនៃកូនរបស់វា ចេញពីការបង្កាត់ជាច្រើនដង។ តម្លៃបង្កាត់របស់ឯកត្តៈមួយ ត្រូវបានកំណត់ជា២ដងនៃលទ្ធភាពផ្សំទូទៅរបស់វា (general combining ability= GCA)។)

**breeding** /ˈbriːdɪŋ/ [n] ជម្រើសវិទ្យា (ការសិក្សាក្នុងការជ្រើសរើស និងការបង្កាត់រវាងឯកត្តៈសមស្របទាំងឡាយ)

- controlled breeding /kənˈtrəʊld ˈbriːdɪŋ/ [n] ការបង្កាត់ត្រួតពិនិត្យដោយអនុញ្ញាតឱ្យតែឯកត្តៈដែលមានលក្ខណៈជ្រើសរើសធ្វើការបន្តពូជ
- conventional breeding /kənˈvɛnʃ(ə)n(ə)l ˈbriːdɪŋ/ [n] ធម្មជម្រើសវិទ្យា (វិធីសាស្ត្រជម្រើស ដោយប្រើវិធីសាស្ត្រសាមញ្ញដូចជា ការបង្កាត់រវាងឯកត្តៈពីរដែលនៅក្នុងអម្បូរតែមួយ)
- cross breeding /krɒs ˈbriːdɪŋ/ [n] ការបង្កាត់ខ្វែង (មេបាមានពូជ ឬអម្បូរខុសគ្នា)
- forest tree breeding /ˈfɒrɪst triː ˈbriːdɪŋ/ [n] ការបង្កាត់ពូជដើមឈើព្រៃ (ការអនុវត្តដែលប្រើចំណេះដឹងសេនេទិចអភិវឌ្ឍន៍សុរុក្ខកម្មដើមឈើ។ ការបង្កាត់ពូជឈើដែលមានលក្ខណៈសាមញ្ញ គឺផ្អែកទៅលើការជ្រើសរើសឯកត្តៈរកលក្ខណៈ ណាមួយដែលគេចង់បាន ហើយបង្កាត់ឯកត្តៈទាំងនេះ ដើម្បីផលិតបាននូវក្រុមពូជមួយដែលមានគុណភាពល្អជាង។)
- plant breeding /plɑːnt ˈbriːdɪŋ/ [n] រុក្ខជម្រើសវិទ្យា, ការបង្កាត់រុក្ខជាតិ
- rice breeding /rʌɪs ˈbriːdɪŋ/ [n] ជម្រើសពូជស្រូវ
- selective breeding /sɪˈlɛktɪv ˈbriːdɪŋ/ [n] ការបង្កាត់ជម្រើស (ការបង្កាត់សត្វ ឬរុក្ខជាតិដើម្បីទទួលបានលក្ខណៈដែលចង់បាន)
- tree breeding /triː ˈbriːdɪŋ/ [n] ការបង្កាត់ដើមឈើ
- breeding arboretum /ˈbriːdɪŋ ˌɑːbəˈriːtəm/ [n] ចម្ការឈើដាំទុកសម្រាប់បង្កាត់ពូជ (ជម្រើស) (ការប្រមូលដើមឈើឬប្រភេទពូជសម្រាំងទុកសម្រាប់ការបង្កាត់ពូជ។ បើសិនការប្រមូលទុក(ជ្រើសរើស) ជាផ្នែកនៃសរីរាង្គលូតលាស់នោះ ជួនកាលគេហៅថាជាធនាគារក្លូន(មែកបំបៅ/ផ្សាំ)។ ការបើកលំហ (កាប់ រហាល) វប្បកម្ម និងការការពារត្រូវបានគ្រោងទុកដើម្បីជំរុញឱ្យចេញផ្កាផ្លែឱ្យបានឆាប់ និងត្រួតពិនិត្យការពោយលម្អង និងការប្រមូលគ្រាប់ពូជ។)
- breeding individual /ˈbriːdɪŋ ɪndɪˈvɪdʒʊ(ə)l/ [n] ឯកត្តបង្កាត់

**breeze** /briːz/ [n] ខ្យល់ជំនោរ

- land breeze /land briːz/ [n] ខ្យល់ជំនោរដី

- mountain breeze /ˈmaʊntɪn briːz/ [n] ខ្យល់ជំនោរភ្នំ
- sea breeze /siː briːz/ [n] ខ្យល់ជំនោរសមុទ្រ

**brewery** /ˈbrʊəri/ [n] រោងចក្រស្រាបៀរ

**brewing** /bruːɪŋ/ [n] ផលិតកម្មស្រា ឬស្រាបៀរ

**briefing** /ˈbriːfɪŋ/ [n] ព័ត៌មានពិស្តារ

**brisket** /ˈbrɪskɪt/ [n] សាច់ទ្រូង (សត្វ)

**brittle** /ˈbrɪt(ə)l/ [adj] ស្រួយ, ផុយ

**broad spectrum** /brɔːd ˈspɛktrəm/ [n] ស្បិចធំទូលាយ, ថ្នាំអាចសម្លាប់មេរោគបានច្រើនយ៉ាង, អាចកំចាត់មេរោគច្រើនយ៉ាង (ចំពោះថ្នាំអង់ទីប៉ូទិក)

**broadcast** /ˈbrɔːdkɑːst/ [v] ព្រោះ (បាចពូជ ឬជីឱ្យមានលក្ខណៈឯកសណ្ឋានទៅលើផ្ទៃដី ឬស្រែដោយដៃ)

**broadleaf** /ˈbrɔːdliːf/ [n] ប្រភេទរុក្ខជាតិ ដែលមានស្លឹកធំ (មានលក្ខណៈផ្ទុយពីរុក្ខជាតិស្លឹកម្ជុល។)

**broccoli** /ˈbrɒkəli/ [n] ផ្កាខាត់ណាបៃតង

**broiler** /ˈbrɔɪlə/ [n] មាន់សាច់, មាន់ចិញ្ចឹមយកសាច់

**bromine** /ˈbrəʊmiːn/ [n] ប្រូម (និមិត្តសញ្ញាគីមី Br)

**bronchi** /ˈbrɒŋki/ [n pl] (ឯកវចនៈ៖ bronchus) ទងសួត

**bronchial** /ˈbrɒŋkɪəl/ [adj] នៃទងសួត

**bronchial asthma** /ˈbrɒŋkɪəl ˈasmə/ [n] សហឹសរោគទងសួត ឬហឺត

**bronchial spasm** /ˈbrɒŋkɪəl ˈspaz(ə)m/ [n] ការរួមរួញដ៏ឆាប់រហ័សនៃសួត ដោយអចេតនា

**bronchial tube** /ˈbrɒŋkɪəl tjuːb/ [n] ចង់សួតឆ្មារៗ (តូចៗ)

**bronchiole** /ˈbrɒŋkɪəʊl/ [n] ទងសួតតូច

**bronchus** /ˈbrɒŋkəs/ [n] (ពហុវចនៈ៖ bronchi) ទងសួត

**bronzing** /brɒnzɪŋ/ [n] ការឡើងពណ៌ទង់ដែងលើស្លឹករុក្ខជាតិ

**brood** /bruːd/ [v] ក្រាបពង

**brood** /bruːd/ [n] ឯកត្តៈទាំងឡាយដែលញាស់ចេញព្រមគ្នា (ក្នុងពេលតែមួយពីពង ដែលពងដោយមេបាមួយគូ ហើយជាធម្មតាវាអាចពេញវ័យក្នុងពេលតែមួយដូចគ្នាដែរ)

**brooder house** /ˈbruːdə haʊs/ [n] ទ្រុងដាក់កូនសត្វទើបញាស់

**brook** /brʊk/ [n] សូមមើលពាក្យ៖ creek

**broth** /brɒθ/ [n] មជ្ឈដ្ឋានរាវ (សម្រាប់បណ្តុះអតិសុខុមប្រាណ)

**brown sleeper** /braʊn ˈsliːpə/ [n] ត្រីដំរីខ្មៅ (ឈ្មោះវិទ្យាសាស្ត្រ *Eleotris fusca*)

**brucellosis** /ˌbruːsəˈləʊsɪs/ [n] ជំងឺរលូតកូន, ជំងឺគ្រុនសត្វពាហនៈ, ជំងឺប្រ៊ុយសែលឡូស (ជំងឺសត្វពាហនៈដែលបណ្តាលឱ្យរលូតកូន)

**bruchid** [n] ក្រុមសត្វល្អិតស៊ីគ្រាប់ (ប្រភេទក្រុមសត្វល្អិតជាច្រើនដែលស៊ីប្រភេទគ្រាប់នៃពួកគ្រួសារ Leguminasae)

**bruise** /bruːz/ [n] របួសខ្ទាំសាច់, ជាំសាច់

**bruit** /bruːt/ [n] សូរ

**brush** /brʌʃ/ [n] ព្រៃគុម្ពោត, ច្រាស

**brush matting** /brʌʃ ˈmatɪŋ/ [n] (ចំពោះធរណីវិទ្យា) (សទិសន័យ៖ grating, mattress) ការដាក់ប្រដើសដើម្បីទប់ដី

**brussels sprout** /ˈbrʌs(ə)lz sprəʊt/ [n] ប្រ៊ូសែលស្ប្រ៉ាវ

**bucca** /ˈbuːkə/ [n] មាត់

**buccal** /ˈbʌk(ə)l/ [adj] នៃមាត់

**bud** /bʌd/ [v] តភ្ជែក (ផ្សាំដើមឈើ)

**bud** /bʌd/ [n] ១. (ចំពោះរុក្ខជាតិ) ពន្លក (មែកឈើ), ត្រួយពន្លក, ក្ដឹបពន្លក (ផ្នែកមួយស្ថិតនៅលើថ្នាំងនៃដើមស្រូវ ហើយហ៊ុំព័ទ្ធដោយស្រទបស្លឹក ហើយក្ដឹបពន្លកអាចដុះចេញ ឬបង្កើតដើមបែក)
២. (ចំពោះសត្វ) អញ្ច្រាញ (កន្ទួលលើអណ្តាតសម្រាប់ឱ្យដឹងរសជាតិ)

- axillary bud /akˈsɪləri bʌd/ [n] ពន្លកមែក (ត្រួយពន្លកដែលដុះឡើងនៅត្រង់មុំស្លឹក)
- lateral bud /ˈlat(ə)r(ə)l bʌd/ [n] ពន្លកមែក
- terminal bud /ˈtəːmɪn(ə)l bʌd/ [n] ពន្លកចុង, ក្ដឹបឬពន្លក (កំពូលរុក្ខជាតិ)

**bud scale** /bʌd skeɪl/ [n] ស្លឹកពន្លក

**budding** /ˈbʌdɪŋ/ [n] (សទិសន័យ៖ graft budding) ការចេញពន្លក, ការតភ្នែក, ការផ្សាំពន្លក (ផ្សាំដើមឈើ) (ការផ្សាំដោយបញ្ចូលពន្លកដែលមានជាលិកាតែបន្តិចចូលទៅក្នុងស្នាមវះឬរន្ធចោះនៅក្នុងសម្បកនៃរុក្ខជាតិពូជ គល់ផ្សាំ។ ក្រោយពីវាផ្សារភ្ជាប់គ្នាហើយ ផ្នែកខាងលើនៃរុក្ខជាតិគល់ផ្សាំនៅខាងលើពន្លកផ្សាំត្រូវបានកាត់ចោល។

- graft budding /grɑːft ˈbʌdɪŋ/ [n] សូមមើលពាក្យ៖ budding

**budget** /ˈbʌdʒɪt/ [n] ថវិកា (គម្រោងទឹកប្រាក់សម្រាប់ចំណាយទៅលើកម្មវិធី ឬគម្រោងអ្វីមួយ)

**budwood** /bʌdwʊd/ [n] ភ្នែក ឬក្តឹបពន្លកនៃរុក្ខជាតិ

**buffalo** /ˈbʌfələʊ/ [n] ក្របី

- iron buffalo /ˈʌɪən ˈbʌfələʊ/ [n] សូមមើលពាក្យ៖ power tiller
- white buffalo /wʌɪtˈbʌfələʊ/ [n] សត្វគោព្រៃ (នៅប្រទេសអាមេរិកខាងជើង)

**buffer** /ˈbʌfə/ [v] ធ្វើជាទ្រនាប់, ការពារ

**buffer** /ˈbʌfə/ [n] ធន់ករ pH (សារធាតុដែលធ្វើឱ្យ pH មិនងាយប្រែប្រួល), ទ្រនាប់, សារធាតុទប់ប្រតិកម្ម ( ជាសារធាតុ ឬលក្ខខណ្ឌអ្វីមួយដែលទប់នឹងការផ្លាស់ប្តូរដែលបណ្តាលមកពីឥទ្ធិពលខាងក្រៅ។ ក្នុងវិស័យគីមី វាមានន័យសំដៅសារធាតុមួយដែលកាត់បន្ថយជាអប្បបរមានូវការប្រែប្រួល pH នៅពេលដែលដាក់អាស៊ីត ឬបេស។ នៅក្នុងបរិស្ថាន ឧ. ទាក់ទងទៅនឹងប្រភេទរុក្ខជាតិ ឬតំបន់ដែលកាត់បន្ថយជាអប្បបរមានូវឥទ្ធិពល នៃការផ្លាស់ប្តូរអាកាសធាតុ (ឧ. គំរបព្រៃកាត់បន្ថយភាពប្រែប្រួលសីតុណ្ហភាពនៅពេលថ្ងៃ)។ ជាធម្មតា ន័យនៅក្នុងការបង្កាត់ពូជទាក់ទងទៅនឹងតំបន់ព័ទ្ធជុំវិញព្រៃពូជ ដើម្បីទប់មិនឆ្លងលម្អងពីខាងក្រៅ។)

**buffer-strip** /ˈbʌfə strɪp/ [n] បន្ទះដីដែលគេដាំរុក្ខជាតិការពារកុំឱ្យទឹកច្រោះដី

**bug** /bʌg/ [n] ស្រឹង, សង្កើច (ពពួកសត្វល្អិតស្ថិតនៅក្នុងលំដាប់ Hemiptera)

- assassin bug /əˈsasɪn bʌg/ [n] ស្រឹងគោកបន្លាខ្នង (សត្វរំពាស្ថិតក្នុងលំដាប់ Hempitera គ្រួសារ Reduviidae)
- bedbug /ˈbɛdbʌg/ [n] សង្កើច
- black bugs /blak bʌgz/ [n pl] សង្កើចខ្មៅ (ឈ្មោះវិទ្យាសាស្ត្រ *Scotinophara spp.* សត្វល្អិតចង្រៃស្ថិតក្នុងលំដាប់ Hermiptera គ្រួសារ Pentatomidae)
- giant water bug /ˈdʒʌɪənt ˈwɔːtə bʌg/ [n] កន្ទាទូក
- lady bug /ˈleɪdi bʌg/ [n] អណ្តើកមាស (សត្វរំពាស្ថិតក្នុងលំដាប់ Coleoptera គ្រួសារ Coccinellidae)
- mealybug /ˈmiːlibʌg/ [n] ចៃស, ក្រាស
- mirid bug /ˈmɪrɪd bʌg/ [n] ស្រឹងគោកទ្រូងខ្មៅ (សត្វរំពាស្ថិតក្នុងលំដាប់ Hemiptera គ្រួសារ Miridae អម្បូរ *Cyrtorhinus lividipennis*)
- rice bug /rʌɪs bʌg/ [n] ស្រឹងស្រូវ (សត្វល្អិតមួយប្រភេទនៃអម្បូរ *Leptocorisa oratorius* ដែលចូលចិត្តបំផ្លាញដំណាំស្រូវដោយជញ្ជក់គ្រាប់ស្រូវនៅដំណាក់កាលស្រូវដាក់ទឹកដោះ)
- ripple bug /ˈrɪp(ə)l bʌg/ [n] ស្រឹងទឹកតូច (សត្វរំពាក្នុងលំដាប់ Hempitera គ្រួសារVeliidae)
- shield bug /ʃiːld bʌg/ [n] សូមមើលពាក្យ៖ stink bug
- stink bug /stɪŋk bʌg/ [n] (សទិសន័យ៖ shield bug) ពពួកគ្រួសារស្រឹង
- velid bug [n] ស្រឹងទឹកតូច (ប្រភេទសត្វល្អិតស្ថិតក្នុងអម្បូរ *Microvelia douglasi*)

**bulb** /bʌlb/ [n] គល់ (សក់ ឆាមជាដើម), មើមស្រទាប់, កូនមើម, គល់មើម

**bulder** /ˈbəʊldə/ [n] សូមមើលពាក្យ៖ small stoneblack

**bulimia nervosa** /bjʊˈlɪmɪə nəˈvəʊsə/ [n] ការចង់បរិភោគអាហារ មិនចេះឆ្អែតឆ្អន់

**bull** /bʊl/ [n] គោបា, គោ ឬក្របីឈ្មោល

**bulla** /ˈbʊlə/ [n] ពងស្បែក

**bulldozer** /ˈbʊldəʊzə/ [n] ឡានអាប៊ុលឈូសដី

**bulletin** /ˈbʊlɪtɪn/ [n] ព្រឹត្តិប័ត្រ (សេចក្តីរាយការណ៍ជាផ្លូវការអំពីរឿងរ៉ាវផ្សេងៗ)

**bullock** /ˈbʊlək/ [n] (សទិសន័យ៖ ox) គោគ្រៀវ

**bunching onion** /bʌn(t)ʃɪŋ ˈʌnjən/ [n] ខ្ទឹមស្លឹក (ឈ្មោះវិទ្យាសាស្ត្រ *Allium fistulosum*)

**bund** /bʌnd/ [n] ភ្លឺស្រែ (ផ្នែកខ្ពស់ព័ទ្ធជុំវិញស្រែ ដើម្បីការពារការពារការហូរច្រោះដី ឬផ្ទុកទឹកក្នុងស្រែ)

- rice field bund /rʌɪs fiːld bʌnd/ [n] ភ្លឺស្រែ
- contour bund /ˈkɒntʊə bʌnd/ [n] ទំនប់វង់ជុំវិញ

**bundle end** /ˈbʌnd(ə)l ɛnd/ [n] ចុងបាច់ (ចុងបាច់សរសៃនាំក្នុងមេសូភីលនៃស្លឹក)

**bundle** /ˈbʌnd(ə)l/ [v] រួមបញ្ចូល, ចងជាកណ្ដាប់

**bundle** /ˈbʌnd(ə)l/ [n]

១. កណ្ដាប់, បង្វិច

២. សហាគមន៍ដី

- amphicribral bundle [n] បាច់អំភីគ្រីប (បាច់សរសៃដែលផ្លូវអែម នៅព័ទ្ធជុំវិញស៊ីឡែម ដូចជាមាននៅក្នុង បណ្ណង្គជាតិខ្លះ)
- bicollateral bundle /bɪˈkɒˈlat(ə)r(ə)l ˈbʌnd(ə)l/ [n] បាច់សរសៃអម (បាច់សរសៃនាំនៃរុក្ខជាតិដែលមានក្រុមផ្លូវអែមពីរ ដោយមួយក្រុមនៅខាងក្នុងស៊ីឡែម និងក្រុមមួយទៀតនៅខាងក្រៅ ឧ. ប៉េងប៉ោះ)
- vascular bundle /ˈvaskjʊlə ˈbʌnd(ə)l/ [n] (សទិសន័យ៖ vascular system) ប្រព័ន្ធសរសៃនាំ, បាច់សរសៃនាំ (ក្រុមសរសៃស៊ីឡែម និងផ្លូវអែមដែលដឹកនាំទឹក និងសូលុយងឆ្លងកាត់ឫស ដើម និងស្លឹកនៃរុក្ខជាតិសរសៃនាំ)

**Bunsen burner** /bʌnsn ˈbɜːnə/ [n] ចំពុះប៊ុនសិន(ក្បាលមាន់)

**bureaucrat** /ˈbjʊərəkrat/ [n] ការិយាល័យនិយម (អ្នកដែលនិយមនៅតែក្នុងការិយាល័យ)

**burn** /bəːn/ [v] រលាក, ដុត

**burrow** /ˈbʌrəʊ/ [n] អំពាយសត្វ (រូងក្នុងដី)

**burrower** /ˈbʌrəʊə/ [n] សត្វកកាយដី

**bursa** /ˈbəːsə/ [n] ថង់ទឹកសន្លាក់ (ថង់ទឹករំអិលនៅចន្លោះឆ្អឹងជង្គង់)

**bursa copulatrix** [n] រន្ធភេទសត្វល្អិត

**bursa seminalis** [n] រន្ធបង្កកំណើត

**burst size** /bəːst sʌɪz/ [n] បរិមាណវីរុសកើតថ្មី

**bush** /bʊʃ/ [n] គុម្ពោធ, ព្រៃគុម្ពោធ

**bushmeat** /ˈbʊʃmiːt/ [n] សាច់សត្វព្រៃ

**business** /ˈbɪznəs/ [n] ជំនួញ, ពាណិជ្ជកម្ម

**butterfly** /ˈbʌtəflʌɪ/ [n] សត្វមេអំបៅ

**buttock** /ˈbʌtək/ [n] (សទិសន័យ៖ rump) កំពីងគូទ, កន្ទុតអង្គ, កញ្ចុញគូទ

**buttress** /ˈbʌtrɪs/ [n]

១. (ចំពោះរុក្ខជាតិ) ប្រឹង, គល់ឈើ, ដើមរឹងមានជាតិឈើ ឬឫសគល់ ដែលមានតួនាទីទប់ដើមជាពិសេស សម្រាប់ដើមឈើធំៗនៅតំបន់ព្រៃត្រូពិច

២. (ចំពោះដី) សូមមើលពាក្យ៖ spur

**leaf buttress** /liːf ˈbʌtrɪs/ [n] ពន្លកស្លឹក

**by-product** /bʌɪ ˈprɒdʌkt/ [n] (សទិសន័យ៖ secondary product) ផលិតផលរង, អនុផល (ផលិតផលមានតម្លៃតិចជាងផលិតផលចម្បងដូចជា ផលិតផលចម្បងនៃការចិញ្ចឹមគោគឺសាច់គោ ឯអនុផលរបស់វាមាន ស្បែក ឆ្អឹងជាដើម)

- animal by-product /ˈanɪm(ə)l bʌɪ ˈprɒdʌkt/ [n] អនុផលសត្វ

C

**cabbage** /ˈkabɪdʒ/ [n] ស្ពៃក្ដោប (ឈ្មោះវិទ្យាសាស្ត្រ *Brassica oleracea* var. *capitata*)

**cacao** /kəˈkɑːəʊ/ [n] កាកាវ (ឈ្មោះវិទ្យាសាស្ត្រ *Theobroma cacao*)

**cachexia** /kəˈkɛksɪə/ [n] ភាពរីងរៃ

**cackle** /ˈkak(ə)l/ [v] ខ្កត (មាន់)

**cactus** /ˈkaktəs/ [n] ដើមដំបងយក្ស

**cadastre** /kəˈdasˌtər/ [n] ការិយាល័យចុះបញ្ជីដីធ្លី (សុរិយោដី)

**cadaver** /kəˈdeɪvə/ [n] សាកសព, ខ្មោច

**Cadmium** /ˈkadmɪəm/ [n] កាត់ម្យូម (និមិត្តសញ្ញាគីមី Cd)

**caducous** /kəˈdjuːkəs/ [adj] ជ្រុះលឿន

**caecilian** /sɪˈsɪlɪən/ [n] សត្វគ្មានជើង

**caecum** /ˈsiːkəm/ [n] សូមមើលពាក្យ៖ cecum

**caeno-** [c] (ដូច៖ caino-) បុព្វបទមានន័យថា ថ្មី (ទើបនឹងកើតឡើង)

***Caesalpinia pulcherrima*** [sci.n] ផ្កាក្ងោក

**caffeine** /ˈkafiːn/ [n] កាហ្វេអ៊ីន

**cage** /keɪdʒ/ [n] ទ្រុង, ប្រអប់

**cage** /keɪdʒ/ [v] ក្រុង, ដាក់ទ្រុង (សត្វ)

**caino-** [prefix] សូមមើលពាក្យ៖ caeno-

***Cajanus cajan*** [sci.n] សូមមើលពាក្យ៖ pigeon pea

**cal spar** /ˈkal spɑː/ [n] ថ្មកំបោរជាក្រាមកាលស៊ីត

**calabash** /ˈkaləbaʃ/ [n] ឃ្លោកសាដៀវ

***Calamus salicifolius*** [sci.n] លំពាត់

**calcar** /ˈkal kɑr/ [n] ខ្នាយ (ផ្នែកជើងរបស់សត្វល្អិត ដែលគេតែងប្រទះឃើញនៅលើជើងក្រោយទាំងសងខាងនៃមមាចត្នោត។ ខ្នាយនេះ មានតែចំពោះប្រភេទមមាចដើមប៉ុណ្ណោះ ចំណែកឯពួកមមាចស្លឹក គឺគ្មានខ្នាយឡើយ)

**calcarenite** [n] ថ្មកំបោរ

**calcareous** /kalˈkɛːrɪəs/ [adj] ដែលជាថ្មកំបោរ, ជាតិកំបោរ

**calcareous tufa** /kalˈkɛːrɪəs ˈt(j)uːfə/ [n] (សទិសន័យ៖ tuffaceous limestone, tuff) ស្រទាប់កំបោរដែលរឹង

**calci** /ˈkalsi/ [adj] ដែលមានធាតុកាល់ស្យូម

**calcicole** /ˈkalsɪkəʊl/ [n] រុក្ខជាតិចំណូលកំបោរ

**calciferous** /kalˈsɪf(ə)rəs/ [adj] ដែលមានធាតុកាល់ស្យូម

**calcification** /kalsɪfɪˈkeɪʃ(ə)n/ [n] ការជក់ឡើងមកស្រទាប់លើនៃអំបិលដែលមានសារធាតុកាល់ស្យូម

**calcifuge** /ˈkalsɪfjuːdʒ/ [n] (សទិសន័យ៖ oxylophyte) រុក្ខជាតិមិនចំណូលកំបោរ, រុក្ខជាតិដុះលូតលាស់លើដីអាស៊ីត

**calciphyte** /ˈkalsifʌɪt/ [n] រុក្ខជាតិនិយមកំបោរ

**calciphytic** /ˈkalsiphytic/ [adj] ដែលនិយមកំបោរ

**Calcium** /ˈkalsɪəm/ [n] កាល់ស្យូម (និមិត្តសញ្ញាគីមី Ca)

**Calculator** /ˈkalkjʊleɪtə/ [n] ម៉ាស៊ីនគិតលេខ

**calculus** /ˈkalkjʊləs/ [n] (សទិសន័យ៖ stone) គ្រាប់ក្រួស (នៅក្នុងប្លោកនោម ឬក្នុងថង់ទឹកប្រមាត់)

**cultural calendar** /ˈkʌltʃ(ə)r(ə)l ˈkalɪndə/ [n] ប្រតិទិនដាំដុះ (ការរៀបចំពេលវេលាសម្រាប់ដាំដុះ ថាតើពេលណាត្រូវចាប់ផ្ដើម ហើយថាតើវាសមស្របនឹងការដុះលូតលាស់របស់ដំណាំផងដែរ)

**calf** /kɑːf/ [n] កូនគោ, កំភួនជើង

**calibration** /kalɪˈbreɪʃ(ə)n/ [n]

១. ការក្រិតតាមខ្នាត ( ទំនាក់ទំនងរវាងនៃការអានក្រិតនៃឧបករណ៍មួយនិងក្រិតបទដ្ឋាន (standard) នៃឧបករណ៍មួយទៀត ឧ.វិធី វាស់សំណើមតាប្រដាប់វាស់សំណើម និង តាមឡសំងួតបទដ្ឋាន ក្នុងការកំណត់បន្ទុកសំណើម។)

២. ក្រិតកម្ម (ការក្រិត ឬការកំណត់តាមខ្នាត តាបរិមាណដី ថ្នាំសត្វល្អិត... មុនពេលដំណើរការពិតប្រាកដ)

**calibration of sprayer** /kalɪˈbreɪʃ(ə)n ɒv ˈspreɪə/ [n] ការក្រិតឧបករណ៍បាញ់ថ្នាំ (ការវាស់កម្រិតមាឌនៃសូលុយស្យុងថ្នាំដែលប្រើប្រាស់សម្រាប់បាញ់ទៅលើដំណាំ ថាតើអស់ប៉ុន្មាន ប្រសិនបើគេបានកត់រយៈពេលបាញ់ ចំងាយដើរទទឹងជះ (មុខកាត់នៃការបាញ់))

**Californium** /ˌkalɪˈfɔːnɪəm/ [n] កាលីផរញ៉ូម (និមិត្តសញ្ញាគីមី Cf)

**calix** /ˈkalɪks/ [n] កញ្ចុំត្របក

**calliper** /ˈkalɪpə/ [n] ឧបករណ៍វាស់ទំហំ

**Calliphora** [n] (សទិសន័យ៖ blow fly, bluebottle) រុយសាលីផ្លូវ៉ា (រុយខៀវ)

**callus** /ˈkaləs/ [n]

១. (ចំពោះសត្វ) ផ្លែ, ស្បែកក្រិន

២. (ចំពោះរុក្ខជាតិ) ក្រិន, របួសក្រិន ១)ជាដុំនៃកោសិកា parenchyma ដែលវិវឌ្ឍន៍ពី និងនៅជុំវិញជាលិការបួសរបស់រុក្ខជាតិដើម្បីកាត់បន្ថយ ការហូតទឹកពីមុខរបួសនិងចាប់ផ្តើមធ្វើឱ្យជាសះវិញ។ នៅក្នុងការបំបៅឬផ្សាំ វាកើតឡើងនៅកន្លែងទីប្រសព្វ នៃការបិទភ្ជាប់គ្នាដែលចេញពីកោសិការស់ទាំង២នៃត្រួយផ្សាំនិងគល់ផ្សាំ។ ការផលិត និងការចាក់ស្រេះផ្សារ ភ្ជាប់គ្នានៃកោសិកា parenchyma (ឬ callus) ជាជំហានសំខាន់មួយក្នុងដំណើរការជាសះនៃការផ្សាំបំបៅ។ ២)នៅក្នុងការបណ្ដុះជាលិកា(micropropagation) និយាយសំដៅលើដុំម៉ាស់មិនអាចបំបែកបាននៃកោសិកា។

**calm** /kɑːm/ [adj] មិនឆេវឆាវ, ស្ងប់

**calorie** /ˈkaləri/ [n] កាល់ឡូរី (ឯកតារង្វាស់តម្លៃថាមពលពីម្ហូបអាហារ)

**calve** /kɑːv/ [v] កើតកូន

**calyptrogen** /kʌlipˈ trəʊdʒ(ə)n/ [n] កាលីបត្រូចឹង (ស្រទាប់កោសិកាដែលលូតគ្របពីលើផ្នែកលូតលាស់របស់ឫស ហើយដែលវិវត្តទៅជាក្បាលឫស)

**calyx** /ˈkalɪks/ [n] ត្របកផ្កា ( ជាពាក្យពហុវចនៈប្រើសម្រាប់ទម្រត្របកផ្កានៃផ្កាមួយ។)

**cambium** /ˈkambɪəm/ [n] (ពហុវចនៈ៖ cambia) ស្រទាប់ក្នុងនៃសម្បកឈើ, ជាលិការុក្ខជាតិ ( ស្រទាប់ជាលិកាស្តើងរបស់រុក្ខជាតិនៅចន្លោះរវាងសម្បក និងសាច់ឈើ។ កោសិការបស់វាជាកោសិកាលូតលាស់ (meristem) ពោលគឺ វាអាចបំបែក និងបង្កើតជាកោសិកាថ្មីបាន។ វាមានរាងស៊ីឡាំង នៅក្នុងឫស និងដើម ដែលកើតមាននៅក្នុង ជាលិកាថ្មីសម្រាប់បង្កើតជាលិកានាំជ័រ xylem និង phloem និងសម្បកឈើ)

**Cambrian** /ˈkambrɪən/ [n] កំប្រ៊ីយាង

**camouflage** /ˈkaməflɑːʒ/ [n] ការបន្លំខ្លួន, វិធីបន្លំខ្លួនទៅនឹងបរិស្ថាន

**campaign** /kamˈpeɪn/ [n] ការឃោសនាយុទ្ធនាការ

**campanulate** /kamˈpanjʊlət/ [adj] រាងដូចជួង (ប្រភេទផ្កាមានត្របកជាប់រាងជួង)

**camphor** /ˈkamfə/ [n] ប្រេងកបូរ

**Campylobacteriosis** [n] មេរោគនៃជំងឺរាក

**campylotropous** [adj] អូវ៉ុលកោង, អូវ៉ុលផ្តេក (ជាទិសនៃអូវ៉ុលដែលអូវ៉ុលងាកបានជាមុំមួយធៀបនឹងគ្រាប់ស្ថិតក្នុងទីតាំងនៅចន្លោះ រវាងនៃអូវ៉ុលត្រង់ និងអូវ៉ុលផ្កាប់។)

**camshaft** /ˈkamʃɑːft/ [n] អ័ក្សឡាកាម (អ័ក្សដែលជំនួយដល់ដំណើរការនៃចំហេះក្នុងនៃចលករ)

**canal** /kəˈnal/ [n]

១. បំពង់, ប្រហោង

២. ព្រែក, ប្រឡាយ (ការជីកជាចង្អូរ និងមានទិសដៅជាក់លាក់តាមសណ្ឋានភាពដី ដើម្បីទាញយកទឹកមកស្រោចស្រព ឬសម្រាប់រំដោះទឹកចេញ)

- alimentary canal /alɪˈmɛnt(ə)ri kəˈnal/ [n] បំពង់រំលាយអាហារ
- gastrovascular canal /ˈgastrəʊˈvaskjʊlə kəˈnal/ [n] សូមមើលពាក្យ៖ gastrointestinal tract
- irrigating canal /ˈɪrɪgeɪtɪŋ kəˈnal/ [n] ចង្អូរ ឬរង្វះបញ្ចូលទឹក
- semi-circular canal /ˈsɛmi ˈsəːkjʊlə kəˈnal/ [n] បំពង់ពាក់កណ្តាលរង្វង់

***Cananga odorata*** [sci.n] សូមមើលពាក្យ៖ ylang-ylang

**cancel** /ˈkans(ə)l/ [v] លុបចោល, ប្រកាសទុកជាមោឃៈ

- cancellation /kansəˈleɪʃ(ə)n/ [n] ការលុបចោល, ការទុកជាមោឃៈ

**cancer** /ˈkansə/ [n] មហារីក (ជំងឺ)

**candid** /ˈkandɪd/ [adj] ឥតលាក់លៀម, ស្មោះត្រង់

**candidate** /ˈkandɪdeɪt/ [n] បេក្ខជន

**candling** /ˈkandɪŋ/ [n] ការព្យាបាលត្រចៀកដោយប្រើភ្លើងទៀន

**cane** /keɪn/ [n] ទំពក់, ប្រដាប់ច្រត់ដើរ

**canine** /ˈkanʌɪn/ [n] ឆ្កែ

**canker** /ˈkaŋkə/ [n] ជំងឺដំបៅលើរុក្ខជាតិ (ជំងឺរុក្ខជាតិបង្កដោយបាក់តេរី ឬផ្សិតដោយសម្លាប់ជាលិកាដែលឆ្លង)

***Cannabis indica*** [sci.n] សូមមើលពាក្យ៖ Indian hemp

**cannibalism** /ˈkanɪbəˌlɪz(ə)m/ [n] ការស៊ីសាច់គ្នាឯងជាអាហារ

**cannibalistic** /kænəbəˈlɪstɪk/ [adj] ពួកសត្វស៊ីសត្វមិនរើស (ឧ. ពួកសត្វរំពា)

**canopy** /ˈkanəpi/ [n] គម្របនៃតួរុក្ខជាតិ, កន្សោមស្លឹក (ការផ្គុំគ្នារបស់ស្លឹក និងមែក)

**cantaloupe** /ˈkantəluːp/ [n] ត្រសក់ផ្អែម

**canyon** /ˈkanjən/ [n] កាញ៉ុង

**cap** /kap/ [n] ផ្ចិតឃ្មុំ, មួក, គម្រប

- cradle cap /ˈkreɪd(ə)l kap/ [n] ក្អែលកករ, អាចម៍ក្របី
- ice cap /ʌɪs kap/ [n] គម្របទឹកកក
- oil filler cap /ɔɪl ˈfɪlə kap/ [n] គម្របប្រេងរំអិលចលករ (គម្របប្រេងរំអិលផង និងសម្រាប់មើលកម្រិតប្រេងរំអិលផង)
- root cap /ruːt kap/ [n] ក្បាលឫស

**capability** /keɪpəˈbɪlɪti/ [n]
 ១. (ចំពោះដី) ជម្រាល
 ២. សមត្ថភាព

**capable of being polished** /ˈkeɪpəb(ə)l ɒv ˈbiːɪŋ ˈpɒlɪʃt/ [adj] ដែលអាចធ្វើឱ្យរលោងបាន

**capacitance** /kəˈpasɪt(ə)ns/ [n] លក្ខណៈស្តុកអគ្គិសនី

**capacitation** /kəˈpasɪteɪʃ(ə)n/ [n] សមត្ថភាពភ្ជាប់ (បម្លាស់ប្តូរដែលកើតមានចំពោះស្ពែមនៅពេលវាស្ថិតនៅក្នុងបំពង់បន្តពូជញី។ បរិស្ថានអាស៊ីតបង្កឱ្យមានការផ្លាស់ប្តូរភ្នាសកោសិការបស់ស្ពែម ដែលធ្វើឱ្យវាអាចភ្ជាប់ទៅនឹងអូវ៉ូស៊ីតទីIIបាន)

**capacity** /kəˈpasɪti/ [n] ចំណុះ, សមត្ថភាព

- capacity building /kəˈpasɪti ˈbɪldɪŋ/ [n] ការកសាងសមត្ថភាព
- capacity for root penetration /kəˈpasɪti fɔː ruːt pɛnɪˈtreɪʃ(ə)n/ [n] សម្បទាដែលឫសដែលអាចជាក់ចូលបាន
- acid neutralizing capacity /ˈasɪd ˈnjuːtrəlʌɪzɪŋ kəˈpasɪti/ [n] សមត្ថភាពបន្សាបអាស៊ីត
- adsorbing capacity /ədˈzɔːbinɪŋ kəˈpasɪti/ [n] សមត្ថភាពជក់ (យកកាចុង) នៃដី
- air capacity /ɛː kəˈpasɪti/ [n] សមត្ថភាព ឬចំណុះខ្យល់ដែល (ដី) អាចស្តុកបាន
- buffer capacity of soil /ˈbʌfə kəˈpasɪti ɒv sɔɪl/ [n] សមត្ថភាពធន់ករ pH នៃដី (សមត្ថភាពនៃដីដែលធន់នឹងបម្រែបម្រួល pH)
- capillary capacity /kəˈpɪləri kəˈpasɪti/ [n] សមត្ថភាពកាពីឡែរ
- carrying capacity /ˈkariɪŋ kəˈpasɪti/ [n] សមត្ថភាពផ្ទុក, សមត្ថភាពទ្រទ្រង់
- crumb capacity /krʌm kəˈpasɪti/ [n] សម្បទាដែលអាចធ្វើឱ្យទម្រង់ទៅជាគ្រាប់មូលៗ, កម្រិតនៃការបង្កើតជាដុំគ្រាប់ (ទម្រង់)
- ecological capacity /iːkəˈlɒdʒɪk(ə)l kəˈpasɪti/ [n] សមត្ថភាពអេកូឡូស៊ី
- environmental capacity /ɪnvʌɪrənˈmɛnt(ə)l kəˈpasɪti/ [n] សមត្ថភាពបរិស្ថានក្នុងការទ្រទ្រង់នឹងអំពើពីក្រៅ
- field capacity /fiːld kəˈpasɪti/ [n] សមត្ថភាពដីស្រែ (ដីដែលអាចផ្ទុកទឹកទុកនៅពេលគេបន្សើមវា រួចបង្ហូរវាចេញ), សមត្ថភាពដី (លទ្ធភាពរក្សាទុកទឹករបស់ដី), សមត្ថភាពស្តុកទឹកនៃដី, ស្ថិរភាពទឹកអតិបរិមា
- germination capacity /dʒəːmɪˈneɪʃ(ə)n kəˈpasɪti/ [n] សមត្ថភាពដំណុះ (សមាមាត្រនៃគំរូគ្រាប់មួយដែលបានដុះជាធម្មតានៅក្នុងរយៈពេលសាកល្បងជាក់លាក់មួយ ជាធម្មតាគេគិតជាភាគរយ)
- heat capacity /hiːt kəˈpasɪti/ [n] ចំណុះកម្តៅ
- maximum moisture capacity /ˈmaksɪməm ˈmɔɪstʃə kəˈpasɪti/ [n] សមត្ថភាព ឬចំណុះទឹកជាអតិបរិមាដែល (ដី) អាចស្តុកបាន
- minimum moisture capacity /ˈmɪnɪməm ˈmɔɪstʃə kəˈpasɪti/ [n] សមត្ថភាព ឬចំណុះទឹកជាអប្បបរមាដែល (ដី) អាចស្តុកបាន
- moisture capacity /ˈmɔɪstʃə kəˈpasɪti/ [n] សមត្ថភាព ឬចំណុះទឹកដែល (ដី) អាចស្តុកបាន
- moisture-holding capacity /ˈmɔɪstʃə ˈhəʊldɪŋ kəˈpasɪti/ [n] ឥទ្ធិពលចាប់យកទឹក, សមត្ថភាពរក្សាសំណើម
- nutrient holding capacity /ˈnjuːtrɪənt ˈhəʊldɪŋ kəˈpasɪti/ [n] សមត្ថភាពចាប់យកសារធាតុចិញ្ចឹម
- rain capacity /reɪn kəˈpasɪti/ [n] ចំណុះទឹកដែលដីអាចជក់យកបានក្រោយពីភ្លៀងរួចហើយ (គិតជាម.ម)
- self-purification capacity /sɛlf pjʊərɪfɪˈkeɪʃ(ə)n kəˈpasɪti/ [n] សមត្ថភាពស្វ័យសុទ្ធិកម្ម

- thermal capacity /ˈθəːm(ə)l kəˈpasɪti/ [n] ចំណុះកម្ដៅ
- till capacity /tɪl kəˈpasɪti/ [n] សម្បទាដែលអាចភ្ជួរ
- vital capacity /ˈvʌɪt(ə)l kəˈpasɪti/ [n] ចំណុះខ្យល់ដែលអាចបញ្ចេញពីសួត
- water field capacity /ˈwɔːtə fiːld kəˈpasɪti/ [n] សមត្ថភាពស្រូបទឹក
- water holding capacity /ˈwɔːtə ˈhəʊldɪŋ kəˈpasɪti/ [n] សមត្ថភាពរក្សាទឹក (បរិមាណទឹកដែលអាចរក្សាបាននៅលើផ្ទៃសារធាតុដំណុះ ក្រោយពីជ្រាបទឹកដោយសេរី។ ក្រួស និងខ្សាច់មានសមត្ថភាពរក្សាទឹក (សំណើម) ទាប ឯល្បាប់ភក់ និងសារធាតុសរីរាង្គមេដ្យូមផ្សេងៗ មានសមត្ថភាពខ្ពស់)
- water storage capacity /ˈwɔːtə ˈstɔːrɪdʒ kəˈpasɪti/ [n] សមត្ថភាពស្តុកទឹក

**capillarity** /ˌkapɪˈlarɪti/ [n] កេសភាព, បាតុភូតរូបសាស្ត្រទាំងឡាយដែលមានក្នុងតំបន់កាពីឡែរ-បញ្ជូនទឹកឡើងលើ

**capillary** /kəˈpɪləri/ [n] សរសៃឈាម, បណ្ដាញរន្ធស្រូប, សរសៃបង្ហូរឈាម, កេសនាលី

- capillary rising height /kəˈpɪləriˈrʌɪzɪŋ hʌɪt/ [n] កម្ពស់ដែលទឹកឡើងបាន ដោយកម្លាំងកាពីឡែរពីស្រទាប់ទឹកក្រោម

**capital** /ˈkapɪt(ə)l/ [n] ទុន, ធន, ដើមទុន (ទ្រព្យសម្បត្តិជាអចលនៈទ្រព្យ (សាច់លុយសុទ្ធ) និងជាអចលនៈទ្រព្យ (មានម៉ាស៊ីនជាដើម)ហើយដែលត្រូវយកមកប្រើប្រាស់ក្នុងដំណើរការផលិតកម្មមួយ)

- capital-intensive /ˈkapɪt(ə)l ɪnˈtɛnsɪv/ [adj] ប្រពលវប្បកម្មដើមទុន (ដែលប្រើទុន ឬម៉ាស៊ីនច្រើន)
- fixed capital /fɪkst ˈkapɪt(ə)l/ [n] ទុនអចលនៈ, ទុនអចល័ត

**capitate** /ˈkapɪteɪt/ [adj] ដូចក្បាល

**capitulum** /kəˈpɪtjʊləm/ [n]

១. (ចំពោះសត្វ) រាងមូល (ក្បាលមូលរបស់ឆ្អឹងជំនីដែលភ្ជាប់ជាមួយតួឆ្អឹងកង)

២. (ចំពោះរុក្ខជាតិ) កញ្ចុំផ្ការាងដុំមូល, ផ្កាចង្កោមក្បាល

**capon** /ˈkeɪp(ə)n/ [n] មាន់ក្រៀវ

***Capparis cambodiana*** [sci.n] ពុកឆ្មា

**capsicum** /ˈkapsɪkəm/ [n] ម្ទេសប្លោក (ឈ្មោះវិទ្យាសាស្ត្រ *Capsicum annuum*)

***Capsicum annuum*** [sci.n] សូមមើលពាក្យ៖ bell pepper, capsicum, cayenne pepper, chilli pepper

***Capsicum frutescens*** [sci.n] សូមមើលពាក្យ៖ tabasco pepper

**capsid** /ˈkapsɪd/ [n] កាប់ស៊ីត (ភ្នាសប្រូតេអ៊ីនរបស់វីរុស)

**capsule** /ˈkapsjuːl/ [n]

១. (ចំពោះជីវវិទ្យា) កន្សោម (បំពង់តូចៗដែលមានគម្របរឹងមាំ មានប្រភេទខុសៗគ្នាជាច្រើន), កាប់ស៊ុល (ស្រទាប់ខាប់អន្ទិលជុំវិញកោសិការបស់បាក់តេរីមួយចំនួន)

២. (ចំពោះសត្វ) គ្រាប់ថ្នាំមូលទ្រវែង

៣. (ចំពោះរុក្ខជាតិ) ផ្លែកន្សោម, ផ្លែស្ងួត (ផ្លែគួ) (ជាធម្មតាជាប្រភេទផ្លែស្ងួតមានគ្រាប់ច្រើន និងប្រេះសម្បកដែលផ្គុំឡើងពីកេសរញីពីរឬច្រើន ដែលនឹងប្រេះបែកពីគ្នានៅពេលទុំដើម្បីជម្រុះ គ្រាប់របស់វា ឧ. ប្រភេទ Swietenia និង Eucalyptus.។ ប្រភេទផ្លែខាបស៊ូលអាចមាន ថត(បន្ទប់)មួយ ឬច្រើន ហៅថា Locules។

bowman capsule /ˈbəʊmən ˈkapsjuːl/ [n] កន្សោមបូម៉ាន់

**capture** /ˈkaptʃə/ [n] ទំនាក់ទន្លេ

**caput** /ˈkapʊt/ [n] ក្បាល, ប៉ែកខាងលើនៃសរីរាង្គណាមួយ

**carabiner** /ˌkarəˈbiːnə/ [n] កងលោហៈ (កងលោហៈសុវត្ថិភាពមួយដែលគេប្រើសម្រាប់ភ្ជាប់ខ្សែពួរឡើងដើមឈើ។ កងនេះមានគន្លឹះចាក់សោដើម្បីធានាមិនឱ្យវាហា ឬរបូតគន្លឹះនៅពេលកំពុងឡើងបេះគ្រាប់ពូជ។)

**carambola** /ˌkar(ə)mˈbəʊlə/ [n] (សទិសសន័យ៖ starfruit) ស្ពឺ (ឈ្មោះវិទ្យាសាស្ត្រ *Averrhoa carambola*)

**carapace** /ˈkarəpeɪs/ [n] ស្នូក

**carbohydrase** /kɑːbəˈhʌɪdreɪz/ [n] កាបូអ៊ីដ្រាស (អង់ស៊ីមដែលជំរុញការបំបែកកាបូនអ៊ីដ្រាត)

**carbohydrate** /kɑːbəˈhʌɪdreɪt/ [n] កាបូនអ៊ីដ្រាត (អព្យាអង្គធាតុដែល កកើតឡើងដោយសារដំណាំ ឬបន្លែបង្ការ)

- complex carbohydrate /ˈkɒmplɛks kɑːbəˈhʌɪdreɪt/ [n] កាបូនអ៊ីដ្រាតសាំញ៉ាំ

**Carbon** /ˈkɑːb(ə)n/ [n]
១. កាបូន (និមិត្តសញ្ញាគីមី C)
២. កាបូន (ន័យទូទៅលើសមាសធាតុសរីរាង្គ)

- activated carbon /ˈaktɪveɪtɪd ˈkɑːb(ə)n/ [n] ធ្យូងសកម្ម
- anomeric carbon [n] កាបូនអាណូមែ (អាតូមកាបូនដែលមានទម្រង់ជាវង់មូលនៃស្ករដែលជាកាបូនកាបូនីលរបស់ស្ករទម្រង់ខ្សែបើក)
- mineral carbon /ˈmɪn(ə)r(ə)l ˈkɑːb(ə)n/ [n] ធ្យូងថ្ម

**carbonaceous** /ˌkɑːbəˈneɪʃəs/ [adj] ដែលមានកាបូន

**carbonate** /ˈkɑːbəneɪt/ [n] កាបូណាត

- lime carbonate /lʌɪm ˈkɑːbəneɪt/ [n] ថ្មកំបោរកាបូណាត (សំដៅចំពោះ CaCO3)

**carbon dioxide** /ˈkɑːb(ə)n dʌɪˈɒksʌɪd/ [n] ឧស្ម័នកាបូនិច, កាបូនឌីអុកស៊ីត

- carbon dioxide conversion stage /ˈkɑːb(ə)n dʌɪˈɒksʌɪd kənˈvəːʃ(ə)n steɪdʒ/ [n] វគ្គបំប្លែងឧស្ម័នកាបូនិច
- carbon dioxide exchange /ˈkɑːb(ə)n dʌɪˈɒksʌɪd ɪksˈtʃeɪndʒ/ [n] បណ្ដូរឧស្ម័នកាបូនិច

**carbonic** /kɑːˈbɒnɪk/ [adj] កាបូនិច

**Carboniferous** /ˌkɑːbəˈnɪf(ə)rəs/ [n] កាបូនីហ្វែ

**carbonification** /ˌkɑːbəˈnɪfɪˈkeɪʃ(ə)n/ [n] កាបូនកម្ម

**carbuncle** /ˈkɑːbʌŋk(ə)l/ [n] (សទិសន័យ៖ boil) បូសទ្រនិច

**carcass (carcase)** /ˈkɑːkəs/ [n] សម្បកដងខ្លួន (កាកាស់), សាកសពសត្វ, គ្រោងឆ្អឹងសត្វដែលមានជាប់សាច់

***Carcharhinus leucas*** [sci.n] សូមមើលពាក្យ៖ bull shark

**carcinogen** /kɑːˈsɪnədʒ(ə)n/ [n] សារធាតុបង្កមហារីក, ភ្នាក់ងារបង្កមហារីក

**carcinogenic** /ˌkɑːs(ɪ)nəˈdʒɛnɪk/ [adj] ដែលអាចកើតមហារីក

**carcinoma** /ˌkɑːsɪˈnəʊmə/ [n] ដំបៅមហារីក, កាស៊ីណូម, មហារីកស្រើស្បែក

***Carcinoscorpius rotundicauda*** [sci.n] សូមមើលពាក្យ៖ mangrove horseshoe crab

**cardamom** /ˈkɑːdəməm/ [n] ក្រវាញ, ដើមក្រវាញ

**cardboard** /ˈkɑːdbɔːd/ [n] ក្រដាសរឹង

- cardboard box /ˈkɑːdbɔːd bɒks/ [n] ប្រអប់ក្រដាសរឹង

**cardiac** /ˈkɑːdɪak/ [adj] បេះដូង

- cardiac monitor **"The Monitor"** /ˈkɑːdɪak ˈmɒnɪtə/ [n] បងាប់ត្រួតមើលបេះដូង ឬ "ប្រដាប់ពិនិត្យគយគន់"

**cardio pulmonary resuscitation (CPR)** /ˈkɑːdiəʊ ˈpʌlmən(ə)ri rɪsʌsɪˈteɪʃ(ə)n/ [n] ការជួយផ្ដិដង្ហើមបេះដូងឱ្យដើរឡើងវិញ

***Cardiochiles philippinensis*** [sci.n] ពួកឌីម៉ាល់ (បរាសិតលើដង្កូវម្ទេសស្លឹក)

***Cardiospermum halicacabum*** [sci.n] សូមមើលពាក្យ៖ balloon vine

**career** /kəˈrɪə/ [n] មុខរបរ, អាជីព

- career path planning /kəˈrɪə pɑːθ ˈplanɪŋ/ [n] ការធ្វើផែនការលើអាជីព

***Caretta caretta*** [sci.n] សូមមើលពាក្យ៖ loggerhead turtle

**cargo** /ˈkɑːgəʊ/ [n] ទំនិញ, ថ្លៃដឹកជញ្ជូន

- cargo boat /ˈkɑːgəʊ bəʊt/ [n] (សទិសន័យ៖ cargo ship) កប៉ាល់ដឹកទំនិញ
- cargo plane /ˈkɑːgəʊ pleɪn/ [n] យន្តហោះដឹកទំនិញ
- cargo ship /ˈkɑːgəʊ ʃɪp/ [n] សូមមើលពាក្យ៖ cargo boat

***Carica papaya*** [sci.n] សូមមើលពាក្យ៖ papaya

**caries (dental)** /ˈkɛːriːz/ [n] ប្រហោងធ្មេញ

**carina** /kəˈrʌɪnə/ [n] (សទិសន័យ៖ keel) ស្រទាប់ស្នូក, ត្របកក្រោម, ត្របកបាត, ទ្រនុងគ្រាប់ (សរសៃ ឬចង្អូរវែងនៅចំកណ្ដាលនៃសម្បកធំ ឬសម្បកផ្កាធំរបស់ស្រូវ)

***Carinotetraodon lorteti*** [sci.n] សូមមើលពាក្យ៖ redeye puffer

**carnivore** /ˈkɑːnɪvɔː/ [n] មំសាសី, មំសាហារសត្វ, សត្វសន្តានស៊ីសាច់

**carotene** /ˈkarəti:n/ [n] ការ៉ូតែន (ជាតិពណ៌ទឹកក្រូចរបស់រុក្ខជាតិ ដែលមានច្រើននៅក្នុងក្លរ៉ូប្លាស ហើយជួនកាលក្លរ៉ូប្លាសរបស់ស្លឹកពណ៌លឿង ឬស្លឹកពណ៌ទឹកក្រូចក្នុងបន្លែនិងផ្លែឈើ។ ការ៉ូតែនមានសារសំខាន់ក្នុងការផលិតវីតាមីន A ក្នុងខ្លួនមនុស្ស)

**carotid** /kəˈrɒtɪd/ [n] ការ៉ូទីត (សរសៃអាទែរដ៏សំខាន់នៅត្រង់កដលែមានសម្បក ឬសម្រោ)

**carp** /kɑ:p/ [n] ត្រីកាប

- bighead carp /bɪghɛd kɑ:p/ [n] ត្រីកាបក្បាលធំ
- Chinese carp /tʃʌɪˈni:z kɑ:p/ [n] ត្រីកាបចិន
- common carp /ˈkɒmən kɑ:p/ [n] ត្រីកាបធម្មតា
- grass carp /grɑ:s kɑ:p/ [n] ត្រីព្រលូង
- Indian carp /ˈɪndɪən kɑ:p/ [n] (សទិសន័យ៖ rohu carp) ត្រីក្អែក (ទឹកសាប)
- mud carp /mʌd kɑ:p/ [n] ត្រីផ្កាត (ឈ្មោះវិទ្យាសាស្ត្រ *Cirrhinus molitorella*)
- rohu carp [n] សូមមើលពាក្យ៖ Indian carp
- silver carp /ˈsɪlvə kɑ:p/ [n] ត្រីកាបសាមញ្ញ

**carpal** /ˈkɑ:p(ə)l/ [n] សូមមើលពាក្យ៖ knee

- carpal joint /ˈkɑ:p(ə)l dʒɔɪnt/ [n] សូមមើលពាក្យ៖ carpus

**carpel** /ˈkɑ:p(ə)l/ [n] (សទិសន័យ៖ pistil) កញ្ចុំកេសរញី, កេសរញី (សរីរាង្គបន្តពូជញី ដែលរួមមានបុប្ផាណករមួយ, អណ្ឌាករមួយ ឬច្រើនហើយនិងមាត់កេសរញី។ ទីនោះបានបង្កលក្ខណៈឱ្យលម្អងផ្កាឈ្មោលធ្លាក់ទំលើមាត់កេសរញី រួចចូលតាមបំពង់កេសរញីឆ្ពោះទៅកាន់អូវុលហើយបង្កកំណើតទៅជាគ្រាប់)

**carpenter** /ˈkɑ:p(ə)ntə/ [n] ជាងឈើ

**carpospore** /ˈkɑ:pəʊspɔ:/ [n] កាប៉ូស្ប៉ រ (ស្ប៉ររបស់សារាយក្រហម ដែលត្រូវបានបង្កើតដោយភេទ)

**carpus** /ˈkɑ:pəs/ [n] (សទិសន័យ៖ carpal joint) ឆ្អឹងកដៃ

**gas carriage** /gas ˈkarɪdʒ/ [n] (សទិសន័យ៖ gas exchange) ដំណឹកនាំឧស្ម័ន, បម្លាស់ប្តូរឧស្ម័ន

**carrier** /ˈkarɪə/ [n]

១. (ចំពោះសត្វ) អ្នកដែលជាសះស្បើយពីជំងឺ តែនៅមានមេរោគក្នុងខ្លួន

២. សារធាតុបន្សំ, អង្គធាតុនាំ, នាំករ (សារធាតុចាំបាច់សម្រាប់ផ្សំ ឬចាប់ធាតុជីឱ្យទៅជាទម្រង់សមស្របមួយសម្រាប់ប្រើប្រាស់ធ្វើជាជី។ ជីវករ (មនុស្ស, សត្វ) ដែលអាចផ្ទុកមេរោគដោយគ្មានសញ្ញាជំងឺ តែអាចនឹងចម្លងមេរោគទៅជីវករផ្សេងៗទៀតបាន)

**carrot** /ˈkarət/ [n] ការ៉ុត (ឈ្មោះវិទ្យាសាស្ត្រ *Daucus carota*)

**carrying-away** /ˈkarin əˈweɪ/ [n] សូមមើលពាក្យ៖ taking-off

**cart** /kɑ:t/ [n] រទេះ

**cartilage** /ˈkɑ:t(ɪ)lɪdʒ/ [n] ឆ្អឹងខ្ចី, ឆ្អឹងទន់

**cartography** /kɑ:ˈtɒgrəfi/ [n] ផែនទីវិទ្យា

**caruncle** /ˈkarəŋk(ə)l/ [n]

១. (ចំពោះសត្វ) ដុំសាច់កន្ទួលឡើង

២. (ចំពោះរុក្ខជាតិ) ដុំពកនៃប្រទេកា, ដុំពកនៃសម្បកគ្រាប់ខ្ចី, ផ្នែកលូតលាស់មានលក្ខណៈដូចឫស នៅលើគ្រាប់រុក្ខជាតិអង់ស្យូស្ពែមខ្លះនៅក្បែរមីក្រូពីល

**caryopsis** /keri:ˈɑpsəs/ [n]

១. ផ្លែគ្រាប់សាច់, ប្រភេទផ្លែស្ងួត

២. គ្រាប់អង្ករសម្រូបដែលមានស្រទាប់ស្តើងស្រោបពីខាងក្រៅ

***Caryota urens*** [sci.n] អន់សែ

**cascade** /kasˈkeɪd/ [n] ល្បាក់ទឹក

**case hardening** /keɪs ˈhɑ:d(ə)nɪŋ/ [n] ការឡើងរឹងនៃសម្បកផ្លែកោន (ការដែលធ្វើឱ្យស្រកាកោនឡើងរឹង ដែលបណ្តាលមកពីការហួតយ៉ាងរហ័ស ដូច្នេះបណ្តាលឱ្យវាមិនអាចបើកស្រកាកោនកើត ដើម្បីជម្រុះគ្រាប់របស់វា)

**case study** /keɪs ˈstʌdi/ [n] ករណីសិក្សា (ដំណើរការនៃការសិក្សាវិភាគវែកញែកអំពីករណីមួយ)

**caseous** /ˈkeɪsɪəs/ [adj] ដូចប្រូម៉ាស

**cash** /kaʃ/ [n] សាច់ប្រាក់, លុយ

- cash advance /kaʃ ədˈvɑ:ns/ [n] លុយផ្តល់ឱ្យជាមុន (ប្រាក់ដែលបើកយកមុនកំណត់សម្រាប់ការចាយទៅលើអ្វីមួយ)
- cash balance /kaʃ ˈbal(ə)ns/ [n] តុល្យភាពសាច់ប្រាក់
- cash credit /kaʃ ˈkrɛdɪt/ [n] ឥណទានសាច់ប្រាក់

- cash flow /kaʃ fləʊ/ [n] ចរន្តទុន, ចរាចរទឹកប្រាក់ (ដំណើរការនៃការប្រើប្រាស់ទុន ចាប់តាំងពីដំណាក់កាលដំបូងនៃផលិតកម្ម រហូតទទួលបានជាប្រាក់នៃការលក់ផលិតផល)
- cash payment /kaʃ ˈpeɪm(ə)nt/ [n] ការចាយវាយជាសាច់ប្រាក់
- cash register /kaʃ ˈrɛdʒɪstə/ [n] ម៉ាស៊ីនគិតលុយ

**cashew** /ˈkaʃuː/ [n] ស្វាយចន្ទី (ឈ្មោះវិទ្យាសាស្ត្រ *Anacardium occidentale*)

- cashew nut /ˈkaʃuː nʌt/ [n] គ្រាប់ស្វាយចន្ទី
- cashew apple /ˈkaʃuːˈap(ə)l/ [n] ផ្លែស្វាយចន្ទី (មិនរួមបញ្ចូលគ្រាប់)

**cassava (red petiole)** /kəˈsɑːvə/ [n] (សទិសន័យ៖ tapioca) ដំឡូងឈើ (ឈ្មោះវិទ្យាសាស្ត្រ Manihot esculenta)

**cassava (white petiole)** /kəˈsɑːvə/ [n] ដំឡូងមី (ឈ្មោះវិទ្យាសាស្ត្រ *Manihot esculenta*)

***Cassia alata*** [sci.n] ដង្ហិត

***Cassia javanica*** [sci.n] បូព្រឹក្ស

***Cassia occidentalis*** [sci.n] សូមមើលពាក្យ៖ coffee senna

**cassia siamea** [n] អង្កាញ់, ដើមអង្កាញ់ (ឈ្មោះវិទ្យាសាស្ត្រ៖ *Cassia siamensis*)

***Cassia siamensis*** [sci.n] សូមមើលពាក្យ៖ cassia siamea

***Cassia tora*** [sci.n] ដង្ហិតឈ្នាង, ដង្ហិតខ្មោច

**cast** /kɑːst/ [n] បាត, រណោបអបឆ្អឹងបាក់, រណោបម្នាងសិលា

- cast a net /kɑːst ə nɛt/ [v] បង់សំណាញ់

**caste** /kɑːst/ [n] ខាស្ត (ឯកត្តៈឯកទេសកម្មក្នុងចំណោមសត្វល្អិតនៅជាសង្គម ឧ. ឃ្មុំកម្មករ និងឃ្មុំឈ្មោល នៅក្នុងកូឡូនីឃ្មុំ)

**castor oil plant** /ˈkɑːstə ɔɪl plɑːnt/ [n] ល្ហុងខ្វែ, ល្ហុងប្រេង (ឈ្មោះវិទ្យាសាស្ត្រ *Ricinus communis*)

**castrate** /kaˈstreɪt/ [v] (សទិសន័យ៖ emasculate, geld, spay) ក្រៀវ (គ្រៀវ)

***Casuarina equisetifolia*** [sci.n] សូមមើលពាក្យ៖ Australian pine

**catabolism** /kəˈtabəlɪz(ə)m/ [n] កាតាបូលីស

**catadromous** /kaˈtadrəməs/ [adj] សូមមើលពាក្យ៖ anadromous

**catalepsy** /ˈkat(ə)lɛpsi/ [n] ការធ្វើពុតជាងាប់

**catalogue** /ˈkat(ə)lɒg/ [n] សៀវភៅគំរូផលិតផល, កាតាឡុក (បញ្ជីកត់ត្រាអំពីលក្ខណៈទូទៅរបស់បញ្ជិក)

**cataloguing** /ˈkat(ə)lɒg ɪŋ/ [n] កាតាឡុកកម្ម (ការធ្វើបញ្ជីកត់ត្រាអំពីលក្ខណៈទូទៅរបស់បញ្ជិក)

**catalysis** /kəˈtalɪsɪs/ [n] កាតាលីកម្ម , ការជំរុញឱ្យមានប្រតិកម្ម

**catalyst** /ˈkat(ə)lɪst/ [n] (សទិសន័យ៖ catalytic agent) កាតាលីករ

**cataphyll** /ˈkat(ə)fɪl/ [n] ស្រោមការពារពន្លកស្លឹក

**cataract** /ˈkatərakt/ [n]
១. ជំងឺឡើងបាយ
២. ល្បាក់ទឹក

**catarrh** /kəˈtɑː/ [n] រលាកភ្នាសសើម, ការរលាកស្រទះស្លេស្ម (ជាពិសេសប្រដាប់ ដកដង្ហើម ដូចជាទងសួត, បំពង់ក, ច្រមុះ)

**catastrophe** /kəˈtastrəfi/ [n] មហន្តរាយ

- ecological catastrophe /iːkəˈlɒdʒɪk(ə)l kəˈtastrəfi/ [n] មហន្តរាយអេកូឡូស៊ី

**catastrophism** /kəˈtastrəfɪz(ə)m/ [n] មហន្តរាយនិយម

**catchment** /ˈkatʃmənt/ [n] អាងរងទឹកភ្លៀង, អាងធម្មជាតិ (តំបន់ទំនាបដែលប្រមូលផ្តុំទឹកពីទីខ្ពស់)

- catchment pond /ˈkatʃm(ə)nt pɒnd/ [n] សូមមើលពាក្យ៖ reservoir
- slope of catchment /sləʊp ɒv ˈkatʃm(ə)nt/ [n] ចំណោតទីជម្រាប, ចំណោតអាងរងទឹកភ្លៀង

**categorize** /ˈkatəgərʌɪz/ [v] ចាត់ថ្នាក់ ឬប្រភេទ

**category** /ˈkatəg(ə)ri/ [n] ប្រភេទ, ក្រុម, ចំណាត់ថ្នាក់

**catenane** /ˈkatəneɪn/ [n] ការប្រទាក់គ្នាដូចច្រវាក់

**catenated** /ˈkatəneɪtɪd/ [adj] ដែលប្រទាក់គ្នាដូចច្រវាក់

**caterpillar** /ˈkatəpɪlə/ [n] ដង្កូវ, ពពួកដង្កូវ, កូនញាស់មេអំបៅ, ដង្កូវមេអំបៅ

- green horned caterpillar /griːn ˈhɔːnd ˈkatəpɪlə/ [n] ដង្កូវស្នែង (សត្វល្អិតស្ថិតក្នុងលំដាប់ Lepidotera គ្រួសារ Satyridae)
- greenhorned caterpillar /griːnhɔːnd ˈkatəpɪlə/ [n] ដង្កូវស្នែង (ឈ្មោះវិទ្យាសាស្ត្រ *Melanitis leda ismene*)
- hair caterpillar /hɛː ˈkatəpɪlə/ [n] ដង្កូវរោម (ដង្កូវដែលមានរោមនៅលើខ្លួន)
- semi-looper caterpillar /ˌsɛmɪ ˈluːpəˈkatəpɪlə/ [n] សូមមើលពាក្យ៖ semilooper

**catfish** /ˈkatfɪʃ/ [n] ត្រីអត់ស្រកា (ឧ. ត្រីឆ្លាំង អណ្ដែង ត្រីកញ្ចុះ)

- armoured sea catfish /ˈɑːməd siː ˈkatfɪʃ/ [n] ត្រីក្អុក (ឈ្មោះវិទ្យាសាស្ត្រ *Arius stormi*)
- Asian bumblebee catfish /ˈeɪʒ(ə)n ˈbʌmb(ə)lbiː ˈkatfɪʃ/ [n] ត្រីកញ្ចុះថ្ម (ឈ្មោះវិទ្យាសាស្ត្រ *Leiocassis siamensis*)
- black lancer catfish /blak ˈlɑːnsə ˈkatfɪʃ/ [n] ត្រីចេកទុំ (ឈ្មោះវិទ្យាសាស្ត្រ *Bagrichthys macracanthus*)
- blackskin catfish /blak skɪn ˈkatfɪʃ/ [n] ត្រីអណ្ដែងទន់ (ឈ្មោះវិទ្យាសាស្ត្រ *Clarias meladerma*)
- broadhead catfish /brɔːd hɛd ˈkatfɪʃ/ [n] ត្រីអណ្ដែងទន់ (ឈ្មោះវិទ្យាសាស្ត្រ Clarias macrocephalus)
- butter catfish /ˈbʌtə ˈkatfɪʃ/ [n] ត្រីក្រមម (ឈ្មោះវិទ្យាសាស្ត្រ *Ompok bimaculatus*)
- crocodile catfish /ˈkrɒkədʌɪl ˈkatfɪʃ/ [n] ត្រីក្របី (ឈ្មោះវិទ្យាសាស្ត្រ *Bagarius suchus*)
- engraved sea catfish /ɪnˈgreɪvd siː ˈkatfɪʃ/ [n] ត្រីក្អុក (ឈ្មោះវិទ្យាសាស្ត្រ Arius caelatus)
- false black lancer catfish /fɔːls blak ˈlɑːnsə ˈkatfɪʃ/ [n] ត្រីចេកទុំ (ឈ្មោះវិទ្យាសាស្ត្រ *Bagrichthys macropterus*)
- froghead sea catfish /frɒg hɛd siː ˈkatfɪʃ/ [n] ត្រីក្អុក (ឈ្មោះវិទ្យាសាស្ត្រ *Batrachocephalus mino*)
- giant catfish /ˈdʒʌɪənt ˈkatfɪʃ/ [n] ត្រីរាជ

giant sea catfish /ˈdʒʌɪənt siː ˈkatfɪʃ/ [n] ត្រីក្អុក (ឈ្មោះវិទ្យាសាស្ត្រ *Arius thalassinus*)

glass catfish /glɑːs ˈkatfɪʃ/ [n] ត្រីកេសប្រាក់ (ឈ្មោះវិទ្យាសាស្ត្រ Kryptopterus bicirrhis)

iridescent shark catfish /ˌɪrɪˈdɛs(ə)nt ʃɑːk ˈkatfɪʃ/ [n] ត្រីប្រា (ឈ្មោះវិទ្យាសាស្ត្រ *Pangasianodon hypophthalmus*)

Mekong giant catfish /miːˈkɒŋ ˈdʒʌɪənt ˈkatfɪʃ/ [n] ត្រីរាជ (ឈ្មោះវិទ្យាសាស្ត្រ *Pangasianodon gigas*)

sagor sea catfish /ˈseɪgə siː ˈkatfɪʃ/ [n] ត្រីក្អុក (ឈ្មោះវិទ្យាសាស្ត្រ *Arius sagor*)

- soldier catfish /ˈsəʊldʒə ˈkatfɪʃ/ [n] ត្រីក្អុក (ឈ្មោះវិទ្យាសាស្ត្រ *Osteogeneiosus militaris*)
- sona sea catfish / səʊnə siː ˈkatfɪʃ/ [n] ត្រីក្អុក (ឈ្មោះវិទ្យាសាស្ត្រ *Arius sona*)
- spotted sea catfish /ˈspɒtɪd siː ˈkatfɪʃ/ [n] ត្រីក្អុក (ឈ្មោះវិទ្យាសាស្ត្រ *Arius maculatus*)
- stinging catfish /stɪŋɪŋ ˈkatfɪʃ/ [n] ត្រីអណ្ដែងទន់ពុកមាត់បួន (ឈ្មោះវិទ្យាសាស្ត្រ *Heteropneustes fossilis*)
- veined catfish /veɪnd ˈkatfɪʃ/ [n] ត្រីក្អុក (ឈ្មោះវិទ្យាសាស្ត្រ *Arius venosus*)
- walking catfish /wɔːkɪŋ ˈkatfɪʃ/ [n] ត្រីអណ្ដែងរឹង (ឈ្មោះវិទ្យាសាស្ត្រ *Clarias batrachus*)

**catgut** /ˈkatgʌt/ [n] ជេសដែលធ្វើពីពោះវៀនសត្វ

**cathartic** /kəˈθɑːtɪk/ [adj] ថ្នាំបញ្ចុះ

**cathepsin** /ˈkaθəpsɪn/ [n] កាតិមស៊ីន (អង់ស៊ីមបំបែកប្រូតេអ៊ីន ស្ថិតក្នុងកោសិកាដែលបណ្ដាលឱ្យកោសិកាបែក)

**catheter** /ˈkaθətə/ [n] កាតេទែ (ទុយោសម្រាប់បង្ហូរទឹកនោម)

**catheterize** /ˈkaθətərʌɪz/ [v] បញ្ចេញទឹកនោមពីផ្លោកនោម (តាមបំពង់)

**cathode** /ˈkaθəʊd/ [n] កាតូត (អេឡិចត្រូតបន្ទុកវិជ្ជមានដែលអ៊ីយ៉ុងវិជ្ជមានមានរំកិលទៅរក)

**cation** /ˈkatˌaɪən/ [n] កាចុង (អ៊ីយ៉ុង ដែលមានបន្ទុកអគ្គិសនីវិជ្ជមាន)

- cation exchange capacity /ˈkatˌaɪən ɪksˈtʃeɪndʒ kəˈpasɪti/ [n] សមត្ថភាពបណ្ដូរកាចុង, ចំណុះកាចុងដោះដូរ (កាចុង) , សមត្ថភាពអតិបរិមាដែលដីអាចចាប់យកកាចុង

**catkin** /ˈkatkɪn/ [n] ផ្កាចង្កោម, ប្រភេទផ្កាចង្កោមម្យ៉ាង

***Catlocarpio siamensis*** [sci.n] សូមមើលពាក្យ៖ giant barb

**catopra** /kratəʊprə/ [n] ត្រីកន្ត្រប់ (ឈ្មោះវិទ្យាសាស្ត្រ Pristolepis fasciata)

**cattle** /ˈkat(ə)l/ [n] សត្វពាហនៈ (ឧ. សត្វគោ ក្របី)

- beef cattle /biːf ˈkat(ə)l/ [n] គោចិញ្ចឹមយកសាច់
- dairy cattle /ˈdɛːri ˈkat(ə)l/ [n] គោទឹកដោះ

**caudal** /ˈkɔːd(ə)l/ [adj] នៃកន្ទុយ

**caudate** /ˈkɔːdeɪt/ [adj] ទម្រង់ចុងស្លឹកទម្រង់កន្ទុយ

**cauliflorous** /ˈkɒlɪflaʊə/ [adj] នៃប្រភេទផ្កាក្តោប (ការចេញផ្កាដែលផ្តុំគ្នាច្រើន និង ក្រោយមកវាក្លាយជាផ្លែ។ ផ្កា-ផ្លែនេះដុះចេញមកពីគល់ឬដើម ច្រើនជាងដុះចេញពី មែកតូច ឧ. ប្រភេទ Arthocarpus និង Ficus spp។)

**cauliflower** /ˈkɒlɪflaʊə/ [n] ស្ពៃផ្កា, ផ្កាខាត់ណា (ឈ្មោះវិទ្យាសាស្ត្រ *Brassica oleracea var. botrytis*)

**cauline** /ˈkɔːlʌɪn/ [adj] លើតួដើម, (អំពីស្លឹក) ស្ថិតនៅផ្នែកខាងលើនៃដើមរុក្ខជាតិ

**caustic** /ˈkɒstɪk/ [adj] ដែលអាចស៊ី, ដែលអាចកាត់បាន

**caustic** /ˈkɔːstɪk/ [n] វត្ថុធាតុប្រើសម្រាប់ដុត, ស៊ី, ឬបំផ្លាញជាលិកានៃខ្លួន

**cautery** /ˈkɔːt(ə)ri/ [n] កូទែ

**cava** /ˈkɑːvə/ [n] (សទិសន័យ៖ vena cava) វ៉ែនកាវ, សរសៃឈាមខ្មៅធំ

**cavern** /ˈkav(ə)n/ [n] រូងភ្នំ, គុហា

**cavity** /ˈkavɪti/ [n] រន្ធក្នុងដី, ថត, ប្រអប់, ទីខូង, ផត, ប្រហោង(ធ្មេញ)

- body cavity /ˈbɒdi ˈkavɪti/ [n] ប្រហោងពោះ

**cavy** /ˈkeɪvi/ [n] (សទិសន័យ៖ guinea pig) កណ្តុរប្រើសម្រាប់ការពិសោធថ្នាំ

***Cayratia carnosa*** [sci.n] វល្លិតាដិត

***Cayratia trifolia*** [sci.n] សូមមើលពាក្យ៖ three-leaf cayratia

**cecum** /ˈsiːkəm/ [n] (សទិសន័យ៖ caecum) (ពហុវចនៈ៖ ceca) ថ្នាក់ពោះវៀន, ថ្នក់ផ្នែកខាងដើមនៃពោះវៀនធំ

**celery** /ˈsɛləri/ [n] ជីរតាំងឱ

**cell** /sɛl/ [n]

១. កោសិកា

២. (ចំពោះដី) រន្ធ (រាងមូលៗ)

- albuminous cell /alˈbjuːmɪnəs sɛl/ [n] កោសិកាអាល់ប៊ុយមីន
- body cell /ˈbɒdi sɛl/ [n] កោសិកាមេ
- brood cell /bruːd sɛl/ [n] សម្បុកឃ្មុំ
- bulliform cells /ˈbʊlifɔːm sɛl/ [n] កោសិការាងពពុះ
- cell / sɛl/ [n] កោសិកា
- chloride secretory cells /ˈklɔːrʌɪd sɪˈkriːtəri sɛlz/ [n pl] កោសិកាបញ្ចេញក្លរ
- daughter cells /ˈdɔːtə sɛlz/ [n pl] កោសិកាកូន
- drainpipe cells /ˈdreɪnpʌɪp sɛlz/ [n pl] កោសិកាបំពង់បង្ហូរ (កោសិកាអេពីតេល្យូមទាំងឡាយណា ដែលមានប្រហោងខាងក្នុង ក្នុងទម្រង់ជាបំពង់បង្ហូរភ្ជាប់ចុង និងចុងជាមួយគ្នា ដូចជាក្នុងករណីបំពង់ខ្យល់របស់សត្វល្អិត និងបំពង់បញ្ចេញរបស់ដង្កូវខ្លួបសំប៉ែត)
- drone cell /drəʊn sɛl/ [n] សម្បុកឃ្មុំ
- egg cell /ɛg sɛl/ [n] កោសិកាស៊ុត (អនាគតត្រូណា ក្រោយពេលដែលវាធ្វើពហុពលកម្មជាមួយនឹងសមាសធាតុរបស់លម្អងដែលធ្លាក់ចុះតាមបំពង់លម្អង)
- flame cell /fleɪm sɛl/ [n] កោសិការោមញ័រ
- generative cell /ˈdʒɛn(ə)rətɪv sɛl/ [n] កោសិកាបង្កកំណើត
- germ cell /dʒəːm sɛl/ [n] កោសិកាបន្តពូជ, កោសិកាភេទ
- guard cell /gɑːd sɛl/ [n] កោសិកាការពារ (កោសិកាអេពីឌែម ២ដែលមានរាងដូចចំណិតលោកខែ ដែលមានមុខនាទីកំណត់ការបើកបិទប្រហោងចំហនៃរន្ធ)
- hair cell /hɛː sɛl/ [n] កោសិការោម
- honey cell /ˈhʌni sɛl/ [n] សម្បុកឃ្មុំ
- nurse cell /nəːs sɛl/ [n] កោសិកាចិញ្ចឹម
- palisade cell /ˌpalɪˈseɪd sɛl/ [n] សូមមើលពាក្យ៖ macrosclereid
- queen cell /kwiːn sɛl/ [n] សម្បុកឃ្មុំមេ
- sex cell /sɛks sɛ/ [n] កោសិកាភេទ
- solar cells /ˈsəʊlə sɛlz/ [n pl] កោសិកាផ្ទុកអគ្គីសនី

- somatic cell /səˈmatɪk sɛl/ [n] (សទិសន័យ៖ vegetative cell) កោលិកាសូម៉ែទិច, កោសិកាលូតលាស់របស់រុក្ខជាតិ (កោសិកាផ្សេងៗនៃអង្គប្រាណ ដែលមិនមែនជាកោសិកាបន្តពូជ(ស្ប៉ែរកាម៉ែត)។ ពាក្យន័យផ្ទុយ reproductive cell-កោសិកាបន្តពូជ។)
- stalk cell /stɔːk sɛl/ [n] កោសិកាប្លោកលម្អង
- storage cell /ˈstɔːrɪdʒ sɛl/ [n] រន្ធនៅលើផ្លិតនៃសម្បុកឃ្មុំ
- swarmer cell /ˈswɔːmə sɛl/ [n] កោសិកាចាប់អាសូត (កោសិកាបាក់តេរី Rhizobium ដែលជ្រៀតចូលទៅក្នុងរោមជញ្ជក់របស់រុក្ខជាតិគ្រួសារសណ្ដែក ដើម្បីបង្កើតទំនាក់ទំនងសហប្រាណសម្រាប់ជំនាប់អាសូត)
- tube cell /tjuːb sɛl/ [n] កោសិកាបំពង់ (កោសិកានៅក្នុងគ្រាប់លម្អងរបស់រុក្ខជាតិមានគ្រាប់ ដែលនឹងលូតលាស់ទៅជាបំពង់លម្អង)
- vegetative cell /ˈvɛdʒɪtətɪv sɛl/ [n] សូមមើលពាក្យ៖ somatic cell
- white blood cell /wʌɪt blʌd sɛl/ [n] សូមមើលពាក្យ៖ leucocyte
- white cell /wʌɪt sɛl/ [n] កោសិកាស
- worker cells /ˈwəːkə sɛlz/ [n] សម្បុកឃ្មុំ
- squamous cell /ˈskweɪməs sɛl/ [n] សូមមើលពាក្យ៖ epithelium
- cell fractionation /sɛl frakʃ(ə)ˈneɪʃ(ə)n/ [n] ការញែកកោសិកា
- cell memory /sɛl ˈmɛm(ə)ri/ [n] កោសិកាចងចាំ
- cell plate /sɛl pleɪt/ [n] បន្ទះកោសិកា

**cellular** /ˈsɛljʊlə/ [adj] ដែលមានរន្ធពាសពេញ

**cellulitis** /ˌsɛljʊˈlʌɪtɪs/ [n] ការរលាកជាលិកាអសរីរាង្គ (ឧ. ការរលាកស្បែក, សាច់, សាច់ដុំ ដោយមាន អាការហើមពណ៌ក្រហម, ឈឺ, ក្ដៅ តែគ្មានបូស)

**cellulose** /ˈsɛljʊləʊz/ [n] សែលុយឡូស

***Celosia argentea*** [sci.n] សូមមើលពាក្យ៖ plumed cockscomb

**cement** /sɪˈmɛnt/ [n] (សទិសន័យ៖ ground mass) ស៊ីម៉ង់ (ក្នុងដី)

**cementation** /ˌsiːmɛnˈteɪʃ(ə)n/ [n] ការផ្សារភ្ជាប់គ្នា

**softy cemented** /ˈsɒfti sɪˈmɛntid/ [adj] ផ្សារភ្ជាប់គ្នា (តែមិនសូវជាប់)

**cenospecies** /ˈsɛnəʊˈspiːʃiːz/ [n] ប្រភេទសត្វដែលអាចបង្កាត់ពូជគ្នាបាន

**census** /ˈsɛnsəs/ [n] ជំរឿន (ការស្រង់ស្ថិតិជាផ្លូវការទៅលើប្រជាករមួយដែលព័ត៌មានសំ ខាន់ៗត្រូវស្រង់មាន ភេទ អាយុ មុខរបរ។ល។)

- census number /ˈsɛnsəs ˈnʌmbə/ [n] ចំនួនដើមសិក្សាហើយ (ចំនួនជាក់ស្ដែងនៃដើមឈើក្នុងក្រុមពូជដែលបានសិក្សាហើយ)

***Centella asiatica*** [sci.n] សូមមើលពាក្យ៖ gotu kola

**center** /ˈsɛntə/ [n] មជ្ឈមណ្ឌល, ចំណុចកណ្ដាល,

- breathing center /ˈbriːðɪŋ ˈsɛntə/ [n] មជ្ឈមណ្ឌលដង្ហើម
- breeding center /ˈbriːdɪŋ ˈsɛntə/ [n] មជ្ឈមណ្ឌលបង្កាត់ពូជ
- Centre For Agricultural Strategy (CAS) [n] មជ្ឈមណ្ឌលរៀបចំយុទ្ធសាស្ត្រខាងកសិកម្ម
- Centre Internal Agriculture Tropicale (CIAT) [n] មជ្ឈមណ្ឌលអន្តរជាតិសម្រាប់កសិកម្មនៅតំបន់ត្រូពិច
- centre of origin /ˈsɛntə ɒv ˈɒrɪdʒɪn/ [n] តំបន់ដើមកំណើត (តំបន់ដែលសត្វ ឬរុក្ខជាតិបានកើតចេញឡើង)
- chiral center /ˈkʌɪr(ə)l ˈsɛntə/ [n] មជ្ឈមណ្ឌលគីរ៉ាល់ (អាតូមដែលមានជំនួសបួនខុសគ្នា)
- forest tree nursery centre /ˈfɒrɪst triː ˈnəːs(ə)ri ˈsɛntə/ [n] មជ្ឈមណ្ឌលបណ្ដុះកូនឈើ
- gene center /dʒiːn ˈsɛntə/ [n] មណ្ឌលសែនចម្រុះ, មណ្ឌលពន្ធុចម្រុះ (មណ្ឌលមានសែនសម្បូរបែប)

**centi-** /ˈsɛnti/ [prefix] បុព្វបទមានន័យថា មួយរយ, មួយភាគមួយរយ

**centigrade** /ˈsɛntɪgreɪd/ [n] (សទិសន័យ៖ Celsius scale) សង់ទីក្រាត

**centimeter** /ˈsɛntɪmiːtə/ [n] សង់ទីម៉ែត្រ

**centipede** /ˈsɛntɪpiːd/ [n] សត្វក្អែប ឬមេរង (សូមមើលពាក្យ៖ chilopod)

- venomous centipede /ˈvɛnəməs ˈsɛntɪpiːd/ [n] ក្អែប

**central** /ˈsɛntr(ə)l/ [adj] កណ្ដាល, មជ្ឈិម, សំខាន់បំផុត

- central office /ˈsɛntr(ə)l ˈɒfɪs/ [n] ការិយាល័យកណ្ដាល

**centrifugation** /sɛntrɪfjʊˈgeɪʃ(ə)n/ [n] រង្វិលចាកផ្ចិត, វិធីញែកដោយកម្លាំងចាកផ្ចិត

- density gradient centrifugation /density ˈgreɪdɪənt sɛntrɪfjʊˈgeɪʃ(ə)n/ [n] ការញែកប្រទាញចេញតាមជម្រាលដង់ស៊ីតេ
- differential centrifugation /ˌdɪfəˈrɛnʃ(ə)l sɛntrɪfjʊˈgeɪʃ(ə)n/ [n] រង្វិលចាកផ្ចិតញែកធាតុកោសិកា
- equilibrium centrifugation /ˌiːkwɪˈlɪbrɪəm sɛntrɪfjʊˈgeɪʃ(ə)n/ [n] រង្វិលចាកផ្ចិតលំនឹង

**centrifuge** /ˈsɛntrɪfjuːdʒ/ [n] ម៉ាស៊ីនរង្វិលចាកផ្ចិត, សង់ទ្រីភុយស៊រ

**centriole** /ˈsɛntrɪəʊl/ [n] សង់ទ្រីយ៉ូល

**centripetal** /ˌsɛntrɪˈpiːt(ə)l/ [adj] ដែលចូលមកកណ្ដាល

**centro** /sɛn trəʊ/ [n] វល្លិកន្ទុយ (ឈ្មោះវិទ្យាសាស្ត្រ *Centrosema pubescens*)

**centrolecithal** /ˌsɛntrəʊ lɛːcɪðɔːl/ [adj] ដែលមានស៊ុតលឿងនៅចំកណ្ដាល

**centromere** /ˈsɛntrə(ʊ)mɪə/ [n] សង់ត្រូមែរ (កន្លែងដែលក្រូម៉ាទីតទាំង២ ភ្ជាប់គ្នា និងត្រូវបានភ្ជាប់ទៅកាន់សរសៃអាក្រូម៉ាទិច)

***Centrosema pubescens*** [sci.n] សូមមើលពាក្យ៖ centro

**centrosome** /ˈsɛntrəsəʊm/ [n] សង់ត្រូសូម (តំបន់នៃស៊ីតូប្លាសដែលមានសង់ទ្រីយ៉ូល)

**centrum** /ˈsɛntrəm/ [n] តួឆ្អឹងកង

**century** /ˈsɛntʃʊri/ [n] សតវត្សរ៍

**Cepaea** [n] សេប៉ាអ៊ា (ពួកមួយនៃខ្យងលើគោក ដែលត្រូវបានសិក្សាយ៉ាងច្រើន ដោយសារតែពហុសណ្ឋាននៃសម្ភារសេនេទិចរបស់វា)

**cephalalgia** /ˌsɛf əˈlal dʒiə/ [n] រោគឈឺក្បាល

**cephalic** /sɪˈfalɪk/ [adj] នៃក្បាល

**cephalisation** /ˌsɛfəlʌɪˈzeɪʃ(ə)n/ [n] វិវដ្ដខួរក្បាល

**cephalo-** /ˈsɛfələʊ/ [prefix] បុព្វបទមានន័យថា ក្បាល

**cerato-** [prefix] បុព្វបទមានន័យថា ដូចស្នែង

**cerc-** [prefix] (ដូច៖ cerco-) បុព្វបទមានន័យថា កន្ទុយ

**cercaria** /səːˈkɛːrɪə/ [n] ស៊ែកែ

**cerco-** [prefix] (ដូច៖ cerc-) បុព្វបទមានន័យថា កន្ទុយ

**cercus** /ˈsəːkəs/ [n] (ពហុវចនៈ៖ cerci) ស្នែងដុះនៅចុងពោះ

**cereal** /ˈsɪərɪəl/ [n] ធញ្ញជាតិ (ពពួករុក្ខជាតិមានគ្រាប់តូចតែរឹងដូចជាស្រូវ ឬស្រូវសាលី)

**cerebellum** /ˌsɛrɪˈbɛləm/ [n] ខួរតូច

**cerebral** /ˈsɛrɪbr(ə)l/ [adj] នៃខួរក្បាល, នៃបញ្ញាចិត្ត

- cerebral palsy /ˈsɛrɪbr(ə)l ˈpɔːlzi/ [n] ការរិកលចលនាសរសៃញាណ ជាអចិន្ត្រៃយ៍

**cerebro** /ˈsɛrɪbrəʊ/ [n] ខួរក្បាល

**cerebrospinal** /ˌsɛrɪbrə(ʊ)ˈspʌɪn(ə)l/ [adj] នៃខួរក្បាល និងខួរឆ្អឹងខ្នង

- cerebrospinal fluid /ˌsɛrɪbrə(ʊ)ˈspʌɪn(ə)l ˈfluːɪd/ [n] ទឹកស្រោមខួរ

**cerebrovascular** /ˌsɛrɪbrə(ʊ)ˈvaskjʊlə/ [n] នៃសរសៃឈាមខួរក្បាល

**cerebrum** /ˈsɛrɪbrəm/ [n] ខួរក្បាលធំ

***Cereus peruvianus*** [sci.n] ដើមដំបងយក្ស

**Cerium** /ˈsɪərɪəm/ [n] សេរ្យ៉ូម (និមិត្តសញ្ញាគីមី Ce)

**certificate** /səˈtɪfɪkət/ [n] វិញ្ញាបនបត្រ (លិខិតបញ្ជាក់ការសិក្សាក្រោយពេលរៀនចប់)

- certificate of completion /səˈtɪfɪkət ɒv kəmˈpliːʃn/ [n] វិញ្ញាបនបត្របញ្ចប់ការសិក្សា
- health certificate /hɛlθ səˈtɪfɪkət/ [n] (សទិសន័យ ៖ phytosanitary certificate) វិញ្ញានប័ត្រសុខភាព, លិខិតបញ្ជាក់សុខភាព(គ្មានរោគ)
- land title certificate /land ˈtʌɪt(ə)l səˈtɪfɪkət/ [n] ប័ណ្ណកម្មសិទ្ធិដី
- phytosanitary certificate /ˌfʌɪθəʊˈsanɪt(ə)ri səˈtɪfɪkət/ [n] (សទិសន័យ៖ health certificate) វិញ្ញាបនបត្រសុខភាព, លិខិតបញ្ជាក់សុខភាព (គ្មានរោគ), វិញ្ញាបនបត្រភូតគាមអនាម័យ (វិញ្ញាបនបត្រដែលចេញឱ្យ និងបង្ហាញពីលទ្ធផលនៃការសាកល្បងដើម្បីឱ្យដឹងថាគ្រាប់ពូជ ឬរុក្ខជាតិគ្មានជំងឺ ឬសារពាង្គកាយដែលគេមិនចង់ឱ្យវារីករាលដាលទៅប្រទេសផ្សេង។ គេអាចអនុញ្ញាតឱ្យបានក្នុងករណីដាក់វាឱ្យដាច់ឆ្ងាយពីគេ ឬសម្អាតមេរោគវារួច។)

**cerumen** /sɪˈruːmən/ [n] អាចម៍ត្រចៀក

**cervic-** [prefix] (ដូច៖ cervico-) បុព្វបទមានន័យថា ក ឬកស្បូន

**cervical** /ˈsəːvɪk(ə)l/ [adj] នៃក (ស្បូន, ឆ្អឹងកង)

**cervico-** [prefix] (ដូច៖ cervic-) បុព្វបទមានន័យថា ក ឬកស្បូន

**cervix** /ˈsəːvɪks/ [n] ក (ស្បូន)

**Cesium** /ˈsiːzɪəm/ [n] សេស្យូម (និមិត្តសញ្ញាគីមី Cs)

**cess-pit** /sɛs-pɪt/ [n] រណ្ដៅទឹកស្អុយ

***Cestrum nocturnum*** [sci.n] ផ្កាណាត្រី

**ceylon spinach** /sɪˈlɒn ˈspɪnɪdʒ/ [n] ជ្រលង់ (ឈ្មោះវិទ្យាសាស្ត្រ *Basella rubra*)

**chacunda gizzard shad** [n] ត្រីកាមួយ (ឈ្មោះវិទ្យាសាស្ត្រ Anodontostoma chacunda)

**chaet-** [prefix] (ដូច៖ chaeto-) បុព្វបទមានន័យថា សក់ ឬរោម

**chaeto-** [prefix] (ដូច៖ chaet-) បុព្វបទមានន័យថា សក់ ឬរោម

**chaetotaxy** /ˈki təˌtak si/ [n] ចំណែកថ្នាក់រោម

**chafe** /tʃeɪf/ [v] (សទិសន័យ៖ irritate) រលាក

**chaff** /tʃɑːf/ [n] គ្រាប់ស្វិត, ចំបើង, អង្កាម (នៅក្នុងប្រភេទ Eucalyptus (ប្រេងខ្យល់) ការសំអាតកំទេចកំទីគ្រាប់ស្វិត ដែលអូវុលមិនបានបង្កកំណើត។)

**chain** /tʃeɪn/ [n] ជួរ, ខ្សែ, ច្រវាក់

**cold chain** /kəʊld tʃeɪn/ [n] តំណាត្រជាក់

**soil chain** /sɔɪl sɔɪl/ [n] ប្រភេទដីផ្សេងៗនៅតាមជម្រាល

**chalaza** /kəˈleɪzə/ [n] (ពហុវចនៈ៖ chalazae) បាតអូវុល (ជាបាតរបស់អូវុលមួយ ជារឿយៗ គេឃើញវាដូចជាផ្នែកនៅខាងក្រោមចំណុចប្រសព្វគ្នានៃ integument ជាមួយនិង megasporangium។ ជាធម្មតា វាប្រសព្វជាមួយទីតាំងរបស់ទងគ្រាប់ (funiculus) ក្នុងករណីនេះ វាដូចគ្នាបេះបិទនឹង hilum នៅលើគ្រាប់។)

**chalk** /tʃɔːk/ [n] ដីស, កំបោរ

- chalk moder /tʃɔːk mɒdə/ [n] មមោកអន្តរការនៅលើដីកំបោរ
- lacustrine chalk /ləˈkʌstrʌɪn tʃɔːk/ [n] កំបោរបាតបឹង
- meadow chalk /ˈmɛdəʊ tʃɔːk/ [n] ស្រទាប់កំបោរកើតក្នុងបឹង (ទឹកសាប)
- chalkiness /ˈtʃɔːkinəs/ [n] ភាពស (លក្ខណៈមួយកំណត់ទៅលើគុណភាពគ្រាប់អង្ករ)
- chalk scree /tʃɔːk skriː/ [n] កម្ទេចកំបោរ, ក្រួសកំបោរ
- chalk-board /tʃɔːk bɔːd/ [n] ក្ដារខៀន (ក្ដារឈើដែលលាបពណ៌ខ្មៅ ឬបៃតងសរសេរជាមួយដីស)

***Chamaesyce hirta*** [sci.n] សូមមើលពាក្យ៖ asthma plant, pillpod sandmat

**chamber** /ˈtʃeɪmbə/ [n] ប្រហោង, រន្ធ, បន្ទប់

- branchial chamber /ˈbraŋkɪəl ˈtʃeɪmbə/ [n] ប្រអប់ស្រកី (ប្រអប់ ឬប្រហោងសម្រាប់ផ្ទុកស្រកី)

**change** /tʃeɪn(d)ʒ/ [n] បម្រែបម្រួល, បម្លាស់ប្ដូរ

- atmospheric change /atməsˈfɛrɪk tʃeɪn(d)ʒ/ [n] បម្លាស់ប្ដូរបរិយាកាស
- chemical change /ˈkɛmɪk(ə)l tʃeɪn(d)ʒ/ [n] ប្រតិកម្មគីមី
- environmental change /ɪnvʌɪrənˈmɛnt(ə)l tʃeɪn(d)ʒ/ [n] បម្លាស់ប្ដូរបរិស្ថាន

***Channa lucius*** [sci.n] ត្រីកញ្ជនដៃ

***Channa marulius*** [sci.n] ត្រីរ៉ស់

***Channa micropeltes*** [sci.n] សូមមើលពាក្យ៖ giant snakehead

***Channa orientalis*** [sci.n] សូមមើលពាក្យ៖ walking snakehead

***Channa striata*** [sci.n] សូមមើលពាក្យ៖ chevron snakehead

**channel** /ˈtʃan(ə)l/ [n] ផ្លូវទឹក (ប្រឡាយ, ស្ទឹង, ព្រែក), ចង្អូរក្នុងតំបន់ស្ងួត

- drainage channel /ˈdreɪnɪdʒ ˈtʃan(ə)l/ [n] ប្រឡាយ ឬចង្អូរបញ្ចេញទឹក (សិប្បនិម្មិត)

**channery** /ˈtʃan ə ri/ [adj] ដែលមានថ្ម

***Chanos chano*** [sci.n] សូមមើលពាក្យ៖ milkfish

**chaplet** /ˈtʃaplɪt/ [n] ការផ្ដុំ, ចង្កោម

- pore chaplet /pɔː ˈtʃaplɪt/ [n] ការផ្ដុំនៃរន្ធ (ក្នុងដី)

**character** /ˈkarəktə/ [n] លក្ខណៈ (កេតនភណ្ឌនៃសរីរាង្គមួយ ដែលជាលទ្ធផលទទួលបានមកពីអន្តរអំពើរវាងពន្ធុ និងបរិស្ថាន)

- acquired character /əˈkwʌɪəd ˈkarəktə/ [n] លក្ខណៈប្រែប្រួល, លក្ខណៈផ្លាស់ប្តូរ, លក្ខណៈក្លាយ (ការប្រែប្រួលមួយដែលបានវិវត្តន៍នៅក្នុងជីវិតសរីរាង្គមួយ ដូចជា លទ្ធផលនៃការជះឥទ្ធិពលរបស់បរិស្ថាន។ ការប្រែប្រួលនេះមិនអាចតពូជបានទេ។)
- epigamic character /ˈɛpɪgamɪk ˈkarəktə/ [n] លក្ខណៈទាក់ទាញ (លក្ខណៈភេទទី២ ដែលកើតឡើងដោយសកម្មភាពអ័រម៉ូន ហើយត្រូវបានប្រើនៅក្នុងការទាក់ទាញដើម្បីពាក់គ្នា)
- physiological character /ˌfɪzɪəˈlɒdʒɪk(ə)l ˈkarəktə/ [n] លក្ខណៈសរីរៈ (លក្ខណៈមួយដែទាក់ទងដំណើរការជីវិតរបស់សារពាង្គកាយមួយ មានតួនាទីមួយផ្ទុយពីទម្រង់ ឬរចនាសម្ពន្ធ។ ជាញឹយៗ វាមិនអាចវិនិច្ឆ័យបានទេ លើកលែងតែការសម្តែងចេញរបស់វា។ ឧ. អត្រាលូតលាស់ ឬភាពអត់ធន់នឹងជំងឺណាមួយ។)
- qualitative character /ˈkwɒlɪtətɪv ˈkarəktə/ [n] លក្ខណៈគុណភាព
- quantitative character /ˈkwɒntɪtətɪv ˈkarəktə/ [n] លក្ខណៈបរិមាណ (លក្ខណៈតំណពូជដែលមានលក្ខណៈប្រែប្រួលជានិរន្តរ៍ និងត្រូវបានទទួលរងឥទ្ធិពលដោយកត្តាបរិយាកាស (ឧ. អាយុ ទម្ងន់ កម្ពស់ជាដើម))

**character convergence** /ˈkarəktə kənˈvəːdʒ(ə)ns/ [n] រួមលក្ខណៈ

**character displacement** /ˈkarəktə dɪsˈpleɪsm(ə)nt/ [n] ដាច់លក្ខណៈ

**characteristic** /karəktəˈrɪstɪk/ [n] បុគ្គលិកលក្ខណៈ, ចរិតលក្ខណៈ

**characteristic** /karəktəˈrɪstɪk/ [adj] នៃបុគ្គលិកលក្ខណៈ

**charcoal** /ˈtʃɑːkəʊl/ [n] ធ្យូងឈើ, ធ្យូង (ទម្រង់នៃកាបូនដែលទាញយកពីចំហេះមិនសព ឬមិនពេញលេញ (incomplete combustion) នៃរុក្ខជាតិ ឬសត្វ ដូចជាឆ្អឹង ឬឈើ)

- activated charcoal /ˈaktɪveɪtɪd ˈtʃɑːkəʊl/ [n] ធ្យូងសកម្ម
- wood charcoal /wʊd ˈtʃɑːkəʊl/ [n] (សទិសន័យ៖ wood coal) ធ្យូងឈើ

**Charophyta** /ˈkɑːrə(ʊ)ˌfʌɪtə/ [n] ការ៉ូភីតា (សារាយមួយក្រុមដូចជាស្លនរ៉ែត ដែលរស់នៅក្នុងទឹកត្រពាំង)

***Charops brachypterum*** [sci.n] ពួកឪម៉ាល់ (បរាសិតដង្កូវ)

**chart** /tʃɑːt/ [n] ប្លង់, ផែនទី, គំនូសតាង (ប្លង់ពិសេសនៃរូបភាព និងព័ត៌មានដែលគេធ្វើឡើងពីក្រដាសធំសម្រាប់ពន្យល់បង្ហាញពេលរៀន)

**chartaceous** /kɑːˈteɪʃəs/ [adj] ខាតាសឺស ((អំពីផ្នែករបស់រុក្ខជាតិ) មានលក្ខណៈដូចជាក្រដាស)

**chasmogamic** /ˌkazməˌgamɪk/ [adj] ខាស្មូហ្គាមីក ((អំពីផ្កា) បើកមុនដំណើរលម្អង)

**chayote** /ˈtʃeɪəʊti/ [n] ផ្លែស៊ូ (ឈ្មោះវិទ្យាសាស្ត្រ *Sechium edule*)

**check** /tʃɑːt/ [v] ត្រួតពិនិត្យ

**checklist** /ˈtʃɛklɪst/ [n] តារាងត្រួតពិនិត្យការងារ (តារាងដែលគូសនៅលើសន្លឹកក្រដាសយ៉ាងពិសេសសម្រាប់ពិនិត្យ និងកត់ត្រាប្រចាំថ្ងៃនូវកិច្ចការដែលធ្វើហើយ ឬមិនទាន់បានធ្វើឱ្យគូសជាសញ្ញាចំណាំ)

**cheek** /tʃiːk/ [n] ថ្ពាល់

**cheetah** /ˈtʃiːtə/ [n] ខ្លាម្យ៉ាំងដូចខ្លារខិន

***Cheilinus undulatus*** [sci.n] សូមមើលពាក្យ៖ humphead wrasse

***Cheilomenes sexmaculata*** [sci.n] អណ្តើកមាសប្រាំមួយចំនុច

**cheironym** /ˈkʌɪrəʊnɪm/ [n] ខៃរ៉ូនីម (ឈ្មោះភាវរស់ដែលមិនបានបោះពុម្ពផ្សាយ)

**chel-** /ˈkiːl/ [prefix] បុព្វបទមានន័យ ទាក់ទងនឹងតង្កៀប

**chela** /ˈkiːlə/ [n] តង្កៀប

**chelate** /ˈkiːleɪt/ [adj]
១. ដែលមានតង្កៀប
២. ភ្ជាប់ (ភ្ជាប់ជាមួយអ៊ីយ៉ុងលោហៈ ដើម្បីបង្កើតសមាសធាតុមានស្ថិរភាព)

**cholelithiasis** /ˌkɒlɪlɪˈθʌɪəsɪs/ [n] ការមានថ្មនៅក្នុងប្រម៉ាត់

**chelicerae** /kəˈlɪs(ə)rə/ [n] ចង្កូម

**Chelonia** /kɪˈləʊnɪə/ [n] ឃេឡូនៀ (លំដាប់ឧរង្គសត្វដែលមានដូចជាសត្វអណ្តើក)

***Chelonia mydas*** [sci.n] សូមមើលពាក្យ៖ green turtle

***Chelonodon biocellatus*** [sci.n] សូមមើលពាក្យ៖ eyespot pufferfish

***Chelonodon fluviatilis*** [sci.n] សូមមើលពាក្យ៖ tidal pufferfish

***Chelonodon nigroviridis*** [sci.n] សូមមើលពាក្យ៖ spotted green pufferfish

**chemical** /ˈkɛmɪk(ə)l/ [adj] នៃគីមី

**chemical** /ˈkɛmɪk(ə)l/ [n] ផលិតផលគីមី, គីមី

- chemical name /ˈkɛmɪk(ə) neɪm/ [n] ឈ្មោះគីមី (របនាបទនៃការដាក់ឈ្មោះទៅតាមទម្រង់នៃធាតុគីមីនោះ ដោយអនុលោមទៅតាមឈ្មោះដែលកំណត់ដោយប្រព័ន្ធអន្តរជាតិចំពោះការប្រើប្រាស់ឈ្មោះគីមី)

**chemistry** /ˈkɛmɪstri/ [n] គីមី

- agricultural chemistry /agrɪˈkʌltʃərəl ˈkɛmɪstri/ [n] សូមមើលពាក្យ៖ agro-chemistry
- analytical chemistry /agrɪˈkʌltʃərəl ˈkɛmɪstri/ [n] គីមីវិភាគ
- applied chemistry /əˈplʌɪd ˈkɛmɪstri/ [n] គីមីអនុវត្ត
- colloid chemistry /ˈkɒlɔɪd ˈkɛmɪstri/ [n] គីមីកូឡូអ៊ីត
- general chemistry /ˈdʒɛn(ə)r(ə)l ˈkɛmɪstri/ [n] គីមីទូទៅ
- industrial chemistry /ɪnˈdʌstrɪəl ˈkɛmɪstri/ [n] គីមីឧស្សាហកម្ម
- inorganic chemistry /ɪnɔːˈganɪk ˈkɛmɪstri/ [n] គីមីខនិជ, គីមីរ៉ែ, គីមីអសរីរាង្គ
- macromolecular chemistry /ˌmakrə(ʊ)məˈlɛkjʊlə ˈkɛmɪstri/ [n] គីមីប៉ូលីមែរ
- organic chemistry /ɔːˈganɪk ˈkɛmɪstri/ [n] គីមីសរីរាង្គ
- physical chemistry /ˈfɪzɪk(ə)l ˈkɛmɪstri/ [n] គីមីរូប
- soil chemistry /sɔɪl ˈkɛmɪstri/ [n] គីមីដី

**chemoheterotroph** /ˈkiːməʊˈhɛt(ə)rə(ʊ)trəʊf/ [n] (សទិសន័យ៖ chemoorganotroph) គីមីបរជីព (សារពាង្គកាយដែលអាស្រ័យលើសារធាតុគីមីសរីរាង្គសម្រាប់ថាមពល និងសារធាតុកាបូន)

**chemoreceptor** /ˈkiːməʊrɪˌsɛptə/ [n] គីមីផ្ទួល

**chemosensory** /ˌkiːməʊˈsɛns(ə)ri/ [n] គីមីញាណ (សរីរាង្គ ឬទម្រង់ដែលអាចដឹងពីវត្តមានសារធាតុគីមីយថាប្រភេទ)

**chemostat** /ˈkiːmə(ʊ)stat/ [n]ឃីម៉ូស្តាត (ធុងបណ្តុះដែលមានការត្រួតពិនិត្យដោយស្វ័យប្រវត្តិនូវរំហូរ សារធាតុចិញ្ចឹម និងរំហូរចេញនៃកោសិកា)

**chemosynthesis** /ˌkiːmə(ʊ)ˈsɪnθɪsɪs/ [n] សំយោគគីមី

**chemotaxis** /ˌkiːmə(ʊ)ˈtaksɪs/ [n] គីមីតំណប (ឧ. ចលនារបស់ឌីម៉ាល់ឆ្ពោះទៅរកក្លិនស្រាបៀរគឺជាគីមីតំណប)

**chemotherapy** /ˌkɛmə(ʊ)ˈθɛrəpi/ [n] គីមីព្យាបាល

**chemotropism** /kēməˈtrōpizəm/ [n] តំណបរំញោចគីមី, គីមីទំនោរ (ចំពោះរុក្ខជាតិ សំដៅលើការលូតលាស់ដែលឆ្ពោះទៅរករំញោចនៃធាតុគីមី)

**chernozem** /ˈtʃəːnəzɛm/ [n] ដីឈៃណូស្យូម, ដីខ្មៅ

**chert** /tʃəːt/ [n] សូមមើលពាក្យ៖ silliceous concretion

**cherty** /tʃəːti/ [adj] ដែលជាក្រួសដែលមានជ្រុងមុតហើយមិនស្មើគ្នា

**chest** /tʃɛst/ [n] (សទិសន័យ៖ chest wall) ទ្រូង

**chestnut** /ˈtʃɛsnʌt/ [n] ផ្លែកៅឡាក់

**chestnut-colored** /ˈtʃɛsnʌt ˈkʌləd/ [n] សូមមើលពាក្យ៖ nut-brown

**chew** /tʃuː/ [v] ទំពា

**chiasma** /kʌɪˈazmə/ [n] (ពហុវចនៈ៖ chiasmata) ភាពខ្វែង (ក្នុងបាតុភូតcrossing over នៃchromatid)

**chicken** /ˈtʃɪkɪn/ [n] មាន់

- chicken comb /ˈtʃɪkɪn kəʊm/ [n] សេមាន់, ចៃមាន់
- chicken pox /ˈtʃɪkɪn pɒks/ [n] រោគអុតស្វាយ, អុតតូច

**chili saltpetre** /ˈtʃɪli sɔːltˈpiːtə/ [n] នីត្រាតសូដ្យូម

**chill** /tʃɪl/ [n] រងាញាក់, គ្រុនរងា, ស្រៀវស្រាញ

**chilli (chili)** /ˈtʃɪli/ [n] ម្ទេស (វាស្ថិតនៅក្នុងគ្រួសារ Solanaceae អម្បូរ *Capsicum frutescens* និង *C.sinensis*

**chilling** /tʃɪlɪŋ/ [n] ការធ្វើឱ្យចុះត្រជាក់, ការបន្ទុំផ្លែគ្រាប់, ការបំបែកភាពសំងំរបស់គ្រាប់ពូជ (តាមន័យត្រង់ គឺធ្វើឱ្យចុះត្រជាក់។ ជាទូទៅ គេប្រើពាក្យនេះសំដៅលើវិធីសាស្ត្រដាក់គ្រាប់នៅក្នុងបរិស្ថាន មួយមានសំណើមត្រជាក់ដើម្បីបន្ទុំវា ឬក៏បំបែកភាពសំងំរបស់គ្រាប់ពូជ។)

**chills and fever** /tʃɪlz ənd ˈfiːvə/ [n] គ្រុនរងាស្រៀវស្រាញ

**chilo-** [prefix] បុព្វបទមានន័យថា ទាក់ទងនឹងបបូរមាត់

**chilopod** /ˈkʌɪləpɒd/ [n] ឃីឡូប៉ូត (អាត្រូប៉ូតទាំងឡាយដែលស្ថិត នៅក្នុងថ្នាក់ឃីឡូប៉ូដា (ពពួកក្អែប)។ ពួកវាជាមំសាសី ហើយនៅអង្គត់ទ្រូងនីមួយៗមានជាជើងមួយគូ)

**chimera** /kʌɪˈmɪərə/ [n] រុក្ខជាតិឃីមីរ៉ា (រុក្ខជាតិដែលផ្សំឡើងពីជាលិកាពីរ ឬច្រើនខុសៗគ្នាខាងសេនេទិចលូតលាស់ជាច់ពីគ្នា ប៉ុន្តែនៅក្បែរគ្នានៅក្នុងដើមតែមួយ។ រុក្ខជាតិឃីមីរ៉ា អាចនឹងបន្តពូជដោយភេទបាន បើសិនពួកវាស្ថិតនៅក្នុងត្រកូលនៃកោសិកាបន្តពូជ។)

**chin** /tʃɪn/ [n] ចង្កា

**Chinaberry** /ˈtʃʌɪnəbɛri/ [n] ដកហ៊ាន, ស្មៅខ្មោច (ឈ្មោះវិទ្យាសាស្ត្រ៖ *Malia azedarach*)

**Chinese broccoli** /tʃʌɪˈniːz ˈbrɒkəli/ [n] ខាត់ណាឈើ (ឈ្មោះវិទ្យាសាស្ត្រ *Brassica oleracea* var. *alboglabra*)

**Chinese cabbage** /tʃʌɪˈniːz ˈkabɪdʒ/ [n] ស្ពៃបូកគោ

**Chinese celery** /tʃʌɪˈniːz ˈsɛləri/ [n] ជីរឃិនឆាយ (ឈ្មោះវិទ្យាសាស្ត្រ *Apium graveolens*)

**Chinese chives** /tʃʌɪˈniːz tʃʌɪvz/ [n pl] គូឆាយ (ឈ្មោះវិទ្យាសាស្ត្រ *Allium tuberosum*)

**Chinese kale** /tʃʌɪˈniːz keɪl/ [n] សូមមើលពាក្យ៖ Chinese broccoli

**Chinese peas** /tʃʌɪˈniːz piːz/ [n pl] សណ្តែកហោឡាំងតាវ, សណ្តែកផ្អែម

**Chinese radish** /tʃʌɪˈniːz ˈradɪʃ/ [n] ឆៃថាវ

**Chinese seerfish** [n] ត្រីបេកា (ឈ្មោះវិទ្យាសាស្ត្រ *Scomberomorus sinensis*)

**chipping** /ˈtʃɪpɪŋ/ [n] (ចំពោះធរណីវិទ្យា) សូមមើលពាក្យ៖ broken stone

**chisel** /ˈtʃɪz(ə)l/ [n] ពន្លាក (ឧបករណ៍ចោះឈើ), ដែកដាប់

**chiseling** /ˈtʃɪz(ə)lɪŋ/ [n] សូមមើលពាក្យ៖ subtilling

***Chitala blanci*** [sci.n] សូមមើលពាក្យ៖ royal featherback

***Chitala lopis*** [sci.n] សូមមើលពាក្យ៖ giant featherback

**chitin** /ˈkʌɪtɪn/ [n] គីធីន (សមាសភាពសំខាន់សម្រាប់គ្រោងឆ្អឹងក្រៅរបស់សត្វល្អិត)

**chitinase** /ˈkʌɪtɪneɪz/ [n] គីទីនណាស (អង់ស៊ីមជំរុញការបំបែកគីទីន និងបង្កើតគីតូប៊ីយ៉ូស អង់ស៊ីមនេះមាននៅក្នុងសត្វ រុក្ខជាតិ និងអតិសុខុមប្រាណផ្សេងៗ)

**chives** /tʃʌɪvz/ [n pl] ផ្កាកាឆាយ

**chlamydate** /ˈklaməˌdāt/ [n] ដែលមានសំបក ឬស្រោម

**chlordane** /ˈklɔːdeɪn/ [n] ក្លរដាន

**chlorenchyma** /kləʊrɪkkɪmə/ [n] ក្លរ៉ង់ស៊ីម (ជាប៉ារ៉ង់ស៊ីម ដែលផ្ទុកក្លរ៉ូប្លាស នៃរុក្ខជាតិថ្នាក់ខ្ពស់)

**chloride** /ˈklɔːrʌɪd/ [n] ក្លរីដ
- chloride solonchak /ˈklɔːrʌɪdˌsɒlənˈtʃak/ [n] ដីប្រៃដែលមានសារធាតុក្លរច្រើន, សូឡុងឆាកដែលមានធាតុក្លរ ខ្មៅហើយសើមជានិច្ច

**chlorination** /ˌklɔːrɪˈneɪʃ(ə)n/ [n] ក្លរកម្ម

**Chlorine** /ˈklɔːriːn/ [n] ក្លរ (និមិត្តសញ្ញាគីមី Cl)

**chlorocruorin** /kləʊrəʊ 'kruːrɪn/ [n] ក្លរ៉ូគ្រូអ៊ីរីន (ជាតិពណ៌ដង្ហើមបៃតង ដែលមានទំនាក់ទំនងយ៉ាងជិតស្និតជាមួយអេម៉ូក្លូប៊ីន និងដែលមាននៅក្នុងដង្កូវពោមច្រើនមួយចំនួន)

**chlorofluorocarbons (CFCs)** /ˌklɔːrə(ʊ)ˌflʊərə(ʊ)ˈkɑːb(ə)n/ [n pl] ក្លរ៉ូភ្លុយអរ៉ូកាបូន (ឧស្ម័ន CFCs)

**chlorophyll** /ˈklɔːrəfɪl/ [n] ក្លរ៉ូភីល

**Chlorophyta** /ˈklɔːrə(ʊ)ˌfʌɪtə/ [n] ក្លរ៉ូហ្វីតតា (សាខាធំបំផុតនៃសារាយបៃតង)

**chloroplast** /ˈklɔːrə(ʊ)plast/ [n] ក្លរ៉ូប្លាស

**chlorosis** /klɒˈrəʊsɪs/ [n] ជំងឺខ្វះជាតិពណ៌បៃតង, ក្លរ៉ូស, ជំងឺក្លរ៉ូស៊ីស, ភាពស្លាំង (ភាពបាត់បង់ក្លរ៉ូហ្វីលនៃស្លឹកដោយធ្វើឱ្យស្លឹកប្រែពណ៌លឿងខ្ចី ឬលឿងស្លេក)

**choan-** [prefix] (ដូច៖ choano-) បុព្វបទមានន័យថា ទាក់ទងនឹងបំពង់ ឬរន្ធ

**choano-** [prefix] (ដូច៖ choan-) បុព្វបទមានន័យថា ទាក់ទងនឹងបំពង់ ឬរន្ធ

**choke** /tʃəʊk/ [v] ស្ទះ, ថប់

**cholecystectomy** /ˌkɒlɪsɪsˈtɛktəmi/ [n] ការវះកាត់យកថង់ទឹកប្រម៉ាត់ចេញ

**cholecystitis** /ˌkɒlɪsɪsˈtʌɪtɪs/ [n] ការរលាកថង់ប្រម៉ាត់

**cholecystogram** /ˌkoʊləsɪˈstɒgrəfi/ [n] ការថតរូបថង់ប្រម៉ាត់ដោយកម្មរស្មីអិក្ស

**cholera** /ˈkɒlərə/ [n] អាសន្នរោគ, អាសន្នរោគបក្សី

**hog cholera** /hɒg ˈkɒlərə/ [n] (សទិសន័យ៖ swine fever) ប៉េសជ្រូក

**cholesterol** /kəˈlɛstərɒl/ [n] កូឡេស្តេរ៉ុល, អង្គធាតុខ្លាញ់

***Chonerhinos nefastus*** [sci.n] សូមមើលពាក្យ៖ greenbottle pufferfish

**vocal chord** /ˈvəʊk(ə)l kɔːd/ [n] បំពង់សំឡេង

**chordo-** [prefix] បុព្វបទមានន័យថា ខ្សែ

**domestic chore** /dəˈmɛstɪk tʃɔː/ [n] ការងារផ្ទះសម្បែង

**chorea** /kɒˈrɪə/ [n] ជំងឺកន្ត្រាក់សាច់ដុំ

**chorion** /ˈkɔːrɪən/ [n] កូរ៉ុង

**choroid** /ˈkɔːrɔɪd/ [n] កូរ៉ូអ៊ីត (ស្រទាប់ដែលនៅខាងក្រោយរេទីននៃភ្នែកសត្វឆ្អឹងកង ដែលផ្ទុកសរសៃឈាម និងជាតិពណ៌)

**chrom-** /krɒm/ [prefix] (ដូច៖ chromo-, chromato-) បុព្វបទមានន័យថា ពណ៌

**chromatin** /ˈkrəʊmətɪn/ [n] ក្រូម៉ាទីន

**chromato-** /ˈkrəʊmətəʊ/ [prefix] (ដូច៖ chrom-, chromo-) បុព្វបទមានន័យថា ពណ៌

**chromatography** /ˌkrəʊməˈtɒgrəfi/ [n] វិធីញែកល្បាយ

**Chromium** /ˈkrəʊmɪəm/ [n] ក្រូម (និមិត្តសញ្ញាគីមី Cr)

**chromo-** /ˈkrəʊməʊ/ [prefix] បុព្វបទមានន័យថា ពណ៌ (ដូច៖ chrom- ឬ chromato-)

**chromocyte** /ˈkrəʊməʊsʌɪt/ [n] ក្រូម៉ូស៊ីត (កោសិកាដែលចាប់យកថ្នាំបន្ស៊ីពណ៌)

***Chromolaena odorata*** [sci.n] សូមមើលពាក្យ៖ Siam weed

**chromoplast** /ˈkrəʊməplast/ [n] ក្រូម៉ូប្លាស

**chromosol** /ˈkroʊməˌsoʊl/ [n] ដីដែលមានពណ៌ខ្លាំងស្រស់បំព្រង

**chromosomal polymorphism** /ˌkrəʊməˈsəʊməl ˌpɒlɪˈmɔːfɪz(ə)m/ [n] ពហុសណ្ឋាននៃក្រូម៉ូសូម

**chromosome painting** /ˈkrəʊməsəʊm ˈpeɪntɪŋ/ [n] ការលាបពណ៌ក្រូម៉ូសូម

**chromosome pair** /ˈkrəʊməsəʊm pɛː/ [n] គូក្រូម៉ូសូម

**chromosome** /ˈkrəʊməsəʊm/ [n] ក្រូម៉ូសូម (អង្គត់ឯកតាមួយនៃរចនាសម្ពន្ធរបស់ណ្វៃយ៉ូដែលមានពន្ធុតំរៀបជាជួរ និង វាជាសារធាតុមួយយ៉ាងតូច ជាធម្មតាមានរូបរាងដូចជាកំណាត់វែង ដែលមានផ្ទុកពន្ធុ។ ចំនួន ទំហំ និងទម្រង់របស់ក្រូម៉ូសូម ជាធម្មតា គឺថេរចំពោះប្រភេទឯកត្តៈមួយ។ ក្រូម៉ូសូមមានក្រូមីទីដដែល បង្កើតឡើងពី DNA រុំព័ទ្ធដោយប្រូតេអ៊ីន(ប្រូតេអ៊ីន)និងមានរាង ជាអង្គញៗ។

- homologuos chromosome /ˌhɒmə(ʊ)ˈzʌɪgəs ˈkrəʊməsəʊm/ [n] ក្រូម៉ូសូមអូម៉ូឡូក ( ក្រូម៉ូសូមដូចគ្នា ១គូ ម្ខាងមានដើមកំណើតពីមេ និងមួយទៀតមកពីបាដែលមាននៅក្នុងកោសិកាឌីផ្លូអ៊ីត។ ក្រូម៉ូសូមនៃគូនីមួយៗ គឺដូចគ្នាទាំង ទំហំ រូបរាង ចំណុះភេទ និងការតំរៀប។ ពួកវាតំឡើងទ្វេរនៅក្នុង ដំណើរមេយ៉ូស។)
- chromosome number /ˈkrəʊməsəʊm ˈnʌmbə/ [n] ចំនួនក្រូម៉ូសូម ( ចំនួននៃចរិតលក្ខណៈក្រូម៉ូសូមនៃប្រភេទពូជមួយ។ ចំនួននៃសម្រាប់(គូ)ក្រូម៉ូសូមដែលផ្សំឡើងពីចំនួននេះ ត្រូវបានគេកំណត់ច្បាស់ ដូចជាប្រភេទស្រល់ ចំនួនក្រូម៉ូសូមអាចមាន n=12 ឬ 2n=24 ដែលអាស្រ័យ ទៅតាម កោសិកាភេទ ឬកោសិកាលូតលាស់ឌីផ្លូអ៊ីត ធម្មតា។)
- chromosome set /ˈkrəʊməsəʊm sɛt/ [n] ឈុតនៃក្រូម៉ូសូម (ក្រុមនៃក្រូម៉ូសូមទាំងឡាយ ដែលផ្ទុកព័ត៌មានផ្នែកពន្ធុនៃឯកត្តៈនីមួយៗ)
- daughter chromosomes /ˈdɔːtə ˈkrəʊməsəʊmz/ [n pl] ក្រូម៉ូសូមកូន

**chronic** /ˈkrɒnɪk/ [adj] រ៉ាំរ៉ៃ, មិនចេះជា, ត្រាំងត្រែង

**chronosequence** /ˈkrɒnəʊˈsiːkw(ə)ns/ [n] លំដាប់ដែលរៀងតាមកាលវេលា, លំដាប់ក្រូណូ (ការសិក្សាតំបន់ណាមួយតាមពេលខុសគ្នា)

**chrys-** /ˈkrɪs/ [prefix] (ដូច៖ chryso-) បុព្វបទមានន័យថា ពណ៌មាស

**chrysalis** /ˈkrɪs(ə)lɪs/ [n] គ្រីសាលីស (ដុកដឿរបស់សត្វល្អិត ដែលកូនញាស់ ធ្វើកំណែរូបទៅជាសត្វល្អិតពេញវ័យក្នុងនោះ។ វាមានតែចំពោះសត្វល្អិតទាំងឡាយណាដែលមានបម្រែបម្រួលរូបពេញលេញ), ការប្តូរពីដង្កូវទៅជាសត្វល្អិតពេញវ័យ

***Chrysanthemum coronarium*** [sci.n] សូមមើលពាក្យ៖ garland chrysanthemum

**chryso-** /ˈkrɪsəʊ/ [prefix] (ដូច៖ chrys-) បុព្វបទមានន័យថា ពណ៌មាស

***Chrysogonum peruvianum*** [sci.n] សូមមើលពាក្យ៖ zinnia

***Chrysophyllum cainito*** [sci.n] សូមមើលពាក្យ៖ milk fruit

**Chrysophyta** /ˈkrɪsəfaɪtə/ [n] គ្រីសូហ្វីតា (សាខាមួយរបស់សារាយទឹកសាប និងសារាយទឹកប្រៃរួមមានសារាយពណ៌មាស សារាយពណ៌បៃតងលឿង និងដ្យាតូម)

***Chrysopogon aciculatus*** [sci.n] ស្មៅកន្ត្រើយ

**chunk** /tʃʌŋk/ [n] ដុំថ្មឡាតេរីត

**chyle** /kʌɪl/ [n] ស៊ីល, ឈីល (ទម្រង់របស់អាហារ ក្រោយពីបានឆ្លងកាត់ ពោះវៀនតូចថនិកសត្វ ហើយបង្កើតបានជាល្បាយរាវមានលក្ខណៈជាអាល់កាឡាំង)

**cicada** /sɪˈkɑːdə/ [n] សត្វរៃ

**cicatrix** /ˈsɪkətrɪks/ [n] សូមមើលពាក្យ៖ scar

**cilium** /ˈsɪlɪəm/ [n] (ពហុវចនៈ៖ cilia) រោមញ័រ, រោម

**cinnamon** /ˈsɪnəmən/ [n] ស៊ីណាម៉ុន (រុក្ខជាតិសម្រាប់ធ្វើជាគ្រឿងទេសដុះនៅប្រទេសឥណ្ឌា)

**sexual circle** /ˈsɛkʃʊəl ˈsəːk(ə)l/ [n] វដ្តបន្តពូជ

**circulate** /ˈsəːkjʊleɪt/ [v] រត់, សាយភាយ (ឈាម, ទឹករងៃ)

**circulation** /səːkjʊˈleɪʃ(ə)n/ [n]

១. (ចំពោះជីវវិទ្យា) របត់ឈាម, បម្លាស់ទីចរន្តឈាមក្នុងរាងកាយ

២. (ចំពោះបរិស្ថាន) ដំណើរ, វដ្ត, ចរាចរ

- general atmospheric circulation /ˈdʒɛn(ə)r(ə)l atməsˈfɛrɪk səːkjʊˈleɪʃ(ə)n/ [n] ដំណើរបរិយាកាសទូទៅ
- monsoonal circulation /mɒnˈsuːn(ə)l səːkjʊˈleɪʃ(ə)n/ [n] ដំណើរខ្យល់មូសុង
- win circulation /wɪn səːkjʊˈleɪʃ(ə)n/ [n] ដំណើរខ្យល់

**circulatory** /ˈsəːkjʊlət(ə)ri/ [n] នៃការរត់ ឬសាយភាយឈាម

**circumcise** /ˈsəːkəmsʌɪz/ [v] កាត់ចុងស្បែកអង្គជាតចេញ,កាត់ស្បែកលិង្គចោល

**circumcision** /səːkəmˈsɪʒ(ə)n/ [n] ការកាត់ចុងអង្គជាត,ការកាត់ស្បែកលិង្គ

**circumnutation** /ˈsəːkəmnjuːˈteɪʃ(ə)n/ [n] ការដុះរុំព័ទ្ធជុំវិញ

**cirque** /səːk/ [n] ទំនាបជារង្វង់មូល

***Cirrhinus jullieni*** [sci.n] ត្រីផ្កាចា

***Cirrhinus microlepis*** [sci.n] ត្រីក្រឡង់ (តូច), ត្រីព្រួល (ធំ)

***Cirrhinus molitorella*** [sci.n] សូមមើលពាក្យ៖ mud carp

***Cirrhinus mrigala*** [sci.n] ត្រីក្រឡង់

***Cirrhinus prosemion*** [sci.n] ត្រីផ្កាគ

***Cirrhinus spilopleura*** [sci.n] ត្រីផ្កាគ

**cirrhosis** /sɪˈrəʊsɪs/ [n] ស៊ីរ៉ូស, រោគថ្លើម

**cirrus** /ˈsɪrəs/ [n] ពពកស្បៃ

**cistern** /ˈsɪstən/ [n] ថ្នក់ទឹក

**citizen** /ˈsɪtɪz(ə)n/ [n] ពលរដ្ឋ, ជនស៊ីវិល, អ្នកក្រុង

***Citrullus vulgaris*** [sci.n] សូមមើលពាក្យ៖ watermelon

***Citrus aurantifolia*** [sci.n] សូមមើលពាក្យ៖ lime

***Citrus hystrix*** [sci.n] សូមមើលពាក្យ៖ kaffir lime

***Citrus maxima*** [sci.n] សូមមើលពាក្យ៖ grapefruit

***Citrus sinensis*** [sci.n] សូមមើលពាក្យ៖ orange

***Citrus tangerina*** [sci.n] សូមមើលពាក្យ៖ tangerine

**civic** /ˈsɪvɪk/ [adj] នៃពលរដ្ឋ

**clad-** /klad/ [prefix] (ដូចៈ clado-) បុព្វបទមានន័យថា ខ្នែង ព្រុយ មែក

**clado-** /ˈkleɪdəʊ/ [prefix] (ដូចៈ clad-) បុព្វបទមានន័យថា ខ្នែង ព្រុយ មែក

**cladode** /ˈkleɪdəʊd/ [n] មែកសំប៉ែតដូចស្លឹក, ខ្លែដូដ (មែករាងសំប៉ែតមានពណ៌បៃតង និងមុខងារដូចស្លឹក)

**cladogenesis** /ˌkleɪdə(ʊ)ˈdʒɛnɪsɪs/ [n] ការបែកមែករបស់រុក្ខាប្រវត្តិពូជអម្បូរ

**cladophyll** /ˈkleɪdəʊdfil/ [n] (សទិសន័យៈ Cladodes) ខ្លែដូហ្វីល, ក្លាដូហ្វីល (មែក ឬដើមដែលដូចគ្នាទៅនឹងស្លឹក ឬស្លឹកដែលក្លាយដូចជាស្រកា ដូចជាពួក casuarinas។ ជារឿយៗ ខ្លែដូដមានទំហំនិងរូបរាងដូចជាគ្រាប់ដែលជួនកាលពិបាកនឹងរំផងវាចេញដោយប្រើវិធីធម្មតាក្នុងការសំអាតគ្រាប់។ ដើម ឬមែកដែលក្លាយ ដើរតួនាទីជាស្លឹក។ ឧ. កើតមានឡើងចំពោះ ប្រភេទCasuarinas។

**clamp** /klamp/ [n] អង្គំ, ប្រដាប់កៀបសរសៃឈាម (កុំឱ្យឈាមហូរ)

***Clarias batrachus*** [sci.n] សូមមើលពាក្យៈ walking catfish

***Clarias gariepinus*** [sci.n] ត្រីអណ្ដែងអាព្រិច

***Clarias macrocephalus*** [sci.n] សូមមើលពាក្យៈ broadhead catfish

***Clarias meladerma*** [sci.n] សូមមើលពាក្យៈ blackskin catfish

***Clarias nieuhofi*** [sci.n] ត្រីអណ្ដែងងាំង

**clarification** /ˌklarɪfɪˈkeɪʃ(ə)n/ [n] តម្លា

**clarifier** /ˈklarɪfʌɪə/ [n] ឧបករណ៍ធ្វើឱ្យថ្លា

- activated sludge clarifier /ˈaktɪveɪtɪd ˈklarɪfʌɪə/ [n] ឧបករណ៍ធ្វើឱ្យថ្លាដោយប្រើភក់សកម្ម
- centrifugal clarifier /ˌsɛntrɪˈfjuːg(ə)l ˈklarɪfʌɪə/ [n] ឧបករណ៍ធ្វើឱ្យថ្លាដោយប្រើកម្លាំងចាកផ្ចិត
- oil clarifier /ɔɪl ˈklarɪfʌɪə/ [n] ឧបករណ៍សម្អាតប្រេង
- ultrasonic clarifier /ʌltrəˈsɒnɪk ˈklarɪfʌɪə/ [n] ឧបករណ៍ធ្វើឱ្យថ្លាដោយប្រើសូរអ៊ុលត្រា

**clarify** /ˈklarɪfʌɪ/ [v] ធ្វើឱ្យថ្លា

- water clarity /ˈwɔːtə ˈklarɪti/ [n] ភាពថ្លារបស់ទឹក

**clarity** /ˈklarɪti/ [n] ភាពថ្លា

**class** /klɑːs/ [n] ថ្នាក់ (ចំណាត់ថ្នាកមួយនៃជីវករតាមវគ្គីករណ៍វិទ្យាដែលទាបជាងសាខា តែខ្ពស់ជាងក្រុម)

- accuracy class /ˈakjʊrəsi klɑːs/ [n] ថ្នាក់ភាពជាក់លាក់
- soil class /sɔɪl klɑːs/ [n] ថ្នាក់ ឬក្រុមដី

**classification** /ˌklasɪfɪˈkeɪʃ(ə)n/ [n] ចំណែកថ្នាក់, ការបែងចែក

- artificial classification /ɑːtɪˈfɪʃ(ə)l ˌklasɪfɪˈkeɪʃ(ə)n/ [n] ចំណាត់ថ្នាក់និម្មិត
- monothetic classification /ˈmɒnəʊˈθɛtɪk ˌklasɪfɪˈkeɪʃ(ə)n/ [n] ចំណាត់ថ្នាក់លក្ខណៈសម្គាល់តែមួយ
- polythetic classification /ˌpɒlɪˈθɛtɪk ˌklasɪfɪˈkeɪʃ(ə)n/ [n] ចំណែកថ្នាក់លក្ខណៈសម្គាល់ច្រើន
- soil classification /sɔɪl ˌklasɪfɪˈkeɪʃ(ə)n/ [n] ការចាត់ថ្នាក់ដី
- wood classification /wʊd ˌklasɪfɪˈkeɪʃ(ə)n/ [n] ប្រព័ន្ធចំណាត់ថ្នាក់ប្រភេទឈើយោងតាមលក្ខណៈវិនិច្ឆ័យ

**classify** /ˈklasɪfʌɪ/ [v] ចែកថ្នាក់, បែងចែក

**clavate** /ˈkleɪveɪt/ [adj] រាងដំបង, មានចុងធំជាងគល់

**clavicle** /ˈklavɪk(ə)l/ [n] ឆ្អឹងដងកាំបិត

**claw** /klɔː/ [n] (សទិសន័យៈ talon) ក្រញ៉ាំ (សត្វ), ដង្កៀប

**clay** /kleɪ/ [n] ដីឥដ្ឋ, ឥដ្ឋ (ភាគល្អិតនៃដីដែលមានវិមាត្រតូចជាង 0.00២ មម)

- activated clay /ˈaktɪveɪtɪd kleɪ/ [n] ដីឥដ្ឋសកម្ម
- alluvial clay /əˈl(j)uːvɪəl kleɪ/ [n] ដីឥដ្ឋល្បាប់
- apyrous clay /kleɪ/ [n] ដីឥដ្ឋធន់ភ្លើង
- bedded clay /ˈbɛdɪd kleɪ/ [n] ដីឥដ្ឋដែលមានសណ្ឋានជាស្រទាប់ៗ
- bottom clay /ˈbɒtəm kleɪ/ [n] ល្បាប់ល្បាយនៅក្នុងជ្រលង
- boulder clay /ˈbəʊldə kleɪ/ [n] ដីឥដ្ឋជាដុំធំៗ
- calcareous clay /kalˈkɛːrɪəs kleɪ/ [n] ឥដ្ឋដែលមានកាល់ស្យូម ឬកំបោរច្រើន
- China-clay /ˈtʃʌɪnə-kleɪ/ [n] ដីប្រភេទកាអូឡាំង, ប៉័សឺឡែន

- clay leaching /kleɪ liːtʃɪŋ/ [n] សូមមើលពាក្យ៖ clay degradation
- clay loamy earth /kleɪˈ ləʊmi əːθ/ [n] ដីភក់ឥដ្ឋ
- clay swelling /kleɪ ˈswɛlɪŋ/ [n] ការហើមនៃដីឥដ្ឋ
- clay warp /kleɪ wɔːp/ [n] ដីឥដ្ឋនៅតាមមាត់ស្ទឹង ឬអូរ
- clay with flints /kleɪ wɪð flɪnts/ [n] ថ្មស៊ីលិកដែលបែកជាដុំតូចៗ ដែលជាសំណល់នៃការរលាយថ្មកំបោរ, ដីឥដ្ឋដែលមានដុំថ្មស៊ីលីសច្រើន (ថ្មមូលៗ)
- coarse clay /kɔːs kleɪ/ [n] គ្រាប់ ឬភាគល្អិតដី កូឡូអ៊ីដឥដ្ឋ ពី ០.៥-២មីក្រុង, គ្រាប់ឥដ្ឋធំ
- colloid clay /ˈkɒlɔɪd kleɪ/ [n] ឥដ្ឋដែលមានលក្ខណៈជាកូឡូអ៊ីត
- colloidal clay /kəˈlɔɪd(ə)l kleɪ/ [n] ភាគល្អិតដី តូចជាង ០.២ មីក្រុង, ភាគល្អិតដី កូឡូអ៊ីតឥដ្ឋ
- colored clay /ˈkʌləd kleɪ/ [n] ឥដ្ឋពណ៌
- decalcification clay /diːkalsɪfɪˈkeɪʃ(ə)n kleɪ/ [n] ឥដ្ឋក្រហមលើខ្ពង់រាប (ឥដ្ឋដែលចេញពីការរលាយនៃថ្មកំបោរ)
- fine clay /fʌɪn kleɪ/ [n] ភាគល្អិតដីតូចជាង ១ មីក្រុង, គ្រាប់ឥដ្ឋឆ្មារ
- gleyed clay /gleɪd kleɪ/ [n] ឥដ្ឋប្រេះខៀវ
- heavy clay /ˈhɛvi kleɪ/ [n] ដីឥដ្ឋធ្ងន់ (ដែលមានគ្រាប់តូចជាង ១០មីក្រុង លើស ៨០%)
- iron clay /ˈʌɪən kleɪ/ [n] ឥដ្ឋដែលមានដែកច្រើន
- kaolin clay /ˈkeɪəlɪn kleɪ/ [n] ប៉័សឺឡែន
- lateritic clay /latəˈrɪtɪk kleɪ/ [n] ឥដ្ឋដែលមានឡាតេរីតច្រើន
- light clay /lʌɪt kleɪ/ [n] ដីឥដ្ឋស្រាល (ដីដែលមានឥដ្ឋតិចជាង ២៥% ល្បាយតិចជាង ៤០%)
- loam clay /ləʊm kleɪ/ [n] (សទិសន័យ៖ loam, plastic clay, pottery clay) ដីឥដ្ឋ (សម្រាប់ធ្វើឆ្នាំង ឬពាងជាដើម)
- marl clay /mɑːl kleɪ/ [n] ឥដ្ឋដែលមានកំបោរច្រើន
- medium clay /ˈmiːdɪəm sɔɪl/ [n] សូមមើលពាក្យ៖ silty clay
- mottled clay /ˈmɒt(ə)ld kleɪ/ [n] ដីឥដ្ឋដែលមានស្នាមច្រើន (ក្រហមប្រេះ ខៀវ ខ្មៅ)
- physical clay /ˈfɪzɪk(ə)l kleɪ/ [n] ឥដ្ឋរូបវន្ត (គ្រាប់ដែលមានទំហំ ០.១-១០ មីក្រុង)
- plastic clay /ˈplastɪk kleɪ/ [n] សូមមើលពាក្យ៖ loam clay
- porcelain clay /ˈpɔːs(ə)lɪn kleɪ/ [n] ប៉័សឺឡែន
- pottery clay /ˈpɒt(ə)ri kleɪ/ [n] សូមមើលពាក្យ៖ loam clay
- pre-colloidal clay /ˈpriːkəˈlɔɪd(ə)l kleɪ/ [n] ដីឥដ្ឋទំហំ ០.២-២ មីក្រុង
- raw clay /rɔː kleɪ/ [n] គ្រាប់ឥដ្ឋ (ទំហំ ០.២ ទៅ ២ មីក្រុង)
- red clay /rɛd kleɪ/ [n] ឥដ្ឋក្រហម
- refractory clay /rɪˈfrakt(ə)ri kleɪ/ [n] ដីឥដ្ឋធន់ភ្លើង
- sand mantled clay /sand ˈmant(ə)ld kleɪ/ [n] ដីឥដ្ឋដែលមានស្រទាប់ខ្សាច់គ្របពីលើ
- sandy clay /ˈsandi kleɪ sɔɪl/ [n] ដីឥដ្ឋដែលមានអត្រាឥដ្ឋមធ្យម (២៥-៤៥%) , ដីឥដ្ឋខ្សាច់
- silty clay /ˈsɪlti kleɪ/ [n] សូមមើលពាក្យ៖ clay loam
- tile clay /tʌɪl kleɪ/ [n] ឥដ្ឋសម្រាប់ធ្វើក្បឿង
- tropical black clay /ˈtrɒpɪk(ə)l blak kleɪ/ [n] ដីឥដ្ឋខ្មៅតំបន់ត្រូពិច
- warp clay /wɔːp kleɪ/ [n] ឥដ្ឋដែលធ្វើឱ្យស្ទះចុករន្ធ
- white clay /wʌɪt kleɪ/ [n] ដីឥដ្ឋស
- clayey /ˈkleɪi/ [adj] ដែលជាដីឥដ្ឋ (យ៉ាងតិចណាស់ឥដ្ឋ ១៥%)
- clayiness /kleɪ ɪnəs/ [n] អត្រាឥដ្ឋ
- claypan /ˈkleɪpan/ [n] ស្រទាប់ដីឥដ្ឋហាប់
- clay-pit /kleɪ pɪt/ [n] អណ្តូង ឬកន្លែងយកដីឥដ្ឋ
- clay-siliceous /kleɪ sɪˈlɪʃəs/ [adj] ដីដែលគ្មានកំបោរ

**clean** /kliːn/ [adj] ស្អាត, បរិសុទ្ធ

**clean** /kliːn/ [v] សម្អាត

**cleaner** /ˈkliːnə/ [n] ឧបករណ៍សម្អាត, អ្នកសម្អាត, សារធាតុសម្រាប់សម្អាត, តម្រង

- air cleaner /ɛː ˈkliːnə/ [n] ឧបករណ៍សម្អាតខ្យល់, តម្រងខ្យល់ (ផ្នែកមួយនៃចលករចំហេះក្នុងសម្រាប់សម្អាតខ្យល់)

- alkaline cleaner /ˈalkəlʌɪn ˈkliːnə/ [n] សូលុយស្យុងអាល់កាឡាំង (បាស) សម្រាប់សម្អាត
- centrifugal gas cleaner /ˌsɛntrɪˈfjuːg(ə)l gas ˈkliːnə/ [n] ឧបករណ៍សម្អាតឧស្ម័ន ដោយប្រើកម្លាំងចាកផ្ចិត
- cloth cleaner /klɒθ ˈkliːnə/ [n] តម្រងកំណាត់
- cooling system cleaner /kuːlɪŋ ˈsɪstəm ˈkliːnə/ [n] ឧបករណ៍សម្អាតដោយប្រើប្រព័ន្ធត្រជាក់
- cottrell gas cleaner /ˈkliːnə/ [n] តម្រងអគ្គិសនីកូត្រេល (ឧបករណ៍សម្អាតភាគល្អិតអណ្តែតរឹងចេញពីឧស្ម័ន)
- dry electrostatic cleaner /drʌɪ ɪˌlɛktrə(ʊ)ˈstatɪk ˈkliːnə/ [n] តម្រងអគ្គិសនីស្តាទិចស្ងួត
- dry gas cleaner /drʌɪ gas ˈkliːnə/ [n] ឧបករណ៍សម្អាតឧស្ម័នស្ងួត
- electric gas cleaner /ɪˈlɛktrɪk gas ˈkliːnə/ [n] ឧបករណ៍សម្អាតឧស្ម័នដោយប្រើអគ្គិសនី
- electrostatic cleaner /ɪˌlɛktrə(ʊ)ˈstatɪk ˈkliːnə/ [n] តម្រងអគ្គិសនីស្តាទិច
- fume cleaner /fjuːm ˈkliːnə/ [n] ឧបករណ៍សម្អាតផ្សែង
- gas cleaner /gas ˈkliːnə/ [n] ឧបករណ៍សម្អាតឧស្ម័ន
- grain cleaner /greɪnˈkliːnə/ [n] ម៉ាស៊ីនសម្អាតគ្រាប់ធុញ្ញជាតិ
- groundnut cleaner /ˈgraʊn(d)nʌt ˈkliːnə/ [n] ម៉ាស៊ីនបកសណ្តែកដី (ម៉ាស៊ីនបក និងសម្អាតគ្រាប់សណ្តែកដី)
- polished rice cleaner /ˈpɒlɪʃt rʌɪs ˈkliːnə/ [n] ម៉ាស៊ីនស្រិតអង្ករ
- primary air cleaner /ˈprʌɪm(ə)ri ɛː ˈkliːnə/ [n] ឧបករណ៍សម្អាតខ្យល់ដំណាក់កាលដំបូង
- secondary air cleaner /ˈsɛk(ə)nd(ə)ri ɛː ˈkliːnə/ [n] ឧបករណ៍សម្អាតខ្យល់ដំណាក់កាលទីពីរ
- steam cleaner /stiːm ˈkliːnə/ [n] ឧបករណ៍សម្អាតចំហាយ
- ultrasonic cleaner /ʌltrəˈsɒnɪk ˈkliːnə/ [n] ឧបករណ៍សម្អាតដោយសូរអ៊ុលត្រា

**cleanness** /ˈkliːnnəs/ [n] ភាពស្អាត

**clear** /klɪə/ [adj] ថ្លា, សុទ្ធ, ច្បាស់

**clear** /klɪə/ [v] ធ្វើឱ្យថ្លា, ទៅជាថ្លា, បន្សុទ្ធ

- clear cut /klɪə kʌt/ [n] (សទិសន័យ៖ clear felling) ការកាប់ផ្តួលទាំងស្រុង, ការកាប់សម្អាត (វិធីសាស្ត្រគ្រប់គ្រង ព្រៃឈើ ដែលទាក់ទងនឹងការកាប់ដើមឈើឈរទាំងអស់។ ការកាត់សម្អាត អាចត្រូវបានធ្វើជាប្លុក ជួរ ឬ ដុំៗ)
- clear felling /klɪə fɛlɪŋ/ [n] សូមមើលពាក្យ៖ clear cut
- clear-cutting /klɪə kʌtɪŋ/ [n] ការកាប់សម្អាត គឺជាការកាប់ដើមឈើ ដែលមានទាំងអស់ចេញពី តំបន់ (ការកាប់សម្អាតត្រូវបានប្រើប្រាស់ ដើម្បីជំនួយដល់ប្រភេទរុក្ខជាតិ ដែលទាមទារពន្លឺខ្លាំងក្នុងការដុះលូតលាស់ឱ្យបានល្អ)

**clearance slip** /ˈklɪər(ə)ns slɪp/ [n] បញ្ជីទូទាត់ (បញ្ជីទូទាត់នូវរាល់របស់ដែលយើងបានខ្ចី)

**clearing** /ˈklɪərɪŋ/ [n]
១. ដីកាប់ឆ្ការរួច
២. សូមមើលពាក្យ៖ deforestation

**cleavage** /ˈkliːvɪdʒ/ [n]
បំបែកអ្វីមួយ, ការចែក ឬការញែក (សកម្មភាពចែក ឬញែក)

**cleft palate** /klɛft ˈpalət/ [n] ពិតានមាត់, ក្រអូមមាត់

**cleistogamy** /klʌɪˈstɒgəmi/ [n] ការបង្កកំណើតមុនផ្ការីក (ការបង្កើតផ្ការតូចៗ ដែលមានការបង្កកំណើតឯងនៅក្នុងខាងក្នុងនោះ គឺតាំងពីមុនផ្ការីកម្ល៉េះ។)

**cleistogamy** /klʌɪˈstɒgəmi/ [n] ការបង្កកំណើតមុនផ្ការីក

***Cleome gynandra*** [sci.n] សូមមើលពាក្យ៖ African spider flower

***Cleome rutidosperma*** [sci.n] សូមមើលពាក្យ៖ fringed spider flower

***Cleome viscosa*** [sci.n] សូមមើលពាក្យ៖ Asian spider flower

**cleptoparasitism** /ˌklɛptə(ʊ)ˈparəsʌɪtɪz(ə)m/ [n] ក្លឹមតូបរាសិត (ទម្លាប់នៃការលួចអាហារពីសត្វដទៃ)

***Cletus bipunctatus*** [sci.n] ស្រឹងសណ្តែកបន្លា

**cliff** /klɪf/ [n] ឆ្នេរ ឬច្រាំងចោតនៃសមុទ្រ

**climate** /ˈklʌɪmət/ [n] អាកាសធាតុ (លក្ខខណ្ឌនៃតំបន់ដែលមានទំនាក់ទំនងទៅលើបាតុភូតជាច្រើនដូចជាសីតុណ្ហភាព ខ្យល់ ទឹកភ្លៀងជាដើម ដែលមានឥទ្ធិពលទៅលើការដុះលូតលាស់ដំណាំ)

- climate change /ˈklʌɪmət tʃeɪn(d)ʒ/ [n] បម្រែបម្រួលអាកាសធាតុ
- climate change mainstreaming /ˈklʌɪmət tʃeɪn(d)ʒ ˈmeɪnstriːmɪŋ/ [n] ការបញ្ជ្រាបការប្រែប្រួលអាកាសធាតុ
- arid climate /ˈarɪd ˈklʌɪmət/ [n] អាកាសធាតុស្ងួតហែង
- artificial climate /ɑːtɪˈfɪʃ(ə)l ˈklʌɪmət/ [n] អាកាសធាតុសិប្បនិម្មិត
- coastal climate /ˈkəʊstl ˈklʌɪmət/ [n] អាកាសធាតុឆ្នេរ
- cold climate /kəʊld ˈklʌɪmət/ [n] អាកាសធាតុត្រជាក់
- continental climate /kɒntɪˈnɛnt(ə)l ˈklʌɪmət/ [n] អាកាសធាតុទ្វីប
- desert climate /dɪˈzəːt ˈklʌɪmət/ [n] អាកាសធាតុវាលលំហ
- equatorial climate /ˌɛkwəˈtɔːrɪəl ˈklʌɪmət/ [n] អាកាសធាតុអេក្វាទ័រ
- global climate /ˈgləʊb(ə)l ˈklʌɪmət/ [n] អាកាសធាតុពិភពលោក
- humid climate /ˈhjuːmɪd ˈklʌɪmət/ [n] អាកាសធាតុសើម
- indoor climate /ˈɪndɔː ˈklʌɪmət/ [n] អាកាសធាតុក្នុងអាគារ
- local climate /ˈləʊk(ə)l ˈklʌɪmət/ [n] អាកាសធាតុប្រចាំទី
- marine climate /məˈriːn ˈklʌɪmət/ [n] (សទិសន័យ៖ maritime climate) អាកាសធាតុសមុទ្រ
- maritime climate /ˈmarɪtʌɪm ˈklʌɪmət/ [n] សូមមើលពាក្យ៖ marine climate
- monsoon climate /mɒnˈsuːn ˈklʌɪmət/ [n] អាកាសធាតុមូសុង
- mountain climate /ˈmaʊntɪn ˈklʌɪmət/ [n] អាកាសធាតុភ្នំ
- oceanic climate /ˌəʊsɪˈanɪk ˈklʌɪmət/ [n] អាកាសធាតុសមុទ្រ
- regional climate /ˈriːdʒənl ˈklʌɪmət/ [n] អាកាសធាតុភូមិភាគ
- steppe climate /stɛp ˈklʌɪmət/ [n] អាកាសធាតុស្តិប
- subtropical climate /sʌbˈtrɒpɪk(ə)l ˈklʌɪmət/ [n] អាកាសធាតុក្បែរត្រូពិច
- subtropical desert climate /sʌbˈtrɒpɪk(ə)l dɪˈzəːt ˈklʌɪmət/ [n] អាកាសធាតុវាលលំហក្បែរត្រូពិច
- summer dry climate /ˈsʌmə drʌɪ ˈklʌɪmət/ [n] អាកាសធាតុស្ងួតនៅរដូវក្តៅ
- temperate climate /ˈtɛmp(ə)rət ˈklʌɪmət/ [n] អាកាសធាតុបង្គួរ
- tropical climate /ˈtrɒpɪk(ə)l ˈklʌɪmət/ [n] អាកាសធាតុត្រូពិច
- tropical-rain-forest climate /ˈtrɒpɪk(ə)l reɪn ˈfɒrɪst ˈklʌɪmət/ [n] អាកាសធាតុព្រៃរងទឹកភ្លៀងត្រូពិច
- tropical-savanna climate /ˈtrɒpɪk(ə)l səˈvanə ˈklʌɪmət/ [n] អាកាសធាតុវាលស្មៅងត្រូពិច
- tundra climate /ˈtʌndrə ˈklʌɪmət/ [n] អាកាសធាតុទុនដ្រា
- warm climate /wɔːm ˈklʌɪmət/ [n] អាកាសធាតុក្តៅ

**climatogenic** /ˈklʌɪmətɒˈdʒɛnɪk/ [adj] ដែលពាក់ព័ន្ធនឹងធាតុអាកាស

**climatology** /klʌɪməˈtɒlədʒi/ [n] អាកាសធាតុវិទ្យា

**agricultural climatology** /agrɪˈkʌltʃərəl klʌɪməˈtɒlədʒi/ [n] (សទិសន័យ៖ agricultural climatology) អាកាសធាតុវិទ្យាកសិកម្ម

**climax** /ˈklʌɪmaks/ [n] គ្លីម៉ាក់

**climber** /ˈklʌɪmə/ [n] វល្លិ

**climbing perch** /ˈklʌɪmɪŋ pəːtʃ/ [n] ត្រីក្រាញ់ស្រែ (ឈ្មោះវិទ្យាសាស្ត្រ *Anabas testudineus*)

**climosequence** /ˈklɪməʊ ˈsiːkw(ə)ns/ [n] ដំណើរតគ្នា ឬឈុតបន្តបន្ទាប់គ្នានៃធាតុអាកាស

**cline** /klʌɪn/ [n] ភាពល្មៀង ឬប្រែប្រួលនៃសេណូទីប (ភាពល្មៀងតាមភូមិសាស្ត្ររបស់ផេណូទីប ឬសេណូទីបនៅក្នុងលំដាប់របស់ប្រភេទ(ពូជ)មួយ)

**clinic** /ˈklɪnɪk/ [n] មន្ទីរពិនិត្យ ឬព្យាបាលរោគ

**clip** /klɪp/ [n] ដង្កៀប, ប្រដាប់ខ្ទាស់, ដំបៀត

**clitellum** /klɪˈteləm/ [n] ចង្កំ (តំបន់លើខ្លួនជន្លេន ដែលបញ្ចេញកន្សោមស្លេស្មនៅពេលបន្តពូជ)

***Clitoria ternatea*** [sci.n] សូមមើលពាក្យ៖ Asian pigeonwing

**clitoris** /ˈklɪt(ə)rɪs/ [n] សិរ, ផ្តេញ (យោនី)

**cloaca** /kləʊˈeɪkə/ [n] ក្លូអាក់ (រន្ធគូទ)

**clod** /klɒd/ [n] ដុំដី (ដុំដី ឬបណ្តុំដី ដែលជាធម្មតាគេអាចឃើញវាច្បាស់នៅឯក្នុងដីសាច់ម៉ដ្ឋ ប៉ុន្តែចំពោះដីខ្សាច់គេកម្រឃើញទម្រង់ដូចនេះណាស់)

**cloddy** /klɒdi/ [n] ដែលជាដុំៗ ធំជាង ១០ សម

**clonal archive** /ˈkləʊn(ə)l ˈɑːkʌɪv/ [n] ធនាគារកូនឈើក្លូន

**clone** /kləʊn/ [n] ក្រុមពូជមួយដែលកោសិកាឬឯកត្តៈរបស់វាមានលក្ខណៈសេនេទិចដូចគ្នា/តែមួយ។ ក្រុមពូជនេះ គឺបានមកពី ការបំបែកដោយម៉ៃតូស៊ីស ឬដោយការបន្តពូជឥតភេទ។ ឧ. កូនឈើបំបៅ, កូនឈើផ្សាំ

**cloning** /kloʊnɪŋ/ [n] ការធ្វើក្លូន, ក្លូនកម្ម

- gene cloning /dʒiːn kləʊnɪŋ/ [n] ការធ្វើក្លូនសែន, ការធ្វើក្លូនពន្ធុ
- therapeutic cloning [n] ការព្យាបាលដោយក្លូន (ជាការប្រើប្រាស់ដ៏មានសក្តានុពលភាពរបស់កោសិកាដើមដើម្បីធ្វើការលូតលាស់ (ក្នុងការពិសោធក្រៅសារពាង្គកាយមានជីវិត) ជាលិកា ឬសរីរាង្គសម្រាប់ការប្រើប្រាស់ក្នុងការដាំសរីរាង្គ។ ដោយសារ កោសិកាទាំងនេះអាចត្រូវបានគេទទួលបាន និងដោយមានលក្ខណៈសេនេទិចដូចគ្នា និងកោសិកាអ្នកជំងឺ បញ្ហាបដិសេធរបស់ការដាំសរីរាង្គអាចត្រូវបានគេជំនះ។ បច្ចេកទេសអាចដកចេញនូវការលំបាកក្នុងការធ្វើអត្តសញ្ញាណរបស់សរីរាង្គដែលផ្តល់ឱ្យ)

**clonus** /ˈkləʊnəs/ [n] ក្លូនុស

**closed** /kləʊzd/ [adj] ចុកជិត, ណែន

**Clostridium** /klɒˈstrɪdɪəm/ [n] ក្លូទ្រីដ្យូម, សណ្ឋានបាក់តេរី

**clot** /klɒt/ [n] ខន់ (ឈាម ទឹកដោះ), កកឈាម

- silk cloth /sɪlk klɒθ/ [n] កំណាត់សូត្រ

**clotted** /klɒtid/ [adj] (សទិសន័យ៖ clotty, grumous) ដែលជាគ្រាប់ៗ

**clotty** /klɒti/ [adj] សូមមើលពាក្យ៖ clotted

**cloudy** /ˈklaʊdi/ [adj] ដែលមានពពក, ស្រទំ, ល្អក់, កករ

**cloven** /ˈkləʊv(ə)n/ [v] ចង្កែក (ជើង)

**clubroot** /ˈklʌbruːt/ [n] ជំងឺត្រម៉ងឫស (ជំងឺនេះបង្កដោយ *Plasmadiophora brassicae* ដែលភ្នាក់ងារបង្កជំងឺអាចរស់នៅជាបរាសិត ហើយស្ប៉ាវាអាចរស់នៅក្នុងដីបានរហូតបានដល់ ១០ ឆ្នាំ និងអាចរស់នៅក្នុងអំបូរស្ពៃក្រុស៊ីហ្វ៊ែរ)

**clump** /klʌmp/ [n] ការស្អិតជាប់

***Clupeichthys aesarnensis*** [sci.n] សូមមើលពាក្យ៖ Thai river sprat

***Clupeichthys goniognathus*** [sci.n] សូមមើលពាក្យ៖ Sumatran river sprat

***Clupeoides borneensis*** [sci.n] សូមមើលពាក្យ៖ Borneo river sprat

**cluster** /ˈklʌstə/ [n] គំនរ, ពំនូក (ថ្ម)

**clutch** /klʌtʃ/ [n] ស៊ុតរួមជំនាន់ (ស៊ុតបក្សីដែលមេពងមួយលើកៗ)

***Cnaphalocrocis medinalis*** [sci.n] សូមមើលពាក្យ៖ leaffolder

**cnido-** [prefix] បុព្វបទមានន័យថា រមាស់ ឆាល (ដោយការទិច)

***Cnidoglanis nudiceps*** [sci.n] ត្រីអណ្តែងទន្លេ

**co-** [prefix] (ដូច៖ con-, corn) បុព្វបទមានន័យថា ជាមួយ, ជាមួយគ្នា, សហ

**coacervate** /kəʊˈasəveɪt/ [n] កូអាស៊ែវ៉ា (បណ្តុំម៉ូលេគុលសរីរាង្គធំៗ ដែលព័ទ្ធជុំវិញដោយម៉ូលេគុលទឹកតម្រៀបគ្នាដើម្បីបង្កើតជាស្វ៊ែមួយ)

**coagulate** /kəʊˈagjʊleɪt/ [v] កក, ធ្វើឱ្យកក, បង្កកឈាម, ធ្វើឱ្យឈាមកក

**coagulation** /kəʊagjuˈleɪʃ(ə)n/ [n]

១. (ចំពោះជីវវិទ្យា) កំណក, ការកក (កករ)

២. (ចំពោះដី) ការកកនៃដីឥដ្ឋ

- acid coagulation /ˈasɪd kəʊagjuˈleɪʃ(ə)n/ [n] កំណកដោយអាស៊ីត
- electric coagulation /ɪˈlɛktrɪk kəʊagjuˈleɪʃ(ə)n/ [n] កំណកដោយអគ្គិសនី
- electrochemical coagulation /ɪˌlɛktrəʊˈkɛmɪk(ə)l kəʊagjuˈleɪʃ(ə)n/ [n] កំណកដោយអគ្គិសនីគីមី

- fractional coagulation /ˈfrakʃ(ə)n(ə)l kəʊagjuˈleɪʃ(ə)n/ [n] កំណកតាមប្រភាគ
- freeze coagulation /friːz kəʊagjuˈleɪʃ(ə)n/ [n] កំណកដោយបញ្ចុះសីតុណ្ហភាព

**coal** /kəʊl/ [n] ធ្យូង, ធ្យូងថ្ម

- anthracitic coal /ˈan θrəˌsaɪt/ [n] ធ្យូងអង់ត្រាស៊ីត
- black coal /blak kəʊl/ [n] ធ្យូងថ្ម
- standard coal /ˈstandəd kəʊl/ [n] ឥន្ធនៈគោល
- stone coal /stəʊn kəʊl/ [n] ធ្យូងអង់ត្រាស៊ីត
- wood coal /wʊd kəʊl/ [n] សូមមើលពាក្យ៖ wood charcoal

**coalesce** /ˌkəʊəˈlɛs/ [n] សហពលភាព (ការរាលដាល ឬរាលចូលគ្នានៃចំណុច ឬស្នាមរបួស)

**coalescent** /ˌkəʊəˈlɛsɛnt/ [adj] ជាប់គ្នាទម្រង់របស់រុក្ខជាតិ

**coarse blocky** /ˈvɛri kɔːs blɒki/ [adj] ជាដុំៗ (២-១០ ស.ម)

**coarse moder** /kɔːs mɒdə/ [n] មមោកអន្តរការគ្រើម, ម៉ូដែលគ្រើម

**coarse part** /kɔːs pɑːt/ [n] កម្ទេចគ្រើមៗ (ធំជាង ២ ម.ម)

**coarsely toothed** /kɔːsli tuːθt/ [adj] ជាជាយស្លឹកដែលមានរាងដូចធ្មេញ, ជាយស្លឹករាងដូចរណា

**coarseness** /ˈkɔːsnəs/ [n] សភាពគ្រើម

**coast** /kəʊst/ [n] ឆ្នេរ

**coastal moring glory** /ˈkəʊstl ˈmɔːnɪŋ ˈglɔːri/ [n] ដើមផ្កាកណ្ដឹងគោ (ឈ្មោះវិទ្យាសាស្ត្រ *Ipomoea cairica*)

**coat** /kəʊt/ [n] ស្រទាប់

- buffy coat /bʌfi kəʊt/ [n] ស្រទាប់គោលិកាស (ដែលខណ្ឌគោលិកាក្រហម និងសេរ៉ូម)

**coat buttons** /kəʊt ˈbʌt(ə)nz/ [n] ស្មៅស្លឹករណា (ឈ្មោះវិទ្យាសាស្ត្រ *Tridax procumbens*)

**coating** /ˈkəʊtɪŋ/ [n] ការស្រោប, វត្ថុខាប់ (ឧ.សម្រាប់ស្រោប ឬលាបពីក្រៅ)

**cobalamin** /kə(ʊ)ˈbaləmɪn/ [n] (សទិសន័យ៖ cyanocobalamin, vitamin B12) ខូបលឡាមីន, ស្យាណូខូបឡាមីន, វីតាមីនបេ ១២

**Cobalt** /ˈkəʊbɔːlt/ [n] កូបាល (និមិត្តសញ្ញាគីមី Co)

**cobaye** /kəʊbʌɪ/ [n] កូបាយ

**cobble** /ˈkɒb(ə)l/ [n] (សទិសន័យ៖ shingle, peeple) ក្រួស (៥-៣០ម.ម)

**cobblestone** /ˈkɒb(ə)lstəʊn/ [n] ថ្មមានជ្រុងមូលៗ

**cobra** /ˈkəʊbrə/ [n] ពស់វែក

**cobweb** /ˈkɒbwɛb/ [n] សម្បុកពីងពាង

**cocaine** /kə(ʊ)ˈkeɪn/ [n] កូកាអ៊ីន

**Coccaceae** [n] ពួកកុកស៊ី (ពពួកមេរោគរាងមូល)

**coccid** /ˈkäksid/ [n] ខកស៊ីត (សត្វល្អិតមានស្រកា)

**coccidiosis** /kɒkˌsɪdɪˈəʊsɪs/ [n] ជំងឺបរាសិតរបស់សត្វដែលបង្កឱ្យមានបញ្ហាដល់ពោះវៀន

**Coccidium (Coccidiosis)** [n] កុកស៊ីដ្យូម

***Coccinella transversalis*** [sci.n] អណ្ដើកមាសកុកស៊ីណែលលីត

***Coccinia grandis*** [sci.n] សូមមើលពាក្យ៖ ivy gourd

**coccoid** /ˈkɒkɔɪd/ [adj] រាងស្មើរស្វៃ

**coccus** /ˈkɒkəs/ [n] (ពហុវចនៈ៖cocci) បាក់តេរីរាងស្វៃ

**coccyx** /ˈkɒksɪks/ [n] ឆ្អឹងកញ្ចុញគូទ

**cochlea** /ˈkɒklɪə/ [n] បំពង់រាងគូទខ្យង, ត្រចៀកក្នុងរាងដូចគូទខ្យង, រន្ធត្រចៀក

**cockroach** /ˈkɒkrəʊtʃ/ [n] កន្លាត

**coconut** /ˈkəʊkənʌt/ [n] ដូង (ឈ្មោះវិទ្យាសាស្ត្រ *Cocos nucifera*)

- coconut cream /ˈkəʊkənʌt kriːm/ [n] ក្រែមខ្ទិះដូង
- coconut milk /ˈkəʊkənʌt mɪlk/ [n] ខ្ទិះដូង

**cocoon** /kəˈkuːn/ [n] សម្បុកនាង, សម្បុកដុកឌឿ (សម្បុកសូត្រដែលដង្កូវរុំការពារខ្លួនវាក្នុងដំណាក់កាលដុកឌឿ), កូនដុកឌឿ

***Cocos nucifera*** [sci.n] សូមមើលពាក្យ៖ coconut

**cod** /kɒd/ [n] ត្រីម័ររុយ

**coefficient** /ˌkəʊɪˈfɪʃ(ə)nt/ [n] មេគុណ

- hygroscopic coefficient /hʌɪgrə(ʊ)ˈskɒpɪk ˌkəʊɪˈfɪʃ(ə)nt/ [n] មេគុណសម្រូបយកសំណើមខ្យល់

**coel-** /siːˈl/ [prefix] បុព្វបទមានន័យថា ប្រហោង

**coelenterate** /siːˈlɛnt(ə)rət/ [n] សឺឡង់តេរ៉េ (សត្វឥតឆ្អឹងកងរស់នៅក្នុងទឹក ស្ថិតក្នុងសាខា Cnidaria និងសាខា Ctenophora)

**coenzyme** /ˈkəʊˌɛnzʌɪm/ [n] កូអង់ស៊ីម

**co-facilitator** /kə fəˈsɪlɪteɪtə/ [n] សហជនសម្រប សម្រួល (អ្នកសហការក្នុងការបង្រៀន ឬសម្រាប់សម្រប សម្រួលកម្មវិធីអ្វីមួយ)

***Coffea arabica*** [sci.n] សូមមើលពាក្យ៖ coffee

**coffee** /ˈkɒfi/ [n] កាហ្វេ (ឈ្មោះវិទ្យាសាស្ត្រ *Coffea arabica*)

**coffee senna** /ˈkɒfiˈseɪnə/ [n] សណ្តែកខ្មោច (ឈ្មោះ វិទ្យាសាស្ត្រ *Cassia occidentalis*)

**coffin** /ˈkɒfɪn/ [n] ក្រហូងបាតជើង

**coherent** /kə(ʊ)ˈhɪər(ə)nt/ [adj] ជាប់ៗគ្នានៅត្រង់ ចំណុចៗ, ជាប់ស្អិត, ដែលទាក់ទងគ្នាយ៉ាងសមហេតុ សមផល, រដឹកហូរហែ

**cohesion** /kə(ʊ)ˈhiːʒ(ə)n/ [n] កម្លាំងទំនាញរវាង ម៉ូលេគុល និងម៉ូលេគុល, កម្លាំងស្អិតជាប់, ការស្អិតជាប់, ភាពហាប់

- soil cohesion /sɔɪl kə(ʊ)ˈhiːʒ(ə)n/ [n] ភាពហាប់ របស់ដី, កំហាប់ដី

**cohort** /ˈkəʊhɔːt/ [n] ហ្វូង

***Coilia lindmani*** [sci.n] សូមមើលពាក្យ៖ Lindman's grenadier anchovy

***Coilia macrognathos*** [sci.n] សូមមើលពាក្យ៖ longjaw grenadier anchovy

**coitus** /ˈkəʊɪtəs/ [n] ពំនាក់គ្នា, ជាប់គ្នា, សំគារគ្នា

**cold** /kəʊld/ [n] គ្រុនរងា

**Coleoptera** /ˌkɒlɪˈɒpt(ə)rə/ [n] ពពួកកញ្ចែ, ពពួកស្លាប រឹង (សត្វល្អិត) ឧទា. អណ្តើកមាស

**coleoptile** /ˌkɒlɪˈɒptʌɪl/ [n] ស្រោមស្លឹកពន្លក, ស្រោម ពន្លកស្លឹក (ស្រោមរាងស៊ីឡាំងគ្របដណ្តប់ការពារពន្លកស្លឹក)

**coleorhiza** /ˌkɒlɪə(ʊ)ˈrʌɪzə/ [n] ស្រោមឫសពន្លក (ស្រោមការពារជុំវិញឫសអំប្រីយ៉ុងក្នុងគ្រាប់អាមីនេ), ស្រោមពន្លកឫស (ស្រទាប់ក្នាសដ៏ស្តើងដែលស្រោបការពារ ពន្លកឫស)

**coleus** /ˈkəʊlɪəs/ [n] ជីរស្លឹកក្រាស់ (ឈ្មោះវិទ្យាសាស្ត្រ *Coleus aromaticus*)

***Coleus aromaticus*** [sci.n] សូមមើលពាក្យ៖ coleus

**colibacillosis** [n] កូលីបាស៊ី (ជំងឺដែលបង្កដោយ *Escherichia coli* ឬ *E-coli*)

**colic** /ˈkɒlɪk/ [n] ការចុក (ជំងឺ), ការចុកពោះខ្លាំង, ដែលទាក់ទងនឹងពោះវៀនធំ

**coliform** /ˈkɒlɪfɔːm/ [adj] រាងគូលី, កូលីហ្វម (បាក់តេរី រាងដំបង) ជាទូទៅ វារស់នៅក្នុងពោះវៀនធំ

**colitis (mucous)** /kəˈlʌɪtɪs/ [n] រោគរលាកផ្សាក្នុង ពោះវៀនធំ

**collagen** /ˈkɒlədʒ(ə)n/ [n] កុលឡាសែន (សរសៃប្រូតេអ៊ីននៅក្នុងជាលិកាសន្ទាន)

**collapse** /kəˈlaps/ [n]

១. ការដួល, ការរលំ

២. (សទិសន័យ៖ deep gigging) (ចំពោះដី) ការបាក់ ស្រុត

៣. អស់កំឡាំង, ទ្រុឌទ្រោម, អន់ខ្សោយ

**collar** /ˈkɒlə/ [n] ចង្កំស្លឹក (ផ្នែកមួយដែលភ្ជាប់បន្ទះស្លឹក នឹងស្រទបវា)

**collard greens** /ˈkɒlɑːd griːnz/ [n] ខាត់ណាដើម

**collection** /kəˈlɛkʃ(ə)n/ [n] សមូហកម្ម, ការប្រមូល, ប្រាក់ដែលប្រមូលបានមក

- fuelwood collection /ˈfjuː(ə)lwʊd kəˈlɛkʃ(ə)n/ [n] ការប្រមូលអុសដុត
- germplasm collection /dʒəːmˈplazmə kəˈlɛkʃ(ə)n/ [n] សមូហកម្មជីវករ (ការប្រមូលនូវរាល់ជីវករធម្មជាតិ ទាំងអស់ដែលមាន ដើម្បីរក្សាទុកកុំឱ្យបាត់បង់)
- seed collection /siːd kəˈlɛkʃ(ə)n/ [n] ការប្រមូល គ្រាប់ពូជ, រដូវប្រមូលគ្រាប់, រដូវគ្រាប់ទុំ

**collective work** /kəˈlɛktɪv wəːk/ [n] ស្នាដៃជាសមូហ ភាព, ការងាររួម

**collenchyma** /kəˈlɛŋkɪmə/ [n] កូឡង់ស៊ីម (ជាលិកា រុក្ខជាតិដែលមាននាទីពង្រឹង និងទ្រទ្រង់)

**colloid** /ˈkɒlɔɪd/ [n] កូឡូអ៊ីត (ល្បាយដែលក្នុងនោះអង្គ ធាតុរលាយត្រូវបានពង្រាយសព្វប៉ុន្តែជាភាគល្អិតដែលមាន ទំហំល្មនឹងបំផ្លាត ឬបំបែកពន្លឺ)

- soil colloid /sɔɪl ˈkɒlɔɪd/ [n] កូឡូអ៊ីត (ភាគល្អិតតូច ឆ្មារតូចជាង ២មីក្រុង)

**colluvial** /kəˈl(j)uːvɪəl/ [adj] ដែលជាកម្ទេចកំទី (ក្រួស ថ្មជាដើម), ដែលរអិលចុះពីលើជម្រាល

**colluvium** /kəˈl(j)uːvɪəm/ [n] ល្បាប់ទីខ្ពស់ (ជាតិល្បាប់ដែលហូរមកពីទីខ្ពស់ដោយសារទឹកភ្លៀង), គំនរក្រួស ឬថ្មដែលរអិលចុះពីលើជម្រាល

***Colocasia antiquorum*** [sci.n] សូមមើលពាក្យ៖ taro

***Colocasia esculenta*** [sci.n] សូមមើលពាក្យ៖ taro

**colon** /ˈkəʊlən/ [n] ពោះវៀនធំ, កូឡុង

**colonial** /kəˈləʊnɪəl/ [adj] នៃកូឡូនី (សំដៅលើបណ្ដុំកោសិកាដែលផ្ដុំគ្នាជាកញ្ចុំតូចមួយ)

**colonization** /ˌkɒlənʌɪˈzeɪʃ(ə)n/ [n] ការមកតាំងទីនៅតំបន់ថ្មី

**colonoscopy** /kɒləˈnɒskəpi/ [n] ការស៊ើកបំពង់ឆ្លុះពិនិត្យពោះវៀនធំ

**colony** /ˈkɒləni/ [n] ក្រុម, កូឡូនី (ក្រុមសត្វ រុក្ខជាតិ មានប្រភេទដូចគ្នា ហើយរស់នៅរួមគ្នា), ចំពោះមីក្រូសរីរាង្គជាបន្ទុំកោសិកាដែលវិវត្តន៍ចេញពីកោសិកាមេ

**coloration** /kʌləˈreɪʃ(ə)n/ [n] ការបំពាក់ពណ៌, ការឱ្យពណ៌, ការដាក់ពណ៌

- aposematic coloration /ˌapə(ʊ)sɪˈmatɪk kʌləˈreɪʃ(ə)n/ [n] ពណ៌ព្រមាន
- cryptic coloration /ˈkrɪptɪk kʌləˈreɪʃ(ə)n/ [n] កំណែពណ៌លាក់ខ្លួន
- disruptive coloration /dɪsˈrʌptɪv kʌləˈreɪʃ(ə)n/ [n] កំណពណ៌បន្លំខ្លួន

**colorectal cancer** /ˌkəʊləʊˈrɛkt(ə)l ˈkansə/ [n] រោគមហារីកនៃពោះវៀនធំ

**colostomy** /kəˈlɒstəmi/ [n] ការវះកាត់ឱ្យមានរន្ធគូទជាអចិន្ត្រៃយ៍, ផ្លូវបង្ហូរលាមក

- colostomy bag /kəˈlɒstəmi bag/ [n] ស្បោង ឬថង់ដាក់លាមក

**colostrum** /kəˈlɒstrəm/ [n] ក្បាលទឹកដោះ

**colporraphy** [n] ការដេរបង្រួមផ្លូវយោនីឱ្យតូច

**columella** /ˌkɒljʊˈmɛlə/ [n] (ពហុវចនៈ៖ columellae) (ចំពោះគ្រាប់រុក្ខជាតិ) អង្គត់ឈរតូច (ឧ. ផ្នែកកណ្ដាលនៃប្រភេទផ្លែ capsule នៃប្រភេទមួយចំនួនក្នុងអំបូរMeliaceae)

**columnar** /kəˈlʌmnə/ [n] គ្រឿងទ្រ

**coma** /ˈkəʊmə/ [n]

១. (ចំពោះរុក្ខជាតិ) កញ្ចុំសក់គ្រាប់ (កញ្ចុំសក់ដែលភ្ជាប់ទៅនឹងសម្បកគ្រាប់)

២. (ចំពោះសត្វ) ការសន្លប់, សន្ទ

***Combretum quadrangulare*** [sci.n] សង្កែ

**combustible** /kəmˈbʌstɪb(ə)l/ [adj] អាចឆេះ, អាចដុតឆេះ

**combustion** /kəmˈbʌstʃ(ə)n/ [n] ចំហេះ, ដំណុត

- complete combustion /kəmˈpliːt kəmˈbʌstʃ(ə)n/ [n] ចំហេះសព្វ
- incomplete combustion /ɪnkəmˈpliːt kəmˈbʌstʃ(ə)n/ [n] ចំហេះមិនសព្វ

***Commelina benghalensis*** [sci.n] សូមមើលពាក្យ៖ tropical spiderwort

***Commelina diffusa*** [sci.n] សូមមើលពាក្យ៖ spreading dayflower

**commence** /kəˈmɛns/ [v] ចាប់ផ្ដើម, ផ្ដើម

**commensal** /kəˈmɛns(ə)l/ [n] ភាវៈបន្ទម (មិនប៉ះពាល់ដល់ភាវផ្សេងទៀត)

**commensalism** /kəˈmɛns(ə)lɪz(ə)m/ [n] បន្ទម, ភាពបន្ទម (ទំនាក់ទំនងសហប្រាណ ដែលភាវរស់មួយទទួលផល និងភាវរស់មួយទៀតមិនខាតផល)

**commercialisation** /kəməːʃ(ə)lʌɪˈzeɪʃ(ə)n/ [n] ពាណិជ្ជភាវូបនីយកម្ម (ការធ្វើឱ្យមានលក្ខណៈជាជំនួញ ឧ. Agricultural commercialisation មានន័យថា ការយកកសិកម្មធ្វើជាជំនួញ)

**commodity** /kəˈmɒdɪti/ [n] ទំនិញ (ជាទូទៅនៅក្នុងន័យសេដ្ឋកិច្ច ទំនិញគឺសំដៅទៅដល់ទំនិញទាំងឡាយណា ឬសេវាណាមួយដែលមានតម្លៃគិតជារូបិយវត្ថុ។ នៅក្នុងវិស័យកសិកម្ម គឺយោងទៅលើដំណាំទាំងឡាយណាមួយដែលត្រូវបានគេជួញដូរជាអន្តរជាតិនៅនឹងកន្លែង ឬក៏នៅទីផ្សារដោះដូរទំនិញភ្លាមៗនៅនឹងកន្លែងដោយគិតជាទឹកប្រាក់។ ទំនិញសំខាន់ៗដែលត្រូវបានដាំដុះនៅទូទាំងតំបន់អាស៊ីអាគ្នេយ៍រួមមាន អង្ករ ពោត សណ្ដែក សៀង ប្រេងដែលអាចហូបបាន និងកាផេ។)

**common bottlenose dolphin** /ˈkɒmən ˈbɒt(ə)lnəʊz ˈdɒlfɪn/ [n] ផ្សោតច្រមុះដបចំពុះវែង (ឈ្មោះវិទ្យាសាស្ត្រ *Tursiops truncatus*)

**common name** /ˈkɒmən neɪm/ [n] ឈ្មោះទូទៅ (ប្រភេទឈ្មោះដែលបង្កើតឡើងសម្រាប់ហៅ)

**common ponyfish** /ˈkɒmən ˈpəʊnifɪʃ/ [n] ត្រីសំបោរហៀរ (ឈ្មោះវិទ្យាសាស្ត្រ *Leignathus equulus*)

**common wireweed** /ˈkɒmən wʌɪəwiːd/ [n] កន្ទ្រាំងបាយស (ឈ្មោះវិទ្យាសាស្ត្រ *Sida acuta*)

**commune council** /ˈkɒmjuːn ˈkaʊns(ə)l/ [n] ក្រុមប្រឹក្សាឃុំ/សង្កាត់

**community** /kəˈmjuːnɪti/ [n] សហគមន៍ ( ជាក្រុមមួយនៃបណ្តាក្រុមពូជទាក់ទងគ្នាខាងភូមិសាស្ត្រនៃប្រភេទពូជផ្សេងៗដែលដុះនៅក្នុងតំបន់ភូមិសាស្ត្រ ណាមួយ និងក្នុងពេលណាមួយច្បាស់លាស់។)

- natural community /ˈnatʃ(ə)r(ə)l kəˈmjuːnɪti/ [n] សហគមន៍ធម្មជាតិ

**compact** /kəmˈpakt/ [adj] (សទិសន័យ៖ tight, condensed) ហាប់, តឹង, ញឹក

**compaction** /kəmˈpakʃ(ə)n/ [n] បង្ហាប់កម្ម, បង្ហាំកម្ម, ការធ្វើឱ្យហាប់ ឬណែន

**compactness** /kəmˈpaktnəs/ [n] ភាពណែន ឬហាប់

**comparative advantage** /kəmˈparətɪv ədˈvɑːntɪdʒ/ [n] អត្ថប្រយោជន៍ដោយប្រៀបធៀប (អត្ថប្រយោជន៍ដែលមានទំនាក់ទំនងគ្នារវាងហិរញ្ញវត្ថុ និងសេដ្ឋកិច្ចនៃការផលិតទំនិញ ឬស្បៀងមួយជំនួសឱ្យទំនិញ ឬស្បៀងមួយផ្សេងទៀត ដែលតែងតែត្រូវបានកំណត់ដោយអត្រានៃផលចំណេញផ្សេងៗដែលពាក់ព័ន្ធ។ទាំងនេះគួរកំណត់ទៅលើជម្រើសផលិតកម្មកម្រិតគ្រួសារ និងប្រទេស។)

**compatibility** /kəmˌpatɪˈbɪlɪti/ [n] (ចំពោះរុក្ខជាតិ) លទ្ធភាពអាចបង្កកំណើតបាន, សមត្ថភាពអាចបង្កកំណើតបាន (១. លទ្ធភាពដែលអាចស្ថិតនៅជាមួយគ្នាយ៉ាងល្អប្រសើរ ២. លក្ខណៈនៃសារធាតុមួយ ដែលអាចត្រូវបានលាយបញ្ចូលគ្នាតាមរូបមន្តដោយគ្មានផ្លាស់ប្តូរលក្ខណៈ ឬបាត់បង់ប្រសិទ្ធភាពផ្ទាល់របស់វាឡើយ)។ ពាក្យផ្ទុយ Incompatiblity (គ្មាន លទ្ធភាព)។

- tissue compatibility /ˈtɪʃuː kəmˌpatɪˈbɪlɪti/ [n] ការត្រូវគ្នារបស់ជាលិកា

**compatible** /kəmˈpatɪb(ə)l/ [adj] ស៊ីគ្នា, ចុះសម្រុងគ្នា

- self-compatible /sɛlf kəmˈpatɪb(ə)l/ [adj] ស្វ័យបន្តពូជ

**compensation** /kɒmpɛnˈseɪʃ(ə)n/ [n] សំណង, ការទូទាត់

**competition** /kɒmpɪˈtɪʃ(ə)n/ [n] ការដណ្តើម, ការប្រកួតប្រជែង (ដំណើរការមួយដែលក្នុងនោះឯកត្តៈពីរ ឬច្រើនធ្វើការប្រកួតប្រជែងគ្នាដើម្បីអ្វីមួយ)

- enzymatic competition /ɛnˈzʌɪmɪk kɒmpɪˈtɪʃ(ə)n/ [n] ការប្រជែងនៃអង់ស៊ីម (ការប្រជែងគ្នារវាងអង់ស៊ីមផ្សេងៗគ្នាជាច្រើនដើម្បីភ្ជាប់ទៅនឹងស៊ុបស្ត្រាតណាមួយ)

**complaint** /kəmˈpleɪnt/ [n]

១. (ចំពោះសត្វ) ស្អូរថ្ងូរ

២. ពាក្យបណ្តឹង, បណ្តឹង

**complementarity** /ˌkɒmplɪmɛnˈtarɪti/ [n] គោលការណ៍នៃការបំពេញបាស

**complex** /ˈkɒmplɛks/ [n] វត្ថុទាំងមូល, សារព័ន្ធ, អគារច្រើនផ្តុំគ្នា

- adsorbing complex /ədˈzɔːbɪŋ ˈkɒmplɛks/ [n] (ចំពោះធរណីវិទ្យា) (សទិសន័យ៖ base exchange complex) កំផ្លិចអាប់ស៊បបង់ (មមោក និងគ្រាប់ដីតូចៗឆ្មារតូចជាង ២មីក្រុង)
- base exchange complex /beɪs ɪksˈtʃeɪndʒ ˈkɒmplɛks/ [n] (ចំពោះធរណីវិទ្យា) សូមមើលពាក្យ៖ adsorbing complex
- clay-humus complex /kleɪ ˈhjuːməs ˈkɒmplɛks/ [n] កំផ្លិចឥដ្ឋ-មមោក
- soil complex /sɔɪl ˈkɒmplɛks/ [n] ដីច្រើនប្រភេទ (តំបន់ដែលមានដីច្រើនប្រភេទ)

**component** /kəmˈpəʊnənt/ [n] ធាតុបង្ក, សមាសភាគផ្សំ (ឯកត្តធាតុទាំងឡាយដែលស្ថិតនៅក្នុងប្រព័ន្ធជាមួគ្នា)

- non-humic component /nɒnˈhjuːmɪk kəmˈpəʊnənt/ [n] សមាសធាតុដែលមិនមែនជាសរីរាង្គ (សារធាតុខនិជ)
- yield component /jiːld kəmˈpəʊnənt/ [n] ទិន្នធាតុ (ធាតុដែលចូលរួមក្នុងការផ្តល់ទិន្នផល។ ចំពោះស្រូវមានប្រវែងកួរ ទម្ងន់គ្រាប់ ចំនួនកួរ និងភាគរយនៃគ្រាប់ដាក់ជាដើម។)

**compost** /ˈkɒmpɒst/ [n]
១. (សទិសន័យ៖ vegetable mould, vegetable earth) ដីស្រទាប់លើដែលមានមមោកច្រើន, ដីដីដែលមានសរីរាង្គមមោកច្រើន
២. (សទិសន័យ៖ compost fertilizer) កំប៉ុស្តិ៍, ដីកំប៉ុស្តិ៍ (ការប្រមូលផ្តុំគ្រប់ធាតុសរីរាង្គទាំងអស់ដែលអាចរលួយដូចជា ចំបើង ស្លឹករុក្ខជាតិ ផេះ ស្មៅ លាមកសត្វជាដើម ដែលគរជាគំនរ ព្រមទាំងផ្តល់សំណើម និងខ្យល់គ្រប់គ្រាន់ដល់ដំណើរការធ្វើឱ្យរលួសមាសធាតុទាំងនោះ។ ក្រោយពីរលួយអស់ហើយគេអាចយកវាទៅប្រើដើម្បីបំប៉នដំណាំដូចដីសរីរាង្គផ្សេងៗទៀតដែរ)

**composting** /ˈkɒmpɒstɪŋ/ [n] កំប៉ុសកម្ម

**compound** /ˈkɒmpaʊnd/ [n]
១. (ចំពោះរុក្ខជាតិ) ស្លឹកសមាស (ស្លឹកសមាស ដែលស្លឹកមួយត្រូវបានចែកជាស្លឹកច្រើនតូចៗជាសន្លឹកៗ ហើយមានលក្ខណៈសំប៉ែត ដោយតំរៀបជាគូនៅលើជាយស្លឹក ពិសេសភាគច្រើនជាប្រភេទគ្រួសារ Fabaceae)
២. (សទិសន័យ៖ complex structure) (ចំពោះដី) ទម្រង់ផ្សំ (ដោយគ្រាប់អាគ្រេហ្គា)
៣. សមាសធាតុ, ធាតុផ្សំ, បរិវេណ

- binary compound /ˈbʌɪnəri ˈkɒmpaʊnd/ [n] សមាសធាតុទ្វេភាគ, សមាសធាតុដែលមានធាតុតែពីរ
- carcinogenic compound /ˌkɑːs(ɪ)nəˈdʒɛnɪk ˈkɒmpaʊnd/ [n] សមាសធាតុបង្កមហារីក
- disintegrating exchange compound /dɪsˈɪntɪgreɪtɪŋɪksˈtʃeɪndʒˈkɒmpaʊnd/ [n] (សទិសន័យ៖ unsaturated soil) ដីដែលស្តុកមិនទាន់ពេញ (ទឹក, ខនិជ...)
- organic compound /ɔːˈganɪk ˈkɒmpaʊnd/ [n] សមាសធាតុសរីរាង្គ

**Comprehensive Food Security and Vulnerability Assessment (CFSVA)** [n] ការវាយតម្លៃដ៏ទូលំទូលាយអំពីសន្តិសុខស្បៀង និងភាពងាយរងគ្រោះ (ការវាយតម្លៃដ៏ទូលំទូលាយអំពីសន្តិសុខស្បៀង និងភាពងាយរងគ្រោះ គឺជាការសិក្សាដែលរៀបរាប់អំពីស្ថានភាពសន្តិសុខស្បៀងរបស់ផ្នែកផ្សេងៗនៃស្រទាប់ប្រជាជនទៅលើផ្នែកផ្សេងៗគ្នានៃប្រទេសមួយ ឬក៏តំបន់មួយដោយមានគោលបំណងធ្វើការកំណត់អំពីមូលហេតុមូលដ្ឋាននៃភាពអសន្តិសុខស្បៀង និងភាពងាយរងគ្រោះ ហើយនិងការធ្វើអន្តរាគមន៍សមស្របដើម្បីដោះស្រាយបញ្ហាដែលបានកំណត់។ តាមធម្មតា ការសិក្សានេះត្រូវបានដឹកនាំធ្វើ និង /ឬនាំមុខដោយកម្មវិធីស្បៀងអាហារពិភពលោក។ ពាក្យដែលទាក់ទងគ្នាការអង្កេតពីផែនការចំណាយនៅក្នុងគ្រួសារ ការអង្កេតពីការចំណាយ និងចំណូលនៅក្នុងគ្រួសារ។)

**compress** /kəmˈprɛs/ [n] ស្បៃ, ក្រណាត់ស្តើងៗប្រហោងៗ, ការសង្កត់

**compression boots for circulation** [n] ទ្រនាប់ជើងសង្កត់ឱ្យណែនសម្រាប់ការសាយភាយឈាម

**computed tomography scan** /kəmˈpjuːtɪd təˈmɒgrəfi skan/ [n] (សទិសន័យ៖ CT scan) ការថតអិក្សរេម៉្យាងដែលអនុញ្ញាតឱ្យគ្រូពេទ្យអាចមើលក្នុងពោះបាន

**con-** /kɒn/ [prefix] (ដូច៖, co-, corn) បុព្វបទមានន័យថា ជាមួយ ឬជាមួយគ្នា

**concave** /ˈkɒnkeɪv/ [adj] ខូង, ផត

**concealed solonchak** [n] សូឡុងឆាកបំពួន

**conceive** /kənˈsiːv/ [v] ចាប់មានផ្ទៃពោះ, ចាប់មានគភ៌

**concentration** /kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់ (បរិមាណធាតុសកម្មគិតជាម៉ាសក្នុងមួយខ្នាតមាឌនៃសូលុយស្យុង ឬល្បាយ)

- atmospheric concentration /atməsˈfɛrɪk kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់បរិយាកាស (ដូចជាឧស្ម័នកាបូនិច)
- background concentration /ˈbakgraʊnd kɒns(ə)nˈtreɪʃ(ə)n/ [n] កម្រិតបំពុលដើម, កំហាប់ដើម
- concentration by freezing /kɒns(ə)nˈtreɪʃ(ə)n bʌɪ ˈfriːzɪŋ/ [n] បង្ហាប់ដោយបង្កក
- concentration by evaporation /kɒns(ə)nˈtreɪʃ(ə)n bʌɪ ɪˌvapəˈreɪʃ(ə)n/ [n] បង្ហាប់ដោយរំហួត
- downwind concentration /daʊnˈwɪnd kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់សារធាតុពុលនៅក្រោមខ្យល់ (បរិយាកាស)
- gas concentration /gas kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់ឧស្ម័ន
- lethal concentration 50 (LC50) /ˈliːθ(ə)l kɒns(ə)nˈtreɪʃ(ə)n ˈfɪfti/ [n] កំហាប់បណ្តាលឱ្យស្លាប់ ៥០%

- maximum acceptable concentration /ˈmaksɪməm əkˈsɛptəb(ə)l kɒns(ə)nˈtreɪʃ(ə)n/ [n] (សទិសន័យ៖ maximum admissible concentration, maximum allowable concentration, maximum permissible concentration) កំហាប់អនុញ្ញាតអតិបរមា
- maximum admissible concentration /ˈmaksɪməm ədˈmɪsɪb(ə)l kɒns(ə)nˈtreɪʃ(ə)n/ [n] សូមមើលពាក្យ៖ maximum acceptable concentration
- maximum allowable concentration /ˈmaksɪməm əˈlaʊəbl kɒns(ə)nˈtreɪʃ(ə)n/ [n] សូមមើលពាក្យ៖ maximum acceptable concentration
- maximum emission concentration /ˈmaksɪməm ɪˈmɪʃ(ə)n kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់អនុញ្ញាតអតិបរមារបស់សារធាតុពុលនៅក្នុងផ្សែង
- maximum permissible concentration /ˈmaksɪməm pəˈmɪsɪb(ə)l kɒns(ə)nˈtreɪʃ(ə)n/ [n] សូមមើលពាក្យ៖ maximum acceptable concentration
- nutrient concentration /ˈnjuːtrɪənt kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់សារធាតុចិញ្ចឹម, កំហាប់អាហារធាតុ
- outlet-dust concentration /ˈaʊtlɛt dʌst kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់ធូលីនៅក្នុងផ្សែង
- particle concentration /ˈpɑːtɪk(ə)l kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់ភាគល្អិត (នៅក្នុងខ្យល់ ឬឧស្ម័ន)
- peak concentration /piːk kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់អតិបរមា
- permissible concentration /pəˈmɪsɪb(ə)l kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់អនុញ្ញាត
- residual concentration /rɪˈzɪdjʊəl kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់សល់
- safe concentration /seɪf kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់គ្មានគ្រោះថ្នាក់
- smoke concentration /sməʊk kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់ផ្សែង
- solution concentration /səˈluːʃ(ə)n kɒns(ə)nˈtreɪʃ(ə)n/ [n] កំហាប់សូលុយស្យុង

**conception** /kənˈsɛpʃ(ə)n/ [n] ការបង្កកំណើត, ចំណាប់កំណើត, បដិសន្ធិ

**agricultural concession** /agrɪˈkʌltʃərəl kənˈsɛʃ(ə)n/ [n] សម្បទានកសិកម្ម

**fishing concession** /ˈfɪʃɪŋ kənˈsɛʃ(ə)n/ [n] សម្បទាននេសាទ

**conchiolin** /ˈkɒntʃɪə(ʊ)lɪn/ [n] ខន់ឃីអូលីន(សារសៃប្រូតេអ៊ីនមិន ដែលបង្កើតទម្រង់គ្រឹះរបស់សិប្បីសត្វ)

***Concombre sauvage*** [sci.n] ត្រសក់ព្រៃ

**concretion** /kənˈkriːʃ(ə)n/ [n]
១. ក្រួសក្រវៀន, កុងក្រេស្យុង
២. ការចាក់បេតុង, ការធ្វើឱ្យខាប់

- calcareous concretion /kalˈkɛːrɪəs kənˈkriːʃ(ə)n/ [n] កុងក្រេស្យុង, ក្រួសក្រវៀន, កំបោរ
- hard-marl concretion /hɑːd mɑːl kənˈkriːʃ(ə)n/ [n] កុងក្រេស្យុងរឹងផ្សំដោយដីឥដ្ឋ និងកំបោរ
- iron concretion /ˈʌɪən kənˈkriːʃ(ə)n/ [n] (សទិសន័យ៖ iron incrustation) កុងក្រេស្យុងផ្សំដោយធាតុដែក, កុងក្រេស្យុងដែក, ក្រួសក្រវៀនដែក
- lime concretion /lʌɪm kənˈkriːʃ(ə)n/ [n] កុងក្រេស្យុង, ក្រួសក្រវៀន, កំបោរ
- rusty friable concretion /ˈrʌsti ˈfrʌɪəb(ə)l kənˈkriːʃ(ə)n/ [n] ក្រួសក្រវៀនដែកច្រេះស្រួយផុយ
- siliceous concretion /sɪˈlɪʃəs kənˈkriːʃ(ə)n/ [n] (សទិសន័យ៖ chert) ក្រួសក្រវៀនជាជាតិស៊ីលីស
- tuffaceous concretion /tʌˈfeɪʃəs kənˈkriːʃ(ə)n/ [n] កុងក្រេស្យុងកំបោរស្រាលដោយមានរន្ធច្រើនខាងក្នុង

**concussion** /kənˈkʌʃ(ə)n/ [n] ការរំភើបខ្លាំង, ការទង្គិចយ៉ាងខ្លាំង, ការញ័ររង្គើខួរក្បាល

**condensation** /kɒndɛnˈseɪʃ(ə)n/ [n] កំណកញើស, កំណក, បង្ខាប់

**condense** /kənˈdɛns/ [v] កកជាញើស, ធ្វើចំហាយឱ្យទៅជាទឹក

**condensed** /kənˈdɛnst/ [adj] សូមមើលពាក្យ៖compact

**condensery** /kənˈdɛnsəri/ [n] រោងចក្រផលិតម្សៅទឹកដោះគោ

**condition** /kənˈdɪʃ(ə)n/ [n] កាយលក្ខណៈ, ស្ថានភាព, លក្ខខណ្ឌ

- aerobic condition /ɛːˈrəʊbɪk kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌមានខ្យល់ ឬអុស៊ីសែន
- anaerobic condition /ˌanɛːˈrəʊbɪk kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌគ្មានខ្យល់
- atmospheric condition /atməsˈfɛrɪk kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌបរិយាកាស

- condition of employment /kənˈdɪʃ(ə)n ɒv ɪmˈplɔɪm(ə)nt/ [n] លក្ខខណ្ឌការងារ
- disfavorable condition /dɪsˈfeɪv(ə)rəb(ə)l kənˈdɪʃ(ə)n/ [n] លក្ខណៈអាកាសធាតុមិនអំណោយផល
- economic condition /ˌiːkəˈnɒmɪk kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌសេដ្ឋកិច្ច
- emergency condition /ɪˈməːdʒ(ə)nsi kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌអាសន្ន, លក្ខខណ្ឌបន្ទាន់
- environmental condition /ɪnvʌɪrənˈmɛnt(ə)l kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌបរិស្ថាន
- equilibrium condition /ˌiːkwɪˈlɪbrɪəm kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌតុល្យភាព, លក្ខខណ្ឌលំនឹង
- existence condition /ɪɡˈzɪst(ə)ns kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌអត្ថិភាព
- extreme condition /ɪkˈstriːm kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌបំផុត
- favorable condition /ˈfeɪv(ə)rəb(ə)l kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌប្រកប, លក្ខខណ្ឌអំណោយផល, លក្ខណៈអាកាសធាតុអំណោយផល, លក្ខខណ្ឌល្អសមស្រប (លក្ខខណ្ឌក្នុងនោះដែលសរីរាង្គកំណត់មួយអាចនឹងរីកចម្រើនលូតលាស់យ៉ាងល្អប្រសើរ)
- geological conditions /dʒiːəˈlɒdʒɪk(ə)l kənˈdɪʃ(ə)nz/ [n pl] លក្ខខណ្ឌភូគព្ភសាស្ត្រ
- in-situ condition /ɪn ˈsɪtjuː kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌនៅកន្លែងកំណើត (បណ្តាលក្ខខណ្ឌដែលធនធានសេនេទិចមាននៅក្នុងប្រព័ន្ធបរិស្ថាន និងជម្រកធម្មជាតិ ហើយក្នុងករណី ប្រភេទដែលគេដាំ ឬផ្សាំងនៅក្នុងបរិវេណជុំវិញ ពួកវាបានវិវឌ្ឍន៍ទៅលក្ខណៈសម្បត្តិផ្សេង)
- living condition /ˈlɪvɪŋ kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌជីវិត
- meteorological condition /ˌmiːtɪərəˈlɒdʒɪk(ə)l kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌឧតុភូត
- moisture condition /ˈmɔɪstʃə kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌសំណើម
- natural condition /ˈnatʃ(ə)r(ə)l kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌធម្មជាតិ
- necessary condition /ˈnɛsəs(ə)ri kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌចាំបាច់
- normal conditions /ˈnɔːm(ə)l kənˈdɪʃ(ə)nz/ [n pl] លក្ខខណ្ឌធម្មតា (សីតុណ្ហភាព 0 ℃ សម្ពាធមួយអាត់ម៉ូស្វ៊ែរ)
- plant conditions /plɑːnt kənˈdɪʃ(ə)nz/ [n pl] លក្ខខណ្ឌផលិតកម្ម, លក្ខខណ្ឌក្នុងរោងចក្រ
- reaction condition /rɪˈakʃ(ə)n kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌប្រតិកម្ម
- run-off condition /ˈrʌnɒf kənˈdɪʃ(ə)n/ [n] របបរំហូរ
- safety condition /ˈseɪfti kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌសុវត្ថិភាព
- sterile condition /ˈstɛrʌɪl kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌគ្មានមេរោគ
- stream condition /striːm kənˈdɪʃ(ə)n/ [n] របបទឹកហូរ
- sufficient condition /səˈfɪʃ(ə)nt kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌគ្រប់គ្រាន់
- temperature condition /ˈtɛmp(ə)rətʃə kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌសីតុណ្ហភាព
- unfavourable condition /ʌnˈfeɪv(ə)rəb(ə)l kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌមិនល្អ, លក្ខខណ្ឌមិនប្រកប
- weather condition /ˈwɛðə kənˈdɪʃ(ə)n/ [n] លក្ខខណ្ឌអាកាស
- wind condition /wɪnd kənˈdɪʃ(ə)n/ [n] របបខ្យល់

**classical conditioning** /ˈklasɪk(ə)l kənˈdɪʃ(ə)nɪŋ/ [n] លក្ខខណ្ឌទម្លាប់ (ទម្រង់នៃការសិក្សាដែលភាវរស់ផ្សំរំញោច និងតំណប ដែលមិនទាក់ទងគ្នាពីមុនមក)

**operant conditioning** /ˈɒp(ə)r(ə)nt kənˈdɪʃ(ə)nɪŋ/ [n] ការបង្កើតលក្ខខណ្ឌពិសោធ

**condyle** /ˈkɒndɪl/ [n] ពន្លួញ (ឆ្អឹង)

**cone** /kəʊn/ [n] កោសិកាកោន, ប្រភេទផ្លែកោន (ប្រភេទផ្លែស្ងួតមានផ្ទុកគ្រាប់ច្រើននៃរុក្ខជាតិស្លឹកម្ជុល (conifers) ដែលកើតមកពី strobilus ញី(ផ្កាកោនញី)។ ចំពោះ strobili ឈ្មោលនៃប្រភេទមួយចំនួន ជួនកាលគេ ហៅថាផ្កាកោនឈ្មោល។ ពួករុក្ខជាតិគ្រាប់ផិតដែលមានផ្លែ មានរាងស្រដៀងកោន ដូចជាប្រភេទ Casuarina ជាប្រភេទផ្លែចង្កោម។)

- alluvial cone /əˈl(j)uːvɪəl kəʊn/ [n] (សទិសន័យ៖ talus) គំនរថ្មនៅលើជើងជម្រាលនាំមកដោយទឹកកក, គំនរថ្មរាងជាសាជីដែលនាំមកដោយទឹកជ្រោះ ឬទន្លេ (នៅខាងចុងជ្រោះ)
- cone in cone /kəʊn ɪn kəʊn/ [n] (ចំពោះដី) ប្រភេទម៉ានម្យ៉ាង (ជាសាជីត្រួតគ្នា)
- debris cone /ˈdɛbriː kəʊn/ [n] គំនរកម្ទេចថ្មជារាងសាជី
- pollen cone /ˈpɒlən kəʊn/ [n] កោនឈ្មោល

**conelet** /kənlɪt/ [n] ក្តិបកោន, កោនខ្ចី (ជាកោនមិនទាន់ពេញវ័យ។ ពាក្យនេះប្រើចំពោះកោនខ្ចី ចាប់តាំងពីស្រកាផ្កាកោនញីបិទ ក្រោយពេលលម្អងរហូតដល់ការចាប់ផ្តើមការវិវឌ្ឍន៍កោនពីរបីខែមុនវាទុំ។)

**configuration of soil** /kənˌfɪgəˈreɪʃ(ə)n ɒv sɔɪl/ [n] រូបសណ្ឋាននៃដី

**confinement** /kənˈfʌɪnmənt/ [n] រយៈពេលសម្រាលកូន, មិនអាចទៅណារួច

**conflict** /ˈkɒnflɪkt/ [n] ទំនាស់, ជម្លោះ

- conflict of interests /ˈkɒnflɪkt ɒv ˈɪnt(ə)rɪsts/ [n] ជម្លោះដណ្តើមប្រយោជន៍

**confluence** /ˈkɒnflʊəns/ [n] មុខប្រសព្វ (ទន្លេ)

**confusion** /kənˈfjuːʒ(ə)n/ [n] ការវង្វេងស្មារតី, ការច្របូកច្របល់, ព្យាកុលភាព

**congelifraction** /kənˌdʒɛl əˈfrak ʃ(ə)n/ [n] ការបាក់បែកកម្ទេចថ្មដោយការត្រជាក់កក

**congeneric** /ˌkɒndʒɪˈnɛrɪk/ [adj] ស្ថិតក្នុងពូជតែមួយ

**congenital** /kənˈdʒɛnɪt(ə)l/ [adj] ពីកំណើត, មានមកពីកំណើត

**congestion** /kənˈdʒɛstʃ(ə)n/ [n] ការស្ទះឈាម

**congestive heart failure** /kənˈdʒɛstɪv hɑːt ˈfeɪljə/ [n] ជំងឺស្លាក់ឈាម, ជំងឺស្ទះបេះដូង

**conglomerate** /kənˈglɒm(ə)rət/ [n] ថ្មដែលកើតពីការផ្គុំផ្សាភ្ជាប់គ្នានៃក្រួសអាចម៍ផ្កាយ

**conical** /ˈkɒnɪk(ə)l/ [adj]

១. រាងដូចកោន

២. នៃកោន, មានទម្រង់ជាកោន, ដែលមានរាងសាជីមូល

**conidiophore** /kəʊˈnɪdɪə(ʊ)fɔː/ [n] សរសៃៗនៃផ្សិតដែលមានទម្រង់ងាយ ឬបែកមែកជាងសាំញ៉ាំមានភ្នាសសរសៃពន្ធុរបស់វាអាចបង្កើតជា conidia

**conidium** /kəʊˈnɪdɪəm/ [n] (ពហុវចនៈ៖ conidia) ឫសផ្សិត (មកពីភាសាក្រិចថាម្សៅ ឬធូលី ហើយវាជាទម្រង់ស្ប៉ដែលមិនបន្តពូជដោយភេទរបស់ផ្សិត។ Conidium ជាផ្នែកមួយនៅខាងចុងនៃConidiophore។)

**conifer** /ˈkɒnɪfə/ [n] សណ្តានស្រល់, សរលកូល, កូនីហ្វែ, ប្រភេទរុក្ខជាតិមានរាងកោណ, ពួករុក្ខជាតិស្លឹកម្ជុល (ក្រុមនៃពួកដើមឈើ gymnosperms ដែលមានគ្រាប់កើតនៅក្នុងកោន ឧ. Pinus, Araucaria និង Agathis ប៉ុន្តែមិនមាននៅក្នុងប្រភេទ ឧ. Podocarpus និង Taxus spp។)

**conjugant** /ˈkɒndʒʊg(ə)nt/ [n] កាម៉េតមួយ(កាម៉េតមួយក្នុងចំណោមកាម៉េតទាំងពីរដែលអាចរលាយចូលគ្នា)

**conjugation** /kɒndʒʊˈgeɪʃ(ə)n/ [n] ជំនាប់ប្តូរ (ជំនាប់បណ្តោះអាសន្នដែលសម្ភារៈបន្តពូជ (សេណេទិច) ត្រូវបានប្តូរគ្នាទៅវិញទៅមករវាងប្រូតូសូអ៊ែពីរឌេលមានរោមញ័រ។ វាក៏កើតមានផងដែរចំពោះសារាយ ផ្សិត និងបាក់តេរីមួយចំនួន

**conjunctiva** /ˌkɒndʒʌŋ(k)ˈtʌɪvə/ [n] ស្រទាប់សន្ទាន, កុងសុងទីវ, យុជា, ភ្នាសគ្របកភ្នែកក្នុងប្រស្រីភ្នែក

**conjunctivitis** /kənˌdʒʌŋ(k)tɪˈvʌɪtɪs/ [n] ជំងឺភ្នែកក្រហម

**connate** /ˈkɒneɪt/ [adj] ជាប់គ្នា (ចំពោះសរីរាង្គរុក្ខជាតិមានប្រភពផ្សេងៗគ្នា តែលូតលាស់ និងជាប់ជាមួយគ្នា)

**connecting rod** /kəˈnɛktɪŋ rɒd/ [n] យ៉េន (ដៃឃ្នាស់រវាងពិស្តុង និងវិឡឹកាំង)

**clamp connection** /klamp kəˈnɛkʃ(ə)n/ [n] ជំនាប់រង្វង់ (ជំនាប់តាមចំហៀងរាងជារង្វង់រវាងកោសិកានៅជិតគ្នាដែលកើតឡើងនៅក្នុងមីសេល្យូមរបស់ផ្សិតបាស៊ីដ្យូមីសែត)

***Conocephalus longipennis*** [sci.n] កណ្តូបអង់តែនវែង

***Conogethes punctiferalis*** [sci.n] មេអំបៅផ្លែប៉ែសពណ៌លឿង

**conscious** /ˈkɒnʃəs/ [adj] មានស្មារតី, ដឹងខ្លួន

**consequence** /ˈkɒnsɪkw(ə)ns/ [n] វិបាក, ផលវិបាក

- environmental consequences /ɪnvʌɪrənˈmɛnt(ə)l ˈkɒnsɪkw(ə)nsɪz/ [n pl] ផលវិបាកបរិស្ថាន (ឥទ្ធិពលនៃការអភិវឌ្ឍន៍ដែលធ្វើឱ្យប៉ះពាល់ដល់បរិស្ថាន)

**conservability** /kənˈsəːvəˈbɪlɪti/ [n] សម្បទាដែលអាចស្ថិតនៅជាសភាពល្អ

**conservation** /kɒnsəˈveɪʃ(ə)n/ [n] អភិរក្ស, ការអភិរក្ស

- biological conservation /bʌɪə(ʊ)ˈlɒdʒɪk(ə)l kɒnsəˈveɪʃ(ə)n/ [n] អភិរក្សជីវសាស្ត្រ
- conservation of ecosystem /kɒnsəˈveɪʃ(ə)n ɒv ˈiːkəʊsɪstəm/ [n] ការអភិរក្សប្រព័ន្ធអេកូឡូស៊ី, ការអភិរក្សប្រព័ន្ធបរិស្ថាន

- conservation of genetic resource /kɒnsəˈveɪʃ(ə)n ɒv dʒɪˈnɛtɪk rɪˈsɔːs/ [n] ការអភិរក្សតំណពូជសែន
- conservation of wildlife habitant /kɒnsəˈveɪʃ(ə)n ɒv ˈwʌɪl(d)lʌɪf ˈhabɪt(ə)nt/ [n] ការអភិរក្សជម្រកសត្វព្រៃ
- environmental conservation /ɪnvʌɪrənˈmɛnt(ə)l kɒnsəˈveɪʃ(ə)n/ [n] អភិរក្សបរិស្ថាន
- germplasm conservation /dʒəːmˈplazmə kɒnsəˈveɪʃ(ə)n/ [n] អភិរក្សកម្មជីវករ (ការរក្សាទុកនូវរាល់ជីវករដែលមានកុំឱ្យមានការបាត់បង់ និងដើម្បីប្រើជាប្រយោជន៍ទៅថ្ងៃមុខ)
- natural resource conservation /ˈnatʃ(ə)r(ə)l rɪˈsɔːs kɒnsəˈveɪʃ(ə)n/ [n] ការអភិរក្សធនធានធម្មជាតិ
- nature conservation /ˈneɪtʃə kɒnsəˈveɪʃ(ə)n/ [n] ការអភិរក្សធម្មជាតិ
- soil conservation /sɔɪl kɒnsəˈveɪʃ(ə)n/ [n] ការអភិរក្សដី,ការថែរក្សាដី
- water conservation /ˈwɔːtə kɒnsəˈveɪʃ(ə)n/ [n] អភិរក្សទឹក
- wildlife conservation /ˈwʌɪl(d)lʌɪf kɒnsəˈveɪʃ(ə)n/ [n] អភិរក្សសត្វព្រៃ

**conservatism** /kənˈsəːvətiz(ə)m/ [n] អភិរក្សនិយម (ភាពនិយមតែទម្លាប់ចាស់ ហើយមិនងាយទទួលយកអ្វីដែលថ្មី)

**conserve** /kənˈsəːv/ [v] អភិរក្ស, រក្សា

**consistence** /kənˈsɪst(ə)n/ [n] ភាពជាប់, ភាពកក

**consistency** /kənˈsɪst(ə)nsi/ [n] សភាពលក្ខណៈ (លក្ខណៈនៃវត្ថុមួយដែលអាចដឹងដោយការប៉ះពាល់ ឬដោយការមើលឃើញ)

- soil consistency /sɔɪl kənˈsɪst(ə)nsi/ [n] សភាពលក្ខណៈនៃដី (លក្ខណៈផុយ រឹង ស្អិត ទន់ជាដើម នៃដីដែលអាចដឹងដោយការស្ទាប ឬឃើញ)

**consolidated** /kənˈsɒlɪdeɪtid/ [adj] ដែលផ្សាភ្ជាប់គ្នា, ដែលធ្វើឱ្យកាន់តែជាប់ (ដោយការផ្សាភ្ជាប់គ្នា ឬមធ្យោបាយផ្សេងៗទៀត)

**consolidation** /kənˌsɒlɪˈdeɪʃ(ə)n/ [n] ការធ្វើឱ្យរឹង, ការធ្វើឱ្យជាប់

**constant** /ˈkɒnst(ə)nt/ [adj] ថេរ (តម្លៃថេរ នៅសមីការ ឬ អនុគមន៍មយយចំនួន)

- acid equilibrium constant /ˈasɪd ˌiːkwɪˈlɪbrɪəm ˈkɒnst(ə)nt/ [n] ថេរលំនឹងអាស៊ីត
- equilibrium constant /ˌiːkwɪˈlɪbrɪəm ˈkɒnst(ə)nt/ [n] ថេរលំនឹង
- water ionization constant (Kw) /ˈwɔːtə ˌʌɪənʌɪˈzeɪʃ(ə)n ˈkɒnst(ə)nt/ [n] ថេរអ៊ីយ៉ុងកម្មនៃទឹក

**constipation** /kɒnstɪˈpeɪʃ(ə)n/ [n] ការទល់លាមក

**constituent** /kənˈstɪtjʊənt/ [n] សូមមើលពាក្យ៖ particle

- soil constituent /sɔɪl kənˈstɪtjʊənt/ [n] បតិដ្ឋានភាគនៃដី (សមាសភាពរបស់ដី រួមទាំងភាវមានជីវិត)

**constraint** /kənˈstreɪnt/ [n] កំហិតភាព (បញ្ហាដែលធ្វើឱ្យរាំងស្ទះក្នុងដំណើរការអ្វីមួយ)

**constriction** /kənˈstrɪkʃn/ [n] (ចំពោះសត្វ) ការខ្ទឹប

**consult** /kənˈsʌlt/ [v] ស្នើ

**consultant** /kənˈsʌlt(ə)nt/ [n] ពិគ្រោះការី (អ្នកទទួលការពិគ្រោះយោបល់អ្វីមួយ ឬលើបច្ចេកទេសនៃកម្មវិធីណាមួយ)

**consumer** /kənˈsjuːmə/ [n]

១. អ្នកស៊ី, ភាវបរជីព

២. អ្នកប្រើប្រាស់, អតិថិជន

- primary consumer /ˈprʌɪm(ə)ri kənˈsjuːmə/ [n] ភាវបរជីពលំដាប់ទីមួយ
- secondary consumer /ˈsɛk(ə)nd(ə)ri kənˈsjuːmə/ [n] ភាវបរជីពលំដាប់ទីពីរ
- tertiary consumer /ˈtəːʃ(ə)ri kənˈsjuːmə/ [n] ភាវបរជីពលំដាប់ទីបី

**contact** /ˈkɒntakt/ [v] (ចំពោះសត្វ) ប៉ះ

**contagion** /kənˈteɪdʒ(ə)n/ [n] ការឆ្លង (រោគ)

**contagious** /kənˈteɪdʒəs/ [adj] ឆ្លងតាមរយៈការប៉ះ, ដែលអាចឆ្លងបាន, ដែលឆ្លងរោគ, ដែលងាយឆ្លងរាលដាល

- contagious disease /kənˈteɪdʒəs dɪˈziːz/ [n] ជំងឺដែលងាយឆ្លងរាលដាល
- contagious pustular dermatitis /kənˈteɪdʒəs ˈpʌstjuːlə ˌdəːməˈtʌɪtɪs/ [n] ជំងឺរលាកស្បែកដែលបង្កឱ្យមានខ្ទុះ

**contaminant** /kənˈtamɪnənt/ [n] សារធាតុបំពុល

- air contaminant /ɛː kənˈtamɪnənt/ [n] សារធាតុបំពុលខ្យល់

- environmental contaminant /ɪnvʌɪrənˈmɛnt(ə)l kənˈtamɪnənt/ [n] សារធាតុបំពុលបរិស្ថាន

**contaminate** /kənˈtamɪneɪt/ [v] ចម្លងមីក្រុប, ធ្វើឱ្យកខ្វក់, បំពុល

**contamination** /kənˌtamɪˈneɪʃ(ə)n/ [n] កង្វក់

- environmental contamination /ɪnvʌɪrənˈmɛnt(ə)l kənˌtamɪˈneɪʃ(ə)n/ [n] កង្វក់បរិស្ថាន
- food contamination /fuːd kənˌtamɪˈneɪʃ(ə)n/ [n] ភាពកខ្វក់នៃចំណីអាហារ (កត្តាណាមួយ និងកត្តាទាំងអស់នៅក្នុងព្រឹត្តិកម្មការកែច្នៃ ការរៀបចំ និងការបញ្ចេញចោលនៃអាហារ ឬស្បៀងដែលសម្របសម្រួលដល់សុវត្ថិភាពស្បៀង បណ្តាលឱ្យមានភាពមិនសក្តិសមសម្រាប់មនុស្សបរិភោគ ឬប្រើប្រាស់ដោយសារតែមានហានិភ័យប៉ះពាល់ទៅលើសុខភាព)
- microbial contamination /mʌɪˈkrəʊbɪəl kənˌtamɪˈneɪʃ(ə)n/ [n] ការឆ្លងមេរោគចូល
- radioactive contamination /ˌreɪdɪəʊˈaktɪv kənˌtamɪˈneɪʃ(ə)n/ [n] កខ្វក់ដោយវិទ្យុសកម្ម

**content** /kənˈtɛnt/ [n] បរិមាណ, អត្រា

- air content /ɛː kənˈtɛnt/ [n] បរិមាណខ្យល់
- amylose content /ˈamɪləʊs kənˈtɛnt/ [n] អាមីឡូសធាតុ (សមាសធាតុអាមីឡូសដែលមាននៅក្នុងគ្រាប់ធុញ្ញជាតិ ហើយបរិមាណនេះ បញ្ជាក់ពីកម្រិតអាមីដុងនៅក្នុងគ្រាប់អង្ករសម្រិត ហើយវាអាចកំណត់គុណភាពបាយ)
- clay content /kleɪ kənˈtɛnt/ [n] អត្រាឥដ្ឋ
- critical moisture content /ˈkrɪtɪk(ə)l ˈmɔɪstʃə kənˈtɛnt/ [n] បន្ទុកសំណើមអប្បបរមា (CMC) ជាធម្មតា ពាក្យនេះប្រើសំដៅទៅលើប្រភេទគ្រាប់ រចោលចិតរានត ឬ recalcitrant (មានលក្ខណៈចន្លោះ) បន្ទុកសំណើមទាបបំ ផុតដែលគ្រាប់អាចសំងួតបាន ដោយមិនបាត់បង់លទ្ធភាពរស់របស់វា ពោលគឺ នៅក្នុងការអនុវត្តជាក់ស្តែង វាមានន័យស្មើនឹងបន្ទុកសំណើមទាបបំផុតដែលមានសុវត្ថិភាព (Lowest Safe Moisture Content)។ CMC ត្រូវបានកំណត់ខុសប្លែកៗពីគ្នា ដូចជា បន្ទុកសំណើមក្នុងកម្រិតមួយដែលគ្រាប់ទាំងអស់ងាប់ ឬ បន្ទុកសំណើមស្ថិតក្នុងកម្រិតមួយដែលកញ្ចប់គ្រាប់អាចដុះបាន៦០%។
- equilibrium moisture content /ˌiːkwɪˈlɪbrɪəm ˈmɔɪstʃə kənˈtɛnt/ [n] លំនឹងបន្ទុកសំណើម, សំណើមលំនឹង (ការធ្វើឱ្យមានលំនឹងសំណើមនៃគ្រាប់ស្រូវ ជាលក្ខខណ្ឌដែលក្នុងនោះ សំណើមនៃគ្រាប់វាដូចគ្នា មានតម្លៃស្មើគ្នាទៅនឹងសំណើមរបស់ខ្យល់ដែរ) (EMC)
- humus content /ˈhjuːməs kənˈtɛnt/ [n] ចំនួនមមោក, អត្រាមមោក
- lowest safe moisture content (LSMC) /ləʊwɪst seɪf ˈmɔɪstʃə kənˈtɛnt/ [n] បន្ទុកសំណើមសុវត្ថិភាពអប្បបរមា (LSMC) (ជាកម្រិតបន្ទុកសំណើមមួយដែលទាបជាងគ្រាប់ពូជទើបប្រមូលមកស្រស់ៗ ត្រូវស្លាប់កាលណាគេសំងួតវា ទាបជាងបន្ទុកសំណើមសុវត្ថិភាពនេះ។ )
- moisture content /ˈmɔɪstʃə kənˈtɛnt/ [n] បន្ទុកសំណើម, សមាសភាពសំណើម (ភាគរយសំណើមនៅក្នុងគ្រាប់រុក្ខជាតិ ឬដី)
- nutrient content /ˈnjuːtrɪənt kənˈtɛnt/ [n] បរិមាណសារធាតុចិញ្ចឹម, បរិមាណអាហារធាតុ
- protein content /ˈprəʊtiːn kənˈtɛnt/ [n] សមាសធាតុប្រូតេអ៊ីន
- water content /ˈwɔːtə kənˈtɛnt/ [n] បរិមាណទឹក, ចំនួនទឹកដែលមាន

**contiguous** /kənˈtɪgjʊəs/ [adj] ប៉ះគ្នា (អំពីផ្នែករបស់រុក្ខជាតិ)

**continent** /ˈkɒntɪnənt/ [n] ទ្វីប

**continental** /kɒntɪˈnɛnt(ə)l/ [adj] នៃទ្វីប

**continuous** /kənˈtɪnjʊəs/ [adj] ដែលបន្ត, ឥតឈប់

**contorted** /kənˈtɔːtɪd/ [adj] ឥតម្រៀបនៃគល់ត្របកផ្កា រមួល

**contra-** /ˈkɒntrə/ [prefix] បុព្វបទមានន័យថា ប្រឆាំង, ផ្ទុយពី

**contraception** /kɒntrəˈsɛpʃ(ə)n/ [n] ការបង្អត់កំណើតកូន, ការបង្ការកុំឱ្យមានកូន

**contract** /ˈkɒntrakt/ [v] បង្រួម(ភ្នែក), រួញ(សាច់ដុំ)

**contractile vacuole** /kənˈtraktʌɪl ˈvakjʊəʊl/ [n] វ៉ាគុយអូលកន្ត្រាក់

**contraction** /kənˈtrakʃ(ə)n/ [n] ដំណើរខ្ទឹប ឬរួញ (រួម)

**control** /kənˈtrəʊl/ [n] ការត្រួតពិនិត្យ, ទំនប់ទំនល់, ការធ្វើឱ្យរៀបរយ

- biological control /bʌɪə(ʊ)ˈlɒdʒɪk(ə)l kənˈtrəʊl/ [n] ទំនប់ទំនល់ខាងជីវសាស្ត្រ, វិធានការការពារជីវសាស្ត្រ (សកម្មភាពមួយដែលពឹងផ្អែកលើពពួកសត្វល្អិតមានប្រយោជន៍)
- birth control /bəːθ kənˈtrəʊl/ [n] ការពន្យាកំណើត, ការមានកូនតាមប្រាថ្នា
- chemical control /ˈkɛmɪk(ə)l kənˈtrəʊl/ [n] ការត្រួតពិនិត្យគីមី, ទំនប់ទំនល់គីមី, វិធានការការពារគីមីសាស្ត្រ (ការកម្ចាត់សមាសភាពចង្រៃ (ទុរករ) ដោយប្រើប្រាស់ថ្នាំពុលគីមី)
- contamination control /kənˌtamɪˈneɪʃ(ə)n kənˈtrəʊl/ [n] ការត្រួតពិនិត្យកម្រិតកង្វក់, ទំនប់ទំនល់កង្វក់
- control of soil erosion /kənˈtrəʊl ɒv sɔɪl ɪˈrəʊʒ(ə)n/ [n] ការប្រឆាំង ឬការប្រយុទ្ធទប់ទល់នឹងការហូរច្រោះ
- cultural control /ˈkʌltʃ(ə)r(ə)l kənˈtrəʊl/ [n] វិធានការដាំដុះ (ការកម្ចាត់សមាសភាពចង្រៃដោយអនុវត្តក្នុងរាស់ប្រែប្រួលពេលដាំដុះ ប្រែប្រួលកម្រិតដី គ្រប់គ្រងទឹកជាដើម)
- cultural insect control /ˈkʌltʃ(ə)r(ə)l ˈɪnsɛkt kənˈtrəʊl/ [n] បាណកវប្បឃាត (ការអនុវត្តន៍តាមវិធីសាស្ត្រដាំដុះដូចជា ការរៀបចំដី ពេលវេលាដាំដុះ ការប្រើពូជ ការប្រើដី ការគ្រប់គ្រងទឹក និងដាំដុះពូជអាយុកាលខ្លី ដើម្បីកាត់បន្ថយចំនួនកើនឡើងរបស់សត្វល្អិតចង្រៃ)
- ecologically sound control /iːkəˈlɒdʒɪkli saʊnd kənˈtrəʊl/ [n] ទំនប់ទំនល់សមស្រប និងរក្សាបរិស្ថាន
- emission control /ɪˈmɪʃ(ə)n kənˈtrəʊl/ [n] ការត្រួតពិនិត្យការបញ្ចេញសំណល់ឧស្ម័ន
- erosion control /ɪˈrəʊʒ(ə)n kənˈtrəʊl/ [n] ការគ្រប់គ្រងការហូរច្រោះ (ការការពារដីប្រឆាំងនឹងការហូរនូវថ្ម ឬស្រទាប់ដី សារធាតុចិញ្ចឹមផ្សេងៗដោយសារទឹក ខ្យល់ ឬទឹកកក។ ការគ្រប់គ្រងការហូរច្រោះ អាចត្រូវបានធ្វើឡើងតាមរយៈការដាំដុះរុក្ខជាតិ ដែលមានឫសជ្រៅប្រើប្រាស់គម្របជារុក្ខជាតិ ឬកសាងនូវថ្នាក់ៗនៅតំបន់ភ្នំ)
- error control /ˈɛrə kənˈtrəʊl/ [n] ការការពារទល់នឹងលម្អៀង (ការបន្ថយការលម្អៀងពិសោធ ដោយធ្វើការរៀបចំប្លុកត្រឹមត្រូវ ជ្រើសរើសប្លង់ពិសោធត្រឹមត្រូវបច្ចេកទេសវាស់ត្រឹមត្រូវ និងបច្ចេកទេសរៀបចំកូនស្រែត្រឹមត្រូវ)
- flood control /flʌd kənˈtrəʊl/ [n] ការទប់ស្កាត់ទឹកជំនន់
- health control /hɛlθ kənˈtrəʊl/ [n] ការត្រួតពិនិត្យសុខភាព
- noise control /nɔɪz kənˈtrəʊl/ [n] ការត្រួតពិនិត្យសូរស័ព្ទ
- odor control /ˈəʊdə kənˈtrəʊl/ [n] ការត្រួតពិនិត្យក្លិន
- pest control /pɛst kənˈtrəʊl/ [n] ការត្រួតពិនិត្យសមាសភាពចង្រៃ, ការកម្ចាត់សមាសភាពចង្រៃ
- pollution control /pəˈluːʃ(ə)n kənˈtrəʊl/ [n] ការត្រួតពិនិត្យការបំពុល
- quality control /ˈkwɒlɪti kənˈtrəʊl/ [n] ការត្រួតពិនិត្យគុណភាព
- sanitary control /ˈsanɪt(ə)ri kənˈtrəʊl/ [n] ការត្រួតពិនិត្យអនាម័យ
- sediment control /ˈsɛdɪm(ə)nt kənˈtrəʊl/ [n] ការត្រួតពិនិត្យកម្ទេចកំណ
- waste control /weɪst kənˈtrəʊl/ [n] ការត្រួតពិនិត្យកាកសំណល់
- water control /ˈwɔːtə kənˈtrəʊl/ [n] ការចាត់ចែង ឬរៀបចំទឹកឱ្យបានត្រឹមត្រូវ (បញ្ចេញ បញ្ចូលទឹក)

**contusion** /kənˈtjuːʒ(ə)n/ [n] ជាំ, ខ្ទាំសាច់

**convalesce** /ˌkɒnvəˈlɛs/ [v] ងើបពីឈឺ, ជាពីជំងឺ

**convection** /kənˈvɛkʃ(ə)n/ [n] ការសាយនៃកម្តៅ

**convenient** /kənˈviːnɪənt/ [adj] ងាយ, ស្រួល, ស្រណុក

**conventional** /kənˈvɛnʃ(ə)n(ə)l/ [adj] តាមប្រពៃណី, តាមទម្លាប់

**convolvulus** /kənˈvɒlvjʊləs/ [n] សណ្តានត្រកួន

- water convolvulus /ˈwɔːtə kənˈvɒlvjʊləs/ [n] សូមមើលពាក្យ៖ water spinach

**convulsion** /kənˈvʌlʃ(ə)n/ [n] (សទិសន័យ៖ seizure) ប្រកាច់ (ជំងឺ)

**snow coombe** /snəʊ kuːm/ [n] ចង្អូរព្រិល (លើខ្នងភ្នំ)

**coop** /kuːp/ [n] ទ្រុងបក្សី

**cooperation** /kəʊˌɒpəˈreɪʃ(ə)n/ [n] សហប្រតិបត្តិការ, សាជីវកម្ម, កិច្ចសហប្រតិបត្តិការ

**cooperative** /kəʊˈɒp(ə)rətɪv/ [n] សហករណ៍
- agricultural cooperative /agrɪˈkʌltʃərəl kəʊˈɒp(ə)rətɪv/ [n] សហករណ៍កសិកម្ម

**cooperator** /kəʊˈɒpəreɪtə/ [n] អ្នកសហការ (ជនដែលចូលរួមគ្នា ដើម្បីធ្វើឱ្យសម្រេចការងារអ្វីមួយ)

**coordination** /kəʊˌɔːdɪˈneɪʃ(ə)n/ [n] សម្របសម្រួល

**coordinator** /ˌkəʊˈɔːdɪneɪtə/ [n] អ្នកសម្របសម្រួល, និយាមករ (អ្នកទទួលខុសត្រូវក្នុងការចាត់ចែងការងារដើម្បីសម្រេចកិច្ចការអ្វីមួយ)
- course coordinator /kɔːs ˌkəʊˈɔːdɪneɪtə/ [n] អ្នកសម្របសម្រួលក្នុងវគ្គសិក្សា

**co-pay** /kəʊpeɪ/ [v] សហ-បង់ប្រាក់

**co-payment** /kəʊˈpeɪm(ə)nt/ [n] ការសហ-បង់ប្រាក់

***Copidosomopsis nacoleiae*** [sci.n] ពួកឌីម៉ាល់ (បារាសិតលើពងដង្កូវមូរស្លឹក)

**Copper** /ˈkɒpə/ [n] ទង់ដែង (និមិត្តសញ្ញាគីមី Cu)

**coppice** /ˈkɒpɪs/ [v] ដុះខ្នែងឡើងវិញ (១. ការផលិតនូវដើមថ្មីពីឫស ឬគល់ ២. ការកាត់ដើម (រុក្ខជាតិស្លឹកធំ) នៅគល់ ដើម្បីឱ្យវាដុះពន្លកថ្មីឡើងវិញ ៣. រុក្ខជាតិ ដែលដុះខ្នែងឡើងវិញ ៤. ពន្លក ដែលដុះចេញពីខ្នែង នៅគល់របស់ឈើដែលបានកាត់)
- coppice shoot /ˈkɒpɪs ʃuːt/ [n] ត្រួយខ្នែង (ត្រួយខ្នែងដែលដុះចេញពីគល់ នៃដើមឈើត្រូវបានកាប់។ ចំពោះប្រភេទ ពូជខ្លះ ត្រួយខ្នែង ក៏អាចធ្វើឱ្យវា ដុះផងដែរ ដោយការជៀរសម្បក។ ជារឿយៗ ត្រួយខ្នែងត្រូវបានប្រើជាចុងផ្សាំ ឬកំណាត់មែកក្នុងការបន្តពូជ ដោយសារវាងូលូតលាស់ ព្រោះថាវានៅខ្ចី និងជាធម្មតាវាលូតលាស់ត្រង់ ទៅលើ។)
- coppice with standards (system) /ˈkɒpɪs wɪð ˈstandədz (ˈsɪstəm)/ [n] ធ្វើឱ្យដុះខ្នែងជាប្រព័ន្ធ ដែលដើមត្រូវបានជ្រើសរើស និងរក្សាឱ្យមានលក្ខណៈស្តង់ដាដោយមានអាយុ និងខួបខុសៗគ្នា

**coprogenic** [adj] ដែលកើតពីអាចម៍សត្វ

**coprophage** /ˈkɒprəʊfeɪdʒ/ [n] សត្វស៊ីអាចម៍ខ្លួនឯង

**coprophilous** /ˈkɒprəʊfiləs/ [adj] ចំណូលលាមក (អំពីភាវរស់)

**copulate** /ˈkɒpjʊleɪt/ [v] ពាក់គ្នា, ជាន់គ្នា, ស្ពាវគ្នា

**copulation** /ˌkɒpjʊˈleɪʃ(ə)n/ [n] ការរួមសង្វាស (អំពើដែលភេទពីរផ្គុំយគ្នានៃមនុស្ស ឬសត្វប្រព្រឹត្តឡើងដើម្បីបំពេញតម្រេក)

**coral** /ˈkɒr(ə)l/ [n] ផ្កាថ្ម
- coral reef /ˈkɒr(ə)lriːf/ [n] ជួរផ្កាថ្មប៉ប្រះទឹក

**corals and sea anemones** /ˈkɒr(ə)lz ənd siː/ əˈnɛmənis/ [n] ផ្កាថ្ម (ឈ្មោះវិទ្យាសាស្ត្រ *Anthozoa spp.*)

***Corchorus capsularis*** [sci.n] សូមមើលពាក្យ៖ jute

***Corchorus olitorius*** [sci.n] សូមមើលពាក្យ៖ jute mallow, nalta jute

**cordate** /ˈkɔːdeɪt/ [adj] ទម្រង់បន្ទះស្លឹករាងបេះដូងស្រួច, ទម្រង់គល់ស្លឹកទម្រង់បេះដូង, ប្រភេទនៃស្លឹកដែលមានរាងបេះដូង (ឧ. ស្លឹកម្លូ ស្លឹកកំប្លោក)

**coriander** /ˌkɒrɪˈandə/ [n] វ៉ាន់ស៊ុយ (ឈ្មោះវិទ្យាសាស្ត្រ *Coriandrum sativum*)

***Coriandrum sativum*** [sci.n] សូមមើលពាក្យ៖ coriander

***Corica laciniata*** [sci.n] សូមមើលពាក្យ៖ Bangkok river sprat

**corm** /kɔːm/ [n] គល់មើម (ខ្ទឹម), មើម (ផ្នែកប៉ោងខាងគល់នៃដើមដែលអាចដុះឫស ឬដើមថ្មី), ដើមមើម (ដើមក្រោមដីខ្លី និងមានសាច់ក្រាស់របស់រុក្ខជាតិម៉ូណូកូទីលេដូនមួយចំនួន និងវាគ្មានស្លឹកសាច់ទេ។ ឧ. ដើមចេក)

**corn-** /kɔːn/ [prefix] (ដូចះ co-, con) បុព្វបទមានន័យថា ជាមួយ ឬជាមួយគ្នា

**corn** /kɔːn/ [n] ពោត (ឈ្មោះវិទ្យាសាស្ត្រ *Zea mays*)
- sweet corn /swiːt kɔːn/ [n] ពោតហាវ៉ៃ (ឈ្មោះវិទ្យាសាស្ត្រ *Zea mays* var.*rugosa*)

**cornea** /ˈkɔːnɪə/ [n] ករនេ, កញ្ចក់ភ្នែក

**cornice** /ˈkɔːnɪs/ [n] ជម្រាល, ផ្នែកមួយនៃជម្រាល

**corolla** /kəˈrɒlə/ [n] កញ្ចុំស្រទាប់ផ្កា, ស្រទាប់ផ្កា (ផ្នែកនៃផ្កាដែលផ្គុំឡើងដោយស្រទាប់ផ្កា (petals)។)

**corona** /kəˈrəʊnə/ [n] (ពហុវចនៈ៖ coronae) ការរីកដូចត្រុំប៉ែត

**coronary** /ˈkɒr(ə)n(ə)ri/ [adj] កូរ៉ូនេ
- coronary artery /ˈkɒr(ə)n(ə)ri ˈɑːtəri/ [n] សរសៃឈាមចិញ្ចឹមបេះដូង

**corporation** /kɔːpəˈreɪʃ(ə)n/ [n] សាជីវកម្ម (ប្រភេទក្រុមហ៊ុនដែលមានភាគហ៊ុនច្រើន ហើយហ៊ុនទាំងនោះត្រូវបានដាក់លក់ជាសាធារណៈ)

**corpus luteum** /ˈkɔːpəs ˈluːtɪəm/ [n] អង្គលឿង

**corpuscle** /ˈkɔːpʌs(ə)l/ [n] អង្គតូច

correlation /ˌkɒrəˈleɪʃ(ə)n/ [n] ការជាប់ទាក់ទងគ្នា, ទំនាក់ទំនងភាព (រង្វាស់នៃកម្រិតទាក់ទងរវាងវិបរិតរូបពីរ)

- genetic correlation /dʒɪˈnɛtɪk ˌkɒrəˈleɪʃ(ə)n/ [n] ការជាប់ទាក់ទងសេនេទិច (រង្វាស់មួយនៃកម្រិតទំនាក់ទំនងសេនេទិចរវាងលក្ខណៈពីរ ឧ. ទំនាក់ទំនងរវាងតម្លៃលទ្ធភាពផ្សំផ្គុំទូទៅ)
- juvenile-mature correlation /ˈdʒuːvənʌɪl məˈtʃʊə ˌkɒrəˈleɪʃ(ə)n/ [n] ទំនាក់ទំនងនៃយុវភាព និងពេញវ័យ , ទំនាក់ទំនងនៃភាពខ្ចី និងពេញវ័យ (ទំនាក់ទំនងខាងសេនេទិចនៃបណ្តាលក្ខណៈដែលគេវាយតម្លៃនៅដំណាក់ខ្ចី ជាមួយលក្ខណៈទាំងនោះដែលសម្តែងនៅអាយុពេញវ័យ។ ទំនាក់ទំនងនេះសម្តែងចេញមកជាមេគុណទំនាក់ទំនងរវាងទិន្នន័យគូៗ ដែលវាស់នៅអាយុផ្សេងៗគ្នា)
- negative correlation /ˈnɛgətɪv ˌkɒrəˈleɪʃ(ə)n/ [n] ការជាប់ទាក់ទងគ្នាជាអវិជ្ជមាន, ទំនាក់ទំនងអវិជ្ជមាន
- positive correlation /ˈpɒzɪtɪv ˌkɒrəˈleɪʃ(ə)n/ [n] ទំនាក់ទំនងវិជ្ជមាន

**corrie** /ˈkɒri/ [n] ទំនាបជារង្វង់មូល

**corrosion** /kəˈrəʊʒ(ə)n/ [n]

១. (ចំពោះបរិស្ថាន) កំណកូត

២. (ចំពោះដី) (សទិសន័យ៖ tooling action, wind-carwing) ការសឹករេចរឹល (ដោយកម្លាំងខ្យល់ដែលមានខ្សាច់ ឧ. នៅវាលខ្សាច់)

**cortex** /ˈkɔːtɛks/ [n]

១. (ចំពោះរុក្ខជាតិ) ផ្នែកសម្បក

២. (ចំពោះសត្វ) ករតិច, ស្រោម

**corymb** /ˈkɒrɪmb/ [n] កញ្ចុំផ្កាត្រឹម, ផ្កាចង្កោមកំពូលស្មើ

**Corynebacterium** /ˌkɒrɪnɪbakˈtɪərɪəm/ [n] ករីណេបាក់តេរីយ៉ូម

**coryza** /kəˈrʌɪzə/ [n]

១. សូមមើលពាក្យ៖ roup

២. សូមមើលពាក្យ៖៖ influenza

**coservation of biodiversity** /kɒnsəˈveɪʃ(ə)n ɒv ˌbʌɪə(ʊ)dʌɪˈvəːsɪti/ [n] ការអភិរក្សជីវចម្រុះ

***Cosmochilus harmandi*** [sci.n] ត្រីកំពូលបាយ

**cost** /kɒst/ [v] ថ្លៃ, មានតម្លៃ

**cost** /kɒst/ [n] តម្លៃ, ថ្លៃដើម

- benefit cost /ˈbɛnɪfɪt kɒst/ [n] ថ្លៃចំណេញ
- cost accounting /kɒst əˈkaʊntɪŋ/ [n] ការចំណាយ (ការរាប់បញ្ចូលនូវការចំណាយផ្សេងៗ)
- cost of living /kɒst ɒv ˈlɪvɪŋ/ [n] ថ្លៃទ្រទ្រង់ជីវភាព
- indirect labour cost /ɪndɪˈrɛkt ˈleɪbə kɒst/ [n] ថ្លៃឈ្នួលពលកម្មប្រយោល
- initial cost /ɪˈnɪʃ(ə)l kɒst/ [n] (សទិសន័យ៖ initial price) ថ្លៃដើម
- labour cost /ˈleɪbə kɒst/ [n] (សទិសន័យ៖ labour charge) ថ្លៃឈ្នួលពលកម្មប្រយោល
- marginal cost /ˈmɑːdʒɪn(ə)l kɒst/ [n] តម្លៃផ្សំ (កំណើននៅក្នុងតម្លៃផ្លាស់ប្តូរដែលកើតមានឡើងក្នុងការប្រែប្រួលផលិតកម្មមួយទៅមួយទៀត ឬច្រើន ហើយត្រូវបានស្មង់ឯកតាដែលទាក់ទងជាមួយឯកតាបន្ថែមនៃប្រាក់ដែលធ្វើវិនិយោគ)
- material cost /məˈtɪərɪəl kɒst/ [n] តម្លៃសម្ភារ
- opportunity cost /ɒpəˈtjuːnɪti kɒst/ [n] តម្លៃការអនុវត្តន៍ (តម្លៃនៃផលិតផលដែលយកមកបរិភោគ ឬប្រើប្រាស់ក្នុងគ្រួសារ ជាទូទៅបានមកដោយគេមិនគិតបញ្ចូលក្នុងតម្លៃសរុបទេ)
- power cost /ˈpaʊə kɒst/ [n] តម្លៃកម្លាំងអូសទាញ
- temporary cost /ˈtɛmp(ə)rəri kɒst/ [n] តម្លៃកាលិក (តម្លៃដែលប្រែប្រួលតាមពេលវេលា, តម្លៃដែលកំណត់ឡើងតាមកាល)
- total cost /ˈtəʊt(ə)l kɒst/ [n] តម្លៃសរុប
- unit cost /ˈjuːnɪt kɒst/ [n] តម្លៃដើមឯកតា
- variable cost /ˈvɛːrɪəb(ə)l kɒst/ [n] តម្លៃអថេរ

***Cotesia angustibasis*** [sci.n] សូមមើលពាក្យ៖ *Apanteles angustibasis*

***Cotesia flavipes*** [sci.n] សូមមើលពាក្យ៖ *Apanteles flavipes*

**cotton** /ˈkɒt(ə)n/ [n] កប្បាស (ឈ្មោះវិទ្យាសាស្ត្រ *Gossypium herbaceum*)

- raw cotton /rɔː ˈkɒt(ə)n/ [n] កប្បាស, សំឡីកប្បាស

**cotyledon** /ˌkɒtɪˈliːd(ə)n/ [n] ស្លឹកកំណើត (ស្លឹកដំបូង), ស្លឹកទី១ដែលដុះចេញពីគ្រាប់រុក្ខជាតិ, កូទីឡេដុង (ជាអំប្រីយ៉ុងរបស់ស្លឹក ដែលរក្សានូវអាហារ ចំណាំ កូទីឡេដុងជាលក្ខណៈរបស់រុក្ខជាតិ ដែលមានគ្រាប់ដូចជា Spermatophyta)

**cough** /kɒf/ [v] ក្អក

- whooping cough /wuːpin kɒf/ [n] ជំងឺក្អកមាន់

**coughing up with blood** [n] ការក្អកធ្លាក់ឈាម

**coulee** /ˈkuːli/ [n] វត្ថុធាតុរលាយហើយហូរ

**Council for Agricultural and Rural Development** [n] ក្រុមប្រឹក្សាស្ដារអភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ

**Coulter counter** /ˈkəʊltə ˈkaʊntə/ [n] ឧបករណ៍រាប់កោសិកា

**cover** /ˈkʌvə/ [n] គម្រប

- forest cover /ˈfɒrɪst ˈkʌvə/ [n] ផ្ទៃដីគ្របដណ្ដប់ដោយព្រៃឈើ
- soil cover /sɔɪl ˈkʌvə/ [n] គម្របដី

**coverage** /ˈkʌv(ə)rɪdʒ/ [n] ការផ្គត់ផ្គង់ឱ្យ

**cow shed** /kaʊ ʃɛd/ [n] រោងគោ, ក្រោលគោ

**cow** /kaʊ/ [n] មេគោ, គោញី

- dry cow /drʌɪ kaʊ/ [n] មេគោដែលមិនមានទឹកដោះបន្ទាប់ការយកទឹកដោះ ឬបំបៅកូន

**cowpea** /ˈkaʊpiː/ [n] សណ្ដែកអង្គុយ (ឈ្មោះវិទ្យាសាស្ត្រ *Vigna unguiculata* ssp. *sinensis*)

**cowpox** /ˈkaʊpɒks/ [n] (សទិសន័យ៖ vaccinia) ជំងឺអុត, អុតស្វាយ

**coxa** /ˈkɒksə/ [n] កំណាត់ក្រោមនៃជើងសត្វល្អិត, ឆ្អឹងចង្កេះ

**crab** /krab/ [n] ក្ដាម

**crack** /krak/ [n] ក្រហែងដី, ប្រហោង

- contraction crack /kənˈtrakʃ(ə)n krak/ [n] (សទិសន័យ៖ shrinkage crack, sun crack) ក្រហែងបែកដោយសារភាពស្ងួត (ឧ. ដីឥដ្ឋ)
- frost crack /frɒst krak/ [n] (សទិសន័យ៖ ice-wedge) ក្រហែងប្រេះដោយការត្រជាក់
- mud crack /mʌd krak/ [n] ក្រហែងបែកប្រេះដោយការស្ងួត
- shrinkage crack /ˈʃrɪŋkɪdʒ krak/ [n] សូមមើលពាក្យ៖ contraction crack
- sun crack /sʌn krak/ [n] សូមមើលពាក្យ៖ contraction crack

**cracking** /ˈkrakɪŋ/ [n] ការប្រេះជាក្រហែង

**cramp** /kramp/ [n] រមួលក្រពើ

**crane** /kreɪn/ [n]
១. ក្រៀល (សត្វស្លាប)
២. ប្រដាប់ស្ទូច

**craniotomy** /ˌkreɪnɪˈɒtəmi/ [n] ការវះចោះឆ្អឹងលលាដ៍ក្បាល

**cranium** /ˈkreɪnɪəm/ [n] (សទិសន័យ៖ skull) លលាដ៍ក្បាល

**crank** /kraŋk/ [n] ដៃវ៉េ, ដៃកវ៉េ

- crank shaft /kraŋk ʃɑːft/ [n] វីឡឺកាំង (ផ្នែកមួយនៃចលករសម្រាប់បញ្ជូនរង្វិលមកក្រៅ)

**crater** /ˈkreɪtə/ [n] មាត់ភ្នំភ្លើង

**crayfish** /ˈkreɪfɪʃ/ [n] បង្កងទឹកសាប

**creation** /kriːˈeɪʃ(ə)n/ [n] ការបង្កើតឡើង

**creationism** /kriːˈeɪʃ(ə)nɪz(ə)m/ [n] ទ្រឹស្ដីនឹងនិយម

**creek** /kriːk/ [n] (សទិសន័យ៖ brook) ព្រែកតូចៗ, ស្ទឹង, អូរ, ប្រឡាយទឹក

- sinking creek /sɪŋk kriːk/ [n] ជ្រលងជ្រោះចង្អៀត, ជ្រលងច្រាំងចោតខ្លាំង

**creep** /kriːp/ [n] ការរអិលស្រទាប់លើ

**creeping** /kriːpɪŋ/ [adj] ដុះវារ (ជាសណ្ឋានរបស់រុក្ខជាតិណាដុះទម្រង់វារលើដីដោយសារខ្នែងខ្យល់ ឬខ្នែងក្នុងដី)

**creeping water primrose** /kriːpɪŋ ˈwɔːtə ˈprɪmrəʊz/ [n] កំពីងពួយ (ឈ្មោះវិទ្យាសាស្ត្រ *Ludwigia adscendens*)

**crenate** /ˈkriːneɪt/ [adj] គែមអង្កាញ់ៗ (អំពីស្លឹករបស់រុក្ខជាតិ), ទម្រង់គែមស្លឹករឆេចរឆូញ

**creosote** /ˈkriːəsəʊt/ [n] ក្រេអូសូត

**crepuscular** /krɪˈpʌskjʊlə/ [adj] ដែលសកម្មនៅពេលយប់

**crest** /krɛst/ [n] កញ្ចុំស្លាប

**crest (of bone)** [n] ទ្រនង់នៃឆ្អឹងអ្វីមួយ

**cribbing** /krɪbɪŋ/ [n] ទម្លាប់អាក្រក់នៃសត្វសេះ ដែលកកេរស្នូក

**cricket** /ˈkrɪkɪt/ [n] ចង្រិត (ឈ្មោះវិទ្យាសាស្ត្រ *Euscyrtus concinnus*)

**cricoid cartilage** /ˈkrʌɪkɔɪd ˈkɑːt(ɪ)lɪdʒ/ [n] ឆ្អឹងខ្ចីនៃបំពង់សំឡេង

**crippled** /ˈkrɪpld/ [adj] ខ្ញើចៗ, ខ្ញើច

**crisis** /ˈkrʌɪsɪs/ [n] វិបត្តិ, ការប្រែប្រួលភ្លាមៗ (ជំងឺ)

- agricultural crisis /agrɪˈkʌltʃərəl ˈkrʌɪsɪs/ [n] វិបត្តិកសិកម្ម
- ecological crisis /iːkəˈlɒdʒɪk(ə)l ˈkrʌɪsɪs/ [n] វិបត្តិអេកូឡូស៊ី

**criterion** /krʌɪˈtɪərɪən/ [n] (ពហុវចនៈ៖ criteria) លក្ខណៈវិនិច្ឆ័យ

- selection criterion /sɪˈlɛkʃ(ə)n krʌɪˈtɪərɪən/ [n] លក្ខណៈជម្រើស (លក្ខណៈដែលបានកំណត់សម្រាប់ការជ្រើសរើស)

**critical** /ˈkrɪtɪk(ə)l/ [adj] ដែលមានវិបត្តិ

**croaking gourami** /krəʊkɪŋ gʊ(ə)ˈrɑːmi/ [n] ត្រីក្រឹមក្ការ (ឈ្មោះវិទ្យាសាស្ត្រ *Trichopsis vittata*)

**crocodile** /ˈkrɒkədʌɪl/ [n] ក្រពើ

- estuarine crocodile /ˈɛstjʊ(ə)rʌɪn ˈkrɒkədʌɪl/ [n] សូមមើលពាក្យ៖ saltwater crocodile

***Crocodylus porosus*** [sci.n] សូមមើលពាក្យ៖ saltwater crocodile

**crocus giant clam** /ˈkrəʊkəs ˈdʒʌɪənt klam/ [n] គ្រុំយក្ស (ឈ្មោះវិទ្យាសាស្ត្រ *Tridacna crocea*)

***Crocus sativus*** [sci.n] សូមមើលពាក្យ៖ safran

**crooked** /ˈkrʊkɪd/ [adj] ដែលមិនត្រង់

**crookedness** /ˈkrʊkɪdnəs/ [n] ភាពមិនត្រង់ (ឧ. ដើមឈើដែលដើមមានលក្ខណៈកោង)

**crop establishment** /krɒp ɪˈstablɪʃm(ə)nt/ [n] ការដាំដុះដំណាំ

**crop** /krɒp/ [n]

១. (ចំពោះសត្វ) តែ (មាន់)

២. ដំណាំ (រុក្ខជាតិដែលដាំក្នុងកសិដ្ឋានក្នុងគោលបំណងសម្រាប់ផ្នែកសេដ្ឋកិច្ច សម្រាប់គ្រួសារ ឬអាចលក់បាន)

- annual crop /ˈanjʊəl krɒp/ [n] ដំណាំឯករវត្ស (ដំណាំដែលផ្តល់ផលក្នុងកំឡុងពេលមួយឆ្នាំ វាមានវដ្តជីវិតមិនលើសពីមួយឆ្នាំហើយត្រូវស្លាប់ក្រោយពេលប្រមូលផលរួច)
- cash crop /kaʃ krɒp/ [n] រូបិយដំណាំ (ដំណាំដែលគេដាំសម្រាប់លក់ ដូចជាដំណាំសណ្តែក ល្ហុងប្រេងជាដើម)
- catch crop /katʃ krɒp/ [n] ដំណាំឆ្លោង (ជាដំណាំដែលដាំនៅចន្លោះរងនៃដំណាំគោល ឬក្នុងពេលដែលមិនដំណាំគោលត្រូវបានកំពុងដាំ)
- cover crop /ˈkʌvə krɒp/ [n] ដំណាំគម្រប (រុក្ខជាតិដាំគ្របដីការពារស្មៅចង្រៃ ការពារការហូរច្រោះ និងផ្តល់ជី)
- farm crop /fɑːm krɒp/ [n] ដំណាំកសិដ្ឋាន
- fiber crop /ˈfʌɪbə krɒp/ [n] ដំណាំសរសៃ
- field crop /fiːld krɒp/ [n] ដំណាំចម្ការ, ដំណាំកសិកម្ម (មិនរាប់បញ្ចូលឈើហូបផ្លែ)
- forage crop /ˈfɒrɪdʒ krɒp/ [n] (សទិសន័យ៖ forage) ដំណាំចំណីសត្វ
- green manure crop /griːn ˈməˈnjʊə krɒp/ [n] ដំណាំជីស្រស់ (រុក្ខជាតិដែលគេដាំសម្រាប់ធ្វើជាជីដូចជាសណ្តែក ទន្រ្ទានខែត្រស្នោជាដើម)
- harvestable seed crop /ˈhɑːvɪsteɪb(ə)l siːd krɒp/ [n] ផលគ្រាប់ដែលអាចប្រមូលបាន
- harvested seed crop /ˈhɑːvɪstɪd siːd krɒp/ [n] ផលគ្រាប់ដែលអាចប្រមូលបាន
- mulch crop /mʌl(t)ʃ krɒp/ [n] ដំណាំគម្រប
- multiple crop /ˈmʌltɪp(ə)l krɒp/ [n] ពហុដំណាំ
- perennial crop /pəˈrɛnɪəl krɒp/ [n] (សទិសន័យ៖ plantation crop) ដំណាំពហុវត្ស (ដំណាំផ្តល់ផលរយៈពេលយូរឆ្នាំ ដូចជាស្វាយ ខ្នុរ ស្វាយចន្ទីជាដើម)
- plantation crop /planˈteɪʃ(ə)n krɒp/ [n] សូមមើលពាក្យ៖ perennial crop
- ridge crop /rɪdʒ krɒpin/ [n] ដំណាំលើរង, ដំណាំរបងចំការ (ព័ទ្ធជុំវិញចំការ)
- root crop /ruːt krɒp/ [n] ដំណាំយកមើម
- rotation of crop /rə(ʊ)ˈteɪʃ(ə)n ɒv krɒp/ [n] ការឆ្លាស់ដំណាំ
- row crop /rəʊ krɒp/ [n] ដំណាំជួរ
- seed crop /siːd krɒp/ [n] ផលគ្រាប់ពូជមួយរដូវ (ផលិតកម្មគ្រាប់សរុបក្នុងរដូវផ្លែ/គ្រាប់កំណត់មួយ)

- upland crop /ˈʌplənd krɒp/ [n] ដំណាំចម្ការ
- vegetable crop /ˈvɛdʒtəb(ə)l krɒp/ [n] ដំណាំបន្លែ
- village garden crop /ˈvɪlɪdʒ ˈgɑːd(ə)n krɒp/ [n] សួនដំណាំក្នុងភូមិ

**cropping** /krɒpɪŋ/ [n] វប្បកម្មដំណាំ, ការដាំដុះដណាំ

- alley cropping /ˈali krɒpɪŋ/ [n] (សទិសន័យ៖ alley farming, avenue cropping, hedgerow intercropping) ការដាំដំណាំនៅចន្លោះប្រភេទឈើ (ការដាំប្រភេទដំណាំជាអាហារ ចំណីសត្វ ឬដំណាំផ្សេងទៀត នៅចន្លោះ ប្រភេទឈើ)
- contour strip cropping /ˈkɒntʊə strɪp krɒpin/ [n] (សទិសន័យ៖ contour tillage) ការភ្ជួរ ឬធ្វើដំណាំជាបន្ទះឆ្នូតស្របនឹងខ្សែរយៈកម្ពស់
- field strip cropping / fiːld strɪp krɒpɪŋ/ [n] សូមមើលពាក្យ៖ strip plating
- hedgerow cropping /ˈhɛdʒrəʊ kroppɪŋ/ [n] ដំណាំរបង (ដំណាំធ្វើជារបងការពារហូរច្រោះ សត្វព្រៃ និងគ្របដី ឬជារបាំងខ្យល់)
- mixed cropping /mɪkst krɒpɪŋ/ [n] វប្បកម្មចម្រុះ (ការដាំដំណាំយ៉ាងតិចពីរប្រភេទក្នុងស្រែ ឬចម្ការជាមួយគ្នា តែដោយគ្មានការប្រកាន់កន្លែងឱ្យបានច្បាស់លាស់)
- multi-storey croppping /ˈmʌlti ˈstɔːri kroppɪŋ/ [n] ការដាំពហុលំដាប់ថ្នាក់ (ប្រព័ន្ធដាំដុះមួយដែលមានស្រទាប់រុក្ខជាតិផ្សេងៗគ្នាត្រូវបានដាំដុះ ដូចជាការដាំដើមដូងបន្ទាប់មកកាហ្វេ និងចុងក្រោយគេដាំដំណាំម្នាស់)
- ratoon cropping /rəˈtuːn kroppɪŋ/ [n] ដំណាំដុះសា (ដំណាំឯកវត្សដុះលូតលាស់ក្រោយពេលច្រូតកាត់រួច ហើយទទួលបាននូវផលផ្លែផ្កាម្តងទៀត ឧ. ស្រូវសា)
- relay cropping /ˈriːleɪ kroppɪŋ/ [n] ការដាំដំណាំបណ្តាក់ (ការដាំដំណាំឯកវត្សមានពីរ ឬច្រើនមុខនៅក្នុងស្រែជាមួយគ្នាដោយដាំដំណាំបន្ទាប់ក្រោយពេលដំណាំដំបូងចេញផ្កា)
- sequential cropping /sɪˈkwɛnʃ(ə)l kroppɪŋ/ [n] រុក្ខវប្បកម្មលំដាប់ (ការដាំដំណាំបន្តបន្ទាប់គ្នាក្រោយពីដំណាំលើកមុនត្រូវបានច្រូតកាត់)
- sorjan cropping [n] ការដាំដុះសូយាន (ប្រព័ន្ធដាំដុះដែលយកវាលស្រែធ្វើជាថ្នាលសម្រាប់ដាំដំណាំដីទួល ឬដំណាំភ្នំ)
- strip cropping /strɪp krɒpɪŋ/ [n] សូមមើលពាក្យ៖ strip planting

**cross** /krɒs/ [v] បង្កាត់ (១. ដំណើរការបង្កាត់រវាងឯកត្តៈពីរ ដែលមានភេទផ្ទុយគ្នា ហើយមានផេណូទីបខុសគ្នា ២. កូនបង្កាត់ដែលមានមេបាមានពន្ធុដូចគ្នា)

**cross** /krɒs/ [n] កូនកាត់

- cross breed /krɒs briːd/ [v] បង្កាត់ពូជ
- cross-match /krɒsˈmatʃ/ [n] ការសាកលាយឈាមទាំងពីរមុននឹងបញ្ចូលក្នុងខ្លួន
- back-cross /bak krɒs/ [v] ការបង្កាត់ពូជត្រឡប់ (ការបង្កាត់រវាងកូនបង្កាត់ជំនាន់ទីមួយនឹងមេ ឬបារបស់វា)
- diallel cross /dʌɪəˈliːl krɒs/ [n] ការបង្កាត់ពូជសុទ្ធជាមួយមេបាផ្សេង, ការបង្កាត់ឌីអាលែល
- double cross /ˈdʌb(ə)l krɒs/ [n] ការបង្កាត់ទ្វេដង
- reciprocal cross /rɪˈsɪprək(ə)l krɒs/ [n] ការបង្កាត់គ្នាទៅវិញទៅមក, បដិការបង្កាត់ (ការត្រាប់ឡើងវិញនៃការបង្កាត់មួយដែលតួនាទីភេទរបស់មេបាត្រូវត្រឡប់ពោលគឺ មេB x បាA ជាបដិការនៃ មេA x បាB)
- test cross /tɛst krɒs/ [n] ការបង្កាត់តេស្ត

**crossbreed** /krɒsbriːd/ [n] អន្តរបង្កាត់ (ការបង្កាត់ពូជផ្សេងគ្នា)

- three breed crossbreed /θriː briːd/ [n] កូនកាត់បីសាសន៍, កូនកាត់បីពូជ

**cross-cutting issue** /krɒs ˈkʌtɪŋ ˈɪsjuː/ [n] បញ្ហាពហុវិស័យ (ប្រធានបទដែលត្រូវបានគេចាត់ទុកថាជាប្រយោជន៍រួម ឬក៏ពាក់ព័ន្ធទៅនឹងវិស័យច្រើនទៀត មិនកំណត់ចំពោះវិស័យណាមួយ ឬក៏ការទទួលខុសត្រូវ ។ គំរូឧទាហរណ៍ រួមមានការផ្លាស់ប្តូរអាកាសធាតុ យ៉េនឌ័រ មេរោគអេដស៍។)

**crossing** /krɒsɪŋ/ [n] ការបង្កាត់

- back-crossing /bak ˈkrɒsɪŋ/ [n] បង្កាត់ត្រឡប់ (ការបង្កាត់កូន (ជាធម្មតាកូនកាត់) ជាមួយកូនមួយទៀតនៃប្រភេទមេបារបស់វា។ ការបង្កាត់ត្រឡប់ច្រើនដង គឺមានប្រសិទ្ធភាព ជាពិសេសក្នុងការផ្ទេរលក្ខណៈតំណពូជងាយៗ ឧ. លក្ខណៈធន់នឹងជំងឺ ផ្ទេរពីមេបាខ្លាំងមួយទៅមេបាខ្សោយ។)

- crossing over /ˈkrɒsɪŋ ˈəʊvə/ [n] បណ្ដូរខ្វែង, ការប្ដូរកំណាត់ក្រូម៉ាទីត (ការផ្លាស់ប្ដូរគ្នានៃកំណាត់ក្រូម៉ាទីតរវាងក្រូម៉ូសូមអូម៉ូឡូកនៅក្នុងដំណាក់ ធ្វើមេយ៉ូសបណ្ដាលឱ្យពន្ធុផ្គុំឡើងជាថ្មី)
- natural crossing /ˈnatʃ(ə)r(ə)l ˈkrɒsɪŋ/ [n] ការបង្កាត់ដោយធម្មជាតិ (ការបង្កាត់ដោយឯកឯងតាមធម្មជាតិ)

***Crossocheilus reticulatus*** [sci.n] ត្រីចង្វាជញ្ជក់

***Crotalaria juncea*** [sci.n] សូមមើលពាក្យ៖ sunhemp

***Crotalaria striata*** [sci.n] ស្មៅចង្រ្កង់ស្វា

**croup** /kruːp/ [n]

១. រោគឈឺបំពង់កទារក និងកូនក្មេង

២. កំប៉េះគូទសេះ

**crowbar** /ˈkrəʊbɑː/ [n] ដែកគាស់

**crumb** /krʌm/ [n] គ្រាប់ៗ (១-២ ម.ម)

- large crumb /lɑːdʒ krʌm/ [n] គ្រាប់ធំៗ (ធំជាង ៥ ម.ម)

**crumbing** /krʌmɪŋ/ [n] ការបែកជាកម្ទេចខ្សាច់

**crumbly** /ˈkrʌmbli/ [adj] កម្ទេច ឬដុំតូចៗ

**crust** /krʌst/ [n] ស្រទាប់ក្ដាំង, គ្រួត

- crust of earth /krʌst ɒv əːθ/ [n] សម្បក ឬគ្រួតផែនដី (ខាងក្រៅ)
- desert crust /dɪˈzəːt krʌst/ [n] ស្រទាប់ក្ដាំង (គ្រួត)
- dusty crust /ˈdʌsti krʌst/ [n] ការកើតនៃស្រទាប់លើផង់ ឬធូលីផង់
- ferruginous crust /fɛˈruːdʒɪnəs krʌst/ [n] ស្រទាប់ក្ដាំងកើតពីដែក
- gypsum crust /ˈdʒɪpsəm krʌst/ [n] ស្រទាប់ក្ដាំងម្នាងសិលា
- lime crust /lʌɪm krʌst/ [n] ស្រទាប់កំបោរក្ដាំង
- salt crust /sɔːlt krʌst/ [n] ស្រទាប់អំបិលក្ដាំង
- superficial crust /ˌsuːpəˈfɪʃ(ə)l krʌst/ [n] ស្រទាប់ក្ដាំងនៅស្រទាប់ខាងលើ
- thin laterite crust /θɪn ˈlatərʌɪt krʌst/ [n] សន្ទះរឹងនៃថ្មក្រួសបាយក្រៀម

**Crustacea** /krʌˈsteɪʃn/ [n] សិប្បីសត្វ, សិប្បីជាតិ

**cryophyte** /ˈkrʌɪə(ʊ)fʌɪt/ [n] ចំណូលត្រជាក់

**cryopreservation** /ˌkrʌɪəʊprɛzəˈveɪʃ(ə)n/ [n] ការរក្សាទុកជាលិកា និងគ្រាប់ពូជ (ការថែរក្សាទុកជាលិកា ឬគ្រាប់ពូជដើម្បីស្តុកទុកឱ្យបានយូរអង្វែង ក្នុងសីតុណ្ហភាពទាបបំផុត ប្រហែលជាក្នុងចន្លោះ ១៥០ - ១៩០ អង្សាសេ)

**cryosphere** /ˈkrʌɪəʊsfɪə/ [n] គ្រីយ៉ូស្វ៊ែ

**cryoturbation** /ˈkrʌɪə(ʊ)təː ˈbeɪʃ(ə)n/ [n]

១. ត្រជាក់ច្របល់កម្ម (ចលនារបស់កម្ទេចផែនដីកកដែលជាលទ្ធផលនៃកំណាទឹកកក)

២. ការច្របូកច្របល់ (ក្នុងដី)

**crypt-** /krɪpt/ [prefix] (សទិសន័យ៖ crypto-) បុព្វបទមានន័យថា ពួន ឬបិទបាំង

**crypto-** /ˈkrɪptəʊ/ [prefix] សូមមើលពាក្យ៖ crypt-

**cryptogam** /ˈkrɪptə(ʊ)gam/ [n] រុក្ខជាតិគ្មានផ្កា, គ្រីបតូកាម

**cryptophyte** /ˈkrɪptəʊfʌɪt/ [n] (សទិសន័យ៖ geophyte) រុក្ខជាតិក្រោមដី

**cryptorchid** /ˌkrɪpˈtɔːkɪd/ [n] ភាពមិនធ្លាក់ពងស្វាស

**Cryptosporidiosis** [n] ជំងឺបង្កដោយ Cryptosporidia

**crystal** /ˈkrɪst(ə)l/ [n] ក្រាម, គ្រិស្តាល់, ចរណៃ

**crystalization** /ˌkrɪstəlaɪˈzeɪ.ʃ(ə)n/ [n] ក្រាមកម្ម, គ្រិស្តាលើកម្ម

**CT scan** /siː tiː skan/ [n] (សូមមើលពាក្យ៖ computed tomorgraphy scan) ការថតឆ្លុះមើលជំពារចនាសម្ពន្ធជាលិកា(ការថតអិក្សរេម៉្យាង ដែលអនុញ្ញាតឱ្យគ្រូពេទ្យអាមើលនៅក្នុងពោះបាន)

***Ctenopharyngodon idella*** [sci.n] សូមមើលពាក្យ៖ grass carp

**Cuban oregano** [n] ជីរត្រចៀកជ្រូក

**cuboid** /ˈkjuːbɔɪd/ [n] សូមមើលពាក្យ៖ nutty structure

**cucumber** /ˈkjuːkʌmbə/ [n] ត្រសក់ផ្អ (ឈ្មោះវិទ្យាសាស្ត្រ *Cucumis sativus*)

**cucumber bacterial wilt** /ˈkjuːkʌmbə bakˈtɪərɪəl wɪlt/ [n] ជំងឺស្រពោនស្រស់លើដំណាំត្រសក់ដោយបាក់តេរី (ជំងឺនេះច្រើនកើតលើដំណាំ ត្រសក់ ម្ទេស ឪឡឹក ត្រប់ និងអំបូរដំណាំត្រសក់)

***Cucumis melo*** [sci.n] សូមមើលពាក្យ៖ musk melon

***Cucumis sativus*** [sci.n] សូមមើលពាក្យ៖ cucumber

***Cucumis vulgaris* var. div.** [sci.n] សូមមើលពាក្យ៖ gherkin

***Cucurbita maxima*** [sci.n] សូមមើលពាក្យ៖ pumpkin

***Cucurbita pepo*** [sci.n] សូមមើលពាក្យ៖ squash

**cub** /kʌb/ [n]
១. កូន (សត្វសិង្ហ ឬតោ, សត្វខ្លាឃ្មុំ, សត្វខ្លាព្រៃ, សត្វកញ្ជ្រោង)
២. ដុំអាហារ

**culantro** [n] (សទិសន័យ៖ fitweed) ជីរបារាំង, ជីរបន្លា, ជីរណារ (ឈ្មោះវិទ្យាសាស្ត្រ Eryngium foetidum)

**culex** /ˈkju:lɛks/ [n] គុយឡិច (អម្បូរមូសដែលរស់នៅតំបន់ត្រជាក់ដែលអាចចម្លងបរាសិត)

**culling** /kʌlɪŋ/ [n] (សទិសន័យ៖ roguing) ការដកប្រភេទលាយ, ការកាប់ដកហូត (ការកាប់ដករហូតជាប្រព័ន្ធនូវបណ្តាឯកត្តៈដែលគេមិនចង់បាន ដើម្បីថែរក្សាក្រុមពូជមួយឱ្យនៅបិតថេរជារៀងរហូត)

- independent culling /ɪndɪˈpɛnd(ə)nt kʌlɪŋ/ [n] ការបេះដោយសេរី (ឯករាជ្យ), ការប្រមូលដោយសេរី (ឯករាជ្យ), ការជ្រើសរើសដោយសេរី (ឯករាជ្យ) (ការជ្រើសរើសពហុលក្ខណៈដែលទាក់ទងនឹងការកំណត់តម្លៃអប្បមារសម្រាប់លក្ខណៈនីមួយៗនៃផលប្រយោជន៍។ បណ្តាឯកត្តៈត្រូវឆ្លើយតបនឹងលក្ខណៈវិនិច្ឆ័យអប្បមារ បើសិនពួកវាត្រូវបានគេរក្សាទុក។)

**culm** /kʌlm/ [n] ដើម (សរីរាង្គនៃរុក្ខជាតិមានរាងមូល ផ្ទៃរលោងដុះឡើងលើមានចន្លោះថ្នាំងភ្ជាប់ដោយផ្នែករឹងគឺថ្នាំង ឧ. ដើមស្រូវ)

**culting** /kʌltɪŋ/ [n] (សទិសន័យ៖ excavation) ដីដែលគេជីកយកអាចម៍ដី

**cultivar** /ˈkʌltɪvɑ:/ [n] ពូជ, ប្រភេទគ្រាប់ដែលបានបណ្តុះទុក, ពូជដំណាំ

- stress-tolerant cultivars /strɛs ˈtɒl(ə)r(ə)nt ˈkʌltɪvɑ:z/ [n pl] ពូជដំណាំដែលធន់នឹងស្ត្រេស (ឧ. ភាពរាំងស្ងួត, ទឹកជំនន់, សីតុណ្ហភាព)
- tolerant cultivar /ˈtɒl(ə)r(ə)nt ˈkʌltɪvɑ:/ [n] ពូជអត់ទ្រាំ, ពូជធន់ (ពូជដែលអាចអត់ទ្រាំនឹងការបំផ្លាញរបស់សត្វល្អិត ឬបរិយាកាសមិនល្អដោយគ្មានថយចុះ ឬបាត់បង់ទិន្នផល)

**cultivation** /kʌltɪˈveɪʃn/ [n] ការដាំដំណាំ, ការរៀបចំដី (សម្រាប់ដាំ), ការដាំ ការថែរក្សា និងការប្រមូលផល, ការចិញ្ចឹម (ត្រី)

- crop cultivation /krɒp kʌltɪˈveɪʃn/ [n] វប្បកម្មដំណាំ
- shifting cultivation /ˈʃɪftɪŋ kʌltɪˈveɪʃn/ [n] សូមមើលពាក្យ៖ swidden cultivation
- swidden cultivation /ˈswɪd(ə)n kʌltɪˈveɪʃn/ [n] (សទិសន័យ៖ slash and burn agriculture, shifting cultivation) ការធ្វើកសិកម្មព្រៃដុត, ការធ្វើកសិកម្មនេចរ, ការដាំដុះមានលក្ខណៈជារង្វិលជុំ

**cultivator** /ˈkʌltɪveɪtə/ [n] អ្នកបណ្តុះ, កសិករ, អ្នកស្រែ

**culture** /ˈkʌltʃə/ [n]
១. វប្បកម្ម (ការដាំដុះរុក្ខជាតិ ឬចិញ្ចឹមសត្វ)
២. វប្បធម៌ (របបរស់នៅ គំនិត ទំនៀមទំលាប់សិល្បៈ និងអារ្យធម៌របស់ជនជាតិមួយ)

- anther culture /ˈanθəˈkʌltʃə/ [n] លម្អងវប្បកម្ម (វិធីសាស្ត្រមួយនៅក្នុងជម្រើសវិទ្យា ដែលយកលម្អងទៅបណ្តុះឱ្យទៅជារុក្ខជាតិថ្មីមួយទៀត)
- batch culture /batʃ ˈkʌltʃə/ [n] ប្រព័ន្ធបិទ
- continuous culture /kənˈtɪnjʊəs ˈkʌltʃə/ [n] ប្រព័ន្ធបើក (វិធីបណ្តុះអតិសុខុមប្រាណ)
- culture medium /ˈkʌltʃə ˈmi:dɪəm/ [n] វប្បសារធាតុ (សារធាតុសិប្បនិម្មិតដែលបានរៀបចំឡើងសម្រាប់បណ្តុះមីក្រូសរីរាង្គដូចជា ពពួកបាក់តេរីជាដើម)
- enrichment culture /ɛnˈrɪtʃm(ə)nt ˈkʌltʃə/ [n] ការបណ្តុះឱ្យបានច្រើន
- fish culture /fɪʃ ˈkʌltʃə/ [n] មច្ឆវប្បកម្ម (ការចិញ្ចឹមត្រីតាមបច្ចេកទេសជាក់លាក់ណាមួយ)
- food culture /fu:d ˈkʌltʃə/ [n] វប្បធម៌ក្នុងការប្រើប្រាស់ស្បៀង ឬផលិតស្បៀង (ការចែករំលែកចំណេះដឹង ឥរិយាបថ ការប្រព្រឹត្តអាកប្បកិរិយា និងប្រពៃណីនៅជុំវិញរឿងចំណីអាហារជាក់លាក់ចំពោះក្រុមប្រពៃណីវប្បធម៌ពិសេស។)
- meristem culture /ˈmɛrɪstɛm ˈkʌltʃə/ [n] កាបណ្តុះជាលិកាសកម្ម, ការបណ្តុះជាលិកាលូតលាស់, កាបណ្តុះសរីរាង្គលូតលាស់
- rice culture /rʌɪs ˈkʌltʃə/ [n] ស្រូវវប្បកម្ម

- tissue culture /ˈtɪʃuː ˈkʌltʃə/ [n] ជាលិកាវប្បកម្ម, ការបណ្ដុះកូនឈើពីជាលិកា (ការបណ្ដុះជាលិកាឱ្យក្លាយទៅជាសរីរាង្គថ្មីមួយ ដែលមានលក្ខណៈ ឬសេណូទីបដូចសរីរាង្គមេ)

**cuneate** /ˈkjuːnɪət/ [adj] រាងស្លួច (អំពីស្លឹក)

**cuneiform** /ˈkjuːnɪfɔːm/ [adj] រាងស្លួចស្ដើងគល់ (អំពីស្លឹក)

**cupula** [n] ផ្លែរាងដូចកូនពែង, មានរាងដូចកូនពែង គំរបរបស់ផ្លែនៃអំបូរ Fagaceae ឧ. Quercus, Fagus និង Castanopsis spp។

**curd** /kəːd/ [n] ទឹកដោះកក, ទឹកដោះខន់(កកតែនៅទន់), ទឹកដោះជូរ,

**cure** /kjɔː/ [v] ព្យាបាល, សះស្បើយ

**cure** /kjʊə/ [n] ឱសថ, គ្រឿងប្រឡាក់, វិធី ឬការធ្វើឱ្យជា (អារោគ្យកម្ម)

**curettage** /ˌkjʊərɪˈtɑːʒ/ [n] កំណោស, ការកោសសរីរាង្គ, ការខ្វារសំអាត

**Curium** /ˈkjʊərɪəm/ [n] គុយរ្យ៉ូម (និមិត្តសញ្ញាគីមី Cm)

**current** /ˈkʌr(ə)nt/ [n] ចរន្ត, ខ្សែទឹក

- current account /ˈkʌr(ə)nt əˈkaʊnt/ [n] គណនីចរន្ត
- littoral current /ˈlɪt(ə)r(ə)l ˈkʌr(ə)nt/ [n] ខ្សែទឹកស្របឆ្នេរ
- ocean current /ˈəʊʃ(ə)n ˈkʌr(ə)nt/ [n] ខ្សែទឹកសមុទ្រ
- river current /ˈrɪvə ˈkʌr(ə)nt/ [n] ចរន្ត ឬខ្សែទឹកទន្លេ
- sea current /siː ˈkʌr(ə)nt/ [n] ខ្សែទឹកសមុទ្រ

**curriculum** /kəˈrɪkjʊləm/ [n] កម្មវិធីសិក្សា (ការកំណត់អំពីរយៈពេលវិធីសាស្ត្រ និងយុទ្ធវិធីសម្រាប់បង្រៀននៅក្នុងកម្មវិធីសិក្សាណាមួយ)

**cursorial** /kəːˈsɔːrɪəl/ [adj] ជំនាញខាងរត់

***Cuscuta maritima*** [sci.n] សូមមើលពាក្យ៖ dodder

**cusp** /kʌsp/ [n] ចុងស្រួច

**cuspidate** /ˈkʌspɪdeɪt/ [adj] ចុងស្រួច ((អំពីស្លឹក) កាន់តែស្រួចទៅៗ), ទម្រង់ចុងស្លឹកចុងស្រួច

**custard apple** /ˈkʌstəd ˈap(ə)l/ [n] ទៀបខ្មែរ (ឈ្មោះវិទ្យាសាស្ត្រ *Annona squamosa*)

**cut** /kʌt/ [v] សូមមើលពាក្យ៖ harvest

**cut down** /kʌt daʊn/ [n] ការរះស្បែករកសរសៃឈាមដើម្បីបញ្ចូលវត្ថុរាវ

**cutaneous** /kjuːˈteɪnɪəs/ [adj] នៃស្បែក, ដែលប៉ះពាល់ដល់ស្បែក

**cutinization** /ˈkjuːtɪnʌɪˈzeɪʃ(ə)n/ [n] សារធាតុថ្លាមិនជ្រាបទឹក (សារធាតុមិនជ្រាបទឹក សារធាតុថ្លាស្ថិតនៅលើ ឬក្នុងស្រទាប់ខាងក្រៅនៃកោសិកាជញ្ជាំងនៅលើផ្ទៃគ្រាប់ ស្លឹក និង ដើម ឬមែកខ្ចី។)

**cutleaf groundcherry** /ˈkʌtliːf graʊndˈtʃɛri/ [n] ប៉េងប៉ោះស្រោម (ឈ្មោះវិទ្យាសាស្ត្រ *Physalis angulata*)

**cut-off** /kʌt ɒf/ [n] ជ្រលងចាស់នៃស្ទឹង

**cuttage** /ˈkʌtɪdʒ/ [n] ការកាត់បណ្ដុះ

**cutting** /kʌtɪŋ/ [n]

១. ខ្នាត់បណ្ដុះ, ការកាត់ផ្សាំ, ការកាត់បំបៅ, មែកដែលត្រូវបានកាត់ដើម្បីយកទៅដាំបន្ត (ការធ្វើឱ្យដុះឡើងវិញ តាមរយៈពន្លក មែក ឬផ្នែកផ្សេងៗរបស់រុក្ខជាតិដើម្បីបង្កើតរុក្ខជាតិថ្មីៗ)

២. ការកាប់រំលំ (ការកាប់រំលំដើមឈើនីមួយៗ)

៣. សូមមើលពាក្យ៖ harvest

- clear cutting /klɪə kʌtɪŋ/ [n] ការកាប់ទាំងអស់
- hardwood cutting /ˈhɑːdwʊd ˈkʌtɪŋ/ [n] ការកាត់មែកសម្រាប់បណ្ដុះកូនឈើ
- nodal cutting /ˈnəʊd(ə)l ˈkʌtɪŋ/ [n] ការកាត់ពក, ការកាត់ថ្នាំង, ការកាត់ភ្នែក (ការកាត់ផ្នែកតូចមួយដែលមានស្លឹកមួយ និងចំពាមពន្លកត្រួយមួយ (មួយថ្នាំង))
- root cutting /ruːt ˈkʌtɪŋ/ [n] ការកាត់ឫសផ្សាំ
- selection cutting /sɪˈlɛkʃ(ə)n ˈkʌtɪŋ/ [n] ការកាប់ជ្រើស
- uncontrolled cutting /ʌnkənˈtrəʊldˈkʌtɪŋ/ [n] ការកាប់ឈើដោយគ្មានការត្រួតពិនិត្យ
- cutting back /ˈkʌtɪŋ bak/ [n] (សទិសន័យ៖ upstream migration) ការធ្វើចរលហូរច្រោះពីក្រោមទៅលើ

**cutworm** /ˈkʌtwəːm/ [n] ដង្កូវកាត់ស្លឹក (ឈ្មោះវិទ្យាសាស្ត្រ *Spodoptera litura*)

**cyanobacteria** /ˌsʌɪənəʊbakˈtɪərɪə/ [n] ស្យាណូបាក់តេរី (កាលពីដើមគេហៅសារាយបៃតងចាស់)

**cyanocobalamin** /sʌɪənə(ʊ)kəˈbaləmɪn/ [n] សូមមើលពាក្យ៖ cobalamin

**cyanophyte** /ˈsʌɪənə(ʊ)fʌɪt/ [n] សៃដែលផលិតអុកស៊ីសែន

**cyanosis** /ˌsʌɪəˈnəʊsɪs/ [n] ភាពឡើងពណ៌ស្វាយ (ស្បែកឡើងស្វាយ ព្រោះខ្វះខ្យល់អុកស៊ីសែនក្នុងឈាម)

***Cyanotis axillaris*** [sci.n] សូមមើលពាក្យ៖ creeping cradle plant

**cycl-** [prefix] (សទិសន័យ៖ cyclo-) បុព្វបទមានន័យថា វង់ ឬមូល

**cycle** /ˈsʌɪk(ə)l/ [n] វដ្ត, ខួប

- biogeochemical cycle /ˈbʌɪəʊˌdʒiːəʊˈkɛmɪk(ə)l ˈsʌɪk(ə)l/ [n] វដ្តជីវភូគព្ភគីមី
- biological cycle /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˈsʌɪk(ə)l/ [n] វដ្តជីវសាស្ត្រ
- calcium cycle /ˈkalsɪəm ˈsʌɪk(ə)l/ [n] វដ្តកាល់ស្យូម
- carbon cycle /ˈkɑːb(ə)n ˈsʌɪk(ə)l/ [n] វដ្តកាបូន
- cell cycle /sɛl ˈsʌɪk(ə)l/ [n] វដ្តកោសិកា
- disease cycle /dɪˈziːz ˈsʌɪk(ə)l/ [n] វដ្តជំងឺ (លំដាប់លំដោយនៃព្រឹត្តិការណ៍ដែលកើតឡើងនៅចន្លោះពេលដែលជំងឺចេញជាធាតុសញ្ញា)
- hydrologic cycle /hʌɪdrəˈlɒdʒɪk ˈsʌɪk(ə)l/ [n] វដ្តធារាសាស្ត្រ, វដ្តទឹក, វដ្តជលសាស្ត្រ
- life cycle /lʌɪf ˈsʌɪk(ə)l/ [n] វដ្តជីវិត (វគ្គលូតលាស់ និងវិវត្តន៍របស់ជីវករដែលចាប់ផ្ដើមពីចេញរូបរាងរហូតដល់ស្លាប់)
- nitrogen cycle /ˈnʌɪtrədʒ(ə)n ˈsʌɪk(ə)l/ [n] វដ្តអាសូត (បម្លាស់ប្ដូរជាបន្តបន្ទាប់ដោយលក្ខណៈគីមីរបស់អាសូត ឬសមាសធាតុអាសូតដែលត្រូវបានប្រព្រឹត្តឡើងនៅក្នុងដី។ ក្នុងធម្មជាតិអាសូតតែងប្លែងពីអាសូតសេរីក្នុងខ្យល់ទៅជាអាសូតក្នុងដីដោយសារពួកបាក់តេរីនៃរុក្ខជាតិពួកសណ្ដែកចាប់យក។ លុះពួករុក្ខជាតិ ឬសត្វស្លាប់រលួយ អាសូតនោះ ក៏ក្លាយជាអាសូតអ៊ី។ នៅក្នុងដីពួកបាក់តេរីនៃដីក៏បំបែកសមាសធាតុអាសូតទៅជាអាសូតសេរី លុះពេលព្យុះភ្លៀង ផ្លេកបន្ទោរធ្វើឱ្យអាសូតផ្សំជាមួយអុកស៊ីសែន រួមជាមួយទឹកក្លាយទៅជាអាស៊ីតនីទ្រិច។ អាស៊ីតនីទ្រិចក្នុងទឹកភ្លៀងចូលផ្សំជាមួយអង្គធាតុដទៃក្លាយជាអាសូតអ៊ី (អំបិលអាម៉ូញូមនីត្រាត)។
- nutrient cycle /ˈnjuːtrɪənt ˈsʌɪk(ə)l/ [n] វដ្តសារធាតុចិញ្ចឹម, វដ្តជីវភូគព្ភគីមី
- oestrous cycle /ˈiːstrəs ˈsʌɪk(ə)l/ [n] វដ្តកម្តៅ
- oxygen cycle /ˈɒksɪdʒ(ə)n ˈsʌɪk(ə)l/ [n] វដ្តអុកស៊ីសែន
- phosphorus cycle /ˈfɒsf(ə)rəs ˈsʌɪk(ə)l/ [n] វដ្តផូស្វរ
- sulfur cycle /ˈsəlfər ˈsʌɪk(ə)l/ [n] វដ្តស្ពាន់ធ័រ
- tidal cycle /ˈtʌɪd(ə)l ˈsʌɪk(ə)l/ [n] ខួបទឹកជោរ, ខួបជំនោរលំនាច
- water cycle /ˈwɔːtə ˈsʌɪk(ə)l/ [n] វដ្តទឹក

**cyclo-** /ˈsʌɪkləʊ/ [prefix] សូមមើលពាក្យ៖ cycl-

***Cyclocheilichthys apogon*** [sci.n] សូមមើលពាក្យ៖ beardless barb

***Cyclocheilichthys armatus*** [sci.n] ត្រីផ្កាគ

***Cyclocheilichthys enoplos*** [sci.n] ត្រីឆ្កោក

***Cyclocheilichthys furcatus*** [sci.n] ត្រីឆ្កោកភ្លើង

***Cyclocheilichthys heteronema*** [sci.n] ត្រីឆ្កោកពុតមាត់បី

***Cyclocheilichthys lagleri*** [sci.n] ត្រីស្រកាក្ដាម

***Cyclocheilichthys microlepis*** [sci.n] ត្រីអង្កត់ប្រាក់

***Cyclocheilichthys repasson*** [sci.n] ត្រីស្រកាក្ដាម

**cyclone** /ˈsʌɪkləʊn/ [n]
១. (សទិសន័យ៖ cyclonic storm) ព្យុះស៊ីក្លូន
២. មណ្ឌលសម្ពាធខ្សោយ

**cyclophysis** /ˈsʌɪklɒps/ [n] ភាពឡើងចាស់នៃកំពូល meristem

**axis cylinder** /ˈaksɪs ˈsɪlɪndə/ [n] ស៊ីឡាំងអ័ក្ស, អាក់សូន

**cylinder** /ˈsɪlɪndə/ [n] សឺមី (ស៊ីឡាំងចលករ) (ស៊ីឡាំងនៃចលករដែលពិស្តុងធ្វើចលនាខាងក្នុង), បំពង់ច្រក, រម្ភាការ

**cylinder head** /ˈsɪlɪndə hɛd/ [n] គម្របគុយឡាស់ (ផ្នែកមួយនៃចលករដែលគ្របលើសឺមី និងពិស្តុង)

***Cymbopogon citratus*** [sci.n] សូមមើលពាក្យ៖ lemon grass

**cyme** /sʌɪm/ [n] កញ្ចុំផ្កា, ផ្កាចង្កោមកញ្ចុំចុង

**cymose** /ˈsʌɪməʊs/ [adj] នៃកញ្ចុំផ្កា

***Cynodon dactylon*** [sci.n] ស្មៅចិញ្ចៀន

***Cynodon dactylon*** [sci.n] សូមមើលពាក្យ៖ bermuda grass

***Cynoglossus bilineatus*** [sci.n] សូមមើលពាក្យ៖ four-line tonguesole

***Cynoglossus cynoglossus*** [sci.n] សូមមើលពាក្យ៖ gangetic tonguesole

***Cynoglossus feldmanni*** [sci.n] សូមមើលពាក្យ៖ river tonguesole

***Cynoglossus lingua*** [sci.n] សូមមើលពាក្យ៖ long tonguesole

***Cynoglossus microlepis*** [sci.n] សូមមើលពាក្យ៖ smallscale tonguesole

***Cynoglossus punticeps*** [sci.n] សូមមើលពាក្យ៖ mottled tonguesole

***Cynoglossus trulla*** [sci.n] ត្រីអណ្ដាតឆ្កែ

***Cyperus difformis*** [sci.n] សូមមើលពាក្យ៖ smallflower umbrella sedge

***Cyperus iria*** [sci.n] សូមមើលពាក្យ៖ rice flat sedge

***Cyperus rotundus*** [sci.n] សូមមើលពាក្យ៖ purple nutsedge

***Cyprinus carpi*** [sci.n] សូមមើលពាក្យ៖ common carp

***Cyprinus carpio*** [sci.n] ត្រីកាបសាមញ្ញ

***Cyrtorhinus lividipennis*** [sci.n] ស្រឹងគោក

**cyst** /sɪst/ [n] គីស, ពក, ប្លោក, ថង់ភ្នាសបិទជិតដែលមានវត្ថុរាវ (ឬខ្យល់នៅក្នុង)

**cystectomy** /sɪsˈtɛktəmi/ [n] ការវះកាត់យកពក ឬប្លោកចេញ

**cysticercus** /ˌsɪstɪˈsəːkəs/ [n] (ពហុវចនៈ៖ cysticerci) គ្រាប់អង្ករតេញ៉ា

**cystitis** /sɪˈstʌɪtɪs/ [n] រលាកប្លោកនោម

**cysto** /ˈsɪstəʊ/ [n] មុត្តាស័យ, ពក, ប្លោក, ថង់

**cystocele** /ˈsɪstəʊsiːl/ [n] ក្លូនលូននៃមុត្តាស័យ

**cystography** /ˈsɪstəʊgrəfi/ [n] ការពិនិត្យមើលប្លោកនោមដោយប្រើរស្មីអិក្ស

**cyto** /ˈsʌɪtəʊ/ [prefix] កោសិកា

**cytochemical** /ˈsʌɪtəʊˈkemikəl/ [adj] នៃគីមីកោសិកា

**cytochemistry** /ˌsʌɪtəʊˈkɛmɪstri/ [n] កោសិកាគីមីវិទ្យា, គីមីកោសិកា

**cytogenesis** /ˌsʌɪtəʊˈjenəsəs/ [n] ការបង្កើតជាផលកោសិកា

**cystoscope** /ˈsɪstəskəʊp/ [n] មុត្តាស័យទស្ស, ការឆ្លុះពិនិត្យមើល មុត្តាស័យ និងបំពង់ទឹកនោម

**cytogenetics** /ˌsʌɪtəʊdʒəˈnɛtɪks/ [n] ការសិក្សាពីពន្ធុក្នុងកោសិកា, សេនេទិចកោសិកា (ការសិក្សាអំពីសេនេទិចរបស់កោសិកា ពោលគឺលក្ខណៈរបស់ក្រូម៉ូសូមដែលទាក់ទងទៅនឹងភាពអា ឬក្រូម៉ូសូមខូច ដែលទាក់ទងទៅនឹងការប្ដូរ បន្ទាប់ពីវងពន្លឺវិទ្យុសកម្ម។)

**cytogenetics** /ˌsʌɪtəʊdʒəˈnɛtɪks/ [n] កោសិកាវង្សត្រកូល, កោសិកាគមន៍វិទ្យាសាស្ត្រ

**cytogeny** /ˌsʌɪtəʊˈdʒəni/ [n] ផលកោសិកា

**cytokinesis** /ˌsʌɪtəʊkʌɪˈniːsɪs/ [n] ចំណែកស៊ីតូប្លាស

**cytology** /sʌɪˈtɒlədʒi/ [n] កោសិកាវិទ្យា (ការសិក្សាពីកោសិកាពោលគឺ រចនាសម្ព័ន្ធ តួនាទី ការវិវឌ្ឍន៍ និងការបន្តពូជរបស់វាទាក់ទងនឹងការលូតលាស់ ការបំបែក និងតំណពូជ)

**cytolysis** /sʌɪˈtɒlɪsɪs/ [n] កោសិការំលាយកម្ម

**cytolytic** /ˌsʌɪtəˈlɪtɪk/ [n] ដែលរំលាយកោសិកា

**cytomegalic** /ˌsʌɪtə(ʊ)mɪˈgalɪk/ [n] មហារីកកោសិកា, កោសិកាដែលរីកធំឡើង

**cytomegalovirus** /ˌsʌɪtə(ʊ)ˈmɛg(ə)lə(ʊ)ˌvʌɪrəs/ [n] វីរុសដែលធ្វើឱ្យកោសិកា រីកធំឡើង ឬធ្វើឱ្យឈាមស្ទះ

**cytomegalovirus (CMV)** /ˌsʌɪtə(ʊ)ˈmɛg(ə)lə(ʊ)ˌvʌɪrəs/ [n] រោគវីរុស ក្នុងក្រពេញកោសិកាឈាមមនុស្ស

**cytophagy** /ˈsʌɪtəʊfədʒi/ [n] ការរំងាប់កោសិកាផ្សេងៗ

**cytophatic** /ˈsʌɪtəʊˈfatɪk/ [adj] នៃកោសិកាវិភេទ

**cystoscopy** /sɪˈstɒskəpi/ [n] ការពិនិត្យមើលប្លោកនោម ដោយប្រើបំពង់មានពន្លឺភ្លើងនៅខាងចុង

**cytophotometric** /ˌsʌɪtəfəʊtəˈmɛtrɪk/ [adj] នៃកោសិការូបមាត្រ

**cystostomy** /sɪˈstɒtəmi/ [n] ការវះបើកមុត្កាស័យ

**cytophotometry** /ˌsʌɪtə(ʊ)fə(ʊ)ˈtɒmɪtri/ [n] កោសិការូបមាត្រ

**cytoplasm** /ˈsʌɪtə(ʊ)plaz(ə)m/ [n] ស៊ីតូប្លាស

**cytoplasmic** /sʌɪtə(ʊ)ˈplazmɪk/ [adj] នៃកោសិកាលោហិត

**cytoplast** / ˈsʌɪtə(ʊ)ˌplast/ [n] កោសិកាលោហិតនីមួយៗ

**cytoskeleton** /ˈsʌɪtəʊˌskɛlɪt(ə)n/ [n] គ្រោងឆ្អឹងកោសិកា

**cytosol** /ˈsʌɪtə(ʊ)sɒl/ [n] សាយតូសូល (ជាផ្នែកដែលអាចរលាយបាននៃស៊ីតូប្លាស នៅពេលដែលរចនាសម្ពន្ធកោសិកាទាំងអស់ និងបណ្តាភាគល្អិតត្រូវបានដកចេញដោយបំបែកធាតុ)

**cytotaxonomy** /ˈsʌɪtə(ʊ) takˈsɒnəmi/ [n] ក្រុម៉ូចំណែកថ្នាក់, វគ្គីសរីរៈតាមពួកកោសិកា(ការបែងចែកសរីរៈនៃកោសិកាតាមថ្នាក់ ពួក ឬក្រុម)

**cytotechnologist** /ˈsʌɪtəʊtɛkˈnɒlədʒi/ [n] អ្នកដែលមានបច្ចេកទេសខាងកោសិកាលោហិត, អ្នកពិនិត្យមើលកោសិកាលោហិតចំឡែក

**cytotoxin** /ˈsʌɪtəʊˈtɒksɪn/ [n] ជាតិពុលកោសិកា

**D**

***Dactyloctenium aegyptium*** [sci.n] សូមមើលពាក្យ៖ crowfoot grass

**daikon** /ˈdʌɪk(ə)n/ [n] ឆៃថាវ (ឈ្មោះវិទ្យាសាស្ត្រ *Raphanus sativus* var. *longipinnatus*)

**dam** /dam/ [n]

១ . (សទិសន័យ៖ dike, levee) ទំនប់ទឹក, ធ្នូស, ភ្លឺ

២. (ចំពោះសត្វ) សូមមើលពាក្យ៖ mother

- brush dam /brʌʃ dam/ [n] ទំនប់ទឹកធ្វើដោយមែកឈើ (កុំឱ្យដីបាក់)
- check dam /tʃɛk dam/ [n] ទំនប់ជាបន្ទះស៊ូប៉ាប
- earth dam /əːθ dam/ [n] ទំនប់ទឹកធ្វើពីដី
- irrigation dam /ˈɪrɪgeɪʃ(ə)n dam/ [n] ទំនប់ទឹកសម្រាប់ស្រោចស្រព
- porous dam /ˈpɔːrəs dam/ [n] ទំនប់ទឹកអាចជ្រាបបាន (ធ្វើពីមែកឈើ)

**damage** /ˈdamɪdʒ/ [n] ការបាត់បង់, ការខូចខាត (ការរងរបួស ឬបែកបាក់ដែលមាននៅលើរបស់មាន និងគ្មានជីវិត)

- deadheart damage /dɛdhɑːt ˈdamɪdʒ/ [n] ងាប់បណ្ដូល (ការងាប់បណ្ដូលនៃដើមស្រូវជាលទ្ធផលនៃការបំផ្លាញរបស់ដង្កូវស៊ីរូងដើមនៅដំណាក់កាលបែកគុម្ព)
- direct damage /dɪˈrɛkt ˈdamɪdʒ/ [n] ការខូចខាតផ្ទាល់ (ការខូចខាតនៃរុក្ខជាតិដោយសត្វល្អិតស៊ី ឬជញ្ជក់ផ្ទាល់)
- ecological damage /iːkəˈlɒdʒɪk(ə)l ˈdamɪdʒ/ [n] ការខូចខាតអេកូឡូស៊ី
- flood damage /flʌdˈdamɪdʒ/ [n] ការខូចខាតដោយទឹកជំនន់

**damping off** /dampɪŋ ɒf/ [n]

១. (ចំពោះបន្លែ) ជំងឺរលាកគល់លើសំណាប (ជំងឺបង្កដោយផ្សិត Rhizoctornia solani)។

២. ការជាំទឹកស្លាប់របស់កូនសំណាប, ជំងឺរបស់កូនឈើ ធ្វើឱ្យកូនឈើងាប់ដោយសារការដក់ទឹកដែលធ្វើឱ្យមានផ្សិតច្រើនប្រភេទកើតលើរុក្ខជាតិ

damping-off disease /dampɪŋ ɒf dɪˈziːz/ [n] ជំងឺរលួយគល់សំណាប (ជំងឺដែលបង្កឡើងដោយផ្សិតមួយប្រភេទ ឬច្រើនប្រភេទ ហើយរោគសញ្ញាវា គេអាចមើលឃើញ ប្រសិនបើគេសង្កេតលើគល់នៃកូនសំណាប ដែលជាប់ទៅនឹងគ្រាប់ស្រូវ គេឃើញមានសរសៃៗផ្សិតសដូចសំឡី)

**damselfly** /ˈdamz(ə)lflʌɪ/ [n] កន្ទុំរុយ

**dandruff** /ˈdandrʌf/ [n] អង្គែសក់

**danger** /ˈdeɪn(d)ʒə/ [n] គ្រោះថ្នាក់

**dangerous** /ˈdeɪn(d)ʒ(ə)rəs/ [adj] ដែលមានគ្រោះថ្នាក់

***Dangila lineata*** [sci.n] ត្រីខ្នងវែង

***Dangila* sp. cf. *cuvieri*** [sci.n] ត្រីខ្នងវែង

***Dangila spilopleura*** [sci.n] ត្រីអាចម៍កុក

***Danio aequipinnatus*** [sci.n] ត្រីចង្វា

**dapog** /dapɒg/ [n] ថ្នាលដាប៉ុក (វិធីសាស្ត្រសាបស្រូវនៅលើស្លឹកចេក ឬលើស៊ីម៉ង់ត៍ ឥដ្ឋ ដោយមានដង់ស៊ីតេសំណាបខ្ពស់។ គេអាចធ្វើនៅលើដីលើថ្នាក្បែរផ្ទះ ឬថ្នាលដីធម្មតាទំហំពី ១៥ ម៉ែត្រការ៉េទៅ ២៥ ម៉ែត្រការ៉េ/ហិចតា ដោយក្រាលស្លឹកចេកពីក្រោម ហើយងាយមូររាដូចកន្ទេលពេលយកទៅស្ទូង។ រយៈពេលសំណាបនោះអាយុពី ៩ ទៅ ១៤ ថ្ងៃ។)

**Darmstadtium** /dɑːmˈstatɪəm/ [n] ដាមស្តាត្យូម (និមិត្តសញ្ញាគីមី Ds)

**darwinism** /ˈdɑːwɪnɪz(ə)m/ [n] ដាវីននិយម

**data** /ˈdeɪtə/ [n] ទិន្នន័យ (ស៊េរីនៃការតាមដានរង្វាស់ ឬហេតុការណ៍ ឬជាព័ត៌មានដែលទទួលបាន)

- environmental data /ɪnvʌɪrənˈmɛnt(ə)l ˈdeɪtə/ [n] ទិន្នន័យបរិស្ថាន
- field data /fiːldˈdeɪtə/ [n] ទិន្នន័យពីទីកន្លែង
- food data /fuːd ˈdeɪtə/ [n] ទិន្នន័យស្បៀង (សូចនាករណាមួយដែលពាក់ព័ន្ធទៅនឹងចំណីអាហារ។ គេអាចរាប់បញ្ចូលទាំងទិន្នន័យមកពីផ្នែកផ្សេងៗដូចជាកសិកម្ម សេដ្ឋកិច្ច ពាណិជ្ជកម្ម និងឧស្សាហកម្ម អាហារូបត្ថម្ភសុខភាព សាធារណៈ ទឹកស្អាត និងអនាម័យ ហើយនឹងបរិស្ថាន។)
- ground truth data /graʊnd truːθˈ deɪtə/ [n] ទិន្នន័យផ្ទៀងផ្ទាត់លើដី
- initial data /ɪˈnɪʃ(ə)ˈdeɪtə/ [n] ទិន្នន័យដើម, ទិន្នន័យដំបូង

- numerical data /njuːˈmɛrɪk(ə)l ˈdeɪtə/ [n] ទិន្នន័យជាលេខ
- observational data /ɒbzəˈveɪʃ(ə)n(ə)lˈdeɪtə/ [n] ទិន្នន័យសង្កេតពិនិត្យ
- primary data /ˈprʌɪm(ə)ri ˈdeɪtə/ [n] ទិន្នន័យបឋម ឬដំបូង, ទិន្នន័យអង្កេត (ទិន្នន័យដែលប្រមូលបានដំបូងពីប្រជាជនគោលដៅ។ ទិន្នន័យដំបូង អាចនឹងត្រូវបានគេប្រើប្រាស់វិធីសាស្ត្រចម្រុះរួមមាន ការសម្ភាសន៍ និងកម្រងសំណួរដែលពាក់ព័ន្ធទៅនឹងអ្នកផ្តល់ព័ត៌មានគន្លឹះសំខាន់ៗ ក្រុមដែលយើងត្រូវផ្តោតការយកចិត្តទុកដាក់ គ្រួសារ និងបុគ្គល។)
- qualitative data /ˈkwɒlɪtətɪv ˈdeɪtə/ [n] ទិន្នន័យតាមបែបគុណភាព (គឺជាការសង្កេតដើម្បីរកមើលពីប្រភេទលក្ខណៈជាជាងរកមើលពីចំនួន។ ជាទូទៅ វាពាក់ព័ន្ធទៅនឹងឥរិយាបថ ឬអាកប្បកិរិយា ការយល់ដឹង និងបំណងប្រាថ្នា។ ទិន្នន័យតាមបែបគុណភាព ជារឿយៗអាចឱ្យជួយយល់ដឹងពីបរិបទនៃរឿងរ៉ាវសំខាន់ៗ។)
- quantitative data /ˈkwɒntɪtətɪv ˈdeɪtə/ [n] ទិន្នន័យតាមបែបបរិមាណ (ជាការវាស់វែងអំពីបរិមាណចំនួន ឬក៏លំដាប់ ដែលបញ្ជាក់ជាលេខដែលគេអាចនឹងវិភាគដោយប្រើប្រាស់វិធីសាស្ត្រ និងគំរូតាមបែបស្ថិតិ។ ទិន្នន័យតាមបែបបរិមាណចង្អុលបង្ហាញអំពីចំនួនដាច់ខាត និងភាគរយនៃ៤៦ប្រជាជនដែលបានរួមចំណែកនូវលក្ខណៈជាក់លាក់ពិសេសទូទៅ។)
- secondary data /ˈsɛk(ə)nd(ə)ri ˈdeɪtə/ [n] ទិន្នន័យដែលមានស្រាប់, ទិន្នន័យដែលអាចរកបានស្រាប់ៗ (ទិន្នន័យដែលប្រមូលបាននៅខាងក្រៅពីដំណើរការនៃការចុះធ្វើការអង្កេត ឬចុះវាយតម្លៃដោយផ្ទាល់ តាមធម្មតាគឺទទួលបានពីការបោះពុម្ពផ្សាយ ឬបើមិនដូច្នេះទេ គឺបានពីប្រភពដែលអាចរកបានជាសាធារណៈ)
- data analysis /ˈdeɪtə əˈnalɪsɪs/ [n] ការវិភាគទិន្នន័យ
- data collection /ˈdeɪtə kəˈlɛkʃ(ə)n/ [n] ការប្រមូលទិន្នន័យ
- data entry /ˈdeɪtə ˈɛntri/ [n] ការបញ្ចូលទិន្នន័យ
- data management /ˈdeɪtə ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងទន្និន័យ
- data network /ˈdeɪtə ˈnɛtwəːk/ [n] បណ្តាញទិន្នន័យ

**data sheet** /ˈdeɪtə ʃiːt/ [n] តារាងទិន្នន័យ

- data source /ˈdeɪtə sɔːs/ [n] ប្រភពទិន្នន័យ

**date** /deɪt/ [n]

១. (សទិសន័យ៖ date palm) លម៉ើ(ដើមប្រភេទដូងដែលដាំនូវតំបន់វាលខ្សាច់នៃមជ្ឈិមបូព៌ា)

២. កាលបរិច្ឆេទ

- carbon dating /ˈkɑːb(ə)n deɪtɪŋ/ [n] វិធីប៉ាន់អាយុកាលសារធាតុសរីរាង្គងាប់

***Datnioides microlepis*** [sci.n] សូមមើលពាក្យ៖ finescale tigerfish

***Datnioides quadrifasciatus*** [sci.n] សូមមើលពាក្យ៖ barred tigerfish

***Datnioides undecimradiatus*** [sci.n] សូមមើលពាក្យ៖ narrow barred tigerperch

**datura** /dəˈtjʊərə/ [n] ស្លាក់

***Datura metel*** [sci.n] សូមមើលពាក្យ៖ datura

***Daucus carota*** [sci.n] សូមមើលពាក្យ៖ carrot

**day /**deɪ/ [n] ថ្ងៃ

- field day /fiːld deɪ/ [n] ទិវាស្រែបង្ហាញ
- day sleep /deɪ sliːp/ [n] ការដេកថ្ងៃ

**daze** /deɪz/ [v] បំភាំងស្មារតី

**DBH (diameter at breast height)** /dʌɪˈamɪtə at brɛst hʌɪt/ [n] អង្កត់ផ្ចិតនៅកម្ពស់ត្រឹមដើមទ្រូង (DBH) (ជាការវាស់វែងអង្កត់ផ្ចិតជាលក្ខណៈបទដ្ឋាន ដែលមានកម្ពស់ប្រហែល ៤ ១/២ feet ពីដី។ ១. នៅត្រង់ទីជំរាលការវាស់ត្រូវបានធ្វើឡើងពីកំពូលនៃទួល ២. DBH អាចវាស់អង្កត់ផ្ចិតនៅលើសម្បកឈើ មើល diameter inside bark, diameter outside bark។)

**DDT(dichlorodiphenyltrichloroethane)** /diːdiːˈtiː/ [n] ដេដេតេ (ថ្នាំកសិកម្ម)

**de novo** /deɪ ˈnəʊvəʊ/ [adv, adj] ការកកើតឡើងវិញ

**de-** /diː/ [prefix] បុព្វបទមានន័យថា ពីក្រៅ ឬចេញពី

- de-pulping /diːˈpʌlpɪŋ/ [n] ការយកសាច់ចេញពីគ្រាប់, ការប្រលេះយកគ្រាប់
- de-winging /diˈwɪŋɪŋ/ [n] ការយកស្លាបចេញ (ការយកឬកាត់ចេញស្លាបពីផ្លែឬគ្រាប់នៅពេលសំអាតគ្រាប់ ឧ. ដាក់ឱ្យស្រូបទឹកបន្តិច (គ្រាប់ស្រស់) ត្រដុស វាចេញ ឬកាត់ម្តងមួយ។)

**dead** /dɛd/ [adj] ងាប់, ស្លាប់, លែងមានតម្លៃប្រើ

**deaf** /dɛf/ [adj] ថ្លង់, ដំឡង់

**deaf-mute** /mju:t dɛf/ [n] មនុស្សថ្លង់ផងគផង

**dealation** /di:leɪʃ(ə)n/ [n] ជម្រុះស្លាប

**dealkalization** /diˈalkəlʌɪziʃ(ə)n/ [n] ការបញ្ចុះpHកុំឱ្យខ្ពស់ពេក

**death** /dɛθ/ [n] ការស្លាប់, ការងាប់, អត្រាមរណភាព

**debilitate** /dɪˈbɪlɪteɪt/ [v] ធ្វើឱ្យខ្សោយ, ធ្វើឱ្យល្វើយកម្លាំង

**debility** /dɪˈbɪlɪti/ [n] ភាពទន់ខ្សោយ, ភាពល្វើយកម្លាំង

**debride** /dɪˈbri:d/ [v] ចៀរ

**debris** /ˈdɛbri:s/ [n]

១. (សទិសន័យ៖ stone fragment, rock waste, detritus) កម្ទេចថ្ម

២. កម្ទេចកំទី, កម្ទេច

**deca-** /ˈdɛkə/ [prefix] បុព្វបទមានន័យថា ដប់

**decade** /ˈdɛkeɪd/ [n] ទសវត្សរ៍

**decalcification** /di:kalsɪfɪˈkeɪʃ(ə)n/ [n] វិកាល់ស្យូមកម្ម, ការខ្សោះនៃសារធាតុកាល់ស្យូម

**decapod** /ˈdɛkəpɒd/ [n] ជើងដប់ (ឧ. ពួកក្ដាម បង្គា មឹកជាដើម)

**decarbonation** /diˌkɑ:bəˈneɪʃ(ə)n/ [n] វិកាបូណាតកម្ម, ការចាកចេញ ឬខ្សោះនៃកាបូណាត

**decarboxylation** /ˌdi:kɑ:bɒksɪˈleɪʃ(ə)n/ [n] ការបាត់បង់កាបូនិច, ដេកាបុកស៊ីលកម្ម

**decay** /dɪˈkeɪ/ [n,v ] បំបែកធាតុ,ស្អុយរលួយ, ពុកផុយ, ការថយចុះ

- radioactive decay /ˌreɪdɪəʊˈaktɪv dɪˈkeɪ/ [n] ការបំបែកធាតុវិទ្យុសកម្ម

**decerebration** /di:ˈsɛrɪbreɪʃ(ə)n/ [n] បង្អាក់សកម្មភាពខួរ

**decibel** /ˈdɛsɪbɛl/ [n] ដេស៊ីបែល (ខ្នាតសូរ)

**decidua** /dɪˈsɪdjʊə/ [n] អញ្ចាញស្បូន

**deciduous** /dɪˈsɪdjʊəs/ [adj] រុក្ខជាតិជ្រុះស្លឹកប្រចាំឆ្នាំ, ដែលរងើ្គ

**decimate** /ˈdɛsɪmeɪt/ [v] បំផ្លាញយ៉ាងច្រើន, សម្លាប់រង្គាល

**deck** /dɛk/ [n] ជាន់ (នាវា, ស្ពាន)

**declination** /ˌdɛklɪˈneɪʃ(ə)n/ [n] ដេគ្លីនេសុង

**decline** /dɪˈklʌɪn/ [n]

១. រាគអស់កម្លាំង

២. ការធ្លាក់ចុះសន្សឹមៗ, តំហយចុះ

- decline of water table /dɪˈklʌɪn ɒv ˈwɔ:tə ˈteɪb(ə)l/ [n] តំហយចុះនៃខ្សែទឹកក្នុងដី

**declivity** /dɪˈklɪvɪti/ [n]

១. សូមមើលពាក្យ៖ slope

២. ទីវាលរាបស្មើដែលមានជម្រាលបន្តិចៗ

**decompose** /di:kəmˈpəʊz/ [v] បំបែក, បំបែកធាតុ, រលួយ, ញែក, ធ្វើឱ្យរលួយ, ធ្វើឱ្យខូច

**decomposer** /ˌdi:kəmˈpəʊzə/ [n] (សទិសន័យ៖ reducer) អ្នកបំបែក

**decomposition** /ˌdi:kɒmpəˈzɪʃn/ [n] (សទិសន័យ៖ decay) ការបំបែក, ការបំបែកធាតុ, ការរលួយ, ការពុកផុយ (ការពុកផុយនៃសារធាតុសរីរាង្គ)

- aerobic decomposition /ɛ:ˈrəʊbɪkˌdi:kɒmpəˈzɪʃn/ [n] ការបំបែកធាតុដោយមានខ្យល់
- anaerobic decomposition /ˌanɛ:ˈrəʊbɪkˌdi:kɒmpəˈzɪʃn/ [n] ការបំបែកធាតុដោយគ្មានខ្យល់
- bacterial decomposition /bakˈtɪərɪəlˌdi:kɒmpəˈzɪʃn/ [n] ការបំបែកធាតុក្រោមអំពើបាក់តេរី
- biological decomposition /bʌɪə(ʊ)ˈlɒdʒɪk(ə)lˌdi:kɒmpəˈzɪʃn/ [n] ការបំបែកធាតុជីវៈ
- chemical decomposition /ˈkɛmɪk(ə)l ˌdi:kɒmpəˈzɪʃn/ [n] ការបំបែកធាតុគីមី, បំបែកកម្មគីមី (ការបំបែកធាតុនៃសារធាតុគីមីទៅជាទម្រង់ទោល ឬសារធាតុទោល)
- sewage decomposition /ˈsu:ɪdʒˌdi:kɒmpəˈzɪʃn/ [n] ការបំបែកធាតុដោយទឹកលូសម្អុយ
- thermal decomposition /ˈθə:m(ə)l ˌdi:kɒmpəˈzɪʃn/ [n] ការបំបែកធាតុដោយកម្ដៅ

**decontaminate** /di:k(ə)nˈtamɪneɪt/ [v] សម្អាត, ធ្វើឱ្យអស់ ឬបន្ថយសារធាតុបំពុល

**decontamination** /ˌdi:k(ə)ntamɪˈneɪʃ(ə)n/ [n] ការសម្អាតសារធាតុពុល

- radioactive decontamination /ˌreɪdɪəʊˈaktɪv ˌdi:k(ə)ntamɪˈneɪʃ(ə)n/ [n] ការសម្អាតសារធាតុវិទ្យុសកម្ម

**decoy** /ˈdi:kɔɪ/ [n] របស់ដាក់បញ្ឆោត, នុយ

**decrease** /dɪˈkri:s/ [v, n] បន្ថយ, ធ្លាក់ចុះ, ថយចុះ

**decumbent** /dɪˈkʌmb(ə)nt/ [adj] វារនៅលើដី (អំពីដើមរុក្ខជាតិ), កន្ទេក (ភាពដួលដេកនៃដើមរុក្ខជាតិទៅលើដី ហើយមានទំនោរដុះដើម ត្រង់ឡើងនៅផ្នែកខាងចុងនៃដើមរបស់វា)

**decurrent** /dɪˈkʌr(ə)nt/ [n] តួស្លឹកបន្តជាប់នៅលើទង ឬដើម

**decussate** /dɪˈkʌseɪt/ [adj] ស្លឹកនៅកែងគ្នា, របៀបតម្រៀបស្លឹកលើមែកជាគូឆ្លាស់ខ្វែង

**dedifferentiation** /ˌdiːdɪfəˈrɛnʃɪeɪʃ(ə)n/ [n] ច្រាសបំប្លែងឯកទេស (ដំណើរការដែលជាលិកាដែលបានរងនូវបំប្លែងឯកទេស អាចត្រូវបានធ្វើឱ្យដំណើរការច្រាសត្រឡប់វិញ ដើម្បីឱ្យវាក្លាយជាកោសិកាដើមវិញ)

**deep** /diːp/ [adj] ជ្រៅ

- deep gigging /diːp gɪgin/ [n] សូមមើលពាក្យ៖ collapse

**deer** /dɪə/ [n] សត្វក្ដាន់

**defecate** /ˈdiːfɪkeɪt/ [v] បញ្ចេញ (បារ)

**defecation** /ˌdɛfɪˈkeɪʃ(ə)n/ [n] ការបន្ទោបង់

**defibrillator** /diːˈfɪbrɪleɪtə/ [n] ប្រដាប់ស្ទង់ចរន្តបេះដូងដើរ

**defibrinate** /diˈfaɪ brəˌneɪt/ [v] បំបាត់ភីប្រិន

**deficiency** /dɪˈfɪʃ(ə)nsi/ [n] ការចុះខ្សោយ, កង្វះ (១. កង្វះនូវសារធាតុចិញ្ចឹមមួយចំនួនសម្រាប់ការលូតលាស់ និងអភិវឌ្ឍន៍នៃដំណាំ
២. ការខ្វះខាតចំណេះដឹងខាងផ្នែកវិទ្យាសាស្ត្រអ្វីមួយ ដែលអាចឱ្យមានការរាំងស្ទះក្នុងការអភិវឌ្ឍន៍ចំណេះដឹងទូទៅ)

- nitrogen deficiency /ˈnʌɪtrədʒ(ə)n dɪˈfɪʃ(ə)nsi/ [n] កង្វះអាសូត
- nutrient deficiency /ˈnjuːtrɪənt dɪˈfɪʃ(ə)nsi/ [n] កង្វះសារធាតុចិញ្ចឹម
- phosporus deficiency /ˈfɒsf(ə)rəs dɪˈfɪʃ(ə)nsi/ [n] កង្វះផូស្វ័រ
- potassium deficiency /pəˈtasɪəm dɪˈfɪʃ(ə)nsi/ [n] កង្វះប៉ូតាស
- rice deficiency /rʌɪs dɪˈfɪʃ(ə)nsi/ [n] កង្វះខាតផលិតផលស្រូវ
- silicon deficiency /ˈsɪlɪk(ə)n dɪˈfɪʃ(ə)nsi/ [n] កង្វះខាតសារធាតុស៊ីលីស
- sulfur deficiency /ˈsəlfər dɪˈfɪʃ(ə)nsi/ [n] កង្វះខាតសារធាតុស្ពាន់ធ័រ
- vitamin deficiency /ˈvɪtəmɪn dɪˈfɪʃ(ə)nsi/ [n] កង្វះជាតិវីតាមីន,កង្វះជីវជាតិ
- zinc deficiency /zɪŋk dɪˈfɪʃ(ə)nsi/ [n] កង្វះជាតិស័ង្កសី

**deficient** /dɪˈfɪʃ(ə)nt/ [adj] មិនគ្រប់គ្រាន់

**deficit** /ˈdɛfɪsɪt/ [n] ខ្វះ, ឱនភាព (ឱនភាពគឺគំលាតរវាងអ្វីដែលមាន និងអ្វីដែលជាតម្រូវការ។ ក្នុងបរិបទនៃសន្តិសុខស្បៀង អាចនិយាយសំដៅទៅរកកង្វះស្បៀងជាទូទៅដោយផ្អែកទៅលើតម្រូវការសម្រាប់បុគ្គលម្នាក់នៅកម្រិតជាតិ។ ឱនភាពក៏ត្រូវបានយកទៅការអនុវត្តន៍នៅក្នុងបរិបទសេដ្ឋកិច្ចផងដែរ។)

- saturation deficit /satʃəˈreɪʃ(ə)n ˈdɛfɪsɪt/ [n] កង្វះភាពឆ្អែត
- water deficit /ˈwɔːtə ˈdɛfɪsɪt/ [n] កង្វះទឹក
- water deficit /ˈwɔːtə ˈdɛfɪsɪt/ [n] ខ្វះទឹក (ឧ. ទឹកក្នុងដីសម្រាប់រុក្ខជាតិ)

**deflation** /dɪˈfleɪʃ(ə)n/ [n] បំណើង, បំណោសខ្យល់

**deflation** /dɪˈfleɪʃ(ə)n/ [n] ការស្ងប់ខ្យល់, ការដកយកដោយខ្យល់

**deflexed** /dɪˈflɛkst/ [adj] ប្លាតចេញ (អំពីទម្រង់បត់)

**deforestation** /ˌdiːfɒrɪˈsteɪʃ(ə)n/ [n] (សទិសន័យ៖ clearing) ការកាប់ព្រៃ, ការកាប់បំផ្លាញព្រៃឈើ, ការគាស់រាន, សម្អាតដីព្រៃ

**deform** /dɪˈfɔːm/ [v] ខូចទ្រង់ទ្រាយ

**deformity** /dɪˈfɔːmɪti/ [n] វិរូបតា (ការខូចទ្រង់ទ្រាយ)

**degasification** /diːˈgasfɪˈkeɪʃ(ə)n/ [n] ដំណាកឧស្ម័ន

**degenerate** /dɪˈdʒɛn(ə)rət/ [v] ហិនហោច

**degeneration** /dɪˌdʒɛnəˈreɪʃ(ə)n/ [n] ការបាត់បង់

**degleification** [n] ការថយនៃសារធាតុគ្លេ (ឥដ្ឋខៀវជាំទឹក)

**deglutition** /ˌdiːgluːˈtɪʃ(ə)n/ [n] ដំណើរលេប

**degrade** /dɪˈgreɪd/ [v] (សទិសន័យ៖ deplete) ធ្វើឱ្យបែក ឬខូច, បំបែកធាតុ

**degraded** /dɪˈgreɪdɪd/ [adj] ដែលខូចខាត

**degradation** /ˌdɛgrəˈdeɪʃ(ə)n/ [n] (សទិសន័យ៖ depletion) ការបំបែកធាតុ, តំហយគុណភាព, ការរេចរឹល, ការខូចខាត (ការបាត់តម្លៃ, ការប្ដូរនៃការវិវត្តន៍)

- clay degradation /kleɪ ˌdɛgrəˈdeɪʃ(ə)n/ [n] (សទិសន័យ៖ clay impoverishment, clay leaching) ការធ្វើឱ្យដីឥដ្ឋកាន់តែថយទៅៗ
- environmental degradation /ɪnvʌɪrənˈmɛnt(ə)l ˌdɛgrəˈdeɪʃ(ə)n/ [n] ការរេចរឹលបរិស្ថាន
- forest degradation /ˈfɒrɪst ˌdɛgrəˈdeɪʃ(ə)n/ [n] ការថយចុះនៃចំនួនព្រៃឈើ
- land degradation /land ˌdɛgrəˈdeɪʃ(ə)n/ [n] ការរេចរិលដី, តំហយគុណភាពដី
- soil degradation /sɔɪl ˌdɛgrəˈdeɪʃ(ə)n/ [n] តំហយគុណភាពដី(ស្រទាប់លើ)
- structure degradation /ˈstrʌktʃə ˌdɛgrəˈdeɪʃ(ə)n/ [n] ការខូចខាតទម្រង់

**degreasing** /diːˈgriːsɪŋ/ [n] ការជម្រះប្រេង និងខ្លាញ់

**degree** /dɪˈgriː/ [n] កម្រិត, អង្សា, ដឺក្រេ

- fertility degree /fəˈtɪlɪti dɪˈgriː/ [n] កម្រិតដីជាតិ, អត្រាកើត(ចំនួនប្រជាជន)
- humification degree /hjuːmɪfɪˈkeɪʃ(ə)n dɪˈgriː/ [n] កម្រិតមមោកកម្ម
- stagnation degree /stagˈneɪʃ(ə)n dɪˈgriː/ [n] ភាពនៅនឹង, ភាពមិនហូរ

**degree of freedom** /dɪˈgriːɒvˈfriːdəm/ [n] (ចំពោះស្ថិតិវិទ្យា) កម្រិតសេរីភាព (ចំនួនប្រៀបធៀបឯករាជ្យមួយ ដែលជាធម្មតា វាស្មើនឹង n-១ ដែល n ជាចំនួនឯកត្តៈនៅក្នុងសារព័ន្ធ)

**dehiscence** /diːˈhɪs(ə)ns/ [n] ការផ្តាច់ចេញ, ការប្រេះ (១. ការផ្តាច់ចេញរបស់ថង់លម្អង ឬប្រភេទផ្លែស្ងួតដើម្បីពង្រាយគ្រាប់។ នៅក្នុងន័យបច្ចេកទេសគ្រាប់ពូជ ប្រភេទផ្លែប្រេះ គឺជាប្រភេទផ្លែណាដែលប្រេះបើកនៅពេលទុំស្ងួត ជាធម្មតា ផ្លែវានៅជាប់នឹងមែកឧ. capsules, follicles និង pods មួយចំនួន។ ពាក្យផ្ទុយ Indehiscence។ ២. ការផ្តាច់ចេញនៃរចនាសម្ព័ន្ធរបស់ផ្កាឬផ្លែ។ ផ្លែផ្តាច់ចេញ គឺជាប្រភេទផ្លែដែលបើកចំហ ឬបំបែកជាចំណែក នៅពេលដែលវានៅជាប់នឹងដើមនៅឡើយ ឧ. ប្រភេទផ្លែ follicles, capsules និងកោន។)

**dehiscent** /diːˈhɪs(ə)nt/ [adj] បែក (អំពីទម្រង់របស់រុក្ខជាតិ) (ផ្ទុះបែកដោយឯកឯង ដើម្បីបញ្ចេញសារធាតុដែលមាននៅខាងក្នុងនោះ ឧទាហរណ៍ ប្លោកលម្អងបញ្ចេញគ្រាប់លម្អង ផ្លែស្ងួតខ្លះបែកដើម្បីបញ្ចេញគ្រាប់ (សណ្តែក))

**dehydration** /ˌdiːhʌɪˈdreɪʃ(ə)n/ [n] ភាពខ្សោះទឹក, ដេអ៊ីដ្រាតកម្ម, ការដកទឹកចេញ, បន្សោះទឹក, ការសម្ងួត, កង្វះជាតិទឹកក្នុងខ្លួន

**dehydrogenase** /ˌdiːhʌɪˈdrɒdʒəneɪz/ [n] ប្រតិកម្មផ្ទេរអ៊ីដ្រូសែន (ក្រុមនៃអង់ស៊ីម (enzyme) ដែលជំនួយដល់ប្រតិកម្មទាក់ទងទៅនឹងការផ្ទេរអ៊ីដ្រូសែន (hydrogen) ពីសារធាតុមួយទៅសារធាតុមួយដែលទទួលយកអ៊ីដ្រូសែន។ ប្រតិកម្មនេះគឺជាប្រភេទដំណើរការគីមីជីវសាស្ត្រនៅក្នុងរុក្ខជាតិ ហើយសកម្មភាពនៃការផ្ទេរអ៊ីដ្រូសែនត្រូវគេយកមកប្រើដើម្បីបង្ហាញពីលទ្ធភាពដុះ របស់គ្រាប់តាមរយៈការពិសោធន៍ TTZ។)

**delamination** /diːˈlamɪneɪʃ(ə)n/ [n] ញែកជាស្រទាប់ៗ

**deletion** /dɪˈliːʃ(ə)n/ [n] ការបាត់

- base deletion /beɪs dɪˈliːʃ(ə)n/ [n] ការបាត់បង់បាស

**delimit** /dɪˈlɪmɪt/ [v] ដាក់ដែនកំណត់, កំណត់ព្រំដែន

**delimitation** /dɪlɪmɪˈteɪʃ(ə)n/ [n] ការកំណត់ព្រំដែន

**deliquescence** /ˌdɛlɪˈkwɛs(ə)ns/ [n] ការស្រូបទឹកក្នុងខ្យល់

**delirium** /dɪˈlɪrɪəm/ [n] ការមមើមមាយ, ការរវើរវាយ, រោគមមើមមាយ

**deliver** /dɪˈlɪvə/ [v] ប្រគល់, សង្គ្រោះ, បោះបង់

**Delphacidae** [n] មមាច (ឈ្មោះនៃគ្រួសារដ៏ធំមួយនៃពពួកសត្វល្អិតដែលជញ្ជក់ដើម ហើយត្រូវបានសម្គាល់ដោយសារមានខ្នាយនៅជើង។ ជាធម្មតា ការធ្វើចលនារបស់វាមិនសូវរហ័សផ្លាស់ទីច្រើនតែថយក្រោយ ឬវារទៅឆ្វេង ឬស្តាំដូចក្តាម។ គេសង្កេតឃើញ វាជ្រកក្នុងគុម្ពផ្នែកគល់នៃដើមស្រូវ ឧទាហរណ៍ ពពួកមមាចដើម)

**delta** /ˈdɛltə/ [n] ដីសណ្ត (ដីដុះដោយសារល្បាប់ដែលហូរនាំមកដោយទឹកទន្លេ ឬជំនន់)

- dry delta /drʌɪ ˈdɛltə/ [n] សូមមើលពាក្យ៖ alluvial fan
- tidal delta /ˈtʌɪd(ə)lˈdɛltə/ [n] ដីសណ្តបាតសមុទ្រ

**deltoid** /ˈdɛltɔɪd/ [adj] ទម្រង់បន្ទះស្លឹករាងត្រីកោណ, រាងត្រីកោណ

**deluvial** /dʌɪˈl(j)uːvɪəl/ [adj] ដែលជាកម្ទេចកំទី (ក្រួស ថ្មជាដើម), ដែលរអិលចុះពីលើជម្រាល

**demand** /dɪˈmɑːnd/ [n] តម្រូវការ

- biochemical oxygen demand /ˌbʌɪəʊˈkɛmɪk(ə)l ˈɒksɪdʒ(ə)n dɪˈmɑːnd/ [n] តម្រូវការអុកស៊ីសែនគីមីជីវៈ (នៅក្នុងទឹក)
- biological oxygen demand (BOD) /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˈɒksɪdʒ(ə)n dɪˈmɑːnd/ [n] តម្រូវការអុកស៊ីសែនជីវៈ
- chemical oxygen demand /ˈkɛmɪk(ə)l ˈɒksɪdʒ(ə)n dɪˈmɑːnd/ [n] តម្រូវការអុកស៊ីសែនគីមី (នៅក្នុងទឹក)
- oxygen demand /ˈɒksɪdʒ(ə)ndɪˈmɑːnd/ [n] តម្រូវការអុកស៊ីសែន

**demand and supply** /dɪˈmɑːnd ənd səˈplʌɪ/ [n] តម្រូវការ និងការផ្គត់ផ្គង់

**demersal** /dɪˈməːs(ə)l/ [adj] លេចក្នុងទឹក

**demi-** /ˈdɛmi/ [prefix] បុព្វបទមានន័យថា កន្លះ

**demineralization** /diːmɪn(ə)r(ə)lʌɪˈzeɪʃ(ə)n/ [n] វិខនិ-ជកម្ម (១.ការដកអំបិលរ៉ែ ឬសរីរាង្គចេញពីជាលិកាពីខ្លួនប្រាណ ២.ការបាត់ជាតិអំបិលជីសារពាង្គកាយ ជាពិសេសតាមរយៈជំងឺ ឧ.បាត់កាលើស្យូមពីឆ្អឹង ឬ ធ្មេញ)។

**demodex** /ˈdɛməʊdɛks/ [n] ដេម៉ូដិច (ពពួកសន្តានចៃល្អិត (tinyparasitic mites) ដែលរស់នៅគល់រោមសត្វ)

**demography** /dɪˈmɒgrəfi/ [n] ប្រជាគណវិទ្យា, ប្រជាសាស្ត្រ (ការសិក្សាទៅលើប្រជាករមនុស្ស)

**demonstrate** /ˈdɛmənstreɪt/ [v] ស្រាយបញ្ជាក់, បង្ហាញ

**demonstration** /dɛmənˈstreɪʃ(ə)n/ [n] ការធ្វើបង្ហាញ (ការធ្វើបង្ហាញអំពីបច្ចេកវិទ្យាថ្មីៗដល់កសិករ ឬអ្នកដែលអាចមានប្រយោជន៍អំពីបច្ចេកវិទ្យាថ្មីៗនោះ)

- field demonstration /fiːld dɛmənˈstreɪʃ(ə)n/ [n] ស្រែបង្ហាញ
- varietal demonstration /vəˈrʌɪət(ə)l dɛmənˈstreɪʃ(ə)n/ [n] ការបង្ហាញពូជ (ដំណើរការដែលក្នុងនោះពូជថ្មីៗត្រូវបានយកមកដាំដុះ បង្ហាញកសិករ)

**demulcent** /dɪˈmʌls(ə)nt/ [adj] សម្រន់, សំងប់

**denaturation** /diːˌnatʃəˈreɪʃ(ə)n/ [n] ការបាត់បង់លក្ខណៈដើម, ការខូចទម្រង់, ការបំប្លែងធម្មជាតិ

**denature** /diːˈneɪtʃə/ [v] បំភ្លៃ, បំលែង

**dendr-** /ˈdɛndrəʊ/ [prefix] (ដូច៖ dendro-) បុព្វបទមានន័យថា ដើមឈើ

**dendrite** /ˈdɛndrʌɪt/ [n] ដង់ឌ្រីត

**dendro-** /ˈdɛndrəʊ/ [prefix] (ដូច៖ dendr-) បុព្វបទមានន័យថា ដើមឈើ

**dendrochronology** /ˌdɛndrəʊkrəˈnɒlədʒi/ [n] ព្រឹក្សាប្រវត្តិវិទ្យា

**dendrology** /dɛnˈdrɒlədʒi/ [n] វិទ្យាសាស្ត្រសិក្សាពីដើមឈើ

**dengue** /ˈdɛŋgi/ [n] ជំងឺគ្រុនឈាម

**denitrification** /diːˈnʌɪtrɪfɪˈkeɪʃ(ə)n/ [n] អាសូតកម្ម, វិនីទ្រីកម្ម (ការបំប្លែងនៃជាតុនីត្រាត ឬនីទ្រីតទៅជាឧស្ម័ន អាសូត ឬជាអាសូតអុកស៊ីត ដោយពពួកមីក្រូសារពាង្គកាយ)

**density** /ˈdɛnsɪti/ [n] ដង់ស៊ីតេ (បរិមាណនៃឯកត្តៈណាមួយក្នុងមួយឯកតាដី)

- actual density /ˈaktʃʊəlˈdɛnsɪti/ [n] ដង់ស៊ីតេពិត
- air density /ɛːˈdɛnsɪti/ [n] ដង់ស៊ីតេខ្យល់
- apparent density /əˈpar(ə)ntˈdɛnsɪti/ [n] (សទិសន័យ៖ volume weight) ដង់ស៊ីតេធម្មជាតិ, ដង់ស៊ីតេទំនង
- bulk density /bʌlk ˈdɛnsɪti/ [n] (សទិសន័យ៖ volume weight) ឃនភាពដី (ទម្ងន់ម៉ាសស្ងួតរបស់ដីក្នុងមួយខ្នាតមាឌនៃដី ដែលគិតជាក្រាមក្នុង ១ស.ម គូប)
- buoyant density /ˈbɔɪənt ˈdɛnsɪti/ [n] ដង់ស៊ីតេវត្ថុរាវ
- particle density /ˈpɑːtɪk(ə)l ˈdɛnsɪti/ [n] ម៉ាសមាឌចុណ្ណភាគ, ដង់ស៊ីតេចុណ្ណភាគ (ទម្រង់ (ម៉ាស) ស្ងួតក្នុងមួយខ្នាតមាឌនៃដីរឹង (ភាគល្អិតដី) ជាដុំគិតជាក្រាមក្នុង១ ស.ម គូប)
- population density /pɒpjʊˈleɪʃ(ə)nˈdɛnsɪti/ [n] ដង់ស៊ីតេប្រជាជន,ដង់ស៊ីតេប្រជាពល, ដង់ស៊ីតេសម្ភារះ
- soil bulk density /sɔɪl bʌlk ˈdɛnsɪti/ [n] ដង់ស៊ីតេដី
- true density /truːˈdɛnsɪti/ [n] ដង់ស៊ីតេពិត

**dental** /ˈdɛnt(ə)l/ [adj] ដែលទាក់ទងនឹងធ្មេញ, នៃធ្មេញ (ទន្តិក)

**dentate** /ˈdɛnteɪt/ [adj] មានធ្មេញ (អំពីទម្រង់រុក្ខជាតិ), ទម្រង់គែមស្លឹក, ទម្រង់ធ្មេញរណា

**dentine** /ˈdɛntiːn/ [n] សាច់ភ្លុកនៃឆ្អឹង

**dentist** /ˈdɛntɪst/ [n] ពេទ្យធ្មេញ

**dentistry** /ˈdɛntɪstri/ [n] វិជ្ជាពេទ្យធ្មេញ (ទន្តិកពេទ្យវិទ្យា)

**denude** /dɪˈnjuːd/ [v] បក

**deoxidized** /diːˈɒksɪdʌɪzd/ [adj] ដែលទទួលរងអុកស៊ីសែន

**deoxygenation** /diːɒksɪdʒəˈneɪʃ(ə)n/ [n] វិអុកស៊ីសែនកម្ម

**department** /dɪˈpɑːtm(ə)nt/ [n] នាយកដ្ឋាន, ដេប៉ាតឺម៉ង់

**dependency** /dɪˈpɛnd(ə)nsi/ [n] ភាពពឹងផ្អែកលើគេ

**deplete** /dɪˈpliːt/ [v] (សទិសន័យ៖ degrade) ធ្វើឱ្យអស់ជីជាតិ, បំបែក, បង្ហិន, ធ្វើឱ្យក្រ

**depletion** /dɪˈpliːʃn/ [n] (សទិសន័យ៖ degradation, leaching, eluviation) ការលាងច្រោះ, គនុកម្ម (ការធ្វើឱ្យអស់រលីង ឬធ្វើឱ្យហិនហោចអស់)

groundwater depletion /ˈɡraʊn(d)wɔːtə dɪˈpliːʃn/ [n] តំហយចុះនៃទឹកក្នុងដី

ozone depletion /ˈəʊzəʊn dɪˈpliːʃn/ [n] ការហិនហោចអូសូន

ozone layer depletion /ˈəʊzəʊnˈleɪə dɪˈpliːʃn/ [n] ការហិនហោចស្រទាប់អូសូន

**deposit** /dɪˈpɒzɪt/ [v] ដាក់ (១. ការដាក់លុយទៅក្នុងធនាគារ ២. ការដាក់ពងរបស់សត្វល្អិតទៅកន្លែងដែលត្រជាក់)

**deposit** /dɪˈpɒzɪt/ [n]

១. ស្រទាប់ដីដែលមាននៅក្នុងដី

២. ដីល្បាប់ដែលនាំមកដោយទឹកទន្លេ

៣. ពំនូក, វត្ថុ ឬល្បាប់ដែលនាំមកដោយទឹក ឬខ្យល់

- aeolian deposit /iːˈəʊlɪən dɪˈpɒzɪt/ [n] សម្ភារ ឬល្បាប់ដែលនាំមកដោយខ្យល់
- alluvial deposit /əˈl(j)uːvɪəl dɪˈpɒzɪt/ [n] ដីល្បាប់ទន្លេ, ល្បាប់ល្បាយតាមជ្រលងទឹក, កំណរល្បាប់
- alluvion deposit /əˈl(j)uːvɪən dɪˈpɒzɪt/ [n] (សទិសន័យ៖ sediment, sediment, alluvial soil) ល្បាប់ (អ្វីៗដែលនាំមកដោយទឹក)
- beach deposit /biːtʃ dɪˈpɒzɪt/ [n] ខ្សាច់ដែលនៅតាមច្រាំង
- benthal deposit /ˈbɛnθ(ə)ldɪˈpɒzɪt/ [n] ពំនូកបង់គូស
- bottom deposit /ˈbɒtəmdɪˈpɒzɪt/ [n] ពំនូកបាត
- braided stream deposit /breɪdid striːm dɪˈpɒzɪt/ [n] ល្បាប់ទន្លេ
- channel fill deposit /ˈtʃan(ə)l fil dɪˈpɒzɪt/ [n] គំនរកំណរភក់តាមជ្រលង-ប្រឡាយ ឬព្រែក
- continental deposit /kɒntɪˈnɛnt(ə)l dɪˈpɒzɪt/ [n] ដីទ្វីប (ដីដែលដាច់មកតាមការហូរច្រោះក្នុងពេលភ្លៀងធំ និងសម្ភាររមៀល)
- cryogenic deposit /krʌɪə(ʊ)ˈdʒɛnɪk dɪˈpɒzɪt/ [n] គំនរមកពីការត្រជាក់
- deluvial deposit /dʌɪˈl(j)uːvɪəl dɪˈpɒzɪt/ [n] ល្បាប់នាំមកដោយទឹកនៅលើជើងជម្រាល
- dust deposit /dʌst dɪˈpɒzɪt/ [n] សម្ភារ ឬធូលីដែលនាំមកដោយខ្យល់
- flood deposit /flʌd dɪˈpɒzɪt/ [n] (សទិសន័យ៖ warp) ការកករឹងនៃល្បាប់, ការបិទប្រហោង ឬចុករន្ធដោយកំណកល្បាប់, ល្បាប់ ឬវត្ថុនាំមកដោយទឹកជំនន់, ដីដែលទឹកសមុទ្រថយទៅ ហើយអាចដាំដំណាំបាន
- flood plain deposit /flʌd pleɪn dɪˈpɒzɪt/ [n] វត្ថុ ឬល្បាប់ ដែលនាំមកដោយទឹកជំនន់
- lag deposit /lag dɪˈpɒzɪt/ [n] ការប្រមូលផ្តុំថ្មដោយកម្ទេចល្អិតហូរទៅបាត់អស់ (ថ្មសំណល់)
- lake deposit /leɪk dɪˈpɒzɪt/ [n] កំណរបឹង (បាតបឹង)
- littoral deposit /ˈlɪt(ə)r(ə)l dɪˈpɒzɪt/ [n] ពំនូកឆ្នេរ
- marine deposit /məˈriːn dɪˈpɒzɪt/ [n] ពំនូកសមុទ្រ
- mineral deposit /ˈmɪn(ə)r(ə)l dɪˈpɒzɪt/ [n] ពំនូករ៉ែ, កន្លែងមានរ៉ែ
- organic deposit /ɔːˈganɪk dɪˈpɒzɪt/ [n] ពំនូកសរីរាង្គ
- overspread deposit /əʊvəˈsprɛd dɪˈpɒzɪt/ [n] ល្បាប់ ឬវត្ថុដែលរាយពាសពេញ
- river deposit /ˈrɪvə dɪˈpɒzɪt/ [n] (សទិសន័យ៖ fluviogenic soil) ល្បាប់ទន្លេ
- sedimentary deposit /sɛdɪˈmɛntri dɪˈpɒzɪt/ [n] កំណរល្បាប់
- terrigenous deposit /tɛˈrɪdʒɪnəs dɪˈpɒzɪt/ [n] គំនរដីដែលធ្លាក់ចុះពីដីគោកខាងលើចូលក្នុងសមុទ្រ
- tidal deposit /ˈtʌɪd(ə)l dɪˈpɒzɪt/ [n] ល្បាប់ទឹកជោរនាច, ល្បាប់សមុទ្រ
- torrent deposit /ˈtɒr(ə)nt dɪˈpɒzɪt/ [n] គំនរកំណរនាំមកដោយទឹកជ្រោះ

- wall deposit /wɔːl dɪˈpɒzɪt/ [n] វត្ថុ ឬល្បាប់ដែលបានកកនៅផ្ទៃក្នុងនៃបំពង់
- wind deposit /wɪnddɪˈpɒzɪt/ [n] ពំនូកខ្យល់

**deposition** /ˌdɛpəˈzɪʃ(ə)n/ [n] ការប្រមូលផ្តុំវត្ថុធាតុអ្វីមួយនៅកន្លែងណាមួយ, ការធ្លាក់, ចំណាក់ពំនូក
- acid deposition /ˈasɪdˌdɛpəˈzɪʃ(ə)n/ [n] ការធ្លាក់អាស៊ីត
- atmospheric deposition /atməsˈfɛrɪk ˌdɛpəˈzɪʃ(ə)n/ [n] ការធ្លាក់ចុះនៃសារធាតុបំពុលពីបរិយាកាស

**depress** /dɪˈprɛs/ [v] បន្ថយ, បន្ទាប, បញ្ចុះ

**depressant** /dɪˈprɛs(ə)nt/ [n] ភ្នាក់ងារ(ថ្នាំ)បន្ថយដំណើរការ នៃសកម្មភាពរូបកាយ (ថ្នាំសង្កត់សកម្មភាពសរសៃប្រសាទ)

**depressed** /dɪˈprɛst/ [adj] ដែលផត, ដែលសំប៉ែត

**depression** /dɪˈprɛʃ(ə)n/ [n]
១. (ចំពោះដី) ល្បាក់, ទំនាប, ដីទំនាប, ដីផត
២. ការធ្លាក់ទឹកចិត្ត, តំហាយកម្លាំង, ការស្រយុតស្រយុងចិត្ត

**depth** /dɛpθ/ [n] ជម្រៅ, បណ្តោយចូលទៅក្នុង ( ការយកសាច់ផ្លែចេញ(ការប្រលេះយកគ្រាប់)ពីប្រភេទផ្លែសាច់ ដូចជាផ្លែប៉ើរ និងខ្នុរ។ ការយកសាច់ចេញ អាចធ្វើតាមវិធីត្រាំទឹក និងធ្វើឱ្យល្វយឡើងមេ ដោយធ្វើការបុក ឬត្រាំឱ្យទន់សាច់ ប្រព្រឹត្តកម្មមេកានិច ឧ. ការប្រលេះ យកគ្រាប់កា-ហ្វេ។)

**compensation depth** /kɒmpɛnˈseɪʃ(ə)n dɛpθ/ [n] ជម្រៅទូទាត់

**derivative** /dɪˈrɪvətɪv/ [n] ធាតុស្រទាប់

**derm-** /dəːm/ [prefix] បុព្វបទមានន័យថា ស្បែក

**dermacentor** /ˈdəːməˈsɛntə/ [n] សូមមើលពាក្យ៖ tick

**dermatitis** /ˌdəːməˈtʌɪtɪs/ [n] ជំងឺរលាកស្បែក ដែលមានលក្ខណៈរមាស់, ក្រហម, និងធ្វើឱ្យមានស្នាម

**dermis** /ˈdəːmɪs/ [n] ខ្នែម (ស្បែក, ស្បែកក្នុង)

***Dermochelys coriacea*** [sci.n] សូមមើលពាក្យ៖ leatherback turtle

***Dermogenys pusilla*** [sci.n] ត្រីផ្ទោង

**derris** /ˈdɛrɪs/ [n] វល្លិតេណួន

**des-** /ˌdez/ [prefix] បុព្វបទមានន័យថា ចំណាង ឬច្រវាក់ (ដូច៖ desmo-)

**desalination** /ˌdiːsalɪˈneɪʃ(ə)n/ [n] ការបិតទឹកសមុទ្រ (ឱ្យទៅជាទឹកសាប), ដំណកអំបិល, វិអំបិលកម្ម, ការយកជាតិអំបិលចេញ (ពីសូលុយស្យុង)

**desalinization** /diːˈsalɪnʌɪziʃ(ə)n/ [n] ការលាង ឬបញ្ចុះអំបិល

**desaturation** /diːsatʃəˈrɛɪʃ(ə)n/ [n] ការធ្វើឱ្យចុះទាប (ឧ. កាចុង)

**descendant** /dɪˈsɛnd(ə)nt/ [n] កូន, ចៅ

**descriptor** /dɪˈskrɪptə/ [n] ពិពណ៌នាករ (អត្ថបទដែលធ្វើអត្ថាធិប្បាយពីអ្វីមួយ)

**desensitization** /diːˌsɛnsɪtʌɪˈzeɪʃ(ə)n/ [n] ការបំបាត់ភាពរួស, ការបំបាត់ភាពដឹង

**desert varnish** /dɪˈzəːt ˈvɑːnɪʃ/ [n] (សទិសន័យ៖ tan) ភាពឡើងពណ៌នៃរបស់អ្វីមួយក្នុងកំឡុងពេលយូរ

**desert** /dɪˈzəːt/ [n] វាលខ្សាច់, វាលលំហ, រហោឋាន
- man-made desert /manmeɪd dɪˈzəːt/ [n] វាលលំហបង្កើតដោយមនុស្ស
- polar desert /ˈpəʊlədɪˈzəːt/ [n] វាលលំហប៉ូល
- rocky desert /ˈrɒki dɪˈzəːt/ [n] វាលរហោស្ថានដែលមានតែថ្ម
- sand desert /sand dɪˈzəːt/ [n] វាលលំហខ្សាច់
- stony desert /ˈstəʊni dɪˈzəːt/ [n] រហោស្ថាន ឬវាលដែលមានតែថ្ម ឬក្រួស, តំបន់ស្ងួត ដែលស្ទើរតែគ្មានរុក្ខ-ជាតិ

**desert rose** /dɪˈzəːt rəʊz/ [n] ផ្កាយិតថូបារាំង (ឈ្មោះវិទ្យាសាស្ត្រ *Allamanda cathartica*)

**desertification** /dɛˌzəːtɪfɪˈkeɪʃ(ə)n/ [n] រហោឋានកម្ម

**desiccant** /ˈdɛsɪk(ə)nt/ [n] សារធាតុគីមីសម្រាប់ស្រូបសំណើម (សារធាតុគីមីម៉្យាងដែលអាចស្រូបសំណើមបានខ្លាំង ដូច្នេះហើយគេប្រើវាសម្រាប់សំងួតឬរក្សាសំណើមទាប នៅ ពេលគេ ដាក់វានៅជាមួយគ្រាប់។ សារធាតុគីមីដែលប្រើជាទូទៅ គឺ SiO, CaO។)

**desiccate** /ˈdɛsɪkeɪt/ [v] សម្ងួត, ធ្វើឱ្យស្ងួតអស់, ធ្វើឱ្យអស់ជាតិទឹក

**desiccation** /dɛsɪˈkeɪʃ(ə)n/ [n] កំហះ (ដេស៊ីជ្រាតកម្ម), ការធ្វើឱ្យស្ងួត

**desiccation sensitive** /dɛsɪˈkeɪʃ(ə)n ˈsɛnsɪtɪv/ [n] គ្រាប់ងាយស្លាប់ដោយសាររំហួត ( គ្រាប់ដែលមិនធន់នឹងការសំងួតឱ្យនៅក្រោមកម្រិតណាមួយនៃបន្ទុកសំណើម ដែលអាចស្លាប់បាន។ ជារឿយៗ គេប្រើ ពាក្យនេះសំដៅទៅលើប្រភេទគ្រាប់ពិបាកប្រព្រឹត្តកម្ម។)

**desiccator** /ˈdɛsɪkeɪtə/ [n] កែវកញ្ចក់មានគម្របបិទជិត , ឧបករណ៍ការពារខ្យល់ចូល (ជាកែវមួយធំមានគំរបសម្រាប់ដាក់របស់អ្វីមួយមិនឱ្យខ្យល់ចេញចូលបាន។ គេប្រើវាសម្រាប់ធ្វើពិសោធន៍រក បន្ទុកសំណើមរបស់គ្រាប់ ដើម្បីការពារគ្រាប់កុំឱ្យស្រូបសំណើមពីបរិយាកាសមកវិញនៅពេលដាក់វាឱ្យចុះ ត្រជាក់។)

**design** /dɪˈzʌɪn/ [v] ធ្វើប្លង់ពិសោធ

**design** /dɪˈzʌɪn/ [n] ប្លង់ (ពិសោធ)

- balanced incomplete block design /ˈbalənst ɪnkəmˈpliːt blɒk dɪˈzʌɪn/ [n] ការរៀបចំប្លុកពេញលេញលំនឹង (ការរៀបចំប្លង់ពិសោធន៍ដែលក្នុងបណ្តាប្លុកដែលមានទំហំប៉ុនគ្នាត្រូវបានបង្កើតឡើង ប៉ុន្តែប្លុកនីមួយៗមានចំនួនតិចជាងចំនួនសរុបរបស់កញ្ចប់គ្រាប់ពូជដែលត្រូវយកមកដាំសាកល្បង។)
- complete pedigree design /kəmˈpliːt ˈpɛdɪgriː dɪˈzʌɪn/ [n] ការរៀបចំគ្រោងការណ៍ដាំឈើជាពង្សាវលី ( គ្រោងការណ៍បង្កាត់(ជម្រើស)ដែលគេស្គាល់ពង្សាវតារបស់មេបាទាំង២។)
- completely random design (CRD) /kəmˈpliːtli ˈrandəm dɪˈzʌɪn/ [n] ការរៀបចំប្លង់ពិសោធតាមការចាប់ការឆ្នោតពេញលេញ
- factorial design /fakˈtɔːrɪəl dɪˈzʌɪn/ [n] (សទិសន័យ៖ tester design) គ្រោងការណ៍បង្កាត់ជា factor (ការរៀបចំបង្កាត់ពង្សាវលីទាំងអស់ដែលក្នុងសមាជិកទាំងនោះមានភេទមួយ (ក្នុងករណីជាប្រភេទដើមឈើមានផ្កាញីឈ្មោល ភេទត្រូវបានគេកំណត់ទុក) ត្រូវបានគេបង្កាត់ឱ្យផ្គុំជាមួយសមាជិកជាច្រើនដែលមានភេទផ្សេង)
- group balanced block design gruːp ˈbalənstm blɒk dɪˈzʌɪn/ [n] ការរៀបចំប្លង់ ឬស្រែពិសោធក្រុមប្លុក
- hierarchical mating design /hʌɪəˈrɑːkɪk(ə)l ˈmeɪtɪŋ dɪˈzʌɪn/ [n] សូមមើលពាក្យ៖ nested design
- incomplete block design /ɪnkəmˈpliːt blɒk dɪˈzʌɪn/ [n] ការរៀបចំប្លុកមិនពេញលេញ
- incomplete pedigree design /ɪnkəmˈpliːt ˈpɛdɪgriː dɪˈzʌɪn/ [n] ការរៀបផែនការបង្កាត់ពង្សាវលីមិនពេញលេញ (ការរៀបចំផែនការឱ្យបង្កាត់គ្នាដែលមានតែមេបាម្ខាងគេស្គាល់សម្រាប់ផលិតកូនមួយបែប ឧ.open pollinated mating (ការបង្កាត់ដោយសេរី), Polycross design និងជួនកាល Topcross (សូមអាន)។ ពាក្យន័យ ផ្ទុយ Complete pedigree design (ការរៀបប្លង់បង្កាត់ពង្សាវលីមិនពេញលេញ)។)
- latin square design /ˈlatɪn skwɛː dɪˈzʌɪn/ [n] ការរៀបប្លង់ជាការេឡាតាំង
- lattice design /ˈlatɪs dɪˈzʌɪn/ [n] សូមមើលពាក្យ៖ latin square design
- mating design /ˈmeɪtɪŋ dɪˈzʌɪn/ [n] ការរៀបចំផ្គូរផ្គង, ការរៀបចំបង្កាត់ពូជ
- nested design /nɛstɪd dɪˈzʌɪn/ [n] (សទិសន័យ៖ hierarchical mating design) ការរៀបប្លង់បង្កាត់ពូជតាមវិធីសម្បុក
- pollen mix design /ˈpɒlən mɪks dɪˈzʌɪn/ [n] (សទិសន័យ៖ polycross design) ការរៀបចំគ្រោងការណ៍បង្កាត់ជាមួយលម្អងចម្រុះ
- polycross design /ˈpɒlikrɒs dɪˈzʌɪn/ [n] សូមមើលពាក្យ៖ pollen mix design
- polycross pollen mix design /ˈpɒlikrɒs ˈpɒlən mɪks dɪˈzʌɪn/ [n] ការរៀបចំគ្រោងការណ៍បង្កាត់ជាមួយលម្អងចម្រុះ (ការរៀបចំគ្រោងការណ៍បង្កាត់វង្សត្រកូលមិនពេញលេញ ដែលក្នុងនោះ ដើមញីនីមួយៗត្រូវបង្កាត់ជាមួយលម្អងចម្រុះ ដែលបានមកពីដើមមួយចំនួន។ អត្តសញ្ញាណគេអាចរក្សាបានតែដើមមេ។ ជាទូទៅ លម្អងជាច្រើនត្រូវបានលាយបញ្ចូលលគ្នា ដើម្បីធានាថា ដើមមេទាំងអស់បានទទួលយកគំរូលម្អងពីតំណាងដើមឈ្មោលផ្សេងៗ។ ល្បាយលម្អងអាចយកទៅរោយដោយសិប្បនិមិត្តទៅលើដើមមេនីមួយៗ ឬការជ្រើសរើសនេះ អាចរោយខ្លួនឯងដោយចំហតាមធម្មជាតិ និងដោយចៃដន្យនៅក្នុងប្លុកនៅដាច់ពីគេឯង(ចម្ការពូជដាំ)។ តាម រយៈការធ្វើពិសោធន៍ គេអាចវាយតម្លៃពីសមត្ថភាពបង្កាត់គ្នាទូទៅក្នុងចំណោមដើមឈ្មោល-ញី ដែលគេបានជ្រើសរើស។

- randomized complete block design (RCB) /ˈrandəmʌɪzt kəmˈpliːt blɒk dɪˈzʌɪn/ [n] ការរៀបពិសោធជាប្លុកតាមការចាប់ឆ្នោតពេញលេញ
- split block design /splɪt blɒk dɪˈzʌɪn/ [n] ការរៀបចំប្លង់ដាំបែកគ្នា (ការរៀបចំប្លង់ដាំពិសោធន៍ដែលនៅក្នុងនោះគេធ្វើការសាកល្បងច្រើនជាង១ឯកតា ឧ. ដាក់ជី និងអំបូរ (ពូជ)។ តំបន់ដាំពិសោធន៍ត្រូវបានចែកចេញជាប្លុក (ពីរ បី) ដែលគេខណ្ឌចែកបន្តទៅទៀតជាអនុប្លុក ដែលផ្សំពីឡូត៍គំរូ។ ឡូត៍គំរូត្រូវបានដាក់រាយប៉ាយនៅក្នុងអនុប្លុកហើយអនុប្លុកត្រូវបានដាក់តាំងរាយប៉ាយនៅក្នុងប្លុក។ ក្នុងរូបភាព វាមាន ៣ប្លុក (៣ជួរឈរ) ប្លុកនីមួយៗ មាន៦អនុប្លុក។)
- split-plot design /splɪt plɒt dɪˈzʌɪn/ [n] ការរៀបចំប្លង់ ឬស្រែពិសោធបំបែក
- test design /tɛst dɪˈzʌɪn/ [n] គ្រោងការណ៍ធ្វើពិសោធ
- tester design /ˈtɛstə dɪˈzʌɪn/ [n] សូមមើលពាក្យ៖ factorial design

**desilicificaiton** /disɪlɪsɪfɪˈkeɪʃ(ə)n/ [n] ការហូរចេញនៃសារធាតុស៊ីលីស

**desinsectization** [n] ការសម្លាប់សត្វល្អិត

**desmo-** /ˈdɛsməʊ/ [prefix] (ដូច៖ des-) បុព្វបទមានន័យថា ចំណងឬ ច្រវាក់

**desolation** /dɛsəˈleɪʃ(ə)n/ [n] ការបំផ្លិចបំផ្លាញ

**desorption** /diːˈsɔːpʃ(ə)n/ [n] ការភាយសំណើម (ការបាត់បង់សំណើមដោយសារតែសារធាតុស្រូបសំណើម។ ដូចជាគ្រាប់ វាហួតជាតិទឹកចេញរហូតដល់កម្រិតសំណើមមួយស្មើនឹងកម្រិតសំណើមក្នុងខ្យល់។ ពាក្យផ្ទុយ Absorption។)

**desquamation** /ˌdɛskwəˈmeɪʃ(ə)n/ [n] ការរបកក្រមរ, ការរបកស្រកា

**destroy** /dɪˈstrɔɪ/ [v] បំផ្លិចបំផ្លាញ, សម្លាប់

**clay destroying** /kleɪ dɪˈstrɔɪn/ [n] ការធ្វើឱ្យខូចខ្ទេចខ្ទីនៃរចនាសម្ព័ន្ធក្រាមឥដ្ឋ

**destruction** /dɪˈstrʌkʃ(ə)n/ [n] ការបំផ្លាញ
- ecological destruction /iːkəˈlɒdʒɪk(ə)l dɪˈstrʌkʃ(ə)n/ [n] ការបំផ្លាញអេកូឡូស៊ី

**detergent** /dɪˈtəːdʒ(ə)nt/ [n] ថ្នាំកាត់ក្អែល, សាប៊ូម្សៅ, សាប៊ូ (សារធាតុសំយោគមួយប្រភេទប្រើសម្រាប់លាងជម្រះជាតិខ្លាញ់ ប្រេង ឬជាតិកខ្វក់អ្វីមួយ)
- synthetic detergent /sɪnˈθɛtɪk dɪˈtəːdʒ(ə)nt/ [n] សារធាតុសំយោគ

**deteriorate** /dɪˈtɪərɪəreɪt/ [v] ចុះថយ, ដុនដាប, ធ្វើឱ្យកាន់តែយ៉ាប់, ធ្វើឱ្យកាន់តែអាក្រក់ឡើង

**deterioration** /dɪˌtɪərɪəˈreɪʃn/ [n] កំហូច
- environmental deterioration /ɪnvʌɪrənˈmɛnt(ə)l dɪˌtɪərɪəˈreɪʃn/ [n] កំហូចបរិស្ថាន
- seed deterioration /siːd dɪˌtɪərɪəˈreɪʃn/ [n] ដំណើរវិវត្តន៍ក្នុងកោសិកាបណ្តាលឱ្យគ្រាប់ស្លាប់
- soil deterioration /sɔɪl dɪˌtɪərɪəˈreɪʃn/ [n] ការរេចរឹលដី
- water equality deterioration /ˈwɔːtəɪˈkwɒlɪtidɪˌtɪərɪəˈreɪʃn/ [n] កំហូចគុណភាពទឹក

**determination** /dɪˌtəːmɪˈneɪʃ(ə)n/ [n] ការកំណត់

**detoxification** /diːˌtɒksɪfɪˈkeɪʃ(ə)n/ [n] ការបន្សាបជាតិពុល

**detoxify** /diːˈtɒksɪfʌɪ/ [v] បន្សាបជាតិពុល

**detritivore** /dɪˈtrɪtɪvɔː/ [n] សត្វស៊ីសាកសព ឬសំណល់សរីរាង្គនៃសារពាង្គកាយនានា

**detritus** /dɪˈtrʌɪtəs/ [n]
១. សូមមើលពាក្យ៖ debris
២. កម្ទេចកំទី (កម្ទេចកំទីសរីរាង្គដែលលិចទៅបាតទឹក)

**deutoplasm** /ˈdutəˌplazəm/ [n] ដឺតូប្លាស (ស៊ុតលឿង ឬសារធាតុអាហាររបស់ស៊ុតលឿង)

**devastate** /ˈdɛvəsteɪt/ [v] ធ្វើឱ្យខ្ទេចខ្ទី

**develop** /dɪˈvɛləp/ [v]
១. (ចំពោះសត្វ) ធ្វើឱ្យលូតលាស់
២. បង្កើត, រីកចម្រើន, អភិវឌ្ឍ

**development** /dɪˈvɛləpm(ə)nt/ [n] ការលូតលាស់, ការអភិវឌ្ឍ (ដំណើរការដែលកោសិកាមួយក្លាយទៅជាសរីរាង្គពេញលេញមួយ)
- courseware development /ˈkɔːswɛː dɪˈvɛləpm(ə)nt/ [n] ការអភិវឌ្ឍសម្ភារក្នុងវគ្គសិក្សា
- crop development /krɒp dɪˈvɛləpm(ə)nt/ [n] អភិវឌ្ឍកម្មនៃដំណាំ, អភិវឌ្ឍន៍ដំណាំ
- curriculum development /kəˈrɪkjʊləm dɪˈvɛləpm(ə)nt/ [n] ការអភិវឌ្ឍន៍លើកម្មវិធីសិក្សា

- panicle development /ˈpanɪk(ə)l dɪˈvɛləpm(ə)nt/ [n] អភិវឌ្ឍន៍កម្មក្ហូរ (ដំណាក់កាលលូតលាស់នៃស្រូវដែលក្នុងនោះគ្រាប់ស្រូវអាចលេចចេញជារូបរាងឡើង ហើយក្ហូរស្រូវបង្កើនប្រវែងរបស់វានៅក្នុងស្រទបស្លឹកទង់ជ័យ)
- rural development /ˈrʊər(ə)ldɪˈvɛləpm(ə)nt/ [n] ការអភិវឌ្ឍជនបទ
- soil development /sɔɪl dɪˈvɛləpm(ə)nt/ [n] ការវិវត្តន៍នៃដី
- sustainable development /səˈsteɪnəb(ə)ldɪˈvɛləpm(ə)nt/ [n] ការអភិវឌ្ឍដោយនិរន្តរភាព
- varietal development /vəˈrʌɪət(ə)l dɪˈvɛləpm(ə)nt/ [n] ការអភិវឌ្ឍពូជ (ដំណើរការដែលក្នុងនោះពូជថ្មីៗត្រូវបានបង្កើតឡើង)

**devil's horsewhip** [n] ស្មៅអណ្ដាតគោ (ឈ្មោះវិទ្យាសាស្ត្រ *Achyranthes aspera*)

**devonian** /dɛˈvəʊnɪən/ [n] ដេវ៉ូញៀង

**dew** /ˈdjuː/ [n] ទឹកសន្សើមដែលជាប់លើស្លឹកឈើនាពេលព្រលឹម

**dewclaw** /ˈdjuːklɔː/ [n] ខ្នាយ, ឆ្នាល់ (មាន់), ម្រាមទី១ នៅផ្នែកខាងលើនៃជើងឆ្កែ

**dewlap** /ˈdjuːlap/ [n] ប្លូរគោ

**deworm** /diːˈwəːm/ [v] ទម្លាក់បរាសិត

**dextro-** /ˈdɛkstrəʊ/ [prefix] បុព្វបទមានន័យថា នៅខាងស្ដាំ

**dextrose** /ˈdɛkstrəʊz/ [n] ស្ករដិចស្ត្រូស, ស្ករម៉្យាងនៃក្រុមគ្លុយកូស

**di-** /di/ [prefix] បុព្វបទមានន័យថា ពីរ

**dia-** /dʌɪə/ [prefix] បុព្វបទមានន័យថា ឆ្លងកាត់

**diabetes** /dʌɪəˈbiːtiːz/ [n] រោគទឹកនោមផ្អែម (មធុមេហរោគ)

- diabetes insipidus /dʌɪəˌbiːtiːz ɪnˈsɪpɪdəs/ [n] ជំងឺទឹកនោមសាប
- diabetes mellitus /dʌɪəˌbiːtiːz mɪˈlʌɪtəs/ [n] ជំងឺទឹកនោមផ្អែម (បណ្ដាលឱ្យស្រេកឃ្លាន ខ្សោយ ដង្ហក់)

**diabetic** /dʌɪəˈbɛtɪk/ [adj] អ្នកកើតរោគទឹកនោមផ្អែម, នៃរោគទឹកនោម

**diadelphous** /ˌdʌɪəˈdɛlfəs/ [adj] កេសរឈ្មោលផ្គុំគ្នាជាពីរបាច់

**diagnose** /dʌɪəgˈnəʊz/ [v] វិនិច្ឆ័យរោគ

**diagnosis** /ˌdʌɪəgˈnəʊsɪs/ [n] រោគវិនិច្ឆ័យ

**diagram** /ˈdʌɪəgram/ [n] ដ្យាក្រាម (រូបភាពបង្ហាញពីលក្ខណៈពិសេសៗដោយគូសជាបន្ទាត់ គំនូរ និងនិមិត្តសញ្ញាផ្សេងទៀត)

***Dialium cochinchinense*** [sci.n] ក្រឡាញ់

**diallel** /dʌɪəˈliːl/ [n, adj] ឌីអាឡែល (លក្ខណៈដែលកំណត់ដោយអាឡែល ឬ សម្ពន្ធករ មួយគូ)។

- complete diallel /kəmˈpliːt dʌɪəˈliːl/ [n] (សទិសន័យ៖ full diallel) ឌីអាលែលពេញលេញ
- full diallel /fʊl dʌɪəˈliːl/ [n] សូមមើលពាក្យ៖ complete diallel
- half diallel /hɑːf dʌɪəˈliːl/ [n] ពាក់កណ្ដាលឌីអាលែល
- incomplete diallel /ɪnkəmˈpliːt dʌɪəˈliːl/ [n] ឌីអាលែលមិនពេញលេញ, ឌីអាលែលមិនគ្រប់ចំនួន
- partial diallel /ˈpɑːʃ(ə)l dʌɪəˈliːl/ [n] ការបង្កាត់ពូជរក្សាទុកឌីអាលែលខ្លះ, ការបង្កាត់ឌីអាលែលដោយផ្នែក (ដៃអឺលែលមួយ ដែលឯកត្តៈ អំបូរ ឬប្រភេទនៃអំបូរណាមួយអាចបាត់។ នៅក្នុងប្រភេទណាមួយនៃការ បង្កាត់អត្តសញ្ញាណទាំងរបស់គ្រាប់និងលម្អងមេបា ត្រូវបានរក្សាទុកសម្រាប់អំបូរនីមួយៗ។ )

**dialysis** /dʌɪˈalɪsɪs/ [n] ដ្យាលីស

**diapause** /ˈdʌɪəpɔːz/ [n] ផ្អាកលូតលាស់, ការផ្អាក (រយៈកាលនៃការដាំដុះ ឬការលូតលាស់ណាមួយត្រូវផ្អាក ឬមិនមានសកម្មភាពទៀត)

***Diaphania indica*** [sci.n] មេអំបៅត្រសក់ ឬឌីឡឺក

**diaphragm** /ˈdʌɪəfram/ [n] សន្ទះទ្រូង

**diarrhea** /ˌdʌɪəˈrɪə/ [n] ចុះរាក, ជំងឺរាករូស, ការចុះរាក

- diarrhea chicken /ˌdʌɪəˈrɪə ˈtʃɪkɪn/ [n] ជំងឺរាកមាន់

**diaspore** /ˈdʌɪəspɔː/ [n] គ្រាប់ឯកតាពង្រាយគ្រាប់

**diastase** /ˈdʌɪəsteɪz/ [n] ដ្យាស្តាស (ឈ្មោយអង់ស៊ីមមាននៅក្នុងគ្រាប់ ដូចជាក្នុងគ្រាប់ធញ្ញជាតិដែលមាននាទីបំបែកអាមីដុង)

**diastole** /dʌɪˈastəli/ [n] រយៈកាលបេះដូងពន្លា

**diatom** /ˈdʌɪətəm/ [n] ដ្យាតូម, ដ្យាតូមេ (ភាវរស់ស្វ័យជីពឯកកោសិកាដែលមានភ្នាសគ្រោងសម្បូទៅដោយជាតិស៊ីលីស)

**dibble** /ˈdɪb(ə)l/ [n] ឈើច្រាន, ឈើបុក

**dibbling** /ˈdɪb(ə)lɪŋ/ [n] ការបុកដាំ (វិធីសាស្ត្រក្នុងការដាំដុះដោយប្រើឈើ និងឫស្សីជាដើមសម្រាប់បុកដាំ ដែលវិធីនេះ គេអនុវត្តលើស្រែជម្រាល ឬភ្នំ)

**dichasium** /dʌɪˈkeɪzɪəm/ [n] ឌីកាសៀម (កញ្ចុំផ្កាដែលមាទងប្រឈមគ្នា និងស្ទើរតែស្មើគ្នា)

**dichlamydeous** /ˌdʌɪkləˈmɪdɪəs/ [adj] ឌីក្លាមីដៀ (ត្របក និងស្រទាប់រៀបគ្នាជារង្វង់ មានពីររង្វង់នៅលើបរិបុប្ផារបស់ផ្កា)

**dichogamy** /dʌɪˈkɒgəmi/ [n] ឌីកូកាមី, ភាពមិនត្រូវពេលគ្នានៃការរីករបស់ផ្កាញី និងផ្កាឈ្មោល (ការទុំរបស់ប្លោកលម្អង និងអូវុលនៅពេលខុសគ្នា។ ការឡើងពេញវ័យរបស់សរីរាង្គបន្តពូជឈ្មោលនិងញីនៅលើដើមឈើតែមួយខុសពេលគ្នា ដូច្នេះការពោយ លម្អង និងការទទួលយកលម្អងពីកេសរញីមិនត្រូវពេលគ្នា។ បាតុភូតដៃខូហ្គាមីជំរុញឱ្យមានការពោយលម្អងឆ្លងគ្នា ដោយធម្មជាតិ។ បាតុភូតដៃខូហ្គាមីមាន២ប្រភេទ គឺ protandry គឺឈ្មោលពេញវ័យមុន និង protogyny គឺញីពេញវ័យមុន។)

***Dicladispa armigera*** [sci.n] សូមមើលពាក្យ៖ hispa

**dicliny** /dɪˈklɪni/ [n] ពួករុក្ខជាតិមានផ្កាភេទផ្សេងគ្នា (ការបែងចែកនៃរចនាសម្ព័ន្ធបន្តពូជឈ្មោលនិងញីទៅជាផ្កាខុសគ្នា។ រុក្ខជាតិមានផ្កាភេទផ្សេងគ្នា អាចមាន ឬ មួយនៅលើដើមតែមួយ (monoecious) ឧ.ពួកស្រល់ ឬមានផ្កាភេទនៅដើមឈើ២ផ្សេងគ្នា(dioecious) ឧ.ប្រភេទ Populus និងផ្តៅ។)

**dicot** /ˈdʌɪkɒt/ [n] (ពាក្យកាត់នៃ dicotyledone) ឌីខត (អង់ស្យូស្ពែមដែលអំប្រីយ៉ុងមានកូទីលេដុងពីរ)

**dicotyledon** /ˌdʌɪkɒtɪˈliːd(ə)n/ [n] ទោពីជបត្ររុក្ខជាតិ, ឌីកូទីឡេដុង (ប្រភេទរុក្ខជាតិដែលមានពន្លកស្លឹកពីរនៅក្នុងគ្រាប់)

**Dictyocaulus** [n] ឌិចស្យូកូលីស (ប្រភេទដង្កូវណេម៉ាតូតក្នុងថ្លើម)

**Dictyoptera** /ˌdɪktɪˈɒptərə/ [n] ឌិចទីអុបតេរ៉ា (លំដាប់មួយរបស់សត្វល្អិតរួមមាន កណ្តូបសេះ និងកន្លាត)

**dicumarol** /dikjuːmərəʊl/ [n] ឌីគុយម៉ារ៉ុល (ថ្នាំ)

**didymous** /ˈdʌɪdɪməs/ [adj] តម្រៀបគ្នាជាគូ (អំពីទម្រង់រុក្ខជាតិ)

**didymus** /di'dʌɪmʌs/ [n] ពងស្វាស

**didynamous** /dʌɪˈdɪnəməs/ [adj] កេសរឈ្មោលវែងពីរ និងខ្លីពីរ

**dieback** /ˈdʌɪbak/ [n] ជំងឺងាប់មែក

**dieldrin** /ˈdiːldrɪn/ [n] ដៀលឌ្រីន

**diesel** /ˈdiːz(ə)l/ [n] ប្រេងម៉ាស៊ូត (អង្គធាតុសម្រាប់ផ្តល់ចលនាឱ្យចលករម៉ាស៊ូត)

- diesel engine /ˈdiːz(ə)l ˈɛndʒɪn/ [n] ម៉ាស៊ីនប្រើប្រេងម៉ាស៊ូត, ចលករម៉ាស៊ូត (ចលករចំហេះក្នុងដែលដើរដោយម៉ាស៊ីនម៉ាស៊ូត)
- diesel fuel /ˈdiːz(ə)l fjuː(ə)l/ [n] ឥន្ធនៈ, ប្រេងម៉ាស៊ូត

**diestrus** /dʌɪˈiːstrəs/ [n] ពេលខ្លីដែលឥតទទួលកូន

**diet** /ˈdʌɪət/ [n] ការបង្អត់អាហារ, អាហារបញ្ញត្តិ, របបអាហារ

- balanced diet /ˈbalənst ˈdʌɪət/ [n] របបអាហារគុណភាព
- bland diet /bland ˈdʌɪət/ [n] របៀបបរិភោគអាហារដែលទន់ៗស្រួលរំលាយ ជាជាងអាហារដែលហឹរ, ញៀន, រឹង, មានសរសៃ, ខ្លាញ់, បន្លែស្រស់, ឬទឹកក្រូចជាដើម
- low fat diet /ləʊ fat ˈdʌɪət/ [n] របបអាហារដែលមានជាតិខ្លាញ់ទាប
- normal diet /ˈnɔːm(ə)l ˈdʌɪət/ [n] របបអាហារធម្មតា

**dietary energy consumption** /ˈdʌɪət(ə)ri ˈɛnədʒi kənˈsʌm(p)ʃ(ə)n/ [n] ការបរិភោគរបបអាហារមានថាមពល (ផ្អែកទៅលើទិន្នន័យថ្នាក់ជាតិស្តីអំពីភាពមានស្បៀង និងតម្រូវការស្បៀង ការបរិភោគរបបអាហារមានថាមពលកម្រិតមធ្យម ត្រូវបានគិតជាគីឡូកាឡូរីក្នុងម្នាក់ក្នុងមួយថ្ងៃ)

**Dietary Energy Unit Value** /ˈdʌɪət(ə)ri ˈɛnədʒi ˈjuːnɪt ˈvaljuː/ [n] តម្លៃឯកតាថាមពលអាហារ

**differential** /ˌdɪfəˈrɛnʃ(ə)l/ [n] គម្លាត

- selection differential /sɪˈlɛkʃ(ə)n ˌdɪfəˈrɛnʃ(ə)l/ [n] គម្លាតលក្ខណៈជម្រើស (ចំពោះលក្ខណៈរបស់ឯកត្តៈ ភាពខុសគ្នារវាង លក្ខណៈមធ្យមរបស់ក្រុមពូជទាំងមូល និងមធ្យមរបស់ក្រុម ដើមដែលបានជ្រើសរើស។)

**differential blood count (D.B.C)** /ˌdɪfəˈrɛnʃ(ə)l blʌd kaʊnt/ [n] ការពិសោធឈាមដើម្បីរាប់ភាពទីទៃពីគ្នានៃគុល្លិកាស

**differential diagnosis** /ˌdɪfəˈrɛnʃ(ə)l ˌdʌɪəgˈnəʊsɪs/ [n] រោគវិនិច្ឆ័យប្រៀបធៀប

**differentiation** /ˌdɪfərɛnʃɪˈeɪʃn/ [n] (ចំពោះរុក្ខជាតិ) ការបំបែកកោសិកា, ដំណាក់អ្វីមួយ (ដំណើរនៃកោសិកា ឬជាលិកាប្រែក្លាយមានតួនាទីពិសេស ជារចនាសម្ព័ន្ធអ្វីមួយ ឧ. ដំណាក់ផ្កា និងដំណាក់ អំប្រីយ៉ុង។)
- cell differentiation /sɛl ˌdɪfərɛnʃɪˈeɪʃn/ [n] បំប្លែងឯកទេសកោសិកា
- ecotypic differentiation /ˈiːkəʊtʌɪpɪk ˌdɪfərɛnʃɪˈeɪʃn/ [n] ការខុសប្លែកគ្នានៃប្រភេទក្នុងបរិស្ថានមួយ ( ដំណើរនៃការផលិតឯកត្តៈប្លែកៗគ្នានៅក្នុងប្រភេទពូជមួយ អនុប្រភេទ ឬភាពប្លែកៗ នៅក្នុងបរិស្ថានណា មួយដែលធ្វើឱ្យវាខុសប្លែកគ្នាខាងលក្ខណៈរូបនិងលក្ខណៈសរីរៈពីឯកត្តៈផ្សេងៗទៀតនៃប្រភេទដូចគ្នានេះ ដុះ នៅបរិស្ថានផ្សេង។)

**diffuse** /dɪˈfjuːz/ [v] ពង្រាយ, សាយភាយ

**diffusion** /dɪˈfjuːʒ(ə)n/ [n] សំណាយ, បន្សាយ
- facilitated diffusion /fəˈsɪlɪteɪtɪd dɪˈfjuːʒ(ə)n/ [n] បន្សាយសម្រួល
- diffusion gradient /dɪˈfjuːʒ(ə)n ˈgreɪdɪənt/ [n] ជម្រាលបន្សាយ

**digenesis** /ˌdʌɪˈdʒɛnɪsɪs/ [n] ឌីចេននេស៊ីស (ការផ្លាស់ប្តូរគ្នារវាងការបន្តពូជដោយភេទ និងឥតភេទ)

**digenetic** /ˌdʌɪˈdʒɛnnɛtɪk/ [adj] ប្តូរធ្នួល (ភាវរស់ដូចជា បរាសិត)

**digest** /dʌɪˈdʒɛst/ [v] រំលាយអាហារ

**digestion** /dʌɪˈdʒɛstʃ(ə)n/ [n] ការរម្លាយអាហារ, ការរំលាយអាហារ
- anaerobic digestion /ˌanɛːˈrəʊbɪkdʌɪˈdʒɛstʃ(ə)n/ [n] ការរំលាយដោយគ្មានខ្យល់
- chemical digestion /ˈkɛmɪk(ə)l dʌɪˈdʒɛstʃ(ə)n/ [n] រំលាយអាហារបែបគីមី (ការបំបែកចំណីអាហារដោយអំពើនៃអង់ស៊ីម និងសារធាតុបំបែកខ្លាញ់)
- mechanical digestion /mɪˈkanɪk(ə)l dʌɪˈdʒɛstʃ(ə)n/ [n] រំលាយអាហារមេកានិច

**digger** /ˈdɪgə/ [n] អ្នកជីក, គ្រឿងជីក

**digging-up** /dɪgin-ʌp/ [n] សូមមើលពាក្យ៖ gullying

***Digitaria adscendens*** [sci.n] ស្មៅសម្បុកមាន់

***Digitaria ciliaris*** [sci.n] សូមមើលពាក្យ៖ crab grass

***Digitaria setigera*** [sci.n] ស្មៅឌីស៊ីតារីយ៉ាសេទីសេរ៉ា

**Digitate** /ˈdɪdʒɪtət/ [adj] ដែលមានរាងស្រដៀងនឹងដៃលា (ឧ. ស្លឹកដំឡូងមីមានរាងដូចដៃលា)

**dikaryon** /diˈkarɪjən/ [n] ណ្វៃយ៉ូអាផ្លូអ៊ីតមួយគូ

**dike** /dīk/ [n] សូមមើលពាក្យ៖ dam
- little dike /ˈlɪt(ə)l dīk/ [n] ភ្លឺស្រែ, ទំនប់តូចៗ

**dilatation** /ˌdʌɪleɪˈteɪʃ(ə)n/ [n] ការពង្រីក, ការធ្វើឱ្យរីក

**dilate** /dʌɪˈleɪt/ [v] រីក, ធ្វើឱ្យរីក, ពង្រីក

**dill** /dɪl/ [n] ឌីល (ប្រភេទបន្លែ)

**diluent** /ˈdɪljʊənt/ [n] ពង្រាវករ, ធាតុពង្រាវ (សារធាតុរឹង រាវ ឬឧស្ម័នសម្រាប់លាយជាមួយធាតុសកម្មណាមួយដើម្បីបន្ថយនូវកំហាប់របស់វាតាមរូបមន្ត)

**dilute** /dʌɪˈl(j)uːt/ [v] ពង្រាវ

**dilute** /dʌɪˈl(j)uːt/ [adj] ដែលរាវ

**dilution** /dʌɪˈluːʃn/ [n] ពង្រាវកម្ម (ការធ្វើឱ្យកំហាប់នៃសារធាតុ ឬល្បាយណាមួយត្រូវថយចុះ)

**diminishing return** /dɪˈmɪnɪʃɪŋ rɪˈtəːn/ [n] ការត្រឡប់ជាអន់វិញ (តាមទ្រឹស្តី និយាយថា កាលណាគេធ្វើសុរុំខ្ជិកម្មដើមឈើកាន់តែទៅមុខលើប្រភេទឈើណាមួយ ទិន្នផល ទទួលបានកាន់តែតិចបើធៀបទៅនឹងការចំណាយ។ ដូច្នេះទ្រឹស្តីបញ្ជាក់ឱ្យដឹងថា ការធ្វើសុរុំខ្ជិកម្មដើមឈើលើកដំបូង នៅត្រឹមកម្រិតប្រភេទនិងប្រភពកំណើត វាចំណាយតិច តែទទួលបានទិន្នផលខ្ពស់ ទន្ទឹមនឹងនោះ ការបង្កាត់ពូជឈើតែមួយ ប្រភេទបន្តទៅទៀត ទទួលទន្និផលកាន់តែតិចធៀប ។)

**dimorphism** /dʌɪˈmɔːfɪz(ə)m/ [n] ទ្វេទម្រង់, ភាពផ្ទុយគ្នា (វត្តមាននៃទម្រង់២ផ្សេងគ្នារបស់រចនាសម្ព័ន្ធមួយ ឧ. ស្លឹកខាងត្រូវថ្ងៃ-ស្លឹកខាងម្លប់ ស្លឹកចាស់-ស្លឹកខ្ចីឈ្មោល-ញី ជាដើម។ល។)
- sexual dimorphism /ˈsɛkʃʊəl dʌɪˈmɔːfɪz(ə)m/ [n] ភេទលក្ខណៈ (លក្ខណៈសម្គាល់មួយដែលនៅក្នុងនោះសត្វល្អិតញី និងឈ្មោលនៅពេលពេញវ័យ មានលក្ខណៈរូបអាចសម្គាល់បានថាជាញី ឬឈ្មោល (ឧ. មេអំបៅដង្កូវរូងដើមពណ៌លឿង ខ្ទុតអង្គរញី ខ្ទុតឈ្មោលជាដើម))

**dioecious** /dʌɪˈiːʃəs/ [adj] ឯកភេទ (រុក្ខជាតិ ដែលមានផ្កាញី និងឈ្មោលស្ថិតនៅលើដើមតែមួយ)

**dioecy** /dʌɪˈiːsi/ [n] រុក្ខជាតិមានសរីរាង្គភេទនៅដើមឈើពីរផ្សេងគ្នា

**dioism** [n] ការដែលមានភេទនៅលើឯកត្តៈពីរផ្សេងគ្នា

***Dioscorea alata*** [sci.n] សូមមើលពាក្យ៖ winged yam (white flesh)

***Dioscorea alata* var. *purpurea*** [sci.n] សូមមើលពាក្យ៖ winged yam (purple flesh)

***Dioscorea hispida*** [sci.n] ក្ដួច

***Diospyros decandra*** [sci.n] ចាន់, ប៉ែន

***Diospyros kaki*** [sci.n] សូមមើលពាក្យ៖ Japanese persimmon

**dioxide** /dʌɪˈɒksʌɪd/ [n] ឌីអុកស៊ីត

**nitrogen dioxide** /ˈnʌɪtrədʒ(ə)ndʌɪˈɒksʌɪd/ [n] អាសូតឌីអុកស៊ីត, អាសូតអុកស៊ីត

**sulphur dioxide** /ˈsəlfərdʌɪˈɒksʌɪd/ [n] ស្ពាន់ធ័រឌីអុកស៊ីត

**dioxin** /dʌɪˈɒksɪn/ [n] ឌីអុកស៊ីន

**dip** /dɪp/ [v] ធ្លាក់ចុះ, ជ្រលក់

**Diphyllobothrium** /diˈfilʊəbʊəθrəm/ [n] ឌីភីឡូបូ-ទ្រីយ៉ូម

**diplobiont** /ˌdɪpləʊˈbaɪɒnt/ [n] សត្វទ្វេទម្រង់បន្តពូជ

**diplococcus** /ˌdɪplə(ʊ)ˈkɒkəs/ [n] (ពហុវចនៈ៖ diplococci) ឌីប្លូកូក, ឌីប្លូខកខឹស (បាក់តេរីរាងមូលដែលស្ថិតនៅជាគូនឹងគ្នា)

***Diplococcus pneumoniae*** [sci.n] ឌីប្លូខកខឹសភ្នឺម៉ូនី (ភ្នាក់ងារបង្កជំងឺរបស់បាក់តេរីបង្កជំងឺសួត)

**diploid** /ˈdɪplɔɪd/ [n] ឌីប្លូអ៊ីត (កោសិកាមួយ ឬសរីរាង្គមួយមានកោសិកាកើតឡើងដោយឈុតក្រូម៉ូសូមពីរ (២n))

**diplura** /dɪˈplʊərə/ [n] ឌីផ្លឺរ៉ា (លំដាប់មួយរបស់សត្វល្អិតគ្មានស្លាប ជាទូទៅគ្មានពណ៌ ឬមានពណ៌ ដែលរស់ក្នុងដី)

**Diplyllobothrium** [n] សូមមើលពាក្យ៖ Bothriocephalus

**Diptera** /ˈdɪpt(ə)rə/ [n pl] ពពួករុយ, ឌីបទែ

**diphtheria** /dɪfˈθɪərɪə/ [n] រោគខាន់ស្លាក់

**direct sowing** /dɪˈrɛkt səʊɪŋ/ [n] ពង្រាយគ្រាប់ពូជនៅលើតំបន់មួយ ដើម្បីដាំដុះព្រៃឈើ

**direction** /dɪˈrɛkʃ(ə)n/ [n] ទិសដៅ, ទិស

- wind direction /wɪnd dɪˈrɛkʃ(ə)n/ [n] ទិសខ្យល់

**director general (of department)** /dɪˈrɛktə ˈdʒɛn(ə)r(ə)l (ɒv dɪˈpɑːtm(ə)nt)/ [n] អគ្គនាយក (នាយកដ្ឋាន)

**Dirofilaria** /dirʊəfiˈlɛːrɪə/ [n] មីក្រូភីលែ (ពពួកដង្កូវណែម៉ាតូត ដែលបរាសិតនៅលើបេះដូងសត្វ)

**dirt** /dəːt/ [n] ធូលី

**disadvantaged group** /dɪsədˈvɑːntɪdʒd gruːp/ [n] ក្រុមជនងាយរងគ្រោះ (ប្រជាជនមួយក្រុមដែលមិនអាចទទួលបានតម្រូវការអាហារជាមូលដ្ឋានដោយសារ ហេតុផលណាមួយ ឬដោយសារការរួមផ្សំគ្នានៃហេតុការណ៍ទាំងអស់នោះ។)

**disaggregated** /dɪsˈagrɪgeɪtēd/ [adj] ផុយ (ថ្ម), រលួយ (សរីរាង្គពុក)

**disassimilation** /dɪsəsɪmɪˈleɪʃ(ə)n/ [n] អសមានកម្ម

**disaster preparedness** /dɪˈzɑːstə prɪˈpɛːrɪdnəs/ [n] ការត្រៀមបង្ការគ្រោះមហន្តរាយ

**disaster** /dɪˈzɑːstə/ [n] មហន្តរាយ, ការខូចខាត

- environmental disaster /ɪnvʌɪrənˈmɛnt(ə)l dɪˈzɑːstə/ [n] មហន្តរាយបរិស្ថាន
- man-made disaster /manmeɪd dɪˈzɑːstə/ [n] មហន្តរាយមនុស្ស
- natural disaster /ˈnatʃ(ə)r(ə)l dɪˈzɑːstə/ [n] មហន្តរាយធម្មជាតិ, គ្រោះធម្មជាតិ
- weather disaster /ˈwɛðədɪˈzɑːstə/ [n] មហន្តរាយធាតុអាកាស

**disc** /dɪsk/ [n]

១. (ចំពោះសត្វ) ជំងឺខ្លួន

២. (ចំពោះរុក្ខជាតិ) ថាស (ផ្នែករបស់ទម្រផ្កា នៅព័ទ្ធជុំវិញអូវែររបស់រុក្ខជាតិ ដែលជាលក្ខណៈសាច់ហើយជួនកាលមានបញ្ចេញទឹកដមផ្កា)

៣. ថាស (នង្គ័ល)

**discard** /dɪˈskɑːd/ [v] (សទិសន័យ៖ reject) ជម្រុះចោល (ការយកចេញនូវអ្វីមួយដែលមិនត្រូវការ)

**discharge** /ˈdɪstʃɑːdʒ/ [n] រំហូរ, ការបង្ហូរចេញ

- flow discharge /fləʊ dɪsˈtʃɑːdʒ/ [n] ធារទឹក

- sediment discharge /ˈsɛdɪm(ə)nt dɪsˈtʃɑːdʒ/ [n] ធារកម្មេចកំណ
- stream discharge /striːm dɪsˈtʃɑːdʒ/ [n] (សទិសន័យ៖ stream flow) ធារទឹក
- toxic discharge /ˈtɒksɪk dɪsˈtʃɑːdʒ/ [n] ការបង្ហូរទឹកកខ្វក់មានសារធាតុពុល
- waste discharge /weɪst dɪsˈtʃɑːdʒ/ [n] ការបង្ហូរទឹកលូសម្អុយចេញ

***Discherodontus ashmeadi*** [sci.n] សូមមើលពាក្យ៖ redtail barb

**discoidal** /dɪˈskɔɪd(ə)l/ [adj] រាងដូចថាស

**discoloration** /ˌdɪskʌləˈreɪʃn/ [n] ការធ្វើឱ្យបាត់បង់ពណ៌ (ឧ. កោសិកា)

**devastating disease** /ˈdɛvəsteɪtɪŋ dɪˈziːz/ [n] ជំងឺរាតត្បាត

**disease** /dɪˈziːz/ [n] ជំងឺ (សមាសភាពចម្រៃដែលរំខាន ឬបំផ្លាញដល់ភាពប្រក្រតីនៃដំណើរជីវគីមីរបស់ដំណាំដោយមីក្រូសរីរាង្គបង្កជំងឺ)

- Aujesky's disease [n] (សទិសន័យ៖ mad itch, pseudorabies) ជំងឺអូសេស្គី (ជំងឺដែលមានសញ្ញាប្រហែលនឹងជំងឺឆ្កែឆ្កួត)
- bacterial disease /bakˈtɪərɪəl dɪˈziːz/ [n] ជំងឺបាក់តេរី
- chronic disease /ˈkrɒnɪk dɪˈziːz/ [n] ជំងឺរ៉ាំរ៉ៃ
- crown-gall disease /kraʊn gɔːl dɪˈziːz/ [n] ជំងឺកំពកដើម
- dwarf disease /dwɔːf dɪˈziːz/ [n] ជំងឺតឿ (ជំងឺវីរុសឆ្លងតាមរយៈពពួកមមាចស្លឹកដែលជាភ្នាក់ងារចម្លង ដែលដំបូង វាបង្ហាញរោគសញ្ញាស្លឹកជាចំណុចលឿងនៅតាមបណ្តោយសរសៃវ៉ែននៃស្លឹក ចំពោះស្លឹកខ្ចី ដែលមិនមូលចុង ហើយមានពណ៌លឿង បៃតង កាលណាមើលឆ្លុះនឹងពន្លឺថ្ងៃ ដើមដងជំងឺមានភាពតឿ)
- fungal disease /ˈfʌŋg(ə)l dɪˈziːz/ [n] ជំងឺផ្សិត (ជំងឺដែលបង្កដោយពួកផ្សិត)
- giallume disease /gɪəlljuːm dɪˈziːz/ [n] ជំងឺវីរុសបង្កដោយភ្នាក់ងារចម្លងម្យ៉ាងស្រដៀងចៃ ឬក្រា ឈ្មោះ *Rhopalosiphium padi* (វាមានរោគសញ្ញាដូចជា តឿ បៃកគុម្ពតិច ស្លឹកប្រែពណ៌ពីបៃតងទៅលឿង ឬលឿងទុំ)
- infectious disease /ɪnˈfɛkʃəs dɪˈziːz/ [n] ជំងឺឆ្លង
- mad cow disease /mad kaʊ dɪˈziːz/ [n] សូមមើលពាក្យ៖ Bovine Spongiform Encephalo-pathy
- mammary gland disease /ˈmaməri gland dɪˈziːz/ [n] ជំងឺក្រពេញទឹកដោះ
- plant disease /plɑːnt dɪˈziːz/ [n] ជំងឺរុក្ខជាតិ
- sickle cell disease /ˈsɪk(ə)l sɛl dɪˈziːz/ [n] ជំងឺកោសិកាឈាមក្រហមដែលធ្វើឱ្យខ្វះឈាម
- soil disease /sɔɪl dɪˈziːz/ [n] ជំងឺដី, ដីដែលទទួលការរេចរឹលដោយហេតុផ្សេងៗ
- vectors of waterborne disease /ˈvɛktə ɒv ˈwɔːtəbɔːn dɪˈziːz/ [n] ភ្នាក់ងារចម្លងជំងឺបង្កតាមទឹក
- venereal disease /vɪˈnɪərɪəl dɪˈziːz/ [n] រោគរាលដាលឆ្លងតាមរយៈការរួមដំណេក (ស្វាយ, ប្រមេះ)
- vesicular disease /vɪˈsɪkjʊlə dɪˈziːz/ [n] ជំងឺពងទឹករងៃ (អុតក្តាម)
- vitamin deficiency disease /ˈvɪtəmɪn dɪˈfɪʃ(ə)nsi dɪˈziːz/ [n] ជំងឺខ្វះវីតាមីន
- Dang' s disease /baŋs dɪˈziːz/ [n] សូមមើលពាក្យ៖ brucellosis
- terminal disease /ˈtəːmɪn(ə)l dɪˈziːz/ [n] ជំងឺដែលគង់តែនឹងស្លាប់
- deficiency disease /dɪˈfɪʃ(ə)nsi dɪˈziːz/ [n] ជំងឺខ្វះជីវជាតិ

**disinfect** /dɪsɪnˈfɛkt/ [v] រម្ងាប់មេរោគ

**disinfectant** /dɪsɪnˈfɛkt(ə)nt/ [n] ភ្នាក់ងារសម្លាប់មីក្រុប, ថ្នាំសម្លាប់មីក្រុប

**disinfection** /ˌdɪs(ɪ)nˈfɛkʃn/ [n] ការសម្លាប់មីក្រុប, ការរម្ងាប់មេរោគ

**disintegration** /dɪsˌɪntɪˈgreɪʃ(ə)n/ [n] ការដាច់ចេញ, របេច, ការបែកចេញ, ការបំបែក

**disjunct** /ˈdɪsdʒʌŋ(k)t/ [adj] ដាច់ពីគ្នា

**dislocate** /ˈdɪsləkeɪt/ [v] បំភ្លាត់, បំបែក

**dislocation** /ˌdɪslə(ʊ)ˈkeɪʃ(ə)n/ [n] ការបាក់គ្រេច, ការភ្លាត់ឆ្អឹង

**dissolve** /dɪˈzɒlv/ [v] រំលាយ, រលាយ

**disorder** /njʊˈtrɪʃ(ə)n(ə)l dɪsˈɔːdə/ [n] អប្រក្រតីភាព, វិបត្តិ, ចលាចល, ការមានជំងឺដោយសារអ្វីមួយ

- attention deficit disorder /əˈtɛnʃ(ə)n ˈdɛfɪsɪt dɪsˈɔːdə/ [n] ឧនភាពខាងការប្រុងស្មារតី
- autistic disorder /ɔːˈtɪstɪk dɪsˈɔːdə/ [n] វិកលមនោវិកត (ដំណើរភ្លាត់)
- bipolar disorder /bʌɪˈpəʊlə dɪsˈɔːdə/ [n] វិបត្តិសតិអារម្មណ៍ ដោយមាន ការខូចចរិត និងការធ្លាក់ទឹកចិត្ត
- iodine deficiency disorder /ˈʌɪədiːn dɪˈfɪʃ(ə)nsi dɪsˈɔːdə/ [n] ជំងឺពកក
- nutritional disorder /njʊˈtrɪʃ(ə)n(ə)l dɪsˈɔːdə/ [n] អប្រក្រតីភាពនៃសារធាតុចិញ្ចឹម (ភាពមិនប្រក្រតីនៃដំណាំស្រូវបណ្តាលមកពីកង្វះសារជាតុចិញ្ចឹម និងភាពពុលបណ្តាលមកពីកម្រិតច្រើនហួសណាមួយ ឬដែកក្នុងដី ឬការពន្យឺតភាពលូតលាស់ដែលបណ្តាលមកពីសម្ពាធអូស្មូសនៃសូលុយស្យុងដីខ្ពស់)
- organic disorder /ɔːˈganɪk dɪsˈɔːdə/ [n] វិបត្តិសរីរាង្គ
- schizoaffective disorder /ˈskɪtsəʊəˈfɛktɪv dɪsˈɔːdə/ [n] វិបត្តិទាំងសតិ- សម្បជញ្ញៈ និងប្រាជ្ញា
- manic-depressive disorder /ˈmanɪk dɪˈprɛsɪv dɪsˈɔːdə/ [n] វិបល្លាស សតិបញ្ញា (ការភ្លាត់ខុសនៃសតិបញ្ញា)
- neuromuscular disorder /ˌnjʊərəʊˈmʌskjʊlə dɪsˈɔːdə/ [n] វិបល្លាស សរសៃញ្ញាណ (សរសៃវិញ្ញាណមិនដើរប្រក្រតី)
- obsessive-compulsive disorder /əbˈsɛsɪv kəmˈpʌlsɪv dɪsˈɔːdə/ [n] វិបត្តិដែលបង្ខំឱ្យគិតមមៃជានិច្ច
- panic disorder /ˈpanɪk dɪsˈɔːdə/ [n] វិបត្តិដែលនាំឱ្យស្លន់ស្លោ ឬបារម្ភយ៉ាងខ្លាំង
- pervasive developmental disorder /pəˈveɪsɪv dɪˌvɛləpˈmɛnt(ə)l dɪsˈɔːdə/ [n] រាលដាលខ្លាំងនៃវិបត្តិខាងគំនិតនិងប្រាជ្ញា

**disorientation** /dɪsɔːrɪɛnˈteɪʃ(ə)n/ [n] ការវង្វេងស្មារតី

**dispensary** /dɪˈspɛns(ə)ri/ [n] កន្លែងព្យាបាល និងចែកថ្នាំជាពិសេសចំពោះអ្នកក្រ

**dispense** /dɪˈspɛns/ [v] ចែក

**dispersal** /dɪˈspɜːsl/ [n] ការពង្រាយ

- ingestive dispersal /ɪnˈdʒɛstɪv dɪˈspɜːsl/ [n] ការពង្រាយគ្រាប់ដោយសត្វ (ស៊ីលេបគ្រាប់), ការពង្រាយគ្រាប់ដោយសត្វដែលស៊ី(លេប)ផ្លែ ហើយបញ្ចេញគ្រាប់វិញតាមកម្អែរ ឬតាមលាមក។

**disperse** /dɪˈspəːs/ [v] ពង្រាយ, បំបែក

**dispersion** /dɪˈspəːʃ(ə)n/ [n] របាយ (ពន្លឺ និងសារធាតុពុល), ការបែកខ្ញែកចេញពីគ្នា

- light dispersion /lʌɪtdɪˈspəːʃ(ə)n/ [n] របាយពន្លឺ
- pollutant dispersion /pəˈl(j)uːt(ə)ntdɪˈspəːʃ(ə)n/ [n] របាយសារធាតុពុល

**disposal** /dɪˈspəʊz(ə)l/ [n] ការបោះចោល

- land disposal /land dɪˈspəʊz(ə)l/ [n] ការកប់សំណល់ក្នុងដី
- nuclear waste disposal /ˈnjuːklɪə weɪst dɪˈspəʊz(ə)l/ [n] ការទុកដាក់សំណល់វិទ្យុសកម្ម
- radioactive waste disposal /ˌreɪdɪəʊˈaktɪv weɪst dɪˈspəʊz(ə)l/ [n] ការទុកដាក់សំណល់វិទ្យុសកម្ម
- refuse disposal /rɪˈfʌnd dɪˈspəʊz(ə)l/ [n] ការចាក់ចោលសម្រាម ឬកាកសំណល់
- sewage disposal /ˈsuːɪdʒdɪˈspəʊz(ə)l/ [n] ការបង្ហូរទឹកលូសម្អុយ
- soil disposal /sɔɪldɪˈspəʊz(ə)l/ [n] ការកប់សំណល់ក្នុងដី
- underground disposal /ʌndəˈgraʊnddɪˈspəʊz(ə)l/ [n] ការកប់ (សំណល់វិទ្យុសកម្ម) ក្នុងដី
- waste disposal /weɪstdɪˈspəʊz(ə)l/ [n] ការទុកដាក់កាកសំណល់

**dispose** /dɪˈspəʊz/ [v] បោះចោល, យកទៅចោល, ទុកដាក់

**dissemination** /dɪˌsɛmɪˈneɪʃn/ [n]
១. (ចំពោះជំងឺ) ការចម្លងរោគ
២. ការផ្សព្វផ្សាយ

**disseminule** /dɪˈsɛmɪnjuːl/ [n] ឯកត្តៈពង្រាយ (ឯកត្តាពង្រាយ នៅក្នុងន័យគ្រាប់ពូជ វាមានន័យស្មើនឹង diaspore ។)

**dissolvent** /dɪˈzɒlv(ə)nt/ [n] ធាតុរំលាយ

**distal** /ˈdɪst(ə)l/ [v]
១. (ចំពោះរុក្ខជាតិ) ខាងចុងឫស, ខាងចុងពន្លក
២. (ចំពោះសត្វ) នាំទៅឆ្ងាយ, ឱ្យចេញឆ្ងាយ

**distance receptor** /ˈdɪst(ə)ns rɪˈsɛptə/ [n] ផ្នួលចម្ងាយ (ផ្នួលដែលដឹងពីរំញោចពីក្នុងបរិស្ថានរបស់សត្វ ដូច្នេះវាអាចធ្វើឱ្យសត្វតម្រង់ទិសទៅរកកន្លែងនោះ)

**distemper** /dɪˈstɛmpə/ [n] ជំងឺការ៉េ (ជំងឺដែលបង្កដោយវីរុសលើសត្វ ដោយបណ្ដាលអោយក្ដៅខ្លួន ក្អក និង ឡើងស្លេស)

**distension** /dɪˈstɛnʃ(ə)n/ [n] ការហើម ឬតឹង (ដូចជាក្រពះ, ពោះ,ឬពោះវៀន)

**distichous** /ˈdɪstɪkəs/ [adj] តម្រៀបជាពីរជួរ (អំពីទម្រង់របស់រុក្ខជាតិ), របៀបតម្រៀបស្លឹកលើមែកជាពីរជួរ

**distill** /dɪˈstɪl/ [v] បិត (ស្រា ទឹក), ចំហុយ

**distillation** /ˌdɪstɪˈleɪʃn/ [n] បំណិត
- fractional distillation /ˌˈfrakʃ(ə)n(ə)ldɪstɪˈleɪʃn/ [n] បំណិតប្រភាគ

**Distoma** /diˈstrəʊmə/ [n] សូមមើលពាក្យ៖ distromiasis

**distress** /dəˈstrɛs/ [n] ទុក្ខភ័យ, គ្រោះអាសន្ន, ការឈឺចាប់, ទុក្ខព្រួយ, លំបាក

**distribution** **/**dɪstrɪˈbjuːʃ(ə)n/ [n] ការចែកចាយ
- food distribution /fuːd dɪstrɪˈbjuːʃ(ə)n/ [n] ការចែកចាយស្បៀង
- land distribution /land dɪstrɪˈbjuːʃ(ə)n/ [n] ការបែងចែកដី
- pore-size distribution /pɔːsʌɪzdɪstrɪˈbjuːʃ(ə)n/ [n] រន្ធ (ការចែកថ្នាក់នៃរន្ធតាមទំហំ)

**distromiasis** /diˈstrəʊmiːəsɪs/ [n] (សទិសន័យ៖ Distoma) ដង្កូវសំប៉ែតក្នុងថ្លើម (ឌូវ)

**disturbance** /dɪˈstəːb(ə)ns/ [n] ការបង្កការរំខាន
- forest disturbance /ˈfɒrɪst dɪˈstəːb(ə)ns/ [n] ការបង្កការរំខានដល់ព្រៃឈើ

**ditch** /dɪtʃ/ [n]
១. (សទិសន័យ៖ water-furrow, gutter) ចង្អូរទឹក, រង្វះទឹក, ប្រឡាយ
២. ស្នាមភ្លោះ
- drainage ditch /ˈdreɪnɪdʒ dɪtʃ/ [n] ប្រឡាយទឹក
- irrigation ditch /ˈɪrɪgeɪʃ(ə)n dɪtʃ/ [n] ប្រឡាយសម្រាប់ស្រោចស្រព

***Ditylenchus angustus*** [sci.n] សូមមើលពាក្យ៖ stem nematode

**diuresis** /ˌdʌɪjʊ(ə)ˈriːsɪs/ [adj] មានទឹកនោមច្រើនខុសពីធម្មតា

**diuretic** /ˌdʌɪjʊ(ə)ˈrɛtɪk/ [adj] នាំឱ្យនោមច្រើន

**divaricate** /dʌɪˈvarɪkeɪt/ [n] ឃ្លាតចេញពីគ្នា

**diversification of production** /dʌɪvəːsɪfɪˈkeɪʃ(ə)n ɒv prəˈdʌkʃ(ə)n/ [n] (សទិសន័យ៖ crop diversification) ពិពិធកម្មដំណាំ (ការពង្រីកសកម្មភាពកសិកម្មឱ្យលើសអំពីសកម្មភាពបែបបុរាណ ឬក៏សកម្មភាពចិញ្ចឹមជីវិតស្នូល។ ពិពិធកម្មដំណាំអាចមានមុខងារជាយុទ្ធសាស្ត្រនៃរបរចិញ្ចឹមជីវិតនៅកម្រិតគ្រួសារ ឬក៏ជាគំរូនៃជំនួញធម្មតាមួយនៅកម្រិតពាណិជ្ជកម្មទ្រង់ទ្រាយធំ។)

**diversification** /dʌɪvəːsɪfɪˈkeɪʃ(ə)n/ [n] ពិពិធកម្ម (ការមានឡើងច្រើនមុខផ្សេងៗពីគ្នា, ការបង្កើតឡើងអោយមានច្រើនមុខផ្សេងៗពីគ្នា)
- crop diversification /krɒp dʌɪvəːsɪfɪˈkeɪʃ(ə)n/ [n] ពិពិធកម្មដំណាំ
- food diversification /fuːd dʌɪvəːsɪfɪˈkeɪʃ(ə)n/ [n] ពិពិធកម្មចំណីអាហារ, ភាពចម្រុះនៃអាហារចម្រុះមុខ (ទាក់ទិនទៅនឹងភាពខុសៗគ្នាជាទូទៅនៃស្បៀងដែលបានបរិភោគនៅក្នុងរបបអាហាររបស់បុគ្គលម្នាក់ៗ ឬរបស់គ្រួសារនីមួយៗ។ អ្នកទាំងឡាយណាដែលបរិភោគអាហារប្រភេទតិចតួចជាងនៅមុខអាហារទាំងឡាយ ជាទូទៅគឺបានទទួលសារធាតុចិញ្ចឹមតិចជាងអ្នកដែលបរិភោគអាហារដែលមានលក្ខណៈចម្រុះជាង។)

**diversity** /dʌɪˈvəːsɪti/ [n] ភាពចម្រុះ, នានាភាព (លក្ខខណ្ឌដែលខុសគ្នា បង្ហាញពីការខុសគ្នា។ ក្នុងបរិបទនៃការបង្កាត់ដើមឈើ ពាក្យនេះមានន័យជាបម្រែបម្រួល នៃសេណូទីបនៅក្នុងក្រុមពូជមួយ។)
- biology diversity /bʌɪˈɒlədʒi dʌɪˈvəːsɪti/ [n] សូមមើលពាក្យ៖ biodiversity (ភាពប្លែកៗគ្នានៅក្នុងចំណោមសារពាង្គមានជីវិតដែលមកពីគ្រប់ប្រភពទាំងអស់ ហើយនិងភាពស្មុគស្មាញ (ជំពាក់វាក់វិន) នៃបរិស្ថាន)

- dietary diversity /ˈdʌɪət(ə)ri dʌɪˈvəːsɪti/ [n] ភាពសំបូរបែបនៃរបបអាហារ (ការបូកចំនួនស្បៀងខុសៗគ្នា ឬក៏ក្រុមអាហារដែលបរិភោគដោយមនុស្សម្នាក់ ឬគ្រួសារមួយក្នុងរយៈពេលមួយជាក់លាក់។ ជួនកាលចំនុចនេះក៏អាចនឹងត្រូវធ្វើការថ្លឹងថ្លែង ដោយគិតពីចំនួនដងនៃការបរិភោគផងដែរ។ របបអាហារផ្សេងៗគ្នាច្រើនមាននិន្នាការទទួលបានអាហារូបត្ថម្ភខ្ពស់។)
- ecosystem diversity /ˈiːkəʊsɪstəm dʌɪˈvəːsɪti/ [n] នានាភាពប្រព័ន្ធអេកូឡូស៊ី
- genetic diversity /dʒɪˈnɛtɪkdʌɪˈvəːsɪti/ [n] នានាភាពសេនេទិច
- nutritional diversity /njuːˈtrɪʃ(ə)n(ə)l dʌɪˈvəːsɪti/ [n] ភាពសំបូរបែបនៃអាហារូបត្ថម្ភ (សទិសសន័យជាមួយនឹងពាក្យ "ភាពសំបូរបែបនៃរបបអាហារ"។ ចំនួនសរុបនៃស្បៀងអាហារផ្សេងៗគ្នា ឬក៏ក្រុមអាហារដែលបរិភោគដោយបុគ្គល ឬដោយគ្រួសារមួយនៅក្នុងអំឡុងរយៈពេលមួយជាក់លាក់។ ជួនកាលចំណុចនេះត្រូវថ្លឹងថ្លែង ដោយចំនួនដងនៃការបរិភោគអាហារ ។)

**diverticulum** /ˌdʌɪvəˈtɪkjʊləm/ [n] ឌីវ៉េទីគុយឡូម

**division** /dɪˈvɪʒ(ə)n/ [n] សាខា (ចំណាត់ថ្នាក់ណាមួយនៃជីវករនៃវគ្គីករណ៍វិទ្យាដែលទាបជាងអាណាចក្រ តែខ្ពស់ជាងថ្នាក់)

- cell division /sɛl dɪˈvɪʒ(ə)n/ [n] ចំណែកកោសិកា

**dizziness** /ˈdɪzɪnəs/ [n] ការវិលមុខ, ការជើងធោង

**dizzy** /ˈdɪzi/ [adj] វិលមុខ

**DNA** /diː ɛn eɪ/ [n] ភិនភាគនៃសាច់សាលោហិត

**doctor of philosophy (PhD)** /ˈdɒktə ɒv fɪˈlɒsəfi/ [n] ថ្នាក់បណ្ឌិត (ប្រភេទថ្នាក់ដែលអ្នកសិក្សា ត្រូវមានចំណេះដឹងជ្រៅជ្រះ និងមានការវិភាគត្រឹមត្រូវច្បាស់លាស់តាមបែបទស្សនៈវិជ្ជាទៅលើចំណុចអ្វីមួយ)

**document** /ˈdɒkjʊm(ə)nt/ [n] ឯកសារ

**dodder** /ˈdɒdə/ [n] វល្លិរមាស (ឈ្មោះវិទ្យាសាស្ត្រ *Cuscuta maritima*)

**dog** /dɒg/ [n] សត្វឆ្កែ

**dogfish** /ˈdɒgfɪʃ/ [n] ត្រីឆ្កែ

***Doliphinus capensis tropicalis*** [sci.n] សូមមើលពាក្យ៖ long-beaked common dophin

**domestic** /dəˈmɛstɪk/ [adj] ផ្ទៃក្នុង, ក្នុងស្រុក

- domestic trade /dəˈmɛstɪk treɪd/ [n] ពាណិជ្ជកម្មក្នុងប្រទេស

**domestication** /dəmɛstɪˈkeɪʃ(ə)n/ [n] ការផ្សាំងឱ្យទៅជាប្រភេទក្នុងស្រុក, ការបន្សាំង, បសុកម្ម (ដំណើរការដែលក្នុងនោះរុក្ខជាតិ ឬសត្វព្រៃដែលត្រូវបានយកមកដាំ ឬចិញ្ចឹមក្រោមការថែទាំយ៉ាងជិតដល់)

**dominance** /ˈdɒmɪnəns/ [n] ភាពលប់ ឬគ្របលើអ្វីមួយ (ការលាក់សកម្មភាពនៃអាលែលមួយដែលជាអាលែលផ្លាស់របស់វា)

- co-dominance /səʊ-ˈdɒmɪnəns/ [n] សហលប់ (ជាលក្ខខណ្ឌក្នុងភាពជាហេតេរីសាយហ្គូត (heterozygote) ដែលសមាជិកទាំង២នៃគូអាលែលមួយត្រូវបាន សម្តែងចេញមក និងរួមចំណែកបង្កើតផេណូទីប ដែលបន្ទាប់មកការលាយចូលគ្នានៃលក្ខណៈផេណូទីប បានផលិតចេញលក្ខខណ្ឌអូម៉ូស៊ីកូតផងដែរ។ គូអាលែលសន្ទតមួយដែលនីមួយៗនៅក្នុងភាពអូម៉ូស៊ីកូត ផលិតផ្កាក្រហមនិងស។ នៅក្នុងលក្ខខណ្ឌសហលប់ វាផលិតបានផ្កាមានទាំងក្រហម និងស។ នៅក្នុងករណីលប់មិនពេញលេញផ្កានឹងចេញជាពណ៌កូលាប)
- incomplete dominance /ɪnkəmˈpliːt ˈdɒmɪnəns/ [n] ភាពលប់មិនពេញលេញ (ការសម្តែងចេញមួយផ្នែករបស់អាលែលទាំង២នៅក្នុងអេតេរ៉ូស៊ីកូតមួយ ដូចនេះផេណូទីបរបស់វាបង្ហាញចេញមកនៅចន្លោះរវាងមេបាអូម៉ូស៊ីកូតទាំង២នោះ)

**donkey** /ˈdɒŋki/ [n] សត្វលា

**donor** /ˈdəʊnə/ [n] ជូន (អ្នកផ្តល់ជូន), អ្នកផ្តល់អំណោយ

**dormancy** /ˈdɔːm(ə)nsi/ [n] ដំណេកភាព, រយៈពេលសំងំ, ភាពសំងំ (ស្ថានភាពធម្មជាតិមួយនៃគ្រាប់ពូជដែលមិនអាចដុះបាន ទោះជាក្នុងលក្ខខណ្ឌដែលអាចដុះបានក៏ដោយ)

- break dormancy /breɪk ˈdɔːm(ə)nsi/ [n] ការបំបែកដំណេកភាព (វិធីសាស្ត្រដែលធ្វើឱ្យគ្រាប់ពូជអាចដុះបានបើទោះបីជាវាស្ថិតក្នុងលក្ខខណ្ឌដំណេកភាពក៏ដោយ)

- bud dormancy /bʌd ˈdɔːm(ə)nsi/ [n] ដំណេកពន្លក , ពន្លកក្រាំង (កំពកពន្លកនៅលើដើម ឬមែកដែលមិនអាចវិវត្តន៍ជាត្រួយបាន បើសិនភាពសម្ងំនេះមិនទាន់បំបែក)
- chemical dormancy /ˈkɛmɪk(ə)l ˈdɔːm(ə)nsi/ [n] ដំណេកដោយសារជាតិគីមី (ភាពសំងំដែលបណ្ដាលមកពីសារធាតុគីមីរារាំងដែលមាននៅក្នុងផ្លែឬគ្រាប់។ ភាពសំងំប្រហែលជាអាច បំបែកបាន ដោយធ្វើការលាងជម្រះសារធាតុនេះចេញ។)
- combined dormancy /kəmˈbʌɪnd ˈdɔːm(ə)nsi/ [n] (សទិសន័យ៖ double dormancy) ដំណេករួមផ្សំ, ដំណេកទ្វេ (ដំណេកដែលបណ្ដាលមកពីកត្តាសំខាន់ពីរ ដូចជាដំណេកដោយសារសម្បកគ្រាប់ និងដំណេកអំប្រ៊ីយ៉ុង តែគេអាចបំបែកដំណេកទាំងពីរនេះឱ្យគ្រាប់ដុះពន្លកបានដោយធ្វើឱ្យមានស្នាមលើគ្រាប់ដោយការត្រាំទឹក)
- double dormancy /ˈdʌb(ə)l ˈdɔːm(ə)nsi/ [n] សូមមើលពាក្យ៖ combined dormancy
- embryo dormancy /ˈɛmbrɪəʊ ˈdɔːm(ə)nsi/ [n] (សទិសន័យ៖ endogenous dormancy) ដំណេកអំប្រ៊ីយ៉ុង, ដំណេកផ្ទៃក្នុង (ភាពសំងំដែលបណ្ដាលមកពីលក្ខខណ្ឌនៅក្នុងអំប្រ៊ីយ៉ុងខ្លួនឯង ឧ.សារធាតុរារាំង ឬអំប្រ៊ីយ៉ុងវិវត្តន៍មិនទាន់ពេញលេញ)
- endogenous dormancy /ɛnˈdɒdʒɪnəs ˈdɔːm(ə)nsi/ [n] សូមមើលពាក្យ៖ embryo dormancy
- exogenous dormancy /ɪkˈsɒdʒɪnəs ˈdɔːm(ə)nsi/ [n] ដំណេកដោយសារសម្បកក្រៅ (ភាពសំងំណាដែលទាក់ទងនឹងសម្បករុំគ្រាប់ និង/ឬផ្លែ ឧ. pericarp ឬសម្បកគ្រាប់។ ភាពសំងំដោយសារសម្បកខាងក្រៅអាចមានដូចជា ឧ. ភាពសំងំមេកានិច, ភាពសំងំលក្ខណៈរូប ឬភាពសំងំពន្លឺ។)
- induced dormancy /ɪnˈdjuːst ˈdɔːm(ə)nsi/ [n] ដំណេកបន្ទាប់
- mechanical dormancy /mɪˈkanɪk(ə)l ˈdɔːm(ə)nsi/ [n] ដំណេកមេកានិច (ភាពសំងំបណ្ដាលមកពីភាពមាំនៃមេកានិចរបស់សម្បកគ្រាប់ (ជាធម្មតា endocarp)ដែលមិនអាចពង្រីកអំប្រ៊ីយ៉ុងរបស់វាបាន។ ភាពសំងំនេះអាចបំបែកបានដោយធ្វើការបំបែករូបនៃសម្បកដែលរារាំង ឬយកគ្រាប់ចេញមក។)
- photodormancy /ˈfəʊtəʊdɔːm(ə)nsi/ [n] ដំណេកពន្លឺ (ភាពសំងំបន្ទាប់ដែលងាយវិវត្តនៅពេលគ្រាប់ត្រូវពន្លឺ។ ភាពសំងំនេះបណ្ដាលមកពីកម្រិតខ្ពស់ហ្វីតូក្រូម (Pr) ដែលត្រូវផ្លាស់ប្ដូរទៅជាហ្វីតូក្រូម (Pfr) ដោយដាក់ហាលវាឱ្យត្រូវពន្លឺក្រហម (៦៦០-៧៦០ ម.ម) ឬហាលឱ្យត្រូវពន្លឺពេញ ១ថ្ងៃ ក្រោយពីស្រូបទឹកដើម្បីដុះពន្លក។)
- physical dormancy /ˈfɪzɪk(ə)l ˈdɔːm(ə)nsi/ [n] ដំណេករូប (ភាពសំងំដែលបណ្ដាលមកពីសម្បកគ្រាប់មិនស្រូបទឹក (គ្រាប់រឹង)។ អំប្រ៊ីយ៉ុងមិនមែនមានសកម្មភាពនោះទេ តែត្រូវបានបិទជិតដោយសារសម្បកមិនស្រូបទឹកនៅក្នុងបន្ទុកសំណើមទាប ប្រភេទសំងំនេះមានច្រើនចំពោះគ្រួសារ Leguminosae)
- physiological dormancy /ˌfɪzɪəˈlɒdʒɪk(ə)l ˈdɔːm(ə)nsi/ [n] ដំណេកសរីរៈ (ប្រភេទមួយនៃដំណេកអំប្រ៊ីយ៉ុងដែលក្នុងនោះការដុះពន្លកត្រូវបានរារាំងដោយសារតែយន្តការរារាំងខាងសរីរៈ ឧ. ដំណេកដោយសារគីមី ឬភាពសំងំដោយសារកម្ដៅ)
- primary dormancy /ˈprʌɪm(ə)ri ˈdɔːm(ə)nsi/ [n] ដំណេកដំបូង (ភាពសំងំដែលមាននៅក្នុងគ្រាប់នៅពេលដែលគ្រាប់កំពុងទុំនៅលើដើម ឬក្រោយពីទុំរួច)
- secondary dormancy /ˈsɛk(ə)nd(ə)ri ˈdɔːm(ə)nsi/ [n] ដំណេកបន្ទាប់, ដំណេកបន្ត (ភាពសំងំដែលវិវត្តន៍នៅក្នុងគ្រាប់សើមក្រោយពីវាត្រូវបានបេះ ឬជ្រុះពីដើម បើសិនជាវាត្រូវរងនូវលក្ខខណ្ឌបរិស្ថានមិនអំណោយផល)
- seed coat dormancy /siːd kəʊt ˈdɔːm(ə)nsi/ [n] ដំណេកដោយសារសម្បក (ភាពសំងំកើតឡើងដោយសារតែលក្ខខណ្ឌរបស់សម្បកគ្រាប់ ឧ. លទ្ធភាពរារាំងការស្រូបទឹក (ភាពសំងំរូប) ឬប្រព័ន្ធហ្វីតូក្រូម (ភាពសំងំពន្លឺ)។ ភាពសំងំនេះអាចនឹងបំបែកបានដោយធ្វើឱ្យមានស្នាមប្រេះ ឬបកសម្បកគ្រាប់ចេញ។)
- seed dormancy /siːd ˈdɔːm(ə)nsi/ [n] ដំណេកនៃគ្រាប់ពូជ (រយៈពេលដែលគ្រាប់ពូជសម្រាកក្រោយពីបានទុំពេញលេញ ឬលទ្ធភាពនៃគ្រាប់ទុំដើម្បីពន្យារពេលនៃដំណុះគ្រាប់)

- thermodormancy /ˈθɜːməʊdɔːm(ə)nsi/ [n] ដំណេកដោយសារកម្ដៅ (ជាប្រភេទភាពសំងំដំបូង ឬបន្ទាប់ដែលក្នុងនោះគ្រាប់ត្រូវគេបានដាក់ឱ្យរងនូវសីតុណ្ហភាពទាប ឬឡើងចុះមុននឹងដុះពន្លក។ នៅតំបន់អាកាសធាតុបង្គួរ ភាពសំងំកម្ដៅត្រូវបានបំបែកដោយការដាក់ឱ្យត្រជាក់ជាមុន ឬសំដិល។ នៅតំបន់ត្រូពិច ដោយដាក់ហាលថ្ងៃ និងសន្សើមមុននឹងដុះពន្លក។)

**dormant** /ˈdɔːm(ə)nt/ [adj] ដែលដេក, នឹង (ទឹក)

**dorsal** /ˈdɔːs(ə)l/ [adj] នៃខ្នង (រុក្ខជាតិ) (ស្ថិតនៅផ្នែកខាងសរីរាង្គ ដែលងាកចេញពីអ័ក្ស)

**dorsi-fixed** /ˈdɔːsi fɪkst/ [adj] ភ្ជាប់នៅផ្នែកខ្នង (អំពីប្លោកលម្អង)

**dorso-** /ˈdɔːsəʊ/ [prefix] បុព្វបទមានន័យថា ខ្នង

**dorsum** /ˈdɔːsəm/ [n] ខ្នង

***Doryichthys boaja*** [sci.n] សូមមើលពាក្យ៖ long-snouted pipefish

**dose** /dəʊs/ [n] អត្រា, កម្រិតស្រូប, រង្វាល់ (ឱសថ) (បរិមាណជាក់លាក់មួយនៃថ្នាំដែលត្រូវប្រើក្នុងមួយពេល)

- absorbed dose /əbˈzɔːbd dəʊs/ [n] កម្រិតស្រូប
- acceptable emergency dose /əkˈsɛptəb(ə)lɪˈməːdʒ(ə)nsidəʊs/ [n] កម្រិតអនុញ្ញាតពេលមានគ្រោះថ្នាក់
- accumulated dose /əˈkjuːmjʊleɪtɪd dəʊs/ [n] កម្រិតផ្ទុក
- cumulative dose /ˈkjuːmjʊlətɪvdəʊs/ [n] កម្រិតស្រូបសរុប
- equivalent dose /ɪˈkwɪv(ə)l(ə)nt dəʊs/ [n] កម្រិតសមមូល
- fatal dose /ˈfeɪt(ə)l dəʊs/ [n] កម្រិតបណ្ដាលឱ្យស្លាប់
- integral dose /ˈɪntɪgr(ə)l dəʊs/ [n] កម្រិតសរុប
- lethal (LD) dose /ˈliːθ(ə)l dəʊs/ [n] កម្រិតបណ្ដាលឱ្យស្លាប់
- lethal 100 dose [n] កម្រិតបណ្ដាលឱ្យស្លាប់ ១០០%
- lethal 50 (LD50) dose [n] (សទិសន័យ៖ median lethal dose) កម្រិតបណ្ដាលឱ្យស្លាប់ ៥០%
- lethal 50/30 dose [n] កម្រិតបណ្ដាលឱ្យស្លាប់ ៥០% ក្រោយរយៈពេល ៣០ថ្ងៃ
- maintenance dose /ˈmeɪnt(ə)nəns dəʊs/ [n] កម្រិតថ្នាំល្មមធ្វើឱ្យនៅសុខជាធម្មតា
- maximum allowable dose /ˈmaksɪməm əˈlaʊəbl dəʊs/ [n] (សទិសន័យ៖ maximum permissible dose) កម្រិតអនុញ្ញាតអតិបរមា
- maximum permissible dose /ˈmaksɪməmpəˈmɪsɪb(ə)ldəʊs/ [n] សូមមើលពាក្យ៖ maximum allowable dose
- median lethal dose /ˈmiːdɪən ˈliːθ(ə)l dəʊs/ [n] សូមមើលពាក្យ៖ lethal 50 (LD50) dose
- permissible dose /pəˈmɪsɪb(ə)l dəʊs/ [n] កម្រិតអនុញ្ញាត
- radiation dose /reɪdɪˈeɪʃ(ə)ndəʊs/ [n] កម្រិតរំភាយ
- safe dose /seɪfdəʊs/ [n] កម្រិតគ្មានគ្រោះថ្នាក់
- specific absorbed dose /spəˈsɪfɪkəbˈzɔːbdəʊs/ [n] កម្រិតស្រូបយថាប្រភេទ
- tolerant dose /ˈtɒl(ə)r(ə)ntdəʊs/ [n] កម្រិតអនុគ្រោះ

**doubly toothed** /ˈdʌbli tuːθt/ [adj] ជាយស្លឹកដែលមានធ្មេញស្ទួន

**doubt** /daʊt/ [n] សង្ស័យ, មន្ទិល

**douche** /duːʃ/ [n] ការរងូតទឹក, ការលាងទឹក, ទឹកធម្មតាមានថ្នាំ, បាញ់លាងផ្នែកនៃខ្លួន ឬបញ្ចូលតាមសរីរាង្គផ្លូវយោនី

**dourine** /ˈdʊəriːn/ [n] ឌូរីន

**dove** /dʌv/ [n] កូឡុម (ព្រាបស)

**downstream** /daʊnstriːm/ [adj] សង្កាត់ទឹកក្រោម, តំបន់ទឹកក្រោម, ទីក្រោមទឹក

**downy mildew** /ˈdaʊni ˈmɪldjuː/ [n] ជំងឺអុចស្លឹកពណ៌លឿង (ជំងឺនេះបង្កដោយផ្សិត *Hyaloperonospora parasitica* រីករាលដាលតាមរយៈខ្យល់ និងទឹកភ្លៀង ដែលភ្នាក់ងារបង្កជំងឺរស់នៅជាបរាសិតក្នុងកាកសំណល់រុក្ខជាតិ ដោយបង្កើតជា Oospores ឬលើដំណាំពពួកស្ពៃ និងស្ពៃ)

**dragon bone** /ˈdrag(ə)n bəʊn/ [n] ដើមជន្លាត់ដៃ (រុក្ខជាតិនៃអម្បូរ *Euphorbia lactea*)

**dragon fly** /ˈdrag(ə)n flʌɪ/ [n] សត្វកន្ទុំរុយ

**drain** /dreɪn/ [v] (សទិសន័យ៖ unwater) (ចំពោះធរណីវិទ្យា) ធ្វើឱ្យស្ងួត (ដី), ពង្រីង, បញ្ចេញទឹក

**drain** /dreɪn/ [n] (សទិសន័យ៖ seton) (ចំពោះសត្វ) បំពង់បង្ហូរ
- drain plug /dreɪn plʌg/ [n] ខ្នៅបង្ហូរប្រេង (ខ្នៅសម្រាប់បង្ហូរប្រេងរំអិលពីចលករ)

**drainage** /ˈdreɪnɪdʒ/ [n] ការបញ្ចេញទឹក, ការបង្ហូរទឹកចេញ, ទឹកដែលបង្ហូរចេញ, ប្រព័ន្ធបង្ហូរចេញ (ប្រព័ន្ធប្រឡាយសម្រាប់បង្ហូរ)
- drying drainage drʌɪɪŋ ˈdreɪnɪdʒ [n] ប្រព័ន្ធបញ្ចេញទឹក(កុំឱ្យដីជាំទឹក)
- land drainage /land ˈdreɪnɪdʒ/ [n] ការបង្ហូរទឹកចេញពីដី, ការដោះទឹកពីដី
- mining drainage /ˈmʌɪnɪŋˈdreɪnɪdʒ/ [n] ទឹកដែលបង្ហូរចេញពីអណ្ដូងរ៉ែ
- poor drainage /pɔː ˈdreɪnɪdʒ/ [n] ទីជាំទឹក
- soil drainage /sɔɪl ˈdreɪnɪdʒ/ [n] ដីជ្រាបទឹក

**draw** /drɔː/ [v] អូស (ឧ. សត្វក្របីអូសនង្គ័ល), គូស, គូរ

**draw up** /drɔː ʌp/ [v] រុញ

**drench** /drɛn(t)ʃ/ [n] ការបញ្ច្រកថ្នាំ (សត្វ)

**dressing** /ˈdrɛsɪŋ/ [n] ការរុំ (ដំបៅ, របួស), ការព្យាបាល
- seed dressing /siːd ˈdrɛsɪŋ/ [n] ការព្យាបាលគ្រាប់ពូជ
- side dressing /sʌɪd ˈdrɛsɪŋ/ [n] ការបាចដីបំប៉ន

**drift** /drɪft/ [n]

១. រំងាក (ការបើងរសាត់តាមខ្យល់ ឬងាកខុសទិសដៅនៃថ្នាំដែលបាញ់មានលក្ខណៈ ដូចលម្អងដែលធ្លាក់ចុះខុសផ្ទៃដែលចង់បាន)

២. សូមមើលពាក្យ៖ glacial till

៣. វត្ថុ ឬល្បាប់ដែលនាំមកដោយទឹក ឬខ្យល់
- antigenic drift /antɪˈdʒɛnɪk drɪft/ [n] បម្រែបម្រួលអង់ទីសែន
- drift of dust /drɪft ɒf dʌst/ [n] ខ្យល់កួចធូលី
- genetic drift /dʒɪˈnɛtɪk drɪft/ [n] ការរលាត់សេនេទិច (ការផ្លាស់ប្ដូរដោយចៃដន្យនៅក្នុង frequency របស់អាលែលនៅក្នុងក្រុមពូជមួយពីមួយជំនាន់ទៅមួយជំនាន់ដោយសារតែក្រុមពូជមានទំហំតូច)
- random drift /ˈrandəm drɪft/ [n] ការរលាត់ (ពន្ធុ) ដោយចៃដន្យ

**drill** /drɪl/ [n]

១. ម៉ាស៊ីនដាំគ្រាប់ពូជ ឬស្ទូង

២. ដែកខួង ឬស្វាន
- electric drill /ɪˈlɛktrɪk drɪl/ [n] ស្វានអគ្គិសនី (ឧបករណ៍ស្វានប្រើថាមពលអគ្គិសនី)
- grain drill /greɪn drɪl/ [n] ម៉ាស៊ីនដាំគ្រាប់ពូជ
- hand drill /hand drɪl/ [n] ប្រដាប់ស្វាន, ស្វានដៃ (ឧបករណ៍ស្វានប្រើដោយកម្លាំងមនុស្ស ឬចរន្តអគ្គិសនីដែលកាន់ដោយដៃ)
- pasture drill /ˈpɑːstʃə drɪl/ [n] ម៉ាស៊ីនដាំ (ម៉ាស៊ីនដាំគ្រាប់ធញ្ញជាតិមានផ្លែឆ្លូតបង្កប់គ្រាប់)

**dripstone** /ˈdrɪpstəʊn/ [n] ថ្មដែលដុះច្រូងប្រាងនៅពិដានរូងភ្នំដោយទឹកភ្លៀងច្រោះថ្មកំបោរ, អាចុតសិលា

**drone** /drəʊn/ [n] (សទិសន័យ៖ male bee) ឃ្មុំឈ្មោល, ឃ្មុំបា

**droop** /druːp/ [n] ដំណើរឱន

**drop** /drɒp/ [v] ដំណក់, បន្តក់

**droppings** /ˈdrɒpɪŋz/ [n pl] លាមកសត្វ

**dropsy** /ˈdrɒpsi/ [n] ទាច (ជំងឺ)

**drought** /draʊt/ [n] (សទិសន័យ៖ aridity) ភាពរាំងស្ងួត, ការរាំងស្ងួត
- contiguous drought /kənˈtɪgjʊəs draʊt/ [n] ចំណាត់ថ្នាក់នៃភាពរាំងស្ងួត ដែលជាលទ្ធផលបណ្ដាលមកពីភាពភ្លៀងមិនទៀងទាត់ហើយដែលបង្កឱ្យមានកង្វះសំណើមក្នុងរដូវភ្លៀង
- drought-prone /draʊt prəʊn/ [adj] ដែលងាយរងគ្រោះដោយភាពរាំងស្ងួត
- drought-resistant /draʊt rɪˈzɪstənt/ [adj] ដែលធន់នឹងភាពរាំងស្ងួត

**droughty** /draʊti/ [adj] ស្ងួត, ក្ដៅស្ងួត

**drug** /drʌg/ [n] ឱសថបករណ៍ (ឧបករណ៍ ឬរុក្ខជាតិដែលគេយកមកធ្វើថ្នាំសង្កូវ)
- maintenance drug /ˈmeɪnt(ə)nəns drʌg/ [n] ឱសថថែរក្សាឱ្យនៅសុខជា ធម្មតា (ថ្នាំពេទ្យសម្រាប់គ្រប់សង្កត់ទៅលើលក្ខណៈ ជំងឺរ៉ាំរ៉ៃ)

**drum seeder** /drʌm ˈsiːdə/ [n] ឧបករណ៍ដាំដូចស្គរ (ឧបករណ៍ដាំគ្រាប់ធញ្ញជាតិជាជួរមានរាងដូចស្គរ)

**drumlin** /ˈdrʌmlɪn/ [n] កូនភ្នំ ឬដំបូកដែលមានប្រភពពីប្រវត្តិកាលទឹកកក (រាងទ្រវែងពងក្រពើ)

**drupe** /druːp/ [n] ប្រភេទផ្លែសាច់គ្រាប់រឹងមួយ, ប្រភេទផ្លែខ្ទប (ផ្លែសាច់ ផ្លែរឹង ដែលមានសាច់នៅក្នុងចតផ្លែ និងមានគ្រាប់មួយ ឬច្រើន)

**dry** /drʌɪ/ [adj] រាំង, ក្រៀម, រីង, ស្ងួត

**dry** /drʌɪ/ [v] សម្ងួត, ហាល, ធ្វើឱ្យស្ងួត, ជូត (ឱ្យស្ងួត)

**dry up** /drʌɪ ʌp/ [v] ជូតឱ្យស្ងួត, ធ្វើឱ្យរីងស្ងួត

**dryer** /ˈdrʌɪə/ [n] ម៉ាស៊ីនសំងួត, ម៉ាស៊ីនសំងួត

- grain dryer /greɪn ˈdrʌɪə/ [n] ម៉ាស៊ីនសំងួត (ម៉ាស៊ីនសម្ងួតគ្រាប់ធញ្ញជាតិ)

**drying** /drʌɪn/ [n] សម្ងួត (ដំណើរការដែលធ្វើឱ្យគ្រាប់ ឬសរីរាង្គណាមួយនៃរុក្ខជាតិ អាចស្ងួតក្នុងកម្រិតសំណើមទាបដោយកម្ដៅថ្ងៃ ឬឧបករណ៍សម្ងួត)

- strong periodic drying /strɒŋ ˌpɪərɪˈɒdɪk drʌɪn/ [n] ការធ្វើឱ្យរឹងស្ងួតតាមពេលកំណត់

**dryinid** /drʌɪnɪd/ [n] ដ្រាយអ៊ីនីត (ឱម៉ាល់ម្យ៉ាងរាងដូចស្រមោច ជាសត្វរំពាផង ជាបរាសិតផង ស្ថិតក្នុងលំដាប់ Hymenoptera គ្រួសារ Dryinidae)

**drylands** /ˈdrʌɪləndz/ [n pl] តំបន់រាំងស្ងួត

**dry-wall bank** /drʌɪ wɔːl baŋk/ [n] បង់កែតធ្វើពីថ្មស្ងួត

**Dubnium** /ˈdʌbnɪəm/ [n] ដូបនូម (និមិត្តសញ្ញាគីមី Db)

**duck** /dʌk/ [n] ទាឈ្មោល

**duct** /dʌkt/ [n]

១. ប្រឡាយ

២. បំពង់ (បំពង់សម្រាប់ដឹកនាំសារធាតុរាវ ដូចជាបំពង់ទឹករងៃ នៅក្នុងសារពាង្គ កាយ។ ចំពោះរុក្ខជាតិ បំពង់ត្រូវបានបង្កើតចេញជួរកោសិកា វែងៗដែលបាត់បង់ការភ្ជាប់ភ្នាសខាងចុងរបស់វា និងត្រូវបានប្រើសម្រាប់ដឹកនាំទឹកនិងខ្យល់)

**ductus deferens** /ˈdʌktəs ˈdɛfərɛnz/ [n] (ពហុវចនៈ៖ ductus deferentia) សូមមើលពាក្យ៖ vas deferens

**duff** /dʌf/ [n] មមោក

- fibrous duff /ˈfʌɪbrəs dʌf/ [n] មមោកស្រទន់មានសភាពជាសរសៃៗ
- greasy duff /ˈgriːsi dʌf/ [n] មមោកស្រទន់
- leaf duff /liːf dʌf/ [n] មមោកស្រទន់ (ដូចរោមចៀម)
- root duff /ruːt dʌf/ [n] មមោកស្រទន់កើតពីឫស

**dug-land** /dʌg land/ [n] សូមមើលពាក្យ៖ excavated earth

**dugong** /ˈduːgɒŋ/ [n] ជ្រូកទឹក, ពយ៉ុង (ឈ្មោះវិទ្យាសាស្ត្រ *Dugong dugon*)

***Dugong dugon*** [sci.n] សូមមើលពាក្យ៖ dugong

**dull** /dʌl/ [adj] ស្រពោន, គ្មានជីវិត, គ្មានសកម្មភាព

**dummy** /ˈdʌmi/ [n] ផលិតផលគំរូ, ផលិតផលសាកល្បង

**dump** /dʌmp/ [n]

១. (ចំពោះដី) សូមមើលពាក្យ៖ bank

២. (សទិសន័យ៖ dumping site) (ចំពោះបរិស្ថាន) កន្លែងចាក់សម្រាម, កន្លែងចោលសំណល់

**dumping** /dʌmpɪŋ/ [n] ការចាក់សម្រាម, ការចោលសំណល់

- ocean dumping /ˈəʊʃ(ə)ndʌmpɪŋ/ [n] ការចោលសំណល់នៅក្នុងសមុទ្រ

**dune** /djuːn/ [n] ផ្នូកខ្សាច់

- coastal dune /ˈkəʊstl djuːn/ [n] ផ្នូកខ្សាច់ឆ្នេរ

**dung** /dʌŋ/ [n] សូមមើលពាក្យ៖ manure

**duodenal** /ˌdjuːəˈdiːn(ə)l/ [adj] ដែលទាក់ទងផ្នែកដើមនៃពោះវៀនតូច, មានប្រវែងប្រហែល ១២ ម្រាមដៃ

**duodenum** /ˌdjuːəˈdiːnəm/ [n] គល់ពោះវៀន

**dura** /ˈdjʊərə/ [n] (សទិសន័យ៖ dura mater) ស្រោមខួរ

- dura mater /ˈdjʊərə ˈmateɪ/ [n] (សូមមើលពាក្យ៖ dura) លលាដ៍ខួរក្បាល ឬស្រោមខួរឆ្អឹងខ្នង(គំម្របខួរក្បាល)

**durability** /dʒɔːrəˈbɪlɪti/ [n] លទ្ធភាព ដែលអាចធន់បានរយៈពេលយូរ ជាពិសេសគ្មានការបំផ្លាញ ឬខូចខាត

**duration** /grəʊwɪŋ djʊˈreɪʃ(ə)n/ [n] រយៈកាល

- growing duration /grəʊwɪŋ djʊˈreɪʃ(ə)n/ [n] រយៈកាលលូតលាស់ (អាយុកាលដែលរុក្ខជាតិមានជីវិតដែលធម្មតា ចាប់គិតពីថ្ងៃដាំរហូតដល់ពេលស្រូវទុំ)

**durian** /ˈdʊərɪən/ [n] ធូរេន (ឈ្មោះវិទ្យាសាស្ត្រ *Durio zibethinus*)

**duricrust** /ˈdjʊərɪkrʌst/ [n] ស្រទាប់ក្ដាំងរឹង (អាលុយមីញ៉ូម-ស៊ីលីស ឬកំបោរ)

***Durio zibethinus*** [sci.n] សូមមើលពាក្យ៖ durian

**durophagous** [adj] ឌុយរ៉ូហ្វាហ្គឺស (ដែលស៊ីរបស់រឹង)

**dusky hairfin anchovy** [n] ត្រីឆ្មា, ត្រីក្រពើ (ឈ្មោះវិទ្យាសាស្ត្រ *Setipinna melanochir*)

**duskyfin glassy perchlet** [n] ត្រីកន្ត្រែងប្រេង (ឈ្មោះវិទ្យាសាស្ត្រ *Parambassis wolffi*)

**dust** /dʌst/ [n] លម្អង, ចុណ្ណភាគ, ផង់ធូលី (0.0៦-0.៥ម.ម) , ធូលី (១.៥-២៥0មីក្រុង)

- atmosphere dust /dʌst/ [n] ធូលីបរិយាកាស
- coal dust /kəʊldʌst/ [n] ធូលីធ្យូងថ្ម
- radioactive dust /ˌreɪdɪəʊˈaktɪv dʌst/ [n] ធូលីវិទ្យុសកម្ម

**dustiness** /ˈdʌstɪnəs/ [n] កម្រិតធូលី

**dusting** /dʌstɪŋ/ [n] បាញ់ម្សៅ (ដំណើរការបាញ់ថ្នាំបំពុលសត្វល្អិត ក្នុងទម្រង់ជាម្សៅ ឬធូលី)

**duty free** /ˈdju:ti fri:/ [adj] ដែលរួចពន្ធ

**duty free goods** /ˈdju:ti fri: gʊdz/ [n pl] ទំនិញរួចពន្ធ

**dwarf goonch** [n] ត្រីក្របី (ឈ្មោះវិទ្យាសាស្ត្រ *Bagarius bagarius*)

**dwarf spinner dolphin** /dwɔ:f ˈspɪnə ˈdɒlfɪn/ [n] ផ្សោតឆ្នូតភ្អែក (ឈ្មោះវិទ្យាសាស្ត្រ *Stenella longirostris roseinventris*)

**dwarfism** /ˈdwɔ:fɪz(ə)m/ [n] ភាពតឿ

**dye** /dʌɪ/ [n] ពណ៌ (សារធាតុប្រើសម្រាប់ប្តូរពណ៌នៃសារធាតុអ្វីមួយ)

- acid dye /ˈasɪd dʌɪz/ [n] ល័ក្តពណ៌អាស៊ីត

**dyestuff** /ˈdʌɪstʌf/ [n] រាល់សារធាតុ ដែលប្រើប្រាស់សម្រាប់ធ្វើពណ៌ ឬល័ក្ខ ឬចម្រាញ់យកពណ៌ ឬល័ក្ខ

**dyke** /dʌɪk/ [n] ភ្លឺស្រែ, ទំនប់តូចៗ

**dynamics** /dʌɪˈnamɪks/ [n] ឌីណាមិច, ការប្រែប្រួលជានិរន្តរ៍

- population dynamics /pɒpjʊˈleɪʃ(ə)n dʌɪˈnamɪks/ [n] ឌីណាមិចបណ្តាសម្ភារ, ការប្រែប្រួលហ្វូងជានិច្ចជាកាល

**dys-** /dɪs/ [prefix] (សទិសន័យ៖ bad, painful, difficult) បុព្វបទមានន័យថា ពិបាក

***Dysdercus cingulatus*** [sci.n] ស្រឹងកប្បាស, គោម៉

**dysentery** /ˈdɪs(ə)nt(ə)ri/ [n] រាកមួល, មួល, អាមាតិសារ

- amoebic dysentery /əˈmi:bɪk ˈdɪs(ə)nt(ə)ri/ [n] រាកមួលដោយអាមីប

**dyspepsia** /dɪsˈpɛpsɪə/ [n] ការរលាយអាហារដោយពិបាក, ពិបាករំលាយអាហារ

**dyspeptic** /dɪsˈpɛptɪk/ [adj] ជំងឺចាក់ច្រាស

**dysphagia** /dɪsˈfeɪdʒɪə/ [n] ការពិបាកលេប, រោគធុមបាយ

**dysphasia** /dɪsˈfeɪzɪə/ [n] ការរឹកលសំដី

**dysphonia** /dɪsˈfəʊnɪə/ [n] ការលំបាកនិយាយ

**dysplasia** /dɪsˈpleɪzɪə/ [n] លូតលាស់ខុសប្រក្រតី

**dyspnea** /dɪspˈni:ə/ [n] ការស្ទះដង្ហើម, ការពិបាកដកដង្ហើម

**dyspneic** /dɪspˈni:əɪk/ [adj] ដែលស្ទះដង្ហើម

**dysprosium** /dɪsˈprəʊzɪəm/ [n] ឌីសប្រូស្យូម (និមិត្តសញ្ញាគីមី Dy)

**dysthymic** /dɪsˈθʌɪmɪk/ [n] ភាពមិនធម្មតានៃរលកក្នុងខួរក្បាល

**dystocia** /dɪsˈtəʊʃə/ [n] ការពិបាកសម្រាលកូន

**dystrophic ranker** /dɪsˈtrəʊfɪk ˈraŋkə/ [n] សូមមើលពាក្យ៖ silicate raw soil

**dystrophy** /ˈdɪstrəfi/ [n] អនិបុណ្យបោសនា, កង្វះអាហារសម្រាប់ចិញ្ចឹមរាងកាយ

**dysuria** /dɪsˈjʊərɪə/ [n] ទល់នោម, ការស្ទះទឹកនោម

# E

**e-** /iː/ [prefix] (ដូចៈ ex-) បុព្វបទមានន័យថា ក្រៅពី, គ្មាន

**ear** /ɪə/ [n] ត្រចៀក, ស្មៀត (ឧ. ពោត)

**ear drum** /ɪə drʌm/ [n] ក្រដាសត្រចៀក

**early** /ˈəːli/ [adj] រួសរាន់, លឿន, ស្រាល (ឧ. ស្រូវស្រាល)

**earth** /əːθ/ [n] ដី, ផែនដី, ពិភពលោក

- black earth of forest /blak əːθ ɒv ˈfɒrɪst/ [n] (សទិសន័យៈ melanized soil, humus incorporated soil) ដីខ្មៅដែលមានមមោកច្រើននៅតំបន់ព្រៃ
- black humus earth /blak ˈhjuːməs əːθ/ [n] (សទិសន័យៈ tropical black soil, black adobe) ដីខ្មៅតំបន់ត្រូពិច ឬស្ទើរតែត្រូពិច
- bleach earth /bliːtʃ əːθ/ [n] (សទិសន័យៈ bleach sand) ដីប្រភេទ ប៉ុដហ្សូល (ដីអាស៊ីតខ្លាំងហើយច្រើនតែជាដីខ្សាច់)
- bleached earth /bliːtʃt əːθ/ [n] សូមមើលពាក្យៈ podzol
- brick earth /brɪk əːθ/ [n] ដីសម្រាប់ធ្វើឥដ្ឋ
- brown earth /braʊn əːθ/ [n] (សទិសន័យៈ brown soil) ដីពណ៌សម្បុរត្នោត, ដីព្រៃ
- calcareous red earth /kalˈkɛːrɪəsrɛd əːθ/ [n] ដីក្រហមដែលមានជាតិកំបោរ
- coloured earth /ˈkʌləd əːθ/ [n] ដីដែលមានស្នាមពណ៌
- common black earth /ˈkɒmən blak əːθ/ [n] ដីខ្មៅធម្មតា
- compact earth /kəmˈpakt əːθ/ [n] ដីហាប់
- degraded red earth /dɪˈgreɪdɪd rɛd əːθ/ [n] ដីក្រហមរេចរឹល
- dust earth /dʌst əːθ/ [n] ដីម៉ដ្តដូចម្សៅ
- excavated earth /ˈɛkskəveɪtid əːθ/ [n] (សទិសន័យៈ made land, dug-land) ការឆាយពង្រាយដី, អាចម៍ដី, ការជីកឆាយពង្រាយដីឱ្យស្មើ
- fine earth /fʌɪn əːθ/ [n] ដីល្អិត (គ្រាប់ដីដែលល្អិតជាង២ម.ម នៅបារាំង ឬ១ម.ម នៅអាល្លឺម៉ង់)
- fine sand earth /fʌɪn sand əːθ/ [n] សូមមើលពាក្យៈ fine sand
- flowing earth /ˈfləʊɪŋ əːθ/ [n] ដីដែលអាចហូរបាន (កាលណាសើមខ្លាំង)
- frozen earth /ˈfrəʊzn əːθ/ [n] (សទិសន័យៈ forzen soil, crymorphic soil) ដីដែលមានភិនភាគពាក់ព័ន្ធនឹងការត្រជាក់ ឬកកនៃដី
- fuller's earth /fʊləz ˈɜːθ/ [n] ឥដ្ឋដែលចេញពីថ្មផ្នូនប្រភេទខ្លះ
- grey earth /greɪ əːθ/ [n] (សទិសន័យៈ grey desert steppe soil, grey soil of the semidesert) ដីខ្មៅប្រផេះតំបន់វាលស្តែប-ស្បៀវសែម
- heavy earth /ˈhɛvi əːθ/ [n] ដីឥដ្ឋ, ដីមានវាយនភាពឥដ្ឋ, ដីដែលពិបាកធ្វើការ, ដីឥដ្ឋខ្លាំងពេក
- humus clay earth /ˈhjuːməs kleɪ əːθ/ [n] ដីឥដ្ឋដែលមានមមោកច្រើន (ឥដ្ឋ ១០-២៥%, មមោក ១០%)
- humus sand earth /ˈhjuːməs sand əːθ/ [n] ដីខ្សាច់ដែលមានមមោកច្រើន (ខ្សាច់ ៣០ -៤០%, សរីរាង្គ>១០%)
- leached brown earth /liːtʃt braʊn sɔɪl/ [n] ដីប្រងច្រោះ
- leached red earth /liːtʃt rɛd əːθ/ [n] ដីក្រហមលាងច្រោះ
- light earth /lʌɪt əːθ/ [n] ដីវាយនភាពខ្សាច់
- lithochromic earth /ˈlʌɪθəʊˈkrəʊmɪk əːθ/ [n] (សទិសន័យៈ lithochromic soil) ដីដែលមានសម្បុរបន្សល់ទុកពីថ្មមេ
- made earth /meɪd əːθ/ [n] ១. ដីដែលគេដឹកយកពីកន្លែងផ្សេងទៀត, ដីដែលគេដាំ ឬធ្វើកសិកម្ម ២. សូមមើលពាក្យៈ excavated earth ៣. សូមមើលពាក្យៈ artificial soil
- modelling earth /ˈmɒd(ə)lɪŋ əːθ/ [n] ដីសម្រាប់សូនរូប
- nourishing earth /ˈnʌrɪʃɪŋ əːθ/ [n] ដីដែលមានជីជាតិល្អ
- nutrient rich brown earth /ˈnjuːtrɪənt rɪtʃ braʊn əːθ/ [n] ដីពណ៌សម្បុរត្នោតដែលសម្បូរទៅដោយខនិជមានជីជាតិល្អ

- peaty earth /piːti əːθ/ [n] ដីប្រភេទពើក (សរីរាង្គមិនរលួយ)
- pitch earth /pɪʧ əːθ/ [n] (សទិសន័យ៖ bituminous earth) ដីដែលមានបីទូមដែលជាសរីរាង្គជាតិធម្មជាតិពណ៌ខ្មៅល្អិត
- red earth /rɛd əːθ/ [n] ដីក្រហម
- saline black earth /ˈseɪlʌɪn blak əːθ/ [n] ដីប្រៃលាងច្រោះពណ៌ខ្មៅ (សម្បូរអំបិលអាល់កាឡាំង pH > ៨.៥)
- salt earth /sɔːlt əːθ/ [n] សូមមើលពាក្យ៖ salt soil
- sand earth /sand əːθ/ [n] ដីដែលមានវាយនភាពខ្សាច់
- south black earth /saʊθ blak əːθ/ [n] ដីខ្មៅភាគខាងត្បូង
- steppe black earth (chernozem) /stɛp blak əːθ (ˈtʃəːnəzɛm)/ [n] ដីខ្មៅតំបន់ស្តែប (ឈែណូស្សូម), ដីខ្មៅតំបន់ស្តែបដែលមានស្មៅ ឬរុក្ខជាតិក្រាស់
- steppe bleached earth /stɛp bliːtʃt əːθ/ [n] (សទិសន័យ៖ salt earth podzol) ដីប្រៃលាងច្រោះអាស៊ីត
- subtropical earth /sʌbˈtrɒpɪk(ə)l əːθ/ [n] ដីខ្មៅនៅតំបន់ជិតត្រូពិច
- sward earth /swɔːd land/ [n] ដីសម្រាប់ដាំស្មៅ
- tile earth /tʌɪl əːθ/ [n] ដីសម្រាប់ធ្វើក្បឿង
- tillable earth /ˈtɪləb(ə)l əːθ/ [n] (សទិសន័យ៖ arable land) ដីដែលអាចដាំដុះបាន, ដីដែលអាចភ្ជួរបាន
- tropical red earth /ˈtrɒpɪk(ə)l rɛd əːθ/ [n] ដីក្រហម, ដីក្រហមតំបន់ត្រូពិច
- tuff earth /tʌf əːθ/ [n] ដីដែលមានដុំក្រវៀន ឬកំបោរច្រើន
- vegetable earth /ˈvɛdʒtəb(ə)l əːθ/ [n] សូមមើលពាក្យ៖ compost
- vine earth /vʌɪn əːθ/ [n] ដីទំពាំងបាយជូរ
- wheat earth /wiːt əːθ/ [n] សូមមើលពាក្យ៖ corn ground
- white earth /wʌɪt əːθ/ [n] ដីសស្លាំង
- yellow earth /ˈjɛləʊ əːθ/ [n] ដីលឿង, ល្បាយលឿង
- bituminous earth /bɪˈtjuːmɪnəs əːθ/ [n] សូមមើលពាក្យ៖ pitch earth
- bog earth /bɒg əːθ/ [n] ដីទំនាបបឹង
- earth stripe /əːθ strʌɪp/ [n] (សទិសន័យ៖ striated soil) ដីដែលគ្រាប់ដីរៀបជាឆ្នូតៗ

**earthquake** /ˈəːθkweɪk/ [n] ការរញ្ជួយដី
- man-made earthquake /manmeɪd ˈəːθkweɪk/ [n] ការរញ្ជួយដីបណ្តាលមកពីមនុស្ស
- tectonic earthquake /tɛkˈtɒnɪk ˈəːθkweɪk/ [n] ការរញ្ជួយដីមានប្រភពតិចតូនិច

**earthwork** /əːθwəːk/ [n] ការជីកលើកដី

**earthy** /ˈəːθi/ [adj] ដែលជាដី

**earwig** /ˈɪəwɪg/ [n] សត្វកន្ទុយពីរ (សត្វរំពាស្ថិតក្នុងលំដាប់ Dermaptera គ្រួសារ Carcinophortdae)

**east** /iːst/ [n] ទិសខាងកើត, ទិសបូព៌ា

**eastern death's-head hawk moth** [n] ដង្កូវខ្នាយ (ឈ្មោះវិទ្យាសាស្ត្រ *Acherontia styx*)

**ec-** /ɛk/ [prefix] បុព្វបទមានន័យថា ក្រៅពី, ឃ្លាតពី

**ecad** /ˈiːkad/ [n] អ៊ីឃេត (ប្រភេទរុក្ខជាតិដែលបណ្តាលមកពីទីតាំង ដែលវារស់នៅ គឺមិនមែនបណ្តាលមកពីសម្ភារសេនេទិចទេ)

**ecchymosis** /ˌɛkɪˈməʊsɪs/ [n] អេគីម៉ូស (ចំណុចជាំអុចៗនៅលើស្បែក ឬសរីរាង្គផ្សេងៗ)

**ecdysis** /ˈɛkdɪsɪs/ [n] ការសក, ជម្រុះ

**ecesis** /ɪˈsiːsɪs/ [n] អ៊ីស៊ីស៊ីស (ការដុះ និងការលូតលាស់របស់រុក្ខជាតិនៅពាសពេញតំបន់ថ្មីមួយ)

***Echidnophaga gallinacea*** [sci.n] សូមមើលពាក្យ៖ tropical chicken flea

**echinate** /ˈɛkɪˌneɪt/ [adj] មានបន្លា, មានរោម

***Echinochloa colona*** [sci.n] សូមមើលពាក្យ៖ jungle-rice

***Echinochloa crus-galli*** [sci.n] សូមមើលពាក្យ៖ barnyard grass

***Echinochloa glabrescens*** [sci.n] ស្មៅកន្ទុយដំរី, ស្មៅបែកក្បាល

**Echinococcus** [n] ប្រភេទតេញ៉ាអេគីណូកុក

**echocardiogram** /ˌɛkəʊˈkɑːdɪə(ʊ)gram/ [n] ការវិនិច្ឆ័យវាស់ស្ទង់រចនាសម្ពន្ធនៃចលនាបេះដូង

**eclampsia** /ɪˈklam(p)sɪə/ [n] អេក្លំស៊ី (ជំងឺប្រកាច់ដោយទឹកនោមប្រៃ) , ការប្រកាច់ នៅពេលមានផ្ទៃពោះ,សម្រាលកូន, ឬនៅពេលឈឺ

***Eclipta prostrata*** [sci.n] សូមមើលពាក្យ៖ false daisy

**ecobalance** /ˈiːkəʊˈbal(ə)ns/ [n] លំនឹងអេកូឡូស៊ី

**ecocide** /ˈiːkə(ʊ)sʌɪd/ [n] ការបំផ្លាញបរិស្ថានធម្មជាតិ

**ecoclimate** /ˈiːkə(ʊ)ˈklʌɪmət/ [n] អេកូអាកាសធាតុ

**ecoclimatology** /ˈiːkə(ʊ)ˈklʌɪməˈtɒlədʒi/ [n] អេកូអាកាសធាតុវិទ្យា

**ecogeography** /ˈiːkə(ʊ)dʒɪˈɒgrəfi/ [n] អេកូភូមិវិទ្យា, ភូមិវិទ្យាប្រព័ន្ធអេកូឡូស៊ី

**ecological** /iːkəˈlɒdʒɪk(ə)l/ [adj] នៃបរិស្ថាន

- ecological efficiency /iːkəˈlɒdʒɪk(ə)l ɪˈfɪʃ(ə)nsi/ [n] ប្រសិទ្ធភាពអេកូឡូស៊ី

**ecologist** /ɪˈkɒlədʒɪst/ [n] អ្នកអេកូឡូស៊ី, អេកូឡូស៊ីវិទូ, បរិស្ថានវិទូ

**ecology** /ɪˈkɒlədʒi/ [n] អេកូឡូស៊ី, បរិស្ថានវិទ្យា (ការសិក្សាពីអន្តរទំនាក់ទំនងរវាងភាវរស់ និងបរិស្ថានជុំវិញ)

- agricultural ecology /agrɪˈkʌltʃərəlɪˈkɒlədʒi/ [n] អេកូឡូស៊ីកសិកម្ម
- animal ecology /ˈanɪm(ə)l ɪˈkɒlədʒi/ [n] អេកូឡូស៊ីសត្វ
- aquatic ecology /əˈkwatɪk ɪˈkɒlədʒi/ [n] អេកូឡូស៊ីមជ្ឈដ្ឋានទឹក
- community ecology /kəˈmjuːnɪtiɪˈkɒlədʒi/ [n] អេកូឡូស៊ីសហគមន៍
- deep ecology /diːpɪˈkɒlədʒi/ [n] អេកូឡូស៊ីហួសហេតុ
- human ecology /ˈhjuːmənɪˈkɒlədʒi/ [n] អេកូឡូស៊ីមនុស្ស
- marine ecology /məˈriːn ɪˈkɒlədʒi/ [n] អេកូឡូស៊ីសមុទ្រ
- plant ecology /plɑːntɪˈkɒlədʒi/ [n] អេកូឡូស៊ីរុក្ខជាតិ
- population ecology /pɒpjʊˈleɪʃ(ə)nɪˈkɒlədʒi/ [n] អេកូឡូស៊ីប្រជាជន
- terrestrial ecology /təˈrɛstrɪəlɪ ˈkɒlədʒi/ [n] អេកូឡូស៊ីមជ្ឈដ្ឋានគោក

**economic** /ˌiːkəˈnɒmɪk/ [adj] នៃសេដ្ឋកិច្ច, ដែលផ្តល់កម្រៃ

- environmental economic /ɪnvʌɪrənˈmɛnt(ə)l iːkəˈnɒmɪk/ [n] សេដ្ឋកិច្ចបរិស្ថាន

**economics** /iːkəˈnɒmɪks/ [n] សេដ្ឋកិច្ច, វិទ្យាសាស្ត្រសេដ្ឋកិច្ច

**economy** /fuːd ɪˈkɒnəmi/ [n] សេដ្ឋកិច្ច

- food economy /fuːd ɪˈkɒnəmi/ [n] សេដ្ឋកិច្ចស្បៀង (របៀបដែលគ្រួសារនីមួយៗបានទទួលស្បៀងអាហារ និងចំណូលរបស់ពួកគេ។ យុទ្ធសាស្ត្រសេដ្ឋកិច្ចស្បៀងអាហារត្រូវបានបង្កើតឡើងដោយអង្គការសង្គ្រោះកុមារដើម្បីវាស់វែងដល់ផលប៉ះពាល់នៃព្រឹត្តិការណ៍ដ៏តក់ស្លុតមួយទៅនឹងសន្តិសុខស្បៀងរបស់គ្រួសារ។ ដោយបូកបញ្ចូលជាមួយនឹងការព្រមានភ្លាមៗ ព័ត៌មានអាចជួយធ្វើការទស្សន៍ទាយផលប៉ះពាល់នៃព្រឹត្តិការណ៍ផ្សេងៗគ្នាដែលនឹងកើតឡើង។)
- socio-economy /ˈsəʊsɪəʊ ɪˈkɒnəmi/ [n] សេដ្ឋកិច្ចសង្គម

**ecosphere** /ˈiːkəʊsfɪə/ [n] អេកូស្វ៊ែ

**ecosystem** /ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ី, ប្រព័ន្ធបរិស្ថាន ( ជាភាពស្មុគស្មាញដែលណាមិក (dynamic) របស់សហគមន៍រុក្ខជាតិ សត្វ និងមីក្រូសរីរាង្គ ហើយនិងអន្តរអំពើនៃបរិស្ថានគ្មានជីវិត បង្កើតបានជាឯកត្តាមុខនាទីមួយ។)

- agricultural ecosystem /agrɪˈkʌltʃərəlˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីកសិកម្ម
- agro-ecosystem /ˈagrəʊɪ ˈiːkəʊsɪstəm/ [n] ប្រព័ន្ធក្សេត្របរិស្ថាន, ប្រព័ន្ធអេកូឡូស៊ីកសិកម្ម
- anthropocentric ecosystem /anθrəpə(ʊ)ˈsɛntrɪkˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីមនុស្ស
- aquatic ecosystem /əˈkwatɪk ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីទឹក
- deep water rice ecosystem /diːp ˈwɔːtə rʌɪs ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូស្រូវឡើងទឹក
- disturbed ecosystem /dɪˈstəːbdˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីរងការរំខាន

- dry season rice ecosystem /drʌɪ ˈsiːz(ə)n rʌɪs ˈiːkəʊsɪstəm/ [n] (សទិសន័យ៖ recession rice ecosystem) ប្រព័ន្ធអេកូស្រូវប្រាំង
- floating rice ecosystem /ˈfləʊtɪŋ rʌɪs ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូស្រូវជម្រៅ
- grassland ecosystem /ˈgrɑːsland ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីវាលស្មៅ
- lacustrine ecosystem /ləˈkʌstrʌɪn ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីបឹង
- mangrove ecosystem /ˈmaŋgrəʊv ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីព្រៃកោងកាង
- man-made ecosystem /manmeɪd ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីសិប្បនិម្មិត
- man-modified ecosystem /manˈmɒdɪfʌɪd ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីដែលកែប្រែដោយសកម្មភាពមនុស្ស
- natural ecosystem /ˈnatʃ(ə)r(ə)l ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីធម្មជាតិ
- recession rice ecosystem /rɪˈsɛʃ(ə)n rʌɪs ˈiːkəʊsɪstəm/ [n] សូមមើលពាក្យ៖ dry season rice ecosystem
- rice ecosystem /rʌɪs ˈiːkəʊsɪstəm/ [n] ប្រព័ន្ធបរិស្ថានស្រូវ, តំបន់អេកូស្រូវ
- tropical rain forest ecosystem /ˈtrɒpɪk(ə)l reɪn ˈfɒrɪst ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីព្រៃត្រូពិចរងទឹកភ្លៀង
- undisturbed ecosystem /ʌndɪˈstəːbdˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីគ្មានរងការរំខាន
- watershed ecosystem /ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីទីជម្រាល
- wetland ecosystem /ˈwɛtlənd ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីតំបន់ដីសើម

**ecotone** /ˈiːkə(ʊ)təʊn/ [n] (សទិសន័យ៖ transition area) អេកូតូន, អន្តរតំបន់

**ecotope** /ˈiːkə(ʊ)təʊp/ [n] អេកូតូប, ទីជម្រករបស់ជីវសហគមន៍

**ecotourism** /ˌiːkəʊˈtʊərɪz/ [n] ទេសចរណ៍ធម្មជាតិ

**ecotoxicology** /ˌiːkəʊtɒksɪˈkɒlədʒi/ [n] អេកូវិសសាស្ត្រ

**ecotype** /ˈiːkəʊtʌɪp/ [n] ប្រភេទបរិស្ថានធម្មជាតិមួយ, ប្រភេទជម្រកធម្មជាតិមួយ, អេកូពូជ, ពូជអេកូឡូស៊ី (ពូជដែលមានឯកត្តៈបម្រែបម្រួលស្រដៀងៗគ្នាជាច្រើននៃប្រភេទតែមួយ), បរិប្រភេទ (ក្រុមនៃអម្បូរមួយ ដែលមានការលូតលាស់ខុសប្លែកនូវលក្ខណៈរូបពីមុន ដើម្បីធន់ទៅនឹងមជ្ឈដ្ឋានថ្មីដែលវារស់ ឧទាហរណ៍ ភាពធន់ចំពោះថ្នាំបំពុលរបស់ស្មៅ)

**ecthyma** /ɛkθɪmə/ [n] ក្រមរដំបៅ, ជំងឺឡើងក្រមរ, អិចទីម៉ា

**ectoderm** /ˈɛktə(ʊ)dəːm/ [n] ក្រៅស្បែក

**ectolecithal** /ˈɛktəʊˈlɛsəθəl/ [adj] ស៊ុតលឿងព័ទ្ធខាងក្រៅ

**ectoparasite** /ˌɛktəʊˈparəsʌɪt/ [n] បរាសិតក្រៅ (បរាសិតដែលរស់នៅខាងក្រៅផ្ទួល)

**ectopic** /ɛkˈtɒpɪk/ [adj] ខុសកន្លែង

**ectotherm** /ˈɛktəʊθəːm/ [n] សត្វអថេរកម្ដៅ

**eczema** /ˈɛksɪmə/ [n] ជំងឺត្រអក ឬតាអក, រោគសើស្បែក

**edaphic** /ɪˈdafɪk/ [adj] នៃលក្ខណៈដី, ដែលទាក់ទងនឹងដី

**edema** /ɪˈdiːmə/ [n] ជំងឺហើម, ការហើម

**edentate** /ˈiːdənteɪt/ [adj] សត្វគ្មានធ្មេញ

**edge** /ɛdʒ/ [n] ទ្រនុងជាជួរ, ជួរកំពូលភ្នំ, គែម, ព្រំ (ចម្ការ)

- plateau edge /ˈplatəʊ ɛdʒ/ [n] គែមខ្ពង់រាប

**education** /ɛdjʊˈkeɪʃ(ə)n/ [n] វិស័យអប់រំ, សិក្សាធិការ

- education attainment /ɛdjʊˈkeɪʃ(ə)n əˈteɪnm(ə)nt/ [n] កម្រិតវប្បធម៌ដែលមាន (ឧ. កម្រិតវប្បធម៌នៃអ្នកដែលបានបញ្ចប់មធ្យមសិក្សាបត្រភាគពីរ ឬវិស្វករផ្នែកក្សេត្រសាស្ត្រជាដើម)

**eel** / iːl/ [n] អន្ទង់, ពពួកត្រីខ្ទីង

- bengal mud eel /bɛnˈgɔl mʌdil [n] អន្ទង់ (ឈ្មោះវិទ្យាសាស្ត្រ *Ophisternon bengalense*)
- fire eel /ˈfʌɪə iːl/ [n] ត្រីខ្ទីងផ្កា (ឈ្មោះវិទ្យាសាស្ត្រ *Mastacembelus erythrotaenia*)
- frecklefin eel /ˈfrɛk(ə)lfɪn iːl/ [n] ត្រីខ្ទីង (ឈ្មោះវិទ្យាសាស្ត្រ Macrognathus maculatus)
- olive snake eel /ˈɒlɪv sneɪk iːl/ [n] អន្ទង់ស (ឈ្មោះវិទ្យាសាស្ត្រ *Ophichthus rutidoderma*)
- peacock eel /ˈpiːkɒk iːl/ [n] ត្រីឆ្លូញឆ្នូត (ឈ្មោះវិទ្យាសាស្ត្រ *Macrognathus siamensis*)

- sea eel /siː iːl/ [n] អន្ទង់សមុទ្រ
- shortfin eel /ʃɔːt fɪn iːl/ [n] ត្រីច្លុក (ឈ្មោះវិទ្យាសាស្ត្រ *Anguilla bicolor*)
- shortspine eel /ʃɔːt spʌɪn iːl/ [n] ត្រីខ្ជឹង (ឈ្មោះវិទ្យាសាស្ត្រ *Macrognathus sp.*)
- swamp eel /swɒmp iːl/ [n] អន្ទង់ (ឈ្មោះវិទ្យាសាស្ត្រ *Monopterus albus*)
- tire track eel /taɪə træk iːl/ [n] ត្រីខ្ជឹង (ឈ្មោះវិទ្យាសាស្ត្រ *Mastacembelus favus*)
- zig-zag eel /ˈzɪgzag iːl/ [n] ត្រីខ្ជឹង (ឈ្មោះវិទ្យាសាស្ត្រ *Mastacembelus armatus*)

**effect** /ɪˈfɛkt/ [n] ផល, ឥទ្ធិពល

- border effect /ˈbɔːdə ɪˈfɛkt/ [n] ការជះឥទ្ធិពលនៅតាមព្រំប្រទល់ ( ការជះឥទ្ធិពលរបស់បរិស្ថាននៅតាមបណ្ដោយព្រំដែននៃតំបន់ពិសោធន៍មួយ ប្លុក ចម្ការពូជ។ល។ ការជះឥទ្ធិពលតាមព្រំប្រទល់ គឺបណ្ដាលមកពីភាពខុសគ្នានៃការប្រជែងយក(ឧ. ពន្លឺ ឬ ជីជាតិ)រវាងខាងក្នុង និងខាង ក្រៅព្រំប្រទល់។ ក្នុងការកាត់បន្ថយឥទ្ធិពលនៅតាមព្រំប្រទល់នៃតំបន់ឬអនុតំបន់ពិសោធន៍ គេនិយមគ្រោងប្លង់តំបន់ជារាងការេ ព្រោះទ្រង់ទ្រាយនេះវាមានវណ្ឌមណ្ឌលតូចជាង បើធៀបនឹងតំបន់មានរាងត្រីកោណ។ តំបន់ទ្រនាប់ ត្រូវបង្កើតព័ទ្ធជុំវិញតំបន់នោះដើម្បីកាត់បន្ថយឥទ្ធិពលតាមព្រំប្រទល់។)
- climatic effect /klʌɪˈmatɪk ɪˈfɛkt/ [n] ឥទ្ធិពលលើអាកាសធាតុ, ឥទ្ធិពលនៃអាកាសធាតុ
- cumulative effect /ˈkjuːmjʊlətɪvɪˈfɛkt/ [n] ឥទ្ធិពលត្រួតលើគ្នា
- ecological effect /iːkəˈlɒdʒɪk(ə)l ɪˈfɛkt/ [n] ឥទ្ធិពលអេកូឡូស៊ី
- environmental effect /ɪnvʌɪrənˈmɛnt(ə)l ɪˈfɛkt/ [n] ឥទ្ធិពលលើបរិស្ថាន, ឥទ្ធិពលនៃបរិស្ថាន
- greenhouse effect /ˈgriːnhaʊs ɪˈfɛkt/ [n] ផលផ្ទះកញ្ចក់
- pollution effect /pəˈluːʃ(ə)nɪˈfɛkt/ [n] នៃការបំពុល
- protection effect /prəˈtɛkʃ(ə)n ɪˈfɛkt/ [n] អនុភាពនៃការការពារ
- residual effect /rɪˈzɪdjʊəlɪˈfɛkt/ [n] ឥទ្ធិពលនៃការបំពុល, ឥទ្ធិពលសល់
- root effect /ruːt ɪˈfɛkt/ [n] (សទិសន័យ៖ root shift) ឥទ្ធិពលឫស, បម្រែបម្រួលឫស (បម្រែបម្រួលសមត្ថភាពអុកស៊ីសែនក្នុងឈាមបណ្ដាលមកពីការប្រែប្រួល pH)
- side effect /sʌɪd ɪˈfɛkt/ [n] ផលបន្ទាប់ពីប្រើថ្នាំរួច
- Wahlund's effect [n] លទ្ធផលរបស់វ៉ាលុន (លទ្ធផលនៃការប្រមូលផ្ដុំបណ្ដាឯកត្តៈពីអនុក្រុមពូជប្លែកខាងសែននេទិចដាក់ទៅជាគំរូមួយ។ សមាមាត្ររបស់អេតេរ៉ូស៊ីកូតវាទាបជាងការគិតទុកនៃមធ្យមហ្វ្រីខ្វិនស៊ីអាលែល។)

**effective** /ɪˈfɛktɪv/ [adj] ចំនួនពិត, ស័ក្តិសិទ្ធិ, ដែលមានប្រសិទ្ធភាព

- effective population size /ɪˈfɛktɪv pɒpjʊˈleɪʃ(ə)n sʌɪz/ [n] ទំហំប្រសិទ្ធភាពនៃក្រុមពូជ, ទំហំប្រសិទ្ធភាពនៃព្រៃពូជ (ទំហំនៃក្រុមពូជគំរូមួយ (សន្មត់ក្នុងគំនិត) ដែលមានអត្រាដូចគ្នានៃកំនើនបង្កាត់ក្នុង ឬការធ្លាក់ចុះនូវចម្រុះភាពពន្ធុដោយសារតែការរសាត់បាត់ពន្ធុ នៅពេលគេសិក្សាពីក្រុមពូជនេះ។ ទំហំប្រសិទ្ធិភាពក្រុមពូជនៃក្រុមពូជពិតមួយ ជាធម្មតា គឺវាមានទំហំតូចជាងទំហំប្រសិទ្ធិភាពពិតប្រាកដរបស់វាច្រើន។ សម្ដែងដោសមីការគណិតសាស្ត្រជា Ne។)

**effectiveness** /ɪˈfɛktɪvnəs/ [n] ប្រសិទ្ធភាព (ភាពនៃការអនុវត្តដែលនាំទៅដល់ការសម្រេចផលតាមគោលដៅកំណត់)

**efferent** /ˈɛf(ə)r(ə)nt/ [adj] ចេញ, នាំចេញ (នាំចេញពីសរីរាង្គកណ្ដាលទៅក្រៅ)

**effervescence** /ˌɛfəˈvɛs(ə)ns/ [n] ការបែកពពុះ, ការកញ្ជ្រោល

**efficiency** /ɪˈfɪʃ(ə)nsi/ [n] ប្រសិទ្ធផល (ភាពនៃការកំណត់អនុវត្តន៍ដែលនាំទៅដល់ការសម្រេចផលតាមគោលដៅកំណត់ ដែលប្រកបដោយភាពឥតខ្ចោះ និងរហ័សរហួន)

**efflorescence** /ɛfləˈrɛs(ə)ns/ [n]

១. (ចំពោះរុក្ខជាតិ) រដូវចេញផ្កា, ផ្ការីក, ការលូតលាស់ក្រៀមស្ងួត

២. (ចំពោះដី) ការចេញជាផ្កា (ឧ. អំបិល)

**effluent** /ˈɛflʊənt/ [n] សំណល់រាវបង្ហូរចេញ, កាកសំណល់រាវ

**effort** /ˈɛfət/ [n] ការខិតខំព្យាយាម, លទ្ធផលនៃការខិតខំព្យាយាម

**eft** /ɛft/ [n] កូនត្រកួតម្យ៉ាង

**egestion** /ɪˈdʒɛsʃ(ə)n/ [n] ការបញ្ចេញកាកសំណល់

**egg banana** /ɛg bəˈnɑːnə/ [n] ចេកពងមាន់

**egg** /ɛg/ [n] កាម៉េតញី (កោសិកាបន្តពូជញី), ស៊ុត, ពង

- cleidoic egg /klʌɪdəʊik ɛg/ [n] ស៊ុតមានសម្បក
- fertilized egg /ˈfəːtɪlʌɪzt ɛg/ [n] ស៊ុតដែលបានបង្កកំណើត

**eggfruit** /ɛgfruːt/ [n] សេដា (ឈ្មោះវិទ្យាសាស្ត្រ *Lucuma nervosa*)

**eggmass** /ɛgmas/ [n] សម្បុកពង (ចំនួនពងតិច ឬច្រើនដែលជម្រុះចេញ ឬទម្លាក់ជាជួរ ឬជាគំនរដោយសត្វល្អិតញី)

***Eichhornia crassipes*** [sci.n] សូមមើលពាក្យ៖ water hyacinth

**Eimeria** / 'eɪm(ə)rɪə/ [n] អៃម៉េរ៉្យា (ឈ្មោះមេរោគម្យ៉ាងមានពពួកកុកស៊ីឌីយោមជាដើម)

**Einsteinium** /ʌɪnˈstʌɪnɪəm/ [n] អាញស្តាញ៉ូម (និមិត្តសញ្ញាគីមី Es)

**ejaculate** /ɪˈdʒakjʊleɪt/ [v] បញ្ចេញទឹកកាម

***Elaeis guineensis*** [sci.n] សូមមើលពាក្យ៖ oil palm

***Elaeocarpus serratus*** [sci.n] រំដេញ

***Elasmus* sp.** [sci.n] ពួកឱម៉ាល់ (បារាសិតលើដង្កូវម្ទេសស្លឹក)

**elbow** /ˈɛlbəʊ/ [n] កែងដៃ

**electrocardiogram (ECG)** /ɪˌlɛktrəʊˈkɑːdɪəgram/ [n] ការថតចរន្តអគ្គីសនីនៃការកន្ត្រាក់សាច់ដុំបេះដូង

**electrocute** /ɪˈlɛktrəkjuːt/ [n] គ្រោះថ្នាក់ខ្សែភ្លើងឆក់

**electrode** /ɪˈlɛktrəʊd/ [n] អេឡិចត្រូត

**electroencephalogram (EEG)** /ɪˌlɛktrəʊɪnˈsɛf(ə)ləgram/ [n] ការថតចរន្តអគ្គីសនីលេកខួរក្បាល

**electrolysis** /ˌɪlɛkˈtrɒlɪsɪs/ [n] អគ្គីសនីវិភាគ

**electrolyte** /ɪˈlɛktrəlʌɪt/ [n] អេឡិចត្រូលីត (វត្ថុធាតុដែលធ្វើជាល្បាយចម្លងអគ្គិសនី, វត្ថុធាតុដែលបំបែក ដោយអគ្គិសនី)

**electrolyze** /ɪˈlɛktrəlʌɪz/ [v] ធ្វើអគ្គីសនីវិភាគ

**electron** /ɪˈlɛktrɒn/ [n] អេឡិចត្រុង

**electrophoresis** /ɪˌlɛktrə(ʊ)fəˈriːsɪs/ [n] ចលនាភាគល្អិតក្នុងអគ្គិសនីវិភាគ (ដំណើរការនៃភាគល្អិតមានបន្ទុកអគ្គីសនីធ្វើចលនា ជាពិសេសឆ្លងកាត់សារធាតុអន្ទិលទៅតាមសញ្ញាអគ្គីសនីមួយ។ ដោយសារតែល្បឿនខុសគ្នានៃចលនានៅក្នុងសារធាតុអន្ទិលនោះ ភាគល្អិតដូចជាប្រូតេអ៊ីនត្រូវបានបំបែកដោយសារដំណើរការនេះ។ ភាគល្អិតដូចគ្នាមាននិន្នាការធ្វើចលនាក្នុងល្បឿនដូចគ្នា។ ដូចនេះ គេអាចធ្វើការផ្ទៀងផ្ទាត់ទំនាក់ទំនងគីមីជីវសាស្ត្រដោយធ្វើការប្រៀបធៀបគំរូចលនាភាគល្អិតបន្ទុកអគ្គីសនី ហើយធ្វើការសំគាល់ភាគល្អិតដោយចែកវាជាក្រុមធៀបទៅនឹងអ្វីដែលស្គាល់ច្បាស់។)

**electuary** /ɪˈlɛktjʊ(ə)ri/ [n] ថ្នាំសូនទឹកឃ្មុំ (ឱសថខាប់, ស្អិតអាចសូនបាន)

**element** /ˈɛlɪm(ə)nt/ [n] ធាតុ

- abiotic element /ˌeɪbʌɪˈɒtɪk ˈɛlɪm(ə)nt/ [n] ធាតុគ្មានជីវិត, ធាតុអាប្បូទិច
- biotic element /bʌɪˈɒtɪk ˈɛlɪm(ə)nt/ [n] ធាតុមានជីវិត, ធាតុប្បូទិច
- chemical element /ˈkɛmɪk(ə)l ˈɛlɪm(ə)nt/ [n] ធាតុគីមី
- essential element /ɪˈsɛnʃ(ə)l ˈɛlɪm(ə)nt/ [n] (សទិសន័យ៖ mineral element) ធាតុចាំបាច់, ធាតុរ៉ែ
- mineral element /ˈmɪn(ə)r(ə)l ˈɛlɪm(ə)nt/ [n] សូមមើលពាក្យ៖ essential element
- minor element /ˈmʌɪnə ˈɛlɪm(ə)nt/ [n] សូមមើលពាក្យ៖ trace element
- trace-element /treɪs ˈɛlɪm(ə)nt/ [n] (សទិសន័យ៖ microelement, minor element) សារធាតុតិចតួចតែចាំបាច់ (ខនិជ), មីក្រូធាតុ (ធាតុចិញ្ចឹមដែលរុក្ខជាតិត្រូវការ ឬស្រូបយកបរិមាណតិច ហើយមីក្រូធាតុទាំងនោះមានដូចជា ដែក ម៉ង់កាណែស ប័រ ម៉ូលីបដែន ទង់ដែង ស័ង្កសី និងក្លរជាដើម)

***Elenchus yasumatsui*** [sci.n] ពួក Strepsiptera (បារាសិតលើពួកមមាច)

***Eleocharis dulcis*** [sci.n] សូមមើលពាក្យ៖ water chestnut

***Eleotris fusca*** [sci.n] សូមមើលពាក្យ៖ brown sleeper

**elephant** /ˈɛlɪf(ə)nt/ [n] សត្វដំរី

**elephant ear gourami** [n] ត្រីត្រចៀកដំរី (ឈ្មោះវិទ្យាសាស្ត្រ *Osphronemus exodon*)

***Eleusine indica*** [sci.n]
១. សូមមើលពាក្យ៖ goosegrass
២. សូមមើលពាក្យ៖ Indian goosegrass

***Eleuthronema tetradactylum*** [sci.n] សូមមើលពាក្យ ៖ fourfinger threadfin

**elevate** /ˈɛlɪveɪt/ [v] ធ្វើឱ្យខ្ពស់ឡើង, លើកឡើង

**elevation** /ˌɛlɪˈveɪʃ(ə)n/ [n] កម្ពស់, រយៈកម្ពស់, រយៈកម្ពស់នៃតំបន់, កម្ពស់តំបន់ធៀបនឹងនីវ៉ូទឹកសមុទ្រ
- absolute elevation /ˈabsəluːt ˌɛlɪˈveɪʃ(ə)n/ [n] សូមមើលពាក្យ៖ absolute altitude

**elimination** /ɪlɪmɪˈneɪʃ(ə)n/ [n] ជម្រុះ

**elixir** /ɪˈlɪksɪə/ [n] ថ្នាំទឹកអេឡិចសៀ (ថ្នាំទឹកលាយនឹងសុរា)

**elliptic** /ɪˈlɪptɪk/ [adj] (សទិសន័យ៖ elliptical) ដូចអេលីប, ទម្រង់បន្ទះស្លឹករាងពងក្រពើស្រួច, ស្លឹករាងអេលីបដែលមានចំនុចកណ្ដាលរីកធំ និងចុងទាំងសងខាងស្មើគ្នា

**elliptical** /ɪˈlɪptɪk(ə)l/ [adj] សូមមើលពាក្យ៖ elliptic

**stem elongation** /stɛm iːlɒŋˈgeɪʃ(ə)n/ [n] ដើមលូត, ការលូតនៃដើម

**elutriation** /ɪl(j)uːtrɪˈeɪʃ(ə)n/ [n] ការទុកឱ្យរង

**eluviation** /ɪˌluviˈeɪʃ(ə)n/ [n]
១. (សទិសន័យ៖ depletion, leaching) ការលាងច្រោះ
២. ការហូរនាំវត្ថុធាតុ (ឧ. ខនិជ) ពីស្រទាប់លើចុះ

**eluvium** /ɪˈlu vɪəm/ [n] អេលុយវ្យ៉ូង

**emaciation** /ɪˌmeɪsɪˈeɪʃ(ə)n/ [n] ការចុះស្គម

**emarginate** /ˈemɑːdʒɪneɪt/ [adj] ទម្រង់ចុងស្លឹកផតស្រួច

**emasculate** /ɪˈmaskjʊleɪt/ [v] សូមមើលពាក្យ៖ castrate

**emasculation** /ɪmaskjʊˈleɪʃ(ə)n/ [n]
១. ការក្រៀវធ្វើឱ្យខ្សោយ, ការក្រៀវ (ដំណើរការដែលក្នុងនោះកេសរឈ្មោលត្រូវបានដកចេញពីកន្សោមផ្កាពេលលម្អងនៅខ្ចី)
២. (ចំពោះសត្វ) ការកាត់ពងស្វាសចោល

**emasculator** /ɪˈmaskjʊlət(ə)r/ [n] ឧបករណ៍ក្រៀវ (ឧបករណ៍ដែលប្រើក្នុងការដកយកកេសរឈ្មោលចេញពីកន្សោមផ្កា)

**embankment** /ɪmˈbaŋkm(ə)nt/ [n]
១. សូមមើលពាក្យ៖ bank
២. សូមមើលពាក្យ៖ terrace

**embolism** /ˈɛmbəlɪz(ə)m/ [n] ការស្ទះសរសៃឈាម, កំណកឈាម (ដែលធ្វើឱ្យស្ទះផ្លូវឈាមរត់)

**embryo** /ˈɛmbrɪəʊ/ [n] អំប្រ៊ីយ៉ុង, ទារកក្នុងស្បូន,ភ្រូណា (ពន្លកនៃអនាគតរុក្ខជាតិថ្មីមួយដើមដែលមាននៅក្នុងគ្រាប់)
- immature embryo /ˌɪməˈtjʊə ˈɛmbrɪəʊ/ [n] អំប្រ៊ីយ៉ុងខ្ចី, អំប្រ៊ីយ៉ុងមិនទាន់ពេញវ័យ (អំប្រ៊ីយ៉ុងរបស់គ្រាប់ដែលមិនសម្រេចបាននូវដំណាក់កាលអភិវឌ្ឍន៍មួយដែលអាចឱ្យវាអាចដុះពន្លកបាន)

**embryology** /ˌɛmbrɪˈɒlədʒi/ [n] អំប្រ៊ីយ៉ុងវិទ្យា

**emendation** /ˌiːmɛnˈdeɪʃ(ə)n/ [n] កំណែកំហុសឈ្មោះវិទ្យាសាស្ត្រ

**emergency** /ɪˈməːdʒ(ə)nsi/ [n] ស្ថានភាពបន្ទាន់
- emergency response /ɪˈməːdʒ(ə)nsi rɪˈspɒns/ [n] ការឆ្លើយតបក្នុងស្ថានភាពបន្ទាន់ (សកម្មភាពមួយ និងសកម្មភាពទាំងឡាយដែលប្រកាន់យកដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការដែលកើតឡើងក្នុងស្ថានភាពបន្ទាន់)

**emesis** /ˈɛmɪsɪs/ [n] ការក្អួតចង្អោរ

**emetic** /ɪˈmɛtɪk/ [adj] ដែលធ្វើឱ្យក្អួត

**emigration** /ˌɛmɪˈgreɪʃn/ [n] បម្លាស់លំនៅ

**emission** /ɪˈmɪʃ(ə)n/ [n] បន្សាយ, ការបញ្ចេញសំណល់ឧស្ម័ន, អេមីស្យុង
- alpha emission /ˈalfə ɪˈmɪʃ(ə)n/ [n] បន្សាយកាំរស្មីអ៊ិច
- anthropogenic emission /ˌanθrəpəˈdʒɛnɪk ɪˈmɪʃ(ə)n/ [n] សំណល់ឧស្ម័នបញ្ចេញចោលដោយមនុស្ស
- atmospheric emission /atməsˈfɛrɪk ɪˈmɪʃ(ə)n/ [n] បន្សាយទៅក្នុងបរិយាកាស
- automobile emission /ɔːtəməbiːl ɪˈmɪʃ(ə)n/ [n] បន្សាយផ្សែងរថយន្ត
- dust emission /dʌst ɪˈmɪʃ(ə)n/ [n] បន្សាយធូលី
- exhaust emission /ɪgˈzɔːst ɪˈmɪʃ(ə)n/ [n] បន្សាយផ្សែងយានយន្ត
- fuel-tank emission /fjuː(ə)l-taŋk ɪˈmɪʃ(ə)n/ [n] បន្សាយ(សារធាតុពុល) ចេញពីអាងស្តុកប្រេង)
- fugitive emission /ˈfjuːdʒɪtɪv ɪˈmɪʃ(ə)n/ [n] អេមីស្យុងគេច
- gamma emission /ˈgamə ɪˈmɪʃ(ə)n/ [n] បន្សាយកាំរស្មីកាម៉ា

- gaseous emission /ˈgasɪəs ɪˈmɪʃ(ə)n/ [n] បន្សាយឧស្ម័ន
- global emission /ˈgləʊb(ə)l ɪˈmɪʃ(ə)n/ [n] ការបញ្ចេញ (ឧស្ម័ន) សកល
- heat emission /hiːt ɪˈmɪʃ(ə)n/ [n] បន្សាយកម្ដៅ
- incinerator emission /ɪnˈsɪnəreɪtə ɪˈmɪʃ(ə)n/ [n] បន្សាយចេញពីឡដុតសំរាម
- industrial emission /ɪnˈdʌstrɪəl ɪˈmɪʃ(ə)n/ [n] បន្សាយឧស្សាហកម្ម
- infrared emission /ɪnfrəˈrɛd ɪˈmɪʃ(ə)n/ [n] បន្សាយកាំរស្មីក្រហមអាំងប្រា
- maximum permissible emission /ˈmaksɪməm pəˈmɪsɪb(ə)l ɪˈmɪʃ(ə)n/ [n] បន្សាយអនុញ្ញាតអតិបរមា
- noise emission /nɔɪz ɪˈmɪʃ(ə)n/ [n] បន្សាយសំឡេង
- plant emission /plɑːnt ɪˈmɪʃ(ə)n/ [n] បន្សាយពីរោងចក្រ
- pollutant emission /pəˈl(j)uːt(ə)nt ɪˈmɪʃ(ə)n/ [n] បន្សាយសារធាតុបំពុល
- radioactive emission /ˌreɪdɪəʊˈaktɪv ɪˈmɪʃ(ə)n/ [n] បន្សាយវិទ្យុសកម្ម
- smoke emission /sməʊk ɪˈmɪʃ(ə)n/ [n] បន្សាយផ្សែង

**emollient** /ɪˈmɒlɪənt/ [adj] ដែលធ្វើឱ្យទន់ជ្រាយ, បន្ទន់

**emotion** /ɪˈməʊʃ(ə)n/ [n] វេទនារម្មណ៍ (ការដឹងអារម្មណ៍ថាជាសុខ ឬជាទុក្ខ)

- emotional disturbances /ɪˈməʊʃ(ə)n(ə)l dɪˈstəːb(ə)ns/ [n] ដំណើរប្រែប្រួល ខាងវេទនារម្មណ៍

**emphysema** /ˌɛmfɪˈsiːmə/ [n] ជំងឺហើមខ្យល់, ជំងឺហើមខ្យល់ក្នុងសួត

**empiric** /ɪmˈpɪrɪk/ [adj] និយមតែពិសោធ (ដែលផ្អែកលើការពិសោធ)

- empirical evidence /ɛmˈpɪrɪk(ə)l ˈɛvɪd(ə)ns/ [n] ភស្តុតាងពិសោធ

**employment** /ɪmˈplɔɪm(ə)nt/ [n] ការងារ, ការជួល

**empowerment** /ɛmˈpaʊəm(ə)nt/ [n] ពលវឌ្ឍន៍ (ការធ្វើឱ្យមានសេចក្ដីក្លាហាន ឬការធ្វើឱ្យមានភាពខ្លាំងក្លា)

**empyema** /ˌɛmpʌɪˈiːmə/ [n] ខ្ទុះនៅក្នុងជាពិសេសក្នុងរន្ធសួត, ការកខ្ទុះនៅចន្លោះរវាងស្រោមសួត

**emulsifiable concentrate (E.C)** /ɪˈmʌlsɪfʌɪˈeɪb(ə)l ˈkɒns(ə)ntreɪt/ [n] រូបមន្តនៃថ្នាំពុលដែលផ្សំឡើងដោយថ្នាំបាណកឃាត ឬសារធាតុនៅក្នុងធាតុរំលាយសរីរាង្គ ហើយក្នុងនោះមានដាក់ទាំងភ្នាក់ងារសម្រាប់តេលូទកាផង

**emulsifier** /ɪˈmʌlsɪfʌɪə/ [n] តេលូទករ (ធាតុដែលធ្វើឱ្យសារធាតុរាវមួយអណ្តែតលើសារធាតុមួយទៀត), អេមុលស្យុង, ភ្នាក់ងារធ្វើឱ្យវត្ថុរាវពីររលាយចូលគ្នាបាន (ប្រេងនឹងទឹក)

**emulsify** /ɪˈmʌlsɪfʌɪ/ [v] គាបយកប្រេង

**emulsion** /ɪˈmʌlʃ(ə)n/ [n] តេលូតកា (ការធ្វើឱ្យអណ្តែតហើយបែកខ្ទែកពាសពេញនៃអង្គធាតុរាវមួយក្នុងអង្គធាតុរាវដំទៃទៀត ឧទាហរណ៍ ប្រេងបំបែកចេញនៅក្នុងទឹក)

**enamel** /ɪˈnam(ə)l/ [n] កាចាធ្មេញ, ចាដើមធ្មេញ (ជាតិរឹងនៃធ្មេញ)

**enation** /ɪˈneɪʃ(ə)n/ [n] ការលូតលាស់ចេញក្រៅនៃស្លឹក

**encapsulated** /ɛnˈkapsjʊleɪtɪd/ [adj] ដែលស្រោបដោយស្រោម ឬសម្បក

**encephalic** /ˌɛnsɪˈfalɪk/ [adj] នៃខួរក្បាល

**encephalitic** /ɛnˌsɛfəˈlɪtɪk/ [adj] នៃរោគរលាកខួរក្បាល

**encephalitis** /ɛnˌkɛfəˈlʌɪtɪs/ [n] ជំងឺរលាកខួរក្បាល, ជំងឺរលាកសំណុំខួរ

**enclose** /ɪnˈkləʊz/ [v] ហ៊ុមព័ទ្ធការពារ, បិទ, ដាក់ក្នុងស្រោម

**enclosure** /ɪnˈkləʊʒə/ [n] តំបន់ការពារព័ទ្ធដោយរបង

**agricultural encroachment** /agrɪˈkʌltʃərəl ɛŋˈkrəʊtʃm(ə)nt/ [n] ការទន្ទ្រានដីធ្វើកសិកម្ម

**iron encrustation** /ˈʌɪən ˌɪnkrʌˈsteɪʃ(ə)n/ [n] (សទិសន័យ៖ iron concretion) កុងក្រេស្យុងផ្សំដោយធាតុដែក, កុងក្រេស្យុងដែក, គ្រួសក្រៀនដែក

**encyst** /ɛnˈsɪst/ [v] កគីស (នៅក្នុងស្រោម)

**encystment** /ɪnˈsɪstm(ə)nt/ [n] កំណគីស

**Endamoeba** /ɛnd əˈmiːbə/ [n] អង់តាម៉ើបា (ពួកមួយរបស់អាមីប)

**endangered** /ɪnˈdeɪndʒəd/ [adj] ដែលជិតផុតពូជ

- endangered species /ɪnˈdeɪndʒəd ˈspiːʃiːz/ [n] អម្បូរដែលជិតផុតពូជ

**endemic** /ɛnˈdɛmɪk/ [adj] រាលកម្ម (ការរាលពីប្រភពដើមទៅពេញស្រុកទេស ភូមិដ្ឋាន ឬតំបន់ណាមួយ)

**endoblast** /ˈɛndəʊblɑːst/ [n] ភ្នាសក្នុងជីវ៉ាណូ, ស្រទាប់ខាងក្នុងស្បូន

**endocardial** /ˌɛndə(ʊ)ˈkɑːdɪəl/ [adj] នៃផ្នែកស្រទាប់បេះដូង

**endocarditis** /ˌɛndəʊkɑːˈdʌɪtɪs/ [n] រលាកភ្នាសក្នុងបេះដូង (ជំងឺរលាកផ្ទៃក្នុងនៃបេះដូង)

**endocardium** /ˌɛndəʊˈkɑːdɪəm/ [n] សរសៃក្នុងហាទយ , ភ្នាសក្នុងបេះដូង

**endocarp** /ˈɛndə(ʊ)kɑːp/ [n] សម្បកក្នុងគ្រាប់, អង់ដូកាប ((បណ្ដូល) ជាស្រទាប់ក្នុងបំផុតនៃផ្លែសាច់ធម្មតា។ វាអាចទន់ដូចក្នុងផ្លែប៉េងប៉ោះ ឬអាចរឹងដូចក្នុងផ្លែប៉េស)

**endochorion** /ˈɛndəʊˈkɔːrɪən/ [n] ភ្នាសក្នុងកូរ្យ៉ុងរបស់ពងសត្វល្អិត

**endocrine** /ˈɛndə(ʊ)krʌɪn/ [n] ក្រពេញអង់ដូគ្រីន (គ្រឿងដែលបញ្ចេញអាប៉ោធាតុខាងក្នុង), អន្តោមញ៉ូន, ក្រពេញផលិតសារធាតុខាងក្នុងខ្លួន, ក្រពេញបញ្ចេញអ័រម៉ូន

**endocrinology** /ˌɛndəʊkrɪˈnɒlədʒi/ [n] អន្តោមញ៉ូនវិជ្ជា, ការសិក្សាអំពី ក្រពេញដែលផលិតសារធាតុក្នុងខ្លួន

**endoderm** /ˈɛndə(ʊ)dəːm/ [n] អង់ដូឌែម (ស្រទាប់ជាលិកាអំប្រីយ៉ុងដែលបង្កើតភ្នាសនៃប្រព័ន្ធរំលាយអាហារ), ភ្នាសក្នុងជីវ៉ាណូ, ស្រទាប់ខាងក្នុង ស្បូន(ចំពោះមនុស្ស)

**endodontic** /ˈɛndəʊ [n] បណ្ដូលធ្មេញ

**endodontics** /ˌɛndəʊˈdɒntɪks/ [n] ទន្តពេទ្យ, ការព្យាបាលខាងពាគបណ្ដូលធ្មេញ

**endogamy** /ɛnˈdɒgəmi/ [n]

១. ដំណើរលម្អងក្នុង, អន្តោលម្អង (ដំណើរលម្អងផ្កាដោយផ្កាផ្សេងទៀតស្ថិតនៅលើដើមជាមួយគ្នា)

២. វង្សត្រកូល, ពូជសាសន៍

**endogenetic** /ˈɛndəʊˈdʒɪˈnɛtɪk/ [adj] សូមមើលពាក្យ៖ authigenic

**endogenic** /ˌɛndəʊˈdʒɛnɪk/ [adj] សូមមើលពាក្យ៖ Internal

**endogenous** /ɛnˈdɒdʒɪnəs/ [adj] ដែលកពីក្នុង, ដែលបង្កើតពីក្នុង

**endolymph** /ˈɛndə(ʊ)lɪmf/ [n] ទឹកក្នុងភ្នាស

**endometriosis** /ˌɛndə(ʊ)miːtrɪˈəʊsɪs/ [n] ការមានដាច់អញ្ចាញស្បូនជាដុំៗទៅកន្លែងខុសពីធម្មតា

**endometritis** /ˌɛndə(ʊ)mɪˈtrʌɪtɪs/ [n] ជំងឺរលាកស្បូន (រលាកភ្នាសសើមក្នុងស្បូន)

**endometrium** /ˌɛndə(ʊ)ˈmiːtrɪəm/ [n] អញ្ចាញស្បូន

**endoparasite** /ˌɛndəʊˈparəsʌɪt/ [n] បរាសិតក្នុង (សរីរាង្គបង្កពាគដែលស្ថិតនៅក្នុងស៊ុត ឬសរីរាង្គរបស់សត្វល្អិត)

**endophyte** /ˈɛndəʊfʌɪt/ [n] អង់ដូភីត (ភាវរស់ (ច្រើនតែជាផ្សិត និងបាក់តេរី) ដែលរស់នៅក្នុងរុក្ខជាតិរហូត ហើយច្រើនតែជាបរាសិតលើរុក្ខជាតិនោះ)

**endoplasm** /ˈɛndə(ʊ)plaz(ə)m/ [n] អង់ដូប្លាស (ផ្នែករបស់ស៊ីតូប្លាសដែលព័ទ្ធជុំវិញណ្វៃយ៉ូ)

**endoskeleton** /ˈɛndəʊˌskɛlɪt(ə)n/ [n] គ្រោងឆ្អឹងក្នុង (គ្រោងដែលទ្រទ្រង់ផ្នែកខាងក្នុងរបស់សត្វ)

**endosperm** /ˈɛndə(ʊ)spəːm/ [n] អង់ដូស្ពែម, សាច់គ្រាប់ (ផ្នែកសារធាតុចិញ្ចឹមនៃគ្រាប់ទុំ ហើយដែលអាចទ្រទ្រង់ការដុះលូតលាស់នៃពន្លកបាន)

- waxy endosperm /ˈwaksi ˈɛndə(ʊ)spəːm/ [n] សាច់ស្អិត (ជាតិស្អិតអង់ដូស្ពែម ដែលក្នុងនោះ វាមានផ្ទុកនូវអាមីឡូប៉ិកទីនប្រហែល ១០០% និងអាមីឡូសពី 0 ទៅ ២% តែប៉ុណ្ណោះ (ឧ. អង្ករដំណើប))

**endothermic** /ˌɛndəʊˈθəːmɪk/ [adj] ដែលត្រូវការថាមពល

**endothermy** /ˌɛndəʊˈθəːmi/ [n] កម្ដៅខាងក្នុងខ្ពស់

**endotoxin** /ˈɛndəʊˌtɒksɪn/ [n] ជាតិពុលក្នុង

**endotracheal** /ˌɛndə(ʊ)ˈtreɪkɪəl/ [adj] ឋិតក្នុងបំពង់ក

**endotracheal tube** /ˌɛndə(ʊ)ˈtreɪkɪəl/ [n] រ៉ែម្ដដាក់ក្នុងបំពង់ក

**endozoochory** [n] ការពង្រាយគ្រាប់ដោយសត្វ (ស៊ីលេបគ្រាប់)

**endrin** /ˈɛndrɪn/ [n] អង់ឌ្រីន

**enema** /ˈɛnɪmə/ [n] ការបញ្ចូលទឹកលាង, ការបញ្ចុះលាមក

**energy** /ˈɛnədʒi/ [n] ថាមពល, កម្លាំង

- alternative energy /ɔːlˈtəːnətɪv ˈɛnədʒi/ [n] ថាមពលជំនួស
- atomic energy /əˈtɒmɪk ˈɛnədʒi/ [n] ថាមពលអាតូមិច, ថាមពលបរមាណូ
- biomass energy /ˈbʌɪə(ʊ)mas ˈɛnədʒi/ [n] ថាមពលជីវម៉ាស
- chemical energy /ˈkɛmɪk(ə)l ˈɛnədʒi/ [n] ថាមពលគីមី
- clean energy /kliːn ˈɛnədʒi/ [n] ថាមពលស្អាត

- decay energy /dɪˈkeɪ ˈɛnədʒi/ [n] ថាមពលបំបែកធាតុ
- electric energy /ɪˈlɛktrɪk ˈɛnədʒi/ [n] ថាមពលអគ្គិសនី
- geothermal energy /dʒiːə(ʊ)ˈθəːm(ə)l ˈɛnədʒi/ [n] ថាមពលភ្នំភ្លើង, ថាមពលកម្តៅក្នុងផែនដី
- germination energy /dʒəːmɪˈneɪʃ(ə) ˈɛnədʒi/ [n] ថាមពលដំណុះ (សមាមាត្រនៃដំណុះ ដែលបានដុះឡើងរហូតដល់ពេលដំណុះវាច្រើនបំផុត ឬចំណុចពេលនៃអត្រាដំណុះអតិបរមា ឬដល់ចំណុចពេលគេកំណត់ទុកជាធម្មតាគឺការពិសោធន៍៧ថ្ងៃ។ ពេលវេលានៃការវាស់ដំណុះ ត្រូវបាន គេជ្រើសរើសតាមមធ្យោបាយជាច្រើន។)
- green energy /griːn ˈɛnədʒi/ [n] ថាមពលបៃតង
- hard energy /hɑːd ˈɛnədʒi/ [n] ថាមពលរឹង
- heat energy /hiːt ˈɛnədʒi/ [n] ថាមពលកម្តៅ
- hydraulic energy /hʌɪˈdrɔːlɪk ˈɛnədʒi/ [n] ថាមពលទឹក
- light energy /lʌɪt ˈɛnədʒi/ [n] ថាមពលពន្លឺ
- mechanical energy /mɪˈkanɪk(ə)l ˈɛnədʒi/ [n] ថាមពលមេកានិច
- nuclear energy /ˈnjuːklɪə ˈɛnədʒi/ [n] សូមមើលពាក្យ៖ nuclear power
- potential energy /pə(ʊ)ˈtɛnʃ(ə)l ˈɛnədʒi/ [n] ថាមពលប៉ូតង់ស្យែល
- radiant energy /ˈreɪdɪənt ˈɛnədʒi/ [n] សូមមើលពាក្យ៖ ray
- renewable energy /rɪˈnjuːəbəl ˈɛnədʒi/ [n] ថាមពលកើតឡើងវិញ
- soft energy /sɒft ˈɛnədʒi/ [n] ថាមពលទន់
- solar energy /ˈsəʊlə ˈɛnədʒi/ [n] ថាមពលព្រះអាទិត្យ
- thermal energy /ˈθəːm(ə)l ˈɛnədʒi/ [n] (សទិសសន័យ៖ heat power) ថាមពលកម្តៅ
- tidal energy /ˈtʌɪd(ə)l ˈɛnədʒi/ [n] (សទិសសន័យ៖ tidal power) ថាមពលទឹកជោរ
- wave energy /weɪv ˈɛnədʒi/ [n] (សទិសសន័យ៖ wave power) ថាមពលរលក
- wind energy /wɪnd ˈɛnədʒi/ [n] (សទិសសន័យ៖ wind power) ថាមពលខ្យល់

**engine** /ˈɛndʒɪn/ [n] ចលករ (អ្នកផ្តល់ចលនាឱ្យឧបករណ៍ដទៃទៀត)

- gasoline engine /ˈgasəliːn ˈɛndʒɪn/ [n] ចលករសាំង (ចលករចំហេះក្នុងដែលដើរដោយប្រេងសាំង)

**engorge** /ɛnˈgɔːdʒ/ [v] ធ្វើឱ្យស្ទះ, បន្លប់

**enlarge** /ɛnˈlɑːdʒ/ [v] ពង្រីក

**enrichment** /ɛnˈrɪtʃm(ə)nt/ [n] ភាពសម្បូរ, ការធ្វើឱ្យកាន់តែសម្បូរឡើងៗ

- selective enrichment /sɪˈlɛktɪv ɛnˈrɪtʃm(ə)nt/ [n] បណ្តុះជម្រើស (បច្ចេកទេសដែលជំរុញការលូតលាស់ប្រភេទយថាប្រភេទ ឬក្រុមអតិសុខុមប្រាណ)

***Entada scandens*** [sci.n] អង្គញ់

***Entamoeba histolytica*** [sci.n] អតិសុខុមប្រាណមានកោសិកាតែមួយ (អាចមាននៅក្នុងពោះវៀន, ថ្លើម, សួត, ឬខួរក្បាល)

**enteritis** /ˌɛntəˈrʌɪtɪs/ [n] រលាកពោះវៀនតូច (បណ្តាលដោយរោគ)

**enterotoxemia** /ˌɛntərəʊtɒkˈsiːmiə/ [n] អង់តេរ៉ូតុកសេមី (ជាតិពុលក្នុងឈាមដែលជ្រាបពីពោះវៀន)

**entire** /ɪnˈtʌɪə/ [adj] (ចំពោះទម្រង់រុក្ខជាតិ) ស្មើ (គ្មានរាងធ្មេញ), ទម្រង់គែមស្លឹករាប

**entoderm** /ɪntaʊdəːm/ [adj] ក្នុងស្បែក, ភ្នាសក្នុងជីវ៉ាណូ, ស្រទាប់ខាងក្នុងស្បូន

**entomogenous** /ˈɛntəməʊdʒɪnəs/ [adj] បរាសិតលើសត្វល្អិត (អំពីផ្សិត)

**entomologist** /ˌɛntəˈmɒlədʒɪst/ [n] បាណកវិទូ (អ្នកសិក្សាអំពីបាណកវិទ្យា)

**entomology** /ˌɛntəˈmɒlədʒi/ [n] បាណកវិទ្យា, សត្វល្អិតវិទ្យា (វិទ្យាសាស្ត្រដែលសិក្សាអំពីពពួកសត្វល្អិតដូចជាមមាច កណ្តូប ចង្រិតជាដើម)

**entomophily** /ˌɛntəˈmɒfɪli/ [n] ដំណើរលម្អងដោយសត្វល្អិត

**entrails** /ˈɛntreɪlz/ [n pl] ពោះវៀន

**enucleate** /ɪˈnjuːklɪeɪt/ [adj] គ្មានណ្វៃយ៉ូ

**enucleate** /ɪˈnjuːklɪeɪt/ [v] ឆ្កឹះ ឬឆ្កៀលចេញ

**enucleation** /ɪnjuːklɪˈeɪʃ(ə)n/ [n] ការវះយកដុំសាច់ ឬវត្ថុផ្សេងទៀតដោយយកទាំងមូលចេញ

**envelope** /rɪˈzɪst(ə)ns/ [n] សម្បកស្រោប

**environment** /ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថាន, បរិយាកាស, មជ្ឈដ្ឋាន (ទីកន្លែងនៅជុំវិញសារពាង្គកាយរស់មួយដែលមានឥទ្ធិពលលើការដុះលូតលាស់នៃសភាវរស់នោះ)

- abiotic environment /ˌeɪbʌɪˈɒtɪk ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានគ្មានជីវិត, បរិស្ថានអាប្យូទិច
- acid environment /ˈasɪd ɪnˈvʌɪrənm(ə)nt/ [n] មជ្ឈដ្ឋានអាស៊ីត
- anthropogenic environment /ˌanθrəpəˈdʒɛnɪk ɪnˈvʌɪrənm(ə)nt/ [n] សូមមើលពាក្យ៖ man-made environment
- aquatic environment /əˈkwatɪk ɪnˈvʌɪrənm(ə)nt/ [n] មជ្ឈដ្ឋានទឹក
- artificial environment /ɑːtɪˈfɪʃ(ə)l ɪnˈvʌɪrənm(ə)nt/ [n] សូមមើលពាក្យ៖ man-made environment
- biological environment /bʌɪə(ʊ)ˈlɒdʒɪk(ə)l ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានជីវសាស្ត្រ
- biotic environment /bʌɪˈɒtɪk ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានមានជីវិត, បរិស្ថានប្យូទិច
- cultural environment /ˈkʌltʃ(ə)r(ə)l ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានវប្បធម៌
- degraded environment /dɪˈgreɪdɪd ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានរេចរឹល
- human environment /ˈhjuːmən ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានមនុស្ស
- humid environment /ˈhjuːmɪd ɪnˈvʌɪrənm(ə)nt/ [n] មជ្ឈដ្ឋានសើម
- man-made environment /man-meɪd ɪnˈvʌɪrənm(ə)nt/ [n] (សទិសន័យ៖ anthropogenic environment, artificial environmen) បរិស្ថានសិប្បនិម្មិត
- marine environment /məˈriːn ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានសមុទ្រ
- moist environment /mɔɪst ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានសើម
- natural environment /ˈnatʃ(ə)r(ə)l ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានធម្មជាតិ
- polluted environment /pəˈluːtid ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានកខ្វក់, បរិស្ថានពុល
- pristine environment /ˈprɪstiːn ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានដើម
- propagation environment /prɒpəˈgeɪʃ(ə)n ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានដុះលូតលាស់ (មានកត្តាដូចជាកត្តាបរិយាកាស កត្តាជីវសាស្ត្រ កត្តាដីជាដើម)
- social environment /ˈsəʊʃ(ə)l ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានសង្គម
- terrestrial environment /təˈrɛstrɪəl ɪnˈvʌɪrənm(ə)nt/ [n] បរិស្ថានដីគោក

**environmental** /ɪnvʌɪrənˈmɛnt(ə)l/ [adj] នៃបរិស្ថាន

- environmental amplitude /ɪnvʌɪrənˈmɛnt(ə)l ˈamplɪtjuːd/ [n] ដែនអេកូឡូស៊ី ដែលប្រភេទអាចរស់បាន (កត្តាបរិស្ថាន របស់រុក្ខជាតិដូចជារយៈកម្ពស់ កម្រិតទឹកភ្លៀង សីតុណ្ហភាព កម្រិតពន្លឺ pH ជាដើម)
- environmental education /ɪnvʌɪrənˈmɛnt(ə)l ɛdjʊˈkeɪʃ(ə)n/ [n] អប់រំបរិស្ថាន
- environmental variation /ɪnvʌɪrənˈmɛnt(ə)l vɛːrɪˈeɪʃ(ə)n/ [n] បម្រែបម្រួលបរិស្ថាន, ការប្រែប្រួលបរិស្ថាន (ការខុសគ្នាខាងផេណូទីបក្នុងចំណោមដើមឈើកំណើតដែលដុះនៅទីកន្លែងផ្សេងៗនៃលំដាប់ប្រភេទពូជមួយ។ បើសិនជា ការខុសប្លែកគ្នានេះ វាមានលក្ខណៈលំអៀងខ្លាំងខាងសេនេទិចជាងបរិស្ថាននោះ បម្រែបម្រួលនេះ ជាធម្មតាវាបញ្ជាក់ថាជាពូជ (race) ប្រភេទបរិស្ថាន (ecotype) ឬភាពស្រដៀង (cline)។)

**environmentalist** /ɪnˌvʌɪrənˈmɛnt(ə)lɪst/ [n] អ្នកបរិស្ថាន

**enzootic** /ˌɛnzəʊˈɒtɪk/ [adj] នៃជំងឺរាតត្បាតតាមតំបន់

**enzyme** /ˈɛnzʌɪm/ [n] អង់ស៊ីម, ដ្យាស្តស (ប្រូតេអ៊ីនពិសេសដែលបង្កើតដោយសារពាង្គកាយរស់ ហើយមានមុខងារជាកាតាលីករក្នុងប្រតិកម្មគីមីជីវក្នុងសារពាង្គកាយ)

- adaptive enzyme /əˈdaptɪv ˈɛnzʌɪm/ [n] អង់ស៊ីមបន្សាំ
- constitutive enzyme /ˈkɒnstɪtjuːtɪv ˈɛnzʌɪm/ [n] អង់ស៊ីមសំខាន់
- debranching enzyme /dibrɑːn(t)ʃ ˈɛnzʌɪm/ [n] អង់ស៊ីមផ្តាច់សម្ពន្ធ

**enzymology** /ˌɛnzʌɪˈmɒlədʒi/ [n] អង់ស៊ីមវិទ្យា

**eocene** /ˈiːə(ʊ)siːn/ [n] អេអូសែន

**ep-** /ɛp/ [prefix] (ដូច៖ eph-, epi-) បុព្វបទមានន័យថាខាងលើ ឬខាងក្រៅ

***Epalzeorhynchos frenatum*** [sci.n] ត្រីគល់ចេក

***Epalzeorhynchos munense*** [sci.n] ត្រីអណ្តាតពីរ

**eph-** [prefix] សូមមើលពាក្យ៖ ep-

**ephemeral** /ɪˈfɛm(ə)r(ə)l/ [adj] មានជីវិតខ្លី (ភាវរស់ ដូចជារុក្ខជាតិនៅវាលរហោឋាន)

**epi-** /ˈɛpi/ [prefix] សូមមើលពាក្យ៖ ep-

**epicenter** /ˈɛpɪsɛntə/ [n] ផ្ចិតលើ

**epicotyl** /ˌɛpɪˈkɒtɪl/ [n] ត្រួយពន្លក, អេពិខកធីល, ផ្នែកខាងចុងរបស់អំប្រីយ៉ុង (ផ្នែកខាងចុងរបស់អំប្រីយ៉ុងដែលនឹងវិវត្តន៍ទៅជាដើម។ នៅក្នុងគ្រាប់ដែលដុះពន្លករួច ឬកូនឈើនោះ គឺវាសំដៅទៅលើផ្នែកនៃដើមនៅចន្លោះកូទីលេដុន និងស្លឹកទី១។)

**epidemic** /ɛpɪˈdɛmɪk/ [n] ជំងឺរាតត្បាត, រាលដាលកម្ម (ការរីករាលដាលនូវភាពចម្លងជំងឺយ៉ាងខ្លាំងក្លាតាមតំបន់ ឬពេញប្រទេសទាំងមូល)

**epidemic** /ˈɛpɪgamɪk/ [adj] នៃជំងឺរាតត្បាត, ដែលរាលដាល

**epidemiology** /ˌɛpɪdiːmɪˈɒlədʒi/ [n] ជំងឺរាតត្បាតវិទ្យា

**epidermis** /ˌɛpɪˈdəːmɪs/ [n]

១. (ចំពោះសត្វ) អេពីឌែម (ស្បែកលើ, សម្បក)

២. (ចំពោះរុក្ខជាតិ) អេពីឌែម (ស្រទាប់កោសិកាទីមួយនៅក្នុងប្រភេទរុក្ខជាតិថ្នាក់ខ្ពស់ ហើយជាកោសិកាក្រាស់)

**epididymis** /ˌɛpɪˈdɪdɪmɪs/ [n] គល់ទងបន្តពីពងស្វាស

**epigeal** /ˌɛpɪˈdʒiːəl/ [adj] ដុះពីលើដីសើៗ

**epiglottis** /ˌɛpɪˈglɒtɪs/ [n] សន្ទះខ្យល់ (កន្ទើត)

**epigyny** /ɪˈpɪdʒənɪ/ [n] ទម្រផ្កាស្រោបលើអូវ៉ែ, នៅក្នុងទម្រផ្កា, នៅក្រោមទម្រផ្កា (ទីតាំងរបស់អូវ៉ែធៀបនឹងទម្រផ្កា។ ទម្រផ្កា និង/ឬទម្រនៃសរីរាង្គផ្សេងៗទៀតរបស់ផ្កាស្រោបលើអូវ៉ែ ឧ. Malus (ដើមប៉ោម)។ ន័យផ្ទុយ Hypogyny (ទម្រផ្កានៅក្រោមអូវ៉ែ)។ Epistasis: មិនសម្តែងចេញ ការលាក់បាំងនូវប្រសិទ្ធិភាពជេណូទីបរបស់អាលែលមួយឬទាំង២ដោយសារពន្ធុ១នៃឡូខឹសខុសគ្នា។)

**epilepsy** /ˈɛpɪlɛpsi/ [n] ជំងឺស្កន់, ឆ្កួតជ្រូក

**epilimnion** /ˌɛpɪˈlɪmnɪən/ [n] ស្រទាប់លើនៃទឹកបឹង

**epinasty** /ˈɛpɪˈnɑːsti/ [n] អេភីណាសស្ទី (ការលូតលាស់បំប្លែងឯកទេសរបស់ទងស្លឹក ដែលបណ្តាលឱ្យតួស្លឹកកោងចុះក្រោម)

**epinephrine** /ˌɛpɪˈnɛfriːn/ [n] អេពីណេហ្វ្រីន (ជាតិអ័រម៉ូនប្រើសម្រាប់ជាជំនួយបេះដូង និងជំងឺហឺត)

**epipetalous** /ˌɛpɪˈpɛtələs/ [adj] នៅចំមុខស្រទាប់ផ្កា ((អំពីទម្រង់រុក្ខជាតិ) បញ្ចូលនៅចំកញ្ចុំស្រទាប់ផ្កា ដូចជាករណីកញ្ចុំកេសរឈ្មោលរបស់ផ្កាព្រីមរូស)

**epiphyte** /ˈɛpɪfʌɪt/ [n] រុក្ខជាតិអាកាស, អេពីភីត (រុក្ខជាតិដុះលើមែកឈើប៉ុន្តែ ទាញយកអាហារ និងសំណើមពីផ្កា)

**epiphytology** /ˌɛpiˌfʌɪtəʊlədʒi/ [n] ការសិក្សាពីក្រិតក្រមនៃកំណកំណើតជំងឺ និងមូលហេតុនៃការរាតត្បាតរបស់វា

**epiphytotic** /ˌɛpifʌɪˈtəʊtɪk/ [adj] អេពីភីតូទិច ((អំពីជំងឺរុក្ខជាតិ និងបរាសិត) ឆ្លងជំងឺទៅរុក្ខជាតិក្នុងតំបន់ភូមិសាស្ត្រយ៉ាងធំ)

**epiplankton** /ˈɛpiˈplaŋ(k)t(ə)n/ [n] អេពីប្លង់តុង

**episiotomy** /ɛˌpiːsɪˈɒtəmi/ [n] ការកាត់យោនី (សម្រួលការសម្រាលកូន)

**epistasis** /ɪˈpɪstəsɪs/ [n] លក្ខណៈមិនសម្តែងចេញ (សេនេទិច)

**epitaxis** /ˌɛpɪˈstaksɪs/ [n] ការចេញឈាមតាមច្រមុះ, ឈាមច្រមុះ

**epithelium** /ˌɛpɪˈθiːlɪəm/ [n] (សទិសន័យ៖ squamous cell) កោសិកាអេពីតេល្យ៉ូម

**epizoic** /ˌɛpɪˈzəʊɪk/ [adj] អេពីសូអ៊ិច (ភាវរស់រស់ដោយភ្ជាប់ខ្លួន ទៅនឹងផ្នែកខាងក្រៅរបស់សារពាង្គកាយសត្វដទៃ។ (ផ្លែ ឬគ្រាប់) មានវិធីពង្រាយ ដោយសារការភ្ជាប់ទៅនឹងផ្នែកខាងក្រៅរបស់សត្វ)

**epizoite** /ɛpɪˈzəʊʌɪt/ [n] អេពីសូអ៊ីត (សត្វដែលរស់ដោយភ្ជាប់ខ្លួនទៅនឹងសត្វដទៃ ដែលវាប្រើសម្រាប់ជាមធ្យោបាយការពារសម្រាប់ការធ្វើចលនា គឺមិនមែនជាទំនាក់ទំនងបរាសិតទេ ឧទាហរណ៍ ពួកខ្យង ឬលៀសដែលរស់ជាប់នៅលើខ្នងអណ្តើកសមុទ្រ)

**epizoology** /ˈɛpizuːˈɒlədʒi/ [n] ការសិក្សាអំពីជំងឺសត្វ

**epizootic** /ˌɛpɪzəʊˈɒtɪk/ [adj] នៃជំងឺរាតត្បាតសត្វ (ឆ្លងភ្លាមៗ លើសត្វយ៉ាងច្រើន), នៃជំងឺឆ្លងរបស់សត្វពាហនៈ, នៃជំងឺរាតត្បាតសត្វ

**epoch** /ˈiːpɒk/ [n] យុគ, សម័យ

**equality** /ɪˈkwɒlɪti/ [n] សមភាព

**equation** /ɪˈkweɪʒ(ə)n/ [n] សមីការ

- balanced equation /ˈbalənst ɪˈkweɪʒ(ə)n/ [n] សមីការបានថ្លឹង

- chemical equation /ˈkɛmɪk(ə)l ɪˈkweɪʒ(ə)n/ [n] សមីការគីមី
- equilibrium equation /ˌiːkwɪˈlɪbrɪəm ɪˈkweɪʒ(ə)n/ [n] សមីការលំនឹង

**Equidae** [n] អស្សសត្វ (គ្រួសារសេះ)

**equilibrium** /ˌiːkwɪˈlɪbrɪəm/ [n] តុល្យភាព, លំនឹង, សមតា (លក្ខខណ្ឌលំនឹងក្នុងខណៈណាមួយ)

- biological equilibrium /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˌiːkwɪˈlɪbrɪəm/ [n] លំនឹងជីវៈសាស្ត្រ
- chemical equilibrium /ˈkɛmɪk(ə)l ˌiːkwɪˈlɪbrɪəm/ [n] លំនឹងគីមី
- ecological equilibrium /iːkəˈlɒdʒɪk(ə)l ˌiːkwɪˈlɪbrɪəm/ [n] លំនឹងអេកូឡូស៊ី

**equipment** /ɪˈkwɪpm(ə)nt/ [n] គ្រឿងបំពាក់ (ឧបករណ៍ដែលភ្ជាប់ពីក្រោយចលករអូស), គ្រឿងបរិក្ខារ, ការបំពាក់គ្រឿងបរិក្ខារ

- durable medical equipment /ˈdjʊərəb(ə)l ˈmɛdɪk(ə)l ɪˈkwɪpm(ə)nt/ [n] និរន្តរាយ បរិក្ខារពេទ្យ (ប្រដាប់ប្រដាពេទ្យដែលមិនងាយ អន្តរាយ ឬវិនាស)
- mechanical equipment /mɪˈkanɪk(ə)l ɪˈkwɪpm(ə)nt/ [n] ឧបករណ៍មេកានិច

**equivalent** /ɪˈkwɪv(ə)l(ə)nt/ [n] សមមូល (ការដែលមានតម្លៃ ឬបរិមាណស្មើគ្នា)

- acid equivalent /ˈasɪd ɪˈkwɪv(ə)l(ə)nt/ [n] សមមូលភាពនៃអាស៊ីត (សមាមាត្រភាគនៃថ្នាំកម្ចាត់សត្វល្អិតដែលក្នុងទ្រឹស្តីត្រូវបានបំប្លែងទៅជាអាស៊ីត)
- ecological equivalent /iːkəˈlɒdʒɪk(ə)l ɪˈkwɪv(ə)l(ə)nt/ [n] សមមូលអេកូឡូស៊ី (ប្រភេទមួយក្នុងចំណោមប្រភេទពីរ ដែលមានប្រភពចេញពីដូនតាតែមួយ ដោយវិវត្តក្នុងបរិស្ថានប្រហាក់ប្រហែលគ្នា)

equivalent /ɪˈkwɪv(ə)l(ə)nt/ [adj] សមមូល, ប៉ុនគ្នានឹង

- moisture equivalent /ˈmɔɪstʃə ɪˈkwɪv(ə)l(ə)nt/ [n] សមមូលសំណើម, សំណើមស្មើ

**era** /ˈɪərə/ [n] ស័ក

- cenozoic era /ˌsiːnəˈzəʊɪk ˈɪərə/ [n] ស័កសេណូសូអ៊ិច (ស័កករកើតជីវិត ដែលគិតចាប់តាំងពី ៦៥ លានឆ្នាំមុន)
- mesozoic era /ˌmɛsə(ʊ)ˈzəʊɪk ˈɪərə/ [n] ស័កមេសូសូអ៊ិច
- palaeozoic era /ˌpalɪə(ʊ)ˈzəʊɪk ˈɪərə/ [n] ស័កប៉ាលេអូសូអ៊ិច, ស័កទីមួយ (ជាស័កជីវិតបុរាណ ឬ ដំបូងបំផុត ដែលមានតាំងពីប្រហែល ៥១៤ ទៅ២៥១,១៧ លានឆ្នាំមុន)
- precambrian era /priːˈkambrɪən ˈɪərə/ [n] ស័កបុរេកំប្រីយាង (ជាស័កដែលមានពេលយូរជាគេក្នុងប្រវត្តិការកើតផែនដី ដែលមានចាប់តាំងពីប្រមាណ ៤,៦លានឆ្នាំមុន)

**eradicant** /ɪˈradɪˌk(ə)nt/ [n] ថ្នាំសម្លាប់មេរោគ

**eradication** /ɪˌradɪˈkeɪʃ(ə)n/ [n] ការបំបាត់ (ជំងឺ), ដំណក

- weed eradication /wiːd ɪˌradɪˈkeɪʃ(ə)n/ [n] ការកម្ទេចស្មៅឱ្យអស់

**Erbium** /ˈəːbɪəm/ [n] អែប្យូម (និមិត្តសញ្ញាគីមី Er)

**erect** /ɪˈrɛkt/ [v] ដុះត្រង់ (ជាសណ្ឋានរបស់រុក្ខជាតិណាមានដើមដុះទម្រង់ឈរត្រង់ទៅលើ)

**erectile** /ɪˈrɛktʌɪl/ [adj] បះ (ដែលមានសមត្ថភាពបះត្រង់ឡើងលើ)

**erection** /ɪˈrɛkʃ(ə)n/ [n] ភាពឡើងតឹងរឹង (ជាលិកាសរីរាង្គ), ការបះ (លិង្គ)

**erepsin** /ɪˈrɛpsɪn/ [n] អ៊ីរេបស៊ីន (ល្បាយអង់ស៊ីមរំលាយដែលបញ្ចេញដោយពោះវៀនតូចរបស់ថនិកសត្វ)

***Eretmochelys imbricata*** [sci.n] សូមមើលពាក្យ៖ hawksbill turtle

**ergot** /ˈəːɡɒt/ [n]

១. ខ្នាយ, ឆ្នាល់

២. អែរកូ (ជំងឺធញ្ញជាតិ)

**erode** /ɪˈrəʊd/ [v] (សទិសន័យ៖ gnaw, wear away) កកេរស៊ី (ច្រេះ)

**eroded** /ɪˈrəʊdid/ [adj] ដែលហូរច្រោះខ្លាំង

**erodibility** /ɪˈrəʊdəˈbɪlɪti/ [n] សមត្ថភាពក្នុងការហូរច្រោះបាន

**erodible** /ɪˈrəʊdˈeɪb(ə)l/ [adj] ដែលហូរច្រោះ

**erose** /ɪˈrəʊs/ [n] រដេចរដូច (ទម្រង់របស់រុក្ខជាតិ)

**erosion** /ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះ, សំណឹក (ការបាត់បង់ភាគល្អិតរបស់ដី (សារធាតុចិញ្ចឹម) ឬផ្នែកនៃដីដោយអំពើជាអចិន្ត្រៃយ៍នៃខ្យល់ ទឹក និងកត្តាដទៃៗ)

- accelerated erosion /əkˈsɛləreɪtid ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះដោយពន្លឿន
- base level of erosion /beɪs ˈlɛv(ə)l ɒv ɪˈrəʊʒ(ə)n/ [n] កម្រិតមូលដ្ឋាននៃការហូរច្រោះ
- chemical erosion /ˈkɛmɪk(ə)l ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះខាងក្នុងដោយកត្តាគីមី, ការនាំចេញទៅនៃអំបិលដោយការលាងច្រោះ
- coastal erosion /ˈkəʊstl ɪˈrəʊʒ(ə)n/ [n] សំណឹកឆ្នេរ
- concealed erosion /kənˈsiːld ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះដោយលាក់បំពួនដោយមើលមិនឃើញ (ដោយច្រោះទៅក្រោមជាជម្រៅ)
- deep erosion /diːp ɪˈrəʊʒ(ə)n/ [n] សូមមើលពាក្យ៖ gully erosion
- downward erosion /ˈdaʊnwəd ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះក្នុងជម្រៅ
- genetic erosion /dʒɪˈnɛtɪk ɪˈrəʊʒ(ə)n/ [n] ការបាត់បង់ពន្ធុ (ដំណើរការបាត់បង់ប្រភពធនធានសម្ភារៈតំណពូជ (សេនេទិច) ដោយការគំរាមកំហែងមកពីកំណើនប្រជាពលរដ្ឋ ការរៀបចំទីក្រុង និងមណ្ឌលឧស្សាហកម្មជាដើម។ ការបាត់បង់នូវនានាភាពរបស់ពន្ធុ និងការបន្សល់កាន់តែតិចទៅៗនូវមូលដ្ឋានសេនេទិកនៃរុក្ខជាតិដែលគេដាំដុះ។ ឆ្លងតាមការនាំចូលនូវពូជនានាមានគុណភាព ធ្វើឱ្យគេអាចដាំដុះនៅតំបន់ជាច្រើនបាន។)
- geological erosion /dʒiːəˈlɒdʒɪk(ə)l ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះដោយភូគព្ភសាស្ត្រ
- glacial erosion /ˈgleɪsɪəl ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះដោយទឹកកក
- gully erosion /ˈgʌli ɪˈrəʊʒ(ə)n/ [n] (សទិសន័យ៖ deep erosion) ការហូរច្រោះជាជ្រោះ
- headward erosion /ˈhɛdwəd ɪˈrəʊʒ(ə)n/ [n] សំណឹកថយ
- lateral erosion /ˈlat(ə)r(ə)l ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះ ឬរេចរឹលពីខាង
- localised erosion /ˈləʊk(ə)lʌɪzd ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះដោយកន្លែង
- micro-erosion /ˈmʌɪkrəʊ ɪˈrəʊʒ(ə)n/ [n] ការរេចរឹលល្អិតៗ
- normal erosion /ˈnɔːm(ə)l ɪˈrəʊʒ(ə)n/ [n] ការរេចរឹលធម្មតា
- plucking erosion /plʌkin ɪˈrəʊʒ(ə)n/ [n] ការរេចរឹលដោយការផ្ទុះ
- rain erosion /reɪn ɪˈrəʊʒ(ə)n/ [n] សំណឹកដោយភ្លៀង
- retrogressive erosion /ˌrɛtrə(ʊ)ˈgrɛsɪv ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះដោយថយក្រោយ
- rill-erosion /rɪl ɪˈrəʊʒ(ə)n/ [n] (សទិសន័យ៖ rill-washing erosion) ការហូរច្រោះជាចង្អូរ
- rill-washing erosion /rɪl-ˈwɒʃɪŋ ɪˈrəʊʒ(ə)n/ [n] សូមមើលពាក្យ៖ rill-erosion
- sheet erosion /ʃiːt ɪˈrəʊʒ(ə)n/ [n] សំណឹកលាត, ការរេចរឹលជាស្រទាប់ៗ, ការហូរច្រោះជាផ្ទាំង (ជាស្រទាប់ៗ ឬនៅស្រទាប់លើ)
- sliding erosion /slʌɪd ɪˈrəʊʒ(ə)n/ [n] ការរេចរឹលដោយរបក និងរអិល
- slip erosion /slɪp ɪˈrəʊʒ(ə)n/ [n] ការរេចរឹលដោយការរអិល
- slope erosion /sləʊp ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះលើជម្រាល
- soil erosion /sɔɪl ɪˈrəʊʒ(ə)n/ [n] សំណឹកដី (ឧ. សំណឹកដោយសារភ្លៀងធ្លាក់)
- splash erosion /splaʃ ɪˈrəʊʒ(ə)n/ [n] ការរេចរឹល ឬហូរច្រោះដោយទម្ងន់ដំណក់ទឹកភ្លៀង
- stream-bed erosion /striːm-bɛd ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះដោយទឹកទន្លេ
- tunnel erosion /ˈtʌn(ə)l ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះជារូងក្នុងដី
- water erosion /ˈwɔːtə ɪˈrəʊʒ(ə)n/ [n] ការហូរច្រោះ ឬរេចរឹលដោយទឹក
- waterfall-erosion /ˈwɔːtəfɔːl-ɪˈrəʊʒ(ə)n/ [n] ការផ្តាច់ដីដោយទឹកភ្លៀង
- wind erosion /wɪnd ɪˈrəʊʒ(ə)n/ [n] សំណឹកដោយខ្យល់

**erosivity** /ɪˈroʊssɪtɪv/ [n] ការហូរច្រោះធ្វើឱ្យរេចរឹល

**error** /ˈɛrə/ [n] ល្មៀង

- embrace error /ɪmˈbreɪs ˈɛrə/ [n] ទទួលយកកំហុស

- experimental error /ɪkˌspɛrɪˈmɛnt(ə)l ˈɛrə/ [n] លម្អៀងពិសោធ (តម្លៃខុសគ្នារវាងកូនស្រែដែលមានបច្ច័យដូចគ្នា ដោយមិនបានធ្វើការចាប់ឆ្នោតត្រឹមត្រូវ ឧ. ការពិសោធដោយដាំពូជដូចគ្នាក្នុងកូនស្រែដូចគ្នា លុះបានផលខុសគ្នា នោះហើយជាលម្អៀងពិសោធ)
- sampling error /ˈsɑːmp(ə)lɪŋ ˈɛrə/ [n] ការអង្កេតអំពីចំនួនសំណាក
- standard error /ˈstandəd ˈɛrə/ [n] ខ្នាតកំហុស (លេខបញ្ជាក់ពីតម្លៃខុសឆ្គងនៃការធ្វើពិសោធអ្វីមួយ)

**eruption** /ɪˈrʌpʃ(ə)n/ [n]
១. (ចំពោះសត្វ) កន្ទួលរទុះ, កន្ទួលឆ្នួតៗ, អ្វីដែលទម្លុះចេញពីស្បែក, ការលេចចេញនូវធ្មេញថ្មីពីអញ្ចាញធ្មេញ
២. (ចំពោះបរិស្ថាន) ការផ្ទុះឡើង, បន្ទុះ

- delayed eruption /dɪˈleɪd ɪˈrʌpʃ(ə)n/ [n] ដំណើរធ្មេញនីមួយៗដុះយឺត
- eruption cyst /ɪˈrʌpʃ(ə)n sɪst/ [n] គីសកើតឡើងនៅពេលធ្មេញដុះ
- eruption of teeth /ɪˈrʌpʃ(ə)n ɒv tiːθ/ ដំណើរដុះធ្មេញ, ដំណើរធ្មេញដុះចេញច្រើន
- volcanic eruption /vɒlˈkanɪk ɪˈrʌpʃ(ə)n/ [n] បន្ទុះភ្នំភ្លើង

***Erwinia chrysanthemi*** [sci.n] សូមមើលពាក្យ៖ foot rot

***Eryngium foetidum*** [sci.n] សូមមើលពាក្យ៖ culantro

**erysipelas** /ˌɛrɪˈsɪpɪləs/ [n] អេរីស៊ីប៉េល (ជំងឺជ្រូកដែលបណ្តាលឱ្យស្បែកឡើងក្រហមដុំៗ)

**Erysipelothrix** /ˌɛr əˈsɪp ə loʊˌθrɪks/ [n] អេរីស៊ីប៉េសឡូទ្រីច (ពពួកមេរោគដែលបង្កើតជំងឺសើស្បែកនៃសត្វជ្រូក)

**erythema** /ˌɛrɪˈθiːmə/ [n] រលាក (ជំងឺដែលធ្វើឱ្យស្បែកឡើងក្រហម)

***Erythrina indica*** [sci.n] រលួស

**erythrocyte** /ɪˈrɪθrə(ʊ)sʌɪt/ [n] គោលិកាក្រហម, កោសិកាឈាមក្រហម

**erythropoisis** /ɪˌrɪθ roʊ pɔɪˈi sɪs/ [n] ការផលិតកោសិកាឈាមក្រហម

**escape** /ɪˈskeɪp/ [v] រួចផុត, ជៀសផុត (ជាឯកត្តៈមួយដែលធន់នឹងជំងឺពិតប្រាកដទៅបាន លុះត្រាតែវាមិនដែលមានជំងឺឆ្លង។ ក៏ដូចជាដើមឈើព្រៃដែលគេរកមកដាំដូច្នោះដែរ។)

**escarpment** /ɪˈskɑːpm(ə)nt/ [n] ចំណោតឆ្នេរ, ឆ្នេរសមុទ្រចោតខ្លាំង, កន្លែងខ្ពស់ត្រង់ចំណោត, ភាពចោត

**Escherichia** /ˌɛʃəˈrɪkɪə/ [n] អេស្កេរីស្យា (ពពួកមេរោគម្យ៉ាងដែលច្រើនរស់នៅក្នុងពោះវៀនមនុស្ស ឬសត្វ)

***Esomus longimanus*** [sci.n] ត្រីចង្វាភ្លៀង

***Esomus metallicus*** [sci.n] សូមមើលពាក្យ៖ striped flying barb

**esophagoscopy** /ɪˈsɒfəgəˌskəʊpi/ [n] ការឆ្លុះពិនិត្យមើលក្នុងបំពង់អាហារ(ដោយប្រដាប់ពិនិត្យមានអំពូលភ្លើង)

**esophagus** /ɪˈsɒfəgəs/ [n] បំពង់អាហារ

**espalier** /ɪˈspaljə/ [n] វិធីបង្រៀនពីដើមឈើ ឬដំណាំ

**estivation** /ˌiːstɪˈveɪʃ(ə)n/ [n US] សូមមើលពាក្យ៖ aestivation

**estrogen** /ˈiːstrədʒ(ə)n/ [n] អឹស្រ្តូសែន (អ័រម៉ូនភេទស្រី ឬញី)

**estrus** /ˈɛstrəs/ [n] (សទិសន័យ៖ oestrus) អ៊ីស្ទ្រូស (រយៈពេលសត្វរកឈ្មោល ឬពេលដែលទារកអាចកឡើងបានបន្ទាប់ពីការរួមដំណេករួច), កម្តៅ (រយៈពេលពី ៥ ទៅ ៦០ ថ្ងៃដែលសត្វញីពេញវ័យភាគច្រើនមានចំណង់ និងអនុញ្ញាតឱ្យមានការពាក់គ្នា)

**estuary** /ˈɛstjʊ(ə)ri/ [n] ពាមសមុទ្រ (តំបន់ប្រសព្វគ្នារវាងទឹកសាបដូចជាស្ទឹង ព្រែក ទន្លេជាដើម ជាមួយនឹងទឹកសមុទ្រ ដែលជាទូទៅជាមជ្ឈដ្ឋានទឹកភ្លាវ ដែលមានកំហាប់អំបិលមិនលើសពី ២០ ភាគពាន់)

**etching** /ˈɛtʃɪŋ/ [n] ការស៊ី, ការកាត់ (ដោយវត្ថុធាតុណាមួយ)

**ethanol** /ˈɛθənɒl/ [n] អេតាណុល

**ethnology** /ɛθˈnɒlədʒi/ [n] ជាតិពន្ធុវិទ្យា

**ethology** /iːˈθɒlədʒi/ [n] អាកប្បកិរិយាវិទ្យា

***Etiella zinckenella*** [sci.n] ដង្កូវស៊ីរុងផ្លែសណ្តែកសៀង

**etiolation** /iːtɪəˈleɪʃ(ə)n/ [n] ការលូតលាស់ក្នុងម្លប់, សភាពរុក្ខជាតិដុះក្នុងម្លប់ (ស្លឹក-ដើមឡើងស)

**etiology** /ˌiːtɪˈɒlədʒi/ [n] ការសិក្សាពីមូលហេតុរបស់ជំងឺ, ការស្រាវជ្រាវបុព្វហេតុជំងឺ

**eubacteria** /ˌjuːbakˈtɪərɪə/ [n] អឺបាក់តេរី (បាក់តេរីភាគច្រើននៃបាក់តេរីទាំងអស់ ដែលភ្នាសរបស់វាផ្ទុកអាស៊ីតមុយរ៉ាមីក លីពីត និងលក្ខណៈពិសេសផ្សេងៗទៀតដែលធ្វើឱ្យពួកវាខុសពីអាកេបាក់តេរី)

***Euborellia stali*** [sci.n] សត្វកន្ទុយពីរ

***Eucalyptus camaldulensis*** [sci.n] ដើមប្រេងខ្យល់ស្លឹកធំ

**eugenics** /juːˈdʒɛnɪks/ [n pl] សុជាតិវិទ្យា, វិជ្ជាដែលបង្កើតកូនឱ្យបានល្អ

***Eupatorium odoratum*** [sci.n] ទន្ទ្រានខែត្រ

***Euphorbia heterophylla*** [sci.n] ទឹកដោះខ្លាធំ

***Euphorbia thymifolia*** [sci.n] ទឹកដោះខ្លាក្រហម

**euplankton** /ˌjuːˈplaŋ(k)t(ə)n/ [n] អឺប្លង់តុង (ប្លង់តុងនៅទីវាល)

***Euproctis* sp.** [sci.n] ដង្កូវធោមវែង

**Europium** /jʊ(ə)rˈəʊpɪəm/ [n] អឺរ៉ូព្យូម (និមិត្តសញ្ញាគីមី Eu)

***Euryglossa harmandi*** [sci.n] ត្រីអណ្តាតឆ្កែ

***Euryglossa orientalis*** [sci.n] ត្រីអណ្តាតឆ្កែ

***Euryglossa panoides*** [sci.n] ត្រីអណ្តាតឆ្កែវែង

**euryhaline** /ˌjʊərɪˈheɪlʌɪn/ [adj] រស់ក្នុងទឹកប្រៃពិត

**eurythermal** /ˌjʊərɪˈθəːm(ə)l/ [n] អឺរីទែម៉ាល (ដែលមានលទ្ធភាពបន្សាំទៅនឹងសីតុណ្ហភាពគ្រប់កម្រិត)

**eurytopy** /ˈjʊəriˈtɒpi/ [n] យូរីថបភី (លទ្ធភាពរស់នៅច្រើនកន្លែងលើផែនដី)

***Euscyrtus concinnus*** [sci.n] សូមមើលពាក្យៈ crickets

**eustachian tube** /juːˈsteɪʃ(ə)n tjuːb/ [n] រន្ធខ្យល់, ភ្ជាប់ផ្នែកត្រចៀកកណ្តាល

**eutherian** /juːˈθɪərɪən/ [n] សត្វមានសុក

**eutrophic** /juːˈtrəʊfɪk/ [adj] ដែលមានសារធាតុគីមីច្រើន ឬជីជាតិច្រើន (សកម្មភាពជីវសាស្ត្រច្រើន ឬជីជាតិខ្ពស់), ដែលសម្បូរសារធាតុចិញ្ចឹម

**eutrophication** /ˌjuːtrəfɪˈkeɪʃ(ə)n/ [n] ដំណើរកខ្វក់ដោយសារសារធាតុចិញ្ចឹម

**evaluate** /ɪˈvaljʊeɪt/ [v] វាយតម្លៃ, គិតតម្លៃ

**evaluation** /ɪˌvaljʊˈeɪʃ(ə)n/ [n] ការវាយតម្លៃ (ដំណើរការនៃការឱ្យពិន្ទុ ឬវិនិច្ឆ័យអំពីអ្វីមួយ)

- curriculum evaluation /kəˈrɪkjʊləm ɪˌvaljʊˈeɪʃ(ə)n/ [n] ការវាយតម្លៃលើកម្មវិធីសិក្សា
- formative evaluation /ˈfɔːmətɪv ɪˌvaljʊˈeɪʃ(ə)n/ [n] ប្រភេទមួយនៃការវាយតម្លៃដែលមានគោលបំណង ដើម្បីឱ្យកម្មវិធីមានការរីកចម្រើនទៅមុខ

**evaporate** /ɪˈvapəreɪt/ [v] ហួត

**evaporation** /ɪˌvapəˈreɪʃ(ə)n/ [n] ការចេញចំហាយទឹក, ការហួត, រំហួតទឹក (ការបាត់បង់ទឹកពីផ្ទៃរាបដោយសារកម្តៅ និងខ្យល់)

- land evaporation /land ɪˌvapəˈreɪʃ(ə)n/ [n] រំហួតពីផ្ទៃដី
- natural evaporation /ˈnatʃ(ə)r(ə)l ɪˌvapəˈreɪʃ(ə)n/ [n] រំហួតពីធម្មជាតិ

**evapotranspiration** /ɪˌvapəʊtranspɪˈreɪʃ(ə)n/ [n] រំហួតរំភាយចំហាយទឹក, បំណាត់បង់ទឹកសរុប (ការបាត់បង់ទឹកសរុបចេញពីផ្ទៃរាប និងរុក្ខជាតិក្នុងមួយឯកតាដីដោយកម្តៅថ្ងៃ ខ្យល់ និងរំភាយចំហាយទឹកចេញពីរុក្ខជាតិក្នុងដំណាកដង្ហើមរបស់វា)

**even-aged** /ˈiːv(ə)n eɪdʒd/ [adj] នៃដើមឈើ ដែលមានអាយុស្មើគ្នា មានលំដាប់ថ្នាក់អាយុតែមួយ

- even-aged forest /ˈiːv(ə)n eɪdʒd ˈfɒrɪst/ [n] ព្រៃមានអាយុស្មើគ្នា
- even-aged stand /ˈiːv(ə)n eɪdʒd stand/ [n] ដើមឈើ ដែលមានអាយុស្មើគ្នា មានលំដាប់ថ្នាក់អាយុតែមួយ

**even-pinnate** /ˈiːv(ə)n ˈpɪneɪt/ [n] ស្លឹកស្លាបគូ (ប្រភេទស្លឹកសមាស)

**evergreen** /ˈɛvəgriːn/ [adj] ពណ៌បៃតងរហូត

**evergreen** /ˈɛvəgriːn/ [n] រុក្ខជាតិបៃតងរហូត

**eversion** /ɪˈvəːʃ(ə)n/ [n] ភាពប្រលាត់ (ភ្នាសសើម), រលាត់

**eviscerate** /ɪˈvɪsəreɪt/ [v] បញ្ចេញ, ធ្លាយសរីរាង្គនៅក្នុងពោះ

**evolution** /ˌiːvəˈluːʃ(ə)n/ [n] វិវត្ត, ចលនា, ការប្រែប្រួលជាលំដាប់

- biological evolution /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˈɛvəluːʃ(ə)n/ [n] វិវត្តន៍ជីវសាស្ត្រ

**evolutionism** /ˌiːvəˈluːʃ(ə)nɪz(ə)m/ [n] ទ្រឹស្តីវិវត្តនិយម

**ex-** /ɛks/ [prefix] (ដូចៈ e-) បុព្វបទមានន័យថា ក្រៅពី ឬគ្មាន

**examine** /ɪɡˈzamɪn/ [v] ពិនិត្យ

**excavation** /ɛkskəˈveɪʃ(ə)n/ [n] (សទិសន័យៈ culting) ដីដែលគេជីកយកអាចម៍ដី, ការជីកដី

**excise** /ˈɛksʌɪz/ [v] កាត់ចេញ, បញ្ជូនចេញ, បណ្ដេញចេញ

**excision** /ɪkˈsɪʒ(ə)n/ [n] ការកាត់ផ្នែកមួយនៃសរីរាង្គចេញ

**excitation** /ˌɛksɪˈteɪʃ(ə)n/ [n] រំញោច

**exclosure** /ɪkˈskləʊʒə/ [n] តំបន់ដែលសត្វមិនត្រូវការត្រូវបានដកចេញ

**exclude** /ɪkˈskluːd/ [v] ទាត់ចោល

**excrement** /ˈɛkskrɪm(ə)nt/ [n] សូមមើលពាក្យៈ feces

**excretion** /ɪkˈskriːʃ(ə)n/ [n] ការបញ្ចេញចោល, សំណល់ពីខ្លួន, លាមក, អាចម៍

**exergonic (exothermic)** /ˌɛksəːˈɡɒnɪk/ [adj] បញ្ចេញថាមពល

**exfoliation** /ɪksfəʊlɪˈeɪʃ(ə)n/ [n] ការរបកជាស្លឹក ឬជាស្រការ

**exhale** /ɪksˈheɪl/ [v] ដក (ខ្យល់ចេញពីសួត)

**exhaust** /ɪɡˈzɔːst/ [v] ធ្វើឱ្យល្អិតល្ហៃ, បង្អស់

**exhaust** /ɪɡˈzɔːst/ [n] ផ្សែងយានយន្ត

- exhaust air /ɪɡˈzɔːst ɛː/ [n] ផ្សែងម៉ាស៊ីន
- exhaust gas /ɪɡˈzɔːst ɡas/ [n] ផ្សែង
- exhaust lead /ɪɡˈzɔːst liːd/ [n] សំណនៅក្នុងផ្សែងរថយន្ត

**exhaustion** /ɪɡˈzɔːstʃ(ə)n/ [n] ភាពរីង, កំសោះ

- heat exhaustion /hiːt ɪɡˈzɔːstʃ(ə)n/ [n] ការបាត់បង់ប្រព័ន្ធភាពត្រជាក់
- soil exhaustion /sɔɪl ɪɡˈzɔːstʃ(ə)n/ [n] ភាពខ្សោះនៃដី

**exine** /ˈɛksɪn/ [n] អិចស៊ីន (ស្រទាប់ក្រៅបំផុតរបស់គ្រាប់ល្អ ឬគ្រាប់លម្អង)

**exocarp** /ˈɛksəʊkɑːp/ [n] អ៊ិចសូខាប់, សម្បកខាងក្រៅរបស់ផ្លែមានសាច់ច្រើន (ស្រទាប់ខាងក្រៅបំផុតរបស់ភេរីខាប សម្បកស្តើង(ដូចស្បែក)នៅលើប្រភេទផ្លែសាច់ ដូចជាប្រភេទ Cornus, Malus និង Prunus។)

**exochorion** /ˌɛksəʊˈkɔːrɪən/ [n] ស្រទាប់ក្រៅកូរ៉ូង (ស្រទាប់ក្រៅកូរ៉ុងនៃស៊ុតសត្វល្អិត ដែលត្រូវបានបញ្ចេញដោយកោសិកាផូលីគុល ស្ថិតនៅក្នុងអូវ៉ុលរបស់សត្វល្អិត)

**exocytosis** /ˌɛksəʊsʌɪˈtəʊsɪs/ [n] អិចសូស៊ីតូស (ការដឹកនាំធាតុចេញពីកោសិកាតាមរយៈថង់)

**exogamy** /ɪkˈsɒɡəmi/ [n] ដំណើរលម្អងក្រៅ

**exogenic** /ˌɛksə(ʊ)ˈdʒɛnɪk/ [adj] សូមមើលពាក្យៈ allogenic

**exogenous** /ɪkˈsɒdʒɪnəs/ [adj] (សទិសន័យៈ external) ដែលមកពីក្រៅ, ដែលមានកំណើតពីក្រៅ

**exoskeleton** /ˈɛksəʊˌskɛlɪt(ə)n/ [n] គ្រោងឆ្អឹងខាងក្រៅ

**exostosis** /ˌɛksɒsˈtəʊsɪs/ [n] (ពហុវចនៈៈ exostoses) ជំងឺពកឆ្អឹង

**exothermic** /ˌɛksə(ʊ)ˈθəːmɪk/ [adj] ដែលបញ្ចេញថាមពល

**exotic** /ɪɡˈzɒtɪk/ [n] ប្រភេទពីប្រទេសក្រៅ, ពូជពីប្រទេសក្រៅ, ប្រភេទនាំចូលពីក្រៅ

**exotoxin** /ˈɛksə(ʊ) tɒksɪn/ [n] ជាតិពុលក្រៅ (សារធាតុពុលដែលផលិតដោយកោសិការស់ រួចបញ្ចេញទៅបរិស្ថាន)

**expand** /ɪkˈspand/ [v] ពង្រីក, វាតទី

**expansion** /ɪkˈspanʃ(ə)n/ [n] ការពង្រីក, ការវាតទី, វិបុលកម្ម

- thermal expansion /ˈθəːm(ə)l ɪkˈspanʃ(ə)n/ [n] ការរីកមាឌដោយសារកម្ដៅ
- course expectation /kɔːs ɛkspɛkˈteɪʃ(ə)n/ [n] ចំណង់បាននៃវគ្គសិក្សា (អ្វីដែលវគ្គចង់បានអំពីសិក្ខាកាមក្រោយពេលដែលគេបានបញ្ចប់ការសិក្សា និងត្រឡប់ទៅកន្លែងដើមវិញ)

**expectorant** /ɪkˈspɛkt(ə)r(ə)nt/ [n] ថ្នាំទម្លាក់កំហាក, ថ្នាំជួយបញ្ចេញស្លេស្ម(ពីសួតនិងបំពង់ខ្យល់)

**expenditure** /ɪkˈspɛndɪtʃə/ [n] ការចំណាយ

**experience** /ɪkˈspɪərɪəns/ [n] បទពិសោធ

**experience** /ɪkˈspɪərɪəns/ [v] ដកពិសោធ, មានបទពិសោធ

**experiment** /ɪkˈspɛrɪm(ə)nt/ [v] ការធ្វើពិសោធ

**experimental** /ɪkˌspɛrɪˈmɛnt(ə)l/ [adj] នៃពិសោធ

- experimental cytology /ɪkˌspɛrɪˈmɛnt(ə)l sʌɪˈtɒlədʒi/ [n] កោសិកាវិទ្យា (ការសិក្សាអំពីកោសិកាដោយការប្រើអតិសុខុមទស្សន៍ និងអតិសុខុមទស្សន៍អេឡិចត្រុង រួមនឹងបច្ចេកទេសគីមីជីវៈ និងរូបសាស្ត្រជីវៈ)
- experimental design /ɪkˌspɛrɪˈmɛnt(ə)l dɪˈzʌɪn/ [n] ការរៀបចម្ការពិសោធ, ប្លង់ពិសោធ (ក្បួនខ្នាតសម្រាប់រៀបចំបច្ច័យក្នុងកូនស្រែពិសោធ), គ្រោងការណ៍ដាំពិសោធ ឬសាកល្បង
- experimental station /ɪkˌspɛrɪˈmɛnt(ə)l ˈsteɪʃ(ə)n/ [n] ស្ថានីយពិសោធ
- experimental units /ɪkˌspɛrɪˈmɛnt(ə)l ˈjuːnɪts/ [n pl] ឯកតាពិសោធ, កូនស្រែពិសោធ (ទីកន្លែង ឬកូនស្រែដែលបច្ច័យផ្សេងៗនៃការពិសោធមួយបានដាក់ក្នុងនោះ)
- experimental variable /ɪkˌspɛrɪˈmɛnt(ə)l ˈvɛːrɪəb(ə)l/ [n] អថេរពិសោធ, វិបរិតរូបពិសោធ

**experiment** /ɪkˈspɛrɪm(ə)nt/ [n] ពិសោធ

**expert** /ˈɛkspəːt/ [n] អ្នកជំនាញការ

**expertness** /ˈɛkspəːtnəs/ [n] ភាពជំនាញ

**expiration** /ˌɛkspɪˈreɪʃ(ə)n/ [n] ដង្ហើមចេញ

**expire** /ɪkˈspʌɪə/ [v] ដកដង្ហើមចេញ, ផុតកំណត់

**explant** /ɪksˈplɑːnt/ [n] សំណាករុក្ខជាតិដើម (ជាកោសិកាដែលធ្វើចំណែកយ៉ាងសកម្មដោយបង្កើតបានកញ្ចុំកោសិកា នៅក្នុងជាលិការប្បកម្ម), សរីរាង្គណាមួយសម្រាប់បណ្ដុះកូនឈើ, សរីរាង្គណាមួយសម្រាប់ជាលិការប្បកម្ម

**exploit** /ɪkˈsplɔɪt/ [v] ធ្វើអាជីវកម្ម, ទាញយកកម្រៃលើ

**exploitaion of natural resource** /ɛksplɔɪˈteɪʃ(ə)n ɒv ˈnatʃ(ə)r(ə)l rɪˈsɔːs/ [n] ការធ្វើអាជីវកម្មធនធានធម្មជាតិ

**exploitation** /ɛksplɔɪˈteɪʃ(ə)n/ [n] អាជីវកម្ម, ការធ្វើអាជីវកម្ម

- forest exploitation /ˈfɒrɪst ɛksplɔɪˈteɪʃ(ə)n/ [n] អាជីវកម្មព្រៃឈើ
- harmonious exploitation /hɑːˈməʊnɪəs ɛksplɔɪˈteɪʃ(ə)n/ [n] ការប្រើប្រាស់ធនធានធម្មជាតិដោយសមហេតុសមផល

**exploration** /ɛkspləˈreɪʃ(ə)n/ [n] ការរុករក (ដំណើររុករក និងកត់ត្រានូវរាល់រុក្ខជាតិ ស្មៅ ផ្កា ដែលមាននៅក្នុងតំបន់កំណត់ណាមួយ)

- gas exploration /gas ɛkspləˈreɪʃ(ə)n/ [n] ការរុករកឧស្ម័ន
- mineral exploration /ˈmɪn(ə)r(ə)l ɛkspləˈreɪʃ(ə)n/ [n] ការរុករករ៉ែ

**explore** /ɪkˈsplɔː/ [v] រុករក, ស្រាវជ្រាវ

**export article** / ɪkˈspɔːt ˈɑːtɪk(ə)l/ [n] មុខទំនិញនាំចេញ

**export duty** /ɪkˈspɔːt ˈdjuːti/ [n] ពន្ធនាំចេញ

**export trade** /ɪkˈspɔːt treɪd/ [n] ពាណិជ្ជកម្មនាំចេញ

**exposure** /ɪkˈspəʊʒə/ [n] ការដាក់ឱ្យត្រូវ, ការសំដិល, ការតាំង

- acute exposure /əˈkjuːt ɪkˈspəʊʒə/ [n] ការដាក់ឱ្យត្រូវធ្ងន់ធ្ងរ

**expression** /ɪkˈsprɛʃ(ə)n/ [n] ការសម្តែងចេញ

**expulsive** /ɪkˈspʌlsɪv/ [adj] រុញបញ្ចេញ

**panicle exsertion** /ˈpanɪk(ə)l ɪgˈzɜːʃn/ [n] ដំណាកកួរ (លទ្ធផលរបស់កួរស្រូវដែលអាចលូតផុតពីស្លឹកទង់ជ័យ)

**ex situ** /ɛks ˈsɪtjuː/ [adj] ក្រៅតំបន់កំណើត

**ex situ conservation** /ɛks ˈsɪtjuː kɒnsəˈveɪʃ(ə)n/ [n] ការដាំអភិរក្សក្រៅតំបន់ធម្មជាតិ, ការដាំអភិរក្សក្រៅតំបន់កំណើត, អភិរក្សកម្មក្រៅតំបន់កំណើត (ការថែរក្សាប្រភពធនធានសេនេទិចជីវករ ក្នុងធនាគារសែន ឬបន្ទប់ត្រជាក់។ ការថែរក្សា អាចធ្វើទៅលើគ្រាប់ ផ្លែ ឬផ្នែកមួយនៃរុក្ខជាតិ។ ចំពោះស្រូវ គ្រាប់របស់វា ជាសម្ភារចម្បងសម្រាប់ការងារអភិរក្ស។)

**extended critical care unit** /ɪkˈstɛndɪd ˈkrɪtɪk(ə)l kɛː ˈjuːnɪt/ [n] ផ្នែកបន្តថែរក្សាអ្នកជំងឺដុនដាប

**extension worker** /ɪkˈstɛnʃ(ə)n ˈwəːkə/ [n] (សទិសន័យ៖ extensionist) អ្នកផ្សព្វផ្សាយ

**extension** /ɪkˈstɛnʃ(ə)n/ [n] ការផ្សព្វផ្សាយ

- agricultural extension /agrɪˈkʌltʃərəl ɪkˈstɛnʃ(ə)n/ [n] (សទិសន័យ៖ agricultural dissemination) ការផ្សព្វផ្សាយកសិកម្ម

**extensionist** /ɪkˈstɛnʃ(ə)nɪst/ [n] សូមមើលពាក្យ៖ extension worker

**extensive** /ɪkˈstɛnsɪv/ [adj] ដ៏ធំទូលាយ, នៃកសិកម្មយថាផល

- extensive agriculture /ɪkˈstɛnsɪv ˈagrɪkʌltʃə/ [n] (សទិសន័យ៖ extensive farming) វិបុលវប្បកម្ម, កសិកម្មយថាផល (ប្រភេទកសិកម្ម ឬការដាំដុះដែលមានលក្ខណៈសាមញ្ញ ឬតាមធម្មជាតិ)។ ផ្ទុយពី intensive agriculture។
- extensive farming /ɪkˈstɛnsɪv fɑːmɪŋ/ [n] សូមមើលពាក្យ៖ extensive agriculture

**extensor** /ɪkˈstɛnsə/ [n] ការពន្លា (សាច់ដុំ)

**extent** /ɪkˈstɛnt/ [n] វិសាលភាព, កម្រិត

**external** /ɪkˈstəːn(ə)l/ [adj] សូមមើលពាក្យ៖ exogenous

- external forcing /ɪkˈstəːn(ə)l fɔːsɪŋ/ [n] កម្លាំងខាងក្រៅ, កត្តាខាងក្រៅ

**exteroceptor** /ˈɛkstərə(ʊ)ˌsɛptə/ [n] ផ្ទួលខាងក្រៅ

**extinct** /ɪkˈstɪŋkt/ [adj] វិនាសផុតពូជ (ប្រភេទសត្វ និងរុក្ខជាតិ)

**extinction** /ɪkˈstɪŋ(k)ʃ(ə)n/ [n] វិនាសសាបសូន្យ, ការផុតពូជ, ការដាច់ពូជ

**extirpate** /ˈɛkstəːpeɪt/ [v] រំលើង, បកសម្បក, ចិតសម្បក, សកសម្បក

**extra** /ˈɛkstrə/ [adj] ខាងក្រៅ, ដែលបំពេញក្រៅពីធម្មតា, បន្ថែម

**extracellular** /ɛkstrəˈsɛljʊlə/ [adj] ក្រៅកោសិកា

**extract** /ɪkˈstrakt/ [v] សម្រង់, ស្រង់ចេញ, ដក, បោះ (ជាតិដែលចម្រាញ់ ឬគាបបញ្ចេញបានមក)

**extract** /ɪkˈstrakt/ [n] សារធាតុចម្រាញ់

- cell-free extract /sɛl friː ɪkˈstrakt/ [n] សម្រង់គ្មានកោសិកា

**extraction** /ɪkˈstrakʃ(ə)n/ [n] ការប្រលេះយកគ្រាប់ចេញពីផ្លែ, ការយកចេញ, ការដកធ្មេញ

- honey extractor /ˈhʌni ɪkˈstraktə/ [n] ប្រដាប់ច្របាច់យកទឹកឃ្មុំ
- vacuum extractor /ˈvakjuːm ɪkˈstraktə/ [n] ប្រដាប់បូមទាញក្បាលទារក

**extraordinary** /ɪkˈstrɔːd(ə)n(ə)ri/ [adj] វិសាមញ្ញ, មិនធម្មតា

**extremity** /ɪkˈstrɛmɪti/ [n] ចុង

**extrorse** /ɛksˈtrɔːs/ [n] បែរទៅក្រៅ (អំពីប្លោកលម្អង)

**exudate** /ˈɛgzjʊdeɪt/ [n] សារធាតុជ័រ, ការបញ្ចេញជាតិញើស

**eye** /ʌɪ/ [n] ភ្នែក

- compound eye /ˈkɒmpaʊnd ʌɪ/ [n] ភ្នែកសមាស
- pink eye /ˈpɪŋk ʌɪ/ [n] ជំងឺភ្នែកក្រហម
- white eye /wʌɪt ʌɪ/ [n] ភ្នែកស (ស្នាមនៃកំបោរដែលកកក្នុងដី)

**eyelid** /ˈʌɪlɪd/ [n] ត្របកភ្នែក

**eyesight** /ˈʌɪsʌɪt/ [n] (សទិសន័យ៖ vision) គំហើញ

**eyespot pufferfish** /ˈʌɪspɒt ˈpʌfəfɪʃ/ [n] ត្រីកំពត (ឈ្មោះវិទ្យាសាស្ត្រ *Chelonodon biocellatus*)

**F**

**F factor** /ɛf ˈfaktə/ [n] (សទិសន័យ៖ fertility factor) កត្តាបន្តពូជ, កត្តា F (អេពីសូននៃកោសិកាបាក់តេរីដែលធ្វើឱ្យកោសិកានោះមានលទ្ធភាពដើរតួជាអ្នកផ្តល់ឱ្យក្នុងពេលជំនាប់ប្តូរ ឬបន្តពូជ)

**F1** /ɛf wʌn/ [n] កូនជំនាន់១ (ចំពោះការបង្កាត់)

**F2** /ɛf tuː/ [n] កូនជំនាន់២ (ចំពោះការបង្កាត់)

**fabric** /ˈfabrɪk/ [n]

១. សូមមើលពាក្យ៖ microstructure

២. ការផ្តុំនៃវត្ថុធាតុ, ការប្រមូលនៃគ្រាប់ល្អិតៗ

- agglomeratic fabric /ˈfabrɪk/ [n] មីក្រូទម្រង់ដែលប្រមូលផ្តុំគ្នា
- banded fabric /bandɪd ˈfabrɪk/ [n] មីក្រូទម្រង់ដែលជាស្រទាប់ៗ
- channel fabric /ˈtʃan(ə)l ˈfabrɪk/ [n] មីក្រូទម្រង់ដែលកើតជារន្ធតូចៗ
- chlamidomorphic fabric /klamidəʊˈmɔːfɪk ˈfabrɪk/ [n] មីក្រូទម្រង់ដែលមានវត្ថុធាតុកូឡូអ៊ីតគ្របព័ទ្ធជុំវិញគ្រាប់នីមួយៗ
- columnar fabric /kəˈlʌmnə ˈfabrɪk/ [n] មីក្រូទម្រង់រាងជាសសរ
- fine coagulum fabric /fʌɪn kəʊˈagjʊləm ˈfabrɪk/ [n] មីក្រូទម្រង់ជាគ្រាប់កកតូចៗ
- intertextic fabric /ˌɪn tərˈtɛkstɪk ˈfabrɪk/ [n] មីក្រូទម្រង់ដែលស៊ីម៉ង់កូឡូអ៊ីតជាគ្រាប់ៗ
- mortar fabric /ˈmɔːtə ˈfabrɪk/ [n] មីក្រូទម្រង់ដែលរន្ធតូចៗញ៉ុកណែនដោយវត្ថុធាតុអ្វីមួយ
- polyhedrous fabric /ˈpɒliˈhɛdrəs ˈfabrɪk/ [n] មីក្រូទម្រង់ជាពហុកោន
- porphyropectic fabric /ˈprɒfirəʊˈpɛk tɪk ˈfabrɪk/ [n] មីក្រូទម្រង់ដែលគ្រាប់ក្រាមធំៗស្រោបទៅដោយសារធាតុខាប់ក្រាស់
- primitive primary fabric /ˈprɪmɪtɪvˈprʌɪm(ə)ri ˈfabrɪk/ [n] សូមមើលពាក្យ៖ elementary microstructure
- prismatic fabric /prɪzˈmatɪk ˈfabrɪk/ [n] សូមមើលពាក្យ៖ prism-like fabric
- prism-like fabric /ˈprɪz(ə)m lʌɪk ˈfabrɪk/ [n] (សទិសន័យ៖ prismatic fabric) មីក្រូទម្រង់ជា ព្រីស
- rendzina fabric /rɛn(d)ˈziːnə ˈfabrɪk/ [n] មីក្រូទម្រង់បែបប្រភេទដីរេនហ្ស៊ីន
- single grain fabric /ˈsɪŋg(ə)l greɪn ˈfabrɪk/ [n] មីក្រូទម្រង់ជាគ្រាប់រាយ
- spongy fabric /ˈspʌn(d)ʒi ˈfabrɪk/ [n] មីក្រូទម្រង់ប្រភេទប្រោងស្ពោត

**face** /feɪs/ [v] ឈមមុខ, ទប់ទល់វិញ

**face** /feɪs/ [n] មុខ, ផ្ទៃក

- scarpe face /skɑːpd feɪs/ [n] មុខ ឬឆ្នេរសមុទ្រចោត

**facet** /ˈfasɛt/ [n] មុខរាបតូច (ផ្ទៃរាបនៅត្រង់សន្លាក់ឆ្អឹង)

**facilitator** /fəˈsɪlɪteɪtə/ [n] បង្ខឹកការី (អ្នកជួយបង្ហាត់បង្ហាញមុខវិជ្ជាមួយ ឬច្រើនក្នុងវគ្គបណ្តុះបណ្តាលណាមួយ)

**facility** /fəˈsɪlɪti/ [n] ភាពងាយស្រួល

- health facility /hɛlθ fəˈsɪlɪti/ [n] កន្លែងផ្តល់សេវាសុខភាព
- skilled nursing facility /skɪld ˈnəːsɪŋ fəˈsɪlɪti/ [n] មន្ទីរជំនាញគិលានុបដ្ឋាកម្ម (ទីសាងសង់ ឬស្ថាប័ន ដើម្បីបំពី ឬថែទាំ អ្នកជំងឺ ដោយមានភាពចេះស្ទាត់ប្រាកដ)
- training facilities /ˈtreɪnɪŋ fəˈsɪlɪtis/ [n pl] សម្ភារជំនួយសម្រាប់វគ្គបណ្តុះបណ្តាល

**facinorous** /fəˈsɪn(ə)rəs/ [adj] កាចពេក, ឆ្នាសហួសហេតុ

**facsimile** /fakˈsɪmɪli/ [n] វត្ថុចម្លងតាម

**factor** /ˈfaktə/ [n] កត្តា

- abiotic factor /ˌeɪbʌɪˈɒtɪk ˈfaktə/ [n] កត្តាគ្មានជីវិត
- anthropogenic factor /ˌanθrəpəˈdʒɛnɪk ˈfaktə/ [n] សូមមើលពាក្យ៖ human factor
- biotic factor /bʌɪˈɒtɪk ˈfaktə/ [n] កត្តាមានជីវិត
- climatic factor /klʌɪˈmatɪk ˈfaktə/ [n] កត្តាអាកាសធាតុ
- density dependent factors /density dɪˈpɛnd(ə)nt ˈfaktəs/ [n pl]កត្តាដង់ស៊ីតេមិនឯករាជ្យ (កត្តាត្រួតពិនិត្យប្រជាករដែលទាក់ទងនឹងបរិមាណរបស់ប្រជាករនោះ ឧ. នៅពេលដែលចំនួនសត្វកាន់តែច្រើន នោះសត្វស៊ីសាច់ជាអាហារក៏មានលក្ខណៈងាយស្រួលក្នុងការចាប់ដែរ)
- density independent factor /ˈdɛnsɪti ɪndɪˈpɛnd(ə)nt ˈfaktə/ [n] កត្តាដង់ស៊ីតេឯករាជ្យ (លក្ខខណ្ឌបរិស្ថានដែលជះឥទ្ធិពលទៅលើចំនួនប្រជាជនដែលមិនទាក់ទងទៅនឹងដង់ស៊ីតេរបស់វា)
- ecological factor /iːkəˈlɒdʒɪk(ə)l ˈfaktə/ [n] កត្តាអេកូឡូស៊ី

- edaphic factor /ɪˈdafɪk ˈfaktə/ [n] កត្តាដី
- environmental factor /ɪnvʌɪrənˈmɛnt(ə)l ˈfaktə/ [n] កត្តាបរិស្ថាន
- fertility factor /fəˈtɪlɪti ɛf ˈfaktə/ [n] សូមមើលពាក្យ ៖ F factor
- geological factor /dʒiːəˈlɒdʒɪk(ə)l ˈfaktə/ [n] កត្តាភូគព្ភសាស្ត្រ
- human factor /ˈhjuːmən ˈfaktə/ [n] (សទិសន័យ៖ anthropogenic factor) កត្តាមនុស្ស (អ្វីៗដែលទាក់ទងនឹងមនុស្ស)
- inhibiting factor /ɪnˈhɪbɪt ˈfaktə/ [n] កត្តាបង្អាក់
- limiting factor /ˈlɪmɪtɪŋ ˈfaktə/ [n] កត្តាកម្រិត (ឥទ្ធិពលបរិស្ថានដែលកម្រិតការលូតលាស់របស់ប្រជាករ)
- mechanical factor /mɪˈkanɪk(ə)l ˈfaktə/ [n] កត្តាមេកានិច (អ្វីៗដែលមានទំនាក់ទំនងនឹងមេកានិច)
- mutagenic factor /mjuːtəˈdʒɛnɪk ˈfaktə/ [n] បរិវីករ (កត្តាដែលបណ្តាលឱ្យមានបរិវត្តន៍ ដែលអាចជារូបធាតុកាំរស្មី ឬគីមីធាតុជាដើម)
- natural factor /ˈnatʃ(ə)r(ə)l ˈfaktə/ [n] កត្តាធម្មជាតិ
- negative factor /ˈnɛɡətɪv ˈfaktə/ [n] កត្តាអវិជ្ជមាន
- noise factor /nɔɪz ˈfaktə/ [n] កត្តាសូរ, កត្តាសំឡេង
- social factor /ˈsəʊʃ(ə)l ˈfaktə/ [n] កត្តាសង្គម
- socioeconomic factor /ˌsəʊʃɪəʊiːkəˈnɒmɪk ˈfaktə/ [n] កត្តាសេដ្ឋកិច្ចសង្គម
- test factor /tɛst ˈfaktə/ [n] កត្តាសាកល្បង (ការអនុវត្តន៍គ្រប់គ្រងដែលលក្ខណៈប្រែប្រួលត្រូវបានប្រើប្រាស់ក្នុងការកំណត់លទ្ធភាព ឬការសម្រេចបាននៃប្រព័ន្ធថ្មីមួយដែលបានសិក្សារួច)
- topographic factor /ˌtɒpəˈɡrafɪk ˈfaktə/ [n] កត្តាសណ្ឋានដី

**factory** /ˈfakt(ə)ri/ [n] រោងចក្រ

**facultative** /ˈfak(ə)lˌtətɪv/ [adj] ដែលអាចរស់នៅក្នុងលក្ខខណ្ឌមិនធម្មតាបាន

**facultative anaerobe** /ˈfak(ə)lˌtətɪv ˈanərəʊb/ [n] គ្មានខ្យល់ពុំចាំបាច់ (បាក់តេរីមិនត្រូវការខ្យល់ ដែលជាទូទៅលូតលាស់ដោយត្រូវការខ្យល់ ប៉ុន្តែវាសម្របទៅនឹងជីវិតគ្មានអុកស៊ីសែនក្នុងលក្ខខណ្ឌមានខ្យល់ និងគ្មានខ្យល់)

**faculty** /ˈfak(ə)lti/ [n] មហាវិទ្យាល័យ, អ្នកបង្ហាត់បង្រៀនទាំងអស់

**fade** /feɪd/ [v] ស្រពោន, ថយកម្លាំង

**faecal pellet** /ˈfiːk(ə)l ˈpɛlɪt/ [n] អាចម៍សត្វ, ហ្វូស៊ីល

**faeces** /ˈfiːsiːz/ [n] លាមក, អាចម៍

**Fahrenheit** /ˈfar(ə)nhʌɪt/ [n] រង្វាស់ស្ទង់សីតុណ្ហភាព (ហ្វារិនហៃ)

**faint** /feɪnt/ [n] ការសន្លប់ដោយខ្វះឈាមក្នុងខួរក្បាល, ខ្សោយកំឡាំងល្ហិតល្ហៃ

**fair** /fɛː/ [adj] មធ្យម (ពិន្ទុ), ត្រឹមត្រូវ

**fair** /fɛː/ [n] ពិពណ៌ពាណិជ្ជកម្ម

**fairly** /ˈfɛːli/ [adv] ដោយយុត្តិធម៌, ដោយស្មោះត្រង់

**faith** /feɪθ/ [n] ជំនឿ

**falcate** /ˈfalkeɪt/ [adj] រាងកណ្តៀវ, ទម្រង់បន្ទះស្លឹករាងដងធ្នូ

**rock fall** /rɒk/ [n] ការធ្លាក់នៃថ្ម

**debris fall** /ˈdɛbriː fɔːl/ [n] ថ្ម ឬកម្ទេចថ្មដែលធ្លាក់ចុះក្រោម, ការប្រមូលផ្តុំក្រួសដែលធ្លាក់ពីលើច្រាំង

**fallopian tubes** /fəˌləʊpɪən ˈtjuːbs/ [n pl] ប្រមោយផាឡុប (បំពង់ដែលនាំពងចេញពីដៃស្បូន)

**fallow** /ˈfaləʊ/ [adj] ដីសម្រាក, ដីដែលបោះបង់ចោល (លែងដាំដុះ), ដីទុកទំនេរ (ដីដាំដំណាំ ប៉ុន្តែវាត្រូវទុកចោលទំនេរមិនបានដាំអ្វីមួយរយៈ)

**false daisy** /fɔːls ˈdeɪzi/ [n] មុខឈ្នាង (ឈ្មោះវិទ្យាសាស្ត្រ *Eclipta prostrata*)

**false killer whale** /fɔːls ˈkɪlə weɪl/ [n] បាឡែនក្របី (ឈ្មោះវិទ្យាសាស្ត្រ *Pseudorca crassidens*)

**false smut** /fɔːls smʌt/ [n] ជំងឺធ្យូងបៃតង (ជំងឺមួយដែលបង្កដោយផ្សិត *Ustilaginoides virens*)

**family** /ˈfamɪli/ [n] គ្រួសារ (ចំណាត់ថ្នាក់មួយនៃជីវករតាមវគ្គីករណ៍វិទ្យាដែលទាបជាងក្រុមតែខ្ពស់ជាងសណ្តាន)

- soil family /sɔɪl ˈfamɪli/ [n] គ្រួសារដី ចំណាត់ថ្នាក់ដី
- spurge family /spəːdʒ ˈfamɪli/ [n] គ្រួសាររុក្ខជាតិមានជ័រល្វីង
- subfamily /ˈsʌbfam(ə)li/ [n] អនុគ្រួសារ

**famine** /ˈfamɪn/ [n] ការស្រេកឃ្លាន, ការអត់អាហារ, គ្រោះទុរភិក្ស

**fang** /faŋ/ [n] ចង្កូម

**fan-talus** /fan ˈteɪləs/ [n] គំនរថ្មបាក់បែកធ្លាក់ចុះពីលើ

**farcy** /ˈfɑːsi/ [n] ជំងឺម៉រ (ជំងឺឆ្លងនៃសត្វសេះដែលអាចចម្លងមកមនុស្សបាន)

**farm house** /fɑːm haʊs/ [n] ផ្ទះកសិដ្ឋាន

**farm** /fɑːm/ [n] កសិដ្ឋាន, កន្លែងធ្វើកសិកម្ម

- whole farm /həʊl ɑːm/ [n] កសិដ្ឋានទាំងមូល

**farmer** /ˈfɑːmə/ [n] កសិករ, ម្ចាស់កសិដ្ឋាន

- farmers' group /ˈfɑːməs gruːp/ [n] ក្រុមកសិករ
- filed crop farmer /fiːld krɒp ˈfɑːmə/ [n] កសិករដាំដំណាំចម្ការ
- fruit farmer /fruːt ˈfɑːməz/ [n] កសិករដាំឈើហូបផ្លែ
- lowland rice farmer /ˈləʊlənd rʌɪs ˈfɑːmə/ [n] កសិករតំបន់ទំនាប
- orchard farmer /ˈɔːtʃəd ˈfɑːmə/ [n] កសិករធ្វើចម្ការ, អ្នកចម្ការ
- pilot farmer /ˈpʌɪlət ˈfɑːmə/ [n] កសិករសាកល្បង
- resource-poor farmer /rɪˈsɔːs pɔː ˈfɑːmə/ [n] កសិករដែលមានដើមទុនតិច, កសិករមានធនធានតិច
- rice farmer /rʌɪs ˈfɑːmə/ [n] កសិករដាំស្រូវ
- settled farmer /ˈsɛt(ə)ld ˈfɑːmə/ [n] កសិករតាំងលំនៅអចិន្ត្រៃយ៍
- upland crop farmer /ˈʌplənd krɒp ˈfɑːmə/ [n] កសិករដាំដំណាំតំបន់ខ្ពង់រាប

**farming** /ˈfɑːmɪŋ/ [n] ដំណាំ, កសិកម្ម, របរកសិកម្ម

- alley farming /ˈali ˈfɑːmɪŋ/ [n] សូមមើលពាក្យ៖ alley cropping
- arable farming /ˈarəb(ə)l ˈfɑːmɪŋ/ [n] កសិកម្មដែលអាចដាំដំណាំបាន (ការធ្វើកសិកម្មដែលអាចផលិតដំណាំបាន)
- contour farming /ˈkɒntʊə ˈfɑːmɪŋ/ [n] ដំណាំតាមខ្សែរយៈកម្ពស់
- dry farming /drʌɪ ˈfɑːmɪŋ/ [n] (សទិសន័យ៖ dryland farming) ដំណាំស្ងួត (គ្មានស្រោចទឹក)
- dryland farming /drʌɪland ˈfɑːmɪŋ/ [n] សូមមើលពាក្យ៖ dry farming
- energy farming /ˈɛnədʒi ˈfɑːmɪŋ/ [n] ដំណាំថាមពល, ដំណាំឥន្ធនៈ
- ley farming /leɪ ˈfɑːmɪŋ/ [n] ដំណាំជួយកែគុណភាពដី (ដោយដាំដំណាំចំណីសត្វ)
- organic farming /ɔːˈganɪk ˈfɑːmɪŋ/ [n] កសិកម្មសរីរាង្គ (មិនប្រើជីគីមី)
- sedentary farming /ˈsɛk(ə)nd(ə)ri ˈfɑːmɪŋ/ [n] សូមមើលពាក្យ៖ sedentary agriculture
- subsistence farming /səbˈsɪst(ə)ns ˈfɑːmɪŋ/ [n] ការដាំដុះសម្រាប់មួយរស់, កសិកម្មចិញ្ចឹមពោះ
- truck farming /trʌk ˈfɑːmɪŋ/ [n] ចម្ការបន្លែ (ដាំសម្រាប់លក់), ការដាំបន្លែលក់
- upland farming /ˈʌplənd ˈfɑːmɪŋ/ [n] ការធ្វើកសិកម្មតំបន់ខ្ពង់រាប

**farrow** /ˈfarəʊ/ [n] ចំនួនកូនជ្រូកក្នុងមួយសម្បុក

**fascia** /ˈfeɪʃə/ [n] ស្រទាប់, បន្ទះ (បន្ទះជាលិកាមានភាពជាសរសៃដែលគ្រងទ្រ និងចងសរីរាង្គខាងក្នុង)

**fascicle** /ˈfasɪk(ə)l/ [n] កញ្ចុំស្លឹក

**fasciculate** /faˈsɪkjʊlət/ [adj] របៀបតម្រៀបស្លឹកលើមែកជាបាច់

**fascine work** /faˈsiːn wəːk/ [n] ការដាក់បាច់ឈើដើម្បីច្រុះដី

**fasciola** /ˈfeɪʃɪəʊlə/ [n] (សទិសន័យ៖ liver fluke) ដង្កូវសំប៉ែតនៅក្នុងថ្លើម, តេនញ៉ា

**fasciolosis** /ˈfeɪʃɪəʊləʊsɪs/ [n] ជំងឺដង្កូវថ្លើម

**fasting** /fɑːstin/ [n] ការតមអាហារ (នៅក្នុងសាសនាអ៊ីស្លាម)

**fat** /fat/ [n] លីពីត, ខ្លាញ់

- brown fat /braʊn fat/ [n] ខ្លាញ់ពណ៌ត្នោត សម្រាប់ខ្លាញ់ស្ថិតនៅរវាងកនិងស្មារបស់ថនិកសត្វខ្លះដូចជាប្រចៀវ និងកំប្រុក។ ខ្លាញ់នេះមានមុខងារជម្រុញឱ្យមានការផលិតកម្តៅច្រើន ជាពិសេសរយៈពេលសំងំនៅរដូវរងារ។ ខ្លាញ់នេះសម្បូរទៅដោយសរសៃឈាម និងមានមីតូ-កុងទ្រីជាច្រើន។ ពណ៌ត្នោតរបស់ខ្លាញ់គឺបានមកពីវត្តមានរបស់អង់ស៊ីមស៊ីមក្រូមអុកស៊ីដាសរបស់មីតូកុងទ្រី។ កម្តៅត្រូវបញ្ចេញយ៉ាងលឿន (គឺលឿនជាងមេតាបូលីសខ្លាញ់ធម្មតា) និងត្រូវបានដឹកនាំចេញយ៉ាងរហ័សតាមរយៈប្រព័ន្ធសរសៃឈាមធំ។

**fatal** /ˈfeɪt(ə)l/ [adj] ដែលស្លាប់បាត់បង់ជីវិត

**fatigue** /fəˈtiːg/ [n] ការហត់, ការអស់កម្លាំង

**fatigue** /fəˈtiːg/ [v] ធ្វើឱ្យអស់កម្លាំង ឬនឿយហត់

**fatty acid** /ˈfati ˈasɪd/ [n] អាស៊ីតខ្លាញ់

- essential fatty acid /ɪˈsɛnʃ(ə)l ˈfati ˈasɪd/ [n] អាស៊ីតខ្លាញ់សំខាន់
- saturated fatty acid /ˈsatʃəreɪtɪd ˈfati ˈasɪd/ [n] អាស៊ីតខ្លាញ់ឆ្អែត
- unsaturated fatty acid /ʌnˈsatʃʊreɪtɪd ˈfati ˈasɪd/ [n] អាស៊ីតខ្លាញ់មិនឆ្អែត

**fault** /fɔːlt/ [n] បំណាក់ស្រុត

**fauna** /ˈfɔːnə/ [n] ពពួកសត្វ (សំដៅលើក្រុមសត្វដែលកំពុងរស់នៅតំបន់ណាមួយ)

- aquatic fauna /əˈkwatɪk ˈfɔːnə/ [n] ពពួកសត្វទឹក
- benthic fauna /ˈbɛnθɪk ˈfɔːnə/ [n] ពពួកសត្វស្រទាប់បាត (សមុទ្រ ឬបាតបឹង ជាដើម)
- mesofauna /ˈmɛsə(ʊ)fɔːnə/ [n] សត្វទំហំមធ្យម
- sea fauna /siː ˈfɔːnə/ [n] ពពួកសត្វសមុទ្រ
- soil fauna /sɔɪl ˈfɔːnə/ [n] ពពួកសត្វនៅក្នុងដី
- terrestrial fauna /təˈrɛstrɪəl ˈfɔːnə/ [n] ពពួកសត្វលើគោក

**feather** /ˈfɛðə/ [n] ស្លាប

- down feathers /daʊn ˈfɛðəz/ [n pl] រោមសម្លី

**featherback** /ˈfɛðəbak/ [n] ពពួកត្រីក្រាយ ដែលស្ថិតនៅក្នុងក្រួសារ Notopteridae

- bronze featherback /brɒnz ˈfɛðəbak/ [n] ត្រីស្លាត (ឈ្មោះវិទ្យាសាស្ត្រ Notopterus notopterus)
- giant featherback /ˈdʒʌɪənt ˈfɛðəbak/ [n] ត្រីក្រាយ (ឈ្មោះវិទ្យាសាស្ត្រ *Chitala lopis*)
- royal featherback /ˈrɔɪəl ˈfɛðəbak/ [n] ត្រីក្រាយ (ឈ្មោះវិទ្យាសាស្ត្រ *Chitala blanci*)

**feature** /ˈfiːtʃə/ [n] លក្ខណៈពិសេស

**febrile** /ˈfiːbrʌɪl/ [adj] គ្រុន (ដែលទាក់ទងនឹងជំងឺគ្រុន)

**feces** /ˈfiːsiːz/ [n pl] (សទិសន័យ៖ excrement, stool) លាមក, អាចម៍

**fecund** /ˈfiːk(ə)nd/ [adj] មានកូន, មានផល (ឱ្យផល)

**feeble** /ˈfiːb(ə)l/ [v] ខ្សោយ, ថយកំឡាំង

**feed** /fiːd/ [v] ផ្តល់ចំណី (សត្វ)

**feeder** /ˈfiːdə/ [n] អ្នកស៊ី, ការផ្គង់អាហារ, ការទទួលចំណីអាហារពិសេស (សត្វ, មនុស្ស)

- carrion feeder /ˈkarɪən ˈfiːdə/ [n] (សទិសន័យ៖ necrophagous feeder) សត្វស៊ីសាកសព
- filter feeder /ˈfɪltə ˈfiːdəz/ [n pl] សត្វស៊ីអាហារដោយច្រោះ (សត្វដែលប្រើរោមញ័រ ឬខ្នែងផ្សេងៗទៀតដើម្បីបង្កើតចរន្តទឹក និងច្រោះយកអាហារទឹកនោះ)
- liquid feeder /ˈlɪkwɪd ˈfiːdə/ [n] សត្វស៊ីវត្ថុរាវ
- necrophagous feeder /ˈnɛkrəʊfəgəs ˈfiːdə/ [n] សូមមើលពាក្យ៖ carrion feeder
- suspension feeder /səˈspɛnʃ(ə)n ˈfiːdə/ [n] សត្វស៊ីកម្ទេចកំទី

**feed** /fiːd/ [n] ចំណីសត្វ

- livestock feed /ˈlʌɪvstɒk fiːd/ [n] ចំណីសត្វ(ពាហនៈ)
- mixed feed /mɪkst fiːd/ [n] ចំណីផ្សំ
- pelleted feed /ˈpɛlɪtɪd fiːd/ [n] ចំណីសត្វគ្រាប់
- supplementary feed /ˌsʌplɪˈmɛnt(ə)ri fiːd/ [n] ចំណីបន្ថែម

**feedback** /ˈfiːdbak/ [n] ផលឆ្លើយតប, ចម្លើយតប (ការបញ្ជូនត្រឡប់នូវព័ត៌មាន ឬលទ្ធផលអ្វីមួយទៅឱ្យអ្នកដើមវិញ (ឧ. កំណើនទិន្នផលនៃផលិតកម្មស្រូវ វាជាចម្លើយតបអំពីប្រសិទ្ធភាពការងារនៃកម្មវិធីបសិដ្ឋកម្មពូជស្រូវ))

**feeding** /fiːdɪŋ/ [n] ការផ្តល់ចំណី

- deposit feeding /dɪˈpɒzɪt fiːdɪŋ/ [n] ការស៊ីដីល្បាប់
- foliar feeding /ˈfəʊlɪə fiːdɪŋ/ [n] បំប៉នរុក្ខជាតិ (ការបាញ់សារធាតុចិញ្ចឹមទៅលើស្លឹក)
- therapeutic feeding /ˌθɛrəˈpjuːtɪk fiːdɪŋ/ [n] ការផ្តល់អាហារព្យាបាល (កម្មវិធីពិសេសផ្តល់អាហារព្យាបាលក្នុងស្ថានភាពសង្គ្រោះបន្ទាន់ ដែលត្រូវបានរចនាឡើង ដើម្បីដោះស្រាយបញ្ហាកង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ។ ដោយត្រូវបានអនុវត្ត ចំពោះកុមារអាយុក្រោម៥ឆ្នាំ ដែលកុមារទាំងអស់នោះ បញ្ហា កង្វះអាហារូបត្ថម្ភរបស់ ពួកគេបានប្រែក្លាយទៅជាស្ថានភាពដែលត្រូវជួយព្យាបាលសង្គ្រោះបន្ទាន់ ដែលឆ្លុះបញ្ចាំងអំពីការស្លាប់ដ៏ច្រើនហួសហេតុ និងបង្កើនអត្រាអាំងស៊ីដង់ជំងឺដែលរួមផ្សំជាមួយនឹងបញ្ហាកង្វះអាហារូបត្ថម្ភ (ក្វាស្សក៏រ, ហើម)។)

**feel** /fiːl/ [v] ដឹង (ដោយវិញ្ញាណ)

**felling** /fɛlɪŋ/ [n] ការកាប់រលំដើមឈើ

**female** /ˈfiːmeɪl/ [adj] ស្រី, ញី

**female** /ˈfiːmeɪl/ [n] មនុស្សស្រី, សត្វញី

**feminine** /ˈfɛmɪnɪn/ [adj] ដែលមានលក្ខណៈដូចស្រី

**femur** /ˈfiːmə/ [n] ឆ្អឹងភ្លៅ

**fen** /fɛn/ [n]

១. (ចំពោះរុក្ខជាតិ) រុក្ខជាតិដីភក់

២. (ចំពោះដី) កន្លែងធ្យូងតូបបាស, ដីដែលជាភក់ល្បាប់, កន្លែងដែលដក់ទឹក

- fragmite fen /ˈfradʒmʌɪt fɛn/ [n] (សទិសន័យ៖ reed peat moor) ដីទំនាបដែលមោកម៉ររកើតពីដើមត្រែង
- valley fen /ˈvali fɛn/ [n] កន្លែងកើតពើកក្នុងជ្រលង
- wood fen /wʊd fɛn/ [n] (សទិសន័យ៖ alder swamp) ដីវាលភក់ដែលមានព្រៃដុះ, ព្រៃដុះលើវាលភក់

**fence** /fɛns/ [v] ធ្វើរបង

**fence** /fɛns/ [n] របង (១. ជញ្ជាំងឬស្សី ឈើ ឬដែកដែលដាក់ជុំវិញសួនច្បារ វាលស្រែ ចម្ការ ឬអាគារ ដើម្បីកុំឱ្យមនុស្ស ឬសត្វចូល ឬចេញ ២. នៅលើម៉ាស៊ីនកែច្នៃឈើដែលកំណត់នូវទទឹង ឬកម្រាស់របស់វត្ថុ ឬឈើដែលត្រូវកែច្នៃ)

- live fence /lɪv fɛns/ [n] សូមមើលពាក្យ៖ living fence
- living fence /ˈlɪvɪŋ fɛns/ [n] (សទិសន័យ៖ live fence) របងរស់ (ដើមឈើដែលត្រូវបានដាំជារបង)

**fenceline (of upland field)** /ˈfɛnslʌɪn/ [n] របង (ចម្ការ)

**fenestrate** /ˈfɛnəstrət/ [v] ទម្លុះ, ចោះ

**feral** /ˈfɛr(ə)l/ [adj] នៃព្រៃ (អំពីសត្វ និងរុក្ខជាតិ)

**ferment** /fəˈmɛnt/ [v] ឡើង ឬកាច់មេ (ស្រា)

**fermentation** /fəːmɛnˈteɪʃ(ə)n/ [n] ការឡើងមេ, ការកាច់មេ, ការឡើងតំបែ, បំបែកកម្ម ការបំបែកសារធាតុសរីរាង្គនៅក្នុងទីគ្មានអកស៊ីដែន។ សមីការគីមីសម្រាប់ការឡើងមេអាល់កូហល(អាល់ កុល)ធម្មតាគឺៈ $C_6H_{12}O_6 = C_2H_5OH + CO_2$ ការឡើងមេ ប្រហែលបណ្ដាលមកពីអំពើរបស់កាតាលីករ នៃមេ(ស្រា)ដែលអាចជារុក្ខជាតិឯករាជ្យមួយ ដូចជាផ្សិតដំបែ ឬបាក់ធីរៀល ឬជាអង់ស៊ីមមួយ។ ការឡើងមេនេះ វាអាចផលិតចេញនូវកម្តៅ និងសារធាតុពុលដូច្នេះការឡើងមេរបស់ផ្លែ ឈើសាច់ អាចមានផលប៉ះពាល់មិនល្អដល់គ្រាប់។)

**Fermium** /ˈfəːmɪəm/ [n] ហ្វែម្យ៉ូម (និមិត្តសញ្ញាគីមី Fm)

**fern** /fəːn/ [n] បណ្ណកជាតិ (រុក្ខជាតិដែលគ្មានផ្កា គ្មានគ្រាប់ មានឫសបន្តពូជតាមស្ប៉ូ ឧ. ចក)

- seed ferns /siːd fəːnz/ [n pl] បណ្ណង្គជាតិមានគ្រាប់

**ferocious** /fəˈrəʊʃəs/ [adj] សាហាវ, កាច (ចំពោះសត្វ)

***Feronia elephantum*** [sci.n] សូមមើលពាក្យ៖ wood apple

***Feroniella lucida*** [sci.n] ក្រសាំង

**ferrolysis** /fəːˈrəʊlɪsɪs/ [n] បាតុភូតរេដុកម្ម (អុកស៊ីតកម្មដែកក្នុងស្រទាប់ដី)

**ferruginisation** /fɛˈruːdʒɪnizaʃ(ə)n/ [n] ការលេចចេញនៃសារធាតុដែកពីវត្ថុអ្វីមួយ

**fertile** /ˈfəːtʌɪl/ [adj] ដែលអាចបន្តពូជបាន, ដែលបង្កកំណើតបាន, ដែលមានជីជាតិ

**fertilise** /ˈfəːtɪlʌɪz/ [v] ដាក់ជី, ធ្វើឱ្យមានជីជាតិ, បង្ករកំណើត

**fertility** /fəˈtɪlɪti/ [n] ពហុពល

១. (ចំពោះដី) ភាពដែលមានជីជាតិ,ភាពមានជីជាតិ, ជីជាតិ, រង្វាស់ពីភាពមានជីជាតិរបស់ដី

២. (ចំពោះរុក្ខជាតិ) លទ្ធភាពបន្តពូជ ឬបង្ករកំណើត

- soil fertility /sɔɪl fəˈtɪlɪti/ [n] ភាពមានជីជាតិរបស់ដី, ជីជាតិនៃដី (លទ្ធភាពដីដើម្បីផ្តល់ធាតុចិញ្ចឹមជាបរិមាណបែបទម្រង់ និងសមាមាត្រភាពសម្រាប់រុក្ខជាតិលូតលាស់ជាអតិបរមា), ឧទរភាព ឬភាពអាចមានផ្ទៃពោះ (ចំពោះមនុស្ស)

**fertilization** /ˌfəːtɪlʌɪˈzeɪʃ(ə)n/ [n]

១. (ចំពោះសត្វ) ការបង្កកំណើត

២. (ចំពោះរុក្ខជាតិ) ពហុពលកម្ម (១. ការធ្វើឱ្យដីមានជីវិតដោយការដាក់ជីគីមី ឬធម្មជាតិ ២. ដំណើរការបន្សាំ (ភពប្រសព្វ) រវាងលម្អងនៃកេសរឈ្មោល និងបុប្ផាករនៃកេសរញី។ ដំណើរការនេះ ចាប់ផ្តើមនៅពេលដែលបំពង់លម្អងចាក់ចូលទៅក្នុងថង់លម្អងហើយផ្សំជាមួយកោសិកាស៊ុតនៃកេសរញី ហើយចាក់ចុះទៅតាមកេសររហូតដល់បុប្ផាណ្ឌករ។)

- cross-fertilization /ˌkrɒsˌfəːtɪlʌɪˈzeɪʃ(ə)n/ [n] សូមមើលពាក្យ៖ allogamy
- double fertilization /ˈdʌb(ə)l ˌfəːtɪlʌɪˈzeɪʃ(ə)n/ [n] ការបង្កកំណើតទ្វេ (ចំពោះអង់ស្យូស្ពែម ដំណើរការដែលស្ពែម៉ាតូសូអ៊ីតមួយបង្កកំណើតជាមួយកាម៉េតញី (អូវុល) ហើយស្ពែម៉ាតូសូអ៊ីតមួយទៀត បង្កកំណើតជាមួយណ្វៃយ៉ូប៉ូល ដើម្បីបង្កើតណ្វៃយ៉ូអង់ដូស្ពែមទីមួយ)
- internal fertilization /ɪnˈtəːn(ə)l ˌfəːtɪlʌɪˈzeɪʃ(ə)n/ [n] ការបង្កកំណើតក្នុង
- self-fertilization /sɛlffəːtɪlʌɪˈzeɪʃ(ə)n/ [n] សូមមើលពាក្យ៖ autogamy

**fertilize** /ˈfəːtɪlʌɪz/ [v] ដាក់ជី, បង្កកំណើត

**fertilizer** /ˈfəːtɪlʌɪzə/ [n] ជី (សារធាតុទាំងឡាយដែលគេបន្ថែមហើយមានតួនាទីជាសារធាតុចិញ្ចឹមសម្រាប់រុក្ខជាតិស្រូបយកដើម្បីចិញ្ចឹមជីវិត)

- ammonia fertilizer /əˈməʊnɪə ˈfəːtɪlʌɪzə/ [n] ជីអាម៉ូញាក់
- balanced fertilizer /ˈbalənst ˈfəːtɪlʌɪzə/ [n] តុល្យភាពជី (ជីដែលដាក់ឱ្យសារធាតុចិញ្ចឹមក្នុងដីមានតុល្យភាព)
- basal fertilizer /ˈbeɪs(ə)l ˈfəːtɪlʌɪzə/ [n] ជីទ្រាប់បាត (ជីទ្រាប់បាត ឬដាក់ក្នុងស្រែ មុនដាំ ឬមុនស្ទូង)
- chemical fertilizer /ˈkɛmɪk(ə)l ˈfəːtɪlʌɪzə/ [n] ជីគីមី (ប្រភេទជីដែលបង្កើតឡើងតាមសិប្បនិម្មិតកម្មគីមី)
- complete fertilizer /kəmˈpliːt ˈfəːtɪlʌɪzə/ [n] ជីគ្រប់ , ជីសមាស (ប្រភេទជីគីមី ដែលមានគ្រប់សមាសធាតុនៃធាតុចិញ្ចឹមចម្បងៗដូចជា អាសូត ផូស្វ័រ និងប៉ូតាសនៅក្នុងនោះ)
- compost fertilizer /ˈkɒmpɒst ˈfəːtɪlʌɪzə/ [n] សូមមើលពាក្យ៖ compost
- compound fertilizer /ˈkɒmpaʊnd ˈfəːtɪlʌɪzə/ [n] ជីលាយ
- fertilizer grade /ˈfəːtɪlʌɪzə greɪd/ [n] កម្រិតជី (បរិមាណ ឬកម្រិតអប្បបរមានៃសារធាតុចិញ្ចឹមចម្បងៗរបស់រុក្ខជាតិនៅក្នុងជីដែលត្រូវបានវិភាគ និងធានាអះអាង)
- granulated fertilizer /ˈgranjʊleɪtid ˈfəːtɪlʌɪzə/ [n] ជីគ្រាប់
- incomplete fertilizer /ɪnkəmˈpliːt ˈfəːtɪlʌɪzə/ [n] ជីមិនគ្រប់មុខ
- inorganic fertilizer /ɪnɔːˈganɪk ˈfəːtɪlʌɪzə/ [n] ជីអសរីរាង្គ, ជីគីមី (សារធាតុជីដែលទាញយកពីសារធាតុខនិជ ឧស្ម័នក្នុងបរិកាស ទឹកជីធាតុនិចល)
- liquid fertilizer /ˈlɪkwɪd ˈfəːtɪlʌɪzə/ [n] ជីរាវ
- manufactured fertilizer /manjʊˈfaktʃəd ˈfəːtɪlʌɪzə/ [n] ជីគីមី (ន័យដូច៖ chemical fertilizer)
- mineral fertilizer /ˈmɪn(ə)r(ə)l ˈfəːtɪlʌɪzə/ [n] ជីខនិជ
- mixed fertilizer /mɪkst ˈfəːtɪlʌɪzə/ [n] ជីលាយ (ជីផ្សំពីជីគីមី ២ ប្រភេទ ឬច្រើនចម្រុះគ្នា)
- nitrate fertilizer /ˈnʌɪtreɪt ˈfəːtɪlʌɪzə/ [n] ជីនីត្រាត
- nitrogen fertilizer /ˈnʌɪtrədʒ(ə)n ˈfəːtɪlʌɪzə/ [n] (សទិសន័យ៖ nitrogen fertilizer, nitrogen manure) ជីអាសូត
- nitrogenous fertilizer /nʌɪˈtrɒdʒɪnəs ˈfəːtɪlʌɪzə/ [n] សូមមើលពាក្យ៖ nitrogen fertilizer, nitrogen manure
- organic fertilizer /ɔːˈganɪk ˈfəːtɪlʌɪzə/ [n] ជីធម្មជាតិ, ជីសរីរាង្គ (ជីបានមកពីផ្នែក ឬសំណល់សត្វនិងរុក្ខជាតិ)
- phosphate fertilizer /ˈfɒsfeɪt ˈfəːtɪlʌɪzə/ [n] (សទិសន័យ៖ phosphatic manure) ជីផូស្វាត
- potash fertilizer /ˈpɒtaʃ ˈfəːtɪlʌɪzə/ [n] (សទិសន័យ៖ potash manure) ជីប៉ូតាស
- single fertilizer /ˈsɪŋg(ə)l ˈfəːtɪlʌɪzə/ [n] ជីទោល (ជីដែលផ្សំឡើងពីធាតុគីមីសំខាន់តែមួយគត់អាចជាអាសូត ផូស្វ័រ ឬប៉ូតាស្យូម)

**fester** /ˈfɛstə/ [n] ដំបៅមានខ្ទុះ, ការឡើងខ្ទុះ

**festoon** /fɛˈstuːn/ [n] កម្រងផ្កា

**festoon** /fɛˈstuːn/ [v] បំពាក់កម្រងផ្កា, តុបតែងដោយកម្រងផ្កា

**fetid** /ˈfiːtɪd/ [adj] ខ្មោះ (ឆ្អេះឆ្អាប)

**fetlock** /ˈfɛtlɒk/ [n] ឆ្អឹងម្រាម (កជើង)

**fetus** /ˈfiːtəs/ [n] គភ៌ (ទារកនៅក្នុងពោះ)

**fever** /ˈfiːvə/ [n] គ្រុន

- hemorrhage fever /ˈhɛmərɪdʒ ˈfiːvə/ [n] គ្រុនពោះវៀន
- Q fever /kjuː ˈfiːvə/ [n] ជំងឺគ្រុនមិនដឹងមូលហេតុ
- scarlet fever /ˈskɑːlɪt ˈfiːvə/ [n] ជំងឺគ្រុនក្តៅ, អុតក្តាម

- typhoid fever /ˈtʌɪfɔɪd ˈfiːvə/ [n] គ្រុនសន្និ, គ្រុនពោះវៀន
- undulant fever /ˈʌndjʊl(ə)nt ˈfiːvə/ [n] គ្រុនក្ដៅឡើងចុះ
- yellow fever /ˈjɛləʊ ˈfiːvə/ [n] ជំងឺគ្រុនលឿង
- swine fever /swʌɪn ˈfiːvə/ [n] សូមមើលពាក្យ៖ hog cholera

**fiber** /ˈfʌɪbə/ [n] (សរសេរជា fibre ក៏បាន) សរសៃ (១. ពាក្យដែលប្រើសំដៅទៅលើកោសិកាឈើច្រើនជាងសរសៃ vessel និង parenchyma ២. ពាក្យប្រើសម្រាប់ឈើជាទូទៅ ៣. សរសៃស្ដើងវែង ដែលមាននៅក្នុងដើម)

- association fiber /əsəʊʃɪˈeɪʃ(ə)n ˈfʌɪbəz/ [n] សរសៃបណ្ដុំ

**fibrillation** /fʌɪbrɪˈleɪʃ(ə)n/ [n] ការកន្ត្រាក់សរសៃសាច់ដុំបេះដូង

**fibrin** /ˈfɪbrɪn/ [n] ជាតិដែលកើតជាក្រដាសស្ដើងលើឈាមកក, សារធាតុនៅក្នុងឈាមកក

**fibroid** /ˈfʌɪbrɔɪd/ [n] ដុំសាច់ដែលមានជាលិកាជាសរសៃភ្ជាប់ តាមធម្មតានៅក្នុងស្បូន (មិនមែនមហារីកទេ), ដែលមានឬដូចជាសរសៃភ្ជាប់តូចៗ

**fibula** /ˈfɪbjʊlə/ [n] ឆ្អឹងកំភួនជើង, ឆ្អឹងស្មងជើង

***Ficus benghalensis*** [sci.n] សូមមើលពាក្យ៖ banyan tree

***Ficus religiosa*** [sci.n] ពោធិ៍

**fiddlehead** /ˈfɪd(ə)lhɛd/ [n] ស្លឹកត្រួយបណ្ណង្គជាតិ

**field** /fiːld/ [n] ចម្ការ, ស្រែ, កន្លែង, ដែន, វិស័យ, តំបន់, វាលស្មៅ

- block field /blɒk fiːld/ [n] កន្លែងដែលមានដុំ ឬផ្ទាំងថ្មច្រើន
- canefield /keɪn fiːld/ [n] ចម្ការអំពៅ
- clinker field /ˈklɪŋkə fiːld/ [n] ចង្អូរថ្មភ្នំភ្លើងដែលមានរន្ធច្រើន, ផ្ទៃគ្រគ្រើម
- fallow rice field /ˈfaləʊ rʌɪs fiːld/ [n] វាលស្រែទុកទំនេរ
- field guard /fiːld gɑːd/ [n] ឆ្មាំចម្ការ
- lowland field /ˈləʊlənd fiːld/ [n] ស្រែទំនាប (ស្រែដែលមានប្រព័ន្ធភ្លឺទំនប់សម្រាប់រក្សាទឹកភ្លៀង ឬទឹកដែលបានស្រោចស្រពតាមប្រព័ន្ធស្រោចស្រព)
- lowland rice field /ˈləʊlənd rʌɪs fiːld/ [n] វាលស្រែតំបន់ទំនាប
- paddy field /ˈpadi fiːld/ [n] សូមមើលពាក្យ៖ paddy
- ploughed field /plaʊd fiːld/ [n] ចម្ការដែលភ្ជួរ
- rice field /rʌɪs fiːld/ [n] វាលស្រែ
- tilled field /tɪld fiːld/ [n] ចម្ការដែលភ្ជួរ
- upland crop field /ˈʌplənd krɒp fiːld/ [n] ចម្ការដំណាំ
- upland field /ˈʌplənd fiːld/ [n] ស្រែខ្ពង់រាប

**field layout** /fiːld ˈleɪaʊt/ [n] ការរៀបចំប្លង់ ឬស្រែពិសោធ

**field trip** /fiːld trɪp/ [n] ទស្សនកិច្ចសិក្សា (ការធ្វើដំណើរទៅអង្កេតជាក់ស្ដែងក្នុងស្រែអំពីការងារអនុវត្តន៍ និងការប្រព្រឹត្តទៅកន្លងមកនៅទីនោះ)

**filament** /ˈfɪləm(ə)nt/ [n]

១. (ចំពោះរុក្ខជាតិ) ទងកញ្ចុំលម្អង, ទងកេសរឈ្មោល, ទងនៃថង់លម្អង, ភីឡាម៉ង់ (ផ្នែកមួយនៃកេសរឈ្មោលដែលភ្ជាប់ទៅនឹងថង់លម្អង)

២. (ចំពោះសត្វ) សរសៃឆ្មារ

- axial filament /ˈaksɪəl ˈfɪləm(ə)nt/ [n] ភីឡាម៉ង់អ័ក្ស (សរសៃឆ្មារៗមួយស៊េរីដែលជាផ្នែករបស់រោមញីរ ឬផ្កាសៃល)

**filamentous** /fɪləˈmɛntəs/ [adj] រាងជាសរសៃ

**Filaria** /fɪˈlɛːrɪə/ [n] ភីលែ (ពពួកដង្កូវឆ្មារដូចសរសៃដែលរស់នៅតាមសរសៃឈាម, ព្រូនម៉្យាងមានរាងដូចអំបោះ)

**filariasis** /fɪˌlɛːrɪˈeɪsɪs/ [n] ជំងឺរាំរ៉ៃបណ្ដាលមកពីព្រូនរាងដូចអំបោះ

**file** /fʌɪl/ [n] ដែកឆាប, ដែកអង្រួស, សំណុំឯកសារ (១. ឧបករណ៍សម្រាប់រំលីងផ្ទៃគ្រើម ២. ព័ត៌មានដែលប្រមូលត្រូវបានរក្សាទុកក្រោមឈ្មោះមួយនៅក្នុងថាសនៃកុំព្យូទ័រ ឬក្នុងការរៀបចំឯកសារ)

**filler** /ˈfɪlə/ [n] អង្គធាតុបំពេញ (ធាតុទាំងឡាយណាដែលមិនមានជាតុចិញ្ចឹម ហើយដែលគេលាយជាមួយជីដើម្បីបង្គ្រប់ទម្ងន់ជីដែលគេចង់បាន)

**filling** /ˈfɪlɪŋ/ [n] ការបំពេញកន្លែងទំនាប

**film** /fɪlm/ [n] កំណៀសឈាម (លើកញ្ចក់សម្រាប់ពិនិត្យឈាម), បន្ទះស្តើង

- water film /ˈwɔːtə fɪlm/ [n] សន្ទះស្តើងនៃទឹក (នៅជុំវិញគ្រាប់ដី)

**filter** /ˈfɪltə/ [v] ច្រោះ, ត្រង

**filter** /ˈfɪltə/ [n] តម្រង, ប្រដាប់ច្រោះ, តម្រង (ក្រដាស)

- absorption filter /əbˈzɔːpʃ(ə)n ˈfɪltə/ [n] តម្រងសម្រូប
- acoustic filter /əˈkuːstɪk ˈfɪltə/ [n] តម្រងអាគូស្ទិច (សន្ទះទប់សំលេងដែលបង្ករដោយសម្ពាធផ្សេងៗ ឧ. សំលេងពីមាស៊ីនត្រជាក់ ឬ ទូទឹកកក)។
- activated carbon filter /ˈaktɪveɪtid ˈkɑːb(ə)n ˈfɪltə/ [n] តម្រងប្រើធ្យូងសកម្ម
- air filter /ɛː ˈfɪltə/ [n] តម្រងខ្យល់
- bacterial filter /bakˈtɪərɪəl ˈfɪltə/ [n] តម្រងបាក់តេរី
- ceramic filter /sɪˈramɪk ˈfɪltə/ [n] តម្រងសេរ៉ាមិច
- dry filter /drʌɪ ˈfɪltə/ [n] តម្រងស្ងួត
- dust filter /dʌst ˈfɪltə/ [n] តម្រងធូលី
- electric filter /ɪˈlɛktrɪk ˈfɪltə/ [n] តម្រងអគ្គិសនី
- fabric filter /ˈfabrɪk ˈfɪltə/ [n] តម្រងក្រណាត់
- fuel filter /fjuː(ə)l ˈfɪltə/ [n] តម្រងប្រេង (តម្រងសម្រាប់សម្អាតប្រេងឥន្ធនៈ)
- gravel filter /ˈgrav(ə)l ˈfɪltə/ [n] តម្រងក្រួស
- gravel sand filter /ˈgrav(ə)l-sand ˈfɪltə/ [n] តម្រង
- heat filter /hiːt ˈfɪltə/ [n] តម្រងការពារកម្តៅ
- membrane filter /ˈmɛmbreɪn ˈfɪltə/ [n] តម្រងភ្នាស
- noise filter /nɔɪz ˈfɪltə/ [n] តម្រងសូរ, តម្រងសំឡេង
- oil filter /ɔɪl ˈfɪltə/ [n] តម្រងប្រេង
- paper filter /ˈpeɪpə ˈfɪltə/ [n] តម្រងក្រដាស
- preliminary filter /prɪˈlɪmɪn(ə)ri ˈfɪltə/ [n] តម្រងសម្អាតដំណាក់កាលដំបូង
- sand filter /sand ˈfɪltə/ [n] តម្រងខ្សាច់
- screen filter /skriːn ˈfɪltə/ [n] តម្រងសំណាញ់
- secondary filter /ˈsɛk(ə)nd(ə)ri ˈfɪltə/ [n] តម្រងសម្អាតដំណាក់កាលទីពីរ
- sewage filter /ˈsuːɪdʒ ˈfɪltə/ [n] តម្រងសម្អាតទឹកលូសម្អុយ
- smoke filter /sməʊk ˈfɪltə/ [n] តម្រងសម្អាតផ្សែង
- soil filter /sɔɪl ˈfɪltə/ [n] តម្រងនៃដី (ឧ. គេអាចយកដីធ្វើជាតម្រងចម្រាញ់ទឹកសម្អុយ)
- textile filter /ˈtɛkstʌɪl ˈfɪltə/ [n] តម្រងកំណាត់
- water filter /ˈwɔːtə ˈfɪltə/ [n] តម្រងទឹក

**filtrate** /ˈfɪltreɪt/ [n] ទឹកច្រោះ, ទឹកតម្រង

**filtration** /fɪlˈtreɪʃn/ [n] ចម្រោះ

- biological filtration /bʌɪə(ʊ)ˈlɒdʒɪk(ə)l fɪlˈtreɪʃn/ [n] ចម្រោះដោយជីវៈ
- clarification filtration /ˌklarɪfɪˈkeɪʃ(ə)n fɪlˈtreɪʃn/ [n] ការធ្វើឱ្យថ្លាដោយច្រោះ, ការច្រោះឱ្យថ្លា
- gravity filtration /ˈgravɪti fɪlˈtreɪʃn/ [n] ចម្រោះដោយទំនាញដី
- membrane filtration /ˈmɛmbreɪn fɪlˈtreɪʃn/ [n] ចម្រោះប្រើភ្នាស
- pressure filtration /ˈprɛʃə fɪlˈtreɪʃn/ [n] ចម្រោះក្រោមសម្ពាធ

***Fimbristylis dischotoma*** [sci.n] សូមមើលពាក្យ៖ forked fringe-rush

***Fimbristylis miliacea*** [sci.n] សូមមើលពាក្យ៖ globe fringe-rush

**fin** /fɪn/ [n] ស្លាប, កន្ទុយ (ត្រី)

- anal fin /ˈeɪn(ə)l fɪn/ [n] ព្រុយគូទ
- caudal fin /ˈkɔːd(ə)l fɪn/ [n] ព្រុយកន្ទុយ
- dorsal fin /ˈdɔːs(ə)l fɪnz/ [n] ព្រុយខ្នង
- homocercal fin /ˌhɒmə(ʊ)ˈsəːk(ə)l fɪn/ [n] ព្រុយស៊ីមេទ្រីគ្នា

**fine** /fʌɪn/ [n] គ្រាប់ល្អិត ឬម៉ត់, ភាពល្អិតល្អន់, ភាពស្តើង ឬឆ្មារ, ការផាកពិន័យ

**fine grained** /fʌɪn greɪnd/ [adj] ដែលមានគ្រាប់ល្អិតៗ

**fine moder** /fʌɪn mɒdə/ [n] មមោកអន្ទរការល្អិត

**finely toothed** /ˈfʌɪnli tuːθt/ [adj] ស្លឹក ដែលមានគែមស្លឹកតូចរាងដូច ធ្មេញរណារ

**finger nail** /ˈfɪŋgə neɪl/ [n] ក្រចកដៃ

**fingerling** /ˈfɪŋgəlɪŋ/ [n] កូនត្រី

**fingerprint** /ˈfɪŋɡəprɪnt/ [n] ស្នាម
- genetic fingerprint /dʒɪˈnɛtɪk ˈfɪŋɡəprɪnt/ [n] ស្នាមសេនេទិច (ស្នាមដែលផិតលើបន្ទះអន្ទិលនៃឧបករណ៍ពិសោធ)

**finless porpoise** /fɪnlɛs ˈpɔːpəs/ [n] ផ្សោតឥតព្រុយខ្នង (ឈ្មោះវិទ្យាសាស្ត្រ *Neophocaena phocaenoides*)
**fire loss** /ˈfʌɪə lɒs/ [n] អ្វីៗដែលបាត់ទៅដោយការឆេះ
**fire-break** /ˈfʌɪə breɪk/ [n] ផ្លូវភ្លើង
**fire-marble** /ˈfʌɪə ˈmɑːb(ə)l/ [n] សូមមើលពាក្យ៖ limestone
**firewood** /ˈfʌɪəwʊd/ [n] (សទិសន័យ៖ fuelwood) អុស
**fiscal year** /ˈfɪsk(ə)l jɪə/ [n] ឆ្នាំសារពើពន្ធ
**fish** /fɪʃ/ [v] ស្ទូចត្រី, នេសាទត្រី
fish /fɪʃ/ [n] ត្រី
- benthic fish /ˈbɛnθɪk fɪʃ/ [n] ត្រីរស់នៅស្រទាប់បាត
- bony fish /ˈbəʊni fɪʃ/ [n] (សទិសន័យ៖ osteichthyes) ត្រីឆ្អឹង
- butter fish /ˈbʌtə fɪʃ/ [n] ប្រភេទត្រីកាបសមុទ្រម្យ៉ាង
- cartilaginous fish /ˌkɑːtɪˈladʒɪnəs fɪʃ/ [n] ត្រីឆ្អឹងខ្ចី
- cichlid fish /ˈsɪklɪd fɪʃ/ [n] ត្រីស៊ីឃ្លីត (ក្រុមត្រីពាំកូនក្នុងមាត់)
- cultured fish /ˈkʌltʃəd fɪʃ/ [n] ត្រីចិញ្ចឹម
- cuttle fish /ˈkʌt(ə)l fɪʃ/ [n] សូមមើលពាក្យ៖ squid
- demersal fish /dɪˈməːs(ə)l fɪʃ/ [n] ត្រីដែលរស់នៅបាតសមុទ្រ ឬបាតបឹង
- fermented fish /fəˈmɛntɪd fɪʃ/ [n] (សទិសន័យ៖ rotten fish) ត្រីផ្អាប់ (ដូចជា ប្រហុក ឬផ្អក)
- fish basket /fɪʃ ˈbɑːskɪt/ [n] កញ្ជេ ឬកញ្ច្រែងដាក់ត្រី
- fresh fish /frɛʃ fɪʃ/ [n] ត្រីស្រស់
- pelagic fish /pɪˈladʒɪk fɪʃ/ [n] ត្រីដែលរស់នៅលំហទឹកសមុទ្រ
- rotten fish /ˈrɒt(ə)n fɪʃ/ [n] សូមមើលពាក្យ៖ fermented fish
- salt water fish /sɔːlt ˈwɔːtə fɪʃ/ [n] ត្រីទឹកប្រៃ
- sea fish /siː fɪʃ/ [n] ត្រីសមុទ្រ
- Siamese fighting fish /ˌsʌɪəˈmiːz ˈfʌɪtɪŋ fɪʃ/ [n] ត្រីក្រឹមភៀក (ឈ្មោះវិទ្យាសាស្ត្រ *Betta splendens*)
- snake head fish /sneɪk hɛd fɪʃ/ [n] ត្រីផ្ទក់, ត្រីរ៉ស់

**fish hook** /fɪʃ hʊk/ [n] ផ្លែសន្ទូច
**fish net** /fɪʃ nɛt/ [n] មង, សំណាញ់
**fish with a hook and line** /fɪʃ wɪð ə hʊk ənd lʌɪn/ [v] ស្ទួចត្រី
**fisherman** /ˈfɪʃəmən/ [n] អ្នកនេសាទត្រី
**fishery** /ˈfɪʃ(ə)ri/ [n] ការនេសាទ, កន្លែងចិញ្ចឹមត្រី
- coastal fishery /ˈkəʊstl ˈfɪʃ(ə)ri/ [n] នេសាទតាមឆ្នេរ, នេសាទក្បែរឆ្នេរ
- commercial fishery /kəˈməːʃ(ə)l ˈfɪʃ(ə)ri/ [n] នេសាទជំនួញ
- Community Fisheries (CF) /kəˈmjuːnɪti ˈfɪʃ(ə)ris/ [n pl] សហគមន៍នេសាទ
- deep-sea fishery /diːp-siː ˈfɪʃ(ə)ri/ [n] (សទិសន័យ៖ offshore fishery) នេសាទសមុទ្រក្រៅ, នេសាទកណ្ដាលសមុទ្រ, នេសាទឆ្ងាយពីឆ្នេរ
- fisheries station /ˈfɪʃ(ə)riz ˈsteɪʃ(ə)n/ [n] ស្ថានីយជលផល
- inshore fishery /ɪnˈʃɔː ˈfɪʃ(ə)ri/ [n] នេសាទតាមឆ្នេរ, នេសាទក្បែរឆ្នេរ
- offshore fishery /ˈɒfʃɔː ˈfɪʃ(ə)ri/ [n] សូមមើលពាក្យ៖ deep-sea fishery
- subsistence fishery /səbˈsɪst(ə)ns ˈfɪʃ(ə)ri/ [n] នេសាទចិញ្ចឹមជីវិត

**fishing line** /ˈfɪʃɪŋ lʌɪn/ [n] ខ្សែសន្ទូច
**fishing lot** /ˈfɪʃɪŋ lɒt ˈɛːrɪə/ [n] ឡូត៍នេសាទ
**fishing rod** /ˈfɪʃɪŋ rɒd/ [n] ដងសន្ទូច
**fishing** /ˈfɪʃɪŋ/ [n] ការនេសាទត្រី
**selective fishing** /sɪˈlɛktɪv ˈfɪʃɪŋ/ [n] ការនេសាទដោយជម្រើសត្រីតាមប្រភេទ
**fishmonger** /ˈfɪʃmʌŋɡə/ [n] អ្នកលក់ត្រី
**fission** /ˈfɪʃ(ə)n/ [n] ការចែកចេញ, ការបំបែក
- binary fission /ˈbʌɪnəri ˈfɪʃ(ə)n/ [n] ចំណែកជាពីរ

**Fissipedia** [n] ហ្វីសស៊ីភេឌៀ (លំដាប់មួយនៃថនិកសត្វដែលជាមំសាសី ដូចជាឆ្មា ឆ្កែ និងខ្លាឃ្មុំ)
**fissure** /ˈfɪʃə/ [n] ស្នាមប្រេះ, ក្រហែង, ចង្អូរតូចៗនៅខួរ, ដំបៅដោយបំរ៉េះ
- dissipation fissure /dɪsɪˈpeɪʃ(ə)n ˈfɪʃə/ [n] ក្រហែងស្ងួត

**fist** /fɪst/ [n] កណ្ដាប់ដៃ

**fistula** /ˈfɪstjʊlə/ [n] បំពង់ ឬរន្ធនិម្មិត (ដែលភ្ជាប់ពីវត្ថុមួយទៅវត្ថុមួយ), ដំបៅស៊ីរូង (ដែលញយៗវាទាក់ទងស្បែក និងសរីរាង្គ), បូសក្លាយ

**fit** /fɪt/ [n] ជំងឺប្រកាច់

**fit** /fɪt/ [adj] សម, ត្រូវ

**fitness** /ˈfɪtnəs/ [n]

១. លទ្ធភាពរស់

២. ការសមគ្នា, ការត្រូវគ្នា (ការរួមចំណែកញាត្តិសន្តានដែលឯកត្តៈមួយបញ្ចូលទៅក្រុមពន្ធុ(gene pool) របស់ជំនាន់បន្ទាប់។)

- physical fitness /ˈfɪzɪk(ə)l ˈfɪtnəs/ [n] ភាពមាំទាំនៃរាងកាយ

**fitweed** /'fɪtwiːd/ [n] សូមមើលពាក្យ៖ culantro

**fix** /fɪks/ [v] ភ្ជាប់, ធ្វើឱ្យនឹង

**fixation** /fɪkˈseɪʃ(ə)n/ [n] ការភ្ជាប់, ការចាប់យក (ឧ. Nitrogen fixation ជាការចាប់យកអាសូតពីក្នុងបរិយាកាសដោយពពួកបាក់តេរី ដែលស្ថិតនៅក្នុងកំណកឫសរបស់រុក្ខជាតិពពួកសណ្តែក និងស្មៅ)

- biological N fixation /bʌɪə(ʊ)ˈlɒdʒɪk(ə)l ɛn fɪkˈseɪʃ(ə)n/ [n] ការបំប្លែងអាសូត (N) របស់បរិយាកាសឱ្យទៅជាទម្រង់អាចប្រើប្រាស់បានដោយអំពើនៃពពួកសារពាង្គកាយដែលមានជីវិត)
- carbon fixation /ˈkɑːb(ə)n fɪkˈseɪʃ(ə)n/ [n] ជំនាប់កាបូន
- chemical fixation /ˈkɛmɪk(ə)l fɪkˈseɪʃ(ə)n/ [n] ចំណាប់កម្មគីមី (ដំណើរការមួយដែលក្នុងនោះសារធាតុចិញ្ចឹមក្នុងដីក្នុងកម្រិតកំណត់មួយ បានបំប្លែងពីទម្រង់សេរីរបស់វា ទៅជាទម្រង់មិនសេរីដូចជា ការចាប់ប៉ូតាស្យូម, អាម៉ូញ៉ូម និងហ្វូសហ្វ័រជាដើម (ឧ. ការចាប់យកអាម៉ូញ៉ូមនៃជីតដ្ឋ យកទុកក្នុងចន្លោះកណ្តាលរវាងស្រទាប់ ស៊ីលីកាទាំងពីរ ហើយក្លាយទៅជាផ្នែករឹងពិបាកត្រឡប់មករកភាពដើម))
- nitrogen fixation /ˈnʌɪtrədʒ(ə)n fɪkˈseɪʃ(ə)n/ [n] បញ្ចប់អាសូត, ចំណាប់អាសូត, ការចាប់អាសូត (ការផ្លាស់ប្តូរធាតុនីត្រូសែនពីបរិយាកាស ទៅឱ្យសារពាង្គកាយរស់ក្នុងការប្រើប្រាស់។ សម្គាល់ ការផ្តល់អាសូតសហប្រាណ (symbiotic) ត្រូវបានធ្វើឡើងតាមរយៈបាក់តេរីដែលមាននៅលើកំពកឫសរុក្ខជាតិប្រភេទសណ្តែក (legumes) ឬអាចធ្វើឡើងដោយពពួកមីក្រូសារពាង្គកាយ ជាក់លាក់មិនមានកំពកឫស និងមិនមែនជាពពួកសណ្តែក (legumes) និងពពួកវារីជាតិ ដូចជាសារាយជាដើម។)
- non-symbiotic nitrogen fixation /nɒn'sɪmbɪˈəʊtɪk ˈnʌɪtrədʒ(ə)n fɪkˈseɪʃ(ə)n/ [n] ការចាប់អាសូតដោយពពួកបាក់តេរីស្វ័យជីព (autotropic bacteria) ដែលរស់នៅសេរីក្នុងដីមានអុកស៊ីសែន និងដីគ្មានអុកស៊ីសែន

**soil fixing** /sɔɪl ˈfɪksɪŋ/ [n] ការបឹតយកនៃដី

**flaccid** /ˈflasɪd/ [n] ភាពទន់, ភាពរលា (សាច់ដុំ)

***Flacourtia cataphracta*** [sci.n] ក្រខុបខ្មែរ

***Flacourtia indica*** [sci.n] សូមមើលពាក្យ៖ governor's plum

**Flagellata** /ˈfladʒ(ə)lə/ [n] ពួកផ្លាសែល (អតិសុខុមប្រាណដែលវារដោយប្រើប្រមោយ ឬដៃ)

**flagellate** /ˈfladʒ(ə)leɪt/ [n] ភាវរស់មានផ្លាសែល

**flagellum** /fləˈdʒɛləm/ [n] (ពហុវចនៈ៖ flagella)

១. (ចំពោះសត្វល្អិត) ចុង (អង់តែន)

២. កន្ទុយ (បាក់តេរី ស្ប៉ជាដើម), រោមញ័រ (ភាពសម្ពន្ធមួយមានរាងដូចរោម ឬសក់ ឬសរសៃ ឬខ្សែ ឬកន្ទុយដែលអាចបម្រើចលនាផ្លាស់ទីបាននៃកោសិកា ឬនៃមីក្រូសារពាង្គកាយណាមួយ)

**flaggy** /flagi/ [n] ឥដ្ឋ, ផ្ទាំង ឬបន្ទះសិលា

**flake** /fleɪk/ [n] ស្លឹកស្រទាប់ៗ, សំណុំ

**flame** /fleɪm/ [n] អណ្តាតភ្លើង

**flank** /flaŋk/ [n] ចង្កេះ (ពោះទឹក ឬកណ្តៀតក្អម)

**flask** /flɑːsk/ [n] ដប

**calcareous mud flat** /kalˈkɛːrɪəs mʌd flat/ [n] សម្ការផង់កំបោរ (ឧ. ភក់បាតបឹងស្ងួត)

**flat** /flat/ [adj] (សទិសន័យ៖ level) ដែលរាបស្មើ, នៃតំបន់ទំនាប

**flat** /flat/ [n]

១. (ចំពោះធរណីវិទ្យា) (សទិសន័យ៖ shoal, swallow) បាតជ្រលង, បាតស្ទឹងបឹងបួរ

២. ផ្ទៃករាបស្មើ

- tidal flat /ˈtʌɪd(ə)l flat/ [n] ទំនាបស្មើនៃវាលភក់ក្នុងជំនោរតំបន់ចុះឡើងទឹកជំនោរ, ដីទំនាបគោកពេលសមុទ្រនាច

**flattening** /ˈflat(ə)nnɪŋ/ [n] សូមមើលពាក្យ៖ levelling

**flatulence** /ˈflatjʊl(ə)ns/ [n] ឆ្អល់ពោះ ឬហើមពោះ

**flatus** /ˈfleɪtəs/ [n] ផោម

• flatus tube /ˈfleɪtəs tjuːb/ [n] បំពង់បន្តឱ្យចេញផោម

**flea** /fliː/ [n] ពពួកចៃ, ពពួកសង្កើច, ចៃឆ្កែ, ស្រមើល

**fleck** / flɛk/ [n] សូមមើលពាក្យ៖ spot

**flesh** /flɛʃ/ [n] សាច់ (ផ្លែឈើ ឬត្រី)

• proud flesh /praʊd flɛʃ/ [n] ផ្លែ (សាច់)

**flexor** /ˈflɛksə/ [n] សាច់ដុំបំបត់

**flexuous** /ˈflɛksjʊəs/ [adj] បត់ក្ងិងក្ងង់ (អំពីដើម)

**flightless** /ˈflʌɪtləs/ [adj] មិនអាចហើរបាន

**flinty** /ˈflɪnti/ [adj] សូមមើលពាក្យ៖ siliceous

**flipper** /ˈflɪpə/ [n] ព្រុយ (ត្រី, ផ្សោត)

**floatation** /fləʊˈteɪʃ(ə)n/ [n] អណ្តែតភាព

**floccose** /ˈflɒkəʊs/ [adj] គ្របដណ្តប់ដោយរោមតូចៗ (ទម្រង់រុក្ខជាតិ)

**flocculation** /flɒkjʊˈleɪʃ(ə)n/ [n] ភាពកក (ឧ. ឈាម, ដីឥដ្ឋ)

**flocculent** /ˈflɒkjʊl(ə)nt/ [adj] ជាសំណុំ, ជាដុំតូច, ជារបុំ

**flood** /flʌd/ [n] (សទិសន័យ៖ inundation) ជំនន់, ការជោរជន់

• flash-flood /flaʃ flʌd/ [n] ជំនន់ផ្លេក (ប្រភេទទឹកជំនន់ដែលឡើងក៏រហ័ស ហើយស្រកទៅវិញក៏រហ័សដែរ)

• flood plain scroll /flʌd pleɪn skrəʊl/ [n] ជ្រលងរបត់ទន្លេ ឬស្ទឹង

• flood gate /flʌd geɪt/ [n] ទំនប់ការពារទឹកជំនន់

• lava flood /ˈlɑːvə flʌd/ [n] សូមមើលពាក្យ៖ lava sheet

• marine flood /məˈriːn flʌd/ [n] ជំនន់ទឹកសមុទ្រ

• tidal flood /ˈtʌɪd(ə)l flʌd/ [n] ជំនន់ជោរនាច (របបទឹកជំនន់ដែលរងឥទ្ធិពលពីសមុទ្រ)

**flooding** /flʌdɪŋ/ [n]

១. (ចំពោះការស្រោចស្រព) សូមមើលពាក្យ៖ controlled flooding

២. ការជន់លិច

• controlled flooding /kənˈtrəʊld flʌdɪŋ/ [n] (សទិសន័យ៖ checked flooding, gradient irrigation) ការស្រោចស្រពដោយបញ្ចូលទឹកក្នុងកន្លែងណាមួយដែលព័ទ្ធជុំវិញដោយទំនប់ (ភ្លឺស្រែ) ឬក្នុងអាងរងទឹកទឹកភ្លៀង

**floor** /flɔː/ [n] ផ្ទៃរាប, ជាន់ថ្នាក់

• forest floor /ˈfɒrɪst flɔː/ [n] សូមមើលពាក្យ៖ leaf-litter

• valley floor /ˈvali flɔː/ [n] បាតជ្រលង

**flor catena** /flor kəˈtiːnə/ [n] ដំណើរតគ្នា ឬឈុតបន្តបន្ទាប់គ្នានៃរុក្ខជាតិ

**flora** /ˈflɔːrə/ [n] ពពួករុក្ខជាតិ, ពពួកភូតគាម, ពពួកមេរោគជម្មតានៅក្នុងពោះវៀន

• aquatic flora /əˈkwatɪk ˈflɔːrə/ [n] រុក្ខជាតិទឹក

• terrestrial flora /təˈrɛstrɪəl ˈflɔːrə/ [n] រុក្ខជាតិលើគោក

**floret** /ˈflɒrɪt/ [n] តួផ្កា (មានសម្បកធំ និងតូច កេសរញីនិងកេសរឈ្មោល)

**floristics** /fləˈrɪstɪks/ [n] ចំនួនរបាយផ្កាវិទ្យា

**flotation** /fləʊˈteɪʃ(ə)n/ [n] វិធីសម្អាតគ្រាប់ប្រើអង្គធាតុរាវ, វិធីបណ្តែតទឹក

**flow** /fləʊ/ [n] ធារ, ចរន្ត, រំហូរ, ការហូរ (ទឹក)

• annual flow /ˈanjʊəl fləʊ/ [n] ធារទឹកប្រចាំឆ្នាំ

• base flow /beɪs fləʊ/ [n] ធារទឹកសម្រក

• daily flow /ˈdeɪli fləʊ/ [n] ធារទឹកប្រចាំថ្ងៃ

• downstream flow /daʊnstriːm fləʊ/ [n] ចរន្តក្រោមទឹក

• earth flow /əːθ fləʊ/ [n] សូមមើលពាក្យ៖ earth slide

• energy flow /ˈɛnədʒi fləʊ/ [n] រំហូរថាមពល

• flood flow /flʌd fləʊ/ [n] ធារទឹកជំនន់

• groundwater-flow /ˈgraʊn(d)wɔːtə fləʊ/ [n] ចរន្តទឹកក្នុងដី

• mud flow /mʌd fləʊ/ [n] ភក់ដែលហូរ, កំអែរភ្លក់, ចរន្តភក់

• soil flow /sɔɪl fləʊ/ [n] ការហូរនៃដី

• stream flow /striːm fləʊ/ [n] សូមមើលពាក្យ៖ stream discharge

• tidal flow /ˈtʌɪd(ə)l fləʊ/ [n] ចរន្តទឹកជោរ

**flowable (F)** /fləʊ ˈeɪb(ə)l/ [n] បាណកឃាតខាប់ (ក្នុងនោះមានថ្នាំពុលផ្សំជាមួយលម្អងម្សៅ(ធូលី) ដែលពង្រាវវាលាយជាមួយទឹកតិចៗ)

**flowage** /fləʊweɪdʒ/ [n] ការហូរ (ឧ. ដែកត្រូវកម្ដៅហូរខ្លាំង)

**flower** /ˈflaʊə/ [v] ចេញផ្កា, មានផ្កា

**flower** /ˈflaʊə/ [n] ផ្កា

- actinomorphic flower /ˌaktɪnə(ʊ)ˈmɔːfɪk ˈflaʊə/ [n] ផ្កាមានរបៀប
- African spider flower /ˈafrɪk(ə)n ˈspʌɪdə ˈflaʊə/ [n] មមាញស្រុក (ឈ្មោះវិទ្យាសាស្ត្រ *Cleome gynandra*)
- Asian spider flower /ˈeɪʒ(ə)n ˈspʌɪdə/ [n] មមាញខ្មោចលឿង (ឈ្មោះវិទ្យាសាស្ត្រ *Cleome viscosa*)
- banana flower /bəˈnɑːnə ˈflaʊə/ [n] ត្រយូងចេក
- carpellate flower /ˈkɑːp(ə)leɪt ˈflaʊə/ [n] កញ្ចុំផ្កាញី
- carrion flower /ˈkarɪən ˈflaʊə/ [n] ផ្កាក្លិនស្អុយ
- cleistogamous flower /klʌɪˈstɒgəməs ˈflaʊə/ [n] ផ្កាក្ដោប, ផ្កាមិនរីក, ផ្កាបាយលម្អងខ្លួនឯង (ផ្កាដែលមិនរីក ឬបើកទទួលយកការបាយលម្អងពីខាងក្រៅ ប៉ុន្តែវាបាយ និងបង្កកំណើតពីលម្អងខ្លួនឯងនៅ ក្នុងប្រព័ន្ធបាយបិទជិត។ ប្រភេទពូជទាំងនេះមានលក្ខណៈជាផ្កាក្ដោប និងជាពិសេសបាយលម្អងខ្លួនឯងនិង បង្កាត់ក្នុង។)
- complete flower /kəmˈpliːt ˈflaʊə/ [n] ផ្កាពេញលេញ (ផ្កាដែលមានត្របក ស្រទាប់ កញ្ចុំកេសរឈ្មោល និងកញ្ចុំកេសរញី)
- fringed spider flower /frɪn(d)ʒt ˈspʌɪdə ˈflaʊə/ [n] មមាញខ្មោចក្រហម (ឈ្មោះវិទ្យាសាស្ត្រ *Cleome rutidosperma*)
- gregarious flowering /grɪˈgɛːrɪəs ˈflaʊəɪŋ/ [n] ការចេញផ្កាច្រើន (ការចេញផ្កាយ៉ាងច្រើននៅក្នុងរយៈពេលមួយខ្លី។ ពាក្យផ្ទុយ Diffuse flowering (ការចេញផ្កាពេញ១ឆ្នាំឬរដូវផ្កា)។)
- imperfect flower /ɪmˈpəːfɪkt ˈflaʊə/ [n] (សទិសន័យ៖ unisexual flower) ផ្កាមិនពេញលេញ, ផ្កាមានភេទតែមួយ, ផ្កាមិនសុក្រឹត (ផ្កាដែលគ្មានកញ្ចុំកេសរឈ្មោល ឬគ្មានកញ្ចុំកេសរញី)
- incomplete flower /ɪnkəmˈpliːt ˈflaʊə/ [n] ផ្កាមិនពេញលេញ (ផ្កាដែលគ្មានត្របក ស្រទាប់ កញ្ចុំកេសរញី ឬកញ្ចុំកេសរឈ្មោល)
- irregular flower /ɪˈrɛgjʊlə ˈflaʊə/ [n] ផ្កាគ្មានរបៀប
- perfect flower /ˈpəːfɪkt ˈflaʊə/ [n] ផ្កាពេញលេញ, ផ្កាឥតខ្ចោះ (ផ្ការបស់ពួករុក្ខជាតិគ្រាប់ជិតដែលមានកេសរឈ្មោល និងកេសរញី)
- pistillate flower /ˈpɪstɪlət ˈflaʊə/ [n] ផ្កាញី
- prickly chaff flower /ˈprɪkli tʃɑːf ˈflaʊə/ [n] ស្មៅអណ្ដាតគោ (ឈ្មោះវិទ្យាសាស្ត្រ *Achyranthes aspera*)
- regular flower /ˈrɛgjʊlə ˈflaʊə/ [n] ផ្កាមានរបៀប
- staminate flower /ˈstamɪnət ˈflaʊə/ [n] ផ្កាឈ្មោល
- stinking passion flower /stɪŋkɪŋ ˈpaʃ(ə)n ˈflaʊə/ [n] សាវម៉ាវព្រៃ (ឈ្មោះវិទ្យាសាស្ត្រ *Passiflora foetida*)
- symmetry of flower /ˈsɪmɪtri ɒv ˈflaʊə/ [n] ប្រភេទផ្កាស៊ីមេទ្រី, ភាពដូចគ្នារបស់ផ្កា
- unisexual flower /juːnɪˈsɛkʃʊəl ˈflaʊə/ [n] (សទិសន័យ៖ imperfect flower) ផ្កាមានភេទតែមួយ
- zygomorphic flower /ˌzʌɪgə(ʊ)ˈmɔːfɪk ˈflaʊə/ [n] ផ្កាដែលគ្មានទម្រង់ដូចគ្នា

**flowering** /ˈflaʊərɪŋ/ [n] (សទិសន័យ៖ flowering period) ដំណាក់ផ្កា, រដូវចេញផ្កា, ការចេញផ្កា (ដំណើរការដែលលម្អងបែកហើយអាចធ្វើពហុពលកម្មជាមួយកេសរញីនៅក្នុងដំណាំស្រូវ)

- diffuse flowering /dɪˈfjuːz ˈflaʊərɪŋ/ [n] ការចេញផ្កាពេញមួយឆ្នាំ, ការចេញផ្កាខុសរដូវ ( ការចេញផ្កាពេញមួយឆ្នាំ ឬចេញផ្កាខុសរដូវ។ ពាក្យផ្ទុយនឹង Gregarious flowering (ចេញផ្កាជាក្រុម)។)
- synchronised flowering /ˈsɪŋkrənʌɪzd ˈflaʊərɪŋ/ [n] សមកាលកម្មចេញផ្កា, ការចេញផ្កាស្រុះ (ដំណើរការដែលក្នុងនោះ ការចេញផ្ការបស់រុក្ខជាតិ ត្រូវបានប្រព្រឹត្តទៅដំណាលគ្នា)

**flowerpot** /ˈflaʊəpɒt/ [n] ថូដាំផ្កា

**flowery** /ˈflaʊəri/ [adj] សម្បូរដោយផ្កា, ដែលមានផ្កាពាសពេញ

**fluctuate** /ˈflʌktjʊeɪt/ [v] ពូនចុះពូនឡើង, ប្រែប្រួល

**fluid** /ˈfluːɪd/ [n] (សទិសន័យ៖ fluid body) សន្ទនីយ, វត្ថុរាវ, អង្គធាតុរាវ
- amniotic fluid /amnɪˈɒtɪk ˈfluːɪd/ [n] ទឹកភ្លោះ
- seminal fluid /ˈsɛmɪn(ə)l ˈfluːɪd/ [n] ទឹកពូជ (សារធាតុរាវដែលស្ពែម៉ាតូសូអ៊ីតនៅក្នុងនោះ)
- spinal fluid /ˈspʌɪn(ə)l ˈfluːɪd/ [n] ទឹកស្រោបខួរឆ្អឹងខ្នង

**fluke** /fluːk/ [n] ដង្កូវក្នុងថ្លើម, ព្រូនមានរាងដូចស្លឹកឈើ

**fluorescence** /flʊəˈrɛs(ə)ns/ [n] ចំណាំងពន្លឺ
- fluorescence microscopy /flʊəˈrɛs(ə)ns mʌɪˈkrɒskəpi/ [n] បច្ចេកទេសអតិសុខុមទស្សន៍ចំណាំងពណ៌ (វិធីប្រើអតិសុខុមទស្សន៍ដែលមានការប្រើល័ក្ខចំណាំង ដើម្បីកំណត់ពីទម្រង់មួយចំនួន (ឧ. អាស៊ីតនុយក្លេអ៊ិច) ដែលបន្ទាប់មក គេអាចមើលឃើញដោយអតិសុខុមទស្សន៍អ៊ុលត្រាស្វាយ)

**Fluorine (F)** /ˈflʊəriːn/ [n] ភ្លុយអរ (និមិត្តសញ្ញាគីមី F)

**flush** /flʌʃ/ [n]
១. ដីសើមជម្រាលភ្នំ
២. បង្ហូរ និងវាយសាយភ្លាមៗ, ក្រហមមុខឬក

**fluted giant clam** /ˈfluːtɪd ˈdʒʌɪənt klam/ [n] គ្រុំយក្ស (ឈ្មោះវិទ្យាសាស្ត្រ *Tridacna squamosa*)

**fluting** /fluːtɪŋ/ [n] គល់ប្រឹង (ផ្នែកគល់ដើមឈើដែលមានរាងមិនជារង្វង់ ដែលជាញឹយៗបង្កើតទៅជាឫសទប់ (ចន្ទល់) ពោលគឺ ដូចជាក្តារបន្ទះដុះត្រង់ទៅលើនៃ ផ្នែកខាងលើរបស់ឫស ដែលផ្តល់ជាទម្រដល់ដើមឈើ។ ឫសចន្ទល់ និងប្រឹងមានលក្ខណៈតពូជទៅតាមកម្រិតផ្សេងៗគ្នា។ ជាធម្មតា វាជាលក្ខណៈមួយដែលគេមិនចង់បានក្នុងការបង្កាត់ពូជឈើព្រៃទេ។)

**fluviraption** /fluːˌvʌɪˈreɪpʃ(ə)n/ [n] ការផ្តាច់ដីដោយទឹកហូរ

**flux** /flʌks/ [n] រំហូរថាមពល, រំហូររូបធាតុ (ភ្លុច)

**fly** /flʌɪ/ [n] រុយ

**fly wheel** /flʌɪ wiːl/ [n] កង់យោងចលករ (កង់រង្វិលនៃចលករសម្រាប់រក្សាថាមពលស៊ីនេទិច)

**foal** /fəʊl/ [n] កូនសេះ

**foal** /fəʊl/ [v] កើតកូន, ទម្លាក់កូន

**focus** /ˈfəʊkəs/ [v] កែតម្រូវ (ផ្តោតទៅលើចំណុចមួយ)

**fodder** /ˈfɒdə/ [n] ស្មៅចំណីសត្វ, ចំណីសត្វ (សារធាតុទាំងឡាយ ដែលសត្វពាហនៈ និងសត្វព្រៃអាចស៊ីបាន)
- fodder yied /ˈfɒdə jiːld/ [n] ទិន្នផលចំណីសត្វ (អនុផលដែលគេផ្តល់ឱ្យសត្វស៊ីជាចំណីដូចជា ដើមសណ្តែក ពោតជាដើម)
- green fodder /griːn ˈfɒdə/ [n] ស្មៅស្រស់ (ចំណីស្រស់សម្រាប់សត្វចិញ្ចឹមដូចជា ស្មៅ ផ្លី ត្រកួនជាដើម)

**fog** /fɒg/ [n] អ័ព្ទ
- acid fog /ˈasɪd fɒg/ [n] អ័ព្ទអាស៊ីត
- atmospheric fog /atməsˈfɛrɪk fɒg/ [n] អ័ព្ទបរិយាកាស
- coastal fog /ˈkəʊstl fɒg/ [n] អ័ព្ទឆ្នេរ
- cold fog /kəʊld fɒg/ [n] អ័ព្ទត្រជាក់
- evaporation fog /ɪˌvapəˈreɪʃ(ə)n fɒg/ [n] អ័ព្ទចំហាយ
- frontal fog /ˈfrʌnt(ə)l fɒg/ [n] អ័ព្ទខាងមុខ
- maritime fog /ˈmarɪtʌɪm fɒg/ [n] អ័ព្ទសមុទ្រ
- radiation fog /reɪdɪˈeɪʃ(ə)n fɒg/ [n] អ័ព្ទរំភាយរស្មី
- sea fog /siː fɒg/ [n] អ័ព្ទសមុទ្រ
- steam fog /stiːm fɒg/ [n] អ័ព្ទចំហាយ
- upslope fog /ˈʌpsləʊp fɒg/ [n] អ័ព្ទចំណោត
- warm fog /wɔːm fɒg/ [n] អ័ព្ទក្តៅ
- wet fog /wɛt fɒg/ [n] អ័ព្ទសើម
- recumbent fold /rɪˈkʌmb(ə)nt fəʊld/ [n] ស្រទាប់ដែលក្រាមពីលើ

**folding** /fəʊldɪŋ/ [n] ពំនើងផ្នត់
- minute folding /ˈmɪnɪt fəʊldɪŋ/ [n] ការធ្វើឱ្យស្រទាប់សិលារពើតរពើងជាំទឹករលក ឬជាផ្នត់ទឹករលក

**foley catheter** /ˈfəʊli ˈkaθətə/ [n] ផ្តោកត្រងទឹកនោម

**foliage** /ˈfəʊlɪɪdʒ/ [n] ស្លឹកឈើ (ទាំងដើម)

**follicle** /ˈfɒlɪk(ə)l/ [n]
១. (ចំពោះរុក្ខជាតិ) ផូលីគុល (ប្រហោង ឬថង់តូចស្ថិតនៅក្នុងអវ្ស៊ុលដែលជាកន្លែងកាម៉ែតញីលូតលាស់), ផ្លែហោ (ផ្នែកស្ងួតដែលកើតឡើងដោយការបែកនៃថតផ្លែដើម្បីបញ្ចេញគ្រាប់របស់វា)
២. (ចំពោះសត្វ) ផូលីគុល (ពងដែលកើតចេញពេញរូបរាងនៅក្នុងស្រោមអូវ៉ែ), រន្ធគល់សក់

- hair follicle /hɛː ˈfɒlɪk(ə)l/ [n] គល់រោម

**fontanel** /ˌfɒntəˈnɛl/ [n] បង្ហើយក្បាល

**food and nutrition security** /fuːd and njʊˈtrɪʃ(ə)n sɪˈkjʊərɪti/ [n] សន្តិសុខស្បៀង និងអាហារូបត្ថម្ភ (សន្តិសុខស្បៀងកើតមាននៅពេលដែលប្រជាពលរដ្ឋគ្រប់រូបមានលទ្ធភាពទាំងផ្នែករូបវ័ន្ត និងផ្នែកសេដ្ឋកិច្ចក្នុងការទទួលបានស្បៀងអាហារមានសុវត្ថិភាព និងមានជីវជាតិគ្រប់គ្រាន់ដើម្បីបំពេញតម្រូវការរបបអាហារ និងចំណង់ចំណូលចិត្តនៅគ្រប់ពេលវេលាទាំងអស់សម្រាប់ជីវិតរស់នៅយ៉ាងសកម្ម និងមានសុខភាពមាំមួន។ គណៈកម្មាធិការទទួលបន្ទុកសន្តិសុខស្បៀងពិភពលោក ខែកក្កដា ឆ្នាំ ២០១២។)

**food** /fuːd/ [n] អាហារ

- organic food /ɔːˈganɪk fuːd/ [n] អាហារសរីរាង្គ
- staple food /ˈsteɪp(ə)l fuːd/ [n] អាហារមូលដ្ឋាន (អាហារទាំងអស់នោះ តាមធម្មតាជាអាហារនៅក្នុងក្រុមកាបូអ៊ីដ្រាត (ពពួកម្សៅ) ដែលបង្កើតជាមូលដ្ឋានរបបអាហារមួយទៅតាមចំណង់ចំណូលចិត្ត និងប្រពៃណីវប្បធម៌នៅក្នុងប្រជាជាតិមួយ ឬតំបន់មួយ។ នៅទូទាំងអាស៊ីអាគ្នេយ៍ អង្ករ ឬបាយគឺជាអាហារមូលដ្ឋានមួយដ៏លើសលប់។ នៅសង្គមផ្សេងៗទៀត ពោត ស្រូវសាឡី ឬដំណាំជាមើម ជាអាហារមូលដ្ឋានមួយដ៏សំខាន់ផងដែរ។)
- supplementary food /ˌsʌplɪˈmɛnt(ə)ri fuːd/ [n] អាហារបំប៉ន
- use and utilization of food /juːs ənd juːtɪlʌɪˈzeɪʃ(ə)n ɒv fuːd/ [n] ការប្រើប្រាស់ស្បៀង
- wild food /wʌɪld fuːd/ [n] អាហារព្រៃ
- food chain /fuːd tʃeɪn/ [n] ខ្សែអាហារ
- food access gap /fuːd ˈaksɛs gap/ [n] ភាពខ្វះចន្លោះក្នុងការទទួលបានស្បៀង (ភាពខ្វះចន្លោះក្នុងការទទួលបានស្បៀង គឺវាស់វែងស្ថានភាពនៃគ្រួសារមួយដែលអាចនឹងឆ្លើយតបទៅនឹងកម្រិត បរិភោគអប្បបរមាដែលតម្រូវឱ្យមានសម្រាប់របបអាហារគ្រប់គ្រាន់មួយ។ ភាពផ្សេងៗគ្នារវាងអ្វីដែលគ្រួសារអាច ទទួលបានធៀបទៅនឹងកម្រិតបរិភោគអប្បបរមា គឺចង់និយាយសំដៅលើគំលាតនៃការទទួលស្បៀង។)
- Food and Drug Administration [n] នាយកដ្ឋានភោជនភណ្ឌ និងឱសថូបករណ៍
- food assistance /fuːd əˈsɪst(ə)ns/ [n] (សទិសន័យ ៖ food aid) ជំនួយជាស្បៀង (ជំនួយស្បៀងអាហារ គឺសំដៅទៅលើសកម្មភាពរួមនៃកម្មវិធីស្បៀងអាហារពិភពលោក ហើយរួមមានជំនួយជាស្បៀង ស្បៀងពលកម្ម កម្មវិធីផ្តល់សាច់ប្រាក់ និងឥណទាន កម្មវិធីធានារ៉ាប់រង និងកម្មវិធីអាហារូបត្ថម្ភ។)
- food balance sheet /fuːd ˈbal(ə)ns ʃiːt/ / [n] តារាងតុល្យភាពស្បៀង (តារាងតុល្យភាពស្បៀង គឺជាឥណទាននៃភាពមានស្បៀង ធៀបទៅនឹងតម្រូវការស្បៀងដែលបានជ្រើសរើស)
- food chemistry /fuːd ˈkɛmɪstri/ [n] គីមីចំណីអាហារ

**food consumption** /fuːd kənˈsʌm(p)ʃ(ə)n/ [n] ការបឹតស្រូបស្បៀង, ការប្រើប្រាស់ស្បៀង

- food consumption score /fuːd kənˈsʌm(p)ʃ(ə)n skɔː/ [n] កម្រិតនៃការប្រើប្រាស់ស្បៀង (សូចនាករតំណាងនៃការប្រើប្រាស់ស្បៀង ដែលពិចារណាទាំងថាមពល (កាឡូរី) និងសារធាតុចិញ្ចឹម (ម៉ាក្រូ និងមីក្រូសារជាតិ) តម្លៃនៃស្បៀងដែលគ្រួសារបរិភោគ។ វាត្រូវបានគណនាដោយផ្អែកទៅលើvolume និងប្រភេទនៃចំណីអាហារដែលបានបរិភោគ និងមុខចំណីអាហារមួយមុខក្នុងរយៈពេល៧ថ្ងៃ។)
- food consumption distribution /fuːd kənˈsʌm(p)ʃ(ə)n dɪstrɪˈbjuːʃ(ə)n/ [n] របាយនៃការប្រើប្រាស់ស្បៀង ឬបរិភោគចំណីអាហារ (របាយនៃការប្រើប្រាស់ស្បៀង ឬបរិភោគចំណីអាហារ គឺចង់និយាយសំដៅទៅដល់ការប្រែប្រួល ឬការផ្លាស់ប្តូរ ក្នុងការប្រើប្រាស់ស្បៀង ឬបរិភោគចំណីអាហារនៅក្នុងស្រទាប់ប្រជាជន។ វាឆ្លុះបញ្ចាំងអំពីសភាពផ្សេងៗគ្នាក្នុងការប្រើប្រាស់ស្បៀង ឬបរិភោគចំណីអាហារដោយសារមកពីកត្តាសង្គមសេដ្ឋកិច្ច (ដូចជាប្រាក់ចំណូល ភាពក្រីក្រ) និង ឬ ឬមួយមកពីកត្តាជីវសាស្ត្រ (ដូចជា ភេទ អាយុ កម្រិតនៃទម្ងន់រាងកាយ និងកម្រិតនៃសកម្មភាពរបស់រាង្គកាយ។)
- food consumption gap /fuːd kənˈsʌm(p)ʃ(ə)n gap/ [n] ភាពខ្វះចន្លោះ ឬគម្លាតក្នុងការប្រើប្រាស់ស្បៀង ឬបរិភោគចំណីអាហារ (ភាពខុសៗគ្នារវាងកម្រិតនៃការបរិភោគចំណីអាហារដែលត្រូវបានគេតម្រូវឱ្យបរិភោគ ដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការអាហារូបត្ថម្ភ និងឆ្លើយតបទៅនឹងការបរិភោគអាហារត្រឹមត្រូវជាក់ស្តែង)

- food consumption pattern /fuːd kənˈsʌm(p)ʃ(ə)n ˈpat(ə)n/ [n] គំរូនៃការប្រើប្រាស់ស្បៀង ឬការបរិភោគចំណីអាហារ (សមាសភាព និងចំនួនដងនៃការបរិភោគចំណីអាហារ នៅក្នុងអំឡុងរយៈពេលយោងជាកំណត់មួយ ដោយវាស់វែងគិតជា ក្រាម ឬគីឡូកាឡូរី ឬក្នុង១ថ្ងៃ)

**food deprivation** /fuːd dɛprɪˈveɪʃ(ə)n/ [n] ការបង្អត់អាហារ (ការបង្អត់អាហារគឺចង់និយាយសំដៅទៅរកលក្ខខណ្ឌរបស់ប្រជាជន ដែលការបរិភោគចំណីអាហាររបស់គាត់គឺបន្តជាប់គ្នានៅក្រោមអ្វីដែលរាងកាយត្រូវការ។ រង្វាស់របស់អង្គការ FAO ទៅលើភាពអត់ឃ្លានអាហារ គឺផ្អែកទៅលើរបាយនៃការបរិភោគចំណីអាហារដែលបញ្ចុះជាលក្ខខណ្ឌនៃថាមពលក្នុងរបបអាហារ។ ភាពអត់ឃ្លានត្រូវបានវាស់វែងដោយ ក) អត្រាប្រេវ៉ាឡង់នៃភាពខ្សត់ខ្សោយនូវសារធាតុចិញ្ចឹម និង ខ) ចំនួនសរុបនៃកង្វះសារធាតុចិញ្ចឹមនៅក្នុងចំណោមប្រជាជនសរុបទាំងអស់។)

**food deprived** /fuːd dɪˈprʌɪvd/ [adj] សូមមើលពាក្យ៖ undernourished

**food expenditure share** /fuːd ɪkˈspɛndɪtʃə ʃɛː/ [n] ចំណែកដែលត្រូវចំណាយទៅលើស្បៀងអាហារ (សមាមាត្រនៃការចំណាយសរុបរបស់គ្រួសារនីមួយៗដែលត្រូវបានចំណាយទៅលើស្បៀងអាហារ)

**food for work** /fuːd fɛ wəːk/ [n] ស្បៀងពលកម្ម (ជាវិធីម្យ៉ាងសម្រាប់ធ្វើការចែកចាយជំនួយជាស្បៀង)

**food insecurity** /fuːd ˌɪnsɪˈkjɔːrɪti/ [n] អសន្តិសុខស្បៀង

- chronic food insecurity /ˈkrɒnɪk fuːd ˌɪnsɪˈkjɔːrɪti/ [n] អសន្តិសុខស្បៀងរ៉ាំរ៉ៃ
- household food insecurity /ˈhaʊshəʊld fuːd ˌɪnsɪˈkjɔːrɪti/ [n] អសន្តិសុខស្បៀងកម្រិតគ្រួសារ (ការពុំមានលទ្ធភាពទទួលការផ្គត់ផ្គង់ស្បៀងបានគ្រប់គ្រាន់របស់គ្រួសារ ដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការស្បៀងរបស់សមាជិកទាំងអស់នៅក្នុងគ្រួសារទាំងអស់សម្រាប់រយៈពេលពេញមួយឆ្នាំ)
- transitory food insecurity /ˈtransɪt(ə)ri fuːd ˌɪnsɪˈkjɔːrɪti/ [n] អសន្តិសុខស្បៀងបណ្តោះអាសន្ន

**food restriction** /fuːd rɪˈstrɪkʃ(ə)n/ [n] ការដាក់កម្រិតចំណីអាហារ (ការកំហិតណាមួយដែលដាក់ទៅលើការលក់ ឬការបរិភោគស្បៀងដោយហេតុផលណាមួយ។ សន្និទានភាព ចំពោះការដាក់កំហិតទៅលើចំណីអាហារបែបនេះអាចនឹងផ្អែកទៅលើការបារម្ភពីផ្នែកជួញដូរសុខភាពសាធារណៈ ឬវប្បធម៌ប្រពៃណី។)

**food security** /fuːd sɪˈkjʊərɪti/ [n] សន្តិសុខស្បៀង, ស្ថិរភាពស្បៀង

- household food security /ˈhaʊshəʊld fuːd sɪˈkjʊərɪti/ [n] សន្តិសុខស្បៀងនៅកម្រិតគ្រួសារ
- individual food security /ɪndɪˈvɪdʒʊ(ə)l fuːd sɪˈkjʊərɪti/ [n] សន្តិសុខស្បៀងកម្រិតបុគ្គល
- macro level food security /ˈmakrəʊ ˈlɛv(ə)l fuːd sɪˈkjʊərɪti/ [n] សូមមើលពាក្យ៖ national food security
- national food security /ˈnaʃ(ə)n(ə)l fuːd sɪˈkjʊərɪti/ [n] (សទិសន័យ៖ macro level food security) សន្តិសុខស្បៀងនៅកម្រិតថ្នាក់ជាតិ

**food supplementation** /fuːd sʌplɪmɛnˈteɪʃ(ə)n/ [n] ការផ្តល់បន្ថែមស្បៀងអាហារ (ក៏ត្រូវបានគេដឹងផងដែរថាជាការបញ្ចូលមីក្រូសារជាតិទៅក្នុងអាហារ គឺសំដៅដល់ការអនុវត្តន៍ក្នុងការបង្កើនបន្ទុកអាហារូបត្ថម្ភនៃចំណីអាហារដោយបន្ថែមនូវពពួកមីក្រូសារជាតិផ្សេងៗ (រ៉ែខនិជ និងវីតាមីន) អាមីណូអាស៊ីត អង់ស៊ីម និង/ឬសារធាតុចិញ្ចឹមផ្សេងៗទៀត។ អំបិលអ៊ីយ៉ូដគឺជាគំរូឧទាហរណ៍មួយសាមញ្ញបំផុត។)

**food taboo** /fuːd təˈbuː/ [n] ការតម ឬតំណមអាហារ (ការតមតាមបែបសាសនា ប្រពៃណី ឬក៏អនាម័យប្រឆាំងទៅនឹងការកាន់ វាល់ ឬក៏បរិភោគស្បៀងជាក់លាក់ពិសេសណាមួយ)

**food utilization** /fuːd juːtɪlʌɪˈzeɪʃ(ə)n/ [n] ការបឺតស្រូបស្បៀង ឬអាហារ (១. ការប្រើប្រាស់ស្បៀងរបស់គ្រួសារដែលពួកគេមានលទ្ធភាពអាចទទួលស្បៀងបាន គឺរាប់បញ្ចូលទាំងស្បៀងទាំងអស់ដែលកាន់ រៀបចំ និងវិធីបរិភោគ អនាម័យរាងកាយ និងអនាម័យលំនៅស្ថានបរិស្ថាន និងការបញ្ចេញចោលកាកសំណល់។ វាក៏រាប់បញ្ចូលផងដែរអំពីរបៀបដែលស្បៀងត្រូវធ្វើការបែងចែកនៅក្នុងគ្រួសារមួយ។ ២. លទ្ធភាពរបស់បុគ្គលម្នាក់ៗក្នុងការបឺតស្រូប និងធ្វើមេតាបូលីសសារធាតុចិញ្ចឹម សក្តិសិទ្ធភាពក្នុងការបំលែងស្បៀងដោយរាងកាយ។ ចំណុចនេះជារឿយៗតែងតែត្រូវពឹងផ្អែករបស់បុគ្គលផ្ទាល់។)

**foot** /fʊt/ [n] (ពហុវចនៈ៖ feet) ជើង, គល់

**foot and mouth disease** /fʊt ənd maʊθ dɪˈziːz/ [n] ជំងឺអុតក្ដាម

**footprint** /ˈfʊtprɪnt/ [n] ដានជើងសត្វ

**forage** /ˈfɒrɪdʒ/ [n] សូមមើលពាក្យ៖ forage crop

**forage crop station** /ˈfɒrɪdʒ krɒp ˈsteɪʃ(ə)n/ [n] ស្ថានីយដំណាំចំណីសត្វ

**foramen** /fəˈreɪmɛn/ [n] ប្រហោង

**forcep** /ˈɑːtəri ˈfɔːsɛp/ [n] ប្រដាប់កៀប ដែលប្រើក្នុងពេលវះកាត់

- **artery forcep** /ˈɑːtəri ˈfɔːsɛp/ [n] ប្រដាប់កៀបសរសៃឈាម កុំឱ្យឈាមហូរចេញ នៅពេលវះកាត់

**forceps** /ˈfɔːsɪps/ [n] ដង្កាប់, ដង្កៀប (ឃាត់ឈាម)

**forecast** /ˈfɔːkɑːst/ [n] ការព្យាករ

- weather forecast /ˈwɛðə ˈfɔːkɑːst/ [n] ការព្យាករធាតុអាកាស

**forecast analysis** /ˈfɔːkɑːst əˈnalɪsɪs/ [n] ការវិភាគលើការព្យាករណ៍ (ការវាយតម្លៃដោយសម្លឹងមើលទៅខាងមុខ ដោយផ្អែកទៅលើទិន្នន័យដែលមាន ឬអាចរកបាន ដែលទិន្នន័យមានការព្យាករណ៍អំពីឱកាសនាពេលអនាគត និងព្រឹត្តិការណ៍តក់ស្លុត ដែលនៅក្នុងនោះស្ថានការណ៍ទំនងជាវិវត្តន៍ទៅរក)

**forefoot** /ˈfɔːfʊt/ [n] ជើងមុខ

**forehead** /ˈfɔːhɛd/ [n] ថ្ងាស

**foreign direct investment (FDI)** /ˈfɒrɪn dɪˈrɛkt ɪnˈvɛs(t)m(ə)nt/ [n] ការវិនិយោគដោយផ្ទាល់ពីបរទេស

**forespore** /'fɔːspɔː/ [n] ស្ប៉ូខ្ចី

**forest** /ˈfɒrɪst/ [n] ព្រៃ, ព្រៃឈើ

- aesthetic forest /iːsˈθɛtɪk ˈfɒrɪst/ [n] ព្រៃសម្រាប់សម្រាកកំសាន្ត
- commercial forest /kəˈməːʃ(ə)l ˈfɒrɪst/ [n] ព្រៃពាណិជ្ជកម្ម
- Community Forest (CF) /kəˈmjuːnɪti ˈfɒrɪst/ [n] សហគមន៍ព្រៃឈើ
- coniferous forest /kəˈnɪfərəs ˈfɒrɪst/ [n] ព្រៃបៃតងជានិច្ច (ដែលមានពពួករុក្ខជាតិស្លឹកម្ជុល ដូចជាស្រល់), ព្រៃកូនីហ្វែ
- deciduous forest /dɪˈsɪdjʊəs ˈfɒrɪst/ [n] ព្រៃជ្រុះស្លឹក, ព្រៃជ្រុះស្លឹកប្រចាំឆ្នាំ, ព្រៃល្បោះ (ជាព្រៃ ដែលមានដើមឈើជម្រុះស្លឹករបស់វាជាធម្មជាតិ។ ជារុក្ខជាតិ ដែលជុះលូតលាស់រយៈពេលច្រើនឆ្នាំ។ ព្រៃ ដែលជម្រុះស្លឹករបស់វាជារៀងរាល់ឆ្នាំ នៅរដូវត្រជាក់ ឬរដូវប្រាំង ផ្ទុយពីព្រៃបៃតងជានិច្ច។ រុក្ខជាតិ នៃតំបន់អាកាសធាតុបង្គួរ ប្រភេទឈើខ្លឹមដែលជម្រុះស្លឹករបស់វានៅពេលត្រជាក់។)
- dense forest /dɛns ˈfɒrɪst/ [n] ព្រៃស្ដុក
- dry deciduous forest /drʌɪ dɪˈsɪdjʊəs ˈfɒrɪst/ [n] ១. ប្រភេទព្រៃល្បោះ ដែលមិនសូវមានភ្លៀង
  ២. ព្រៃល្បោះ ដែលនៅតំបន់រាំងស្ងួត ឬ ពាក់កណ្ដាលរាំងស្ងួត
- evergreen broadleaved forest /ˈɛvəgriːn brɔːdˈliːvd ˈfɒrɪst/ [n] ព្រៃស្រោងបៃតងជានិច្ច
- evergreen forest /ˈɛvəgriːn ˈfɒrɪst/ [n] ព្រៃបៃតងជានិច្ច, ប្រភេទព្រៃ ដែលមានដើមឈើ អាចរក្សាស្លឹករបស់ពួកវានៅក្នុងរយៈពេលពេញមួយឆ្នាំ
- flooded forest /flʌdɪd ˈfɒrɪst/ [n] ព្រៃលិចទឹក
- forest disturbed by road /ˈfɒrɪst dɪˈstəːbd bʌɪ rəʊd/ [n] ព្រៃរុករានដោយមានផ្លូវកាត់
- forest disturbed by village /ˈfɒrɪst dɪˈstəːbd bʌɪ ˈvɪlɪdʒ/ [n] ព្រៃរុករានដោយមានភូមិកាត់
- high forest /hʌɪ ˈfɒrɪst/ [n] ព្រៃស្រោង (ព្រៃមានដើមឈើខ្ពស់ ដែលដុះចេញពីកូនឈើតូចៗ និងលូតលាស់ជាដើមឈើខ្ពស់ និងកន្សោមស្លឹកជិតៗគ្នា)
- inhomogeneous forest /ˌɪnhɒmə(ʊ)ˈdʒiːnɪəs ˈfɒrɪst/ [n] ព្រៃធម្មជាតិ
- Inundated forest /ˈɪnʌndeɪtɪd ˈfɒrɪst/ [n] ព្រៃរនាម, ព្រៃលិចទឹក (កំរាលព្រៃត្រូវបានគ្របដណ្ដប់ដោយទឹក ឧទាហរណ៍ ព្រៃលិចទឹកនៅកម្ពុជា ដូចជាព្រៃកោងកាង និង ព្រៃលិចទឹកជុំវិញបឹងទន្លេសាប)
- less disturbed forest /lɛs dɪˈstəːbd ˈfɒrɪst/ [n] ព្រៃមានការរុករានតិច
- mangrove forest /ˈmaŋgrəʊv ˈfɒrɪst/ [n] ព្រៃកោងកាង
- man-made forest /man-meɪd ˈfɒrɪst/ [n] ព្រៃដាំ
- mixed forest /mɪkst ˈfɒrɪst/ [n] ព្រៃចម្រុះ
- moist forest /mɔɪst ˈfɒrɪst/ [n] ព្រៃស្ដុក
- monsoon forest /mɒnˈsuːn ˈfɒrɪst/ [n] ព្រៃមូសុង
- natural forest /ˈnatʃ(ə)r(ə)l ˈfɒrɪst/ [n] ព្រៃធម្មជាតិ
- plantation forest /planˈteɪʃ(ə)n ˈfɒrɪst/ [n] ព្រៃដាំ
- primary forest /prʌɪm(ə)ri ˈfɒrɪst/ [n] ព្រៃស្ដុក

- protected forest /prəˈtɛktid ˈfɒrɪst/ [n] ព្រៃការពារ
- rain forest /reɪn ˈfɒrɪst/ [n] ព្រៃរងទឹកភ្លៀង
- recreation forest /ˌrɛkrɪˈeɪʃ(ə)n ˈfɒrɪst/ [n] ព្រៃសម្រាប់សម្រាកកំសាន្ត
- reserve forest /rɪˈzəːv ˈfɒrɪst/ [n] ព្រៃបម្រុងទុក
- riparian forest /rʌɪˈpɛːrɪən ˈfɒrɪst/ [n] ប្រភេទព្រៃដែលដុះនៅតំបន់ដីសើម (ឧទាហរណ៍តាមដងទន្លេ ស្ទឹង តំបន់ទឹកជោរ)
- secondary forest /ˈsɛk(ə)nd(ə)ri ˈfɒrɪst/ [n] ព្រៃដុះឡើងវិញ, ព្រៃបន្ទាប់
- semi-evergreen forest /ˌsɛmiˈɛvəgriːn ˈfɒrɪst/ [n] ព្រៃពាក់កណ្ដាលស្រោង (១. ព្រៃ ដែលមានដើមឈើដុះលាយគ្នាជាព្រៃស្រោង និងព្រៃល្បោះ ឬជម្រុះស្លឹកដុះលាយគ្នា ២. ព្រៃជម្រុះ ស្លឹក រុក្ខជាតិជម្រុះស្លឹករបស់វាជារៀងរាល់ឆ្នាំ)
- tidal forest /ˈtʌɪd(ə)l ˈfɒrɪst/ [n] ព្រៃទឹកជោរ
- tropical forest /ˈtrɒpɪk(ə)l ˈfɒrɪst/ [n] ព្រៃត្រូពិច

**forester** /ˈfɒrɪstə/ [n] អ្នកថែរក្សាព្រៃឈើ, មេព្រៃ

**forestry** /ˈfɒrɪstri/ [n] (សទិសន័យ៖ forestry profession) រុក្ខាប្រមាញ់, រុក្ខកម្ម, វិទ្យាសាស្ត្រព្រៃឈើ
- community forestry /kəˈmjuːnɪti ˈfɒrɪstri/ [n] ព្រៃឈើសហគមន៍
- farm forestry /fɑːm ˈfɒrɪstri/ [n]
  ១. សូមមើលពាក្យ៖ agroforestry
  ២. ការអនុវត្តការគ្រប់គ្រងព្រៃឈើ នៅលើដីភូមិ ជាទូទៅមានរួមបញ្ចូលតិច ឬច្រើននូវការអនុវត្តក្នុងកសិដ្ឋាន)
- industrial forestry /ɪnˈdʌstrɪəl ˈfɒrɪstri/ [n] ឧស្សាហកម្មព្រៃឈើ

**Forestry Administration (FA)** /ˈfɒrɪstri ədmɪnɪˈstreɪʃ(ə)n/ [n] រដ្ឋបាលព្រៃឈើ

**forestry profession** /ˈfɒrɪstri prəˈfɛʃ(ə)n/ [n] សូមមើលពាក្យ៖ forestry

**fork** /fɔːk/ [n] ត្រាក់ទ័រតូចៗសម្រាប់លើករបស់ធ្ងន់ៗ, សម (ស្លាបព្រា)

**forked fringe-rush** /fɔːkt frɪn(d)ʒ rʌʃ/ [n] កក់ភ្នែកក្ដាមធំ (ឈ្មោះវិទ្យាសាស្ត្រ *Fimbristylis dischotoma*)

**forking** /fɔːkɪŋ/ [adj] បែកចំពាម (ដើម)

**form** /fɔːm/ [n] រាង, ទ្រង់ទ្រាយ, ទម្រង់
- definitive form /dɪˈfɪnɪtɪv fɔːm/ [n] ទម្រង់ពេញលេញ

**formaldehyde** /fɔːˈmaldɪhʌɪd/ [n] ផរម៉ាល់ដេអ៊ីត (ឧស្ម័នប្រើសម្រាប់រម្ងាប់មេរោគ)

**formalin** /ˈfɔːm(ə)lɪn/ [n] ផរម៉ាលីន (ឧស្ម័នលាយជាមួយទឹកសម្រាប់រម្ងាប់មេរោគ)

**formation** /fɔːˈmeɪʃ(ə)n/ [n] ការកកើត
- eluvial-diluvial formation /ɪluːvɪəl dʌɪˈl(j)uːvɪəl fɔːˈmeɪʃ(ə)n/ [n] ការកកើតលាយឡំគ្នាពីវត្ថុធាតុសំណល់ និងល្បាប់ទន្លេ
- mull-like humus formation /mʌllʌɪk ˈhjuːməs fɔːˈmeɪʃ(ə)n/ [n] ការកកើតនៃមមោកល្អក្នុងដី
- peat formation /piːt fɔːˈmeɪʃ(ə)n/ [n] ការប្រែក្លាយជាពើក, ការវិវត្តន៍នៃពើកនៅស្រទាប់លើនៃដី
- soil formation /sɔɪl fɔːˈmeɪʃ(ə)n/ [n] ការកកើតនៃដី
- water-bearing formation /ˈwɔːtə ˈbɛːrɪŋ fɔːˈmeɪʃ(ə)n/ [n] សូមមើលពាក្យ៖ aquifer

**formicarium** /ˌfɔːmɪˈkɛːrɪəm/ [n] សម្បុកស្រមោចសិប្បនិម្មិត

**formless** /ˈfɔːmləs/ [adj] ដែលគ្មានរូបរាង

**formula** /ˈfɔːmjʊlə/ [n] រូបមន្ត, និម្មិតសញ្ញា
- chemical formula /ˈkɛmɪk(ə)l ˈfɔːmjʊlə/ [n] រូបមន្តគីមី
- line formula /lʌɪn ˈfɔːmjʊlə/ [n] រូបមន្តស្នើរលោត
- molecular formula /məˈlɛkjʊlə ˈfɔːmjʊlə/ [n] រូបមន្ត, ម៉ូលេគុល

**fossil** /ˈfɒs(ə)l/ [n] ផូស៊ីល (ស្នាម ឬសំណល់របស់ភាវរស់ដែលមានជីវិតនៅកាលពីជំនាន់មុនយូរណាស់មកហើយ ដែលកើតក្នុងថ្ម)។
- chemical fossils /ˈkɛmɪk(ə)l ˈfɒs(ə)lz/ [n pl] ផូស៊ីលគីមី

**fossilization** /fɒsəlʌɪˈzeɪʃ(ə)n/ [n] ផូស៊ីលកម្ម

**foul-brood** /faʊl bruːd/ [n] ជំងឺភូលព្រូត (ជំងឺឆ្លងនៃឃ្មុំ)

**fourfinger threadfin** /fɔːˈfɪŋgə ˈθrɛdfɪn/ [n] ត្រីព្រាម (ឈ្មោះវិទ្យាសាស្ត្រ *Eleuthronema tetradactylum*)

**four-line tonguesole** /fɔː lʌɪn ˈtʌŋsəʊl/ [n] ត្រីអណ្ដាតឆ្កែ (ឈ្មោះវិទ្យាសាស្ត្រ *Cynoglossus bilineatus*)

**fowl** /faʊl/ [n] បក្សីស្រុក (សត្វស្លាប)
- fowl cholera /faʊl ˈkɒlərə/ [n] ជំងឺអាសន្នរោគមាន់

**fox tail** /fɒks teɪl/ [n] ដូចកន្ទុយកញ្ជ្រោង (លក្ខណៈនៃការលូតលាស់ដែលកំណត់ដោយសេនេទិចនៃប្រភេទរុក្ខជាតិស្រល់ដែលបង្ហាញឱ្យ ឃើញមែកចន្លោះថ្នាំងយ៉ាងវែងមួយ។ ជាធម្មតាលក្ខណៈនេះវាទាក់ទងទៅនឹងភាពធន់នឹងខ្យល់កាន់តែថយចុះ ដូច្នេះហើយ វាមិនជាលក្ខណៈ ដែលគេចង់បាននៅក្នុងការបង្កាត់ពូជដើមឈើទេ។)

**fracture** /ˈfraktʃə/ [n] ការបាក់ឆ្អឹង

**fragile** /ˈfradʒʌɪl/ [adj] ដែលផុយស្រួយ

**fragment** /ˈfragm(ə)nt/ [n] អំបែង, ភាគ, ផ្នែក, ដុំ

- stone fragment /stəʊn ˈfragm(ə)nt/ [n] សូមមើលពាក្យ៖ debris

**fragmentation** /fragmɛnˈteɪʃ(ə)n/ [n] ការកាត់ដាំ (ការបន្តពូជដោយឥតភេទ ដែលផ្នែករបស់រុក្ខជាតិលូតលាស់ទៅជារុក្ខជាតិពេញលេញថ្មី)

**fragrance** /ˈfreɪgr(ə)ns/ [n] សូមមើលពាក្យ៖ aroma

**frame** /freɪm/ [n] ស៊ុមសម្រាប់ដាក់ឱ្យឃ្មុំធ្វើឆ្អិត

- balkan frame /ˈbɔːlkən freɪm/ [n] ដែកដាក់លើគ្រែសម្រាប់ព្យួរ ឧបករណ៍ទាញឆ្អឹងឱ្យត្រង់ឡើងវិញ
- sampling frame /ˈsɑːmp(ə)lɪŋ freɪm/ [n] បញ្ជីចំនួនសំណាក (ចំនួនកម្រិតមធ្យម ដែលតាមរយៈចំនួនកម្រិតមធ្យមនោះ ឯកតាទាំងអស់នៅក្នុងតំបន់ដែលមានការចាប់អារម្មណ៍របស់គម្រោងកម្មវិធី (ភូមិសាស្ត្រ សង្គមសេដ្ឋកិច្ច ឬផ្សេងៗទៀត) ត្រូវបានកំណត់យកធ្វើជាសំណាកសម្រាប់ចុះធ្វើការអង្កេត)

**framework** /ˈfreɪmwəːk/ [n] គ្រោង, គម្រោង

**Francium** /ˈfransɪəm/ [n] ហ្វ្រង់ស្យូម (និមិត្តសញ្ញាគីមី Fr)

**frankia** /fraŋkɪə/ [n] អតិសុខុមប្រាណម៉្យាងឈ្មោះហ្វ្រេនគីយ៉ា (ក្រុមមួយនៃអតិសុខុមប្រាណ (មានប្រយោជន៍រស់នៅជាមួយគ្នា) ដែលឆ្លងចូល និងរស់នៅជាមួយប្រភេទរុក្ខជាតិណាមួយ ដូចជាប្រភេទ Alnus និង casuarinas។ ដើមឈើផ្តល់ជម្រក គេហៅថា Actinorhizal plants។)

**free-central** /friː ˈsɛntr(ə)l/ [adj] នៅចំកណ្តាល, នៅចំបណ្តូល (ទីតាំងរបស់ផ្លាសេនតានៅក្នុងអូវ៉េ)

**freeze-drying** /friːz drʌɪɪŋ/ [n] សម្ងួតដោយកំណក

**freeze-etching** /friːz ˈɛtʃɪŋ/ [n] ការកាត់ដោយកំណក

**freezer** /ˈfriːzə/ [n] ប្រដាប់ធ្វើឱ្យកក

**friable state** /ˈfrʌɪəb(ə)l steɪt/ [n] សូមមើលពាក្យ៖ good tilth

**fringed threadfin** /frɪn(d)ʒt ˈθrɛdfɪn/ [n] ត្រីម្រាំ, ត្រីកំព្រាម (ឈ្មោះវិទ្យាសាស្ត្រ *Polynemus multifilis*)

**frog** /frɒg/ [n] កង្កែប

**frond** /frɒnd/ [n] ធាងស្លឹក

**frost table** /frɒst ˈteɪb(ə)l/ [n] បន្ទះទឹកដែលកកទឹករឹង

**frostlifting** /frɒstlɪftin/ [n] ការកាយដីពីគល់

**fructose** /ˈfrʌktəʊs/ [n] ព្រុចតូស (ជាតិស្ករដែលបានមកពីផ្លែឈើ)

**fruit fly** /fruːt flʌɪ/ [n] រុយចោះផ្លែ

**fruit** /fruːt/ [n] ផ្លែឈើ (សរីរាង្គដែលផ្ទុកនូវគ្រាប់ នៃប្រភេទរុក្ខជាតិ ដែលមានផ្កាដោយមានអូវ៉ារីទុំ ឧ. ផ្លែសាច់ ឬផ្លែក្រៀ)

- aggregate fruit /ˈagrɪgət fruːt/ [n] ប្រភេទផ្លែចង្កោម ( ផ្លែដែលមានគ្រាប់ច្រើនកើតចេញពីកញ្ចុំកេសរញីនៃផ្កាមួយដែលបង្កើតជាផ្លែទោល។ ឧ. ផ្លែទៀប(Annona) ជាប្រភេទផ្លែសាច់ និងផ្លែ Magnolia ជាប្រភេទផ្លែស្ងួត)
- compound fruit /ˈkɒmpəʊnd fruːt/ [n] ផ្លែសមាស (ផ្លែមួយដែលកើតចេញពីកេសរញីច្រើន។ កេសរញីច្រើនចាប់កំណើតចេញពីកន្លែងដែលជាផ្នែកនៃផ្កាមួយ គេហៅវាថាជាផ្លែចង្កោម (aggregrate fruit) រីឯកេសរញីច្រើនចាប់កំណើតចេញពីផ្កាផ្សេងគ្នា គេហៅវាថាជាពហុផ្លែ (multiple fruit)។)
- dry fruit /drʌɪ fruːt/ [n] ប្រភេទផ្លែស្ងួត ( ជាចំណាត់នៃប្រភេទផ្លែដែលហួតទឹកឬស្ងួតនៅពេលវាទុំ។ ជារឿយៗ ការហួតទឹកបណ្តាលឱ្យវាប្រេះផ្លែ ហើយជម្រុះគ្រាប់។ ពួកផ្លែស្ងួត គឺមាន Capsules, pods, folicles, cones និងពួកផ្លែចង្កោម និងពហុផ្លែ មួយចំនួន។)
- false fruit /fɔːls fruːt/ [n] ប្រភេទផ្លែមិនពិត, ផ្លែក្លែងក្លាយ, ផ្លែបញ្ឆោត, សាច់ទម្រផ្កាស្រោបពីក្រៅអូវ៉េ (ជាពាក្យទូទៅមួយប្រើសម្រាប់ប្រភេទផ្លែដែលកើតចេញពីរចនាសម្ពន្ធផ្សេងៗរបស់ផ្កាលើកលែងតែកេសរញី (gynoecium) ជារឿយៗ គឺមានទម្រផ្កា ឧ.ប្រភេទផ្លែប៉ោម(pomes)។ ផ្លែបញ្ឆោតអាចកើតឡើងពីប្រភេទ ផ្កាទោល ដូចនេះ រួមមានប្រភេទផ្លែចង្កោម និងកើតមកពីផ្កាចង្កោមទាំងមូល ឧ.ប្រភេទពហុផ្លែ (Multiple fruits)។)

- fleshy fruit /ˈfleʃi fruːt/ [n] ប្រភេទផ្លែសាច់, ផ្លែមានជាតិទឹកច្រើន (ជារឿយៗ ផ្លែឈើគេចែកជាប្រភេទផ្លែស្ងួត និងផ្លែសាច់។ ក្នុងប្រភេទផ្លែសាច់ គ្រាប់រុំព័ទ្ធដោយសាច់ផ្លែដែល ជាធម្មតា ជាសារធាតុផ្អែម និងមានជាតិទឹកច្រើន។ ប្រភេទផ្លែសាច់ រួមមាន បឺរី )ប៉ោម ខ្ទុប និងពួកផ្លែ ចង្កោម និងសមាសមួយ ចំនួន។ តាមធម្មតា ប្រភេទផ្លែសាច់ពង្រាយគ្រាប់ដោយសារសត្វ (zoochory)។ ជាធម្មតា ប្រភេទផ្លែសាច់ទាំងនេះផ្លាស់ប្តូរ ពណ៌ និងវិវត្តន៍ជាតិផ្អែម និង/ឬ ក្លិន នៅពេលវាទុំដើម្បីទាក់ ទាញភ្នាក់ងារពង្រាយគ្រាប់ ។)
- fruit vegetable /fruːt ˈvɛdʒtəb(ə)l/ [n] បន្លែយកផ្លែ (ពពួករុក្ខជាតិដែលផ្លែវាត្រូវបានយកមកធ្វើជាបន្លែដូចជាត្រប់ ននោងជាដើម)
- milk fruit /mɪlk fruːt/ [n] ទឹកដោះ (ឈ្មោះវិទ្យាសាស្ត្រ *Chrysophyllum cainito*)
- multiple fruit /ˈmʌltɪp(ə)l fruːt/ [n] ពហុផ្លែ (ជាផ្លែសមាសដែលផ្គុំឡើងពីឯកត្តៈផ្លែច្រើន នៅក្នុងកន្សោមផ្កាមួយដែលអាចរលាយ ចូលគ្នា ឬដាច់ពីគ្នាប៉ុន្តែនៅជាប់គ្នា ឧ.ប្រភេទ Casuarina (ផ្លែស្ងួត) និង Arthocarpus (ផ្លែសាច់)។)
- simple fruit /ˈsɪmp(ə)l fruːt/ [n] ផ្លែទោល (ប្រភេទផ្លែដែលលូតលាស់ពីអូវែទោលនៃផ្កាមួយ)
- snake fruit /sneɪk fruːt/ [n] ផ្លែរកាំ
- sugar palm fruit / ˈʃʊgə pɑːm fruːt/ [n] ផ្លែត្នោត

**fruiting** /fruːtɪŋ/ [n] ដំណាក់ផ្លែ (រយៈពេលនៃបាតុភូតចាប់ពីបញ្ចប់នៃរដូវផ្កា រហូតដល់ផ្លែទុំ និងជ្រុះពង្រាយ)

**fry** /frʌɪ/ [n]

១. កូនត្រីម្សៅ (ចាប់ពីញាស់ រហូតអាយុ ៣០ ទៅ ៤៥ ថ្ងៃ)

២. ធាតុឆេះ

**fuel** /fjuː(ə)l/ [n] ឥន្ធនៈ

- alternate fuel /ˈɔːltəneɪt fjuː(ə)l/ [n] ឥន្ធនៈជំនួស
- automotive fuel /ˌɔːtəˈməʊtɪv fjuː(ə)l/ [n] ឥន្ធនៈសម្រាប់ម៉ាស៊ីនចំហេះក្នុង
- biomass fuel /ˈbʌɪə(ʊ)mas fjuː(ə)l/ [n] ឥន្ធនៈជីវម៉ាស
- fossil fuel /ˈfɒsɪl fjuː(ə)l/ [n] ឥន្ធនៈផូស៊ីល
- fuel clock /fjuː(ə)l klɒk/ [n] កុងតាក់ប្រេងឥន្ធនៈ (ផ្នែកមួយនៃចលករសម្រាប់បិទ ឬបើកប្រេងឥន្ធនៈ)
- fuel tank /fjuː(ə)l taŋk/ [n] ធុងសាំងចលករ (ធុងផ្ទុកប្រេងសម្រាប់ចលនានៃចលករ)
- fuelwood /ˈfjuː(ə)lwʊd/ [n] សូមមើលពាក្យៈ firewood
- gas(gaseous) fuel /gas fjuː(ə)l/ [n] ឥន្ធនៈឧស្ម័ន
- hydrocarbon fuel /ˌhʌɪdrə(ʊ)ˈkɑːb(ə)n fjuː(ə)l/ [n] ឥន្ធនៈអ៊ីដ្រូកាបួ
- nuclear fuel /ˈnjuːklɪə fjuː(ə)l/ [n] ឥន្ធនៈនុយក្លេអ៊ែ
- pollution-free fuel /pəˈluːʃ(ə)n-friː fjuː(ə)l/ [n] ឥន្ធនៈស្អាត (ប្រភពថាមពលពលដែលបំពុលបរិស្ថានតិច ឬ ស្ទើរតែគ្មាន)
- waste fuel /weɪst fjuː(ə)l/ [n] ឥន្ធនៈពីសំណល់

**fugacious** /fjʊˈgeɪʃəs/ [adj] ស្វិតរួចជ្រុះយ៉ាងលឿន (អំពីសរីរាង្គរុក្ខជាតិ)

**fumigant** /fjuːmɪgant/ [n] ថ្នាំពុលមានចំហាយជាឧស្ម័នកម្រិតខ្លាំង (អាចសម្លាប់សត្វចង្រៃ សត្វល្អិត ស្មៅ និងសារពាង្គកាយមានជីវិតផ្សេងទៀត តាមការជ្រាបចូលតាមរន្ធដងខ្លួន រន្ធញើស ឬរន្ធដង្ហើមជាដើម)

**fumigation** /fjuːmɪˈgeɪʃ(ə)n/ [n] ការបញ្ចូលឧស្ម័ន, ការធ្វើធូបទកម្ម ( ការបញ្ចូលសមាសធាតុគីមី ដូចជាឧស្ម័នកាបូនិក $CO_2$ ឬ methyl bromide)

**fumigator** /ˈfjuːmɪgeɪtə/ [n] ឧបករណ៍បាញ់ថ្នាំកំចាត់សត្វល្អិតធុនតូច (ជាឧបករណ៍បាញ់ថ្នាំដែលប្រើថ្នាំតិចតែបាញ់បានផ្ទៃធំ)។

**function** /ˈfʌŋ(k)ʃ(ə)n/ [n] មុខងារ, តួនាទី

**fundus** /ˈfʌndəs/ [n] មូលដ្ឋាន, ផ្នែកប្រឈមក្នុងសរីរាង្គមួយ (បាតស្បូន)

**fungic moder** /ˈfʌŋgiː mɒdə/ [n] មមោកអន្តរការសមស្របសម្រាប់ពពួកផ្សិត

**fungicide** /ˈfʌŋgɪsʌɪd/ [n] ថ្នាំសម្លាប់ផ្សិត, ថ្នាំផ្សិតឃាត (សារធាតុគីមីដែលកម្ចាត់ ឬសម្លាប់ស្ព័ ឬmycelium របស់ផ្សិត)

**fungistasis** /ˈfʌŋgiːˈsteɪsɪs/ [n] ថ្នាំបង្អាក់ផ្សិតលូតលាស់

**fungivore** /ˈfʌŋgiːˈvwɑː/ [n] ភាវរស់ស៊ីផ្សិត

**fungus** /ˈfʌŋgəs/ [n] (ពហុវចនៈ៖ fungi) ផ្សិត (រុក្ខជាតិ, ពពួកផ្សិត), ផ្សិត (សរីរៈមួយគ្មានក្លរ៉ូហ្វីល អាចបន្តកូនចៅដោយភេទ ឬអភេទនៃស្ប៉ជាទូទៅមាន mycelia និងនុយក្លេអ៊ែរច្បាស់លាស់)

- cloud ear fungus /klaʊd ɪə ˈfʌŋgəs/ [n] ផ្សិតត្រចៀកកណ្តុរ (ឈ្មោះវិទ្យាសាស្ត្រ *Auricularia polytricha*)
- imperfect fungi /ɪmˈpəːfɪkt ˈfʌŋgiː/ [n pl] ផ្សិតមានលក្ខណៈមិនគ្រប់គ្រាន់, ផ្សិតមិនសុក្រឹត (ផ្សិតដែលមិនដឹងភេទច្បាស់លាស់)

**funicle** /ˈfjuːnɪk(ə)l/ [n] (សទិសន័យ៖ funiculus) ទងអូវុល, សណ្តង់គ្រាប់, ទងបុប្ផា

**funiculus** /fjʊˈnɪkjʊləs/ [n] (ពហុវចនៈ៖ funiculi) សូមមើលពាក្យ៖ funicle

**funnel** /ˈfʌn(ə)l/ [n] ឡាវ (ជីវឡាវ)

**funnelform** /ˈfʌn(ə)l fɔːm/ [n] ប្រភេទផ្កាមានត្របកជាប់រាងឡាវ

**fur** /fəː/ [n] រោមសត្វ

**furcate** /ˈfəːkeɪt/ [adj] បែកចំពាម, ព្រែកជាពីរ

**furrow** /ˈfʌrəʊ/ [n] គន្លងនង្គ័ល (ស្នាម ឬចង្អូរនៃនង្គ័លនៅពេលភ្ជួរដី), រង

- back furrow /bak ˈfʌrəʊ/ [n] បំណាស់ផ្ទប់ (របៀបភ្ជួរពុះពីកណ្តាលស្រែ បកទៅបកមករហូតដល់ចុងបញ្ចប់តាមទិសដៅទ្រនិចនាឡិកា)
- cleavage furrow /ˈkliːvɪdʒ ˈfʌrəʊ/ [n] ចង្អូរចែកកោសិកា (ផ្នត់របស់ភ្នាសកោសិកានៅពេលចាប់ផ្តើមធ្វើចំណែកស៊ីតូប្លាសនៃកោសិកាសត្វ)
- female furrow /ˈfiːmeɪl ˈfʌrəʊ/ [n] ចង្អូរញី (ចង្អូរស្របតាមបណ្តោយថ្នាលសំណាប)
- furrow slice /ˈfʌrəʊ slʌɪs/ [n] អាចម៍បំណាស់
- male furrow /meɪl ˈfʌrəʊ/ [n] ចង្អូរឈ្មោល (ចង្អូរតែមួយដែលកាត់តាមខ្សែទ្រូងថ្នាលសំណាក)
- water-furrow /ˈwɔːtə -ˈfʌrəʊ/ [n] សូមមើលពាក្យ៖ ditch

**furrowing** /ˈfʌrəʊwɪŋ/ [n] ការឆូតគន្លងនង្គ័ល (ការឆូតគន្លងសម្រាប់ដាំ)

- water furrowing /ˈwɔːtə ˈfʌrəʊɪŋ/ [n] សូមមើលពាក្យ៖ gullying

**fusarium yellow** /fjʊˈzɛːrɪəm ˈjɛləʊ/ [n] ជំងឺស្រពោនលឿងស្លឹក (ជំងឺនេះបង្កដោយផ្សិត *Fasurium* f.sp *conglutinans* ដែលភ្នាក់ងារបង្កជំងឺឆ្លងរាលដាល តាមរយៈឧបករណ៍កសិកម្ម ការហូរច្រោះ និងការស្ទូងកូនដែលឆ្លងជំងឺ)

**fusion** /ˈfjuːʒ(ə)n/ [n] ការរលាយចូលគ្នា

- centric fusion /ˈsɛntrɪk ˈfjuːʒ(ə)n/ [n] ជំនាប់កណ្តាល

## G

**gadfly** /ˈgadflʌɪ/ [n] របោម (សត្វខាំគោ ឬសេះ)

**Gadolinium** /ˌgadəˈlɪnɪəm/ [n] កាដូលីញ៉ូម (និមិត្តសញ្ញាគីមី Gd)

**gag** /gag/ [n] ឆ្នុកមាត់ (ប្រដាប់បើកមាត់សត្វឱ្យចំហ)

**galactase** /gəˈlaktəz/ [n] កាឡាក់តាស (ជាតិដែលធ្វើឱ្យទឹកដោះឡើងជូរ)

**galactic** /gəˈlaktɪk/ [adj] ដែលទាក់ទងទៅនឹងទឹកដោះគោ

**galactosemia** /gəˌlaktəˈsimiə/ [n] លក្ខណៈជំងឺខ្វះជាតិស្ករពីកំណើតដែលមិនអាចប្តូរជាតិហ្កាឡាក់តូ (ស្ករ) ទៅជាគ្លុយកូស

**galangal** /ˈgal(ə)ŋgal/ [n] (សទិសន័យ៖ galangale, blue ginger) រំដេញ

**galingale** /ˈgalɪŋˌgeɪl/ [n] សូមមើលពាក្យ៖ galangal

**gall** /gɔːl/ [n] ភាពលូតលាស់មិនប្រក្រតីនៃរុក្ខជាតិដូចជាការហើម ឬប៉ោងនៃស្លឹក ឬពក, ដុំពក (ការលូតលាស់ខុសប្រក្រតីរបស់ជាលិការុក្ខជាតិ បង្កដោយសត្វល្អិតផ្សេងៗ ឬផ្សិត)

**gall dwarf** /gɔːl dwɔːf/ [n] ជំងឺតឿពកដុំ

**gall midge** /gɔːl mɪdʒ/ [n] មូសផ្លង

**gallbladder** /gɔːl ˈbladə/ [n] ប្រម៉ាត់

**Galliformes** /ˌgalɪˈfɔːmz/ [n] ហ្កាលីហ្វម (លំដាប់បក្សីដែលមានដូចជា សត្វទា សត្វក្រួច និងសត្វស្លាបផ្សេងៗទៀតក្នុងព្រៃ)

**gallinaceous** /ˌgalɪˈneɪʃəs/ [adj] ដូចមាន់ (ទាក់ទងទៅនឹងសត្វក្នុងលំដាប់ Galliformes)

**Gallium** /ˈgalɪəm/ [n] កាល្យូម (និមិត្តសញ្ញាគីមី Ga)

**galvanism** /ˈgalvəˌnɪz(ə)m/ [n] ការព្យាបាល (របៀបព្យាបាលរោគដោយប្រើចរន្តអគ្គិសនី)

**galvanization** /galvənʌɪˈzeɪʃ(ə)n/ [n] ការជ្រលក់ស័ង្កសី

**galvanize** /ˈgalvənʌɪz/ [v] ជ្រលក់ស័ង្កសី

**game-cock** /geɪm kɒk/ [n] មាន់ប្រជល់

**gamete** /ˈgamiːt/ [n] កោសិកាភេទ, កាម៉ែត (កោសិកាឯកប្លូអ៊ីតដែលត្រូវបន្សាំជាមួយនឹងកោសិកាឯកប្លូអ៊ីតនៃភេទផ្ទុយគ្នាដើម្បីបង្កើតជាកោសិកាឌីប្លូអ៊ីត ឬទារិកោសិកា)

**gametopetalous** /gəˈmiːtəʊ pɛt(ə)ləs/ [adj] (សទិសន័យ៖ sympetalous) ស្រទាប់ផ្កាជាប់គ្នា

**gametophyte** /gəˈmiːtə(ʊ)fʌɪt/ [n] កាម៉ែតតូហ្វីត (ផ្នែកមួយរបស់រុក្ខជាតិដែលផលិតកាម៉ែត ឬកោសិកាភេទ ពោលគឺមានកាម៉ែតថឺហ្វីតញី និងកាម៉ែតថឺហ្វីត ឈ្មោល។ កាម៉ែតថឺហ្វីតមានចំនួនក្រូម៉ូសូមហាប់ផ្លអ៊ីត(n)។)

- female gametophyte /ˈfiːmeɪl gəˈmiːtə(ʊ)fʌɪt/ [n] កាម៉ែតតូហ្វីតញី (ដំណាក់កាលនៃរុក្ខជាតិ ឬផ្កាញីក្នុងការឆ្លាស់កំណើតដែលបង្កើតបានជាកាម៉ែតញី។ ជាខួបនៃជីវិតផ្ទុកក្រូម៉ូសូមតែម្ខាងនៃពួករុក្ខជាតិមួយដែលមានស៊ុត។ ក្នុងរុក្ខជាតិគ្រាប់ជិត (angiosperm) ដែលបានបន្ថយនៅកោសិកាមួយចំនួនតូច(ថង់អំប្រីយ៉ុង)។ នៅក្នុងពួករុក្ខជាតិគ្រាប់ស្រាតវិញ អូវុលនៅ ក្នុងកាម៉ែតថឺហ្វីតញីដែលវិវត្តន៍នៅពេលវាទុំទៅជាជាលិកាបំរុង ពោលគឺប្រែតួនាទី ដូចទៅនឹងអែនដូស្ពែម ក្នុងគ្រាប់របស់ពួករុក្ខជាតិគ្រាប់ជិត។)

**gamma-emitting** /ˈgamə ɪˈmɪtɪŋ/ [n] អ៊ីសូតូបរំភាយកាំរស្មីកាម៉ា

**gamopetalous** /ˌgam əˈpɛtləs/ [adj] ប្រភេទផ្កាមានត្របកជាប់

**gamosepalous** /gəˈtəʊ sɛˈp(ə)ləs/ [adj] ត្របកផ្កាជាប់គ្នា

**gandaria** /ˈgandərɪə/ [n] ផ្លែមាក់ប្រេង

**gangetic leaffish** /ˈganɛtɪk liːffɪʃ/ [n] ត្រីខ្លា (ឈ្មោះវិទ្យាសាស្ត្រ *Nandus nandus*)

**gangetic tank goby** /ˈganɛtɪk taŋk ˈgəʊbi/ [n] ត្រីក្បាន (ឈ្មោះវិទ្យាសាស្ត្រ *Glossogobius giuris*)

**gangetic tonguesole** /ˈganɛtɪk ˈtʌŋsəʊl/ [n] ត្រីអណ្តាតឆ្កែ (ឈ្មោះវិទ្យាសាស្ត្រ *Cynoglossus cynoglossus*)

**ganglion** /ˈgaŋglɪən/ [n] កូនកណ្តុរ, កង់គ្លីយ៉ុង (មជ្ឈមណ្ឌលប្រសាទ, ដុំសាច់តូច រឹងកើតនៅស្រោមសរសៃពួរ ឬសន្លាក់)

**gangrene** /ˈgaŋgriːn/ [n] ដំបៅរលួយ (ដោយកង្វះឈាមរត់ឬដោយសារមុខរបួសមិនស្អាត)

**garage** /ˈgarɑː(d)ʒ/ [n] យានដ្ឋាន, កន្លែងជួសជុលរថយន្ត

**garbage** /ˈgɑːbɪdʒ/ [n] សម្រាមផ្ទះបាយ, អាហារសំណល់, សម្រាមពីបន្ទប់ចំអិនអាហារ

***Garcinia loureiri*** [sci.n] សណ្តាន់

***Garcinia mangostana*** [sci.n] សូមមើលពាក្យ៖ mangosteen

**garden** /ˈɡɑːd(ə)n/ [n] សួន, សួនច្បារ

- clonal garden /ˈkləʊn(ə)l ˈɡɑːd(ə)n/ [n] សួនកូនបំបៅ ឬផ្សាំ (ជាការប្រមូលកូនឈើបំបៅ (clone) ជម្រើសចេញពីដើមមានសរីរាង្គលូតលាស់ ដូចជាការកាត់ (cuttings) ត្រូវបានគេប្រមូលផលកូន)
- kitchen garden /ˈkɪtʃɪn ˈɡɑːd(ə)n/ [n] ចម្ការបន្លែ, សួនគ្រួសារ, ច្បារបន្លែ
- market garden /ˈmɑːkɪt ˈɡɑːd(ə)n/ [n] ចម្ការបន្លែ ឬផ្លែឈើដាំសម្រាប់លក់
- vegetable garden /ˈvɛdʒtəb(ə)l ˈɡɑːd(ə)n/ [n] សួនបន្លែ
- garden spurge /ˈɡɑːd(ə)n spəːdʒ/ [n] ទឹកដោះខ្លា (ឈ្មោះវិទ្យាសាស្ត្រ *Phorbia pilulifera*)

**gargle** /ˈɡɑːɡ(ə)l/ [v] ខ្ពុរមាត់

**garland** /ˈɡɑːlənd/ [n] កម្រងផ្កា, កម្រងស្លឹកឈើ

**garland chrysanthemum** /ˈɡɑːlənd krɪˈsanθɪməm/ [n] តាំងអោ (ឈ្មោះវិទ្យាសាស្ត្រ *Chrysanthemum coronarium*)

**stone garland** /stəʊn ˈɡɑːlənd/ [n] ដុំថ្មដូចកម្រង ឬខ្សែក

**garlic** /ˈɡɑːlɪk/ [n] ខ្ទឹមស (ឈ្មោះវិទ្យាសាស្ត្រ *Allium sativum*)

**garner** /ˈɡɑːnə/ [n] ជង្រុក

**gas** /ɡas/ [n] ឧស្ម័ន

- combustible gas /kəmˈbʌstɪb(ə)l ɡas/ [n] ឧស្ម័នឥន្ធនៈ, ឧស្ម័នដុតឆេះ
- condensed gas /kənˈdɛnst ɡas/ [n] ឧស្ម័នរាវ
- contaminant gas /kənˈtamɪnənt ɡas/ [n] ឧស្ម័នកខ្វក់
- conventional gas /kənˈvɛnʃ(ə)n(ə)l ɡas/ [n] ឧស្ម័នធម្មជាតិ
- gasoline gas /ˈɡasəliːn ɡas/ [n] សាំង
- hydrocarbon gas /ˌhʌɪdrə(ʊ)ˈkɑːb(ə)n ɡas/ [n] ឧស្ម័នអ៊ីដ្រូកាបួ
- ideal gas /ʌɪˈdɪəl ɡas/ [n] ឧស្ម័នបរិសុទ្ធ
- inert gas /ɪˈnəːt ɡas/ [n] ឧស្ម័ននិចល, ឧស្ម័នកម្រ
- inflammable gas /ɪnˈflaməb(ə)l ɡas/ [n] ឧស្ម័នឆាបភ្លើង
- landfill gas /ˈlan(d)fɪl ɡas/ [n] ឧស្ម័នកន្លែងទុកដាក់កាកសំណល់
- lead-free gas /liːd friː ɡas/ [n] សាំងគ្មានសំណ
- liquefied natural gas /ˈlɪkwɪfʌɪ ˈnatʃ(ə)r(ə)l ɡas/ [n] ឧស្ម័នធម្មជាតិពង្រាវ
- manure gas /məˈnjʊə ɡas/ [n] ឧស្ម័នជីវៈ
- marsh gas /mɑːʃ ɡas/ [n] ឧស្ម័នត្រពាំង, មេតាន
- natural gas /ˈnatʃ(ə)r(ə)l ɡas/ [n] ឧស្ម័នធម្មជាតិ
- noxious gas /ˈnɒkʃəs ɡas/ [n] ឧស្ម័នពុល
- olefiant gas /ˈəʊləfʌɪənt ɡas/ [n] អេទីឡែន
- poison gas /ˈpɔɪz(ə)n ɡas/ [n] ឧស្ម័នពុល
- pollutant gas /pəˈl(j)uːt(ə)nt ɡas/ [n] ឧស្ម័នបំពុល
- premium gas /ˈpriːmɪəm ɡas/ [n] សាំងមានសន្ទស្សន៍អុកតានមិនតិចជាង ៨៧,២
- radioactive gas /ˌreɪdɪəʊˈaktɪv ɡas/ [n] ឧស្ម័នវិទ្យុសកម្ម
- rare gas /rɛː ɡas/ [n] ឧស្ម័នកម្រ
- regular gas /ˈrɛɡjʊlə ɡas/ [n] សាំងមានសន្ទស្សន៍អុកតានមិនតិចជាតិ ៨២
- sewage gas /ˈsuːɪdʒ ɡas/ [n] ឧស្ម័នទឹកលូសម្អុយ
- toxic gas /ˈtɒksɪk ɡas/ [n] ឧស្ម័នពុល
- waste gas /weɪst ɡas/ [n] ឧស្ម័នសំណល់, ផ្សែង

**gasmain** /ˈɡasmeɪn/ [n] បំពង់ឧស្ម័ន

**gasoline** /ˈɡasəliːn/ [n] ប្រេងសាំង

**Gasterophilus** /ɡastərəʊfɪləs/ [n] កាស្តេរ៉ូភីលុស (ពពួកសត្វរុយដែលពងលាក់ក្រោមស្បែកសត្វសេះ ឬមនុស្ស)

**Gastrectomy** /ɡaˈstrɛktəmi/ [n] ការវះកាត់យកក្រពះ ឬផ្នែកខ្លះនៃក្រពេញ

**gastric** /ˈɡastrɪk/ [adj] នៃក្រពះ, ដែលទាក់ទងនឹងក្រពះ

- gastric lavage /ˈɡastrɪk ˈlavɪdʒ/ [n] ការលាងក្រពះ

**gastritis** /ɡaˈstrʌɪtɪs/ [n] ជំងឺរលាកក្រពះ

**gastro-enteritis** /ˈɡastrəʊ ˌɛntəˈrʌɪtɪs/ [n] ជំងឺរលាកក្រពះ និងពោះវៀន

**gastrointestinal** /ˌɡastrəʊɪnˈtɛstɪn(ə)l/ [adj] ក្រពះនិងពោះវៀន (ដែលទាក់ទងតាំងពីក្រពះរហូតដល់ពោះវៀន)

**gas exchange** /gas ɪksˈtʃeɪndʒ/ [n] សូមមើលពាក្យ៖ gas carriage

**gauge** /geɪdʒ/ [n]

១. សូមមើលពាក្យ៖ sieve

២. កាលីប (ទំហំម្ទុល)

- rain gauge /reɪn geɪdʒ/ [n] រង្វាស់ទឹកភ្លៀង (ប្រដាប់សម្រាប់វាស់ទឹកភ្លៀង)

**gauze** /gɔːz/ [n] ស្បៃស្តើងសម្រាប់ទ្រាប់មុខរបួស

**gecko** /ˈgɛkəʊ/ [n] តុកកែ

**gel consistency** /dʒɛl kənˈsɪst(ə)nsi/ [n] ភាពកកអន្ទឹល (លក្ខណៈគុណភាពនៃគ្រាប់អង្ករ ឬគុណភាពបាយដោយវាអាចបញ្ជាក់ពីភាពទន់ ឬរឹងនៃបាយ)

**gelatin** /ˈdʒɛlətɪn/ [n] ជាតិខាប់អន្ទិលៗដូចចាហួយ

**gelatinization** /dʒɪˈlatɪnʌɪzeɪʃ(ə)n/ [n] អន្ទិលកម្ម (ដំណើរការនៃគ្រាប់អង្ករចាប់ហើម)

**gelatinous** /dʒɪˈlatɪnəs/ [adj] ដែលមានលក្ខណៈអន្ទិល

**geld** /gɛld/ [v] សូមមើលពាក្យ៖ castrate

**gelding** /ˈgɛldɪŋ/ [n] ការក្រៀវ

**gene** /dʒiːn/ [n] ពន្ធុ, ធាតុតំណពូជ, សែន (ឯកតាបន្តពូជពិសេសដែលអាចបញ្ជូនព័ត៌មានពីជំនាន់មួយទៅមួយក្រោយទៀត ឬពីមេបាទៅកូន)

- additive gene /ˈadɪtɪv dʒiːn/ [n] ប្រសិទ្ធភាពសែនបន្ថែម, ប្រសិទ្ធភាពពន្ធុបន្ថែម (ពន្ធុដែលបង្ហាញឱ្យឃើញប្រសិទ្ធភាពបន្ថែម។ ប្រសិទ្ធភាពពន្ធុជាមូលដ្ឋានសម្រាប់ទ្រឹស្តីតំណពូជខាងបរិមាណ និងការសិក្សាខាងបង្កាត់ពូជ។ ឧ. ការរំពឹងទុកនៃលក្ខណៈសម្តែងឡើងរបស់កូនកាត់ (hybrid) គឺជាតម្លៃមធ្យមនៃពន្ធុរបស់មេបា ពោលគឺពាក់កណ្តាលមេ និងពាក់កណ្តាលបា)
- deleterious gene /ˌdɛlɪˈtɪərɪəs dʒiːn/ [n] សែនឃាយីជីវិត, ពន្ធុឃាយីជីវិត (អាលែលរបស់សែន ដែលមានឥទ្ធិពលទៅលើផេណូទីបបង្កឱ្យមានសុខភាពថមថយ ហើយសែនប្រភេទនេះ ច្រើនតែជាសែនអន់ និងត្រូវបានបញ្ជូនតាមរយៈគ្រួសារដោយគ្មានលេចចេញនូវលក្ខណៈអ្វីឡើយ លើកលែងតែមានពីរកើតឡើងនៅលើឯកត្តៈតែមួយ)
- dominant gene /ˈdɒmɪnənt dʒiːn/ [n] សែនលុប, ពន្ធុលុប (លក្ខណៈលុបនៃពន្ធុ (សម្ពន្ធករ) មួយទៅលើពន្ធុមួយផ្សេងទៀត ក្នុងពេលដែលគូសម្ពន្ធករនេះនៅជាមួយគ្នា ឧទាហរណ៍ Aa នឹងមានផេណូទីបដូច AA ដែរ)
- lethal gene /ˈliːθ(ə)l dʒiːn/ [n] ពន្ធុស្លាប់ (ពន្ធុ ឬសែនមួយដែលពេលវាសម្តែងចេញមក គឺវាស្លាប់ ឧ. ឡើងពណ៌ស (albinism))
- major gene /ˈmeɪdʒə dʒiːn/ [n] សែន ឬពន្ធុសំខាន់, សែន ឬពន្ធុកំណត់ (បណ្តាពន្ធុ ឬសែនដែលរួមចំណែកមួយភាគធំដល់លក្ខណៈដែលបានសម្តែងចេញមក ដែលមានទាក់ទងនឹងឥទ្ធិពលបរិស្ថាន និងកត្តាប្រែប្រួលផ្សេងៗទៀត)
- recessive gene /rɪˈsɛsɪv dʒiːn/ [n] សែនអន់, ពន្ធុអន់ (ពន្ធុដែលមិនអាចបញ្ចេញនូវលក្ខណៈរបស់វានៅពេលដែលវាស្ថិតនៅជាមួយពន្ធុលុបក្នុងសម្ពន្ធករ ឧទាហរណ៍ Aa = AA តែ aa ≠ AA ហើយក្នុងនោះ a ជាពន្ធុអន់)
- gene bank /dʒiːn baŋk/ [n] ពន្ធុធនាគារ, ធនាគារសែន (ទីកន្លែងដែលរាល់ជីវករប្រមូលបានត្រូវរក្សាទុកយ៉ាងម៉ត់ចត់)
- gene conservation /dʒiːn kɒnsəˈveɪʃ(ə)n/ [n] ការអភិរក្សសែន, ការអភិរក្សពន្ធុ (ការការពារ និងការថែរក្សាទុកនូវបម្រែបម្រួលភាពរបស់សេនេទិចនៃប្រភេទពូជមួយដើម្បីរក្សាទុកធនធានសេនេទិច សម្រាប់ការស្រាវជ្រាវ និងសុវត្ថិកម្មនាអនាគត)
- gene engineering /dʒiːn ɛndʒɪˈnɪərɪŋ/ [n] សូមមើលពាក្យ៖ Genetic engineering
- gene expression /dʒiːn ɪkˈsprɛʃ(ə)n/ [n] ការសម្តែងចេញរបស់សែន, ការសម្តែងចេញរបស់ពន្ធុ (ដំណើរនៃការបកប្រែក្រមសេនេទិច (genetic code) ឱ្យទៅជាលក្ខណៈអាចមើលឃើញ ឬស្គាល់តាមរយៈការសំយោគប្រូតេអ៊ីន)
- gene flow /dʒiːn fləʊ/ [n] ការសាយភាយរបស់សែន ឬពន្ធុ, រំហូរសែន ឬពន្ធុ (ការផ្លាស់ទីរបស់ពន្ធុពីក្រុមពូជ (សារព័ន្ធ) មួយទៅក្រុម (សារព័ន្ធ) មួយទៀត (អាចហៅថា gene migration = ពន្ធុធ្វើអន្តោប្រវេសន៍)
- gene frequency /dʒiːn ˈfriːkw(ə)nsi/ [n] សែនហ្រ្វីខ្វីនស៊ី, ហ្វ្រីខ្វីនស៊ីពន្ធុ (ទំហំនៃអាលែលមួយនៅក្នុងក្រុមពូជមួយដែលធៀបជាមួយនឹងអាលែលផ្សេងទៀតៗរបស់សែននោះ។ បើសិនសែន A មានអាលែលពីរ a និង A ហើយមានហ្វ្រីខ្វីនស៊ី a = 0.២ (២0%) ដូចនេះហ្វ្រីខ្វីនស៊ីរបស់ A = 0.៨ (៨0%) ដូច្នេះ A + a = ១ (១00%))

- gene mutation /dʒiːn mjuːˈteɪʃ(ə)n/ [n] មុយតាស្យុងសែន, បម្រែបម្រួលតពូជពន្ធុ
- gene pool /dʒiːn puːl/ [n] ឃ្លាំងសែន, ឃ្លាំងពន្ធុ (ចំនួនពន្ធុ ឬសែនទាំងអស់ និងអាលែលរបស់វាមានវត្តមានក្នុងពូជបង្កាត់មួយ ឬប្រភេទពូជណាមួយនៅក្នុងគ្រាមួយ)

**generate** /ˈdʒɛnəreɪt/ [v] សូមមើលពាក្យ៖ produce

**generation** /dʒɛnəˈreɪʃ(ə)n/ [n] ជំនាន់, ការបង្កើត, សន្តតិវង្ស

- alternation of generations /ɔːltəˈneɪʃ(ə)n ɒv dʒɛnəˈreɪʃ(ə)n/ [n] ការឆ្លាស់ជំនាន់

**generator** /ˈdʒɛnəreɪtə/ [n] ម៉ាស៊ីនភ្លើង (ម៉ាស៊ីនផ្តល់ចរន្តអគ្គិសនី)

**genesis** /ˈdʒɛnɪsɪs/ [n] ដើមកំណើត, ប្រភពកំណើត

- soil genesis /sɔɪl ˈdʒɛnɪsɪs/ [n] ប្រភពដី

**genetic amplification** /dʒɪˈnɛtɪk ˌamplɪfɪˈkeɪʃ(ə)n/ [n] កំណើនសេនេទិច

**genetic code** /dʒɪˈnɛtɪk kəʊd/ [n] ក្រមសេនេទិច (លំដាប់ជាក់លាក់មួយនៃអាមីណូអាស៊ីតតំរៀបនៅក្នុងប្រូតេអ៊ីនមួយ ដែលកំណត់ដោយលំដាប់នុយក្លេអូទីតក្នុង RNAm ឬ RNAនាំសារ ដែលបកប្រែផ្អែកទៅតាមលំដាប់នុយក្លេអូទីត DNA)

**genetic engineering** /dʒɪˈnɛtɪk ɛndʒɪˈnɪərɪŋ/ [n] (សទិសន័យ៖ gene engineering, recombinant DNA technology) វិស្វកម្មសេនេទិច (បច្ចេកវិទ្យាបង្កាត់ DNA), វិស្វកម្មសែន, វិស្វកម្មពន្ធុ (បច្ចេកវិទ្យាទំនើបដូចជាការបង្កើតនូវឯកត្តៈថ្មីមួយដែលគ្មានក្នុងធម្មជាតិ។ ការដាក់ពន្ធុមានប្រយោជន៍ឱ្យនៅដាច់ពីសារពាង្គកាយ ឬជាលិកាអ្នកផ្តល់ឱ្យ និងការបញ្ចូលវាទៅក្នុងសារពាង្គកាយមួយដែលវាមិនមានពន្ធុនោះ។)

**genetic gain** /dʒɪˈnɛtɪk geɪn/ [n] ការទទួលបានសេនេទិច (ការបង្កើនគុណភាពមធ្យមរបស់មេបា។ ការកើនគុណភាពដែលអាចសម្រេចទៅបាន ដោយការជ្រើសរើសនៅក្នុងជំនាន់មេបា ចំនួនរបស់វាអាស្រ័យទៅនឹងប្រពលភាពជម្រើសនានាភាពរបស់មេបា និងសមត្ថភាពបន្តពូជ)

**genetic makeup** /dʒɪˈnɛtɪk meɪkʌp/ [n] សមាសភាពសេនេទិច (ចំណុះសម្ភារតំណពូជសរុបរបស់ឯកត្តៈប្រភេទ ឬពូជមួយដែលមានត្រូវបានគេហៅថាសេណូម (genome))

**genetic marker** /dʒɪˈnɛtɪk ˈmɑːkə/ [n] ឧបករណ៍សម្គាល់សែន, ឧបករណ៍សម្គាល់ពន្ធុ (ជាអំលែលមួយដែលគេប្រើជារង្វាស់ពិសោធ ដើម្បីឈ្វេយ៉ូ ក្រូម៉ូសូម ឬពន្ធុមួយ។ តាមរយៈឧបករណ៍នេះ គេអាចបែងចែកជាឧបករណ៍ជីវគីមីសាស្ត្រ (biochemical markers) ឧ. Isozyme និងឧបករណ៍សម្គាល់ម៉ូលេគុល (molecular marker) ឧ. DNA markers)

**genetic recombination** /dʒɪˈnɛtɪk riːˌkɒmbɪˈneɪʃ(ə)n/ [n] ការបង្កាត់សែន, ការផ្គុំសែន

**genetic resource** /dʒɪˈnɛtɪk rɪˈsɔːs/ [n] ធនធានសែន (ឯកតាមួយនៃលទ្ធភាពបម្រែបម្រួលតំណពូជនៃតម្លៃពិត (ជាក់ស្តែង) ឬជាសក្តានុពល)

**genetic response** /dʒɪˈnɛtɪk rɪˈspɒns/ [n] ការឆ្លើយតបសេនេទិច (ការផ្លាស់ប្តូរនៅក្នុងfrequency សេណូទីបក្នុងការជ្រើសរើសជាបន្តបន្ទាប់។ ក្រោយពីមួយជំនាន់នៃការជ្រើសរើស ការឆ្លើយតបសេនេទិច R ត្រូវបានគេសម្តែងដោយ R = h2 x D ដែល h2 ជាលទ្ធភាពដំណពូជនៃ លក្ខណៈនោះក្នុងការគិតទុកហើយ D ជាការជ្រើសរើសផ្សេងៗគ្នា)

**genetic base** /dʒɪˈnɛtɪk beɪs/ [n] មូលដ្ឋានសេនេទិច (ចំនួនសរុបនៃចម្រុះភាពរបស់សេនេទិចនៅក្នុងក្រុមមួយ)

**genetics** /dʒɪˈnɛtɪks/ [n] វិទ្យាសាស្ត្រសេនេទិច, ពន្ធុវិទ្យា (វិទ្យាសាស្ត្រសិក្សាអំពីការបន្តពូជ ឬអំពីពន្ធុ។)

- population genetics /pɒpjʊˈleɪʃ(ə)n dʒɪˈnɛtɪks/ [n] ការសិក្សាពីសែនក្រុមពូជ (ក្សាពីចំនួនបម្រែបម្រួល (ភាពខុសគ្នា) និងរបាយរបស់ពន្ធុ ឬសែននៅក្នុងក្រុមពូជ ឬប្រភេទពូជមួយ ហើយនិងកត្តាដែលមានឥទ្ធិពលទៅលើពួកវាទាំងនេះ)
- quantitative genetics /ˈkwɒntɪtətɪv dʒɪˈnɛtɪks/ [n] សេនេទិចបរិមាណ

**genital** /ˈdʒɛnɪt(ə)l/ [adj] បន្តពូជ (អង្គជាតិ)

**genitalia** /ˌdʒɛnɪˈteɪlɪə/ [n] ប្រព័ន្ធប្រដាប់ភេទ

**genito-urinary** /ˌdʒɛnɪtəʊ ˈjʊərɪn(ə)ri/ [n] ប្រដាប់បន្តពូជ-នោម (ដែលទាក់ទងជាមួយអង្គជាតិ និងប្រដាប់នោម)

**genome** /ˈdʒiːnəʊm/ [n] សមាសភាពសែន, សេណូម

**genotype** /ˈdʒɛnətʌɪp/ [n] សេណូទីប (សមាសពន្ធុដែលមានក្នុងកោសិកាមួយ ឬគ្រប់កោសិកាទាំងអស់នៃសរីរាង្គ។ ១. សមាសភាពតពូជរបស់ឯកត្តៈមួយ ដែលមាន ឬគ្មានការសម្តែងចេញផេណូទីបរបស់លក្ខណៈមួយ ឬ ច្រើនដែលលាក់នៅខាងក្នុង។ ក៏ដូចជាការចាត់ថ្នាក់ពន្ធុនៃសមាសភាពផ្ដុំនេះដែលមានបញ្ចាក់នៅក្នុងរូបមន្តមួយ។ សេណូទីប ត្រូវបានគេសំគាល់ ជាសំខាន់តាមរយៈការសម្តែងឱ្យឃើញលក្ខណៈរបស់កូន និងសន្តាន ផ្សេងៗទៀត។ សេណូទីបមានអន្តរអំពើជាមួយបរិស្ថាននៅទីនោះ ដើម្បីសម្តែងចេញនូវផេណូទីបនោះ។ ២. ឯកត្តៈដែលបញ្ចាក់លក្ខណៈដោយសមាសភាពផ្ដុំសេនេទិចណាមួយ។ )

**genotype-environment interaction** /ˈdʒɛnətʌɪp ɪnˈvʌɪrənm(ə)nt ɪntərˈakʃ(ə)n/ [n] អន្តរអំពើពន្ធុ ឬសែនណឺថែប-បរិស្ថាន (នៅពេលដែលសេណូទីបមួយចំនួនកើតឡើងនៅក្នុងបរិស្ថានផ្សេងៗគ្នាច្រើន ប្រសិទ្ធិភាពសេណូទីបអាច ប្រែប្រួលទៅតាមបរិស្ថាននោះដែរ។ សេណូទីបមួយអាចសម្តែងចេញបានល្អនៅទីកន្លែងមួយ និងមិនបានល្អ នៅទីកន្លែងផ្សេងទៀត បើប្រៀបធៀបទៅនិងសេណូទីបផ្សេងៗ។ ការសម្តែងចេញរបស់លក្ខណៈមួយ ផេណូទីប (P) អាចសំអាងទៅសេណូទីប (G) និងបរិស្ថាននៅទីនោះ (E) ហើយ និងអន្តរអំពើ (I) ។ ទំនាក់ទំនងនេះត្រូវបានសម្តែង ចេញជាៈ P = G + E + I។)

**gentian** /ˈdʒɛnʃ(ə)n/ [n] សង់ស្យាន (រុក្ខជាតិម្យ៉ាងដែលមានឫសមានពណ៌ស្វាយ ប្រើសម្លាប់មេរោគ)

- gentian violet /ˈdʒɛnʃ(ə)n ˈvʌɪələt/ [n] ទឹកថ្នាំពណ៌ខៀវសម្រាប់សម្លាប់មេរោគ

**genus** /ˈdʒiːnəs/ [n] (ពហុវចនៈ៖ genera) សណ្តាន (ចំណាត់ថ្នាក់មួយនៃជីវករដោយវត្ថីករណ៍វិទ្យា ដែលទាបជាងគ្រួសារតែខ្ពស់ជាងអម្បូរ)

**geochemistry** /dʒiːəʊˈkɛmɪstri/ [n] គីមីធរណីវិទ្យា

**geodesy** /dʒɪˈɒdɪsi/ [n] ភូមិមាត្រវិទ្យា

**geographical relief** /dʒiːəˈgrafɪk(ə)l rɪˈliːf/ [n] លក្ខណៈភូមិសាស្ត្រ

**geography** /dʒɪˈɒgrəfi/ [n] ភូមិវិទ្យា

- applied geography /əˈplʌɪd dʒɪˈɒgrəfi/ [n] ភូមិវិទ្យាអនុវត្ត
- economic geography /ˌiːkəˈnɒmɪk dʒɪˈɒgrəfi/ [n] ភូមិវិទ្យាសេដ្ឋកិច្ច
- human geography /ˈhjuːmən dʒɪˈɒgrəfi/ [n] ភូមិវិទ្យាមនុស្ស
- industrial geography /ɪnˈdʌstrɪəl dʒɪˈɒgrəfi/ [n] ភូមិវិទ្យាឧស្សាហកម្ម
- physical geography /ˈfɪzɪk(ə)l dʒɪˈɒgrəfi/ [n] ភូមិវិទ្យានយោបាយ
- regional geography /ˈriːdʒənl dʒɪˈɒgrəfi/ [n] ភូមិវិទ្យាតំបន់

**geology** /dʒɪˈɒlədʒi/ [n] ភូគព្ភសាស្ត្រ, ធរណីវិទ្យា, ការសិក្សាអំពីថ្ម

**geomorphology** /ˌdʒiːə(ʊ)mɔːˈfɒlədʒi/ [n] ភូមិសណ្ឋានវិទ្យា

**geophysics** /ˌdʒiːə(ʊ)ˈfɪzɪks/ [n] រូបធរណីវិទ្យា

**geophyte** /ˌdʒiːə(ʊ)fʌɪt/ [n] សូមមើលពាក្យ៖ cryptophyte

**geotropism** /ˌdʒiːə(ʊ)ˈtrəʊpɪz(ə)m/ [n] ការលូតលាស់បែររកទិសរបស់រុក្ខជាតិ, ធរណីទំនោរ (តំណបលូតលាស់របស់រុក្ខជាតិទៅតាមទំនាញផែនដី ឬតម្រង់ទិសទៅដី (ទិសវិជ្ជមានតាមទំនាញផែនដី មានឫស និងពន្លកឫស) ឬដុះឡើងពីដី (ច្រាសទិសទំនាញ ឧ. ពន្លកត្រួយ))

**germ** /dʒəːm/ [n]

១. មេរោគ

២. ជីវាណូ (អំប្រីយ៉ុរបស់គ្រាប់ស្រូវ ឬកន្លែងដែលដុះពន្លក និងឫស)

**Germanium** /dʒəːˈmeɪnɪəm/ [n] ហ្គែរម៉ានីញ៉ូម (និមិត្តសញ្ញាគីមី Ge)

**germicide** /ˈdʒəːmɪsʌɪd/ [n] ថ្នាំសំឡាប់មេរោគ, ការសំឡាប់មេរោគ

**germinate** /ˈdʒəːmɪneɪt/ [v] ដុះ, បណ្ដុះ

**germination** /dʒəːmɪˈneɪʃ(ə)n/ [n] ដំណុះគ្រាប់, ការដុះពន្លកគ្រាប់, ការដុះពន្លករបស់លម្អង, ការដុះ, ដំណុះ (ដំណើរការដុះឫស និងពន្លកស្លឹករុក្ខជាតិក្នុងលក្ខខណ្ឌសមស្រប)

- epigeal germination /ˌɛpɪˈdʒiːəl dʒəːmɪˈneɪʃ(ə)n/ [n] (សទិសន័យ៖ epigeous germination) ដំណុះពន្លកលើដើម (ប្រភេទនៃដំណុះពន្លកដែលកូទីលេដុនត្រូវបានរុញឡើងលើផុតពីដីដោយសារការពន្លូតវែងរបស់ហៃប៉ូខកធីល។ ផ្ទុយនឹងពាក្យ Hypogeal germination ការដុះពន្លកពីក្រោមដី។)

- epigeous germination /ˌɛpɪˈdʒiəs dʒəːmɪˈneɪʃ(ə)n/ [n] សូមមើលពាក្យ៖ epigeal germination
- hypogeal germination /ˌhʌɪpə(ʊ)ˈdʒiːəl dʒəːmɪˈneɪʃ(ə)n/ [n] (សទិសន័យ៖ hypogeous germination) ដំណុះពន្លកពីក្រោមដី
- hypogeous germination /ˌhaɪpəˈdʒiəl dʒəːmɪˈneɪʃ(ə)n/ [n] សូមមើលពាក្យ៖ hypogeal germination
- peak germination /piːk dʒəːmɪˈneɪʃ(ə)n/ [n] ចំណុចដំណុះខ្ពស់, ចំណុចដំណុះច្រើនបំផុត (ជាពាក្យទូលាយមួយដែលគេពិពណ៌នាអំពីចំណុចពេលដែលអត្រាដំណុះដុះខ្ពស់បំផុត)
- transition from seed development to seed germination [n] អន្តរកាលពីការវិវឌ្ឍន៍គ្រាប់ទៅដំណុះ
- germination pattern /dʒəːmɪˈneɪʃ ˈpat(ə)n/ [n] គំរូប្រភេទដំណុះ

**germplasm** /dʒəːmˈplaz(ə)m/ [n] ពូជសម្ភូហកម្ម, សម្ភារតំណពូជ, ជីវកំណា, ជីវករ (សភាវរស់មានជីវិតរីកចម្រើនលូតលាស់ និងអភិវឌ្ឍន៍ដូចជាមនុស្ស សត្វ និងរុក្ខជាតិជាដើម។ នៅក្នុងឯកត្តៈឬក្រុមពូជមួយ បណ្តុំសំភារៈតពូជដែលជាមូលដ្ឋានរូបសម្រាប់ការទទួលមរតក ពោលគឺ សេណូទីបអាស្រ័យទៅតាមការផ្ទេររបស់វាទៅជំនាន់ក្រោយ។)

***Gerres filamentosus*** [sci.n] សូមមើលពាក្យ៖ whipfin silver-biddy

**gestation** /dʒɛˈsteɪʃ(ə)n/ [n] ភាពមានគភ៌

**gherkin** /ˈɡəːkɪn/ [n] ត្រសក់ជ្រក់ (ឈ្មោះវិទ្យាសាស្ត្រ *Cucumis vulgaris* var. *div.)*

**giant clam** /ˈdʒʌɪənt klam/ [n] គ្រុំយក្ស (ឈ្មោះវិទ្យាសាស្ត្រ *Tridacna gigas*)

**giant gourami** /ˈdʒʌɪənt ʊ(ə)ˈrɑːmi/ [n] ត្រីរមាស (ឈ្មោះវិទ្យាសាស្ត្រ *Osphronemus gouramy)*

**giant pigweed** /ˈdʒʌɪənt ˈpɪɡwiːd/ [n] ផ្ទីថ្ម (ឈ្មោះវិទ្យាសាស្ត្រ *Trianthema portulacastrum*)

**giant sensitive plant** /ˈdʒʌɪənt ˈsɛnsɪtɪv plɑːnt/ [n] បន្លាស្អិត (ឈ្មោះវិទ្យាសាស្ត្រ *Mimosa diplotricha, Mimosa invisa*)

**giant's kettle** /ˈdʒʌɪənts ˈkɛt(ə)l/ [n] រណ្តៅបាតខ្ទះធំ

**gilgai microrelief** /ˈɡɪlɡʌɪ ˈmʌɪkrə(ʊ)rɪˈliːf/ [n] ស្ថានភាពផ្ទៃដីខាងលើ

**gill** /ɡɪl/ [n] ស្រកី

**gimlet** /ˈɡɪmlɪt/ [n] ដែកកណ្តារ, ដែកខួង

**ginger** /ˈdʒɪndʒə/ [n] ខ្ញី (ឈ្មោះវិទ្យាសាស្ត្រ *Zingiber officinale*)

**gingiva** /dʒɪnˈdʒʌɪvə/ [n] សូមមើលពាក្យ៖ gum

**gingivitis** /ˌdʒɪndʒɪˈvʌɪtɪs/ [n] ជំងឺរលាកអញ្ចាញធ្មេញ

**GINI coefficient** /ˈdʒiːni ˌkəʊɪˈfɪʃ(ə)nt/ [n] មេគុណតាមបែបហ្គីនី (មេគុណតាមបែបហ្គីនី គឺជាការវាស់វែងពីរបាយដែលពុំស្មើភាពគ្នា ដោយត្រូវបានគេប្រើដើម្បីកំណត់ពីភាពផ្សេងៗ ឬខុសៗគ្នានៃប្រាក់ចំណូលនៅទូទាំងសង្គម។ មេគុណនេះ មានលំដាប់ពីលេខ 0 (ស្មើភាពគ្នាឥតខ្ចោះ) ទៅលេខ ១ (ពុំស្មើភាពគ្នាទាល់តែសោះ ឬគំលាតឥតខ្ចោះ)។)

**girdling** /ˈɡəːd(ə)lɪŋ/ [n] ការជៀសម្បកដើមឈើ, វិធីសាស្ត្រសម្លាប់ដើមឈើ (ដោយការកាត់សម្បកដើមជុំវិញ វារួមមានការប្រើប្រាស់ថ្នាំសម្លាប់រុក្ខជាតិ ថ្នាំគីមីផងដែរ។)

**gizzard** /ˈɡɪzəd/ [n] កោះ (សត្វ), កោះមាន់

**glabrous** /ˈɡleɪbrəs/ [adj] រលោងភាព (ភាពរលោង មិនគ្រើម មិនមានដុះរោម), គ្មានរោម (អំពីទម្រង់របស់រុក្ខជាតិ)

**glacial scratching** /ˈɡleɪsɪəl skratʃɪŋ/ [n] គំនូរស្លាកស្នាមនៃទឹកកក

**glacial till** /ˈɡleɪsɪəl tɪl/ [n] (សទិសន័យ៖ drift) ល្បាប់ដែលនាំមកដោយដុំទឹកកក

**glaciation** /ˌɡleɪsɪˈeɪʃ(ə)n/ [n] សម័យទឹកកក

**glacier** /ˈɡlasɪə/ [n] ផែនទឹកកក

**glaciology** /ˌɡleɪsɪˈɒlədʒi/ [n] ទឹកកកវិទ្យា

**glamour** /ˈɡlamə/ [n] ភាពស្រស់បំព្រង

**gland** /ɡland/ [n] (សទិសន័យ៖ node) ក្រពេញ

- antennal gland /anˈtɛnəl ɡland/ [n] ក្រពេញអង់តែន (សរីរាង្គបញ្ចេញក្រៅ ដែលស្ថិតនៅខាងចុងរបស់ពពួកបង្កងមួយចំនួន)
- endocrine gland /ˈɛndə(ʊ)krʌɪn ɡland/ [n] ក្រពេញបញ្ចេញអ័រម៉ូន, ក្រពេញអន្តោមញ្ញ៉ន
- lymph gland /lɪmf ɡland/ [n] (សទិសន័យ៖ lymph node) គ្រន្ថី, ក្រពេញទឹករងៃ
- mammary gland /ˈmaməri ɡland/ [n] ក្រពេញទឹកដោះ
- parotid gland /pəˈrɒtɪd ɡland/ [n] ក្រពេញត្រចៀ

**glanders** /ˈglandəz/ [n pl] ជំងឺរលាកសរសៃឆ្លង (សត្វ), ជំងឺឆ្លងនៃសត្វពាហនៈដែលអាចឆ្លងមកមនុស្ស

**glans** /glanz/ [n] (ពហុវចនៈ៖ glandes) ក្រពេញ (នៅចុងលិង្គ)

**glasser's disease** /glɛsəs dɪˈziːz/ [n] ជំងឺក្លាសេ

**glasshouse** /ˈglɑːshaʊs/ [n] ផ្ទះកញ្ចក់

**glaucoma** /glɔːˈkəʊmə/ [n] ជំងឺអៀស៊ីភ្នែក, ជំងឺភ្នែកដែលតង់ស្យុងភ្នែកលើសពីធម្មតា

**glaucous** /ˈglɔːkəs/ [adj] បៃតងព្រលែត (អំពីទម្រង់របស់រុក្ខជាតិ)

**glebe** /gliːb/ [n] ដីសម្បូរជីជាតិ

**gleization** /gleɪˈzeɪʃ(ə)n/ [n] (សទិសន័យ៖ gleying process) ការក្លាយជាឥដ្ឋ

**gley** /gleɪ/ [n] ដីប្រផេះខៀវដោយជាំទឹកខ្វះខ្យល់អុកស៊ីសែន

**global warming** /ˈgləʊb(ə)l wɔːmɪŋ/ [n] ការកើនឡើងកម្តៅផែនដី

**globe fringe-rush** /gləʊb frɪn(d)ʒ rʌʃ/ [n] កក់ភ្នែកក្តាមតូច (ឈ្មោះវិទ្យាសាស្ត្រ *Fimbristylis miliacea*)

***Globicephala macrorhynchus*** [sci.n] សូមមើលពាក្យ៖ short-finned pilot whale

**globose** /ˈgləʊbəʊs/ [adj] រាងមូល, រាងស្វៃ

**globular** /ˈglɒbjʊlə/ [adj] រាងស្វៀ, រាងមូលដូចបាល់

**globule** /ˈglɒbjuːl/ [n] គោលិកា

**globulin** /ˈglɒbjʊlɪn/ [n] ក្លូប៊ុយលីន (គោលិកាដែលមិនរលាយនៅក្នុងទឹកសាប តែរលាយនៅក្នុងទឹកប្រៃ)

**glomerulus** /glɒˈmɛr(j)ʊləs/ [n] (ពហុវចនៈ៖ glomeruli) ក្លូមេរុល, ក្រុមសរសៃឈាមតូចៗ (បិតនៅវក្កំ)

**glossitis** /glɒˈsʌɪtɪs/ [n] ជំងឺរលាកអណ្តាត, ជ្រាំងអណ្តាត

***Glossogobius aureus*** [sci.n] សូមមើលពាក្យ៖ golden tank goby

***Glossogobius giuris*** [sci.n] សូមមើលពាក្យ៖ gangetic tank goby

***Glossogobius koragensis*** [sci.n] សូមមើលពាក្យ៖ koragu tank goby

***Glossogobius sparsipapillus*** [sci.n] សូមមើលពាក្យ៖ linecheek tank goby

**glottis** /ˈglɒtɪs/ [n] រន្ធខ្យល់

**glove** /glʌv/ [n] ស្រោមដៃ

**gluconeogenesis** /ˌglukoʊˌniəˈdʒɛnə sɪs/ [n] កំណគ្លុយកូស (ការសំយោគគ្លុយកូសពីម៉ូលេគុលមិនមែនជាកាបូ-អ៊ីដ្រាតជាច្រើន។ វាកើតក្នុងថ្លើម និងតម្រងនោមសត្វ និងក្នុងគ្រាប់រុក្ខជាតិ។)

**glucose** /ˈgluːkəʊz/ [n] គ្លុយកូស (មធុរជាតិ, ជាតិផ្អែមក្នុងផ្លែឈើ), ជាតិស្ករ

**glume** /gluːmz/ [n] កំពកតូចមួយស្ថិតនៅផ្ទាល់ពីក្រោមសម្បក និប្ផល

- rudimentary glume /ˌruːdɪˈmɛnt(ə)ri gluːm/ [n] កំពកនៃចុងស្មែង (ផ្នែកខាងចុងគេបំផុតនៃស្មែង ដែលមានកំប៉ោងដូចពែង។ វាស្ថិតនៅក្រោមត្របកមិនបានការ។)

**gluteus** /ˈgluːtɪəs/ [n] សាច់ដុំខ្ទង់នៅត្រង់ត្រគាក

**glutinous** /ˈgluːtɪnəs/ [adj] ស្អិត

**glycerine** /ˈglɪs(ə)rɪn/ [n] (សទិសន័យ៖ glycerol) គ្លីសេរីន

**glycerol** /ˈglɪs(ə)rɒl/ [n] សូមមើលពាក្យ៖ glycerine

***Glycine max*** [sci.n] សូមមើលពាក្យ៖ soybean, soya bean

**glycogen** /ˈglʌɪkədʒ(ə)n/ [n] គ្លីកូសែន (ជាតិផ្អែមដែលស្តុកក្នុងថ្លើម)

***Glyptothorax fuscus*** [sci.n] ត្រីកញ្ចុះក្របី

***Glyptothorax lampris*** [sci.n] ត្រីក្របី

***Glyptothorax* sp. cf. *fuscus*** [sci.n] ត្រីក្របី

**gnat** /nat/ [n] សុច, មមង់

**gnaw** /nɔː/ [v] សូមមើលពាក្យ៖ erode

**goad** /gəʊd/ [n] ជន្លួញ (ចាក់គោ)

**goat** /gəʊt/ [n] ពពែញី

**goat weed** /gəʊt wiːd/ [n] ទន្រ្ទានខេត្តស្វាយ (ឈ្មោះវិទ្យាសាស្ត្រ *Ageratum conyzoides*)

**godown** /ˈgəʊdaʊn/ [n] (សទិសន័យ៖ warehouse) ឃ្លាំង

**goitre** /ˈgɔɪtə/ [n] ជំងឺពកក

**Gold** /gəʊld/ [n] មាស (និមិត្តសញ្ញាគីមី Au)

**golden apple snail** /ˈɡəʊld(ə)n ˈap(ə)l sneɪl/ [n] ខ្យងស៊ីស្រូវ (ពួកខ្យងដែលមានសម្បកពណ៌លឿងដូចមាស ស្ថិតក្នុងអម្បូរ *Pomacea sp.*)

**golden tank goby** /ˈɡəʊld(ə)n taŋk ˈɡəʊbi/ [n] ត្រីក្បាន (ឈ្មោះវិទ្យាសាស្ត្រ *Glossogobius aureus*)

**gonad** /ˈɡəʊnad/ [n] ក្រពេញភេទ (ពងចាប់កកើតដំបូង)

***Gonatocerus* spp.** [sci.n] ឪម៉ាល់ (បារាសិតលើពងមមាច)

***Goniozus* nr. *Triangulifer*** [sci.n] ពួកឪម៉ាល់ (បារាសិតលើដង្កូវមូរស្លឹក)

**gonorrhea** /ˌɡɒnəˈrɪə/ [n] រោគប្រមេះ

**gonochoristic** /ˌɡɒnəkləʊrˈrɪstɪk/ [adj] ឯកភេទ

**gonococcus** /ˌɡɒnəˈkɒkəs/ [n] មេរោគប្រមេះ

**goonch** /ɡuːn(t)ʃ/ [n] ត្រីក្របី (ឈ្មោះវិទ្យាសាស្ត្រ *Bagarius yarrelli*)

**goose** /ɡuːs/ [n] (ពហុវចនៈ៖ geese) ក្ងានញី

**gooseberry** /ˈɡʊzb(ə)ri/ [n] ពពួកកន្ទួត

- Chinese star gooseberry /tʃʌɪˈniːz stɑː ˈɡʊzb(ə)ri/ [n] កន្ទួត
- Indian gooseberry /ˈɪndɪən ˈɡʊzb(ə)ri/ [n] កន្ទួតព្រៃ (ឈ្មោះវិទ្យាសាស្ត្រ *Phyllanthus emblica*)
- otaheite gooseberry [n] កន្ទួត (ឈ្មោះវិទ្យាសាស្ត្រ *Phyllanthus distichus*)

**gooseweed** /ɡuːs wiːd/ [n] ស្មៅតាសៀវ (ឈ្មោះវិទ្យាសាស្ត្រ *Sphenoclea zeylanica*)

**gossen** /ˈɡɒz(ə)n/ [n] ថ្មជាសារធាតុដែក, មួកដែក

***Gossypium herbaceum*** [sci.n] សូមមើលពាក្យ៖ cotton

**gossypol** /ˈɡɒsɪpɒl/ [n] កូសស៊ីប៉ុស (ជាតិពុលលឿងនៅក្នុងគ្រាប់កប្បាស)

**gotu kola** [n] វល្លិត្រចៀកក្រាញ់ (ឈ្មោះវិទ្យាសាស្ត្រ *Centella asiatica*)

**gourd** /ɡʊəd/ [n] ពពួកបន្លែឡើងទ្រើង ដូចជាត្រឡាច ននោង ម្រះ ឃ្លោក, ប្រភេទផ្លែសាច់ត្រសក់-ឃ្លោក

- bitter gourd /ˈbɪtə ɡʊəd/ [n] (សទិសន័យ៖ bitter lemon) ម្រះ (ឈ្មោះវិទ្យាសាស្ត្រ Momordica charantia)
- bottle gourd /ˈbɒt(ə)l ɡʊəd/ [n] ឃ្លោកដប (ឈ្មោះវិទ្យាសាស្ត្រ *Lagenaria siceraria*)
- sponge gourd /spʌn(d)ʒ ɡʊəd/ [n] (សទិសន័យ៖ loofah) ននោងសាញ, ននោងប្រហើរ, ននោងមូល (ឈ្មោះវិទ្យាសាស្ត្រ *Luffa cylindrica*)
- wax gourd /waks ɡʊəd/ [n] ត្រឡាច (ឈ្មោះវិទ្យាសាស្ត្រ *Benincasa hispida*)
- winter gourd /ˈwɪntə ɡʊəd/ [n] ត្រឡាច (ឈ្មោះវិទ្យាសាស្ត្រ *Benincasa hispida*)

**governor's plum** /ˈɡʌv(ə)nəs plʌm/ [n] ក្រខុបញី

**grading** /ɡreɪdɪŋ/ [n] ការចាត់គ្រាប់ពូជជាប្រភេទ ឬធុន (ជាទូទៅ ផ្អែកលើគុណភាព)

**gradual metamorphosis** /ˈɡradʒʊəl ˌmɛtəˈmɔːfəsɪs/ [n] រូបផ្តុំមិនពេញលេញ (ពួកសត្វល្អិតដែលក្នុងវដ្តជីវិតមានការប្រែប្រួលពី ពង-កូនញាស់-សត្វពេញវ័យ ឧទាហរណ៍ ស្រឹងជញ្ជាក់ទឹកដោះ)

**graft** /ɡrɑːft/ [v] បន្សាំ, បំបៅ

**graft** /ɡrɑːft/ [n] ការបំបៅមែកឈើ, ខ្នែងបំបៅ, ភ្នែកបំបៅ

**graft union** /ɡrɑːft ˈjuːnjən/ [n] ចំណុចបន្សីគ្នានៃការបំបៅ, កន្លែងបន្សីគ្នានៃការបំបៅ (ចំណុចបន្សីរបស់រុក្ខជាតិដែលបានបំបៅបញ្ចូលគ្នា (កន្លែងមែកបំបៅ និងគល់បំបៅបន្សីគ្នា))

**graft versus host disease (GVHD)** /ɡrɑːft ˈvəːsəs həʊst dɪˈziːz/ [n] ការផ្សាំប្រឆាំងនឹងជំងឺរបស់ធ្មួល

**grafter** /ˈɡrɑːftə/ [n] អ្នកផ្សាំមែកឈើ

**grafting** /ɡrɑːftɪŋ/ [n] ការបំបៅមែក ខ្នែង ( ការផ្គុំផ្នែកផ្សេងៗរបស់ឯកត្តៈខុសៗគ្នាដោយផ្តិតជាលិកាដើម្បីវាប៉ះស៊ីគ្នា និងធ្វើឱ្យវាអាចដុះលូតលាស់បាន។ ជាទូទៅ ផ្នែកខាងលើ (មែក/ខ្នែង) ត្រូវគេផ្គុំវាជាមួយផ្នែកក្រោមជាប់ឬស (គល់បំបៅ)។ ផ្នែកទាំង២បន្សីគ្នា នេះនិងឯកត្តៈដែលផ្សំបាននេះគេហៅថាមែកឈើបំបៅ។ ព្រោះតែមែក/ខ្នែងផ្សាំខាងលើនៅរក្សាសមាសភាពសេនេទិចដើមរបស់វា ដូច្នេះការបំបៅមែកឈើមានប្រយោជន៍សម្រាប់ធ្វើការរក្សាទុកពិសោធន៍ និងការបណ្តុះកូនឈើ។)

**grain** /ɡreɪn/ [n]

១. គ្រាប់ធញ្ញជាតិ (ពពួកគ្រាប់តូចៗនៃរុក្ខជាតិដូចជា ស្រូវ ឬស្រូវសាលីជាដើម ហើយជួនកាលសំដៅទៅលើគ្រាប់សណ្តែកសម្រាប់ធ្វើអាជីវកម្ម), ប្រភេទផ្លែស្ងួតគ្រាប់

២. កូនជញ្ជីងដែលមានទម្ងន់ស្រាល

- filled grain /fɪld ɡreɪn/ [n] គ្រាប់ពេញ (គ្រាប់ស្រូវ ឬអង្គដែលពេញទៅដោយអង់ដូស្ពែមល្អ)

- mature grain /məˈtʃʊə greɪn/ [n] គ្រាប់ទុំ (ដំណាក់កាលនៅពេលដែលគ្រាប់ស្រូវទាំងឡាយក្នុងកួរមានពណ៌លឿង គ្រាប់ពេញ ហើយរឹង)
- milk grain /mɪlk greɪn/ [n] គ្រាប់ទឹកដោះ (ស្រូវ) (គ្រាប់ស្រូវនៅដំណាក់កាលទឹកដោះ)
- naked grain /ˈneɪkɪd greɪn/ [n] គ្រាប់បកសម្បកហើយ

**gram negative** /gram ˈnɛgətɪv/ [n] ក្រាមដកនៃបាក់តេរី (អាចសាកពណ៌វិញ)

**gram positive** /gram ˈpɒzɪtɪv/ [n] ក្រាមបូកនៃបាក់តេរី (ពុំអាចសាកពណ៌វិញ)

**Gramineae** [n] (សទិសន័យ៖ Poaceae) គ្រួសារធញ្ញជាតិ (គ្រួសាររុក្ខជាតិមួយដ៏ធំនៅក្នុងចន្ទរុក្ខជាតិ ស្លឹករបស់វារាងវែងជាស៊ីឡាំងស្រួចចុង ហើយចែកជាបន្ទះ និងស្រទបស្លឹក ផ្លែរបស់វាជាគ្រាប់តូចៗហើយរឹង។ ក្នុងគ្រួសារនេះមានស្រូវ ពោត ស្រូវសាលី ឬស្សី អំពៅជាដើម ដែលមានសារៈសំខាន់យ៉ាងខ្លាំងក្នុងវិស័យកសិកម្ម)

**granite** /ˈgranɪt/ [n] ថ្មក្រានីត (ស៊ីលីស, ហ្វែលស្បាត)

**granular** /ˈgranjʊlə/ [adj] ដែលជាគ្រាប់តូចៗ

**granulation** /ˌgranjʊˈleɪʃ(ə)n/ [n]
១. (ចំពោះសត្វ) ផ្លួច, តូចៗ (មានគ្រាប់តូចៗ)
២. ការបែក ឬកើតជាគ្រាប់ៗ
៣. កន្ទួលសាច់តូចៗ កើតលើផ្ទៃដំបៅ

**granule** /ˈgranjuːl/ [n]
១. (ចំពោះសត្វ) គ្រាប់តូចៗ (នៅលើផ្ទៃដំបៅ)
២. គ្រួសតូចៗ

**granulometry** /ˈgranjuːlˈɒmɪtri/ [n] វង្វាស់វែង

**grape** /greɪp/ [n] ទំពាំងបាយជូរ

**grapefruit** /ˈgreɪpfruːt/ [n] (សទិសន័យ៖ pomelo, shaddock) ក្រូចថ្លុង (ឈ្មោះវិទ្យាសាស្ត្រ *Citrus maxima*)

**grapevine** /ˈgreɪpvʌɪn/ [n] ដើមទំពាំងបាយជូរ

**graph** /grɑːf/ [n] ក្រាហ្វិក (វិធីសាស្ត្រនៃការឡើងបង្ហាញពីទិន្នន័យដោយមានទីតាំងចំណុចប្រសព្វរវាងបន្ទាត់ដេក (អាប់ស៊ីស) និងបន្ទាត់ឈរ (អរដោនេ))

**carp** /kɑːp/ [n] ពពួកត្រីកាប និង ត្រីព្រលូង

**grass thrips** /grɑːs θrɪps/ [n pl] ទ្រីប

**grass** /grɑːs/ [v] ដាំស្មៅ, ឱ្យស៊ីស្មៅ

**grass** /grɑːs/ [n] ស្មៅ (ស្មៅក្នុងគ្រួសារ Gramineae (Poaceae) មានដើមតូច មូលត្រង់ឡើងលើមានអាយុកាលតិចជាងមួយឆ្នាំ ឬច្រើនជាងមួយឆ្នាំ។ ដើមវាគេហៅថា culm មានថ្នាំង និងចន្លោះថ្នាំងក្លីរលោង។ ស្លឹកវាដុះចេញពីថ្នាំង មានបន្ទះស្លឹក និងស្រទបស្លឹកស្រោបជុំវិញ។

- barnyard grass /bɑːnjɑːd grɑːs/ [n] ស្មៅបែកក្បាលមានកន្ទុយ, ស្មៅបែកក្បាល (ប្រភេទស្មៅដែលស្ថិតក្នុងអម្បូរ *Echinochola crus-gali*)
- bermuda grass /bərˈmjuːdə grɑːs/ [n] ស្មៅចិញ្ចៀន (ឈ្មោះវិទ្យាសាស្ត្រ *Cynodon dactylon*)
- blade of grass /bleɪd ɒv grɑːs/ [n] ស្លឹកស្មៅ (ដែលរាងដូចមុខកាំបិត)
- cogon grass /ˈkəʊgɒn grɑːs/ [n]
  ១. ស្បូវ (ប្រភេទស្មៅស្ថិតក្នុងអម្បូរ *Echinochloa crus-galli*)
  ២. ស្បូវឃ្លាំង (ឈ្មោះវិទ្យាសាស្ត្រ *Imperata cylindrica*)
- crab grass /krab grɑːs/ [n] ស្មៅពុកបង្កង (ឈ្មោះវិទ្យាសាស្ត្រ *Digitaria ciliaris*)
- creeping panic grass /kriːpɪŋ ˈpanɪk grɑːs/ [n] ស្មៅគោ (ឈ្មោះវិទ្យាសាស្ត្រ *Brachiaria reptans*)
- crowfoot grass /ˈkrəʊfʊt grɑːs/ [n] ស្មៅជើងតុកកែ, ស្មៅជើងក្រាស់ (ឈ្មោះវិទ្យាសាស្ត្រ *Dactyloctenium aegyptium*)
- Egyptian grass /ɪˈdʒɪpʃ(ə)n grɑːs/ [n] ស្មៅជើងក្រាស់ (ឈ្មោះវិទ្យាសាស្ត្រ *Dactyloctenium aegyptium*)
- goosegrass /'guːsgrɑːs/ [n] ស្មៅជើងក្រាស់ (ឈ្មោះវិទ្យាសាស្ត្រ *Eleusine indica*)
- guinea grass /ˈgɪni grɑːs/ [n] ស្មៅស៊ីមួន (ឈ្មោះវិទ្យាសាស្ត្រ *Panicum maximum*)
- hamil guinea grass [n] ស្មៅហាមីល
- Indian goosegrass /ˈɪndɪən ˈguːsgrɑːs/ [n] ស្មៅទន្សោង (ឈ្មោះវិទ្យាសាស្ត្រ *Eleusine indica*)
- itchgrass /'ɪtʃgrɑːs/ [n] ស្មៅរមាស់ (ឈ្មោះវិទ្យាសាស្ត្រ *Rottboellia cochinchinensis*)
- Johnson grass /ˈdʒɒns(ə)n grɑːs/ [n] ត្រែង (ឈ្មោះវិទ្យាសាស្ត្រ *Sorghum halepense*)

- knotgrass /ˈnɒtgrɑːs/ [n] ស្មៅរពាក់ទឹកវារ (ឈ្មោះវិទ្យាសាស្ត្រ *Paspalum distichum*)
- lemon grass /ˈlɛmən grɑːs/ [n] ស្លឹកគ្រៃ (ឈ្មោះវិទ្យាសាស្ត្រ *Cymbopogon citratus*)
- *Imperata grass* [sci.n] ស្បូវឃ្លាំង
- Napier grass /ˈneɪpɪə grɑːs/ [n] ស្តេចស្មៅ, ស្មៅដំរី (ឈ្មោះវិទ្យាសាស្ត្រ៖ *Pennisetum purpureum*)
- paragrass /ˈparəgrɑːs/ [n] ស្មៅបារាំង (ឈ្មោះវិទ្យាសាស្ត្រ *Brachiaria mutica*)
- ruzi grass /ruːzi grɑːs/ [n] ស្មៅរុហ្សីសម្រាប់ចំណីសត្វ
- saramollagrass [n] (សទិសន័យ៖ wrinkled grass) ស្មៅចំពុះទា (ឈ្មោះវិទ្យាសាស្ត្រ Ischaemum rugosum)
- torpedo grass [n] ស្មៅបំពង់ (ឈ្មោះវិទ្យាសាស្ត្រ *Panicum repens*)
- wrinkled grass /ˈrɪŋk(ə)ld grɑːs/ [n] សូមមើលពាក្យ៖ saramollagrass

**grass-burning** /grɑːs ˈbəːnɪŋ/ [n] ការដុតស្មៅ ឬព្រៃ (ដើម្បីដាំដំណាំ)

**grassland** /ˈgrɑːsland/ [n] វាលស្មៅ

- **flooded grassland** /flʌdɪd ˈgrɑːsland/ [n] វាលស្មៅលិចទឹក

**grassless** /ˈgrɑːslɛs/ [adj] ដែលគ្មានស្មៅដុះ

**grassy** /ˈgrɑːsi/ [adj] ដែលមានស្មៅដុះដុក

**grating** /ˈgreɪtɪŋ/ [n]
១. (ចំពោះធរណីវិទ្យា) ការដាក់ប្រដើសដើម្បីទប់ដី
២. ការឈូស (ឧ. ការ៉ុត)

**gravel pit** /ˈgrav(ə)l pɪt/ [n] ការរដ្ឋានយកថ្ម

**gravel** /ˈgrav(ə)l/ [v] ចាក់ក្រួស

**gravel** /ˈgrav(ə)l/ [n] ក្រួស, កម្ទេចថ្ម, កម្ទេចឥដ្ឋ, កម្ទេចក្រួស (មកពីការរុះរើពីការដ្ឋាន)

- chalky gravel /ˈtʃɔːki ˈgrav(ə)l/ [n] ក្រួសថ្មកំបោរ
- fine gravel /fʌɪn ˈgrav(ə)l/ [n] ក្រួស (០.២-២០ ម.ម)
- lag gravel /lag ˈgrav(ə)l/ [n] សូមមើលពាក្យ៖ desert pavement

**gravelly** /ˈgrav(ə)li/ [adj] ដែលមានក្រួស

**gravid** /ˈgravɪd/ [adj] សូមមើលពាក្យ៖ pregnant

**gravida** [n] ស្ត្រីមានផ្ទៃពោះ (គេនិយាយពាក្យនេះព្រមគ្នាជាមួយចំនួនពេលមានផ្ទៃពោះ)

**gray leaf spot** /greɪ liːf spɒt/ [n] ជំងឺអុតស្លឹកពណ៌ប្រផេះ (ជំងឺនេះបង្កដោយផ្សិត Stemphylium solani និង Stemphylium lycopersici ដោយឆ្លងតាមរយៈខ្យល់ ដោយឆ្លងរាលដាលតាមរយៈខ្យល់ ភាគច្រើនកើតមាននៅពេលមានអាកាសធាតុក្តៅល្មម។ ភ្នាក់ងារបង្កជំងឺអាចរស់នៅក្នុងកាកសំណល់រុក្ខជាតិ ដំណាំប៉េងប៉ោះដុះមួរ និងដំណាំអំបូរប៉េងប៉ោះផ្សេងទៀត និងស្មៅចង្រៃ។ ស្លឹកសើមយូរ កម្តៅខ្ពស់ និងក្តៅល្មមជាលក្ខខណ្ឌសមស្របសម្រាប់ការរាលដាលនៃជំងឺ)

**graze** /greɪz/ [v] ស៊ីស្មៅ, ប៉ះប្រផិតៗ

**grazing** /ˈgreɪzɪŋ/ [n] វាលស្មៅ, ដីសម្រាប់ចិញ្ចឹមគោក្របី

**grease** /griːs/ [n] សូមមើលពាក្យ៖ fat

**greater scissortail** /greɪtə ˈsɪzəteɪl/ [n] ត្រីចង្វាពោត (ឈ្មោះវិទ្យាសាស្ត្រ *Rasbora caudimaculata*)

**greenhouse** /griːn haʊs/ [n] ផ្ទះកញ្ចក់

**green kuang futsoi** [n] ស្ពៃចង្កឹះ

**green manuring** /griːn ˈməˈnjʊərɪŋ/ [n] ការប្រើប្រាស់ដីស្រស់ (ការយកជីស្រស់ទៅប្រើប្រាស់លើដំណាំផ្សេងៗ)

**green onion** /griːn ˈʌnjən/ [n] ខ្ទឹមស្លឹក

**green semilooper** /griːn ˈsɛmiluːpə/ [n] ដង្កូវបាក់ខ្នង (ឈ្មោះវិទ្យាសាស្ត្រ *Naranga aenescens*)

**green smut** /griːn ˈsmʌt/ [n] សូមមើលពាក្យ៖ false smut

**greenbottle pufferfish** /griːnˈbɒt(ə)l ˈpʌfəfɪʃ/ [n] ត្រីកំពត (ឈ្មោះវិទ្យាសាស្ត្រ *Chonerhinos nefastus*)

**greenhouse gas** /ˈgriːnhaʊs gas/ [n] ឧស្ម័នផ្ទះកញ្ចក់

**grid** /grɪd/ [n] សំណាញ់លួស, ទ្រុងដែក

**grime** /grʌɪm/ [n] ក្អែល

**grimy** /ˈgrʌɪmi/ [adj] ដែលមានក្អែល, កខ្វក់

**grind** /grʌɪnd/ [v] សំលៀង, កិនម៉ដ្ឋ

**grinder** /ˈgrʌɪndə/ [n] អ្នកសំលៀងកាំបិត, អ្នកកិនគ្រាប់កាហ្វេ

**grindstone** /ˈgrʌɪn(d)stəʊn/ [n] ថ្មសំលៀងកាំបិត

**grit** /grɪt/ [n] អំបែង, ដុំដែលមានជ្រុង, ខ្សាច់គ្រើមដូចអំបិលក្រួស

**groin** /grɔɪn/ [n] ក្រលៀន

**leached grood** /liːtʃt gruːd/ [n] ដីប្រភេទព្រៃប្រផេះខ្មៅដែលមានស្មៅដុះ

**groove** /gruːv/ [v] បង្កើតជាប្រឡាយ, ចោះប្រឡាយ

**groove** /gruːv/ [n] ជ្រលង, ស្នាមលក

**gross domestic product (GDP)** /grəʊs dəˈmɛstɪk ˈprɒdʌkt/ [n] ផលិតផលក្នុងស្រុកសរុប, ផលទុនក្នុងស្រុកសរុប (ចំណូលជាតិដែលត្រូវគណនាតាមវិធីផលសរុបដែលទទួលបាន ពោលគឺជាផលបូកនៃតម្លៃទាំងអស់ដែលបូកបន្ថែមនៅក្នុងសេដ្ឋកិច្ច ឬជាតម្លៃនៃផលិតផលចុងក្រោយដែលផលិតបាននៅក្នុងសេដ្ឋកិច្ច)

**gross national product (GNP)** /grəʊs ˈnaʃ(ə)n(ə)l ˈprɒdʌkt/ [n] ផលទុនជាតិសរុប (ចំណូលជាតិដែលត្រូវគណនាតាមវិធីចំណូលសរុប ពោលគឺជាផលបូកនៃកត្តាចំណូលដែលរកបាន បូកនឹងការបញ្ចុះតម្លៃ (ដើម្បីឱ្យបានតម្លៃទីផ្សារ) បូកនឹងតម្លៃពន្ធដារមិនចំពោះ ដកនឹងជំនួយជាប្រាក់)

**gross output** /grəʊs ˈaʊtpʊt/ [n] ទិន្នផលសរុប

**gross price** /grəʊs prʌɪs/ [n] ថ្លៃដុល

**gross production** /grəʊs prəˈdʌkʃ(ə)n/ [n] ផលិតកម្មសរុប

**gross return** /grəʊs rɪˈtəːn/ [n] ចំណូលក្នុង១ខ្នាតឯកតា (ចំណូលដុល)

**gross return on capital** /grəʊs rɪˈtəːn ɒn ˈkapɪt(ə)l/ [n] ចំណូលដែលបានពីការលក់ផលដែលផលិតបាន ផាត់ថ្លៃទិញសម្ភារឧបករណ៍ចំណាយលើពលកម្ម ដី ការប៉ិនប្រសប់របស់អ្នកគ្រប់គ្រង និងពន្ធដារចេញ

**grotto** /ˈgrɒtəʊ/ [n] ល្អាង, គុហា, រូង

**ground lizard** /graʊnd ˈlɪzəd/ [n] សត្វជាស

**ground** /graʊnd/ [n] ផ្ទៃដី, ដី

- barren ground /ˈbar(ə)n graʊnd/ [n] សូមមើលពាក្យ៖ barren land
- corn ground /kɔːn graʊnd/ [n] (សទិសន័យ៖ wheat earth) ដីសម្រាប់ដាំស្រូវសាលីទន់
- gradin ground /grəˈdiːn graʊnd/ [n] ដីដែលមានទិដ្ឋភាពជាថ្នាក់ៗ (នៅលើជម្រាល)
- loose ground /luːs graʊnd/ [n] ដីដែលអាចហូរបាន (សើមខ្លាំង)
- low ground /ləʊ graʊnd/ [n] (ចំពោះធរណីវិទ្យា) (សទិសន័យ៖ flat, shoal, swallow) បាតជ្រលង, បាតស្ទឹងបឹងបួ
- natural ground /ˈnatʃ(ə)r(ə)l graʊnd/ [n] ដីធម្មជាតិ
- patterned ground /ˈpat(ə)nd graʊnd/ [n] សូមមើលពាក្យ៖ fissure network soil
- permanently frozen ground /ˈpəːm(ə)nəntli ˈfrəʊzn graʊnd/ [n] ស្រទាប់ដីដែលកកជានិច្ច
- unfrozen ground /ʌnˈfrəʊzn graʊnd/ [n] ដីដែលមិនត្រជាក់កក

**groundnut** /ˈgraʊn(d)nʌt/ [n] សណ្ដែកដី (ឈ្មោះវិទ្យាសាស្ត្រ *Arachis hypogea*)

**groundwater** /ˈgraʊn(d)wɔːtə/ [n] (សទិសន័យ៖ phreatic water) ទឹកក្នុងដី, ដង្ហើមទឹក, ទឹកក្រោមដីតាមតំបន់មាត់បឹង (ទន្លេ)

- confined groundwater /kənˈfʌɪnd ˈgraʊn(d)wɔːtə/ [n] ទឹកផុសពីក្នុងដី
- floating groundwater /ˈfləʊtɪŋ graʊnd ˈwɔːtə/ [n] ស្រទាប់ទឹកក្នុងដីពីលើស្រទាប់ដែលមានខ្យល់
- local groundwater /ˈləʊk(ə)l graʊnd ˈwɔːtə/ [n] ទឹកក្នុងដីដែលមានប្រភពនៅនឹងកន្លែង

**group** /gruːp/ [n] ក្រុម

- alkyl group /ˈalkʌɪl gruːp/ [n] ក្រុមអាល់គីល
- cross inoculation group /krɒs ɪˌnɒkjʊˈleɪʃn gruːp/ [n] ក្រុមដែលអាចចាក់ចម្លងអតិសុខុមមានប្រយោជន៍ (ក្រុមមួយនៃប្រភេទពូជដែលអតិសុខុមប្រាណមានប្រយោជន៍ (រស់នៅជាមួយ) របស់វា អាចយកទៅចាក់ចម្លងទៅប្រភេទពូជផ្សេងទៀតនៅក្នុងក្រុមដូចគ្នា។ ពាក្យនេះត្រូវបានគេប្រើទាក់ទងនឹងយថាប្រភេទអតិសុខុមប្រាណ Rhizobia និង Frankia។)
- soil group /sɔɪl gruːp/ [n] ក្រុមដី
- vulnerable group /ˈvʌln(ə)rəb(ə)l gruːp/ [n] ក្រុមជនងាយរងគ្រោះ

**grow** /grəʊ/ [v] ដុះ, ដាំ (រុក្ខជាតិ), លូតលាស់

**grower** /ˈgrəʊə/ [n] អ្នកដាំ, អ្នកបណ្ដុះ

**growl** /graʊl/ [v] គ្រហឹម (ចង់ខាំ), និយាយសំឡុត

**growl** /graʊl/ [n] សូរគ្រហឹម

**growth** /grəʊθ/ [n] ការដុះលូតលាស់ (ដំណើរការដែលជីវករីកធំធាត់ឡើងៗ), កំណើន (ឧ. ប្រជាជន)

- annual growth /ˈanjʊəl grəʊθ/ [n] កំណើនប្រចាំឆ្នាំ, ការលូតលាស់ប្រចាំឆ្នាំ (ដើមឈើ)
- apical growth /ˈeɪpɪk(ə)l grəʊθ/ [n] ការលូតលាស់កម្ពស់(ដើមឈើ)
- diameter growth /dʌɪˈamɪtə grəʊθ/ [n] ការលូតលាស់អង្កត់ផ្ចិត (ដើមឈើ)
- economic growth /ˌiːkəˈnɒmɪk grəʊθ/ [n] កំណើនសេដ្ឋកិច្ច
- gross growth /grəʊs grəʊθ/ [n] ការលូតលាស់សរុប (ដើមឈើ)
- initial growth /ɪˈnɪʃ(ə)l grəʊθ/ [n] ការលូតលាស់ដំបូង
- orthotropic growth /ˌɔːθə(ʊ)ˈtrəʊpɪk grəʊθ/ [n] ការលូតលាស់ត្រង់ទៅលើ (ស្ថានភាពដែលត្រួយលូតលាស់ដុះឡើងត្រង់ទៅលើ)
- plagiotropic growth /ˌpleɪdʒɪəʊˈtrəʊpɪk grəʊθ/ [n] ការលូតលាស់ទៅទិសផ្តេក, ការលូតលាស់ទៅទិសទ្រេត (ស្ថានភាពរបស់រុក្ខជាតិដែលដើមរបស់វាលូតលាស់មិនទៅលើតាមធម្មតា គឺវាលូតលាស់ដូចជាមែកទៅខាង)
- population growth /pɒpjʊˈleɪʃ(ə)n grəʊθ/ [n] កំណើនប្រជាជន

**grub** /grʌb/ [n] សូមមើលពាក្យ៖ larva

- white grub /wʌɪt grʌb/ [n] ដង្កូវខ្មូង

**grumous** /gruːməs/ [adj] សូមមើលពាក្យ៖ clotted

***Gryllotalpa africana*** [sci.n] សូមមើលពាក្យ៖ mole cricket

**guava** /ˈgwɑːvə/ [n] ត្របែក (ឈ្មោះវិទ្យាសាស្ត្រ *Psidium guajava*)

**guideline** /ˈgʌɪdlʌɪn/ [n] គោលការណ៍ណែនាំ, ការណែនាំ (ឧ. ការណែនាំសម្រាប់ការអនុវត្តន៍កម្មវិធី ឬកិច្ចការអ្វីមួយ)

- EIA guideline /iː ʌɪ eɪ ˈgʌɪdlʌɪn/ [n] គោលការណ៍ណែនាំស្តីពីការវាយតម្លៃហេតុផលប៉ះពាល់បរិស្ថាន

**guinea pig** /ˈgɪni pɪg/ [n] សូមមើលពាក្យ៖ cavy

**gullet** /ˈgʌlɪt/ [n] បំពង់អាហារ

**gully** /ˈgʌli/ [n] (សទិសន័យ៖ channel) ប្រឡាយ ឬចង្អូរក្នុងតំបន់ស្ងួត

**gullying** /ˈgʌliɪŋ/ [n] (សទិសន័យ៖ digging-up, trenching, water furrowing) ការជីកចង្អូរ, ការជីកប្រឡាយ

**gum** /gʌm/ [n]

១. (ចំពោះសត្វ) (សទិសន័យ៖ gingiva) ជើងធ្មេញ, អញ្ចាញធ្មេញ

២. ជ័រឈើ (ជាពាក្យ ប្រើសម្រាប់ រុក្ខជាតិ ឬដើមឈើដែលអាចទាញយក ជាតិជ័របាន និងជាសារធាតុ ដែលមានទម្រង់គីមីស៊ាំញ៉ាំ ត្រូវបាន ចាត់ទុកថាមានកម្រិតកាបូនអ៊ីដ្រាតប៉ូលីមែខ្ពស់។ នៃជ័រ ដែល អាចរលាយក្នុងទឹកបាន ដូចជាជ័រអាកាស្យា (gum arabic) – ការប្រើប្រាស់ជាចម្បងនូវជ័រ ដែលរលាយក្នុងទឹក គឺជាឱសថ និងការផលិតក្រដាស)

**gut** /gʌt/ [n] ពោះវៀន

**guttation** /gʌˈteɪʃ(ə)n/ [n] រំភាយចំហាយទឹក (ការបញ្ចេញជាតិទឹកពីស្លឹករុក្ខជាតិ ដែលបណ្តាលមកពីសម្ពាធឫស)

**gutter** /ˈgʌtə/ [n]

១. សូមមើលពាក្យ៖ ditch

២. ទ (ត្រងទឹក)

**guttering** /ˈgʌt(ə)rɪŋ/ [n] ប្រព័ន្ធប្រឡាយ

**guttural** /ˈgʌt(ə)r(ə)l/ [adj] បំពង់ក

**gymnosperm** /ˈdʒɪmnə(ʊ)spəːm/ [n] ពួករុក្ខជាតិគ្រាប់ស្រាត, ពួករុក្ខជាតិគ្មានផ្កា, មច្ឆនបុប្ផាណ្ឌរុក្ខជាតិ (ប្រភេទរុក្ខជាតិដែលគ្រាប់ស្ថិតនៅក្រៅផ្លែ ឬគ្មានសាច់បិទបាំង ឧទាហរណ៍ ដើមស្រល់។ ចំណាត់ថ្នាក់រុក្ខវិទ្យានៃក្រុមរុក្ខជាតិគ្រាប់ ដែលក្នុងនោះអូវុល (ក្រោយមកក្លាយជាស៊ុត) គ្មានអ៊ីរុំជិតក្នុង អូវែ (ដែលខុសប្លែកពីពួករុក្ខជាតិគ្រាប់ជិត)។ ភាគច្រើននៃពួករុក្ខជាតិគ្រាប់ស្រាតផលិតគ្រាប់នៅក្នុងកោន (ឈ្មោះទូទៅហៅ conifers)។ ពួករុក្ខជាតិជីមណូស្ពែមមិនផលិតផ្លែកោន គឺ Podocarpus, Ginkgo និង Taxus។)

***Gynandropsis pentaphylla*** [sci.n] មមាញ

**gynecology** /ˌgʌɪnɪˈkɒlədʒi/ [n] វិជ្ជាពេទ្យខាងសរីរៈ, ពេទ្យរោគស្ត្រី

**gyno-** /dʒɪnəʊ/ [prefix] បុព្វបទមានន័យថា ស្រី ឬញី

**gynobasic** /dʒɪnəʊˈbeɪsɪk/ [adj] ទងទ្រកញ្ចុំកេសរញី

**gynodioecious** /dʒɪnəʊdʌɪˈiːʃəs/ [adj] រុក្ខជាតិមានផ្កាញី និងផ្កាទ្វេភេទនៅលើដើមផ្សេងគ្នា

**gynoecium** /gʌɪˈniːsɪəm/ [n] កេសរញី, កញ្ចុំកេសរញី (ជាពាក្យបច្ចេកទេសន័យប្រមូលផ្តុំសំដៅទៅលើផ្នែកញីរបស់ផ្កាពោលគឺ កេសរញី (Pistil)។ ពាក្យន័យផ្ទុយ Androecium កេសរឈ្មោល។)

**gynomonoecious** /dʒɪnəʊməˈniːʃəs/ [adj] រុក្ខជាតិមានផ្កាញី និងផ្កាទ្វេភេទនៅលើដើមតែមួយ

**gyps** /dʒɪpz/ [n pl] សូមមើលពាក្យ៖ gypsum

**gypsum** /ˈdʒɪpsəm/ [n] (សទិសន័យ៖ gyps) ម្នាងសិលា, ហ្សីប, ស៊ុលហ្វា, ស៊ុលហ្វាតកំបោរ

**gypsum quarry** /ˈdʒɪpsəmˈkwɒri/ [n] ការដ្ឋានយកម្នាងសិលា

***Gyrinocheilus aymonieri*** [sci.n] សូមមើលពាក្យ៖ Siamese algae eater

***Gyrinocheilus pennocki*** [sci.n] សូមមើលពាក្យ៖ spotted algae eater

H

**habit** /ˈhabɪt/ [n] ទម្លាប់

- plant habit /plɑːnt ˈhabɪt/ [n] ប្រភេទទម្លាប់ដុះនៃរុក្ខជាតិ

**habitant in the marine realm** /ˈhabɪt(ə)nt ɪn ðə məˈriːn rɛlm/ [n] ជម្រកសត្វដែនសមុទ្រ

**habitat** /ˈhabɪtat/ [n] លំនៅ, ជម្រក (កន្លែង ឬប្រភេទនៃបរិស្ថានដែលប្រភេទសត្វ និងរុក្ខជាតិ ត្រូវបានរកឃើញ ឬជួប)

- aqueous habitat /ˈeɪkwɪəs ˈhabɪtat/ [n] លំនៅទឹក
- native habitat /ˈneɪtɪv ˈhabɪtat/ [n] ជម្រកធម្មជាតិ

**habituation** /həbɪtʃʊˈeɪʃ(ə)n/ [n] ទម្លាប់, ការស៊ាំ

**hack** /hak/ [v] កាប់, កាត់, ហាន់, ចិញ្ច្រាំ

**hack** /hak/ [n] ស្នាមកាប់

**hack saw** /hak sɔː/ [n] រណារអាដែក

**hacking cough** /hakɪŋ kɒf/ [n] ក្អកស្ងួត

**haemophilia** /ˌhiːməˈfɪlɪə/ [n] ជំងឺឈាមក្រកក, អេម៉ូភីលី

**haemophilus influenza type B** [n] រោគផ្តាសាយធ្វើឱ្យរលាកបំពង់ក

**haemorrhagic septicemia** /ˌhɛməˈradʒɪk ˌsɛptɪˈsiːmɪə/ [n] ជំងឺសារទឹកនៃគោ

**Hafnium** /ˈhafnɪəm/ [n] អាប់ញ៉ូម (និមិត្តសញ្ញាគីមី Hf)

**hair** /hɛː/ [n] សក់, រោម (សត្វ)

- root hair /ruːt hɛː/ [n] រោមជញ្ជក់
- root of hair /ruːt ɒv hɛː/ [n] ឫសរោម

**halfbog** /hɑːfbɒg/ [n] ដីសរីរាង្គដែលល្វេយមិនល្អ

**halflife** /hɑːflʌɪf/ [n] ពាក់កណ្តាលជីវិត

***Halictophagus spectrus*** [sci.n] ពួក Strepsiptera (បារាសិតលើពួកមមាច)

**hallucination** /həˌluːsɪˈneɪʃ(ə)n/ [n] ការមមើមមាយ

**halobacteria** /ˈheɪləʊbækˈtɪəriə/ [n] បាក់តេរីចំណួលប្រៃ

**halocarbon** /ˌheɪləʊˈkɑːbən/ [n] អាឡូកាបូន

**halogen** /ˈhalədʒ(ə)n/ [n] អាឡូសែន (ធាតុគីមីក្នុងក្រុមទី ៧ នៃតារាងខួបគីមីមានដូចជា ក្លរ ប្រូម ភ្លុយអរជាដើម)

**halogenic** /haləˈdʒɛnɪk/ [adj] ដែលមានអំបិល, ដែលមានជាតិប្រៃខ្ពស់

**halolimnic** /ˈlɪmnɪk/ [adj] រស់នៅក្នុងស្រែអំបិល

**halophile** /ˈhalə(ʊ)fʌɪl/ [n] ភាវរស់ចំណួលជាតិប្រៃខ្ពស់ (ឧ. មីក្រូសរីរាង្គធន់កំហាប់អំបិលខ្ពស់)

**halophyte** /ˈhaləfʌɪt/ [n] រុក្ខជាតិនិយមអំបិល, រុក្ខជាតិធន់នឹងកំហាប់អំបិលខ្ពស់, រុក្ខជាតិចំណួលជាតិប្រៃខ្ពស់

**halter** /ˈhɔːltə/ [n] ឃ្នុំ, ប្រឡៅ (គោ ឆ្កែ), ខ្សែបង្ហៀរ (សេះ)

**ham** /ham/ [n] ភ្លៅក្រោយទាំងមូល (ជ្រូក)

**hammer** /ˈhamə/ [n] ញញួរ

**hammer mill** /ˈhamə mɪl/ [n] ម៉ាស៊ីនកិនគ្រាប់ធញ្ញជាតិ (ម៉ាស៊ីនកិនគ្រាប់ធញ្ញជាតិស្ងួតឱ្យទៅជាម្សៅ ឬគ្រើមតាមចំណង់)

**hammock** /ˈhamək/ [n] អង្រឹង

***Hampala dispar*** [sci.n] ត្រីខ្មាន់

***Hampala macrolepidota*** [sci.n] ត្រីខ្មាន់

**hamster** /ˈhamstə/ [n] អាំស្ទែរ (សត្វ)

**hand** /hand/ [n] ប្រអប់ដៃ

**handicraft** /ˈhandɪkrɑːft/ [n] សិប្បកម្ម, ហត្ថកម្ម

**handloom** /ˈhandluːm/ [n] កីតម្បាញ

**handmade** /han(d)ˈmeɪd/ [adj] ដែលធ្វើនឹងដៃ

**haplochlamydeous** /ˈhapləʊkləˈmidɪəs/ [adj] (សទិសន័យ៖ monochlamydeous) ផ្កាមានបរិបុប្ផាតែមួយរង្វង់ (អាប្លូក្លាមីឌៀស)

***Haplogonatopus apicalis*** [sci.n] ពួកឱម៉ាល់ (បារាសិតឬរំពាលើមមាច)

**haploid** /ˈhaplɔɪd/ [n] ឯកប្លូអ៊ីត, អាប្លូអ៊ីត ( មានក្រូម៉ូសូមតែ១សម្រាប់នៅក្នុងកោសិកាមួយ។ ជាធម្មតា នៅក្នុងកោសិកាបន្តពូជគឺមាន n ក្រូម៉ូសូមហើយមាន 2n នៅក្នុងកោសិកាលូតលាស់។)

**harbour** /ˈhɑːbə/ [n] កំពង់ផែ

**hardboard** /ˈhɑːdbɔːd/ [n] ក្តារបន្ទះដែលបិទការ (ផលិតផលពីឈើដែលប្រើការបិទភ្ជាប់គ្នា និងជាផលិតផលដែលមានលក្ខណៈសេដ្ឋកិច្ច)

**harden off** /ˈhɑːd(ə)n ɒf/ [v] ធ្វើឱ្យរុក្ខជាតិស៊ាំ ឬសមស្របនឹងលក្ខខណ្ឌខាងក្រៅ (ដូចជាភាពត្រជាក់នៃខ្យល់ ពន្លឺ មុនពេលយកវាទៅដាំដុះនៅខាងក្រៅ)

**hardness** /ˈhɑːdnəs/ [n] របឹង, ភាពរឹងមាំ, ភាពណែនហាប់, ភាពស្វិត

- magnesium hardness /magˈniːzɪəm ˈhɑːdnəs/ [n] របឹងដោយម៉ាញ៉េស្យូម

**hardwood** /ˈhɑːdwʊd/ [n] ឈើខ្លឹម (ជាឈើរុក្ខជាតិស្លឹកធំ និងជម្រុះស្លឹក ដើមឈើដែលមានឈើខ្លឹមច្រើនស្ថិតនៅក្នុងក្រុម Angiospermae)

**Hardy-weinberg law** /ˈhɑːdi ˈwʌɪnbəːg lɔː/ [n] ច្បាប់ហាឌី-វ៉ែនប៊ឺត (ច្បាប់នេះចែងថាបណ្ដាលក្ខខណ្ឌដែលគេផ្ដល់ឱ្យត្រូវជួបប្រទះ frequencyសេណូទីបក្នុងក្រុមពូជមួយនៃបណ្ដាសារពាង្គកាយនឹងរក្សាថេរ និងបែងចែកជាឯកលក្ខណភាព p2, 2pq និង q2 ចំពោះសេណូទីប A1A1, A1A2 និង A2A2 ជាបន្តបន្ទាប់ ដែល p ជាfrequencyរបស់អាលែល A1 និង q ជាfrequencyរបស់អាលែល A2 ដែល p + q = 1)

**harm** /hɑːm/ [v] បំផ្លាញ, ឱ្យទោស

***Harmonia octomaculata*** [sci.n] អណ្ដើកមាស

**harness** /ˈhɑːnəs/ [n] ខ្សែពុង (ខ្សែប្រទាក់ត្រង់ក និងលើខ្លួនសត្វដើម្បីឱ្យវាអូសរទេះ)

**harpoon** /hɑːˈpuːn/ [n] ស្នម្យ៉ាងមានផ្លៀងសម្រាប់ចាក់ឬបាញ់

**harrier** /ˈharɪə/ [n] ឆ្កែបរបាញ់សម្រាប់រកទន្សាយស្លឹក

**harrow** /ˈharəʊ/ [v] រាស់

**harrow** /ˈharəʊ/ [n]

១. រនាស់ (សម្ភារផលិតកម្មប្រើសម្រាប់បំបែកដី និងពង្រាបដី ហើយពេលខ្លះប្រើវាសម្រាប់កៀរបង្គប់គ្រាប់ស្រូវ ឬកៀរស្មៅចេញពីស្រែ)

២. (សទិសន័យ៖ harrowing) ការរាស់ដី (ការកៀរដីឱ្យស្មើ)

- disc harrow /dɪsk ˈharəʊ/ [n] រនាស់រាស់ដែលភ្ជាប់នឹងម៉ាស៊ីនត្រាក់ទ័រ

**harrowing** /ˈharəʊɪŋ/ [n] សូមមើលពាក្យ៖ harrow

**harvest** /ˈhɑːvɪst/ [v] (សទិសន័យ៖ cut) ច្រូតកាត់, ប្រមូលផលកសិកម្ម, ប្រមូលផល, បេះផ្លែ-គ្រាប់

**harvest** /ˈhɑːvɪst/ [n] (សទិសន័យ៖ cutting, harvesting) ការច្រូតកាត់, ការប្រមូលផលកសិកម្ម

**havester** /ˈhɑːvɪstə/ [n] ម៉ាស៊ីនប្រមូលកសិផល

- combine harvester /kəmˈbʌɪn ˈhɑːvɪstə/ [n] ម៉ាស៊ីនច្រូត (ប្រភេទម៉ាស៊ីនច្រូតដែលយើងអាចទទួលជាគ្រាប់ស្រូវសុទ្ធតែម្ដង)
- corn harvester /kɔːn ˈhɑːvɪstə/ [n] ម៉ាស៊ីនប្រមូលផលពោត
- root harvester /ruːt ˈhɑːvɪstə/ [n] ម៉ាស៊ីនដក
- stripper harvester /ˈstrɪpə ˈhɑːvɪstə/ [n] ម៉ាស៊ីនបូត (ម៉ាស៊ីនប្រមូលផលស្រូវដោយប្រើមេកានិចបូតគ្រាប់ស្រូវពីកួរតែម្ដង)

**harvesting** /ˈhɑːvɪstɪŋ/ [n] សូមមើលពាក្យ៖ harvest

- seed harvesting /siːd ˈhɑːvɪstɪŋ/ [n] ការប្រមូលគ្រាប់ពូជ

**Hassium** /ˈhasɪəm/ [n] ហាស្យូម (និមិត្តសញ្ញាគីមី Hs)

**hastate** /ˈhasteɪt/ [adj] ទម្រង់គល់ស្លឹកទម្រង់ផ្លែលំពែង

**hatch** /hatʃ/ [v] ញាស់, ភ្ញាស់, ក្រាប

**hatchery** /ˈhatʃəri/ [n] កន្លែងភ្ញាស់ពងមាន់ ឬត្រី

**hay** /heɪ/ [n] ចំបើង, ស្មៅស្ងួតប្រើសម្រាប់ជាចំណីសត្វ

**hayseed** /ˈheɪsiːd/ [n] គ្រាប់ស្មៅ

**haystack** /ˈheɪstak/ [n] គំនរចំបើង (សម្រាប់រក្សាទុក)

**hazard** /ˈhazəd/ [n] គ្រោះថ្នាក់, កត្តាគ្រោះថ្នាក់

- environmental hazard /ɪnvʌɪrənˈmɛnt(ə)l ˈhazəd/ [n] គ្រោះថ្នាក់បរិស្ថាន
- hazard statement /ˈhazəd ˈsteɪtm(ə)nt/ [n] សញ្ញាគ្រោះថ្នាក់ (ឧ. សញ្ញារូបក្បាលខ្មោចនៅលើស្លាកថ្នាំពុល)
- health hazard /hɛlθ ˈhazəd/ [n] គ្រោះថ្នាក់ដល់សុខភាព
- occupational hazard /ɒkjʊˈpeɪʃ(ə)n(ə)l ˈhazəd/ [n] គ្រោះថ្នាក់ក្នុងការងារ
- radiation hazard /reɪdɪˈeɪʃ(ə)n ˈhazəd/ [n] គ្រោះថ្នាក់វិការយវិទ្យុសកម្ម
- toxic hazard /ˈtɒksɪk ˈhazəd/ [n] គ្រោះថ្នាក់ពុល

**head** /hɛd/ [n]

១. ចរន្ដកក់ និងដុំថ្ម

២. ក្បាល

៣. ផ្កាចង្កោមក្បាល

- valley head /ˈvali hɛd/ [n] ក្បាលជ្រលង
- white head /wʌɪt hɛd/ [n] កួរស (កួរស្កកដែលជាលទ្ធផលនៃការបំផ្លាញរបស់ដង្កូវស៊ីរូងដើម ដោយកាត់ផ្នែកខាងក្រោមនៃដើម

**heading** /ˈhɛdɪŋ/ [n] ការចេញក្បូរ (ដំណាក់កាល ស្រូវចាប់ផ្ដើមចេញក្បូរពីស្រទបស្លឹកទង់ជ័យ ហើយចាប់ផ្ដើមចេញផ្កាផ្នែកខាងលើ)

**heal** /hiːl/ [v] ផ្សះរោគ, មានសុខភាពល្អវិញ, ព្យាបាល

**heal** /hiːl/ [n] ជាលិកាចាស់ (ចំពោះរុក្ខជាតិ៖ ផ្នែកតូចមួយនៃជាលិកាពេញវ័យដែលរក្សានៅបាត (គល់) របស់ត្រួយខ្ចី)

**health care** /hɛlθ kɛː/ [n] សុខាភិបាល (ការថែរក្សា ឬគ្រប់គ្រង, ការទំនុកបម្រុងឱ្យបានសុខ)

**health practitcioner** /hɛlθ prakˈtɪʃ(ə)nə/ [n] អ្នកវេជ្ជជីវៈ (អ្នកប្រកបរបរខាងព្យាបាលអ្នកជំងឺ)

**health** /hɛlθ/ [n] សុខភាព, សុខាភិបាល

- environmental health /ɪnvʌɪrənˈmɛnt(ə)l hɛlθ/ [n] សុខភាពបរិស្ថាន
- public health /ˈpʌblɪk hɛlθ/ [n] សុខភាពសាធារណៈ, សុខាភិបាលសាធារណៈ
- reproductive health /ˌriːprəˈdʌktɪv hɛlθ/ [n] សុខភាពបន្តពូជ

**heap** /hiːp/ [n] គំនរ, ពំនូក

**heart** /hɑːt/ [n]
១. បេះដូង (គុណភាពដីសម្រាប់ដាំដុះ)
២. បេះដូង

**heart attack** /hɑːt əˈtak/ [n] ជម្ងឺបេះដូង, រោគគាំងបេះដូង

**heart burn** /hɑːt bəːn/ [n] ការឆ្អល់ចុងដង្ហើម (ដោយទឹកក្រពះចូលក្នុងបំពង់អាហារ)

**heartwood** /ˈhɑːtwʊd/ [n] ខ្លឹមឈើ (ឈើផ្នែកកណ្ដាលរបស់ដើមឈើ ឬមែក ដែលមានអាយុ ចាស់ ខ្មៅ និងរឹងជាងឈើ ដែលនៅជុំវិញវា ហើយកោសិកាឈើខ្លឹមមិនមានវត្ថុរស់ទេ និងមិនមានដំណើរការប្រតិកម្មអ្វីទាំងអស់)

**heat** /hiːt/ [n] កម្ដៅ

- heat of fusion /hiːt ɒv ˈfjuːʒ(ə)n/ [n] កម្ដៅនៃភាពរលាយ
- heat of vaporization /hiːt ɒv veɪpərʌɪˈzeɪʃ(ə)n/ [n] កម្ដៅនៃរំហួត
- soil specific heat /sɔɪl spəˈsɪfɪk hiːt/ [n] កម្ដៅពិសេសនៃដី

**heat-labile** /hiːt ˈleɪbɪl/ [adj] ដែលអាចខូចដោយកម្ដៅ

**heave** /hiːv/ [n] ដង្ហើមធំ (ដង្ហើមផតប៉ោង), ការប្រឹងដកខ្យល់

**heavy** /ˈhɛvi/ [n] ធ្ងន់ (ដីដែលមានអត្រាឥដ្ឋ និងល្បាយម៉ដ្ឋខ្ពស់)

**hectare (ha)** /ˈhɛktɛː/ [n] ហិចតា (ខ្នាតម៉ែត្រនៃតំបន់ដែលស្មើនឹង ១០០ អារឬ ១០ ០០ ម៉ែត្រការេ)

**hedge** /hɛdʒ/ [n] របងឈើរស់តូចៗ

**hedging** /ˈhɛdʒɪŋ/ [n] ការកាត់មែក, ការកាត់ដើម, ការកាត់ឫស ( ការកាត់តម្រឹមដើមឈើ ឬរុក្ខជាតិ ហើយរក្សាវាឱ្យនៅទាបដើម្បីជំនះការចាក់ឫសមិនល្អ ហើយជារឿយៗទម្រង់មិនល្អនៃការកាត់យកមកពីដើមឈើចាស់ៗ។ ការកាត់មែកពីដើមឈើកាត់តម្រឹមទាំងនេះ គេកាត់តែដើម ណាមានអាយុសរីរៈខ្ចីៗ)

***Hedyotis diffusa*** [sci.n] សូមមើលពាក្យ៖ snake-needle grass

**heel** /hiːl/ [n] កែងជើង

**heifer** /ˈhɛfə/ [n] គោញីជំទង់, គោក្រមុំ

**plant height** /plɑːnt hʌɪt/ [n] កម្ពស់ដើម

***Helianthus annuus*** [sci.n] សូមមើលពាក្យ៖ sunflower

**helical** /ˈhɛlɪk(ə)l/ [adj] ដែលមានរាងរង្វេល, រង្វេលដូចគួទខ្យង

***Helicophagus waandersi*** [sci.n] ត្រីប្រាកណ្ដុរ

***Helicoverpa armigera*** [sci.n] ដង្កូវស៊ីរូងផ្លែសណ្ដែក

**heliophyte** /ˈhiːlɪəʊfʌɪt/ [n] រុក្ខជាតិត្រូវការពន្លឺព្រះអាទិត្យពេញ

***Heliotropium indicum*** [sci.n] សូមមើលពាក្យ៖ Indian heliotrope

**Helium** /ˈhiːlɪəm/ [n] អេល្យ៉ូម (និមិត្តសញ្ញាគីមី He)

**helminth** /ˈhɛlmɪnθ/ [n] ដង្កូវបរាសិត

**helminthology** /ˌhɛlmɪnˈθɒlədʒi/ [n] ដង្កូវបរាសិតវិទ្យា

***Helostoma temmincki*** [sci.n] សូមមើលពាក្យ៖ kissing gourami

**hema-** /ˈhiːmə/ [prefix] (ន័យដូច៖ hemo-) បុព្វបទមានន័យថា ឈាម

**hemagglutination** /ˌhiːməgluːtɪˈneɪʃ(ə)n/ [n] ការស្អិតជាប់នៃឈាម

**hematemesis** /ˌhiːməˈtɛmɪsɪs/ [n] ការក្អួតធ្លាក់ឈាម

**hematic** /hiːˈmatɪk/ [adj] នៃកោសិកាឈាមក្រហម

**hemato** /ˈhiːmətəʊ/ [n] ឈាម, លោហិត

**hematoblast** /hiˈmadəˌblast/ [n] ឈាមខ្ចី, ឈាមមិនទាន់ក្រហម

**hematocrit** /ˈhiːmətə(ʊ)krɪt/ [n] អេម៉ាតូគ្រីត, ផលធៀបគោលិកាក្រហម

**hematogenesis** /ˈhiːmətə(ʊ)ˈdʒɛnɪsɪs/ [n] ការបង្កបង្កើតឈាម

**hematology** /ˌhiːməˈtɒlədʒi/ [n] ឈាមវិទ្យា

**hematolysis** /ˌhiːməˈtɒlɪsɪs/ [n] ការវិភាគឈាម

**hematoma** /ˌhiːməˈtəʊmə/ [n] អេម៉ាតូម (រំហូរឈាមដក់ទៅកន្លែងណាមួយ), ដាំសាច់, ហើមសាច់មានបែកឈាមក្នុងស្បែក

**hematopoiesis** /ˌhiːmatə(ʊ)pɔɪˈiːsɪs/ [n] កំណគោលិកាឈាម, ដំណើរបង្កបង្កើតឈាម

**hematosis** /ˌhiːməˈtɒsɪs/ [n] ដំណើរធ្លាក់ឈាម

**hematuria** /ˌhiːməˈtjʊərɪə/ [n] នោមឈាម, ទឹកនោមមានឈាម

**hemeralopia** /ˌhiːməˈrəloʊpiə/ [n] រោគងងឹតភ្នែកពេលថ្ងៃ, រោគស្រវាំងភ្នែក

**hemeralopic** /ˌhiːməˈrəloʊpik/ [n] ខ្វាក់មាន់

**hemialgia** [n] ការឈឺពាក់កណ្ដាលខ្លួន

**hemianopsia** [n] ភ្នែកខ្វាក់ពាក់កណ្ដាលប្រស្រីភ្នែក

**hemicrania** [n] រោគឈឺមួយចំហៀងក្បាល

**hemicryptophyte** [n] ហេមីគ្រីបតូហ្វីត (ប្រភេទស្មៅ ឬជីរដែលចុងត្រួយរបស់វា ស្ថិតនៅស្របនឹងផ្ទៃដីដែលការពារដោយស្លឹកឈើ ឬដោយដី)

***Hemipimelodus bicolor*** [sci.n] ត្រីក្អុក

***Hemipimelodus borneensis*** [sci.n] ត្រីក្អុក

***Hemipimelodus daugeti*** [sci.n] ត្រីក្អុក

***Hemipimelodus intermedius*** [sci.n] ត្រីក្អុក

**hemiplegia** [n] រោគស្លាប់ពាក់កណ្ដាលខ្លួន

**Hemiptera** /hɛˈmɪpt(ə)rə/ [n] ពពួកស្រឹង

***Hemisilurus mekongensis*** [sci.n] ត្រីក្រម៉ម

**hemispherical** /hɛmɪˈsfɛrɪk(ə)l/ [adj] អឌ្ឍគោល

១. មួយចំហៀងនៃផែនដី ជាពិសេសពាក់កណ្ដាលខាងជើង ឬខាងត្បូងអេក្វាទ័រ ឬនៅខាងលិច ឬកើតខ្សែ meridian

២. ពាក់កណ្ដាលស្វ៊ែ ឬវត្ថុដែលមានរាងមូល

**hemo-** /ˈhiːməʊ/ [prefix] (ន័យដូច៖ hema-) បុព្វបទមានន័យថា ឈាម

**hemocyte** /ˌhiːməsʌɪt/ [n] កោសិកាក្រហម

**hemoglobin** /ˌhiːməˈgləʊbɪn/ [n] អេម៉ូក្លូប៊ីន (គោលិកាឈាមក្រហម)

**hemoglobinuria** /ˌhiːməˈgləʊbɪnjʊərɪə/ [n] ការធ្លាក់ឈាមតាមទឹកនោម

**hemoleukocyte** /ˌhiːməˈluːkə(ʊ)sʌɪt/ [n] គោសិកាឈាមស

**hemolysis** /hiːˈmɒlɪsɪs/ [n] អេម៉ូលីស (ការបែកគោលិកាក្រហម)

**hemophilia** /ˌhiːməˈfɪlɪə/ [n] រោគមិនខន់ឈាម

**hemophiliac** /ˌhiːməˈfɪlɪək/ [n] អ្នកកើតរោគមិនខន់ឈាម

**hemophobia** /ˌhiːməˈfəʊbɪə/ [n] ការខ្លាចឈាម

**hemoptysis** /hiːˈmɒptɪsɪs/ [n] ក្អកធ្លាក់ឈាម, ការធ្លាក់ឈាមតាមមាត់

**hemorrhage** /ˈhɛmərɪdʒ/ [n] ការធ្លាក់ឈាម, ការចេញឈាម

**hemorrhagic septicemia** /ˌhɛməˈradʒɪk ˌsɛptɪˈsiːmɪə/ [n] (សទិសន័យ៖ barbone) ជំងឺសារទឹក

**hemorrhoid** /ˈhɛmərɔɪd/ [n] ឫសដូងបាត

**hemostasis** /ˌhiːmə(ʊ)ˈsteɪsɪs/ [n] ការឃាត់ឈាម

**hemostat** /ˈhiːməstat/ [n] ដង្កៀបឃាត់ឈាម

**hemotoxin** /ˈhiːməʊˈtɒksɪn/ [n] ជាតិពុលដែលបំផ្លាញឈាមក្រហម (អេម៉ូតុកស៊ីន)

**hemp** /hɛmp/ [n] ដំណាំដាំសម្រាប់យកសរសៃ (ឧ. ធ្មៃ ក្រចៅ)

**hen** /hɛn/ [n] មាន់មេ

***Henicorhynchus caudimaculatus*** [sci.n] ត្រីរៀល

***Henicorhynchus cryptopogon*** [sci.n] ត្រីរៀលអង្កាម

***Henicorhynchus siamensis*** [sci.n] ត្រីរៀល, ត្រីរៀលតុប

***Henosepilachna vigintisexpunctata*** [sci.n] អណ្ដើកមាសចំណុច

***Heosemys annandalli*** [sci.n] សូមមើលពាក្យ៖ yellow-leaded temple turtle

***Heosemys grandis*** [sci.n] សូមមើលពាក្យ៖ Asian giant terrapin

**heparin** /ˈhɛpərɪn/ [n] ថ្នាំប្រើការពារកុំឱ្យឈាមកក (អេប៉ារីន)

**heparin-lock** /ˈhɛpərɪn lɒk/ [n] ការស៊កធាតុម៉្យាងដើម្បីកុំឱ្យកកឈាម

**hepatic** /hɪˈpatɪk/ [adj] នៃថ្លើម

**hepatitis** /ˌhɛpəˈtʌɪtɪs/ [n] រោគហើមថ្លើម

**hepatocellular** [n] ការពិនិត្យមើលរចនាសម្ព័ន្ធកោសិកា

**hepatoma** /ˌhɛpəˈtəʊmə/ [n] ការដុះសាច់នៅថ្លើម, មហារីកថ្លើម

**herb** /həːb/ [n] តិណជាតិ (ស្មៅ ជីរ), រុក្ខជាតិសម្បុរស្លឹក (ដែលមានដើមភាគច្រើនតូច ល្អិត ហើយទន់ ឬពពួកស្មៅ)

- annual herb /ˈanjʊəl həːb/ [n] តិណទេសឯករត្យ

**herbaceous** /həːˈbeɪʃəs/ [adj] នៃតិណទេស

**herbicide** /ˈhəːbɪsʌɪd/ [n] ថ្នាំសម្លាប់ស្មៅ, ថ្នាំស្មៅឃាត (សារធាតុគីមីប្រើប្រាស់ដើម្បីសម្លាប់ ឬការពារការដុះលូតលាស់នៃស្មៅចង្រៃ)

- contact herbicide /ˈkɒntakt ˈhəːbɪsʌɪd/ [n] ថ្នាំកម្ចាត់ស្មៅដោយប៉ះ (ថ្នាំសម្លាប់ស្មៅទាំងឡាយណាដែលមានឥទ្ធិពល ឬប្រតិកម្មទៅលើរាល់ផ្នែកទាំងអស់របស់រុក្ខជាតិកាលណាប៉ះផ្នែកទាំងនោះ)
- herbivore herbicide /ˈhəːbɪvɔː ˈhəːbɪsʌɪd/ [n] ថ្នាំសម្លាប់ស្មៅតិណាសី
- nonselective herbicide /nɒn sɪˈlɛktɪv ˈhəːbɪsʌɪd/ [n] ថ្នាំសម្លាប់ស្មៅមិនជ្រើសរើស
- selective herbicide /sɪˈlɛktɪv ˈhəːbɪsʌɪd/ [n] ថ្នាំស្មៅឃាតជម្រើស (ថ្នាំពុលសម្រាប់ស្មៅនៅក្នុងដំណាំ ហើយអាចមិនបង្កឱ្យខូចខាតដល់ដំណាំ ឬខូចខាតតិចតួចបំផុត)

**herbivore** /ˈhəːbɪvɔː/ [n] សត្វស៊ីរុក្ខជាតិ, តិណាសី

**herbivorous** /həːˈbɪv(ə)rəs/ [adj] តិណាសី (សត្វស៊ីស្មៅជាអាហារ)

**herd** /həːd/ [n] ហ្វូង (សត្វ)

**heredity** /hɪˈrɛdɪti/ [n]

១. ការឆ្លងបន្តពូជពីដូនតារហូតដល់ចៅ

២. ថ្នាំសម្លាប់ស្មៅតំណពូជ

**heritability** /hɛrɪtəˈbɪlɪti/ [n] លទ្ធភាពតំណពូជ (កម្រិតដែលលក្ខណៈមួយរងឥទ្ធិពលដោយការទទួលមរតកខណៈដែលប្រៀបធៀបទៅបរិស្ថាន។ លទ្ធភាពតំណពូជចង្អៀត គឺភាគនៃបម្រែបម្រួលសរុបដែលបានចូលរួមចំណែកដោយឥទ្ធិពលបន្ថែមរបស់បណ្តាពន្ធុ ពោលគឺ វាជាអនុបាតនៃបម្រែបម្រួលសេនេទិចបន្ថែមទៅលើបម្រែបម្រួលផេណូទីប។ លទ្ធភាពតំណពូជទូលាយ អាចអនុវត្តបានចំពោះប្រភេទដាំដុះដោយសរីរាង្គលូតលាស់ រួមទាំងគ្មានឥទ្ធិពលបន្ថែមផងដែរ។ តំណពូជខ្លាំងបង្ហាញឱ្យឃើញថា ផេណូទីបរបស់ឯកត្តៈ គឺបញ្ជាក់ឱ្យដឹងពីសេណូទីបរបស់វា។ បើគេគណនាទិន្នន័យរបស់មេបា- កូន គេប៉ាន់ស្មានពីកម្រិតនៃភាពដូចរវាងមេបានិងកូនរបស់វា។)

**hermaphrodite** /həːˈmafrədʌɪt/ [n] រួមភេទ, ទ្វេភេទ (សារពាង្គកាយមួយមានទាំងសរីរាង្គបន្តពូជឈ្មោល និងសរីរាង្គបន្តពូជញី ឧទាហរណ៍ ខ្យង។ ពាក្យន័យដូច មានភេទតែមួយ (Dicliny ឬ Unisexual)។)

**hermaphroditic** /həːmafrəˈdɪtɪk/ [adj] (សទិសន័យ៖ monoclinous, bisexual) ទ្វេភេទ, មានភេទពីររួមគ្នា

**hermatically** /həˈmɛtɪkli/ [adv] ជិតស្លុង

**hernia** /ˈhəːnɪə/ [n] រោគកោប, រោគក្លូន, ក្លូនលូន

**herniorrhaphy** [n] ការវះរោគក្លូន

**herpes** /ˈhəːpiːz/ [n] ជំងឺពងដោរ ដូចរើម (អ៊ែប៉ែស) (ពងតូចៗតម្រៀបជិតៗគ្នាមានទឹកថ្លា បន្ទាប់មកក្លាយជាល្អក់ រួចរឹងស្ងួតដោយទុកក្រមរ)

**hesperidium** /ˌhɛspəˈrɪdɪəm/ [n] ប្រភេទផ្លែសាច់ដូចក្រូច

**hetero-** /ˈhɛt(ə)rəʊ/ [prefix] បុព្វបទមានន័យថា មិនដូចគ្នា

***Heterobagrus bocourti*** [sci.n] ត្រីកញ្ចុះភ្លោង

**heterochlamydeous** /ˈhɛt(ə)rəʊkləˈmidēəs/ [adj] ផ្កាមានត្របកខុសស្រទាប់ (មានត្របក និងស្រទាប់មិនដូចគ្នា ក្នុងរង្វង់នៃបរិបុប្ផា)

**heterogamy** /ˌhɛtəˈrɒgəmi/ [n] ទម្រង់បន្តពូជខុសគ្នា (ការបន្តពូជដោយភេទ)

**heterogeneous** /ˌhɛt(ə)rə(ʊ)ˈdʒiːnɪəs/ [adj] ដែលខុសគេ, វិសភាគ (១. សមាសមួយដែលបន្សំឡើងដោយធាតុផ្សេងៗគ្នា ឧទាហរណ៍ ល្បាយនៃទឹក និងប្រេង ២. ការសម្ដែងចេញឱ្យឃើញភាពខុសគ្នានៅក្នុងចំណោមសមាជិករបស់ក្រុមមួយ។ ពាក្យផ្ទុយ Homogeneous (ភាពដូចគ្នា)

**heterolecithal** /ˈhɛt(ə)rəʊles.ɪ.θəl/ [adj] របាយមិនស្មើ (ដែលមានរបាយស៊ុតលឿងមិនស្មើគ្នា នៅក្នុងស៊ុតមួយ)

**heterolysis** [n] ការបំបែកកោសិកា (ការរំលាយជាលិកា និងកោសិកាដោយសកម្មភាពរបស់អង់ស៊ីម និងសារធាតុផ្សេងៗ ដែលមានប្រភពមកពីខាងក្រៅភាវរស់)

***Heteropneustes fossilis*** [sci.n] សូមមើលពាក្យ៖ stinging catfish

**heterosexual** /hɛt(ə)rə(ʊ)ˈsɛkʃʊəl/ [adj] មានភេទផ្ទុយគ្នា

**heterosis** /ˌhɛtəˈrəʊsɪs/ [n] ភាពជាកូនកាត់, អេតេរ៉ូស៊ីស (បាតុភូតមួយដែលក្នុងជំនាន់ F1 ទទួលបាន ដោយការបង្កាត់ពីមេបាដែលមានលក្ខណៈសេនេទិចមិនដូចគ្នា)

**heterotaxis** /ˈhɛt(ə)rəʊˈtaksɪs/ [n] ការតម្រៀបមិនស្មើ

**heterotherm** /ˈhɛt(ə)rəʊθəːm/ [n] សត្វអថេរកម្ដៅ

**heterotroph** /ˈhɛt(ə)rə(ʊ)trəʊf/ [n] ថ្នាំសម្លាប់ស្មៅភាវៈបរជីព

**heterotrophy** [n] បរជីព

**heterozygous** /ˌhɛt(ə)rə(ʊ)ˈzʌɪgəs/ [adj] នៃអេតេរ៉ូស៊ីកូត, កូនកាត់ (នៃឯកត្តៈដែលមានគូសម្ពន្ធខុសគ្នា និងមានបុគ្គលិកលក្ខណៈកាត់ប្លែកពីមួយទៅមួយ ឧ. គូពន្ធុដែលមានគូសម្ពន្ធករខុសគ្នាដូចជា Aa)

***Hevea brasiliensis*** [sci.n] សូមមើលពាក្យ៖ rubber

**hexagon eye pattern** /ˈhɛksəg(ə)n ʌɪ ˈpat(ə)n/ [n] ភ្នែកឆកោណ (ឧ. ពីងពាង *Oxyopes sp.*)

**hexapod** /ˈhɛksəpɒd/ [n] ជើងប្រាំមួយ (អំពីសត្វល្អិត)

**hibernation** /ˌhʌɪbəˈneɪʃ(ə)n/ [n] ក្រាំងកម្ម (រយៈពេលដែលរុក្ខជាតិ ឬសត្វបង្អាក់ការលូតលាស់ដោយសារអាកាសធាតុត្រជាក់ខ្លាំង)

***Hibiscus cannabinus*** [sci.n] សូមមើលពាក្យ៖ kenaf

***Hibiscus Rosa sinensis*** [sci.n] ផ្កាំរំយោល

**hiccough** /ˈhɪkʌp/ [n] (សូមមើលពាក្យ៖ hiccup)

**hiccup** /ˈhɪkʌp/ [n] (សទិសន័យ៖ hiccough) ក្អើក

**hide** /hʌɪd/ [n] (សទិសន័យ៖ skin) ស្បែក

**hidrosis** /hɪˈdrəʊsɪs/ [n] ដំបៅជាំទឹក

**hierarchy** /ˈhʌɪərɑːki/ [n] ឋានានុក្រម (ប្រព័ន្ធមានលំដាប់ថ្នាក់នៅក្នុងធម្មជាតិ។ ប្រព័ន្ធមួយ ដែលផ្សំឡើងពីប្រព័ន្ធតូចជាច្រើន វាអាចបង្កើតជាអនុប្រព័ន្ធ ហើយបង្កើតជាប្រព័ន្ធធំ)

- taxonomic hierarchy /taksəˈnɒmɪk ˈhʌɪərɑːki/ [n] ឋានានុក្រមនៃវគ្គីករណ៍សាស្ត្រ (ចំណាត់ថ្នាក់) (លំដាប់ថ្នាក់នៃសារពាង្គកាយមានជីវិត (ឬផុតពូជទៅហើយ) យោងទៅតាមវគ្គីករណ៍សាស្ត្រ។ ចំណាត់ថ្នាក់កើតចេញពីរូបរាង (របស់សារពាង្គកាយ)។)

**highland** /ˈhʌɪlənd/ [n] ដីទួលខ្ពស់ និងស្រោះទឹកល្អ

**highlander** /hʌɪ landə/ [n] អ្នកភ្នំ, អ្នកកុលសម្ពន្ធ

**highly mechanized** /ˈhʌɪli ˈmɛk(ə)nʌɪzt/ [adj] ដែលធ្វើដោយគ្រឿងម៉ាស៊ីន

**hill** /hɪl/ [n]

១. គុម្ព (ក្រុមនៃដើមស្រូវដែលនៅក្បែរគ្នា ពីព្រោះសំណាប ឬគ្រាប់ស្រូវត្រូវបានស្ទូង ឬដាំដុះជាមួយគ្នា ហើយស្រូវមួយគុម្ពអាចមានតែមួយដើម)

២. កូនភ្នំ, ភ្នំតូចៗ, ដំបូក

- glacial hill /ˈgleɪsɪəl hil/ [n] ភ្នំតូចៗដែលកើតមកពីសំណល់នៃការរលាយនៃផ្ទាំងទឹកកក
- isolated hill /ˈʌɪsəleɪtɪd hɪl/ [n] សូមមើលពាក្យ៖ hillock
- little hill /ˈlɪt(ə)l hil/ [n] ជម្រាលភ្នំ, ភ្នំតូច
- residual hill /rɪˈzɪdjʊəl hɪl/ [n] (សទិសន័យ៖ outlier) (ចំពោះធរណីវិទ្យា) ដំបូកកសិណ (ដំបូកដែលជាស្រទាប់ថ្ម ដែលរលាយបាត់ទៅហើយ)
- sandy desert hill /ˈsandi dɪˈzəːt hil/ [n] ភ្នំខ្សាច់តូចៗក្នុងតំបន់វាលខ្សាច់

**hillock** /ˈhɪlək/ [n] (សទិសន័យ៖ mound, knoll, isolated hill) ដំបូក, ពន្លក, ផ្នូក

- peat hillock /piːt ˈhɪlək/ [n] កូនដំបូកនៅកន្លែងពើក (សរីរាង្គដែលកប់ក្នុងដីមិនរលួយ)
- hillocky tundra /ˈhɪləki ˈtʌndrə/ [n] តំបន់ទុងដ្រាដែលមានដំបូកពាសពេញ

**hill-side** /hɪl sʌɪd/ [n] ក្បែរភ្នំ, កៀនជើងភ្នំ

**hillside** /ˈhɪlsʌɪd/ [n] សូមមើលពាក្យ៖ slope

**hilly** /ˈhɪli/ [adj]
១. សូមមើលពាក្យ៖ slopy
២. ដែលជាកូនភ្នំ ឬដំបូក, ដែលខ្ពស់ទាបខ្លាំង

**hilum** /ˈhʌɪləm/ [n] ស្នាមដៅលើសម្បកគ្រាប់ (ហៀលឹម ៖ ស្នាមនៅលើសម្បកគ្រាប់បន្សល់ទុកដោយសណ្ដង់គ្រាប់ (funicle) នៃពួករុក្ខជាតិគ្រាប់ជិត។ ពួករុក្ខជាតិគ្រាប់ ស្រាត គ្មានសណ្ដង់គ្រាប់ទេ តែស្នាមដូចហៃលឹម អាចកើតនៅកន្លែង ដែលគ្រាប់ភ្ជាប់ជាមួយ megasporophyl។)

***Himantura chaophraya*** [sci.n] ត្រីបបែល

***Himantura krempfi*** [sci.n] ត្រីបបែល

***Himantura signifer*** [sci.n] ត្រីបបែល

**hip** /hɪp/ [n] ត្រគាក, ឆ្អឹងត្រគាក

***Hippichthys spicifer*** [sci.n] សូមមើលពាក្យ៖ bellybarred pipefish

***Hippocampus* spp.** [sci.n] សូមមើលពាក្យ៖ sea horse

**hirsute** /ˈhəːsjuːt/ [adj] ដែលមានរោមស្រមូម (ប្រភេទរោម លើស្លឹក)

***Hirsutella citriformis*** [sci.n] ជំងឺផ្សិត

**hispid** /ˈhɪspɪd/ [adj] មានរោមរឹងដូចបន្លា (អំពីជាលិការុក្ខ ជាតិ)

**histamine** /ˈhɪstəmiːn/ [n] អ៊ីស្តាមីន (វត្ថុធាតុមានក្នុងខ្លួន ដែលធ្វើឱ្យមានប្រតិកម្ម)

**histochemistry** /hɪstəʊˈkɛmɪstri/ [n] ជាលិកាគីមីវិទ្យា

**histocompatibility** /ˈhɪstə(ʊ)kəmˌpatɪˈbɪlɪti/ [n] ជាលិកាត្រូវគ្នា

**histogenesis** /ˌhɪstə(ʊ)ˈdʒɛnɪsɪs/ [n] កំណជាលិកា (ការបង្កើតជាលិកា និងសរីរាង្គពីកោសិកាមិនបំប្លែងឯកទេស)

**histology** /hɪˈstɒlədʒi/ [n] ជាលិកាវិទ្យា (វិទ្យាសាស្ត្រដែល សិក្សាអំពីជាលិកានៃជីវករ)

**histolysis** /hɪˈstɒlɪsɪs/ [n] ការបំបែកជាលិកា

**HIV** [n] (សូមមើលពាក្យ៖ Human immunodeficiency virus) កង្វះភាពស៊ាំឱ្យមនុស្សធន់នឹងមេរោគវីរុស

**hive** /hʌɪv/ [n] សម្បុក, បង្គង (ឃ្មុំ), ផ្លូត
- log hive /lɒg hʌɪv/ [n] បង្គងឃ្មុំ

**hives** /hʌɪvz/ [n pl] សូមមើលពាក្យ៖ urticaria

**hoarse** /hɔːs/ [v] ស្អក

**hock** /hɒk/ [n] សន្លាក់ជើងក្រោយ, គន្លាក់អាចម៍

**Hodgkin's disease** [n] ជំងឺម៉ាំងនៃក្រពេញទឹករងៃ

**hoe** /həʊ/ [n] ចបកាប់

**hoeing** /həʊɪŋ/ [n] ការកាប់នឹងចបកាប់, ការជម្រះស្មៅ

**hog** /hɒg/ [n] សូមមើលពាក្យ៖ pig

**hog plum** /hɒg plʌm/ [n] ដើម ឬផ្លែម្កាក់

**hog wallow** /hɒg ˈwɒləʊ/ [n]
១. ទំនាបធម្មជាតិនៅតំបន់ដីឥដ្ឋ (ដោយការហើមនៃដីឥដ្ឋ)
២. ខ្នាច (ជ្រូកព្រៃ)

**hoja blanca** [n] ជំងឺវីរុសស្លឹកស, ជំងឺស្លឹកស (ជំងឺវីរុស ចម្លងពីពួកមមាចដើម (Sogatodes orificola) និងមមាច ស្លឹក (Hortensia similis)។ រោគសញ្ញា គឺដើមថយកម្ពស់ (តឿ) តួស្លឹកប្រែជាសឆ្នូត)

***Holarrhena antidysenterica*** [sci.n] ស្នែងគង់

**hole** /həʊl/ [n] ប្រហោង, រូង, រន្ធ
- swallow hole /ˈswɑloʊ həʊl/ [n] រន្ធអន្លង់ជ្រៅ

**hollow** /ˈhɒləʊ/ [v] បង្ហូង, ជីកជារូង

**hollow** /ˈhɒləʊ/ [n]
១. (ចំពោះដី) ទំនាបបាតខ្ទះ, ទឹកវាលទំនាប
២. (ចំពោះឧតុនិយម) វិសម្ពាធ

**hollow tree trunk** /ˈhɒləʊ triː trʌŋk/ [n] ពង្រួត (ឃ្មុំដែល មានសម្បុកក្នុងប្រហោងឈើ)

**Holmium** /ˈhəʊlmɪəm/ [n] អុលម្ញ៉ូម (និមិត្តសញ្ញាគីមី Ho)

**holotroph** /ˈhɒləʊtrəʊf/ [n] សូមមើលពាក្យ៖ autotroph

**holy basil** /trʌŋk ˈbaz(ə)l/ [n] (សទិសន័យ៖ hot basil) ម្រះព្រៅ

**home for the aged** [n] លំនៅជរាជនាស្រ័យ (ទីអាស្រ័យ នៅសម្រាប់ជនជរា)

**homeless** [n] អនាថជន, ជនអនាល័យ, មនុស្សគ្មាន លំនៅ

**homeo-** [prefix] (ន័យដូច៖ homo-) បុព្វបទមានន័យថា ដូចគ្នា ប្រហែលគ្នា

**homeostasis** /ˌhɒmɪə(ʊ)ˈsteɪsɪs/ [n] ថេរលំនឹង

**homeotherm** /ˈhɒmɪə(ʊ)ˌθəːm/ [n] (សទិសន័យ៖ homoiotherm, homotherm) សត្វថេរកម្ដៅ

**homeothermic** /ˌhɒmɪə(ʊ)ˈθəːmɪk/ [adj] ថេរកម្ដៅ

**homo-** /ˈhəʊməʊ/ [prefix] (ន័យដូច៖ homeo-) បុព្វបទមានន័យថា ដូចគ្នា ប្រហែលគ្នា

**homogeneity** /ˌhɒmə(ʊ)dʒɪˈneɪɪti/ [n] ភាពស្មើសាច់

**homogeneous** /ˌhɒmə(ʊ)ˈdʒiːnɪəs/ [adj] នៃភាពដូចគ្នា, នៃភាពសុទ្ធ, សភាគ (សមាសមួយដែលផ្សំដោយធាតុដូចគ្នាដូចជា ល្បាយនៃទឹក និងអំបិលជាដើម) ។ ពាក្យផ្ទុយ Heterogeneous)

**homograft** /ˈhɒməgrɑːft/ [n] (សទិសន័យ៖ allograft) បំបៅប្រភេទតែមួយ

**homoiotherm** /ˈhəʊməʊˈʌɪəʊθəːm/ [n] សូមមើលពាក្យ៖ homeotherm

**homopetalous** /ˈhəʊməʊ ˈpɛt(ə)ləs/ [adj] មានស្រទាប់ផ្កាដូចគ្នា

**homotherm** /ˈhəʊməθəːm/ [n] សូមមើលពាក្យ៖ homeotherm

**homozygous** /ˌhɒmə(ʊ)ˈzʌɪgəs/ [adj] នៃអូម៉ូស៊ីកូត (ដែលមានបុគ្គលិកលក្ខណៈកាត់ដូចគ្នាពីមួយទៅមួយ។ មានអាលែលដូចគ្នា១ឬច្រើនសម្រាប់ ឧ. លប់ទាំង២ (AA) ឬអន់ទាំង២ (aa)។ គេថាវាអូម៉ូស៊ីកូត បង្កាត់ ក្នុងកាលណាវាផ្សំផ្គុំសេណូទីបដូចគ្នា។)

**honey** /ˈhʌni/ [n] ទឹកឃ្មុំ

**honey guide** /ˈhʌni gʌɪd/ [n] សញ្ញានាំផ្លូវឃ្មុំ

**honeybee** /ˈhʌnibiː/ [n] ឃ្មុំយកទឹក

**honeycomb** /ˈhʌnɪkəʊm/ [n] ផ្លិតឃ្មុំ, រន្ធក្នុងសម្បុកឃ្មុំ

**honeycombed** /ˈhʌnɪkəʊmd/ [adj] ដែលមានរន្ធពាសពេញ

**honeydew** /ˈhʌnɪdjuː/ [n] ទឹកដម, អាចម៍ជាតិផ្អែមរបស់ចៃ (សារធាតុកាកសំណល់ស្ករ ដែលបញ្ចេញដោយពួក Aphids និងសត្វល្អិតស្រដៀងគ្នា)

**hoof** /huːf/ [n] ក្រចក (គោ, ក្របី, សេះ)

**hopper** /ˈhɒpə/ [n] (ចំពោះសត្វល្អិត) ពពួកសត្វល្អិតដែលលោត (សំដៅលើពពួកកណ្តូបតូច ឬ young locust)។

- brown planthopper /braʊn plɑːntˈhɒpə/ [n] មមាចត្នោត (ប្រភេទបាណកសត្វដែលមានឈ្មោះវិទ្យាសាស្ត្រ *Nilaparvata lugens* ស្ថិតក្នុងលំដាប់ Homoptera គ្រួសារ Delphacidea)
- grasshopper /ˈgrɑːshɒpə/ [n] កណ្តូប (ពពួកសត្វល្អិតស្ថិតក្នុងលំដាប់ Orthoptera)
- green leafhopper /griːn ˈliːfhɒpə/ [n] មមាចខៀវ (ឈ្មោះវិទ្យាសាស្ត្រ *Nephotettix spp.*)
- leaf hopper /liːf ˈhɒpə/ [n] មមាចស្លឹក (សត្វល្អិតក្នុងលំដាប់ Homoptera នៃគ្រួសារ Cicadellidae ហើយចិញ្ចឹមជីវិតដោយការជញ្ជក់រុក្ខរសពីសរសៃស្លឹកស្រូវ។ វាជាភ្នាក់ងារចម្លងជំងឺវីរុស ហើយមានរាងស្រាវ (ផៀវ) ហើយធ្វើចលនាលឿនជាងមមាចដើម)
- long horned grasshopper /lɒŋ hɔːnd ˈgrɑːshɒpə/ [n] កណ្តូបអង់តែនវែង (ប្រភេទសត្វល្អិតស្ថិតក្នុងអម្បូរ *Conocephalus longipennis*)
- meadow grasshopper /ˈmɛdəʊ ˈgrɑːshɒpə/ [n] កណ្តូបអង់តែនវែង (សត្វរំពាស្ថិតក្នុងលំដាប់ Othophera គ្រួសារ tettigoniidae)
- orange head leafhopper /ˈɒrɪn(d)ʒ hɛd ˈliːfhɒpə/ [n] មមាចក្បាលពណ៌ទឹកក្រូច (សត្វបរាសិតស្ថិតក្នុងលំដាប់ Hemiptera គ្រួសារ Cicadelidae)
- planthopper /plɑːntˈhɒpə/ [n] មមាចដើម
- short-horned grasshopper /ʃɔːt hɔːnd ˈgrɑːshɒpə/ [n] កណ្តូបអង់តែនខ្លី (សត្វល្អិតចង្រៃស្ថិតក្នុងលំដាប់ Orthoptera)
- smaller brown planthopper /smɔːlə braʊn plɑːnt ˈhɒpə/ [n] មមាចត្នោតតូច (សត្វល្អិតចង្រៃស្ថិតក្នុងលំដាប់ Hemiptera គ្រួសារ Delphacidae)
- white-backed planthopper /wʌɪt bakt plɑːnt ˈhɒpə/ [n] មមាចខ្នងស (ឈ្មោះវិទ្យាសាស្ត្រ៖ *Sogatella furcifera*)
- zigzag leafhopper /ˈzɪgzag ˈliːfhɒpə/ [n] មមាចត្នោតពព្រុះ (សត្វល្អិតចង្រៃស្ថិតក្នុងលំដាប់ Hemiptera គ្រួសារ Cicadelidae)

**hopperburn** /ˈhɒpəbəːn/ [n] ការខ្លោចដោយមមាច (ការឡើងស្គួតទាំងមូល សញ្ញាខ្លោច ឬឆេះស្លឹករបស់រុក្ខជាតិ ដែលបណ្តាលមកពីការបំផ្លាញយ៉ាងធ្ងន់ធ្ងររបស់ពួកមមាចត្នោត ដែលជញ្ជក់យករុក្ខរសនៃដំណាំស្រូវនោះ)

**horizon** /həˈrʌɪz(ə)n/ [n] ស្រទាប់ដី

- A horizon /eɪ həˈrʌɪz(ə)n/ [n] ស្រទាប់លើ (ដីខាងលើ) (ស្រទាប់លើបំផុតរបស់ដី ដែលទូទៅមានកម្រាស់ពី ១០ ទៅ ២០ ស.ម)

- accumulation horizon /əkjuːmjʊˈleɪʃ(ə)n həˈrʌɪz(ə)n/ [n] ស្រទាប់កក (ដោយដីឥដ្ឋ), ស្រទាប់កកដោយវត្ថុជាតិគីមី
- B horizon /biː həˈrʌɪz(ə)n/ [n] (សទិសន័យ៖ subsoil) ស្រទាប់ដីបន្ទាប់ (ស្រទាប់ដីជាប់ផ្ទាល់ពីក្រោមស្រទាប់ដីលើ ដែលជាទូទៅមានកម្រាស់ចាប់ពី ២៥ ទៅ ៥០ ស.ម)
- dead horizon /dɛd həˈrʌɪz(ə)n/ [n] ស្រទាប់ស្លាប់
- eluvial horizon /ɪˈl(j)uːvɪəlhəˈrʌɪz(ə)n/ [n] ស្រទាប់ថយចុះ (ដោយខនិជ)
- grey sandstone-like horizon [n] សូមមើលពាក្យ៖ concretionary sand
- humus enriched horizon /ˈhjuːməs ɪnˈrɪtʃd həˈrʌɪz(ə)n/ [n] ស្រទាប់កកទៅដោយមមោក
- illuvial horizon /ɪˌl(j)uːvɪˈeɪʃl həˈrʌɪz(ə)n/ [n] ស្រទាប់កកទៅដោយសារធាតុផ្សេងៗ (ឧ. ឥដ្ឋ ខនិជជាដើម) ដែលចល័តពីស្រទាប់លើតាមទឹកលាងច្រោះ
- leached horizon /liːtʃt həˈrʌɪz(ə)n/ [n] ស្រទាប់លាងច្រោះ, ស្រទាប់ចុះក្រោម
- low soil horizon /ˈləʊ sɔɪl həˈrʌɪz(ə)n/ [n] ស្រទាប់ដីរាក់ៗ
- podzolic horizon /ˈpɒdzɒlik həˈrʌɪz(ə)n/ [n] ស្រទាប់ដីអាស៊ីត, ប៉ុតហ្សូលិក (មើលស្រទាប់ប្រផេះ)
- soil horizon /sɔɪl həˈrʌɪz(ə)n/ [n] ស្រទាប់ដី
- subhorizon /sʌb həˈrʌɪz(ə)n/ [n] អនុស្រទាប់
- superficial horizon /ˌsuːpəˈfɪʃ(ə)l həˈrʌɪz(ə)n/ [n] ស្រទាប់លើបង្អស់

**hormone** /ˈhɔːməʊn/ [n] (សទិសន័យ៖ growth substance) អ័រម៉ូន, សារធាតុបណ្ដុះ

- folliclestimulating hormone (FSH) /ˈfɒlɪk(ə)l ˈstɪmjʊleɪtɪŋ ˈhɔːməʊn/ [n] អ័រម៉ូនភ្ញោចផូលីគុល
- plant hormone /plɑːnt ˈhɔːməʊn/ [n] អ័រម៉ូនរុក្ខជាតិ
- rooting hormone /ruːtɪŋ ˈhɔːməʊn/ [n] អ័រម៉ូនបណ្ដុះឫស (សារធាតុបណ្ដុះឫសដែលជំរុញជាពិសេសឱ្យដុះលូតលាស់ឫស។ ជាធម្មតា សមាសភាពសកម្ម គឺអាស៊ីតបែលតា-អ៊ីនដូល-ប៊ូទីរិក (beta-indole-butyric acid = IBA) ឬអាស៊ីតអាល់ហ្វា-ណែបតាឡែន-អាសេទិច (alpha-napthalene-acetic acid = NAA)។ គេដាក់លក់នៅក្នុងឈ្មោះពាណិជ្ជកម្មផ្សេងៗ ឧ. RooTone ឬ Seradix។)

**horn** /hɔːn/ [n] ស្នែង

**hornbill** /ˈhɔːnbɪl/ [n] សត្វត្មាត

**hornet** /ˈhɔːnɪt/ [n] ឪម៉ាល់ (ម្យ៉ាង)

**hornless** /ˈhɔːnləs/ [adj] ដែលគ្មានស្នែង

**horse** /hɔːs/ [n] សេះ, អាជានេយ្យ

**horse purslane** /hɔːs ˈpəːslən/ [n] ផ្ទីថ្ម (ឈ្មោះវិទ្យាសាស្ត្រ *Trianthema portulacastrum*)

**horticulture** /ˈhɔːtɪˌkʌltʃə/ [n] សាកវប្បកម្ម (វិទ្យាសាស្ត្រកសិកម្មដែលទាក់ទងនឹងការដាំដុះច្បារដំណាំ និងចម្ការ ឈើហូបផ្លែ បន្លែ), ដំណាំច្បារ

**hospice care** [n] គិលានសង្គ្រោះជនមានជំងឺដែលមុខតែនឹងស្លាប់ (ការជួយជីវិតឬថែទាំអ្នកជំងឺដែលឈឺ គង់តែនឹងស្លាប់)

**host** /həʊst/ [n] ផ្ទួល, ម្ចាស់បញ្ញើ

- host specific /həʊst spəˈsɪfɪk/ [adj] ប្រកាន់ជម្រក (ឧ. ពួកបរាសិត)
- host specificity /həʊst ˌspɛsɪˈfɪsɪti/ [n] ប្រភេទពូជអាចរស់នៅបានជាមួយគ្នា, ប្រភេទប្រកាន់ជម្រក, ពូជប្រកាន់ជម្រក (កម្រិតដែល ឧ. សត្វល្អិតបំផ្លាញ ផ្សិត ឬអតិសុខុមប្រាណរស់លើប្រភេទរុក្ខជាតិម្ចាស់ផ្ទះក្នុងចំនួនច្រើន ឬតិច)
- alternate host /ˈɔːltəneɪt həʊst/ [n] បាហនិកជំនួយ (ប្រភេទរុក្ខជាតិដែលផ្ដល់អាហារ ឬជម្រកឱ្យសត្វល្អិត ឬជំងឺក្នុងពេលដែលដំណាំដែលវាចូលចិត្តបំផ្លាញត្រូវបានច្រូតកាត់ ហើយអាចបំពេញវដ្ដជីវិតរបស់វានៅលើរុក្ខជាតិនោះ)

**house fly** /haʊs flʌɪ/ [n] រុយធម្មតា

**household expenditure** /ˈhaʊshəʊld ɪkˈspɛndɪtʃə/ [n] ការចំណាយនៅក្នុងគ្រួសារ (ការចំណាយទៅលើការប្រើប្រាស់ ឬបរិភោគ (ស្បៀងអាហារ) នៅក្នុងគ្រួសារ បូកជាមួយនឹងការចំណាយ ដែលមិនចាយវាយទៅលើការប្រើប្រាស់ ឬបរិភោគ (ស្បៀងអាហារ) នៅក្នុងគ្រួសារដែលចាយវាយដោយគ្រួសាររួមទាំងស្បៀងអាហារផងដែរ។ វាគឺជាបរិមាណសរុបនៃទឹកប្រាក់ដែលចាយវាយដោយគ្រួសារមួយនៅក្នុងរយៈពេលមួយ ដែលគេបានបញ្ជាក់យ៉ាងជាក់ច្បាស់។)

**household income** /ˈhaʊshəʊld ˈɪnkʌm/ [n] ចំណូលនៅក្នុងគ្រួសារ (គឺជាចំនួនបូកសរុបនៃអ្វីៗទាំងអស់ដែលយើងទទួលបានជាប្រាក់ ឬជារបស់របរដែលជាគោលការណ៍ គឺបានទទួលជាទៀងទាត់ ហើយនិងមានចរិកលក្ខណៈវិលជុំម្តងហើយម្តងទៀតៗ រួមទាំងស្បៀងអាហារផងដែរ។ ចំណូលអាចបានមកពីការប្រឹងរក ឬបានមកពីការមិនចាំបាច់ប្រឹងរក (បានមកដោយឯកឯង)។)

**housing** /haʊzɪŋ/ [n] ការផ្តល់ជម្រក

***Houttuynia cordata*** [sci.n] ជីរប៉ាហោ, ជីរថ្ពាល់ត្រី

**hoverfly** /ˈhɒvəflʌɪ/ [n] រុយសំកាំង

**hull** /hʌl/ [v] យកសម្បកចេញ, កិនសម្រូប (កិនស្រូវ)

**hull** /hʌl/ [n] អង្កាម (សម្បកតូច និងសម្បកធំនៃគ្រាប់ស្រូវ)

- rice hull /rʌɪs hʌl/ [n] សូមមើលពាក្យ៖ rice husk

**human immunodeficiency virus** [n] (សទិសន័យ៖ HIV) កង្វះភាពស៊ាំឱ្យមនុស្សធន់នឹងមេរោគវីរុស

**human T cell lymphotropic (HTLV)** [n] មេរោគវីរុសក្នុងផ្លោកនោមមនុស្ស

**humerus** /ˈhjuːm(ə)rəs/ [n] ឆ្អឹងដើមដៃ, ឆ្អឹងជើងមុខបន្ទាប់ពីស្មា

**humid** /ˈhjuːmɪd/ [adj] ដែលសើម, ដែលទទឹក

- semi-humid /ˈsɛmi ˈhjuːmɪd/ [adj] ដែលមានកម្ពស់ភ្លៀង ៤០០-៨០០ ម.ម ក្នុង១ឆ្នាំ

**humidification** /hjʊmɪdɪfɪˈkeɪʃ(ə)n/ [n] (សទិសន័យ៖ immibition) ការធ្វើឱ្យសើមជោកទឹក, ការជ្រាបទឹក, ការស្រូបទឹក

**humidity** /hjʊˈmɪdɪti/ [n] សំណើម (ភាពសើម (បរិមាណទឹកមធ្យម ឬចំហាយទឹក) នៅក្នុងខ្យល់)

- absolute humidity /ˈabsəluːt hjʊˈmɪdɪti/ [n] សំណើមដាច់ខាត ( បរិមាណនៃចំហាយទឹកក្នុងបរិយាកាសដែលមាននៅក្នុង១ខ្នាតមាឌ។ គិតជាក្រាម ក្នុង១គីឡូត៍ខ្យល់ស្ងួត ឬ ក្រាមក្នុង ១ម៉ែត្រត្រីគុណ(គីប)ខ្យល់ស្ងួត។)
- ambient humidity /ˈambɪənt hjʊˈmɪdɪti/ [n] សំណើមមជ្ឈដ្ឋានជុំវិញ
- atmospheric humidity /atməsˈfɛrɪk hjʊˈmɪdɪti/ [n] សំណើមបរិយាកាស
- relative humidity (RH) /ˈrɛlətɪv hjʊˈmɪdɪti/ [n] សំណើមធៀប, ទំនាក់ទំនងសំណើមបរិយាកាស, សំណើមបរិយាកាស (សមាមាត្រ (ភាគរយ) នៃបរិមាណទឹកដែលភាយនៅក្នុងខ្យល់ ក្រោមសីតុណ្ហភាពកំណត់មួយ)
- small relative humidity /smɔːl ˈrɛlətɪv hjʊˈmɪdɪti/ [n] ទំនាក់ទំនងមានកម្រិតទាប

**humification** /hjuːmɪfɪˈkeɪʃ(ə)n/ [n] មមោកកម្ម, ការក្លាយជាមមោក

**earth hummock** /əːθ ˈhʌmək/ [n] (សទិសន័យ៖ sodded mound, earth mound) ទួលដែលមានស្មៅដុះ, ទួលនៅតំបន់ត្រជាក់ខ្លាំង

**hummocky** /ˈhʌməki/ [adj] សូមមើលពាក្យ៖ rough

- wind hummocky /wind ˈhʌməki/ [n] កូនភ្នំខ្សាច់ដែលនាំមកដោយខ្យល់

**humor** /ˈhjuːmə/ [n] ទឹកមុខ

**hump** /hʌmp/ [n] បូក (គោ)

**humphead wrasse** [n] ត្រីសេកបូក (ឈ្មោះវិទ្យាសាស្ត្រ *Cheilinus undulatus*)

**humus** /ˈhjuːməs/ [n] មមោក (សារធាតុខ្មៅ ឬត្នោត ដែលមានសមាសធាតុសុំញ៉ាំប្រើសម្រាប់បំបែកសំណល់រុក្ខជាតិនិងសត្វនៅលើផ្ទៃដី)

- abiotic forest humus /ˌeɪbʌɪˈɒtɪk ˈfɒrɪst ˈhjuːməs/ [n] មមោកព្រៃឈើ (លក្ខណៈមិនសមស្របសម្រាប់ជីវិតសត្វ) មានលក្ខណៈប្រហែលនឹងមមោកធម្មតាដែរ តែ pH អាស៊ីត ៥.៥
- accumulation humus /əkjuːmjʊˈleɪʃ(ə)n ˈhjuːməs/ [n] មមោកដែលគរបន្តៗគ្នា (ជាគំនរ)
- active humus /ˈaktɪv ˈhjuːməs/ [n] មមោកសកម្ម
- alkaline raw humus /ˈalkəlʌɪn rɔː ˈhjuːməs/ [n] មមោកដុលអាល់កាឡាំង (pH ធំជាង ៨), មមោកដុល ឬម៉ររលាយជាមួយដុំក្រួសថ្មកំបោរ
- anaerobious forest humus [n] មមោកព្រៃឈើនៅកន្លែងខ្វះអុកស៊ីសែន (ឧ. ជាំទឹក)
- brown humus /braʊn ˈhjuːməs/ [n] មមោកសម្បុរត្នោត
- coarse humus /kɔːs ˈhjuːməs/ [n] សូមមើលពាក្យ៖ rough humus
- cryptorganic fraction of humus [n] មមោកបំពួន (មើលស្ទើរតែមិនស្គាល់), គ្រិបតូមមោក

- durable humus /ˈdjʊərəb(ə)l ˈhjuːməs/ [n] មមោកប្រចបល់ល្អជាមួយដី
- earth humus /əːθ ˈhjuːməs/ [n] មមោកលាយល្អជាមួយដី
- ectorganic fraction of humus [n] មមោកនៅក្នុងស្រទាប់ដីខាងលើ, សរីរាង្គដែលភាគខ្លះប៉ុណ្ណោះដែលរលួយ
- fibrillous humus /ˈfʌɪbrɪlus ˈhjuːməs/ [n] មមោកជាសរសៃល្អិត
- inert humus /ɪˈnəːt ˈhjuːməs/ [n] មមោកអសកម្ម ឬគ្មានការវិវត្តន៍
- infiltrated humus /ˈɪnfɪltreɪtid ˈhjuːməs/ [n] សូមមើលពាក្យ៖ intimate humus
- insect mild humus /ˈɪnsɛkt mʌɪld ˈhjuːməs/ [n] មមោកមូលនៃសត្វល្អិត
- intimate humus /ˈɪntɪmət ˈhjuːməs/ [n] (សទិសន័យ ៖ infiltrated humus) មមោកលាយប្រចបល់ល្អជាមួយដី
- microbe humus /ˈmʌɪkrəʊb ˈhjuːməs/ [n] មមោកកើតពីសារពាង្គកាយអតិសុខុមប្រាណ
- mycelial humus /mʌɪˈsiːlɪəl ˈhjuːməs/ [n] (សទិសន័យ៖ mycogenous humus) មមោកដុលជាសភាពសរសៃឆ្មារដូចជាផ្សិត
- mycogenous humus /ˈmʌɪkəʊ dʒɪnəs ˈhjuːməs/ [n] សូមមើលពាក្យ៖ mycelial humus
- nourishing humus /ˈnʌrɪʃɪŋ ˈhjuːməs/ [n] សូមមើលពាក្យ៖ nutritive humus
- nutritive humus /ˈnjuːtrɪtɪv ˈhjuːməs/ [n] (សទិសន័យ៖ nourishing humus) មមោកដែលមានជីជាតិច្រើន ឬសារធាតុចិញ្ចឹមច្រើន
- peat humus /piːt ˈhjuːməs/ [n] មមោកពើក, មមោកតួប (មមោកដែលវិវត្តន៍មិនល្អ)
- peaty forest humus /ˈpiːti ˈfɒrɪst ˈhjuːməs/ [n] មូលព្រៃដែលមានសភាពដូចពើក ឬតួប
- raw humus /rɔː ˈhjuːməs/ [n] មមោកដុល, មមោកឆៅ, ពើកស្ងួត
- rhizogenous humus /ˈrʌɪzəʊ dʒɪnəs ˈhjuːməs/ [n] មមោកកើតពីឫសរលួយ
- rough humus /rʌf ˈhjuːməs/ [n] (សទិសន័យ៖ coarse humus) មមោកគ្រើម (កម្ទេចឈើលាយនឹងមមោកមូលធម្មតា)
- soft humus /sɒft ˈhjuːməs/ [n] សូមមើលពាក្យ៖ earth mull
- sour humus /saʊə ˈhjuːməs/ [n] មមោកអាស៊ីតនៃរុក្ខជាតិ (មមោកដុលអាស៊ីត ឬមមោកមិនរលួយ)
- total humus /ˈtəʊt(ə)l ˈhjuːməs/ [n] មមោកសរុប
- veil humus /veɪl ˈhjuːməs/ [n] មមោកជាស្រទាប់ស្តើង
- humus impoverishing /ˈhjuːməs ɪmˈpɒv(ə)rɪʃɪŋ/ [n] ការធ្វើឱ្យមមោកកាន់តែក្រទៅៗ ឬហោចទៅៗ

**hunger** /ˈhʌŋgə/ [n] គម្លាន, ការឃ្លានអាហារ, ភាពស្រេកឃ្លាន

**hunt** /hʌnt/ [v] បរបាញ់, រុករកចាប់

**hunter** /ˈhʌntə/ [n] ព្រាន, អ្នកប្រមាញ់

**hunter-gatherer** /ˈhʌntə-ˈgaðərə/ [n] ព្រានព្រៃ, អ្នកបេះផ្លែឈើ

**hunting** /ˈhʌntɪŋ/ [n] ការបរបាញ់, ការដេញសត្វ

- commercial hunting /kəˈməːʃ(ə)l ˈhʌntɪŋ/ [n] ការបរបាញ់បែបជំនួញ

***Hura crepitans*** [sci.n] រលួសបារាំង

**hurt** /həːt/ [n] ការឈឺចាប់, ក្តីឈឺចាប់

**hurt** /həːt/ [v] ឈឺ, ពុល (ពុលរលក)

**animal husbandry** /ˈanɪm(ə)l ˈhʌzbəndri/ [n] ការចិញ្ចឹមសត្វ

**animal husbandry person** /ˈanɪm(ə)l ˈhʌzbəndri ˈpəːs(ə)n/ [n] អ្នកចិញ្ចឹមសត្វ

**husk rice** /hʌsk rʌɪs/ [v] កិនសម្រូប

**husk** /hʌsk/ [n] សម្បកគ្រាប់, ស្រកី (ដូង), អង្កាម

- burned rice husk /bərnd rʌɪs hʌsk/ [n] ផេះអង្កាម
- coconut husk /ˈkəʊkənʌt hʌsk/ [n] ស្រកីដូង
- rice husk /rʌɪs hʌsk/ [n] (សទិសន័យ៖ rice hull) អង្កាម

**hut** /hʌt/ [n] កូនផ្ទះតូច, ខ្ទម, រោងដោល

- grain storage hut /greɪn ˈstɔːrɪdʒ hʌt/ [n] ជង្រុក

**hutch** /hʌtʃ/ [n] ទ្រុងទន្សាយ

**hybrid** /ˈhʌɪbrɪd/ [n] អ៊ីប្រ៊ីត, បង្កាត់រិត, កូនកាត់ (ឯកត្តៈនៃកូនបង្កាត់ណាដែលមេបាមានសេណូទីបខុសគ្នា)
- interspecific hybrid /ˌɪntəspəˈsɪfɪk ˈhʌɪbrɪd/ [n] សូមមើលពាក្យ៖ species hybrid
- intraspecific hybrid /ˌɪntrəspəˈsɪfɪk ˈhʌɪbrɪd/ [n] កូនកាត់រវាងប្រភេទដូចគ្នា
- species hybrid /ˈspiːʃiːz ˈhʌɪbrɪd/ [n] (សទិសន័យ៖ interspecific hybrid) កូនដែលផលិតចេញពីការបង្កាត់ពូជពីរប្រភេទ

**hybridization** /ˌhʌɪbrɪdʌɪˈzeɪʃ(ə)n/ [n] ភាវូបនីយកម្មបង្កាត់ពូជ, អ៊ីប្រ៊ីតកម្ម, បង្កាត់កម្ម (វិធីសាស្ត្រផលិតកូនចៅដោយប្រើមេបាដែលមានពន្ធុខុសគ្នា)
- colony hybridization /ˈkɒləni ˌhʌɪbrɪdʌɪˈzeɪʃ(ə)n/ [n] អ៊ីប្រ៊ីតកម្មកូឡូនី (បច្ចេកទេសដែលប្រើប្រ៉ូប ដើម្បីស្វែងរកកូឡូនីបាក់តេរី ដែលមានផ្ទុកនូវសែនដែលគេចង់បាន ឬសែនដែលមានប្រយោជន៍)
- introgressive hybridization [n] ការបង្កាត់រាលដាល (ការរាលដាលដោយធម្មជាតិរបស់ពន្ធុ ឬសែនពីប្រភេទពូជ ឬក្រុមពូជមួយទៅមួយផ្សេងទៀតតាមរយៈការបង្កាត់ពូជ និងការបង្កាត់ត្រឡប់នៃបណ្ដាកូនកាត់។ ក្រុមកូនកាត់មួយអាចជាដំណាក់កាលមួយនៅក្នុងដំណើរការនេះ។ លទ្ធផលអាចមានផ្សេងៗគ្នា តាំងពីការជ្រៀតចូលពន្ធុ ឬសែនតិចរហូតដល់ការបញ្ចូលគ្នានៃប្រភេទពូជនេះ។ ជាគោលការណ៍ ការរាលដាលពន្ធុ ឬសែន វាប្រហាក់ប្រហែលទៅនឹងការធ្វើអន្តោប្រវេសន៍ ប៉ុន្តែវាកើតឡើងក្នុងរវាងប្រភេទ។)

**hybridize** /ˈhʌɪbrɪdʌɪz/ [v] បង្កាត់ពូជ

**hydathode** /ˈhʌɪdəθəʊd/ [n] ញើស (ដំណក់ទឹក ដែលកើតមាននៅគែម ឬចុងនៃស្លឹករុក្ខជាតិមួយចំនួន)

**hydatid** /ˈhʌɪdətɪd/ [n] កូនញាស់, តេញ៉ា

**hydatiform mole** [n] ដុំក្រាបដូចផ្លែទំពាំងបាយជូរលូតលាស់ក្នុងស្បូន (កើតពីភ្នាសស៊ុត)

**hydrate** /ˈhʌɪdreɪt/ [n] អ៊ីដ្រាត

**hydrated** /hʌɪˈdreɪtɪd/ [adj] អ៊ីដ្រាតេ (ដែលមានលាយទឹក)

**hydration** /hʌɪˈdreɪʃ(ə)n/ [n] ការស្រូបទឹក, អ៊ីដ្រាតកម្ម (ដំណើរការដែលក្នុងនោះសមាសធាតុមួយចងសម្ពន្ធជាមួយទឹកក្នុងសមាមាត្រកំណត់មួយ), ការផ្សំនឹងទឹក

**hydraulic** /hʌɪˈdrɔːlɪk/ [adj] ដែលប្រើទឹក, នៃកម្លាំងទឹក

**hydraulic punch presser** /hʌɪˈdrɔːlɪk pʌn(t)ʃ ˈprɛsə/ [n] ឧបករណ៍សង្កត់ប្រើដោយសម្ពាធប្រេង (ប្រេសអ៊ីដ្រូលិក)

**hydraulic ram** /hʌɪˈdrɔːlɪk ram/ [n] ប្រដាប់បុកទម្លាយដែលប្រើចំហាយទឹក

***Hydrellia philipina*** [sci.n] សូមមើលពាក្យ៖ whorl maggot

**hydride** /ˈhʌɪdrʌɪd/ [n] អ៊ីឌ្រីត

**hydro-** /ˈhʌɪdrəʊ/ [prefix] បុព្វបទមានន័យថា ទឹក

**hydrobiology** /ˈhʌɪdrəʊbʌɪˈɒlədʒi/ [n] ជលជីវវិទ្យា

**hydrobiont** /ˈhʌɪdrəʊˈbaɪɒnt/ [n] ភាវរស់ទឹក

**hydrocarbon** /ˌhʌɪdrə(ʊ)ˈkɑːb(ə)n/ [n] អ៊ីដ្រូកាបួ
- aromatic hydrocarbon /arəˈmatɪk ˌhʌɪdrə(ʊ)ˈkɑːb(ə)n/ [n] អ៊ីដ្រូកាបួប្រហើរ
- chlorinated hydrocarbon /ˈklɔːrɪneɪtɪd ˌhʌɪdrə(ʊ)ˈkɑːb(ə)n/ [n] អ៊ីដ្រូកាបួផ្ទុកក្លរ
- gas hydrocarbon /gas ˌhʌɪdrə(ʊ)ˈkɑːb(ə)n/ [n] អ៊ីដ្រូកាបួឧស្ម័ន
- liquid hydrocarbon /ˈlɪkwɪd ˌhʌɪdrə(ʊ)ˈkɑːb(ə)n/ [n] អ៊ីដ្រូកាបួរាវ
- saturated hydrocarbon /ˈsatʃəreɪtɪd ˌhʌɪdrə(ʊ)ˈkɑːb(ə)n/ [n] អ៊ីដ្រូកាបួឆ្អែត

**hydrocephalic** [n] ការសំបូរទឹកច្រើនក្នុងខួរក្បាល (ធ្វើឱ្យក្បាលធំ)

**hydrocephalus** /ˌhʌɪdrəˈkɛf(ə)ləs/ [n] អ៊ីដ្រូសេផាល (លក្ខណៈដែលសារធាតុរាវប្រមូលផ្ដុំក្នុងខួរក្បាល ពិសេសក្មេង ដែលធ្វើឱ្យក្បាលរីកធំ និងជួនកាលបំផ្លាញខួរក្បាល)

**hydrochlorofluorocarbon** /ˌhʌɪdrəˌklɔːrə(ʊ)ˈflʊərə(ʊ)kɑːbən/ [n] អ៊ីដ្រូក្លរ៉ូភ្លុយអរ៉ូកាបូន (HCFC)

**hydroelectricity** /hʌɪdrəʊɪlɛkˈtrɪsɪti/ [n] វារីអគ្គិសនី

**Hydrogen** /ˈhʌɪdrədʒ(ə)n/ [n] អ៊ីដ្រូសែន (និមិត្តសញ្ញាគីមី H)

**hydrogenic** /ˈhʌɪdrəʊˈdʒiːnɪk/ [adj] (សទិសន័យ៖ hydromorphic) ជាំទឹក

**hydrogeology** /ˌhʌɪdrəʊdʒɪˈɒlədʒi/ [n] ជលធរណីវិទ្យា

**hydrography** /hʌɪˈdrɒgrəfi/ [n] ជលធារវិទ្យា, ជលធារសាស្ត្រ

**hydrology** /hʌɪˈdrɒlədʒi/ [n] ធារាសាស្ត្រ

- agricultural hydrology /agrɪˈkʌltʃərəl hʌɪˈdrɒlədʒi/ [n] ជលវិទ្យាកសិកម្ម
- groundwater hydrology /ˈgraʊn(d)wɔːtə hʌɪˈdrɒlədʒi/ [n] ជលវិទ្យាទឹកក្រោមដី
- river hydrology /ˈrɪvə hʌɪˈdrɒlədʒi/ [n] ជលវិទ្យាទន្លេ
- sea hydrology /siː hʌɪˈdrɒlədʒi/ [n] ជលវិទ្យាសមុទ្រ
- soil hydrology /sɔɪl hʌɪˈdrɒlədʒi/ [n] ជលវិទ្យាទឹកក្នុងដី (វិទ្យាសាស្ត្រសិក្សាពីសារធាតុរបាយ ការប្រើប្រាស់ និងចលនារបស់ទឹកនៅក្នុងដី)
- surface-water hydrology /ˈsəːfɪs-ˈwɔːtə hʌɪˈdrɒlədʒi/ [n] ជលវិទ្យាទឹកលើផ្ទៃដី

**hydrolysis** /hʌɪˈdrɒlɪsɪs/ [n] អ៊ីដ្រូលីស, ប្រតិកម្មអ៊ីដ្រូលិក (ការបំបែកសមាសធាតុមួយដោយទឹក ដែលក្នុងនោះអាញ៉ុង ចាប់យកអ៊ីដ្រូសែន ឯកាចុងចាប់យកអ៊ីដ្រុកស៊ីលពីទឹក ដើម្បីក្លាយជាអាស៊ីត ឬបាស)

**hydrometeorology** /ˈhʌɪdrəʊˌmiːtɪəˈrɒlədʒi/ [n] ជលឧតុភូតវិទ្យា

**hydrometry** /hʌɪdrəˈmɛtrɪ/ [n] ជលមាត្រ

**hydromorphic** /ˈhʌɪdrəʊˈmɔːfɪk/ [adj] សូមមើលពាក្យ៖ hydrogenic

**hydrophyte** /ˈhʌɪdrəfʌɪt/ [n] (សទិសន័យ៖ hydrophytic vegetation) រុក្ខជាតិដែលចូលចិត្តទឹក ឬដែលដុះក្នុងទឹក

**hydroponics** /ˌhʌɪdrə(ʊ)ˈpɒnɪks/ [n pl] ដំណាំគ្មានដី, ជលវប្បកម្ម, ជលបាតវប្បកម្ម (ការដាំដុះដំណាំក្នុងសូលុយស្យុងដែលមានធាតុចិញ្ចឹម)

**hydroscopicity** [n] ការស្រូបយកសំណើមខ្យល់

**hydrosere** /ˈhʌɪdrəsɪə/ [n] តំណរុក្ខជាតិ (ដែលលូតចេញពីក្នុងទឹក)

**hydrosphere** /ˈhʌɪdrəsfɪə/ [n] មណ្ឌលទឹក (អ៊ីដ្រូស្វ៊ែ)

**hydrotiller** /ˌhaɪdrəˈtɪlə/ [n] ក្របីយន្ត (ឧបករណ៍វាយដីភក់)

- complemental males /kɒmplɪˈmɛnt(ə)l meɪlz/ [n pl] សត្វឈ្មោលរស់ជាប់លើសត្វញី (សត្វទាំងឡាយណាដែលរស់ជាប់ទៅនឹងសត្វញី ដែលមានទំហំធំជាងវាយ៉ាងខ្លាំង ឧ. ត្រីangler)

**malfunctioning** /malˈfʌŋ(k)ʃ(ə)nɪŋ/ [n] ការបំពេញតួនាទីខុសធម្មតា, ការខូច, ការមិនដំណើរការ

***Malia azedarach*** [sci.n] សូមមើលពាក្យ៖ Chinaberry

**malignancy** /məˈlɪgnənsi/ [n] ជំងឺដែលធ្វើឱ្យខ្លាំងឡើងជានិច្ច

**malignant** /məˈlɪgnənt/ [adj] ធ្ងន់ធ្ងរ, ទាន់ហន់ (ជំងឺ)

- malignant edema /məˈlɪgnənt ɪˈdiːmə/ [n] ជំងឺហើមកម្រិតធ្ងន់

**malleable** /ˈmalɪəb(ə)l/ [n] ដែលអាចពត់ ឬបត់បាន

**mallet** /ˈmalɪt/ [n] ញញួរឈើ

**malleus** /ˈmalɪəs/ [n] ឆ្អឹងមានរាងដូចញញួរ ជាប់នឹងក្រដាសត្រចៀក

**mallophaga** /məˈlɒfəgə/ [n] ចៃម្យ៉ាង

**malnourishment** /malˈnʌrɪʃm(ə)nt/ [n] កង្វះសារធាតុចិញ្ចឹម

**malnutrition** /malnjʊˈtrɪʃ(ə)n/ [n] កង្វះអាហារូបត្ថម្ភធ្ងន់ធ្ងរ, កង្វះជីវជាតិ, ការចិញ្ចឹមមិនគ្រប់គ្រាន់, ការបរិភោគមិនគ្រប់គ្រាន់

- acute malnutrition /əˈkjuːt malnjʊˈtrɪʃ(ə)n/ [n] កង្វះអាហារូបត្ថម្ភស្រួចស្រាវ (កង្វះអាហារូបត្ថម្ភស្រួចស្រាវ គឺជាការស្តែងចេញឱ្យឃើញនូវការមានទម្ងន់ទាបធៀបទៅនឹងកម្ពស់របស់កុមារ និង /ឬមានហើមមានស្នាមទ្រុតនៅជើងទាំងសងខាង។ សុចនាករគន្លឹះសម្រាប់កង្វះអាហារូបត្ថម្ភស្រួចស្រាវ គឺជាសមាមាត្រនៃកុមារអាយុក្រោម៥ឆ្នាំដែលមានទម្ងន់តិចជាង២SD ដែលស្ថិតនៅក្រោមខ្សែមេដ្យាន។ នៅក្នុងឡទំរង់ធ្ងន់ធ្ងរបំផុតរបស់បញ្ហានេះ (តូចជាង -៣SD) ត្រូវបានគេដឹងថាជាបញ្ហាស្គមស្គាំង។)
- chronic malnutrition /ˈkrɒnɪk malnjʊˈtrɪʃ(ə)n/ [n] កង្វះអាហារូបត្ថម្ភរ៉ាំរ៉ៃ (កង្វះអាហារូបត្ថម្ភស្រួចស្រាវ គឺជាការស្តែងចេញឱ្យឃើញនូវការមានទម្ងន់ទាបធៀបទៅនឹងកំពស់របស់កុមារ និង/ឬមានហើមមានស្នាមទ្រុតនៅជើងទាំងសងខាង។ សុច្ឆនាករគន្លឹះសំរាប់កង្វះអាហារូបត្ថម្ភស្រួចស្រាវ គឺជាសមាមាត្រនៃកុមារអាយុក្រោម៥ឆ្នាំដែលមានទំងន់តិចជាង ២ SD ដែលស្ថិតនៅក្រោមខ្សែមេដ្យាន។ នៅក្នុង ទំរង់ធ្ងន់ធ្ងរបំផុតរបស់បញ្ហានេះ (តូចជាង -៣SD) ត្រូវបានគេដឹងថាជាបញ្ហាស្គាំង។)
- severe acute malnutrition /sɪˈvɪə əˈkjuːt malnjʊˈtrɪʃ(ə)n/ [n] បញ្ហាកង្វះអាហារូបត្ថម្ភស្រួចស្រាវធ្ងន់ធ្ងរ

**mamba** /ˈmambə/ [n] ពស់វែក

**mammal** /ˈmam(ə)l/ [n] ថនិកសត្វ (សត្វដែលចិញ្ចឹមកូនដោយទឹកដោះ)

**mammalogy** /maˈmalədʒi/ [n] ថនិកសត្វវិទ្យា

**mammary** /ˈmaməri/ [adj] ដែលទាក់ទងនឹងដោះ ឬថនិកសត្វ, នៃដោះ

**mammogram** /ˈmaməgram/ [n] ការឆែករកសាច់ដុះនៅដោះ

**weather man** /ˈwɛðə man/ [n] អ្នកឧតុនិយម, អ្នកព្យាករធាតុអាកាស

**manage** /ˈmanɪdʒ/ [n] អនុមាន (ចាត់ចែង, ត្រិះរិះ, លៃលក)

**management** /ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រង

- crop management /krɒp ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងដំណាំ (បច្ចេកទេស និងសិល្បវិធីនៃការចាត់ចែងនិងប្រតិបត្តិលើការដាំដុះដំណាំរួមទាំងការកំណត់បញ្ហា និងរកដំណោះស្រាយ ដើម្បីទទួលបានផលកម្រៃអតិបរមា)
- environmental management /ɪnvʌɪrənˈmɛnt(ə)l ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងបរិស្ថាន
- forest management /ˈfɒrɪst ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងព្រៃឈើ
- nature management /ˈneɪtʃə ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងធម្មជាតិ
- pest management /pɛst ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងទុរករ (ការគ្រប់គ្រងនៃប្រជាករសមាសភាពចង្រៃតាមរយៈវិធីសាស្ត្រត្រួតពិនិត្យហើយធ្វើការវាស់វែងក្នុងការកម្ចាត់ដោយផ្អែកទៅលើកម្រិតសេដ្ឋកិច្ច)
- resource management /rɪˈsɔːs ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងធនធានធម្មជាតិ
- soil management /sɔɪl ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងដី
- solid waste management /ˈsɒlɪd weɪst ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងសំណល់រឹង
- waste management /weɪst ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងកាកសំណល់
- water management /ˈwɔːtə ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងទឹក
- watershed management /ˈwɔːtəʃɛd ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងទីជម្រាល
- wildlife management /ˈwʌɪl(d)lʌɪf ˈmanɪdʒm(ə)nt/ [n] ការគ្រប់គ្រងសត្វព្រៃ

**mandible** /ˈmandɪb(ə)l/ [n] ថ្គាមក្រោម, ថ្គាមមុខ, ឆ្អឹងថ្គាមក្រោម

**Manganese** /ˈmaŋgəniːz/ [n] ម៉ង់កាណែស (និមិត្តសញ្ញាគីមី Mn)

**mange** /meɪn(d)ʒ/ [n] អង្គែ, កមរមាស់

***Mangifera indica*** [sci.n] សូមមើលពាក្យ៖ mango

**mangle** /ˈmaŋg(ə)l/ [v] កិនយកទឹក, ច្របាច់យកទឹក

**mango** /ˈmaŋgəʊ/ [n] ស្វាយ (ឈ្មោះវិទ្យាសាស្ត្រ *Mangifera indica*)

**mangosteen** /ˈmaŋgəstiːn/ [n] មង្ឃុត (ឈ្មោះវិទ្យាសាស្ត្រ *Garcinia mangostana*)

**mangrove** /ˈmaŋgrəʊv/ [n] ដើមកោងកាង

**mangrove horseshoe crab** [n] កាចរ (ឈ្មោះវិទ្យាសាស្ត្រ *Carcinoscorpius rotundicauda*)

***Manihot esculenta*** [sci.n] សូមមើលពាក្យ៖ cassava (red petiole), cassava (white petiole)

**manila tamarind** /məˈnɪlə ˈtam(ə)rɪnd/ [n] អម្ពិលទឹក

***Manilkara zapota*** [sci.n] សូមមើលពាក្យ៖ sapodilla

**manipulate** /məˈnɪpjʊleɪt/ [v] បញ្ជាដោយដៃ, ចាប់កាន់ដោយដៃ

**manipulation** /məˌnɪpjʊˈleɪʃ(ə)n/ [n] ការព្យាបាលជំងឺគ្រេចដោយដៃ

**manometer** /məˈnɒmɪtə/ [n] ម៉ាណូម៉ែត្រ, ប្រដាប់វាស់សម្ពាធវត្ថុរាវ

**manpower** /ˈmanpaʊə/ [n] កំលាំងពលកម្ម

**mantle** /ˈmant(ə)l/ [n] ម៉ង់តូ

**manual** /ˈmanjʊ(ə)l/ [adj] ដែលប្រើ ឬបញ្ជាដោយដៃ, ធ្វើដោយដៃ

**manufacture** /manjʊˈfaktʃə/ [n] សិប្បកម្ម (កន្លែងផលិតឧបភោគបរិភោគ)

**manufacturer** /ˌmanjʊˈfaktʃ(ə)rə/ [n] សិប្បករ (អ្នកផលិតឧបភោគបរិភោគ)

**manure** /məˈnjʊə/ [n] (សទិសន័យ៖ dung) ជីលាមកសត្វ, ជី (សំណល់សត្វ និងរុក្ខជាតិ)

- cow manure /kaʊ məˈnjʊə/ [n] លាមកគោ (លាមកគោអាចយកទៅប្រើជាជី (ប្រភេទជីសរីរាង្គ) សម្រាប់ដាក់ដំណាំ)
- farmyard manure /ˈfɑːmjɑːd məˈnjʊə/ [n] ជីធម្មជាតិ
- green manure /griːn ˈməˈnjʊə/ [n] ជីស្រស់ (ជីនៃរុក្ខជាតិដែលបង្កប់ដីពេលនៅសល់ ដើម្បីបង្កើនផលិតភាពដី។ ក្នុងនោះមានពពួកសណ្តែក ពពួកវារីជាតិដូចជាស្លឹកពោតស្លឹកអង្កាដី ស្លឹកកន្ទំថេត ទន្ទ្រានខេត្ត សណ្តែក ស្នោ ចកអាសូឡាជាដើម ដែលត្រូវបានយកទៅចិញ្ច្រាំដាក់ក្នុងស្រែ)
- manure spreader /məˈnjʊə ˈsprɛdə/ [n] ម៉ាស៊ីន ឬរថយន្តសម្រាប់ពង្រាយលាមកសត្វ
- nitrogen manure /ˈnʌɪtrədʒ(ə)n məˈnjʊə/ [n] សូមមើលពាក្យ៖ nitrogen fertilizer, nitrogenous fertilizer
- organic manure /ɔːˈganɪk məˈnjʊə/ [n] ជីសរីរាង្គ
- phosphatic manure /fɒsˈfatɪk məˈnjʊə/ [n] សូមមើលពាក្យ៖ phosphate fertilizer
- potash manure /ˈpɒtaʃ məˈnjʊə/ [n] សូមមើលពាក្យ៖ potash fertilizer

**map** /map/ [n] ផែនទី

- absolute topography map /ˈabsəluːt təˈpɒgrəfi map/ [n] ផែនទីសណ្ឋានដីដាច់ខាត
- administrative boundaries map /ədˈmɪnɪstrətɪv ˈbaʊnd(ə)ris map/ [n] ផែនទីព្រំប្រទល់រដ្ឋបាល
- aerial map /ˈɛːrɪəl map/ [n] ផែនទីពីលើអាកាស
- airborne photogeological map /ˈɛːbɔːn ˈfəʊtəʊdʒiːəˈlɒdʒɪk(ə)l map/ [n] ផែនទីធរណីពីលើអាកាស
- biosphere reserve map /ˈbʌɪə(ʊ)sfɪə rɪˈzəːv map/ [n] ផែនទីបម្រុងជីវមណ្ឌល
- climatic map /klʌɪˈmatɪk map/ [n] ផែនទីអាកាសធាតុ
- cytological map /sʌɪtəˈlɒdʒɪk(ə)l map/ [n] ផែនទីកោសិកាវិទ្យា
- ecological map /iːkəˈlɒdʒɪk(ə)l map/ [n] ផែនទីអេកូឡូស៊ី
- geological map /dʒiːəˈlɒdʒɪk(ə)l map/ [n] ផែនទីធរណីវិទ្យា
- geophysical map /ˌdʒiːə(ʊ)ˈfɪzɪk(ə)l map/ [n] ផែនទីរូបធរណីវិទ្យា
- hydrogeological map /ˌhʌɪdrəʊdʒɪəˈlɒdʒɪk(ə)l map/ [n] ផែនទីជលធរណីវិទ្យា
- isohyetal map [n] ផែនទីកម្ពស់ទឹកភ្លៀង
- isothermic map [n] ផែនទីកម្តៅ
- map of the water table /map ɒv ðə ˈwɔːtə ˈteɪb(ə)l/ [n] ផែនទីទឹកក្នុងដី, ផែនទីដង្ហើមទឹក

meteorological map /ˌmiːtɪərəˈlɒdʒɪk(ə)l map/ [n] ផែនទីឧតុភូត

- mineral map /ˈmɪn(ə)r(ə)l map/ [n] ផែនទីរ៉ែ
- natural-hazard map /ˈnatʃ(ə)r(ə)l ˈhazəd map/ [n] ផែនទីគ្រោះថ្នាក់ធម្មជាតិ
- rainfall map /ˈreɪnfɔːl map/ [n] ផែនទីកម្ពស់ទឹកភ្លៀង

relative topography map /ˈrɛlətɪv təˈpɒgrəfi map/ [n] ផែនទីសណ្ឋានដីធៀប

- run-off map /ˈrʌnɒf map/ [n] ផែនទីហូរចរន្តទឹក
- satellite map /ˈsatəlʌɪt map/ [n] ផែនទីផ្កាយរណប

- sea-surface temperature map /siː ˈsəːfɪs ˈtɛmp(ə)rətʃə map/ [n] ផែនទីសីតុណ្ហភាពផ្ទៃទឹកសមុទ្រ
- soil fertility map /sɔɪl fəˈtɪlɪti map/ [n] ផែនទីដីដែលមានជីជាតិ
- space photogeological map /speɪs ˈfəʊtəʊdʒiːəˈlɒdʒɪk(ə)l map/ [n] ផែនទីធរណីវិទ្យាពីអវកាស
- tectonic map /tɛkˈtɒnɪk map/ [n] ផែនទីតិចតូនិច
- topographical map /ˌtɒpəˈgrafɪkəl map/ [n] ផែនទីឋានលេខា ឬសណ្ឋានដី
- water resource map /ˈwɔːtə rɪˈsɔːs map/ [n] ផែនទីធនធានទឹក
- weather map /ˈwɛðə map/ [n] ផែនទីធាតុអាកាស

**mapping** /ˈmapɪŋ/ [n] ទម្ងើផែនទី

- aerial mapping /ˈɛːrɪəl ˈmapɪŋ/ [n] (សទិសន័យ៖ aeroplane mapping) គំហាតពីលើអាកាស
- aeroplane mapping /ˈɛːrəpleɪn ˈmapɪŋ/ [n] សូមមើលពាក្យ៖ aerial mapping
- chromosome mapping /ˈkrəʊməsəʊm ˈmapɪŋ/ [n] ការកំណត់ទីតាំងក្រូម៉ូសូម
- field mapping /fiːld ˈmapɪŋ/ [n] គំហាតនៅទីកន្លែង
- pollutant mapping /pəˈl(j)uːt(ə)nt ˈmapɪŋ/ [n] ទម្ងើផែនទីរបាយសារធាតុពុល
- poverty mapping /ˈpɒvəti ˈmapɪŋ/ [n] ការគូសបង្ហាញពីភាពក្រីក្រ
- regional mapping /ˈriːdʒənl ˈmapɪŋ/ [n] ទម្ងើផែនទីតំបន់
- satellite mapping /ˈsatəlʌɪt ˈmapɪŋ/ [n] ទម្ងើផែនទីដោយប្រើទិន្នន័យពីផ្កាយរណប
- seismic mapping /ˈsʌɪzmɪk ˈmapɪŋ/ [n] ទម្ងើផែនទីសេស្មិច
- space mapping /speɪs ˈmapɪŋ/ [n] ទម្ងើផែនទីពីអវកាស

***Maranta arundinacea*** [sci.n] សូមមើលពាក្យ៖ arrowroot

**marble** /ˈmɑːb(ə)l/ [n] ថ្មកែវ, ថ្មពពាល, ថ្មម៉ាប

**marbled** /ˈmɑːb(ə)ld/ [adj] (សទិសន័យ៖ mottled) ស្នាមប្រពេកប្រតាក

**marbled sleeper** /ˈmɑːb(ə)ld ˈsliːpə/ [n] ត្រីដំរី (ឈ្មោះវិទ្យាសាស្ត្រ *Oxyeleotris marmorata*)

**marcasite** /ˈmɑːkəsʌɪt/ [n] រ៉ែត្បូងថ្ម

**marcotting** [n] (សទិសន័យ៖ air layering) ការផ្សាំមែក (ការធ្វើឱ្យឫសដុះនៅលើសរីរាង្គផ្នែកខាងលើដីរបស់រុក្ខជាតិដោយជៀសម្បក ឬធ្វើឱ្យរបួសកន្លែងណាមួយ ដែលគេចង់ឱ្យដុះឫស ហើយរុំជុំវិញកន្លែងនោះនូវសារធាតុបណ្ដុះឫស ឬអាចប្រើអរម៉ូនចិញ្ចឹមឫស)

**marcroelement** /ˈmakrəʊˈɛlɪm(ə)nt/ [n] ម៉ាក្រូធាតុ (ធាតុចិញ្ចឹមដែលរុក្ខជាតិត្រូវការ ឬស្រូបយកបរិមាណច្រើនក្នុងចំនួនលើសពី ០.១ %នៃទម្ងន់ស្ងួតវា។ ធាតុម៉ាក្រូទាំងនោះមានដូចជា កាបូន អ៊ីដ្រូសែន អុកស៊ីសែន អាសូត ផូស្វ័រ ប៉ូតាស្យូម កាល់ស្យូម ម៉ាញេស្យូម និងស៊ុលផួរ។)

**mare** /mɛː/ [n] សេះ ឬលាញី

**margin** /ˈmɑːdʒɪn/ [n]
១. គែម (ស្លឹក)
២. ព្រំ (ចម្ការ)

**marijuana** /ˌmarɪˈhwɑːnə/ [n] កញ្ឆា

**marine** /məˈriːn/ [adj] នៃសមុទ្រ, តាមសមុទ្រ

**marker** /ˈmɑːkə/ [n] លក្ខណៈសម្គាល់ (លក្ខណៈ ឬពន្ធុ ឬសែនមួយ ដោយអាស្រ័យភាពមានលក្ខណៈទំនាក់ទំនងគ្នា គេអាចប្រើដើម្បីចង្អុលប្រាប់ពីវត្តមានរបស់ពន្ធុ ឬសែនផ្សេងៗទៀត)

- DNA marker /diːɛnˈeɪ ˈmɑːkə/ [n] ឧបករណ៍សម្គាល់ DNA ( ចំណែកសម្រាប់សំគាល់មួយនៃច្រវាក់ DNA។ )
- molecular marker /məˈlɛkjʊlə ˈmɑːkə/ [n] ឧបករណ៍សម្គាល់ម៉ូលេគុល

**marl** /mɑːl/ [n] ថ្មកំបោរម៉ាន (ដីឥដ្ឋ និងកំបោរ)

- bog marl /bɒgmɑːl/ [n] (សទិសន័យ៖ marsh marl) ម៉ានក្នុងទំនាបបឹង
- clayey marl /ˈkleɪi mɑːl/ [n] ម៉ានដែលឥដ្ឋច្រើន
- gravelly marl /ˈgrav(ə)li mɑːl/ [n] កម្ទេចថ្មកំបោរ
- irised marl /ˈʌɪrɪst mɑːl/ [n] ម៉ានចម្រុះពណ៌
- marl with pebbles /mɑːl wɪð ˈpɛb(ə)ls/ [n] សូមមើលពាក្យ៖ stony marl
- marsh marl /mɑːʃ mɑːl/ [n] សូមមើលពាក្យ៖ bog marl

- meadow marl /ˈmɛdəʊ mɑːl/ [n] ស្រទាប់កំបោរក្នុងវាលភក់ (សម្រាប់យកទៅកែច្នៃដីពើក)
- sandy marl /ˈsandi mɑːl/ [n] ថ្មកំបោរម៉ានដែលមានខ្សាច់ច្រើន
- shell-marl /ʃɛl mɑːl/ [n] សូមមើលពាក្យ៖ lime bog
- stony marl /ˈstəʊni mɑːl/ [n] (សទិសន័យ៖ marl with pebbles) ម៉ានដែលមានក្រួស

**marmalade** /ˈmɑːməleɪd/ [n] ដំណាប់ផ្លែឈើម្យ៉ាង

**marrow** /ˈmarəʊ/ [n] ខួរឆ្អឹង

- bone marrow /bəʊn ˈmarəʊ/ [n] ខួរឆ្អឹង

**marrowfat** /ˈmarə(ʊ)fat/ [n] សណ្តែកបារាំងម្យ៉ាងមានគ្រាប់ៗ

**marsh border soil** /mɑːʃ ˈbɔːdə sɔɪl/ [n] សូមមើលពាក្យ៖ half-bog soil, semi-swamp soil

**marsh** /mɑːʃ/ [n] សូមមើលពាក្យ៖ swamp

- dike marsh /dʌɪk mɑːʃ// [n] ដីទំនាបដែលព័ទ្ធជុំវិញដោយទំនប់សមុទ្រ
- eutrophic marsh /juːˈtrəʊfɪk mɑːʃ/ [n] ដីទំនាបបឹងដែលមានជីជាតិខ្ពស់
- fresh-water marsh /frɛʃ ˈwɔːtə mɑːʃ/ [n] (សទិសន័យ៖ soft water marsh) ទំនាបបឹង (ទឹកសាប)
- new marsh /njuː mɑːʃ/ [n] ទំនាបបឹងថ្មី, ប៉ុលដែរ
- old marsh /əʊld mɑːʃ/ [n] ដីទំនាបបឹងចាស់តាមបណ្តោយឆ្នេរ
- raw marsh /rɔː mɑːʃ/ [n] ដីថ្មីក្នុងទំនាបបឹង, ដីគ្មានស្រទាប់ A ច្បាស់លាស់
- river marsh /ˈrɪvə mɑːʃ/ [n] ទំនាបនៅតាមមាត់ស្ទឹងទន្លេ
- salt marsh /sɔːlt mɑːʃ/ [n] រុក្ខជាតិដុះលើដីភក់ប្រៃ
- salt water marsh /sɔːlt ˈwɔːtə mɑːʃ/ [n] ទំនាបបឹងដែលជាទឹកប្រៃ
- tidal marsh /ˈtʌɪd(ə)l mɑːʃ/ [n] ទំនាបតាមឆ្នេរសមុទ្រ
- tropical flat marsh /ˈtrɒpɪk(ə)l flat mɑːʃ/ [n] ទំនាបបឹងនៅតំបន់ត្រូពិច
- tropical high marsh /ˈtrɒpɪk(ə)l hʌɪ mɑːʃ/ [n] ដីបឹងនៅតំបន់ខ្ពស់ក្នុងតំបន់ត្រូពិច

**marsh-pepper smartweed** [n] ម្រេចទឹក (ឈ្មោះវិទ្យាសាស្ត្រ *Polygonum hydropiper*)

**marshy** /ˈmɑːʃi/ [adj] (សទិសន័យ៖ swampy) ដែលពាសពេញទៅដោយវាលភក់ល្បប់

***Marsilea minuta*** [sci.n] សូមមើលពាក្យ៖ water clover

**marsupial** /mɑːˈsuːpɪəl/ [adj] ថនិកសត្វមានថង់ដាក់កូន (ឧ. កង់គូរូ)

**marten** /ˈmɑːtɪn/ [n] សត្វសំពោច

**martin** /ˈmɑːtɪn/ [n] សត្វសារិកាកែវ

***Maruca vitrata*** [sci.n] ដង្កូវស៊ីរូងផ្លែសណ្តែក

**masculine** /ˈmaskjʊlɪn/ [adj] សូមមើលពាក្យ៖ male

**mask** /mɑːsk/ [n] របាំងមុខ, ប្រដាប់គ្របមុខ

**mass** /mas/ [n] ដុំ, ម៉ាស

- air mass /ɛː mas/ [n] ម៉ាសខ្យល់
- cold mass /kəʊld mas/ [n] ម៉ាសខ្យល់ត្រជាក់
- continental mass /kɒntɪˈnɛnt(ə)l mas/ [n] ម៉ាសខ្យល់ទ្វីប
- dry mass /drʌɪ mas/ [n] (សទិសន័យ៖ dry weight) ម៉ាសស្ងួត
- ground mass /graʊnd mas/ [n] (សទិសន័យ៖ cement) ស៊ីម៉ង់ (ក្នុងដី)
- warm mass /wɔːm mas/ [n] ម៉ាសខ្យល់ក្តៅ
- mass wasting /mas weɪst/ [n] ការប្រមូលផ្តុំកម្ទេចកំទី (ដោយប៉ីសសង់ទ័រ ឬទឹក), ការច្រោះជាដុំ ឬដុលគំនរ

**massif** /ˈmasɪf/ [n] ប្រជុំភ្នំ, ផ្ទាំងដុល

**mast year** /mɑːst jɪə/ [n] (សទិសន័យ៖ seed year) ឆ្នាំផ្លែច្រើន (ឆ្នាំមួយដែលសម្បូរផលផ្លែរ ឬគ្រាប់ច្រើន)

***Mastacembelus armatus*** [sci.n] សូមមើលពាក្យ៖ zig-zag eel

***Mastacembelus erythrotaenia*** [sci.n] សូមមើលពាក្យ៖ fire eel

***Mastacembelus favus*** [sci.n] សូមមើលពាក្យ៖ tire track eel

**mastectomy** /maˈstɛktəmi/ [n] ការកាត់យកដោះចេញ

**mastication** /mastɪˈkeɪʃ(ə)n/ [n] ការទំពា, ការអង្កៀម

**masting** /mɑːstɪŋ/ [n] ការចេញផ្លែច្រើន (ពាក្យន័យខាងបរិស្ថានដែលគេប្រើដើម្បីពិពណ៌នាពីយុទ្ធសាស្ត្ររបស់ប្រភេទរុក្ខជាតិមួយចំនួនក្នុងការផលិតផលគ្រាប់បានច្រើននៅក្នុងចន្លោះពេលវែងមួយ ឧ. ប្រភេទ dipterocarps និង araucarias)

**mastitis** /maˈstʌɪtɪs/ [n] ជំងឺរលាកដោះ, លាសដោះ (ជំងឺដោះឡើងតឹងរឹងក្រហមហើយឈឺ)

**mastoiditis** /ˌmastɔɪˈdʌɪtɪs/ [n] ជំងឺរលាកឆ្អឹងមួយនៅជិតកណ្ដាលត្រចៀក

**material** /məˈtɪərɪəl/ [n] ឧបករណ៍, សម្ភារ (របស់របរប្រើប្រាស់)

- crossreacting material (CRM) /krɒsrɪˈaktɪŋ məˈtɪərɪəl/ [n] ធាតុបង្កាក់ប្រតិកម្ម
- food material /fuːd məˈtɪərɪəl/ [n] សារធាតុអាហារ
- forest reproductive material /ˈfɒrɪst ˌriːprəˈdʌktɪv məˈtɪərɪəl/ [n] សម្ភារបន្តពូជនៃប្រភេទឈើព្រៃ ( គ្រាប់ កោន និងផ្នែកផ្សេងៗរបស់រុក្ខជាតិដែលអាចដុះទៅជារុក្ខជាតិ រួមមានទាំងកូនរុក្ខជាតិដែលដុះពីគ្រាប់ ឬពីសរីរាង្គលូតលាស់។)
- genetic material /dʒɪˈnɛtɪk məˈtɪərɪəl/ [n] សម្ភារតំណពូជ, សម្ភារសេនេទិច
- green plant material /griːn ˈplɑːnt məˈtɪərɪəl/ [n] សារធាតុរុក្ខបៃតង (សារធាតុដើមស្រស់ ដូចជា ដើមសណ្ដែកនៅក្រោយពេលប្រមូលផលគ្រាប់រួចហើយ វាត្រូវបានគេភ្ជួរបង្កប់ចូលក្នុងដី)
- illuvial material /ɪˌl(j)uːvɪˈeɪl məˈtɪərɪəl/ [n] សម្ភារ ឬវត្ថុធាតុនាំមកពីកន្លែងផ្សេងទៀតដែលធ្វើឱ្យកកស្ទះរន្ធដី
- parent material /ˈpɛːr(ə)nt məˈtɪərɪəl/ [n] សម្ភារដើម
- raw material /rɔː məˈtɪərɪəl/ [n] វត្ថុធាតុដើម
- selected reproductive material /sɪˈlɛktɪd ˌriːprəˈdʌktɪv məˈtɪərɪəl/ [n] ជម្រើសសម្ភារបន្តពូជ

**maternal** /məˈtəːn(ə)l/ [adj] ខាងម្ដាយ, ម្ដាយ

**maternity** /məˈtəːnɪti/ [n] មត្តេយ្យភាព, ភាពជាម្ដាយ

**mating** /ˈmeɪtɪŋ/ [n] កាបង្កាត់ពូជ, ការបន្តពូជ, ពំនាក់គ្នា (សត្វជើងបួន), ការជាន់គ្នា (បក្សី), សំគារគ្នា(ល្មូន ត្រី), កំទុតគ្នា (សត្វល្អិត)

- assortative mating /əˈsɔːtətɪv ˈmeɪtɪŋ/ [n] ការបន្តពូជក្នុងក្រុម
- consanguineous mating /ˌkɒnsaŋˈgwɪnɪəs ˈmeɪtɪŋ/ [n] ការបង្កាត់គ្នារវាងពូជដែលមានស្រឡាយជិត
- open pollination mating /ˈəʊp(ə)n pɒlɪˈneɪʃ(ə)n/ [n] ការបង្កាត់ពាយលម្អងសេរី (គ្រោងការណ៍បង្កាត់វង្សត្រកូលមិនពេញលេញ ដែលក្នុងនោះគ្រាប់ត្រូវបានគេប្រមូលពីដើមមេដែលគ្មានព័ត៌មានអំពីប្រភពលម្អង។ ដូចជាវិធីសាកល្បងកូនដែរ វាអាចផ្ដល់ព័ត៌មានអំពីលទ្ធភាពផ្សំទូទៅរបស់គ្រាប់មេបា។)
- random mating /ˈrandəm ˈmeɪtɪŋ/ [n] (សទិសន័យ៖ panmixia) ការបង្កាត់គាដោយចៃដន្យ ( ការកើតឡើងនៃការបន្តពូជតាមភេទក្នុងចំណោមសមាជិកឯកត្តៈរបស់ក្រុមពូជមួយដែលក្នុងនោះភវនីយ ភាព(probability) នៃការបង្កាត់គ្នារបស់ឯកត្តៈ២ណាមួយ គឺស្មើគ្នា។)
- single-pair mating /ˈsɪŋg(ə)l pɛː ˈmeɪtɪŋ/ [n] ការបង្កាត់គូម្ខាង (ការរៀបចំគ្រោងការណ៍បង្កាត់វង្សរាវលីពេញលេញ ដែលក្នុងនោះមេបានីមួយៗត្រូវបាន បង្កាត់ជាមួយសមាជិកម្ខាងទៀតរបស់ក្រុមពូជ។ ការបង្កាត់នេះបង្កើតបានជាចំនួនអតិបរមានៃអម្បូរមិនជាប់សាច់ញាតតិគ្នានៅក្នុងជំនាន់នីមួយៗ ជាមួយនិងចំនួនអតិបរមា ។)

**matter** /ˈmatə/ [n] រូបធាតុ, វត្ថុធាតុ

- harvestable dry matter /ˈhɑːvɪsteɪb(ə)l drʌɪ ˈmatə/ [n] សមាសធាតុស្ងួតដែលប្រមូលបាន
- inorganic matter /ɪnɔːˈganɪk ˈmatə/ [n] រូបធាតុអសរីរាង្គ
- mechanical organic matter /mɪˈkanɪk(ə)l ɔːˈganɪk ˈmatə/ [n] (សទិសន័យ៖ unhumified organic matter) សរីរាង្គដែលមិនក្លាយជាមមោក
- mineral matter /ˈmɪn(ə)r(ə)l ˈmatə/ [n] រូបធាតុខនិជ
- organic matter /ɔːˈganɪk ˈmatə/ [n] រូបធាតុសរីរាង្គ, សារធាតុសរីរាង្គ (ផ្នែកសារធាតុសរីរាង្គនៃដីដែលរួមមានសំណល់រុក្ខជាតិ ឬសត្វដែលរលួយក្នុងកម្រិតផ្សេងៗ និងសារធាតុដទៃៗទៀត ដែលសំយោគដោយប្រជាកររបស់ដី)
- prehumic matter /prɪˈhjuːmɪk ˈmatə/ [n] បុរេសរីរាង្គមមោក
- unhumified organic matter /ʌnˈhjuːmɪfʌɪ ɔːˈganɪk ˈmatə/ [n] សូមមើលពាក្យ៖ mechanical organic matter

**mattress** /ˈmatrɪs/ [n]
១. (ចំពោះធរណីវិទ្យា) ការដាក់ប្រដើសដើម្បីទប់ដី
២. ពូក

**maturation** /matjʊˈreɪʃ(ə)n/ [n] ភាពពេញវ័យ, ដំណើរទុំ (ចាស់), ការវិវត្តន៍ធម្មតា
- maturation of germ cells /matjʊˈreɪʃ(ə)n ɒv dʒəːm sɛlz/ [n] ភាពពេញវ័យរបស់កោសិកាកាម៉េត

**mature** /məˈtʃʊə/ [adj] ទុំ, ចំណាស់, ពេញវ័យ, ចាស់ទុំ (ដំណាក់កាលពេញវ័យ)
១. រុក្ខជាតិ: ដំណាក់កាលនៃឯកត្តៈក្រោយពីឆ្លងផុតពីភាពខ្ចី ជារឿយៗមានន័យដូចពាក្យ Reproductive age អាយុបន្តពូជបាន)។ ពាក្យផ្ទុយ Juvenile ។
២. ផ្លែ: ដំណាក់កាលរបស់ផ្លែពេលដែលគ្រាប់ត្រៀមខ្លួនពង្រាយ ជាធម្មតាបែបនេះ តែមិនជានិច្ចកាលទេ វាត្រូវគ្នា នឹងលទ្ធភាពដំណុះរបស់គ្រាប់។ ជារឿយៗ គេអាចសំគាល់បាន ឧ. ការប្រែប្រួលពណ៌ ការស្ងួតទឹក និងរចនាសម្ព័ន្ធផ្លែរបើក។
៣. គ្រាប់: គ្រាប់ដែលអាចដុះពន្លកបាន ក្រោយពីប្រលេះវាចេញពីផ្លែ និងអាចបំបែកភាពសំងំវាបាន។

**physiological maturity** /ˌfɪzɪəˈlɒdʒɪk(ə)l məˈtʃʊərəti/ [n] ភាពពេញវ័យខាងសរីរៈ (ពាក្យន័យទូទៅមួយសំដៅលើដំណាក់កាលខួបជីវិតរបស់គ្រាប់មួយ នៅពេលដែលការវិវត្តន៍របស់វាចប់សព្វគ្រប់ ហើយសមាសធាតុគីមីជីវសាស្ត្រចាំបាច់សម្រាប់ដំណើរការខាងសរីរៈអាចមានសកម្មភាព ឬត្រៀមមានសកម្មភាព)

**maxilla** /makˈsɪlə/ [n] (ពហុវចនៈ៖ maxillae) ថ្គាមលើ, ថ្គាមក្រោយ, ឆ្អឹងថ្គាមខាងលើ

**meadow** /ˈmɛdəʊ/ [n] វាលស្មៅ, ចម្ការ (គ្រាមភាសា)
- wet meadow /wɛt ˈmɛdəʊ/ [n] វាលស្មៅសើម, វាលស្មៅលិចទឹក

**fish meal** /fɪʃ miːl/ [n] ម្សៅត្រី

**meander** /mɪˈandə/ [n] ភ្នែន (ទន្លេ)

**measle** /ˈmiːz(ə)lz/ [n] កញ្ជ្រិល

**measurable** /ˈmɛʒ(ə)rəb(ə)l/ [adj] ដែលអាចវាស់បាន

**measure** /ˈmɛʒə/ [v] វាស់, ស្ទង់

**measure** /ˈmɛʒə/ [n] វិធានការ
- mitigation measure /mɪtɪˈgeɪʃ(ə)n ˈmɛʒə/ [n] វិធានការកាត់បន្ថយ
- sanitary measure /ˈsanɪt(ə)ri ˈmɛʒə/ [n] វិធានការអនាម័យ
- tape measure /teɪp ˈmɛʒə/ [n] ម៉ែត្រមូរ, ម៉ែត្រសំពត់

**measurement** /ˈmɛʒəm(ə)nt/ [n] រង្វាស់, ខ្នាត
- measurement tape /ˈmɛʒəm(ə)nt teɪp/ [n] (សទិសន័យ៖ measuring tape) ម៉ែត្រមូរ (ម៉ែត្រខ្សែដែលអាចមូរជារមូរបាន)
- flow measurement /fləʊ ˈmɛʒəm(ə)nt/ [n] រង្វាស់រង្វាល់ការហូរ

**measuring tape** /ˈmɛʒərɪŋ teɪp/ [n] សូមមើលពាក្យ៖ measurement tape

**meat** /miːt/ [n] សាច់
- meat ball /miːt bɔːl/ [n] ប្រហិតសាច់
- meat chicken /miːt ˈtʃɪkɪn/ [n] មាន់សាច់
- pickled meat /ˈpɪk(ə)ld miːt/ [n] សាច់ប្រឡាក់

**mechanism** /ˈmɛk(ə)nɪz(ə)m/ [n]
១. ចលនការ (ដំណើរការនៃប្រព័ន្ធតួនាទីរបស់ជីវករ ឧទាហរណ៍ យន្តការចេញផ្កា),
២. យន្តការ (ប្រព័ន្ធនៃចល័តផ្នែកផ្សេងៗដែលបំពេញតួនាទីឧសគ្នា ឧទាហរណ៍ គ្រឿងម៉ាស៊ីន)
- avoidance mechanism /əˈvɔɪd(ə)ns ˈmɛk(ə)nɪz(ə)m/ [n] យន្តការបញ្ចៀស
- escape mechanism /ɪˈskeɪp ˈmɛk(ə)nɪz(ə)m/ [n] យន្តការបញ្ចៀស (ការបង្អាត់ពូជសម្រាប់រកភាពធន់នឹងភាពរាំងស្ងួត ដើម្បីរកសមត្ថភាពរបស់រុក្ខជាតិ (ស្រូវ) ណាដែលអាចបំពេញចប់សព្វគ្រប់វដ្តជីវិតវាមុនពេលភាពរាំងស្ងួតមកដល់)

regulating mechanism /ˈrɛgjʊleɪtɪŋ ˈmɛk(ə)nɪz(ə)m/ [n] ការធ្វើឱ្យម៉ាស៊ីនមានដំណើរការល្អ

**mechanization** /ˈmɛk(ə)nʌɪzeɪʃ(ə)n/ [n] យន្តកម្ម (អំពើនៃគ្រឿងយន្ត)

farm mechanization /fɑːm mɛk(ə)nʌɪˈzeɪʃ(ə)n/ [n] យន្តកម្មកសិកម្ម (ការប្រើគ្រឿងយន្តក្នុងវិស័យកសិកម្ម)

**mechanize** /ˈmɛk(ə)nʌɪz/ [v] ធ្វើយន្តកម្ម (ការអនុវត្តន៍ដោយគ្រឿងយន្ត)

**meconium** /mɪˈkəʊnɪəm/ [n] អាចម៍ព្រៃ, អាចម៍ខ្មាំង

**media** /ˈmiːdɪə/ [n pl] (ឯកវចនៈ៖ medium) មជ្ឈដ្ឋាន (បណ្តុះមេរោគ)

**median** /ˈmiːdɪən/ [n] មេដ្យាន

**mediastinum** /ˌmiːdɪəˈstʌɪnəm/ [n] ចុងដង្ហើម

**Medicaid** /ˈmɛdɪkeɪd/ [n] ជំនួយពេទ្យ

**medical** /ˈmɛdɪk(ə)l/ [adj] ផ្នែកពេទ្យ, ខាងវិជ្ជាពេទ្យ, ខាងសុខភាព ដែលទាក់ទងនឹងថ្នាំ ឬការព្យាបាល

- medical necessary /ˈmɛdɪk(ə)l ˈnɛsəs(ə)ri/ [n] ការត្រូវការពេទ្យជាចាំបាច់

**Medicare** /ˈmɛdɪkɛː/ [n] ការថែរក្សារោគ

**medication** /mɛdɪˈkeɪʃ(ə)n/ [n] ការឱ្យថ្នាំ

**folk medicine** /fəʊk ˈmɛds(ə)n/ [n] ថ្នាំឱសថបុរាណ

**Medigap** /ˈmɛdɪgap/ [n] វិវរពេទ្យ (ការពេទ្យអ្វីដែលមិនបានចេញឱ្យ ត្រូវបានផ្តល់ជូន)

**medium** /ˈmiːdɪəm/ [n] (ពហុវចនៈ medium) មជ្ឈដ្ឋាន (បណ្តុះមេរោគ)

- defined medium /dɪˈfʌɪnd ˈmiːdɪəm/ [n] មជ្ឈដ្ឋានស្គាល់សមាសធាតុផ្សំ
- differential medium /ˌdɪfəˈrɛnʃ(ə)l ˈmiːdɪəm/ [n] មជ្ឈដ្ឋានញែកភាពខុសគ្នា
- selective medium /sɪˈlɛktɪv ˈmiːdɪəm/ [n] មជ្ឈដ្ឋានបណ្តុះជម្រើស (មជ្ឈដ្ឋានទាំងឡាយណាដែលកម្រិតការលូតលាស់របស់ អតិសុខុមប្រាណមួយចំនួន ប៉ុន្តែមិនកម្រិតសម្រាប់មីក្រុបផ្សេងទៀតទេ)

**medulla** /mɛˈdʌlə/ [n]

១. ខ្លឹមឈើ

២. ខួរក្នុងឆ្អឹង, ផ្នែកក្រោមនៃខួរ

**megaspore** /ˈmɛgəspɔː/ [n] សូមមើលពាក្យ៖ macrospore

**megastrobili** [n] កេសរញី, មេហ្គាស្ត្របីឡាយ

**meiosis** /mʌɪˈəʊsɪs/ [n] ដំណើរការផលិតកោសិកាបន្តពូជ, ចំណែកកោសិកាបន្តពូជ, មេយ៉ូស (ការបន្ថយចំនួនក្រូម៉ូសូម ពីឌីប្លូអ៊ីត (២n) ទៅឯកប្លូអ៊ីត (n) ក្នុងដំណើរការចំណែកកោសិកា)

**Meitnerium** /mʌɪtˈnɪərɪəm/ [n] ម៉េតនីរ្យ៉ូម (និមិត្តសញ្ញាគីមី Mt)

**Mekong blind sole** /miːˈkɒŋ blʌɪnd səʊl/ [n] ត្រីអណ្តាតឆ្កែ (ឈ្មោះវិទ្យាសាស្ត្រ *Typhlachirus elongatus*)

**Mekong River Commission (MRC)** /miːˈkɒŋ ˈrɪvə kəˈmɪʃ(ə)n/ [n] គណៈកម្មការទន្លេមេគង្គ

***Mekongina erythrospila*** [sci.n] ត្រីប៉ាសេអ៊ី

***Melanitis leda ismene*** [sci.n] សូមមើលពាក្យ៖ greenhorned caterpillar

**melanoma** /ˌmɛləˈnəʊmə/ [n] សាច់ដុះ (ដូចជាដំពោះជាដើម)

**melazone** /ˈmeɪləːzəʊn/ [n] ស្រទាប់ខ្មៅដោយមមោក

**melena** /mɪˈliːnə/ [n] កំអួតពណ៌ខ្មៅ, ការមានលាមកពណ៌ខ្មៅ

**melllow** /ˈmɛləʊ/ [adj] សូមមើលពាក្យ៖ loose

**mellowing** /ˈmɛləʊwɪŋ/ [n] សូមមើលពាក្យ៖ tillage

***Meloidogyne graminicola*** [sci.n] សូមមើលពាក្យ៖ root-knot nematode

**honey dew melon** /ˈhʌni ˈdjuː ˈmɛlən/ [n] ត្រសក់ស្រូវម៉្យាង (ប្រភពមកដើមបារាំង)

**membrane** /ˈmɛmbreɪn/ [n] ភ្នាស, ជាលិកាស្តើងៗ, សម្រោប

- egg membrane /ɛg ˈmɛmbreɪn/ [n] ភ្នាសស៊ុត
- embryonic membrane /ˌɛmbrɪˈɒnɪk ˈmɛmbreɪn/ [n] (សទិសន័យ៖ extraembryonic membrane) ភ្នាសអំប្រីយ៉ុង
- extraembryonic membrane / ˈɛkstrəˌɛmbrɪˈɒnɪk ˈmɛmbreɪn/ [n] សូមមើលពាក្យ៖ embryonic membrane
- fertilisation membrane /ˌfəːtɪlʌɪˈzeɪʃ(ə)n ˈmɛmbreɪn/ [n] ភ្នាសបង្កកំណើត
- mucous membrane /ˈmjuːkəs ˈmɛmbreɪn/ [n] (សទិសន័យ៖ mucous) ភ្នាសសើម
- serous membrane /ˈsɪərəs ˈmɛmbreɪn/ [n] ភ្នាសសេរ៉ូម

**men/animal/day** [n] មនុស្ស/សត្វ/ថ្ងៃ (ខ្នាតពលកម្មគិតជាកម្លាំងមនុស្ស និងកម្លាំងសត្វពាហនៈ)

**men/day** [n] មនុស្ស/ថ្ងៃ (ខ្នាតពលកម្មគិតជាកម្លាំងមនុស្ស)

**menace** /ˈmɛnəs/ [n] ការគំរាមកំហែង

**menarche** /mɛˈnɑːki/ [n] ការមានរដូវដំបូង

**Mendelevium** /ˌmɛndəˈliːvɪəm/ [n] មិនដេលេវ្យូម (និមិត្តសញ្ញាគីមី Md)

**Mendel's principles** /ˈmɛnd(ə)ls ˈprɪnsɪp(ə)ls/ [n pl] ច្បាប់ម៉ង់ដែល, គោលការណ៍ម៉ង់ដែល (ការខុសគ្នាខាងតំណពូជមានឯកតាមូលដ្ឋានពិសេសដែលគេហៅថាពន្ធុ ឬសែន។ ពន្ធុ ឬសែនមានវត្តមានជាគូៗ ដែលពន្ធុ ឬសែន នីមួយៗគឺជាអាលែលមួយ។ អាលែលមួយអាចមានលក្ខណៈលប់លើអាលែលមួយទៀត។ នៅក្នុងអំឡុង ពេលធ្វើមេយ៉ូស គូអាលែលត្រូវផ្តាច់ចេញពីគ្នា។ នៅក្នុងអំឡុងពេលធ្វើការបង្កកំណើតបណ្តាអាលែលមក ពីខាងមេនិងខាងបាធ្វើការផ្គុំគ្នា។ លទ្ធផលរបស់កូនបង្ហាញពីអនុបាតវិនិយោគកម្ម (ការបំបែកខ្លួន) ចំពោះ ការផ្សំផ្គុំលក្ខណៈផ្សេងៗអាស្រ័យទៅតាមច្បាប់ភវនីយភាព (ផរៀបាបិលិតយ) ដោយសារតែអាលែលវិនិយោគនីមួយៗត្រូវបានចែករំលែកដោយចៃដន្យទៅឱ្យកាម៉ែតមួយ ហើយឯករាជ្យពីបណ្តាពន្ធុ ឬសែនដ៏ទៃទៀត និងដោយ សារតែស៊ុតនិងស្ពែម ផ្គុំគ្នាដោយចៃដន្យ។)

**meningioma** /mɪˌnɪndʒɪˈəʊmə/ [n] សាច់ដុះលើស្រោមខួរ

**meningitis** /ˌmɛnɪnˈdʒʌɪtɪs/ [n] រោគរលាកស្រោមខួរ

**meniscus** /mɪˈnɪskəs/ [n] ផ្ទៃផត (នៃវត្ថុរាវនៅក្នុងកែវ)

***Menochilus sexmaculatus*** [sci.n] អណ្តើកមាស

**menopause** /ˈmɛnəpɔːz/ [n] វេលាដែលស្ត្រីលែងមានរដូវ

**mense** /ˈmɛns/ [n] រដូវ (សំដៅលើការទម្លាក់អូវុលទុំ ដែលមិនបានបង្កកំណើត)

**menstruation** /mɛnstrʊˈeɪʃ(ə)n/ [n] ការមានរដូវ

**mental** /ˈmɛnt(ə)l/ [n] មនសិការ ឬមនស្មារ, ផ្លូវសតិ (នៃខាងខួរក្បាល ឬគំនិតប្រាជ្ញា, ការកំណត់ទុកក្នុងចិត្ត, ដំណើរយកចិត្តទុកដាក់,ដំណើរតាំងចិត្ត,ការផ្តេងចិត្ត ឬសតិបញ្ញា)

- mental disability /ˈmɛnt(ə)l dɪsəˈbɪlɪti/ [n] ភាពពិការសតិបញ្ញា, ពុទ្ធិវិបល្លាស (ដំណើរប្រែប្រួលនៃប្រាជ្ញា, ការខូចសតិបញ្ញា, វិបត្តចរិត)
- mental health /ˈmɛnt(ə)l hɛlθ/ [n] សុខារម្មណ៍, សុខភាពនៃសតិ បញ្ញា (ការសុខនៃអារម្មណ៍, អារម្មណ៍ដែលទទួល សេចក្តីសុខ), ជាសុខភាព
- mental retardation /ˈmɛnt(ə)l riːtɑːˈdeɪʃ(ə)n/ [n] ការវិកលសតិបញ្ញា,ដំ ណើរយឺតយ៉ាវខាងផ្លូវសតិបញ្ញា

***Mentha arvensis*** [sci.n] សូមមើលពាក្យ៖ peppermint

**Mercury** /ˈməːkjəri/ [n] បារ៉ត (និមិត្តសញ្ញាគីមី Hg)

**mere** /mɪə/ [n] ត្រពាំង, ស្រះទឹក

**merino** /məˈriːnəʊ/ [n] ពូជសត្វចៀមដែលមានរោមវែងល្អ

**meristem** /ˈmɛrɪstɛm/ [n] មេជាលិកា, តំបន់ជាលិកាសកម្ម, ផ្នែកលូតលាស់របស់រុក្ខជាតិ (ចុងឫស ត្រួយ), ជាលិកាលូតលាស់ (ជាលិការុក្ខជាតិ ដែលមានតួនាទីទ្រទ្រង់ការលូតលាស់រុក្ខជាតិ ជាទូទៅស្ថិតនៅខាងចុងពន្លក ឬត្រួយ ឬក៏ចុងឫស)

- apical meristem /ˈeɪpɪk(ə)l ˈmɛrɪstɛm/ [n] ចុង, កំពូលជាលិកាដំណុះ (ម៉េរីស្ទែម), មេជាលិកាកំពូល, មេជាលិកាមេកំពូល (កោសិកាមិនបំប្លែងឯកទេសដែលធ្វើចំណែក ដើម្បីបង្កើតកោសិកាថ្មីៗនៅក្បាលឫស ឬចុងត្រួយ)
- ground meristem /graʊnd ˈmɛrɪstɛm/ [n] មេជាលិកា (ជាលិកាគ្រឹះនៃមេជាលិកាកំពូលដែលផលិតសម្បក)
- intercalary meristem /ɪnˈtəːkəl(ə)ri ˈmɛrɪstɛm/ [n] មេជាលិកាចន្លោះ (មេជាលិកានៅគល់ស្លឹក និង/ឬ ស្រោមគ្រាប់របស់រុក្ខជាតិម៉ូណូកូទីលេដូនជាច្រើន)
- lateral meristem /ˈlat(ə)r(ə)l ˈmɛrɪstɛm/ [n] មេជាលិកាចំហៀង (ជាមេជាលិកាដែលផលិតជាលិកាទីពីរ)
- primary meristem /ˈprʌɪm(ə)ri ˈmɛrɪstɛm/ [n] មេជាលិកាទី១ (មេជាលិការបស់អំប្រ៊ីយ៉ុងរុក្ខជាតិ ដែលនឹងវិវត្តទៅជាអេពីឌែម)
- primary thickening meristem /ˈprʌɪm(ə)ri ˈθɪk(ə)nɪŋ ˈmɛrɪstɛm/ [n] មេជាលិកាបង្កើតកម្រាស់ទី ១ (មេជាលិកាដែលបង្កើតកម្រាស់អ័ក្សដើម នៅក្នុងរុក្ខជាតិម៉ូណូកូទីលេដូនមួយចំនួន)
- secondary meristem /ˈsɛk(ə)nd(ə)ri ˈmɛrɪstɛm/ [n] មេជាលិកាទី ២ (មេជាលិកាកំប្យូម ដែលស្ថិតនៅរវាងស៊ីឡែម និងផ្លូអែមរបស់ឫស និងដើមរបស់រុក្ខជាតិឌីកូទីលេដូន) មេជាលិកាផ្តល់កំណើតទៅកោសិកាចំហៀង ឬការឡើងកម្រាស់ទី២)

**merry gold** /ˈmɛri gəʊld/ [n] ផ្កាស្បៃរឿង (ឈ្មោះវិទ្យាសាស្ត្រ *Tagetes erecta*)

**mesentery** /ˈmɛs(ə)nt(ə)ri/ [n] ភ្នាសពោះវៀន

**mesh** /mɛʃ/ [n] សំណាញ់

**mesocarp** /ˈmɛsə(ʊ)kɑːp/ [n] មេសូខាប (ស្រទាប់កណ្តាលរបស់ភេរីខាប ជាសាច់របស់ផ្លែប៉ែរ និងខ្ទេប)

**mesocotyl** /ˈmɛsəʊkŏtˈl) [n] ថ្នាំងពន្លក (ថ្នាំងដំបូងបំផុតរបស់ដើមធញ្ញជាតិ នៅពេលដុះចេញពីគ្រាប់)

**mesolecithal** /ˈmɛsəʊles.ɪ.θəl/ [adj] មានស៊ុតលឿងមធ្យម

**mesophyte** /ˈmɛsə(ʊ)fʌɪt/ [n] មេសូភីត

**mesophytic** /ˈmɛsəʊˈfɪtɪk/ [adj] នៃមេសូភីត

**mesosphere** /ˈmɛsə(ʊ)sfɪə/ [n] មេសូស្វ៊ែ, ស្រទាប់កណ្ដាល (ផែនដី)

**mesothorax** /ˌmɛsə(ʊ)ˈθɔːraks/ [n] ទ្រូងកណ្ដាល

***Mesovelia vittigera*** [sci.n] ស្រឹងទឹក

**metabolism** /mɪˈtabəlɪz(ə)m/ [n] មេតាបូលីស, ដំណើរប្រតិកម្មថាមពលជាតិគីមីក្នុងសរីរាង្គ (ការបំបែកអាហារ)

**metal** /ˈmɛt(ə)l/ [n] លោហៈធាតុ

- heavy metal /ˈhɛvi ˈmɛt(ə)l/ [n] លោហៈធ្ងន់
- precious metal /ˈprɛʃəs ˈmɛt(ə)l/ [n] លោហៈមានតម្លៃ

**metamorphism** /mɛtəˈmɔːfɪz(ə)m/ [n] បម្រែកំណកើត

**metamorphosis** /ˌmɛtəˈmɔːfəsɪs/ [n] ការប្រែប្រួលរូបរាង, បម្រែរូប (សត្វ, រុក្ខជាតិ)

- complete metamorphosis /kəmˈpliːt ˌmɛtəˈmɔːfəsɪs/ [n] រូបផ្ដុំពេញលេញ (ពួកសត្វល្អិតដែលមានវដ្តជីវិតរបស់វាប្រែប្រួលពីពង-ដង្កូវ-ដុកដឿ-សត្វពេញវ័យ)

**metaphyte** /ˈmɛtəfʌɪt/ [n] រុក្ខជាតិពហុកោសិកា

***Metarhizium anisopliae*** [sci.n] ពួកជំងឺផ្សិត

***Metarhizium flavoviride*** [sci.n] ពួកជំងឺផ្សិត

**metathorax** /ˈmɛtəˌθɔːraks/ [n] ទ្រូងក្រោយ (សត្វល្អិត)

**metaxenia** /ˈmɛtəˈzēnyə/ [n] ប្រសិទ្ធភាពលម្អង

**Metazoa** /ˌmɛtəˈzəʊə/ [n pl] សត្វពហុកោសិកា

**metazoan** /ˌmɛtəˈzəʊən/ [n] មេតាសូអ៊ែ (សត្វពហុកោសិកា)

**meteorology** /ˌmiːtɪəˈrɒlədʒi/ [n] ឧតុភូតវិទ្យា, លក្ខខណ្ឌអាកាសធាតុ

- agricultural meteorology /ˌmiːtɪəˈrɒlədʒi/ [n] ឧតុភូតវិទ្យាកសិកម្ម
- applied meteorology /əˈplʌɪd ˌmiːtɪəˈrɒlədʒi/ [n] ឧតុភូតវិទ្យាអនុវត្ត
- coastal meteorology /ˈkəʊstl ˌmiːtɪəˈrɒlədʒi/ [n] ឧតុភូតវិទ្យាតំបន់ឆ្នេរ
- dynamic meteorology /dʌɪˈnamɪk ˌmiːtɪəˈrɒlədʒi/ [n] ឧតុភូតវិទ្យាឌីណាមិច, ឧតុភូតវិទ្យាចល័ត
- marine meteorology /məˈriːn ˌmiːtɪəˈrɒlədʒi/ [n] ឧតុភូតវិទ្យាសមុទ្រ
- micrometeorology /ˌmʌɪkrə(ʊ)miːtɪəˈrɒlədʒi/ [n] មីក្រូឧតុភូតវិទ្យា
- satellite meteorology /ˈsatəlʌɪt ˌmiːtɪəˈrɒlədʒi/ [n] ឧតុភូតវិទ្យាផ្កាយរណប
- space meteorology /speɪs ˌmiːtɪəˈrɒlədʒi/ [n] ឧតុភូតវិទ្យាអវកាស
- statistical meteorology /stəˈtɪstɪk(ə)l ˌmiːtɪəˈrɒlədʒi/ [n] ឧតុភូតវិទ្យាសមុទ្រស្ថិតិ
- tropical meteorology /ˈtrɒpɪk(ə)l ˌmiːtɪəˈrɒlədʒi/ [n] ឧតុភូតវិទ្យាត្រូពិច

**meter** /ˈmiːtə/ [n] ម៉ែត្រ

- moisture meter /ˈmɔɪstʃə ˈmiːtə/ [n] ម៉ែត្រវាស់សំណើម, ឧបករណ៍វាស់សំណើម

**metestrus** /miːtɛstrʌs/ [n] ពេលមុនអ៊ីសទ្រុះ

**methane** /ˈmiːθeɪn/ [n] មេតាន

**methanogen** /ˈmɛθənə(ʊ)dʒ(ə)n/ [n] បាក់តេរីមេតាន (បាក់តេរីដែលអាចផលិតមេតានបាន)

**methemoglobin** /mɛtˌhiːməˈgləʊbɪn/ [n] មេតេម៉ូក្លូប៊ីន (អង្គធាតុដែលកកើតឡើងអំពីជាតិក្រហមនៅក្នុងឈាម)

***Methioche vittaticollis*** [sci.n] ចង្រិត

**method** /ˈmɛθəd/ [n] វិធី, របៀប

- basin-check method /ˈbeɪs(ə)n tʃɛk ˈmɛθəd/ [n] ការស្រោចស្រពដោយពន្លិចទឹក និងត្រួតពិនិត្យបាន
- clustering methods /ˈklʌstərɪŋ ˈmɛθədz/ [n pl] វិធីចងជាក្រុម
- contour-check method /ˈkɒntʊə tʃɛk ˈmɛθəd/ [n] ការស្រោចស្រពដោយពន្លិចទឹកដែលអាចគ្រប់គ្រងបានតាមខ្សែរយៈកម្ពស់
- contour-furrow method /ˈkɒntʊə ˈfʌrəʊ ˈmɛθəd/ [n] ការស្រោចស្រពដោយបង្ហៀរទឹកលើដី
- cross-slope furrow method /krɒs sləʊp ˈfʌrəʊ ˈmɛθəd/ [n] ការបញ្ចូលទឹកដោយប្រឡាយកាត់ទទឹងជម្រាល
- drybed method /drʌɪbɛd ˈmɛθəd/ [n] វិធីសាស្ត្រធ្វើថ្នាលសំណាបគោក (ការសាបគ្រាប់ពូជស្ងួតនៅក្នុងថ្នាលគោក ដែលជាធម្មតា គេច្រើនធ្វើថ្នាលគោកនៅតំបន់មានភ្លៀង ឬប្រព័ន្ធស្រោចស្រពដែលមិនមានទឹកគ្រប់គ្រាន់)

- levigation analysis method /lɛvɪˈgeɪʃ(ə)n əˈnalɪsɪs ˈmɛθəd/ [n] របៀបវិភាគដោយបង្ហូរក្នុងចរន្តទឹកនូវវត្ថុធាតុដែលគេបំបែកជាម្សៅរួចជាមុន
- pedigree method /ˈpɛdɪgriː ˈmɛθəd/ [n] ពង្សាវិធី (វិធីសាស្ត្រជម្រើសដែលក្នុងនោះគេអាចមានលទ្ធភាពងាយស្រួលក្នុងការរកពូជពង្សរបស់ឯកត្តៈនីមួយៗ)
- regeneration method /rɪdʒɛnəˈreɪʃn ˈmɛθəd/ [n] វិធីសាស្ត្រកាប់ដើមឈើ (ដើម្បីទទួលបាននូវចំណាត់ថ្នាក់អាយុថ្មី)
- sedimentation analysis method /sɛdɪmɛnˈteɪʃ(ə)n əˈnalɪsɪs ˈmɛθəd/ [n] របៀបធ្វើការវិភាគដោយអវសាទកម្ម (ដោយដាក់ឱ្យរងក្នុងទឹក)
- usage method /ˈjuːsɪdʒ ˈmɛθəd/ [n] វិធីប្រើប្រាស់
- wetbed method /wɛtbɛd ˈmɛθəd/ [n] វិធីសាស្ត្រថ្នាលសំណាបទឹក (ការបណ្ដុះសំណាបលើដី (ថ្នាល) ដែលទទឹកនិងមានភក់)

**methodology** /mɛθəˈdɒlədʒi/ [n] វិធីសាស្ត្រ

**methyl** /ˈmiːθʌɪl/ [n] មេទីល

**metritis** /mɪˈtrʌɪtɪs/ [n] រលាកស្បូន

**mica** /ˈmʌɪkə/ [n] ក្រាមមីកា

- black mica /black ˈmʌɪkə/ [n] ក្រាមមីកាខ្មៅ ឬប៊ីយ៉ូទីត
- iron magnasium mica /ˈʌɪən magnəsɪəm ˈmʌɪkə/ [n] សូមមើលពាក្យ៖ black mica
- potassium mica /pəˈtasɪəm mʌɪkə/ [n] សូមមើលពាក្យ៖ white mica
- white mica /wʌɪt ˈmʌɪkə/ [n] (សទិសន័យ៖ potash, potassium) ក្រាមមីកា (ពណ៌) ស

***Michelia alba*** [sci.n] ផ្កាចំប៉ាស

***Michelia champaca*** [sci.n] ផ្កាចំប៉ាលឿង

***Micraspis crocea*** [sci.n] អណ្ដើកមាស

***Micraspis* sp.** [sci.n] អណ្ដើកមាស

**micro-** /ˈmʌɪkrəʊ/ [prefix] បុព្វបទមានន័យថា តូច

**micro-zonality** /ˈmʌɪkrəʊ ˈzəʊnəlɪti/ [n] សកម្មភាពជិតស្និទ្ធនៃកត្តាផ្សេងៗក្នុងកន្លែងមួយ

**microaerophlie** /ˈmʌɪkrəʊˈɛːrəʊfʌɪl/ [n] ភាវរស់ត្រូវការខ្យល់តិច

**microbe** /ˈmʌɪkrəʊb/ [n] អតិសុខុមប្រាណ, មេរោគ, មីក្រុប

**microbiology** /ˌmʌɪkrə(ʊ)bʌɪˈɒlədʒi/ [n] សូមមើលពាក្យ៖ bacteriology

**microbiota** /ˌmʌɪkrəʊbvɪˈəʊtə/ [n] មីក្រូភាវរស់

**microcephaly** /ˌmʌɪkrəʊˈsɛfəli/ [n] អនិបុណភាពគំនិតពីកំណើត(ភាពមានខ្វោះពីកំណើត ដោយមានក្បាលតូច មិនធម្មតា)

**microclimate** /ˈmʌɪkrə(ʊ)ˌklʌɪmət/ [n] មីក្រូអាកាសធាតុ (អាកាសធាតុនៅមូលដ្ឋានត្រង់ផ្ទៃផែនដី ឬនៅជិតផ្ទៃផែនដី)

**microelement** /ˈmʌɪkrəʊˈɛlɪm(ə)nt/ [n] (សទិសន័យ៖ trace element) មីក្រូធាតុ (ធាតុចិញ្ចឹមដែលរុក្ខជាតិត្រូវការ ឬស្រូបយកបរិមាណតិច ហើយមីក្រូធាតុទាំងនោះមានដូចជា ដែក ម៉ង់កាណែស ប៉រ ម៉ូលីបដែន ទង់ដែង ស័ង្កសី និងក្លរជាដើម)

**microfauna** /ˈmʌɪkrə(ʊ)fɔːnə/ [n] ពពួកសត្វមីក្រូ

**microfilaria** /ˌmʌɪkrəʊfɪˈlɛːrɪə/ [n] មីក្រូភីលែ (មេរោគក្នុងឈាមមានរាងដូចសរសៃអំបោះ)

**microflora** /ˈmʌɪkrə(ʊ)flɔːrə/ [n] ព្រយ, ពពួករុក្ខជាតិមីក្រូ

**microfossil** /ˈmʌɪkrəʊˈfɒs(ə)l/ [n] មីក្រូផូស៊ីល

**micro-hilly** /ˈmʌɪkrəʊ ˈhɪli/ [n] សូមមើលពាក្យ៖ rough

**microlecithal** /ˈmʌɪkrəʊles'əthəl)/ [adj] មានស៊ុតលឿងតិច

**micron** /ˈmʌɪkrɒn/ [n] មីក្រុង (ខ្នាតដែលតូចជាងមីលីម៉ែតមួយពាន់ដង)

***Micronema apogon*** [sci.n] ត្រីកេស

***Micronema bleekeri*** [sci.n] ត្រីកេស

***Micronema micronema*** [sci.n] ត្រីកេស

**micronutrient** /ˈmʌɪkrəʊˈnjuːtrɪənt/ [n] មីក្រូធាតុចិញ្ចឹម, មីក្រូអាហារធាតុ (សារធាតុចិញ្ចឹមបន្ទាប់បន្សំ)

- fortification of food with micronutrients /ˌfɔːtɪfɪˈkeɪʃ(ə)n ɒv fuːd wɪð mʌɪkrə(ʊ)ˈnjuːtrɪənts/ [n] ការបញ្ចូលមីក្រូសារជាតិទៅក្នុងចំណីអាហារ

**micronutrient deficiencies** /mʌɪkrə(ʊ)ˈnjuːtrɪənt dɪˈfɪʃ(ə)nsis/ [n] កង្វះមីក្រូសារជាតិ

**microorganism** /mʌɪkrəʊˈɔːg(ə)nɪz(ə)m/ [n] មីក្រូសរីរាង្គ, មីក្រូសារពាង្គកាយ, អតិសុខុមប្រាណ

**micropalaeonlogy** /ˈmʌɪkrəʊˈpalɪəʊnˈləʊgi/ [n] មីក្រូផូស៊ីលវិទ្យា

***Microphis brachyurus*** [sci.n] សូមមើលពាក្យ៖ short-tailed pipefish

**microphyll** /ˈmʌɪkrə(ʊ)fɪl/ [n] ស្លឹកតូចៗ (ស្លឹកតូចៗគ្មានបាច់សរសៃនាំ ដែលមានចំពោះស្លែមួយចំនួន)

***Microplitis manilae*** [sci.n] ពួកឱម៉ាល់ (បារាសិតលើដង្កូវកាត់ស្លឹក)

**micropore** /ˈmʌɪkrə(ʊ)pɔː/ [n] រន្ធល្អិត

**microporosity** /mʌɪkrə(ʊ)ˌpɔːrəsiti/ [n] (សទិសន័យ៖ infracapillary space) រន្ធឆ្មារល្អិតៗ (រន្ធតូចល្អិតៗក្នុងដី), មីក្រូរន្ធ

**micropropagation** /ˈmʌɪkrə(ʊ)prɒpəgeɪʃn/ [n] ការបណ្ដុះកូនឈើពីជាលិកា (ការបណ្ដុះ (កូន) រុក្ខជាតិចេញពីផ្នែកតូចៗបំផុតរបស់រុក្ខជាតិ ជាលិកា ឬកោសិកាដែលគេបណ្ដុះនៅក្នុងបំពង់សាក ឬ ឧបករណ៍ផ្សេងៗដែលគ្មានមេរោគ ហើយបរិយាកាស និងសារធាតុចិញ្ចឹមនៅក្នុងនោះ ត្រូវបានត្រួតពិនិត្យយ៉ាងដិតដល់បំផុត)

**micropyle** /ˈmʌɪkrə(ʊ)pʌɪl/ [n] មីក្រូភីល, រន្ធមីក្រូភីល (ជាការបើកចំហមួយភ្លែតនៅស្បែកក្រៅរបស់អូវុល ដែលតាមរន្ធនោះ គ្រាប់លម្អង ឬបំពង់លម្អងឆ្លងកាត់ ទៅដល់ថង់អំប្រីយ៉ុង។ នៅលើគ្រាប់ទុំ មីក្រូភៃល ជួនកាលគេអាចឃើញហាក់ដូចជារន្ធមួយនៅលើសម្បក គ្រាប់។ គ្រាប់ដែលផលិតចេញពីអូវុលឈរ មីក្រូភៃលនិងហៃលឹមនៅឆ្ងាយពីគ្នា ផលិតចេញពីអូវុល ផ្កាប់ វានៅជិតគ្នា ផលិតចេញពីអូវុលផ្ដេក វានៅមិនឆ្ងាយ ពីគ្នាប៉ុន្មានទេ។ រ៉ាឌីខលរបស់អំប្រីយ៉ុង ជានិច្ចកាលប្រឈមមុខនឹងមីក្រូភៃល។)

**microscope** /ˈmʌɪkrəskəʊp/ [n] មីក្រូទស្សន៍

**compound microscope** /ˈkɒmpaʊnd ˈmʌɪkrəskəʊp/ [n] អតិសុខុមទស្សន៍សមាស

**microscopic** /mʌɪkrəˈskɒpɪk/ [adj] តូចមើលមិនឃើញ

- dark-field microscopy /dɑːk fiːld mʌɪˈkrɒskəpi/ [n] ការប្រើអតិសុខុមប្រាណទស្សន៍ផ្ទៃងងឹត

**microspore** /ˈmʌɪkrə(ʊ)spɔː/ [n] មីក្រូស្ប៉រ (កោសិកាឈ្មោលដែលផលិតដោយការបំបែកកោសិកាភេទ(មេយ៉ូស) ហើយក្លាយទៅជាគ្រាប់លម្អង។)

**microsporophyll** (mīˈkrəspôrˈəfĭl') [n] មីក្រូស្ប៉ូរ៉ូភីល, ទម្រសរីរាង្គបន្តពូជឈ្មោល (ជាស្លឹកក្លាយមួយដែលទ្រសរីរាង្គបន្តពូជឈ្មោល។ ពួករុក្ខជាតិគ្រាប់ជិត តំណាងដោយកេសរឈ្មោល ចំពោះ រុក្ខជាតិ gymnosperm វិញ តំណាងជាស្រកានៃស្រ្ដបៃឡែឈ្មោល(កោនឈ្មោល)។)

**microsporum** /mʌɪkrəˈspɔːrʌm/ [n] មីក្រូស្ប៉ូរ៉ូម (ពពួកមេរោគជាផ្សិតដូចជាមេស្រែងជាដើម)

**microstructure** /ˈmʌɪkrə(ʊ)ˌstrʌktʃə/ [n] (សទិសន័យ៖ fabric) មីក្រូទម្រង់

- coated microstructure /kəʊtɪd ˈmʌɪkrə(ʊ)ˌstrʌktʃə/ [n] មីក្រូទម្រង់ដោយការស្រោបពីក្រៅនៃគ្រាប់ដី
- elementary microstructure /ɛlɪˈmɛnt(ə)ri ˈmʌɪkrəʊˈstrʌktʃə/ [n] (សទិសន័យ៖ primitive primary fabric) មីក្រូទម្ងន់ដើម, ការប្រមូលផ្ដុំវត្ថុធាតុជាមីក្រូទម្រង់

**microsymbiont** (mʌɪkrəʊˈsɪmbɪˌɒnt) [n] អតិសុខុមប្រាណ (រស់នៅជាមួយរុក្ខជាតិ) មានប្រយោជន៍ (អតិសុខុមប្រាណដែលរស់ជាមួយគ្នាយ៉ាងជិតស្និត(រស់នៅជាមួយគ្នា-symbiosis)ជាមួយរុក្ខជាតិផ្ដល់ជម្រក។ អតិសុខុមប្រាណមានប្រយោជន៍ គឺជាប្រភេទផ្សិតម៉ៃយីរីហ្សា(mycorrhiza) ប្រភេទរីហ្សូប៊ែ(rhizobia) និងប្រ្វេនគីយ៉ា (frankia)។)

***Microvelia douglasi atrolineata*** [sci.n] ស្រឹងទឹក

**microvillus** /ˌmʌɪkrəʊˈvɪləs/ [n] (ពហុវចនៈ៖ microvilli) មីក្រូវីលី

**micturition** /ˌmɪktjʊˈrɪʃ(ə)n/ [n] ការបញ្ចេញទឹកនោម

**midge** /mɪdʒ/ [n] សត្វសុច, មមង់

**midrib** /ˈmɪdrɪb/ [n] ទ្រនុងស្លឹកកណ្ដាលនៃស្លឹក, វ៉ែនស្លឹក (សរសៃវ៉ែនកណ្ដាលធំរបស់ស្លឹក)

**midwife** /ˈmɪdwʌɪf/ [n] ឆ្មប

**migraine** /ˈmiːgreɪn/ [n] ជំងឺប្រកាំង, ការឈឺមួយចំហៀងក្បាល

**migration** /mʌɪˈgreɪʃ(ə)n/ [n] ទេសន្តរប្រវេសន៍, ដំណើរផ្លាស់ទីកន្លែង

**upstream migration** /ˈʌpstriːm mʌɪˈgreɪʃ(ə)n/ [n] សូមមើលពាក្យ៖ cutting back

**mildew** /ˈmɪldjuː/ [n]

១. ជំងឺរុក្ខជាតិបង្កដោយផ្សិត

២. ផ្សិត (ដូចជា Erysiphe ដែលបង្កជំងឺផ្សិតលើរុក្ខជាតិ)

៣. ផ្សិតស្អិតក្នុងដំណាក់មីសេល្យូមលូតលាស់លើស៊ុបស្ត្រាតដោយគ្មានកន្សោមស្ប៉រច្បាស់លាស់ទេ

**milk** /mɪlk/ [n] ទឹកដោះ

- crop milk /krɒp mɪlk/ [n] ទឹកដោះគែ (ទឹកដោះរបស់សត្វព្រាប ដែលបញ្ចេញដោយអេពីតេល្យូមគែ ដើម្បីចិញ្ចឹមកូនក្នុងសម្បុក)
- ultra heat treated milk (UHT) /ˈʌltrə hiːt triːt mɪlk/ [n] ទឹកដោះគោដែលសម្លាប់មេរោគដោយកម្ដៅខ្ពស់
- milk tooth /mɪlk tuːθ/ [n] ធ្មេញទឹកដោះ, ធ្មេញកំណើត, ធ្មេញព្រៃ
- milk vein /mɪlk veɪn/ [n] សរសៃវ៉ែនកន្សោមដោះ (សរសៃនាំទឹកដោះ)

**milkfish** /ˈmɪlkfɪʃ/ [n] ត្រីនួនចាន់ (ឈ្មោះវិទ្យាសាស្ត្រ *Chanos chanos*)

**milky** /ˈmɪlki/ [adj] ដូចទឹកដោះគោ, មិនថ្លា, សៗ

**mill** /mɪl/ [n] រោងកិនស្រូវ, រោងអារឈើ

- hand grain mill /hand greɪn mɪl/ [n] ត្បាល់កិនដៃ (ត្បាល់កិនម្សៅឱ្យស្ងួតដោយដៃ)
- paper mill /ˈpeɪpə mɪl/ [n] រោងចក្រធ្វើក្រដាស
- rice mill /rʌɪs mɪl/ [n] ម៉ាស៊ីនកិនស្រូវ (ម៉ាស៊ីនកិនស្រូវបានជាអង្ករសម្រូប ឬសម្រិត)
- sugar mill /ˈʃʊgə mɪl/ [n] រោងចក្រស្ករអំពៅ (ជាទូទៅផលិត raw sugar ដែលជាស្ករវត្ថុធាតុដើមសម្រាប់នាំចេញ)

**millet** /ˈmɪlɪt/ [n] ស្រូវមីយេ

**milli-** /ˈmɪli/ [prefix] បុព្វបទមានន័យថា ១០០០ ឬ១/១០០០

**milling** /mɪlɪŋ/ [n] ការកិន (ដំណើរការញែកចេញសម្បកពីសាច់គ្រាប់ដែលទទួលបានជាអង្ករសម្រិត)

***Millingtonia hortensis*** [sci.n] ផ្កាអង្គាបុស្ស

**millipede** /ˈmɪlɪpiːd/ [n] សត្វម្រេមព្រះ

**milt** /mɪlt/ [n] ទឹកកាមត្រី

**mimic threadfin** /ˈmɪmɪkˈθrɛdfɪn/ [n] ត្រីព្រាមស (ឈ្មោះវិទ្យាសាស្ត្រ *Polynemus dubius*)

***Mimosa diplotricha*** [sci.n] សូមមើលពាក្យ៖ giant sensitive plant

***Mimosa invisa*** [sci.n] សូមមើលពាក្យ៖ giant sensitive plant

***Mimosa pigra*** [sci.n] សូមមើលពាក្យ៖ giant sensitive tree

***Mimosa pudica*** [sci.n] សូមមើលពាក្យ៖ sensitive plant

**mine** /mʌɪn/ [n] អណ្ដូងរ៉ែ

**mine** /mʌɪn/ [v] ធ្វើអាជីវកម្មរ៉ែ

**mineral** /ˈmɪn(ə)r(ə)l/ [adj] នៃជាតិខនិជ, នៃជាតិរ៉ែ

**mineral** /ˈmɪn(ə)r(ə)l/ [n] សារធាតុរ៉ែ (សារធាតុខនិជដែលជាសមាសធាតុចម្បងរបស់ដី និងជាប្រភពនៃធាតុចិញ្ចឹម)

- energy mineral /ˈɛnədʒi ˈmɪn(ə)r(ə)l/ [n] រ៉ែផ្ដល់ថាមពល
- hard mineral /hɑːd ˈmɪn(ə)r(ə)l/ [n] រ៉ែរឹង
- heavy mineral /ˈhɛvi ˈmɪn(ə)r(ə)l/ [n] ក្រាមធ្ងន់
- metallic mineral /mɪˈtalɪk ˈmɪn(ə)r(ə)l/ [n] រ៉ែលោហៈ
- nonfuel mineral /nɒnfjuː(ə)l ˈmɪn(ə)r(ə)l/ [n] រ៉ែមិនមែនឥន្ធនៈ
- nonmetallic mineral /ˌnɒnmɪˈtalɪk ˈmɪn(ə)r(ə)l/ [n] រ៉ែអលោហៈ
- primary mineral /ˈprʌɪm(ə)ri ˈmɪn(ə)r(ə)l/ [n] ក្រាមដើម
- secondary mineral /ˈsɛk(ə)nd(ə)ri ˈmɪn(ə)r(ə)l/ [n] ក្រាមបន្ទាប់
- strategic mineral /strəˈtiːdʒɪk ˈmɪn(ə)r(ə)l/ [n] រ៉ែយុទ្ធសាស្ត្រ
- weatherable mineral /ˈwɛðəˈreɪb(ə)l ˈmɪn(ə)r(ə)l/ [n] រ៉ែសំណឹក

**mineralization** /ˌmɪn(ə)rəlʌɪˈzeɪʃ(ə)n/ [n] រ៉ែកម្ម, ខនិជកម្ម (ការបែកផុយឬរលួយនៃថ្ម ឬវត្ថុធាតុដើមក្លាយទៅជាខនិជ)

**mineralize** /ˈmɪn(ə)rəlʌɪz/ [v] ធ្វើខនិជកម្ម

**mineralogy** /mɪnəˈralədʒi/ [n] ខនិជវិទ្យា

**minicell** /ˈmɪnisɛl/ [n] បាក់តេរីគ្មានក្រូម៉ូសូម

**minimization** /mɪnɪmʌɪˈzeɪʃ(ə)n/ [n] អប្បបរមាកម្ម

- waste minimization /weɪst mɪnɪmʌɪˈzeɪʃ(ə)n/ [n] អប្បបរមាកម្មសំណល់

**minimum** /ˈmɪnɪməm/ [n] អប្បបរមា

- Minimum Daily Energy Requirement (MDER) /ˈmɪnɪməm ˈdeɪli ˈɛnədʒi rɪˈkwʌɪəm(ə)nt/ [n] តម្រូវការថាមពលប្រចាំថ្ងៃអប្បបរមា

- Minimum Viable Population (MVP) /ˈmɪnɪməm ˈvʌɪəb(ə)l pɒpjʊˈleɪʃ(ə)n/ [n] ក្រុមដែលអាចរស់នៅបានអប្បបរមា (ទំហំនៃក្រុមពូជមួយដែលវាមិនអាចរក្សាស្ថេរភាពកម្រិតរបស់វានៅក្រោមឬកើនឡើងហួសពីនេះ ប៉ុន្តែវានឹង កាន់តែធ្លាក់ចុះ និងបាត់បង់តែម្តង ដោយសារតែឬមួយការបន្តពូជមិនគ្រប់គ្រាន់ ឬមួយហេតុបច្ច័យសេនេទិច នៃការបង្កាត់ក្នុង។)

**mining** /ˈmʌɪnɪŋ/ [n] អាជីវកម្មរ៉ែ, ការងារយករ៉ែ

**minnie root** /ˈmɪni ruːt/ [n] សូមមើលពាក្យ៖ popping pod

**minor** /ˈmʌɪnə/ [adj] តូចជាង, ពៅ

**mint** /mɪnt/ [n] ជីរអង្កាម

**miotic** /mʌɪˈɒtɪk/ [n] ភ្នាក់ងារនៃការបង្រួមកែវភ្នែក

***Mirabilis jalapa*** [sci.n] ផ្កាម៉ោងបួន

**miracidium** /ˌmʌɪrəˈsɪdɪəm/ [n] មីរ៉ាស៊ីឌីអូម

**mire** /mʌɪə/ [n] សូមមើលពាក្យ៖ mud

**miscarriage** /mɪsˈkarɪdʒ/ [n] រលូតកូន

**miscible** /ˈmɪsɪb(ə)l/ [adj] ដែលអាចលាយចូលគ្នាបាន (ចំពោះវត្ថុរាវ)

**mist** /mɪst/ [n] អ័ព្ទ, តំណក់ចំហាយទឹក

- mist irrigation bench /mɪst ˈɪrɪgeɪʃ(ə)n bɛn(t)ʃ/ [n] សូមមើលពាក្យ៖ mist irrigation bed

**misuse** /mɪsˈjuːz/ [n] ការប្រើប្រាស់ខុស

**mite** /mʌɪt/ [n] មេកម

- red mite /rɛd mʌɪt/ [n] កណ្តៀរក្រហម

**mitigate** /ˈmɪtɪgeɪt/ [v] សម្រាល, បន្ធូរ, កាត់បន្ថយ

**mitigation** /mɪtɪˈgeɪʃ(ə)n/ [n] ការសម្រាល, ការបន្ធូរ, ការកាត់បន្ថយ

- acid rain mitigation /ˈasɪd reɪn mɪtɪˈgeɪʃ(ə)n/ [n] ការកាត់បន្ថយភ្លៀងអាស៊ីត
- emission mitigation /ɪˈmɪʃ(ə)n mɪtɪˈgeɪʃ(ə)n/ [n] ការកាត់បន្ថយសារធាតុពុលក្នុងផ្សែង
- flood mitigation /flʌd mɪtɪˈgeɪʃ(ə)n/ [n] វិធានការទប់ស្កាត់ទឹកជំនន់

**mitochondrion** /ˌmʌɪtə(ʊ)ˈkɒndrɪən/ [n] (ពហុវចនៈ៖ mitochondria) មីតូកុងទ្រី

**mitosis** /mʌɪˈtəʊsɪs/ [n] មីតូស (របៀបបង្កើនចំនួនកោសិកាដោយបំបែកខ្លួនជាពីរភាគស្មើគ្នា)

**mitral** /ˈmʌɪtr(ə)l/ [adj] នៃសន្ទះក្នុងបេះដូងខាងឆ្វេង

**mitten** /ˈmɪt(ə)n/ [n] ស្រោមដៃឥតម្រាម

**mix** /mɪks/ [v] លាយ, លាយបញ្ចូលគ្នា, ផ្សំ

**mix** /mɪks/ [n] ល្បាយ, សមាសធាតុ

**mixture** /ˈmɪkstʃə/ [n] ល្បាយ, ភាពលាយ (ភាពលាយច្រើនមុខ ឧ. ពូជលាយដែលពូជផ្សេងចម្រុះលាយជាមួយ)

- heterogeneous mixture /ˌhɛt(ə)rə(ʊ)ˈdʒiːnɪəs ˈmɪkstʃə/ [n] ល្បាយមិនស្មើសាច់
- homogenous mixture /həˈmɒdʒɪnəs ˈmɪkstʃə/ [n] ល្បាយស្មើសាច់
- seed mixture /siːd ˈmɪkstʃə/ [n] ពូជចម្រុះ

**mobilize** /ˈməʊbɪlʌɪz/ [v] ធ្វើយោធូបនីយកម្ម, យកមកប្រើប្រាស់, ធ្វើឱ្យមានចលនា, កៀងគរ (ឧ. ធនធាន)

**mode of production** /məʊd ɒv prəˈdʌkʃ(ə)n/ [n] បែបផែនផលិតកម្ម

**model** /ˈmɒd(ə)l/ [v] ធ្វើជាគំរូ, តាំងបង្ហាញ

**model** /ˈmɒd(ə)l/ [n] គំរូ, តួយ៉ាង, ម៉ូដែល

- agroforestry model /agrəʊˈfɒrɪstri ˈmɒd(ə)l/ [n] ម៉ូឌែលកសិរុក្ខកម្ម

**modelling** /ˈmɒd(ə)lɪŋ/ [n] ប្រព័ន្ធគំរូ, ការបង្កើតម៉ូដែល

**modernisation** /mɒd(ə)nʌɪˈzeɪʃ(ə)n/ [n] ការធ្វើទំនើបកម្ម

**modification** /ˌmɒdɪfɪˈkeɪʃ(ə)n/ [n] កំណាកែប្រែ, ការកែប្រែ (ដំណើរការលក្ខណៈដែលក្នុងនោះឯកត្តៈមួយត្រូវបានប្រែប្រួលដោយឥទ្ធិពលនៃទីកន្លែង)

**modify** /ˈmɒdɪfʌɪ/ [v] កែប្រែ, ប្តូរ

**modulus of elasticity** /ˈmɒdjʊləs ɒv ɛlaˈstɪsɪti/ [n] កម្រិតអាចបត់បែនបានដើម្បីកំណត់ភាពរឹងរបស់ឈើ

**modulus of rupture** /ˈmɒdjʊləs ɒv ˈrʌptʃə/ [n] ការវាស់វែងនូវកម្រិតទម្ងន់ខ្ពស់បំផុតរបស់ឈើ (ការវាស់វែងនូវកម្រិតទម្ងន់ខ្ពស់បំផុត ដែលសរសៃឈើមិនអាចទ្រទ្រង់បានដោយប្រើនូវបន្ទុកដែលធ្វើឱ្យឈើកោង)

**moist** /mɔɪst/ [adj] សើម

**moistening** /ˈmɔɪs(ə)nin/ [n] ការធ្វើឱ្យសើម, ការជ្រើម

**moisture** /ˈmɔɪstʃə/ [n] សំណើម

- air moisture /ɛː ˈmɔɪstʃə/ [n] សំណើមខ្យល់
- available moisture /əˈveɪləb(ə)l ˈwɔːtə/ [n] សូមមើលពាក្យ៖ available water

- residual moisture /rɪˈzɪdjʊəl ˈmɔɪstʃə/ [n] សំណើមសល់
- rock moisture /rɒk ˈmɔɪstʃə/ [n] សំណើមសិលា
- soil moisture /sɔɪl ˈmɔɪstʃə/ [n] សំណើមដី

stagnant moisture /ˈstagnənt ˈmɔɪstʃə/ [n] សំណើមនឹង (មិនហូរ)

- unavailable moisture /ʌnəˈveɪləb(ə)l ˈmɔɪstʃə/ [n] សំណើមដីដែលរុក្ខជាតិមិនអាចប្រើបាន

**molar** /ˈməʊlə/ [n] ថ្គាម, ធ្មេញថ្គាម

**molasses** /məˈlasɪz/ [n] ទឹករង្វ

**mold** /məʊld/ [n, US] (អាចសរសេរបាន៖ mould) ១. ផ្សិតផ្ទរ(ផ្សិតដែលបង្កើតមីសែលៀម (mycelium) ឬម៉ាស់ស្ប៉ រនៅលើផ្ទៃដែលវារស់នៅ ឧ. ផ្សិតប្រភេទ mucor និង penicillium ។ ឧ. លើនំប៉័ង) ផ្សិតផ្ទរ (ពពួកបរាសិតក្រុមផ្សិត), ពពួកផ្សិតសាប្រូភីត (saprophyte) ដែលបង្ហាញយ៉ាងច្បាស់លាស់នូវសរសៃ ឬស្ប៉ររបស់វា ២. (សទិសន័យ៖ mallow soil) ដីធូរ ឬផុស

- animal mold /ˈanɪm(ə)l məʊld/ [n] សូមមើលពាក្យ៖ earthworm mull
- black leaf mold /blak liːf məʊld/ [n] ជំងឺធ្យូងស្លឹក (ជំងឺនេះបង្កដោយផ្សិត Pseudomocercospora uligena ឆ្លងតាមរយៈខ្យល់ក្នុងតំបន់ត្រូពិច តំបន់ក្បែរត្រូពិច។ ស្លឹកសើមយូរ កម្ពស់ខ្ពស់ និងក្តៅល្មមគឺជាលក្ខខណ្ឌសមស្រប សម្រាប់ការរាលដាលនៃជំងឺ។)
- bread mold /brɛd məʊld/ [n] ផ្សិតនំប៉័ង
- brushwood mold /ˈbrʌʃwʊd məʊld/ [n] តែរ៉ូធ្វើអំពីកម្ទេចកំទីស្លឹក ឬមែកឈើផ្សេងៗ
- fine mold /fʌɪn məʊld/ [n] ដីល្បាយល្អិត
- ice mold /ʌɪs məʊld/ [n] ពកកើតពីត្រជាក់ (ទឹកកក)
- leaf mold /liːf məʊld/ [n] ១. ជំងឺខ្នូរស្លឹក (ជំងឺនេះបង្កដោយផ្សិត *Fulvia fulva* ឬ *Cladosporium fulvum* ឆ្លងតាមរយៈខ្យល់ក្នុងតំបន់ត្រូពិច តំបន់ក្បែរត្រូពិច និងពាសពេញពិភពលោកនៅក្នុងផ្ទះកញ្ចក់។) ២. ស្រទាប់ស្លឹកឈើលើដី (ស្រទាប់មមោកកម្មដែលស្លឹកឈើកំពុងតែរលួយ)
- sooty mold /məʊld/ [n] ផ្សិតម្រែងភ្លើង
- vegetable mold /ˈvɛdʒtəb(ə)l məʊld/ [n] សូមមើលពាក្យ៖ compost
- water mold /ˈwɔːtə məʊld/ [n] ផ្សិតទឹក (ប្រភេទសាប្រូភីត ឬផ្សិតបរាសិតដែលរស់នៅក្នុងទឹកសាប ឬក្នុងដីសើម)

**mole** /məʊl/ [n]

១. ប្រជ្រុយដុះ, ស្នាមប្រជ្រុយ

២. ថនិកសត្វម្យ៉ាងស្រដៀងកណ្តុរ

- mole burrow /məʊl ˈbʌrəʊ/ [n] (សទិសន័យ៖ mole tunnel) រូង, រន្ធកណ្តុរ
- mole cricket /məʊl ˈkrɪkɪt/ [n] ខ្ទុលដី, ខ្ទុល (ឈ្មោះវិទ្យាសាស្ត្រ *Gryllotalpa africana*)
- mole tunnel /məʊl ˈtʌn(ə)l/ [n] សូមមើលពាក្យ៖ mole burrow

**molecule** /ˈmɒlɪkjuːl/ [n] ម៉ូលេគុល, អណូ (តូច, តូចឆ្មារ, ល្អិតណាស់)

- amphoteric molecule /ˌamfəˈtɛrɪk ˈmɒlɪkjuːl/ [n] ម៉ូលេគុលអំផូទែ
- carrier molecule /ˈkarɪə ˈmɒlɪkjuːl/ [n] ម៉ូលេគុលដឹកនាំ
- nonpolar molecule /nɒnˈpəʊlə/ [n] ម៉ូលេគុលមិនប៉ូលែ

**mole-hill** /ˈməʊl-hɪl/ [n] គំនរដីដែលសត្វកណ្តុរ "តូប" កកាយចេញមកក្រៅ, អំពាយកណ្តុរ

**mollusc** /ˈmɒləsk/ [n] សូមមើលពាក្យ៖ mollusk

**Mollusca** /ˈmɒləskə/ [n] សូមមើលពាក្យ៖ mollusk

**molluscicide** /ˈmɒləskɪsʌɪd/ [n] ថ្នាំកម្ចាត់ខ្យង, ខ្ចៅ

**mollusk** /ˈmɒləsk/ [n] (សទិសន័យ៖ Mollusca, mollusc) សិប្បីសត្វ

**molt** /məʊlt/ [v] (សរសេរជា moult ក៏បាន) សក ឬជម្រុះ

**molt** /məʊlt/ [n] សំណកភាព (១. ភាពជម្រុះរោម សក់ ស្នែង ស្លាប ឬអ្វីៗដែលនៅក្រៅស្បែក ដើម្បីវិវត្តធំធាត់ ឬប្រែប្រួលដើម្បីសម្របក្នុងការរស់នៅ ២. ចំពោះសត្វល្អិត ជាការសក ឬការដកខ្លួនចេញពីស្រោមនៃស្បែកចាស់ ឬស្បែកកំណើត)

**Molybdenum** /məˈlɪbdənəm/ [n] ម៉ូលីបដែន (និមិត្តសញ្ញាគីមី Mo)

***Momordica charantia*** [sci.n] សូមមើលពាក្យ៖ bitter gourd

**monadelphous** /ˌmɒnəˈdɛlfəs/ [adj] ទងកេសរឈ្មោលភ្ជាប់គ្នានៅលើបំពង់តែមួយ (អំពីភីឡាម៉ង់កញ្ចុំកេសរឈ្មោល)

**mongoose** /ˈmɒŋguːs/ [n] សត្វស្ការ

**monitor** /ˈmɒnɪtə/ [v] ឃ្លាំមើល, អង្កេតតាមដាន

**monitor** /ˈmɒnɪtə/ [n] ឧបករណ៍ត្រួតពិនិត្យ

- atmospheric composition monitor /atməsˈfɛrɪk kɒmpəˈzɪʃ(ə)n ˈmɒnɪtə/ [n] ឧបករណ៍ត្រួតពិនិត្យសមាសភាពបរិយាកាស
- bedside monitor /ˈbɛdsʌɪd ˈmɒnɪtə/ [n] ប្រដាប់ពិនិត្យគយគន់ នៅនឹងគ្រែសំរាន្ត
- environmental noise monitor /ɪnvʌɪrənˈmɛnt(ə)l nɔɪz ˈmɒnɪtə/ [n] ឧបករណ៍កត់ត្រាសូរនៅជុំវិញ
- pollution monitor /pəˈluːʃ(ə)n ˈmɒnɪtə/ [n] ឧបករណ៍ត្រួតពិនិត្យការពុល
- radiation monitor /reɪdɪˈeɪʃ(ə)n ˈmɒnɪtə/ [n] ឧបករណ៍ត្រួតពិនិត្យកម្រិតវិទ្យុសកម្ម

**monitoring** /ˈmɒnɪtərɪŋ/ [n] ការឃ្លាំមើល, ការអង្កេតតាមដាន, ការត្រួតពិនិត្យ

- air monitoring /ɛː ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានគុណភាពខ្យល់
- atmosphere monitoring /ˈatməsfɪə ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានបរិយាកាស
- biological monitoring /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានជីវសាស្ត្រ
- chemical monitoring /ˈkɛmɪk(ə)l ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានគីមី
- emission monitoring /ɪˈmɪʃ(ə)n ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានការបញ្ចេញសំណល់ឧស្ម័ន
- environmental monitoring /ɪnvʌɪrənˈmɛnt(ə)l ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានបរិស្ថាន
- impact monitoring /ˈɪmpakt ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានហេតុប៉ះពាល់បរិស្ថាន
- physical monitoring /ˈfɪzɪk(ə)l ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានរូបសាស្ត្រ
- quality monitoring /ˈkwɒlɪti ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានគុណភាព
- regional monitoring /regional ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានតំបន់
- remote monitoring /rɪˈməʊt ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានពីចម្ងាយ
- satellite monitoring /ˈsatəlʌɪt ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានពីផ្កាយរណប
- space monitoring /speɪs ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានពីអវកាស
- terrestrial monitoring /təˈrɛstrɪəl ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានគុណភាពបរិស្ថានលើគោក
- water quality monitoring /ˈwɔːtə ˈkwɒlɪti ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានគុណភាពទឹក
- weather monitoring /ˈwɛðə ˈmɒnɪtərɪŋ/ [n] ការអង្កេតតាមដានធាតុអាកាស

**monkey** /ˈmʌŋki/ [n] សត្វស្វា

**mono-** /ˈmɒnəʊ/ [prefix] បុព្វបទមានន័យថា ទោល, មួយ

**monocarpic** /ˌmɒnə(ʊ)ˈkɑːpɪk/ [adj] នៃពួករុក្ខជាតិមានផ្កាតែម្តងស្លាប់, ម៉ូណូខាភីច (រុក្ខជាតិមានផ្កាតែម្តងគត់ក្នុងមួយជីវិត)

**monocarpy** /ˌmɒnə(ʊ)ˈkɑːpiː/ [n] ពួករុក្ខជាតិមានផ្កា ឬផ្លែតែម្តងស្លាប់

**monochlamydeous** (ˌmɒnəʊkləˈmɪdɪəs) [n] សូមមើលពាក្យ៖ haplochlamydeous

**monochoria** [n] ប្រាច់ (ឈ្មោះវិទ្យាសាស្ត្រ *Monochoria vaginalis*)

***Monochoria vaginalis*** [sci.n] សូមមើលពាក្យ៖ monochoria

**monoclinous** /mɒnə(ʊ)ˈklʌɪnəs/ [adj] (សទិសន័យ៖ hermaphroditic, bisexual )ទ្វេភេទ, មានភេទពីររួមគ្នា

**monocotyledon** /ˌmɒnə(ʊ)kɒtɪˈliːd(ə)n/ [n] ឯកពីជបត្តរុក្ខជាតិ, មូណូកូទីឡេដូន (ក្រុមរុក្ខជាតិដែលគ្រាប់ដុះពន្លកមានស្លឹកមួយ ឧទាហរណ៍ ស្រូវជាដើម)

**monocropping** /ˌmɒnə(ʊ)krɒppɪŋ/ [n] ការដាំដំណាំទោល (ការដាំដំណាំមួយមុខនៅលើស្រែមួយ ឬចម្ការមួយពីមួយឆ្នាំទៅមួយឆ្នាំ)

**monoculture** /ˈmɒnə(ʊ)kʌltʃə/ [n] ឯកវប្បកម្ម (ក្រុមរុក្ខជាតិដែលគ្រាប់ដុះពន្លកមានស្លឹកមួយ ឧទាហរណ៍ ស្រូវជាដើម)

**monoecious** /məˈniːʃəs/ [adj] ដែលមានផ្កាញី និងឈ្មោលលើដើមតែមួយ, ចំនួនប្រភេទ ឬប្រភេទដែលមានតួនាទីជាផ្កាញី និងឈ្មោលនៅកន្លែងខុសគ្នាលើរុក្ខជាតិតែមួយ

***Monolepta signata*** [sci.n] អណ្តើកមាសស៊ីស្លឹក

**monophagous** /məˈnɒfəgəs/ [adj] ស៊ីអាហារតែមួយប្រភេទ

***Monopterus albus*** [sci.n] សូមមើលពាក្យ៖ swamp eel

***Monotreta cambodgiensis*** [sci.n] ត្រីកំពត

***Monotreta fangi*** [sci.n] ត្រីកំពត

***Monotreta leiurus*** [sci.n] ត្រីកំពត

**monotrichous** [adj] ប្រភេទបាក់តេរីដែលកោសិកាមានកន្ទុយមួយនៅចុងម្ខាង

**monoxide** /məˈnɒksʌɪd/ [n] ម៉ូណូអុកស៊ីត

- carbon monoxide /ˈkɑːb(ə)n məˈnɒksʌɪd/ [n] កាបូនម៉ូណូអុកស៊ីត
- nitrogen monoxide /ˈnʌɪtrədʒ(ə)n məˈnɒksʌɪd/ [n] អាសូតម៉ូណូអុកស៊ីត

**monsoon** /mɒnˈsuːn/ [n] ខ្យល់មូសុង

- summer monsoon /ˈsʌmə mɒnˈsuːn/ [n] មូសុងប្រាំង
- tropical monsoon /ˈtrɒpɪk(ə)l mɒnˈsuːn/ [n] មូសុងត្រូពិច
- winter monsoon /ˈwɪntə mɒnˈsuːn/ [n] មូសុងត្រជាក់

**montane** /ˈmɒnteɪn/ [adj] ដុះលើភ្នំ, រស់នៅលើភ្នំ

**montmorillonite** /ˌmɒntməˈrɪlənʌɪt/ [n] ក្រាមឥដ្ឋខនិជប្រភេទម៉ុងម៉ូរីយូនិត

**moonlight gourami** /ˈmuːnlʌɪt gʊ(ə)ˈrɑːmi/ [n] ត្រីកំភ្លាញភ្លុក (ឈ្មោះវិទ្យាសាស្ត្រ *Trichogaster microlepis*)

**moor** /mɔː/ [n] ពើក ឬមមោកដុលមិនរលួយនៅលើដី

- climatic moor /klʌɪˈmatɪk mɔː/ [n] កន្លែងកើតពើកស្ថិតលើជម្រាល
- high moor /hʌɪmɔː/ [n] ដីជាំទឹកទំនាបបឹងក្នុងតំបន់ខ្ពស់, កន្លែងកើតពើក ឬតួបនៅលើទួល
- reed peat moor /riːd piːt mɔː/ [n] សូមមើលពាក្យ៖ fragmite fen
- reed peat moor /riːd piːt mɔː/ [n] ពើកកើតពីដើមត្រែង

**mor** /mɔː/ [n] មមោកដុល ឬម័រ

- carex mor [n] មមោកអាស៊ីតនៃរុក្ខជាតិស្មៅ "ការីក", មមោកប្រភេទម័រ
- coprogenous mor /ˈkɒprəʊ dʒɪnəs mɔː/ [n] មមោកដុល ឬម័រ ដែលជាអាចម៍សត្វ
- fibrous mor /ˈfʌɪbrəs mɔː/ [n] មមោកដុលជាសរសៃៗ
- granular mor /ˈgranjʊlə mɔː/ [n] មមោកដុល ឬម័រជាគ្រាប់ៗ
- greasy mor /ˈgriːsi mɔː/ [n] មមោកដុល ឬម័ររលើបដូចខ្លាញ់
- laminated mor /ˈlamɪneɪtid mɔː/ [n] មមោកដុលជាស្រទាប់ៗ
- lichen mor /ˈlʌɪk(ə)n mɔː/ [n] មមោកដុលប្រភេទលីកែន, មមោកប្រភេទម័រអាស៊ីត
- lignified mor /ˈlɪgnɪfʌɪd mɔː/ [n] មមោកដុល ឬម័រដែលមានសារធាតុលីញីនច្រើន
- moss mor /mɒs mɔː/ [n] (សទិសន័យ៖ sphagnum mor) មមោកដុល, ម័រប្រភេទស្លែ
- peaty mor /ˈpiːti mɔː/ [n] មមោកដុល, ម័រដែលជាពើក, ម័រដែលជាតួប
- rendzina mor /rɛn(d)ˈziːnə mɔː/ [n] សូមមើលពាក្យ៖ raw humus rendzina
- sog mor /ˈsɒg mɔː/ [n] (សូមមើលពាក្យ៖ soggy mor) មមោកដុល ឬម័រដែលមានទឹកជោគជាំ
- soggy mor /ˈsɒgi mɔː/ [n] សទិសន័យ៖ sog mor
- sphagnum mor /ˈsfagnəm mɔː/ [n] សូមមើលពាក្យ៖ moss mor

**moraine** /məˈreɪn/ [n] ដុំថ្ម ឬកម្ទេចថ្មដែលចេញពីគំនរទឹកកករលាយ

**morass** /məˈras/ [n] សូមមើលពាក្យ៖ bog

**morbid** /ˈmɔːbɪd/ [adj] ដែលមានជំងឺ

**morbidity** /mɔːˈbɪdɪti/ [n] ភាពឈឺ

- morbidity rate /mɔːˈbɪdɪti reɪt/ [n] អត្រាឈឺ (ចំនួនប្រជាជនជៅក្នុងចំណោមប្រជាជនមួយក្រុម ដែលកើតមានជំងឺនៅពេលកំណត់មួយ (ឧទាហរណ៍ ២០ ០០០ ករណីកើតមានជំងឺផ្តាសាយ នៅក្នុងចំណោមប្រជាជន ១០០ ០០០នាក់ ស្មើនឹងអត្រាឈឺ ២០%)

**moribund** /ˈmɒrɪbʌnd/ [adj] ជិតស្លាប់

**moringa** \məˈriŋgə\ [n] ម្រុំ (ឈ្មោះវិទ្យាសាស្ត្រ *Moringa oleifera*)

***Moringa oleifera*** [sci.n] សូមមើលពាក្យ៖ moringa

**morphology** /mɔːˈfɒlədʒi/ [n] រូបសាស្ត្រ, សណ្ឋានវិទ្យា, រាងវិទ្យា, រូបសាស្ត្រវិទ្យា (ផ្នែកមួយនៃជីវវិទ្យាដែលនិយាយពីលក្ខណៈរូបសាស្ត្រទូទៅ និងរចនាសម្ពន្ធរបស់រុក្ខជាតិ ឬសត្វ)

- drainage basin morphology /ˈdreɪnɪdʒ ˈbeɪs(ə)n mɔːˈfɒlədʒi/ [n] សណ្ឋានអាងរងទឹកភ្លៀង
- river morphology /ˈrɪvə mɔːˈfɒlədʒi/ [n] សណ្ឋានទន្លេ
- seed morphology /siːd mɔːˈfɒlədʒi/ [n] រូបសាស្ត្រគ្រាប់
- soil morphology /sɔɪl mɔːˈfɒlədʒi/ [n] លក្ខណៈរូបរបស់ដី ដែលមានដូចជាទម្រង់ វាយនភាពជាដើម
- surface morphology /ˈsəːfɪs mɔːˈfɒlədʒi/ [n] សណ្ឋានផ្ទៃ

**morphotypic** /mɔː' fəʊˈtipɪk/ [adj] ម័រហ្វូទីពិច (ប្រភេទចំណែកថ្នាក់ដែលផ្អែកលើលក្ខណៈរូបរាងខាងក្រៅទាំងស្រុង)

**overpopulation** /əʊvəpɒpjʊˈleɪʃ(ə)n/ [n] ប្រជាជនលើសចំណុះ, បណ្ដាភារៈលើសចំណុះ

**overrun** /əʊvəˈrʌn/ [v] លឿនហួសកម្រិតកំណត់

**overstock** /əʊvəˈstɒk/ [v] ដាក់ត្រី ឬសត្វចិញ្ចឹមលើសចំណុះ

**overstretched** /əʊvəˈstrɛtʃt/ [adj] ដែលធំ ឬរីកជ្រុល

**overturn** /əʊvəˈtəːn/ [v] បត់ហួសកម្រិតកំណត់

**overwash** /ˈəʊvəwɒʃ/ [n] (សទិសន័យ៖ deluvial soil) ដីល្បាប់ (ដែលនាំមកដោយចរន្តទឹក)

**oviduct** /ˈəʊvɪdʌkt/ [n] បំពង់អូវុល (ចំពោះសត្វ)

**oviposit** /ˌəʊvɪˈpɒzɪt/ [v] ជម្រុះ, ទម្លាក់ពង (ការបញ្ចេញ ឬទម្លាក់ពងរបស់សត្វល្អិតទៅក្នុង ឬលើអ្វីមួយ)

**ovipositor** /ˌəʊvɪˈpɒzɪtə/ [n] ទម្រពង (ផ្នែកមួយនៃសរីរាង្គរបស់សត្វល្អិតសម្រាប់ទ្រស៊ុតនាពេលវាពង)

**ovoid** /ˈəʊvɔɪd/ [adj] រាងដូចស៊ុត, រាងមូលទ្រវែង

**ovulate** /ˈɒvjʊleɪt/ [v] បញ្ចេញបុប្ផាណ្ឌ, ចេញអូវុល, បញ្ចេញពងទុំ, បង្កកំណើត

**ovulation** /ɒvjʊˈleɪʃ(ə)n/ [n] ការបញ្ចេញអូវុល

**ovule** /ˈɒvjuːl/ [n] បុប្ផាណករ, អូវុល, ពង, កោសិកាញីនៅក្នុងកោសិកា

- anatropous ovule /əˈnætrəpəs ˈɒvjuːl/ [n] អូវុលផ្កាប់(ជាទិសអូវុលមួយដែលអូវុលនោះ បញ្ច្រាសនៅនឹងសណ្ដង់អូវុល (funiculus) រន្ធមីក្រូភៃល (micropyle) ស្ថិតនៅស្មើនឹងគល់របស់សណ្ដង់អូវុល)

**ovum** /ˈəʊvəm/ [n] (សូមមើលពាក្យ៖ egg cell) ពងទឹកកាមស្ត្រី, បប្ផាណ្ឌ

**ox** /ɒks/ [n] សូមមើលពាក្យ៖ bullock

**oxidability** /ˈɒksʌɪdəˈbɪlɪti/ [n] ភាពចាប់បានអុកស៊ីសែន

**oxidant** /ˈɒksɪd(ə)nt/ [n] អុកស៊ីតករ

**oxidation** /ɒksɪˈdeɪʃ(ə)n/ [n] អុកស៊ីតកម្ម, ចំហេះ, ការលាយជាមួយអុកស៊ីសែន

- air oxidation /ɛː ɒksɪˈdeɪʃ(ə)n/ [n] អុកស៊ីតកម្មដោយអុកស៊ីសែនក្នុងខ្យល់
- alkaline oxidation /ˈalkəlʌɪn ɒksɪˈdeɪʃ(ə)n/ [n] អុកស៊ីតកម្មមជ្ឈដ្ឋានបាស
- biochemical oxidation /ˌbʌɪəʊˈkɛmɪk(ə)l ɒksɪˈdeɪʃ(ə)n/ [n] អុកស៊ីតកម្មក្នុងគីមីជីវៈ
- biological oxidation /bʌɪə(ʊ)ˈlɒdʒɪk(ə)l ɒksɪˈdeɪʃ(ə)n/ [n] អុកស៊ីតកម្មជីវៈ
- dry oxidation /drʌɪ ɒksɪˈdeɪʃ(ə)n/ [n] អុកស៊ីតកម្មស្ងួត
- high-temperature oxidation /hʌɪ ˈtɛmp(ə)rətʃə ɒksɪˈdeɪʃ(ə)n/ [n] អុកស៊ីតកម្មនៅសីតុណ្ហភាពខ្ពស់
- neutral oxidation /ˈnjuːtr(ə)l ɒksɪˈdeɪʃ(ə)n/ [n] អុកស៊ីតកម្មមជ្ឈដ្ឋានណឺត
- slow oxidation /sləʊ ɒksɪˈdeɪʃ(ə)n/ [n] ការឆេះយឺតៗ, អុកស៊ីតកម្មយឺតៗ
- wet air oxidation /wɛt ɛː ɒksɪˈdeɪʃ(ə)n/ [n] អុកស៊ីតកម្មក្នុងខ្យល់សើម

**oxide** /ˈɒksʌɪd/ [n] អុកស៊ីត

- acid oxide /ˈasɪdˈɒksʌɪd/ [n] អុកស៊ីតអាស៊ីត
- hydrated oxide /ˈhʌɪdreɪtɪd ˈɒksʌɪd/ [n] អ៊ីដ្រុកស៊ីត
- nitric oxide /ˈnʌɪtrɪk ˈɒksʌɪd/ [n] អាសូតម៉ូណូអុកស៊ីត
- nitrogen oxide /ˈnʌɪtrədʒ(ə)n ˈɒksʌɪd/ [n] អាសូតអុកស៊ីត

- nitrous oxide /ˈnʌɪtrəs ˈɒksʌɪd/ [n] ឱអាសូតម៉ូណូអុកស៊ីត

**oxidise** /ˈɒksɪdʌɪz/ [v] ធ្វើអុកស៊ីតកម្ម

**oxy-** /ˈɒksɪ/ [prefix] បុព្វបទមានន័យថា អុកស៊ីសែន

***Oxyeleotris marmorata*** [sci.n] សូមមើលពាក្យ៖ marbled sleeper

***Oxygaster anomalura*** [sci.n] ត្រីស្លឹកឫស្សី

***Oxygaster pointoni*** [sci.n] ត្រីស្លឹកឫស្សី

**oxygen** /ˈɒksɪdʒ(ə)n/ [n] អុកស៊ីសែន (និមិត្តសញ្ញាគីមី )

- dissolved oxygen /dɪˈzɒlvd ˈɒksɪdʒ(ə)n/ [n] អុកស៊ីសែនរលាយ

**oxygenation** /ɒksɪdʒəˈneɪʃ(ə)n/ [n] អុកស៊ីសែនកម្ម

**oxylophyte** /ˈɒksilə(ʊ)fʌɪt/ [n] សូមមើលពាក្យ៖ calcifuge

***Oxyopes javanus*** [sci.n] ពីងពាង

***Oxyopes lineatipes*** [sci.n] ពីងពាង

**oyster** /ˈɔɪstə/ [n] ងាវសមុទ្រ (អយស្ទ័រ)

- oyster oil /ˈɔɪstə ɔɪl/ [n] ប្រេងគ្រំ

**ozonation** /ˈəʊzəʊˈneɪʃ(ə)n/ [n] អូសូនកម្ម

**ozone** /ˈəʊzəʊn/ [n] អូសូន

**ozonosphere** /əʊˈzəʊnəsfɪə/ [n] មណ្ឌលអូសូន

**P**

**pacemaker** /ˈpeɪsmeɪkə/ [n] ប្រដាប់ជំនួយបេះដូងឱ្យដើរធម្មតា

***Pachyrhizus erosus*** [sci.n] សូមមើលពាក្យ៖ yam bean

**pack** /pak/ [v] វេចខ្ចប់

**package** /ˈpakɪdʒ/ [n] កញ្ចប់

**packing** /ˈpakɪŋ/ [n] ការធ្វើឱ្យហាប់ ឬណែន (ឧ. ដី)

**paddock** /ˈpadək/ [n] វាលស្មៅមានរបងព័ទ្ធជុំវិញ (សម្រាប់ដាក់សេះ)

**paddy** /ˈpadi/ [n]

១. (សទិសន័យ៖ paddy field) វាលស្រែ

២. (សទិសន័យ៖ paddy rice) ស្រូវ

**pain** /peɪn/ [v] ឈឺ, ចុក

**pain** /peɪn/ [n] ការឈឺចាប់

**palaeo-** /ˈpalɪəʊ/ [prefix] បុព្វបទមានន័យថា បុរាណ

**palaeoanthropology** /ˌpalɪəʊanθrəˈpɒlədʒi/ [n] បុរាណនរវិទ្យា

**palaeobioclimatology** /ˈpalɪəʊˌbīōˌklīməˈtäləjē/ [n] បុរាណជីវអាកាសធាតុវិទ្យា

**palaeobiogeography** /ˈpalɪəʊˌbʌɪəʊdʒɪˈɒgrəfi/ [n] បុរាណជីវភូមិវិទ្យា

**palaeobiology** /ˌpalɪəʊbʌɪˈɒlədʒi/ [n] បុរាណជីវវិទ្យា

**palaeobotany** /ˌpalɪəʊˈbɒtəni/ [n] បុរាណរុក្ខវិទ្យា

**Palaeocene** /ˈpalɪə(ʊ)siːn/ [n] ប៉ាឡេអូសែន

**palaeoclimate** /ˈpalɪəʊˌklʌɪmət/ [n] បុរាណអាកាសធាតុ

**palaeoclimatology** /ˈpalɪəʊklʌɪməˈtɒlədʒi/ [n] បុរាណអាកាសធាតុវិទ្យា

**palaeoecology** /ˌpalɪəʊɪˈkɒlədʒi/ [n] បុរាណអេកូឡូស៊ី

**palaeogeography** /ˌpalɪəʊdʒɪˈɒgrəfi/ [n] បុរាណភូមិវិទ្យា

**palaeontology** /ˌpalɪɒnˈtɒlədʒi/ [n] ផូស៊ីលវិទ្យា

**palate** /ˈpalət/ [n] ក្រអូម (មាត់), ផ្នែកខាងលើនៃមាត់, កន្លើង, ពិតានមាត់, តាលុ

**pale** /peɪl/ [adj] ស្លាំង, ស្លេកស្លាំង, ខ្វះឈាម

**palea** /ˈpeɪlɪə/ [n] សម្បកតូច (សម្បកគ្រាប់ស្រូវ (អង្កាម ផ្នែកសម្បកតូច))

**turning pale** /ˈtəːnɪŋ peɪl/ [n] សាកពណ៌ (ឡើងស្លាំង)

**Palladium** /pəˈleɪdɪəm/ [n] ប៉ាឡាដ្យូម (និមិត្តសញ្ញាគីមី Pd)

**palliative** /ˈpalɪətɪv/ [adj] សម្រន់

**pallor** /ˈpalə/ [n] សម្បុរស្លាំង

**palm** /pɑːm/ តាលព្រឹក្ស (ពពួកត្នោត ដូង)

- areca palm /ˈarɪkə pɑːm/ សូមមើលពាក្យ៖ batel nut palm
- batel (nut) palm /ˈbat tɛl nʌt pɑːm/ [n] ដើមស្លា
- betel nut palm /ˈbiːt(ə)l nʌt pɑːm/ [n] ស្លា (ដើម) (ឈ្មោះវិទ្យាសាស្ត្រ *Areca catechu*)
- cabbage palm /ˈkabɪdʒ pɑːm/ ដើមដូងអាមេរិកាំង
- coconut palm /ˈkəʊkənʌt pɑːm/ ដើមដូង
- date palm /deɪt pɑːm/ [n] សូមមើលពាក្យ៖ date
- oil palm /ɔɪl pɑːm/ [n] ដូងប្រេង (ឈ្មោះវិទ្យាសាស្ត្រ *Elaeis guineensis*)
- sago palm /ˈseɪgəʊ/ [n] ត្នោតសាហ្គោ, ត្នោតតឿជប៉ុន
- sugar palm /ˈʃʊgə pɑːm/ [n] សូមមើលពាក្យ៖ Asian palmyra palm

**palmate** /ˈpalmeɪt/ [adj] រាងកង្ហារ, រាងដូចជាបាតដៃ (អំពីស្លឹក)

**palmatifid** /pălmāˈtəfĭd/ [adj] ទម្រង់គែមស្លឹកទម្រង់ម្រាមដៃ

**palpate** /palˈpeɪt/ [v] ស្ទាបច្របាច់

**palpitation** /palpɪˈteɪʃ(ə)n/ [n] ដំណើរបេះដូងដើរញាប់ពេក

**palsy** /ˈpɔːlzi/ [n] រោគស្លាប់អវយវៈ, លក្ខណៈនៃការញ័រដៃជើង ឬខ្លួនប្រាណទប់មិនបាន

**pan-** /pan/ [prefix] ជាបុព្វបទមានន័យថា ទាំងអស់

**pan** /ˈbrɪt(ə)l pan/ [n] ស្រទាប់

- brittle pan /ˈbrɪt(ə)l pan/ [n] ស្រទាប់រឹងបានពីការពុកផុយនៃដី
- clay pan /kleɪ pan/ [n] ស្រទាប់ឥដ្ឋរឹង (នៅក្នុងដី)
- fragi pan /pan/ [n] ស្រទាប់រឹងបានពីការពុកផុយនៃដី
- hard pan /hɑːd pan/ [n] (សទិសន័យ៖ soil barrier) ស្រទាប់បាតនង្គ័ល (ស្រទាប់ដីរឹងដែលនៅចន្លោះស្រទាប់ភ្ជួរ និងស្រទាប់ក្រោម)
- humic iron pan /ˈhjuːmɪk ˈʌɪən pan/ [n] ស្រទាប់រឹង "អាល្យោស" ដែលមានមមោក និងដែក (ឧ. ក្នុងប៉ុតសូល)

- iron pan /ˈʌɪən pan/ [n] (សទិសន័យ៖ wrought iron) ស្រទាប់ ឬសន្ទះរឹងថ្មបាយក្រៀមផ្សំដោយធាតុដែក (ក្នុងដី)
- iron-humus pan /ˈʌɪən ˈhjuːməs pan/ [n] ស្រទាប់កកដោយសារធាតុដែក និងមមោក
- non-indurated pan /nɒnˈɪndjʊreɪtid pan/ [n] ស្រទាប់រឹងបានពីការពុកផុយនៃដី
- salt pan /sɔːlt pan/ [n] ស្រទាប់អំបិលក្រាំងហើយរឹង, ផ្ទាំងរឹងនៃអំបិលដែលកកក្នុងតំបន់ទំនាប (បឹង)
- silica pan /ˈsɪlɪkə pan/ [n] ស្រទាប់រឹងដោយស៊ីលីស, ស្រទាប់ទៅដោយសារធាតុស៊ីលីស
- silt pan /sɪlt pan/ [n] ស្រទាប់រឹងក្នុងដីដែលសម្បូរទៅដោយធាតុស៊ីលីស
- traffic pan /ˈtrafɪk pan/ [n] ស្រទាប់រឹង (ស្រទាប់រឹងនៃដីដែលកើតដោយសារចរាចរ)

**pancreas** /ˈpaŋkrɪəs/ [n] លំពែង

**pancreatitis** /ˌpaŋkrɪəˈtʌɪtɪs/ [n] ជំងឺរលាកលំពែង

***Pangasianodon gigas*** [sci.n] សូមមើលពាក្យ៖ Mekong giant catfish

***Pangasianodon hypophthalmus*** [sci.n] សូមមើលពាក្យ៖ iridescent shark-catfish

***Pangasius bocouri*** [sci.n] ត្រីប្រាខ្លាំ

***Pangasius conchophilus*** [sci.n] ត្រីកែ, ត្រីប្រាកែ

***Pangasius djambal*** [sci.n] ត្រីប្រា

***Pangasius krempfi*** [sci.n] ត្រីប្រា, ត្រីបុងឡាវ

***Pangasius larnaudiei*** [sci.n] ត្រីពោ

***Pangasius macronema*** [sci.n] ត្រីឈ្វាត

***Pangasius micronema*** [sci.n] ត្រីពោ

***Pangasius pleurotaenia*** [sci.n] ត្រីឈ្វាត

***Pangasius polyuranodon*** [sci.n] ត្រីឈ្វាត

***Pangasius sanitwongsei*** [sci.n] ត្រីពោព្រុយ

***Pangasius siamensis*** [sci.n] ត្រីឈ្វាត

***Pangasius sutchi*** [sci.n] ត្រីប្រា

**panhysterectomy** [n] ការវះកាត់យកស្បូនទាំងអស់

**panic** /ˈpanɪk/ [n] ការស្លន់ស្លោ

**panicle** /ˈpanɪk(ə)l/ [n] ផ្កាចង្កោមៗ, កញ្ចុំផ្កា, កញ្ចុំមែកផ្ទុំផ្កា, ក្បាលគ្រាប់ពូជ, កួរស្រូវ (ផ្នែកចុងនៃដើមដែលផ្ទុកទៅដោយផ្កា)

**panicle pulvinus** /ˈpanɪk(ə)l pʌlˈvʌɪnəs/ [n] កំពកស្មែងកួរ (ផ្នែកប៉ោងរលោងត្រង់គល់បែកពីស្មែងទីមួយ)

***Panicum maximum*** [sci.n] សូមមើលពាក្យ៖ Guinea grass

***Panicum miliaceum*** [sci.n] សូមមើលពាក្យ៖ millet

***Panicum repens*** [sci.n] សូមមើលពាក្យ៖ torpedo grass

**panleukopenia** /panˌluːkə(ʊ)ˈpiːnɪə/ [n] ជំងឺរលាកក្រពះ និងពោះវៀនឆ្មា

**panmixia** /panˈmɪksɪə/ [n] ការបង្កាត់ដោយចៃដន្យ (ការកើតឡើងនៃការបន្តពូជតាមភេទក្នុងចំណោមសមាជិកឯកត្តៈរបស់ក្រុមពូជមួយដែលក្នុងនោះភវនីយភាព (probability) នៃការបង្កាត់គ្នារបស់ឯកត្តៈ ២ ណាមួយគឺស្មើគ្នា)

***Panstenon* nr. *collaris*** [sci.n] ពួកឪម៉ាល់ (សត្វរំពាលើពងមមាច)

**pant** /pant/ [v] ភ័យដង្ហក់

**pantropical spotted dolphin** [n] ផ្សោតអុច (ឈ្មោះវិទ្យាសាស្ត្រ *Stenella attenuata*)

**pap smear** /pap smɪə/ [n] ការពិនិត្យរកមហារីកស្បូន

**Papaver somniferum** [sci.n] សូមមើលពាក្យ៖ opium poppy

**papaya** /pəˈpʌɪə/ [n] (សទិសន័យ៖ pawpaw) ល្ហុង (ឈ្មោះវិទ្យាសាស្ត្រ Carica papaya)

**paper** /ˈpeɪpə/ [n] ក្រដាស

- recycled paper /riːˈsʌɪk(ə)ld ˈpeɪpə/ [n] ក្រដាសកែច្នៃ, ក្រដាសប្រើប្រាស់ឡើងបាន

**paprika** /ˈpaprɪkə/ [n] ម្ទេសប៉ាព្រិកា

**para-** /ˈparə/ [prefix] បុព្វបទមានន័យថា លើស

**abdominal paracentesis** /abˈdɒmɪn(ə) l ˌparəsɛnˈtiːsɪs/ [n] ការបូមទឹកចេញពីពោះ

**paracentesis** /ˌparəsɛnˈtiːsɪs/ [n] ការចាក់ម្ជុលទៅក្នុងខ្លួនបូមទឹកចេញ

***Parachela maculicauda*** [sci.n] ត្រីជន្ទាសភ្លុក

***Parachela oxygastroides*** [sci.n] ត្រីជន្ទាសភ្លុក

***Parachela siamens*** [sci.n] ត្រីជន្ទាសភ្លុក

***Parachela williaminae*** [sci.n] ត្រីជន្ទាសភ្លុក

**paraffin** /ˈparəfɪn/ [n] សូមមើលពាក្យ៖ kerosene

***Paralaubuca barron*** [sci.n] ត្រីស្លឹកឫស្សី

***Paralaubuca harmandi*** [sci.n] ត្រីស្លឹកឫស្សី

***Paralaubuca typus*** [sci.n] ត្រីស្លឹកឫស្សី

**paralysis** /pəˈralɪsɪs/ [n] ប៉ារ៉ាលីស៊ី (មិនមានសមត្ថភាពក្នុងការផ្លាស់ទីជាដើម), ការខ្វិន, ការគ្មានចលនា, ពិការ

***Parambassis apogonoides*** [sci.n] សូមមើលពាក្យ៖ iridescent glassy perchlet

***Parambassis wolffi*** [sci.n] សូមមើលពាក្យ៖ duskyfin glassy perchlet

**parameter** /pəˈramɪtə/ [n] ប៉ារ៉ាម៉ែត្រ (តម្លៃមួយអាចប្រែប្រួល ឬថេរ ដែលប្រើដើម្បីរៀបរាប់ពីលក្ខខណ្ឌមួយតាមគណិតវិទ្យា)

**paraphasia** /ˌparəˈfeɪzɪə/ [n] ដំណើរមិនប្រក្រតីនៃអំណាចប្រើពាក្យឬសំដី

**paraphimosis** /ˈparəfʌɪˈməʊsɪs/ [n] ភាពតឿៀតចុងបង្ហួរ (ប្រដាប់បន្តពូជឈ្មោល)

**paraplegic** /ˌparəˈpliːdʒə/ [n] ការខ្វិនមួយកំណាត់ខ្លួនចុះក្រោម

**parasite** /ˈparəsʌɪt/ [n] បារាសិត (សត្វល្អិតដែលរស់នៅក្នុង ឬនៅលើសារពាង្គកាយរស់ គឺការខ្ចី ឬពឹងពាក់អ្នកដទៃដើម្បីស្នាក់អាស្រ័យ និងបង្កើតកូនចៅ ហើយស្រូបយកសារធាតុចិញ្ចឹមសរីរាង្គខ្លះៗ ឬទាំងអស់ពីជម្រកដែលវាស្នាក់នៅ។ ឧ. សត្វល្អិតមានប្រយោជន៍ពពួកបារាសិត ជាក្រុមឱម៉ាល់ស្រាំង ឃ្មុំជាដើម ដែលបំផ្លាញដង្កូវ ឬសត្វចង្រៃដោយធ្វើការពងដាក់ក្នុងខ្លួនសត្វទាំងនោះ។ លុះកូនកើតមក ក៏ជញ្ជក់ ឬស៊ីសុះសារធាតុក្នុងខ្លួនដង្កូវនោះតែម្តង។)

- brood parasite /bruːd ˈparəsʌɪt/ [n] បារាសិតក្រាបពង (សត្វទាំងឡាយណាដែលដាក់ពង នៅក្នុងសម្បុករបស់សត្វដទៃ ជាប្រភេទសត្វដូចគ្នា ឬប្រភេទខុសគ្នា បន្ទាប់មកធ្វើការចិញ្ចឹមកូនក្រោយពីញាស់)
- external parasite /ɪkˈstəːn(ə)l ˈparəsʌɪt/ [n] បារាសិតខាងក្រៅ
- obligate intracellular parasites /ˈɒblɪgeɪt ˌɪntrəˈsɛljʊlə ˈparəsʌɪtz/ [n pl] បារាសិតក្នុងកោសិកាចាំបាច់ (វីរុសដែលអាចមានសកម្មភាពតែនៅក្នុងកោសិកាមានជីវិត)

**parasitism** /ˈparəsɪtɪz(ə)m/ [n] បារាសិតភាព, លក្ខណៈបារាសិត

**parasitoid** /ˈparəsɪtɔɪd/ [n] បារាសិតតយ (សត្វល្អិតដែលដង្កូវរបស់វាជាបារាសិតនៃសត្វល្អិតផ្សេងទៀត)

**parasitology** /ˌparəsɪˈtɒlədʒi/ [n] បារាសិតវិទ្យា

**paratuberculosis** /ˈparə tjʊˌbəːkjʊˈləʊsɪs/ [n] (សទិសន័យ៖ Johne's disease) ជំងឺសណ្ឋានរបេង, ជំងឺប៉ារ៉ាទូប៊ែគូលូស

**parboil** /ˈpɑːbɔɪl/ [v] ស្ងោរឆ្អិនល្មម

**parboiling** /ˈpɑːbɔɪlɪŋ/ [n] ចំហុយកម្ម (ដំណើរការនៃការត្រាំ និងចំហុយអង្ករសម្រូប ដោយអនុលោមតាមការសម្ងួតជាបន្តបន្ទាប់ ដើម្បីទទួលបានបាយពាក់កណ្តាលសម្រាប់គោលបំណងនៃការស្តុកទុកវាក្នុងរយៈពេលយូរ)

**pare** /pɛː/ [v] ចិតសម្បកចេញ

**paregoric** /ˌparɪˈgɒrɪk/ [n] បង្អន់ការចុកពោះ

**parenchyma** /pəˈrɛŋkɪmə/ [n] កោសិកាផារ៉ែនឃីម៉ា, កោសិកាប៉ារ៉ង់ស៊ីម (កោសិការស់តែមិនបំបែក (ដុះ) ទេ។ នៅក្នុងសំបកគ្រាប់ស្រទាប់មួយនៃប៉ារ៉ង់ស៊ីម ជាញឹយៗនៅជាន់ខាងក្រោមនៃកោសិកាសំបកគ្រាប់រឹង។)

- xylem parenchyma /ˈzʌɪləm pəˈrɛŋkɪmə/ [n] ប៉ារ៉ង់ស៊ីមស៊ីឡែម (កោសិការុក្ខជាតិដែលមានលក្ខណៈខ្លីមានលីញីន និងជាទូទៅមានភ្នាសស្តើង។ វានៅព័ទ្ធជុំវិញសារជាតុដឹកនាំ និងជួយដោយផ្ទាល់ ឬដោយប្រយោលនៅក្នុងការដឹកនាំទឹកឡើងតាមរយៈសរសៃ និងត្រាកេអ៊ីត និងមាននាទីជាកន្លែងស្តុកអាហារផងដែរ។)

**parent** /ˈpɛːr(ə)nt/ [n] មេបា (ឯកត្តៈពីរ ដែលមានភេទផ្ទុយគ្នា មានសេណូទីបខុសគ្នា ហើយប្រើនៅក្នុងការងារបង្កាត់កម្ម)

**parentage** /ˈpɛːr(ə)ntɪdʒ/ [n] វង្សត្រកូល (នាមស័ព្ទដែលបញ្ជាក់ពីមេបាដោយបង្កាត់វិទូ)

**paresis** /pəˈriːsɪs/ [n] ប៉ារ៉ាលីស៊ីមិនពេញលេញ

**parietal** /pəˈrʌɪɪt(ə)l/ [adj] នៅតាមជញ្ជាំង (ទីតាំងរបស់ផ្កាសេនតានៅក្នុងអូវ៉ែ)

**park** /pɑːk/ [n] ឧទ្យាន

- marine park /məˈriːn pɑːk/ [n] ឧទ្យានសមុទ្រ
- national park /ˈnaʃ(ə)n(ə)l pɑːk/ [n] ឧទ្យានជាតិ

**parotid** /pəˈrɒtɪd/ [n] ក្រពេញបិតនៅជិតត្រចៀក (សម្រាប់បញ្ចេញទឹកមាត់)

**parsley** /ˈpɑːsli/ [n] វ៉ាន់ស៊ុយបារាំង

**part** /pɑːt/ [n] ផ្នែក
- ventral part /ˈvɛntr(ə)l pɑːt/ [n] ផ្នែកពោះ (ផ្នែកដែលនៅជាប់នឹងផ្នែកខាងក្រោមនៃពោះ)

**parthenocarpy** /ˈpɑːθɪnə(ʊ)ˌkɑːpi/ [n] ការមានផ្លែគ្មានគ្រាប់ខាងក្នុង (ការវិវឌ្ឍនៃផ្លែមួយដែលគ្មានគ្រាប់មានជីវិត។ ផ្លែប្រហែលជាគ្មានគ្រាប់ឬមួយមានគ្រាប់គ្មានអំប្រីយ៉ុង។ វាអាចបណ្ដាលមកពី ការពោយលម្អងខុស ឬការបង្កកំណើតខុស ឬការវិវឌ្ឍន៍មិនប្រក្រតីរបស់អំប្រីយ៉ុង។)

**parthenogenesis** /ˌpɑːθɪnə(ʊ)ˈdʒɛnɪsɪs/ [n] ការបន្តពូជគ្មានការបង្កកំណើត (ការបន្តពូជចេញពីស៊ុតគ្មានការបង្កកំណើត ជាប្រភេទមួយនៃការបន្តពូជគ្មានភេទ (apomixis-ការបន្តពូជ គ្មានការបង្កកំណើត)។ អំប្រីយ៉ុងរបស់អាចមានក្រូម៉ូសូម អាប្លូអ៊ីត ឬឌីប្លូអ៊ីត។)
- artificial parthenogenesis /ɑːtɪˈfɪʃ(ə)l ˌpɑːθɪnə(ʊ)ˈdʒɛnɪsɪs/ [n] កំណើតកើតឯងនិម្មិត

**particle** /ˈpɑːtɪk(ə)l/ [n]
១. ចុណ្ណភាគ, ភាគតូចល្អិតឆ្មារ, ប៉ាទីគូល
២. (ចំពោះដី) (សទិសន័យ៖ constituent)
- alpha particle /ˈalfə ˈpɑːtɪk(ə)l/ [n] ភាគល្អិតអាល់ផា
- beta particle /ˈbiːtə ˈpɑːtɪk(ə)l/ [n] ភាគល្អិតបែតា
- colloidal particle /kəˈlɔɪd(ə)l ˈpɑːtɪk(ə)l/ [n] ភាគល្អិតកូឡូអ៊ីត
- particle board /ˈpɑːtɪk(ə)l bɔːd/ [n] ក្ដារកម្ទេចឈើ (ជាផលិតផលឈើបានមកពីការបិតការនូវកម្ទេចឈើឱ្យទៅជាក្ដាសម្រាប់ប្រើប្រាស់)
- primary particle /ˈprʌɪm(ə)ri ˈpɑːtɪk(ə)l/ [n] ភាគល្អិតដើម (ឧ. ដី)
- soil particle /sɔɪl ˈpɑːtɪk(ə)l/ [n] ចុណ្ណភាគដី (ចំណែកយ៉ាងតូចៗ)
- suspended particle /səˈspɛndɪd ˈpɑːtɪk(ə)l/ [n] ភាគល្អិតវិលវល់

**particularity** /pəˌtɪkjʊˈlarɪti/ [n] វិសេសភាព

**parturition** /ˌpɑːtjʊˈrɪʃ(ə)n/ [n] ការកើតកូន

***Paspalum distichum*** [sci.n] សូមមើលពាក្យ៖ knotgrass

***Paspalum scrobiculatum*** [sci.n] សូមមើលពាក្យ៖ kodo millet

**transovarial passage** [n] ការចម្លងជំងឺវីរុសនៅក្នុងសត្វល្អិតពីជំនាន់មួយទៅជំនាន់មួយទៀត តាមរយៈពងរបស់វា

**passerine** /ˈpasərʌɪn/ [n] វដកបក្សី (ពពួកសត្វបក្សីដែលជើងរបស់វាមានការវិវត្តឱ្យវាអាចទំទ្រនំបាន)

***Passiflora foetida*** [sci.n] សូមមើលពាក្យ៖ stinking passion flower

**passive** /ˈpasɪv/ [adj] ធន់អកម្ម

**shrimp paste** /ʃrɪmp peɪst/ [n] កាពិ

**pastern** /ˈpast(ə)n/ [n] កង់កជើងសេះ

**Pasteurella** /ˌpɑːstərɛˈla/ [n] អម្បូរបាក់តេរីប៉ាស្ទ័រ៉ែល (ដែលបង្កជំងឺសារទឹក)

**pasteurellosis** /ˌpastərɛˈləʊsɪs/ [n] ជំងឺសារទឹក

**pasteurise** /ˈpɑːstʃərʌɪz/ [v] កម្ដៅរំងាប់មេរោគ

**pasteurization** /pɑːstʃərʌɪˈzeɪʃ(ə)n/ [n] ប៉ាស្ទ័រកម្ម

**pastoral** /ˈpɑːst(ə)r(ə)l/ [adj] ដែលមានស្មៅដុះដុក (ចំពោះដីដែលប្រើសម្រាប់ចិញ្ចឹមសត្វពាហនៈ)

**pastoralist** /ˈpɑːst(ə)r(ə)lɪst/ [n] អ្នកគង្វាលសត្វ

**pasture** /ˈpɑːstʃə/ [n] វាលស្មៅ (សម្រាប់សត្វស៊ី)
- mixed pasture /mɪkst ˈpɑːstʃə/ [n] វាលស្មៅចម្រុះ

**patch** /patʃ/ [n] បំណះ, ដីមួយមានក្បាលតូច (ប្រើសម្រាប់ធ្វើសួនច្បារ)

**brood patch** /bruːd patʃ/ [n] កន្លែងផ្ដល់កម្ដៅ (តំបន់សរសៃឈាមរីកធំនៅលើទ្រូងបក្សី ដែលមានមុខងារផ្ដល់កម្ដៅនៅពេលក្រាបពង)

**patchy** /ˈpatʃi/ [adj] រដិបរដុប, មិនស្មើ

**patella** /pəˈtɛlə/ [n] (ពហុវចនៈ៖ patellae) គ្រាប់អង្គុញ (ជង្គង់)

**path** /patʃ/ [n] ផ្លូវ

**pathogen** /ˈpaθədʒ(ə)n/ [n] ភ្នាក់ងារបង្កជំងឺ, ធាតុបង្កជំងឺ, អតិសុខុមប្រាណជំងឺ, ពូកបង្ករោគ (ពពួកសារពាង្គកាយរបស់រុក្ខជាតិទាំងឡាយដែលបង្កជំងឺដល់រុក្ខជាតិ (ឧ. ពួកវីរុស ពួកផ្សិត ពួកបាក់តេរី និងណេម៉ាតូត))
- airborne pathogen /ˈɛːbɔːn ˈpaθədʒ(ə)n/ [n] ភ្នាក់ងារបង្កជំងឺតាមខ្យល់
- opportunistic pathogen /ɒpətjuːˈnɪstɪk ˈpaθədʒ(ə)n/ [n] មេរោគឱកាសនិយម

- seed borne pathogen [n] មេរោគគ្រាប់ពូជ (អតិសុខុមប្រាណបង្ករោគមួយ ដែលមានក្នុងគ្រាប់ លើគ្រាប់ ឬជាមួយគ្រាប់ មិនថាវាបណ្តាលឱ្យគ្រាប់ខូចខាត ឬអត់នោះទេ)
- seedborne pathogen /siːd bɔːn ˈpaθədʒ(ə)n/ [n] មេរោគឆ្លងតាមគ្រាប់ពូជ
- seed-transmitted pathogen /siːd tranzˈmɪtɪd ˈpaθədʒ(ə)n/ [n] មេរោគចម្លងពីគ្រាប់ពូជ (អតិសុខុមប្រាណចម្លងមួយដែលមាននៅក្នុង លើ ឬជាមួយគ្រាប់ពូជ ដែលមានសក្តានុពលបណ្តាលឱ្យកើតជំងឺដល់កូនឈើ ឬរុក្ខជាតិ ប៉ុន្តែមិនបណ្តាលធ្វើឱ្យខូចដល់គ្រាប់ពូជនេះទេ)

**pathogenicity** /ˈpaθədʒ(ə)niksɪti/ [n] ភាពបង្ករោគ (សមត្ថភាពនៃពួកបង្ករោគ បង្កឱ្យមានជំងឺ)

**pathology** /pəˈθɒlədʒi/ [n] រោគវិទ្យា, រោគសាស្ត្រ (វិទ្យាសាស្ត្រសិក្សាពីជំងឺ)
- plant pathology /plɑːnt pəˈθɒlədʒi/ [n] (សទិសន័យ៖ phytopathology) ភូតគាមរោគវិទ្យា, រុក្ខរោគវិទ្យា (វិទ្យាសាស្ត្រសិក្សាពីជំងឺរុក្ខជាតិ)
- seed pathology /siːd pəˈθɒlədʒi/ [n] រោគសាស្ត្រគ្រាប់

**pathway** /ˈpɑːθweɪ/ [n] បថវិធី (រចនាបថមួយ ដែលបង្ហាញពីទំនាក់ទំនង ឬដំណើរការនៃរចនាសម្ពន្ធ)
- branched pathway /brɑːn(t)ʃt ˈpɑːθweɪ/ [n] លំនាំបែកមែក

**patient** /ˈpeɪʃ(ə)nt/ [n] អ្នកជំងឺ

**pattern** /ˈpat(ə)n/ [n] គម្រូ
- circuitous pattern /səːˈkjuːɪtəs ˈpat(ə)n/ [n] មជ្ឈវិធី (វិធីសាស្ត្រភ្ជួរដីតាមទិសដៅប្រាស់ដំណើរទ្រនិចនាឡិកាចាប់ពីក្បែរភ្លឺស្រែ រហូតដល់បញ្ចប់កណ្តាលស្រែ ហើយជាទូទៅគេច្រើនធ្វើលើស្រែចតុកោណកែងតូចៗ)
- cropping pattern /krɒppɪŋ ˈpat(ə)n/ [n] គំរូដាំដុះ (ការរៀបចំវិធីដាំដុះដំណាំជាក់លាក់ដូចជា ស្រូវ-ស្រូវ សណ្តែក-ស្រូវ ស្រូវ-សណ្តែក)
- flooding pattern /flʌdɪŋ ˈpat(ə)n/ [n] របបជំនន់ (ពេលកំណត់ដែលធម្មតាទឹកឡើង និងស្រក)

**paunch** /pɔːn(t)ʃ/ [n] ពោះធំ, ពោះ (កំប៉ោង), ក្បាលពោះ (ដែលដុះ)

**pause** /pɔːz/ [v] ឈប់មួយរយៈ, ផ្អាក

**desert pavement** /dɪˈzəːt ˈpeɪvm(ə)nt/ [n] (សទិសន័យ៖ paved land, lag gravel) ភាគក្រាលថ្មនៃដី

**paw** /pɔː/ [n] ក្រញាំ (ឆ្កែ, ឆ្មា)

**pawpaw** /ˈpɔːpɔː/ [n] សូមមើលពាក្យ៖ papaya

**pea** /piː/ [n] សណ្តែកបារាំង (ឈ្មោះវិទ្យាសាស្ត្រ *Pisum sativum*)
- black pea /blak piː/ [n] (សទិសន័យ៖ cow pea) សណ្តែកអង្គុយ, សណ្តែកសពោះខ្មៅ
- cow pea /kaʊ piː/ [n] សូមមើលពាក្យ៖ black pea
- pigeon pea /ˈpɪdʒɪn piː/ [n] សណ្តែកក្លិង្គ, សណ្តែកអង្រែ (ឈ្មោះវិទ្យាសាស្ត្រ *Cajanus cajan*)

**peach** /piːtʃ/ [n] ប៉ែស (ផ្លែឈើម្យ៉ាងស្រដៀងនឹងផ្លែសេដា) (ឈ្មោះវិទ្យាសាស្ត្រ *Prunus persica*)

**peacock** /ˈpiːkɒk/ [n] សត្វក្ងោក

**peak** /piːk/ [adj] កំពូលស្រួច

**peanut** /ˈpiːnʌt/ [n] សណ្តែកដី (ឈ្មោះវិទ្យាសាស្ត្រ *Arachis hypogea*)

**prickly pear** /ˈprɪkli pɛː/ [n] ផ្លែដំបងយក្ស

**peasant** /ˈpɛz(ə)nt/ [n] អ្នកស្រែ, កសិករ, អ្នកចម្ការ, អ្នកជនបទ

**peat** /piːt/ [n] ធ្យូងតួប, ល្បាប់ភក់បាតបឹង (ល្បាប់ភក់នេះមានលទ្ធភាពរក្សាសំណើមបានយូរ), រុក្ខជាតិពុក (សម្រាប់ធ្វើជី)
- acid low-moor peat /ˈasɪd ləʊmɔː piːt/ [n] (សទិសន័យ៖ muskeg) ពើកអាស៊ីត, ពើកសើម
- acid peat /ˈasɪdpiːt/ [n] ពើកអាស៊ីត (pH<៥)
- alkaline peat /ˈalkəlʌɪn piːt/ [n] ពើកអាល់កាឡាំង (pH>៧)
- amorphus peat /əˈmɔːfəs piːt/ [n] ពើកដែលគរហាប់លើគ្នា
- basin peat /ˈbeɪs(ə)n piːt/ [n] ពើកនៅក្នុងតំបន់ទំនាប , ពើកដែលមានជីជាតិល្អ
- brown moss peat /braʊn mɒs piːt/ [n] ពើកកើតពីស្លែពណ៌ត្នោត
- earth peat /əːθ piːt/ [n] ពើករលាយនឹងដី
- fibrous peat /ˈfʌɪbrəs piːt/ [n] ពើក ឬមមោកដុលដែលមានសភាពជាសរសៃៗ
- forest upland peat /ˈfɒrɪst ˈʌplənd piːt/ [n] មមោកពើកនៅតំបន់ដីខ្ពស់

- green moss peat /gri:n mɒs pi:t/ [n] ពើកកើតពីសរីរាង្គស្លែបៃតង
- heath peat /hi:θ pi:t/ [n] ពើកដែលកើតពីរុក្ខជាតិព្រុយយ៉ែរ
- high moor peat /hʌɪ mɔ: pi:t/ [n] ពើកលើទួល
- hill peat /hɪl pi:t/ [n] ពើក ឬមមោកដុលនៅកន្លែងខ្ពស់ៗ, ពើកស្លែស
- intermediate peat /ˌɪntəˈmi:dɪət pi:t/ [n] ពើកអន្តរការ (អត្រាខនិជមធ្យម)
- limnic peat /ˈlɪmnɪk pi:t/ [n] (សទិសន័យ៖ liver peat, peat mud, dystrophic lacustrine soil) ដីល្បាប់បាតបឹងអាស៊ីតដែលមានសកម្មភាពជីវសាស្ត្រតិច, ដីមិនសូវមានជីជាតិ, ភក់ពណ៌ត្នោត
- liver peat /ˈlɪvə pi:t/ [n] សូមមើលពាក្យ៖ limnic peat
- low moor wood peat /ləʊ mɔ: wʊd pi:t/ [n] សូមមើលពាក្យ៖ alder swamp
- moss peat /mɒs pi:t/ [n] ពើកដែលជាសរីរាង្គស្លែ, កន្លែងកើតពើកក្លាយពីស្លែ
- muck peat /mʌk pi:t/ [n] សូមមើលពាក្យ៖ muck
- muddy peat /ˈmʌdi pi:t/ [n] ពើករលាយនឹងភក់
- mull-like peat /mʌl-lʌɪk pi:t/ [n] មមោកដែលមានសភាពដូចពើក
- nutritive peat /ˈnju:trɪtɪv pi:t/ [n] ពើកដែលមានជីជាតិល្អ (អត្រាខនិជខ្ពស់) នៅតំបន់ទំនាប
- pitch-like peat /pɪt-lʌɪkʃ pi:t/ [n] តួប ឬពើកដែលល្អិត
- podzolic peat /pɒdzɒlic pi:t/ [n] ដីពើកអាស៊ីត
- sedge peat /pɪt-lʌɪkʃ pi:t/ [n] ពើកដែលកើតពីប្រភេទកក់
- swamp wood peat /swɒmpwʊdpi:t/ [n] សូមមើលពាក្យ៖ alder swamp
- white moss peat /wʌɪt mɒs pi:t/ [n] ពើកដែលជាសរីរាង្គស្លែ (ពណ៌) ស
- woddy peat /ˈwʊdipi:t/ [n] ស្រទាប់តួប ឬពើក (កើតពីរុក្ខជាតិព្រៃ)
- wood peat /wʊd pi:t/ [n] ពើកដែលជាធាតុលីញើន
- woody peat /ˈwʊdi pi:t/ [n] ពើកកើតក្រោមព្រៃជាំទឹក, ដីដែលមានសរីរាង្គពើកតំបន់ព្រៃ

**transitional peatland** /tranˈzɪʃ(ə)n(ə)l pi:tland/ [n] (សទិសន័យ៖ half bog) កន្លែងកើតពើកអន្តរកាល

**peaty** /ˈpi:ti/ [adj] ដែលជាពើក

- half peaty /hɑ:f pi:ti/ [adj] ពើកកំពុងរលួយជាមមោក

**pebble** /ˈpɛb(ə)l/ [n] ក្រួសអាចម៍ផ្កាយ (ក្រួសរមៀល)

- facetted pebble /ˈfasɪtɪd ˈpɛb(ə)l/ [n] (សទិសន័យ៖ wind-carved pebble, wind-worn pebble) ក្រួសដែលមានមុខជ្រុងច្រើនរចនាដោយខ្យល់, ថ្មក្រួសមានមុំច្រើន
- fluvial pebble /ˈflu:vɪəl ˈpɛb(ə)l/ [n] ក្រួសអាចម៍ផ្កាយ (ដែលរមៀលដោយទឹកទន្លេ)
- large pebble /lɑ:dʒ ˈpɛb(ə)l/ [n] ក្រួសធំ (៣-៧ម.ម)
- middle-sized pebble /ˈmɪd(ə)l sʌɪz ˈpɛb(ə)l/ [n] ក្រួសមធ្យម (៥-៣០ម.ម)
- polished pebble /ˈpɒlɪʃ ˈpɛb(ə)l/ [n] (សទិសន័យ៖ ventifact) ក្រួសដែលខាត់សំលៀងដោយខ្យល់, ថ្មដែលឆ្លាក់ដោយថាមពលខ្យល់
- small pebble /smɔ:l ˈpɛb(ə)l/ [n] ក្រួសតូចៗ (តូចជាង ១.៥ ស.ម)
- wind-carved pebble /wɪndkɑ:v ˈpɛb(ə)l/ [n] សូមមើលពាក្យ៖ facetted pebble
- wind-worn pebble /wɪnd wɔ:n ˈpɛb(ə)l/ [n] សូមមើលពាក្យ៖ facetted pebble

**pebbly** /pɛbi/ [adj] (សទិសន័យ៖ rudaceous) ជាកម្ទេចថ្ម

**peccary** /ˈpɛk(ə)ri/ [n] ជ្រូកព្រៃ

**pectoral** /ˈpɛkt(ə)r(ə)l/ [adj] នៃទ្រូង

**pedestal** /ˈpɛdɪst(ə)l sləʊp/ [n] ថ្មទ្រនាប់ជើងភ្នំដែលមានជម្រាលទេខ្លាំង

**pediatric** [adj] នៃវិជ្ជាពេទ្យកុមារ

**pediatrician** /ˌpi:dɪəˈtrɪʃ(ə)n/ [n] ពេទ្យកុមារ

**pedicel** /ˈpɛdɪs(ə)l/ [n]
១. ទងគ្រាប់, ទងផ្កា (ផ្នែកមួយដែលភ្ជាប់ផ្កាទៅនឹងស្នែងក្ស ឬជាប់ទម្រផ្កា)
២. (ចំពោះសត្វល្អិត) ដើម (អង់តែន)

**pediculosis** /pɪˌdɪkjʊˈləʊsɪs/ [n] ជំងឺចៃខាំ

**pedigree** /ˈpɛdɪgri:/ [n] ពង្សាវលី, ពង្សា (បញ្ជីដែលកត់ត្រាពីពូជពង្សនៃឯកត្តៈ)

**pediment** /ˈpɛdɪm(ə)nt/ [n] គំនរកម្ទេចកំទីដែលរាប់ស្មើ ហើយជ្រេលចុះបន្តិចម្ដងៗនៅក្រោមជើងភ្នំ

**pediplain** /ˈpɛdɪpleɪn/ [n] ផ្ទៃស្មើរតែរាបស្មើរក្នុងតំបន់ស្ងួត ដោយការរីកកាន់តែធំឡើងនៃក្លាស៊ីលាងច្រោះនៃថ្ម

- pediment of pediplain /ˈpɛdɪm(ə)nt ɒv ˈpɛdɪpleɪn/ [n] ផ្ទៃរាបកើតពីការលាងច្រោះនៃថ្មរឹងនៅក្រោមជើងភ្នំ ឬដំបូក

**paedogenesis** /ˌpiːdə(ʊ)ˈdʒɛnɪsɪs/ [n] បាតុភូតដែលបង្កជាដីដែលមានថ្មមេជាវត្ថុធាតុដើម

**pedologist** /pɪˈdɒlədʒɪst/ [n] អ្នកឯកទេសផ្នែកធរណីវិទ្យា

**pedology** /pɪˈdɒlədʒi/ [n] ធរណីវិទ្យា, ដីវិទ្យា

**pedosphere** /ˈpɛdɪsfɪə/ [n] ដែននៃធរណីវិទ្យា

**peduncle** /pɪˈdʌŋk(ə)l/ [n] ទងធំរបស់ផ្កា, ទងធំរបស់ផ្លែឈើ (ជាទងអ័ក្សធំរបស់ផ្កាចង្កោម ឬ ក្នុងករណីផ្កាទោលជាទងផ្កាឬទងផ្លែ។)

**peel** /piːl/ [v] បកសម្បក, ចិតសម្បក

**pelagic** /pɪˈladʒɪk/ [adj] នៃលំហសមុទ្រ, ប៉េឡាស៊ិច

**pelican** /ˈpɛlɪk(ə)n/ [n] សត្វទុង

**pellagra** /pɛˈlagrə/ [n] ជំងឺខ្វះជីវជាតិ ដែលធ្វើឱ្យឈឺលើស្បែក,ក្នុងមាត់, និងក្នុងគ្រឿងរំលាយអាហារ

**pelleting** /ˈpɛlɪtɪŋ/ [n] ការស្រូនគ្រាប់ (ដំណើរការដែលគ្រាប់ពូជនីមួយៗ ត្រូវបានគេស្រោបសារធាតុស្អិតដែលមានផ្ទុក ឧ. សារធាតុចិញ្ចឹម ការបញ្ចូលអតិសុខុមប្រាណមានប្រយោជន៍ និង/ឬថ្នាំពុល។ អត្ថប្រយោជន៍បន្ថែមនៃការស្រូនគ្រាប់នេះ គឺជួយសម្រួលដល់ការសាប ដាំតាមមេកានិចដោយសារការស្រូននេះធ្វើឱ្យគ្រាប់ធំបន្តិច និងមានទំហំស្មើរតែស្មើគ្នា។)

**pell-mell** /pɛl ˈmɛl/ [adj] រាត់រាយ, ច្របូកច្របល់

**pelt** /pɛlt/ [n] ស្បែកសត្វ

**pelvimeter** /pɛlˈvɪmɪtri/ [n] ប្រដាប់វាស់រន្ធឆ្អឹងត្រគាក

**pelvis** /ˈpɛlvɪs/ [n] ឆ្អឹងត្រគាក

**pen** /pɛn/ [n] ទ្រុង, ក្រោល (សត្វ)

**pendulum** /ˈpɛndjʊləm/ [n] ប៉ោល

**peneplain** /ˈpiːnɪpleɪn/ [n] ស្ថានភាពដីដែលមានជម្រាលខ្សោយ (មិនសូវចោត) និងរង្វះជ្រលងទូលាយ

**penetrability** /pɛnɪtrəˈbɪlɪti/ [n] ភាពដែលអាចជ្រាតបាន

- root penetrability /ruːt pɛnɪtrəˈbɪlɪti/ [n] ភាពជ្រាត ឬ ចាក់ចូលបាននៃឫស

**penetration** /pɛnɪˈtreɪʃ(ə)n/ [n] ការទម្លាយចូល, ជ្រាបចូល, ជ្រៀតចូល, ការចាក់ចូល

- root penetration /ruːt pɛnɪˈtreɪʃ(ə)n/ [n] សម្បទានៃការចាក់ចូលនៃឫសរុក្ខជាតិ

**penetrometer** /ˌpɛnɪˈtrɒmɪtə/ [n] របឹងម៉ែត្រ (ឧបករណ៍ដែលប្រើសម្រាប់វាស់ស្ទង់ភាពរឹងនៃដី។ ខ្នាតរង្វាស់ដែលទទួលបានពីការវាស់ស្ទង់នេះ ជាគីឡូប៉ាស្កាល់ (KPa))

**penicillin** /pɛnɪˈsɪlɪn/ [n] ប៉េនីស៊ីលីន

**penis** /ˈpiːnɪs/ [n] លិង្គ, អង្គជាតិ, ក្ដ

**penknife** /ˈpɛnnʌɪf/ [n] (សទិសន័យ៖ pocket knife) កាំបិតបត់, កូនកាំបិត

**pennate** /ˈpɛnət/ [adj] ដែលមានស្លាប ឬរោម

***Pennisetum purpureum*** [sci.n] សូមមើលពាក្យ៖ Napier grass

**penstock** /ˈpɛnstɒk/ [n] ទ្វារទឹកជំនន់

***Pentapetes phoenicea*** [sci.n] ក្រជិប

**grassroot people** /ɡrɑːs ruːt ˈpiːp(ə)l/ [n] ប្រជាជនស្រទាប់ក្រោមបង្អស់

**indigenous people** /ɪnˈdɪdʒɪnəs ˈpiːp(ə)l/ [n] អន្ដោជន (ជនដែលរស់នៅកន្លែងមួយដោយមិនផ្លាស់ប្ដូរពីកន្លែងមួយផ្សេងទៀត)

***Peperomia pellucida*** [sci.n] សូមមើលពាក្យ៖ pepper elder

**pepo** /ˈpiːpəʊ/ [n] ប្រភេទផ្លែសាច់ត្រសក់-ឃ្លោក

**pepper** /ˈpɛpə/ [n] ក្រុមរុក្ខជាតិ ឬ គ្រឿងទេសមានរសជាតិហឹរដូចជា ម្ទេស ម្រេច

- bell pepper /bɛl ˈpɛpə/ [n] ម្ទេសប្លោក (ឈ្មោះវិទ្យាសាស្ត្រ *Capsicum annuum*)
- bird pepper /bəːd ˈpɛpə/ [n] ម្ទេសអាចម៍សត្វ
- black pepper /blak ˈpɛpə/ [n] ម្រេច (ឈ្មោះវិទ្យាសាស្ត្រ *Piper nigrum*)
- cayenne pepper /keɪˈɛn ˈpɛpə/ [n] ម្ទេសហាវ៉ៃ (ឈ្មោះវិទ្យាសាស្ត្រ *Capsicum annuum*)
- chilli pepper /ˈtʃɪli ˈpɛpə/ [n] ម្ទេសហឹរ (ឈ្មោះវិទ្យាសាស្ត្រ *Capsicum annuum*)

- lolot pepper [n] ជីរភ្លូ (ឈ្មោះវិទ្យាសាស្ត្រ *Piper lolot*)
- sweet pepper /swiːt ˈpɛpə/ [n] ម្ទេសផ្លោក
- water pepper /ˈwɔːtə ˈpɛpə/ [n] ម្រេចទឹក (ឈ្មោះវិទ្យាសាស្ត្រ *Polygonum hydropiper*)
- tabasco pepper /təˈbaskəʊ ˈpɛpə/ [n] ម្ទេសអាចម៍សត្វ (ឈ្មោះវិទ្យាសាស្ត្រ *Capsicum frutescens*)

**pepper elder** /ˈpɛpə ˈɛldə/ [n] ក្រសាំងទាប (ឈ្មោះវិទ្យាសាស្ត្រ៖ *Peperomia pellucida*)

**peppercorn** /ˈpɛpəkɔːn/ [n] គ្រាប់ម្រេច

**peppermint** /ˈpɛpəmɪnt/ [n] ជីរអង្កាម (ឈ្មោះវិទ្យាសាស្ត្រ *Mentha arvensis*)

**pepsin** /ˈpɛpsɪn/ [n] អង់ស៊ីមនៃទឹកក្រពះ សម្រាប់ជួយរំលាយប្រូតេអ៊ីន

**per-** /pəː/ [prefix] (សទិសន័យ៖ through, throughout) បុព្វបទមានន័យថា ឆ្លងកាត់

**per capita** /pəː ˈkapɪtə/ [adj] ក្នុងមនុស្សម្នាក់, សម្រាប់មនុស្សម្នាក់

**per diem** /pəː ˈdiːɛm/ [n] លុយប្រចាំថ្ងៃ

**per os** /pəː ɒs/ [adv] តាមមាត់

**peracute** /ˌpəːrəˈkjuːt/ [adj] សាហាវខ្លាំង (ប្រើចំពោះជំងឺ)

**percent** /pəˈsɛnt/ [n] ភាគរយ

**percentage** /pəˈsɛntɪdʒ/ ភាគរយ

- germination percentage /dʒəːmɪˈneɪʃ(ə)n pəˈsɛntɪdʒ/ [n] ភាគរយដំណុះ
- permanent wilting percentage /ˈpəːm(ə)nənt wɪltɪŋ pəˈsɛntɪdʒ/ [n] ភាគរយនៃភាពស្វិតស្រពោននិរន្តរ៍ (ភាគរយនៃសមាសធាតុទឹកដែលត្រូវបានបន្ថយនៅក្នុងដីមួយ ហើយដែលនៅក្នុងកម្រិតទឹកនោះ រុក្ខជាតិ និងការលូតលាស់របស់វាត្រូវបានទទួលរងនូវភាពស្វិតស្រពោនជានិរន្តរ៍)

**perceptible** /pəˈsɛptɪb(ə)l/ [adj] អាចដឹងបាន

**perch-bass** /pəːtʃ-beɪs/ [n] ជាក្រុមត្រីទឹកសាប និងទឹកប្រៃដែលស្ថិតក្នុងលំដាប់ Perciformes

**percolate** /ˈpəːkəleɪt/ [v] ជ្រាបចុះក្រោម, ជ្រាបឈរ

**percolation** /pəːkəˈleɪʃ(ə)n/ [n] ជម្រាបឈរ (ការជ្រាបចុះនៃទឹកទៅក្នុងដីតាមខ្សែឈរ), ការជ្រាប ឬច្រោះទឹកចូលក្នុងដីយឺតៗនៃទឹក (ឧ. ទឹកភ្លៀង)

**percussion** /pəˈkʌʃ(ə)n/ [n] ការពិនិត្យដោយគោះ

**perennial** /pəˈrɛnɪəl/ [adj] ពហុវត្ស (រុក្ខជាតិដែលមានអាយុលើសពី ២ ឆ្នាំចាប់ពីពេលដុះ)

**perfect** /ˈpəːfɪkt/ [adj] ឥតខ្ចោះ, សុក្រឹត

**perforate** /ˈpəːfəreɪt/ [n] ធ្វើឱ្យមានជាប្រហោង, ទម្លុះជារន្ធ

**performance** /pəˈfɔːm(ə)ns/ [n] សម្តែងកម្ម (អំពើ ឬរបៀបរបបអនុវត្តសកម្មភាពអ្វីមួយ ឬការងារអ្វីមួយ ឬជាលទ្ធភាពក្នុងការអនុវត្តន៍អ្វីមួយនោះ (ឧ. ចំនួនកម្រិត ឬប្រសិទ្ធភាព និងចំណូលផលិតផលនៅក្នុងប្រព័ន្ធ))

**peri-** /ˈpɪəri/ [prefix] (សទិសន័យ៖ surrounding, enclosing) បុព្វបទមានន័យថា ជុំវិញ

**perianth** /ˈpɛrɪanθ/ [n] ត្របក (សំដៅទៅលើផ្នែកខាងក្រៅរបស់ផ្ការួមមានត្របកផ្កា និងស្រទាប់ផ្កា។ ជាធម្មតាពាក្យនេះប្រើសំដៅប្រភេទពូជដែលមានការខុសគ្នាបន្តិចបន្តួចនៅក្នុងត្របកផ្កា និងស្រទាប់ផ្កា។)

**pericardium** /ˌpɛrɪˈkɑːdɪəm/ [n] (សទិសន័យ៖ heart sac) ស្រោមបេះដូង, ពេរីកាត

**peri-care** [n] ការថែទាំផ្នែកខាងក្រោមនៃខ្លួន(ចន្លោះគូថ និងយោនី ឬលិង្គ)

**pericarp** /ˈpɛrɪkɑːp/ [n] សម្បកផ្លែ, ភេរីខេប (ជញ្ជាំង (សម្បក) របស់អូវុលទុំ ពោលគឺសម្បកផ្លែ។ ប្រភេទពូជខ្លះមានសម្បកផ្លែតែមួយជាន់ តែប្រភេទខ្លះទៀតផ្សំឡើងពី ៣ ស្រទាប់ខុសគ្នាគឺស្រទាប់ក្រៅ (exocarp) ស្រទាប់កណ្តាល (mesocarp) និងស្រទាប់ក្នុង (endocarp))

**pericycle** /ˈpɛrɪsʌɪk(ə)l/ [n] ប៉េរីស៊ីក (ស្រទាប់កោសិកាព័ទ្ធជុំវិញស៊ីឡែម និងផ្លូអែមរបស់ឫស ដែលវាបង្កើតឫស ឬខ្នែង)

**perigyny** [n] នៅពាក់កណ្តាលទម្រផ្កា (ទីតាំងរបស់អូវ៉ែធៀបនឹងទម្រផ្កា)

**perimeter** /pəˈrɪmɪtə/ [n] បរិមាត្រ

**perineal** /ˌpɛrɪˈniːəl/ [adj] នៃចន្លោះគូទ និងយោនី ឬលិង្គ

**perineum** /ˌpɛrɪˈniːəm/ [n] ពេរីនេ, ចន្លោះគូទ និងយោនី ឬលិង្គ

**period** /ˈpɪərɪəd/ [n] ខួប, សម័យកាល

- dry period /drʌɪ ˈpɪərɪəd/ [n] រយៈពេលរាំងស្ងួត

- flowering period /ˈflaʊərɪŋ ˈpɪərɪəd/ [n] សូមមើលពាក្យ៖ flowering
- gestation period /dʒɛˈsteɪʃ(ə)n ˈpɪərɪəd/ [n] រយៈពេលមានគភ៌
- incubation period /ɪŋkjʊˈbeɪʃ(ə)n ˈpɪərɪəd/ [n] រយៈពេលកកើត, ចិរវេលាផ្ចាប់ (រយៈពេលដែលត្រូវការសម្រាប់ឱ្យរោគសញ្ញារបស់ជំងឺមួយចេញជារូបរាងបាន ក្រោយពីវាបានចាប់ផ្តើមចូលលុកលុយទៅលើសរីរាង្គនៃជីវករមួយ)
- latent period /ˈleɪt(ə)nt ˈpɪərɪəd/ [n] សុវត្តិពេល (រយៈពេលដែលវីរុសត្រូវការបំបែកខ្លួន និងបន្សាំក្នុងភ្នាក់ងារចម្លងរហូតដល់ពេលដែលវាអាចឆ្លងសិន។ ហេតុនេះ ប្រសិនបើដើមស្រូវថ្មីណាមួយ ត្រូវភ្នាក់ងារចម្លងជញ្ជក់នៅរយៈពេលនេះ មិនបណ្តាលឱ្យកើតជំងឺវីរុសទេ។)
- quaternary period /kwəˈtəːn(ə)ri ˈpɪərɪəd/ [n] សម័យកាលទីបួន
- tertiary period /ˈtəːʃ(ə)ri ˈpɪərɪəd/ [n] សម័យកាលទីបី

**periodic table of the elements** [n] តារាងខួបនៃធាតុគីមី

**periodicity** /ˌpɪərɪəˈdɪsɪti/ [n] ភាពទៀងពេលកំណត់, ខួបចេញផ្លែ (គិតជាឆ្នាំ) (និន្នាការរបស់ឯកត្តៈដើមពូជ ឬប្រភេទពូជផលិតគ្រាប់នៅរយៈពេលមួយវែង ប៉ុន្តែជារឿយៗមានចន្លោះពេលទៀងទាត់វែង ឬខ្លីប៉ុណ្ណោះ។ រដូវផ្លែនេះទាក់ទងយ៉ាងខ្លាំងរវាងការចេញផ្កាច្រើន និងច្រើនបំផុត។)

**periodontic** /ˌpɛrɪəˈdɒntɪks/ [n] អញ្ចាញធ្មេញ

**periosteum** /ˌpɛrɪˈɒstɪəm/ [n] សម្បកឆ្អឹង, ស្រោមឆ្អឹង

**peripheral** /pəˈrɪf(ə)r(ə)l/ [n] ផ្នែខាងក្រៅ, នៅឆ្ងាយពីទីកណ្តាល

**periphysis** [n] បម្រែបម្រួលការលូតលាស់ (ការប្រែប្រួលទម្លាប់លូតលាស់របស់សរីរាង្គលូតលាស់ដោយសារតែដើមកំណើតរបស់វាមកពីបរិស្ថានផ្សេងដូចជាម្លប់ និងស្លឹកត្រូវការពន្លឺថ្ងៃ។)

**perisperm** /ˈpɛrɪspəːm/ [n] ជាលិកាបម្រុងផៃរីស្ពែម (ស្រទាប់មួយនៃជាលិកាអាហារបម្រុងដែលមានប្រភពពីកោសិកាមេឌីផ្លូអ៊ីត កើតចេញពីប្រទេកា ហើយជារឿយៗព័ទ្ធជុំវិញដោយអង់ដូស្ពែម។ ជាធម្មតាវាត្រូវបានស្រូបអស់មុននឹងផ្លែឡើងចាស់ពេញវ័យ ប៉ុន្តែបង្កើតជាជាលិកាបម្រុងចំពោះពូជខ្លះ ឧ. Caryophyllaceae។)

**perispore** /ˈpɪərispɔː/ [n] ភ្នាសស្ប៉

**peristalsis** /ˌpɛrɪˈstalsɪs/ [n] ចលនាកន្ត្រាក់ (បំពង់អាហារ)

**peritoneum** /ˌpɛrɪtəˈniːəm/ [n] ភ្នាសពោះ, ស្រោមពោះ

**peritonitis** /ˌpɛrɪtəˈnʌɪtɪs/ [n] ជំងឺរលាកស្រោមពោះ

**peritrichous** [adj] ប្រភេទបាក់តេរីដែលកោសិកាមានកន្ទុយច្រើននៅជាមួយ

**perlite** /ˈpəːlʌɪt/ [n] មេដ្យមសម្រាប់ដាំ, សារធាតុសម្រាប់ដាំ, ភឺឡៃត (សារធាតុអសរីរាង្គសម្រាប់ដាំដែលស្រាលបំផុតផលិតចេញពីកំអែភ្នំភ្លើង។ វាមានសមត្ថភាពរក្សាសំណើមបានល្អណាស់។ គេប្រើវាជាអាទិ៍ដើម្បីកែលម្អការចេញចូលខ្យល់របស់មេដ្យមសម្រាប់ដាំ។)

**permafrost** /ˈpəːməfrɒst/ [n]

១. មណ្ឌលកក (ផ្ទៃដី ឬថ្ម និងរួមបញ្ចូលទឹកកក និងសារធាតុសរីរាង្គ ដែលនៅត្រឹម 0អង្សា ឬទាបជាងនេះយ៉ាងហោចណាស់រយៈពេលពីរឆ្នាំជាប់គ្នា)

២. (សទិសន័យ៖ permanently frozen soil) ដីដែលត្រជាក់កកជានិច្ច, កំណកដីអចិន្ត្រៃយ៍ (ស្រទាប់ដីនៅតំបន់ទុនដ្រា ដែលមានទឹកកកជានិច្ច)

**permanent** /ˈpəːm(ə)nənt/ [adj] អចិន្ត្រៃយ៍

- permanent wilting /ˈpəːm(ə)nənt wɪltɪŋ/ [n] និរន្តស្រពោន (ភាពស្វិតស្រពោន ដែលមិនអាចវិលមករកភាពដើមវិញបានឡើយ ទោះមានទឹកគ្រប់គ្រាន់វិញក៏ដោយ)

**permeability** /pəːmɪəˈbɪlɪti/ [n] ភាពជ្រាបទឹក

- air permeability /ɛː pəːmɪəˈbɪlɪti/ [n] ភាពដែលខ្យល់អាចជ្រាបបាន

**permeable** /ˈpəːmɪəb(ə)l/ [adj] ដែលជ្រាបទឹក, អាចជ្រាបចូលបាន

**permeate** /ˈpəːmɪeɪt/ [v] ជ្រាប (ទឹក)

**permission** /pəˈmɪʃ(ə)n/ [n] (សទិសន័យ៖ permit) ការអនុញ្ញាត

**permit** /ˈpəːmɪt/ [n] (សទិសន័យ៖ permission) ការអនុញ្ញាត

- permit for dumping /ˈpəːmɪt fɔː dʌmpɪŋ/ [n] ការអនុញ្ញាតឱ្យចោលសំណល់

**perosis** /pəˈrəʊsɪs/ [n] ប៉េរូស (ជំងឺកូនមាន់ដែលបណ្តាលឱ្យឆ្អឹងខូចទ្រង់ទ្រាយ)

**peroxide** /pəˈrɒksʌɪd/ [n] ពែអុកស៊ីត (ទឹកអុកស៊ីសែន)

***Persicaria odorata*** [sci.n] ជីរក្រសាំងទំហំ

**Persistent** /pəˈsɪst(ə)nt/ [adj] មិនងាយសាប (ឧ. ថ្នាំពុល DDT)

**chairperson** /ˈtʃɛːpəːs(ə)n/ [n] អ្នកដឹកនាំអង្គប្រជុំ

**perspire** /pəˈspʌɪə/ [v] បែកញើស, ចេញញើស

**pervious** /ˈpəːvɪəs/ [adj] ដែលមានរន្ធ

**pessary** /ˈpɛs(ə)ri/ [n] គ្រឿងដាក់ក្នុងយោនីដើម្បីទ្រស្បូន, ថ្នាំសុលតាមយោនី

**pest** /pɛst/ [n] ទុរករ, សមាសភាពចង្រៃ, ជំងឺឆ្លង (ពពួកសារពាង្គកាយទាំងឡាយណាដែលមិនចង់បាន (សត្វល្អិត កណ្ដុរ ប៉ាតូសែន ស្មៅ និងសត្វតូចៗជាដើម) ហើយមានលក្ខណៈប្រជែងជាមួយមនុស្សដូចជាចំណីអាហារ និងជម្រក ឬគំរាមកំហែងដល់សុខភាព ឬផាសុខភាព ឬសុខុមាលភាព)

- chronic pest /ˈkrɒnɪk pɛst/ [n] ទុរករ៉ាំរ៉ៃ
- secondary pest /ˈsɛk(ə)nd(ə)ri pɛst/ [n] ទុរករបន្ទាប់បន្សំ (ប្រភេទទុរករដែលការបំផ្លាញរបស់វាមានការប៉ះពាល់ដល់កម្រិតសេដ្ឋកិច្ចទាប ឬតិចតួចប៉ុណ្ណោះ)
- target pest /ˈtɑːɡɪt pɛst/ [n] ទុរករកំណត់ (ប្រភេទទុករដែលត្រូវតែធ្វើការកម្ចាត់ចោល)

**pesticide** /ˈpɛstɪsʌɪd/ [n] ថ្នាំសម្លាប់សមាសភាពចង្រៃ, ថ្នាំសត្វឃាត (សារធាតុដែលប្រើសម្រាប់បំផ្លាញ ឬបំពុលពពួកចង្រៃ។ ក្នុងនោះមានថ្នាំបំពុលសត្វល្អិត ថ្នាំកម្ចាត់ស្មៅ ថ្នាំកម្ចាត់ជំងឺផ្សិត ថ្នាំកម្ចាត់បាក់តេរី ថ្នាំកម្ចាត់កណ្ដុរ ថ្នាំកម្ចាត់ពពួកណេម៉ាតូតជាដើម)

- pesticide treatmill /ˈpɛstɪsʌɪd ˈtrɛdmɪl/ [n] បង្កើនកម្រិតពុល (ការប្រើប្រាស់ថ្នាំពុលដោយប្រើកម្រិតជាតិពុលកើនជានិច្ចពីពេលមួយទៅពេលមួយ)
- accumulative pesticide /əˈkjuːmjʊlətɪv ˈpɛstɪsʌɪd/ [n] ថ្នាំពុលសមាច័យ (ថ្នាំពុលដែលធ្វើឱ្យជាតិពុលក្នុងជាលិកាសត្វ រុក្ខជាតិ និងបរិស្ថានកើនឡើង)
- contact pesticide /ˈkɒntakt ˈpɛstɪsʌɪd/ [n] ថ្នាំទុរករឃាតប៉ះផ្ទាល់ (ថ្នាំពុលដែលសម្លាប់ទុករដោយប៉ះផ្ទាល់)
- inorganic pesticide /ɪnɔːˈɡanɪk ˈpɛstɪsʌɪd/ [n] ថ្នាំសម្លាប់កត្តាចង្រៃអសរីរាង្គ
- non-accumulative pesticide /nɒn əˈkjuːmjʊlətɪv ˈpɛstɪsʌɪd/ [n] ថ្នាំពុលអសមាច័យ (ប្រភេទថ្នាំពុលដែលមិនរក្សាកំណើនជាតិពុលរបស់វាក្នុងកោសិកាសត្វ ឬរុក្ខជាតិ)
- organic pesticide /ɔːˈɡanɪk ˈpɛstɪsʌɪd/ [n] ថ្នាំសម្លាប់កត្តាចង្រៃសរីរាង្គ
- persistent pesticide /pəˈsɪst(ə)nt ˈpɛstɪsʌɪd/ [n] ថ្នាំសត្វឃាតរ៉ាំរ៉ៃ (ថ្នាំកម្ចាត់សត្វល្អិតទាំងឡាយណា ដែលមិនបាត់បង់ភាពពុលរបស់វាក្នុងបរិយាកាសនារយៈពេលយូរ និងមិនងាយបំបែកសមាសធាតុគីមីរបស់វាទៅជាទោល ដោយមីក្រូសារពាង្គកាយ អង់ស៊ីម កម្ដៅ ឬពន្លឺពណ៌ស្វាយ។ វាជាសំណល់ជាតិពុល ដែលបានប្រើប្រាស់ក្នុងមជ្ឈដ្ឋានណាមួយ មិនបាត់បង់ទៅណាទេ ទោះជារាប់សិបឆ្នាំក៏ដោយ។ ឧ. បើបាញ់លើដំណាំ គឺវានៅជាប់ដំណាំ ឬជ្រាបខ្លះចូលក្នុងដំណាំ បើលាងទឹក វាធ្លាក់ជាតិពុលទៅក្នុងទឹក បើកប់ដីវានៅក្នុងដី គឺមិនបំប្លែង ឬបាក់បែកទម្រង់ជាតិពុលនោះឡើយ។)
- selective pesticide /sɪˈlɛktɪv ˈpɛstɪsʌɪd/ [n] ថ្នាំសត្វឃាតជម្រើស (ថ្នាំសម្លាប់ទុករទាំងឡាយដោយមិនបណ្ដាលឱ្យគ្រោះថ្នាក់ដល់សត្វល្អិតមានប្រយោជន៍ទេ (ឧ. វាអាចកម្ចាត់ស្មៅ ប៉ុន្តែមិនមានឥទ្ធិពលលើដំណាំស្រូវទេ))
- systemic pesticide /sɪˈstɛmɪk ˈpɛstɪsʌɪd/ [n] ថ្នាំពុលជ្រាប (ថ្នាំពុលដែលអាចជ្រាបចូលតាមឫស និងផ្នែកខាងលើនៃរុក្ខជាតិ ហើយផ្លាស់ទីកន្លែងនៅក្នុងរុក្ខជាតិ)

**pestle** /ˈpɛs(ə)l/ [n] អង្រែបុក

**pet** /pɛt/ [n] សត្វចិញ្ចឹមលេង

**petal** /ˈpɛt(ə)l/ [n] ស្រទាប់ផ្កា

**petaloid** /ˈpɛt(ə)lɔːd/ [n] ដូចស្រទាប់ផ្កា (អំពីទម្រង់របស់រុក្ខជាតិ)

**petechia** /pɪˈtiːkɪə/ [n] ស្នាមក្រហមអុចៗ

**petiole** /ˈpɛtɪəʊl/ [n]
១. (ចំពោះរុក្ខជាតិ) ធាង, ទងស្លឹក
២. (ចំពោះសត្វល្អិត) ចង្កេះ (ស្រមោច ឃ្មុំ ឱម៉ាល់ជាដើម)

**petit mal epilepsy** /ˈpɛti mal ˈɛpɪlɛpsi/ [n] ការប្រកាច់តែមួយភ្លែត នៃជំងឺឆ្កួតជ្រូកមិនសូវខ្លាំង

**Petri dish** /ˈpɛtri dɪʃ/ [n] ចានបណ្ដុះមីក្រុប, កែវបណ្ដុះមេរោគ, ប្រអប់ប៉េទ្រី, កែវប៉េទ្រី

**petrochemical** /pɛtrə(ʊ)ˈkɛmɪk(ə)l/ [n] ផលិតផលគីមីប្រេងកាត

**petrography** /pɛˈtrɒɡrəfi/ [n] សិលាវិទ្យា

**petrol** /ˈpɛtr(ə)l/ [n] ប្រេងសាំង

**petroleum** /pɪˈtrəʊlɪəm/ [n] ប្រេងកាត

**crude petroleum** /kruːd pɪˈtrəʊlɪəm/ [n] ប្រេងកាតឆៅ

**pH** /piːˈeɪtʃ/ [n] ប៉េហាស់ (តម្លៃលេខ), កម្រិតសម្គាល់អាស៊ីត ឬបាស, កំហាប់ដោយអ៊ីយ៉ុងអ៊ីដ្រូសែន

- pH meter /piːˈeɪtʃ ˈmiːtə/ [n] pH ម៉ែត្រ (ឧបករណ៍ស្ទង់ប៉េហាស់)
- soil pH /sɔɪl piːˈeɪtʃ/ [n] ប៉ូតង់ស្យែលអ៊ីដ្រូសែននៃដី (ប៉េហាសដី)

**phagocyte** /ˈfagə(ʊ)sʌɪt/ [n] កោសិកាស៊ីមេរោគ

**phagotroph** [n] សូមមើលពាក្យ៖ predator

**phalanx** /ˈfalaŋks/ [n] ថ្នាំងម្រាម

**phanerogam** /ˈfan(ə)rə(ʊ)gam/ [n] ផានេរ៉ូកាម

**pharmaceutical** /ˌfɑːməˈs(j)uːtɪk(ə)l/ [adj] នៃឱសថកម្ម, នៃឱសថស្ថាន

**pharmacokinetic profile ofintrahepatic delivery** [n] ការសិក្សាពីភាពជ្រួតជ្រាប និងការបែងចែកក្នុងរូបកាយនៃការផ្តល់ ឬការបង្ហូរតាមថ្លើម

**pharmacy** /ˈfɑːməsi/ [n] ឱសថស្ថាន

**pharyngeal** /fəˈrɪn(d)ʒɪəl/ [adj] នៃបំពង់អាហារផ្នែកខាងលើ, នៃដើមក

**pharyngitis** /ˌfarɪŋˈdʒʌɪtɪs/ [n] ជំងឺរលាកដើមក (បំពង់អាហារ)

**pharyngoscope** [n] គ្រសនីទស្សន៍, ប្រដាប់ឆ្លុះពនិត្យដើមក

**pharynx** /ˈfarɪŋks/ [n] ដើមក, បំពង់អាហារផ្នែកខាងលើ

**phase** /feɪz/ [n] ប្រភេទ (ក្នុងស្រុក)

- climacteric phase /klʌɪˈmakt(ə)rɪk feɪz/ [n] ដង្ហើមសកម្ម, កំណើនដង្ហើម
- death phase /dɛθ feɪz/ [n] វគ្គធ្លាក់ចុះ (ចំពោះវគ្គនៃការលូតលាស់របស់មីក្រូសរីរាង្គ)
- feeding phase /fiːdɪŋ feɪz/ [n] ដំណាក់ស៊ីចំណី
- follicular phase /fɒˈlɪkjʊlə feɪz/ [n] វគ្គផូលីគុល
- lag phase /lag feɪz/ [n] ដំណាក់កាលឈប់ស្រូបទឹក, ដំណាក់កាលឆ្អែតទឹក, ដំណាក់កាលស្ងប់ស្ងៀម។ (ទាក់ទងទៅនឹងដំណុះគ្រាប់ ដំណាក់កាល ក្រោយពីស្រូបទឹក និងមុនពន្លកឬសលូត ចេញមក។ ក្នុងដំណាក់កាលនេះ គ្មានឬ មានការស្រូបទឹកតិចតួចបំផុត និងឃើញ គ្មានឬមានសញ្ញាវិវឌ្ឍន៍តិចតួចណាស់។)
- overwash phase /ˈəʊvəwɒʃ feɪz/ [n] វត្ថុ ឬល្បាប់ដែលនាំមកដោយទឹក ឬខ្យល់
- reproductive phase /ˌriːprəˈdʌktɪv feɪz/ [n] ដំណាក់កាលបន្តពូជ, វគ្គបន្តពូជ
- ripening phase /ˈrʌɪp(ə)nɪŋ feɪz/ [n] វគ្គទុំ (អាយុកាលស្រូវចាប់ពីផ្ការហូតដល់ទុំ)
- soil phase /sɔɪl feɪz/ [n] អនុក្រុមដី
- vegetative phase /ˈvɛdʒɪtətɪv feɪz/ [n] វគ្គលូតលាស់ (វគ្គនៅក្នុងវដ្តជីវិតរបស់រុក្ខជាតិ ចាប់ពីពេលដាំរហូតដល់ដំណាក់កាលកំណកំណើតក្បូរ)

***Phaseolus vulgaris*** [sci.n] សូមមើលពាក្យ៖ snap bean

**pheasant** /ˈfɛz(ə)nt/ [n] សត្វមាន់ទោរ

**phenol** /ˈfiːnɒl/ [n] (សទិសន័យ៖ carbolic acid) ផេណុល

**phenology** /fɪˈnɒlədʒi/ [n] បាតុភូតវិទ្យា, អភិរូបវិទ្យា (ការសិក្សាពីការអភិវឌ្ឍន៍នៃរុក្ខជាតិតាមលក្ខណៈរូបសាស្ត្រក្រោមឥទ្ធិពលនៃកត្តាអាកាសធាតុតាមរដូវដូចជាសីតុណ្ហភាព ឬរយៈពេលពន្លឺថ្ងៃ ជាពិសេសដូចជាការផ្លាស់ប្តូរជះឥទ្ធិពលដល់បាតុភូតរដូវដូចជាចេញស្លឹក ចេញផ្កា និងភាពក្រាំង)

**phenomenon** /fɪˈnɒmɪnən/ [n] បាតុភូត

**phenoperiod** /ˈfiːnəʊ ˈpɪərɪəd/ [n] រយៈពេលនៃបាតុភូត, ថេរវេលានៃបាតុភូត ( ជាពាក្យបង្រួញនៃ phonological period ពោលគឺ រយៈពេលនៃដំណាក់កាលបាតុភូតមួយ ឧ. ដំណាក់ផ្កា។)

**phenotype** /ˈfiːnə(ʊ)tʌɪp/ [n] ផេណូទីប, គំរូទិដ្ឋភាព (លក្ខណៈរូបនៃឯកត្តៈមួយដែលជាលទ្ធផលអន្តរកម្មរវាងសេណូទីប និងបរិស្ថាន)

**phenotypic acceptability** /fiːnə(ʊ)ˈtɪpɪk əksɛptəˈbɪlɪti/ [n] ពិន្ទុលើផេណូទីប (ការវាយតម្លៃទៅលើលក្ខណៈរូបនៃឯកត្តៈទៅតាមលក្ខខណ្ឌ និងតម្រូវការ)

**phenylketonuria** /ˌfiːnʌɪlˌkiːtə(ʊ)ˈnjʊərɪə/ [n] ភាពមិនខ្វោះពីកំណើត ដែលមិនអាចបំបែកជាតិប្រូតេអ៊ីនក្នុងម្ហូប រារាំងដល់ការធំធាត់នៃខួរក្បាល ហើយក៏ក្លាយជាពិការសតិបញ្ញា

***Phidippus* spp.** [sci.n] ពីងពាងលោត

**phlebitis** /flɪˈbʌɪtɪs/ [n] ជំងឺរលាកសរសៃឈាមខ្មៅ

**phlegm** /flɛm/ [n] ស្លេស្ម, សម្បោរ

**phloem** /ˈfləʊɛm/ [n] សរសៃនាំជ័រសុចិត្រ, សរសៃផ្លូអែម

**phneumonia** /njuːˈməʊnɪə/ [n] ការហើមសួត ឬ ជំងឺហើមសួត,ការមានទឹកចូលសួត

**phobia** /ˈfəʊbɪə/ [n] រោគខ្លាច

***Phorbia pilulifera*** [sci.n] សូមមើលពាក្យ៖ garden spurge

**phosphate** /ˈfɒsfeɪt/ [n] ផូស្វាត

- rock phosphate /rɒk ˈfɒsfeɪt/ [n] ថ្មផូស្វាត

**Phosphorus** /ˈfɒsf(ə)rəs/ [n] ផូស្វរ (និមិត្តសញ្ញាគីមី P)

**photogrammetry** /ˌfəʊtə(ʊ)ˈgramɪtri/ [n] ផូតូមាត្រលេខ

**photography** /fəˈtɒgrəfi/ [n] តំហាត, រូបថត

- aerial photography /ˈɛːrɪəl fəˈtɒgrəfi/ [n] រូបថតពីលើអាកាស
- infrared photography /ɪnfrəˈrɛd fəˈtɒgrəfi/ [n] តំហាតរូបដោយប្រើពន្លឺក្រហម

**photoperiod** /ˈfəʊtəʊpɪərɪəd/ [n] រយៈពន្លឺ (ទំនាក់ទំនងនៃប្រវែងថ្ងៃ និងយប់ដែលឆ្លាស់គ្នា ហើយមានឥទ្ធិពលទៅលើភាពលូតលាស់ និងភាពពេញវ័យនៃរុក្ខជាតិ)

- photoperiod insensitive variety /ˈfəʊtəʊpɪərɪəd ɪnˈsɛnsɪtɪv vəˈrʌɪəti/ [n] ពូជអវេទរសនឹងរយៈពន្លឺ, ពូជមិនប្រកាន់រដូវ (ពូជដែលរយៈពន្លឺគ្មានប្រសិទ្ធភាពពេលចេញផ្កា។ ពូជទាំងនោះ អាចដាំដុះបានគ្រប់ពេលវេលា ដែលមានលក្ខខណ្ឌសមស្របសម្រាប់ការលូតលាស់របស់វា។)
- photoperiod sensitive variety /ˈfəʊtəʊpɪərɪəd ˈsɛnsɪtɪv vəˈrʌɪəti/ [n] វេទរសភាពនឹងរយៈពន្លឺ (ដំណើរការ ឬការសិក្សាពីប្រតិកម្មរយៈពន្លឺទៅលើការចេញផ្កា)

**photoperiodism** /fəʊtəʊˈpɪərɪədɪz(ə)m/ [n] រយៈពន្លឺនិយម (ដំណើរការប្រតិកម្មរយៈពន្លឺទៅលើការចេញផ្កា)

**net photosynthesis** /nɛt ˌfəʊtə(ʊ)ˈsɪnθɪsɪs/ [n] រស្មីសំយោគសុទ្ធ (ការស្រូបឧស្ម័នកាបូនិចចូលទៅក្នុងស្លឹក ឧ. រស្មីសំយោគសរុប ដកដង្ហើមចេញ)

**photosynthesis** /ˌfəʊtə(ʊ)ˈsɪnθɪsɪs/ [n] រស្មីសំយោគ, សមានកម្មក្លរ៉ូភីល

**phreatophyte** /frɪˈatəfʌɪt/ [n] រុក្ខជាតិមានឫសដល់ស្រទាប់ទឹកក្នុងដី

**phrenic** /ˈfrɛnɪk/ [adj] នៃឱរប្រាចីរ៍, ជាប់ទាក់ទងចិត្តគំនិត

**phycology** /fʌɪˈkɒlədʒi/ [n] សូមមើលពាក្យ៖ algology

***Phyllanthus distichus*** [sci.n] សូមមើលពាក្យ៖ otaheite gooseberry

***Phyllanthus emblica*** [sci.n] សូមមើលពាក្យ៖ Indian gooseberry

***Phyllanthus niruri*** [sci.n] សូមមើលពាក្យ៖ seed under leaf

***Phyllanthus urinaria*** [sci.n] សូមមើលពាក្យ៖ niruri

**phylliform** /ˈfɪlʌɪtfɔːm/ [adj] រាងជាស្លឹក, ជាស្រទាប់ស្តើងៗ

**phylloclade** /ˈfɪlə(ʊ)kleɪd/ [n] គល់មានតួនាទីជាស្លឹក

**phylloplane** /ˈfɪləʊpleɪn/ [n] ផ្ទៃស្លឹក (ផ្ទៃស្លឹករុក្ខជាតិ)

***Phyllostachys* spp.** [sci.n] សូមមើលពាក្យ៖ bamboo

**opposite phyllotaxis** /ˈɒpəzɪt ˌfɪlə(ʊ)ˈtaksɪs/ [n] ស្លឹកឈម

**phyllotaxy** /ˌfɪlə(ʊ)ˈtaksi/ [n] របៀបតម្រៀបស្លឹកលើមែក

**phylum** /ˈfʌɪləm/ [n] សាខា (ន័យក្នុងចំណាត់ថ្នាក់វិទ្យា) (ចំណាត់ថ្នាក់ សត្វ និងរុក្ខជាតិទៅក្រុម ដែលបង្កើតបានជាចំនួនថ្នាក់ (classes) ជាច្រើន)

**subphylum** /sʌbˈfʌɪləm/ [n] សាខារង

***Physalis angulata*** [sci.n] សូមមើលពាក្យ៖ cutleaf groundcherry

**physical examination** /ˈfɪzɪk(ə)l ɪgˌzamɪˈneɪʃ(ə)n/ [n] ការពិនិត្យរូបកាយ

**physician** /fɪˈzɪʃ(ə)n/ [n] គ្រូពេទ្យ

**physics** /ˈfɪzɪks/ [n] រូបវិទ្យា

- biological physics /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˈfɪzɪks/ [n] រូបវិទ្យាជីវៈ

**physiographic** /ˌfɪzɪəˈgrafɪk/ [n] ក្រាហ្វិកសរីសាស្ត្រ (ដែលទាក់ទង ឬប្រើប្រាស់សេចក្តីអធិប្បាយមួយអំពីធម្មជាតិ ឬអំពីបាតុភូតធម្មជាតិ)

**physiology** /ˌfɪzɪˈɒlədʒi/ [n] សរីរវិទ្យា, សរីរៈសាស្ត្រ, កាយវិទ្យា (វិទ្យាសាស្ត្រសិក្សាពីតួនាទីរបស់សរីរាង្គ)

**phyto-** /ˈfʌɪtəʊ/ [prefix] បុព្វបទមានន័យថា រុក្ខជាតិ

**phytobenthos** /ˈfʌɪtəʊˈbɛnθɒs/ [n] រុក្ខជាតិបង់គូស

**phytochrome** /ˈfʌɪtəkrəʊm/ [n] ជាតិពណ៌ប្រតិកម្មជាមួយពន្លឺ (ជាតិពណ៌ប្រូតេអ៊ីនមួយដែលជាប់ទាក់ទងនឹងប្រតិកម្មពន្លឺ ឧ. ពន្លឺដាស់ឱ្យចេញដំណុះ។ ជាតិពណ៌ប្រតិកម្មពន្លឺមាន២ប្រភេទ Pr និង Pfr ដែលអាចផ្លាស់ប្តូរគ្នាទៅវិញទៅមក ទៅជាប្រភេទណាមួយ ដោយសារឥទ្ធិពលរបស់ពន្លឺ។ Pr ស្រូបយកកាំរស្មីក្រហម ដែលធ្វើឱ្យវាប្រែទៅជា Pfr ហើយ Pfr ស្រូបយកកាំរស្មីក្រហមវែង (far-red) ក៏ប្រែទៅជា Pr។)

**phytogenic** /ˈfʌɪtəʊˈdʒiːnɪk/ [adj] ដែលបង្កើតឡើងដោយរុក្ខជាតិ

**phytoimmunology** /ˈfʌɪtəʊɪmjʊˈnɒlədʒi/ [n] ការសិក្សាពីសមត្ថភាពរបស់រុក្ខជាតិក្នុងការទប់ទល់នឹងជំងឺ

**phytomass** /ˈfʌɪtəʊmas/ [n] រុក្ខម៉ាស, ភីតូម៉ាស

**phytopathology** /ˌfʌɪtəʊpəˈθɒlədʒi/ [n] សូមមើលពាក្យ៖ plant pathology

**phytophage** /fʌɪˈtɒfədʒ/ [n] រុក្ខបរិភោគ (ប្រភេទសត្វដែលស៊ីរុក្ខជាតិជាអាហារ)

**phytoplankton** /ˈfʌɪtəʊˌplaŋ(k)t(ə)n/ [n] ប្លង់តុងរុក្ខជាតិ

**phytosanitary** /ˌfʌɪθəʊˈsanɪt(ə)ri/ [adj] ភូតគាមអនាម័យ (សំដៅលើលក្ខខណ្ឌនៃសក្តានុពលចម្លងរោគពីគ្រាប់ពូជ)

**phytotoxic** /ˌfʌɪtə(ʊ)ˈtɒksɪk/ [adj] ដែលពុលដល់រុក្ខជាតិ (សមាសធាតុដែលពុលដល់ជាលិការុក្ខជាតិ ឧ. ឥទ្ធិពលរបស់ថ្នាំពុល)

**phytotoxicity** /ˌfʌɪtə(ʊ)tɒkˈsɪsɪti/ [n] រុក្ខពុលភាព (រុក្ខជាតិដែលរងគ្រោះ ឬដោយសារជាតិគីមី ឬភ្នាក់ងារដទៃដោយលេចចេញនូវរោគសញ្ញាមួយចំនួនដូចជាមានស្នាមអុចដំបៅ ស្វិត ស្រពោន ក្រិន ឬដើមលូតខុសធម្មតា រមូរ ឬជ្រួញស្លឹកជាដើម)

**phytotoxin** /ˌfʌɪtə(ʊ)ˈtɒksɪn/ [n] រុក្ខពុល (ការបំផ្លាញ ឬការពុលរបស់រុក្ខជាតិដែលបង្កឡើងដោយសារធាតុគីមី ឬសារធាតុដទៃៗទៀត។ រោគសញ្ញាជារួមគឺស្នាមអុចលើស្លឹក ស្លោកស្រពោនស្លឹក ស្លឹកខ្ចី បែកគុម្ពច្រើន និងរមួលច្រើន។)

**pia mater** /ˈpʌɪə ˈmeɪtə/ [n] ស្រោមខួរ

**pica** /ˈpʌɪkə/ [n] ជំងឺខ្វះជាតិអាហារ

**pick** /pɪk/ [v] បេះ (ផ្លែឈើ), រើស

**picker** /ˈpɪkə/ [n] ម៉ាស៊ីនបេះ ឬប្រមូលផល

- fruit picker /fruːt ˈpɪkə/ [n] ម៉ាស៊ីនបេះផ្លែឈើ
- picker corn /ˈpɪkə kɔːn/ [n] ម៉ាស៊ីនប្រមូលផលគ្រាប់ពោត

**pickle** /ˈpɪk(ə)l/ [n] ជ្រក់

**piece** /piːs/ [n] ដុំ, កំណាត់

**piedmont** /ˈpiːdmɒnt/ [n] ជើងភ្នំ

***Piezodorus hybneri*** [sci.n] ស្រឹងសណ្តែកវណ្ណក្រហម

**pig** /pɪg/ [n] (សទិសន័យ៖ hog, swine) ជ្រូក

**piglet** /ˈpɪglət/ [n] កូនជ្រូក

**pigment** /ˈpɪgm(ə)nt/ [n] សារធាតុផ្ទុកពណ៌, ជាតិពណ៌

- blood pigment /blʌd ˈpɪgm(ə)nt/ [n] ជាតិពណ៌ឈាម

**pigskin** /ˈpɪgskɪn/ [n] ស្បែកជ្រូក

**pigsty** /ˈpɪgstʌɪ/ [n] ទ្រុងជ្រូក

**pigweed** /ˈpɪgwiːd/ [n] ផ្ទីបន្លា (ឈ្មោះវិទ្យាសាស្ត្រ *Amaranthus spinosus*)

**pilchard** /ˈpɪltʃəd/ [n] ត្រីផ្លាធូ

**pile up** /pʌɪl ʌp/ [v] គរ

**pile** /pʌɪl/ [n] គំនរ, ពំនូក

- pile of rubbish /pʌɪl ɒvˈ rʌbɪʃ/ [n] គំនរកម្ទេចកំទី (ឧ. ថ្ម ឥដ្ឋ)

**pill** /pɪl/ [n]
១. (សទិសន័យ៖ tablet) ថ្នាំគុលិកា, ថ្នាំគ្រាប់, គ្រាប់ឱសថ
២. (ចំពោះសត្វល្អិត) រោម (ឧ. បាក់តេរី)

**pillpod sandmat** [n] ទឹកដោះខ្លាតូច (ឈ្មោះវិទ្យាសាស្ត្រ *Chamaesyce hirta*)

**pimple** /ˈpɪmp(ə)l/ [n] មុនមុខ

**pine cone** /pʌɪn kəʊn/ [n] ផ្លែស្រល់

**pineapple** /ˈpʌɪnap(ə)l/ [n] ម្នាស់ (ឈ្មោះវិទ្យាសាស្ត្រ *Ananas sativus*)

**pinna** /ˈpɪnə/ [n]
១. កូនស្លឹក
២. ស្លាប, ព្រុយត្រី
៣. ស្លឹកត្រចៀក

**pinnate** /ˈpɪneɪt/ [adj] តម្រៀប (ស្លឹក) ជាលក្ខណៈឆ្លាស់គ្នា

**pinnatifid** /pɪˈneɪtɪfɪd/ [adj] ស្លឹកឆែក, ទម្រង់គែមស្លឹកទម្រង់ស្លាប

**pinnatisect** /pɪˈnætɪˌsɛkt/ [adj] ស្លឹកឆែកជ្រៅ

**pint** /pʌɪnt/ [n] កន្លះលីត្រ

**pipe** /pʌɪp/ [n] បំពង់
- culvert pipe /ˈkʌlvət pʌɪp/ [n] លូទឹក, លូបង្ហូរទឹកស្អុយ
- exhaust pipe /ɪɡˈzɔːst pʌɪp/ [n] ស៊ីម៉ាំង (បំពង់ផ្សែងចលករ)

**pipefish** /ˈpʌɪpfɪʃ/ [n] ពពួកត្រីក្រពើ ស្ថិតនៅក្នុងគ្រួសារ Syngnathidae
- bellybarred pipefish /ˈbɛli bɑːd ˈpʌɪpfɪʃ/ [n] ត្រីក្រពើ (ឈ្មោះវិទ្យាសាស្ត្រ *Hippichthys spicifer*)
- freshwater pipefish /ˈfrɛʃwɔːtə ˈpʌɪpfɪʃ/ [n] ត្រីក្រពើ (ឈ្មោះវិទ្យាសាស្ត្រ *Ichthyocampus carce*)
- long-snouted pipefish [n] ត្រីកាបូ, ត្រីចៃក្រពើ (ឈ្មោះវិទ្យាសាស្ត្រ *Doryichthys boaja*)
- short-tailed pipefish /ʃɔːt teɪld ˈpʌɪpfɪʃ/ [n] ត្រីក្រពើ (ឈ្មោះវិទ្យាសាស្ត្រ *Microphis brachyurus*)

***Piper betle*** [sci.n] សូមមើលពាក្យ៖ betel leaf

***Piper lolot*** [sci.n] សូមមើលពាក្យ៖ lolot pepper

***Piper nigrum*** [sci.n] សូមមើលពាក្យ៖ black pepper

***Piper nigrum*** [sci.n] សូមមើលពាក្យ៖ black pepper

**piperazine** /pʌɪˈpɛrəziːn/ [n] ពីពេរ៉ាស៊ីន (ថ្នាំព្រូន)

**pipette** /pɪˈpɛt/ [n] បំពង់បឺត

**pipit** /ˈpɪpɪt/ [n] សត្វប្រចៀវ

***Pipunculus javanensis*** [sci.n] ពួករុយក្បាលធំ (បរាសិតលើពួកមមាចបំផ្លាញស្លឹក)

***Pipunculus mutillatus*** [sci.n] ពួករុយក្បាលធំ (បរាសិតលើពួកមមាចបំផ្លាញស្លឹក)

**piroplasmosis** /ˌpʌɪrə(ʊ)plazˈməʊsɪs/ [n] ពីរ៉ូប្លាស្មូស

**pisolite** /ˈpɪzəlʌɪt/ [n] ថ្មកំបោរដែលផ្សំដោយគ្រាប់តូចៗ (គ្រាប់ពោត)

***Pistia stratiotes*** [sci.n] សូមមើលពាក្យ៖ water lettuce

**pistil** /ˈpɪstɪl/ [n] សូមមើលពាក្យ៖ carpel
- compound pistil /ˈkɒmpəʊnd ˈpɪstɪl/ [n] កេសរញីសមាស ( កេសរញីមួយផ្គុំឡើងពីខាផល់ (carpel)។ កេសរញី(ក្រោយមកកើតជាផ្លែ)អាចបង្កើតបានជាថត (locules) ច្រើន អាស្រ័យទៅតាមចំនួន របស់ខាផល់ ឬមាន១ថតដែលមានអូវុលច្រើន(ឬគ្រាប់)

**pistillate** /ˈpɪstɪlət/ [adj] មានតែកេសរញី (មានតែសរីរាង្គញីតែប៉ុណ្ណោះ។ ពាក្យនេះអាចប្រើ ចំពោះផ្កាទោល ឬផ្កាកន្សោម ឬចំពោះរុក្ខជាតិដែលមាន ភេទតែមួយនៃពួក angiosperm (រុក្ខជាតិគ្រាប់ជិត)។ កេសរញីប្រមូលផ្តុំគេហៅថាកញ្ចុំកេសរញី (gynoecium)។)

**piston** /ˈpɪst(ə)n/ [n] ពីស្តុង
- piston pin /ˈpɪst(ə)n pɪn/ [n] អ័ក្សពីស្តុង

***Pisum sativum*** [sci.n] សូមមើលពាក្យ៖ pea

***Pisum sativum* var. *saccharatum*** [sci.n] សូមមើលពាក្យ៖ snow pea

**pit** /pɪt/ [n]
១. សូមមើលពាក្យ៖ quarry
២. រណ្តៅ ស្មូងថ្ម, រណ្តៅ
- clay pit /kleɪ pɪt/ [n] ថ្មជាជាតិដីឥដ្ឋ, ថ្មឆ្នួន
- coated pit /kəʊtɪd pɪt/ [n] កំហូងភ្នាស
- frozen pit /ˈfrəʊzn pɪt/ [n] រណ្តៅដែលកក (ត្រជាក់)
- manure pit /məˈnjʊə pɪt/ [n] រណ្តៅជីធម្មជាតិ
- sand pit /sand/ [n] កន្លែងយកខ្សាច់
- stone pit /stəʊn pɪt/ [n] សូមមើលពាក្យ៖ quarry
- turf pit /təːf pɪt/ [n] រណ្តៅទូប ឬពើក

**pitch** /pɪtʃ/ [n] កៅស៊ូក្រាលថ្នល់

**pitcher** /ˈpɪtʃə/ [n] ថូទឹក, ថូស្រា

**pith** /pɪθ/ [n] បណ្តូល, ខ្លឹម (ជាលិកាប៉ារ៉ង់ស៊ីនៅចំកណ្តាលដើម ហើយស្ថិតក្នុងបាច់សរសៃនាំ)

***Pithecellotium dule*** [sci.n] សូមមើលពាក្យ៖ manila tamarind

**pituitary** /pɪˈtjuːɪt(ə)ri/ [n] ក្រពេញពីទ្វីទែ, ក្រពេញបិតនៅក្រោមខួរក្បាល

**pituitary gland** /pɪˈtjuːɪt(ə)ri gland/ [n] ក្រពេញអ៊ីប៉ូភីស

**pivotal** /ˈpɪvətl/ [adj] សំខាន់ខ្លាំង

**placebo** /pləˈsiːbəʊ/ [n] ប្លាសេបូ (ថ្នាំអសកម្ម)

**placement** /ˈpleɪsmənt/ [n] បង្កប់
- deep placement /diːp ˈpleɪsmənt/ [n] បង្កប់ជ្រៅ (វិធីសាស្ត្របាចជីអាសូតដោយផ្ទាល់ដល់ស្រូវនៅក្នុងស្រែ ដោយធ្វើការកប់ជីនោះទៅក្នុងស្រទាប់ដីគ្មានខ្យល់ (ស្រទាប់ដីដែលធ្វើរេដុកម្ម))

**placenta** /pləˈsɛntə/ [n]
១. (ចំពោះសត្វ) (សទិសន័យ៖ afterbirth) សុក
២. (ចំពោះរុក្ខជាតិ) (ពហុវចនៈ៖ placentae) ផ្លាសេនតា (សរីរាង្គដែលផ្ទុក (ភ្ជាប់) អូវុលនៅក្នុងអូវែមួយជារឿយៗ នៅតាមគែមនៃស្លឹកកេសរញី។ ដោយសារតែការវិវត្ត បង្រួញកេសរញីនោះ ប្រភេទផ្លាសេនតាជាច្រើនបាន កើតឡើង ឧ. ផ្លាសេនតានៅបាត ផ្លាសេនតានៅគែម និងនៅកណ្តាលដែលអាចនៅបន្ទប់មួយ ឬច្រើន)

**placentation** /ˌplas(ə)nˈteɪʃ(ə)n/ [n] ជំនាប់
- axillary placentation /akˈsɪləri ˌplas(ə)nˈteɪʃ(ə)n/ [n] ជំនាប់តាមអ័ក្ស (ការជាប់នៃអូវុលនៅជុំវិញអ័ក្សនៃអូវែ ដែលមានថតផ្ទុកអូវុលច្រើន ឧ. ផ្កាលីលី)
- marginal placentation /ˈmɑːdʒɪn(ə)l ˌplas(ə)nˈteɪʃ(ə)n/ [n] ជំនាប់អូវុលតាមគែម (ការភ្ជាប់អូវុលតាមបណ្ដោយនៃអូវែ ឧទាហរណ៍ សណ្ដែក កួរជាពពួករុក្ខជាតិដែលមានជំនាប់អូវុលតាមគែម)

**placentome** /pləˈsɛntəʊm/ [n] ទងសុក

**plagiotrophy** /ˈpleɪdʒɪəʊˈtrəʊfi/ [n] សូមមើលពាក្យ៖ topophysis

**plague** /pleɪg/ [n] មហាភ័យ (ការវាយលុកដោយជំងឺដែល អាចនឹងសម្លាប់មនុស្សជាច្រើននាក់), ជំងឺអាសន្នរោគ, មេរោគសាហាវ, ប៉េស្ត

**plain** /pleɪn/ [n] វាល, ទីវាល, ទំនាប
- alluvial plain /əˈl(j)uːvɪəl pleɪn/ [n] សូមមើលពាក្យ៖ flood plain
- dissected plain /dʌɪˈsɛktɪd pleɪn/ [n] វាលដែលច្រោះ ជាជ្រលង
- flood plain /flʌd pleɪn/ [n] (សទិសន័យ៖ alluvial plain) វាលទំនាបលិចទឹក
- lacustrine flood plain /ləˈkʌstrʌɪn flʌd pleɪn/ [n] ទំនាបមាត់បឹង
- piedmont alluvial plain /ˈpiːdmɒnt əˈl(j)uːvɪəl pleɪn/ [n] វាលល្បាប់លាតសន្ធឹងក្រោមជើងភ្នំ
- stony plain /ˈstəʊni pleɪn/ [n] វាលមានក្រួសច្រើន

**plan** /plan/ [v] ធ្វើផែនការ

**plan** /plan/ [n] ផែនការ, ប្លង់
- breeding plan /ˈbriːdɪŋ plan/ [n] ផែនការបង្កាត់ពូជ, ផែនការជម្រើសពូជ (កាលវិភាគពិស្ដារនៃប្រតិបត្តិការនឹង ត្រូវធ្វើក្នុងគោលបំណងអនុវត្តយុទ្ធសាស្រ្តបង្កាត់ពូជ។)
- development plan /dɪˈvɛləpm(ə)nt plan/ [n] ផែនការអភិវឌ្ឍន៍
- master plan /ˈmɑːstə plan/ [n] ផែនការមេ
- regional plan /ˈriːdʒənl plan/ [n] ផែនការតំបន់
- strategic plan /strəˈtiːdʒɪk plan/ [n] ផែនការយុទ្ធ សាស្រ្ត

**planar** /ˈpleɪnə/ [adj] នៃធរណីមាត្ររបស់ផ្ទៃរាប, រាបស្មើ

**planation** /pləˈneɪʃ(ə)n/ [n] សូមមើលពាក្យ៖ levelling

**plane** /pleɪn/ [n] ផ្ទៃរាប, មុំផ្ទៃ, ដែកឈូស

**plankton** /ˈplaŋ(k)t(ə)n/ [n] ប្លង់តុង
- aerial plankton /ˈɛːrɪəl ˈplaŋ(k)t(ə)n/ [n] សូមមើលពាក្យ៖ aeroplankton
- thalasso plankton [n] ប្លង់តុងសមុទ្រ

**planning** /ˈplanɪŋ/ [n] ផែនការកម្ម, ការធ្វើផែនការ
- economic planning /ˌiːkəˈnɒmɪk ˈplanɪŋ/ [n] ផែនការកម្មសេដ្ឋកិច្ច, ការធ្វើផែនការសេដ្ឋកិច្ច
- environmental planning /ɪnvʌɪrənˈmɛnt(ə)l ˈplanɪŋ/ [n] ផែនការកម្មបរិស្ថាន, ការធ្វើផែនការបរិស្ថាន
- land-use planning /land juːz planɪŋ/ [n] ផែនទី ឬ ផែនការប្រើប្រាស់ដី, គម្រោងប្រើប្រាស់ដី

**plant** /plɑːnt/ [v] ដាំ, ស្ទូង, សាប, ព្រោះ

**plant** /plɑːnt/ [n]
១. រុក្ខជាតិ
២. រោងចក្រ (អគ្គិសនី)
- actinorhizal plant /ˈaktɪnoˈrʌɪz(ə)l plɑːnt/ [n] រុក្ខជាតិផ្តល់ទីជម្រកដល់មីក្រូសារពាង្គកាយអន្តរអំពើ (រុក្ខជាតិដែលបង្កើតនូវទីអាស្រ័យដល់មីក្រូសារពាង្គកាយ អន្តរអំពើ ដែលមានឈ្មោះហ្វ្រេនគីយ៉ា (frankie))
- aerial plant /ˈɛːrɪəl plɑːnt/ [n] សូមមើលពាក្យ៖ aerophyte
- annual plant /ˈanjʊəl plɑːnt/ [n] ឯកវត្សរុក្ខជាតិ (រុក្ខជាតិដែលបញ្ចប់វដ្តជីវិតរបស់ខ្លួនក្នុងមួយឆ្នាំ ឬតិចជាង)
- asthma plant /ˈasmə plɑːnt/ [n] ទឹកដោះខ្លាតូច (ឈ្មោះវិទ្យាសាស្ត្រ *Chamaesyce hirta*)
- carnivorous plants /kɑːˈnɪv(ə)rəs plɑːntz/ [n pl] រុក្ខជាតិស៊ីសត្វល្អិត

- carpellate plant /ˈkɑːp(ə)leɪt plɑːnt/ [n] រុក្ខជាតិញី
- chameleon plant /kəˈmiːlɪən plɑːnt/ [n] ជីរថ្គាល់ត្រី
- creeping cradle plant /kriːpɪŋ ˈkreɪd(ə)l plɑːnt/ [n] ស្មៅចំពុះទា (ឈ្មោះវិទ្យាសាស្ត្រ *Cyanotis axillaris*)
- cross pollinated plant /krɒs ˈpɒlɪneɪtɪd plɑːnt/ [n] រុក្ខជាតិចរលម្អងបង្កាត់ (ប្រភេទរុក្ខជាតិដែលទទួលលម្អងពីរុក្ខជាតិផ្សេងក្នុងការធ្វើពហុពលកម្ម)
- day neutral plant /deɪˈnjuːtr(ə)l plɑːnt/ [n] រុក្ខជាតិណឺតថ្ងៃ (រុក្ខជាតិដែលមិនទទួលរងឥទ្ធិពលពីរយៈពេលថ្ងៃ)
- desalination plant /ˌdiːsalɪˈneɪʃ(ə)n plɑːnt/ [n] រោងចក្របិតទឹកសមុទ្រឱ្យទៅជាទឹកសាប (ឧ. នៅប្រទេសនៅតំបន់មជ្ឈឹមបូព៌ា)
- disposal plant /dɪˈspəʊz(ə)l plɑːnt/ [n] រោងចក្រកែច្នៃសំណល់
- effluent treatment plant /ˈɛflʊənt ˈtriːtm(ə)nt plɑːnt/ [n] រោងចក្រសម្អាតសំណល់រាវ
- egg plant /ɛg plɑːnt/ [n] (សទិសន័យ៖ aubergine) ត្រប់វែង (ឈ្មោះវិទ្យាសាស្ត្រ Solanum melongena)
- electric power plant /ɪˈlɛktrɪk ˈpaʊə plɑːnt/ [n] រោងចក្រអគ្គិសនី
- graft plant /grɑːft plɑːnt/ [n] រុក្ខជាតិបំបៅ, រុក្ខជាតិផ្សាំ
- host plant /həʊst plɑːnt/ [n] រុក្ខជាតិជម្រក (ជម្រកឆ្លាស់របស់សត្វល្អិតដែលអាចការពារខ្លួន អាស្រ័យនឹងការស្នាក់នៅពីកន្លែងមួយទៅកន្លែងមួយ ព្រមទាំងបង្កើតកូនចៅដើម្បីធ្វើការបំផ្លាញទៀត)
- hydroelectric plant /hʌɪdrəʊɪˈlɛktrɪk plɑːnt/ [n] រោងចក្រវារីអគ្គិសនី
- industrial waste treatment plant /ɪnˈdʌstrɪəl weɪst ˈtriːtm(ə)nt plɑːnt/ [n] រោងចក្រប្រព្រឹត្តិកម្មសំណល់ឧស្សាហកម្ម
- light demanding plant /lʌɪt dɪˈmɑːndɪŋ plɑːnt/ [n] រុក្ខជាតិដែលត្រូវការពន្លឺខ្លាំងដើម្បីដុះលូតលាស់ (ដូចជាប្រភេទស្រល់ស្លឹកពីរ *Pinus spp.* ដែលត្រូវការពន្លឺខ្លាំង)
- medicinal plant /mɪˈdɪsɪn(ə)l plɑːnt/ [n] រុក្ខជាតិឱសថ, រុក្ខោសថ (ប្រភេទរុក្ខជាតិអាចយកធ្វើថ្នាំព្យាបាល)
- nonvascular plant /nɒnˈvaskjʊlə plɑːnt/ [n] រុក្ខជាតិគ្មានសរសៃនាំ
- nuclear power plant /ˈnjuːklɪə ˈpaʊə plɑːnt/ [n] រោងចក្រអគ្គិសនីបរមាណូ
- ornamental plant /ɔːnəˈmɛnt(ə)l plɑːnt/ [n] រុក្ខជាតិលម្អ (រុក្ខជាតិដែលប្រើប្រាស់សម្រាប់ការតែងលម្អដូចជាសួនច្បារ និងតាមផ្លូវ)
- perennial plant /pəˈrɛnɪəl plɑːnt/ [n] រុក្ខជាតិពហុវស្ស (រុក្ខជាតិដែលអាចរស់នៅលើសពីមួយឆ្នាំឡើងទៅ (ឧ. ប្រភេទស្រង៉ៃខ្លះ ដើមឈើធំៗ))
- petroleum chemical plant /pɪˈtrəʊlɪəm ˈkɛmɪk(ə)l plɑːnt/ [n] រោងចក្រគីមីប្រេងកាត
- pistillate plant /ˈpɪstɪlət ˈbriːdɪŋ/ [n] រុក្ខជាតិញី
- plant establishment /plɑːnt ɪˈstablɪʃm(ə)nt/ [n] ការដាំដុះរុក្ខជាតិ
- plant introduction /plɑːnt ˌɪntrəˈdʌkʃ(ə)n/ [n] រុក្ខជាតិនាំចូល
- plywood manufacturing plant /ˈplʌɪwʊd manjʊˈfaktʃərɪŋ/ [n] រោងចក្រក្តារបន្ទះ
- power plant /ˈpaʊə plɑːnt/ [n] រោងចក្រអគ្គិសនី
- rice plant /rʌɪs plɑːnt/ [n] ស្រូវ (ពេញមួយតួដើម)
- self pollinated plant /sɛlf ˈpɒlɪneɪtɪd plɑːnt/ [n] រុក្ខជាតិស្វ័យចរលម្អង (ប្រភេទរុក្ខជាតិដែលប្រើលម្អងខ្លួនឯងក្នុងការធ្វើពហុពលកម្ម)
- sensitive plant /ˈsɛnsɪtɪv plɑːnt/ [n] ព្រះខ្លប, មក្លប (ឈ្មោះវិទ្យាសាស្ត្រ *Mimosa pudica*)
- sewage disposal plant /ˈsuːɪdʒ dɪˈspəʊz(ə)l plɑːnt/ [n] រោងចក្រសម្អាតទឹកលូសម្អុយ
- short day plant /ʃɔːt deɪ plɑːnt/ [n] រុក្ខជាតិពេលថ្ងៃខ្លី (រុក្ខជាតិដែលចេញផ្កាតែនៅពេលដែលរយៈពេលថ្ងៃខ្លីជារយៈពេលកំណត់)
- solar power plant /ˈsəʊlə ˈpaʊə plɑːnt/ [n] រោងចក្រអគ្គិសនីដើរដោយថាមពលព្រះអាទិត្យ
- spore plant /spɔː plɑːnt/ [n] រុក្ខជាតិបន្តពូជដោយស្ប៉ (ក្រុមនៃរុក្ខជាតិថ្នាក់ទាប ដែលលក្ខណៈសំខាន់របស់វាគឺការបន្តពូជដោយស្ប៉មានស្លាប។ ស្ប៉ជាអាប្លូអ៊ីត ហើយដុះទៅជាកាម៉េតតូហ្វីត អាប្លូអ៊ីតដែលនៅក្នុងក្រុមនេះគឺជាពួករុក្ខជាតិឯករាជ្យ (ដែលមិនពឹងពាក់គ្នាទៅវិញទៅមក)។ ពួករុក្ខជាតិស្ប៉ រួមមានពួកស្លែ និងបណ្ណង្គជាតិ។)
- staminate plant /ˈstamɪnət plɑːnt/ [n] រុក្ខជាតិឈ្មោល
- stool plant /stuːl plɑːnt/ [n] រុក្ខជាតិត្រូវបានកាត់តម្រឹម
- thermal plant /ˈθəːm(ə)l plɑːnt/ [n] រោងចក្រអគ្គិសនីដើរដោយកម្តៅ

- treatment plant /ˈtriːtm(ə)nt plɑːnt/ [n] រោងចក្រប្រព្រឹត្តិកម្មសម្អាត
- vascular plant /ˈvaskjʊlə plɑːnt/ [n] រុក្ខជាតិសរសៃនាំ (មានជាលិកាឯកទេសសម្រាប់ដឹកនាំអាហារ និងទឹក)
- volunteer plant /ˌvɒlənˈtɪə plɑːnt/ [n] រុក្ខជាតិដុះម្សូរ (ពពួករុក្ខជាតិ ដែលដុះដោយមិនចាំបាច់ដាំ ហើយដែលជាទូទៅ ជាគ្រាប់ដែលនៅសេសសល់ពីរដូវ ឬឆ្នាំមុន)
- waste-to-energy plant /weɪst tə ˈɛnədʒi plɑːnt/ [n] រោងចក្រអគ្គិសនីដើរដោយសំណល់
- water treatment plant /ˈwɔːtə ˈtriːtm(ə)nt plɑːnt/ [n] រោងចក្រសម្អាតទឹក

***Plantago major* var. *asiatica*** [sci.n] ស្លាបប្រវា

**plantar wart** /ˈplantə wɔːt/ [n] សាច់ដុះនៅបាតជើង

**plantation** /planˈteɪʃ(ə)n/ [n] ចម្ការដំណាំធំៗ

- clonal plantation /ˈkləʊn(ə)l planˈteɪʃ(ə)n/ [n] ចម្ការដាំពីកូនបំបៅ (ចម្ការឈើមួយ (ក្រុមពូជផលិតឈើ) ត្រូវបានដាំពីកូនឈើមែកបំបៅ (ឧ. ពីការកាត់មែកឬកូនឈើបណ្តុះពីជាលិកា។ ចម្ការឈើដាំមែកបំបៅ/ផ្សាំអាចផ្សំឡើងពីកូនក្លូនជាច្រើនគ្រួសារ។)
- compact plantation /kəmˈpakt planˈteɪʃ(ə)n/ [n] ចម្ការស្អុក (រួមបញ្ចូលទាំងរុក្ខជាតិធំ និងតូច ដែលដុះលូតលាស់ ជាប្រព័ន្ធរៀបរយ និងទៀងទាត់។ រុក្ខជាតិ ដើមឈើដែលដុះលូតលាស់មិនទៀងទាត់ និងមិនតាមរបៀបរៀបរយ ប៉ុន្តែអាចឱ្យចូលទៅប្រមូលទិន្នន័យបាននៅក្នុងតំបន់នោះក៏ត្រូវបានចាត់ជាចម្ការស្អុក)
- forest plantation /ˈfɒrɪst planˈteɪʃ(ə)n/ [n] (សទិសន័យ៖ forestry planting) ចម្ការឈើដាំ (ដើមឈើឈរ ដែលត្រូវបានបង្កើតដោយការដាំ ឬបាចគ្រាប់ដោយមនុស្ស)
- rubber plantation /ˈrʌbə planˈteɪʃ(ə)n/ [n] ចម្ការកៅស៊ូ

**planting** /plɑːntɪŋ/ [n] ការដាំ

- forestry planting /ˈfɒrɪstri plɑːntɪŋ/ [n] សូមមើលពាក្យ៖ forest plantation
- staggered planting /ˈstagərd plɑːntɪŋ/ [n] ការដាំបណ្តាក់
- strip planting /strɪp plɑːntɪŋ/ [n] (សទិសន័យ៖ field strip cropping, strip cropping) ដាំឆ្នូត (វិធីសាស្ត្រដាំដុះមួយដែលដំណាំត្រូវបានដាំជាចង្អូរៗ)

**plantlet** /plɑːntlɛt/ [n] កូនរុក្ខជាតិតូច (កូនរុក្ខជាតិតូចដែលបានមកពីការបណ្តុះចេញពីជាលិកា (micropropagation /tissue culture))

**plasma** /ˈplazmə/ [n] ប្លាស្មា, ទឹកឈាម, ទឹកគ្មានកោសិកាជាផ្នែកនៃឈាមរត់

**plastic** /ˈplastɪk/ [n] ប្លាស្ទិច, ជ័រ, ដែលអាចសូនជារូបបាន

**plasticine** /ˈplastɪsiːn/ [n] ដីមានជាតិប្រេង

**plasticity** /plaˈstɪsɪti/ [n] ភាពបត់បែន

- morphological plasticity /mɔːfəˈlɒdʒɪk(ə)l plaˈstɪsɪti/ [n] ការប្រែប្រួលរូបរាង
- phenotypic plasticity /fiːnə(ʊ)ˈtɪpɪk plaˈstɪsɪti/ [n] ភាពប្រែប្រួលលក្ខណៈ (កម្រិតដែលផេណូទីបឬ phenotype (ភាពងាយរងឥទ្ធិពល) មានចំពោះការផ្លាស់ប្តូរបរិស្ថានខុសប្លែកគ្នាក្នុងចំណោមស៊ីណូទីប)
- phenotypic plasticity /fiːnə(ʊ)ˈtɪpɪk plaˈstɪsɪti/ [n] ភាពបត់បែនបាននៃផេណូទីប (សមត្ថភាពនៃសារពាង្គកាយមួយ ក្នុងការបន្សាំទៅនឹងបរិស្ថានដែលប្រែប្រួលតាមរយៈការប្រែប្រួលផេណូទីបរបស់វាដោយគ្មានកែប្រែសេណូទីបរបស់វា)

**plateau** /ˈplatəʊ/ [n] ខ្ពង់រាប

- barren limestone plateau /ˈbar(ə)n ˈlʌɪmstəʊn ˈplatəʊ/ [n] ខ្ពង់រាបជាសារធាតុកំបោរ
- table-land plateau /ˈteɪb(ə)l land ˈplatəʊ/ [n] ខ្ពង់រាប

**platelet** /ˈpleɪtlɪt/ [n] គោលិកាដែលគ្មានអេម៉ូក្លូប៊ីន

**platform** /ˈplatfɔːm/ [n] ថ្នាក់រាប, ឈ្នាន់, ឆាក

- continental platform /kɒntɪˈnɛnt(ə)l ˈplatfɔːm/ [n] សូមមើលពាក្យ៖ continental shelf

**dilution plating** /dʌɪˈluːʃn ˈpleɪtɪŋ/ [n] ការបណ្តុះដោយពង្រាវ (មីក្រុប)

**Platinum** /ˈplatɪnəm/ [n] ប្លាទីន (និមិត្តសញ្ញាគីមី Pt)

**platyhelminth** /ˌplatɪˈhɛlmɪnθ/ [n] ដង្កូវសំប៉ែត

***Plautia affinis*** [sci.n] ស្រឹងស្អុយស្លាបពណ៌ត្នោត

**playa** /ˈplʌɪə/ [n] ដីរាបស្មើ ស្ងួត ជាញឹកញាប់ជាដីប្រៃក្នុងតំបន់ក្តៅស្ងួត

**pleach** /pliːtʃ/ [v] ត្បាញ, ក្រង

**pleat** /pliːt/ [n] ផ្នត់

**pleat** /pliːt/ [v] ធ្វើឱ្យមានផ្នត់

**plectoamictic** [adj] មីក្រូទម្រង់ដែលស៊ីម៉ង់កូឡូអ៊ីតមានភាពច្របូកច្របល់គ្នា

**Pleistocene** /ˈplʌɪstəsiːn/ [n] ប្លេស្តូសែន

**pleura** /ˈplʊərə/ [n] ស្រោមសួត

**pleural cavity** /ˈplʊərəl ˈkavɪti/ [n] ចន្លោះរវាងស្រោមសួត

**pleurisy** /ˈplʊərɪsi/ [n] ជំងឺរលាកស្រោមសួត

**pleurogram** /ˈplʊərəʊgram/ [n] ស្នាមជើងក្រចកសេះ (ខ្សែបន្ទាត់មួយរាងដូចជើងក្រចកសេះដែលឃើញច្បាស់លើគ្រាប់ប្រភេទសណ្តែក ឧ. ប្រភេទពូជ Acacia និង Albizia)

**Pleurovac-drain chest tube** [n] ភ្លូវ៉ាកម្ពែ (បំពង់ ឬទុយ៉ូ) ចំរោះទឹកពីដើមទ្រូង

**pliers** /ˈplʌɪəz/ [n] ដង្កាប់

**plinthile** /plɪnθʌɪl/ [n] ថ្មបាយក្រៀម, ក្រួសបាយក្រៀម

**ploidy** /ˈplɔɪdi/ [n] ប្លូអ៊ីត

**plot** /plɒt/ [n] ឡូត៍គំរូ
- demonstration plot /dɛmənˈstreɪʃ(ə)n plɒt/ [n] កន្លែងធ្វើបង្ហាញ

***Plotosus canius*** [sci.n] ត្រីអណ្តែងទន្លេ

***Plotosus lineatus*** [sci.n] ត្រីអណ្តែងទន្លេ

**plough in** /plaʊ ɪn/ [v] ភ្ជួរកប់ ឬលុប

**plough** /plaʊ/ [v] (សទិសន័យ៖ plow) ភ្ជួរ

**plough** /plaʊ/ [n] (សទិសន័យ៖ plow) នង្គ័ល, ការភ្ជួរ
- chisel plough /ˈtʃɪz(ə)l plaʊ/ [n] នង្គ័លស្លាប (នង្គ័លមានស្លាបសងខាង ហើយភ្ជួរមិនត្រឡប់ដី)
- disc plough /dɪsk plaʊ/ [n] នង្គ័លថាស (នង្គ័លភ្ជួរដែលភ្ជាប់នឹងម៉ាស៊ីនត្រាក់ទ័រ)
- four-furrow plough /fɔːˈfʌrəʊ plaʊ/ [n] ត្រាក់ទ័រភ្ជួរដីដែលមានផាលបួន
- mouldboard plough /ˈməʊl(d)bɔːd plaʊ/ [n] នង្គ័លភ្នាង
- offset disc plough /ˈɒfsɛt dɪsk plaʊ/ [n] រនាស់ថាស (រនាស់ប្រើថាសស្រដៀងនឹងនង្គ័លថាសដែរ តែរនាស់មានថាស ២ជួរ)
- reversible plough /rɪˈvəːsɪb(ə)l plaʊ/ [n] ការភ្ជួរត្រឡប់
- seven-disc plough /ˈsɛv(ə)n dɪsk plaʊ/ [n] នង្គ័លថាស ៧
- three-disc plough /θriː dɪsk plaʊ/ [n] នង្គ័លថាស ៣
- two-disc plough /tuː dɪsk plaʊ/ [n] នង្គ័លថាស ២

**ploughpan** /plaʊpan/ [n] (សទិសន័យ៖ plowpan) ស្រទាប់ដីហាប់ដែលនៅក្រោមបាតនង្គ័ល

**ploughshare** /ˈplaʊʃɛː/ [n] ផាលនង្គ័ល

**plow** /plaʊ/ [n US] សូមមើលពាក្យ៖ plough

**plow** /plaʊ/ [v US] សូមមើលពាក្យ៖ plough

**ploughing (plowing)** /plaʊɪŋ/ [n] ការភ្ជួរដី (១. ធ្វើឱ្យដីមានរាងជាគន្លងធ្វើការ បំបែកដី និងត្រលប់ចុះឡើង ២. កាត់អ្វីមួយ កាត់អ្វីមួយតាមរយៈការភ្ជួរ ៣. ធ្វើការសម្អាត ភ្ជួរសម្អាតព្រិល ដែលគ្របនៅលើផ្លូវ ៤. ការដាំអ្វីមួយនៅក្រោមដី ការដាក់ ដូចជាជី ឬ ដំណាំ ដោយប្រើប្រាស់ការភ្ជួរ)
- contour plowing /ˈkɒntʊə plaʊɪŋ/ [n] ការភ្ជួរកាត់ទទឹង

**plowpan** /plaʊpan/ [n] សូមមើលពាក្យ៖ ploughpan

**plucking** /plʌkin/ [n] ការចិត ឬការកាប់ដោយផ្ទាំងទឹកកក, ការរំជួលដោយផ្ទាំងទឹកកក, ការផ្តាច់ដីដោយទឹកកក

**plumber** /ˈplʌmə/ [n] ជាងបំពង់, ជាងទុយោ

**plumed cockscomb** /ˈplʌm ˈkɒkskəʊm/ [n] ស្មៅសិរមាន់ព្រៃ (ឈ្មោះវិទ្យាសាស្ត្រ *Celosia argentea*)

***Plumeria acutifolia*** [sci.n] ផ្កាចំប៉ីស, ក្រហម

**plumule** /ˈpluːmjuːl/ [n] ពន្លកស្លឹក, ពន្លកត្រួយ (ត្រួយរបស់អំប្រីយ៉ុងដែលចេញពីអេពិខកធីល(epicotyl)។ នៅក្នុងគ្រាប់ dicotyledon វាស្ថិតនៅចន្លោះកូទីលេដុង dicotyledon)

**pluralism** /ˈplʊər(ə)lɪz(ə)m/ [n] ចម្រុះនិយម

**plus** /plʌs/ [adj] ល្អ, វិជ្ជមាន (ការលេចឡើងលក្ខណៈល្អលើមធ្យម។ ពាក្យនេះ ត្រូវគេប្រើសម្រាប់ពិពណ៌នាផេណូទីបរបស់ព្រៃឈើ(ព្រៃឈើវិជ្ជមាន) និងដើមឈើតែមួយ (ដើមវិជ្ជមាន)។ លក្ខណៈល្អលើសគេ ត្រូវបានគេបញ្ជាក់ ពោលគឺវិជ្ជមាន(ល្អ)ខាងមាឌគុណភាព ធន់នឹងជំងឺ ឬការផ្សំឡើងរបស់លក្ខណៈ។)

**Plutonium** /pluːˈtəʊnɪəm/ [n] ពុយតូញ៉ូម (និមិត្តសញ្ញាគីមី Pu)

**ply** /plʌɪ/ [v] កៀប, បិត, តម្បូត, ប្រកប

**plywood** /ˈplʌɪwʊd/ [n] ក្តារកុងប្លាកេ, ក្តាបន្ទះ (ផលិតផលដែលបានមកពីការបិតស្រទាប់ឈើស្តើងជាប់គ្នា)

**pneumatophore** /ˈnjuːmətəfɔː/ [n] ឫសដង្ហើម

**pneumo-** /ˈnjuːməʊ/ [prefix] (សទិសន័យ៖ lungs) បុព្វបទមានន័យថា សួត

**pneumococcus** /ˌnjuːmə(ʊ)ˈkɒkəs/ [n] មេរោគធ្វើឱ្យរលាកប្រព័ន្ធសួត

**pneumonia** /njuːˈməʊnɪə/ [n] ជំងឺហើមសួត, រោគទឹកចូលសួត

**pneumothorax** /ˌnjuːmə(ʊ)ˈθɔːraks/ [n] (សូមមើលពាក្យ៖ aerothorax) ដំណើរកើតខ្យល់ក្នុងស្រោមសួត

**Poaceae** [n] សូមមើលពាក្យ\៖ gramineae

**poach** /pəʊtʃ/ [v] បរបាញ់, ស្ងោរ

**poacher** /ˈpəʊtʃə/ [n] អ្នកលួចបរបាញ់ដោយលួចលាក់

**pod** /pɒd/ [n] ផ្លែស្ងួត (ដែលប្រេះបែក), ផ្លែ ឬក្តួរ (ជាផ្លែដែលមានគ្រាប់តម្រៀបគ្នាជាជួរ ឬក្តួរ ឧ. គ្រួសារសណ្តែក)

**podiatry** /pə(ʊ)ˈdʌɪətri/ [n] ការព្យាបាលប្រអប់ជើង

**podium** /ˈpəʊdɪəm/ [n] វេទិកា

**pododermatitis** /ˈpəʊdəʊˌdəːməˈtʌɪtɪs/ [n] រលាកស្បែកគល់ក្រចកជើង

**podzol** /ˈpɒdzɒl/ [n] (សទិសន័យ៖ bleached earth) ដីសាកពណ៌សម្បុរស្លាំង, ប៉ូតសូល (ដី)

- alkaline podzol /ˈalkəlʌɪn ˈpɒdzɒl/ [n] (សទិសន័យ៖ grey sodic soil) ដីប្រផេះខ្មៅដែលមានសូដ្យូមច្រើន
- ambiguous podzol /amˈbɪgjʊəsˈpɒdzɒl/ [n] ប៉ុដហ្សូល មិនច្បាស់លាស់
- beginning podzol /bɪˈgɪnɪŋ ˈpɒdzɒl/ [n] ដីប៉ុដហ្សូលដែលទើបតែចាប់ផ្តើមកំណើត
- gley-podzol /gleɪ ˈpɒdzɒl/ [n] ដីប៉ុដហ្សូលជាំទឹកដោយទឹកដែលមានគ្លេជាសញ្ញា (ឥដ្ឋខៀវប្រផេះ)
- groundwater podzol /ˈgraʊn(d)wɔːtə pɒdzɒl/ [n] ដីអាស៊ីតប៉ូតសូលិក ដែលមានស្រទាប់ទឹកខាងក្រោម
- humic podzol /ˈhjuːmɪkˈpɒdzɒl/ [n] ប៉ុដហ្សូលដែលខាងក្រោមគ្មានស្រទាប់ដែក មានតែស្រទាប់មមោក
- iron podzol /ˈʌɪən ˈpɒdzɒl/ [n] ដីប៉ុដហ្សូលដែលខាងក្រោមមានស្រទាប់ដែកតែគ្មានមមោក, ប៉ុដហ្សូលដែក
- iron-humic podzol /ˈʌɪən ˈhjuːmɪk ˈpɒdzɒl/ [n] ដីប៉ុដហ្សូលដែលខាងក្រោមមានស្រទាប់មមោកលើស្រទាប់ដែក
- meadow podzol /ˈmɛdəʊ ˈpɒdzɒl/ [n] ដីប៉ុដហ្សូលនៅលើវាលស្មៅសើម
- organic gley-podzol /ɔːˈganɪk gleɪˈpɒdzɒl/ [n] ដីប៉ុដហ្សូលប្រភេទឥដ្ឋហើយសរីរាង្គច្រើន
- peat podzol /piːt ˈpɒdzɒl/ [n] ដីប៉ុដហ្សូលពើក ឬតួប (ដីដែលមានស្រទាប់ពើកខាងលើក្រាស់)
- regular podzol /ˈrɛgjʊlə ˈpɒdzɒl/ [n] ដីប៉ុដហ្សូលធម្មតា
- salt earth podzol /sɔːlt əːθˈ pɒdzɒl/ [n] សូមមើលពាក្យ៖ steppe bleached earth
- sandy podzol /ˈsandiˈpɒdzɒl/ [n] ដីប៉ុដហ្សូលដែលជាដីខ្សាច់
- secondary podzol /ˈsɛk(ə)nd(ə)ri ˈpɒdzɒl/ [n] ដីមីក្រូប៉ូតសូលិកថ្មីមួយដែលកំពុងកកើតលើដីចាស់
- sod podzol /sɒdˈpɒdzɒl/ [n] ប៉ុដហ្សូលគ្លេជាំទឹក ដែលស្រទាប់លើបង្អស់ជាស្រទាប់មមោកក្រាស់ហើយច្រើន
- true podzol /truːˈpɒdzɒl/ [n] ដីប៉ុដហ្សូលពិតប្រាកដ
- waterlogged gley podzol /ˈwɔːtəlɒg gleɪ ˈpɒdzɒl/ [n] ដីប៉ុដហ្សូលជាំទឹកដោយទឹកនៅនឹងថ្កល់មិនហូរសោះ
- wet podzol /wɛtˈpɒdzɒl/ [n] ដីប៉ុដហ្សូលសើម

**podzolic** /ˈpɒdzɒlɪk/ [n] ដីប៉ុដហ្សូលលិក

**podzolisation** /ˈpɒdzɒlʌɪseɪʃ(ə)n/ [n] ប៉ុដហ្សូលកម្ម

**podzolised** /ˈpɒdzɒlʌɪs/ [adj] ដែលទទួលបានបាតុភូតប៉ុដហ្សូលកម្ម (កំពុងក្លាយជាប៉ុដហ្សុល)

**poikilotherm** /ˈpɔɪkɪlə(ʊ)ˌθəːm/ [n] សត្វអថេរកម្តៅ

**point** /pɔɪnt/ [n] ចំនុច, គំនិត

- assembly point /əˈsɛmbli pɔɪnt/ [n] កន្លែងប្រមូលផ្តុំ
- boiling point /bəʊltɪŋ pɔɪnt/ [n] ចំណុចរំពុះ
- $CO_2$ compensation point /ˌsiːˈəʊ tuː kɒmpɛnˈseɪʃ(ə)n pɔɪnt/ [n] ចំណុចសមមូលឧស្ម័នកាបូនិច
- dew point /ˈdjuː pɔɪnt/ [n] ចំណុចឆ្អែតសំណើម (ចំណុចសីតុណ្ហភាពនៅក្នុងកម្រិតសំណើម១០០%(ឆ្អែត) ហើយទឹកករទៅជាញើសពេលសីតុណ្ហភាពធ្លាក់ចុះបន្តទៀត)
- growing point /grəʊwɪŋ pɔɪnt/ [n] ចំណុចលូតលាស់ (ជាលិកាលូតលាស់ នៅផ្នែកចុងនៃដើមរុក្ខជាតិ ធ្វើឱ្យដើមលូតប្រវែង)
- interpolated data point /ɪnˈtəːpəleɪtɪd ˈdatəˌpoint/ [n] ចំនុចកម្ពស់ទឹកភ្លៀង
- ligh compensation point /lʌɪt kɒmpɛnˈseɪʃ(ə)n pɔɪnt/ [n] ចំណុចស្មើនៃពន្លឺ (កម្រិតពន្លឺដែលរស្មីសំយោគស្មើនឹងដង្ហើម)

- melting point /mɛltɪŋ pɔɪnt/ [n] ចំណុចរលាយ

**poison** /ˈpɔɪz(ə)n/ [n] ជាតិពុល, ថ្នាំពុល

**poisonous** /ˈpɔɪzənəs/ [adj] ដែលពុល

**polarity** /pə(ʊ)ˈlarɪti/ [n] ការរក្សាទិស (លក្ខខណ្ឌដែលផ្នែកនានារបស់រុក្ខជាតិរក្សាទិសក្នុងលំហរបស់វា នៅពេលដែលវាដុះបំបែកចេញពីដើមមេ។ បាតុភូត នេះមានសារសំខាន់ណាស់ ក្នុងការងារបណ្តុះកូនឈើដោយកាត់មែក និងផ្សាំមែក។)

***Polianthes tuberosa*** [sci.n] សូមមើលពាក្យ៖ tuberose

**policy** /ˈpɒlɪsi/ [n] គោលនយោបាយ, នយោបាយ, ច្បាប់, គោលការណ៍

- common agricultural policy (CAP) /ˈkɒmən agrɪˈkʌltʃərəlˈpɒlɪsi/ [n] នយោបាយកសិកម្មទូទៅ
- conservation policy /kɒnsəˈveɪʃ(ə)n ˈpɒlɪsi/ [n] នយោបាយអភិរក្សបរិស្ថាន
- environmental policy /ɪnvʌɪrənˈmɛnt(ə)l ˈpɒlɪsi/ [n] នយោបាយបរិស្ថាន

**polio** /ˈpəʊlɪəʊ/ [n] ជំងឺខ្វិន

**poliomyelitis** /ˌpəʊlɪəʊmʌɪəˈlʌɪtɪs/ [n] ជំងឺខ្វិនកូនក្មេង

**wind polishing** /wind ˈpɒlɪʃɪŋ/ [n] ការធ្វើឱ្យរលោងដោយកម្លាំងខ្យល់

**economic politic** /ˌiːkəˈnɒmɪk ˈpɒlɪtɪk/ [n] នយោបាយសេដ្ឋកិច្ច

**pollen** /ˈpɒlən/ [n] លម្អង (ស្ព័រតូចៗ (microspores) របស់រុក្ខជាតិមានគ្រាប់ ដែលផលិតចំនួនយ៉ាងច្រើននៅក្នុងផ្នែកឈ្មោលរបស់ផ្កា (កញ្ចុំកេសរឈ្មោល) ឬ strobili។ ប្រភេទពូជរោយលម្អងតាមខ្យល់ មានលក្ខណៈផលិតលម្អងច្រើននិង ស្រាល(រុក្ខជាតិស្លឹកម្ជុលជាធម្មតាលម្អងវាមានស្លាប)។ ប្រភេទរោយលម្អងតាមសត្វ ជាធម្មតាលម្អងវាមានជាតិស្អិតម៉្យាង។)

- pollen basket /ˈpɒlən ˈbɑːskɪt/ [n] ថង់លម្អង
- pollen chamber /ˈpɒlən ˈtʃeɪmbə/ [n] បន្ទប់លម្អង (នៅក្នុងប្រភេទរុក្ខជាតិគ្រាប់ស្រាត កំលាយមួយនៃចុង megasporangium ដែលទទួលលម្អង ហើយនៅក្នុងនោះលម្អងនៅសម្ងំរហូតដល់មានការបង្កកំណើតកើតឡើង)

**pollen tube** /ˈpɒlən tjuːb/ [n] បំពង់លម្អង (ផ្នែកមួយដូចបំពង់ដែលដុះចេញមកពីគ្រាប់លម្អង។ ចំពោះពួករុក្ខជាគ្រាប់ជិត លម្អងចេញពន្លកនៅលើស្ទិចម៉ា (stigma) ហើយលូតចូលតាមបំពង់អូវែរី (style) រហូតជួបនឹងអូវុល។ ចំពោះពួករុក្ខជាតិគ្រាប់ស្រាត លម្អងចេញពន្លកនៅលើកំពូលរបស់អូវុល។)

**pollinate** /ˈpɒlɪneɪt/ [v] រោយលម្អងផ្កា

**pollination** /ˈpɒlɪneɪteɪʃ(ə)n/ [n] ដំណើរលម្អង, លម្អងចរ, ការរោយលម្អង (ការទំលាក់ខ្លួនរបស់លម្អងនៅលើផ្នែកទទួលរបស់ផ្កាញី។ ចំពោះប្រភេទរុក្ខជាតិគ្រាប់ជិត ផ្នែកនេះជាផ្ទៃរបស់ស្ទិចម៉ា ចំពោះប្រភេទរុក្ខជាតិគ្រាប់ស្រាត គឺជាចុងអូវុល។)

- artificial pollination /ɑːtɪˈfɪʃ(ə)l pɒlɪˈneɪʃ(ə)n/ [n] ការរោយលម្អងសិប្បនិម្មិត
- background pollination /ˈbakgraʊnd pɒlɪˈneɪʃ(ə)n/ [n] ការរោយលម្អងរយៈចម្ងាយឆ្ងាយ
- controlled pollination /kənˈtrəʊld pɒlɪˈneɪʃ(ə)n/ [n] ការរោយលម្អងស្ថិតក្រោមការត្រួតពិនិត្យ (ការផ្ទេរ ឬការអនុញ្ញាតឱ្យផ្ទេរនូវលម្អងពីប្រភពច្បាស់លាស់ទៅផ្កាដែលទទួលយកលម្អងដែលគេស្គាល់ច្បាស់លាស់។ លម្អងផ្សេងៗទៀត រួមទាំងលម្អងនៃដើមខ្លួនឯង ក៏ត្រូវបញ្ចៀសផងដែរ (ឧ. គ្របផ្កាដោយថង់ការពារលម្អង និង/ឬធ្វើការក្រៀវមុនវារោយលម្អង)។)
- cross-pollination /krɒs pɒlɪˈneɪʃ(ə)n/ [n] ការរោយលម្អងបង្កាត់, ដំណើរលម្អងកាត់ (ការរោយលម្អងដោយរុក្ខជាតិដែលមានសេនេទិចខុសគ្នា។ ការរោយលម្អងទៅក្រៅ គឺជាការរោយលម្អងបង្កាត់ជាមួយឯកត្តៈមួយដែលមិនមែនជាញាត្តិសន្តាន។)
- self-pollination /sɛlf pɒlɪˈneɪʃ(ə)n/ [n] ស្វ័យដំណើរលម្អង, ការរោយលម្អងលើខ្លួនឯង (ការរោយលម្អងរបស់ផ្កាមួយ ជាមួយលម្អងមកពីដើមឈើតែមួយ ឬដើមផ្សាំ(ក្លូន)។ កូនវាគេឱ្យឈ្មោះថា self pollination (កូនខ្លួនឯង)។ ពាក្យន័យផ្ទុយ Cross pollination (ការរោយលម្អងឆ្លងគ្នា)។)
- wind pollination /wɪnd pɒlɪˈneɪʃ(ə)n/ [n] ការរោយលម្អងតាមខ្យល់
- pollination droplet /pɒlɪˈneɪʃ(ə)n ˈdrɒplɪt/ [n] ដំណក់ទឹកតូចៗសម្រាប់រោយលម្អង (ជាដំណក់តូចមួយនៃវត្ថុរាវដែលចេញពីរន្ធមីក្រូភៃលរបស់ពួករុក្ខជាតិគ្រាប់ស្រាត (Gymnosperm) នៅពេលរោយលម្អង តួនាទីរបស់ដំណក់ទឹកនេះ គឺដើម្បីចាប់យកលម្អង ហើយបន្ទាប់មកក៏បង្ហួតទឹកដើម្បីទាញលម្អងនេះចូលទៅក្នុងបន្ទប់រង់ចាំរបស់លម្អង។)

**pollinator** /ˈpɒlɪneɪtə/ [n] (សទិសន័យ៖ pollination agent) សត្វនាំលម្អង, សត្វចម្លងលម្អង។ ឧ. សត្វល្អិត បក្សី ឬប្រចៀវ។

**pollinium** /pəˈlɪnɪəm/ [n] សំណុំគ្រាប់លម្អង

**pollutant** /pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុល, សារធាតុកង្វក់, ភ្នាក់ងារបំពុល

- acid pollutant /ˈasɪd pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលអាស៊ីត
- air pollutant /ɛː pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលខ្យល់
- airborne pollutant /ˈɛːbɔːn pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលសោត់តាមខ្យល់
- automotive pollutant /ˌɔːtəˈməʊtɪv pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលចេញពីយានយន្ត
- gaseous pollutant /ˈgasɪəs pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលជាឧស្ម័ន
- global pollutant /ˈgləʊb(ə)l pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលសាកល
- hazardous pollutant /ˈhazədəs pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលប្រកបដោយគ្រោះថ្នាក់
- man-made pollutant /man meɪd pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលសិប្បនិម្មិត
- natural pollutant /ˈnatʃ(ə)r(ə)l pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលពីធម្មជាតិ
- primary pollutant /ˈprʌɪm(ə)ri pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលបឋម
- secondary pollutant /ˈsɛk(ə)nd(ə)ri pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលបន្ទាប់
- thermal pollutant /ˈθəːm(ə)l pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលជាកម្ដៅ
- toxic pollutant /ˈtɒksɪk pəˈl(j)uːt(ə)nt/ [n] សារធាតុកង្វក់ពុល
- water pollutant /ˈwɔːtə pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលទឹក
- waterborne pollutant /ˈwɔːtəbɔːn pəˈl(j)uːt(ə)nt/ [n] សារធាតុបំពុលហូរតាមទឹក

**pollute** /pəˈluːt/ [v] បំពុល, ធ្វើឱ្យកខ្វក់, ការបំពុល (បរិស្ថាន, ខ្យល់, ទឹក, ដី)

pollution /pəˈluːʃ(ə)n/ [n] ការបំពុល, កខ្វក់

- acid pollution /ˈasɪd pəˈluːʃ(ə)n/ [n] ការបំពុលដោយអាស៊ីត
- agricultural pollution /agrɪˈkʌltʃərəl pəˈluːʃ(ə)n/ [n] ការបំពុលដោយសំណល់កសិកម្ម
- air pollution /ɛː pəˈluːʃ(ə)n/ [n] ការបំពុលខ្យល់, កខ្វក់បរិយាកាស
- atmosphere pollution /ˈatməsfɪə pəˈluːʃ(ə)n/ [n] ការបំពុលបរិយាកាស
- automotive pollution /ˌɔːtəˈməʊtɪv pəˈluːʃ(ə)n/ [n] ការបំពុលបណ្ដាលមកពីយានយន្ត
- background pollution /ˈbakgraʊnd pəˈluːʃ(ə)n/ [n] ការបំពុលដើម
- bacteria pollution /bakˈtɪəriə pəˈluːʃ(ə)n/ [n] ការបំពុលដោយបាក់តេរី
- chemical pollution /ˈkɛmɪk(ə)l pəˈluːʃ(ə)n/ [n] ការបំពុលគីមី
- dust pollution /dʌst pəˈluːʃ(ə)n/ [n] ការបំពុលដោយធូលី
- environmental pollution /ɪnvʌɪrənˈmɛnt(ə)l pəˈluːʃ(ə)n/ [n] ការបំពុលបរិស្ថាន
- global pollution /ˈgləʊb(ə)l pəˈluːʃ(ə)n/ [n] ការបំពុលសកល
- groundwater pollution /ˈgraʊn(d)wɔːtə pəˈluːʃ(ə)n/ [n] ការបំពុលទឹកក្រោមដី
- heat pollution /hiːt pəˈluːʃ(ə)n/ [n] ការបំពុលដោយកម្ដៅ
- hydrocarbon pollution /ˌhʌɪdrə(ʊ)ˈkɑːb(ə)n pəˈluːʃ(ə)n/ [n] ការបំពុលដោយអ៊ីដ្រូកាបួ
- indoor pollution /ˈɪndɔː pəˈluːʃ(ə)n/ [n] ការបំពុលខ្យល់ក្នុងអាគារ
- industrial pollution /ɪnˈdʌstrɪəl pəˈluːʃ(ə)n/ [n] ការបំពុលដោយឧស្សាហកម្ម
- land-based pollution /land beɪst pəˈluːʃ(ə)n/ [n] ការបំពុលពីទ្វីប
- light pollution /lʌɪt pəˈluːʃ(ə)n/ [n] ការបំពុលដោយពន្លឺ
- local pollution /ˈləʊk(ə)l pəˈluːʃ(ə)n/ [n] ការបំពុលនៅកន្លែងណាមួយ
- man-made pollution /man meɪd pəˈluːʃ(ə)n/ [n] ការបំពុលដោយមនុស្ស
- marine pollution /məˈriːn pəˈluːʃ(ə)n/ [n] ការបំពុលសមុទ្រ
- metal pollution /ˈmɛt(ə)l pəˈluːʃ(ə)n/ [n] ការបំពុលដោយលោហៈ

- motor vehicle pollution /ˈməʊtə ˈviːɪk(ə)l pəˈluːʃ(ə)n/ [n] ការបំពុលដោយយានយន្ត
- natural pollution /ˈnatʃ(ə)r(ə)l pəˈluːʃ(ə)n/ [n] ការបំពុលពីធម្មជាតិ
- nitrate pollution /ˈnʌɪtreɪt pəˈluːʃ(ə)n/ [n] ការបំពុលដោយនីត្រាត
- noise pollution /nɔɪz pəˈluːʃ(ə)n/ [n] ការបំពុលដោយសូរស័ព្ទ
- nonpoint pollution /nɒnpɔɪnt pəˈluːʃ(ə)n/ [n] ការបំពុលរាយប៉ាយ
- nutrient pollution /ˈnjuːtrɪənt pəˈluːʃ(ə)n/ [n] ការបំពុលដោយសារធាតុចិញ្ចឹម
- ocean pollution /ˈəʊʃ(ə)n pəˈluːʃ(ə)n/ [n] សូមមើលពាក្យ៖ oceanic pollution
- oceanic pollution /ˌəʊsɪˈanɪk pəˈluːʃ(ə)n/ [n] (សទិសន័យ៖ ocean pollution) ការបំពុលមហាសមុទ្រ
- oil pollution /ɔɪl pəˈluːʃ(ə)n/ [n] ការបំពុលដោយប្រេង
- ozone pollution /ˈəʊzəʊn pəˈluːʃ(ə)n/ [n] ការបំពុលដោយអូសូន
- radioactive pollution /ˌreɪdɪəʊˈaktɪv pəˈluːʃ(ə)n/ [n] ការបំពុលដោយវិទ្យុសកម្ម
- sewage pollution /ˈsuːɪdʒ pəˈluːʃ(ə)n/ [n] ការបំពុលដោយទឹកលូសម្អុយ
- space pollution /speɪs pəˈluːʃ(ə)n/ [n] ការបំពុលលំហអវកាស
- thermal pollution /ˈθəːm(ə)l pəˈluːʃ(ə)n/ [n] ការបំពុលដោយកម្ដៅ
- transboundary pollution /trɑːnzˈbaʊnd(ə)ri pəˈluːʃ(ə)n/ [n] ការបំពុលឆ្លងកាត់ព្រំដែន
- uncontrolled pollution /ʌnkənˈtrəʊld pəˈluːʃ(ə)n/ [n] ការបំពុលដោយគ្មានការត្រួតពិនិត្យ
- visual pollution /ˈvɪʒ(j)ʊəl pəˈluːʃ(ə)n/ [n] ការបំពុលដែលអាចមើលឃើញ
- water pollution /ˈwɔːtə pəˈluːʃ(ə)n/ [n] ការបំពុលទឹក
- zero pollution /ˈzɪərəʊ pəˈluːʃ(ə)n/ [n] អវត្តមាននៃការបំពុល

**Polonium** /pəˈləʊnɪəm/ [n] ប៉ូឡូញ៉ូម (និមិត្តសញ្ញាគីមី Po)

**poly-** /ˈpɒli/ [prefix] (សទិសន័យ៖ many) បុព្វបទមានន័យថា ច្រើន, ពហុ

**polyandry** /ˈpɒlɪandri/ [n] មានកេសរឈ្មោលច្រើន

**polyarthritis** /ˈpɒli ˈɑːˈθrʌɪtɪs/ [n] ជំងឺរលាកសន្លាក់ដៃជើង

**polyculture** /ˈpɒlɪkʌltʃə/ [n] ពហុវប្បកម្ម (ការដាំដំណាំច្រើនមុខនៅលើស្រែមួយ ចម្ការមួយ ឬតំបន់មួយ)

**polyembryology** /ˈpɒliˌɛmbrɪˈɒlədʒi/ [n] វិទ្យាសាស្ត្រអំពីពហុក្រូណា, វិទ្យាសាស្ត្រអំពីពហុអំប្រីយ៉ុង

**polyembryony** /ˌpɒlɪˈɛmbrɪəni/ [n] ពហុក្រូណា, ពហុអំប្រីយ៉ុង (១. ការផលិតអំប្រីយ៉ុងពីរ ឬច្រើនចេញពីអូវុល១ និងនៅក្នុងគ្រាប់១ (ជីវសាស្ត្រគ្រាប់ពូជ)។ ២. ការបង្កើតអំប្រីយ៉ុងលើសពីមួយនៅក្នុងអូវុលមួយ (សុវុឌ្ឍិកម្មដើមឈើ)។)

**polyethylene** /ˌpɒlɪˈɛθɪliːn/ [n] សារធាតុប៉ូលីអេទីឡែន, សារធាតុសំពត់ផ្លាស្ទិច

**polygene** /ˈpɒlɪdʒiːn/ [n] (សទិសន័យ៖ polymeric system) ឥទ្ធិពលពហុពន្ធុ ឬសែន (ពន្ធុ ឬសែនមិនអាលែលនឹងគ្នាជាច្រើន ទាំងអស់មានឥទ្ធិពលលើលក្ខណៈតែមួយនិងមានឥទ្ធិពលបន្ថែមប្រហាក់ប្រហែល (polymeric systems))

***Polygonatum odoratum*** [sci.n] ជីរក្រសាំងទំហំ

***Polygonum barbatum*** [sci.n] កន្ទ្រាំងហៃ

***Polygonum hydropiper*** [sci.n] សូមមើលពាក្យ៖ marsh-pepper smartweed, water pepper

**polymer** /ˈpɒlɪmə/ [n] ប៉ូលីមែ

**polymerization** /ˌpɒlɪmərʌɪˈzeɪʃ(ə)n/ [n] ប៉ូលីមែកម្ម

***Polynemus borneensis*** [sci.n] សូមមើលពាក្យ៖ borneo threadfin

***Polynemus dubius*** [sci.n] សូមមើលពាក្យ៖ mimic threadfin

***Polynemus longipectoralis*** [sci.n] សូមមើលពាក្យ៖ longwhip threadfin

***Polynemus multifilis*** [sci.n] សូមមើលពាក្យ៖ fringed threadfin

**polyp** /ˈpɒlɪp/ [n] សាច់ដុះចេញពីផ្ទៃដែលស្មើ

**polypetalous** /ˈpɒlɪpˈɛtələs/ [adj] ពហុត្របកផ្កា

**polyphage** /pəˈlɪfəg/ [n] សូមមើលពាក្យ៖ omnivore

**polyphagous** /pəˈlɪfəgəs/ [adj] ពហុបរិភោគ (ពពួកសត្វដែលស៊ីចំណីអាហារច្រើនប្រភេទ ឬធ្វើបារាសិតទៅលើជម្រកច្រើនប្រភេទធ្វើជាកន្លែងស្នាក់អាស្រ័យ និងបង្កើតកូនចៅ)

**polyploid** /ˈpɒlɪplɔɪd/ [adj] ពហុប្លូអ៊ីត (មានច្រើនជាង២ដងនៃចំនួនមូលដ្ឋាន n នៃក្រូម៉ូសូមរបស់ប្រភេទបុព្វរុក្ខករ (ពូជជីដូនជីតា) នៅក្នុងកោសិកាលូតលាស់របស់វា។ កោសិកា ជាលិកា ឬសាពាង្គកាយមួយដែលមាន៣សម្រាប់ (3n) គេហៅទ្រីប្លូអ៊ីត និងមាន៤ សម្រាប់(4n) ហៅតេត្រាប្លូអ៊ីត។)

**polyploidy** /ˈpɒlɪplɔɪdi/ [n] ពហុប្លូអ៊ីត (ភាពដែលចំនួនឈុតនៃក្រូម៉ូសូមនៅក្នុងកោសិកាមានពីបីឡើងទៅ)

**polythene** /ˈpɒlɪθiːn/ [n] សារធាតុប៉ូលីអេទីឡែន, សារធាតុសំពត់ប្លាស្ទិច (ជាអក្សរកាត់របស់ពាក្យ Polyethylene ជាសារធាតុមួយ ដែលគេប្រើធ្វើជាសំពត់ផ្លាស្ទិច និងថង់ (ក្រៀមភាសា polypot))

***Polytoxus fuscovittatus*** [sci.n] ស្រឹងគោក

**polytrophe** [n] សូមមើលពាក្យ៖ omnivore

**pome** /pəʊm/ [n] ប្រភេទផ្លែសាច់ប៉ោម (ជាប្រភេទផ្លែឈើមួយមានគ្រាប់ច្រើន ដែលកើតចេញពីកេសរញីសមាស ដែលបង្កប់នៅក្នុងទម្រផ្កា ដែលមានរាងដូចពែងនៃប្រភេទផ្កា ភេរីពន្ធុ ឬសែននី(perigyny) ឬបំពង់ផ្កានៃប្រភេទផ្កាអេពិពន្ធុ ឬសែននី (epigyny) ឧ.ផ្លែប៉ោម។)

**pomegranate** /ˈpɒmɪgranɪt/ [n] ទទឹម (ឈ្មោះវិទ្យាសាស្ត្រ *Punica granatum*)

**pomelo** /ˈpɒmələʊ/ [n] សូមមើលពាក្យ៖ grapefruit

**pond** /pɒnd/ [n] ត្រពាំង, ស្រះ, អាង

- fish pond /fɪʃ pɒnd/ [n] ស្រះត្រី
- oxidation pond /ɒksɪˈdeɪʃ(ə)n pɒnd/ [n] អាងអុកស៊ីតកម្ម

**pons** /pɒnz/ [n] ជាលិកាស្តើងៗទាក់ទងគ្នានៃសរីរាង្គមួយ

**pony** /ˈpəʊni/ [n] សេះតូច

**poor** /pɔː/ [adj] ដែលក្រខ្សត់, ដែលមិនសម្បូរ

***Popowia aberrans*** [sci.n] ផ្កាវំដួល

***Popowia disc pyrifolia*** [sci.n] ផ្កាក្រវ៉ាន់

**popping pod** / pɒpin pɒd/ [n] (សទិសន័យ៖ minnie root) ស្មៅគ្រាប់បែក (ឈ្មោះវិទ្យាសាស្ត្រ Ruellia tuberosa)

**population** /pɒpjʊˈleɪʃ(ə)n/ [n] ប្រជាជន, បណ្ដាភាវៈ, ចំនួនប្រជាពល (ស្ថិតិវិទ្យា), ក្រុមពូជ, ក្រុមដំណុះរុក្ខជាតិ

- base population /beɪs pɒpjʊˈleɪʃ(ə)n/ [n] ព្រៃពូជមូលដ្ឋាន, ក្រុមពូជមូលដ្ឋាន ឬជម្រើស
- breeding population /ˈbriːdɪŋ pɒpjʊˈleɪʃ(ə)n/ [n] ក្រុមពូជសម្រាប់បង្កាត់, ការបង្កាត់ក្រុមពូជ (ចំនួននៃឯកត្តៈដែលគេជ្រើសរើសចេញពីក្រុមពូជមូលដ្ឋាន ដែលមានលក្ខណៈដែលគេចង់បាន ដើម្បីធ្វើជា មេបាសម្រាប់ជំនាន់ក្រោយសម្រាប់បង្កាត់ពូជ)
- infusion population /ɪnˈfjuːʒ(ə)n pɒpjʊˈleɪʃ(ə)n/ [n] ការបង្កាត់បញ្ចូលក្រុមពូជក្រៅ, ជម្រើសបញ្ចូលក្រុមពូជក្រៅ
- pest population /pɛst pɒpjʊˈleɪʃ(ə)n/ [n] ប្រជាករទុរករ (ក្រុមកត្តាចង្រៃនៃប្រភេទដូចគ្នារស់នៅក្នុងកន្លែងមួយច្បាស់លាស់)
- plant population /plɑːnt pɒpjʊˈleɪʃ(ə)n/ [n] រុក្ខប្រជាករ
- production population /prəˈdʌkʃ(ə)n pɒpjʊˈleɪʃ(ə)n/ [n] (សទិសន័យ៖ propagation population) ការផលិតក្រុមពូជ, ការផលិតកូនឈើក្លូន
- propagation population /prɒpəˈgeɪʃ(ə)n pɒpjʊˈleɪʃ(ə)n/ [n] សូមមើលពាក្យ៖ production population
- rural population /ˈrʊər(ə)l pɒpjʊˈleɪʃ(ə)n/ [n] ចំនួនប្រជាជននៅជនបទ
- segregating population /ˈsɛgrɪgeɪtɪŋ pɒpjʊˈleɪʃ(ə)n/ [n] រុក្ខប្រជាករវិយោគ (រុក្ខប្រជាករណាដែលឯកត្តៈរបស់វាមានសេណូទីបខុសៗគ្នា ហើយក្នុងនោះពពួកដែលមានសេណូទីបជាអេតេរ៉ូស៊ីកូត នឹងបែកលក្ខណៈបន្តបន្ទាប់)
- selection population /sɪˈlɛkʃ(ə)n pɒpjʊˈleɪʃ(ə)n/ [n] ព្រៃពូជមូលដ្ឋាន, ក្រុមពូជមូលដ្ឋាន ឬជម្រើស
- wood production population /wʊd prəˈdʌkʃ(ə)n pɒpjʊˈleɪʃ(ə)n/ [n] ក្រុមពូជសម្រាប់ផលិត (សាច់) ឈើ (ចំការឈើដែលគេដាំនូវកម្មវិធីស្តារព្រៃឈើឡើងវិញ)

**porcelain** /ˈpɔːs(ə)lɪn/ [n] ប៉សឺឡែន

**pore** /pɔː/ [n] (សទិសន័យ៖ void, interstice) ប្រហោង, រន្ធ, ចន្លោះរន្ធ, រន្ធតូចៗ

- anal pore /ˈeɪn(ə)l pɔː/ [n] រន្ធទ្វារធំ
- fine pore /fʌɪn pɔː/ [n] រន្ធឆ្មារ, រន្ធតូច (តូចជាង 0.២ មីក្រុង)
- large pore /lɑːdʒpɔː/ [n] រន្ធធំ (ធំជាង ៨ មីក្រុង)

- middle pore /ˈmɪd(ə)lpɔː/ [n] រន្ធមធ្យម (0.២-៨ មីក្រុង)

**pork** /pɔːk/ [n] សាច់ជ្រូក

***Poropuntius deauratus*** [sci.n] ត្រីលលកស, ត្រីក្រុសភ្នំ

**porosity** /pɔːˈrəsɪti/ [n] លំហោស, ភាពស្ពោត, រំហោល (បរិមាណរន្ធខ្យល់)

- cavernous porosity /ˈkavənəs pɔːˈrɒsɪti/ [n] ភាពជារន្ធមូលៗ
- cellular porosity /ˈsɛljʊlə pɔːˈrɒsɪti/ [n] ភាពជារន្ធដូចកោសិកា (ទំហំធំជាង ១០ ម.ម)
- efficient porosity /ɪˈfɪʃ(ə)ntpɔːˈrɒsɪti/ [n] ប្រព័ន្ធរន្ធមានប្រសិទ្ធភាព (រន្ធសម្រាប់ខ្យល់រត់)
- spongy porosity /ˈspʌn(d)ʒipɔːˈrɒsɪti/ [n] ប្រព័ន្ធរន្ធដូចពពុះទឹក (ទំហំពី ៣-៥ ម.ម)

**porous** /ˈpɔːrəs/ [adj] ដែលមានរន្ធច្រើន, ដែលមានរន្ធតូចៗអាចជ្រាបបាន

**porridge** /ˈpɒrɪdʒ/ [n] បបរ

***Portulaca grandiflora*** [sci.n] ផ្កាម៉ោងដប់

***Portulaca oleracea*** [sci.n] សូមមើលពាក្យ៖ little hogweed, purslane

**position** /pəˈzɪʃ(ə)n/ [n] ទីតាំង, ទីកន្លែង, ជំហរ

- taxonomic position /taksəˈnɒmɪk pəˈzɪʃ(ə)n/ [n]
  ១. ក្រុមនៃសារពាង្គកាយវិទ្យាសាស្ត្រចាត់ថ្នាក់រុក្ខជាតិ សត្វ និងមីក្រូសរីរាង្គជាពួក ឬក្រុម ដែលយោងទៅតាមលក្ខណៈ។ ការចាត់ថ្នាក់ថ្មីៗនេះ គឺផ្អែកលើលក្ខណៈសេនេទិច។
  ២. គោលការណ៍នៃការចាត់ថ្នាក់
  ៣. ការសិក្សាពីចំណាត់ថ្នាក់

**positive** /ˈpɒzɪtɪv/ [adj] វិជ្ជមាន, ពិត, ជាក់លាក់, ឱ្យហេតុថាមានរោគ, មានអ្វីមួយដែលពិនិត្យឃើញ

**positron emission tomography (PET)** /ˈpɒzɪtrɒn ɪˈmɪʃ(ə)n təˈmɒgrəfi/ [n] របៀបឆ្លុះស្រមោលដោយបញ្ចាំងរស្មីប៉ូស៊ីត្រុន ទៅលើកន្លែងផ្លាស់ប្តូរជាតិគីមី (ការផ្ទុក និងរំលាយអាហារ) នៅក្នុងសរីរាង្គ

**possess** /pəˈzɛs/ [v] មាន, កាន់កាប់, ជាម្ចាស់

**possession** /pəˈzɛʃ(ə)n/ [n] ការកាន់កាប់, ភាពជាម្ចាស់

**post-** /pəʊst/ [prefix] (សទិសន័យ៖ after) បុព្វបទមានន័យថា ក្រោយ

**post-harvest** /pəʊst-harvest/ [adj] ក្រោយពេលប្រមូលផល

**posterior** /pɒˈstɪərɪə/ [adj] ក្រោយ, ដែលឋិតនៅខាងក្រោយ, គូទ

**postmortem** /pəʊs(t)ˈmɔːtəm/ [n] ក្រោយការស្លាប់

**postpartum** /ˈpɑːtəm/ [adj] ក្រោយការកើត, ក្រោយពេលសម្រាលកូនហើយ

**postpone** /pəʊs(t)ˈpəʊn/ [v] ពន្យារពេល, ផ្អាក

**posy** /ˈpəʊzi/ [n] បាច់ផ្កា (តូច)

**pot** /pɒt/ [n] ថូ, ជើង, ភាជន៍

**potable** /ˈpəʊtəb(ə)l/ [adj] អាចផឹកបាន

**potash** /ˈpɒtaʃ/ [n] សូមមើលពាក្យ៖ white mica

**Potassium** /pəˈtasɪəm/ [n] ប៉ូតាស្យូម (និមិត្តសញ្ញាគីមី K)

**potato** /pəˈteɪtəʊ/ [n] ដំឡូងបារាំង (ឈ្មោះវិទ្យាសាស្ត្រ *Solanum tuberosum*)

**potent** /ˈpəʊt(ə)nt/ [adj] នៃកម្លាំង, នៃអានុភាព, ខ្លាំង ,មានអំណាច, ទ្បើងរឹង

**potential** /pə(ʊ)ˈtɛnʃ(ə)l/ [n] សក្តានុពល

- biotic potential /bʌɪˈɒtɪk pə(ʊ)ˈtɛnʃ(ə)l/ [n] សក្តានុពលជីវិត
- capillary potential /kəˈpɪləri pə(ʊ)ˈtɛnʃ(ə)l/ [n] ប៉ូតង់ស្យែលកាពីលែរ, សក្តានុពលកាពីលែរ (ទាញទឹកឡើងលើ)
- water potential /ˈwɔːtə pə(ʊ)ˈtɛnʃ(ə)l/ [n] សក្តានុពលទឹក, ប៉ូតង់ស្យែលទឹក

**pothole** /ˈpɒthəʊl/ [n] គ្រលុក

**poultice** /ˈpəʊltɪs/ [n] ថ្នាំបំពោក

**poultry** /ˈpəʊltri/ [n pl] បសុបក្សី (បក្សីដែលគេចិញ្ចឹមនៅទីធ្លាដូចជាមាន់ ទាជាដើម សម្រាប់យកស៊ុត និងសាច់)

**pound** /paʊnd/ [v] កម្ទេច, គោះ, វាយ

**pour** /pɔː/ [v] ចាក់ផ្ទេរ

**poverty** /ˈpɒvəti/ [n] ភាពក្រីក្រ

- anti-poverty /ˈantɪ ˈpɒvəti/ [n] ការប្រឆាំងនឹងភាពក្រីក្រ (សកម្មភាពណាមួយធ្វើឡើងដើម្បីបំបាត់ភាពក្រីក្រ)

- critical food poverty /ˈkrɪtɪk(ə)l fuːd ˈpɒvəti/ [n] កង្វះស្បៀងធ្ងន់ធ្ងរ (កម្រិតចំណូលដែលស្ថិតនៅក្រោមចំណូលដែលបុគ្គលម្នាក់ ឬគ្រួសារមួយមិនអាចរកបានដើម្បីឱ្យឆ្លើយតបទៅនឹងតម្រូវការអាហារូបត្ថម្ភកម្រិតអប្បបរមារបស់ខ្លួនបានតាមធម្មតាគឺតូចជាង-២SD ក្រោមស្តង់ដារអន្តរជាតិរបស់អង្គការសុខភាពពិភពលោកដែលកំណត់យក ២១០០ kcl ឬ១ថ្ងៃ ឬក៏តាមកម្រិតសមមូលរបស់ប្រជាជាតិមួយៗ។)
- food poverty /fuːd ˈpɒvəti/ [n] ភាពក្រីក្រស្បៀងអាហារ, កង្វះខាតស្បៀងអាហារ (ភាពអសមត្ថភាពរបស់បុគ្គល ឬគ្រួសារក្នុងការទទួលបានស្បៀង ដែលតម្រូវឱ្យមានសម្រាប់សុខភាព និងអាហារូបត្ថម្ភដែលជាលទ្ធផលនៃការមានស្បៀងខ្សត់ខ្សោយ លទ្ធភាពទទួលស្បៀង ឬក៏ការប្រើប្រាស់ និងបឺតស្រូបស្បៀង។)

**powder** /ˈpaʊdə/ [n] ១. (ចំពោះដី) ផង់ធូលី (0.0៦-0.៥ ម.ម) ២. ម្សៅ

- absorbing podwer /əbˈzɔːbɪŋˈpaʊə/ [n] សូមមើលពាក្យ៖ absorbent

**powdery** /ˈpaʊdəriː/ [adj] ដែលជាផង់ដូចម្សៅ

**powdery mildew** /ˈpaʊdəriː ˈmɪldjuː/ [n] ជំងឺម្សៅស្លឹក (ជំងឺនេះបង្កដោយផ្សិត *Erysiphe cichoracearum* និង *Sphaerotheca fuligena* ដែលភ្នាក់ងារបង្កជំងឺរស់នៅក្នុងកាកសំណល់រុក្ខជាតិ និងអំបូរត្រសក់ ដែលដុះក្នុងព្រៃបានពេញមួយឆ្នាំនៅតំបន់ត្រូពិច)

**power** /ˈpaʊə/ [n] អនុភាព, កម្លាំង, ថាមពល

- buffer-power /ˈbʌfəˈpaʊə/ [n] ឥទ្ធិពលទប់មិនឱ្យអ្វីៗប្តូរល្បឿនពេក (ឧ. pH)
- draught power /drɑːft ˈpaʊə/ [n] (សរសេរជា draft power ក៏បាន) កម្លាំងអូសទាញ
- economic power /ˌiːkəˈnɒmɪk ˈpaʊə/ [n] មហាអំណាចសេដ្ឋកិច្ច
- horse power (HP) /hɔːs ˈpaʊə/ [n] កម្លាំងសេះ (រង្វាស់កម្លាំងចលករ)
- hydroelectric power /hʌɪdrəʊɪˈlɛktrɪk ˈpaʊə/ [n] ថាមពលវារីអគ្គិសនី
- nuclear power /ˈnjuːklɪə ˈpaʊə/ [n] (សទិសន័យ៖ nuclear energy) ថាមពលនុយក្លេអ៊ែ
- solar power /ˈsəʊlə ˈpaʊə/ [n] ថាមពលព្រះអាទិត្យ
- suction power /ˈsʌkʃ(ə)n ˈpaʊə/ [n] កម្លាំងបឺតយកទឹក
- tidal power /ˈtʌɪd(ə)l ˈpaʊə/ [n] សូមមើលពាក្យ៖ tidal energy
- water power /ˈwɔːtə ˈpaʊə/ [n] កម្លាំងទឹក
- wave power /weɪv ˈpaʊə/ [n] សូមមើលពាក្យ៖ wave energy
- wettable powder /ˈwɛtəb(ə)l ˈpaʊdə/ [n] ថ្នាំម្សៅ
- wind power /wɪnd ˈpaʊə/ [n] សូមមើលពាក្យ៖ wind energy

**powerhouse** /ˈpaʊəhaʊs/ [n] រោងចក្រអគ្គីសនី

**pox** /pɒks/ [n] អុត (រោគ)

**practice** /ˈpraktɪs/ [n] ទំនៀមទម្លាប់, ទម្លាប់, ការអនុវត្តជាទម្លាប់

- cultural practice /ˈkʌltʃ(ə)r(ə)l ˈpraktɪs/ [n] វប្បនុវត្តន៍ (ការអនុវត្តន៍ដំទៀងទាត់របស់កសិករ ដែលពេលនោះកសិករត្រូវគិតគូរពីការរៀបចំដី ជ្រើសរើសពូជ របៀបដាំដុះការប្រើប្រាស់ដីក្នុងការដាំដុះដំណាំដែលគាត់បានជ្រើសរើស និងដើម្បីឱ្យបានផលល្អ)
- lifestyle practices /ˈlʌɪfstʌɪl ˈpraktɪs/ [n pl] ការប្រតិបត្តិអំពីរបៀបរបបរស់នៅ (ឥរិយាបថ និងការអនុវត្តន៍ និងសកម្មភាពណាមួយ ដែលរួមចំណែកដោយក្រុមសង្គមមួយដែលបានកំណត់។ នៅក្នុងបរិបទនៃសន្តិសុខស្បៀង និងអាហារូបត្ថម្ភ ការប្រើប្រាស់ដែលមានទំនោរចង់អនុវត្តន៍ចំពោះឥរិយាបថ ដែលបណ្តាលឱ្យកើតមានការលើសទម្ងន់ ជំងឺធាត់ ឬបង្កើតអាំងស៊ុយលីននៃជំងឺមិនឆ្លងដូចជា ជំងឺទឹកនោមផ្អែមប្រភេទទី២ ជំងឺបេះដូង និងជំងឺមហារីក។ ក៏ដូចគ្នានេះដែរ វាត្រូវបានគេអនុវត្តន៍នៅក្នុងបរិបទសុខភាពសាធារណៈដូចជាការការពារជំងឺអេដស៍។)

**pragmatism** /ˈpragmətɪz(ə)m/ [n] ការណ៍និយម

**prairie** /ˈprɛːri/ [n] វាលស្មៅធំៗ

- shortgrass prairie /ʃɔːt grɑːs ˈprɛːri/ [n] វាលស្មៅខ្លី (ប្រភេទស្មៅនៅភាគខាងលិចនៃសហរដ្ឋអាមេរិក ដែលមានអាកាសស្ងួត)
- tallgrass prairie /tɔːl grɑːs ˈprɛːri/ [n] វាលស្មៅខ្ពស់ៗ (ប្រភេទស្មៅនៅភាគខាងកើតនៃសហរដ្ឋអាមេរិក ដែលមានភ្លៀងច្រើន)

**Praseodymium** /ˌpreɪzɪə(ʊ)ˈdɪmɪəm/ [n] ប្រាសេអូឌីម (និមិត្តសញ្ញាគីមី Pr)

**prawn** /prɔːn/ [n] បង្កង

- fresh water prawn /frɛʃ ˈwɔːtə prɔːn/ [n] បង្កងទឹកសាប

**praying mantis** /preɪ ɪŋ ˈmantɪs/ [n] កណ្ដូបបុកស្រូវ

**pre-** /ˈpriː/ [prefix] (សទិសន័យ៖ after) បុព្វបទមានន័យថា មុន

**phytosanitary precaution** /ˌfʌɪθəʊˈsanɪt(ə)ri prɪˈkɔːʃ(ə)n/ [n] ការយកចិត្តទុកដាក់ឱ្យបានម៉ត់ចត់អំពីភូតគាមអនាម័យ

**pre-chilling** /ˈpriː tʃɪlɪŋ/ [n] (ចំពោះគ្រាប់ពូជ) ការធ្វើប្រព្រឹត្តិកម្មគ្រាប់ក្នុងទីត្រជាក់សើម, ការធ្វើប្រព្រឹត្តិកម្មគ្រាប់បំបែកភាពសម្ងំកម្ដៅ (ប្រព្រឹត្តកម្មត្រជាក់សើម ដែលស្រដៀងគ្នានិងការធ្វើឱ្យចុះត្រជាក់ ប៉ុន្តែគេអនុវត្តជាពិសេសទៅលើគ្រាប់សម្ងំ និងមានបំណងបំបែកភាពសម្ងំកម្ដៅ)

**precipitate** /prɪˈsɪpɪteɪt/ [n] កករ

**precipitation** /prɪˌsɪpɪˈteɪʃ(ə)n/ [n] កំណកអាកាស (ភ្លៀង ព្រិល ទឹកកកសំឡីជាដើម), ការកកជាដុំ ឬគ្រាប់ (នៃសារធាតុគីមី)

- acid precipitation /ˈasɪd prɪˌsɪpɪˈteɪʃ(ə)n/ [n] កំណអាកាសអាស៊ីត
- annual precipitation /ˈanjʊəl prɪˌsɪpɪˈteɪʃ(ə)n/ [n] កំណកអាកាសប្រចាំឆ្នាំ
- daily precipitation /ˈdeɪli prɪˌsɪpɪˈteɪʃ(ə)n/ [n] កំណកកអាកាសប្រចាំថ្ងៃ

**precipitous** /prɪˈsɪpɪtəs/ [adj] ដែលចោត

**precocious** /prɪˈkəʊʃəs/ [adj] ដែលដុះពន្លកក្នុងផ្លែ, ដែលដុះពន្លលពេលមិនទាន់ជ្រុះពីដើម

**precuring** /ˈpriːˈkjʊərɪŋ/ [n] ការសំដិលផ្លែក្រោមម្លប់ (ការទុកដាក់ដែលបានគ្រោងទុក និងប្រើខ្យល់សំងួតយឺតៗ នៅក្រោមម្លប់ នូវផ្លែដែលមានគ្រាប់ ដើម្បីងាយស្រួលប្រលេះគ្រាប់ និងក្រោយពីបន្ទុំគ្រាប់រួចៗ)

**predation** /prɪˈdeɪʃ(ə)n/ [n] ការស៊ីដោយសត្វល្អិត, រំពាភាព, ជីវភាពសត្វរំពា (ការប្រើប្រាស់សារពាង្គកាយមានជីវិតមួយ ដោយសត្វស៊ីអាហារ ឧ. សត្វល្អិតស៊ីគ្រាប់)

**predator** /ˈprɛdətə/ [n] អជ្ឈបាតករ, សត្វរំពា (ប្រភេទសត្វដែលស៊ី និងបំផ្លាញដោយចំហ ឬជញ្ជក់រុក្ខរសពីសត្វល្អិតតាំងពីនៅក្នុងវ័យក្មេង និងមេចំណាស់។ នៅក្នុងស្រែ ពពួកអជ្ឈបាតករដែលជាមិត្តរបស់កសិករមានដូចជាពីងពាង កន្ទុំរុយ អណ្ដើកមាស ស្រមោច ខ្ទួតដី ស្រឹងគោក ចាបជាដើម។)

**predict** /prɪˈdɪkt/ [v] ទាយ, ព្យាករ, ប្រមើល

**predispose** /ˌpriːdɪˈspəʊz/ [v] រៀបចំទុកជាមុន

**preeclampsia** /priːɪˈklam(p)sɪə/ [n] ការកកើតរោគឡើងឈាមដោយមានប្រូតេអ៊ីនក្នុងទឹកនោម, ការហើមខ្លួន នៅពេលមានផ្ទៃពោះ

**preference** /ˈprɛf(ə)r(ə)ns/ [n] ការចូលចិត្ត

**pregermination** /ˈpriːdʒəːmɪˈneɪʃ(ə)n/ [n] ការបណ្ដុះជាមុន (ដំណើរការនៃការធ្វើឱ្យចេញពន្លកពីគ្រាប់ពូជ មុនពេលយកទៅសាប ឬព្រោះដោយការបង្ខំ ឬពន្យឹតការដុះចេញជាពន្លក។ ដំណើរការនេះ រួមមានការត្រាំ និងផ្អាប់គ្រាប់ពូជ។)

**pregnancy** /ˈprɛgnənsi/ [n] ដំណើរមានគភ៌, ការមានផ្ទៃពោះ, ការមានទម្ងន់

- ectopic pregnancy /ɛkˈtɒpɪk /ˈprɛgnənsi/ [n] កូនក្រៅស្បូន (ការលូត លាស់នៃស៊ុតនៅក្នុងប្រមោយ)
- mask of pregnancy /mɑːsk ɒv ˈprɛgnənsi/ [n] ការជាំមុខពេលមានផ្ទៃពោះ

**pregnant** /ˈprɛgnənt/ [adj] (សទិសន័យ៖ gravid) មានទម្ងន់, ផើម, ពោះធំ, មានផ្ទៃ

**prehension** /prɪˈhɛnʃ(ə)n/ [n] ចំណាប់

**premature** /ˈprɛmətʃə/ [adj] មុនកំណត់, កើតមិនគ្រប់ខែ

**premises** /ˈprɛmɪsɪz/ [n pl] ទីឋាន, ទីក្នុងបរិវេណ

**premolar** /priːˈməʊlə/ [n] ថ្គាមតូច,ថ្គាមមុខ, ធ្មេញចង្កូម

**prenatal** /priːˈneɪt(ə)l/ [adj] មុនឆ្លងទន្លេ, មុនកើតកូន

**preparation** /prɛpəˈreɪʃ(ə)n/ [n] របៀបរៀបចំ, ការត្រៀមបម្រុងជាមុន

- dryland preparation /drʌɪland ˌprɛpəˈreɪʃ(ə)n/ [n] ភ្ជួររាស់ស្ងួត (ភ្ជួររាស់ដាស់ដីពេលស្រែស្ងួត ឬសើមតិចតួច)
- land preparation /land ˌprɛpəˈreɪʃ(ə)n/ [n] ការរៀបចំដី (ការធ្វើដីដោយឧបករណ៍កសិកម្ម)
- soil preparation /sɔɪl ˌprɛpəˈreɪʃ(ə)n/ [n] ការរៀបចំដី

**prepare** /prɪˈpɛː/ [v] ប្រុងប្រៀប, រៀបចំ

**prepuce** /ˈpriːpjuːs/ [n] ស្បែកគ្របចុងលិង្គ

**prescription** /prɪˈskrɪpʃ(ə)n/ [n] (សទិសន័យ៖ recipe, treatment) វេជ្ជបញ្ជា

**presentation** /prɛz(ə)nˈteɪʃ(ə)n/ [n] ការបង្ហាញ, លំនាំគតិរៀបកើត

- breech presentation /briːtʃ prɛz(ə)nˈteɪʃ(ə)n/ [n] ការកើតបញ្ច្រាស

**preservation** /prɛzəˈveɪʃ(ə)n/ [n] កិច្ចការពារ, ការថែរក្សា ,ការអភិរក្ស

**preserve** /prɪˈzəːv/ [v] ការពារ, ថែរក្សា, អភិរក្ស

**pressure** /ˈprɛʃə/ [n] សម្ពាធ, ការសង្កត់, គាប

- atmosphere pressure /ˈatməsfɪə ˈprɛʃə/ [n] សម្ពាធបរិយាកាស
- osmotic pressure /ɒzˈmɒtɪk ˈprɛʃə/ [n] សម្ពាធអូស្មូស
- systolic blood pressure /sɪˈstɒlɪk blʌd ˈprɛʃə/ [n] កម្រិតសម្ពាធឈាមនៅពេលបេះដូងរួមតូច
- pressure on forest resource /ˈprɛʃə ɒn ˈfɒrɪst rɪˈsɔːs/ [n] សម្ពាធទៅលើធនធានព្រៃឈើ
- sound pressure /saʊnd ˈprɛʃə/ [n] សម្ពាធសូរ
- pressure-vacuum (PREVAC) /ˈprɛʃə ˈvakjuːm/ [n] បន្សុទ្ធកម្មគ្រាប់ដោយប្រើសម្ពាធ

**presume** /prɪˈzjuːm/ [v] ប៉ាន់ស្មាន, សន្មតជាមុន

**presumptive** /prɪˈzʌm(p)tɪv/ [adj] សន្មត់

**PREVAC (Pressure-vacuum)** [n] ការបន្សុទ្ធគ្រាប់ដោយប្រើសំពាធ (ជាវិធីសាស្ត្រមួយនៃការញែកគ្រាប់បែកខូចចេញពីគ្រាប់ល្អរបស់កញ្ចប់គ្រាប់ពូជមួយ។ គ្រាប់ស្ងួតត្រូវបានគេដាក់ចូលក្នុងទឹកគ្មានខ្យល់។ នៅពេលដែលសំពាធត្រូវបានបន្ធូរ គ្រាប់ខូចស្រូបទឹកលឿនជាងគ្រាប់ល្អ។ ក្នុងពេលនោះគ្រាប់បែកខូច លិចទៅបាត ហើយគ្រាប់ល្អ (មិនបែក) អណ្តែតឡើង។)

**prevalance** /ˈprɛvəl(ə)ns/ [n] អត្រាប្រេវ៉ាឡង់ (ទំហំដែលនៅក្នុងទំហំនោះ កត្តាជាក់លាក់ពិសេស ឬក៏ការឆ្លងកាត់ជួបប្រទះ ត្រូវបានរួមចំណែកជាមួយគ្នានៅទូទាំងប្រជាជនមួយក្រុម។ គឺថាចំនួននៃប្រជាជនមាននៅក្នុងប្រជាជនសរុបទាំងអស់ដែលបានរួមចំណែកនូវកាលៈទេសៈតែមួយជាមួយគ្នា។)

**prevalent** /ˈprɛv(ə)l(ə)nt/ [adj] រាយ, រាលដាល

**prevent** /prɪˈvɛnt/ [v] បង្ការ, ទប់

**preventative care** /prɪˈvɛntətɪv kɛː/ [n] ការថែរក្សាការពាររោគ

**prevention** /prɪˈvɛnʃn/ [n] ការទប់ស្កាត់, វិធានការបង្ការ, កិច្ចការពារទុកជាមុន

- flood prevention /flʌd prɪˈvɛnʃn/ [n] ការទប់ស្កាត់ទឹកជំនន់
- pollution prevention /pəˈluːʃ(ə)n prɪˈvɛnʃn/ [n] ការទប់ស្កាត់ការបំពុល

**prey** /preɪ/ [n] សត្វចំណី (ប្រភេទសត្វ ដែលសត្វរំពាចាប់ស៊ីជាចំណីដូចជា មមាចបៃតង មេអំបៅជាដើម)

**price** /prʌɪs/ [n] តម្លៃថេរ

- constant price /ˈkɒnst(ə)nt prʌɪs/ [n] តម្លៃថេរ
- food price /fuːd prʌɪs/ [n] តម្លៃស្បៀង
- initial price /ɪˈnɪʃ(ə) prʌɪs/ [n] សូមមើលពាក្យ៖ initial cost
- retail rice price /ˈriːteɪl rʌɪs prʌɪs/ [n] តម្លៃអង្ករលក់រាយ
- rice price /rʌɪs prʌɪs/ [n] តម្លៃស្រូវអង្ករ
- rural retail rice price /ˈrʊər(ə)l ˈriːteɪl rʌɪs prʌɪs/ [n] តម្លៃអង្ករលក់រាយនៅជនបទ
- unit price /ˈjuːnɪt prʌɪs/ [n] តម្លៃដើមមួយឯកតា
- urban retail rice price /ˈəːb(ə)n ˈriːteɪl rʌɪs prʌɪs/ [n] តម្លៃអង្ករលក់រាយនៅទីក្រុង
- wholesale rice price /ˈhəʊlseɪl rʌɪs prʌɪs/ [n] តម្លៃអង្ករលក់ដុំ

**prickle** /ˈprɪk(ə)l/ [n] បន្លា

**primary** /ˈprʌɪm(ə)ri/ [adj]

១. សូមមើលពាក្យ៖ authigenic

២. ដំបូង, ទីមួយ

- Primary **Care** Physician (PCP) /ˈprʌɪm(ə)ri kɛːfɪˈzɪʃ(ə)n/ [n] បឋមវេជ្ជបណ្ឌិតថែរក្សា, គ្រូពេទ្យផ្ទាល់ខ្លួន
- Primary Care Provider (PCP) /ˈprʌɪm(ə)ri kɛːprəˈvʌɪdə/ [n] បឋមសុខទាយក (អ្នកឱ្យសុខជាបឋម), អ្នកផ្តល់ ការថែរក្សាដ៏បឋម, អ្នកផ្តល់ការថែរក្សាដ៏សំខាន់

**primate** /ˈprʌɪmət/ [n] ព្រីម៉ាត (ត្រកូលថនិកសត្វ មានស្វាជាតួយ៉ាង)

**prioritized list** /prʌɪˈɒrətʌɪzt lɪst/ [n] ប្រថមបញ្ជី

**priority** /prʌɪˈɒrɪti/ [n] អាទិភាព (ក្នុងគោលនយោបាយ និងការធ្វើកម្មវិធី បញ្ហាមួយ ឬបញ្ហាច្រើនដែលមានសារៈសំខាន់ជាទីបំផុត ឬតម្រូវឱ្យមានការយកចិត្តទុកដាក់ភ្លាមៗខ្លាំងបំផុត)

- priority ecosystem /prʌɪˈɒrɪtiˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូឡូស៊ីអាទិភាព

***Pristis microdon*** [sci.n] សូមមើលពាក្យ៖ largetooth sawfish

***Pristolepis fasciata*** [sci.n] សូមមើលពាក្យ៖ catopra

**privilege** /ˈprɪvɪlɪdʒ/ [n] ឯកសិទ្ធិ, បុព្វសិទ្ធិ

**pro-** /prəʊ/ [prefix] (សទិសន័យ៖ in front of, taking the place of) បុព្វបទមានន័យថា នៅមុខ, ជំនួស

**probability** /prɒbəˈbɪlɪti/ [n] ភវនីយភាព (ភាពអាចមានឡើង)

***Probarbus jullieni*** [sci.n] សូមមើលពាក្យ៖ seven-line barb

***Probarbus labeamajor*** [sci.n] សូមមើលពាក្យ៖ tricklip barb

***Probarbus labeamajor*** [sci.n] សូមមើលពាក្យ៖ thilip barb

***Probarbus labeaminor*** [sci.n] សូមមើលពាក្យ៖ thinlip barb

**probe** /prəʊb/ [n] សន្ទង់, ការរុករក

**proboscis** /prəˈbɒsɪs (pl. prəˈbɒsiːz)/ [n] (ពហុវចនៈ៖ probosces) ប្រូបូស៊ីស, មាត់វែង (ចំពោះសត្វល្អិត)

**procaine** /ˈprəʊkeɪn/ [n] ប្រូកាអ៊ីន (ប្រើធ្វើឱ្យស្ពឹកសាច់)

**procedure** /prəˈsiːdʒə/ [n] នីតិវិធី

**process** /ˈprəʊsɛs/ [n] ដំណើរប្រព្រឹត្ត, របៀប, លំនាំ

- activated sludge process /ˈaktɪveɪtɪd ˈprəʊsɛs/ [n] ដំណើរប្រព្រឹត្តដោយភក់សកម្ម
- anaerobic process /ˌanɛːˈrəʊbɪk ˈprəʊsɛs/ [n] ដំណើរប្រព្រឹត្តគ្មានខ្យល់
- biological process /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˈprəʊsɛs/ [n] ដំណើរប្រព្រឹត្តជីវសាស្ត្រ
- gleying process /gleɪŋ ˈprəʊsɛs/ [n] សូមមើលពាក្យ៖ gleization
- physiological process /ˌfɪzɪəˈlɒdʒɪk(ə)l ˈprəʊsɛs/ [n] ដំណើរសរីរៈ
- training process /ˈtreɪnɪŋ ˈprəʊsɛs/ [n] ដំណើរការវគ្គបណ្តុះបណ្តាល

**processing** / ˈprəʊsɛsɪŋ/ [n] ដំណើរការ (ឧ. ទិន្នន័យ), ការកែច្នៃ (ឧ. ម្ហូបអាហារ)

- downstream processing /ˌdaʊnˈstriːm ˈprəʊsɛsɪŋ/ [n] ដំណើរការប្រមូលផល
- food processing /fuːd ˈprəʊsɛsɪŋ/ [n] ការកែច្នៃស្បៀងអាហារ (វិធីណាមួយដែលគេប្រើដើម្បីបំលែងវត្ថុធាតុដើមដែលអាចបរិភោគបានឱ្យទៅជាទម្រង់មួយផ្សេងទៀតក្នុងគោលបំណងប្រើប្រាស់ ឬបរិភោគ។ អត្ថប្រយោជន៍អាចរួមមាន អាចស្តុកទុកបានយូរ ងាយប្រើប្រាស់ ឬងាយបរិភោគជាងមុន ងាយ ស្រួលក្នុងការដឹកជញ្ជូនជាងមុន និងមានរសជាតិប្រសើរជាងមុន និងមានឱជារស។)
- food processing /fuːd ˈprəʊsɛsɪŋ/ [n] ការកែច្នៃម្ហូបអាហារ
- seed processing /siːd ˈprəʊsɛsɪŋ/ [n] សូមមើលពាក្យ៖ seed cleaning

**procidentia** /prəʊsɪdɛntia/ [n] ដែលស្រុត ឬទ្រុឌទ្រោមសរីរាង្គ

**proctoscopy** /prɒkˈtɒskəpi/ [n] ការឆ្លុះពិនិត្យចុងពោះវៀន

**produce** /prəˈdjuːs/ [v] (សទិសន័យ៖ generate) ផលិត, បង្កើត

**product** /ˈprɒdʌkt/ [n] ផលិតផល

- anonymous product /əˈnɒnɪməs ˈprɒdʌkt/ [n] ផលិតផលអានាមិក
- competitive product /kəmˈpɛtɪtɪv ˈprɒdʌkt/ [n] ផលិតផលប្រជែងគ្នា
- designer product /dɪˈzʌɪnə ˈprɒdʌkt/ [n] ផលិតផលដែលបង្កើតឡើងដោយអ្នកជំនាញខាងគូរប្លង់
- domestic product /dəˈmɛstɪk ˈprɒdʌkt/ [n] ផលិតផលក្នុងស្រុក
- end-product /ɛnd ˈprɒdʌkt/ [n] ផលិតផលសម្រេច
- food product /fuːd ˈprɒdʌkt/ [n] ផលិតផលស្បៀង (មុខអាហារណាមួយដែលអាចបរិភោគបានទទួលរងនូវការកែច្នៃអាហារក្នុងទម្រង់ណាមួយ នៅមុនពេលដែលអាហារនោះត្រូវបានបរិភោគ)
- forest product /ˈfɒrɪst ˈprɒdʌkt/ [n] ផលិតផលព្រៃឈើ
- non timber forest products (NTFPs) /nɒn ˈtɪmbə ˈfɒrɪst ˈprɒdʌkts/ [n] អនុផលព្រៃឈើ
- phytosanitary product /ˌfʌɪθəʊˈsanɪt(ə)ri ˈprɒdʌkt/ [n] ផលិតផលភូតគាមអនាម័យ
- recycling product /riːˈsʌɪk(ə)lɪŋ ˈprɒdʌkt/ [n] ផលិតផលកែច្នៃ
- secondary product /ˈsɛk(ə)nd(ə)ri ˈprɒdʌkt/ [n] សូមមើលពាក្យ៖ by-product

**producer** /prəˈdjuːsə/ [n] អ្នកផលិត, ភាវស្វ័យជីព
- primary producer /ˈprʌɪm(ə)ri prəˈdjuːsə/ [n] ភាវស្វ័យជីព

**production** /prəˈdʌkʃ(ə)n/ [n] ផលិតកម្ម
- charcoal production /ˈtʃan(ə)l prəˈdʌkʃ(ə)n/ [n] ផលិតកម្មធ្យូង
- crop production /krɒp prəˈdʌkʃ(ə)n/ [n] ផលិតកម្មដំណាំ
- food production /fuːd prəˈdʌkʃ(ə)n/ [n] ផលិតកម្មស្បៀង
- mechanical production /mɪˈkanɪk(ə)l prəˈdʌkʃ(ə)n/ [n] ផលិតកម្មមេកានិច (ផលដែលបានពីអំពើមេកានិច)
- rice production /rʌɪs prəˈdʌkʃ(ə)n/ [n] បរិមាណផលស្រូវ, ផលិតកម្មស្រូវ
- seed production /siːd prəˈdʌkʃ(ə)n/ [n] ផលិតកម្មគ្រាប់ពូជ (ដំណើរការមួយដែលក្នុងនោះគ្រាប់ពូជសុទ្ធត្រូវបានផលិតឡើងតាមលំដាប់លំដោយ)
- sustainable agricultural production /səˈsteɪnəb(ə)l agrɪˈkʌltʃərəl prəˈdʌkʃ(ə)n/ [n] ផលិតកម្មកសិកម្មសមស្រប, ផលិតកម្មកសិកម្មប្រកបដោយនិរន្តរភាព

**productivity** /prɒdʌkˈtɪvɪti/ [n] ផលិតភាព, ដំណើរឱ្យផល
- agricultural productivity /agrɪˈkʌltʃərəl prɒdʌkˈtɪvɪti/ [n] ផលិតភាពកសិកម្ម
- soil productivity /sɔɪl prɒdʌkˈtɪvɪti/ [n] ផលិតភាពដី (សមត្ថភាពរបស់ដីក្នុងមជ្ឈដ្ឋានធម្មតាមួយ ដើម្បីផលិតដំណាំកំណត់មួយ ឬដាំដំណាំបន្តបន្ទាប់គ្នាក្រោមប្រព័ន្ធគ្រប់គ្រងដ៏ត្រឹមត្រូវមួយ។ ផលិតភាពដីបង្ហាញពីសមត្ថភាពនៃដីដើម្បីផលិតដំណាំ ហើយត្រូវបានបញ្ជាក់ ឬកំណត់ដោយទិន្នផលដំណាំ)

**profile** /ˈprəʊfʌɪl/ [n] ទម្រង់, ពណ៌ត្រួសៗ, ទម្រង់ដីតាមខ្នាតទទឹង
- abnormal profile /əbˈnɔːm(ə)lˈprəʊfʌɪl/ [n] ប្រូហ្វីលខុសធម្មតា (ដី)
- level bottom normal profile /ˈlɛv(ə)l ˈbɒtəm ˈnɔːm(ə)l ˈprəʊfʌɪl/ [n] ប្រូហ្វីលធម្មតាដែលមានបាតស្មើ (នៃតែរ៉ាស់សិប្បនិម្មិត)
- major profile /ˈmeɪdʒəˈprəʊfʌɪl/ [n] ប្រូហ្វីលធំ
- melting profile /mɛltɪŋ ˈprəʊfʌɪl/ [n] សីតុណ្ហភាពរលាយ
- normal profile /ˈnɔːm(ə)lˈprəʊfʌɪl/ [n] ប្រូហ្វីលធម្មតា (នៃដីចាស់ជ្រៅ)
- soil profile /sɔɪl ˈprəʊfʌɪl/ [n] ប្រូហ្វីលដី (ពំនុះស្រទាប់ដីតាមខ្សែឈរចាប់ពីផ្ទៃ ឬស្រទាប់ខាងលើរហូតដល់ស្រទាប់គ្រឹះ (ស្រទាប់មេបា))
- truncated profile /trʌŋˈkeɪtɪd ˈprəʊfʌɪl/ [n] ប្រូហ្វីលកាត់ (ដី) ពីលើ
- uniform profile /ˈjuːnɪfɔːmˈprəʊfʌɪl/ [n] ប្រូហ្វីលដែលមានរាងដូចគ្នា (ដី)

**profit** /ˈprɒfɪt/ [n] ចំណេញ

**profitability** /prɒfɪtəˈbɪlɪti/ [n] ធនវិទ្ធ, វិទ្ធភាព

**progeny** /ˈprɒdʒəni/ [n] កូន, ចៅ

**proglottid** /prəʊˈglɒtɪd/ [n] (សទិសន័យ៖ segment) កង (ដង្កូវសំប៉ែត)

**prognosis** /prɒgˈnəʊsɪs/ [n] បំនាន់ (ការប្រមើលមើលទុកជាមុន)

**programme** /ˈprəʊgram/ [n] កម្មវិធី
- extension programme /ɪkˈstɛnʃ(ə)n ˈprəʊgram/ [n] កម្មវិធីផ្សព្វផ្សាយ
- rice breeding programme /rʌɪs ˈbriːdɪŋ ˈprəʊgram/ [n] កម្មវិធីជម្រើសពូជស្រូវ
- varietal improvement programme /vəˈrʌɪət(ə)l ɪmˈpruːvm(ə)nt ˈprəʊgram/ [n] កម្មវិធីបសិដ្ឋកម្មពូជ (កម្មវិធី ដែលក្នុងនោះពូជថ្មីៗត្រូវបានបង្កើត និងជ្រើសរើសសម្រាប់ក្សេត្របរិស្ថាន និងតំបន់ខុសៗគ្នា ឬទៅតាមគុណភាព ឬលក្ខណៈចង់បានណាមួយ)

**progress** /ˈprəʊgrɛs/ [n] ភាពជឿនលឿន, វឌ្ឍនភាព, ដំណើរទៅមុខ

**project** /ˈprɒdʒɛkt/ [n] គម្រោង, ផែនការ

**projection** /prəˈdʒɛkʃ(ə)n/ [n] ការធ្វើសន្ទន៍

**prolapse** /prəˈlaps/ [v] ស្រុត, ការស្រុតចុះនៃសរីរាង្គ

**proliferate** /prəˈlɪfəreɪt/ [v] ដុះកូនឈើពីកោសិកា, កើតកូនចៅច្រើន, សាយកូន, ផ្លែច្រើន

**proliferation** /prəlɪfəˈreɪʃn/ [n] សំណាយកូន, សំណាយពូជ

**prolific** /prəˈlɪfɪk/ [adj] សាយកូន, ផ្លែច្រើន

**prolong** /prəˈlɒŋ/ [v] បន្តឱ្យវែង, ធ្វើឱ្យបានយូរ, អូសបន្លាយពេល

**prolonged** /prəˈlɒŋd/ [adj] ដែលធ្វើឱ្យបានយូរ, ដែលអូសបន្លាយពេល

**Promethium** /prəˈmiːθɪəm/ [n] ប្រូមេចូម (និមិត្តសញ្ញាគីមី Pm)

**prominent** /ˈprɒmɪnənt/ [adj] ចំណាន, ល្បីល្បាញ

**flood prone** /flʌd prəʊn/ [adj] និន្នាការជំនន់ (តំបន់ដែលរមែងជួបប្រទះទឹកជំនន់)

**prontosil** /ˈprɒntəsɪl/ [n] ប្រុងតូស៊ីល (ថ្នាំរម្ងាប់មេរោគ)

**propagate** /ˈprɒpəgeɪt/ [v] សាយពូជ, កាត់បណ្ដុះ, បណ្ដុះ, ផ្សាំ, បណ្ដុះតៗគ្នា, ធ្វើវិបុលកម្ម (ពង្រីកផ្សាយនៃពូជរុក្ខជាតិតាមរយៈការបណ្ដុះបន្តគ្នា)

**propagation** /ˈprɒpəgeɪʃ(ə)n/ [n] វិបុលកម្ម (ការពង្រីកផ្សាយនៃពូជសត្វ រុក្ខជាតិតាមការបណ្ដុះបណ្ដាលតៗគ្នា), ការដាំ ឬបណ្ដុះនូវរុក្ខជាតិថ្មីពីគ្រាប់ ពន្លក ការកាត់ ឬបំបៅ

- clonal propagation /ˈkləʊn(ə)l prɒpəˈgeɪʃ(ə)n/ [n] (សទិសន័យ៖ Vegetative propagation) ការផលិតកូនឈើពីការផ្សាំ ឬបំបៅ ឬកាត់មែក
- mass propagation /mas prɒpəˈgeɪʃ(ə)n/ [n] ការបណ្ដុះកូនឈើច្រើន, ការផលិតកូនឈើជាទ្រង់ទ្រាយធំ
- vegetative propagation /ˈvɛdʒɪtətɪv prɒpəˈgeɪʃ(ə)n/ [n] ការផលិតកូនឈើពីការផ្សាំ បំបៅ ឬកាត់មែក, ការបន្តពូជដោយសរីរាង្គឥតភេទ (ឧ. ពន្លកខ្ទឹង), ការបន្តពូជតាមសរីរាង្គលូតលាស់ (ការបន្តពូជរបស់រុក្ខជាតិមួយតាមមធ្យោបាយឥតភេទដូចជា ពន្លកខ្ទឹង បំបៅ ការបណ្ដុះកំណាត់មែក ហើយនិងការផ្សាំមែក។ លក្ខណៈតំណពូជរបស់កូនបំបៅ (សាពាង្គកាយចម្លង) គឺមានលក្ខណៈដូចដើមមេរបស់វា។)

**propagule** /ˈprɒpəgjuːl/ [n] សរីរាង្គសម្រាប់បណ្ដុះកូនឈើ, សរីរាង្គសម្រាប់បណ្ដុះកូនក្លូន កូនខ្លួនតូចៗ (ដែលបំបែកចេញពីគ្នា), សរីរាង្គបន្តពូជ (សំដៅផ្នែកនៃរុក្ខជាតិដែលអាចបន្តពូជបានដូចជាគ្រាប់ ឬមើមជាដើម)

**propane** /ˈprəʊpeɪn/ [n] ប្រូប៉ាន

**proper** /ˈprɒpə/ [adj] ដែលត្រូវ, ដែលត្រឹមត្រូវ

**property** /ˈprɒpəti/ [n] លក្ខណៈ, សមត្ថភាព, កម្មសិទ្ធិ, ទ្រព្យសម្បត្តិ

- wood properties /wʊd ˈprɒpətis/ [n] លក្ខណៈរបស់ឈើ (សារធាតុដែលទាក់ទាញអ្នកប្រើប្រាស់ឈើដូចជាភាពធន់ ពណ៌ ដង់ស៊ីតេ សរសៃឈើ និងការប្រើប្រាស់)

**prophylactic** /ˌprɒfɪˈlaktɪk/ [n] វិធីបង្ការជំងឺ

**prophylaxis** /ˌprɒfɪˈlaksɪs/ [n] វិធីការពារជំងឺ

**prophyllum** /prəʊˈfʌɪləm/ [n] ខ្នែងមិនបានការ (ខ្នែងម្យ៉ាងដូចស្លឹក តែគ្មានបន្ទះស្លឹកដុះចេញពីគល់នៃដើមស្រូវ។ ខ្នែងនេះ ដុះចេញបានតែក្នុងរយៈកាលខ្លីមួយក៏ស្រពោនងាប់ទៅវិញ។)

**proposal** /prəˈpəʊz(ə)l/ [n] សំណើសុំ (គម្រោង)

- grant proposal /grant prəˈpəʊz(ə)l/ [n] សំណើសុំថវិកា
- training proposal /ˈtreɪnɪŋ prəˈpəʊz(ə)l/ [n] សំណើសុំបើកវគ្គបណ្ដុះបណ្ដាល

**proprietary** /prəˈprʌɪət(ə)ri/ [adj] ម្ចាស់កម្មសិទ្ធិ

**prostaglandin** /ˌprɒstəˈglandɪn/ [n] ប្រូស្តាក្លង់ឌីន

**prostate (gland)** /ˈprɒsteɪt/ [n] ក្រពេញប្រូស្តាត, ក្រពេញព័ទ្ធបំពង់នោមប្រុស

**prostatectomy** /ˌprɒstəˈtɛktəmi/ [n] ការវះកាត់ក្រពេញព័ទ្ធ

**prosthodontic** /ˌprɒsθəˈdɒntɪks/ [adj] វិធិ, នៃទន្តជួសពេទ្យវិទ្យា

**Protactinium** /ˌprəʊtakˈtɪnɪəm/ [n] ប្រូតាក់ទីញ៉ូម (និមិត្តសញ្ញាគីមី Pa)

**protandric** /prəʊtanˈdrɪk/ [adj] កេសរឈ្មោលរោយមុន (កេសរញី)

**protandry (male-first)** [n] ការរោយកេសរឈ្មោលមុនកេសរញី

**protect** /prəˈtɛkt/ [v] គាំពារ, ការពារ

**protection** /prəˈtɛkʃ(ə)n/ [n] កិច្ចការពារ, ការការពារ

- environment protection /ɪnˈvʌɪrənm(ə)nt prəˈtɛkʃ(ə)n/ [n] ការការពារបរិស្ថាន
- plant protection /plɑːnt prəˈtɛkʃ(ə)n/ [n] ការការពារដំណាំ
- social protection /ˈsəʊʃ(ə)l prəˈtɛkʃ(ə)n/ [n] ការការពារសង្គម
- wilderness protection /ˈwɪldənɪs prəˈtɛkʃ(ə)n/ [n] ការពារទីរហោស្ថាន

**protein** /ˈprəʊtiːn/ [n] ប្រូតេអ៊ីន
- complete protein /kəmˈpliːt ˈprəʊtiːn/ [n] ប្រូតេអ៊ីនពេញលេញ (ម៉ូលេគុលប្រូតេអ៊ីនដែលផ្តល់គ្រប់អាស៊ីតអាមីនេសំខាន់ទាំងអស់)
- conjugated protein /ˈkɒndʒʊgeɪtɪd ˈprəʊtiːn/ [n] ប្រូតេអ៊ីនឆ្លាស់
- fibrous proteins /ˈfʌɪbrəs ˈprəʊtiːnz/ [n pl] ប្រូតេអ៊ីនសរសៃ
- globular proteins /ˈglɒbjʊlə ˈprəʊtiːnz/ [n pl]
- ប្រូតេអ៊ីនគ្រាប់
- native protein /ˈneɪtɪv ˈprəʊtiːn/ [n] ប្រូតេអ៊ីនកើតតាមធម្មជាតិ

**Proteobacteria** /prəʊˈteɪəʊbakˈtɪərɪə/ [n] (សទិសន័យ៖ purple bacteria) បាកតេរីពណ៌ស្វាយ (ប្រូតេអូបាក់តេរី)

**proteolytic** /ˌprəʊtiːəˈlɪtɪk/ [adj] ដែលរំលាយប្រូតេអ៊ីន

**proteus** /ˈprəʊtɪəs/ [n] ប្រូតេអាស (អង់ស៊ីមរម្លាយប្រូទីត)

**prothesis** /ˈprɒθɪsɪs/ [n] សិប្បនិម្មិតកាយគន្លះ, ការធ្វើឱ្យមាន រចនាវិចិត្រ ដើម្បីប្រើជំនួសអវយវៈ (អវយវៈក្លែង ក្លាយ ឬគ្រឿងឧបករណ៍ យកមកប្រើជំនួសអវយវៈសពាង្គកាយ)

**prothorax** /prəʊˈθɔːraks/ [n] (ចំពោះសត្វល្អិត) ទ្រូងមុខ, ដើមទ្រូង (ផ្នែកខាងមុខនៃទ្រូងរបស់សត្វល្អិត ដែលមានដុះជើងមុខមួយគូ)

**prothrombin** /prəʊˈθrɒmbɪn/ [n] វត្ថុធាតុនៃឈាមដែលជួយបង្កកឈាម

**proto-** /ˈprəʊtəʊ/ [prefix] (សទិសន័យ៖ first of a series) បុព្វបទមានន័យថា ទីមួយ

**protocol** /ˈprəʊtəkɒl/ [n] ពិធីការ, គម្រោង (ការរៀបចំឱ្យមានរបៀបរៀបរយ និងសណ្តាប់ធ្នាប់ល្អក្នុងពិធីអ្វីមួយ)

**protogynous** /prəʊˈtɒdʒɪnəs/ [adj] កេសរញីចាយមុន (កេសរឈ្មោល)

**protogyny (female-first)** /prəʊˈtɒdʒɪnɪ/ [n] ការចាយកេសរញីមុនកេសរឈ្មោល

**proton** /ˈprəʊtɒn/ [n] ប្រូតុង

**protophyte** /ˈprəʊtəʊfʌɪt/ [n] រុក្ខជាតិឯកកោសិកា

**protoplasm** /ˈprəʊtə(ʊ)ˌplaz(ə)m/ [n] ប្រូតូប្លាស
- soil protoplasm /sɔɪl ˈprəʊtə(ʊ)plaz(ə)m/ [n] (សទិសន័យ៖ microskeleton) ឆ្អឹងដី, មាត្រដ្ឋានល្អិត

**prototype** /ˈprəʊtətʌɪp/ [n] គំរូដើម

**protozoa** /ˌprəʊtəˈzəʊə/ [n] សត្វឯកកោសិកា, ប្រូតូសូអ៊ែរ

**protrude** /prəˈtruːd/ [v] លយចេញ

**protuberance** /prəˈtjuːb(ə)r(ə)ns/ [n] ពក

**provenance** /ˈprɒv(ə)nəns/ [n] ដើមកំណើត (តំបន់ដើមកំណើតរបស់ប្រភពគ្រាប់ពូជ)

**proventriculus** /ˌprəʊvɛnˈtrɪkjʊləs/ [n] ប្រូវង់ទ្រីគុល

**provide** /prəˈvʌɪd/ [v] ផ្គត់ផ្គង់

**provision** /prəˈvɪʒ(ə)n/ [n] ការផ្តល់ឱ្យ

**provitamin** /ˈprəʊvɪtəmɪn/ [n] ប្រូវីតាមីន

**proximal** /ˈprɒksɪm(ə)l/ [adj] ប្រុកស៊ីមាល់, ជិតចំណុចភ្ជាប់ (ផ្ទុយឆ្ងាយពីចំណុចភ្ជាប់), ដែលនៅជិតបំផុតគល់ ឬស ឬដើម (នៅខាងចុងទាំងខាងគល់នៃឫស ឬទាំងគល់នៃដើម គឺថានៅកៀកជាប់នឹង ទីប្រសព្វរវាងគល់ និងឫសរបស់រុក្ខជាតិ ហើយជាចំណុចឆ្ងាយបំផុតពីចុង របស់ឫស ឬកំពូលត្រួយ។ ពាក្យន័យផ្ទុយ Distal ដែលនៅឆ្ងាយបំផុត។)

**pruning** /pruːnɪŋ/ [n] ការក្រៀវ, ការច្រិប, ការកាត់មែក

**crop pruning** /krɒp pruːnɪŋ/ [n] ការកាត់សម្អាត (ការកាត់សម្អាត ស្លឹក ឬដើមចាស់ៗចោល)

***Prunus persica*** [sci.n] សូមមើលពាក្យ៖ peach

**pruritus** /prʊˈrʌɪtəs/ [n] រមាស់, ជំងឺរមាស់ខ្លាំង

***Pseudambassis notatus*** [sci.n] សូមមើលពាក្យ៖ Siamese glassfish

**pseudo-** /ˈsjuːdəʊ/ [prefix] (សទិសន័យ៖ false) បុព្វបទមានន័យថា មិនពិត, ប្រហាក់ប្រហែល

**pseudobacterium** /ˈsjuːdəʊ bakˈtɪərɪəm/ [adj] ស្រដៀងបាក់តេរី

**pseudocarp** /ˈsjuːdə(ʊ)kɑːp/ [n] ប្រភេទផ្លែមិនពិត, ផ្លែក្លែងក្លាយ, ផ្លែបញ្ឆោត, សាច់ទម្រង់ស្រោបពីក្រៅអូវែ, ផ្លែរហស្សសាច់ (សាច់ផ្លែស្រោបអូវែ)

**pseudo-corpus luteum** /ˈsjuːdəʊ ˈkɔːpəs ˈluːtɪəm/ [n] គ្មានដំណើរអូវុល

**pseudocyesis** /ˌsjuːdəʊsʌɪˈiːsɪs/ [adj] ដូចដើម

**variety of pseudogley** /vəˈrʌɪəti ˈsjuːdəʊgleɪ/ [n] លោមឥដ្ឋល្បាយដែលមានស្នាមខៀវ ប្រផេះ និងច្រែះ

***Pseudogonatopus flavifemur*** [sci.n] ពួកឪម៉ាល់ (បរាសិត ឬរំពាលើមមាច)

***Pseudogonatopus nudus*** [sci.n] ពួកឪម៉ាល់ (បរាសិតឬរំពាលើមមាច)

**pseudomembrane** /ˌsjuːdəʊˈmɛmbreɪn/ [n] ភ្នាសបញ្ឆោត

**pseudomonas** /ˌsjuːdə(ʊ)ˈməʊnəs/ [n] សីដូមីណាស (ធ្វើឱ្យខ្ទុះឡើងខៀវ), បាក់តេរីដែលអាចនៅក្នុងខ្ទុះឬដំបៅ

**pseudorabies** /ˌsjuːdəʊˈreɪbiːz/ [n] សូមមើលពាក្យ៖ Aujesky's disease

***Pseudorca crassidens*** [sci.n] សូមមើលពាក្យ៖ false killer whale

***Psidium guajava*** [sci.n] សូមមើលពាក្យ៖ guava

**psittacosis** /ˌsɪtəˈkəʊsɪs/ [n] ជំងឺស៊ីតាកូស (ជំងឺបក្សីអាចឆ្លងមកមនុស្ស)

***Psix lacunata*** [sci.n] ឪម៉ាល់ (បរាសិតលើពងសង្កើចខ្មៅ)

***Psophocarpus tetragonolobus*** [sci.n] សូមមើលពាក្យ៖ winged bean

**psoriasis** /sɒˈrʌɪəsɪs/ [n] រោគបែកស្រការបកស្បែកព្រុំរើ

**psychology** /sʌɪˈkɒlədʒi/ [n] ចិត្តវិទ្យា

**ptyalin** /ˈtʌɪəlɪn/ [n] ត្យាលីន (អាមីឡាសទឹកមាត់)

**pubescent** /pjʊˈbɛs(ə)nt/ [adj] ដែលមានរោមខ្លីៗ, ដែលមានមមិះខ្លីៗ (ប្រភេទរោមលើស្លឹក)

**pubic** /ˈpjuːbɪk/ [n] ឆ្អឹងពុយប៊ីស

**pubis** /ˈpjuːbɪs/ [n] ឆ្អឹងថ្ងាស, ថ្ងាសយោនី ឬអង្គជាត

**pudding** /ˈpʊdɪŋ/ [n] ការបំផ្លាញ ឬកម្ទេចទម្រង់ (ឧ. ដី)

**puddle** /ˈpʌd(ə)l/ [v] បូកដីឥដ្ឋ, ដាក់ដីឥដ្ឋលាយក្នុងដីលាយបាយអ, បំបែកដីមុនពេលដាំដំណាំ, រៀបចំដីមុខពេលដាំដំណាំ

**puddle** /ˈpʌd(ə)l/ [n] គ្រលុកមានទឹកដក់

**puddled** /ˈpʌd(ə)ld/ [adj] ដែលធ្វើឱ្យហាប់ (ដោយទម្រង់ដីដែលខូចខាត)

**puddling** /ˈpʌd(ə)lɪŋ/ [n] ការរាស់បំបែកភក់

**puerperal sepsis** /pjuːˈəːpər(ə)l ˈsɛpsɪs/ [n] ជំងឺឈាមក្រោយពេលសម្រាលកូនរួច ពីព្រោះមេរោគបានចូលតាមយោនី ឬស្បូន

**pulicidae** /ˈpʌblɪsɪdi/ [n] ពពួកចៃ

**pullet** /ˈpʊlɪt/ [n] មាន់ញីជំទង់

**pulley** /ˈpʊli/ [n] រ៉ក

**pulling** /pʊlɪŋ/ [n] ដំណក (សំណាប)

**pulmonary** /ˈpʌlmən(ə)ri/ [adj] នៃសួត, ប្រព័ន្ធសួត

**pulp** /pʌlp/ [n]

១. (ចំពោះសត្វ) បណ្តូលធ្មេញ

២. (ចំពោះរុក្ខជាតិ) សាច់ផ្លែឈើ (ផ្នែកសាច់របស់ផ្លែដែលអាចកើតឡើងពីភេរីខាបទាំងស្រុង(ផ្លែបើរី) ឬកើតពីតែអ៊ិចសូខាប និងមេសីខាប(ផ្លែខ្ទប)។ ចំពោះប្រភេទពូជខ្លះអាចរួមមានទាំងអារីល និងសាច់រុំគ្រាប់ផងដែរ។)

**pulper** /ˈpʌlpə/ [n] ម៉ាស៊ីនដកគ្រាប់ផ្លែឈើ

**pulpwood** /ˈpʌlpwʊd/ [n] ឈើមូល, កម្ទេចឈើ, សំណល់ឈើ (ដែលប្រើប្រាស់សម្រាប់ផលិតកម្មឈើ)

**pulse** /pʌls/ [n]

១. (ចំពោះសត្វ) ជីពចរ

២. (ចំពោះរុក្ខជាតិ) ពួកសណ្តែក ដែលយកគ្រាប់សម្រាប់ធ្វើអាហារ

**pulse oximeter finger probe** [n] ប្រដាប់វាស់ជីពចរពិនិត្យតាមម្រាមដៃ

**pump** /pʌmp/ [n] ស្នប់ខ, ប្រដាប់បូម, ម៉ាស៊ីនបូម

- air pump /ɛː pʌmp/ [n] ស្នប់ខ្យល់
- axial flow pump /ˈaksɪəl fləʊ pʌmp/ [n] ស្នប់បណ្តោយអ័ក្ស (ស្នប់បូមទឹកដែលទិសដៅបឺត និងបញ្ចេញស្របតាមបណ្តោយកង្ហាបឺត)
- blood pump /blʌd pʌmp/ [n] ស្នប់បំពង់បញ្ចូលឈាម (សម្រាប់ធ្វើឱ្យឈាមហូរស្រួល)
- breast pump /brɛst pʌmp/ [n] ប្រដាប់បូមទឹកដោះចេញ
- electric pump /ɪˈlɛktrɪk pʌmp/ [n] ម៉ូទ័របូមទឹក
- fuel injection pump /fjuː(ə)l nˈdʒɛkʃ(ə)n pʌmp/ [n] កូនជ្រុកចលករ (បូមសម្ពាធខ្ពស់សម្រាប់បាញ់ប្រេងទៅប៊ិចចលករ)
- hydraulic pump /hʌɪˈdrɔːlɪk pʌmp/ [n] បូមអ៊ីដ្រូលិក (ស្នប់ដែលផ្តល់សម្ពាធទៅដៃឃ្នាសលើកដាក់នៃគ្រាក់ទ័រ ឬឧបករណ៍ផ្សេងៗ)
- oil pump /ɔɪl pʌmp/ [n] បូមប្រេងរំអិល (ស្នប់ប្រេងរំអិលសម្រាប់ចែកទៅគ្រប់ប្រព័ន្ធចលនានៃចលករ)
- prime a pump /ˈprʌɪm(ə)ri eɪ pʌmp/ [n] វិធីដែលប្រើចំណាយនាំមុខដើម្បីដកយកផល, ម៉ូយទឹក (ស្នប់បូម)

- sipa pump /sipɑː pʌmp/ [n] ស្នប់ស៊ីប៉ា (ស្នប់បូមទឹកប្រភេទបណ្ដោយអ័ក្សឈ្មោះស៊ីប៉ា)
- tapak-tapak pump /ˈtɑːpək ˈtɑːpək pʌmp/ [n] ស្នប់អង្កៀក
- water pump /ˈwɔːtə pʌmp/ [n] ស្នប់បូមទឹក

**pumpkin** /ˈpʌm(p)kɪn/ [n] ល្ពៅធំ (ឈ្មោះវិទ្យាសាស្ត្រ *Cucurbita maxima*)

**punarvana** [n] ផ្ទីថ្មឈ្មោល (ឈ្មោះវិទ្យាសាស្ត្រ *Boerhavia diffusa*)

**punctate** /ˈpʌŋ(k)teɪt/ [adj] ចំនុចបន្ត, ឡើងអុចៗ

**puncture** /ˈpʌŋ(k)tʃə/ [n] ចំណាក់បូម

**puncture** /ˈpʌŋ(k)tʃə/ [v] ចាក់, ធ្វើឱ្យធ្លុះ, ចោះទម្លុះ

***Punica granatum*** [sci.n] សូមមើលពាក្យ៖ pomegranate

***Puntioplites bulu*** [sci.n] ត្រីគជ្រា, ត្រីកញ្ច្រៀ

***Puntioplites bulu*** [sci.n] ត្រីគជ្រា

***Puntioplites falcifer*** [sci.n] ត្រីច្រកែង

***Puntioplites proctozysron*** [sci.n] ត្រីច្រកែង

***Puntioplites sp. cf. wanndersi*** [sci.n] ត្រីច្រកែង

***Puntioplites waandersi*** [sci.n] ត្រីច្រកែង

***Puntius brevis*** [sci.n] សូមមើលពាក្យ៖ swamp barb

***Puntius masyai*** [sci.n] ត្រីអង្កត់ប្រាក់

**pupa** /ˈpjuːpə/ [n] (ពហុវចនៈ៖ pupae) ដុកដឿ

**pupate** /pjuːˈpeɪt/ [v] ក្លាយជាដុកដឿ

**pupil** /ˈpjuːpɪl/ [n] (សទិសន័យ៖ retina) វន្នប្រស្រី

**pure** /pjʊə/ [adj] សុទ្ធ, បរិសុទ្ធ

**purgative** /ˈpəːgətɪv/ [n] (សូមមើលពាក្យ៖ laxative) ថ្នាំបញ្ចុះ

**purification** /pjʊərɪfɪˈkeɪʃ(ə)n/ [n] សម្អាត, សុទ្ធិកម្ម, បន្សុទ្ធកម្ម (ដំណើរការដែលក្នុងនោះកម្រិតសុទ្ធភាពនៃគ្រាប់ពូជកើនឡើងដោយការកាត់ចោលនៃពូជលាយ)

- self-purification /sɛlf pjʊərɪfɪˈkeɪʃ(ə)n/ [n] ស្វ័យសុទ្ធិកម្ម

**purifier** /ˈpjʊərɪfʌɪə/ [n] ឧបករណ៍បន្សុទ្ធ, ឧបករណ៍សម្អាត

**purify** /ˈpjʊərɪfʌɪ/ [v] បន្សុទ្ធ, សម្អាត, ធ្វើឱ្យបរិសុទ្ធ

**purity** /ˈpjʊərɪti/ [n] ភាពសុទ្ធ (សមាមាត្រនៃភាពស្អាតគ្រាប់មូលស្អាត (យោងទៅតាមនិយមន័យគ្រាប់សុទ្ធ) នៃប្រភេទពូជដែលគេកំណត់នៅក្នុងកញ្ចប់គ្រាប់ ជាធម្មតាភាពសុទ្ធសម្ដែងជាខ្នាតភាគរយនៃទម្ងន់)

- seed purity /siːd ˈpjʊərɪti/ [n] សុទ្ធភាពនៃគ្រាប់ពូជ (ភាពនៃគ្រាប់ពូជដែលគ្មានការលាយពីសំណាក់គ្រាប់ស្មៅ គ្រាប់ពូជដទៃទៀត និងអង្គធាតុផ្សេងៗដូចជាដុំក្រួស ឬខ្សាច់ជាដើម)

**purple nutsedge** /ˈpəːp(ə)l ˈnətsej/ [n] ស្មៅក្រវាញជ្រូក (ឈ្មោះវិទ្យាសាស្ត្រ *Cyperus rotundus*)

**purpura** /ˈpəːpjʊrə/ [n] ពួពុយរ៉ា (ជំងឺពួព្រៃ ជំងឺជាំស្បែក និងគ្រឿងក្នុង), ការមានពណ៌ស្វាយជាដុំៗ នៅលើស្បែក និងស្រទះស្លេស

**purr** /pəː/ [v] ង៉ាវៗ (ដូចឆ្មាស្រែក)

**purslane** /ˈpəːslən/ [n] ក្បិចជូន (ឈ្មោះវិទ្យាសាស្ត្រ *Portulaca oleracea*)

**purulent** /ˈpjʊərʊl(ə)nt/ [adj] គំខ្ទុះ

**pus** /pʌs/ [n] ខ្ទុះ

**pustule** /ˈpʌstjuːl/ [n] ពងខ្ទុះ

**putrefaction** /ˌpjuːtrɪˈfakʃ(ə)n/ [n] ការរលួយ, ភាពពុករលួយ

**putrid** /ˈpjuːtrɪd/ [adj] ស្អុយ, រលួយ

**pyelogram** /ˈpʌɪələ(ʊ)gram/ [n] ការថតបំពង់នោមដោយរស្មីអិក្ស

**pyelonephritis** /ˌpʌɪələʊnɪˈfrʌɪtɪs/ [n] ជំងឺរលាកវក្កំ និងផ្នែកបំពង់នោម

**pyemia** /pʌɪˈiːmɪə/ [n] ខ្ទុះខូរអណ្ដែង, ខ្ទុះលាយនឹងឈាម

**pygmy gourami** /ˈpɪgmi gʊ(ə)ˈrɑːmi/ [n] ត្រីក្រឹមទន្សាយ (ឈ្មោះវិទ្យាសាស្ត្រ *Trichopsis pumila*)

**pyloric** /pʌɪˈlɒrɪk/ [n] នៃទ្វារក្រពះចូលក្នុងពោះវៀនតូច

**pylorus** /pʌɪˈlɔːrəs/ [n] ទ្វារក្រោមក្រពះ

**pyo-** /ˌpʌɪə/ [prefix] (សទិសន័យ៖ pus) បុព្វបទមានន័យថា ខ្ទុះ

**pyometra** /ˌpʌɪəˈmɛtrə/ [n] ដំណក់ខ្ទុះក្នុងស្បូន

**pyorrhea** /ˌpʌɪəˈriːə/ [n] រំហូរខ្ទុះ

**pyothorax** /ˌpʌɪə ˈθɔːraks/ [n] ខ្ទុះក្នុងប្រហោងទ្រូង

**pyramid** /ˈpɪrəmɪd/ [n] ពីរ៉ាមីត

- ecological pyramid /iːkəˈlɒdʒɪk(ə)l ˈpɪrəmɪd/ [n] ពីរ៉ាមីតអេកូឡូស៊ី (មធ្យមភាគនៃក្រាហ្វិក បង្ហាញពីទម្រង់ ឬមុខងារអាហារបស់សហគមន៍មួយ)

**pyrene** /ˈpʌɪriːn/ [n] គ្រាប់ (រុក្ខជាតិ) រឹងដូចថ្ម (ជាពាក្យរុក្ខវិទ្យាសំដៅទៅលើអែនដូខាបដែលមានគ្រាប់ស្រោបជិតក្នុងប្រភេទផ្លែខ្ទួប។ នៅក្នុងន័យខាង ប្រមូលទុកដាក់គ្រាប់ពូជវិញ វាមានន័យថា ឪថ្ម ឬគ្រាប់រឹងដូចថ្មឪ ជាទូទៅគេប្រើពាក្យ Pyrene (ផៃរីន)។)

**pyretic** /pɪˈrɛtɪk/ [adj] គ្រុន

**pyrex** /ˈpʌɪrɛks/ [n] កែវធន់នឹងកម្ដៅ

**pyrexia** /pʌɪˈrɛksɪə/ [n] គ្រុន

**pyrogenic** /ˌpʌɪrə(ʊ)ˈdʒɛnɪk/ [adj] ធ្វើឱ្យក្ដៅ, ធ្វើឱ្យគ្រុន

**pyuria** /pʌɪˈjʊərɪə/ [n] ជំងឺនោមខ្ទុះ

**Q**

**q s** [abbr] បរិមាណគ្រប់គ្រាន់ (មកពីពាក្យឡាទីន quantum satis)

**Q.I.D** [abbr] ៤ដងក្នុងមួយថ្ងៃ (មកពីពាក្យឡាទីន quater in die)

**quack** /kwak/ [n] សម្រែកសត្វទា

**quadri-** /ˈkwɒdri/ [prefix] បុព្វបទមានន័យថា បួន

**quadruped** /ˈkwɒdrʊpɛd/ [n] សត្វជើងបួន, សត្វចតុប្បាទ

**quadruple** /ˈkwɒdrʊp(ə)l/ [adj] ដែលមានបួនជ្រុង

**quadruplets** /ˈkwɒdrʊplɪts/ [n pl] កូនភ្លោះបួន

**quagmire** /ˈkwagmʌɪə/ [n] សូមមើលពាក្យ៖ bog

**quail** /kweɪl/ [n] សត្វក្រួច

**quake** /kweɪk/ [v] ញាប់ញ័រ, រញ្ជួយ

**quality** /ˈkwɒlɪti/ [n] គុណភាព

- air quality /ɛːˈkwɒlɪti/ [n] គុណភាពខ្យល់
- environmental quality /ɪnvʌɪrənˈmɛnt(ə)l ˈkwɒlɪti/ [n] គុណភាពបរិស្ថាន
- food quality /fuːd ˈkwɒlɪti/ [n] គុណភាពស្បៀងអាហារ
  ១. និយាយយោងទៅរកស្តង់ដារផ្នែកអនាម័យ និងសុវត្ថិភាពជាទូទៅរបស់អាហារមួយដែលបានកំណត់ ។ អាហារដែលមានស្តង់ដារគុណភាពខ្ពស់ ជាអាហារដែលពុំមានគំរាមកំហែងដល់សុខភាពរបស់មនុស្ស។
  ២. ក៏អាចនិយាយយោងទៅរកស្បៀងដែលផ្តល់តម្លៃអាហារូបត្ថម្ភ វប្បធម៌ ឬសេដ្ឋកិច្ចកម្រិតខ្ពស់ជាង ដោយគុណសម្បត្តិនៃរបៀប និងទីកន្លែងដែលស្បៀងត្រូវបានដាំដុះ ឬ ផលិត។
  ៣. នៅក្នុងបរិបទអាហារូបត្ថម្ភ ចំណីអាហារដែលមានយ៉ាងជំផេង ចំពោះរាងកាយត្រូវបានគេចាត់ទុកថាមានគុណភាពខ្ពស់ជាងចំណីអាហារដែលមានចំណុះអាហារូបត្ថម្ភទាប។
- grain quality /greɪn ˈkwɒlɪti/ [n] គុណភាពគ្រាប់ (ពហុលក្ខណៈនៃគ្រាប់ដូចជា ទម្រង់គ្រាប់ ក្លិន ភាពស អាមីឡូសធាតុ គុណភាពបាយជាដើម)
- ordinary quality /ˈɔːdɪn(ə)ri ˈkwɒlɪti/ [n] គុណភាពធម្មតា
- seed quality /siːd ˈkwɒlɪti/ [n] គុណភាពគ្រាប់ (ជាពាក្យន័យទូទៅដែលអាចទាក់ទងនឹងភាពសុទ្ធ គុណភាពសរីរៈ (សមត្ថភាពដំណុះ ភាពរឹងមាំ) និងគុណភាពផេណូទីបរបស់កញ្ចប់គ្រាប់មួយ)
- water quality /ˈwɔːtə ˈkwɒlɪti/ [n] គុណភាពទឹក

**quantity** /ˈkwɒntɪti/ [n] បរិមាណ, ចំនួន

**quarantine** /ˈkwɒrəntiːn/ [v] ធ្វើការ៉ង់តែន

**quarantine** /ˈkwɒrəntiːn/ [n] ធានាភាព, ការ៉ង់តែន, ច្បាប់ការពារជំងឺឆ្លង (សត្វ ឬគ្រាប់ដែលស្ថិតក្នុងថេរវេលាមួយក្រោមការឃ្លាំមើល និងត្រួតពិនិត្យមើលជំងឺឆ្លង ផ្សិត ឬសត្វល្អិត (ចំពោះគ្រាប់) ដែលអាចកើតលើវា។ ការផ្ទេរតាមព្រំដែនអន្តរជាតិ ជារឿយៗតម្រូវឱ្យប្រើច្បាប់ការពារជំងឺឆ្លង។)

**quarry** /ˈkwɒri/ [v] គាស់យកថ្ម

**quarry** /ˈkwɒri/ [n]
  ១. (សទិសន័យ៖ pit, stone pit) កន្លែងយកថ្ម
  ២. សត្វដែលគេបរបាញ់
- top soil of quarry /tɒp sɔɪl ɒv ˈkwɒri/ [n] ស្រទាប់ដីដែលគ្របពីលើថ្ម

**quart** /kwɔːt/ [n] ១/៤ កាឡុង (gallon)

**quarter** /ˈk(w)ɔːtə/ [n] ១/៤

**quartz** /kwɔːts/ [n] ក្វាត (ថ្ម)

**questionnaire** /ˌkwɛstʃəˈnɛː/ [n] បញ្ជីសំណួរ, កម្រងសំណួរ

**quicksilver** /ˈkwɪksɪlvə/ [n] សូមមើលពាក្យ៖ mercury

**quiescent** /kwɪˈɛs(ə)nt/ [adj] មិនលូតលាស់, គ្មានសកម្មភាព, នៅស្ងៀម (គ្មានសកម្មភាព ដំណាក់កាលសម្រាករបស់គ្រាប់។ គេប្រើចំពោះគ្រាប់មិនសម្ងំ នៅកំឡុងចន្លោះពេលរវាង ការឡើងពេញវ័យនៅលើដើម និងការចាប់ផ្តើមដំណុះ។ ដួនកាល គេតែងតែច្រឡំថាវាសម្ងំ។)

**quinine** /kwɪˈniːn/ [n] គីនីន

***Quisqualis densiflora*** [sci.n] ដូងព្រះ

***Quisqualis indica*** [sci.n] ផ្កាសក់សេះ

**quittor** /ˈkwɪtə/ [n] ដំបៅគល់ក្រចកសេះ ឬគោ

**quota** /ˈkwəʊtə/ [n] បរិមាណភាព, ចំនួនកំណត់, បរិមាណកំណត់

## R

**RBC (medical)** [abbr] (red blood cells) ការរាប់កោសិកាឈាមក្រហម

**rabbit** /ˈrabɪt/ [n] ទន្សាយ

**rabies** /ˈreɪbiːz/ [n] ជំងឺឆ្កែឆ្កួត, រោគឆ្កួត (ពិសេសឆ្លងពីឆ្កែ)

**race** /reɪs/ [n] (សទិសន័យ៖ breed) ពូជ (ក្រុមពូជមួយនៅក្នុងប្រភេទពូជមួយដែលបង្ហាញពីចរិតលក្ខណៈសេនេទិចទូទៅ មិនជាប់លាប់ និងខុសប្លែកពីលក្ខណៈនៃបណ្ដាក្រុមពូជផ្សេងៗទៀត។ ជាធម្មតា វាជាក្រុមដែលបង្កាត់គ្នាឯងៗ។ ពេលដែលលក្ខណៈប្លែកពី គេនៃពូជមួយផ្សាំទៅបាន ពាក្យនេះមានន័យដូចប្រភេទបរិស្ថាន (ecotype) ហើយពូជនេះគេថាវាប្រហាក់ ប្រហែលគ្នា ឧ. ពូជមានទឹកដី ឬអាកាសធាតុដូចគ្នា។)

- ecological race /iːkəˈlɒdʒɪk(ə)l reɪs/ [n] សូមមើលពាក្យ៖ ecotype
- geographic race /dʒiːəˈgrafɪk reɪs/ [n] ពូជតាមភូមិសាស្ត្រ (ពូជមានដើមកំណើតនៅទីកន្លែងភូមិសាស្ត្រមួយ)
- land race /land reɪs/ [n] ពូជមូលដ្ឋាន (ប្រភេទពូជដែលបានទទួលការដាំដុះនៅកន្លែងមួយតាំងពីយូរលង់ណាស់មកហើយ), ពូជផ្សាំក្នុងស្រុក, ពូជដែលបានបន្សាំក្នុងស្រុក, ពូជនាំចូលមកដាំអស់ជាច្រើនជំនាន់មកហើយ

**raceme** /ˈrasiːm/ [n] កញ្ចុំផ្កា

**raceway** /ˈreɪsweɪ/ [n] ឈើដាក់ឱ្យសត្វដើរឡើងឡាន

**rachilla** [n] អ័ក្សទ្រគ្រាប់ (ផ្នែកមួយដែលជាចំណុចប្រសព្វរវាងសម្បកធំ និងសម្បកតូច ហើយមានតួនាទីកាន់ទ្រផ្កានីមួយៗ)

**radial** /ˈreɪdɪəl/ [adj] រាងជាកាំ, កាត់ជាកាំរង្វង់

**radiation** /reɪdɪˈeɪʃ(ə)n/ [n] រស្មី, បន្សាយរស្មី, ការបញ្ចេញរស្មី, រំភាយរស្មី

- adaptive radiation /əˈdaptɪv reɪdɪˈeɪʃ(ə)n/ [n] សំណាយបន្សាំ (ការវិវត្តរបស់ក្រុមផ្សេងៗពីបុព្វបទរួម)
- alpha radiation /ˈalfə reɪdɪˈeɪʃ(ə)n/ [n] ការបញ្ចេញកាំរស្មីអាល់ហ្វា
- background radiation /ˈbakgraʊnd reɪdɪˈeɪʃ(ə)n/ [n] កាំរស្មីមជ្ឈដ្ឋាន (កាំរស្មីទទួលបានពីធាតុវិទ្យុសកម្មធម្មជាតិក្នុងបរិយាកាស និងនៅលើផ្ទៃផែនដី និងកាំរស្មីអវកាស។ ប្រហែល៦៥% នៃកាំរស្មីប្រចាំឆ្នាំបានមកពីកាំរស្មីមជ្ឈដ្ឋាន)
- beta radiation /ˈbiːtə reɪdɪˈeɪʃ(ə)n/ [n] ការបញ្ចេញកាំរស្មីបែតា
- electromagnetic radiation /ɪˌlɛktrə(ʊ)magˈnɛtɪk reɪdɪˈeɪʃ(ə)n/ [n] រំភាយអេឡិចត្រូម៉ាញេទិច
- gamma radiation /ˈgamə reɪdɪˈeɪʃ(ə)n/ [n] ការបញ្ចេញកាំរស្មីកាម៉ា
- solar radiation /ˈsəʊlə reɪdɪˈeɪʃ(ə)n/ [n] រំភាយរស្មីព្រះអាទិត្យ, កាំរស្មីព្រះអាទិត្យ
- terrestrial radiation /təˈrɛstrɪəl reɪdɪˈeɪʃ(ə)n/ [n] រំភាយចំហាយដី
- thermal infrared radiation /ˈθəːm(ə)l ɪnfrəˈrɛd reɪdɪˈeɪʃ(ə)n/ [n] កាំរស្មីអាំងប្រាកម្តៅ
- thermal radiation /ˈθəːm(ə)l reɪdɪˈeɪʃ(ə)n/ [n] រំភាយកម្តៅ
- ultraviolet radiation /ʌltrəˈvʌɪələt reɪdɪˈeɪʃ(ə)n/ [n] ការបញ្ចេញកាំរស្មីស្វាយអ៊ុលត្រា
- X radiation /ɛks reɪdɪˈeɪʃ(ə)n/ [n] ការបញ្ចេញកាំរស្មីអ៊ិច
- infrared radiation /ɪnfrəˈrɛd reɪdɪˈeɪʃ(ə)n/ [n] កាំរស្មីអាំងប្រា

**radiative forcing** /ˈreɪdɪətɪv fɔːsɪŋ/ [n] កម្លាំងកាំរស្មី

**radicle** /ˈradɪk(ə)l/ [n] ពន្លកឫស, ឫសខ្ចី, ឫសសរសៃវិញ្ញាណ, ពន្លកឫសដំបូង (ឫសដែលដុះចេញដំបូង ហើយវាតែងតែងាប់ទៅវិញក្នុងរវាងអាយុ ១ខែ នៅក្រោយពេលដែលឫសរយាងដុះពេញលេញ)

**radioactive** /ˌreɪdɪəʊˈaktɪv/ [adj] នៃវិទ្យុសកម្ម

**radioactivity** /ˌreɪdɪəʊakˈtɪvɪti/ [n] វិទ្យុសកម្ម

- airborne radioactivity /ˈɛːbɔːn ˌreɪdɪəʊakˈtɪvɪti/ [n] វិទ្យុសកម្មក្នុងបរិយាកាស
- environmental radioactivity /ɪnvʌɪrənˈmɛnt(ə)l ˌreɪdɪəʊakˈtɪvɪti/ [n] វិទ្យុសកម្មមជ្ឈដ្ឋានជុំវិញ
- natural radioactivity /ˈnatʃ(ə)r(ə)l ˌreɪdɪəʊakˈtɪvɪti/ [n] វិទ្យុសកម្មធម្មជាតិ

**radiogram** /ˈreɪdɪə(ʊ)gram/ [n] សូមមើលពាក្យ៖ radiograph

**radiograph** /ˈreɪdɪə(ʊ)grɑːf/ [n] (សទិសន័យ៖ radiogram, roentgenogram) រូបថតកាំរស្មីអ៊ិច (រូបភាពដែលបានបង្កើតនៅលើហ្វីល (Film) ឬក្រដាសរូបភាពមួយក្រោយពីថតវិទ្យុសកម្មដោយកាំរស្មីអ៊ិច)

**radish** /ˈradɪʃ/ [n] ផែថាវ

**Radium** /ˈreɪdɪəm/ [n]
១. រ៉ាដ្យូម (និមិត្តសញ្ញាគីមី Ra)
២. លោហធាតុប្រើសម្រាប់ព្យាបាល

**radius** /ˈreɪdɪəs/ [n]
១. ឆ្អឹងតូចកំភួនដៃ
២. កាំរង្វង់

**Radon** /ˈreɪdɒn/ [n] រ៉ាដុង (និមិត្តសញ្ញាគីមី Rn)

***Raiamas guttatus*** [sci.n] ត្រីសកាកែវ

**rain** /reɪn/ [v] ធ្លាក់ភ្លៀង

**rain** /reɪn/ [n] ភ្លៀង
- acid rain /ˈasɪdreɪn/ [n] ភ្លៀងអាស៊ីត (សារធាតុបំពុលអាស៊ីត ដែលធ្លាក់មកជាទម្រង់ខុសៗ ជាទម្រង់សើម (ភ្លៀង អ័ព្ទ ឬព្រិល) ឬ ទម្រង់ស្ងួត (ឧស្ម័ន ឬធូលីតូចៗ))
- radioactive rain /ˌreɪdɪəʊˈaktɪv reɪn/ [n] ភ្លៀងវិទ្យុសកម្ម

**rainfall** /ˈreɪnfɔːl/ [n] កម្ពស់ទឹកភ្លៀង, ការធ្លាក់ភ្លៀង
- annual rainfall /ˈanjʊəl ˈreɪnfɔːl/ [n] កម្រិតទឹកទឹកភ្លៀងប្រចាំឆ្នាំ (បរិមាណសរុបនៃទឹកភ្លៀងដែលធ្លាក់នៅតំបន់ណាមួយនៅរៀងរាល់ឆ្នាំ)
- effective rainfall /ɪˈfɛktɪv ˈreɪnfɔːl/ [n] ចំណែកមួយនៃទឹកភ្លៀងដែលត្រូវបានរក្សាទុក ឬចាប់ទុកដោយឫសជ្រៅៗក្នុងស្រទាប់ដីនៃដំណាំ ឬដោយផ្ទៃខាងលើដីស្រែ ហើយវាអាចយកមកប្រើប្រាស់នៅពេលបន្ទាប់ដោយដំណាំរុក្ខជាតិ
- mean annual rainfall /miːn ˈanjʊəl ˈreɪnfɔːl/ [n] កម្ពស់ទឹកភ្លៀងមធ្យមប្រចាំឆ្នាំ

**rainfed** /reɪnfɛd/ [adj] ដែលរំពឹងទឹកភ្លៀង, ដែលអាស្រ័យទឹកភ្លៀង
- rainfed lowland rice /reɪnfɛd ˈləʊlənd rʌɪs/ [n] ស្រូវរំពឹងទឹកភ្លៀង (ប្រភេទស្រូវដែលដុះលូតលាស់អាស្រ័យដោយរបបទឹកភ្លៀងសុទ្ធសាធ)
- rainfed lowland rice ecosystem /reɪnfɛd ˈləʊlənd rʌɪs ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូស្រូវស្រែស្បាដីទំនាប
- rainfed upland rice ecosystem /reɪnfɛd ˈʌplənd rʌɪs ˈiːkəʊsɪstəm/ [n] ប្រព័ន្ធអេកូស្រូវស្រែស្បាដីទួល

**rainforest** /ˈreɪnfɒrɪst/ [n] ព្រៃតំបន់ត្រូពិច

**rainmaking** /ˈreɪnmeɪkɪŋ/ [n] ការធ្វើឱ្យមានភ្លៀង

**rain-rill** /reɪn-rɪl/ [n] (សទិសន័យ៖ rill) ចង្អូរកើតនៅពេលភ្លៀងខ្លាំង, ចង្អូរតូចៗ

**rainsheet** /reɪnʃiːt/ [n] (សទិសន័យ៖ sheetflood, sheetwash) ជលស្តារ ឬស្រទាប់ទឹកដែលហូរច្រោះលើផ្ទៃដី, ការហូរយ៉ាងលឿននៃផ្ទៃទឹកនៅលើជម្រាល ពិសេសកន្លែងគ្មានដើមឈើ

**raise** /reɪz/ [v] ចិញ្ចឹម

raising /reɪzɪŋ/ [n] ការចិញ្ចឹម, ការរៃអង្គាស
- fund raising /reɪzɪŋ/ [n] ការរៃអង្គាសប្រាក់
- livestock raising /ˈlʌɪvstɒk reɪzɪŋ/ [n] ការចិញ្ចឹមសត្វ
- silk raising /sɪlk reɪzɪŋ/ [n] ការចិញ្ចឹមដង្កូវនាង

**rake** /reɪk/ [v] រាស់ដោយរនាស់

**rake** /reɪk/ [n] រនាស់

**rale** /rɑːl/ [n] សូរដកសង្កាមាន់

***Ralstonia solanacearum*** [n] ជំងឺបាក់តេរីស្រពោនស្រស់ (ដំណាំជម្រកប៉េងប៉ោះ ដំឡូងបារាំង ម្ទេស ត្រប់ និងត្រសក់ ជាលក្ខខណ្ឌរាលដាលរបស់ជំងឺនេះ)

**ram** /ram/ [n] ចៀម ឬពពែឈ្មោល (ដែលមិនទាន់ក្រៀវ)

**rambutan** /ramˈb(j)uːt(ə)n/ [n] សាវម៉ាវ (ឈ្មោះវិទ្យាសាស្ត្រ *Nephelium lappaceum*)

**ramet** /ˈramɪt/ [n] កូនឈើផ្សាំ (ជាសមាជិកឯកត្តៈមួយរបស់ក្លូនមួយ)

**ramicorn** /ˈramɪkɔːn/ [n] មែកឈើល្អិតៗ (មែកលូតទៅលើ ឬចំហៀង។ ជារឿយៗ វាមានចំពោះពួករុក្ខជាតិស្លឹកស្រួចដូចជាមែកមួយនៅក្រោមមែកកួចធម្មតា។ មែកល្អិតមិនជ្រុះងាយៗនោះទេ និងតែងតែបន្សល់ភ្នែកធំៗនៅក្នុងឈើ។ លក្ខណៈទាំងនេះ ជាលក្ខណៈបន្តពូជ ហើយជារឿយៗក្នុងកម្មវិធីបង្កាត់ពូជ គេមិនជ្រើសយកទេ។)

**ramie** /ˈrami/ [n] ធ្មៃ (ឈ្មោះវិទ្យាសាស្ត្រ *Boehmeria nivea*)

**ramming** /ramin/ [n] (សទិសន័យ៖ tamping) ការបុកបង្ហាប់ដី

**ranch** /rɑːn(t)ʃ/ [n] វាលចិញ្ចឹមសត្វពាហនៈ

**rancher** /ˈrɑːn(t)ʃə/ [n] ម្ចាស់វាលចិញ្ចឹមសត្វ

**ranching** /ˈrɑːn(t)ʃɪŋ/ [n] ការដាំស្មៅសម្រាប់ចិញ្ចឹមសត្វ

**rancid** /ˈransɪd/ [adj] រសខារ, ក្លិនខារ

**randomization** /ˈrandəmʌɪzˈeɪʃ(ə)n/ [n] ការចាប់ឆ្នោត (វិធីសាស្ត្រមួយ ក្នុងការចាត់បច្ច័យទៅក្នុងកូនស្រែពិសោធទៅតាមសានីមួយៗតាមការចាប់ឆ្នោត)

**range** /reɪn(d)ʒ/ [n] ជួរ (ភ្នំ), ដែន

- breeding range /ˈbriːdɪŋ reɪn(d)ʒ/ [n] តំបន់បង្កាត់ពូជ
- home range /həʊmreɪn(d)ʒ/ [n] ដែន
- host range /həʊst reɪn(d)ʒ/ [n] ប្រភេទរុក្ខជាតិជម្រកមួយចំនួនដែលពពួកpathogen ឬសត្វល្អិតចង្រៃស្នាក់អាស្រ័យ និងធ្វើការបំផ្លាញ
- waste range /weɪst reɪn(d)ʒ/ [n] គំនរកម្ទេចបែកបាក់
- water capacity range /ˈwɔːtə kəˈpasɪti reɪn(d)ʒ/ [n] អត្រានៃសក្តានុពលសំណើម

**ranger** /ˈreɪn(d)ʒə/ [n] អ្នកល្បាត

- park ranger /pɑːkˈreɪn(d)ʒə/ [n] អ្នកល្បាតព្រៃឆ្នាំព្រៃ

***Raphanus sativus* var. *longipinnatus*** [sci.n] សូមមើលពាក្យ៖ daikon

**raphe** /ˈreɪfi/ [n] រ៉ាហ្វី, ច្រវែបដូចថ្នេរ (ចង្អូរមួយដែលកើតនៅលើសម្បកគ្រាប់ បើសិនទងអូវុល (funiculus) ត្រូវបានរលាយចូលជាមួយសម្បកក្រៅគ្រាប់ នូវប្រវែងមួយផ្នែកក្នុងអូវុលឈរ ឬអូវុលផ្តេក)

**rapid rural appraisal** /ˈrapɪd ˈrʊər(ə)l əˈpreɪz(ə)l/ [n] វិធីប៉ាន់ស្មានភ្លាមៗដោយមានកសិករចូលរួម

**rapids** /ˈrapɪds/ [n pl] ទឹកជួរ

***Rasbora aurotaenia*** [sci.n] សូមមើលពាក្យ៖ pale rasbora

***Rasbora borapetensis*** [sci.n] សូមមើលពាក្យ៖ blackline rasbora

***Rasbora caudimaculata*** [sci.n] សូមមើលពាក្យ៖ greater scissortail

***Rasbora daniconius*** [sci.n] សូមមើលពាក្យ៖ slender rasbora

***Rasbora dusonensis*** [sci.n] សូមមើលពាក្យ៖ rosefin rasbora

***Rasbora espei*** [sci.n] សូមមើលពាក្យ៖ lambchop rasbora

***Rasbora hobelmani*** [sci.n] ត្រីចង្វា

***Rasbora myersi*** [sci.n] សូមមើលពាក្យ៖ silver rasbora

***Rasbora pauciperforata*** [sci.n] សូមមើលពាក្យ៖ red-line rasbora

***Rasbora paucisquamis*** [sci.n] ត្រីចង្វាឆ្នូត

***Rasbora paviei*** [sci.n] សូមមើលពាក្យ៖ sidestripe rasbora

***Rasbora sp. cf. beauforti*** [sci.n] សូមមើលពាក្យ៖ stoplight rasbora

***Rasbora spilocera*** [sci.n] សូមមើលពាក្យ៖ dwarf scissortail rasbora

***Rasbora tornieri*** [sci.n] សូមមើលពាក្យ៖ yellowtail rasbora

**Rasbora trilineata** [sci.n] សូមមើលពាក្យ៖ scissortail rasbora

**rasbora** /razˈbɔrə/ [n] ពពួកត្រីប្រភេទតូចជាងត្រីចង្វាឆ្នូតកណ្តាលខ្លួន ដែលស្ថិតនៅក្នុងគ្រួសារ Cyprinidae (carps)

- blackline rasbora /ˈblaklʌɪn/ razˈbɔrə/ [n] ត្រីចង្វាស្រលូង (ឈ្មោះវិទ្យាសាស្ត្រ *Rasbora borapetensis*)
- dwarf scissortail rasbora /dwɔːf ˈsɪzəteɪl razˈbɔrə/ [n] ត្រីចង្វាពោត (ឈ្មោះវិទ្យាសាស្ត្រ *Rasbora spilocera*)
- lambchop rasbora /lamtʃɒp razˈbɔrə/ [n] ត្រីចង្វាឆ្នូត (ឈ្មោះវិទ្យាសាស្ត្រ *Rasbora espei*)
- pale rasbora /peɪl razˈbɔrə/ [n] ត្រីចង្វាមូល (ឈ្មោះវិទ្យាសាស្ត្រ *Rasbora aurotaenia*)
- redline rasbora /ˈrɛdlʌɪn razˈbɔrə/ [n] ត្រីចង្វា (ឈ្មោះវិទ្យាសាស្ត្រ *Rasbora pauciperforata*)
- scissortail rasbora /ˈsɪzəteɪl razˈbɔrə/ [n] ត្រីចង្វាពោត (ឈ្មោះវិទ្យាសាស្ត្រ *Rasbora trilineata*)
- sidestripe rasbora /sʌɪd strʌɪp razˈbɔrə/ [n] ត្រីចង្វាឆ្នូត (ឈ្មោះវិទ្យាសាស្ត្រ *Rasbora paviei*)
- silver rasbora /ˈsɪlvə razˈbɔrə/ [n] ត្រីចង្វា (ឈ្មោះវិទ្យាសាស្ត្រ *Rasbora myersi*)
- slender rasbora /ˈslɛndə razˈbɔrə/ [n] ត្រីចង្វាឆ្អឹត (ឈ្មោះវិទ្យាសាស្ត្រ *Rasbora daniconius*)
- stoplight rasbora /stɒplʌɪt razˈbɔrə/ [n] ត្រីចង្វាស្រលូង (ឈ្មោះវិទ្យាសាស្ត្រ *Rasbora* sp. cf. *beauforti*)

- yellowtail rasbora /ˈjɛləʊ teɪl razˈbɔrə/ [n] ត្រីចង្វាមូល (ឈ្មោះវិទ្យាសាស្ត្រ *Rasbora tornieri*)

**rash** /raʃ/ [n] (សូមមើលពាក្យ៖ urticaria) កន្ទួល, រោល

**rat** /rat/ [n] កណ្ដុរប្រែង

**rate** /reɪt/ [n] អត្រា, ល្បឿន, ប្រេកង់, កម្រិត

- birth rate /bəːθreɪt/ [n] សូមមើលពាក្យ៖ natality rate
- corrosion rate /kəˈrəʊʒ(ə)n reɪt/ [n] ល្បឿនកំណូត
- crop growth rate /krɒp grəʊθ reɪt/ [n] អត្រាលូតលាស់កសិផល, អាត្រាលូតលាស់នៃដំណាំ (ដំណើរការបន្តបន្ទាប់ដែលជាប់ទាក់ទងទៅនឹងការផលិតនៅនូវជាលិកាថ្មី និងសរីរាង្គថ្មីទាំងឡាយពេញមួយវដ្ដជីវិតរបស់ដំណាំ ឧ. កម្រិត ឬបរិមាណនៃសារធាតុស្ងួតរបស់ដំណាំ)
- death rate /dɛθ reɪt/ [n] អត្រាស្លាប់
- decay rate /dɪˈkeɪ reɪt/ [n] ល្បឿនបំបែកធាតុ
- disposal rate /dɪˈspəʊz(ə)l reɪt/ [n] អត្រាបញ្ចេញចោល (សំណល់)
- erosion rate /ɪˈrəʊʒ(ə)n reɪt/ [n] ល្បឿនសំណឹក
- evaporation rate /ɪˌvapəˈreɪʃ(ə)n reɪt/ [n] ល្បឿនរំហួត, អត្រារំហួត
- flow rate /fləʊ reɪt/ [n] ធារទឹក
- growth rate /grəʊθ reɪt/ [n] អត្រាកំណើន
- heart rate /hɑːt reɪt/ [n] ល្បឿនបេះដូង
- mortality rate /mɔːˈtalɪti reɪt/ [n] អត្រាមរណប្រមាណ
- natality rate /nəˈtalɪti reɪt/ [n] (សទិសន័យ៖ birth rate) អត្រាជាតិប្រមាណ
- net assimilation rate /nɛt əsɪmɪˈleɪʃ(ə)n reɪt/ [n] កម្រិតកើនសុទ្ធ, អត្រារស្មីសំយោគ (ទម្ងន់ដើមដែលកើនឡើងក្នុងមួយឯកតានៃផ្ទៃស្លឹក)
- oxidation rate /ɒksɪˈdeɪʃ(ə)n reɪt/ [n] ល្បឿនអុកស៊ីតកម្ម
- population growth rate /pɒpjʊˈleɪʃ(ə)n grəʊθ reɪt/ [n] អត្រាកំណើនប្រជាជន
- poverty rate /ˈpɒvəti reɪt/ [n] អត្រាភាពក្រីក្រ
- radiation rate /reɪdɪˈeɪʃ(ə)nreɪt/ [n] អត្រាវិភាយរស្មី
- radioactive decay rate /ˌreɪdɪəʊˈaktɪv dɪˈkeɪ reɪt/ [n] ល្បឿនបំបែកធាតុវិទ្យុសកម្ម
- rate of mortality /reɪt ɒv mɔːˈtalɪti/ [n] អត្រាមរណប្រមាណ
- rate of rainfall /reɪtɒvˈreɪnfɔːl/ [n] កម្រិតកម្ពស់ទឹកភ្លៀង
- rate of return /reɪt ɒv rɪˈtəːn/ [n] កម្រិតចំណូល, អត្រាចំណូល
- rate of sedimentation /reɪt ɒv sɛdɪmɛnˈteɪʃ(ə)n/ [n] ល្បឿនកម្ទេចកំណ
- recommended rate / rɛkəˈmɛndɪd reɪt/ [n] កម្រិតអនុសាសន៍, កម្រិតណែនាំ (បរិមាណដែលបានផ្ដល់ទៅលើអ្វីមួយ ហើយវាបំពេញនូវសេចក្ដីត្រូវការសមស្រប)
- run-off rate /ˈrʌn ɒf reɪt/ [n] ធារហូរ
- saturation rate /satʃəˈreɪʃ(ə)n reɪt/ [n] អត្រាឆ្អែត
- seed rate /siːd reɪt/ [n] កម្រិតប្រើគ្រាប់ពូជ
- survival rate /səˈvʌɪv(ə)l reɪt/ [n] អត្រារស់រាន
- water use rate /ˈwɔːtə juːz reɪt/ [n] កម្រិតប្រើប្រាស់ទឹក

**rathole** /ˈrathəʊl/ [n] ក្រហូងដែលបង្កើតដោយទឹកកួច

**raticide** /ˈratɪsʌɪd/ [n] ថ្នាំបំពុលកណ្ដុរ

**ratio** /ˈreɪʃɪəʊ/ [n] អត្រា, សមាមាត្រ, ផលធៀប, កម្រិត, អនុបាត (ផលធៀបនៃសមាសភាពពីរ (ឧ. បណ្ដោយគ្រាប់ និងទទឹងគ្រាប់))

- benefit cost ratio /ˈbɛnɪfɪt kɒst ˈreɪʃɪəʊ/ [n] អនុបាតថ្លៃចំណេញ
- blood sugar ratio /blʌd ˈʃʊgə ˈreɪʃɪəʊ/ [n] ការពិសោធន៍ឈាម ដើម្បីឱ្យដឹងកម្រិតជាតិស្ករក្នុងឈាម
- fertilizer ratio /ˈfəːtɪlʌɪzə ˈreɪʃɪəʊ/ [n] អនុបាតជី (សមាមាត្ររវាងកម្រិតជី N, $P_2O_5$ និង $K_2O$ ក្នុងជី 14-14-14 មានសមាមាត្រភាព 1:1:1)
- leaching ratio /liːtʃɪŋ ˈreɪʃɪəʊ/ [n] សមាមាត្រ ឬអនុបាតនៃការលាងច្រោះ
- marginal cost benefit ratio /ˈmɑːdʒɪn(ə)l kɒst ˈbɛnɪfɪt ˈreɪʃɪəʊ/ [n] អត្រាចំណេញរបស់តម្លៃផ្សំ (ចំណូលសរុបបន្ថែមដែលទទួលបានដោយធ្វើការផ្លាស់ប្ដូរនូវបច្ចេកវិទ្យាថ្មី (ឧ. ការឈប់ប្រើគោ ហើយប្រើត្រាក់ទ័រវិញ) ហើយត្រូវបានចែកដោយអត្រានៃតម្លៃអថេរសរុបបន្ថែមរួច ហើយដកនឹង១។ វាស្មើនឹងកម្រិតអត្រានៃចំណូល។)

- mixing ratio /mɪksɪŋ ˈreɪʃɪəʊ/ [n] អត្រាលាយ
- saturation ratio /satʃəˈreɪʃ(ə)nˈreɪʃɪəʊ/ [n] សមាមាត្រភាពឆ្អែត
- shoot/root ratio /ʃuːt ruːt ˈreɪʃɪəʊ/ [n] សមាមាត្រដើម/ឫស, អនុបាតដើម/ឫស
- straw grain ratio /strɔː greɪn ˈreɪʃɪəʊ/ [n] អនុបាតនៃចំបើង និងគ្រាប់ (ប្រភាគ ឬផលធៀបនៃទម្ងន់គ្រាប់លើទម្ងន់ចំបើងដែលបានត្រូវច្រូតកាត់)

**ration** /ˈraʃ(ə)n/ [n] ចំនួនកម្រិត

- carbon-nitrogen ration /ˈkɑːb(ə)n ˈnʌɪtrədʒ(ə)n ˈraʃ(ə)n/ [n] ផលធៀប ឬអនុបាត កាបូន អាសូត

**rational** /ˈraʃ(ə)n(ə)l/ [adj] សមតាមវិចារណញ្ញាណ, សមហេតុសមផល

**ratoon** /rəˈtuːn/ [n] រុក្ខសា (ដើមរុក្ខជាតិទាំងឡាយដែលដុះចេញពីគល់ជញ្ជ្រាំងក្នុងស្រែសល់ពីការច្រូតកាត់រដូវមុន ហើយប្រហែលជាអាចបង្កើតគ្រាប់)

**rattan** /rəˈtan/ [n] ផ្តៅ, វល្លិ

**rattle** /ˈrat(ə)l/ [v] បញ្ចេញសូរព្រេះៗ (ក្នុងសួត)

**ravine** /rəˈviːn/ [n] ជ្រោះ, ប្រឡាយបញ្ចេញទឹក (ធម្មជាតិ)

**raw** /rɔː/ [adj] ឆៅ

**rawness** /ˈrɔːnəs/ [n] សភាពដុល (មិនទាន់ច្នៃ)

**ray** /reɪ/ [n] (សទិសន័យ៖ radiant energy) រស្មី

- alpha ray /ˈalfəreɪ/ [n] កាំរស្មីអាល់ហ្វា
- astral ray /ˈastr(ə)l reɪ/ [n] វង់កាំសរសៃ (សរសៃកើតឡើងជុំវិញសង់ទ្រីយ៉ូលនៅពេលមីតូស)
- beta ray /ˈbiːtə reɪ/ [n] កាំរស្មីបែតា
- cathode ray /ˈkaθəʊd reɪ/ [n] កាំរស្មីកាតូត
- gamma ray /ˈgamə reɪ/ [n] កាំរស្មីកាម៉ា
- infrared ray /ɪnfrəˈrɛd reɪ/ [n] កាំរស្មីក្រហមអាំងប្រា
- laser ray /ˈleɪzə reɪ/ [n] កាំរស្មីឡាស៊ែ
- sun ray /sʌn reɪ/ [n] កាំរស្មីអាទិត្យ
- ultraviolet ray /ʌltrəˈvʌɪələt reɪ/ [n] កាំរស្មីស្វាយអ៊ុលត្រា

**RBC** [abbr] គោលិកាឈាមក្រហម (ពាក្យពេញ red blood cells)

**re-** /riː/ [prefix] (សទិសន័យ៖ again) បុព្វបទមានន័យថាជាថ្មី

**react** /rɪˈakt/ [v] មានប្រតិកម្ម

**reaction** /rɪˈakʃ(ə)n/ [n] ប្រតិកម្ម

- acid reaction /ˈasɪd rɪˈakʃ(ə)n/ [n] ប្រតិកម្មអាស៊ីត
- addition reaction /əˈdɪʃ(ə)n rɪˈakʃ(ə)n/ [n] ប្រតិកម្មបូក
- back reaction /bak rɪˈakʃ(ə)n/ [n] ប្រតិកម្មច្រាស
- balanced reaction /ˈbalənst rɪˈakʃ(ə)n/ [n] ប្រតិកម្មទៅមក
- catalytic reaction /ˌkatəˈlɪtɪk rɪˈakʃ(ə)n/ [n] ប្រតិកម្មក្រោមអំពើកាតាលីករ
- chain reaction /tʃeɪn rɪˈakʃ(ə)n/ [n] ប្រតិកម្មជាខ្សែ, ប្រតិកម្មជាស៊េរី
- chemical reaction /ˈkɛmɪk(ə)l rɪˈakʃ(ə)n/ [n] ប្រតិកម្មគីមី
- condensation reaction /kɒndɛnˈseɪʃ(ə)n rɪˈakʃ(ə)n/ [n] ប្រតិកម្មផ្តាច់ទឹក
- coupled reaction /ˈkʌp(ə)ld rɪˈakʃ(ə)n/ [n] ប្រតិកម្មគូ (ប្រតិកកម្មដែលផ្តល់ថាមពលសម្រាប់ប្រតិកម្ម ដែលត្រូវការថាមពលដោយផ្សំជាមួយនឹងប្រតិកម្មដែលបញ្ចេញថាមពល)
- dark reaction /dɑːk rɪˈakʃ(ə)n/ [n] ប្រតិកម្មងងឹត (នៅក្នុងដំណើរការរស្មីសំយោគ)
- decomposition reaction /ˌdiːkɒmpəˈzɪʃn rɪˈakʃ(ə)n/ [n] ប្រតិកម្មបំបែក
- dehydration synthesis reaction /ˌdiːhʌɪˈdreɪʃ(ə)n ˈsɪnθɪsɪs rɪˈakʃ(ə)n/ [n] ប្រតិកម្មសំយោគរំដោះទឹក
- displacement reaction /dɪsˈpleɪsm(ə)nt rɪˈakʃ(ə)n/ [n] ប្រតិកម្មជំនួស
- drug reaction /drʌg rɪˈakʃ(ə)n/ [n] ប្រតិកម្មថ្នាំ
- endothermic reaction /ˌɛndəʊˈθəːmɪk rɪˈakʃ(ə)n/ [n] ប្រតិកម្មស្រូបកម្ដៅ
- exothermic reaction /ˌɛksə(ʊ)ˈθəːmɪk rɪˈakʃ(ə)n/ [n] ប្រតិកម្មបញ្ចេញកម្ដៅ
- light compass reaction /lʌɪt ˈkʌmpəs rɪˈakʃ(ə)n/ [n] ប្រតិកម្មតម្រង់ទៅរកពន្លឺ
- nuclear reaction /ˈnjuːklɪə rɪˈakʃ(ə)n/ [n] ប្រតិកម្មនុយក្លេអ៊ែ
- oxidation reaction /ɒksɪˈdeɪʃ(ə)n rɪˈakʃ(ə)n/ [n] ប្រតិកម្មអុកស៊ីត
- oxidation-reduction reaction /ɒksɪˈdeɪʃ(ə)n rɪˈdʌkʃ(ə)n rɪˈakʃ(ə)n/ [n] ប្រតិកម្មអុកស៊ីតដូរដុកម្ម

- reversible reaction /rɪˈvəːsɪb(ə)l rɪˈakʃ(ə)n/ [n] ប្រតិកម្មទៅមក
- secondary reaction /ˈsɛk(ə)nd(ə)ri rɪˈakʃ(ə)n/ [n] ប្រតិកម្មបន្ទាប់
- soil reaction /sɔɪl rɪˈakʃ(ə)n/ [n] ប្រតិកម្មដី
- substitution reaction /sʌbstɪˈtjuːʃn rɪˈakʃ(ə)n/ [n] ប្រតិកម្មជំនួស
- zero order reaction /ˈzɪərəʊ ˈɔːdə rɪˈakʃ(ə)n/ [n] ប្រតិកម្មលំដាប់សូន្យ (ប្រតិកម្មគីមី ដែលអត្រាគឺមិនពឹងផ្អែកលើកំហាប់អង្គធាតុប្រតិករទេ)

**reactivate** /rɪˈaktɪveɪt/ [v] ធ្វើឱ្យសកម្មជាថ្មី

**reagent** /rɪˈeɪdʒ(ə)nt/ [n] ធាតុបន្ទាល់

**reap** /riːp/ [v] បេះ, ប្រមូលយកផល

**reaper** /ˈriːpə/ [n] ម៉ាស៊ីនច្រូត (ប្រើគោយន្ត) (ម៉ាស៊ីនច្រូតផ្តួលដើមស្រូវដោយប្រើគោយន្ត)

**rearer** /ˈrɪərə/ [n] អ្នកចិញ្ចឹមសត្វ

**chromosomal rearrangement** /ˌkrəʊməˈsəʊməl riːəˈreɪn(d)ʒm(ə)nt/ [n] ការតម្រៀបក្រូម៉ូសូមឡើងវិញ

**recalcitrant** /rɪˈkalsɪtr(ə)nt/ [adj]

១. មានការពិបាកក្នុងគ្រប់គ្រង ឬទុកដាក់ (សំដៅទៅលើការបន្តពូជរបស់រុក្ខជាតិ គ្រាប់ពូជ)

២. ប្រភេទគ្រាប់សើម (ពិពណ៌នាអំពីគ្រាប់ដែលមិនអាចរស់នៅក្នុងភាពស្ងួតទាបជាងបន្ទុកសំណើម ៣០-៤០% ហើយចំពោះប្រភេទពូជនៅត្រូពិច វាមិនធន់នឹងសីតុណ្ហភាពទាប។ គ្រាប់អាចបាត់បង់នូវលទ្ធភាពរបស់វាយ៉ាងរហ័ស ហើយមិនអាចស្តុកទុកបានយូរទេ។ ពាក្យន័យផ្ទុយ Orthodox (ប្រភេទគ្រាប់ ស្ងួត)។)

**receptacle** /rɪˈsɛptək(ə)l/ [n]

១. សណ្តាប់ផ្កា, ទម្រផ្កា (ខាងចុងរបស់ទងផ្កាដែលនៅលើនោះមានសរីរាង្គផ្កាដុះឡើង)

២. កន្លែងសម្រាប់ស៊កបន្តភ្លើងអគ្គិសនី

**receptivity** /riːsɛpˈtɪvɪti/ [n] ការទទួលយក (លក្ខខណ្ឌនៃផ្កា ឬកោនញីដែលបានអនុញ្ញាតឱ្យការលាយលម្អងមានប្រសិទ្ធភាព)

**recess** /ˈriːsɛs/ [n] ប្រហោង

**recipe** /ˈrɛsɪpi/ [n] សូមមើលពាក្យ៖ prescription

**recipient** /rɪˈsɪpɪənt/ [n] អ្នកទទួល

**reclaim** /rɪˈkleɪm/ [v] រាន, កាប់យក (ឧ. ដី)

**reclamation** /rɛkləˈmeɪʃ(ə)n/ [n] ការរានយកដី, ការដាំដំណាំឡើងវិញ (ឈូសឆាយដី)

**recombination** /riːˌkɒmbɪˈneɪʃ(ə)n/ [n] ការកាត់ពូជ, ការផ្គុំឡើងវិញ ( ការកើតឡើងក្នុងកូននូវបង្គុំថ្មីនៃសែនជាប់គ្នាដែលគ្មានវត្តមាននៅក្នុងមេបាណាមួយ។ ការផ្គុំថ្មីនេះគឺដោយសារតែមានបាតុភូត crossing over នៅក្នុងដំណើរការមេយ៉ូស។ការផ្គុំឡើងថ្មីក្នុងអវត្តមាននៃការទាក់ទងគ្នា។)

**recommendation** /ˌrɛkəmɛnˈdeɪʃ(ə)n/ [n] អនុសាសន៍

- varietal recommendation /vəˈrʌɪət(ə)l ˌrɛkəmɛnˈdeɪʃ(ə)n/ [n] អនុសាសន៍ពូជ (ដំណើរការដែលក្នុងនោះ ពូជដែលបង្កាត់ថ្មីៗត្រូវបានអនុញ្ញាតឱ្យប្រើប្រាស់ជាផ្លូវការ)
- recommendation domain /ˌrɛkəmɛnˈdeɪʃ(ə)n də(ʊ)ˈmeɪn/ [n] ដែនអនុសាសន៍ (ការផ្តល់ឱវាទ ឬមតិណែនាំទៅឱ្យកសិករស្រដៀងគ្នាមួយក្រុម នៅក្នុងកាលៈទេសៈដូចគ្នា ឬលក្ខខណ្ឌដូចគ្នា)

**reconstitute** /riːˈkɒnstɪtjuːt/ [v] បង្កបង្កើតជាថ្មី, ផ្សំបង្កើតឡើងវិញ

**reconstruct** /riːkənˈstrʌkt/ [v] ស្តារ, កសាងឡើងវិញ

**reconstruction** /riːkənˈstrʌkʃn/ [n] ការស្តារ, ការកសាងឡើងវិញ

**recover** /rɪˈkʌvə/ [v] (សទិសន័យ៖ recuperate) បានជាវិញ, ធូរស្បើយ, មានកម្លាំងវិញ

**recovery** /rɪˈkʌv(ə)ri/ [n] ដំណើររើបឡើងវិញ, ការទទួលបានវិញ

- drought recovery /draʊt rɪˈkʌv(ə)ri/ [n] រំងើបពីការរាំងស្ងួត (លទ្ធភាពដែលរុក្ខជាតិអាចងើបពីការទ្រុឌទ្រោមដែលបង្កឡើងដោយការរាំងស្ងួតបាន)
- milling recovery /mɪlɪŋ rɪˈkʌv(ə)ri/ [n] ភាគរយអង្ករ (ទម្ងន់សរុបនៃគ្រាប់)

**rectal** /ˈrɛkt(ə)l/ [n] នៃចុងពោះវៀនធំ, គូទ

**rectum** /ˈrɛktəm/ [n] ចុងពោះវៀន, គូទ

**recuperate** /rɪˈkuːpəreɪt/ [v] សូមមើលពាក្យ៖ recover

**recur** /rɪˈkəː/ [v] ឈឺឡើងវិញ, មានឡើងវិញ, ត្រឡប់មកវិញ

**recyclability** /riːˈsʌɪkləˈbɪlɪti/ [n] ភាពអាចកែច្នៃជាថ្មី

**recyclable** /riːˈsʌɪkləbl/ [n] ដែលអាចកែជាថ្មី

**recycle** /riːˈsʌɪk(ə)l/ [n] កែច្នៃជាថ្មី, សារវដ្តកម្ម (ប្រើប្រាស់ ឬកែច្នៃឡើងវិញ) (ការកែច្នៃវត្ថុដែលប្រើរួចគ្មានប្រយោជន៍ឱ្យទៅជាវត្ថុមានប្រយោជន៍វិញ ហើយអាចប្រើការបានទៀត)

**recycled** /riːˈsʌɪk(ə)ld/ [adj] ដែលអាចប្រើឡើងវិញបាន

**recycling** / riːˈsʌɪk(ə)lɪŋ / [n] កំណែច្នៃជាថ្មី, ការកែច្នៃឡើងវិញ

- nutrient recycling /ˈnjuːtrɪənt riːˈsʌɪk(ə)lɪŋ/ [n] សារវដ្តកម្មសារធាតុចិញ្ចឹម (ឧ. ការក្លួរលប់កាកសំណល់ដំណាំចូលទៅក្នុងដីវិញ)
- paper recycling /ˈpeɪpəriːˈsʌɪkɪŋ/ [n] ការយកក្រដាសទៅកែច្នៃជាថ្មី
- waste recycling /ˈwɔːtəriːˈsʌɪkɪŋ/ [n] ការយកសំណល់ទៅកែច្នៃជាថ្មី

**red currant** /rɛd ˈkʌr(ə)nt/ [n] ដំណាំម៉្យាងដែលដាំយកផ្លែទៅធ្វើជាដំណាប់

**red sprangletop** /ˈrɛd /ˈspraŋg(ə)l tɒp/ [n] ស្មៅកន្ទុយក្ងោក (ឈ្មោះវិទ្យាសាស្ត្រ *Leptochloa chinensis*)

**red-eye puffer** /ˈrɛd ʌɪ ˈpʌfə/ [n] ត្រីកំពត (ឈ្មោះវិទ្យាសាស្ត្រ *Carinotetraodon lorteti*)

**reduce** /rɪˈdjuːs/ [v] បន្ថយ, បង្រួម

**reducer** /rɪˈdjuːsə/ [n] សូមមើលពាក្យ៖ decomposer

**reduction** /rɪˈdʌkʃ(ə)n/ [n] ការបន្ថយ, រេដុកម្ម

- pollution reduction /pəˈluːʃ(ə)n rɪˈdʌkʃ(ə)n/ [n] ការបន្ថយការបំពុល

**redwater** /ˈrɛdwɔːtə/ [n] ជំងឺទឹកនោមឈាម (ចំពោះសត្វពាហនៈ)

**reed** /riːd/ [n] ត្រែង

**reedbed** /riːdbɛd/ [n] ព្រៃត្រែង, ព្រៃបបុស

**reef** /riːf/ [n] ជួរថ្មប៉ប្រះទឹក

**refine** /rɪˈfʌɪn/ [v] កែច្នៃ

**refined** /rɪˈfʌɪnd/ [adj] ដែលកែច្នៃ

**refinement** /rɪˈfʌɪnm(ə)nt/ [n] ការកែច្នៃ, ការចម្រាញ់

**refinery** /rɪˈfʌɪn(ə)ri/ [n] រោងចក្រចម្រាញ់, រោងចក្រចម្រាញ់ស្ករ

**reflect** /rɪˈflɛkt/ [v] ចាំងពន្លឺ, ឆ្លុះបញ្ចាំង

**reflex** /ˈriːflɛks/ [n] រេផ្លិច

- conditioned reflex /kənˈdɪʃ(ə)nd ˈriːflɛks/ [n] រេផ្លិចលក្ខខណ្ឌ

**reforest** /riːˈfɒrɪst/ [n] ដាំព្រៃឈើឡើងវិញ

**reforestation** /ˌriːfɒrɪˈsteɪʃ(ə)n/ [n] ការដាំព្រៃឈើឡើងវិញ, ការបង្កើតគម្របព្រៃឈើទាំងដោយធម្មជាតិ ឬសិប្បនិម្មិត (ដោយគ្រាប់ផ្ទាល់ ឬដាំកូន)

**reform** /rɪˈfɔːm/ [n] ការធ្វើកំណែទម្រង់, ការរៀបឡើងវិញ

**land reform** /land rɪˈfɔːm/ [n] កំណែទម្រង់ដីធ្លី

**refresh** /rɪˈfrɛʃ/ [v] ធ្វើឱ្យមុខរបួសមានស្នាមថ្មីដើម្បីផ្សះដូចដើម

**refuse** /rɪˈfjuːz/ [n] សំណល់

- vegetable refuse /ˈvɛdʒtəb(ə)l rɪˈfjuːz/ [n] កម្ទេចរុក្ខជាតិ

**regenerate** /rɪˈdʒɛnəreɪt/ [v] ដុះឡើងវិញ

**regeneration** /rɪdʒɛnəˈreɪʃn/ [n] ការដុះឡើងវិញ

- natural regeneration /ˈnatʃ(ə)r(ə)l rɪdʒɛnəˈreɪʃn/ [n] (សូមមើលពាក្យ៖ natural revegetation) ការដុះលូតលាស់ដោយធម្មជាតិរបស់រុក្ខជាតិ ដោយសារគ្រាប់

**region** /ˈriːdʒ(ə)n/ [n] ផ្នែក, ភូមិភាគ

- biogeographical region /ˌbʌɪəʊdʒɪəˈgrafɪk(ə)l ˈriːdʒ(ə)n/ [n] តំបន់ជីវភូមិសាស្ត្រ
- diversity (D) region /dʌɪˈvəːsɪti (diː) ˈriːdʒ(ə)n/ [n] តំបន់ដោយឡែក (នៅក្នុងតំណលំដាប់អាមីណូអាស៊ីត)

**regional** /ˈriːdʒənl/ [adj] នៃតំបន់, នៃភូមិភាគ

**regradation** /ˌrɛgrəˈdeɪʃ(ə)n/ [n] ការធ្វើឱ្យល្អឡើងវិញនូវបាស (កាចុង) ឬទម្រង់ដី

**regraded** /riːˈgreɪdɪd/ [adj] ដែលធ្វើឱ្យល្អ (វិវត្តន៍ថយពីការលាងច្រោះ)

**regression** /rɪˈgrɛʃ(ə)n/ [n] ហាយនកម្ម (អនុគមន៍ដែលក្នុងនោះវិបត្តិរូបមួយអាស្រ័យទៅនឹងវិបត្តិរូបមួយ ឬច្រើនផ្សេងទៀត), ការដើរថយក្រោយ (ការវិវត្តន៍ពីចាស់ទៅក្មេង)

**regrowth** /riːˈgrəʊθ/ [n] ការដាំឡើងវិញ

**regulation** /rɛgjʊˈleɪʃ(ə)n/ [n] បទបញ្ញត្តិ, បទបញ្ជា, និយតកម្ម, កំណែតម្រូវ

- climate regulation /ˈklʌɪmət rɛgjʊˈleɪʃ(ə)n/ [n] និយតកម្មអាកាសធាតុ

- emission regulation /ɪˈmɪʃ(ə)n rɛgjʊˈleɪʃ(ə)n/ [n] បទបញ្ញត្តិស្តីពីការបញ្ចេញសំណល់ឧស្ម័ន, បទបញ្ញាត្តិស្តីពីអេមីស្យុង
- environmental regulation /ɪnvʌɪrənˈmɛnt(ə)l rɛgjʊˈleɪʃ(ə)n/ [n] បទបញ្ញត្តិបរិស្ថាន
- noise regulation /nɔɪz rɛgjʊˈleɪʃ(ə)n/ [n] បទបញ្ញត្តិស្តីពីកម្រិតសំឡេង
- pollution regulation /pəˈluːʃ(ə)n rɛgjʊˈleɪʃ(ə)n/ [n] បទបញ្ញត្តិស្តីពីការបំពុលបរិស្ថាន
- safety regulation /ˈseɪfti rɛgjʊˈleɪʃ(ə)n/ [n] បទបញ្ជាសុវត្ថិភាព
- temperature regulation /ˈtɛmp(ə)rətʃə rɛgjʊˈleɪʃ(ə)n/ [n] តម្រូវសីតុណ្ហភាព

**regulator** /ˈrɛgjʊleɪtə/ [n] និយតករ

- plant growth regulator /plɑːnt grəʊθ ˈrɛgjʊleɪtə/ [n] រុក្ខនិយតករ
- temperature regulator /ˈtɛmp(ə)rətʃə ˈrɛgjʊleɪtə/ [n] និយតករសីតុណ្ហភាព

**regurgitate** /rɪˈgəːdʒɪteɪt/ [n] រើអៀង

**rehabilitation** /riːhəˈbɪlɪteɪtʃ(ə)n/ [n] ការស្តារ, ទង្វើឱ្យបានល្អឡើងវិញ, និតិសម្បទា

**reiteration** /riːɪtəˈreɪʃ(ə)n/ [n] បំពង់ត្រួយដុះពីមែក (បំពង់ត្រួយលូតត្រង់ទៅលើដុះចេញពីផ្ទៃខាងខ្នងរបស់មែកនៃកន្ទ្រាមមែក ឧ. ប្រភេទ dipterocarp។ គេអាចកាត់វាសម្រាប់បណ្តុះកូនឈើ។)

**reject** /rɪˈdʒɛkt/ [v] សូមមើលពាក្យ៖ discard

**rejuvenation** /rɪdʒuːvəˈneɪʃ(ə)n/ [n] យុវកម្ម, ការផ្សាំមែក

- apparent rejuvenation /əˈpar(ə)nt rɪdʒuːvəˈneɪʃ(ə)n/ [n] ការធ្វើយុវកម្មពក-ខ្នែង (ការផលិតដូចជា បំពង់ត្រួយខ្នែង ដែលមានឫសរួចហើយដុះចេញពីពន្លកត្រួយសម្ងំនៅខ្ញី ឧ. ដោយការកាត់សម្បក។ ការប្រែត្រឡប់នៃដំណើរឡើងចាស់ខាងសរីរៈមិនជាប់ពាក់ព័ន្ធទេ។)
- true rejuvenation /truː rɪdʒuːvəˈneɪʃ(ə)n/ [n] យុវកម្មពិតជាលិកា (ការប្រែត្រឡប់នៃស្ថានភាពប្រែជាពេញវ័យឆ្លងតាមរយៈវប្បកម្មជាលិកា ឬការផ្សាំមែក ធ្វើដូច្នេះ វានឹងដុះឫសបាន)

**relapse** /rɪˈlaps/ [v] លាប់ជំងឺ, រើឈឺឡើងវិញ

**symbiotic relationship** /ˌsɪmbɪˈəʊtɪk rɪˈleɪʃ(ə)nʃɪp/ [n] ទំនាក់ទំនងសារពាង្គកាយរស់, ទំនាក់ទំនងសហប្រាណ

**relax** /rɪˈlaks/ [v] បន្ធូរ

**release** /rɪˈliːs/ [v] រំដោះ, ដោះលែង, រួចផុត, បញ្ចេញ

**released fishing lot area** /rɪˈliːst ˈfɪʃɪŋ lɒt ˈɛːrɪə/ [n] ឡូត៍នេសាទដែលរំសាយចោល

**relief** /rɪˈliːf/ [n] សម្រាល, ការស្រួលខ្លួនឡើងវិញ, ការធូរស្រាល

- surface relief /ˈsəːfɪs-rɪˈliːf/ [n] សូនឱ្យមានជារូបរាង

**relieve** /rɪˈliːv/ [v] ធ្វើឱ្យស្រួលខ្លួនឡើងវិញ, ធ្វើឱ្យធូរស្រាល

**remainder** /rɪˈmeɪndə/ [n] សំណល់

**remedy** /ˈrɛmɪdi/ [n] ឱសថ, ថ្នាំកែរោគ

**remission** /rɪˈmɪʃ(ə)n/ [n] ការស្រាក

**removal** /rɪˈmuːv(ə)l/ [n] ការយកចេញ, ដំណកចេញ

- crop removal /krɒp rɪˈmuːv(ə)l/ [n] ដំណកចេញដោយដំណាំ (ការស្រូបយកសារធាតុចិញ្ចឹមពីដីដោយដំណាំ)
- mass removal /mas rɪˈmuːv(ə)l/ [n] ចលនាជាផ្ទាំងដុល, ការលើកមកទាំងផ្ទាំង
- oil removal /ɔɪlrɪˈmuːv(ə)l/ [n] ការយកប្រេងចេញ
- oxygen removal /ˈɒksɪdʒ(ə)nrɪˈmuːv(ə)l/ [n] ដំណកអុកស៊ីសែន
- removal of the litter from a forest /rɪˈmuːv(ə)l ɒf ðə ˈlɪtə frɒm ə ˈfɒrɪst/ [n] ការឈូសចោលនៃស្រទាប់ស្លឹកឈើខាងលើនៃដីព្រៃ

**remove** /rɪˈmuːv/ [v] យកចេញ

**renal** /ˈriːn(ə)l/ [n] តម្រងនោម, នៃវក្ក

**rendzina** /rɛn(d)ˈziːnə/ [n] ដីកំបោរប្រភេទរេនហ្ស៊ីន

- brown rendzina /braʊn rɛn(d)ˈziːnə/ [n] ដីរេនហ្ស៊ីនសម្បុរត្នោត
- cushion rendzina /ˈkʊʃ(ə)n rɛn(d)ˈziːnə/ [n] ដីរេនហ្ស៊ីន រាងជាកូនខ្នើយ
- degraded rendzina /dɪˈgreɪdɪd rɛn(d)ˈziːnə/ [n] ១. សូមមើលពាក្យ៖ degraded humus carbonate soil ២. សូមមើលពាក្យ៖ calcareous brown soil
- gravely humus rendzina /ˈgreɪvli ˈhjuːməs rɛn(d)ˈziːnə/ [n] ដីក្រួសកំបោរច្រើន
- magnesium rendzina /magˈniːzɪəm rɛn(d)ˈziːnə/ [n] ដីកើតពីម៉ាញេស្យូមកាបូណាត

- mixed rendzina /mɪkst rɛn(d)ˈziːnə/ [n] ដីផនហ្សីនលាយឡំគ្នា, ដីដែលមានរូបភាពដូចជា ផនហ្សីនលាយគ្នា
- mull-like rendzina /mʌl lʌɪk rɛn(d)ˈziːnə/ [n] (សទិសន័យ៖ rubble stone) មមោកប្រភេទ ម៉ូដូរ ដែលមានសភាពដូចមូល (mull)
- podozolised rendzina /ˈpɒdzɒlʌɪsd rɛn(d)ˈziːnə/ [n] ដីចាស់ ដែលកំពុងវិវត្តទៅរកដីប៉ុដហ្សូលដោយ pH ចុះអាស៊ីតខ្លាំង
- raw humus rendzina /rɔ ˈhjuːməs rɛn(d)ˈziːnə/ [n] (សទិសន័យ៖ rendzina mor) ដីផនហ្សីនដែលមានស្រទាប់មមោកដុលក្រាស់ពីលើ
- red rendzina /rɛd rɛn(d)ˈziːnə/ [n] ដីផនហ្សីនក្រហម
- rendzina on gypsum /rɛn(d)ˈziːnə ɒn ˈdʒɪpsəm/ [n] សូមមើលពាក្យ៖ humus sulphate soil
- stone rendzina /stəʊnrɛn(d)ˈziːnə/ [n] ដីកាបូណាតមានមមោកច្រើន (កើតលើថ្មកំបោរ)
- subalpine rendzina /sʌbˈalpʌɪn rɛn(d)ˈziːnə/ [n] ដីផនហ្សីនតំបន់ភ្នំ (កន្លែងត្រជាក់)
- white rendzina /wʌɪt rɛn(d)ˈziːnə/ [n] ដីផនហ្សីន (ពណ៌) ស

**rendzinification** /rɛn(d)ˈziːnifɪˈkeɪʃ(ə)n/ [n] ការក្លាយ ឬវិវត្តន៍ទៅជាដីផនហ្សីន

**renew** /rɪˈnjuː/ [v] ធ្វើសាថ្មី

**reniform** /ˈriːnɪfɔːm/ [adj] ទម្រង់បន្ទះស្លឹករាងបេះដូងប៉ោង

**rennet** /ˈrɛnɪt/ [n] ខន់ទឹកដោះ

**rennin** /ˈrɛnɪn/ [n] អង់ស៊ីមធ្វើឱ្យទឹកដោះខន់

**repair** /rɪˈpɛː/ ការជួសជុល

- dark repair /dɑːk rɪˈpɛː/ [n] ការជួសជុលងងឹត (ការជួសជុស DNA តាមរបៀបមិនត្រូវការពន្លឺ)

**repartition** / riːpɑːˈtɪʃ(ə)n/ ការចែករន្ធដី

- pore-size repartition /pɔː sʌɪz riːpɑːˈtɪʃ(ə)n/ [n] ការចែករន្ធដីតាមទំហំរន្ធ

**repel** /rɪˈpɛl/ [v] ច្រានទៅវិញ, បណ្តេញចេញ (សត្វល្អិត)

**repellent** /rɪˈpɛl(ə)nt/ [n] ថ្នាំបណ្តេញសត្វល្អិត

**replacement** /rɪˈpleɪsm(ə)nt/ [n] ការជំនួស

**replant** /riːˈplɑːnt/ [v] ដាំឡើងវិញ

**replicate** /ˈrɛplɪkeɪt/ [v] ប៉ាន់គំរូ

**replication** /rɛplɪˈkeɪʃ(ə)n/ [n] ឡូត៍គំរូដូចៗគ្នា, សា (ការធ្វើផ្ទួនៗគ្នា ហើយនៅក្នុងពេលតែមួយ និងកន្លែងតែមួយ)

- self-replication /sɛlf rɛplɪˈkeɪʃ(ə)n/ [n] ស្វ័យដំឡើងទ្វេខ្លួន

**representative** /rɛprɪˈzɛntətɪv/ [n] អ្នកតំណាង, ជាតំណាង (ឯកតាតូចមួយដែលតាងស្ទើរតែទាំងអស់នៃបម្រែបម្រួលសរុបនៃឯកតាធំជាងដែលវាតំណាងឱ្យ។ ទីកន្លែងដាំសាកល្បងអាចតំណាងឱ្យរបាយភូមិសាស្ត្រសរុបនៃពូជមួយប្រភេទ ព្រោះពួកវាគ្របដណ្តប់លើវិសាលភាព បរិស្ថានសរុប ឧ. រយៈកម្ពស់ និងរបបទឹកភ្លៀង។ ព្រៃពូជគំរូ ឬអភិរក្សមួយ គឺជាតំណាង បើវាគ្របដណ្តប់លើបម្រែបម្រួលសេនេទិចនៃក្រុមពូជនេះដែលវាតាងឱ្យ។)

**reproduction** /riːprəˈdʌkʃ(ə)n/ [n] ការបន្តពូជ

- asexual reproduction /eɪˈsɛkʃʊəl riːprəˈdʌkʃ(ə)n/ [n] ការបន្តពូជដោយឥតភេទ
- holocarpic reproduction [n] ការបន្តពូជដោយផ្តាច់ខ្លួន
- sexual reproduction /ˈsɛkʃʊəl riːprəˈdʌkʃ(ə)n/ [n] ការបន្តពូជដោយភេទ (ការបន្សំរវាងកាម៉េតឈ្មោល និងញី ឬការបង្កកំណើតដែលឱ្យកំណើតជាទារិកោសិកា ឬស៊ុត)

**reproductive** /ˌriːprəˈdʌktɪv/ [adj] ដែលបង្កើត, នៃការបន្តពូជ

**reptile** /ˈrɛptʌɪl/ [n] សត្វល្មូន, ឧរង្គសត្វ

- aquatic reptile /əˈkwatɪk ˈrɛptʌɪl/ [n] ល្មូនទឹក
- terrestrial reptile /təˈrɛstrɪəl ˈrɛptʌɪl/ [n] ល្មូនគោក

**research fellow** /rɪˈsəːtʃ ˈfɛləʊ/ [n] កម្មសិក្សាស្រាវជ្រាវជន (អ្នកដែលទទួលបានអាហារូបករណ៍សម្រាប់ធ្វើការស្រាវជ្រាវលើការស្រាវជ្រាវលើប្រធានបទកំណត់ណាមួយ)

**research grant** /rɪˈsəːtʃ grɑːnt/ [n] ថវិកាស្រាវជ្រាវ (ថវិកាសម្រាប់ផ្តល់ឱ្យជនណាមួយមានលទ្ធភាពក្នុងការធ្វើការស្រាវជ្រាវលើប្រធានបទកំណត់ណាមួយ)

**research** /rɪˈsəːtʃ/ [n] ការស្រាវជ្រាវ

- empirical research /ɛmˈpɪrɪk(ə)l rɪˈsəːtʃ/ [n] ការស្រាវជ្រាវដែលសម្អាងលើតួលេខ
- scope of research /skəʊp ɒv rɪˈsəːtʃ/ [n] ទំហំនៃការស្រាវជ្រាវ

**researcher-managed trial** /rɪˈsəːtʃə ˈmanɪdʒd ˈtrʌɪəl/ [n] ការពិសោធដែលអ្នកបច្ចេកទេសគ្រប់គ្រង (ការពិសោធធ្វើឡើងនៅលើស្រែកសិករ ដែលគ្រប់គ្រងដោយអ្នកបច្ចេកទេសផ្ទាល់)

**resection** /rɪˈsɛkʃ(ə)n/ [n] ការកាត់ត

**reserve** /rɪˈzəːv/ [n] បម្រុង, ដែនបម្រុង, អាហារបម្រុង

- biosphere reserve /ˈbʌɪə(ʊ)sfɪərɪˈzəːv/ [n] មណ្ឌលជីវបម្រុង
- ecological reserve /iːkəˈlɒdʒɪk(ə)l rɪˈzəːv/ [n] ដែនបម្រុងអេកូឡូស៊ី
- forest reserve /ˈfɒrɪstrɪˈzəːv/ [n] ព្រៃបម្រុង
- mineral reserve /ˈmɪn(ə)r(ə)l rɪˈzəːv/ [n] បម្រុងខនិជ
- natural reserve /ˈnatʃ(ə)r(ə)lrɪˈzəːv/ [n] ដែនបម្រុងធម្មជាតិ

**reservoir** /ˈrɛzəvwɑː/ [n] (សទិសន័យ៖ catchment pond) អាងទឹកក្រោមដី

- flood-control reservoir /flʌd kənˈtrəʊl ˈrɛzəvwɑː/ [n] អាងការពារទឹកជំនន់
- groundwater reservoir /ˈgraʊn(d)wɔːtə ˈrɛzəvwɑː/ [n] អាងទឹកក្នុងដី
- sedimentation reservoir /sɛdɪmɛnˈteɪʃ(ə)n ˈrɛzəvwɑː/ [n] អាងរងកករ
- storage reservoir /ˈstɔːrɪdʒ ˈrɛzəvwɑː/ [n] អាងស្តុក
- water-storage reservoir /ˈwɔːtə ˈstɔːrɪdʒ ˈrɛzəvwɑː/ [n] អាងស្តុកទឹក

**resettle** /riːˈsɛt(ə)l/ [v] ប្តូរលំនៅទៅ, ផ្លាស់ទីលំនៅ

**residual** /rɪˈzɪdjʊəl/ [n]

១. សល់

២. (សទិសន័យ៖ variation) បម្រែបម្រួល

**residue** /ˈrɛzɪdjuː/ [n] សំណល់

- chemical residue /ˈkɛmɪk(ə)l ˈrɛzɪdjuː/ [n] កាកសំណល់គីមី
- crop residue /krɒp ˈrɛzɪdjuː/ [n] កាកសំណល់ដំណាំ (ផ្នែកមួយរបស់ដំណាំដែលគេទុកក្នុងស្រែ ឬចម្ការក្រោយពេលប្រមូលផលរួចដូចជា ស្លឹក គល់ជញ្ជ្រាំង ដើម ឬសចំបើងជាដើម)
- decalcification residue /diːkalsɪfɪˈkeɪʃ(ə)n ˈrɛzɪdjuː/ [n] សំណល់ពីការរលាយថ្មកំបោរ
- leaching residue /liːtʃɪŋ ˈrɛzɪdjuː/ [n] កម្ទេចកំទីសំណល់
- plant residue /plɑːnt ˈrɛzɪdjuː/ [n] កម្ទេចកំទីរុក្ខជាតិ

**resilience** /rɪˈzɪlɪəns/ [n] ភាពធន់ទ្រាំ

**resin** /ˈrɛzɪn/ [n] ជ័រទឹក, ជ័រឈើ (វត្ថុធាតុដែលអាចលាយនឹងអាល់កុលបាន ប៉ុន្តែមិនអាចលាយនឹងទឹកបានទេ)

**resinous** /ˈrɛzɪnəs/ [adj] ដែលមានជ័រ

**resist** /rɪˈzɪst/ [v] ធន់, ទប់ទល់

**resistance** /rɪˈzɪst(ə)ns/ [n] ភាពធន់, អំណត់ធន់ (សមត្ថភាពដែលទាក់ទងនឹងភាពស៊ូទ្រាំនឹងជំងឺ ឬឥទ្ធិពលបំផ្លិចបំផ្លាញផ្សេងៗទៀត។ វាអាចប្រែប្រួលទៅ តាមកម្រិតភាពស៊ាំនឹងរោគ ដែលការចម្លង ឬឥទ្ធិពលណាមួយគ្មានប្រសិទ្ធភាពទៅលើវាទាល់តែសោះ។ តែចំពោះភាពងាយឆ្លងជំងឺវិញ គឺបណ្តាលធ្វើឱ្យវាស្លាប់តែម្តង។)

- disease resistance /dɪˈziːz rɪˈzɪst(ə)ns/ [n] ធន់នឹងជំងឺ, ស៊ាំទៅនឹងជំងឺ
- environmental resistance /ɪnvʌɪrənˈmɛnt(ə)l rɪˈzɪst(ə)ns/ [n] ការប្រឆាំងនៃបរិស្ថាន, ធន់នឹងបរិស្ថាន, ស៊ាំទៅនឹងបរិស្ថាន
- horizontal resistance /hɒrɪˈzɒnt(ə)l rɪˈzɪst(ə)ns/ [n] ភាពធន់ដេក, ភាពធន់បណ្តោយ (ភាពធន់ដែលនាំមុខដោយពន្ធុដែលមានឥទ្ធិពលតិចតួច ហើយក្នុងនោះវាងាយទទួលនូវឥទ្ធិពលនៃបរិយាកាស (ឧ. ពូជមិនធន់នឹងការបំផ្លាញរបស់ដង្កូវស៊ីរូងដើម ដែលដាំក្នុងផ្ទះកញ្ចក់ ប៉ុន្តែធន់នឹងការបំផ្លាញនៃដង្កូវរូងដើមនៅពេលគេយកវាទៅដាំក្នុងស្រែ ឬកន្លែងដទៃៗទៀត ឬផ្ទុយមកវិញ))
- insecticide resistance /ɪnˈsɛktɪsʌɪd rɪˈzɪst(ə)ns/ [n] ភាពធន់នឹងថ្នាំសម្លាប់សត្វល្អិត
- vertical resistance /ˈvɛntr(ə)l rɪˈzɪst(ə)ns/ [n] ភាពធន់ឈរ (ភាពធន់ដែលគ្រប់គ្រងដោយសែនមួយ ពីរ ឬបី។ ពូជដែលមានភាពធន់បែបនេះ ជាទូទៅ មានភាពធន់បែបខ្ពស់ទៅនឹងជំងឺមួយ ឬច្រើនប្រភេទ ឬជីវប្រភេទនៃប្រភេទសត្វល្អិតមួយ ប៉ុន្តែវាមិនធន់ទ្រាំទៅនឹងប្រភេទសត្វល្អិត ឬជំងឺដទៃទៀត។)

**resistant** /rɪˈzɪstənt/ [adj] ដែលមានភាពធន់នឹង

**resolution** /rɛzəˈluːʃ(ə)n/ [n] ដំណោះស្រាយ

- conflict resolution /ˈkɒnflɪkt rɛzəˈluːʃ(ə)n/ [n] ដំណោះស្រាយទំនាស់

**resorption** /rɪˈzɔːpʃ(ə)n/ [n] ការស្រូបឡើងវិញ

**resource** /rɪˈsɔːs/ [n] ធនធាន, ភោគផល, ភោគទ្រព្យ

- biological resource /bʌɪə(ʊ)ˈlɒdʒɪk(ə)l rɪˈsɔːs/ [n] ធនធានជីវសាស្ត្រ
- energy resource /ˈɛnədʒi rɪˈsɔːs/ [n] ធនធានថាមពល
- environmental resource /ɪnvʌɪrənˈmɛnt(ə)l rɪˈsɔːs/ [n] ធនធានបរិស្ថាន
- food resource /fuːd rɪˈsɔːs/ [n] ធនធានម្ហូបអាហារ
- forest resource /ˈfɒrɪst rɪˈsɔːs/ [n] ធនធានព្រៃឈើ
- gas resource /gas rɪˈsɔːs/ [n] ធនធានឧស្ម័ន
- geothermal resource /dʒiːə(ʊ)ˈθəːm(ə)l rɪˈsɔːs/ [n] ធនធានកម្ដៅក្រោមដី
- groundwater resource /ˈgraʊn(d)wɔːtə rɪˈsɔːs/ [n] ធនធានទឹកក្នុងដី
- hypothetical resource /ˌhʌɪpəˈθɛtɪk(ə)l rɪˈsɔːs/ [n] ធនធានប៉ាន់ស្មាន
- land resource /land rɪˈsɔːs/ [n] ធនធានដី
- natural resource /ˈnatʃ(ə)r(ə)l rɪˈsɔːs/ [n] ធនធានធម្មជាតិ
- natural water resource /ˈnatʃ(ə)r(ə)l ˈwɔːtə rɪˈsɔːs/ [n] ធនធានទឹកធម្មជាតិ
- nonrenewable natural resource /nɒnrɪˈnjuːəbəl ˈnatʃ(ə)r(ə)l rɪˈsɔːs/ [n] ធនធានធម្មជាតិមិនកើតឡើងវិញ
- nonrenewable resource /nɒnrɪˈnjuːəbəl rɪˈsɔːs/ [n] ធនធានដែលមិនអាចសំយោគជាថ្មីវិញបាន
- plant genetic resource /plɑːnt dʒɪˈnɛtɪk rɪˈsɔːs/ [n] ធនធានសេនេទិចរុក្ខជាតិ (ពពួកជីវករដែលមានស្រាប់ក្នុងធម្មជាតិ)
- renewable natural resource /rɪˈnjuːəbəl ˈnatʃ(ə)r(ə)l rɪˈsɔːs/ [n] ធនធានធម្មជាតិកើតឡើងវិញ
- surface-water resource /ˈsəːfɪs ˈwɔːtə rɪˈsɔːs/ [n] ធនធានទឹកលើផ្ទៃដី
- water resource /ˈwɔːtə rɪˈsɔːs/ [n] ធនធានទឹក

**respiration** /rɛspɪˈreɪʃ(ə)n/ [n] (សទិសន័យ៖ breathing) ដង្ហើម, ការដកដង្ហើម, ដំណកដង្ហើម

- aerial respiration /ˈɛːrɪəl rɛspɪˈreɪʃ(ə)n/ [n] ដំណកដង្ហើមលើគោក (ដំណកដង្ហើមដែលត្រូវការខ្យល់ ឬអុកស៊ីសែន)
- aerobic cellular respiration /ɛːˈrəʊbɪk ˈsɛljʊlə rɛspɪˈreɪʃ(ə)n/ [n] ដំណកដង្ហើមកោសិកាដែលត្រូវការខ្យល់, ដង្ហើមកោសិកាមានខ្យល់ (ដំណើរគីមីជីវៈ ដែលត្រូវការអុកស៊ីសែន និងបំប្លែងអាហារ ដូចជាគ្លុយស៊ីតឱ្យទៅជាឧស្ម័នកាបូនិច និងទឹក។ នៅពេលបំប្លែងបញ្ចេញថាមពលសម្ពន្ធគីមី ជាម៉ូលេគុល ATP។)
- anaerobic respiration /ˌanɛːˈrəʊbɪk rɛspɪˈreɪʃ(ə)n/ [n] ដង្ហើមគ្មានខ្យល់ (ដំណកដង្ហើមដែលមិនត្រូវការខ្យល់ ឬអុកស៊ីសែន)
- aquatic respiration /əˈkwatɪk rɛspɪˈreɪʃ(ə)n/ [n] ដង្ហើមក្នុងទឹក
- artificial respiration /ɑːtɪˈfɪʃ(ə)l rɛspɪˈreɪʃ(ə)n/ [n] ដង្ហើមនិម្មិត
- cutaneous respiration /kjuːˈteɪnɪəs rɛspɪˈreɪʃ(ə)n/ [n] ដង្ហើមតាមស្បែក
- external respiration /ɪkˈstəːn(ə)l rɛspɪˈreɪʃ(ə)n/ [n] ដង្ហើមក្រៅ (បណ្ដូរឧស្ម័នរវាងមជ្ឈដ្ឋានខាងក្រៅ និងឈាម)

**respirator** /ˈrɛspɪreɪtə/ [n] ប្រដាប់ជំនួយការដកដង្ហើម, ឧបករណ៍ជំនួយការដកដង្ហើម

**respite** /ˈrɛspʌɪt/ [n] ការថែទាំមួយរយៈកាល

**response analysis** /rɪˈspɒns əˈnalɪsɪs/ [n] ការវិភាគពីវិធានការសម្រាប់ទប់ស្កាត់ (ការវិភាគពីវិធានការសម្រាប់ទប់ស្កាត់គឺជាដំណើរការនៃការអង្កេតពីតម្រូវការដែលមានទំនាក់ទំនងរវាងគ្នា ឬក៏ការវិភាគអំពីសភាពការណ៍ទូទៅ ដើម្បីរចនារៀបចំកម្មវិធី។ ដំណើរការនេះដែលជាសកម្មភាពមួយលំដាប់ត្រូវបានកំណត់ដោយផ្អែកលើ ក) តម្រូវការ និងជីវភាពរស់នៅរបស់ប្រជាជនដែលរងផលប៉ះពាល់ ខ) បរិស្ថាន ដែលកំពុងប្រតិបត្តិការ និង គ) ធនធានដែលមាន។)

**response** /rɪˈspɒns/ [n] ប្រតិកម្ម, តំនបរំញោច, ចម្លើយភាព

- biological response /bʌɪə(ʊ)ˈlɒdʒɪk(ə)l rɪˈspɒns/ [n] តំនបរំញោចជីវៈ
- correlated response /ˈkɒrəleɪtɪd rɪˈspɒns/ [n] តំនបជម្រើស, ការឆ្លើយតបដែលជាប់ទាក់ទង (ចំពោះលក្ខណៈដែលទាក់ទងគ្នា ការប្រែប្រួលក្នុងលក្ខណៈមួយនៅពេលដែលគេជ្រើសរើសលក្ខណៈផ្សេងទៀត)
- photoperiod response /ˈfəʊtəʊpɪərɪəd rɪˈspɒns/ [n] ចម្លើយភាពនឹងរយៈពន្លឺ (ភាពឆ្លើយតបរបស់ឯកត្តៈទៅនឹងរយៈពន្លឺ)

**restoration** /rɛstəˈreɪʃ(ə)n/ [n] ការជួសជុល, ការស្ដារ, ការកែប្រែ

**restore** /rɪˈstɔː/ [v] ជួសជុល, ស្ដារ

**restraint** /rɪˈstreɪnt/ [n] ការបង្ខាំង

**resurgence** /rɪˈsəːdʒ(ə)ns/ [n] កំនើនលើស, ការលូតលាស់ឡើងវិញ

- pest resurgence /pɛst rɪˈsəːdʒ(ə)ns/ [n] ការមានឡើងវិញនៃទុរការ, ការមានឡើងវិញនៃសមាសភាពចង្រៃ

**resuscitate** /rɪˈsʌsɪteɪt/ [v] ប្រស់, ធ្វើឱ្យមានដង្ហើមវិញ

**resuscitation** /rɪsʌsɪˈteɪʃ(ə)n/ [n] ការជួយឱ្យមានដង្ហើមវិញ

**retardation** /riːtɑːˈdeɪʃ(ə)n/ [n]
១. ការពន្យារការលូតលាស់
២. ការវិលទាំងប្រាជ្ញា និងចិត្តគំនិត

**retard** /rɪˈtɑːd/ [v] ពន្យារ

**retch** /rɛtʃ/ [v] ប្រឹងក្អួត

**retention** /rɪˈtɛnʃ(ə)n/ [n]
១. ការរក្សាទុក
២. ការទល់ (នោម)

- water retention /ˈwɔːtə rɪˈtɛnʃ(ə)n/ [n] ការចាប់យកទឹក, ការរក្សាឱ្យមានទឹក

**reticulocyte** /rɪˈtɪkjʊlə(ʊ)sʌɪt/ [n] គោលិកាក្រហមថ្មីមានរាងដូចជា សំណាញ់

**reticulum** /rɪˈtɪkjʊləm/ [n] ពោះចក

**retina** /ˈrɛtɪnə/ [n] (សូមមើលពាក្យ៖ pupil) រេទីន (ផ្នែកមួយនៃភ្នែក)

**retro-** /ˈrɛtrəʊ/ [prefix] (សទិសន័យ៖ backward, behind) បុព្វបទមានន័យថា ត្រឡប់, នៅខាងក្រោយ

**retrogradation** /ˌrɛtrəʊgrəˈdeɪʃ(ə)n/ [n] ការថយចុះ (ឧ. ប្រសិទ្ធភាព)

**retro-ocular** /ˈrɛtrəʊ ˈɒkjʊlə/ [n] នៅក្រោយភ្នែក

**retroversion** /rɛtrəʊˈvəːʃ(ə)n/ [n] ការផ្អៀងទៅខាងក្រោយនៃសរីរាង្គមួយទាំងមូល

**retuse** [adj] ទម្រង់ចុងស្លឹកផតទាល

**revaccinate** /riːˈvaksɪneɪt/ [v] ចាក់វ៉ាក់សាំងឡើងវិញ

**revegetation** /riːvɛdʒɪˈteɪʃ(ə)n/ [n] ការដាំរុក្ខជាតិឡើងវិញ

- artificial revegetation /ɑːtɪˈfɪʃ(ə)l riːvɛdʒɪˈteɪʃ(ə)n/ [n] ការដាំរុក្ខជាតិឡើងវិញដោយមនុស្ស
- natural revegetation /ˈnatʃ(ə)r(ə)l riːvɛdʒɪˈteɪʃ(ə)n/ [n] (សូមមើលពាក្យ៖ natural regeneration) ដំណុះរុក្ខជាតិឡើងវិញដោយខ្លួនឯង

**reverse** /rɪˈvəːs/ [v] អាចត្រឡប់បាន, ចម្រាស

**revolution** /rɛvəˈluːʃ(ə)n/ [n] បដិវត្តន៍

- green revolution /griːn ˈrɛvəˈluːʃ(ə)n/ [n] បដិវត្តន៍បៃតង (ការវិវត្តន៍បច្ចេកវិទ្យានៃពូជ ដី និងទឹក)

**reworking** /riːˈwəːkɪŋ/ [n] ការកែប្រែ, ការផ្លាស់ប្ដូរ

**Rhenium** /ˈriːnɪəm/ [n] រ៉េញ៉ូម (និមិត្តសញ្ញាគីមី Re)

**rheostat** /ˈriːəstat/ [n] រេអូស្ដា

**rheumatism** /ˈruːmətɪz(ə)m/ [n] រុយម៉ាទីស, រោគគ្រុនក្នុងសន្លាក់ឆ្អឹង

**Rheusus factor (Rh factor)** [n] វត្ថុធាតុម៉្យាងដែលធម្មតាមានក្នុងឈាមមនុស្ស បើវត្ថុធាតុនេះចូលក្នុងខ្លួនមនុស្សម្នាក់ដែលគ្មានទេ វានឹងបណ្ដាលឱ្យកើតអង្គបដិបក្ខប្រាណ

**rhin-** /rʌɪn/ [prefix] (សទិសន័យ៖ nose) បុព្វបទមានន័យថា ច្រមុះ

***Rhincodon typus*** [sci.n] សូមមើលពាក្យ៖ whale shark

**rhinitis** /rɪˈnʌɪtɪs/ [n] រលាកច្រមុះ (ជំងឺ)

**Rhinotracheitis** /ˈrʌɪnəʊˌtreɪkɪˈʌɪtɪs/ [n] ជំងឺផ្លូវរលាកក្លោងច្រមុះ និងទងសួត

**Rhipicephalus** /rʌɪn pʌɪˈsɛf(ə)lʌs/ [n] សូមមើលពាក្យ៖ tick

**rhizobium** /rʌɪˈzəʊbɪəm/ [n] (ពហុវចនៈ៖ rhizobia) រីហ្សូប៊ីយ៉ូម (បាក់តេរីរស់នៅក្នុងកំពកឫសរុក្ខជាតិ)

***Rhizoctornia solani*** [sci.n] ជំងឺបង្កដោយផ្សិតរីស៊ុកតូនីញ៉ាសូឡានី

**rhizome** /ˈrʌɪzəʊm/ [n] ឫសមើម, មើមក្លៀង, ដើមក្រោមដី, ខ្នែងក្នុងដី (ជាផ្នែកនៃដើមដែលដុះក្នុងដីបន្តពីកញ្ចុំឫសមួយទៅកញ្ចុំឫសមួយទៀត)

**rhizomorph** /ˈrʌɪzəʊmɔːf/ [n] ឫសសណ្ឋាន (ជាលិកាផ្សិតដែលនៅផ្ដុំគ្នាដូចជាខ្សែយ៉ាងណែន ដោយមានសណ្ឋានជាឫស ដែលត្រូវបានបង្កើតដោយផ្សិតថ្នាក់ខ្ពស់ខ្លះ ដូចជា Armillaria។ ឫសសណ្ឋាន ធ្វើឱ្យផ្សិតអាចលូតលាលដាលបាន)

**rhizoplane** /ˈrʌɪzəʊpleɪn/ [n] តំបន់ឫសរង

***Rhizoprionodon acutus*** [sci.n] សូមមើលពាក្យ៖ milk shark

**rhizosphere** /ˈrʌɪzə(ʊ)ˌsfiːə/ [n] តំបន់ជុំវិញឫស, ដែននៃឫស

**Rhodium** /ˈrəʊdɪəm/ [n] រ៉ូដ្យូម (និមិត្តសញ្ញាគីមី Rh)

**rhomboid** /ˈrɒmbɔɪd/ [adj] ទម្រង់បន្ទះស្លឹករាងចតុកោណស្មើ, ទម្រង់បន្ទះស្លឹករាងដូចពេជ្រ

***Rhopalosiphum maidis*** [sci.n] ចៃពោត

**rhythm** /ˈrɪð(ə)m/ [n] ចង្វាក់

**annual rhythm** /ˈanjʊəl ˈrɪð(ə)m/ [n] ចង្វាក់សកម្មភាពប្រចាំឆ្នាំ (សកម្មភាពដែលភាវរស់ជួបប្រទះជាប្រចាំឆ្នាំ)

**circadian rhythm** /səːˈkeɪdɪən ˈrɪð(ə)m/ [n] ចង្វាក់សកម្មភាពប្រចាំថ្ងៃ

**heart rhythm** /hɑːt ˈrɪð(ə)m/ [n] ចង្វាក់បេះដូង

**rib** /rɪb/ [n] ឆ្អឹងជំនី

**riboflavin** /ˌrʌɪbə(ʊ)ˈfleɪvɪn/ [n] រីបូផ្លាវីន (ជីវជាតិ $B_2$)

**Ribonucleic acid (RNA)** /ˌrʌɪbə(ʊ)njuːˈkleɪɪk ˈasɪd/ [n] អាស៊ីតរីបូនុយក្លេអ៊ិច

**rice** /rʌɪs/ [n] ស្រូវ (ឈ្មោះវិទ្យាសាស្ត្រ *Oryza sativa*)

- aerobic rice /ɛːˈrəʊbɪk rʌɪs/ [n] ប្រព័ន្ធផលិតកម្មស្រូវដែលប្រើប្រាស់ទឹកតិចដែលបង្កើតដោយ IRRI
- aromatic rice /arəˈmatɪk rʌɪs/ [n] ស្រូវក្រអូប, អង្ករក្រអូប
- black glutinous rice /blak ˈgluːtɪnəs rʌɪs/ [n] អង្ករឬស្រូវដំណើបខ្មៅ
- boiled rice /bɔɪld rʌɪs/ [n] បាយ
- broken rice /ˈbrəʊk(ə)n rʌɪs/ [n] ចុងអង្ករ (បំណែកតូចៗពីអង្ករដើម ដែលទទួលបានក្រោយពេលកិនស្រូវ)
- broken rice grains /ˈbrəʊk(ə)n rʌɪs greɪnz/ [n pl] អង្ករកំណាត់
- brown rice /braʊn rʌɪs/ [n] អង្ករសម្រូប (គ្រាប់អង្ករដែលពុំទាន់ស្រិត ឬគ្រាន់តែបានបកអង្កាមចេញ)
- deepwater rice /diːpˈwɔːtə rʌɪs/ [n] (សទិសន័យ៖ floating rice) ស្រូវឡើងទឹក
- dry season rice /drʌɪ ˈsiːz(ə)n rʌɪs/ [n] ស្រូវប្រាំង
- early rice /ˈəːli rʌɪs/ [n] ស្រូវស្រាល (ប្រភេទស្រូវ ជាធម្មតាមានអវេទរសនឹងរយៈពន្លឺ ហើយមានអាយុកាលតិចជាង ១២០ ថ្ងៃ ហើយវាអាចដាំទាំងនារដូវវស្សា និងរដូវប្រាំង)
- floating rice /ˈfləʊtɪŋ rʌɪs/ [n] សូមមើលពាក្យ៖ deepwater rice
- glutinous rice /ˈgluːtɪnəs rʌɪs/ [n] (សទិសន័យ៖ sticky rice) ស្រូវដំណើប, អង្ករដំណើប
- head rice /hɛd rʌɪs/ [n] អង្ករដើម (គ្រាប់អង្ករដែលរលូនមិនបាក់បន្ទាប់ពីកិនរួច)
- husked rice /hʌskt rʌɪs/ [n] អង្ករសម្រូប
- hybrid rice /hybrid rʌɪs/ [n] ស្រូវអ៊ីប្រ៊ីត (ស្រូវដែលដាំជាពាណិជ្ជកម្មធំទូលាយនៅជំនាន់ទីមួយ (F1))
- jungle rice /ˈdʒʌŋg(ə)l rʌɪs/ [n] ស្មៅបែកក្បាលគ្មានកន្ទុយ (ឈ្មោះវិទ្យាសាស្ត្រ *Echinochloa colona*)
- late rice /leɪt rʌɪs/ [n] (សទិសន័យ៖ long duration rice) ស្រូវធ្ងន់ (ចំពោះពពួកអវេទរស រយៈពន្លឺវាមានអាយុកាលលើសពី ១៥០ថ្ងៃ ឯពពួកវេទរសវិញ គឺកំណត់ចំពោះពូជដែលចេញផ្កាក្រោយថ្ងៃ ១៥ វិច្ឆិកា)
- long duration rice /lɒŋ djʊˈreɪʃ(ə)n rʌɪs/ [n] សូមមើលពាក្យ៖ late rice
- lowland rice /ˈləʊlənd rʌɪs/ [n] ស្រូវទំនាប (ប្រភេទស្រូវដែលដាំនៅស្រែទំនាប)
- medium rice /ˈmiːdɪəm rʌɪs/ [n] ស្រូវកណ្ដាល (ស្រូវដែលមានអាយុកាលពី ១២០ ថ្ងៃទៅ១៥០ថ្ងៃចំពោះពួកអវេទរស ឬដែលចេញផ្កានៅចន្លោះពាក់កណ្ដាលខែតុលា ទៅពាក់កណ្ដាលខែវិច្ឆិកា ចំពោះពពួកវេទរសនឹងពន្លឺ)
- milled rice /mʌɪld rʌɪs/ [n] អង្ករសម្រិត (អង្ករដែលកិននិងស្រិតរួច ហើយស្រទាប់កន្ទក់ត្រូវបានបកចេញ)
- non-glutinous rice /nɒnˈgluːtɪnəs rʌɪs/ [n] ស្រូវខ្សាយ, អង្ករខ្សាយ
- non-waxy rice /nɒnˈwaksi rʌɪs/ [n] អង្ករខ្សាយ (អង្ករដែលសមាសធាតុអាមីឡូសច្រើនជាង ១០% ជាប្រភេទអង្ករសម្រាប់បរិភោគប្រចាំថ្ងៃ)
- paddy rice /ˈpadi rʌɪs/ [n] សូមមើលពាក្យ៖ paddy
- polished rice /ˈpɒlɪʃt rʌɪs/ [n] អង្ករសម្រិត

- post-harvest rice /pəʊst ˈhɑːvɪst rʌɪs/ [n] ផលិតផលស្រូវនៅក្រោយពេលប្រមូលផល (ការប្រមូល ស្រូវសុទ្ធដែលវាសក្តិសមសម្រាប់ការបរិភោគរបស់មនុស្ស ការបាត់បង់នៅកន្លែងពាងចក្រ ដែលកើតឡើងក្នុងអំឡុងពេលបោកបែនស្រូវ ការហាលសម្ងួត និងការស្តុក ហើយនិងការបាត់បង់ ដែលទាក់ទងទៅនឹងសត្វល្អិតបំផ្លាញដំណាំ)
- receding rice /rɪˈsiːdɪŋ rʌɪs/ [n] ស្រូវបណ្តែញទឹក
- red rice /rɛd rʌɪs/ [n] ស្រូវស្មៅ (ឈ្មោះវិទ្យាសាស្ត្រ *Oryza sativa*)
- sticky rice /ˈstɪki rʌɪs/ [n] សូមមើលពាក្យ៖ glutinous rice
- surplus of milled rice /ˈsəːpləs ɒv mɪld rʌɪs/ [n] អង្ករលើស
- unhusked rice /ʌnˈhʌskt rʌɪs/ [n] ស្រូវ (គ្រាប់ស្រូវ)
- upland rice /ˈʌplənd rʌɪs/ [n] ស្រូវចម្ការ, ស្រូវភ្នំ
- weedy rice /ˈwiːdi rʌɪs/ [n] ស្រូវស្មៅ (ឈ្មោះវិទ្យាសាស្ត្រ *Oryza sativa*)
- wet rice /wɛt rʌɪs/ [n] ស្រូវមិនទាន់សម្ងួត, ស្រូវសើម
- wet season rice /wɛt ˈsiːz(ə)n rʌɪs/ [n] ស្រូវវស្សា
- white rice /wʌɪt rʌɪs/ [n] អង្ករសម្រិត
- wild rice /wʌɪld rʌɪs/ [n] ស្រងែ

**rice blast** /rʌɪs blɑːst/ [n] ជំងឺប្លាស (ជំងឺផ្សិតនៃដំណាំស្រូវបណ្តាលឱ្យស្លឹក ថ្នាំង ផ្នែកខ្លះនៃកួរស្រូវ និងគ្រាប់ស្រូវមានអុចរាងពងក្រពើតិច ឬច្រើន ដោយគែមសងខាងពណ៌ត្នោត និងចំណុចកណ្តាលពណ៌ប្រផេះ។ ជំងឺប្លាសនេះគេអាចហៅថាម្យ៉ាងទៀតថាជា ជំងឺអ្នកមាន ព្រោះកាលណាដីស្រែនោះមានបរិមាណជី ឬអាសូតលើសនោះគេនឹងឃើញវត្តមានជំងឺនេះ។)

**rice consumption** /rʌɪs kənˈsʌm(p)ʃ(ə)n/ [n] ការប្រើប្រាស់អង្ករ, ការបរិភោគបាយ (បរិមាណសរុបនៃអង្ករដែលបានបរិភោគ ដោយគ្រួសារ ឬបុគ្គលម្នាក់ៗដោយវាស់វែងជាក្រាម ជាទូទៅ គឺមានការវាស់វែងជាគីឡូកាឡូរី)

**rice crop** /rʌɪs krɒp/ [n] ដំណាំស្រូវ

**rice deficit province** /rʌɪs ˈdɛfɪsɪt ˈprɒvɪns/ [n] ខេត្តខ្វះខាតស្រូវ

**rice delphacid** /rʌɪs ˈdɛlfacɪd/ [n] មមាចត្នោតតូច (ឈ្មោះវិទ្យាសាស្ត្រ៖ *Laodelphax striatellus*)

**rice flour** /rʌɪs ˈflaʊə/ [n] ម្សៅអង្ករ

**rice thresher** /rʌɪs ˈθrɛʃə/ [n] ម៉ាស៊ីនបោកស្រូវ

**rice-field terrapin** /rʌɪs fiːld/ [n] អណ្តើកស្រែ (ឈ្មោះវិទ្យាសាស្ត្រ *Malayemys subtrijuga*)

**rice field crab** /rʌɪs fiːld krab/ [n] ក្តាមស្រែ

**rice flat sedge** /rʌɪs flat sɛdʒ/ [n] កក់ជ្រុង (ឈ្មោះវិទ្យាសាស្ត្រ *Cyperus iria*)

**rice gall midge** /rʌɪs gɔːl mɪdʒ/ [n] មូសផ្លុង (ស្រូវ)

**rice hispa** /rʌɪs hɪpə/ [n] ខ្លុងបន្លា (ឈ្មោះវិទ្យាសាស្ត្រ *Dicladispa armigera*)

**rice huller** /rʌɪs ˈhʊlə/ [n] ម៉ាស៊ីនកិនស្រូវសម្រូប

**rice skipper** /rʌɪs ˈskɪpə/ [n] មេអំបៅភ្នែកឆ្មា (សត្វល្អិតចង្រៃស្ថិតក្នុងលំដាប់ Lepidoptera គ្រួសារ Hesperidae ដែលដង្កូវស៊ីស្លឹកស្រូវចាប់តាំងពីរឹម (ជាយ) ស្លឹកចូលទៅក្នុង)

**rice surplus province** /rʌɪs ˈsəːpləs ˈprɒvɪns/ [n] ខេត្តផលិតស្រូវលើស

**rich** /rɪtʃ/ [adj] សម្បូរ, មាន

***Richardia brasiliensis*** [sci.n] សូមមើលពាក្យ៖ Brazil pusley, tropical Mexican clover

**ricin** /ˈrɪsɪn/ [n] ជាតិពុលរបស់ល្ហុងខ្វែ ឬល្ហុងប្រេង (ដែលពុលខ្លាំង)

***Ricinus communis*** [sci.n] សូមមើលពាក្យ៖ castor oil plant

**rick** /rɪk/ [n] ផ្ទឹមចំបើង

**rickets** /ˈrɪkɪts/ [n] ក្រិស (ជំងឺ)

**Rickettsia** /rɪˈkɛtsɪə/ [n] រីកេតស៊ី (ពពួកបាក់តេរី ដែលអាចចម្លងមកមនុស្សតាមរយៈចៃ)

**riddle** /ˈrɪd.l̩/ [n] (សទិសន័យ៖ garden sieve) កញ្ច្រែងរែងដី

**ridged gourd** /rɪdʒd gʊəd/ [n] សូមមើលពាក្យ៖ angled luffa

**ridge** /rɪdʒ/ [n] ទ្រនុងជាជួរ, ជួរកំពូលភ្នំ, គែម, ទំបន់ភ្លឺ

**stone ridge** /stōn rɪdʒ/ [n] ទ្រនុងដីដែលមានថ្មច្រើន

**rigid** /ˈrɪdʒɪd/ [adj] ដែលរឹង, ដែលបត់មិនបាន

**rigor mortis** /ˈrɪgɔː mɔːtɪs/ [n] ភាពរឹងដូចខ្មោច, រឹងសាច់ (ការរឹងសាច់របស់សារពាង្គកាយក្រោយពេលស្លាប់)

**rill** /rɪl/ [n] សូមមើលពាក្យ៖ rain-rill

**rind** /raɪnd/ [n] ស្បែក, ផ្នែកខាងក្រៅ, សម្បក

**rinderpest** /ˈrɪndəpɛst/ [n] ប៉េសគោ (ក្របី)

**ring** /rɪŋ/ [n] កង

- annual rings /ˈanjʊəl rɪŋs/ [n] (សទិសន័យ៖ growth ring) រង្វង់លូតលាស់ រង្វង់លូតលាស់ប្រចាំឆ្នាំ, វណ្ឌប្រចាំឆ្នាំ (ជាស៊េរីនៃរង់ដែលស្ថិតនៅផ្នែកខ្លឹមរបស់ឈើ)
- earth ring /əːθ rɪŋ/ [n] ពហុកោណដី (ដីបែកជាពហុកោណ)
- growth ring /grəʊθ rɪŋ/ [n] សូមមើលពាក្យ៖ annual ring
- piston ring /ˈpɪst(ə)n rɪŋ/ [n] ក្រវ៉ាត់ពីស្តុង
- stone ring /stəʊn rɪŋ/ [n] ដុំថ្មដែលផ្តុំជារង្វង់មូល

**ringing in the ear** [n] ហ៊ឹងត្រចៀក

**ripe** /raɪp/ [adj] ទុំ

**ripen** /ˈraɪ.pən/ [v] ឡើងទុំ

- after ripening /ˈɑːftə ˈrʌɪp(ə)nɪŋ/ [n] រយៈពេលលូតលាស់បន្ថែម

***Riptortus linearis*** [sci.n] ស្រឹងភ្លៅធំ, ស្រឹងសណ្តែកពណ៌ត្នោត

**rise** /rʌɪz/ កំណើន

- climacteric rise /klʌɪˈmakt(ə)rɪk rʌɪz/ [n] កំណើនខ្ពស់បំផុត
- capillary rising /kəˈpɪləri ˈrʌɪzɪŋ/ [n] ការឡើងពីក្រោមមកលើដោយថាមពលកាពីលែរ

**risk** /rɪsk/ [n] ហានិភ័យ, ភាពប្រថុយប្រថាន

- explosive risk /ɪkˈspləʊsɪv rɪsk/ [n] គ្រោះថ្នាក់ដែលអាចនឹងមានបណ្តាលមកពីការផ្ទុះ
- fire risk /ˈfʌɪə rɪsk/ [n] គ្រោះថ្នាក់ដែលអាចនឹងមានបណ្តាលមកពីភ្លើងឆេះ
- nuclear risk /ˈnjuːklɪə rɪsk/ [n] គ្រោះថ្នាក់ដែលអាចនឹងមានបណ្តាលមកពីវិភាយវិទ្យុសកម្ម
- production risk /prəˈdʌkʃ(ə)n rɪsk/ [n] ផលវិបាកនៃផលិតកម្ម

**river** /ˈrɪvə/ [n] ទន្លេ, ស្ទឹង

- meander river /mɪˈandə ˈrɪvə/ [n] ទន្លេបន់បែន
- subterranean river /ˌsʌbtəˈreɪnɪən ˈrɪvə/ [n] ស្ទឹងកប់

**river tonguesole** [n] ត្រីអណ្តាតឆ្កែ (ឈ្មោះវិទ្យាសាស្ត្រ *Cynoglossus feldmanni*)

**RNA (Ribo-Nucleic-Acid)** [n] អាស៊ីតរីបូនុយក្លេអ៊ិច, ម៉ូលេគុលសរីរាង្គមួយ មានរាងជាខ្សែអង្កួញៗ ដែលមានភ្ជាប់ម៉ូលេគុលស្ករនិងបេស(បាស) ដែលធ្វើសកម្ម ភាពក្នុងពេលសំយោគប្រូតេអ៊ីន ដោយធ្វើការបកប្រែនិងចម្លងយូដសេនេទិច។ មាន RNA ៣ប្រភេទ គឺ RNA នាំសារ (mRNA) RNA ដឹកជញ្ជូន (tRNA) និង RNA រីបូសូម (សំយោគប្រូតេអ៊ីន) (rRNA)។

**road** /rəʊd/ [n] ផ្លូវ

- main road /meɪn rəʊd/ [n] ផ្លូវមេ, ផ្លូវជាតិ
- secondary road /ˈsɛk(ə)nd(ə)ri rəʊd/ [n] ផ្លូវលំ

**roar** /rɔː/ [v] រោទិ៍

**roast** /rəʊst/ [v] អាំង, ខ្វៃ, លីង

**rock avalanche** /rɒk ˈavəlɑːnʃ/ [n] សូមមើលពាក្យ៖ rock slide

**rock fan** /rɒk fan/ [n] ការប្រមូលផ្តុំកម្ទេចជាគំនរនៅជើងច្រាំងចោតនៃសមុទ្រ

**rock** /rɒk/ [n] ថ្ម, សិលា

- acidic rock /əˈsɪdɪkrɒk/ [n] សិលាអាស៊ីត
- alkaline rock /ˈalkəlʌɪnrɒk/ [n] សិលាអាល់កាឡាំង
- basic rock /ˈbeɪsɪk rɒk/ [n] ថ្មអាល់កាឡាំង, ថ្មបាស (ដោយការពុកផុយនៃថ្មនេះ នឹងក្លាយជាប្រភេទដីអាល់កាឡាំង)
- bed rock /bɛdrɒk/ [n] សិលាមេ
- coombe rock /kuːm rɒk/ [n] (សទិសន័យ៖ rubble drilt) ឥដ្ឋដែលហូរលាយនឹងដុំថ្ម
- crystalline rock /ˈkrɪst(ə)lʌɪnrɒk/ [n] សិលាគ្រាម
- endogenous rock /ɛnˈdɒdʒɪnəs rɒk/ [n] សិលាកំណក្នុង
- exogenous rock /ɪkˈsɒdʒɪnəs rɒk/ [n] សិលាកំណក្រៅ
- igneous rock /ˈɪgnɪəsrɒk/ [n] សូមមើលពាក្យ៖ magmatic rock

- magmatic rock /magˈmatɪk rɒk/ [n] (សទិសន័យ៖ igneous rock ) សិលាម៉ាក់ម៉ា
- mantle rock /ˈmant(ə)l rɒk/ [n] (សទិសន័យ៖ rock outcrop soil) ដីដែលមានថ្មបែកជាកម្ទេច, ដីដែលមានដុំថ្មផុសឡើង
- massive rock /ˈmasɪv rɒk/ [n] សិលាដុល
- metamorphic rock /mɛtəˈmɔːfɪk rɒk/ [n] សិលាប្រែរូប
- organic rock /ɔːˈganɪk rɒk/ [n] សិលាសរីរាង្គ
- sand rock /sand rɒk/ [n] ថ្មសំលៀង, សិលាក្រែ
- sedimentary rock /sɛdɪˈmɛntri rɒk/ [n] សិលាកម្ទេចកំណ
- volcanic rock /vɒlˈkanɪk rɒk/ [n] សិលាភ្នំភ្លើង
- waste rock /weɪst rɒk/ [n] សិលាសំណល់

**rock-fall** /rɒk fɔːl/ [n] ការបាក់ ឬរលំនៃថ្ម

**rockiness** /ˈrɒkɪnəs/ [n] សមាមាត្រថ្មនៅក្នុងដី

**rockslide** /ˈrɒkslʌɪd/ [n] (សទិសន័យ៖ rockslip) ការរលំ ឬស្រុតនៃថ្ម

**rockslip** /rɒkslɪp/ [n] សូមមើលពាក្យ៖ rockslide

**rock-step** /rɒk-stɛp/ [n] ផ្ទៃរាបនៃផ្ទាំងថ្ម

**rod** /rɒd/ [n] បាក់តេរីរាងដូចចង្កឹះ, កោសិកាដំបង

**rodent** /ˈrəʊd(ə)nt/ [n] សត្វកកេរ (ឧ. កណ្ដុរ)

**rodenticide** /rəˈdɛntɪsʌɪd/ [n] ថ្នាំសម្លាប់សត្វកកេរ

- chronic rodenticides /ˈkrɒnɪk rəˈdɛntɪsʌɪds/ [n pl] រទច្ឆេទឃាតខ្សោយ (ថ្នាំបំពុលពពួកសត្វកកេរដូចជា កណ្ដុរ ដែលធ្វើឱ្យឈាមមិនកក ហើយហូរជ្រាបចេញជាប់ជានិច្ច តាមសារពាង្គកាយដែលមានរបួស ឬតាមច្រមុះនៅពេលកណ្ដុរស៊ីចូលក្នុងពោះ)

**roentgen** /ˈrʌntdʒən/ [n] រ៉េន-កែន (ទាក់ទងទៅនឹង X-ray)

**roentgenogram** /ˈrəːntgənə(ʊ)gram/ [n] សូមមើលពាក្យ៖ radiograph

**rogue** /rəʊg/ [v] ដកប្រភេទលាយ (ការយកចេញនូវអ្វីៗដែលមិនត្រូវការ)

**roguing** /rəʊgɪŋ/ [n] សូមមើលពាក្យ៖ culling

**rolling** /ˈrəʊlɪŋ/ [adj] ដែលមានទិដ្ឋភាពជាទឹករលកធំខ្លាំង

**root** /ruːt/ [n] ឫស

- adventitious root /ˌadv(ə)nˈtɪʃəs ruːt/ [n] ឫសរយាង (ឫសដែលដុះចេញពីថ្នាំង), ឫសចៃដន្យ
- branch root /brɑːn(t)ʃ ruːt/ [n] ឫសរយាងខ្ចី
- buttress root /ˈbʌtrɪs ruːt/ [n] ដើមរឹងមានជាតិឈើ ឬឫសគល់ ដែលមានតួនាទីទប់ដើម ជាពិសេសសម្រាប់ដើមឈើធំៗនៅតំបន់ព្រៃត្រូពិច
- climbing root /ˈklʌɪmɪŋ ruːt/ [n] ឫសតោង
- fibrous root /ˈfʌɪbrəs ruːt/ [n] (សទិសន័យ៖ lateral root) ឫសរយាង
- lateral root /ˈlat(ə)r(ə)l ruːt/ [n] សូមមើលពាក្យ៖ fibrous root
- nail root /neɪl ruːt/ [n] ឫសក្រចក
- prop root /prɒp ruːt/ [n] ឫសជន្ទល់, ឫសព្រយោង (ឫសដែលដុះចេញពីដើមដែលទ្រទ្រង់រុក្ខជាតិ)
- secondary adventitious root /ˈsɛk(ə)nd(ə)ri ˌadv(ə)nˈtɪʃəs ruːt/ [n] ឫសខ្យល់ទីពីរ (ឫសដែលដុះចេញពីថ្នាំងខាងក្រោមគេ នៅក្នុងដីនៃដើមស្រូវ)
- seminal root /ˈsɛmɪn(ə)l ruːt/ [n] ឫសកែវ (ឫសដែលដុះចេញមុនគេពីគ្រាប់ផ្ទាល់ ហើយមានតួនាទីសំខាន់ក្នុងការទ្រទ្រង់ជីវិតរបស់រុក្ខជាតិ ជាពិសេសក្នុងដំណាក់កាលដំបូង)
- storage root /ˈstɔːrɪdʒ ruːt/ [n] ឫសមើម
- tape root /teɪp ruːt/ [n] ឫសកែវ
- tuberous root /ˈtjuːb(ə)rəs ruːt/ [n] ឫសជាមើម

**root lesion** /ruːt ˈliːʒ(ə)n/ [n] ស្នាមដំបៅឫស

**root pattern** /ruːt ˈpat(ə)n/ [n] (សទិសន័យ៖ root type) គំរូប្រភេទឫស

**rooting** /ruːtɪŋ/ [n] ការធ្វើឱ្យដុះ ឬចាប់ឫស

**rootlet** /ˈruːtlɪt/ [n] ខ្នែងឫស, ឫសតូចៗ (ឫសដែលដុះចេញពីឫសមេ ឬឫសចាស់ៗនៃស្រូវ)

**rootstock** /ˈruːtstɒk/ [n] គល់បំបៅ ឬជើងទម្រ (រុក្ខជាតិមានឫស ឬផ្នែករបស់រុក្ខជាតិជាធម្មតាជាគល់ ឬជាឫសដែលគេយករុក្ខជាតិមួយផ្សេងទៀតទៅផ្សាំពីលើ)

***Rosa spp.*** [sci.n] សូមមើលពាក្យ៖ rose

**rose** /rəʊz/ [n] ផ្កាកូឡាប (ឈ្មោះវិទ្យាសាស្ត្រ *Rosa spp.*)

**rose apple** /rəʊz ˈap(ə)l/ [n] ជម្ពូ

**rosefin rasbora** /rəʊzfɪn razˈbɔrə/ [n] ត្រីចង្វា (ឈ្មោះវិទ្យាសាស្ត្រ *Rasbora dusonensis*)

**rosella** /rə(ʊ)ˈzɛlə/ [n] ម្ទូរព្រឹក

**rostrate** /ˈrɒstrət/ [adj]

១. ផ្នែករាងដូចចំពុះ

២. ចំពុះនៃ Hemiptera, ស្នែងរបស់ពពួកខ្មូត ឬកញ្ចៃ (Curculionidae)

**rostrum** /ˈrɒstrəm/ [n] រ៉ូស្ត្រឹម (មាត់របស់សត្វល្អិតទាំងអស់នៅក្នុងលំដាប់ Hemiptera មានរាងទ្រវែងសម្រាប់ចោះទម្លុះ និងជញ្ជាក់។ សំដៅទៅលើច្រមុះសត្វកញ្ចៃ (Curculionidae))

**rot** /rɒt / [n] រលួយ, ស្អុយ

- bottom rot /ˈbɒtəm rɒt/ [n] ជំងឺរលួយគូទក្ដោប (ជំងឺបង្កដោយផ្សិត *Rhizoctornia solani*)
- brown rot /braʊn rɒt/ [n] ជំងឺរលួយពណ៌ត្នោត (ផ្សិត ឬបាក់តេរីទាំងឡាយណាដែលបង្កជំងឺរុក្ខជាតិ ដែលធ្វើឱ្យរុក្ខជាតិនោះ មានពណ៌ត្នោត និងជាលិការលួយខូច)
- buckeye rot /ˈbʌkʌɪ rɒt/ [n] ជំងឺខ្លោចផ្លែផ្នែកខាងក្រោយ (ចំពោះប៉េងប៉ោះ ជំងឺនេះបង្កដោយផ្សិត *Phytophthora nicotianae* និង *Phytophthora capcisi* ភាគច្រើនរាលដាលនៅតំបន់អាកាសធាតុក្ដៅ និងសើមខ្លាំង។ ភ្នាក់ងារបង្កជំងឺនេះ រស់នៅក្នុងដីបាន ដែលបង្កើតផ្សិត Oospores, Sporangia និង Zoospores។ ភ្នាក់ងារបង្កជំងឺមានដំណាំច្រើនប្រភេទ ភ្លៀងរយៈពេលយូរ និងសីតុណ្ហភាពខ្ពស់ជាលក្ខណៈសមស្របសម្រាប់ការរាលដាលនៃជំងឺ។)
- dry rot /drʌɪ rɒt/ [n] ជំងឺរលួយស្ងួត, ជំងឺរលួយពុក
- foot rot /fʊt rɒt/ [n] ជំងឺរលួយគល់
- fruit rot /fruːt rɒt/ [n] ជំងឺរលួយផ្លែ (ចំពោះត្រសក់ ជំងឺនេះបង្កដោយផ្សិត *Chaonephora curbitarium, Phythium spp., Rhizochonia solani* ដែលស្ប៉ររបស់វាឆ្លងតាមរយៈសត្វល្អិត ខ្យល់ និងទឹក ដោយឆ្លងរាលដាលខ្លាំងកំឡុងពេលភ្លៀង និងសំណើមខ្ពស់)
- head rot /hɛd rɒt/ [n] ជំងឺរលួយក្ដោប (ជំងឺបង្កដោយផ្សិត *Rhizoctornia solani*)
- mold watery soft rot /məʊld [n] ជំងឺផ្សេះក្ដោបដោយផ្សិត (ជំងឺនេះបង្កដោយផ្សិត *Sclerotinia sclerotiorum* កើតមាននៅតំបន់ក្ដៅ និងតំបន់ខ្ពង់រាបត្រូពិច។ ភ្នាក់ងារបង្កជំងឺអាចរស់នៅក្នុងកាកសំណល់ដំណាំជម្រកផ្សេងៗ ឬរស់នៅក្នុងដី។)
- root rot /ruːt rɒt / [n] ជំងឺរលួយឫស
- sheath rot /ʃiːθ rɒt/ [n] ជំងឺរលួយដើម, ជំងឺរលួយស្រទបស្លឹក (វាបង្កដោយជំងឺផ្សិត Acrocylindrium Oryzae។ ភាពរលួយកើតនៅផ្នែកខាងលើនៃស្រទបស្លឹកស្រោបជុំវិញកួរខ្ចី។ សញ្ញាជំងឺចាប់ផ្ដើមដំបូងជារាងទ្រវែង ឬជាអុតៗដែលមានរាងមិនប្រាកដមានបណ្ដោយពី ០.៥ ទៅ ១.៥ ស.ម ពណ៌ត្នោតសងខាង (គែម) និងចំណុចកណ្ដាលពណ៌ប្រផេះ។ ស្នាមរបួសទាំងនេះ អាចជារួមមានពណ៌ត្នោតប្រផេះតែម្ដង ហើយវាឆ្លងចូលគ្នារាលចេញទាំងស្រទប ជាហេតុបណ្ដាលឱ្យកួរស្រូវចេញពុំរួចហើយក៏រលួយ។ នៅក្នុងស្រទបស្លឹកដែលកើតជំងឺនេះ អាចសង្កេតឃើញមានម្សៅ។)
- soft rot /sɒft rɒt/ [n] ជំងឺរលួយសើម
- stem rot /stɛm rɒt/ [n] ជំងឺរលួយស្រទបស្លឹក, ជំងឺរលួយដើម

**rotate** /rə(ʊ)ˈteɪt/ [adj] ប្រភេទផ្កាមានត្របកជាប់រាងឆ្លាស់

**rotate** /rə(ʊ)ˈteɪt/ [v] បង្វិល

**rotation** /rə(ʊ)ˈteɪʃ(ə)n/ [n] ការឆ្លាស់, ការបង្វិល, ដំណើរវិលជុំ, រង្វិលជុំ, ខួប (ចំនួនឆ្នាំដែលរុក្ខជាតិត្រូវការក្នុងការពេញវ័យ ឬលូតលាស់ដល់ទំហំដែលចង់បាន។ ខួបនៅក្នុងប្រព័ន្ធស្មើអាយុ អំឡុងពេលរវាងការដុះឡើងវិញ និងការកាប់ចុងក្រោយ។ ខួបអាចអាស្រ័យនឹងលក្ខណៈវិនិច្ឆ័យដូចជា ទំហំមធ្យម អាយុ កំណើនមាឌប្រចាំឆ្នាំនិងកម្រិតលូតលាស់ ព្រមទាំងលក្ខខណ្ឌជីវសាស្ត្រ។)

- crop rotation /krɒp rə(ʊ)ˈteɪʃ(ə)n/ [n] ការឆ្លាស់មុខដំណាំ, បន្លាស់ដំណាំ, ដំណាំបង្វិល (ប្រព័ន្ធដាំដុះមួយដែលក្នុងនោះដំណាំពីរ ឬច្រើនប្រភេទត្រូវបានដាំដុះនៅកន្លែងជាប់ៗគ្នា ហើយដំណាំនីមួយៗនឹងត្រូវផ្លាស់ប្ដូរទីកន្លែងជាបន្តបន្ទាប់ទៅតាមកាលកំណត់មួយ ដើម្បីកាត់បន្ថយការបំផ្លាញពីសមាសភាពចង្រៃ)

**rotavator** /ˈrəʊtəveɪtə/ [n] រ៉ូតាវ៉ាទ័រ (ឧបករណ៍កសិកម្ម)

**rotenone** /ˈrəʊtənəʊn/ [n] រ៉ូតេណូន (ថ្នាំរម្ងាប់មេរោគ)

***Rottboellia cochinchinensis*** [sci.n] សូមមើលពាក្យ៖ itchgrass

**rotten** /ˈrɒt(ə)n/ [adj] (សទិសន័យ៖ decay) រលួយ, ពុកផុយ

**rough** /rʌf/ [adj]

១. (សទិសន័យ៖ micro-hilly, hummock) ទិដ្ឋភាពជាកំពូកៗ

២. ដែលគគ្រើម, ដែលមិនសម, ដែលមិនទៀង, សភាពខ្ពស់ ទាបខ្លាំង

**rough lemon** /rʌf ˈlɛmən/ [n] សូមមើលពាក្យ៖ kaffir lime

**roughage** /ˈrʌfɪdʒ/ [n] កម្ទេចកំទី, អាហារដែលសម្បូរជាតិសរសៃ, ស្មៅចំណីសត្វ

**rounds** /raʊndz/ [n pl] (ចំពោះវេជ្ជសាស្ត្រ) វេនពិនិត្យអ្នកជំងឺ

**roup** /raʊp/ [n] (សទិសន័យ៖ coryza) ខាន់ស្លាក់មាន់ (ជំងឺ)

**route** /ruːt/ [n] ផ្លូវ

**routine** /ruːˈtiːn/ [n] ការធ្វើតាមអ្វីដែលធ្លាប់ធ្វើ, ទម្លាប់

**row** /rəʊ/ [n] ជួរ

**rubb** /rʌb/ [n] (សទិសន័យ៖ land talus) ដីដែលមានសុទ្ធតែថ្ម

**rubber** /ˈrʌbə/ [n]

១. ដើមកៅស៊ូ (ឈ្មោះវិទ្យាសាស្ត្រ *Hevea brasiliensis*)

២. កៅស៊ូ (ឧ. របស់ប្រើប្រាស់ធ្វើពីកៅស៊ូ)

- rubber band /ˈrʌbə band/ [n] ជ័រកៅស៊ូ, កៅស៊ូកង
- rubber boot /ˈrʌbə buːt/ [n] ស្បែកជើងកវែង
- rubber nipple /ˈrʌbə ˈnɪp(ə)l/ [n] ក្បាលដោះកៅស៊ូ
- rubber sheet /ˈrʌbə ʃiːt/ [n] កៅស៊ូសន្លឹក
- rubber tubing /ˈrʌbə ˈtjuːbɪŋ/ [n] បំពង់កៅស៊ូ

**rubbish** /ˈrʌbɪʃ/ [n] (សទិសន័យ៖ litter, gabage) សម្រាម

**rubble** /ˈrʌb(ə)l/ [n] ថ្មគ្រេកំបោរទន់ផុយ

- rubble drilt /ˈrʌb(ə)ldrɪlt/ [n] សូមមើលពាក្យ៖ coombe rock

**rubella** /rʊˈbɛlə/ [n] រោគកញ្ជ្រិលស្រាល (ប៉ុន្តែគ្រោះថ្នាក់ដល់ទារកក្នុងផ្ទៃ បើម្តាយមានជំងឺនេះ)

**Rubidium** /rʊˈbɪdɪəm/ [n] រុយប៊ីដ្យូម (និមិត្តសញ្ញាគីមី Rb)

**rudaceous** /rʊˈdeɪʃəs/ [adj] សូមមើលពាក្យ៖ pebbly

**ruderal** /ˈruːd(ə)r(ə)l/ [adj] រុក្ខជាតិដុះលើកម្ទេចសំណល់

**rudimentary** /ˌruːdɪˈmɛnt(ə)ri/ [adj] បែបដើម

***Ruellia tuberosa*** [sci.n] សូមមើលពាក្យ៖ popping pod

**rugose** /ˈruːgəʊs/ [adj]

១. ជ្រួញ (ចំពោះផ្ទៃករបស់រុក្ខជាតិ)

២. គគ្រាត, គគ្រើម (ចំពោះដី)

**rumen** /ˈruːmɛn/ [n] ពោះធំ

**ruminant** /ˈruːmɪnənt/ [n] សត្វទំពាអៀង

**ruminate** /ˈruːmɪneɪt/ [adj] រាងក្រហេងក្រហូង (អំពីទម្រង់របស់រុក្ខជាតិ)

**ruminate** /ˈruːmɪneɪt/ [v] ទំពាអៀង

**rump** /rʌmp/ [n] សូមមើលពាក្យ៖ buttock

**runch** /rʌntʃ/ [n] រុក្ខជាតិតូចៗ

**runcinate** /ˈrʌnsɪneɪt/ [adj] ស្លឹកប្រាសទង

**runholder** /ˈrʌnhəʊldə/ [n] ម្ចាស់សត្វ (ឧ. ចៀម)

**runner** /ˈrʌnə/ [n] គល់វារ, ដើមតោងគេ, ដើមសណ្តោង, ដើមវារ (ដើមរុក្ខជាតិ ឬស្មៅ ដែលដុះបែកចេញពីគុម្ពហើយវារនៅលើដី ព្រមទាំងមានថ្នាំងនីមួយៗ ផ្នែកខាងក្រោមមានដុះឫស អាចបង្កើតបានជាកូនរុក្ខជាតិ (ស្មៅ) ថ្មីពីថ្នាំងទាំងនោះ)

- root runner /ruːt rʌn.ə/ [n] ដៃ, ខ្នែង (រុក្ខជាតិ)

**run-off** /ˈrʌnɒf/ [n] (សទិសន័យ៖ outflow) ការហូរច្រោះ, រំហូរ, ការហូរចេញ (ចលនាទឹកនៅលើដីពីទីខ្ពស់ទៅទីទំនាបហើយដែលបណ្តាលឱ្យមានការបាត់បង់ដីជាតិ ដោយសារការហូរចេញនេះ)

- agricultural run-off /agrɪˈkʌltʃərəl rʌn ɒf/ [n] រំហូរពីដីកសិកម្ម
- annual run-off /ˈanjʊəl rʌn ɒf/ [n] រំហូរប្រចាំឆ្នាំ
- average run-off /ˈav(ə)rɪdʒ rʌn ɒf/ [n] (សទិសន័យ៖ mean run-off) រំហូរមធ្យម
- flood run-off /flʌd rʌn ɒf/ [n] រំហូរជំនន់
- mean annual run-off /miːn ˈanjʊəl ˈrʌn ɒf/ [n] រំហូរមធ្យមប្រចាំឆ្នាំ
- mean run-off /miːn ˈrʌn ɒf/ [n] សូមមើលពាក្យ៖ average run-off

- monthly run-off /ˈmʌnθli rʌn ɒf/ [n] រំហូរប្រចាំខែ
- natural run-off /ˈnatʃ(ə)r(ə)l rʌn ɒf/ [n] រំហូរធម្មជាតិ
- polluting run-off /pəˈluːtɪŋ rʌn ɒf/ [n] រំហូរកខ្វក់, រំហូរបំពុល
- sediment run-off /ˈsɛdɪm(ə)nt rʌn ɒf/ [n] រំហូរកម្ទេចកំណ
- surface run-off /ˈsəːfɪs rʌn ɒf/ [n] រំហូរលើផ្ទៃ
- urban run-off /ˈəːb(ə)n rʌn ɒf/ [n] រំហូរពីទីក្រុង

**runway** /ˈrʌnweɪ/ [n] ផ្លូវរត់ (ផ្លូវដែលកណ្ដុរតែងរត់ចុះឡើងក្នុងការចេញទៅបំផ្លាញដំណាំ)

**rupture** /ˈrʌptʃə/ [n] ធ្លាយ, ក្លូន

**rust** /rʌst/ [n] ច្រែះ (ប្រភេទផ្សិតដែលបង្កជំងឺដល់រុក្ខជាតិច្រើនប្រភេទ និងធ្វើឱ្យខូចដំណាំ)

**rut** /rʌt/ [n] ពេលរកឈ្មោលញី

**Ruthenium** /rʊˈθiːnɪəm/ [n] រ៉ុយតេញ៉ូម (និមិត្តសញ្ញាគីមី Ru)

**Rutherfordium** /ˌrʌðəˈfɔːdɪəm/ [n] រូតេហ្វដ្យូម (និមិត្តសញ្ញាគីមី Rf)

## S

**sabertooth thryssa** [n] ត្រីធ្មាក្រពើ (ឈ្មោះវិទ្យាសាស្ត្រ *Lycothrissa crocodilus*)

**sac** /sak/ [n] ថង់, ស្បោង (ភាគនៃសរីរាង្គរាងដូចថង់ ឬថ្លោក)

- embryo sac /ˈɛmbrɪəʊ sak/ [n] ថង់អំប្រីយ៉ុង, ថង់ពន្លក (បរិធានដែលមានកោសិកាស៊ុតនៅក្នុងនោះ ហើយមានការធ្វើពហុពលកម្មនៅខាងក្នុង (នេះជាអនាគតគ្រាប់ក្រោយពីការធ្វើពហុពលកម្ម))
- heart sac /hɑːt sak/ [n] សូមមើលពាក្យ៖ pericardium
- poison sac /ˈpɔɪz(ə)n sak/ [n] បាវ ឬថង់ថ្នាំពុល

**saccharide** /ˈsakərʌɪd/ [n] (សទិសន័យ៖ saccharose, sucrose, sugar) សាការីត, ស្ករស, ស្ករសាការ៉ូស

**Saccharomyces** /ˈsakərəʊmʌɪsɛs/ [n] សាការ៉ូមីសែស (មេដំបែ)

**saccharose** /ˈsakərəʊz/ [n] សូមមើលពាក្យ៖ saccharide

***Saccharum officinarum*** [sci.n] សូមមើលពាក្យ៖ sugar cane

**sack** /sak/ [n] បាវ

**sacro-** /ˈseɪkrəʊ/ [prefix] ដែលទាក់ទងទៅនឹងឆ្អឹងគូទ

**sacroma** /sɑːˈkəʊmə/ [n] សាច់ដុះម៉្យាង ធ្វើពីវត្ថុធាតុមានភាពដូចឆ្អឹង ដែលធម្មតាមានរីកធំឡើងជានិច្ច

**sacrum** /ˈsakrəm/ [n] ឆ្អឹងគូទ, ផ្នែកធំនៅលើឆ្អឹងកញ្ចូញគូទ

**safety** /ˈseɪfti/ [n] សុវត្ថិភាព

- environmental safety /ɪnvʌɪrənˈmɛnt(ə)l ˈseɪfti/ [n] សុវត្ថិភាពបរិស្ថាន
- food safety /fuːd ˈseɪfti/ [n] សុវត្ថិភាពស្បៀង

**safran** [n] រមៀតsafran (ឈ្មោះវិទ្យាសាស្ត្រ *Crocus sativus*)

**saggittate** /ˈsadʒɪteɪt/ [adj] រាងក្បាលព្រួញ (អំពីទម្រង់របស់រុក្ខជាតិ)

**sagittal** /səˈdʒɪt(ə)l/ [n] សូមមើលពាក្យ៖ section

**sagittate** /ˈsadʒɪteɪt/ [adj] ទម្រង់គល់ស្លឹកទម្រង់ផ្លែព្រួញ

**saline** /ˈseɪlʌɪn/ [adj] ប្រៃ, នៃអំបិល, ដែលមានជាតិប្រៃ

**saline** /ˈseɪlʌɪn/ [n] សូលុយស្យុងដែលមានជាតិអំបិល (វាត្រូវបានប្រើក្នុងវិស័យវេជ្ជសាស្ត្រ)

**salinity** /səˈlɪnɪti/ [n] កម្រិតប្រៃ, ជាតិប្រៃ, អត្រាអំបិល, ភាពប្រៃ (ភាពដែលមានបរិមាណអំបិលលាយច្រើន ហើយដែលក្នុងនោះមានបម្លាស់ប្តូរកាចុងសូដ្យូម)

**salinization** /salɪnʌɪˈzeɪʃ(ə)n/ [n] ការឡើងប្រៃ, អំបិលកម្ម, ការផ្អាប់អំបិល, ការកកអំបិលនៅក្នុងដី

**saliva** /səˈlʌɪvə/ [n] ទឹកមាត់

**salmon** /ˈsamən/ [n] ត្រីសាលម៉ុង

**Salmonella** /ˌsalməˈnɛlə/ [n] បាក់តេរីសាល់ម៉ូណែល (មេរោគដែលបណ្តាលឱ្យមានការពុលអាហារ)

**Salmonellosis** /ˌsalmənəˈləʊsɪs/ [n] ជំងឺគ្រុនពោះវៀន (ជំងឺដែលបណ្តាលមកពីបាក់តេរីសាល់ម៉ូណែល)

**salpingectomy** /ˌsalpɪnˈdʒɛktəmi/ [n] ការវះកាត់យកប្រមោយស្បូនចេញ

**salpingitis** /ˌsalpɪnˈdʒʌɪtɪs/ [n] រលាកដៃស្បូន, ជំងឺរលាកប្រមោយស្បូន

**salpingo-oophorectomy** [n] ការវះកាត់យកប្រមោយ និងអូវ៉ារីចេញ

**salt** /sɔːlt/ [n] អំបិល

- rock salt /rɒk sɔːlt/ [n] អំបិលថ្ម, អំបិលគ្រួស

**saltation** /salˈteɪʃ(ə)n/ [n] ការចល័ត ឬហូរវត្ថុអ្វីមួយនៅក្នុងទឹកដោយខ្យល់បក់

**salt evaporator** /sɔːlt ɪˈvapəreɪtə/ [n] ស្រែអំបិល

**saltmarsh bulrush** /sɔːltmɑːʃ ˈbʊlrʌʃ/ [n] កក់ផ្កាកញ្ចុំ (ឈ្មោះវិទ្យាសាស្ត្រ *Bolboschoenus maritimus*)

**saltwater crocodile** /sɔːltˈwɔːtə ˈkrɒkədʌɪl/ [n] (សទិសន័យ៖ estuarine crocodile) ក្រពើសមុទ្រ (ឈ្មោះវិទ្យាសាស្ត្រ *Crocodylus porosus*)

**saltwedge** /sɔːltwɛdʒ/ [n] ការជ្រៀតចូលនៃទឹកសមុទ្រនៅក្រោមទឹកទន្លេតំបន់ពាម (តំបន់ទឹកប្រៃខ្លាំង ដែលមានកំហាប់អំបិលពី ៣០ ភាគពាន់ឡើងទៅ)

**salve** /salv/ [n] ថ្នាំលាប ឬរឹត, ប៉ូម៉ាត

**salverform** /ˈsalvəfɔːm/ [adj] ប្រភេទផ្កាមានត្របកជាប់រាងថាស

**samara** /ˈsamərə/ [n] ប្រភេទផ្លែ(មាន)ស្លាប ផ្លែប្រភេទសាមអឺរ៉ា (ជាប្រភេទផ្លែមានស្លាប មិនប្រេះ ស្ងួត មានគ្រាប់មួយ ឬច្រើន)

**Samarium** /səˈmɛːrɪəm/ [n] សាម៉ារ្យូម (និមិត្តសញ្ញាគីមី Sm)

**sample** /ˈsɑːmp(ə)l/ [n] ភាគសំណាក, សំណាក, គំរូតាង, គំរូ (គ្រាប់ពូជ), ប៉ាន់, តំណាង, តួយ៉ាង

- blood sample /blʌd ˈsɑːmp(ə)l/ [n] សំណាកឈាម
- composite sample /ˈkɒmpəzɪt ˈsɑːmp(ə)l/ [n] គំរូតំណាងល្បាយគ្រាប់នៃកញ្ចប់គ្រាប់ពូជ (ការលាយចូលគ្នានៃតំណាងគ្រាប់ជាច្រើនដែលគេយកមកពីបណ្ដាផ្នែកជាច្រើនខុសៗគ្នានៃកញ្ចប់គ្រាប់)
- primary sample /ˈprʌɪm(ə)ri ˈsɑːmp(ə)l/ [n] គំរូបឋម , ប៉ាន់បឋម (គំរូប៉ាន់មួយចំនួនតូចដែលយកចេញពីទីតាំងមួយកន្លែងរបស់កញ្ចប់គ្រាប់ពូជ។ គំរូបឋមជាច្រើនផ្សំគ្នាបាន ជាគំរូសមាសមួយ។)
- soil samples /sɔɪl ˈsɑːmp(ə)lz/ [n pl] សំណាកដី
- submitted sample /səbˈmɪtɪd ˈsɑːmp(ə)l/ [n] គំរូគ្រាប់ដែលបានផ្ញើរមក (គំរូនៃគ្រាប់ដែលបានផ្ញើរមកស្ថានីយ៍ពិសោធគ្រាប់ពូជ។ វាជាផ្នែកមួយនៃគំរូគ្រាប់សមាស (ល្បាយ))
- working sample /ˈwəːkɪŋ ˈsɑːmp(ə)l/ [n] គំរូគ្រាប់បានពិសោធរួច, ប៉ាន់គ្រាប់បានពិសោធរួច (ប៉ាន់គ្រាប់ពូជដែលយកចេញពីប៉ាន់គ្រាប់ផ្ញើរឱ្យនៅក្នុងមន្ទីពិសោធន៍ដែលការពិសោធពីគុណភាពគ្រាប់បានធ្វើរួចហើយខ្លះ)

**sampling** /ˈsɑːmp(ə)lɪŋ/ [n] ការជ្រើសរើស, ការធ្វើសំណាក (ដំណើរការ ឬវិធីសាស្ត្រជ្រើសរើសតំណាងរបស់ប្រជាករណាមួយ)

- random sampling /ˈrandəm ˈsɑːmp(ə)lɪŋ/ [n] ការជ្រើសរើសចំនួនសំណាកតាមវិធីរើសដោយចៃដន្យ (គឺជាវិធីជ្រើសរើសសំណាក ដោយប្រើសម្រាប់ជ្រើសរើសចំនួនសំណាកសម្រាប់ធ្វើការអង្កេត ដែលនៅក្នុងនោះឯកតានីមួយៗ នៅក្នុងទំហំនៃការអង្កេតមានប្រូបាប៊ីលីតេនៃការជ្រើសរើសចំនួនសំណាក គឺមានការកំណត់ ប៉ុន្តែមិនចាំបាច់ឱ្យដូចគ្នានោះទេ។ វាអាចផ្ទុយគ្នាទៅនឹងការជ្រើសរើសសំណាកតាមគោលបំណង ដែលក្នុងនោះប្រជាជនទាំងអស់ត្រូវបានជ្រើសរើសសម្រាប់លក្ខណៈជាក់លាក់ណាមួយ (ឧ. គ្រួសារក្រីក្រ)។)

***Sanaanea saman*** [sci.n] សូមមើលពាក្យ៖ rain tree

**sanctuary** /ˈsaŋ(k)tjʊəri/ [n] ដែនជម្រក

- fish sanctuary /fɪʃ ˈsaŋ(k)tjʊəri/ [n] ដែនជម្រកមច្ឆាជាតិ
- wildlife sanctuary /ˈwʌɪl(d)lʌɪf ˈsaŋ(k)tjʊəri/ [n] ដែនជម្រកសត្វព្រៃ

**sand** /sand/ [n] ដីខ្សាច់ (ភាគល្អិតនៃដីដែលមានអង្កត់ផ្ចិតពី 0.0៥ ទៅ ២ ម.ម)

- barren sand /ˈbar(ə)n sand/ [n] ដីខនិជដែលមានគ្រាប់ដីជាខ្សាច់ (គ្មានមមោក គ្មានឥដ្ឋ) (ដីគ្មានជីជាតិ)
- bleach sand /bliːtʃ sand/ [n] សូមមើលពាក្យ៖ bleach earth
- blown sand /bləʊn sand/ [n] សូមមើលពាក្យ៖ shifting sand
- clay sand /kleɪ sand/ [n] ដីវាយនភាពឥដ្ឋខ្សាច់
- coarse sand /kɔːs sand/ [n] ខ្សាច់គ្រើម
- coarse sand (USA) /kɔːs sand/ [n] (សទិសន័យ៖ light sand (UK)) ដីដែលមានវាយនភាពខ្សាច់គ្រើម, ខ្សាច់គ្រើម (គ្រាប់ ពី ២០-២០០ មីក្រុង)
- concretionary sand /kənˈkriːʃən(ə)ri sand/ [n] ខ្សាច់ដែលមានក្រួសក្រវៀន, ស្រទាប់ដីដែលមានក្រួសក្រវៀនច្រើន
- cover sand /ˈkʌvə sand/ [n] ខ្សាច់ដែលគ្របពីលើ
- drift-sand /drɪft-sand/ [n] (សទិសន័យ៖ quick-sand) ខ្សាច់ចល័ត, ខ្សាច់ក្អួច
- eolian sand /iːˈəʊlɪən sand/ [n] ខ្សាច់នាំមកដោយខ្យល់
- fine sand /fʌɪn sand/ [n] (សទិសន័យ៖ fine sand earth) ខ្សាច់ម៉ដ្ឋ
- gleyed sand /gleɪd sand/ [n] ខ្សាច់ជាំទឹក
- grey sand /greɪ sand/ [n] ខ្សាច់ប្រផេះ
- heavy sand /ˈhɛvi sand/ [n] ដីខ្សាច់ម៉ដ្ឋ (គ្រាប់តូចជាង ១០ មីក្រុងពី 0-១០%)
- light sand /lʌɪt sand/ [n, UK] (សទិសន័យ៖ coarse sand US) ដីដែលមានវាយនភាពខ្សាច់គ្រើម

- loamy coarse sand /ləʊmi kɔːs ˈsand/ [n] ខ្សាច់គ្រើមល្បាយ
- loamy sand /ˈləʊmi sand/ [n] (សទិសន័យ៖ mealy sand) ខ្សាច់ល្បាយ
- mealy sand /ˈmiːli sand/ [n] សូមមើលពាក្យ៖ loamy sand
- medium sand /ˈmiːdɪəm sand/ [n] ខ្សាច់មធ្យម
- moving sand /ˈmuːvɪŋ sand/ [n] ខ្សាច់ចល័ត, ខ្សាច់កួចចុះក្រោម
- muddy sand /ˈmʌdi sand/ [n] ដីខ្សាច់ជាភក់
- quick-sand /kwɪk sand/ [n] សូមមើលពាក្យ៖ drift-sand
- reddish-brown ferruginous sand [n] ខ្សាច់ក្រហម (ដោយវត្ថុធាតុដែក)
- shelly sand /ʃɛli sand/ [n] (សទិសន័យ៖ shell-marl) ថ្មកំបោរ ឬខ្សាច់កំបោរកើតពីសម្បកខ្យង ឬលៀស
- shifting sand /ˈʃɪftɪŋsand/ [n] (សទិសន័យ៖ blown sand) ខ្សាច់ចល័ត, ខ្សាច់ហោះ
- very fine sand /ˈvɛri fʌɪn sand/ [n] គ្រាប់ ២០-២០០ មីក្រុង (ខ្សាច់ម៉ដ្ឋ)
- warp sand /wɔːp sand/ [n] ខ្សាច់ទន្លេ, ខ្សាច់នាំមកដោយទឹកទន្លេ

***Sandoricum indicum*** [sci.n] សូមមើលពាក្យ៖ santol

**sandpaper** /ˈsan(d)peɪpə/ [n] ក្រដាសខាត់ (ក្រដាសប្រឡាក់ដោយដីខ្សាច់សម្រាប់ខាត់ផ្ទៃគ្រើម)

**sandstone** /ˈsan(d)stəʊn/ [n] ថ្មសំលៀង, ថ្មភក់, សិលាក្រៃ

- iron sandstone /ˈʌɪən ˈsan(d)stəʊn/ [n] ថ្មគ្រៃដែលមានដែកច្រើន

**sandy** /ˈsandi/ [adj] (សទិសន័យ៖ arenaceous) ដែលជាខ្សាច់, ដែលមានខ្សាច់ច្រើន

**sanguine** /ˈsaŋgwɪn/ [adj] ទំនាក់ទំនងនឹងឈាម

**sanitary** /ˈsanɪt(ə)ri/ [adj] ដែលមានអនាម័យ, ដែលទាក់ទងសុខភាព, ដែលទាក់ទងសុខាភិបាល

**sanitation** /sanɪˈteɪʃ(ə)n/ [n] អនាម័យ (និយាយសំដៅទៅរកការផ្តល់គ្រឿងប្រដាប់ប្រដារសំរាប់ធ្វើអនាម័យ និងសេវាសម្រាប់ការបញ្ចេញចោលប្រកបដោយសុវត្ថិភាពនូវកាកសំណល់ទាំងឡាយរបស់មនុស្ស ដូចជាទឹកនោម និងលាមក។ កង្វះអនាម័យ ឬអនាម័យ មិនគ្រប់គ្រាន់ ជាមូលហេតុចំបងដែលបណ្តាលឱ្យកើតមានជម្ងឺនៅទូទាំងពិភពលោក ហើយការធ្វើឱ្យប្រសើរឡើងនូវបញ្ហាអនាម័យត្រូវបានគេដឹងថា មានផលប៉ះពាល់ជាគុណប្រយោជន៍ដ៏ធំធេងទៅលើសុខភាព និងសន្តិសុខស្បៀង ទាំងនៅតាមគ្រួសារ និងនៅតាមទូទាំងសហគមន៍។ ក៏ដូចគ្នានេះដែរ ពាក្យនេះក៏ត្រូវបាននិយាយសំដៅទៅរកការថែរក្សាលក្ខខណ្ឌអនាម័យតាមរយៈសេវានានា ដូចជាសេវាប្រមូលសម្រាម និងសេវាបញ្ចេញ ទឹកលូ/ទឹកសំអុយជាដើម។)

**sanitation service** /sanɪˈteɪʃ(ə)n ˈsəːvɪs/ [n] សេវាអនាម័យ ( លំនៅដ្ឋាន ឬបរិស្ថាន)

**santol** [n] បំពេញរាជ (ឈ្មោះវិទ្យាសាស្ត្រ *Sandoricum indicum*)

**sap** /sap/ [n] រុក្ខរស

- cell sap /sɛl sap/ [n] រុក្ខរស, សារធាតុរាវនៅក្នុងវ៉ាគុយអូលរបស់កោសិការុក្ខជាតិ

**sapling** /ˈsaplɪŋ/ [n] កូនឈើ, កូនឈើប៉ុនថ្នោល

**sapodilla** /ˌsapəˈdɪlə/ [n] (សទិសន័យ៖ naseberry) ល្មុត (ឈ្មោះវិទ្យាសាស្ត្រ *Manilkara zapota*)

**saprobe** /ˈsaprəʊb/ [n] សាប្រូប, អ្នកបំបែក (ភាវៈរស់ដែលចិញ្ចឹមជីវិតដោយសារធាតុសរីរាង្គដែលងាប់ៗ)

**saprobiont** /ˈsaprəʊbˈbaɪɒnt/ [n] ភាវរស់លើសត្វ ឬរុក្ខជាតិងាប់

**saprophyte** /ˈsaprə(ʊ)fʌɪt/ [n] សាប្រូភីត (សារពាង្គកាយដែលស្រូបយកអាហារពីសារធាតុសរីរាង្គដែលងាប់ ឬរលួយ)

**saprophytic** /saprə(ʊ)ˈfɪtɪk/ [adj] ដែលរស់នៅជាសាប្រូភីត

**sapwood** /ˈsapwʊd/ [n] ស្រាយឈើ (ស្រទាប់ដើមក្រៅបង្អស់ដែលមាននៅក្នុងដើមឈើ ដែលផ្ទុំពីកោសិការស់ និងជាភ្នាក់ងារនាំយកទឹកទៅផ្នែកខាងលើដើមឈើ។ ឈើទន់ ឬស្រាយមានលក្ខណៈស្រាល និងពណ៌ស្រាលជាងឈើខ្លឹម។)

**sarco-** /ˈsɑːkəʊ/ [prefix] (សទិសន័យ៖ flesh, muscle) បុព្វបទមានន័យថា សាច់ដុំ

**Sarcodina** /sɑːkaʊdɪnə/ [n] ដំបៅមហារីកដុះត្រង់កន្លែងភ្ជាប់សាច់ នឹងឆ្អឹង

**sarcoma** /sɑːˈkəʊmə/ [n] សាកូម

**Sarcophaga** /ˈsɑːkəʊfəgə/ [n] សាកូផា (មេកម)

**Sarcoptes** /ˈsɑːkɒptɛs/ [n] សូមមើលពាក្យ៖ scabies

**Sarcosporidia** /ˈsɑːkəʊspəʊrɪdɪə/ [n] សាកូស្ប៉ូរីឌី

**sarcotesta** [n] ស្រទាប់ទន់ជ្រាយរបស់សម្បកគ្រាប់

**satellite image** /ˈsatəlʌɪt ˈɪmɪdʒ/ [n] រូបភាពថតពីផ្កាយរណប

**saturate** /ˈsatʃəreɪt/ [n] ភាពឆ្អែត (ការបំពេញតាមចន្លោះទំនេរៗនៃភាគល្អិតដីទៅដោយទឹក (ឧ. ដីឆ្អែតទឹកជាដើម))

**saturate** /ˈsatʃəreɪt/ [v] ឆ្អែត

**saturated** /ˈsatʃəreɪtɪd/ [adj] ឆ្អែត (សូលុយស្យុង), ណឹត

**saturation** /satʃəˈreɪʃ(ə)n/ [n] ភាពឆ្អែត, ភាពជោគជាំ

- oxygen saturation /ˈɒksɪdʒ(ə)n satʃəˈreɪʃ(ə)n/ [n] ការជ្រួតជ្រាបនៃខ្យល់អុកស៊ីសែន
- saturation indice /satʃəˈreɪʃ(ə)n ˈɪndɪs/ [n] ភាពពោរពេញទៅដោយកាចុង (ខនិជ)

***Sauropus androgynus*** [sci.n] ងប់ (ឈ្មោះរុក្ខជាតិ)

**sausage** /ˈsɒsɪdʒ/ [n] សាច់ក្រក

**savanna** /səˈvanə/ [n] វាលស្មៅ (ជាវាលស្មៅតំបន់ទំនាបតំបន់ត្រូពិច ឬអនុត្រូពិចដែលមានដើមឈើដុះជាដុំៗ)

**saw** /sɔː/ [v] អារ

**saw** /sɔː/ [n] រណារ

- power saw /ˈpaʊə sɔː/ [n] ម៉ូទ័រអារឈើ

**saw chain** /sɔː tʃeɪn/ [n] ច្រវាក់ធ្មេញរណារនៅលើម៉ាស៊ីនអារឈើ

**saw guide** /sɔː gʌɪd/ [n] ឧបករណ៍ក្រិតទំហំអារនៅលើម៉ាស៊ីនអារឈើ

**sawmill** /ˈsɔːmɪl/ [n] រោងចក្រអារឈើ, រោងម៉ាស៊ីនអារឈើ

**saw-edgedblade** /sɔː ɛdʒdbleɪd/ [n] ផ្លែរណារ

**sawdust** /ˈsɔːdʌst/ [n] អាចម៍រណារ

**scab** /skab/ [n] ក្រមរ, សំណក

**scabies** /ˈskeɪbiːz/ [n] មេកម (ជំងឺ), រោគរមាស់, រោគស្បែក

**scabland** /ˈskabland/ [n] ដីដែលមានកំពកថ្មភ្នំភ្លើងលេចខាងលើ

**scalariform** /skəˈlarɪfɔːm/ [adj] រាងដូចជណ្ដើរ

**scald** / skɔːld/ [n] សូមមើលពាក្យ៖ spot

**scald** /skɔːld/ [v] រលាកទឹកក្ដៅ, ស្រុស

**scale** /skeɪl/ [n]

១. ស្រកា

២. មាត្រដ្ឋាន (ខ្នាតសម្រាប់សម្គាល់ទំហំ ឬប្រវែង)

- Beaufort scale /ˈbəʊfət skeɪl/ [n] មាត្រដ្ឋានបូផត, មាត្រដ្ឋានកម្លាំងខ្យល់
- Celsius scale /ˈsɛlsɪəs skeɪl/ [n] សូមមើលពាក្យ៖ centigrade
- fish scale /fɪʃ skeɪl/ [n] ស្រកាត្រី
- geological time scale /dʒiːəˈlɒdʒɪk(ə)l tʌɪm skeɪl/ [n] មាត្រដ្ឋានពេលវេលាតាមភូគព្ភសាស្ត្រ
- ovuliferous scale [n] ស្រកាអូវុល (ស្រកាដែលទ្រអូវុលនៅក្នុងកោននៃពួករុក្ខជាតិស្លឹកម្ជុល)
- Richter scale /ˈrɪktə skeɪl/ [n] មាត្រដ្ឋានរិចទ័រ
- small scale /smɔːl skeɪl/ [n] ទ្រង់ទ្រាយតូច
- weighing scale /weɪn skeɪl/ [n] ម៉ាស៊ីនថ្លឹង

**scale bar** /skeɪl bɑː/ [n] អង្កត់មាត្រដ្ឋាន

**scalp** /skalp/ [n] ស្បែកលលាដ៏ក្បាល

**scalpel** /ˈskalp(ə)l/ [n] កាំបិតវះកាត់

**Scandium** /ˈskandɪəm/ [n] ស្កង់ដ្យូម(និមិត្តសញ្ញាគីមីSc)

**thermal scanning** /ˈθəːm(ə)l skanɪŋ/ [n] ការធ្វើរូបភាពនិងផែនទីបង្ហាញពីតំបន់ក្ដៅ និងត្រជាក់

**scape** /skeɪp/ [n]

១. (ចំពោះរុក្ខជាតិ) ទម្របុប្ផា (ទងផ្កាគ្មានស្លឹក និងលូតចេញពីកញ្ចុំស្លឹក)

២. (ចំពោះសត្វល្អិត) គល់អង់តែន

***Scaphognathops bandanensis*** [sci.n] ត្រីប៉ាផាក់

***Scaphognathops stejnegeri*** [sci.n] ត្រីប្រកែង, ត្រីប៉ាកៀន

**scapula** /ˈskapjʊlə/ [n] (សទិសន័យ៖ shoulder blade) ឆ្អឹងស្លាបប្រចៀវ

**scar** /skɑː/ [n] (សទិសន័យ៖ cicatrix) សម្លាក, ស្នាម, មុខរបួសជា

**scarcity** /ˈskɛːsɪti/ [n] ភាពកម្រ, តនុភាព

**scarecrow** /ˈskɛːkrəʊ/ [n] (សទិសន័យ៖ jackstraw) ទីងមោងចាំចាប

**scarification** /skarɪfɪˈkeɪʃ(ə)n/ [n] ជំនោះ (សម្បកគ្រាប់), ការធ្វើប្រព្រឹត្តិកម្មគ្រាប់សម្បករឹង, ការធ្វើឱ្យមានស្នាមលើសម្បកគ្រាប់ (ការធ្វើឱ្យប្រេះដល់សម្បករឹងនៃគ្រាប់ ជាធម្មតាគឺប្រើមេកានិចធ្វើឱ្យសឹកមានស្នាម ឬធ្វើប្រព្រឹត្តកម្មគីមីមួយភ្លែតក្នុងទឹកអាស៊ីតខ្លាំង ដើម្បីបង្កើនលទ្ធភាពជ្រាបទឹក និងឧស្ម័នរបស់វា ឬដើម្បីកាត់បន្ថយភាពធន់នឹងមេកានិចរបស់វា)

**scarify** /ˈskarɪfʌɪ/ [v] ជ្រោយដី, បកសម្បក

**scarious** /ˈskɛːrɪəs/ [adj] (ចំពោះរុក្ខជាតិ) ដូចស្រកា (មានលក្ខណៈស្ងួតស្តើង ពិសេសស្ថិតនៅខាងចុងគែមពន្លក)

**scarp** /skɑːp/ [n] មុខចំណោត

- alluvial scarp /əˈl(j)uːvɪəl skɑːp/ [n] ចំណោតល្បាប់

**scavenger** /ˈskavɪn(d)ʒə/ [n] សត្វណឺត (ប្រភេទសត្វល្អិត ដែលស៊ីសារធាតុរលួយ (គំរង់) ជាអាហារ ឧ. ពពួក Collembola)

**scenario** /sɪˈnɑːrɪəʊ/ [n] សេណារីយ៉ូ (សេចក្តីអធិប្បាយដែលអាចទុកចិត្តបាន និងជាញឹកញាប់ជាទម្រង់ងាយអំពីថាតើអនាគតទៅជាបែបណា ដោយផ្អែកលើការសន្មត់សង្វាក់គ្នា និងមានសង្គតិភាពក្នុងអំពីកត្តានាំមុខ និងទំនាក់ទំនងសំខាន់ៗ)

**scent** /sɛnt/ [n] ក្លិន (សារធាតុអរូបមួយ ដែលអាចឱ្យយើងដឹងបានតាមឃានវិញ្ញាណ)

**schedule** /ˈʃɛdjuːl/ [n] កាលវិភាគ

**schematic** /skɪˈmatɪk/ [v] បំប្រួញ

**Schistosoma** /ˈʃɪstə(ʊ)ˌsəʊm/ [n] ស៊ីស្តូសូម

**schizocarp** /ˈʃʌɪzə(ʊ)kɑːp/ [n] ប្រភេទផ្លែប្រេះ

**schizoprenia** /ˌskɪtsə(ʊ)ˈfriːnɪə/ [n] ការវិកលសតិសម្បជញ្ញៈយ៉ាងខ្លាំង ដោយបាត់បង់នូវការទាក់ទងនឹងដំណើរជីវិតប្រចាំថ្ងៃ

***Schleichera trijuga*** [sci.n] ពង្រ

**sciatic** /sʌɪˈatɪk/ [adj] ស្យាទិច, នៃភ្លៅ ឬត្រគាក

**sciatica** /sʌɪˈatɪkə/ [n] ការឈឺនៅប៉ែកភ្លៅ ឬត្រគាក

science /ˈsʌɪəns/ [n] វិទ្យាសាស្ត្រ

- earth science /əːθ ˈsʌɪəns/ [n] វិទ្យាសាស្ត្រផែនដី
- soil science /sɔɪl ˈsʌɪəns/ [n] វិទ្យាសាស្ត្រផ្នែកដី
- veterinary science /ˈvɛt(ə)rɪn(ə)ri ˈsʌɪəns/ [n] ការសិក្សាពីជំងឺសត្វ
- science-based advance /ˈsʌɪəns beɪsd ədˈvɑːns/ [n] ការលម្អដោយការស្រាវជ្រាវបែបវិទ្យាសាស្ត្រ

**scientific name** /sʌɪənˈtɪfɪk neɪm/ [n] ឈ្មោះឡាតាំងរបស់សរីរាង្គដែលប្រើប្រាស់ក្នុងចំណាត់ថ្នាក់

**scientist** /ˈsʌɪəntɪst/ [n] អ្នកវិទ្យាសាស្ត្រ

- soil scientist /sɔɪl ˈsʌɪəntɪst/ [n] អ្នកឯកទេសដី, ធរណីវិទូ

**scintillation** /sɪntɪˈleɪʃ(ə)n/ [n] ការបញ្ចេញពន្លឺ (ការឱ្យពន្លឺនៅពេលដែលអាតូមត្រូវបានប៉ះដោយផង់នៃណ្វៃយ៉ូ ឬកាំរស្មីហ្គាម៉ា)

**scion** /ˈsʌɪən/ [n] ខ្នែងបំបៅ, មែកបំបៅ (ត្រួយ ឬពន្លកមែកដែលយកមកពីរុក្ខជាតិមួយ ហើយត្រូវបានយកទៅតភ្ជាប់នឹងខ្នែងបំបៅរបស់រុក្ខជាតិមួយទៀត នៅក្នុងការបំបៅ), មែកបំបៅខាងលើ

***Scirpus grossus*** [sci.n] កក់កន្ទេល

**scirrhous** /ˈskɪrəs/ [adj] ឡើងរឹង, ក្រោះ

**scissors** /ˈsɪzəz/ [n] កន្ត្រៃ

**sclera** /ˈsklɪərə/ [n] ស្ក្លេរ៉ូទិច

**sclerenchyma** /ˌsklɪəˈrɛŋkɪmə/ [n] ស្ក្លេរ៉ង់ស៊ីម (ជាជាលិការុក្ខជាតិមានមុខងារពង្រឹក ទ្រទ្រង់ និងការពារដែលភ្នាសគ្រោងឡើងក្រាស់ដោយលីញីន)

***Scleropages formosus*** [sci.n] សូមមើលពាក្យ៖ Asian bonytongue

**scolex** /ˈskəʊlɛks/ [n] (សទិសន័យ៖ Taenia cystecercus) ក្បាលតេញ៉ា

***Scomberomorus sinensis*** [sci.n] សូមមើលពាក្យ៖ Chinese seerfish

**scorching** /ˈskɔːtʃɪŋ/ [n] ការរោលភ្លើង (ការដាក់ឱ្យត្រូវសីតុណ្ហភាពយ៉ាងខ្ពស់មួយភ្លែត ឧ. រោលភ្លើង ឬដាក់ក្នុងឡដែលគេប្រើសម្រាប់ប្រលេះគ្រាប់ពីផ្លែ ឬកោនដែលត្រូវការកម្តៅខ្លាំង)

**scorpion** /ˈskɔːpɪən/ [n] ខ្ទួយ, ខ្យាដំរី

***Scotinophara* spp.** [sci.n] សូមមើលពាក្យ៖ black bugs

**scour** /ˈskaʊə/ [n] ជំងឺរាគសត្វចិញ្ចឹម (ឧ. គោ ក្របី ជ្រូក)

**scouring** /ˈskaʊərɪŋ/ [n] ការចិត (ដោយកម្លាំងទឹកឬខ្យល់)

**scratch** /skratʃ/ [v] របកស្បែក, រលាត់ស្បែក

**scree** /skriː/ [n] ជម្រាលនៃគំនរបែកបាក់នៃថ្ម

- bedded scree /ˈbɛdɪd skriː/ [n] សូមមើលពាក្យ៖ stratified debris slope
- consolidated scree /kənˈsɒlɪdeɪtid skriː/ [n] ប្រែសនៅលើជម្រាល, សម្ភារជម្រាលដែលផ្សាជាប់គ្នា (ក្រួស, ខ្សាច់ជាដើម)

**screen** /skriːn/ [n]
១. សូមមើលពាក្យ៖ sieve
២. អេក្រង់
- smoke screen /skriːn/ [n] របាំងផ្សែង
- window screen /skriːn/ [n] សំណាញ់បង្អួច

**screen** /skriːn/ [v] បាំង, ត្រួតពិនិត្យ

**screening** /ˈskriːnɪŋ/ [n] ការពិសោធន៍តាមដាន (ប្រភេទនៃពិសោធន៍មួយដែលធ្វើឡើងដើម្បីពិនិត្យទៅលើលក្ខណៈផ្សេងៗរបស់បច្ច័យ ឬពូជ), ការច្រោះ, ស្រាល់, ការពិនិត្យជ្រើសរើស (នៅក្នុងការវាយតម្លៃហេតុប៉ះពាល់បរិស្ថាន)

**scrofula** /ˈskrɒfjʊlə/ [n] រោគម្រេញ

**scrotum** /ˈskrəʊtəm/ [n] ស្បែកពងស្វាស

**scrub** /skrʌb/ [n] ព្រៃគុម្ពោត

**scruffy** /ˈskrʌfi/ [n] រោមបះ

**scurf** /skəːf/ [n] ស្បែកស្តើងងាប់, អង្គែក្បាល

**scurvy** /ˈskəːvi/ [n] ជំងឺកង្វះវីតាមីនសេ

**scutellum** /skjʊˈtɛləm/ [n] ស្កូតេលូម (កូទីលេដុងរបស់គ្រាប់ក្រាមីនេដែលមានតួនាទីពិសេសក្នុងការស្រូបសារធាតុចិញ្ចឹមពីអង់ដូស្ពែមនៅពេលគ្រាប់នោះចេញពន្លក)

**scuvy** /ˈskəːvi/ [n] ជំងឺរាក់ធ្មេញ

**scythe** /sʌɪð/ [n] កណ្តៀវ

**sea** /siː/ [n] សមុទ្រ

**sea horse** /siː hɔːs/ [n] សេះសមុទ្រ (ឈ្មោះវិទ្យាសាស្ត្រ *Hippocampus spp.*)

**Seaborgium** /siːˈbɔːgɪəm/ [n] ស៊ីបូក្យូម (និមិត្តសញ្ញាគីមី Sg)

**sealed** /siːld/ [adj] ដែលដាក់កូន(ឃ្មុំ), ដែលបានអ៊ុតឬគ្រប

**seam** /siːm/ [n] (ចំពោះដី) សូមមើលពាក្យ៖ vein

**season** /ˈsiːz(ə)n/ [n] រដូវ, រដូវកាល
- breeding season /ˈbriːdɪŋ ˈsiːz(ə)n/ [n] រដូវបង្កបង្កើតកូន, រដូវបន្តពូជ, រដូវបង្កាត់ពូជ
- dry season /drʌɪ ˈsiːz(ə)n/ [n] រដូវប្រាំង
- high-water season /hʌɪ ˈwɔːtə ˈsiːz(ə)n/ [n] រដូវទឹកឡើង
- low-water season /ləʊ ˈwɔːtə ˈsiːz(ə)n/ [n] រដូវទឹកស្រក
- rainy season /ˈreɪni ˈsiːz(ə)n/ [n] រដូវភ្លៀង, រដូវវស្សា
- wet season /wɛt ˈsiːz(ə)n/ [n] រដូវវស្សា

**seasonality** /siːz(ə)ˈnalɪti/ [n] រដូវកាលផ្លែ (រយៈពេលនៃបាតុភូតផលិតគ្រាប់ដែលកើតឡើងផ្សាភ្ជាប់យ៉ាងជិតស្និតទៅនឹងរដូវអាកាសធាតុច្បាស់លាស់នៅក្នុងឆ្នាំ ឧ. រដូវភ្លៀង រដូវប្រាំង រដូវក្តៅ រដូវរងា)

**seawater** /ˈsiːwɔːtə/ [n] ទឹកសមុទ្រ

**sebaceous** /sɪˈbeɪʃəs/ [adj] ដែលមានជាតិខ្លាញ់ ឬប្រេង, នៃក្រពេញសេបូម

**sebum** /ˈsiːbəm/ [n] សេបូម

**secateurs** /ˌsɛkəˈtəːz/ [n pl] កន្ត្រៃកាត់មែកឈើ

***Sechium edule*** [sci.n] សូមមើលពាក្យ៖ chayote

**secondary** /ˈsɛk(ə)nd(ə)ri/ [n] បន្ទាប់បន្សំ,មិនសូវសំខាន់

**secretin** /sɪˈkriːtɪn/ [n] អ័រម៉ូនក្រពះបញ្ចេញជាតិជូរ

**secretion** /sɪˈkriːʃ(ə)n/ [n] ការបញ្ចេញ

**section** /ˈsɛkʃ(ə)n/ [n] (សទិសន័យ៖ sagittal) មុខកាត់, ពំនុះឈរបណ្តោយ
- caesarean section /sɪˈzɛːrɪən ˈsɛkʃ(ə)n/ [n] ការបង្កើតកូនដោយវះ, ការវះកាត់យកកូន
- cross-section /krɒs ˈsɛkʃ(ə)n/ [n] មុខកាត់ទទឹង

**secund** /sɪˈkʌnd/ [adj] បែរទៅម្ខាង (អំពីទម្រង់រុក្ខជាតិ)

**sedate** /sɪˈdeɪt/ [n] នឹងធឹង, ស្ងប់ស្ងៀម, ងុយងោក

**sedation** /sɪˈdeɪʃ(ə)n/ [n] ការធ្វើឱ្យស្ងប់ស្ងៀម ឬនឹងធឹង

**sedative** /ˈsɛdətɪv/ [n] ថ្នាំបង្អន់ការចុកចាប់

**sedentary** /ˈsɛd(ə)nt(ə)ri/ [n] និសិន្ន

**sedge** /sɛdʒ/ [n] ពួកកក់

**sediment** /ˈsɛdɪm(ə)nt/ [n]
១. (ចំពោះដី) ល្បាប់ (អ្វីៗដែលនាំមកដោយទឹក)
២. កកររង, កម្ទេចកំណក, សារធាតុល្អិត (នៅក្នុងវត្ថុរាវ)
- bottom sediment /ˈbɒtəm ˈsɛdɪm(ə)nt/ [n] កម្ទេចកំណកបាត

- clastic sediment /ˈklastɪk ˈsɛdɪm(ə)nt/ [n] កំណដែលជាកម្ទេច
- continental sediment /kɒntɪˈnɛnt(ə)l ˈsɛdɪm(ə)nt/ [n] កម្ទេចកំណកទ្វីប
- deposition of sediment /ˌdɛpəˈzɪʃ(ə)n ɒv ˈsɛdɪm(ə)nt/ [n] ដីដុះ
- fluvial sediment /ˈfluːvɪəl ˈsɛdɪm(ə)nt/ [n] កម្ទេចកំណកល្បាប់
- marine sediment /məˈriːn ˈsɛdɪm(ə)nt/ [n] កម្ទេចកំណកសមុទ្រ

**sedimentation** /sɛdɪmɛnˈteɪʃ(ə)n/ [n] ភាពរងកករ, កំណកកម្ទេច

**sedimentology** /ˈsɛdɪm(ə)ntˈɒlədʒi/ [n] កម្ទេចកំណវិទ្យា

**seed coat** /siːd kəʊt/ [n] សម្បកគ្រាប់ (ភ្នាសរឹងមិនជ្រាបទឹក ដែលព័ទ្ធស្រោបការពារគ្រាប់)

**seed drill** /siːd drɪl/ [n] ម៉ាស៊ីនបុក និងដាក់គ្រាប់ពូជ

**seed registration board** /siːd rɛdʒɪˈstreɪʃ(ə)n bɔːd/ [n] ក្រុមអ្នកបច្ចេកទេសដែលសម្រេចលើឈ្មោះពូជរុក្ខជាតិ និងដាក់ឱ្យកសិករប្រើប្រាស់

**seed** /siːd/ [n] គ្រាប់ពូជ, ពូជ

- breeder seed /ˈbriːdə siːd/ [n] គ្រាប់ពូជសុទ្ធនៃជម្រើសវិទូ (គ្រាប់ពូជដែលត្រូវផលិតដោយរុក្ខជម្រើសវិទូ ហើយប្រើសម្រាប់ផលិតគ្រាប់សុទ្ធគ្រឹះ)
- certified seed /ˈsəːtɪfʌɪt siːd/ [n] គ្រាប់ពូជមានលិខិតស្នាម, គ្រាប់ពូជសុទ្ធអនុញ្ញាត (ប្រភេទគ្រាប់ពូជដែលទទួលបានពីគ្រាប់ពូជសុទ្ធគ្រឹះ ឬពូជសុទ្ធទទួលស្គាល់)
- certified tree seed /ˈsəːtɪfʌɪd triː siːd/ [n] ដើមពូជបានទទួលស្គាល់គុណភាព
- empty seed /ˈɛm(p)ti siːd/ [n] គ្រាប់ស្វិត, គ្រាប់ស្លៀត
- filled seed /fɪld siːd/ [n] គ្រាប់ពេញ, គ្រាប់មូល, គ្រាប់ល្អ (គ្រាប់មួយដែលប្រហោងក្នុងបំពេញដោយគ្រប់ប្រភេទជាលិកាសំខាន់ៗសម្រាប់ការដុះពន្លក។ គ្រាប់មូលមិនទៀងថាវាមានជីវិតនោះទេ។)
- foundation seed /faʊnˈdeɪʃ(ə)n siːd/ [n] គ្រាប់ពូជសុទ្ធគ្រឹះ (ប្រភេទគ្រាប់ពូជដែលត្រូវបានផលិតពីគ្រាប់ពូជសុទ្ធនៃរុក្ខជម្រើសវិទូ)
- good seed /gʊd siːd/ [n] គ្រាប់ពូជល្អ (ប្រភេទគ្រាប់ពូជដែលមានកម្រិតសុទ្ធភាពខ្ពស់ដែលផលិតចេញពីគ្រាប់ពូជសុទ្ធទទួលស្គាល់ ហើយត្រូវប្រើក្នុងផលិតកម្មពូជស្រូវ)
- hard seed /hɑːd siːd/ [n] គ្រាប់រឹង (ឧ. គ្រាប់នៃអម្បូរ Leguminosae ដែលសម្បកគ្រាប់របស់វាអាចការពារការជ្រាបទឹក ឬការពារមិនឱ្យខូចពីការប៉ះទង្គិចខ្លាំង)
- intermediate seed /ˌɪntəˈmiːdɪət siːd/ [n] ទាក់ទងទៅនឹងលទ្ធភាពស្តុកទុក គ្រាប់ពូជដែលគេអាចសម្ងួតដល់បន្ទុកសំណើមមួយ ដូចប្រភេទគ្រាប់រឹង ក៏ប៉ុន្តែងាយខូចគុណភាពនៅក្នុងសីតុណ្ហភាពទាបដែលគេតែងធ្វើចំពោះប្រភេទគ្រាប់រឹង។
- legume seed /ˈlɛgjuːm siːd/ [n] គ្រាប់របស់រុក្ខជាតិអំបូរ Leguminosae។ ជារឿយៗ គ្រាប់នេះរឹង និងមិនជ្រាបទឹកទេ។ សម្បកគ្រាប់ផ្សំឡើងពី៣ស្រទាប់ខុសគ្នាដែល ស្រទាប់ ២ខាងក្រៅៈ cuticle និង palisade ធ្វើមិនឱ្យទឹកជ្រាបទឹក និងការពារមិនឱ្យហួតទឹកចេញ។
- nucleus seed /ˈnjuːklɪəs siːd/ [n] គ្រាប់ពូជមេ (គ្រាប់ពូជដំបូងដែលយកពីគុម្ព ឬដើមផ្សេងៗនៃពូជ ដែលត្រូវបន្សុទ្ធ។ គ្រាប់ពូជនេះ បន្ទាប់មកត្រូវយកទៅដាំជាជួរដោយឡែកៗពីគ្នា ដើម្បីផលិតគ្រាប់ពូជសុទ្ធនៃជម្រើសវិទូ។)
- pathogen-free seed /ˈpaθədʒ(ə)n friː siːd/ [n] គ្រាប់ពូជដែលគ្មានជំងឺ
- pre-germinated seed /ˈpriː ˈdʒəːmɪneɪtɪd siːd/ [n] គ្រាប់ពូជបណ្តុះ (គ្រាប់ពូជដែលបានត្រាំទឹកអស់រយៈពេល ២៤ ម៉ោង ហើយស្រង់យកមកធ្វើការផ្អាប់ ២៤ ទៅ ៤៨ ម៉ោងរហូតដល់គ្រាប់ពូជដុះចេញជាពន្លក)
- pure seed /pjʊə siːd/ [n] គ្រាប់សុទ្ធ (ជាផ្នែកនៃកញ្ចប់គ្រាប់មួយដែលមានគ្រាប់នៃប្រភេទពូជដែលគេកំណត់។ យោងតាមច្បាប់ ISTA ទៅ វាមានមិនត្រឹមតែគ្រាប់ទុំ គ្រាប់បែកខូច ប៉ុណ្ណោះទេ តែថែមទាំងមានគ្រាប់តូចស្វិត មិនទុំ និងគ្រាប់ដុះទៀតផង គេអាចសំគាល់បានថាជាគ្រាប់នៃពូជនេះ ហើយនិងកំទេចកំទីគ្រាប់ បណ្តាលមកពីការបែកដែលធំជាងពាក់កណ្តាលនៃគ្រាប់ល្អ។)
- registered seed /ˈrɛdʒɪstərd siːd/ [n] គ្រាប់ពូជសុទ្ធទទួលស្គាល់ (ប្រភេទគ្រាប់ពូជសុទ្ធដែលទទួលបានពីការដាំគ្រាប់ពូជសុទ្ធគ្រឹះ)

- seed handling /siːd ˈhand(ə)lɪŋ/ [n] ការប្រមូលទុកដាក់គ្រាប់ពូជ (វិធីសាស្ត្រប្រតិបត្តិនៃលទ្ធកម្មគ្រាប់ពូជតាំងពីការប្រមូលរហូតដល់សាបគ្រាប់។ ជួនកាល គេប្រើមានន័យដូច លទ្ធកម្មគ្រាប់ពូជដែរ (seed procurement) ប៉ុន្តែជាទូទៅ វាគ្របដណ្តប់លើពេលវេលាវែងជាង ឧ. បច្ចេកទេសសាប។)
- selected tree seed /sɪˈlɛktɪd triː siːd/ [n] គ្រាប់ពូជពីដើមមេជម្រើស (គ្រាប់ពូជដែលបានប្រមូលពីបណ្តាដើមឈើដែលគេបានធ្វើការជ្រើសរើសយ៉ាងហ្មត់ចត់យកលក្ខណៈ ឬគុណសម្បត្តិផេណូទីបដែលអាចមានជោគជ័យ ប៉ុន្តែគេមិនទាន់បានដាំសាកល្បងកូននៅឡើយ។ គេត្រូវបញ្ជាក់ ប្រភព និងរយៈកម្ពស់។)
- sound seed /saʊnd siːd/ [n] គ្រាប់នៅរស់ (គ្រាប់នៅរស់ មានសុខភាពល្អដែលមិនមានខូចខាតអ្វីសំខាន់)
- source identified seed /sɔːs ʌɪˈdɛntɪfʌɪd siːd/ [n] (សទិសន័យ៖ source identified tree seed) គ្រាប់ពូជដែលមានអត្តសញ្ញាណប្រភព (គ្រាប់ដែលប្រមូលបានពីព្រៃពូជធម្មជាតិ ដែលគេស្គាល់ដើមកំណើតភូមិសាស្ត្រ (ប្រភពនិងរយៈកម្ពស់) និងបញ្ជាក់ច្បាស់ ឬពីចម្ការពូជ ពីចម្ការឈើដែលស្គាល់ដើមកំណើតរបស់វា ដែលបានបញ្ជាក់ច្បាស់ដោយភ្នាក់ងារផ្តល់វិញ្ញាបនបត្រគ្រាប់ពូជ)
- viable seed /ˈvʌɪəb(ə)l siːd/ [n] គ្រាប់មានជីវិត, គ្រាប់អាចដុះបាន (គ្រាប់មួយដែលអាចដុះពន្លកបាននៅក្រោមលក្ខខណ្ឌអំណោយផល ក្នុងករណីដែលភាពសម្ងំរបស់ត្រូវបានបំបែក)

**seed cleaning** /siːd kliːnɪŋ/ [n] (សទិសន័យ៖ seed processing) ការសម្អាតគ្រាប់(ជាវិធីសាស្ត្រប្រមូលទុកដាក់គ្រាប់ពូជ តាំងពីការបេះប្រមូលរហូតដល់ស្តុកទុក ជាធម្មតាពាក្យនេះ ប្រើសំដៅទៅលើ ការងារប្រឡេះគ្រាប់ សំអាតគ្រាប់ និងសម្ងួតគ្រាប់)

**seed lot** /siːd lɒt/ [n] កញ្ចប់គ្រាប់ (បរិមាណមួយនៃគ្រាប់ពូជនៃប្រភេទពូជតែមួយ មានប្រភពកំណើត ថ្ងៃខែឆ្នាំប្រមូល និងប្រវត្តិរៀបចំទុកដាក់តែមួយ និងបានឱ្យអត្តសញ្ញាណដាក់លេខតែមួយ)

**seed procurement** /siːd prəˈkjʊəmənt/ [n] លទ្ធកម្មគ្រាប់ពូជ

**seed transmitted** /siːd tranzˈmɪtɪd/ [adj] ចម្លងតាមគ្រាប់ (ជំងឺដែលមានប្រភពពីគ្រាប់ដោយរោគសញ្ញានៃជំងឺកើតលេចឡើងនៅលើជាលិកាដើមនៃរុក្ខជាតិនោះដោយផ្ទាល់ មិនមែនបង្ក ឬចម្លងដោយសារខ្យល់ ដី ឬសត្វល្អិតឡើយ)

**seed wings** /siːd wɪŋz/ [n] ស្លាបគ្រាប់ (សរីរាង្គបន្ថែមស្ងួតនៅលើផ្លែ និងគ្រាប់ដែលសម្រួលដល់ការពង្រាយគ្រាប់តាមខ្យល់ (anemochory)។ ស្លាបអាចមានកំណើតចេញពី ១. សម្បកគ្រាប់ ឧ. សណ្តានគ្រាប់បែក (Khaya) និងសណ្តានកណ្តឹងដំរី (Swietenia) ២. រចនាសម្ពន្ធក្លាយរបស់ផ្លែ ឧ. សណ្តានធ្នង់ (Pterocarpus) ៣. រចនាសម្ពន្ធក្លាយមិនជ្រុះរបស់ផ្កា ឧ. សណ្តានឈើទាល (Dipterocarpus)។ ស្លាបអាចមានលក្ខណៈស្តើង និងដូចក្រដាសដូចជាសណ្តានស្រល់ (Pinus) និងសណ្តានស្វាវ (Casuarina) ឬដូចជាឈើសណ្តាន Acer និងសណ្តានដូនថែម (Tarrietia)។ ជាធម្មតាស្លាបត្រូវបានគេកាត់ចេញនៅពេលសម្អាតគ្រាប់ ដើម្បីកាត់បន្ថយមាឌ និងសម្រួលក្នុងការរៀបចំទុកដាក់។)

**seed year** /siːd jɪə/ [n] សូមមើលពាក្យ៖ mast year

**seedbed** /ˈsiːdbɛd/ [n] ថ្នាលសំណាប, ថ្នាលបណ្តុះ

**seed-borne** /siːd bɔːn/ [adj] គ្រាប់ពូជចម្លង (ប្រភពជំងឺ ឬការផ្ទេរជំងឺនៃពពួកបង្ករោគ ឬពួកមីក្រូសារពាង្គកាយ ឬសត្វចង្រៃក្នុង ឬលើ ឬលាយឡំជាមួយគ្រាប់ពូជ (ប៉ុន្តែវាមិនចម្លងតាមរយៈគ្រាប់ពូជទេ))

**seeding** /siːdɪŋ/ [n] ការដាំ, ការសាប, ការបណ្តុះ

- direct seeding /dɪˈrɛkt siːdɪŋ/ [n] ការព្រោះ (វិធីសាស្ត្រដាំស្រូវដោយបាចគ្រាប់ដាំតែម្តង), ការសាប ឬបាចគ្រាប់ពូជដោយដៃ ឬម៉ាស៊ីន, ពង្រាយគ្រាប់ពូជ

**seedling** /ˈsiːdlɪŋ/ [n] កូនឈើ (បណ្តុះពីគ្រាប់), សំណាប (រុក្ខជាតិមួយដែលបណ្តុះពីគ្រាប់ ដែលខុសពីរុក្ខជាតិបណ្តុះពីសរីរាង្គលូតលាស់។ កូនឈើដែលបណ្តុះពីសរីរាង្គលូតលាស់ ហៅថា កំណាត់មែក(cuttings) កូនស្តុំ(stumps) ឬកូនឈើតូច(plantlets) អាស្រ័យទៅតាម វិធីបណ្តុះ។)

- abnormal seedling /əbˈnɔːm(ə)l ˈsiːdlɪŋ/ [n] កូនឈើអន់, កូនឈើខ្សោយ, កូនឈើមិនធម្មតា
- transplant rice seedling /transˈplɑːnt rʌɪs ˈsiːdlɪŋ/ [n] សំណាប

**seep** /siːp/ [v] ជ្រាបចូល, ជ្រាបចេញ

**seepage** /ˈsiːpɪdʒ/ [n] ការជ្រាបចូល, ការជ្រាបចេញ, ជម្រាបទេរ (ការហូរយឺតៗនៃទឹកក្នុងដី)។ តាមលក្ខណៈសាមញ្ញ វាជាការជ្រាបតាមភ្លឺដែលទាក់ទងភាពហូរផ្នែកខាងក្នុងនៃទឹកពីដីស្រែមួយទៅដីស្រែមួយទៀត ឬក៏បញ្ច្រាសមកវិញ។ នេះជាការជ្រាបទឹកតាមខ្សែដេក។)

**segment** /ˈsɛgm(ə)nt/ [n] (សូមមើលពាក្យ៖ proglottid) ផ្នែកតូច, ភាគ, កំណាត់

**segregation** /ˌsɛgrɪˈgeɪʃ(ə)n/ [n] ការបំបែកបំបាក់, វិយោគកម្ម (ដំណើរការដែលក្នុងនោះការបំបែកលក្ខណៈនៅតែមានជាបន្ត (ឧ. ចំពោះឯកត្តៈណាដែលលក្ខណៈណាមួយរបស់វា ជាអេតេរ៉ូស៊ីកូត (Aa) នោះមានលក្ខណៈនេះ វានឹងបែកទៅជា AA, Aa និងaa នៅជំនាន់ក្រោយទៀត))

- transgressive segregation /tranzˈgrɛsɪv ˌsɛgrɪˈgeɪʃ(ə)n/ [n] ការសម្តែងលក្ខណៈនៅជំនាន់ទី២ វិនិយោគកម្មនៅជំនាន់ទី២ (ការលេចឡើងលក្ខណៈនៅជំនាន់ F២ ឬការធ្វើវិនិយោគកម្មជំនាន់ផ្សេងៗរបស់ឯកត្តៈដែលការសម្តែងឡើងនូវលក្ខណៈមួយចំនួន (ជាធម្មតាវាលាក់បាំង ឬមិនសម្តែងចេញមក) គឺមានច្រើនខ្លាំងជាងនៅក្នុងជំនាន់មេប របស់វា ឬជំនាន់F១)

**seine** /seɪn/ [n] អួនអូសត្រី

**seismicity** /sʌɪzˈmɪsɪti/ [n] ភាពរញ្ជួយដី, សកម្មភាពរញ្ជួយដី

**seismograph** /ˈsʌɪzmə(ʊ)grɑːf/ [n] រង្វាស់រញ្ជួយដី

**seismology** /sʌɪzˈmɒlədʒi/ [n] រញ្ជួយដីវិទ្យា

**seizure** /ˈsiːʒə/ [n] សូមមើលពាក្យ៖ convulsion

- grandmal seizure /grɒˈmal ˈsiːʒə/ [n] ការប្រកាច់ខ្លាំងនៃជំងឺឆ្កួតជ្រូក
- petit mal seizure /ˈpɛti mal ˈsiːʒə/ [n] ការប្រកាច់តែមួយភ្លែត

***Selaroides leptolepis*** [sci.n] សូមមើលពាក្យ៖ yellowstripe scad

**selection** /sɪˈlɛkʃ(ə)n/ [n] ជម្រើស, ការជ្រើសរើស, ជម្រើសកម្ម (ដំណើរការដែលក្នុងនោះឯកត្តៈត្រូវបានជ្រើសរើសដោយយោងទៅលើលក្ខណៈកំណត់)

- advanced-generation selection /adˈvɑːnst dʒɛnəˈreɪʃ(ə)n sɪˈlɛkʃ(ə)n/ [n] ការជ្រើសរើសជំនាន់ជឿនលឿន (ការជ្រើសរើសដើមឈើមួយ ដោយធ្វើការពិសោធន៍ពន្ធុក្នុងការបង្កាត់ឆ្លាស់គ្នានៃមេបាជំនាន់មុន។ មានវិធី មួយចំនួន ដូចជា ជម្រើសគ្រួសារ និងជម្រើសនៅក្នុងគ្រួសារ ជាធម្មតាត្រូវបានគេប្រើដើម្បីជ្រើសរើសជម្រើសជំនាន់ដែលមានលក្ខណៈរីកចំរើន។)
- aposematic selection /ˌapə(ʊ)sɪˈmatɪk sɪˈlɛkʃ(ə)n/ [n] ជម្រើសមិនពេញចិត្ត (ជាប្រភេទនៃជម្រើសធ្វើឡើងដោយសេរី ដែលជាការធ្វើត្រាប់តាមប្រភេទខុសៗគ្នា និងដែលជាសកម្មភាពមិនពេញចិត្ត)
- artificial selection /ɑːtɪˈfɪʃ(ə)l sɪˈlɛkʃ(ə)n/ [n] ជម្រើសដោយមនុស្ស, ជម្រើសនិម្មិត
- balancing selection /ˈbal(ə)nsɪŋ sɪˈlɛkʃ(ə)n/ [n] ជម្រើសតុល្យភាព
- bulk selection /bʌlk sɪˈlɛkʃ(ə)n/ [n] សមូហជម្រើសវិធី (ការដាំដុះនូវរុក្ខប្រជាកនៃរុក្ខជាតិស្វ័យចរលម្អងដែលមានពន្ធុខុសៗគ្នាក្នុងកូនស្រែជាមួយគ្នាដោយគ្មានជ្រើសរើស)
- dysgenic selection /dɪsˈdʒɛnɪk sɪˈlɛkʃ(ə)n/ [n] ការជ្រើសរើសក្នុងចំណោមដើមអន់ (ការជ្រើសរើសមួយដោយមិនបានព្រៀងទុកនិងមិនចង់បានកើតឡើងក្នុងករណីដែលដើមឈើល្អក្នុងព្រៃនេះ ត្រូវបានកាប់អស់បន្សល់តែដើមអន់ផលិតគ្រាប់ពូជសម្រាប់ជំនាន់ក្រោយ។ បណ្តាលឱ្យគុណភាពសេនេទិច កាន់តែអន់ទៅៗសម្រាប់ជំនាន់ក្រោយ។ ពាក្យនេះ ប្រើជាពិសេសមានន័យសំដៅទៅលើការបំផ្លាញរបស់មនុស្សដូចជាការបាត់បង់បណ្តាលមកពីការកាប់ដកចេញដើមឈើល្អៗចេញពីព្រៃ។ ពាក្យផ្ទុយ Eugenic (សុជាតិវិទ្យា)។)
- family selection /ˈfamɪli sɪˈlɛkʃ(ə)n/ [n] ជម្រើសអម្បូរ
- index selection /ˈɪndɛks sɪˈlɛkʃ(ə)n/ [n] ការជ្រើសរើសសន្ទស្សន៍
- indirect selection /ɪndɪˈrɛkt sɪˈlɛkʃ(ə)n/ [n] ការជ្រើសរើសដោយប្រយោល (ការជ្រើសរើសបណ្តាឯកត្តៈឬក្រុមពូជផ្អែកលើលក្ខណៈមួយ (ជាធម្មតា មិនមានសារប្រយោជន៍សេដ្ឋកិច្ចទេ ក្នុងនោះទេ)ដែលគេជឿថាអាចមានលក្ខណៈមួយដែលគេចង់បានមានសារប្រយោជន៍សេដ្ឋកិច្ចជាជាងផ្អែក លើលក្ខណៈដែលចង់បាននោះ។)
- individual selection /ɪndɪˈvɪdʒʊ(ə)l sɪˈlɛkʃ(ə)n/ [n] ការជ្រើសរើសឯកត្តៈ (គេជ្រើសរើសរុក្ខជាតិមួយចេញពីអំបូរ ឬក្រុមពូជមួយផ្អែកទៅលើលក្ខណៈរូបល្អរបស់វាធ្វើជាមេបា។ ជួនកាលគេ ហៅថា ការជ្រើសរើសផេណូទីប។)

- juvenile selection /ˈdʒuːvənʌɪl sɪˈlɛkʃ(ə)n/ [n] ការជ្រើសរើសយុវភាព, ការជ្រើសរើសភាពនៅខ្ចី (ការជ្រើសរើសពីព្រៃពូជមិនទាន់ពេញវ័យដើម្បីកាត់បន្ថយចន្លោះពេលរបស់ជំនាន់។ ការជ្រើសរើសយុវភាពនេះ គេអាចកំណត់បាន បើសិនមានទំនាក់ទំនងយុវភាព-ពេញវ័យខ្ពស់មួយ។)
- mass selection /mas sɪˈlɛkʃ(ə)n/ [n] ការជ្រើសរើសពូជទូទៅ, ជម្រើសជាក្រុម (ជម្រើសវិធីដែលគ្រប់ឯកត្តៈជ្រើសរើស ត្រូវយកទៅដាំដោយលាយគ្រាប់បញ្ចូលគ្នា)
- natural selection /ˈnatʃ(ə)r(ə)l sɪˈlɛkʃ(ə)n/ [n] ជម្រើសដោយធម្មជាតិ
- pure line selection /pjʊə lʌɪn sɪˈlɛkʃ(ə)n/ [n] ជម្រើសឯកត្តៈ
- recurrent selection /rɪˈkʌr(ə)nt sɪˈlɛkʃ(ə)n/ [n] ការជ្រើសរើសដួនៗគ្នា (ការជ្រើសរើសឯកត្តៈ ឬអំបូរ ហើយធ្វើការបង្កាត់ពូកវាទៅវិញទៅមក ឬអនុញ្ញាតឱ្យពូកវាលាយលម្អងទៅវិញទៅមក ដើម្បីផលិតជំនាន់ក្រោយ ឧ. តំបន់ផលិតគ្រាប់ពូជ ឬចម្ការផលិតកូនផ្សាំ។ ជំនាន់ថ្មីនេះជាទូទៅ គេប្រើធ្វើជាក្រុមពូជសម្រាប់បង្កាត់ ក្នុងនោះដើម្បីចាប់ផ្តើមធ្វើខួបសាឡើងវិញនៃការជម្រើសពូជ និងការបង្កាត់។)
- tandem selection /ˈtandəm sɪˈlɛkʃ(ə)n/ [n] ការជ្រើសរើសជាបន្តបន្ទាប់ (ការបង្កាត់ និងការជ្រើសរើសលក្ខណៈមួយនៅពេលមួយរហូតដល់កម្រិតដែលគេចង់បាននៃការបង្កើនគុណភាព (សុវឌ្ឍិកម្ម) ឬសម្រេចបានលក្ខណៈនោះ។ គេធ្វើការជ្រើសរើសបែបនេះ ដូចជានៅក្នុងការបង្កាត់ចង់បានលក្ខណៈធន់នឹងជំងឺ និងភាពធន់នឹងភាពត្រជាក់ តែគេកម្រប្រើនៅក្នុងវិស័យព្រៃឈើណាស់ ដោយសារតែរយៈពេលយូរពេកក្នុងមួយជំនាន់ៗ។)

**selection criteria** /sɪˈlɛkʃ(ə)n krʌɪˈtɪərɪə/ [n pl] សូមមើលពាក្យ៖ selection criterion

**selective** /sɪˈlɛktɪv/ [adj] ដែលរើស, ដែលសម្រាំង

**Selenium** /sɪˈliːnɪəm/ [n] សេលេញ៉ូម (និមិត្តសញ្ញាគីមី Se)

**self-** /sɛlf/ [prefix] ខ្លួនឯង

- self-clarification /sɛlf ˌklarɪfɪˈkeɪʃ(ə)n/ [n] ស្វ័យសម្អាត, សម្អាតដោយខ្លួនឯង
- self-limiting /sɛlf ˈlɪmɪtɪŋ/ [n] ស្វ័យកម្រិត
- self-reliance /sɛlf rɪˈlʌɪəns/ [n] ភាពម្ចាស់ការ

**selfing** /sɛlfɪŋ/ [n] ការលាយលម្អងលើខ្លួនឯង, ស្វ័យបង្កកំណើត, ស្វ័យបន្តពូជ (ប្រភេទរុក្ខជាតិស្វ័យចរលម្អង)

**semen** /ˈsiːmən/ [n] (សទិសន័យ៖ sperm) ទឹកកាម

**semi-** /ˈsɛmi/ [prefix] (សទិសន័យ៖ half) បុព្វបទមានន័យថា ពាក់កណ្តាល

- semi-permeable /sɛmɪˈpəːmɪəb(ə)l/ [adj] អាចជ្រាបបានម៉ូលេគុលតូចៗ (អាចជ្រាបបានតែម៉ូលេគុលតូចៗប៉ុណ្ណោះ)

**semilooper** /ˌsɛmɪˈluːpə/ [n] (សទិសន័យ៖ semi-looper caterpillar) ដង្កូវបាក់ខ្នង

**seminal** /ˈsɛmɪn(ə)l/ [adj] នៃទឹកកាម, តាមទឹកកាម

**senescence** /sɪˈnɛs(ə)ns/ [n] ការឡើងចាស់, ជរាភាព

**senile** /ˈsiːnʌɪl/ [n] ចាស់វង្វេងភាន់ភាំង

**sensation** /sɛnˈseɪʃ(ə)n/ [n] សូមមើលពាក្យ៖ sense

**sense** /sɛns/ [n] (សទិសន័យ៖ sensation) វិញ្ញាណ

**sensitive** /ˈsɛnsɪtɪv/ [adj] រួស (ងាយទទួលរងនូវជំងឺ ឬខូច)

**sensitivity** /sɛnsɪˈtɪvɪti/ [n] ភាពងាយខូចខាត

- sensitivity analysis /sɛnsɪˈtɪvɪti əˈnalɪsɪs/ [n] វិភាគនៃវេយិតភាព, ការវិភាពផលប៉ះពាល់នៃការប្រែប្រួល
- culture and sensitivity (C&S) /ˈkʌltʃə ənd sɛnsɪˈtɪvɪti/ [n] ការបណ្តុះមេរោគពីខ្លួន ដើម្បីរកមុខជំងឺ ឬរកថ្នាំការពារ

**sepal** /ˈsɛp(ə)l/ [n] ត្របកផ្កា

**sepaloid** /ˈsɛp(ə)lɔːd/ [adj] ដូចត្របកផ្កា (អំពីទម្រង់របស់រុក្ខជាតិ)

**sepsis** /ˈsɛpsɪs/ [n]

១. (សទិសន័យ៖ septicemia) បាក់តេរីនៅក្នុងឈាម ដែលតែងតែបង្កជំងឺធ្ងន់ធ្ងរ

២. ការកើតមានខ្ទុះ និងមេរោគផ្សេងទៀត

**septic** /ˈsɛptɪk/ [adj] សិបទិច, កខ្វក់, មិនស្អាត, ក្លាយ, មានមេរោគ

**septicemia** /ˌsɛptɪˈsiːmɪə/ [n] (សូមមើលពាក្យ៖ sepsis) រោគពុលឈាម

**septum** /ˈsɛptəm/ [n] សន្ទះខណ្ឌ, សន្ទះថ្នាំង (ស្រទាប់មួយនៅក្នុងថ្នាំង ដែលខណ្ឌចែកចន្លោះថ្នាំងចេញពីគ្នា)

- nodal septum /ˈnəʊd(ə)l ˈsɛptəm/ [n] ផ្នែករឹងនៃថ្នាំង

**sequence** /ˈsiːkw(ə)ns/ [n] តំណលំដាប់

- amino-acid sequence /əˈmiːnəʊ ˈasɪd ˈsiːkw(ə)ns/ [n] តំណលំដាប់អាស៊ីតអាមីនេ
- canonical sequence /kəˈnɒnɪk(ə)l ˈsiːkw(ə)ns/ [n] លំដាប់តាមលំនាំ
- hydrogenic sequence /ˈhʌɪdrəʊʒɛnɪk ˈsiːkw(ə)ns/ [n] ដំណើរតគ្នានៃទឹក, ឈុតបន្តបន្ទាប់គ្នានៃទឹក
- lithologenic sequence /lɪˈθɒˈdʒiːnɪk ˈsiːkw(ə)ns/ [n] ដំណើរតគ្នានៃសិលាវិទ្យា, និម្មិតកម្មសិលា
- slope sequence /sləʊp ˈsiːkw(ə)ns/ [n] ដំណើរតគ្នានៅជម្រាល, ឈុតបន្តបន្ទាប់គ្នានៅជម្រាល

**sequestration** /ˌsiːkwəˈstreɪʃ(ə)n/ [n] ការស្រូបយក, អំណូសបង្ការវិសុណ្ឌាបនកម្មការបង្ខំទុក

- carbon sequestration /ˈkɑːb(ə)n ˌsiːkwəˈstreɪʃ(ə)n/ [n] ការស្រូបយកកាបូន (ការបញ្ចេញ ឬស្តុកទុកាបូនពីបរិយាកាស នៅក្នុងអន្លង់កាបូន ឧទាហរណ៍ មហាសមុទ្រ ព្រៃឈើ ឬដី តាមរយៈរូបសាស្ត្រ ឬជីវសាស្ត្រ។ ឧ. ការធ្វើរស្មីសំយោគ។)

**sera** /ˈsɪərə/ [n pl] សេរ៉ូម

**serial** /ˈsɪərɪəl/ [n] សូមមើលពាក្យ៖ series

**series** /ˈsɪəriːz/ [n] (សទិសន័យ៖ serial) ស៊េរី, ផ្នែក

**sero-** /ˈsɪərəʊ/ [prefix] បុព្វបទមានន័យថា ទាក់ទងទៅនឹងសេរ៉ូម

**serofibrinous** /ˈsɪərəʊˈfʌɪbrɪnəs/ [n] សេរ៉ូមលាយដោយសរសៃឈាម

**serology** /sɪəˈrɒlədʒi/ [n] រោគសញ្ញាវិទ្យា (វិទ្យាសាស្ត្រសិក្សាពីរោគសញ្ញា)

**serotinous** [adj] ដែលចេញផ្កា-ផ្លែយឺត (ការយឺតយ៉ាវ ជាពិសេស ប្រើសំដៅលើប្រភេទរុក្ខជាតិ ឬឯកត្តៈណាដែលចេញផ្កា ឬផ្លែយឺតក្នុងរដូវ និងប្រើសំដៅលើផ្លែ ឬកោនដែលនៅរក្សាលើដើមមិនបើកចំហអស់ពេលមួយឆ្នាំ ឬច្រើនឆ្នាំ ឧ. Pinus contoria។ ប្រភេទផ្លែត្រូវការកម្តៅ ជាធម្មតា ត្រូវការសីតុណ្ហភាពខ្ពស់សម្រាប់ប្រេះ/បើក ដើម្បីជម្រុះគ្រាប់។)

**serrate** /ˈsɛreɪt/ [adj] ទម្រង់គែមស្លឹកធ្មេញរណារល្អិត

**serum** /ˈsɪərəm/ [n] សេរ៉ូម

- blood serum /blʌd ˈsɪərəm/ [n] សេរ៉ូមឈាម

**sesame** /ˈsɛsəmi/ [n] ល្ង (ឈ្មោះវិទ្យាសាស្ត្រ *Sesamum indicum*)

**sesamoid** /ˈsɛsəmɔɪd/ [n] ឆ្អឹងសេសាម៉ូអ៊ីត (រាងគ្រាប់ល្ង)

***Sesamum indicum*** [sci.n] សូមមើលពាក្យ៖ sesame

**sesbania** [n] ស្នោ (ឈ្មោះវិទ្យាសាស្ត្រ *Sesbania drummondii*)

***Sesbania drummondii*** [sci.n] សូមមើលពាក្យ៖ sesbania

***Sesbania grandiflora*** [sci.n] សូមមើលពាក្យ៖ hummingbird tree

**sessile joyweed** /ˈsɛsʌɪl dʒɔɪwiːd/ [n] ស្មៅជើងបង្កង (ឈ្មោះវិទ្យាសាស្ត្រ *Alternanthera sessilis*)

***Setipinna melanochir*** [sci.n] សូមមើលពាក្យ៖ dusky hairfin anchovy

**seton** /ˈsiːt(ə)n/ [n] សូមមើលពាក្យ៖ drain

**setting** /ˈsɛtɪŋ/ [n] ការធ្វើឱ្យហាប់ ឬណែន

**settlement** /ˈsɛt(ə)lm(ə)nt/ [n] ការតាំងលំនៅដ្ឋាន

**severe** /sɪˈvɪə/ [adj] ខ្លាំង, ធ្ងន់ធ្ងរ (ចំពោះជំងឺ)

**severity** /sɪˈvɛrɪti/ [n] ទម្ងន់ភាព (ទំហំ ឬវិសាលភាពនៃការខូចខាត)

- disease severity /dɪˈziːz sɪˈvɛrɪti/ [n] ទម្ងន់ភាពនៃជំងឺ (ទំហំ ឬកម្រិតជំងឺដែលកើតមានលើរុក្ខជាតិណាមួយ ជាទូទៅគិតជាភាគរយនៃផ្ទៃសរុប)

**sewage** /ˈsuːɪdʒ/ [n] ទឹកលូស្អុយ, ទឹកកខ្វក់, ទឹកសម្អុយ

- crude sewage /kruːd ˈsuːɪdʒ/ [n] (សទិសន័យ៖ raw sewage) ទឹកលូសម្អុយដើម
- domestic sewage /dəˈmɛstɪk ˈsuːɪdʒ/ [n] សូមមើលពាក្យ៖ household sewage
- household sewage /ˈhaʊshəʊld ˈsuːɪdʒ/ [n] (សទិសន័យ៖ domestic sewage, residential sewage) ទឹកលូសម្អុយពីគេហដ្ឋាន
- industrial sewage /ɪnˈdʌstrɪəl ˈsuːɪdʒ/ [n] ទឹកលូសម្អុយពីឧស្សាហកម្ម
- raw sewage /rɔː ˈsuːɪdʒ/ [n] សូមមើលពាក្យ៖ crude sewage
- residential sewage /rɛzɪˈdɛnʃ(ə)l ˈsuːɪdʒ/ [n] សូមមើលពាក្យ៖ household sewage
- settled sewage /ˈsɛt(ə)ld ˈsuːɪdʒ/ [n] ទឹកលូសម្អុយរង

- treated sewage /triːtɪd ˈsuːɪdʒ/ [n] ទឹកលូសម្អុយធ្វើប្រតិកម្មហើយ
- untreated sewage /ʌnˈtriːtɪd ˈsuːɪdʒ/ [n] ទឹកលូសម្អុយពុំទាន់ធ្វើប្រតិកម្មហើយ

**sewer** /ˈsuːə/ [n] លូទឹកសម្អុយ

**sewerage** /ˈsuːərɪdʒ/ [n] បណ្ដាញលូទឹកសម្អុយ, ទឹកលូសម្អុយ

**sex** /sɛks/ [n] ភេទ

**shaddock** /ˈʃadək/ [n] សូមមើលពាក្យ៖ grapefruit

**shade demanding** /ʃeɪd dɪˈmɑːndɪŋ/ [adj] ត្រូវការម្លប់

**shading** /ˈʃeɪdɪŋ/ [n] ម្លប់

**shake** /ʃeɪk/ [v] (សូមមើលពាក្យ៖ shiver, tremble) ញ័រ, រញ្ជួយ

**shale** /ʃeɪl/ [n]

១. (សទិសន័យ៖ clay shale, mudstone) ថ្មភាជន៍, ថ្មស្រទាប់

២. ឆ្នួនឥដ្ឋ

- alum shale /ˈaləm ʃeɪl/ [n] ឆ្នួនដែមានវត្ថុធាតុសាច់ជូរ
- clay shale /kleɪ ʃeɪl/ [n] សូមមើលពាក្យ៖ shale

**shallot** /ʃəˈlɒt/ [n] ខ្ទឹមក្រហម (ឈ្មោះវិទ្យាសាស្ត្រ *Allium cepa* var. *aggregatum*)

**shallow** /ˈʃaləʊ/ [adj] សូមមើលពាក្យ៖ superficial

**shaly** /ˈʃeɪli/ [adj] ដែលកើតពីកម្ទេចថ្មឆ្នួន

**shank** /ʃaŋk/ [n] សូមមើលពាក្យ៖ tibia

**share-cropping** /ʃɛː krɒppɪŋ/ [n] ធ្វើស្រែប្រវាស់គ្នា

**shark** /ʃɑːk/ [n] ពពួកត្រីឆ្លាម

- bull shark /bʊl ʃɑːk/ [n] ត្រីឆ្លាម (ឈ្មោះវិទ្យាសាស្ត្រ *Carcharhinus leucas*)
- milk shark /mɪlkʃɑːk/ [n] ត្រីឆ្លាម (ឈ្មោះវិទ្យាសាស្ត្រ *Rhizoprionodon acutus*)
- whale shark /weɪl ʃɑːk/ [n] ត្រីបាឡាណន់គីង្គក់ (ឈ្មោះវិទ្យាសាស្ត្រ *Rhincodon typus*)

**sharp** /ʃɑːp/ [adj] មុត, ស្រួច

**shattering** /ˈʃat(ə)rɪŋ/ [n] ការជ្រុះគ្រាប់ (ភាពដែលក្នុងនោះ គ្រាប់ធញ្ញជាតិជ្រុះចេញពីទងរបស់ខ្លួនដោយឯកឯង ដោយខ្យល់ ឬដោយសត្វល្អិត)

**shears** /ʃɪəz/ [n pl] កន្ត្រៃកាត់ស្មៅ

**sheath** /ʃiːθ/ [n] ស្រោម, ស្នប

**sheath pulvinus** /ʃiːθ pʌlˈvʌɪnəs/ [n] ផ្នែកប៉ោងនៃស្រទបស្លឹក (កន្លែងដែលប៉ោងនៅផ្នែកគល់នៃស្រទបស្លឹក ស្រទបស្លឹកខាងលើនៃថ្នាំង។ ជួនកាល កន្លែងប៉ោងនោះ នៅខុសពីកន្លែងថ្នាំង។)

**pollen shedding** /ˈpɒlən ʃɛdɪŋ/ [n] ការធោយលម្អង

**sheep** /ʃiːp/ [n] សត្វចៀម

**sheet** /ʃiːt/ ស្រទាប់

- lava sheet /ˈlɑːvə ʃiːt/ [n] (សទិសន័យ៖ lava flood) ស្រទាប់ថ្មរលាយដែលចេញពីភ្នំភ្លើង
- sheetflood /ʃiːtflʌd/ [n] សូមមើលពាក្យ៖ rainsheet
- sheetwash / ʃiːt wɒʃ/ [n] សូមមើលពាក្យ៖ rainsheet

**shelf** /ʃɛlf/ [n] ថ្នាក់, ធ្នើរ, ជាយ

- continental shelf /kɒntɪˈnɛnt(ə)l ʃɛlf/ [n] (សទិសន័យ៖ continental platform) ជាយទ្វីប

**seashell** /siː ʃɛl/ [n] សម្បក (ខ្យង, ខ្ចៅ)

**shellfish** /ˈʃɛlfɪʃ/ [n] ស័ង្ខ (ពួកខ្យង ខ្ចៅ លៀស គ្រុំ)

**shell-marl** /ʃɛl mɑːl/ [n] សូមមើលពាក្យ៖ shelly sand

**shelterwood** /ˈʃɛltəwʊd/ [n] ឈើផ្ដល់ជម្រក, ឈើរបាំង

**shield** /ʃiːld/ [v] ការពារ (ប្រឆាំងនឹង)

**shift** /ʃɪft/ [n] ចលនា, បម្លាស់ប្ដូរ

- antigenic shift /antɪˈdʒɛnɪk ʃɪft/ [n] បម្លាស់ប្ដូរអង់ទីសែន
- root shift /ruːt ʃɪft/ [n] សូមមើលពាក្យ៖ root effect

**shigella** /ʃɪˈgɛlə/ [n] ពួកបាក់តេរីដែលមាននៅក្នុងពោះវៀន ហើយបង្កើតឱ្យមានរោគរាកមួល

**shingle** /ˈʃɪŋg(ə)l/ [n]

១. សូមមើលពាក្យ៖ sand-bank

២. សូមមើលពាក្យ៖ cobble

**shingle-spit** /ˈʃɪŋg(ə)l-spɪt/ [n] ទំនប់, ភ្លឺដែលជាគំនរក្រួស

**shiver** /ˈʃɪvə/ [v] សូមមើលពាក្យ៖ shake

**shoal** /ʃəʊl/ [n]

១. សូមមើលពាក្យ៖ flat

២. សូមមើលពាក្យ៖ sand-bank

**shock** /ʃɒk/ [n] ការទង្គិច, ការស្លុត

- heat shock /hiːt ʃɒk/ [n] ភ្ញោចដោយកម្ដៅ

**shoot** /ʃu:t/ [n] ផ្នែកលូតលាស់ (ស្លឹក ដើម) លើដីនៃរុក្ខជាតិ , ពន្លកមែក, ពន្លកត្រួយ, កូនរុក្ខជាតិតូចៗ

- epicormic shoot /ˌɛpɪˈkɔ:mɪk ʃu:t/ [n] ត្រួយលាស់ពីតួដើម, ត្រួយអេពីកូមីក (ត្រួយដែលលាស់ចេញពីពន្លកសម្ងំនៅលើដើមនៃដើមឈើមួយ ក្រោយពីដើមឈើ ដែលនៅក្បែរវា ត្រូវបានគេកាប់ចេញ ពោលគឺដោយសារតែវាបានត្រូវពន្លឺព្រះ អាទិត្យ។ ត្រួយអេពីកូមីកដែលដុះចេញពីផ្នែកខាងក្រោមនៃដើម មានទំនោដុះ ឡើងទៅលើ ហើយអាចប្រើធ្វើជាកូនបំបៅបាន។)

**shore** /ʃɔ:/ [n] ឆ្នេរ, ឆ្នេរសមុទ្រ, ខ្លង់រាបមាត់សមុទ្រ

- flat sandy shore /flat sandɪ shore/ [n] ឆ្នេរសមុទ្រដែលមានខ្សាច់ និងក្រួស

**shoreline** /ˈʃɔ:lʌɪn/ [n] ខ្សែឆ្នេរ

**shortage** /ˈʃɔ:tɪdʒ/ កង្វះខាត

- rice shortage /rʌɪs ˈʃɔ:tɪdʒ/ [n] កង្វះខាតស្រូវ

**short-finned pilot whale** / ʃɔ:t fɪnd ˈpʌɪlət weɪl/ [n] បាឡែនក្បាលធំ (ឈ្មោះវិទ្យាសាស្ត្រ *Globicephala macrorhynchus*)

**short-term** /ʃɔ:t tə:m/ [adj] ដែលមានរយៈពេលខ្លី

**shot** /ʃɒt/ [n] សូមមើលពាក្យ៖ injection

**shoulder** /ˈʃəʊldə/ [n] ស្មា

**shoulder blade** /ˈʃəʊldə bleɪd/ [n] សូមមើលពាក្យ៖ scapula

**shovel** /ˈʃʌv(ə)l/ [n] ប៉ែល

**shrimp** /ʃrɪmp/ [n] បង្កង, បង្គា

**shrivel** /ʃrɪv(ə)l/ [v] ស្វិត, រួញ, ធ្វើឱ្យស្វិតជ្រួញ, ឡើងជ្រីវជ្រួញ

**shrub** /ʃrʌb/ [n] គុម្ព, ព្រៃរបោះ, ចុល្លព្រឹក្ស (ជារុក្ខជាតិដែលមានជាតិឈើ និងមានទំហំតូចជាងដើមឈើ និងមានការធន់ខ្ពស់ ខុសពីពពួកស្មៅ)

- flooded shrub /flʌdɪd ʃrʌb/ [n] ព្រៃគុម្ពោតលិចទឹក
- perennial shrub /pəˈrɛnɪəl ʃrʌb/ [n] ចុល្លព្រឹក្សពហុវស្ស
- shrubland /ʃrʌbland/ [n] ព្រៃគុម្ពោត (តំបន់ដែលមានឈើដុះលូតលាស់ជាប្រភេទរុក្ខជាតិដែលខុសពីដើមឈើ គឺពពួករុក្ខជាតិតូចៗដែលមានឫសច្រើនជំនួសឱ្យដើមតែ១)

**shy leaf** /ʃʌɪ li:f/ [n] ស្មៅអំបោះ (ឈ្មោះវិទ្យាសាស្ត្រ *Aeschynomene americana*)

**Siamese algae eater** /ˌsʌɪəˈmi:z ˈalgə ˈi:tə/ [n] ត្រីបណ្ដូលសុក, ត្រីស្មុក, ត្រីសេះ (ឈ្មោះវិទ្យាសាស្ត្រ *Gyrinocheilus aymonieri*)

**Siamese glassfish** /ˌsʌɪəˈmi:z ˈglɑ:sfɪʃ/ [n] ត្រីកញ្ចាញ់ច្រាសតូច (ឈ្មោះវិទ្យាសាស្ត្រ *Pseudambassis notatus*)

**siblings** /ˈsɪblɪŋz/ [n] (សទិសន័យ៖ sibs) ការជាប់សាច់ញាតិ, បងប្អូន

**sibs** /sɪbz/ [n] សូមមើលពាក្យ៖ siblings

**sick** /sɪk/ [adj] ឈឺ, មានជំងឺ

**sickle** /ˈsɪk(ə)l/ [n] កណ្ដៀវ

**sickness** /ˈsɪknəs/ [n] សូមមើលពាក្យ៖ illness

***Sida acuta*** [sci.n] សូមមើលពាក្យ៖ common wireweed

***Sida rhombifolia*** [sci.n] សូមមើលពាក្យ៖ arrowleaf sida

**side** /sʌɪd/ [n] ជ្រុង, ខាង

**sieve** /sɪv/ [n] (សទិសន័យ៖ screen, gauge) ប្រដាប់រែង

- garden sieve /ˈgɑ:d(ə)n sɪv/ [n] (សទិសន័យ៖ riddle កញ្ច្រែងរែងដី)

**sifting** /sɪftɪŋ/ [n] ការរែង

**sigmoid flexure** /ˈsɪgmɔɪd ˈflɛkʃə/ [n] កំណោងសិចម៉ូអ៊ីត

**sigmoidoscopy** /ˌsɪgmɔɪˈdɒskəpi/ [n] ការស៊ើកបំពង់ឆ្លុះពិនិត្យតាមទ្វារលាមក

**sign** /sʌɪn/ [n] សញ្ញា

***Sikukia gudgeri*** [sci.n] ត្រីកំបុតច្រមុះ

**silage** /ˈsʌɪlɪdʒ/ [n] ផ្អកចំណីសត្វ

**silica** /ˈsɪlɪkə/ [n] ស៊ីលីស (ស៊ីលីស្យូមអុកស៊ីត)

**silicate** /ˈsɪlɪkeɪt/ [n] ស៊ីលីកាត

**silicate moder** /ˈsɪlɪkeɪt mɒdə/ [n] មមោកអន្តរការ (រវាងមមោកមូល និងមមោកអាស៊ីត) ក្នុងដីគ្មានកំបោរ

**siliceous** /sɪˈlɪʃəs/ [adj] (សទិសន័យ៖ flinty) ដែលមានជាតិស៊ីលីស (ខ្សាច់) ច្រើន

**silicification** /sɪlɪsɪfɪˈkeɪʃ(ə)n/ [n] ការកកនៃជាតិស៊ីលីស

**Silicon (Si)** /ˈsɪlɪk(ə)n/ [n] ស៊ីលីចូម (និមិត្តសញ្ញាគីមី Si)

**silique** /sɪˈli:k/ [n] ប្រភេទផ្លែស្ងួតមានស្រោម

**silk** /sɪlk/ [n] សូត្រ

- warp silk /wɔːp sɪlk/ [n] សូត្រអំបោះ, សូត្រដែលអន្ទោងរួច

**silkiness** /ˈsɪlkɪnəs/ [n] សភាពទន់

**silo** /ˈsʌɪləʊ/ [n] ស្មៅស៊ីឡូ

**silt** /sɪlt/ [n] ដីល្បប់ម៉ដ្ឋ

- coarse silt /kɔːs sɪlt/ [n] ល្បាយគ្រើម, ភាគល្អិតដី ៥-៥០ មីក្រុង (ល្បាយ ឬធូលី)
- fine silt /fʌɪn sɪlt/ [n] ភាគល្អិតដី ២-១០ មីក្រុង (ល្បាយម៉ដ្ឋ ឬឆ្អារ)
- flood plain silt /flʌd pleɪn sɪlt/ [n] ល្បាប់ល្បាយនាំមកដោយទឹកជំនន់
- silt-agglomeration /sɪlt-əglɒməˈreɪʃ(ə)n/ [n] ការផ្សារភ្ជាប់គ្នាជាគ្រាប់ៗ

**siltation** /sɪlˈteɪʃ(ə)n/ [n] កំណកល្បាប់ម៉ដ្ឋ

**silting** /sɪltɪŋ/

- internal silting /ɪnˈtəːn(ə)l sɪltɪŋ/ [n] ការចម្រើនដោយភក់ល្បាប់
- silting-up /sɪltɪŋ-ʌp/ [n] ការចល័តទៅក្រោមនៃគ្រាប់ម៉ដ្ឋចូលទៅក្នុងដី, ការបំពេញដោយភក់

**silty-loamy** /ˈsɪlti ˈləʊmi/ [adj] ដែលជាដីល្បាយភក់ល្បប់

**Silver** /ˈsɪlvə/ [n] ប្រាក់ (និមិត្តសញ្ញាគីមី Ag)

**silver sharkminnow** /ˈsɪl və ʃɑːk ˈmɪnəʊ/ [n] ត្រីក្រុស (ឈ្មោះវិទ្យាសាស្ត្រ *Osteochilus hasselti*)

**silviculture** /ˈsɪlvɪˌkʌltʃə/ [n] រុក្ខវប្បកម្ម (ជាសិល្បៈ និងវិទ្យាសាស្ត្រក្នុងគ្រប់គ្រងការដាំដុះលូតលាស់ សមាសធាតុ សុខភាព និងគុណភាពរបស់ឈើដើម្បីបំពេញតម្រូវការ អ្នកគ្រប់គ្រង និងសង្គម)

**silvopastoralism** [n] ទម្រង់នៃកសិរុក្ខកម្មដែលរួមមាន ដើមឈើ ដំណាំកសិកម្ម និងការចិញ្ចឹមសត្វ

**sink** /sɪŋk/ [n] (ចំពោះដី) (សទិសន័យ៖ swallet) អណ្តូងធម្មជាតិដែលកើតនៅតំបន់ថ្មកំបោរ ឬដោយការរលាយនៃដំបូលរូងភ្នំ

- carbon sink /ˈkɑːb(ə)n sɪŋk/ [n] អាងស្រូបការបូន
- collapse sink /kəˈlaps sɪŋk/ [n] ទំនាបកើតឡើងដោយការស្រុត (ក្រហែង, ក្រហែងស្នាមក្រហែង)
- solution sink /səˈluːʃ(ə)n sɪŋk/ [n] ទំនាបកើតដោយការរលាយ

**sink-hole** /sɪŋk-həʊl/ [n] រណ្តៅបានពីការបាក់ស្រុត(ឧ.ដី)

**sinking** /sɪŋkɪŋ/ [n] ភាពស្រុត, ភាពហាប់

**sinuate** /ˈsɪnjʊət/ [adj] (ចំពោះទម្រង់រុក្ខជាតិ) គែមរាងរលក

**sinus** /ˈsʌɪnəs/ [n] ស៊ីនុស, រន្ធ, ប្រហោង (រន្ធ ឬប្រហោងក្នុងឆ្អឹងក្បាល ឬជាលិកាផ្សេងៗ)

**sinusitis** /ˌsʌɪnəˈsʌɪtɪs/ [n] រោគរលាករន្ធ ឬប្រហោងក្នុងឆ្អឹងក្បាល

**siphon** /ˈsʌɪf(ə)n/ [n] ស៊ីផុង (ទម្រង់មានរាងដូចក្បាលទុយោដែលសប្បិសត្វសិរបាទប្រើសម្រាប់បម្លាស់ទីលឿន)

**Siphonaptera** /ˌsʌɪfəˈnapt(ə)rə/ [n] សូមមើលពាក្យ៖ tropical chicken flea

**siratro** [n] វល្លិកន្ទុយកណ្តុរ (ឈ្មោះវិទ្យាសាស្ត្រ *Macroptilium atropurpureum*)

**site** /sʌɪt/ [n] តំបន់, ទីតាំង, ទីកន្លែង

- amino acid acceptor site /əˈmiːnəʊ ˈasɪd əkˈsɛptə sʌɪt/ [n] តំបន់ទទួលអាស៊ីតអាមីនេ
- attachment site /əˈtatʃm(ə)nt sʌɪt/ [n] កន្លែងភ្ជាប់
- binding site /ˈbʌɪndɪŋ sʌɪt/ [n] តំបន់ភ្ជាប់
- disposal site /dɪˈspəʊz(ə)l sʌɪt/ [n] កន្លែងចាក់សម្រាម, កន្លែងចោលសំណល់
- dumping site /dʌmpɪŋ sʌɪt/ [n] សូមមើលពាក្យ៖ dump
- nesting site /nɛstɪŋ sʌɪt/ [n] កន្លែងសត្វធ្វើសម្បុក
- shallow site /ˈʃaləʊ sʌɪt/ [n] សាច់ដីស្តើង
- uniform site /ˈjuːnɪfɔːm sʌɪt/ [n] ទីឯកសណ្ឋាន
- variable site /ˈvɛːrɪəb(ə)l sʌɪt/ [n] ទីកន្លែងប្រែប្រួល

**sitka spruce** /ˈsɪtkə spruːs/ [n] រុក្ខជាតិម្យ៉ាងដាំសម្រាប់ធ្វើក្រដាស

**situation analysis** /sɪtjʊˈeɪʃ(ə)n əˈnalɪsɪs/ [n] ការវិភាគពីស្ថានភាព (ដំណើរស្រាវជ្រាវអំពីស្ថានភាពសន្តិសុខស្បៀង និងអាហារូបត្ថម្ភនាពេលបច្ចុប្បន្នរបស់ប្រជាជន ហើយនិងហានិភ័យរបស់វាចំពោះជីវិត និងជីវភាពរស់នៅ ឬការប្រកបរបរចិញ្ចឹមជីវិតរបស់ពួកគាត់)

**situs** /ˈsʌɪtəs/ [n] លក្ខណៈធម្មតា, កន្លែងសរីរាង្គកាយ

**size** /sʌɪz/ [n] ទំហំ, មាឌ

**size grade** /sʌɪz greɪd/ [n] ក្រុមគ្រាប់ដី

**skeletal** /ˈskɛlɪt(ə)l/ [adj] នៃគម្រោងឆ្អឹង

**skeleton** /ˈskɛlɪt(ə)n/ [n] គ្រោងឆ្អឹង

- carbon skeleton /ˈkɑːb(ə)n ˈskɛlɪt(ə)n/ [n] គ្រោងកាបូន
- micro-skeleton /ˈmʌɪkrəʊ ˈskɛlɪt(ə)n/ [n] (សទិសន័យ៖ soil protoplasm) ឆ្អឹងដី, មាត្រដ្ឋានល្អិត
- soil skeleton /sɔɪlˈ skɛlɪt(ə)n/ [n] ឆ្អឹងដី, ផ្នែកធំៗនៃដី (ថ្មក្នុងដី)

**skimming** /skɪmɪŋ/ [n] ការចូលយកប្រេង ឬពពុះចេញពីផ្ទៃទឹក

**skin** /skɪn/ [n] សូមមើលពាក្យ៖ hide

**skull** /skʌl/ [n] (សូមមើលពាក្យ៖ cranium) លលាដ៍ក្បាល

**slant** /slɑːnt/ [n] ទម្រេត (ទីតាំង)

**slash and burn** /slaʃ ənd bəːn/ [adj] ដែលកាប់ហើយដុត

**slash and burn agriculture** /slaʃ ənd bəːn ˈagrɪkʌltʃə/ [n] សូមមើលពាក្យ៖ swidden cultivation

**slate** /sleɪt/ [n] ថ្ម, ឆ្នួន

**slaty** /ˈsleɪti/ [adj] ដែលកើតពីកម្ទេចថ្ម ឬឆ្នួន

**slaughter** /ˈslɔːtə/ [n] ការធ្វើសត្តឃាតសត្វ

**slaughter** /ˈslɔːtə/ [v] ពិឃាតសត្វ

**slaughterhouse** /ˈslɔːtəhaʊs/ [n] (សទិសន័យ៖ abattoir) ទីសត្តឃាត, កន្លែងពិឃាតសត្វ

**slender amaranth** /ˈslɛndə ˈamərанθ/ [n] ផ្ទីដូង, ផ្ទីអាចម៍មាន់ (ឈ្មោះវិទ្យាសាស្ត្រ *Amaranthus viridis*)

**slide** /slʌɪd/ ការរអិល

- ash slide /aʃ slʌɪd / [n] (សទិសន័យ៖ slip in volcanic ash) ការរអិលចុះនៃផេះ (ភ្នំភ្លើងនៅលើជម្រាល)
- debris slide /ˈdɛbriː slʌɪd/ [n] (សទិសន័យ៖ slope slip, debris slope) កម្ទេចកំទីជម្រាល
- earth slide /əːθ slʌɪd/ [n] (សទិសន័យ៖ earth flow, landslide) ការរអិលចុះនៃជម្រាល (ពិសេសនៅពេលភ្លៀងច្រើន)
- rock slide /rɒk slʌɪd/ [n] (សទិសន័យ៖ rock avalanche) ការរអិលចុះនៃដុំថ្មពីលើជម្រាល
- subaqueous slide /sʌbˈeɪkwɪəs slʌɪd/ [n] ការរអិលដីនៅក្រោមទឹក

**slime** /slʌɪm/ ភក់

- fetid slime /ˈfɛtɪd slʌɪm/ [n] ភក់រលួយស្អុយ

**sling** /slɪŋ/ [n] កំណាត់ស្ពាយដៃ

**sliver** /ˈslʌɪvə/ [n] បំណែក

**slobber** /ˈslɒbə/ [v] ការចេញទឹកមាត់

**slope semi-gley** /sləʊpˈsɛmigleɪ/ [n] ដីឥដ្ឋជាំទឹកជ្រៅក្នុងដី នៅលើជម្រាល

**slope slip** /sləʊp slɪp/ [n] សូមមើលពាក្យ៖ debris slide

**slope** /sləʊp/ [n] (សទិសន័យ៖ declivity) ជម្រាល (ភ្នំ), ទីជម្រាល, ចំណោត, ភ្លឺ, ភ្នំតូច

- abrupt slope /əˈbrʌpt sləʊp/ [n] ជម្រាលចោតខ្លាំង
- accumulation slope /əkjuːmjʊˈleɪʃ(ə)n sləʊp/ [n] ជម្រាលនៃគំនរប្រមូល
- back slope /bak sləʊp/ [n] ជម្រាលក្រោយច្រាំង (តំបន់ទំនាបដែលស្ថិតនៅជាប់នឹងដងទន្លេ)
- bottom of slope /ˈbɒtəm ɒv sləʊp/ [n] សូមមើលពាក្យ៖ foot slope
- continental slope /kɒntɪˈnɛnt(ə)l sləʊp/ [n] ចំណោតជាយទ្វីប, ជម្រាលទ្វីប
- debris slope /ˈdɛbriː sləʊp/ [n] សូមមើលពាក្យ៖ debris slide
- embankment slope /ɪmˈbaŋkm(ə)nt sləʊp/ [n] ភ្លឺដែលលើកដោយអាចម៍ដី
- erosion slope /ɪˈrəʊʒ(ə)n sləʊp/ [n] ជម្រាលនៃការហូរច្រោះ
- excavation slope /ɛkskəˈveɪʃ(ə)n sləʊp/ [n] ជម្រាលដែលគេជីកយកអាចម៍ដីចេញ
- foot slope /fʊt sləʊp/ [n] (សទិសន័យ៖ bottom of slope) ជើងជម្រាល
- gentle slope /ˈdʒɛnt(ə)l sləʊp/ [n] ជម្រាលទេរ
- low slope /sləʊp/ [n] ជម្រាលទេរខ្លាំងផ្នែងខាងក្រោមនៃជម្រាល
- mid-slope /mɪd sləʊp/ [n] ពាក់កណ្ដាលជម្រាល
- pitching of slope /pɪtʃɪŋ ɒv sləʊp/ [n] ខឿនទប់ដី, ជញ្ជាំងថ្មទប់ដី
- reversal of slope /rɪˈvəːs(ə)l ɒv sləʊp/ [n] ជម្រាលខាងនាយ, ជម្រាលទល់មុខនឹងជម្រាលមួយទៀត
- slope of river /sləʊp ɒv ˈrɪvə/ [n] ចំណោតទន្លេ

- stratified debris slope /ˈstratɪfʌɪd ˈdɛbriː sləʊp/ [n] (សទិសន័យ៖ bedded scree) កម្ទេចកំទីដែលគរជាស្រទាប់ៗ
- talus slope /ˈteɪləs sləʊp/ [n] ជម្រាលនៃគំនរបែកបាក់នៃថ្ម
- turfed slope /təːf sləʊp/ [n] ភ្លឺជម្រាលគ្របដោយស្មៅ

**slopy** /sləpi/ [adj] (សទិសន័យ៖ hilly) ទាបខ្ពស់ដែលជាសភាពភ្នំ

**slough** /slaʊ/ [n] សូមមើលពាក្យ៖ bog

**slough** /slaʊ/ [v] របក, ជ្រុះ (ក្រមរ ឬផ្នែកជាលិកាស្លាប់បែកចេញពីជាលិការស់)

**sludge** /ˈslʌdʒ/ [n] សូមមើលពាក្យ៖ mud

- acid sludge /ˈasɪd ˈslʌdʒ/ [n] ភក់អាស៊ីត
- activated sludge /ˈaktɪveɪtɪd ˈslʌdʒ/ [n] សូមមើលពាក្យ៖ biological sludge
- aerated sludge /ˈɛəreɪtɪd ˈslʌdʒ/ [n] ភក់អាកាសកម្ម
- basin sludge /ˈbeɪs(ə)n ˈslʌdʒ/ [n] ភក់រងបាតអាង
- biological sludge /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˈslʌdʒ/ [n] (សទិសន័យ៖ activated sludge) ភក់សកម្ម, ភក់ជីវៈ
- dewatered sludge /diːˈwɔːtəd ˈslʌdʒ/ [n] ភក់គ្មានទឹក
- dried sludge /drʌɪd ˈslʌdʒ/ [n] ភក់ស្ងួត
- sedimentation sludge /sɛdɪmɛnˈteɪʃ(ə)n ˈslʌdʒ/ [n] ភក់កម្ទេចកំណ
- sewage sludge /ˈsuːɪdʒ ˈslʌdʒ/ [n] ភក់ទឹកលូសម្អុយ

**slug** /slʌg/ [n] ខ្យងគោកម៉្យាងដែលឥតមានស្នូក

**slurry** /ˈslʌri/ [n] ភក់រាវ (ឧ. ភក់បានពីកសិដ្ឋានចិញ្ចឹមសត្វ)

**smallflower umbrella sedge** /smɔːlˈflaʊə ʌmˈbrɛlə sɛdʒ/ [n] កក់ឆ័ត្រតូច (ឈ្មោះវិទ្យាសាស្ត្រ *Cyperus difformis*)

**smallholder** /ˈsmɔːlhəʊldə/ [n] កសិករខ្នាតតូច, កសិករកាន់កាប់ដីខ្នាតតូច

**smallpox** /ˈsmɔːlpɒks/ [n] អុតធំ

**smallscale archerfish** /smɔːlskeɪl ˈɑːtʃəfɪʃ/ [n] ត្រីកញ្ចាក់ស្លា (ឈ្មោះវិទ្យាសាស្ត្រ *Toxotes microlepis*)

**smallscale croaker** /smɔːlskeɪl ˈkrəʊkə/ [n] ត្រីប្រមា (ឈ្មោះវិទ្យាសាស្ត្រ *Boesemania microlepis*)

**smallscale tonguesole** /smɔːlskeɪl ˈtʌŋsəʊl/ [n] ត្រីអណ្តាតឆ្កែ (ឈ្មោះវិទ្យាសាស្ត្រ *Cynoglossus microlepis*)

**smear** /smɪə/ [v] ពាស, ពាក់ពីលើ

**smear** /smɪə/ [n]

១. វិធីសង្កត់បំបែកជាលិកា

២. វត្ថុធាតុដែលលាបលើបន្ទះកញ្ចក់ដើម្បីយកទៅពិនិត្យ (ចំពោះរុក្ខជាតិ៖ ការរៀបចំមួយភ្លែត និងការដាក់ពណ៌ក្នុងការសិក្សាក្រូម៉ូសូម ដោយការប្រើសម្ពាធសង្កត់ពង្រាបបំបែក ជាលិកាបែកពីគ្នា។ វិធីនេះ ជារឿយៗ គេធ្វើចំពោះលម្អងកោសិកាមេនៅដំណាក់កាលមេយ៉ូស (Pollen Mother Cells- PMC smears) និងចំពោះគ្រាប់លម្អង ចុងឫស និងកោសិកាលូតលាស់ផ្សេងៗទៀតនៅ ដំណាក់កាលម៉ៃតូស៊ីស។)

**smeary** /ˈsmɪəri/ [adj] ខ្លាញ់

**smegma** /ˈsmɛgmə/ [n] កាកសេបូម

**smell** /smɛl/ [n] ក្លិន

**smog** /smɒg/ [n] ស្មូក, ផ្សែងលាយអ័ព្ទ

- photochemical smog /fəʊtə(ʊ)ˈkɛmɪk(ə)l smɒg/ [n] ស្មូកផូតូគីមី

**smoke** /sməʊk/ [n] ផ្សែង

- exhaust smoke /ɪgˈzɔːst sməʊk/ [n] ផ្សែងម៉ាស៊ីន (ម៉ាស៊ីនចំហេះក្នុង)

**smoothing** /smuːðθɪŋ/ [n] សូមមើលពាក្យ៖ levelling

**smother** /ˈsmʌðə/ [v] ដុះគ្រប (ឧ. ដំណាំ)

**smut** /smʌt/ [n] ជំងឺប្រភេទម្រែងភ្លើង

**snail** /sneɪl/ [n] ខ្យង

**snake** /sneɪk/ [n] ពស់

**snakehead** /sneɪkhɛd/ [n] ពពួកត្រីត្រីផ្ទក់, ត្រីរ៉ស់

- chevron snakehead /ˈʃɛvrən sneɪkhɛd/ [n] ត្រីផ្ទក់ (តូច), ត្រីរ៉ស់ (ធំ) (ឈ្មោះវិទ្យាសាស្ត្រ *Channa striata*)
- giant snakehead /ˈdʒʌɪənt sneɪkhɛd/ [n] ត្រីដៀប (តូច), ត្រីឆ្តោ (ធំ) (ឈ្មោះវិទ្យាសាស្ត្រ *Channa micropeltes*)
- walking snakehead /wɔːkɪŋ sneɪkhɛd/ [n] ត្រីក្បាន (ឈ្មោះវិទ្យាសាស្ត្រ *Channa orientalis*)

**snake-needle grass** /sneɪk ˈniːd(ə)l grɑːs/ [n] កំប៉ោយចិន (ឈ្មោះវិទ្យាសាស្ត្រ *Hedyotis diffusa*)

**snakeskin gourami** /ˈsneɪkskɪn gʊ(ə)ˈrɑːmi/ [n] ត្រីកន្ធរ (ឈ្មោះវិទ្យាសាស្ត្រ *Trichogaster pectoralis*)

**snare** /snɛː/ [n] ដងដោក, ដងអន្ទាក់

**sneeze** /sniːz/ [v] កណ្តាស

***Snellenius manilae*** [sci.n] ពួកឪម៉ាល់ (បរាសិតលើដង្កូវកាត់ស្លឹក)

**sniffle** /ˈsnɪf(ə)l/ [v] (សទិសន័យ៖ snuffle) ហិត

**snout** /snaʊt/ [n] ច្រមុះ (ជ្រូក)

**snow pea** /snəʊ piː/ [n] សណ្តែកហោឡាន់តាវ (ឈ្មោះវិទ្យាសាស្ត្រ *Pisum sativum* var. *saccharatum*)

**snow** /snəʊ/ [n] ទឹកកកសម្លី, ព្រិល

- acid snow /ˈasɪd snəʊ/ [n] ទឹកកកសម្លីអាស៊ីត

**snuffle** /ˈsnʌf(ə)l/ [v] សូមមើលពាក្យ៖ sniffle

**soaking** /ˈsəʊkɪŋ/ [n] ការត្រាំ (ដំណើរការដែលក្នុងនោះគ្រាប់ពូជ ត្រូវបានយកមកត្រាំឱ្យមានសំណើមគ្រប់គ្រាន់សម្រាប់ការចាប់ផ្តើមដុះលូតលាស់)

**sociology** /səʊʃɪˈɒlədʒi/ [n] សង្គមវិទ្យា

**socket** /ˈsɒkɪt/ [n] ផ្នែកប្រហោងរបស់ឆ្អឹង, រន្ធសម្រាប់ស៊ក

**sod** /sɒd/ [n] សូមមើលពាក្យ៖ turf

**soda** /ˈsəʊdə/ [n] សូមមើលពាក្យ៖ caustic sodium

**Sodium** /ˈsəʊdɪəm/ [n] សូដ្យូម (និមិត្តសញ្ញាគីមី Na)

- caustic sodium /ˈkɔːstɪk ˈsəʊdɪəm/ [n] (សទិសន័យ៖ soda) ស៊ូតកាត់

**soft** /sɒft/ [adj] សូមមើលពាក្យ៖ loose

**soft wrist restraint** /sɒft rɪst rɪˈstreɪnt/ [n] ខ្សែទន់ៗចងកដៃ (ដើម្បីបូមឈាម)

**softwood** /ˈsɒf(t)wʊd/ [n] ឈើទន់, ឈើស្គោត (ដើមឈើនៅក្នុងក្រុម gymnosperm ដែលរួមមានពពួកស្រល់ hemlocks, larches, spruces, firs និង junipers។ ឈើទន់តែត្រូវបានហៅថា conifer ទោះបីមាន ប្រភេទខ្លះ ដូចជា junipers និង yews មិនមានផ្លែជាលក្ខណៈកោនក៏ដោយ។)

***Sogatella furcifera*** [sci.n] សូមមើលពាក្យ៖ whitebacked planthopper

**soil** /sɔɪl/ [n] ដី

- accumulation soil /əkjuːmjʊˈleɪʃ(ə)nsɔɪl/ [n] ដីដែលកើតមកពីសម្ភារដែលនាំមកគរកន្លែងណាមួយ
- acid peat soil /ˈasɪdpiːtsɔɪl/ [n] ដីអាស៊ីតជាំទឹកក្នុងទំនាបបឹងដែលមានពើក
- acid peat soil /ˈasɪd piːt sɔɪl/ [n] ដីពើកអាស៊ីត
- acid soil /ˈasɪd sɔɪl/ [n] ដីជូរ, ដីអាស៊ីត (ដីដែលមាន pH<៧.0)
- acid sulfate soil /ˈasɪd ˈsʌlfeɪt sɔɪl/ [n] ដីអាស៊ីតស៊ុលហ្វាត (ជាដីដែលមានតម្លៃ pH<៤ នៅក្នុងលក្ខខណ្ឌដីស្ងួត ហើយផ្ទុកនូវចំនួនដ៏ខ្ពស់មួយនៃស៊ុលហ្វាត និងចំណុចលឿងច្រើនលាយលំក្នុងដី។ ដីប្រភេទនេះ រមែងជួបប្រទះភាពពុល ជាតិអាលុយមីញ៉ូម ដែក អាស៊ីតស៊ុលហ្វីត និងកង្វះផូស្វ័រ។ លើសដីនេះ គេអាចដាំដុះដំណាំណាដែលជាពូជធន់នឹងភាពមិនប្រក្រតីខាងលើ ឬធន់នឹងភាពប្រៃ ឬធន់នឹងការពន្លិចទឹក។)
- acidic soil /əˈsɪdɪk sɔɪl/ [n] ដីអាស៊ីត, ដីជូរ
- active soil /ˈaktɪv sɔɪl/ [n] ដីសកម្ម (ដីសម្បូរទៅដោយជីវសាស្ត្រ, លក្ខណៈសមស្របសម្រាប់សត្វរស់នៅ)
- adobe soil /əˈdəʊbi sɔɪl/ [n] ប្រភេទដីសម្រាប់ធ្វើឥដ្ឋម្យ៉ាង
- aeolian soil /iːˈəʊlɪən sɔɪl/ [n] (សទិសន័យ៖ eolian soil, wind-blown soil) ដីដែលនាំមកដោយខ្យល់
- aged soil /eɪdʒd sɔɪl/ [n] (សទិសន័យ៖ aged soil, past mature soil) ដីចាស់ធេចរឹល
- alkaline soil /ˈalkəlʌɪn sɔɪl/ [n] ដីអាល់កាឡាំង, ដីបាស, ដីក្បុង (ដីដែលមាន pH>៧.0 ដែលមានអ៊ីយ៉ុងអ៊ីដ្រូលីសជាអ៊ីយ៉ុងអ៊ីដ្រូសែន។)
- allitic soil /əˈlɪttɪk sɔɪl/ [n] សូមមើលពាក្យ៖ allit
- alluvial brown soil /əˈl(j)uːvɪəl braʊn sɔɪl/ [n] ដីប្រងសម្បុរត្នោតដែលមានប្រភពពីល្បាប់
- alluvial crust soil /əˈl(j)uːvɪəl krʌst sɔɪl/ [n] ដីល្បាប់ដែលមានស្រទាប់ដែករឹងខាងក្រោម
- alluvial meadow soil /əˈl(j)uːvɪəl mɛdəʊ sɔɪl/ [n] សូមមើលពាក្យ៖ riverside soil
- alluvial soil /əˈl(j)uːvɪəl sɔɪl/ [n] (សទិសន័យ៖ fluviogenic soil, valley filling soil) ដីល្បាប់ទន្លេ (ដីល្បាប់ដែលកកើតដោយសារជំនន់ទន្លេ ស្ទឹងបឹងបួ)

- alpha-gley soil /ˈalfə gleɪ sɔɪl/ [n] (សទិសន័យ៖ shallow-gley soil) ដីដែលស្រទាប់ជាំទឹកគ្លោក់ខាងលើ
- alpine carbonate raw soil /ˈalpʌɪn ˈkɑːbəneɪt rɔː sɔɪl/ [n] ដីថ្មីលើថ្មកំបោរក្នុងតំបន់ភ្នំ
- alpine humus soil /ˈalpʌɪn ˈhjuːməs sɔɪl/ [n] ដីមមោកច្រើនក្នុងតំបន់ភ្នំ, ដីវាលស្មៅតំបន់ភ្នំ
- alpine meadow soil /ˈalpʌɪn ˈmɛdəʊ sɔɪl/ [n] ដីវាលស្មៅតំបន់ភ្នំ
- alpine meadow soil /ˈalpʌɪn mɛdəʊ sɔɪl/ [n] ដីវាលស្មៅនៅតំបន់ភ្នំត្រជាក់
- alumi soil /ˈaləmē sɔɪl/ [n] ដីប្រៃដែលមានសារធាតុស៊ុលហ្វាត
- amorphous soil /əˈmɔːfəs sɔɪl/ [n] ដីដែលគ្មានទម្រង់ ឬជាទម្រង់ដុល (គ្មានបែកជាគ្រាប់តូចៗ)
- anthropic soil /anˈθrɒpɪk sɔɪl/ [n] (សទិសន័យ៖ man-made soil) ដីដែលកើតដោយសារសកម្មភាពមនុស្ស, ដីសិប្បនិម្មិត
- aqueous soil /ˈeɪkwɪəs sɔɪl/ [n] ដីជាំទឹក
- artificial soil /ɑːtɪˈfɪʃ(ə)l sɔɪl/ [n] (សទិសន័យ៖ made land) ដីសិប្បនិម្មិត, ដីដែលគេជុំឡើង
- ashy humus soil /ˈaʃi ˈhjuːməs sɔɪl/ [n] ដីមមោកច្រើនដែលមានសភាពដូចផេះ
- autochton soil /ɔːˈtɒkθ(ə)n sɔɪl/ [n] សូមមើលពាក្យ៖ primary soil
- autochtonal soil [n] សូមមើលពាក្យ៖ primary soil
- automorphic soil /ˈɔːtəʊˈmɔːfɪk sɔɪl/ [n] (សទិសន័យ៖ idiomorphic soil) ដីដែលជាធម្មជាតិទឹកអាចជ្រាបចេញបានល្អ និងមិនជាំទឹក
- basic soil /ˈbeɪsɪk sɔɪl/ [n] ដីមានជាតិបាស (pH>៧)
- basin soil /ˈbeɪs(ə)n sɔɪl/ [n] ដីក្នុងតំបន់ទំនាបបាតខ្វះ
- black alkali soil /blakˈ alkəlʌɪ sɔɪl/ [n] ដីប្រៃអាល់កាលីខ្មៅ
- black calcareous soil / blakˈ kalˈkɛːrɪəs sɔɪl/ [n] ដីកំបោរពណ៌ខ្មៅ
- black soil /blak sɔɪl/ [n] ដីខ្មៅ
- black top soil /blak tɒp sɔɪl/ [n] សូមមើលពាក្យ៖ muck
- black turf soil /blak təːf sɔɪl/ [n] ដីឥដ្ឋខ្មៅក្នុងតំបន់វាលស្មៅ, ដីខ្មៅក្រោមវាលស្មៅ
- blue clay soil /bluː kleɪ sɔɪl/ [n] ដីឥដ្ឋពណ៌ខៀវ
- bolus-like soil /ˈbəʊləs-lʌɪk sɔɪl/ [n] ដីដែលមានអត្រាឥដ្ឋច្រើនអាចប៉ានជារូបផ្សេងៗបាន, ដីឥដ្ឋក្រហមច្រេះម្យ៉ាង (ដែលមិនសូវស្អិត)
- brown humus-calcareous soil /braʊn ˈhjuːməs kalˈkɛːrɪəs sɔɪl/ [n] ដីកាបូណាតមានមមោកច្រើនសម្បុរត្នោត
- brown lateritic soil /braʊn latəˈrɪtɪk sɔɪl/ [n] (សទិសន័យ៖ humic latosol) ដីឡាតេរីតសម្បុរត្នោត
- brown podzolic soil /braʊn ˈpɒdzɒlɪk sɔɪl/ [n] (សទិសន័យ៖ podzolised soil, dark forest soil) ដីលាងច្រោះខ្លាំង
- brown soil /braʊn sɔɪl/ [n] (សទិសន័យ៖ brown earth) ដីពណ៌សម្បុរត្នោត, ដីព្រៃ
- brownearth-like soil /braʊnəːθ lʌɪk sɔɪl/ [n] ដីដែលមានកិនភាគដូចដីសម្បុរត្នោត (ដីដែលគ្មានការលាងច្រោះ)
- buried soil /ˈbɛrid sɔɪl/ [n] សូមមើលពាក្យ៖ fossil soil
- calcareous brown soil /kalˈkɛːrɪəs braʊn sɔɪl/ [n] (សទិសន័យ៖ degraded rendzina) ដីប្រេងដែលមានកំបោរលាយជាមួយនឹងដី
- calcareous soil /kalˈkɛːrɪəs sɔɪl/ [n]
  ១. ដីដែលមានកំបោរច្រើន (ច្រើនជាង ២០%)
  ២. ដីដែលសំបូរដោយកាល់ស្យូមកាល់បូណាត $CaCO_3$ និងសារធាតុកាបូនផ្សេងទៀត (ដើម្បីមើលឃើញសារធាតុនេះ គេអាចប្រើ 0.១ M HCl ចំណាំ ដីទាំងនេះភាគច្រើនមានពី ១០ ទៅ ១០០០គ.ក)
- calcimorphic soil /ˈkalsiˈmɔːfɪk sɔɪl/ [n] ដីដែលមានសារធាតុកាល់ស្យូមច្រើន
- carried soil /ˈkarid sɔɪl/ [n] សូមមើលពាក្យ៖ transported soil
- cellular soil /ˈsɛljʊlə sɔɪl/ [n] ដីដែលមានរូបរាងជាពហុកោណនៅតំបន់ត្រជាក់ខ្លាំង
- chalk-deficient subaqueous raw soil [n] ដីលិចទឹកដែលគ្មានពើក គ្មានកំបោរ
- chalky soil /ˈtʃɔːki sɔɪl/ [n] ដីកំបោរ

- chernozem soil /ˈtʃəːnəzɛm sɔɪl/ [n] ដីខ្មៅតំបន់ស្ដែប
- chesnut tree soil /ˈtʃɛsnʌt triː sɔɪl/ [n] ដីសម្រាប់ដាំដំណាំសាតែញ
- chocolate soil /ˈtʃɒk(ə)lət sɔɪl/ [n] ដីសម្បុរសូកូឡា
- chronomorphic soil /ˈkrɒnəʊˈmɔːfɪk sɔɪl/ [n] ដីដែលសភាពទូទៅផ្លាស់ប្ដូរទៅតាមពេលវេលា
- clay soil /kleɪ sɔɪl/ [n] ដីឥដ្ឋ, ដីដែលមានឥដ្ឋច្រើន (អត្រាឥដ្ឋច្រើនជាង ៥០%)
- clay warp soil /kleɪ wɔːp sɔɪl/ [n] ដីឥដ្ឋនៅកន្លែងទំនាប
- clear brown soil /klɪə braʊn sɔɪl/ [n] ដីប្រេង ដែលមានសម្បុរត្នោតថ្លា
- cleyed soil /gleɪd sɔɪl/ [n] ដីដែលមានឥដ្ឋច្រើន (អត្រាឥដ្ឋច្រើនជាង ៥០%)
- coarse textured soil /kɔːs ˈtɛkstʃəd sɔɪl/ [n] ប្រភេទដីសាច់គ្រើម (ដីដែលមានសមាមាត្រនៃភាគល្អិតរបស់ដីខ្សាច់ច្រើន)
- coarse-structured soil /kɔːs ˈstrʌktʃəd sɔɪl/ [n] ដីដែលមានវាយនភាពគ្រើម
- coastal marsh soil /ˈkəʊstl mɑːʃ sɔɪl/ [n] សូមមើលពាក្យ៖ sea-marsh soil
- cobbly soil /ˈkɒbli sɔɪl/ [n] សូមមើលពាក្យ៖ stony soil
- colby soil /ˈkɒlbi sɔɪl/ [n] (សទិសន័យ៖ stony soil) ដីខ្ចីថ្មច្រើនដែលទើបតែវិវត្ត
- cold soil /kəʊld sɔɪl/ [n] ដីត្រជាក់ខ្លាំង
- colluvial crust soil /kəˈl(j)uːvɪəl krʌst sɔɪl/ [n] ដីកើតពីសម្ភាររមៀលដែលមានស្រទាប់គូរ៉ាស់ ដែលរឹងខាងក្រោម
- colluvial soil /kəˈl(j)uːvi.əl sɔɪl/ [n] ដីល្បាប់ខ្ពស់ (ដីល្បាប់ដែលហូរមកពីទីខ្ពស់ដោយសារទឹកភ្លៀង)
- columnar alkali soil [n] សូមមើលពាក្យ៖ black alkali soil
- compacted soil /kəmˈpaktɪd sɔɪl/ [n] ដីហាប់
- complex soil /ˈkɒmplɛks sɔɪl/ [n] (សទិសន័យ៖ polygenetic soil) ដីកំផ្លិចដែលកើតពីថ្មមេពីរជាន់លើគ្នា
- continental humus soil /kɒntɪˈnɛnt(ə)l ˈhjuːməs sɔɪl/ [n] ដីមមោកច្រើននៅលើទ្វីប
- cotton soil /ˈkɒt(ə)n sɔɪl/ [n] ដីសម្រាប់ដំណាំកប្បាស
- crude soil /kruːd sɔɪl/ [n] ដីថ្មី (ដែលមិនធ្លាប់ធ្វើអាជីវកម្មសោះ)
- crumbing black soil /krʌmɪŋ blak sɔɪl/ [n] ដីខ្មៅដែលមានទម្រង់ល្អជាគ្រាប់មូលៗ (ដូចគ្រាប់ពោត)
- crymorphic soil /krʌɪˈmɔːfɪk sɔɪl/ [n] សូមមើលពាក្យ៖ frozen earth
- cryptogenic soil /ˌkrɪptəʊˈdʒɛnɪk sɔɪl/ [n] ១. ដីដែលការវិវត្តមើលមិនឃើញ ២. សូមមើលពាក្យ៖ immature soil
- cultivated soil /ˈkʌltɪveɪtɪd sɔɪl/ [n] (សទិសន័យ៖ tilled soil) ដីដែលគេដាំ, ដីធ្វើកសិកម្ម, ដីដែលគេភ្ជួរ, ដីដែលគេធ្លាប់ប្រកបអាជីវកម្មកសិកម្មពីមុនមកហើយ
- cumulose soil [n] (សទិសន័យ៖ organic soil) ដីដែលសរីរាង្គនៅគរបន្តបន្ទាប់គ្នា (លើសពី ២០%)
- dark forest soil /dɑːk ˈfɒrɪst sɔɪl/ [n] សូមមើលពាក្យ៖ brown podzolic soil
- dark humus soil /dɑːk ˈhjuːməs sɔɪl/ [n] (សទិសន័យ៖ melanized soil) ដីពណ៌ក្រម៉ៅ
- debris soil /ˈdɛbriː sɔɪl/ [n] សូមមើលពាក្យ៖ talus soil
- decalcified soil /diːˈkalsɪfʌɪd sɔɪl/ [n] ដីដែលខ្សោះដោយជាតិកាល់ស្យូម (Ca)
- deep gley brown soil /diːp gleɪ braʊn sɔɪl/ [n] ដីប្រេងសម្បុរត្នោតដែលមានគ្លេជាំទឹកនៅជ្រៅ
- deep gley clay soil /diːp gleɪ kleɪ sɔɪl/ [n] ដីឥដ្ឋដែលស្រទាប់ជាំទឹកជាអចិន្ត្រៃយ៍នៅជ្រៅខាងក្រោម
- deep gley soil /diːp gleɪ sɔɪl/ [n] (សទិសន័យ៖ gamma gley soil) ដីគ្លេជាំទឹកជ្រៅ, ដីដែលស្រទាប់ជាំទឹកគ្លេនៅជ្រៅ
- deep unconsolidated mineral soil /diːp ʌnkənˈsɒlɪdeɪtɪd ˈmɪn(ə)r(ə)l sɔɪl/ [n] ដីខនិជ (គ្មានសរីរាង្គ ឬមមោក) ដែលដុំ ឬគ្រាប់មិនជាប់គ្នា
- deep-gley soil /diːp gleɪ sɔɪl/ [n] (សទិសន័យ៖ gamma-gley soil) ដីដែលជាំទឹក
- degenerated soil /dɪˈdʒɛn(ə)rətid sɔɪl/ [n] សូមមើលពាក្យ៖ aged soil
- degraded alkali soil /dɪˈgreɪdɪd ˈalkəlʌɪ sɔɪl/ [n] ដីប្រែប្រភេទអាល់កាលី (pH>៨.៥)

- degraded black-earth soil /dɪˈgreɪdɪd blak əːθ sɔɪl/ [n] សូមមើលពាក្យ៖ prairie-forest soil
- degraded humus carbonate soil /dɪˈgreɪdɪd ˈhjuːməs ˈkɑːbəneɪt sɔɪl/ [n] (សទិសន័យ៖ degraded rendzina) ដីកំបោរប្រភេទផែនហ្សីនរេចរឹល
- de-ironized brown soil [n] ដីជាប្រភេទល្បាយត្នោតថ្លា ដោយការចាកចេញនៃសារធាតុដែក
- deluvial soil [n] សូមមើលពាក្យ៖ overwash
- denuded soil /dɪˈnjuːdɪd sɔɪl/ [n] សូមមើលពាក្យ៖ eroded soil
- desert dust soil /dɪˈzəːt dʌst sɔɪl/ [n] ដីផង់ធូលីនៅតំបន់ក្ដៅហែង
- desert soil /dɪˈzəːtsɔɪl/ [n] ដីតំបន់ក្ដៅហែង
- drained soil /dreɪnd sɔɪl/ [n] ដីដោះទឹក, ដីស្រស់ទឹក
- dry desert raw soil /drʌɪ dɪˈzəːt rɔː sɔɪl/ [n] ដីខ្ចីមិនទាន់វិវត្តក្នុងតំបន់វាលខ្សាច់ស្ងួតមមោកតិច
- dune soil /djuːn sɔɪl/ [n] ដីដែលជាផ្នូក, ដំបូកខ្សាច់
- dwarf soil /dwɔːf sɔɪl/ [n] ដីស្ដើង, ដីរាក់ខ្លាំង, ដីតឿ
- dystrophic lacustrine soil /dɪsˈtrəʊfɪk ləˈkʌstrʌɪn sɔɪl/ [n] សូមមើលពាក្យ៖ limnic peat
- eluvial hydromorphic soil [n] ដីលាងច្រោះជាំទឹក
- eluvial soil [n] ដីដែលជាវត្ថុធាតុសំណល់អេលុយវីយ៉ុម
- embryonic soil /ˌɛmbrɪˈɒnɪk sɔɪl/ [n] សូមមើលពាក្យ ៖ immature soil
- endoadynamic organic mineral soil [n] ដីខ្ចីវិវត្តយឺតពេកដោយកត្តាក្នុងនៃថ្មមេមិនសមស្រប (ឧ. ថ្មរឹងពេក)
- eolian soil /iˈəʊlɪən sɔɪl/ [n] សូមមើលពាក្យ៖ aeolian soil
- eroded soil /ɪˈrəʊdɪd sɔɪl/ [n] (សទិសន័យ៖ denuded soil) ដីហូរច្រោះ
- erosion soil /ɪˈrəʊʒ(ə)n sɔɪl/ [n] ដីទទេដោយការហូរច្រោះ
- eutrophic gley /juːˈtrəʊfɪk gleɪ/ [n] ដីគ្លេជាំទឹកសម្បូរដោយខនិជ ឬជីជាតិ
- eutrophic lacustrine soil /juːˈtrəʊfɪk ləˈkʌstrʌɪn sɔɪl/ [n] ដីល្បាប់បាតបឹងដែលមានសកម្មភាពជីវសាស្ត្រច្រើន, ដីមានជីជាតិច្រើន
- ever frozen soil /ˈɛvə ˈfrəʊzn sɔɪl/ [n] ដីកកជានិច្ច
- exoadynamic organic mineral soil [n] ដីខ្ចីវិវត្តយឺតពេកដោយកត្តាបរិស្ថានមិនសមស្រប (ឧ. ធាតុអាកាស)
- extremely light soil /ɪkˈstriːmli lʌɪt sɔɪl/ [n] ដីដែលអាចចល័តបានយ៉ាងងាយស្រួល (ឧ. ដីខ្សាច់)
- facetted soil /ˈfasɪted sɔɪl/ [n] (សទិសន័យ៖ tesselated soil, rhomboid soil, polygonal fissure soil) ដីដែលបែកជាដុំៗតម្រៀបជារូបភាពក្រឡាចត្រង្គ
- fen peat soil /fɛn piːt sɔɪl/ [n] (សទិសន័យ៖ low moor soil, peaty muck) ដីពើកណើតកន្លែងទំនាប pH ណើត (ជាំទឹក ឬគ្មានជាំទឹក)
- fen soil /fɛn sɔɪl/ [n] ដីវាលភក់ជាំទឹក (ដែលមានពើក)
- ferallitic soil /ˈfɛr(ə)lˈlɪtɪk sɔɪl/ [n] ដីឡាតេរីត, ដីក្រហមដោយសារធាតុអុកស៊ីដែក (ឧ. ដីក្រហមក្នុងខេត្តកំពង់ចាម)
- ferrimorphic soil /ˈfɛriˈmɔːfɪk sɔɪl/ [n] (សទិសន័យ៖ haemomorphic soil) ដីក្រហមដែលមានសារធាតុដែកអុកស៊ីតច្រើន
- fertile soil /ˈfəːtʌɪl sɔɪl/ [n] ដីមានជីជាតិ, ដីដែលមានជីជាតិល្អ
- fined-textured soil /ˈfʌɪnd ˈtɛkstʃəd sɔɪl/ [n] សូមមើលពាក្យ៖ fine-textured soil
- fine-grained soil /fʌɪn greɪnd sɔɪl/ [n] ដីគ្រាប់ល្អិត
- fine-textured soil /fʌɪn ˈtɛkstʃəd sɔɪl/ [n] (សទិសន័យ៖ fined-textured soil) ដីមានវាយនភាពល្អិតឬល្បាយ
- firm soil /fəːm sɔɪl/ [n] ដីរឹង
- fissure network soil /ˈfɪʃəˈ nɛtwəːk sɔɪl/ [n] (សទិសន័យ៖ patterned ground) ដីដែលមានក្រហែងប្រេះជាបណ្ដាញ
- flocalated soil [n] ដីដែលកកជាគ្រាប់ៗ
- flood loamy soil /flʌd ˈləʊmi sɔɪl/ [n] ដីល្បាប់ល្បាយដែលអាចលិចទឹកបាន
- flooded soil /flʌdɪd sɔɪl/ [n] ដីលិចទឹក (ដីរមែងទទួលទឹកជំនន់ក្នុងរយៈពេលវែង)
- fluviogenic soil /ˈfluːvɪəʊˈdʒiːnɪk sɔɪl/ [n]
  ១. សូមមើលពាក្យ៖ river deposit
  ២. (សទិសន័យ៖alluvial soil, valley filling soil) ដីល្បាប់ដែលនាំមកដោយចរន្តទឹក

- forest soil /ˈfɒrɪst sɔɪl/ [n] (សទិសន័យ៖ sylvogenic soil, woody soil, timber soil, wooded soil) ដីព្រៃ, ដីដែលកើតក្រោមព្រៃឈើ
- formerly burned soil /ˈfɔːməli bərnd sɔɪl/ [n] ដីដែលគេដុតស្មៅ ឬចំបើងធ្វើជីមុននឹងដាំ
- forzen soil /ˈfrəʊzn sɔɪl/ [n] សូមមើលពាក្យ៖ frozen earth
- fossil soil /ˈfɒs(ə)lsɔɪl/ [n] (សទិសន័យ៖ buried soil) ដីដែលកប់ទៅក្រោម, ដីផូស៊ីល
- fragmental soil /ˌfragˈmɛnt(ə)l sɔɪl/ [n] ដីបែកជាដុំៗ
- fresh soil /frɛʃ sɔɪl/ [n] ដីថ្មី
- friable soil /friable sɔɪl/ [n] សូមមើលពាក្យ៖ loose soil
- frozen crack soil /ˈfrəʊzn krak sɔɪl/ [n] ដីដែលមានក្រហែងធំៗដោយត្រជាក់ខ្លាំង
- gamma gley soil /ˈgamə gleɪ sɔɪl/ [n] (សទិសន័យ៖ deep gley soil) ដីគ្លេជាំទឹកជ្រៅ, ដីដែលស្រទាប់ជាំទឹកគ្លេនៅជ្រៅ
- gamma-gley soil /ˈgamə gleɪ sɔɪl/ [n] សូមមើលពាក្យ៖ deep-gley soil
- garden soil /ˈgɑːd(ə)n sɔɪl/ [n] ដីសួន
- garland-like soil /ˈgɑːlənd lʌɪk sɔɪl/ [n] ដីដូចជាកម្រងផ្កា
- glacial soil /ˈgleɪsɪəl sɔɪl/ [n] ដីដែលមានប្រភពពីប្រវត្តិកាលទឹកកក
- gley alluvial brown soil /gleɪ əˈl(j)uːvɪəl braʊn sɔɪl/ [n] ដីល្បាប់កំបោរត្នោតដែលមានស្រទាប់គ្លេជាំទឹកខាងក្រោម
- gley alluvial meadow soil /gleɪ əˈl(j)uːvɪəl ˈmɛdəʊ sɔɪl/ [n] ដីល្បាប់ជាំទឹកនៅកន្លែងវាលស្មៅក្នុងវាលភក់ល្បាប់
- gley clay soil /gleɪ kleɪ sɔɪl/ [n] ដីឥដ្ឋជាំទឹកជាអចិន្ត្រៃយ៍
- gley forest gray soil /gleɪ ˈfɒrɪst greɪ sɔɪl/ [n] ដីប្រភេទព្រៃប្រផេះខ្មៅដែលមានគ្លេ (ជាំទឹក)
- gley prairie soil /gleɪ ˈprɛːri sɔɪl/ [n] ដីវាលស្មៅលិចទឹក
- gley soil /gleɪ sɔɪl/ [n] ដីជាំទឹកដែលមានស្រទាប់ទឹកជ្រៅក្នុងដី
- gley-like grey forest soil [n] ដីប្រភេទព្រៃដែលមានពណ៌ប្រផេះដូចជាគ្លេ (ជាំទឹក)
- gley-like soil /gleɪ-lʌɪk sɔɪl/ [n] (សទិសន័យ៖ marbled gley-like soil) ដីដែលមានពណ៌ក្រហមច្រែះលាយនឹងខៀវ ឬខ្មៅ ជាសញ្ញាជាំទឹកម្តងៗ
- grass-covered soil /grɑːs ˈkʌvəd sɔɪl/ [n] ដីដែលមានស្មៅ ឬរុក្ខជាតិដុះគ្របពីលើ
- gravelly soil /ˈgrav(ə)li sɔɪl/ [n] ដីដែលមានកូនក្រួសច្រើន, កូនក្រួស (១.២-៧.៥ ស.ម)
- gray ferruginous soil /greɪ fɛˈruːdʒɪnəs sɔɪl/ [n] ប្រភេទដីក្នុងតំបន់ត្រូពិចដែលមានដែកអុកស៊ីត (គ្មានអាលុយមីញ៉ូម)
- gray forest soil /greɪ ˈfɒrɪst sɔɪl/ [n] (សទិសន័យ៖ gray wooded soil, steppe soil) ដីខ្មៅប្រផេះប្រភេទព្រៃ, ដីប្រផេះក្រម៉ៅនៅវាលលាយជាមួយព្រៃ
- gray wooded soil /greɪ ˈwʊdɪd sɔɪl/ [n] សូមមើលពាក្យ៖ gray forest soil
- gray-brown desert soil /greɪ braʊn dɪˈzəːt sɔɪl/ [n] ដីត្នោតប្រផេះតំបន់ក្តៅហែង
- gray-brown podzolic soil /gleɪ braʊn ˈpɒdzɒlɪk sɔɪl/ [n] (សទិសន័យ៖ grood soil, grayish brown-podzolic soil) ដីត្នោតខ្មៅអាស៊ីតប៉ូតសូលិក, ដីខ្មៅប្រផេះប្រភេទព្រៃ
- grayish brown-podzolic soil /grayish braʊn ˈpɒdzɒlɪk sɔɪl/ [n] (សទិសន័យ៖ gray-brown podzolic soil, grood soil) ដីត្នោតខ្មៅអាស៊ីតប៉ូតសូលិក, ដីខ្មៅប្រផេះប្រភេទព្រៃ
- grey desert soil /greɪ dɪˈzəːt sɔɪl/ [n] ដីប្រផេះក្រម៉ៅតំបន់ក្តៅហែង
- grey desert steppe soil /greɪ dɪˈzəːt stɛp sɔɪl/ [n] (សទិសន័យ៖ grey earth, grey soil of the semidesert) ដីខ្មៅប្រផេះ
- grey semi-dessert chalk soil [n] ដីកំបោរប្រផេះនៅកន្លែងពាក់កណ្តាលស្ងួត
- grey sodic soil /greɪ ˈsəʊdɪc sɔɪl/ [n] (សទិសន័យ៖ alkaline podzol) ដីប្រផេះខ្មៅដែលមានសូដ្យូមច្រើន

- grey soil /greɪ sɔɪl/ [n]
  ១. ដីប្រផេះ (តំបន់ស្ងួត)
  ២. (សទិសន័យ៖ steppe soil) ដីតំបន់ស្តែប, ដីខ្មៅប្រផេះ , ដីមមោកច្រើន
- grey soil of the semidesert /greɪ sɔɪl ɒv ðɪ dɪˈzəːt/ [n] (សទិសន័យ៖ grey earth, grey desert steppe soil) ដីខ្មៅប្រផេះតំបន់វាលស្តែប-ស្បៀវសែម
- grey warp soil /greɪ wɔːp sɔɪl/ [n] ដីល្បាប់ពណ៌ខ្មៅប្រផេះ (មានកំបោរខ្លះៗនៅខាងលើ)
- gritty soil /ˈgrɪti sɔɪl/ [n] ដីជាកម្ទេចថ្មតូចៗ (តូចជាង ២.៥ ម.ម)
- grood soil /gruːd sɔɪl/ [n] (សទិសន័យ៖ gray-brown podzolic soil, grayish brown-podzolic soil) ដីត្នោតខ្មៅអាស៊ីតប៉ូតសូលិក, ដីខ្មៅប្រផេះប្រភេទព្រៃ
- groundwater laterite soil /ˈgraʊn(d)wɔːtə ˈlatərʌɪt sɔɪl/ [n] ដីឡាតេរីតដែលមានស្រទាប់ទឹកក្នុងដី
- groundwater mineral soil /ˈgraʊn(d)wɔːtə ˈmɪn(ə)r(ə)l sɔɪl/ [n] ដីខនិជដែលមានស្រទាប់ទឹកខាងក្រោម
- groundwater soil /ˈgraʊn(d)wɔːtə sɔɪl/ [n] ដីជាំទឹកដែលមានស្រទាប់ទឹកជ្រៅក្នុងដី
- grove soil /grəʊv sɔɪl/ [n] ដីដែលបែងចែកជាចម្ការព័ទ្ធទៅដោយរបងលួស ឬកូនឈើ
- grumous soil /ˈgruːməs sɔɪl/ [n] ដីដែលមានទម្រង់មូលៗដូចគ្រាប់ពោត
- gumbotil [n] ដីប្រវត្តិកាលទឹកកកដែលមានស្រទាប់ក្រោមមិនជ្រាបទឹក
- gypsum crust soil /ˈdʒɪpsəm krʌst sɔɪl/ [n] ដីដែលស្រទាប់លើជាម្នាងសិលារឹង, ដីដែលជាម្នាងសិលាដែលមានស្រទាប់ក្តាំង
- halfbog soil /hɑːfbɒg sɔɪl/ [n]
  ១. (សទិសន័យ៖ marsh border soil, semi-swamp soil) មមោកជាំទឹក (មមោកលាយនឹងដីឥដ្ឋ)
  ២. ដីអាស៊ីតជាំទឹកក្នុងទំនាបបឹងដែលមានពើក
- half-gleyed clay soil /hɑːf gleɪd kleɪ sɔɪl/ [n] ដីឥដ្ឋដែលមានគ្លេ (ឥដ្ឋពណ៌ខៀវ) ពាក់កណ្តាល
- halomorphic soil /ˈheɪləʊˈmɔːfɪk sɔɪl/ [n] សូមមើលពាក្យ៖ saline soil
- heath soil /hiːθ sɔɪl/ [n] ដីខ្សាច់ដែលមានមមោកប្រភេទ ម៉រ គរច្រើនលើគ្នា
- heather soil /ˈhɛðə sɔɪl/ [n] (សទិសន័យ៖ very acid soil) ដីដែលដីអាស៊ីតខ្លាំង
- heavy clay soil /ˈhɛvi kleɪ sɔɪl/ [n] ដីឥដ្ឋដែលមានអត្រាឥដ្ឋខ្ពស់
- heavy soil /ˈhɛvi sɔɪl/ [n] ដីធ្ងន់ (ដីដែលមានបរិមាណឥដ្ឋច្រើន)
- high fertility soil /hʌɪ fəˈtɪlɪti sɔɪl/ [n] ដីដែលមានជីជាតិខ្លាំង
- high moor soil /hʌɪ mɔː sɔɪl/ [n] (សទិសន័យ៖ atmospheric swamp) ដីពើកអាស៊ីតកន្លែងខ្ពស់ (pH ៤)
- high mountain soil /hʌɪ ˈmaʊntɪn sɔɪl/ [n] ដីភ្នំខ្ពស់ៗ
- historic soil /hɪˈstɒrɪk sɔɪl/ [n] ដីជាប្រវត្តិសាស្ត្រ
- homeomorphic soil /hɒmɪəˈmɔːfɪk sɔɪl/ [n] សូមមើលពាក្យ៖ ferrimorphic soil
- humic latosol [n]
  ១. (សទិសន័យ៖ brown lateritic soil) ដីឡាតេរីតសម្បុរត្នោត
  ២. ដីក្រហមឡាតេរីត
- humic soil /ˈhjuːmɪk sɔɪl/ [n] ដីមមោក (ដី ដែលកើតមកពីមមោក)
- humic-gley soil /ˈhjuːmɪk gleɪ sɔɪl/ [n] (សទិសន័យ ៖ mucky soil) ដីមមោកជាំទឹក
- humid soil /ˈhjuːmɪd sɔɪl/ [n] (សទិសន័យ៖ moist soil) ដីសើម
- humo-calcareous soil /ˈhjuːməʊ kalˈkɛːrɪəs sɔɪl/ [n] ដីកំបោរប្រភេទរេនហ្សីន
- humus calcareous peaty soil /ˈhjuːməs kalˈkɛːrɪəs ˈpiːti sɔɪl/ [n] ដីកាបូណាតដែលមានមមោកជាពើក (កន្លែងជាំទឹក)
- humus enriched lateritic soil /ˈhjuːməs ɪnˈrɪtʃd latəˈrɪtɪk sɔɪl/ [n] (សទិសន័យ៖ melanized lateritic soil) ដីឡាតេរីតមានមមោកច្រើន

- humus incorporated soil /ˈhjuːməs ɪnˈkɔːpəreɪtɪd sɔɪl/ [n] (សទិសន័យ៖ melanized soil, black earth of forest) ដីខ្មៅដែលមានមមោកច្រើននៅតំបន់ព្រៃ
- humus silicate soil /ˈhjuːməs ˈsɪlɪkeɪt sɔɪl/ [n] ដីមមោកដែលជាដីធម្មតា (គ្មានកំបោរ)
- humus sulphate soil /ˈhjuːməs ˈsʌlfeɪt sɔɪl/ [n] (សទិសន័យ៖ rendzina on gypsum) ដីរេនហ្ស៊ីនកើតមកពីថ្មម្នាងសិលា
- hydrogen soil /ˈhʌɪdrədʒ(ə)n sɔɪl/ [n] (សទិសន័យ៖ hydromorphic soil, waterlogged soil) ដីជាំទឹ
- hydro-halogenic soil /ˈhʌɪdrəʊ haləˈdʒɛnɪk sɔɪl/ [n] សូមមើលពាក្យ៖ saline soil
- hydromorphic soil /ˌhaɪdrəˈmɔːfɪk sɔɪl/ [n] សូមមើលពាក្យ៖ hydrogen soil
- idiomorphic soil [n] សូមមើលពាក្យ៖ automorphic soil
- illuvial soil /ɪˌl(j)uːvɪˈeɪl sɔɪl/ [n] ស្រទាប់ដីដែលឥដ្ឋច្រោះពីលើទៅកកខាងក្រោម
- immature soil /ˌɪməˈtjʊə sɔɪl/ [n]
  ១. (សទិសន័យ៖ embryonic soilprimitive soil, cryptogenic soil) ដីខ្ចីដែលទើបតែចាប់កំណើត
  ២. (សទិសន័យ៖ imperfectly developed soil) ដីមិនទាន់ចាស់
- imperfectly developed soil /ɪmˈpəːfɪktli dɪˈvɛləpt sɔɪl/ [n] (សទិសន័យ៖ immature soil) ដីមិនទាន់ចាស់
- intensely podzolised soil /ɪnˈtɛnsɛli ˈpɒdzɒlʌɪzd sɔɪl/ [n] ដីដែលអាស៊ីតខ្លាំង ដូចជាប៉ូតសូល
- intermittent water-table soil /ɪntəˈmɪt(ə)nt ˈwɔdər ˈteɪbəl sɔɪl/ [n] ដីដែលខាងក្នុងជាំទឹកម្តងៗ ជាពិសេសនៅរដូវភ្លៀង ហើយគោកទៅវិញនៅរដូវប្រាំង
- intrazonal soil /ɪntrəˈzəʊn(ə)l sɔɪl/ [n] ដីចាស់ដែលទទួលការវិវត្តខុសពីធាតុអាកាសតំបន់
- iron lateritic soil /ˈʌɪən latəˈrɪtɪk sɔɪl/ [n] ដីក្រហមឡាតេរីត (គ្រួសដែកក្រៀនច្រើន)
- lake chalk raw soil /leɪk tʃɔːk rɔː sɔɪl/ [n] ដីខ្ចីថ្មកំបោរបាតបឹង
- late soil /leɪt sɔɪl/ [n] តំបន់ត្រជាក់ដែលកម្តៅឡើងយឺតពេក
- laterite soil /ˈlatərʌɪt sɔɪl/ [n] ដីឡាតេរីត, ដីក្រហមដោយសារជាតុអុកស៊ីតដែក (ឧ. ដីក្រហមខេត្តកំពង់ចាម)
- lateritic soil /latəˈrɪtɪk sɔɪl/ [n] (សទិសន័យ៖ red lateritic loam) ដីឡាតេរីត, ដីក្រហមនៅតំបន់ត្រូពិច
- lawn soil /lɔːn sɔɪl/ [n] ដីនៅក្រោមកម្រាលស្មៅ ឬស្លាប់ស្មៅ
- leached alkali soil /liːtʃt ˈalkəlʌɪ sɔɪl/ [n] ដីប្រៃលាងច្រោះអាល់កាលី (pH>៨.៥)
- leached forest soil /liːtʃt ˈfɒrɪst sɔɪl/ [n] ដីប្រភេទព្រៃ "លាងច្រោះ" (ឥដ្ឋចល័តទៅស្រទាប់ក្រោម)
- lean soil /liːn sɔɪl/ [n] (សទិសន័យ៖ unproductive soil) ដីខ្សត់, ដីក្រ
- light calcareous soil /lʌɪt kalˈkɛːrɪəs sɔɪl/ [n] ដីដែលមានកាបូណាតសម្បុរថ្លា
- light soil /lʌɪt sɔɪl/ [n] ដីស្រាល (ប្រភេទដីដែលមានសាច់ដីគ្រើម ដូចជាដីខ្សាច់), ដីដែលមានទម្រង់ល្អ ឬផុស
- light-colored soil /lʌɪt ˈkʌləd sɔɪl/ [n] ដីសម្បុរថ្លា (ដោយមមោកមានតិច)
- lithochromic soil /ˈlʌɪθəʊˈkrəʊmɪk sɔɪl/ [n] សូមមើលពាក្យ៖ lithochromic earth
- lithogenic soil /lɪˈθɒˈdʒiːnɪk sɔɪl/ [n] សូមមើលពាក្យ ៖ lithosolic soil
- lithosolic soil /ˈlɪθəʊˈsəʊlɪk sɔɪl/ [n] (សទិសន័យ៖ lithogenic soil) ដីរាក់ដែលមានថ្មច្រើនតាំងពីស្រទាប់លើទៅក្រោម
- loess soil /ˈləʊɪssɔɪl/ [n] សូមមើលពាក្យ៖ loess
- loose soil /luːs sɔɪl/ [n] (សទិសន័យ៖ non coherent soil, friable soil) ដីធូរ, ដីផុស, ដីដែលគ្រាប់មិនជាប់គ្នា
- low fertility soil /ləʊ fəˈtɪlɪti sɔɪl/ [n] ដីដែលមានជីជាតិតិច
- low moor soil /ləʊ mɔː sɔɪl/ [n] សូមមើលពាក្យ៖ fen peat soil
- low-humic gley soil /ləʊ ˈhjuːmɪk gleɪ sɔɪl/ [n] ដីជាំទឹកប្រភេទគ្លេដែលមានមមោកតិច
- mallow soil /ˈmaləʊ sɔɪl/ [n] (សទិសន័យ៖ mould) ដីធូរ ឬផុស
- mangrove soil /ˈmaŋgrəʊv sɔɪl/ [n] ដីប្រៃភក់សមុទ្រក្រោមព្រៃកោងកាង

- man-made soil /man-meɪd sɔɪl/ [n] សូមមើលពាក្យ៖ anthropic soil
- marbled gley-like soil /ˈmɑːb(ə)ld gleɪ-lʌɪk sɔɪl/ [n] សូមមើលពាក្យ៖ gley-like soil
- marbled soil /ˈmɑːb(ə)ld sɔɪl/ [n] ដីដែលមានពណ៌ប្រតេកប្រតាកក្រហមច្រេះខៀវក្រម៉ៅ (ស្រទាប់ក្រោម)
- marl soil /mɑːl sɔɪl/ [n] ដីឥដ្ឋដែលមានកំបោរ (៥-២០% កំបោរកាល់ស្យូមកាបូណាត)
- mature soil /məˈtʃʊə sɔɪl/ [n] ដីចាស់
- meadow bog soil /ˈmɛdəʊ bɒg sɔɪl/ [n]
  ១. (សទិសន័យ៖ silty bog, meadow-land soil) ដីវាលភក់ខ្មៅ (ដោយមមោកច្រើនហើយរលួយ)
  ២. ដីវាលស្មៅក្នុងវាលភក់ល្បាប់ (ទំនាបបឹង)
- meadow soil /ˈmɛdəʊsɔɪl/ [n]
  ១. ដីល្បាប់ដែលនៅក្រោមវាលស្មៅ
  ២. សូមមើលពាក្យ៖ riverside soil
- meadow-land soil /ˈmɛdəʊ land sɔɪl/ [n] សូមមើលពាក្យ៖ meadow bog soil
- meadow-podzolic soil /ˈmɛdəʊ ˈpɒdzɒlic sɔɪl/ [n] ដីលាងច្រោះតំបន់វាលស្មៅ
- medium fertility soil /ˈmiːdɪəm fəˈtɪlɪti sɔɪl/ [n] ដីដែលមានជីជាតិមធ្យម
- medium moor soil /ˈmiːdɪəm mɔː sɔɪl/ [n] ដីពាក់កណ្ដាលពើក (ជាំទឹក ឬគ្មានជាំទឹក)
- melanized lateritic soil [n] (សទិសន័យ៖ humus enriched lateritic soil) ដីឡាតេរីតដែលមានមមោកច្រើន
- melanized soil /ˈmɛlənʌɪzd sɔɪl/ [n]
  ១. (សទិសន័យ៖ black earth of forest, humus incorporated soil) ដីខ្មៅដែលមានមមោកច្រើននៅតំបន់ព្រៃ
  ២. សូមមើលពាក្យ៖ muck
  ៣. សូមមើលពាក្យ៖ dark humus soil
- mixed soil /mɪkst sɔɪl/ [n] ដីលាយគ្នា
- moderately leached soil /ˈmɒd(ə)rətli liːtʃt sɔɪl/ [n] ដីលាងច្រោះជាមធ្យម
- moderately weathered soil /ˈmɒd(ə)rətli ˈwɛðəd sɔɪl/ [n] (សទិសន័យ៖ weakly leached soil) ដីទើបតែរិវត្ត, ដីខ្ចី
- moist soil /mɔɪst sɔɪl/ [n] សូមមើលពាក្យ៖ humid soil
- monder gley soil /ˈmɒndə gleɪ sɔɪl/ [n] ដីជាំទឹកខ្លាំងដែលមមោកជាប្រភេទម៉ូដែរ
- mosaic soil /mə(ʊ)ˈzeɪɪksɔɪl/ [n] ដីជាក្រឡាចត្រង្គ
- mountain forest soil /ˈmaʊntɪn ˈfɒrɪst sɔɪl/ [n] ដីតំបន់ភ្នំដែលមានលក្ខណៈព្រៃ
- mountain meadow soil /ˈmaʊntɪn ˈmɛdəʊ sɔɪl/ [n] (សទិសន័យ៖ mountain peaty soil, peaty alpine meadow soil) ដីពើកតំបន់ភ្នំ, ដីវាលស្មៅដុះនៅលើពើកលើភ្នំតំបន់ត្រជាក់
- mountain peaty soil /ˈmaʊntɪn ˈpiːti sɔɪl/ [n] សូមមើលពាក្យ៖ mountain meadow soil
- mountain soil /ˈmaʊntɪnsɔɪl/ [n] ដីភ្នំ
- mountain steppe soil /ˈmaʊntɪn stɛp sɔɪl/ [n] ដីស្ដេប (steppe) ក្នុងតំបន់ភ្នំ
- muck soil /mʌk sɔɪl/ [n] ដីរលួយ, ដីជ្រាំ (ប្រភេទដីដែលសរីរាង្គរលួយសព្វល្អ)
- muck warp soil /mʌk wɔːp sɔɪl/ [n] សូមមើលពាក្យ៖ muck
- mucky soil /ˈmʌki sɔɪl/ [n] (សទិសន័យ៖ humic-gley soil) ដីមមោកជាំទឹក
- mud soil /mʌd sɔɪl/ [n] (សទិសន័យ៖ muddy soil) ដីភក់
- muddy soil /ˈmʌdi sɔɪl/ [n] សូមមើលពាក្យ៖ mud soil
- neutral soil /ˈnjuːtr(ə)l sɔɪl/ [n] (សទិសន័យ៖ sweet soil) ដីណឺត (ដីដែលស្រទាប់លើរបស់វាយ៉ាងហោចណាស់ក៏មានជម្រៅមួយផាលនង្គ័លដែរ ហើយមិនមែនជាដីអាស៊ីត និងមិនមែនជាដីអាល់កាឡាំង។ ក្នុងការអនុវត្តន៍ជាក់ស្ដែង ដីណឺតជាដីមាន pH ពី ៦.៦ ទៅ ៧.៤)
- new land soil /njuː land sɔɪl/ [n] ដីទំនាបថ្មីនៅតាមឆ្នេរសមុទ្រ, ប៉ុលដែរ
- nival snow basin soil /ˈnʌɪv(ə)l snəʊ ˈbeɪs(ə)n sɔɪl/ [n] ដីទំនាបអាងដែលកើតដោយព្រិល
- non coherent soil /nɒn kə(ʊ)ˈhɪər(ə)nt sɔɪl/ [n] សូមមើលពាក្យ៖ loose soil
- normal soil /normal sɔɪl/ [n] ដីដែលវិវត្តធម្មតា

- now cultivated soil /naʊ ˈkʌltɪveɪtɪd sɔɪl/ [n] ដីដែលគេដុតស្មៅ ឬចំបើងធ្វើជីមុននឹងដាំ
- oligotrophic moor soil /ˌɒlɪgə(ʊ)ˈtrəʊfɪk mɔː sɔɪl/ [n] ដីទំនាបបឹងដែលមានមមោកអាស៊ីតប្រភេទម័រ
- orange soil /ˈɒrɪn(d)ʒ sɔɪl/ [n] ដីលឿងទុំ
- organic soil /ɔːˈganɪk sɔɪl/ [n]
  ១. ដីសរីរាង្គ (ដីដែលមានភាគរយនៃសារធាតុសរីរាង្គខ្ពស់ជាង ១៥ % ទៅ ២០% នៅក្នុងទម្រង់ជាស្រទាប់ A និង B លាយចូលគ្នា)
  ២. (សទិសន័យ៖ melanized soil, black top soil, muck) ដីដែលមានមមោកច្រើន (លើសពី៥%) , ដីក្រម៉ៅដោយមមោក
  ៣. (សទិសន័យ៖ cumulose soil) ដីដែលសរីរាង្គនៅគរបន្តបន្ទាប់គ្នា (លើសពី ២០%)
- organic wet soil /ɔːˈganɪk wɛt sɔɪl/ [n] (សទិសន័យ៖ bog soil) ដីសើមដែលមានសរីរាង្គច្រើន (ឧ. ពើក)
- paddy soil /ˈpadi sɔɪl/ [n] ដីស្រែ
- pan soil /pan sɔɪl/ [n] ដីដែលស្រទាប់កកអាចឃើញច្បាស់ (ឧ. ឥដ្ឋ កំបោរជាដើម)
- past mature soil /pɑːst məˈtʃʊə sɔɪl/ [n] សូមមើលពាក្យ៖ aged soil
- paved soil /peɪvd sɔɪl/ [n] ដីដែលមានដុំថ្មច្រើន, ដីដែលស្រទាប់លើក្រាលទៅដោយដុំថ្ម
- peat bog soil /piːt bɒg sɔɪl/ [n] ដីទំនាបដែលមានពើក (គំនរសរីរាង្គដែលមិនរលួយ)
- peat gley soil /piːt gleɪ sɔɪl/ [n] សូមមើលពាក្យ៖ muck
- peat soil /piːt sɔɪl/ [n] ដីសរីរាង្គ, ដីពើក, ដីភីត, ដីមមោក (ដីកើតពីការពុកផុយនៃសារធាតុសរីរាង្គ)
- peat-gley soil /piːtgleɪ sɔɪl/ [n] ដីពើកជាំទឹកខ្លាំង
- peaty alpine meadow soil /ˈpiːti ˈalpʌɪn ˈmɛdəʊ sɔɪl/ [n] សូមមើលពាក្យ៖ mountain meadow soil
- peaty meadow soil /ˈpiːti ˈmɛdəʊ sɔɪl/ [n] ដីពើកតំបន់វាលស្មៅ
- peaty soil /ˈpiːti sɔɪl/ [n] សូមមើលពាក្យ៖ bog soil
- permanently frozen soil /ˈpəːm(ə)nəntli ˈfrəʊzn sɔɪl/ [n] សូមមើលពាក្យ៖ permafrost
- permeable soil /ˈpəːmɪəb(ə)l sɔɪl/ [n] ដីជ្រាបទឹក, ដីជម្រាប
- persistant water-table soil [n] ដីដែលខាងក្នុងមានស្រទាប់ជាំទឹកស្ថិតនៅជាអចិន្ត្រៃយ៍
- phytogenic soil /ˈfʌɪtəʊˈdʒiːnɪk sɔɪl/ [n] សូមមើលពាក្យ៖ phytomorphic soil
- phytomorphic soil /ˈfʌɪtəʊˈmɔːfɪk sɔɪl/ [n] (សទិសន័យ៖ phytogenic soil, phytomorphic soil) ដីរុក្ខជាតិ, ដីដែលកើតពីរុក្ខជាតិ
- pink soil /pɪŋk sɔɪl/ [n] ដីពណ៌ក្រហមកូឡាប (ឥដ្ឋកំបោរ)
- plastic soil /ˈplastɪk sɔɪl/ [n] (សទិសន័យ៖ silicate soil) ដីដែលមានឥដ្ឋ (គ្មានកំបោរ) អាចប៉ាន់ជារូបផ្សេងៗបាន, ដីយឺត (ប្រភេទដីដែលមានទម្រង់រួសដូចកៅស៊ូ)
- plinthic soil [n] ដីផ្លីនតូស៊ុល (ដីដែលមានសារធាតុ petroplinthic នៅកម្រាស់ ៥០ ស.ម ពីផ្ទៃស្រទាប់លើដី)
- podzolic soil /ˈpɒdzɒlɪk sɔɪl/ [n] សូមមើលពាក្យ៖ strongly leached soil
- podzolised lateritic soil /ˈpɒdzɒlʌɪzd latəˈrɪtɪk sɔɪl/ [n] ដីឡាតេរីតអាស៊ីតខ្លាំងដែលវិវត្តទៅរកប៉ូតសូល
- podzolised soil /pɒdzɒlʌsd sɔɪl/ [n] សូមមើលពាក្យ៖ brown podzolic soil
- podzolized red soil /pɒdzɒlʌɪzd rɛd sɔɪl/ [n] (សទិសន័យ៖ red podzolic soil) ដីក្រហមលាងច្រោះ (តំបន់ត្រូពិច), ដីក្រហមអាស៊ីតប៉ូតសូលិក (ដីអាស៊ីតខ្លាំង)
- podzolized soil /ˈpɒdzɒlʌɪzd sɔɪl/ [n] ដីអាស៊ីតខ្លាំងដែលមានប្រតិកម្មដូចប៉ូតសូល
- polar soil /ˈpəʊlə sɔɪl/ [n] ដីតំបន់ត្រជាក់ប៉ូល (ផ្ទៃផែនដី)
- polygenetic soil /ˌpɒlɪdʒɪˈnɛtɪksɔɪl/ [n] សូមមើលពាក្យ៖ complex soil
- polygonal fissure soil /pəˈlɪg(ə)n(ə)l ˈfɪʃə sɔɪl/ [n] សូមមើលពាក្យ៖ facetted soil
- poorly drained soil /ˈpɔːli dreɪnd sɔɪl/ [n] (សទិសន័យ៖ soil with impeded drainage) ដីដែលទឹកជ្រាបមិនល្អ ឬស្រោះទឹកមិនល្អ
- porous soil /ˈpɔːrəs sɔɪl/ [n] ដីដែលសម្បូរទៅដោយរន្ធខ្យល់

- prairie alkaline soil /ˈprɛːri ˈalkəlʌɪn sɔɪl/ [n] ដីអាល់កាឡាំងក្រោមវាលស្មៅ
- prairie gray soil /ˈprɛːri greɪ sɔɪl/ [n] ដីខ្មៅប្រផេះតំបន់វាលស្មៅ
- prairie saline soil /ˈprɛːri ˈseɪlʌɪn sɔɪl/ [n] ដីប្រៃតំបន់វាលស្មៅ
- prairie soil /ˈprɛːri sɔɪl/ [n] សូមមើលពាក្យ៖ grood soil
- prairie steppe brown soil /ˈprɛːri stɛp braʊn sɔɪl/ [n] ដីប្រង នៅក្នុងតំបន់វាលស្មៅ
- prairie-forest soil /ˈprɛːri ˈfɒrɪst sɔɪl/ [n] (សទិសន័យ៖ degraded black-earth soil) ដីវាលស្មៅដែលឈើព្រៃដុះជាមួយ
- primary soil /ˈprʌɪm(ə)ri sɔɪl/ [n] (សទិសន័យ៖ autochton soil, sedentary soil) ដីដើម, ដីនៅនឹងកន្លែង , ដីដែលគ្មានចល័តទៅណា
- primitive soil /ˈprɪmɪtɪv sɔɪl/ [n] សូមមើលពាក្យ៖ immature soil
- puddle soil /ˈpʌd(ə)l sɔɪl/ [n] (សទិសន័យ៖ soil of low aggregate stability) ដីដែលមានស្ថិរភាពទម្រង់មិនល្អ, ដីដែលទម្រង់អាចបែកយ៉ាងងាយ (ធ្វើឱ្យដីឆាប់ហាប់), ដីម៉ដ្ឋ
- purely mineral soil /ˈpjʊəli ˈmɪn(ə)r(ə)l sɔɪl/ [n] ដីខនិជ (ផ្នែកខនិជនៃដី)
- raw gley soil /rɔː gleɪ sɔɪl/ [n] ដីខ្ញីជាំទឹក
- raw humus forest soil /rɔːˈhjuːməsˈfɒrɪst sɔɪl/ [n] ដីព្រៃដែលស្រទាប់លើជាពើកស្ងួត (មមោកមិនរលួយ)
- raw organic soil /rɔː ɔːˈganɪk sɔɪl/ [n] (សទិសន័យ៖ turfy soil) ដីសរីរាង្គឆៅ ឬដុល (ដែលមិនទាន់រលួយ)
- raw soil /rɔː sɔɪl/ [n] ដីដែលជាកម្ទេចវត្ថុធាតុដើម (មិនទាន់វិវត្តន៍)
- raw warp soil /rɔːwɔːpsɔɪl/ [n] ដីល្បាប់ឆៅ, ល្បាប់ថ្មី, ល្បាប់ខ្ចី (ល្បាប់ដែលនាំមកដោយការបញ្ចូលទឹកទន្លេជាច្រើនស្រទាប់ជាន់លើគ្នា)
- recent soil /ˈriːs(ə)ntsɔɪl/ [n] ដីបច្ចុប្បន្ន (ដែលកំពុងតែវិវត្ត)
- red dessert soil /rɛd dɪˈzəːt sɔɪl/ [n] ដីក្រហមក្នុងតំបន់រហោឋានស្ងួត
- red podzolic soil /rɛd pɒdzɒlic sɔɪl/ [n] សូមមើលពាក្យ៖ podzolized red soil
- red warp soil /rɛd wɔːp sɔɪl/ [n] ដីល្បាប់ក្រហម
- reddish chestnut soil /rɛdɪʃ ˈtʃɛsnʌt sɔɪl/ [n] ដីសម្បុរត្នោតថ្មលាដែលឡើងក្រហម
- reddish prairie soil /rɛddɪʃ ˈprɛːri sɔɪl/ [n] ដីក្រហមក្រោមវាលស្មៅស្ងួត
- reddish woody soil /rɛdɪʃ ˈwʊdi sɔɪl/ [n] ដីប្រភេទព្រៃពណ៌ក្រហម (ដោយទឹកជ្រាបល្អ)
- reddish-brown lateritic soil /rɛdɪʃ braʊn latəˈrɪtɪk sɔɪl/ [n] ដីឡាតេរីត សម្បុរត្នោត-ក្រហម
- red-yellow podzolic soil /rɛdˈ jɛləʊ ˈpɒdzɒlɪk sɔɪl/ [n] ដីប៉ូតសូលិកលឿង-ក្រហម (ដោយសារធាតុដែក)
- relic soil /ˈrɛlɪk sɔɪl/ [n] សូមមើលពាក្យ៖ relict soil
- relict soil /ˈrɛlɪkt sɔɪl/ [n] (សទិសន័យ៖ relic soil) ដីសំណល់ដែលជាកេរ្តិ៍ដំណែល (ដែលបាត់រលាយទៅហើយ)
- rendzina soil /rɛn(d)ˈziːnə sɔɪl/ [n] ដីកំបោរដែលមានក្រួសច្រើន
- rendziniform soil /rɛndzɪnnɪˈfɔːm sɔɪl/ [n] ដីដែលមានរូបភាពដូចជាដីប្រភេទរ៉េហ្សីន
- residual soil /rɪˈzɪdjʊəl sɔɪl/ [n] សម្ភារសំណល់ (ដែលនៅសល់ក្នុងស្រទាប់លើ)
- rhomboid soil /ˈrɒmbɔɪd sɔɪl/ [n] សូមមើលពាក្យ៖ facetted soil
- rich soil /rɪtʃ sɔɪl/ [n] ដីមានជីជាតិ
- river marsh soil /ˈrɪvə mɑːʃ sɔɪl/ [n] សូមមើលពាក្យ៖ muck
- riverside soil /ˈrɪvəsʌɪd sɔɪl/ [n] (សទិសន័យ៖ warp soil, meadow soil, alluvial meadow soil) ដីនៅតាមមាត់ស្ទឹង (ដីសើម វាលស្មៅ), ដីល្បាប់ដែលកើតពីការបង្ហូរចូលនៃទឹកទន្លេនៅលើដីចាស់
- rock outcrop soil /rɒk ˈaʊtkrɒp sɔɪl/ [n] សូមមើលពាក្យ៖ mantle rock
- rocky debris soil /ˈrɒki ˈdɛbriː sɔɪl/ [n] ដីដែលមានកម្ទេចថ្មច្រើន
- rust spot forest soil /rʌst spɒt ˈfɒrɪst sɔɪl/ [n] ដីប្រភេទព្រៃដែលមានស្នាមច្រែះ
- rusty soil /ˈrʌsti sɔɪl/ [n] ដីពណ៌ច្រែះ (ដីព្រៃ)

- saline clay soil /ˈseɪlʌɪn kleɪ sɔɪl/ [n] ដីឥដ្ឋប្រៃ (មានអំបិល)
- saline peaty soil /ˈseɪlʌɪn ˈpiːti sɔɪl/ [n] (សទិសន័យ៖ saline turfy soil) ដីប្រៃដែលមានសរីរាង្គច្រើន
- saline soil /ˈseɪlʌɪn sɔɪl/ [n] (សទិសន័យ៖ alkali soil, halomorphic soil, hydro-halogenic soil) ដីប្រៃអាល់កាលី (pH ខ្ពស់ជាង ៨.៥ ឬអំបិលអាល់កាលីច្រើន)
- saline turfy soil /ˈseɪlʌɪn ˈtəːfi sɔɪl/ [n] សូមមើលពាក្យ៖ saline peaty soil
- saline-sodic soil /ˈseɪlʌɪn ˈsəʊdɪk sɔɪl/ [n] ដីបាសប្រៃ (ដីមានជាតិបាស និងអំបិល ដែលក្នុងនោះមានបម្លាស់ប្តូរសូដ្យូមគ្រប់គ្រាន់ ក្នុងការបង្អាក់ការលូតលាស់នៃដំណាំភាគច្រើនដោយបណ្តាលមកពីមានបរិមាណដ៏ច្រើននៃអំបិលរលាយនៅក្នុងដីនោះ)
- salt crust soil /sɔːlt krʌst sɔɪl/ [n] ដីដែលស្រទាប់រឹងខាងលើប្រៃ
- salt soil /sɔːlt sɔɪl/ [n] (សទិសន័យ៖ salt earth) ដីប្រៃ
- salted soil /sɔːltid sɔɪl/ [n] ដីប្រៃ (នៅមាត់សមុទ្រ ឬវាលក្តៅ រហោឋាន)
- sand desert soil /sand dɪˈzəːt sɔɪl/ [n] ខ្សាច់បាតជ្រលង ឬផ្នូកភ្នំខ្សាច់ ក្នុងតំបន់ក្តៅហែង
- sandy soil [n]
  ១. ដីដែលមានវាយនភាពខ្សាច់ (ឥដ្ឋតិចជាង ១០%)
  ២. (សទិសន័យ៖ siliceous soil) ដីខ្សាច់ (ដែលជាជាតិស៊ីលីស)
- saturated soil /ˈsatʃəreɪtɪd sɔɪl/ [n] ដីជាំទឹក
- savanna red soil /səˈvanə rɛd sɔɪl/ [n] ដីក្រហមក្រោមវាលស្មៅ សាវ៉ាន់
- sea-marsh soil /siː mɑːʃ sɔɪl/ [n] (សទិសន័យ៖ coastal marsh soil) ដីសើមទំនាបតាមបណ្តោយឆ្នេរ
- secondary soil /ˈsɛk(ə)nd(ə)ri sɔɪl / [n] សូមមើលពាក្យ៖ transported soil
- sedentary detrital soil /ˈsɛd(ə)nt(ə)ri dɪˈtrʌɪt(ə)l sɔɪl/ [n] ដីដែលកើតពីកម្ទេចកំទីដែលមានប្រភពនៅនឹងកន្លែង
- sedentary soil /ˈsɛd(ə)nt(ə)ri sɔɪl/ [n] សូមមើលពាក្យ៖ primary soil
- self-mutching soil /sɛlfˈmatʃɪŋsɔɪl/ [n] ដីដែលមានទម្រង់ល្អក្នុងស្រទាប់ខាងលើអាចធ្វើឱ្យដីធន់នឹងទឹកហូរច្រោះ
- semi-arid soil /ˈsɛmi ˈarɪd sɔɪl/ [n] ដីពាក់កណ្តាលស្ងួត (ភ្លៀងប្រចាំឆ្នាំ ២០០ - ៤០០ ម.ម)
- semi-mature soil /ˈsɛmi məˈtʃʊə sɔɪl/ [n] ដី (ជំទង់)
- semi-swamp soil /ˈsɛmi swɒmp sɔɪl/ [n] (សទិសន័យ៖ marsh border soil) មមោកជាំទឹក (មមោកលាយនឹងដីឥដ្ឋ)
- semi-terrestrial soil /ˈsɛmi-təˈrɛstrɪəl sɔɪl/ [n] ដីជាំទឹក
- sewage field soil /ˈsuːɪdʒ fiːld sɔɪl/ [n] ដីចម្ការដែលទទួលការបាចរាយទឹកសម្អុយ (សម្រាប់ធ្វើជាជី)
- shallow soil /ˈʃaləʊ sɔɪl/ [n] ដីរាក់
- shallow-gley soil /ˈʃaləʊgleɪ sɔɪl/ [n] (សទិសន័យ៖ alpha-gley soil) ដីដែលស្រទាប់ជាំទឹកគ្លេនៅរាក់ខាងលើ
- shifting soil /ˈʃɪftɪŋ sɔɪl/ [n] (សទិសន័យ៖ unfixed soil, unstable soil) ដីចល័ត, ដីដែលមិនជាប់នឹងកន្លែង, ដីគ្មានស្ថិរភាព
- silicate raw soil /ˈsɪlɪkeɪt rɔː sɔɪl/ [n] ដីខ្ចីដែលជាសម្ភារស៊ីលីកាត (គ្មានកំបោរ), ដីខ្ចីធម្មតា (ដែលមិនមែនជាដីកំបោរ)
- silicate soil /ˈsɪlɪkeɪt sɔɪl/ [n] សូមមើលពាក្យ៖ plastic soil
- siliceous soil /sɪˈlɪʃəs sɔɪl/ [n] (សទិសន័យ៖ sandy soil) ដីខ្សាច់ (ដែលជាជាតិស៊ីលីស)
- silty gravel soil /ˈsɪlti ˈgrav(ə)l sɔɪl/ [n] ដីល្បាយដែលមានក្រួស
- silty meadow soil /ˈsɪlti ˈmɛdəʊ sɔɪl/ [n] ដីល្បាយតំបន់វាលស្មៅសើម, ដីវាលភក់ល្បាប់មានស្មៅដុះច្រើន
- skeletal soil /ˈskɛlɪt(ə)l sɔɪl/ [n] ដីខ្ចីស្តើង (កម្រាស់ < ៣០ស.ម) ហើយក្រួសច្រើន
- slippery soil /ˈslɪp(ə)ri sɔɪl/ [n] ដីរអិល
- slope foot soil /sləʊp fʊt sɔɪl/ [n] ដីនៅជើងជម្រាល
- slope gley soil /sləʊp gleɪ sɔɪl/ [n] ដីគ្លេជាំទឹកលើជម្រាល
- slope silty colluvial soil /sləʊp ˈsɪlti kəˈl(j)uːvɪəl sɔɪl/ [n] ដីឡើស ធេចរឹលនៅលើជម្រាល

- slope soil /sləʊp sɔɪl/ [n] ដីលើជម្រាល
- sod forest soil /sɒd ˈfɒrɪst sɔɪl/ [n] ដីព្រៃតំបន់ភ្នំដែលមានស្មៅ
- soda soil /ˈsəʊdə sɔɪl/ [n] ដីប្រៃសាឡាំងដែលមានសូដ្យូមកាបូណាត
- sodic soil /ˈsəʊdɪk sɔɪl/ [n] ដីបាស, ដីមានសូដ្យូម ១៥ ភាគរយ (អាចដោះដូរបាន និងលើសពី ៥០ ភាគរយនៃសូល្យូម និងម៉ាញេស្យូមនៅកម្រិត ៥០ ស.ម ពីផ្ទៃដី)
- sodium carbonate soil /ˈsəʊdɪəm ˈkɑːbəneɪt sɔɪl/ [n] ដីដែលសម្បូរទៅដោយសូដ្យូមកាបូណាត, ដីប្រៃអាល់កាលីខ្មៅ
- sodium soil /ˈsəʊdɪəm sɔɪl/ [n] ដីដែលមានសារធាតុសូដ្យូមច្រើន
- soil of low aggregate stability /sɔɪl ɒv ləʊ ˈagrɪgət stəˈbɪlɪti/ [n] សូមមើលពាក្យ៖ puddle soil
- soil with impeded drainage [n] សូមមើលពាក្យ៖ poorly drained soil
- solodic soil [n] (សទិសន័យ៖ solod-like soil) ដីដែលមានរូបភាពប្រហ្វីលដូចសូឡូត
- solod-like meadow soil [n] ដីដែលមានរូបភាពដូចសូឡូតនៅតំបន់វាលស្មៅជាំទឹក
- step soil /stɛp sɔɪl/ [n] ដីដែលចាត់ចែងជាថ្នាក់ៗ
- steppe soil /stɛpsɔɪl/ [n]
  ១. សូមមើលពាក្យ៖ gray forest soil
  ២. សូមមើលពាក្យ៖ grey soil
- stesomorphic soil /ˈstɛnəʊˈmɔːfɪk sɔɪl/ [n] ដីដែលការវិវត្ត៍ត្រូវឈប់ ឬស្ទះ
- stiff soil /stɪf sɔɪl/ [n] សូមមើលពាក្យ៖ heavy loam
- stiped soil /stʌɪpt sɔɪl/ [n] ដីដែលមានឆ្នូត (ដីតំបន់ត្រជាក់)
- stony soil /ˈstəʊni sɔɪl/ [n] (សទិសន័យ៖ cobbly soil) ដីខ្ចីថ្មច្រើនដែលទើបតែវិវត្ត
- stream bottom soil /striːm ˈbɒtəm sɔɪl/ [n] ដីល្បាប់
- striated soil /strʌɪˈeɪtɪd sɔɪl/ [n] សូមមើលពាក្យ៖ earth stripe
- strongly humic soil /strɒŋli ˈhjuːmɪk sɔɪl/ [n] ដីដែលមានមមោកច្រើន (១០-២០%)
- strongly leached soil /strɒŋli liːtʃt sɔɪl/ [n] (សទិសន័យ៖ podzolic soil) ដីដែលមានបាតុភូតលាងច្រោះខ្លាំង (ឥដ្ឋចល័តពីស្រទាប់លើចុះក្រោមខ្លាំង)
- structureless saline soil /ˈstrʌktʃ(ə)ləs seɪlʌɪn sɔɪl/ [n] (សទិសន័យ៖ white alkali soil) ដីប្រៃប្រភេទសូឡុងឆាកដែលមានផ្កាអំបិលសពីលើ (ជាពិសេសអំបិលក្លរួ និងស៊ុលហ្វាត), ដីប្រៃអាល់កាលី (ពណ៌) ស
- subaqueous raw soil /sʌbˈeɪkwɪəs rɔː sɔɪl/ [n] ដីខ្ចីលិចទឹក
- subaqueous soil /sʌbˈeɪkwɪəs sɔɪl/ [n] (សទិសន័យ៖ underwater soil) ដីនៅពីក្រោមទឹក, ដីលិចទឹក
- submerge soil /səbˈməːdʒ sɔɪl/ [n] ដីពន្លិចទឹក
- subsoil /ˈsʌbsɔɪl/ [n] សូមមើលពាក្យ៖ B horizon
- sulphate soil /ˈsʌlfeɪt sɔɪl/ [n] ដីដែលមានស៊ុលហ្វាតអាលុយមីញ៉ូម
- surface soil /ˈsəːfɪs sɔɪl/ [n] (សទិសន័យ៖ top soil) ដីមុខលើ (ស្រទាប់មួយនៃដីដែលជាទូទៅមានសារៈសំខាន់យ៉ាងខ្លាំងដល់ការដាំដុះដំណាំកសិកម្ម។ វាជាស្រទាប់ដែលត្រូវបានត្រឡប់ចុះឡើងដោយការភ្ជួររាស់។ ជាធម្មតា វាមានជម្រៅពី ៨ ទៅ ១០ស.ម ដល់ ២០ ទៅ ២៥ ស.ម។)
- swampy tundra soil /ˈswɒmpi ˈtʌndrə sɔɪl/ [n] ដីវាលភក់ក្នុងតំបន់ទុងដ្រា
- sward podzolic soil /swɔːd ˈpɒdzɒlɪk sɔɪl/ [n] ដីអាស៊ីតប៉ូតសូលិកដែលមានស្មៅដុះក្រាល
- sweet soil /swiːt sɔɪl/ [n] សូមមើលពាក្យ៖ neutral soil
- sylvogenic soil [n] សូមមើលពាក្យ៖ forest soil
- takyr soil /ˈteɪkə sɔɪl/ [n] ដីប្រៃសាឡាំងដែលមានស្រទាប់អំបិលក្រាំងពីលើបែកប្រេះជារូបផ្សេងៗ, តាគៀ
- takyr-like soil /ˈteɪkə-lʌɪk sɔɪl/ [n] ដីដែលមានរូបភាពដូចជាដីប្រៃដែលមានស្រទាប់អំបិលក្រាំងពីលើបែកប្រេះជារូបផ្សេង
- talus soil /ˈteɪləs sɔɪl/ [n] (សទិសន័យ៖ debris soil) ដីដែលកើតពីគំនរកម្ទេចវត្ថុអ្វីមួយ
- terrestrial soil /təˈrɛstrɪəl sɔɪl/ [n] (សទិសន័យ៖ upland soil) ដីទួលស្រោះទឹកល្អ
- tesselated soil /ˈtɛsəleɪtɪd sɔɪl/ [n] សូមមើលពាក្យ៖ facetted soil

- texture soil /ˈtɛkstʃə sɔɪl/ [n] (សទិសន័យ៖ soil with pattern design) ដីដែលមានរចនាសម្ពន្ធជាគំនូរ
- thermal podzolized soil /ˈθəːm(ə)l ˈpɒdzɒlʌɪzd sɔɪl/ [n] ដីប៉ូតសូលកើតកន្លែងត្រជាក់ខ្លាំង (ឧ. ប៉ូល)
- tilled soil /tɪld sɔɪl/ [n] សូមមើលពាក្យ៖ cultivated soil
- timber soil /ˈtɪmbə sɔɪl/ [n] សូមមើលពាក្យ៖ forest soil
- top soil /tɒp sɔɪl/ [n] សូមមើលពាក្យ៖ surface soil
- topsoil /ˈtɒpsɔɪl/ [n] ដីស្រទាប់លើ, ស្រទាប់ដាំដុះ, ស្រទាប់ដីខាងលើ
- torrent deposit soil /ˈtɒr(ə)nt dɪˈpɒzɪt sɔɪl/ [n] ដីដែលកើតពីគំនរសម្ភារដែលនាំមកដោយជ្រោះ
- transformation into fertile soil /transfəˈmeɪʃ(ə)n ˈɪntʊ ˈfəːtʌɪ sɔɪl/ [n] ការប្រែទៅជាដីដែលអាចផ្តល់ផល
- transformation into light soil /transfəˈmeɪʃ(ə)n ˈɪntʊ lʌɪt sɔɪl/ [n] ការក្លាយនៃពើកទៅជាដីផុសល្អ
- transitional soil /tranˈzɪʃ(ə)n(ə)l sɔɪl/ [n] ដីអន្តរកាល
- transitional wood moor soil /tranˈzɪʃ(ə)n(ə)l wʊd mɔː sɔɪl/ [n] ដីវាលភក់អន្តរភាព (ពើកនៅពាក់កណ្តាលខ្ពង់រាប)
- transported soil /tranˈspɔːtɪd sɔɪl/ [n] (សទិសន័យ៖ carried soil, secondary soil) ដីដែលកើតពីសម្ភារដែលនាំមកតាមរយៈកត្តាអ្វីមួយ (ទឹក ខ្យល់ជាដើម)
- tropical black soil /ˈtrɒpɪk(ə)l blak sɔɪl/ [n] (សទិសន័យ៖ black humus earth, black adobe) ដីខ្មៅតំបន់ត្រូពិច ឬស្ទើរតែត្រូពិច
- tropical fine gravely soil /ˈtrɒpɪk(ə)l fʌɪn ˈgreɪvli sɔɪl/ [n] ដីដែលមានកូនក្រួសមូលៗច្រើន (តំបន់ត្រូពិច)
- truncated soil /trʌŋˈkeɪtɪd sɔɪl/ [n] ដីដែលស្រទាប់លើត្រូវបានចិតចេញដោយទឹកច្រោះ
- tundra soil /ˈtʌndrə sɔɪl/ [n] ដីតំបន់ទុងដ្រា
- turfy soil /ˈtəːfi sɔɪl/ [n] សូមមើលពាក្យ៖ raw organic soil
- unfixed soil /ʌnˈfɪkst sɔɪl/ [n] សូមមើលពាក្យ៖ shifting soil
- unproductive soil /ʌnprəˈdʌktɪv sɔɪl/ [n] សូមមើលពាក្យ៖ lean soil
- unsalted soil /ʌnˈsɔːltɪd sɔɪl/ [n] ដីដែលគេលាងអំបិល
- unsaturated soil /ʌnˈsatʃʊreɪtɪd sɔɪl/ [n] សូមមើលពាក្យ៖ disintegrating exchange compound
- unstable soil /ʌnˈsteɪb(ə)l sɔɪl/ [n] សូមមើលពាក្យ៖ shifting soil
- unweathered mineral soil /ʌnˈwɛðəd ˈmɪn(ə)r(ə)l sɔɪl/ [n] ដីខនិជដែលមិនវិវត្ត, ដីដែលមានតែដុំថ្ម
- upland soil /ˈʌplənd sɔɪl/ [n] សូមមើលពាក្យ៖ terrestrial soil
- valley filling soil /ˈvali ˈfɪlɪŋ sɔɪl/ [n] សូមមើលពាក្យ៖ alluvial soil
- valley gley soil /ˈvali gleɪ sɔɪl/ [n] ដីគ្លេជាំទឹកនៅក្នុងជ្រលង
- very acid soil /ˈvɛri ˈasɪd sɔɪl/ [n] សូមមើលពាក្យ៖ heather soil
- very plastic loamy soil /ˈvɛri ˈplastɪk ˈləʊmi sɔɪl/ [n] ដីវាយនភាពល្បាយដែលអាចសូន ឬពត់ជារូបផ្សេងៗបានយ៉ាងងាយ
- virgin soil /ˈvəːdʒɪn sɔɪl/ [n] ដីថ្មី (ដីដែលគេពុំធ្លាប់ដាំដុះ)
- volcanic soil /vɒlˈkanɪk sɔɪl/ [n] ដីភ្នំភ្លើង
- warp soil /wɔːp sɔɪl/ [n] សូមមើលពាក្យ៖ riverside soil
- wasted soil /ˈweɪstɪd sɔɪl/ [n] ដីខ្សោះ
- waterlogged soil /ˈwɔːtəlɒgd sɔɪl/ [n] សូមមើលពាក្យ៖ hydrogen soil
- weakly leached soil /ˈwiːkli liːtʃt sɔɪl/ [n] សូមមើលពាក្យ៖ moderately weathered soil
- weathering soil /ˈwɛðərɪŋ sɔɪl/ [n] ដីដែលវិវត្តទៅរកការធេចរឹល
- wet soil /wɛt sɔɪl/ [n] សូមមើលពាក្យ៖ wet land
- white alkali soil /wʌɪt ˈalkəlʌɪ sɔɪl/ [n] សូមមើលពាក្យ៖ structureless saline soil
- wind-blown soil /wɪnd bləʊn sɔɪl/ [n] សូមមើលពាក្យ៖ aeolian soil
- wood soil /wʊd sɔɪl/ [n] សូមមើលពាក្យ៖ continental swamp
- wooded soil /ˈwʊdɪd sɔɪl/ [n] សូមមើលពាក្យ៖ forest soil

- woody peat soil /ˈwʊdi piːt sɔɪl/ [n] ដីពើកតំបន់ព្រៃ
- woody soil /ˈwʊdi sɔɪl/ [n] សូមមើលពាក្យ៖ forest soil
- yellow lateritic soil /ˈjɛləʊ latəˈrɪtɪk sɔɪl/ [n] ដីឡាតេរីតលឿង
- yellow podzolic soil /ˈjɛləʊ ˈpɒdzɒlɪk sɔɪl/ [n] ដីអាស៊ីតប៉ូតសូលិកដែលមានពណ៌លឿង (ដោយធាតុអាកាសក្ដៅ ហើយសើម)
- yellow soil /ˈjɛləʊ sɔɪl/ [n] ដីលឿង ឬក្រហមត្រូពិចដែលទឹកជ្រាបមិនបានពេញលេញ
- yellowish-brown lateritic soil /ˈjɛləʊɪʃ braʊn latəˈrɪtɪk sɔɪl/ [n] ដីឡាតេរីតសម្បុរត្នោត-លឿង
- young silicate soil /jʌŋ ˈsɪlɪkeɪt soil/ [n] ដីខ្ចីដែលទើបតែវិវត្តន៍ (ស្រទាប់ A ឬ Ah ១០-៤០ស.ម ឬថ្មមេ), ដីក្មេងពណ៌លឿង (ទម្រង់ផុស)
- young soil /jʌŋ sɔɪl/ [n] ដីខ្ចី, ដីដែលទើបចាប់ផ្ដើមវិវត្តន៍
- young valley filling soil /jʌŋ ˈvali ˈfɪlɪŋ sɔɪl/ [n] សូមមើលពាក្យ៖ undifferenciated alluvium
- zonal soil /ˈzəʊnəl sɔɪl/ [n] ដីតំបន់យោងទៅតាមធាតុអាកាស
- bog soil /bɒg sɔɪl/ [n]
  ១. ដីសើមទំនាបបឹង, ដីលិចទឹក
  ២. ដីអាស៊ីតជាំទឹកក្នុងទំនាបបឹងដែលមានពើក
  ៣. (សទិសន័យ៖ organic wet soil) ដីសើមដែលមានសរីរាង្គច្រើន (ឧ. ពើក)
  ៤. (សទិសន័យ៖ peaty soil) ដីដែលមានសរីរាង្គពើកច្រើន (ពើកស្តើងជាង ៣០ ស.ម និងដីខនិជ> ៤០%)
- underwater soil /ʌndəˈwɔːtə sɔɪl/ [n] សូមមើលពាក្យ៖ subaqueous soil

**soil-abundance** /sɔɪl əˈbʌnd(ə)ns/ [n] ការរីកកាន់តែធំ ឬកាន់តែច្រើន

**soil-covering** /sɔɪl ˈkʌv(ə)rɪŋ/ [n] គម្របលើដី (ឈើរស់ ឬងាប់)

**soil alliance** /sɔɪl əˈlʌɪəns/ [n] សម្ពន្ធដី

**soil amendment** /sɔɪl əˈmɛn(d)m(ə)nt/ [n] ការកែប្រែដី

**soil auger** /sɔɪl ˈɔːgə/ [n] ដែកខួងដី (ប្រដាប់យកសំណាកដី)

**soil barrier** /sɔɪl ˈbarɪə/ [n] សូមមើលពាក្យ៖ hard pan

**soil living** /sɔɪl ˈlɪvɪŋ/ [n] (សទិសន័យ៖ soil organism) ក្រុមសត្វ រុក្ខជាតិក្នុងដី, ជីវសាស្រ្តដី, សារពាង្គកាយដី

**soil mantle** /sɔɪl ˈmant(ə)l/ [n] ស្រទាប់លើ ឬក្រៅនៃដី

**soil map** /sɔɪl map/ [n] ផែនទីដី

**soil of the depression** /sɔɪl ɒv ðɪ dɪˈprɛʃ(ə)n/ [n] ដីនៃល្បាក់ទំនាប

**soil patch** /sɔɪl patʃ/ [n] (សទិសន័យ៖ soil spot) ស្នាមដី

**soil probe** /sɔɪl prəʊb/ [n] ឧបករណ៍ខួងដី (ឧបករណ៍ខួងយកសំណាកដី)

**soil seed bank** /sɔɪl siːd baŋk/ [n] ធនាគារគ្រាប់ក្នុងដី (គ្រាប់នៅរស់សម្ងំ នៃប្រភេទពូជមួយ ឬច្រើន ដែលនៅកប់ក្នុងដីកាន់តែច្រើនឡើង អស់រយៈពេលជាង១ឆ្នាំ ឬច្រើនឆ្នាំ)

**soil separate** /sɔɪl ˈsɛp(ə)rət/ [n] ការញែកប្រភេទដី (ក្រុមនៃភាគល្អិតនៃដីដែលដាច់ពីគ្នា ដោយយោងទៅតាមទំហំនៃគ្រាប់ដី។ ជាគោលការណ៍ គេចែកវាជាដីខ្សាច់ ដីល្បាប់ម៉ដ្ឋ និងដីឥដ្ឋ។)

**soil series** /sɔɪl ˈsɪəriːz/ [n] ចំណាត់ថ្នាក់ដី, ស៊េរីដី, ឈុតដី

**sola pith plant** /ˈsəʊlə pɪθ plɑːnt/ [n] ស្នោទឹក (ឈ្មោះវិទ្យាសាស្រ្ត *Aeschynomene aspara*)

***Solanum lycopersicum*** [sci.n] សូមមើលពាក្យ៖ tomato

***Solanum melongena*** [sci.n] សូមមើលពាក្យ៖ eggplant

***Solanum tuberosum*** [sci.n] សូមមើលពាក្យ៖ potato

***Solenopsis geminata*** [sci.n] សូមមើលពាក្យ៖ ant

**solid** /ˈsɒlɪd/ [n] រូបធាតុរឹង

- suspended solid /səˈspɛndɪd ˈsɒlɪd/ [n] កករវិលវល់
- total dissolved solid (TDS) /ˈtəʊt(ə)l dɪˈzɒlvd ˈsɒlɪd/ [n] រូបធាតុរឹងរលាយសរុប

**solochak** [n] ដីប្រៃសូឡុងឆាក, ដីប្រៃសំបូរដោយអំបិលណឺត pH<៨.៥

**solodisation** [n] ការប្រែក្លាយនៃដីប្រៃសូឡូណែតឱ្យទៅជាសូឡូត

**solod-like soil** [n] សូមមើលពាក្យ៖ solodic soil

**solonchak** [n] ដីប្រៃប្រភេទសូឡុងឆាក

- sulphate solonchak [n] ដីប្រៃប្រភេទសូឡុងឆាកដែលមានស៊ុលហ្វាត

- disguised solonchak-solonetz [n] ដីប្រែអាល់កាលីសបំពួន

**solodised solonetz** [n] សូឡូណែតដែលក្លាយជាសូឡូត

**solonisation** /ˌsɒlənʌɪˈzeɪʃ(ə)n/ [n] ការកកើតនៃសូឡូណែត

**solubility** /sɒljʊˈbɪlɪti/ [n] ភាពរលាយ, លក្ខណៈរលាយ

**solubilize** /ˈsɒljʊbɪlʌɪz/ [v] ធ្វើឱ្យរលាយ

**soluble** /ˈsɒljʊb(ə)l/ [adj] រលាយ

- fat-soluble vitamin /fat ˈsɒljʊb(ə)l ˈvɪtəmɪn/ [n] វីតាមីនរលាយក្នុងខ្លាញ់
- water-soluble /ˈwɔːtə ˈsɒljʊb(ə)l/ [adj] រលាយក្នុងទឹក

**solum** [n] (ពហុវចនៈ៖ sola) ស្រទាប់ផ្នែកខាងលើភាគច្រើនជាស្រទាប់ដែលធ្វើ weathering ខ្លាំងនៃរូបសាស្ត្រស្រទាប់ដី ជារួមវាផ្សំឡើងដោយស្រទាប់ A និង B

**solute** /ˈsɒljuːt/ [n] ធាតុរលាយ

**solution** /səˈluːʃ(ə)n/ [n] ល្បាយ, សូលុយស្យុង

- acid solution /ˈasɪd səˈluːʃ(ə)n/ [n] (សទិសន័យ៖ acidic solution) សូលុយស្យុងអាស៊ីត
- acidic solution /əˈsɪdɪk səˈluːʃ(ə)n/ [n] សូមមើលពាក្យ៖ acid solution
- alkaline solution /ˈalkəlʌɪn səˈluːʃ(ə)n/ [n] (សទិសន័យ៖ basic solution) សូលុយស្យុងបាស
- basic solution /ˈbeɪsɪk səˈluːʃ(ə)n/ [n] សូមមើលពាក្យ៖ alkaline solution
- buffer solution /ˈbʌfə səˈluːʃ(ə)n/ [n] ល្បាយធន់ករ pH (សារធាតុ ឬសូលុយស្យុងដែលប្រើឱ្យ pH មានលំនឹង)
- chemical solution /ˈkɛmɪk(ə)l səˈluːʃ(ə)n/ [n] សូលុយស្យុងគីមី
- colloidal solution /kəˈlɔɪd(ə)l səˈluːʃ(ə)n/ [n] សូលុយស្យុងកូឡូអ៊ីត
- diluted solution /dʌɪˈl(j)uːtɪd səˈluːʃ(ə)n/ [n] សូលុយស្យុងរាវ
- nutrient solution /ˈnjuːtrɪənt səˈluːʃ(ə)n/ [n] ល្បាយសារធាតុចិញ្ចឹម, ល្បាយអាហារធាតុ
- soil solution /sɔɪl səˈluːʃ(ə)n/ [n] (សទិសន័យ៖ intermicellar liquid) សូលុយស្យុងដី, ទឹកដែលនៅជុំវិញគ្រាប់ដី

**solvable** /ˈsɒlvəb(ə)l/ [adj] អាចរលាយ

**solvent** /ˈsɒlv(ə)nt/ [n] ធាតុរំលាយ

- organic solvent /ɔːˈganɪk ˈsɒlv(ə)nt/ [n] ធាតុរំលាយសរីរាង្គ

**somatic embryogenesis** /səˈmatɪk ˌɛmbrɪə(ʊ)ˈdʒɛnɪsɪs/ [n] ការបណ្ដុះអំប្រ៊ីយ៉ុង (ការវិវត្តន៍របស់អំប្រ៊ីយ៉ុងចេញពីកោសិកាសូម៉ាទិកឪប្លូអ៊ីតក្នុងសូលុយស្យុង (solution) បណ្ដុះ)

**sorghum** /ˈsɔːgəm/ [n] ស្កួយ, ស្រូវមីយេ (ឈ្មោះវិទ្យាសាស្ត្រ៖ *Sorghum vulgare*)

***Sorghum halepense*** [sci.n] សូមមើលពាក្យ៖ Johnson grass

***Sorghum vulgare*** [sci.n] សូមមើលពាក្យ៖ sorghum

**sorption** /ˈsɔːpʃ(ə)n/ [n] ការស្រូប

**sort** /sɔːt/ [n] បែប, ប្រភេទ, ពួក, ពូជ, ធុន

**sound** /saʊnd/ [n] សំឡេង, សូរ

- infrasound /ˈɪnfrəsaʊnd/ [n] សូរអាំងប្រា
- urethral sound /jʊəˈriːθrəl saʊnd/ [n] ប្រដាប់ពង្រីកសម្រាប់ពិនិត្យ មើលរន្ធ ឬទ្វារនោម

**sour berry** /saʊə ˈbɛri/ [n] មើលៈ rambi

**seed source** /siːd sɔːs/ [n] ប្រភពគ្រាប់ពូជ (ទីកន្លែង ឬជាឯកត្តៈដើមនៃគ្រាប់ពូជ)

- local seed source /ˈləʊk(ə)l siːd sɔːs/ [n] ប្រភពគ្រាប់ពូជនៅក្នុងស្រុក ( ប្រភពគ្រាប់ពូជដែលមានដើមកំណើតនៅទីកន្លែងណាមួយដែលកូនឈើដុះលូតលាស់នៅទីនោះ ពោលគឺជា ពូជនៅក្នុងភូមិសាស្ត្រស្រុកនោះ។ តំបន់ប្រមូលគ្រាប់ពូជរបស់វា ជាធម្មតា គេបានកំណត់ដោយធ្វើពិសោធន៍ ដូចជាក្នុងរយៈចំងាយណាមួយ ឬរយៈកម្ពស់នៃទីកន្លែងដាំ(ចម្ការ)។)
- source identified tree seed /sɔːs ʌɪˈdɛntɪfʌɪd triː siːd/ [n] សូមមើលពាក្យ៖ source identified seed

**source** /sɔːs/ [n] ប្រភព, ដើមកំណើត

- acoustic source /əˈkuːstɪk sɔːs/ [n] ប្រភពសូរ
- alternative energy source /ɔːlˈtəːnətɪv ˈɛnədʒi sɔːs/ [n] ប្រភពថាមពលជំនួស
- dust source /dʌst sɔːs/ [n] ប្រភពធូលី
- earthquake source /ˈəːθkweɪk sɔːs/ [n] ប្រភពរញ្ជួយដី
- emission source /ɪˈmɪʃ(ə)n sɔːs/ [n] ប្រភពការបញ្ចេញសំណល់ឧស្ម័ន
- energy source /ˈɛnədʒi sɔːs/ [n] ប្រភពថាមពល

- heat source /hiːt sɔːs/ [n] (សទិសន័យ៖ thermal source) ប្រភពកម្តៅ
- land-based source /land beɪst sɔːs/ [n] ប្រភពបំពុលចេញពីដីគោក
- light source /lʌɪt sɔːs/ [n] ប្រភពពន្លឺ
- line pollution source /lʌɪn pəˈluːʃ(ə)n sɔːs/ [n] ប្រភពបំពុលជាខ្សែ
- man-made radiation source /man meɪd reɪdɪˈeɪʃ(ə)n sɔːs/ [n] ប្រភពវិកិរណស្មីសិប្បនិម្មិត
- maritime pollution source /ˈmarɪtʌɪm pəˈluːʃ(ə)n sɔːs/ [n] ប្រភពបំពុលសមុទ្រ
- mobile pollution source /ˈməʊbʌɪl pəˈluːʃ(ə)n sɔːs/ [n] ប្រភពបំពុលចល័ត
- natural radiation source /ˈnatʃ(ə)r(ə)l reɪdɪˈeɪʃ(ə)n sɔːs/ [n] ប្រភពវិកិរណស្មីធម្មជាតិ
- noise source /nɔɪz sɔːs/ [n] (សទិសន័យ៖ sound source) ប្រភពសូរស័ព្ទ, ប្រភពសំឡេង
- nonconventional power source /nɒn kənˈvɛnʃ(ə)n(ə)l ˈpaʊə sɔːs/ [n] ប្រភពថាមពលមិនប្រពៃណី, ប្រភពថាមពលថ្មី
- non-point source /nɒn pɔɪnt sɔːs/ [n] ប្រភពពាយប៉ាយ
- nuclear energy source /ˈnjuːklɪə ˈɛnədʒi sɔːs/ [n] ប្រភពថាមពលបរមាណូ, ប្រភពថាមពលនុយក្លេអ៊ែ
- photochemical pollution source /fəʊtə(ʊ)ˈkɛmɪk(ə)l pəˈluːʃ(ə)n sɔːs/ [n] ប្រភពបំពុលផូតូគីមី
- point source /pɔɪnt sɔːs/ [n] ប្រភពចំហុយ
- pollution energy source /pəˈluːʃ(ə)n ˈɛnədʒi sɔːs/ [n] ប្រភពថាមពលដែលបំពុលបរិស្ថាន
- pollution source /pəˈluːʃ(ə)n sɔːs/ [n] ប្រភពបំពុល
- pollution-free energy source /pəˈluːʃ(ə)n friːˈɛnədʒi sɔːs/ [n] ប្រភពថាមពលដែលមិនបំពុលបរិស្ថាន
- radiation source /reɪdɪˈeɪʃ(ə)n sɔːs/ [n] ប្រភពវិកិរណស្មី
- renewable energy source /rɪˈnjuːəbəl ˈɛnədʒi sɔːs/ [n] ប្រភពថាមពលកើតឡើងវិញ
- solar power source /ˈsəʊlə ˈpaʊə sɔːs/ [n] ប្រភពព្រះអាទិត្យ
- sound source /saʊnd sɔːs/ [n] សូមមើលពាក្យ៖ noise source
- source of river /sɔːs ɒv ˈrɪvə/ [n] ប្រភពទន្លេ, ប្រភពស្ទឹង
- terrestrial energy source /təˈrɛstrɪəl ˈɛnədʒi sɔːs/ [n] ប្រភពថាមពលលើផែនដី
- thermal source /ˈθəːm(ə)l sɔːs/ [n] សូមមើលពាក្យ៖ heat source
- transportation pollution source /transpɔːˈteɪʃ(ə)n pəˈluːʃ(ə)n sɔːs/ [n] ប្រភពបំពុលពីការដឹកជញ្ជូន
- ultraviolet source /ʌltrəˈvʌɪələt sɔːs/ [n] ប្រភពកាំរស្មីស្វាយអ៊ុលត្រា
- vibration source /vʌɪˈbreɪʃ(ə)n sɔːs/ [n] ប្រភពរំញ័រ
- water source /ˈwɔːtə sɔːs/ [n] ប្រភពទឹក

**soursop** /ˈsaʊəsɒp/ [n] ទៀបបន្លា, ទៀបបារាំង (ឈ្មោះវិទ្យាសាស្ត្រ *Annona muricata*)

***Sousa chinensis*** [sci.n] សូមមើលពាក្យ៖ Indo-Pacific hump-backed dolphin

**southern cutgrass** [n] ស្មៅរនាម (ឈ្មោះវិទ្យាសាស្ត្រ *Leersia hexandra*)

**sow** /səʊ/ [v] សាប, ព្រោះ, បណ្ដុះ (ដំណើរការដែលក្នុងនោះគ្រាប់ពូជ ត្រូវបានដាក់នៅទីកន្លែង ឬថ្នាល ដែលមានការថែទាំត្រឹមត្រូវសម្រាប់ការដុះលូតលាស់)

**sowing** /səʊwɪŋ/ [n] ការសាបព្រោះ

**space** /speɪs/ [n] ចន្លោះ, រន្ធ

- air space /ɛː speɪs/ [n] រន្ធដីសម្រាប់ផ្ទុកខ្យល់
- dead space /dɛd speɪs/ [n] លំហងាប់ (ខ្យល់ក្នុងបំពង់ខ្យល់ ទងសួត និងកូនទងសួត ដែលមិនត្រូវបានប្រើប្រាស់បណ្ដូរឧស្ម័ន)
- infracapillary space /ˈɪnfrə kəˈpɪləri speɪs/ [n] សូមមើលពាក្យ៖ microporosity
- planting space /plɑːntɪŋ speɪs/ [n] ចន្លោះគុម្ព
- pore space /pɔː speɪs/ [n] ចន្លោះ ឬរន្ធទទេ
- supracapillary space /ˈs(j)uːprə kəˈpɪləri speɪs/ [n] សូមមើលពាក្យ៖ macroporosity

**spacing** /ˈspeɪ.sɪŋ/ [n] ចន្លោះ

- tree spacing /triː ˈspeɪ.sɪŋ / [n]
  ១. ចន្លោះដើមឈើ
  ២. ការរៀបជាចន្លោះនៃដើមឈើ

**spade** /speɪd/ [n] ប៉ែលដៃ

**spadix** /ˈspeɪdɪks/ [n] ផ្កាចង្កោមរាងផ្លែចបជីក

**spanner** /ˈspanə/ [n] សោរប៊ូឡុង

**spark plug** /spɑːk plʌg/ [n] ប៊ូស៊ី

**spasm** /ˈspaz(ə)m/ [n] ការញាក់ ឬកន្ត្រាក់សាច់ដុំ

**spathulate** /ˈspatjʊlət/ [adj] ទម្រង់បន្ទះស្លឹករាងវែកបាយ, រាងចង្វា, រាងស្លាបព្រា (អំពីទម្រង់របស់រុក្ខជាតិ)

**spatula** /ˈspatjʊlə/ [n] បន្ទះឈើសំប៉ែត, វែកកូរ

**spavin** /ˈspavɪn/ [n] កំពកឆ្អឹង, គន្លាក់ជើង (សេះ)

**spawn** /spɔːn/ [n] ពង (ត្រី, កង្កែប)

- induced spawning /ɪnˈdjuːst spɔːnɪŋ/ [n] ការបង្កាត់ត្រីសិប្បនិម្មិត

**spay** /speɪ/ [v] សូមមើលពាក្យ៖ castrate

**specialist** /ˈspɛʃ(ə)lɪst/ [n] អ្នកឯកទេស (អ្នកដែលមានជំនាញអ្វីមួយច្បាស់លាស់)

- livestock specialist /ˈlʌɪvstɒk ˈspɛʃ(ə)lɪst/ [n] អ្នកឯកទេសខាងបសុសត្វ

**specialize** /ˈspɛʃ(ə)lʌɪz/ [v] ធ្វើឯកទេសកម្ម, ដាក់ទៅតាមជំនាញ, មានជំនាញ

**speciation** /ˌspiːʃɪˈeɪʃ(ə)n/ [n] ការបង្កាត់ពូជថ្មី

- abrupt speciation /əˈbrʌpt ˌspiːʃɪˈeɪʃ(ə)n/ [n] កំណប្រភេទរយៈពេលខ្លី
- allopatric speciation /ˌaləˈpatrɪk ˌspiːʃɪˈeɪʃ(ə)n/ [n] កំណប្រភេទតាមតំបន់ខុសៗគ្នា
- biological speciation /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˌspiːʃɪˈeɪʃ(ə)n/ [n] ការបង្កើតប្រភេទ

**species** /ˈspiːʃiːz/ [n] ប្រភេទ, ពូជ, អម្បូរ (ក្នុងចំណាត់ថ្នាក់វិទ្យា)

- climax tree species /ˈklʌɪmaks triː ˈspiːʃiːz/ [n] ប្រភេទពូជឈើព្រៃស្រោង, ប្រភេទព្រៃឃ្លៃម៉ែក្យ (ប្រភេទពូជឈើដែលដុះនៅក្នុងទីកន្លែងណាមួយដែលមានប្រភេទអាកាសធាតុ និងដីប្រសើរបំផុត ដែលនៅ ក្នុងកំឡុងពេលនោះ លក្ខខណ្ឌបរិស្ថានមានស្ថេរភាពច្រើនឬតិចក្តី។ ជាធម្មតា ប្រភេទឈើឃ្លៃម៉ាក្យមាន អាយុវែង និងអាយុបន្តពូជយឺតជាង បើប្រៀបធៀបទៅនឹងប្រភេទឈើឈានមុខ (pioneers) ដែលមាន លក្ខណៈផ្ទុយពីនេះ។)
- cryptic species /ˈkrɪptɪk ˈspiːʃiːz/ [n] អម្បូរបងប្អូន
- endangered species /ɪnˈdeɪndʒəd ˈspiːʃiːz/ [n] ប្រភេទកំពុងផុតពូជ
- exotic species /ɪgˈzɒtɪk ˈspiːʃiːz/ [n] ប្រភេទក្រៅស្រុក
- indicator species /ˈɪndɪkeɪtə ˈspiːʃiːz/ [n] ប្រភេទសូចនាករ, ប្រភេទសញ្ញាចង្អុល
- indigenous species /ɪnˈdɪdʒɪnəs ˈspiːʃiːz/ [n] ប្រភេទនៅក្នុងស្រុក
- introduced species /ɪntrəˈdjuːst ˈspiːʃiːz/ [n] ពូជនាំចូល (ពូជដែលមិនកើតមានដោយធម្មជាតិនៅក្នុងតំបន់នោះ និងដែលត្រូវនាំចូលដោយចៃដន្យ ឬដោយបំណងដោយមនុស្ស)
- pioneer species /pʌɪəˈnɪə ˈspiːʃiːz/ [n] ប្រភេទរុក្ខជាតិឈានមុខ, ពូជរុក្ខជាតិឈានមុខ, ប្រភេទព្រៃដំបូង, ពូជព្រៃដំបូង ( ជាពាក្យន័យខាងបរិស្ថានដែលទាក់ទងនឹងក្រុមប្រភេទដែលដុះជាអាណានិគមរុក្ខជាតិមុនគេលើដីវាលហើយ ចាប់ផ្តើមកើតជាព្រៃដំបូង។ ជាធម្មតា ព្រៃឈានមុខនេះក្រោយមក ត្រូវជំនួសដោយប្រភេទព្រៃស្រោង (ធំ) ។ ប្រភេទឈានមុខ គឺមានលក្ខណៈលូតលាស់លឿនអាយុបន្តពូជខ្លី ការផលិតគ្រាប់ពូជតូចៗនិងច្រើន ហើយជាធម្មតា ងាយបន្តពូជ ដោយខ្ទែង។ ពាក្យន័យផ្ទុយ Climax species។)
- threatened species /ˈθrɛt(ə)nd ˈspiːʃiːz/ [n] ពពួកសត្វដែលទទួលរងការគម្រាមកំហែង

**specific gravity** /spəˈsɪfɪk ˈgravɪti/ [n] ទម្ងន់ពិតប្រាកដ, ផលចែកនៃដង់ស៊ីតេ (ទម្ងន់ឈើក្នុងមួយខ្នាតមាឌ) នៃឈើទៅនឹងដង់ស៊ីតេទឹកនៅកម្រិត 4 $^0$C (39.2 $^0$F)

**specimen** /ˈspɛsɪmɪn/ [n] សំណាក, បដិរូប, តួយ៉ាង

**speckled** /ˈspɛkld/ [adj] សូមមើលពាក្យ៖ spotted

**speckletail horseface loach** /ˈspɛk(ə)l teɪl hɔːsfeɪs ləʊtʃ/ [n] ត្រីឫសចេក (ឈ្មោះវិទ្យាសាស្ត្រ *Acantopsis* sp.)

**speculum** /ˈspɛkjʊləm/ [n] ចំពុះទា (ប្រដាប់បើករន្ធ ឬប្រដាប់សម្រាប់ពង្រីកផ្លូវ ឬបំពង់នៃខ្លួន ដើម្បីឱ្យស្រួលដល់ការពិនិត្យមើល)

**speech theraphy** /spiːtʃ ˈθɛrəfi/ [n] វិធីព្យាបាលសំដី

**engine speed (RPM)** /ˈɛndʒɪn spiːd/ [n] ល្បឿនចលករ (ល្បឿនរង្វិលជុំនៃចលករ)

**speleology** /ˌspiːlɪˈɒlədʒi/ [n] គុហាវិទ្យា

**sperm** /spəːm/ [n] (សទិសន័យ៖ semen) ទឹកកាម, មេជីវិត

**spermary** [n] សូមមើលពាក្យ៖ antheridium

**spermatozoid** /ˌspəːmətə(ʊ)ˈzəʊɪd/ [n] ស្ពែម៉ាតូសូអ៊ីត

***Sphenoclea zeylanica*** [sci.n] សូមមើលពាក្យ៖ gooseweed

**spheroidal weathering** /sfɪəˈrɔɪd(ə)l ˈwɛðərɪŋ/ [n] ការផុយ ឬរលួយជាដុំមូលៗ

**sphincter** /ˈsfɪŋktə/ [n] សាច់ខ្ទីបទ្វារ, ក្រសាល់ (សាច់ដុំម៉្យាងរាងរង្វង់មូលដែលបង្រួម ឬបិទប្រហោងធម្មជាតិមួយនៃខ្លួន)

**spider** /ˈspʌɪdə/ [n] ពីងពាង (សត្វរំពាមានប្រយោជន៍ស្ថិតក្នុងលំដាប់ Aranea)

- dwarf spider /dwɔːf ˈspʌɪdə/ [n] ពីងពាងកន្ទុល (សត្វរំពាស្ថិតក្នុងលំដាប់ Araneae គ្រួសារ Linyphiidae)

**spiderling** /ˈspʌɪdəlɪŋ/ [n] កូនពីងពាង

**spike** /spʌɪk/ [n] ផ្កាចង្កោមចុងស្រួច, ប្រភេទផ្កាស្នៃងទោល (ក្បូរ) (ជាប្រភេទផ្កាកន្ទ្រោមវែង ដែលមានផ្កាជាប់នឹងស្នៃង (គ្មានទងផ្កា) ផ្កាខ្ចីនៅគល់ស្នៃង)

**spikelet** /ˈspʌɪklɪt/ [n] កន្ទ្រោមផ្កា (បណ្តុំនៃផ្កាធញ្ញជាតិភាគច្រើន ដោយរួមទាំងសម្បក និប្ផល និងទងរបស់វា)

**spiketooth harrow** /spʌɪktuːθ ˈharəʊ/ [n] រនាស់ធ្មេញ (រនាស់ក្រឡាមានធ្មេញជាចម្រូងខ្ពស់ៗសម្រាប់រាស់ពីលើដើម្បីលុប ឬរាស់បង្កប់គ្រាប់ពូជដែលបានព្រួស ឬបាចរួចតាមចង្អូរ ឬគន្លងក្នុងស្រែ)

***Spilanthes paniculata*** [sci.n] ដើមចម្អេះ

**spill** /spɪl/ [n] ការហៀរកំពប់

**spillway** /ˈspɪlweɪ/ [n] ផ្លូវបង្ហូរ (ទំនប់ទឹក), ទំនប់បង្ហៀរ

**spinach** /ˈspɪnɪdʒ/ [n] ស្ពៃណាច (បន្លែម៉្យាង)

**spinal** /ˈspʌɪn(ə)l/ [adj] នៃឆ្អឹងខ្នង

**spinal anesthesis** [n] ការធ្វើឱ្យឆ្អឹងខ្នងស្ពឹក,ការចាក់ថ្នាំស្ពឹកក្នុងស្រោមខួរឆ្អឹងខ្នង

**spinal cord** /ˈspʌɪn(ə)l kɔːd/ [n] ខួរឆ្អឹងខ្នង

**spine** /spʌɪn/ [n]

១. សូមមើលពាក្យ៖ backbone

២. បន្លា

**spiny amaranth** /ˈspʌɪni ˈamərənθ/ [n] ផ្ទីបន្លា (ឈ្មោះវិទ្យាសាស្ត្រ *Amaranthus spinosus*)

**spiracle** /ˈspʌɪrək(ə)l/ [n] ផ្លូវដង្ហើម

**spirits** /ˈspɪrɪts/ [n] ស្រាបិតដែលមានកម្រិតអាល់កុលខ្ពស់

**spirochactales** [n] (សទិសន័យ៖ spirochete) ស្ពីរ៉ូកែត (ក្រុមមីក្រុបដែលមានរាងជារង្វេល)

**spirochete** /ˈspʌɪrə(ʊ)kiːt/ [n] (សូមមើលពាក្យ៖ spirochactales) សត្វតូចម៉្យាងមានរាងស្តើងហើយរួញក ដែលរស់នៅក្នុងទឹក

**spleen** /spliːn/ [n] ដាល, អណ្តើក (សរីរាង្គក្នុងខ្លួន)កូន

**splint** /splɪnt/ [n] ឈើអបឆ្អឹង, រណបឆ្អឹង

**split** /splɪt/ [n] ក្រហែង ឬស្នាមប្រេះតូច, ការដាច់

***Spodoptera litura*** [sci.n] សូមមើលពាក្យ៖ cutworm

***Spoladea recurvalis*** [sci.n] ដង្កូវម្ជូរស្លឹក

***Spondias dulcis*** [sci.n] សូមមើលពាក្យ៖ ambarella

**spooky** /ˈspuːki/ [adj] ផ្អើល

**spore** /spɔː/ [n] ស្ប៉រ (សរីរាង្គបន្តពូជឯកកោសិកា ឬពហុកោសិការបស់ពពួកផ្សិត)

- ameobic flagellate spore /əˈmiːbɪk ˈfladʒ(ə)leɪt spɔː/ [n] ស្ប៉រសណ្ឋានដូចអាមីប
- asexual spore /eɪˈsɛkʃʊəl spɔː/ [n] ស្ប៉រអភេទ
- isopore [n] ស្ប៉រឥតភេទ, អ៊ីសូស្ប៉រ
- non-flagellate spore /nɒnˈfladʒ(ə)leɪt spɔː/ [n] ស្ប៉រគ្មានកន្ទុយ
- sexual spore /ˈsɛkʃʊəl spɔː/ [n] ស្ប៉រភេទ

**sporophore** /ˈspɒrəfɔː/ [n] ស្ប៉រ៉ូផរ (ទម្រង់ទាំងឡាយរបស់ផ្សិតដែលផលិតស្ប៉រ)

**sporophyte** /ˈspɒrəfʌɪt/ [n] ស្ប៉រ៉ូហ្វីត (ជាឯកត្តៈមួយនៃជំនាន់ (តំណ) ឌីប្លូអ៊ីតនៃខួបជីវិតរបស់រុក្ខជាតិមួយ។ វាជាសរីរាង្គថ្នាក់ខ្ពស់នៃពពួករុក្ខជាតិថ្នាក់ខ្ពស់ជាងទាំងអស់ ដែលកាម៉េតតូហ្វីត (ជំនាន់អាប្លូអ៊ីត) ត្រូវបានកាត់បន្ថយទៅជាសរីរាង្គអនិស្សរភាពនៅក្នុងពពួកស្ប៉រ៉ូហ្វីត (ចង់អំប្រ៊ីយ៉ុងក្នុងពពួករុក្ខជាតិ)។ ពពួករុក្ខជាតិថ្នាក់ទាបខ្លះបានកាត់បន្ថយ ហើយជំនាន់ខ្ពស់ គឺកាម៉េតតូហ្វីត។)

**spot welder** /spɒt wɛldə/ [n] ផ្សារចំណុច (ឧបករណ៍ផ្សាភ្ជាប់រវាងលោហធាតុដោយសង្កត់ជាចំណុចៗ)

**spot** /spɒt/ [n]

១. (សទិសន័យ៖ scald, fleck) ពពាល, ស្នាមអុជៗ

២. ចំណុច, កន្លែង

- alternaria leaf spot /ˈɔːltənnɛːrɪə liːf spɒt/ [n] ជំងឺអុតស្លឹក (ជំងឺនេះបង្កដោយផ្សិត *Alternaria brassica* និង *Alternaria brassicicola* ដោយរាលដាលតាមរយៈខ្យល់។ ភ្នាក់ងារបង្កជំងឺ នឹងបង្កើតស្ប៉ក្នុងកាកសំណល់ដំណាំ និងរស់នៅលើរុក្ខជាតិចង្រៃ និងគ្រាប់ពូជ ដែលងាយទទួលរងជំងឺ។)
- angular leaf spot /ˈaŋgjʊlə liːf spɒt/ [n] ជំងឺអុចស្លឹក (សណ្តែក) (បង្កដោយផ្សិត Phaeoisariopsis griseola-Sacc)
- black spot /blak ˈspɒt/ [n] ស្នាមខ្មៅ
- brown spot /braʊn spɒt/ [n] ជំងឺអុចត្នោត (ជំងឺផ្សិតដែលបង្កដោយផ្សិតម្យ៉ាងឈ្មោះ *Bipolaris oryzae = Drechstera oryzae = Helminthosporium oryzae* ហើយជំងឺនេះកើតឡើងចំពោះស្រូវ ដែលដុះនៅលើដីខ្វះសារធាតុចិញ្ចឹម ជាពិសេសអាសូត ដូចនេះទើបគេហៅ ជំងឺនេះបានម្យ៉ាងទៀតថា ជំងឺអ្នកក្រ)
- clay spot /kleɪ ˈspɒt/ [n] ស្នាមដីឥដ្ឋ
- corynespora leaf spot [n] ជំងឺអុចរទុះស្លឹក (ជំងឺនេះបង្កដោយផ្សិត *Corynespora cassiicola* ដោយឆ្លងរាលដាលនៅតំបន់ត្រូពិច ភាគច្រើនទៅតាមខ្យល់ ឬទឹកភ្លៀង)
- leaf spot /liːf spɒt/ [n] អុចស្លឹក
- narrow brown spot /ˈnarəʊ braʊn spɒt/ [n] ជំងឺអុចត្នោតវែង, ជំងឺអុចត្នោតឆ្នូត (ជំងឺផ្សិតដែលបង្កដោយផ្សិតឈ្មោះ *Cercospora Oryzae* ដែលរោគសញ្ញារបស់វាគឺជាស្នាមអុចរាងជាបន្ទាត់ពណ៌ត្នោត ដែលមានបណ្តោយពី ២ ទៅ ១០ ម.ម និងទទឹង ១ ម.ម ច្រើនកើតលើស្លឹក ស្រទបស្លឹក ឬសម្បកផ្កា)
- rusty spot /ˈrʌstiˈ spɒt/ [n] ស្នាមច្រែះ
- soil spot /sɔɪlˈ spɒt/ [n] (សទិសន័យ៖ soil patch) ស្នាមដី
- wet spot /wɛt spɒt/ [n] ស្នាមសើម

**spotted** /ˈspɒtɪd/ [adj] (សទិសន័យ៖ speckled) អុជៗ (ពណ៌), ដែលមានស្នាម

**spotted algae eater** /ˈspɒtɪd ˈalgə ˈiːtə/ [n] ត្រីស្មុក (ឈ្មោះវិទ្យាសាស្ត្រ *Gyrinocheilus pennocki*)

**spotted green pufferfish** /ˈspɒtɪd griːn ˈpʌfəfɪʃ/ [n] ត្រីកំពត (ឈ្មោះវិទ្យាសាស្ត្រ *Chelonodon nigroviridis*)

**spotted horseface loach** /ˈspɒtɪd hɔːsfeɪs ləʊtʃ/ [n] ត្រីឫសចេក (ឈ្មោះវិទ្យាសាស្ត្រ *Acantopsis* sp.)

**sprain** /spreɪn/ [v] គ្រិច

**spray gun** /spreɪ gʌn/ [n] មុខទុយោសម្រាប់បាញ់ថ្នាំ

**spray** /spreɪ/ [v] បាញ់ (ទឹក, ថ្នាំ, ប្រេង)

**spray** /spreɪ/ [n] ថ្នាំបាញ់

- foliar spray /ˈfəʊlɪə spreɪ/ [n] ការបាញ់លើស្លឹក

**spraying** /spreɪɪŋ/ [n] បំណាច (ជី), ការបាញ់ (ថ្នាំ)

**spreading** /sprɛdɪŋ/ [n] ការរីកសាយភាយ

**spreading dayflower** /sprɛdɪŋ deɪˈflaʊə/ [n] ស្មៅស្លាបទាឈ្មោល (ឈ្មោះវិទ្យាសាស្ត្រ *Commelina diffusa*)

**spring** /sprɪŋ/ [n] ទឹកចេញពីដី, ប្រភពទឹក, រដូវផ្ការីក

- earth spring /əːθ sprɪŋ/ [n] ការរំជួលឡើងលើនៃស្រទាប់លើនៃដីទំនាបបឹងតំបន់ទុងជ្រា
- hot spring /hɒt sprɪŋ/ [n] ប្រភពទឹកក្តៅ

**sprinkler** /ˈsprɪŋklə/ [n] ស្ព្រីងឃ្ល័រ (ឧបករណ៍សម្រាប់ស្រោចទឹកបាចសាច), ការស្រោចស្រពដោយស្រោចពីលើ

- revolving sprinkler /rɪˈvɒlvɪŋ ˈsprɪŋklə/ [n] ស្ព្រីងគ្លីចល័ត

**sprout** /sprəʊt/ [n] ពន្លក, លេចពន្លក

**sprout** /sprəʊt/ [v] បណ្តុះ, ដុះពន្លក

**spur** /spəː/ [n] ញកភ្នំ, ជួរភ្នំរង

**sputum** /ˈspjuːtəm/ [n] ស្លេស្ម, កំហាក

**squash** /skwɒʃ/ [n]

១. ល្ពៅក្តាម (ឈ្មោះវិទ្យាសាស្ត្រ *Cucurbita pepo*)

២. វិធីសង្កត់បំបែកជាលិកា

**squid** /skwɪd/ [n] (សទិសន័យ៖ cuttle fish) ត្រីមឹកបំពង់

**stability** /stəˈbɪlɪti/ [n] ស្ថិរភាព, ភាពនឹង, ភាពធន់, ភាពស៊ប់

- acid stability /ˈasɪd stəˈbɪlɪti/ [n] ភាពធន់នឹងអាស៊ីត
- aggregate stability /ˈagrɪgət stəˈbɪlɪti/ [n] ស្ថិរភាពនៃគ្រាប់ទម្រង់ (អាហ្គ្រេហ្គា) ដី
- alkali stability /ˈalkəlʌɪ stəˈbɪlɪti/ [n] ភាពធន់នឹងបាស
- chemical stability /ˈkɛmɪk(ə)l stəˈbɪlɪti/ [n] ភាពធន់នឹងសារធាតុគីមី
- corrosion stability /kəˈrəʊʒ(ə)n stəˈbɪlɪti/ [n] ភាពធន់នឹងកំណូត

- ecosystem stability /ˈiːkəʊsɪstəm stəˈbɪlɪti/ [n] ស្ថិរភាពប្រព័ន្ធអេកូឡូស៊ី
- environmental stability /ɪnvʌɪrənˈmɛnt(ə)l stəˈbɪlɪti/ [n] ស្ថិរភាពបរិស្ថាន
- food stability /fuːd stəˈbɪlɪti/ [n] ស្ថិរភាពស្បៀង
- oxidation stability /ɒksɪˈdeɪʃ(ə)n stəˈbɪlɪti/ [n] ភាពធន់នឹងអុកស៊ីតកម្ម
- stability of food stock [n] ស្ថិរភាពនៃការស្តុកស្បៀង (ទំហំដែលអាហារមូលដ្ឋានគន្លឹះសំខាន់ៗមានបម្រុងទុក គឺនៅតែអាចព្យាករណ៍បាននៅក្នុងរយៈពេលមួយ។ នេះគឺមិនបានផ្តល់ជាយោបល់ថាកម្រិតស្តុកត្រូវតែមានជាប់ជាប្រចាំនោះទេ ក៏ប៉ុន្តែគ្រាន់តែផ្តល់ជាយោបល់ថា រាល់ការប្រែប្រួលណាមួយ គឺស្ថិតនៅក្នុងការប៉ាន់ស្មានទុកជាមុន។)
- structure stability /ˈstrʌktʃə stəˈbɪlɪti/ [n] ស្ថិរភាពនៃទម្រង់ដី
- temperature stability /ˈtɛmp(ə)rətʃə stəˈbɪlɪti/ [n] ស្ថិរភាពសីតុណ្ហភាព
- thermal stability /ˈθəːm(ə)l stəˈbɪlɪti/ [n] ស្ថិរភាពកម្តៅ

**stable** /ˈsteɪb(ə)l/ [n] ក្រោលសេះ

***Stachyarpheta indica*** [sci.n] ស្មៅគ្រាប់ស្អិត

**stage** /steɪdʒ/ [n] ឋាស (មីក្រូទស្សន៍)

- evolution stage /ˌiːvəˈluːʃ(ə)n steɪdʒ/ [n] ដំណាក់នៃការវិវត្តន៍
- first stage /fəːst steɪdʒ/ [n] ដំណាក់ដំបូង
- growth stage /grəʊθ steɪdʒ/ [n] ដំណាក់កាលលូតលាស់ (ជាធម្មតានៅក្នុងការសិក្សាទៅលើភាវរស់ ដូចជាវដ្តជីវិតទាំងមូលរបស់រុក្ខជាតិ (ចាប់ពីចេញពន្លករហូតដល់ទុំ) ត្រូវបានគេបែងចែកជាដំណាក់កាលៗ)
- seedling stage /ˈsiːdlɪŋ steɪdʒ/ [n] ដំណាក់កាលសំណាប (ដំណាក់កាលដែលចាប់ផ្តើមដុះស្លឹកទី១ រហូតដល់ស្រូវមានស្លឹកពី ៤ ទៅ ៥ សន្លឹកដំបូង ឬរហូតទាល់តែដើមស្រូវចាប់ផ្តើមបែកគុម្ព ទើបលែងមានឈ្មោះថាសំណាប)
- stem elongation stage /stɛm iːlɒŋˈgeɪʃ(ə)n steɪdʒ/ [n] ដំណាក់កាលពន្លូតដើម
- tillering stage /ˈtɪlərɪŋ steɪdʒ/ [n] ដំណាក់បែកគុម្ព

**stagger** /ˈstagə/ [v] ផ្អៀងចុះឡើង, ទ្រេតទ្រោត

**stagnant** /ˈstagnənt/ [adj] នឹង

**stagnate** /stagˈneɪt/ [v] មិនរីកចម្រើន, គាំង

**stagnation** /stagˈneɪʃ(ə)n/ ភាពនឹងថ្កល់, ភាពគាំង

- water stagnation /ˈwɔːtə stagˈneɪʃ(ə)n/ [n] ភាពនៅនឹងថ្កល់នៃទឹក (មិនហូរ)

**stain** /steɪn/ [n] ល័ខ, ពណ៌, ដំណាក់ពណ៌, របៀបដាក់ពណ៌

- Gram stain /gram steɪn/ [n] ការបន្ស៊ីពណ៌ក្រាម

**stake** /steɪk/ [n] បង្គោលតូច (ដែលបោះលើដី បង្គោលដោតទៅលើដីជាចំណាំ អ្វីមួយ)

**stakeholder** /ˈsteɪkhəʊldə/ [n] បុគ្គលិកពាក់ព័ន្ធ, ស្ថាប័នពាក់ព័ន្ធ

**stalactite** /ˈstaləktʌɪt/ [n] ស្តាឡាក់ទីត (ថ្មដែលដុះច្រូងច្រាងនៅពិដានរូងភ្នំដោយទឹកភ្លៀងច្រោះថ្មកំបោរ ឬអាចុតសិលា)

**stalagmite** /ˈstaləgmʌɪt/ [n] ស្តាឡាក់មីត (ថ្មដែលដុះច្រូងច្រាងនៅបាតរូងភ្នំដោយទឹកភ្លៀងច្រោះថ្មកំបោរ)

**stalk** /stɔːk/ [n] ទង, ដើម, មែក

**stallion** /ˈstaljən/ [n] សេះបា

**stamen** /ˈsteɪmən/ [n] កេសរឈ្មោល (លម្អងផ្កា) (សរីរាង្គផ្ទុកលម្អងក្នុងពួករុក្ខជាតិគ្រាប់ជិត រួមមានថង់លម្អង និងទងកេសរឈ្មោល)

**stamina** /ˈstamɪnə/ [n] ភាពជាប់, អំណត់ធន់

**staminate** /ˈstamɪnət/ [adj] ចេញផ្កាឈ្មោល (សរីរាង្គមានតែលម្អង (កេសរឈ្មោល)។ គេអាចប្រើពាក្យនេះសំដៅទៅលើ រុក្ខជាតិឯកត្តៈឈ្មោលនៃពួករុក្ខជាតិមានភេទដាច់ពីគ្នា ឬផ្កាកន្ទ្រាម។)

**stanch** /stɑːn(t)ʃ/ [v] ទប់, ឃាត់, បិទ, ចុក (មិនឱ្យចេញឈាម)

**stand** /stand/ [n] ដើមពូជ, ព្រៃពូជ (ក្រុមពូជមួយនៃដើមឈើដែលមានភាពដូចគ្នា ក្នុងសមាសភាពការផ្សំឡើង ហើយនិងការតំរៀបខុសប្លែកពីក្រុមពូជនៅក្បែរៗ)

- plus stand /plʌs stand/ [n] ព្រៃពូជវិជ្ជមាន (ព្រៃឈើមួយដែលមានដើមឈើដែលផ្ទុកឧត្តមានុភាពនៃផេណូទីបល្អៗដោយមិនចាំបាច់មានដើមវិជ្ជមានទេ)
- provenance resource stand /ˈprɒv(ə)nəns rɪˈsɔːs stand/ [n] ប្រភពព្រៃពូជដើមកំណើត
- seed stand /siːd stand/ [n] ដើមមេ ឬពូជ (នៃបណ្តាដើមឈើដែលកំពុងដុះនៅក្នុងតំបន់ផលិតគ្រាប់ពូជ១)

- stand count /stand kaʊnt/ [n] ដើមប្រមូលផល (បរិមាណដើមដែលត្រូវគេប្រមូលផល ដែលស្ថិតនៅក្នុងបរិវេណច្រូតកាត់ ឬប្រមូលផល)
- two-aged stand /tuː eɪdʒd stand/ [n] តំបន់ដាំដុះដើមឈើ ដែលមានថ្នាក់អាយុពីរខុសៗគ្នា

**standard** /ˈstandəd/ [n]
១. ស្តង់ដា, ខ្នាតគំរូ, កម្រិតកំណត់បទដ្ឋាន, និយាម
២. (ចំពោះរុក្ខជាតិ) ត្របកលើ, ត្របកធំ

- air quality standard /ɛː ˈkwɒlɪti ˈstandəd/ [n] ស្តង់ដាគុណភាពខ្យល់
- air-emission standard /ɛː ɪˈmɪʃ(ə)n ˈstandəd/ [n] ស្តង់ដាអេមីស្យុងបញ្ចេញចោលទៅក្នុងខ្យល់
- emission standard /ɪˈmɪʃ(ə)n ˈstandəd/ [n] ស្តង់ដាអេមីស្យុង, និយាមនៃការបញ្ចេញសំណល់ឧស្ម័ន
- environmental standard /ɪnvʌɪrənˈmɛnt(ə)l ˈstandəd/ [n] ស្តង់ដាគុណភាពបរិស្ថាន
- international standard /ɪntəˈnaʃ(ə)n(ə)l ˈstandəd/ [n] ស្តង់ដាអន្តរជាតិ
- standard deviation /ˈstandəd diːvɪˈeɪʃ(ə)n/ [n] លម្អៀងគោល (តម្លៃលម្អៀងរបស់តម្លៃមធ្យម)
- standard of living /ˈstandəd ɒv ˈlɪvɪŋ/ [n] បទដ្ឋាននៃការរស់នៅ, កម្រិតជីវភាព
- water quality standard /ˈwɔːtə ˈkwɒlɪti ˈstandəd/ [n] ស្តង់ដាគុណភាពទឹក

**staph** /staf/ [abbr] ស្តាភីឡូកុក (ពាក្យកាត់ពីពាក្យ៖ Staphylococcus)

**Staphylococcus** /ˌstafɪlə(ʊ)ˈkɒkəs/ [n] ស្តាភីឡូកុក (មេរោគបង្កឱ្យមានខ្ទុះលើស្បែក)

**staple** /ˈsteɪp(ə)l/ [n] ផលិតផលសំខាន់

**starch** /stɑːtʃ/ [n] ម្សៅអាមីដុង, អាមីដុង (កាបូអ៊ីដ្រាតហើយក៏ជាសារធាតុចិញ្ចឹមផ្តល់ថាមពលដល់សត្វ និងរុក្ខជាតិ។ កាបូនអ៊ីដ្រាតកើតឡើងដោយសារថាមពលពន្លឺបានមកពីប្រតិកម្មគីមីរវាងទឹក និងឧស្ម័នកាបូនិចនៃខ្យល់។ នៅក្នុងអាមីដុងមានអាមីឡូស និងអាមីឡូប៉ិចទីន។)

**starfruit** /ˈstɑː fruːt/ [n] សូមមើលពាក្យ ៖ carambola

**electric starter** /ɪˈlɛktrɪk ˈstɑːtə/ [n] ដេម៉ាររ៉ (ចលករបញ្ឆេះទាក់ទាញចលករមួយទៀតដោយប្រើអាគុយ)

**starvation** /stɑːˈveɪʃn/ [n] ការស្រេកឃ្លាន

**stasis** /ˈstasɪs/ [n] ការឈប់ ឬការថយល្បឿន (ឈាមរត់)

**station** /ˈsteɪʃ(ə)n/ [n] ស្ថានីយ

- breeding station /ˈbriːdɪŋ ˈsteɪʃ(ə)n/ [n] ស្ថានីយបង្កាត់ពូជ
- field crop experimental station /fiːld krɒp ɪkˌspɛrɪˈmɛnt(ə)l ˈsteɪʃ(ə)n/ [n] ស្ថានីយពិសោធដំណាំវាល
- grass experiment station /grɑːs ɪkˈspɛrɪm(ə)nt ˈsteɪʃ(ə)n/ [n] ស្ថានីយពិសោធស្មៅ
- livestock experiment station /ˈlʌɪvstɒk ɪkˈspɛrɪm(ə)nt ˈsteɪʃ(ə)n/ [n] ស្ថានីយពិសោធលើបសុសត្វ
- orchard crop experimental station /ˈɔːtʃəd krɒp ɪkˌspɛrɪˈmɛnt(ə)l ˈsteɪʃ(ə)n/ [n] ស្ថានីយពិសោធដំណាំចម្ការ

**stationery** /ˈsteɪʃ(ə)n(ə)ri/ [n] សម្ភារការិយាល័យ

**statistics** /stəˈtɪstɪks/ [n] ស្ថិតិ, ស្ថិតិវិទ្យា (វិទ្យាសាស្ត្រដែលសិក្សាពីការវិភាគទៅលើលេខនព្វន្ត)

**status** /ˈsteɪtəs/ [n] ឋានៈ, ស្ថានភាព

**steam** /stiːm/ [n] ចំហាយ

- dry steam /drʌɪ stiːm/ [n] ចំហាយស្ងួត
- moist steam /mɔɪst stiːm/ [n] (សទិសន័យ៖ wet steam) ចំហាយសើម
- saturated steam /ˈsatʃəreɪtɪd stiːm/ [n] ចំហាយឆ្អែត
- water steam /ˈwɔːtə stiːm/ [n] (សទិសន័យ៖ water vapor) ចំហាយទឹក
- wet steam /wɛt stiːm/ [n] សូមមើលពាក្យ៖ moist steam

**steel** /stiːl/ [n] ដែកថែប

**steep** /stiːp/ [adj] ចោត (ឧ.ជម្រាលចោត)

**steep** /stiːp/ [v] ធ្វើឱ្យស៊ប់ (ទៅនឹងអ្វីមួយ)

**steer** /stɪə/ [n] គោគ្រៀវ

**stele** /stiːl/ [n] ស្ទែល (បំពង់សរសៃនាំកណ្តាលរបស់ឫស និងដើម)

**stellate** /ˈstɛleɪt/ [adj] រោមផ្កាយ (ប្រភេទរោមលើស្លឹក)

**stem** /stɛm/ [n] ទង, មែក, តួដើម, ដើម (ស្រូវ, រុក្ខជាតិ)

- aerial stem /ˈɛːrɪəl stɛm/ [n] ប្រភេទនៃគល់លើដី
- subterranean stem /ˌsʌbtəˈreɪnɪən stɛm/ [n] ប្រភេទគល់ក្នុងដី

- wire stem /wʌɪə stɛm/ [n] ជំងឺរលាកគល់ដូចខ្សែលួស (ជំងឺបង្កដោយផ្សិត *Rhizoctornia solani*)

**stemborer** /stɛmˈbɔːrə/ [n] ពពួកដង្កូវស៊ីរូងដើម
- dark headed stemborer /dɑːk ˈhɛdɪd stɛmˈbɔːrə/ [n] ដង្កូវស៊ីរូងដើមក្បាលខ្មៅ (ប្រភេទសត្វល្អិតចង្រៃស្ថិតក្នុងលំដាប់ Lepidoptera គ្រួសារ Pyralidae មេអំបៅមានពណ៌ដូចចំបើង ឬត្នោតស្រាលនៅពីលើកណ្តាលស្រោបតូចមានពណ៌ទឹកប្រាក់។ ដង្កូវរបស់វាមានក្បាលពណ៌ខ្មៅ និងដងខ្លួនមានឆ្នូត ៣ ពណ៌ត្នោតនៅលើខ្នង និង២ទៀតនៅសងខាង។)
- pink stemborer /pɪŋk stɛmˈbɔːrə/ [n] ដង្កូវរូងដើមផ្កាឈូក (ស្ថិតក្នុងអម្បូរ *Sesamia inferens* វាជាសត្វចង្រៃចម្បងៗ នៅក្នុងតំបន់ដែលដាំដំណាំ ២ ដងក្នុងមួយរដូវ ពីព្រោះតែនៅកន្លែងនោះមានរុក្ខជាតិជម្រកជាច្រើន។ វាទម្លាក់ពងនៅកន្លែងមានរុក្ខជាតិជម្រកជាច្រើន។)
- stripe stemborer /strʌɪp stɛmˈbɔːrə/ [n] ដង្កូវរូងដើមឆ្នូត
- white stemborer /wʌɪt stɛmˈbɔːrə/ [n] ដង្កូវស៊ីរូងដើមពណ៌ស (ប្រភេទសត្វល្អិតចង្រៃស្ថិតក្នុងលំដាប់ Lepidoptera គ្រួសារ Pyralidae)
- yellow stemborer /ˈjɛləʊ stɛmˈbɔːrə/ [n] ដង្កូវរូងដើមពណ៌លឿង (ប្រភេទសត្វល្អិតចង្រៃស្ថិតក្នុងលំដាប់ Lepidoptera គ្រួសារ Pyralidae។ វាជាដង្កូវស៊ីរូងដើមអម្បូរ *Scirpophaga incertulas* ដែលបំផ្លាញដំណាំស្រូវគ្រប់ដំណាក់កាលលូតលាស់ទាំងអស់។ វាជម្រុះដាក់ពងក្បែរចុងនៃបន្ទះស្លឹកពី ៥០ ទៅ ២០០ ពង ក្នុងមួយសម្បុក (សម្បុកពងវារាងពងក្រពើ) ដែលញាស់ក្នុងរយៈពេល ៨ថ្ងៃបន្ទាប់។ ដង្កូវវាពណ៌ក្រែម ហើយក្បាលពណ៌ក្រហមត្នោត។ ដុកឌឿពណ៌លឿងខ្ចីជាមួយស្នាមបែតងព្រឿងៗ ប៉ុន្តែវាប្រែជាត្នោតចាស់មុនវាកើតជាមេអំបៅ។ មេអំបៅញីមានពណ៌លឿង និងស្នាមអុចត្នោតយ៉ាងច្បាស់ នៅចំណុចកណ្តាលនៃស្នាមមុខ (forewing)។ ស្លាបក្រោយមានពណ៌ចំបើង។)

**stench** /stɛn(t)ʃ/ [v] សូមមើលពាក្យ៖ stink

***Stenella attenuata*** [sci.n] សូមមើលពាក្យ៖ pantropical spotted dolphin

***Stenella longirostris roseinventris*** [sci.n] សូមមើលពាក្យ៖ dwarf spinner dolphin

***Stenobracon nicevillei*** [sci.n] ពួកឱម៉ាល់ (បរាសិតលើដង្កូវរូងដើម)

**stenohaline** /ˌstɛnəʊˈheɪlʌɪn/ [adj] រស់នៅក្នុងទឹកប្រៃតិច

**stenosis** /stɪˈnəʊsɪs/ [n] ភាពរួម, ភាពស្ទួច, ការបង្រួមរន្ធ ឬផ្លូវនៃខ្លួន

**step** /stɛp/ [n] កាំជណ្តើរ
- valley-head step /ˈvali hɛd stɛp/ [n] កាំជណ្តើរថ្នាក់ៗនៅខាងលើនៃជ្រលង

**steppe** /stɛp/ [n] វាលស្តិប

**steppe solonchak** [n] ដីប្រៃស ប្រភេទសូឡុងឆាកតំបន់ស្តែប

***Sterculia lychnophora*** [sci.n] សូមមើលពាក្យ៖ malva nut

**stereoscope** /ˈstɛrɪə(ʊ)skəʊp/ [n] ស្តេរេអូទស្សន៍

**sterile** /ˈstɛrʌɪl/ [adj] ដែលគ្មានមេរោគ, ដែលអារ, និប្ផល (នៃសរីរាង្គដែលអារ ដែលមិនអាចបន្តពូជ, នៃអ្វីៗដែលរម្ងាប់មេរោគ)

**sterility** /stəˈrɪlɪti/ [n] ភាពអនាម័យ, ភាពឥតមានមីក្រុប, ភាពឥតជីជាតិ, និប្ផលភាព (ភាពអារ, ភាពដែលមិនអាចបន្តពូជបាន)
- hybrid sterility /ˈhʌɪbrɪd stəˈrɪlɪti/ [n] ភាពអាររបស់កូនកាត់ (សមត្ថភាពធ្លាក់ចុះរបស់កូនកាត់មួយចំនួនក្នុងការផលិតកាម៉េតរស់។ បញ្ហានេះបណ្តាលមកពីអវត្តមានរបស់គូក្រូម៉ូសូមអូម៉ូឡូក ដែលធ្វើឱ្យវាឡង់ពីរ មិនអាចបង្កើតបាននៅក្នុងដំណើរមេយ៉ូស។ ដូច្នេះ បណ្តាលឱ្យកាម៉េតមានចំនួន ក្រូម៉ូសូមមិនធម្មតា។)
- male sterility /meɪl stəˈrɪlɪti/ [n] និប្ផលភាពនៃអង្គធាតុឈ្មោល (ភាពដែលអង្គធាតុឈ្មោលមិនអាចមានលទ្ធភាពបន្តពូជបាន)

**sterilization** /stɛrɪlʌɪˈzeɪʃ(ə)n/ [n] ការរម្ងាប់មីក្រុប, បន្សាប (សំណល់), ការគ្រៀវ
- cold sterilization /kəʊld stɛrɪlʌɪˈzeɪʃ(ə)n/ [n] ការរម្ងាប់មីក្រុបត្រជាក់ (ដោយមិនប្រើកម្តៅ)
- dry-air sterilization /drʌɪ ɛː stɛrɪlʌɪˈzeɪʃ(ə)n/ [n] (សទិសន័យ៖ dry-heat sterilization) ការរម្ងាប់មីក្រុបដោយខ្យល់ស្ងួតក្តៅ

- dry-heat sterilization /drʌɪ hiːt stɛrɪlʌɪˈzeɪʃ(ə)n/ [n] សូមមើលពាក្យ៖ dry-air sterilization
- filter sterilization /ˈfɪltə stɛrɪlʌɪˈzeɪʃ(ə)n/ [n] (សទិសន័យ៖ filtration sterilization) ការរម្ងាប់មីក្រុបដោយច្រោះ
- filtration sterilization /fɪlˈtreɪʃn stɛrɪlʌɪˈzeɪʃ(ə)n/ [n] សូមមើលពាក្យ៖ filter sterilization
- flame sterilization /fleɪm stɛrɪlʌɪˈzeɪʃ(ə)n/ [n] ការរម្ងាប់មីក្រុបដោយអណ្ដាតភ្លើង
- gas sterilization /gas stɛrɪlʌɪˈzeɪʃ(ə)n/ [n] ការរម្ងាប់មីក្រុបដោយឧស្ម័ន
- heat sterilization /hiːt stɛrɪlʌɪˈzeɪʃ(ə)n/ [n] ការរម្ងាប់មីក្រុបដោយកម្ដៅ
- high sterilization /hʌɪ stɛrɪlʌɪˈzeɪʃ(ə)n/ [n] ការរម្ងាប់មីក្រុបដោយចរន្តអគ្គិសនីប្រេកង់ខ្ពស់
- infrared sterilization /ɪnfrəˈrɛd stɛrɪlʌɪˈzeɪʃ(ə)n/ [n] ការរម្ងាប់មីក្រុបដោយក្រហមអាំប្រា
- moist-heat sterilization /mɔɪst hiːt stɛrɪlʌɪˈzeɪʃ(ə)n/ [n] ការរម្ងាប់មីក្រុបដោយចំហាយ
- steam sterilization /stiːm stɛrɪlʌɪˈzeɪʃ(ə)n/ [n] ការរម្ងាប់មីក្រុបដោយចំហាយ
- ultrasonic sterilization /ʌltrəˈsɒnɪk stɛrɪlʌɪˈzeɪʃ(ə)n/ [n] ការរម្ងាប់មីក្រុបដោយសូរអ៊ុលត្រា
- ultraviolet sterilization (UV) /ʌltrəˈvʌɪələt stɛrɪlʌɪˈzeɪʃ(ə)n/ [n] ការរម្ងាប់មីក្រុបដោយកាំរស្មីស្វាយអ៊ុលត្រា
- x-ray sterilization /ˈɛksreɪ stɛrɪlʌɪˈzeɪʃ(ə)n/ [n] ការរម្ងាប់មីក្រុបដោយកាំរស្មីអ៊ិច

**sterilize** /ˈstɛrɪlʌɪz/ [v] ធ្វើការរម្ងាប់មេរោគ

**sterilizer** /ˈstɛrɪlʌɪzə/ [n] ប្រដាប់រម្ងាប់មីក្រុប

**sternum** /ˈstəːnəm/ [n] សូមមើលពាក្យ៖ keel-bone

**steroid** /ˈstɛrɔɪd/ [n] ស្តេរ៉ូអ៊ីត

**stethoscope** /ˈstɛθəskəʊp/ [n] ស្តេតូ, សោតាទស្សន៍, ប្រដាប់ពាក់នៅត្រចៀកស្ដាប់សួត ឬបេះដូង

**stickiness** /ˈstɪkɪnəs/ [n] ភាពអន្ទិល

**sticky** /ˈstɪki/ [adj] សូមមើលពាក្យ៖ adhesive

**stiff** /stɪf/ [adj] រឹង

**stifle** /ˈstʌɪf(ə)l/ [n] ជើងទុប

**stigma** /ˈstɪgmə/ [n] មាត់កេសរញី, ស្ទិចម៉ា (ជាផ្នែកមួយរបស់កេសរញី ដែលលម្អងត្រូវតែធ្លាក់ទើនៅលើនោះដើម្បីដុះនិងលូតទៅជួបអូវុល)

**stillbirth** /ˈstɪlbəːθ/ [n] កំណើតទារកដែលស្លាប់មុនពេលសម្រាល

**stillborn** /ˈstɪlbɔːn/ [adj] កើតស្លាប់

**stimulant** /ˈstɪmjʊl(ə)nt/ [n] គ្រឿងលើកកម្លាំង, ថ្នាំដាស់

**stimulate** /ˈstɪmjʊleɪt/ [v] ដាស់, ជំរុញ

**stimulation** /stɪmjʊˈleɪʃ(ə)n/ [n] រំញោចកម្ម, កម្រើកកម្ម (ព័ត៌មាន ហេតុការណ៍ ឬសារធាតុ ដែលធ្វើឱ្យមានការកក្រើកឡើងនៅក្នុងអារម្មណ៍ ឬក្នុងការលូតលាស់)

**stimulus** /ˈstɪmjʊləs/ [n] (ពហុវចនៈ៖ stimuli) សារធាតុជំរុញ, កត្តាជម្រុញ, គ្រឿងរំភ្ញោច

**sting** /stɪŋ/ [n] ទ្រនិច (សត្វល្អិត)

**stink** /stɪŋk/ [v] (សទិសន័យ៖ stench) ចោលក្លិនអសោច

**stipe** /stʌɪp/ [n] ដើមរបស់រុក្ខជាតិគ្មានសរសៃនាំ

**stipitate** /ˈstɪpɪteɪt/ [adj] មានទង (អំពីទម្រង់របស់រុក្ខជាតិ)

**stipule** /ˈstɪpjuːl/ [n] ស្លឹកស្នប, ខ្នាយស្នប, ខ្នាយស្លឹក (ផ្នែកតូចដែលដុះនៅគល់ទងស្លឹករបស់រុក្ខជាតិ ដែលមានស្លឹកតូចៗ នៅលើមែកនៅពេលវាជ្រុះ)

**stitch** /stɪtʃ/ [n] (សទិសន័យ៖ suture) ចេស, ការដេរភ្ជិតមុខរបួស

**stock** /stɒk/ [v] មានក្នុងស្តុក, ដាក់ក្នុងស្តុក

**stock** /stɒk/ [n]

១. ពូជគល់ផ្សាំ, ពូជគល់បំបៅ (ក្រុមមួយនៃរុក្ខជាតិមានត្រកូលរួមគ្នា ទោះបីមិនខុសប្លែកគ្នាខាងចំណាត់ថ្នាក់ត្រឹមប្រភេទផ្សេងៗ តែអាចខុសប្លែកគ្នាត្រង់ផលិតភាព ភាពមាំមួន ភាពធន់នឹងជំងឺ ឬលក្ខណៈផ្សេងៗនៃបរិស្ថាន ឬសរីរៈសាស្ត្រ)

២. ស្តុក

- female breeding stock /ˈfiːmeɪl ˈbriːdɪŋ stɒk/ [n] ស្តុកសត្វមេ (សត្វញី), ស្តុកសត្វញីសម្រាប់បង្កាត់
- food stock /fuːd stɒk/ [n] ការស្តុកស្បៀង (អាហារទាំងអស់ដែលទុកបម្រុងនៅតាមថ្នាក់គ្រួសារ សហគមន៍ តំបន់ ឬជាតិ។ សមាសភាគនៃតារាងតុល្យភាពស្បៀងដ៏សំខាន់ក្នុងការគណនា។)
- male breeding stock /meɪl ˈbriːdɪŋ stɒk/ [n] ស្តុកបាពូជ

**stolon** /ˈstəʊlɒn/ [n] គល់វារ, ខ្នែងខ្យល់, ដៃ (ខ្នែង) (រុក្ខជាតិ ឬស្មៅមានចន្លោះថ្នាំងអាចលូតវែង វារលើទឹក ឬក្នុងទឹក។ កាលណា ថ្នាំងនោះចាប់ឫស នោះវាបង្កើតបានជារុក្ខជាតិថ្មី (កំប្លោក ស្មៅ ត្រចៀកក្រាញ់ជាដើម))

**stomach** /ˈstʌmək/ [n] (សូមមើលពាក្យ៖ abomasum)

**stomachic** /stəˈmakɪk/ [adj] ដែលទាក់ទងនឹងក្រពះ

**stomata** /ˈstəʊmətə/ [n] រន្ធស្តូម៉ាត (រន្ធតូចៗនៅផ្ទៃខាងក្រោមនៃស្លឹក)

**stomatitis** /ˌstəʊməˈtʌɪtɪs/ [n] ជំងឺរលាកក្នុងមាត់

***Stomopteryx subsecivella*** [sci.n] ដង្កូវស៊ីញ៉ៀស្លឹកសណ្តែកដី

**stone free** /stəʊn friː/ [adj] គ្មានថ្ម

**stone hand-mill** /stəʊn hand mɪl/ [n] ត្បាល់ថ្មកិនម្សៅ

**stone lattice** /stəʊn ˈlatɪs/ [n] ប្រព័ន្ធដុំថ្ម, កន្លែងដែលមានដុំ ឬផ្ទាំងថ្មច្រើន

**stone pavement** /stəʊn ˈpeɪvm(ə)nt/ [n] ការក្រាលដោយថ្ម

**stone** /stəʊn/ [n]

១. (ចំពោះសត្វ) សូមមើលពាក្យ៖ calculus

២. (ចំពោះដី) ថ្ម

៣. (ចំពោះរុក្ខជាតិ) ប្រភេទគ្រាប់ថ្ម (រឹងដូចថ្ម), ផ្លែរឹងដែលមានគ្រាប់រឹងតែមួយ ឬច្រើន

- broken stone /ˈbrəʊk(ə)n stəʊn/ [n] (សទិសន័យ៖ chipping) កម្ទេចថ្មបែកបាក់, កម្ទេចថ្ម
- crushed stone /krʌʃd stəʊn/ [n] សូមមើលពាក្យ៖ ballast
- cut stone /kʌt stəʊn/ [n] ថ្មចិតឬកាត់, ដុំថ្មកាត់
- fire-stone /ˈfʌɪə stəʊn/ [n] ថ្មកេះ (ដើម្បីបញ្ចេញភ្លើង)
- gall stone /gɔːl stəʊn/ [n] គ្រួសប្រមាត់ (គ្រួសនៅក្នុងប្រមាត់)
- round stone /raʊnd stəʊn/ [n] ថ្មមូល
- rubble stone / ˈrʌb(ə)l stəʊn/ [n] សូមមើលពាក្យ៖ rubble

**small stoneblock** /smɔːl stəʊnbak/ [n] (ចំពោះធរណីវិទ្យា) (សទិសន័យ៖ bulder, largestone) ដុំថ្មតូច (ទំហំ ២៥ ស.ម)

**stoneland** /stəʊnland/ [n] (សទិសន័យ៖ stony land) ដីដែលមានថ្មច្រើន

**stonepacking** /stəʊnˈpakɪŋ/ [n] កញ្ចប់ថ្ម

**stoniness** /ˈstəʊnɪnəs/ [n] សមាមាត្រដុំថ្មនៅក្នុងដី

**stool** /stuːl/ [n]

១. (ចំពោះរុក្ខជាតិ) ការកាត់មែក, ការកាត់ដើម, ការកាត់ឫស

២. (ចំពោះសត្វ) សូមមើលពាក្យ៖ feces

**storability** /stɔːrəˈbɪlɪti/ [n] លទ្ធភាពរក្សាទុកបាន (រយៈពេលនៃសក្តានុពលជីវិតរបស់គ្រាប់នៅក្រោមលក្ខខណ្ឌស្តុកទុកសមរម្យ)

**storage** /ˈstɔːrɪdʒ/ [n] ការស្តុកទុក

- seed storage /siːd ˈstɔːrɪdʒ/ [n] ការស្តុកទុកគ្រាប់, វិធីសាស្ត្រនៃការការពារគ្រាប់ពូជ (ដោយរក្សាដំណុះនៅក្នុងរយៈពេលជាក់ណាមួយ។ ការរក្សាទុកគ្រាប់ពូជអាចរួមមានដំណើរការក្នុងការសម្ងួត ឬការប្រើប្រាស់ទូរទឹកកកជាដើម)

**store** /stɔː/ [v] ស្តុកទុក

**store** /stɔː/ [n] ស្តុក

- ground water store /graʊnd ˈwɔːtə stɔː/ [n] ស្តុកទឹកនៅក្នុងដី

**storm** /stɔːm/ [n] ព្យុះ

- cyclonic storm /sʌɪˈklɒnɪk stɔːm/ [n] សូមមើលពាក្យ៖ cyclone
- dust storm /dʌst stɔːm/ [n] ព្យុះធូលី
- rain storm /reɪn stɔːm/ [n] ព្យុះភ្លៀង
- sand storm /sand stɔːm/ [n] ព្យុះខ្សាច់
- snow storm /snəʊ stɔːm/ [n] ព្យុះទឹកសន្សើម, ព្យុះព្រិល

**stove** /stəʊv/ [n] ចង្ក្រាន

**strain** /streɪn/ [n] ពូជ, គល់ផ្សាំ, គល់បំបៅ

- pure strain /pjʊə streɪn/ [n] (សទិសន័យ៖ pure line) ពូជសុទ្ធ

**strainer** /ˈstreɪnə/ [n] កញ្ច្រែងត្រង, កន្ត្រង

**strand** /strand/ [n] ច្រាំងលិចទឹកនៅពេលទឹកជោរហើយគោកពេលទឹកនាច

**strangulation** /straŋgjʊˈleɪʃ(ə)n/ [n] ការរាំងស្ទះទឹក និងសារធាតុចិញ្ចឹម (ការស្ទះដំណើរកាត់របស់ទឹក និងសារធាតុចិញ្ចឹមនៅស្រទាប់ក្រោមសម្បក (cambium) ដោយសារការរួមតូចរបស់សម្បកឈើ។ ការធ្វើឱ្យរាំងស្ទះដល់ដំណើរជាតិទឹក និងសារធាតុចិញ្ចឹមនេះដែលគេប្រើជាកត្តាសម្រាប់ជំរុញឱ្យឆាប់ចេញផ្កា។)

**strategy** /ˈstratɪdʒi/ [n] យុទ្ធសាស្ត្រ

- breeding strategy /ˈbriːdɪŋ ˈstratɪdʒi/ [n] យុទ្ធសាស្ត្របង្កាត់ពូជ, យុទ្ធសាស្ត្រជម្រើសពូជ (ឧ. ចំពោះរុក្ខជាតិ វិធានការមួយនៃការគ្រប់គ្រងសុរុង្គិកម្មសេនេទិចនៃប្រភេទឈើមួយដែលគេអនុវត្តក្នុងព្រៃដាំ)

**stratification** /stratɪfɪˈkeɪʃ(ə)n/ [n] ដំណុះជាស្រទាប់, វិធីធ្វើប្រព្រឹត្តិកម្មដាក់សំដិលជាស្រទាប់ (ការធ្វើប្រព្រឹត្តកម្មគ្រាប់សម្ងំដោយដាក់វាឱ្យស្រូបសំណើមមួយរយៈនៅក្នុងសីតុណ្ហភាពណាមួយ។ ការដាក់ជាស្រទាប់ថ្នាក់ឱ្យត្រូវសំណើមត្រជាក់ ផ្អែកតាមការធ្វើប្រព្រឹត្តកម្មតាមប្រពៃណីនៃគ្រាប់នៅតំបន់ត្រជាក់បង្គួរ ដោយដាក់គ្រាប់សើមនៅក្នុងលក្ខខណ្ឌត្រជាក់ (ដើមឡើយដាក់វាជាស្រទាប់ឆ្លាស់គ្នាជាមួយមជ្ឈដ្ឋានសើម)។ ក្រោមការដាក់សំដិលក្តៅ-សើម គ្រាប់ត្រូវបានរក្សានៅក្នុងសីតុណ្ហភាពមួយដែលមានសកម្មភាពសរីរៈការអនុវត្តមាននេះត្រូវបានគេប្រើ ឧ. គ្រាប់ក្រោយពីបន្ទុំ។)

- naked stratification /ˈneɪkɪd stratɪfɪˈkeɪʃ(ə)n/ [n] ការធ្វើប្រព្រឹត្តិកម្មគ្រាប់ក្នុងទឹកត្រជាក់ (ការធ្វើប្រព្រឹត្តិកម្មគ្រាប់ក្នុងទីត្រជាក់ដោយមិនប្រើសារធាតុចិញ្ចឹមផ្ទុកសំណើម)
- stratification bedding /stratɪfɪˈkeɪʃ(ə)n ˈbɛdɪŋ/ [adj] សភាពជាស្រទាប់ៗ

**stratify** /ˈstratɪfʌɪ/ [v] ដុះជាស្រទាប់

**stratigraphy** /strəˈtɪgrəfi/ [n] ស្រទាប់វិទ្យា

**stratosphere** /ˈstratəˌsfɪə/ [n] មណ្ឌលអាកាសស្ងប់, ស្រ្តាតូស្វ៊ែរ (តំបន់ដែលមានខុសគ្នាជាខ្លាំងនៃបរិយាកាសនៅស្រទាប់ខាងលើក្នុងត្រូបោះស្វ៊ែដែលលាតសន្ធឹងចាប់ពីចម្ងាយប្រមាណ ១០គ.ម (៨គ.ម ក្នុងតំបន់ដែលមានរយៈទទឹងខ្ពស់ ដល់ ១៦គ.ម ក្នុងតំបន់ត្រូពិច) រហូតលប្រមាណ ៥០គ.ម)

**straw mushroom** /strɔː ˈmʌʃruːm/ [n] ផ្សិតចំបើង (ឈ្មោះវិទ្យាសាស្ត្រ *Volvariella volvacea*)

**straw** /strɔː/ [n] ចំបើង

- rice straw /rʌɪs strɔː/ [n] ចំបើង

**straw burning** /strɔː ˈbəːnɪŋ/ [n] ការដុតចំបើង

**straw chopper** /strɔː ˈtʃɒpə/ [n] ប្រដាប់កាត់ចំបើង

**straw spreader** /strɔː ˈsprɛdə/ [n] ប្រដាប់ពង្រាយចំបើង

**streak** /striːk/ [n] បន្ទះពណ៌ដាក់ពីលើផ្ទៃមានពណ៌ខុសគ្នា

**stream** /striːm/ [n] ស្ទឹង, អូរ

- muddy stream /ˈmʌdi striːm/ [n] ចរន្តភក់
- rock stream /rɒk striːm/ [n] ចរន្តថ្ម
- small stream /smɔːl striːm/ [n] កូនអូរ
- cytoplasmic streaming /sʌɪtə(ʊ)ˈplazmɪk ˈstriːmɪŋ/ [n] វិហូរស៊ីតូប្លាស

***Streblus asper*** [sci.n] ស្នាយ

**strength** /strɛŋθ/ [n] កម្លាំង, របឹង, ភាពរឹងមាំ

- bond strength /bɒnd strɛŋθ/ [n] កម្លាំងសម្ពន្ធ
- culm strength /kʌlm strɛŋθ/ [n] ភាពរឹងមាំនៃដើម (លទ្ធភាពនៃរុក្ខជាតិដែលអាចទ្រាំទ្រនឹងកម្លាំងខ្យល់បក់ហើយនៅឈរមិនដួល)
- soil strength /sɔɪl strɛŋθ/ [n] របឹងដី

**Streptococcus** /ˌstrɛptə(ʊ)ˈkɒkəs/ [n] មេរោគមួយជំពូកមានរាងមូលពេញ ដែលបំបែកខ្លួនវាជាច្រើនទៀត មានភាពជាប់គ្នាជាច្រវាក់, ស្ត្រេបតូកូក (មេរោគ)

**streptomycin** /ˌstrɛptə(ʊ)ˈmʌɪsɪn/ [n] ស្ត្រិបតូមីស៊ីន

**stress** /strɛs/ [n]

១. កង្វះលក្ខខណ្ឌគ្រប់គ្រាន់ (នៅក្រោមលក្ខខណ្ឌលូតលាស់មិនប្រសើរដូចជា ខ្វះទឹក សីតុណ្ហភាពទាបពេក ឬខ្ពស់ពេក ខ្វះពន្លឺ ឬជីជាដើម)

២. ភាពតានតឹង, ភាពមិនសមប្រកប, ស្ត្រេស

- natural stress /ˈnatʃ(ə)r(ə)l strɛs/ [n] ស្ត្រេសដោយកត្តាធម្មជាតិ
- water stress /ˈwɔːtə strɛs/ [n] សញ្ញាកង្វះទឹក, ស្ត្រេសទឹក (ភាពរួញស្វិតរបស់រុក្ខជាតិ បណ្តាលមកពីការភាយទឹកចេញមានបរិមាណច្រើនជាងការស្រូបទឹកចូលតាមរយៈឫស)
- biotic stress /bʌɪˈɒtɪk strɛs/ [n] ជីវស្ត្រេស (ការគំរាមគំហែងដោយវត្ថុមានជីវិត)

**stretcher** /ˈstrɛtʃə/ [n] ស្នែងរបួស ឬដឹកអ្នកជំងឺ

**striated** /strʌɪˈeɪtɪd/ [adj] ឆ្នូត

**strict** /strɪkt/ [adj] លូតត្រង់យ៉ាងរឹង (អំពីទម្រង់របស់រុក្ខជាតិ)

**stricture** /ˈstrɪktʃə/ [n] ការរួម

**stridor** /ˈstrʌɪdə/ [n] សូរសំឡេងអាក្រក់ឮដោយការដកដង្ហើមមកពីតៀតបំពង់ក

**strinkage** /ˈstrɪŋkɪdʒ/ [n] ការដកថយ, ការស្រក, ការបង្រួម (ឧ. ដីឥដ្ឋ)

**strip** /strɪp/ [v] ដកយកចេញ

**stripe** /strʌɪp/ [n] ជំងឺឆ្នូតបៃតងចាស់

- stone stripe /stəʊn strʌɪp/ [n] ដីមានដុំថ្មរៀបឆ្នូតៗ
- zebra stripe /ˈzɛbrə strʌɪp/ [n] ជំងឺឆ្នូតបង្កង់ (ស្នាមពណ៌លឿងដែលកាត់ទទឹង ឬបណ្តោយនៃស្លឹកសំណាប ហើយបន្ទាប់មកក៏រលាយបាត់វិញ)

**striped flying barb** /strʌɪpt ˈflʌɪɪŋ bɑːb/ [n] ត្រីចង្វាភ្លៀង (ឈ្មោះវិទ្យាសាស្ត្រ *Esomus metallicus*)

**striped horseface loach** /strʌɪpt hɔːsfeɪs ləʊtʃ/ [n] ត្រីឫសចេក (ឈ្មោះវិទ្យាសាស្ត្រ *Acantopsis* sp.)

**strobilus** /ˈstrəʊbɪləs/ [n] (ពហុវចនៈ៖ strobili) ផ្កាពួករុក្ខជាតិស៊ីមណ្ឌស្តែម (កោននៃរុក្ខជាតិស្លឹកម្ជុល (ស្រល់) និងរុក្ខជាតិផ្សេងទៀតណាមួយនោះ។ strobilusនេះ មានផ្ទុកសរីរាង្គបន្តពូជមានភេទ១ ឬទាំង២ភេទ។ មុន និងក្នុងកំឡុងពេលលម្អង ពេលគេតែងហៅថាជាផ្កា ហើយក្រោយពីនោះមកបន្តិចគេហៅវាជាកូនកោន។)

**stroke** /strəʊk/ [n] ការចាប់ឈឺ (ទាន់ហន់), ជំងឺស្ទ្រូក

**stroma** /ˈstrəʊmə/ [n] ស្ត្រូម៉ា, ប៉ារ៉ង់ស៊ីម

**strong** /strɒŋ/ [adj] ខ្លាំង

**strongyles** /ˈstrɒndʒɪl/ [n] ស្ត្រុងស៊ីល (ពួកដង្កូវណេម៉ាតូតដែលបង្កជំងឺបរាសិតដល់សត្វពាហនៈ និងបក្សី)

**strongyloidiasis** /ˌstrɒndʒɪlɔɪˈdʌɪəsɪs/ [n] ស្ត្រិងស៊ីឡូអ៊ីតដេ (ប្រភេទដង្កូវខ្លួនមូលដែលមានវត្តមាននៅតំបន់ត្រូពិច និងមានចម្លងជំងឺទៅកាន់ពោះវៀនដែលអាចបណ្តាលឱ្យរាគ)

**Strontium** /ˈstrɒntɪəm/ [n] ស្ត្រុងចូម (និមិត្តសញ្ញាគីមី Sr)

**strophiole** [n] ស្ត្រូហ្វីល (សាច់តូចមួយដែលដុះចេញពីបណ្តាផ្នែកផ្សេងៗនៃសម្បកគ្រាប់ ឧ. ទងបុប្ផាណ្ឌ ឬសណ្តង់អូវុល អូវុលផ្កាប់ ឬអូវុលផ្តេក)

**structure** /ˈstrʌktʃə/ [n] ទម្រង់, រចនាសម្ពន្ធ

- amorphous structure /əˈmɔːfəs ˈstrʌktʃə/ [n] ទម្រង់ដែលគ្មានរាងប្រាកដ ឬគ្មានរូបជាគ្រាប់ៗ
- analogous structure /əˈnaləgəs ˈstrʌktʃə/ [n] ទម្រង់អាណាឡូក (ទម្រង់ដែលមានមុខងារដូចគ្នា ប៉ុន្តែមានប្រភពខុសគ្នា នៅពេលដែលប្រៀបធៀបជាមួយទម្រង់ផ្សេងទៀត។ ឧ. ភ្នែកមនុស្ស និងភ្នែករបស់មឹក)
- angular blocky structure /ˈaŋgjʊlə blɒk ˈstrʌktʃə/ [n] ទម្រង់ពហុកោណដែលមានជ្រុងមុត
- ashy structure /ˈaʃi ˈstrʌktʃə/ [n] ទម្រង់ម៉ដ្ឋដូចផេះ
- bench structure /bɛn(t)ʃ ˈstrʌktʃə/ [n] ទម្រង់ជាស្រទាប់ (រឹងហើយក្រាស់)
- block-like structure /blɒk-lʌɪk ˈstrʌktʃə/ [n] (សទិសន័យ៖ polyhedral structure) ទម្រង់ជាពហុកោណ
- blocky structure /blɒki ˈstrʌktʃə/ [n] ដីដុំៗ
- breccia-like structure /ˈbrɛtʃə lʌɪk ˈstrʌktʃə/ [n] សូមមើលពាក្យ៖ brecciation
- cellular structure /ˈsɛljʊlə ˈstrʌktʃə/ [n] ទម្រង់ជាកោសិកា
- clod structure /klɒd ˈstrʌktʃə/ [n] សូមមើលពាក្យ៖ lum-aggregate
- columnar structure /kəˈlʌmnə ˈstrʌktʃə/ [n] (សទិសន័យ៖ column-like structure) ទម្រង់បញ្ឈរដូចសសរ
- column-like structure /ˈkəlʌm-lʌɪk ˈstrʌktʃə/ [n] (សទិសន័យ៖ columnar structure) ទម្រង់បញ្ឈរដូចសសរ
- complex structure /ˈkɒmplɛks ˈstrʌktʃə/ [n] សូមមើលពាក្យ៖ compound
- crumb structure /krʌm ˈstrʌktʃə/ [n] (សទិសន័យ៖ crummy structure) ទម្រង់ខ្ទេច, ទម្រង់មូលៗដូចគ្រាប់ពោត (០.២-៥.០ ម.ម)
- crummy structure /ˈkrʌmi ˈstrʌktʃə/ [n] សូមមើលពាក្យ៖ crumb structure
- cube-like structure /kjuːb-lʌɪk ˈstrʌktʃə/ [n] ទម្រង់ជាគូប ឬជាដុំគូប
- earthworm dejection structure /ˈəːθwəːm dɪˈdʒɛkʃ(ə)n ˈstrʌktʃə/ [n] ទម្រង់ដុំមូលៗដែលកើតពីអាចម៍ជន្លេន
- embryonal structure /ˈɛmbrɪən(ə)l ˈstrʌktʃə/ [n] (សទិសន័យ៖ weak structure) ទម្រង់ដែលទើបតែចាប់ផ្តើមកើត, ទម្រង់ខ្ចី
- finely granular structure /ˈfʌɪnli ˈgranjʊlə ˈstrʌktʃə/ [n] សូមមើលពាក្យ៖ pounder-like structure
- flake structure /fleɪk ˈstrʌktʃə/ [n] (សទិសន័យ៖ meal structure) ទម្រង់ដូចជាសំណុំជាដុំស្រាលៗ

- fluidal structure /ˈfluːɪd(ə)l ˈstrʌktʃə/ [n] ទម្រង់រាវខាប់ (អាចហូរបាន)
- fragmental structure /ˌfragˈmɛnt(ə)l ˈstrʌktʃə / [n] ទម្រង់ជាដុំៗ
- granular structure /ˈgranjʊlə ˈstrʌktʃə/ [n] ទម្រង់គ្រាប់, ទម្រង់ជាគ្រាប់ៗដាច់ពីគ្នា, ទម្រង់ជាគ្រាប់មូលៗ (០.២-១០ ម.ម)
- honeycomb structure /ˈhʌnikəʊm ˈstrʌktʃə/ [n] តំបន់បាតខ្ទះដែលច្រោះដោយកម្លាំងខ្យល់
- laminar structure /ˈlamɪnə ˈstrʌktʃə/ [n] សូមមើលពាក្យ៖ platy structure
- large nutty structure /lɑːdʒ ˈnʌti ˈstrʌktʃə/ [n] ទម្រង់រាងមូលៗ ហើយធំ (ទំហំ ២-៥ស.ម)
- lattice structure /ˈlatɪs ˈstrʌktʃə/ [n] ទម្រង់ជាប្រជីសខ្វែងគ្នា
- massive structure /ˈmasɪv ˈstrʌktʃə/ [n] ទម្រង់ផ្ទាំងៗ, ទម្រង់ដុំៗ
- meal structure /miːl ˈstrʌktʃə/ [n] សូមមើលពាក្យ៖ flake structure
- mesh structure /mɛʃ ˈstrʌktʃə/ [n] (សទិសន័យ៖ reticulated structure, netted structure) ទម្រង់ជាបណ្ដាញ
- mortar structure /ˈmɔːtə ˈstrʌktʃə/ [n] ទម្រង់ជាបោគុង
- netted structure /nɛtiːd ˈstrʌktʃə/ [n] សូមមើលពាក្យ៖ mesh structure
- nutty structure /ˈnʌti ˈstrʌktʃə/ [n] (សទិសន័យ៖ cuboid) ទម្រង់ជាគ្រាប់មូលៗ (ទំហំ ០.៥-៤.០ ស.ម)
- pea-like structure /'piː-lʌɪk ˈstrʌktʃə/ [n] ទម្រង់ដូចគ្រាប់សណ្ដែកបារាំង
- phylliform structure /ˈfɪlʌɪtfɔːm ˈstrʌktʃə/ [n] សូមមើលពាក្យ៖ platy structure
- plate-like structure /ˈplat-lʌɪk ˈstrʌktʃə/ [n] សូមមើលពាក្យ៖ platy structure
- platy structure /ˈplati ˈstrʌktʃə/ [n] (សទិសន័យ៖ phylliform structure, plate-like structure, laminar structure) ទម្រង់ជាបន្ទះ (កម្រាស់ ១-៣ ស.ម), ទម្រង់ជាបន្ទះស្ដើងៗ
- polyhedral structure /ˌpɒlɪˈhiːdrəl ˈstrʌktʃə/ [n] (សទិសន័យ៖ block-like structure) ទម្រង់ជាពហុកោណ
- population age structure /pɒpjʊˈleɪʃ(ə)n eɪdʒ ˈstrʌktʃə/ [n] រចនាសម្ពន្ធអាយុប្រជាជន
- population structure /pɒpjʊˈleɪʃ(ə)n ˈstrʌktʃə/ [n] រចនាសម្ពន្ធក្រុមពូជ (ការរៀបចំលំដាប់នៃបម្រែបម្រួលសេនេទិចនៅក្នុងនិងក្នុងរវាង (ចំណោម) ក្រុមពូជ)
- pounder-like structure /ˈpaʊndə-lʌɪk ˈstrʌktʃə/ [n] (សទិសន័យ៖ finely granular structure) ទម្រង់ម៉ដ្ឋដូចម្សៅ ឬធូលី
- prismatic structure /prɪzˈmatɪk ˈstrʌktʃə/ [n] (សទិសន័យ៖ prism-like structure) ទម្រង់ជាព្រីស (ដែលមានកំពូលរាងមូល)
- prism-like structure /ˈprɪz(ə)m-lʌɪk ˈstrʌktʃə/ [n] សូមមើលពាក្យ៖ prismatic structure
- reticulated structure /rɪˈtɪkjʊleɪtɪd ˈstrʌktʃə/ [n] សូមមើលពាក្យ៖ mesh structure
- schistose structure /ˈʃɪstəʊs ˈstrʌktʃə/ [n] ទម្រង់ផ្ដេកជាស្រទាប់ក្រាស់ៗ (ក្រាស់ជាង ៥ ស.ម)
- simple structure /ˈsɪmp(ə)l ˈstrʌktʃə/ [n] ទម្រង់សុទ្ធ ឬធម្មតា
- sleet-like structure /sliːt-lʌɪk ˈstrʌktʃə/ [n] ទម្រង់ដូចជាព្រិលគ្រាប់ល្អិត
- soil structure /sɔɪl ˈstrʌktʃə/ [n] ទម្រង់ដី
- squamose structure [n] ទម្រង់ដូចស្រកាត្រី (ទ្រនុងសងខាងឡើងលើ)
- strong structure /strɒŋ ˈstrʌktʃə/ [n] ទម្រង់ច្បាស់លាស់
- subangular blocky structure /subˈaŋgjʊlə blɒkiː ˈstrʌktʃə/ [n] ទម្រង់ពហុកោណដែលមានជ្រុងទាល
- undefined structure /ʌndɪˈfʌɪnd ˈstrʌktʃə/ [n] ទម្រង់ដែលមិនអាចវិនិច្ឆ័យបាន
- vesicular structure /vɪˈsɪkjʊlə ˈstrʌktʃə/ [n] ទម្រង់រាងជាដំណក់ទឹក, ទម្រង់ជារន្ធខ្យល់ទ្រវែង
- weak structure /wiːk ˈstrʌktʃə/ [n]
  ១. សូមមើលពាក្យ៖ embryonal structure
  ២. ទម្រង់ធូរទូលាយ, ទម្រង់រយាល

**structureless** /ˈstrʌktʃ(ə)ləs/ [adj] ដែលគ្មានទម្រង់

**strychnine** /ˈstrɪkniːn/ [n] ស្ទ្រិចនីន (សារជាតិពុលនៅក្នុងគ្រាប់ស្លែង)

***Strychnos nux-vomica*** [sci.n] សូមមើលពាក្យ៖ nux vomica

**stubble** /ˈstʌb(ə)l/ [n] ជញ្រ្ជាំង, គល់ជញ្រ្ជាំង

**stump** /stʌmp/ [n]

១. (ចំពោះរុក្ខជាតិ) គល់ឈើ

២. (ចំពោះសត្វ) ដៃ ឬជើងដែលកំបុត

**stunt** /stʌnt/ [v] ក្រិន

**stunt** /stʌnt/ [n] ក្រិន

- grassy stunt /ˈgrɑːsi stʌnt/ [n] ជំងឺតឿ (ជំងឺវីរុសចម្លងមកពីមមាចត្នោត។ ជំងឺនេះ បណ្ដាលឱ្យស្រូវតឿ (ក្រិន) បែកគុម្ពខ្លាំងខុសពីធម្មតា ភាពទាបនៃដើមគឺបណ្ដាលមកពីភាពខ្លីនៃស្រទបស្លឹក បន្ទះស្លឹក និងចន្លោះថ្នាំង។ ស្លឹក មានលក្ខណៈរាវតូចត្រង់ ជាទូទៅរាងលឿងទៅលឿងបៃតង ជាមួយអុចខ្មៅៗច្រើន។ ស្រូវដែលកើតជំងឺនេះ មិនមានផលិតគ្រាប់ទេ។), ជំងឺតឿស្មៅ
- ragged stunt /ˈragɪd stʌnt/ [n] ជំងឺតឿរួញស្លឹក, ជំងឺតឿរមូលស្លឹក (ជំងឺវីរុសលើដំណាំស្រូវដែលឆ្លងតាមរយៈពួកមមាចត្នោត។ ជំងឺនេះបណ្ដាលឱ្យដើមស្រូវតឿ ចំនួនដើមថយចុះ ស្លឹករមួល ឬជ្រួញស្លឹក និងប៉ោងហើមតាមសរសៃវែននៃស្លឹក។ ក្នុងករណីនេះ វាធ្វើឱ្យមានការយឺតយ៉ាវក្នុងការចេញផ្កា និងចេញកួរ ឬជួនកាលចេញបានត្រឹមតែពាក់កណ្ដាល ប៉ុន្តែគ្មានដាក់គ្រាប់។)

**stunted** /stʌntɪd/ [adj] ដែលក្រិន

**stunting** /stʌntɪŋ/ [n] ការដុះធេញៗ, ការក្រិន (រោគសញ្ញារបស់រុក្ខជាតិដែលតឿខុសធម្មតា)

**style** /stʌɪl/ [n] ទងកេសរញី, កកេសរញី, បំពង់កេសរញី (ទងរបស់កេសរញីដែលនៅចន្លោះស្ទិចម៉ាត និងអូវុល)

**stylo** /ˈstʌɪləʊ/ [n] ស្មៅស្ទីឡូ (ឈ្មោះវិទ្យាសាស្ត្រ៖ *Stylosanthes guianensis*)

***Stylosanthes guianensis*** [sci.n] សូមមើលពាក្យ៖ stylo

**styptic** /ˈstɪptɪk/ [adj] ថ្នាំឃាត់ ឬទប់

**sub-** /sʌb/ [prefix] (សទិសន័យ៖ under, below) បុព្វបទមានន័យថា ក្រោម

**subculture** /ˈsʌbkʌltʃə/ [n] ការបណ្ដុះកូនឈើពីជាលិកា (ដំណើរនៃការបណ្ដុះកូនឈើពីជាលិកា ដែលនៅក្នុងនោះជាលិការបស់រុក្ខជាតិ ត្រូវបានបែងចែក ហើយផ្ទេរដាក់បណ្ដុះនៅក្នុងសារធាតុបណ្ដុះស្រស់)

**subcutaneous** /ˌsʌbkjuːˈteɪnɪəs/ [adj] ក្រោមស្បែក

**sublingual** /sʌbˈlɪŋgw(ə)l/ [adj] ក្រោមអណ្ដាត

**sublining** [n] ការបង្កាត់ពីក្រុមពូជច្រើន (ការប្រើប្រាស់ក្រុមពូជបង្កាត់ច្រើន ដើម្បីជៀសវាងការបង្កាត់ក្នុង នៅចម្ការផលិតគ្រាប់ពូជ)

**submersion** /səbˈməːʒn/ [n] ការពន្លិចទឹក, ភាពលិចទឹក

**submucous** /ˌsʌbmjʊːˈkəʊs/ [n] ដែលនៅខាងក្រោមស្រទះស្លេស្ម

**subpopulation** /sʌbpɒpjʊˈleɪʃ(ə)n/ [n] អនុតំបន់ក្រុមពូជ (អនុតំបន់នៃការបង្កាត់ក្រុមពូជ ដើម្បីជៀសវាងការបង្កាត់ក្នុងនៅក្នុងអនាគតចម្ការឈើ ឬចម្ការពូជ)

**subsidy** /ˈsʌbsɪdi/ [n] ឧបត្ថម្ភធន

- agricultural subsidy /agrɪˈkʌltʃərəl ˈsʌbsɪdi/ [n] ឧបត្ថម្ភធនសម្រាប់កសិកម្ម

**subsoil** /ˈsʌbsɔɪl/ [n] ដីស្រទាប់ក្រោម (B ឬ C)

- deep subsoil /diːp ˈsʌbsɔɪl/ [n]
  ១. (សទិសន័យ៖ underground) ស្រទាប់ដីផ្នែកខាងក្រោម
  ២. សូមមើលពាក្យ៖ bedrock
- lower subsoil /ˈləʊə ˈsʌbsɔɪl/ [n] ស្រទាប់ដីដែលនៅជ្រៅខាងក្រោម
- permafrost subsoil /ˈpəːməfrɒst ˈsʌbsɔɪl/ [n] ដីស្រទាប់ក្រោមដែលកកជានិច្ចកាល
- superior subsoil /suːˈpɪərɪə ˈsʌbsɔɪl/ [n] (សទិសន័យ៖ upper subsoil) ស្រទាប់ដីក្រោម (ផ្នែកខាងលើ)
- upper subsoil /ˈʌpə ˈsʌbsɔɪl/ [n] សូមមើលពាក្យ៖ superior subsoil

**subsoiling** /sʌbsɔɪlɪŋ/ [n] សូមមើលពាក្យ៖ subtilling

**substance** /ˈsʌbst(ə)ns/ [n] សារធាតុ

- air-polluting substance /ɛː pəˈluːtɪŋ ˈsʌbst(ə)ns/ [n] សារធាតុបំពុលខ្យល់
- allelopathic substance /əˌliːlə(ʊ)ˈpaθɪk ˈsʌbst(ə)ns/ [n] សារធាតុអាលេឡូប៉ាទី
- chemically active substance /ˈkɛmɪk(ə)li ˈaktɪv ˈsʌbst(ə)ns/ [n] សារធាតុសកម្មគីមី
- chemically inert substance /ˈkɛmɪk(ə)li ɪˈnəːt ˈsʌbst(ə)ns/ [n] សារធាតុនិចលគីមី
- chemically passive substance /ˈkɛmɪk(ə)li ˈpasɪv ˈsʌbst(ə)ns/ [n] សារធាតុអសកម្មគីមី

- chemically stable substance /ˈkɛmɪk(ə)li ˈsteɪb(ə)l ˈsʌbst(ə)ns/ [n] សារធាតុស៊ីបគីមី
- chemically unstable substance /ˈkɛmɪk(ə)li ʌnˈsteɪb(ə)l ˈsʌbst(ə)ns/ [n] សារធាតុមិនស៊ីបគីមី
- growth substance /grəʊθ ˈsʌbst(ə)ns/ [n] (សទិសន័យ៖ hormone) សារធាតុជួយឱ្យលូតលាស់
- hazardous substance /ˈhazədəs ˈsʌbst(ə)ns/ [n] សារធាតុប្រកបដោយគ្រោះថ្នាក់
- inorganic substance /ɪnɔːˈganɪk ˈsʌbst(ə)ns/ [n] សារធាតុអសរីរាង្គ
- mineral substance /ˈmɪn(ə)r(ə)l ˈsʌbst(ə)ns/ [n] សារធាតុខនិជ
- nutrient substance /ˈnjuːtrɪənt ˈsʌbst(ə)ns/ [n] (សទិសន័យ៖ nutriment) សារធាតុចិញ្ចឹម, ជីជាតិ
- organic substance /ɔːˈganɪk ˈsʌbst(ə)ns/ [n] សារធាតុសរីរាង្គ
- toxic substance /ˈtɒksɪk ˈsʌbst(ə)ns/ [n] សារធាតុពុល
- waste substance /weɪst ˈsʌbst(ə)ns/ [n] សារធាតុសំណល់

**substantial** /səbˈstanʃ(ə)l/ [adj] សារធាតុវន្ត, ដែលសំខាន់, ដែលសន្ធឹក

**substitute** /ˈsʌbstɪtjuːt/ [v] ជំនួស

**substitution** /sʌbstɪˈtjuːʃn/ [n] ការជំនួស

- base substitution /beɪs sʌbstɪˈtjuːʃn/ [n] ការជំនួសបាស

**substratum** /sʌbˈstrɑːtəm/ [n]

- underlaying substratum /ʌndəˈleɪɪŋ sʌbˈstrɑːtəm/ [n]
  ១. សូមមើលពាក្យ៖ bedrock
  ២. សូមមើលពាក្យ៖ lower bed

**subsurface** /ˈsʌbsəːfɪs/ [n] ស្រទាប់ជិតទៅផ្ទៃខាងលើ

- subsurface soil /ˈsʌbsəːfɪs sɔɪl/ [n] ដីនៅស្រទាប់ក្រោម, ស្រទាប់ក្រោមនៃដីខ្មៅខាងលើ

**subtilling** [n] (សទិសន័យ៖ subsoiling, chiseling) ការភ្ជួរជ្រៅ (៤០ ឬ៥០ ស.ម) ដើម្បីបំផុសស្រទាប់ដីខាងក្រោមឱ្យជ្រាបទឹកបានស្រួល

**subulate** /ˈsjuːbjʊlət/ [adj] ទម្រង់បន្ទះស្លឹករាងផ្លែលំពែងតូច

**succession** /səkˈsɛʃ(ə)n/ [n]
១. លំដាប់លំដោយនៃរុក្ខជាតិយោងទៅតាមប្រភេទដី
២. តំណគ្នា

**succulent** /ˈsʌkjʊl(ə)nt/ [adj] ទឹកច្រើន (រុក្ខជាតិសាច់ក្រាស់ ដែលស្តុកទឹកនៅខាងក្នុងដើម ឬស្លឹករបស់វា)

**suck** /sʌk/ [v] សូមមើលពាក្យ៖ suckle

**sucker** /ˈsʌkə/ [n] កូនឈើដុះចេញពីគល់, ពន្លកដុះចេញពីគល់, ខ្នែងកូនឈើដុះចេញពីឫស

- root sucker /ruːt ˈsʌkə/ [n] កូនឈើដុះចេញតាមឫស (បំពង់ត្រួយដែលដុះចេញពីពន្លកត្រួយដែលដុះឯងនៅលើផ្ទៃរបស់ឫស)

**suckle** /ˈsʌk(ə)l/ [v] (សទិសន័យ៖ suck) បំបៅ (ចិញ្ចឹម, បណ្ដុះ, ផ្គត់ផ្គង់, បិតថេរ)

**sucrose** /ˈs(j)uːkrəʊz/ [n] សូមមើលពាក្យ៖ saccharide

**sufficiency** /səˈfɪʃ(ə)nsi/ [n] ភាពគ្រប់គ្រាន់

- self-sufficiency /sɛlf səˈfɪʃ(ə)nsi/ [n] ភាពគ្រប់គ្រាន់សម្រាប់ខ្លួនឯង

**suffocate** /ˈsʌfəkeɪt/ [v] ថប់ដង្ហើមស្លាប់, ធ្វើឱ្យថប់ដង្ហើមស្លាប់

**suffusion** /səˈfjuːʒ(ə)n/ [n] ការហើមដីនៅរដូវក្ដៅនៃដីនៅតំបន់ត្រជាក់ខ្លាំង

**sugar apple** /ˈʃʊgə ˈap(ə)l/ [n] ទៀប

**sugar beet** /ˈʃʊgə biːt/ [n] ផែថាវស្ករ

**sugar cane** /ˈʃʊgə keɪn/ [n] អំពៅ (ឈ្មោះវិទ្យាសាស្ត្រ *Saccharum officinarum*)

**sugar** /ˈʃʊgə/ [n] សូមមើលពាក្យ៖ saccharide

- amino sugar /əˈmiːnəʊ ˈʃʊgə/ [n] ស្ករអាមីន
- brown sugar /braʊn ˈʃʊgə/ [n] ស្ករពណ៌ត្នោត (ស្ករចម្រាញ់ពី raw suagar ដោយមិនដកសារធាតុពណ៌)
- milk sugar /mɪlk ˈʃʊgə/ [n] សូមមើលពាក្យ៖ lactose
- raw sugar /rɔː ˈʃʊgə/ [n] ស្ករវត្ថុធាតុដើម (ស្ករដែលបានពីរោងចក្រស្ករអំពៅសម្រាប់នាំចេញដើម្បីផលិតស្ករស)
- refined sugar /rɪˈfʌɪnd ˈʃʊgə/ [n] (សទិសន័យ៖ white sugar) ស្ករស (ស្ករដែលប្រើប្រាស់ និងលក់នៅលើទីផ្សារ)
- white sugar /wʌɪt ˈʃʊgə/ [n] សូមមើលពាក្យ៖ refined sugar

**sulfanilamide** /ˌsʌlfəˈnɪləmʌɪd/ [n] ស៊ុលផានីឡាមីត

**sulfate** /ˈsʌlfeɪt/ [n] ស៊ុលផាត

**Sulfur** /ˈsəlfər/ [n] ស្ពាន់ធ័រ (និមិត្តសញ្ញាគីមី S)

**Sumatran river sprat** /sʊˈmɑːtrən ˈrɪvə sprat/ [n] ត្រីបណ្ដូលល្ពៅ (ឈ្មោះវិទ្យាសាស្ត្រ *Clupeichthys goniognathus*)

**sun loach** /sʌn ləʊtʃ/ [n] ត្រីកញ្ជ្រូកក្រហម (ឈ្មោះវិទ្យាសាស្ត្រ *Botia eos*)

**sunflower** /ˈsʌnflaʊə/ [n] ផ្កាឈូករ័ត្ន (ឈ្មោះវិទ្យាសាស្ត្រ *Helianthus annuus*)

**sunhemp** /sʌnhɛmp/ [n] កក់ទុង (ឈ្មោះវិទ្យាសាស្ត្រ *Crotalaria juncea*)

**sunlight** /ˈsʌnlʌɪt/ [n] ពន្លឺព្រះអាទិត្យ

**super-** /ˈsuːpə/ [prefix] (សទិសន័យ៖ over, above, better,more then) បុព្វបទមានន័យថា លើ ប្រសើរ

**superficial** /ˌsuːpəˈfɪʃ(ə)l/ [adj]
១. (សទិសន័យ៖ shallow) រាក់សើខាងលើ, ស្តើង
២. ស្រទាប់លើ, ដែលនៅលើស្បែក, ដែលសើៗ

**superior** /suːˈpɪərɪə/ [adj] ឧត្តម (ដែលប្រសើរ ដែលខ្ពស់), ល្អបំផុត, ល្អជាងគេ

**superiority** /suːˌpɪərɪˈɒrɪti/ [n] ឧត្តមភាព (ភាពល្អប្រសើរ ភាពខ្ពង់ខ្ពស់)

**supernumerary** /ˌsuːpəˈnjuːm(ə)r(ə)ri/ [adj] លើស (ពីចំនួនកម្រិត)

**supplementary feeding** /ˌsʌplɪˈmɛnt(ə)ri fiːdɪŋ/ [n] ការផ្ដល់អាហារបំប៉ន

**supply** /səˈplʌɪ/ [n] (ចំពោះធរណីវិទ្យា) ការដាក់បន្ថែមវត្ថុធាតុអ្វីមួយ (ឧ. បាចកំបោរ)

- water supply /ˈwɔːtə səˈplʌɪ/ [n] ទឹកបម្រុង

**supposition** /ˌsʌpəˈzɪʃ(ə)n/ [n] សូមមើលពាក្យ៖ hypothesis

**suppository** /səˈpɒzɪt(ə)ri/ [n] ថ្នាំសុល (ថ្នាំសុលតាមទ្វារបាត)

**suppression** /səˈprɛʃ(ə)n/ [n] ការបង្ក្រាប (ឧ. កម្ពស់ទឹកក្នុងស្រែទប់ស្កាត់មិនឱ្យស្មៅដុះលូតលាស់បានធម្មតា)

**suppurate** /ˈsʌpjʊreɪt/ [v] ហៀរខ្ទុះ, កខ្ទុះ

**supra-** /ˈs(j)uːprə/ [prefix] (សទិសន័យ៖ above, beyond, super) បុព្វបទមានន័យថា លើស, ខាងលើ

**supramammary** /ˈs(j)uːprəˈmaməri/ [adj] ខាងលើដោះ

**supra-pubic** /ˈs(j)uːprə ˈpjuːbɪk/ [n] នៅខាងលើឆ្អឹងថ្វាស (ថ្វាសយោនី ឬលិង្គ)

**suprarenal** /ˌs(j)uːprəˈriːn(ə)l/ [adj] ខាងលើក្រលៀន

**suprasilt** /ˈs(j)uːprəsɪlt/ [n] ភាគល្បាយ (២០-៥០មីក្រុង)

**surface** /ˈsəːfɪs/ [n] ផ្ទៃ, មុខ, លើសើៗ

- mamillated surface /ˈmamɪleɪtɪd ˈsəːfɪs/ [n] ផ្ទៃដែលជាដំពូករដិបរដុបជាផ្ទៃទឹករលក
- specific surface /spəˈsɪfɪk ˈsəːfɪs/ [n] ផ្ទៃយថាប្រភេទនៃដី

**surgeon** /ˈsəːdʒ(ə)n/ [n] សុល្យពេទ្យ, វេជ្ជបណ្ឌិតខាងវះកាត់

**surgery** /ˈsəːdʒ(ə)ri/ [n] ការវះកាត់, វិជ្ជាវះកាត់

- plastic surgery /ˈplastɪk ˈsəːdʒ(ə)ri/ [n] ការវះកាត់កែរាងកាយ
- reconstructive surgery /ˌriːkənˈstrʌktɪv ˈsəːdʒ(ə)ri/ [n] ការវះកាត់កែលក្ខណៈឱ្យមានភាពធម្មតាវិញ

**surplus** /ˈsəːpləs/ [n] អតិរេក, ចំនួនលើស, ផលលើស

- milled rice production surplus /mɪld rʌɪs prəˈdʌkʃ(ə)n ˈsəːpləs/ [n] អតិរេកផលិតកម្មអង្ករ
- paddy rice production surplus /ˈpadi rʌɪs prəˈdʌkʃ(ə)n ˈsəːpləs/ [n] អតិរេកផលិតកម្មស្រូវ

**surra** /ˈsʊərə/ [n] ស៊ូរ៉ា (ជំងឺឆ្លងពពួកសត្វសេះ)

**survey** /səˈveɪ/ [v] អង្កេត

**survey** /səˈveɪ/ [n] ការអង្កេត, ការសិក្សាស្រាវជ្រាវ, ការស្ទាបស្ទង់

- aerial survey /ˈɛːrɪəl səˈveɪ/ [n] តំហាតពីលើអាកាស
- air pollution survey /ɛː pəˈluːʃ(ə)n səˈveɪ/ [n] ការសិក្សាស្រាវជ្រាវការបំពុលខ្យល់
- airborne survey /ˈɛːbɔːn səˈveɪ/ [n] តំហាតពីលើអាកាស
- baseline survey /ˈbeɪslʌɪn səˈveɪ/ [n] ការសិក្សាអង្កេតជាមូលដ្ឋាន, ការអង្កេតគ្រឹះ (ការចុះសាកសួរព័ត៌មានដំបូង)
- biological survey /bʌɪə(ʊ)ˈlɒdʒɪk(ə)l səˈveɪ/ [n] ការសិក្សាស្រាវជ្រាវជីវសាស្ត្រ
- field survey /fiːld səˈveɪ/ [n] ការសិក្សាស្រាវជ្រាវដល់ទីកន្លែង

- formal survey /ˈfɔːm(ə)l səˈveɪ/ [n] ការស្ទាបស្ទង់មតិដោយមានគម្រោងសំណួរច្បាស់លាស់
- geological survey /dʒiːəˈlɒdʒɪk(ə)l səˈveɪ/ [n] ការសិក្សាស្រាវជ្រាវធរណីវិទ្យា
- geophysical survey /ˌdʒiːə(ʊ)ˈfɪzɪk(ə)l səˈveɪ/ [n] ការសិក្សាស្រាវជ្រាវរូបធរណីវិទ្យា
- ground survey /graʊnd səˈveɪ/ [n] ការសិក្សាស្រាវជ្រាវនៅលើដី
- land-survey /land səˈveɪ/ [n] ការធ្វើអង្កេតពីដី
- satellite survey /ˈsatəlʌɪt səˈveɪ/ [n] ការអង្កេតពីផ្កាយរណប
- seismic survey /ˈsʌɪzmɪk səˈveɪ/ [n] ការសិក្សាស្រាវជ្រាវសេស្មិច
- soil survey /sɔɪl səˈveɪ/ [n] ការអង្កេតដី, ការសិក្សាស្រាវជ្រាវដី
- water survey /ˈwɔːtə səˈveɪ/ [n] ការសិក្សាស្រាវជ្រាវទឹក

**survival** /səˈvʌɪv(ə)l/ [n] ភាពរស់រាន (ការដែលជីវករអាចទ្រាំទ្របានបាតុភូតអ្វីមួយដែលតឹងតែងខ្លាំង)

**susceptibility** /səˌsɛptɪˈbɪlɪti/ [n] ភាពងាយទទួលរងដោយអ្វីមួយ, ភាពឆាប់ខូចខាត (ឧ. ចម្រោះ, ការហូរច្រោះ)

**susceptible** /səˈsɛptɪb(ə)l/ [adj] អាច, ងាយ, ឆាប់ (ឈឺ), មិនធន់ (លក្ខណៈដែលងាយរងឥទ្ធិពលពីកត្តាមិនប្រក្រតី)

**suspect** /səˈspɛkt/ [v] សង្ស័យ

**suspension** /səˈspɛnʃ(ə)n/ [n] សារធាតុម៉ដ្ឋ, កម្ទេចល្អិតដែលរលាយក្នុងទឹក

**suspensor** [n] សឺសស្ពែនសឺ (បន្ទាត់មួយនៃកោសិកាដែលធ្វើអវិកលកម្មក្នុងការវិវត្តដំបូងគេរបស់អំប្រីយ៉ុង ហើយភ្ជាប់វាទៅជាលិកាមេ។ នៅក្នុងគ្រាប់នៃពួករុក្ខជាតិគ្រាប់ស្រាតខ្លះ វាដូចជាសរសៃឆ្មារមួយភ្ជាប់ទៅចុងរ៉ាឌីកាល់របស់អំប្រីយ៉ុង។)

**sustainability** /səsteɪnəˈbɪlɪti/ [n] និរន្តរភាព, ចីរភាព

**sustainable** /səˈsteɪnəb(ə)l/ [adj] នៃនិរន្តរភាព, នៃចីរភាព

**sustained baiting** /səˈsteɪnd beɪtɪŋ/ [n] ការដាក់នុយនិរន្ត (ការដាក់នុយបន្តរហូត ឬហួតដល់កម្រិតក្នុងពេលយូរមួយ)

**suture** /ˈsuːtʃə/ [n]
១. (ចំពោះរុក្ខជាតិ) ស្នាមបន្ទាត់សម្រាប់ប្រេះ (ស្នាមបន្ទាត់មួយសម្រាប់ប្រេះ ឬបើកនៅលើប្រភេទផ្លែប្រេះ)
២. (ចំពោះសត្វ) សូមមើលពាក្យ៖ stitch

**swab** /swɒb/ [n] តម្បារ

**swab** /swɒb/ [v] សម្អាតដោយជូតនឹងសំឡី, ផ្តិតយកសំណាកទៅពិនិត្យ

**swale** /sweɪl/ [n] (សទិសន័យ៖ small valley) កូនជ្រលង

**swallet** /ˈswɒl ɪt/ [n] សូមមើលពាក្យ៖ sink

**swallow** /ˈswɒləʊ/ [n]
១. (ចំពោះធរណីវិទ្យា) សូមមើលពាក្យ៖ flat
២. សត្វត្រចៀកកាំ

**swamp mornig glory** [n] សូមមើលពាក្យ៖ water spinach

**swamp spinach** /swɒmp ˈspɪnɪdʒ/ [n] ត្រកួនចិន, ត្រកួនស

**swamp** /swɒmp/ [n] (សទិសន័យ៖ marsh) ដីទំនាបបឹង, វាលភក់

- alder swamp /ˈɔːldə swɒmp/ [n] (សទិសន័យ៖ low moor wood peat, swamp wood peat, wood fen) ដីវាលភក់ដែលមានព្រៃដុះ, ព្រៃដុះលើវាលភក់, ដីព្រៃសើម, កន្លែងលិចទឹក
- atmospheric swamp /atməsˈfɛrɪk swɒmp/ [n] សូមមើលពាក្យ៖ high moor soil
- continental swamp /kɒntɪˈnɛnt(ə)l swɒmp/ [n] (សទិសន័យ៖ wood soil) ដីវាលភក់នៅលើទ្វីប (ក្នុងតំបន់ដីគោក)
- low marsh swamp /ləʊ mɑːʃ swɒmp/ [n] ទំនាបបឹង

**swampy** /ˈswɒmpi/ [adj] សូមមើលពាក្យ៖ marshy

**sward** /swɔːd/ [n] សូមមើលពាក្យ៖ turf

- prairie sward /ˈprɛːri swɔːd/ [n] មមោកកើតពីឫសស្មៅលាយចូលល្អជាមួយនឹងដី

**swarm** /swɔːm/ [v] ឆោមជុំវិញ, ពាសពេញទៅដោយ

- swarm down /swɔːm daʊn/ [v] តោងចុះ
- swarm up /swɔːm ʌp / [v] តោងឡើង

**swarm** /swɔːm/ [n] ហ្វូង, ក្រុម

- hybrid swarm /ˈhʌɪbrɪd swɔːm/ [n] កូនកាត់មួយក្រុម ( ក្រុមពូជមួយដែលមានប្រភេទកូនកាត់និងប្រភេទបង្កាត់ត្រឡប់ផ្សេងៗរវាងក្រុមពូជ២ឬច្រើនក្រុមដែល បង្កាត់គ្នាទៅវិញទៅមក។ ក្រុមពូជនេះអាចមានប្រភេទមេបាមួយឬច្រើន ឬក្រុមពួកទាំងនេះអាចជំនួសគ្នា ដោយការបង្កាត់ត្រឡប់។)

**swathe** /sweɪð/ [n] មុខគម្លាត (ការច្រូតកាត់ជាឆ្នូតក្នុង១ខ្នាតនៃឧបករណ៍ ឬទទឹងជះនៃថ្នាំដែលបាញ់ អាស្រ័យទៅនឹងចំនួននៃក្បាលបាញ់ក្នុងដែនកំណត់)

**swatow mustard** /swɒˈtaʊ ˈmʌstəd/ [n] ស្ពៃជើងទា, ស្ពៃជ្រក់ (ឈ្មោះវិទ្យាសាស្ត្រ *Brassica juncea var. rugosa*)

**swayback** /sweɪbak/ [n] អ៊ែនស៊ែ

**sweat** /swɛt/ [n] ញើស

**sweet basil** /swiːt ˈbaz(ə)l/ [n] ជីរលីងល័ខ (ឈ្មោះវិទ្យាសាស្ត្រ *Ocimum basilicum*)

**sweet potato** /swiːt pəˈteɪtəʊ/ [n] ដំឡូងជ្វា (ឈ្មោះវិទ្យាសាស្ត្រ *Ipomea batatas*)

**swell** /swɛl/ [v] ហើម

**swelling** /ˈswɛlɪŋ/ [n] កន្លែងកំពុងឡើងប៉ោង

- root swelling /ruːt ˈswɛlɪŋ/ [n] ការហើមឫស, ការប៉ោងឫស

**swine** /swʌɪn/ [n] សូមមើលពាក្យ៖ pig

**swollen** /ˈswəʊlən/ [adj] ប៉ោង, ហើម

**symbiosis** /ˌsɪmbɪˈəʊsɪs/ [n] មានជីវសាស្ត្ររួមគ្នា, ការរស់នៅជាមួយគ្នា, សហប្រាណភាព (ទំនាក់ទំនងរវាងសរីរាង្គពីរដែលមានអម្បូរខុសគ្នា និងបានទទួលផលប្រយោជន៍ទៅវិញទៅមក)

**symbiote** [n] អង្គសហប្រាណ

**symbiotic** /ˌsɪmbɪˈɒtɪk/ [adj] សហប្រាណ

**symbioza** [n] សហប្រាណ

**symbol** /ˈsɪmb(ə)l/ [n] និម្មិតរូប, និម្មិតសញ្ញា

- chemical symbol /ˈkɛmɪk(ə)l ˈsɪmb(ə)l/ [n] និម្មិតសញ្ញាគីមី

**symparasitism** /sɪmˈparəsɪtɪz(ə)m/ [n] បរាសិតរួមផ្គួល

**sympathectomy** /ˌsɪmpəˈθɛktəmi/ [n] ការវះកាត់យកសរសៃប្រសាទ មួយ (ធម្មតាដើម្បីធ្វើឱ្យឈាមរត់ល្អនៅក្នុងជើងនៃអ្នកមានរោគទឹកនោមផ្អែម)

**sympatric** /sɪmˈpatrɪk/ [adj] មានដើមកំណើតដូចគ្នា (តែមួយ) (ការរៀបរាប់ពីក្រុមពូជ២ ឬច្រើនក្រុមរស់នៅក្នុងតំបន់តែមួយ ឬត្រួតស៊ីគ្នា ហើយដែលអាចបង្កាត់គ្នាបាន តែមិនបានជានិច្ចកាលនោះទេ ពីព្រោះថាវាមានភាពខុសគ្នាច្រើនដូចជា រដូវចេញផ្កា ឬប្រភេទសត្វចម្លងលម្អង)

**sympetalous** /sɪmˈpɛt(ə)ləs/ [adj] ស្រទាប់ផ្កាជាប់ៗគ្នា

**symphysis** /ˈsɪmfɪsɪs/ [n] សន្លាក់អឌ្ឍចល័ត

**symptom** /ˈsɪm(p)təm/ [n] និម្មិតហេតុ, សញ្ញាជំងឺ, រោគសញ្ញា, លក្ខណៈរោគ, អាការរោគ

- cytological symptom /sʌɪtəˈlɒdʒɪk(ə)l ˈsɪm(p)təm/ [n] រោគសញ្ញាកោសិកា
- histological symptom /hɪstəˈlɒdʒɪk(ə)l ˈsɪm(p)təm/ [n] រោគសញ្ញាជាលិកា
- morphological symptom /mɔːfəˈlɒdʒɪk(ə)l ˈsɪm(p)təm/ [n] រោគសញ្ញារូបសាស្ត្រ

**symptomatic** /sɪm(p)təˈmatɪk/ [adj] និម្មិតហេតុ, សញ្ញាជំងឺ

**synapse** /ˈsɪnaps/ [n] កន្លែងប្រទល់សរសៃ

**syncarp** [n] ប្រភេទផ្លែចង្កោម

**syncarpous** /sɪnˈkɑːpəs/ [adj] រលាយចូលគ្នាទាំងអស់ (ប្រភេទនៃកេសរញីសមាស)

**syncarpy** /sɪnˈkɑːpi/ [n] ប្រភេទមួយនៃកេសរញីសមាសដែលផ្គុំឡើងពីកេសរញីសាមញ្ញពីរ ឬច្រើន

**synchronising** /ˈsɪŋkrənʌɪzɪŋ/ [n] សមកាលភាព (ភាពដែលធ្វើក្នុងពេលដំណាលគ្នា)

**syncline** /ˈsɪŋklʌɪn/ [n] សាំងគ្លីណាល់

**syndrome** /ˈsɪndrəʊm/ [n] សហានិមិត្តហេតុ (ក្រុមនៃសញ្ញា និងអាការរោគដែលកើតព្រមគ្នា ហើយមានលក្ខណៈមិនមែនជាធម្មតា)

- sudden death infant syndrome [n] សហានិមិត្តក្ស័យសង្ខារទារកភ្លាមៗ

**synedrella** [n] ស្ពៃគោក (ឈ្មោះវិទ្យាសាស្ត្រ *Synedrella nodiflora*)

***Synedrella nodiflora*** [sci.n] សូមមើលពាក្យ៖ synedrella

**synergist** /ˈsɪnədʒɪst/ [n] សហចលនា

**Syngamus** [n] សាំងកាមុស (ពពួកព្រូនម្យ៉ាងនូវក្នុងពោះវៀនសត្វស្លាប)

**synovia** [n] ទឹកសន្លាក់

**synthesis** /ˈsɪnθɪsɪs/ [n] សំយោគ

- chemical synthesis /ˈkɛmɪk(ə)l ˈsɪnθɪsɪs/ [n] សំយោគគីមី
- organic synthesis /ɔːˈganɪk ˈsɪnθɪsɪs/ [n] សំយោគសរីរាង្គ
- protein synthesis /ˈprəʊtiːn ˈsɪnθɪsɪs/ [n] សំយោគប្រូតេអ៊ីន

**synthetic** /sɪnˈθɛtɪk/ [adj] ដែលសំយោគ, ខុសពីធម្មតា

**syphilis** /ˈsɪfɪlɪs/ [n] រោគស្វាយ

**syringe** /ˈsɪrɪn(d)ʒ/ [n] សឺរ៉ាំង, ប្រដាប់ចាក់ថ្នាំ

**syrinx** /ˈsɪrɪŋks/ [n] ស៊ីរ៉ាំង (បំពង់ខ្យល់ ក្នុងបំពង់កសត្វស្លាបសម្រាប់ផ្តល់សំឡេង)

**system** /ˈsɪstəm/ [n] ប្រព័ន្ធ, របៀប, ក្រុមសរីរាង្គដែលធ្វើការជាមួយគ្នា

- agrarian system /əˈgrɛːrɪən ˈsɪstəm/ [n] ប្រព័ន្ធកសិកម្មនៅក្នុងបរិបទនយោបាយកសិកម្មមួយដែលអន្តរកម្មរវាងសមាសភាគប្រព័ន្ធមានលក្ខណៈទូលំទូលាយ ហើយសាំញ៉ាំ
- annual cropping system /ˈanjʊəl krɒpɪŋ ˈsɪstəm/ [n] ប្រព័ន្ធដាំដុះដំណាំឯកវត្សរ
- binary system /ˈbʌɪnəri ˈsɪstəm/ [n] ប្រព័ន្ធទ្វេ
- breeding system /ˈbriːdɪŋ ˈsɪstəm/ [n] ប្រព័ន្ធបង្កាត់ពូជ, ប្រព័ន្ធជម្រើសពូជ
- circulatory system /ˈsəːkjʊlət(ə)ri ˈsɪstəm/ [n] ប្រព័ន្ធរបត់ឈាម
- closed circulatory system /kləʊzd ˈsəːkjʊlət(ə)ri ˈsɪstəm/ [n] ប្រព័ន្ធរបត់ឈាមបិទ
- cropping system /krɒpɪŋ ˈsɪstəm/ [n] ប្រព័ន្ធដាំដុះ (ការគ្រប់គ្រងទៅលើផលិតផលដំណាំណាមួយដែលបានប្រើថាមពលព្រះអាទិត្យ និងអ្វីផ្សេងៗទៀតដូចជា ដី ជីជាតិ និងទឹក ដើម្បីបង្កើតផល។ ដំណាំ ដី ស្មៅ ជំងឺ សត្វល្អិត និងអាកាសធាតុសុទ្ធសឹងជាសមាសភាគនៃប្រព័ន្ធ ហើយតែងមានអន្តរកម្មទៅមកជាមួយគ្នា)
- dapog system /dapɒg ˈsɪstəm/ [n] ប្រព័ន្ធដាប៉ុក (វិធីសាស្ត្រនៃការសាបសំណាបមួយប្រភេទដោយត្រាំ និងផ្ទាប់គ្រាប់ពូជ រួចហើយសាបលើកម្រាលស្លឹកចេក ឬប្លាស្ទិចផ្តល់ភាពងាយស្រួលក្នុងការយកវាទៅស្ទូង។ សំណាបនោះគេនិយមស្ទូងនៅពេលមានអាយុពី ៩ ទៅ ១៤ ថ្ងៃ ក្រោយការសាប។)
- economic system /ˌiːkəˈnɒmɪk ˈsɪstəm/ [n] ប្រព័ន្ធសេដ្ឋកិច្ច
- enzyme system /ˈɛnzʌɪm ˈsɪstəm/ [n] ប្រព័ន្ធអង់ស៊ីម
- farmer's cropping system /ˈfɑːməs krɒpɪŋ ˈsɪstəm/ [n] ប្រព័ន្ធដំណាំកសិករ (ប្រព័ន្ធដាំដុះក្នុងលក្ខខណ្ឌរបស់កសិករផ្ទាល់ ទាំងការងារដាំដុះ និងការគ្រប់គ្រង)
- farming system /ˈfɑːmɪŋ ˈsɪstəm/ [n] ប្រព័ន្ធកសិកម្ម
- grading system /greɪdɪŋ ˈsɪstəm/ [n] ប្រព័ន្ធចាត់ថ្នាក់
- hurdle system /ˈhəːd(ə)l ˈsɪstəm/ [n] ការរៀបទប់ដីកុំឱ្យបាក់ដោយដាក់ប្រដឹស និងសសរ
- hydrogen carrier system /ˈhʌɪdrədʒ(ə)n ˈkarɪə ˈsɪstəm/ [n] ប្រព័ន្ធដឹកនាំអ៊ីដ្រូសែន
- integrated farming system /ˈɪntɪgreɪtɪd ˈfɑːmɪŋ ˈsɪstəm/ [n] ប្រព័ន្ធកសិកម្មចម្រុះ
- land tenure system /land ˈtɛnjə ˈsɪstəm/ [n] ប្រព័ន្ធកម្មសិទ្ធិដីធ្លី
- long-term cropping system /lɒŋ təːm krɒpɪŋ ˈsɪstəm/ [n] ប្រព័ន្ធដាំដុះយូរអង្វែង
- low-pressure spray system /ləʊ-ˈprɛʃə spreɪ ˈsɪstəm/ [n] ប្រព័ន្ធបាញ់ថ្នាំដែលមានសម្ពាធទាប
- Mekong river system /miːˈkɒŋ ˈrɪvə ˈsɪstəm/ [n] ប្រព័ន្ធទន្លេមេគង្គ
- parkland system /ˈpɑːkland ˈsɪstəm/ [n] ការដាំដុះដំណាំជាចន្លោះក្រោមដើមឈើដែលដុះនៅឆ្ងាយពីគ្នា
- polymeric system /pɒlɪˈmɛrɪk ˈsɪstəm/ [n] (សទិសន័យ៖ polygene) ឥទ្ធិពលពហុសែន, ឥទ្ធិពលពហុពន្ធុ, ប្រព័ន្ធប៉ូលីមែរ (ពន្ធុមិនអាលែលនឹងគ្នាជាច្រើនទាំងអស់មានឥទ្ធិពលទៅលើលក្ខណៈតែមួយ)

- regression system /rɪˈɡrɛʃ(ə)n ˈsɪstəm/ [n] ប្រព័ន្ធវាយតម្លៃគុណភាព ( ប្រព័ន្ធវាយតម្លៃគុណភាពដែលទាក់ទងទៅនឹងលក្ខណៈមានប្រយោជន៍នៅក្នុងកម្មវិធីសុវ៉ុឌ្ឍិកម្មដើមឈើធៀបទៅនឹងអាយុ។ តម្លៃរបស់លក្ខណៈមានប្រយោជន៍ដាក់ធៀបនឹងអាយុ។ បន្ទាត់ទំនាក់ទំនងដែលទទួលបានប្រើធ្វើជាបន្ទាត់មូលដ្ឋានសម្រាប់ការចាត់គុណភាពជាបន្តបន្ទាប់នៃព្រៃ(ដើម)ពូជដែលមានអាយុខុសគ្នា ឬដែលមានប្រភេទពូជចម្រុះ។)
- rice based farming system /rʌɪs beɪst ˈfɑːmɪŋ ˈsɪstəm/ [n] ប្រព័ន្ធកសិកម្មមូលដ្ឋានស្រូវ (ប្រព័ន្ធកសិកម្មមួយដែលគេយកស្រូវជាមូលដ្ឋាន)
- shelterwood system [n] ប្រព័ន្ធឈើផ្តល់ជម្រក, ប្រព័ន្ធឈើរបាំង
- silvicultural system /ˌsɪlvɪˈkʌltʃ(ə)r(ə)l 'sɪstəm/ [n] ប្រព័ន្ធរុក្ខវប្បកម្ម (ជាគម្រោងប្រព្រឹត្តកម្មក្នុងដាំដុះ ថែរក្សាប្រមូលផលឈើ យោងទៅតាមចំនួនថ្នាក់ អាយុ (ការដុះខែង ភាពស្មើអាយុ និងមិនស្មើអាយុ) ឬ វិធីសាស្ត្រ ធ្វើឱ្យដុះឡើងវិញ)
- sub-system /ˈsʌbsɪstəm/ [n] អនុប្រព័ន្ធ
- Tonle Sap lake system /ˌtɒnleɪˈsap leɪk ˈsɪstəm/ [n] ប្រព័ន្ធបឹងទន្លេសាប
- two-aged system /tuː eɪdʒd ˈsɪstəm/ [n] ការធ្វើប្រព្រឹត្តិកម្មឈើ ឬគ្រប់គ្រងឈើឱ្យមានថ្នាក់អាយុចំនួន
- vascular system /ˈvaskjʊlə ˈsɪstəm/ [n] សូមមើលពាក្យ៖ vascular budle
- water supply system /ˈwɔːtə səˈplʌɪ ˈsɪstəm/ [n] ប្រព័ន្ធផ្គត់ផ្គង់ទឹក

**systemic** /sɪˈstiːmɪk/ [adj] នៃប្រព័ន្ធ, ដែលទាក់ទងនឹងខ្លួនទាំងមូល

**systole** /ˈsɪstəli/ [n] ការកន្ត្រាក់នៃបេះដូង

***Systomus aurotaeniatus*** [sci.n] ត្រីអង្កត់ប្រាក់

***Systomus orphoides*** [sci.n] ត្រីអំពិលទុំ

***Systomus partipentazona*** [sci.n] ត្រីបីកំណាត់, ត្រីខ្លា

***Syzygium cumini*** [sci.n] សូមមើលពាក្យ៖ jambolaum

**T**

**tablet** /ˈtablɪt/ [n] សូមមើលពាក្យ៖ pill

**tachycardia** /ˌtakɪˈkɑːdɪə/ [n] ល្បឿនបេះដូងដើរលឿនជាងធម្មតា

***Tachypleus gigas*** [sci.n] សូមមើលពាក្យ៖ triangular-tail horseshoe crab

**tachypnea** /ˌtakɪpˈniːə/ [n] ការដកដង្ហើមញាប់ជាងធម្មតា

**taenia** /ˈtiːnɪə/ [n] តេញ៉ា, ព្រូនសំប៉ែត

***Taenia cysticercus*** [sci.n] សូមមើលពាក្យ៖ scolex

**taffy** /ˈtafi/ [n] ស្ករតាំងម៉ែ

***Tagetes erecta*** [sci.n] សូមមើលពាក្យ៖ merry gold

**taiga** /ˈtʌɪgə/ [n] ព្រៃតៃកា

**tail** /teɪl/ [n] កន្ទុយ, ចុង

**taking-off** /ˈteɪkɪŋ ɒf/ [n] (សទិសន័យ៖ carrying-away) ការយក ឬដកចេញ (ដោយខ្យល់, ដោយទឹក)

**talc** /talk/ [n] ម្សៅតាល់, សមាសធាតុស៊ីលីកាតដែលមានលក្ខណៈទន់ និងមានភាពរអិលខ្លាំង

**talon** /ˈtalən/ [n] សូមមើលពាក្យ៖ claw

**talus** /ˈteɪləs/ [n]

១. សូមមើលពាក្យ៖ alluvial cone

២. ការប្រមូលផ្តុំកម្ទេចជាគំនរដែលធ្លាក់ពីលើ (ដី ក្រួស ថ្មជាដើម)

**tamarind** /ˈtam(ə)rɪnd/ [n] អំពិល (ឈ្មោះវិទ្យាសាស្ត្រ *Tamarindus indica*)

***Tamarindus indica*** [sci.n] សូមមើលពាក្យ៖ tamarind

**tamping** /tampin/ [n] សូមមើលពាក្យ៖ ramming

**tan** /tan/ [n] សទិសន័យ៖ desert varnish

**tangential** /tanˈdʒɛnʃ(ə)l/ [adj]

១. នៃតង់ស្យង់

២. មុខកាត់តង់ស្យង់, ដែលការកាត់មិនកាត់តាមផ្នែកកណ្តាលរបស់ឈើ

**tangerine** /tan(d)ʒəˈriːn/ [n] ក្រូចឃ្វិច (ឈ្មោះវិទ្យាសាស្ត្រ *Citrus tangerina*)

**tank** /taŋk/ [n] អាង, ធុង

- aeration tank /ɛːˈreɪʃ(ə)n taŋk/ [n] អាងបញ្ចូលខ្យល់
- oxidation tank /ɒksɪˈdeɪʃ(ə)n taŋk/ [n] អាងអុកស៊ីតកម្ម
- sedimentation tank /sɛdɪmɛnˈteɪʃ(ə)n taŋk/ [n] អាងរងកករ
- septic tank /ˈsɛptɪk taŋk/ [n] អាងសិបទិច
- sewage tank /ˈsuːɪdʒ taŋk/ [n] អាងលូសម្អុយ
- sludge tank /ˈslʌdʒ taŋk/ [n] អាងទទួលភក់

**tanner** /ˈtanə/ [n] អ្នកសម្លាប់ស្បែក

**tannery** /ˈtan(ə)ri/ [n] កន្លែងសម្លាប់ស្បែក

**Tannin** /ˈtanɪn/ [n] តាណាំង (សារធាតុរាវដែលមានលក្ខណៈសាំញ៉ាំនៅក្នុងស្លឹក សម្បក ផ្លែ ឬស ឬផ្នែកផ្សេងទៀត។ ពួកវាមាននាទីជា situ prophylactics នៅក្នុងជាលិការុក្ខជាតិ។ ពួកវាត្រូវបានប្រើសម្រាប់ពាណិជ្ជកម្មទៀតផង។)

**Tantalum** /ˈtantələm/ [n] តង់តាល់ (និមិត្តសញ្ញាគីមី Ta)

**tapioca** /ˌtapɪˈəʊkə/ [n] សូមមើលពាក្យ៖ cassava

**tarn** /tɑːn/ [n] សរសៃសូត្រ, អំបោះ, ចេស

**taro** /ˈtɑːrəʊ/ [n] ត្រាវ (ឈ្មោះវិទ្យាសាស្ត្រ៖ *Colocasia esculenta*, *Colocasia esculenta*)

**tarsus** /ˈtɑːsəs/ [n] ឆ្អឹង (ក្រញ៉ាំ)

**tartar** /ˈtɑːtə/ [n] ក្រាំង (ធ្មេញ ឬធុងស្រាទំពាំងបាយជូរ)

**tassel** /ˈtas(ə)l/ [n] ពន្លកផ្កា

**taste** /teɪst/ [n] រសជាតិ, ជីវ្ហាវិញ្ញាណ, ការភ្លក់, ការសាកល្បង

**taungya** [n] កសិកម្មពនេចរ

- taungya agroforestry [n]

  ១. ការដាំដុះដារវដ្ត ដែលត្រូវបានអនុវត្តនៅតំបន់ត្រូពិចនៅកន្លែង ដែលអ្នកដាំដុះ កាប់ដើមឈើដុត និងដាំដំណាំកសិកម្ម សម្រាប់រយៈពេលមួយ ឬច្រើនឆ្នាំមុនពេលផ្លាស់ប្តូរទៅកន្លែងផ្សេងទៀត

  ២. ប្រព័ន្ធដាំដុះរបស់ភូមា ដែលព្រៃត្រូវបានកាប់ និងដុតសម្រាប់ការដាំដុះរយៈពេល ពីមួយទៅពីរឆ្នាំ ទើបទុកចោលឱ្យដុះព្រៃឡើងវិញ

- taungya system [n] ការដាំដុះដើមឈើលាយជាមួយដំណាំកសិកម្ម

**tawes** [n] ត្រីឆ្ពិន, ត្រីឆ្ពិនប្រាក់ (ឈ្មោះវិទ្យាសាស្ត្រ *Barbonymus gonionotus*)

**taxis** /ˈtaksɪs/ [n] ទំនោរទី

**taxon** /ˈtaksɒn/ [n] (ពហុវចនៈ៖ taxa) ចំណាត់ថ្នាក់ (ប្រភេទលំដាប់ថ្នាក់ជាផ្លូវការណាមួយ ឧ. អំបូរ សន្តាន ឬភេទ ពូជ)

**taxonomist** /takˈsɒnəmɪst/ [n] វគ្គីករណ៍វិទូ (អ្នកវិទ្យាសាស្ត្រដែលមានចំនេះដឹងខាងផ្នែកវគ្គីករណ៍វិទ្យា)

**taxonomy** /takˈsɒnəmi/ [n] វគ្គីករណ៍វិទ្យា (វិទ្យាសាស្ត្រដែលសិក្សាពីការរៀបចំលំដាប់ថ្នាក់ជីវករទៅតាមលំដាប់លំដោយ)

- pant taxonomy /pant takˈsɒnəmi/ [n] រុក្ខវគ្គីករណ៍វិទ្យា (ប្រព័ន្ធចំណាត់រុក្ខជាតិ)
- soil taxonomy /sɔɪl takˈsɒnəmi/ [n] ធរណីវគ្គីករណ៍វិទ្យា (ប្រព័ន្ធចំណាត់ថ្នាក់ដី)

**tea** /tiː/ [n] តែ (ឈ្មោះវិទ្យាសាស្ត្រ *Thea sinensis*)

**teak** /tiːk/ [n] ដើមឈើម៉ៃសាក់ (ឈ្មោះវិទ្យាសាស្ត្រ *Tectona grandis*)

**tear** /tɛː/ [n] ទឹកភ្នែក

**teat** /tiːt/ [n] ក្បាលដោះ (មនុស្ស)

**Technetium** /tɛkˈniːʃɪəm/ [n] តិចនេចូម (និមិត្តសញ្ញាគីមី Tc)

**technique** /tɛkˈniːk/ [n] បច្ចេកទេស

- aseptic technique /eɪˈsɛptɪk tɛkˈniːks/ [n pl] បច្ចេកទេសជម្រះមេរោគ
- masking technique /mɑːskɪŋ tɛkˈniːk/ [n] ការគ្របបាំងដោយក្រដាសលើហ្វីលបញ្ចាំង (បច្ចេទេសប្រើហ្វីលបញ្ចាំង)

**technology** /tɛkˈnɒlədʒi/ [n] បច្ចេកវិទ្យា

- appropriate technology /əˈprəʊprɪət tɛkˈnɒlədʒi/ [n] បច្ចេកវិជ្ជាសមស្រប, បច្ចេកទេសសមស្រប
- component technology /kəmˈpəʊnənt tɛkˈnɒlədʒi/ [n] សមាសភាគបច្ចេកវិទ្យា (បច្ចេកវិទ្យានៃការដាំដុះទាំងឡាយដែលប្រើប្រាស់ដើម្បីគ្រប់គ្រងដំណាំពិសេសណាមួយក្នុងប្រព័ន្ធដាំដុះ)
- environmentally appropriate technology /ɛnvʌɪrənˈmɛnt(ə)li əˈprəʊprɪət tɛkˈnɒlədʒi/ [n] បច្ចេកវិជ្ជាសមស្របពុំផ្តល់គ្រោះថ្នាក់ដល់បរិស្ថាន
- recombinant DNA technology /rɪˈkɒmbɪnənt diːɛnˈeɪ tɛkˈnɒlədʒi/ [n] សូមមើលពាក្យ៖ genetic engineering
- soil technology /sɔɪl tɛkˈnɒlədʒi/ [n] បច្ចេកទេសដី (ផ្នែកភូគព្ភសាស្ត្រសិក្សាអំពីលក្ខណៈសម្រាប់សំណង់)
- wasteless technology /weɪstlɛs tɛkˈnɒlədʒi/ [n] បច្ចេកវិជ្ជាគ្មានសំណល់

**technology intervention** /tɛkˈnɒlədʒi ɪntəˈvɛnʃ(ə)n/ [n] ការបញ្ចូលបច្ចេកវិទ្យាថ្មី

**technology transfer** /tɛkˈnɒlədʒi transˈfəː/ [n] បន្ទេរបច្ចេកវិទ្យា

**technote** /tɛkˈnəʊt/ [n] អត្ថបទបច្ចេកទេស

***Tectona grandis*** [sci.n] សូមមើលពាក្យ៖ teak

**tectrices** /ˈtɛktrɪsiːz/ [n] (សរសេរជា tetrices ក៏បាន) រោមនៅលើស្លាបបក្សី

**tegmen** /ˈtɛgmɛn/ [n] ស្រទាប់ក្នុងនៃសម្បកគ្រាប់, តេកមែន (ស្រទាប់កណ្តាលនៃស្រទាប់ទាំងបីព័ទ្ធជុំវិញអង់ដូស្ពែមនៃគ្រាប់ធញ្ញជាតិ)

***Telenomus cyrus*** [sci.n] ឪម៉ាល់ (បរាសិតលើពងសង្កើចខ្មៅ)

***Telenomus rowani*** [sci.n] ឪម៉ាល់ (បរាសិតលើពងដង្កូវស៊ីរូងដើម)

**Tellurium** /tɛˈljʊərɪəm/ [n] តែលួ (និមិត្តសញ្ញាគីមី Te)

**telotaxis** /ˈtɛləʊ ˈtak·səs/ [n] ចលនាសំដៅរំញោច

***Temelucha philippinensis*** [sci.n] ពួកឪម៉ាល់ (បរាសិតដង្កូវ)

**temma** [n] ទឹមម៉ា

**temperate recalcitrant** /ˈtɛmp(ə)rət recalcitrant/ [adj] ប្រភេទគ្រាប់សើមធុនកណ្តាល (ក្រុមមួយនៃប្រភេទគ្រាប់សើម ដែលងាយហួតបន្ទុកសំណើម ហើយមិនធន់នឹងការស្តុកទុកដែលមានបន្ទុកសំណើមទាបទេ តែវាធុននឹងសីតុណ្ហភាពទាប ដែលជាចំណុចខុសប្លែកពីប្រភេទគ្រាប់សើមក្នុងតំបន់ត្រូពិច។ ប្រភេទនេះមានច្រើនក្នុងព្រៃតំបន់ត្រជាក់បង្គួរ)

**temperature** /ˈtɛmp(ə)rətʃə/ [n] សីតុណ្ហភាព

- ambient temperature /ˈambɪənt ˈtɛmp(ə)rətʃə/ [n] សីតុណ្ហភាពជុំវិញ
- core temperature (Tc) /kɔː ˈtɛmp(ə)rətʃə/ [n] សីតុណ្ហភាពស្នូល (សីតុណ្ហភាពមធ្យម នៅក្នុងជាលិការបស់ភាវរស់មួយ)
- extreme of temperature /ɪkˈstriːm ɒv ˈtɛmp(ə)rətʃə/ [n] សីតុណ្ហភាពដែលក្តៅខ្លាំង ឬត្រជាក់ខ្លាំង

- gelatinization temperature /dʒɪˈlatɪnʌɪzeɪʃ(ə)n ˈtɛmp(ə)rətʃə/ [n] សីតុណ្ហភាពនៃអន្ទិលកម្ម (សីតុណ្ហភាពដែលគ្រាប់អង្ករចាប់ហើម ឬរីក)
- room temperature /ruːm ˈtɛmp(ə)rətʃə/ [n] សីតុណ្ហភាពក្នុងបន្ទប់ (បន្ទប់ដែលសីតុណ្ហភាពមានតម្លៃឯកលក្ខណៈភាពក្បែរ ២៧ អង្សារសេ)

**temporal mandibular joint** /ˈtɛmp(ə)r(ə)l manˈdɪbjʊlə dʒɔɪnt/ [n] សន្លាក់ឆ្អឹងក្រអូមថ្គាម និងឆ្អឹងសៀតផ្កា

**temporary** /ˈtɛmp(ə)rəri/ [adj] បណ្តោះអាសន្ន

**tenacity** /tɪˈnasɪti/ [n] ភាពស្អិត, ភាពស្វិត ឬជាប់

**tender** /ˈtɛndə/ [adj] រួស, ផុយ, មិនស្វិត

**tendon** /ˈtɛndən/ [n] សរសៃពួរ

**tendril** /ˈtɛndrɪl/ [n] ដៃវល្លិ (សរីរាង្គនៃដើម ឬស្លឹកដែលតោងវារឡើង ឬក្បៀបជាប់នឹងអ្វីមួយ និងមានដើមស្រាវតូចៗ)

- stem tendril /stɛm ˈtɛndrɪl/ [n] គល់រុំ

**tenorrhaphy** [n] ការដេរសរសៃពួរ

**tense** /tɛns/ [adj] តឹងតែង, សន្ទឹង

**tension** /ˈtɛnʃ(ə)n/ [n] ភាពតឹងតែង, សន្ទឹង, ភាពទាញតឹង, សម្ពាធ

- soil-moisture tension /sɔɪl ˈmɔɪstʃə ˈtɛnʃ(ə)n/ [n] សម្ពាធទឹកក្នុងដី, តង់ស្យុងទឹកក្នុងដី
- superficial tension /ˌsuːpəˈfɪʃ(ə)l ˈtɛnʃ(ə)n/ [n] តង់ស្យុងផ្ទៃខាងលើ
- moisture tention /ˈmɔɪstʃə ˈtɛnʃ(ə)n/ [n] ថាមពលទាញផ្អឹបយកទឹក

**tension meter** /ˈtɛnʃ(ə)n mɪtə/ [n] ឧបករណ៍សម្រាប់វាស់ថាមពលដែលធ្វើឱ្យទឹកបឺតជាប់ទៅលើដី

***Tenualosa thibaudeaui*** [sci.n] សូមមើលពាក្យ៖ Laotian shad

***Tenualosa toli*** [sci.n] សូមមើលពាក្យ៖ toli shad

**tepal** /ˈtɛp(ə)l/ [n] បរិបុប្ផា

***Tephrosia purpurea*** [sci.n] ត្រុំខ្មោច

**tepid** /ˈtɛpɪd/ [n] ក្តៅឧណ្ហៗ

**Terbium** /ˈtəːbɪəm/ [n] ទែប្យូម (និមិត្តសញ្ញាគីមី Tb)

**terete** /təˈriːt/ [adj] រលោង រាងស៊ីឡាំង និងរាងស្រួច (ឧទាហរណ៍ ដើមរបស់ស្មៅ)

**terminal** /ˈtəːmɪn(ə)l/ [adj] នៅខាងចុង (អំពីទម្រង់របស់រុក្ខជាតិ)

**terminology** /ˌtəːmɪˈnɒlədʒi/ [n] ប្រជុំស័ព្ទបច្ចេកទេស

**termite** /ˈtəːmʌɪt/ [n] កណ្តៀរ

**terrace** /ˈtɛrəs/ [n]

១. ថ្នាក់ជម្រាល, ល្បាក់រាប

២. (សទិសន័យ៖ step terrace) តេរ៉ាស់ (ធម្មជាតិ)

៣. (សទិសន័យ៖ embankment) ផ្ទៃដីរាបស្មើ (នៅលើជម្រាលទន្លេ ឬស្ទឹង), តេរ៉ាស់សិប្បនិម្មិត

- absorptive terrace /əbˈzɔːptɪv ˈtɛrəs/ [n] តេរ៉ាស់សម្រាប់បឺតទឹក
- alluvial terrace /əˈl(j)uːvɪəl ˈtɛrəs/ [n] អំពបល្បាប់
- backshore terrace /bakʃɔːˈtɛrəs/ [n] (សទិសន័យ៖ marine terrace, berm) តេរ៉ាស់តាមឆ្នេរសមុទ្រ
- bedrock terrace /ˈbɛdrɒkˈtɛrəs/ [n] តេរ៉ាស់ដែលកើតពីការហូរច្រោះ
- bench terrace /bɛn(t)ʃ ˈtɛrəs/ [n] តេរ៉ាស់ជាថ្នាក់ៗនៅតាមមាត់ទន្លេ ឬស្ទឹង
- bench terrace /bɛn(t)ʃ ˈtɛrəs/ [n] ថ្នាក់កាំជណ្តើរដាំដំណាំនៅតំបន់ខ្ពង់រាប, តេរ៉ាស់ជាថ្នាក់ៗ
- broad-base terrace /brɔːd-beɪs ˈtɛrəs/ [n] តេរ៉ាស់ដែលមានបាតធំទូលាយ
- denudation terrace /diːnjʊˈdeɪʃ(ə)n ˈtɛrəs/ [n] តេរ៉ាស់ទទេ (គ្មានរុក្ខជាតិសោះ)
- diversion terrace /dʌɪˈvəːʃ(ə)nˈtɛrəs/ [n] តេរ៉ាស់បង្វែរ (តេរ៉ាស់សិប្បនិម្មិត)
- graded terrace /greɪd ˈtɛrəs/ [n] តេរ៉ាស់ដែលមានជម្រាល, តេរ៉ាស់ផ្សៀងតាមបណ្តោយ (សម្រាប់ស្រោចស្រពនិងបញ្ចេញទឹក)
- high terrace /hʌɪ ˈtɛrəs/ [n] តេរ៉ាស់លើ
- level terrace /ˈlɛv(ə)l ˈtɛrəs/ [n] តេរ៉ាស់រាបស្មើនៅតាមបណ្តោយ (ប៉ុន្តែអាចមានជម្រាលពីខាង)
- marine terrace /məˈriːn ˈtɛrəs/ [n] (សទិសន័យ៖ backshore terrace, berm) តេរ៉ាស់តាមឆ្នេរសមុទ្រ
- narrow base terrace /ˈnarəʊ beɪsˈ tɛrəs/ [n] តេរ៉ាស់ដែលមានបាតតូចទ្រវែង (សិប្បនិម្មិត)

- residual terrace /rɪˈzɪdjʊəl ˈtɛrəs/ [n] តេរ៉ាស់ដែលជាសម្ភារសំណល់
- ridge terrace /rɪdʒˈtɛrəs/ [n] តេរ៉ាស់ដែលមានចង្អូរប្រឡាយតាមបណ្ដោយខាងលើជម្រាល, តេរ៉ាស់លើភ្នំ
- river terrace /ˈrɪvəˈtɛrəs/ [n] តេរ៉ាស់ទន្លេស្ទឹងដែលកើតពីប្រភពច្រើនបន្តបន្ទាប់គ្នា (តេរ៉ាស់ធម្មជាតិ)
- solifluction terrace /sɒlɪˈflʌkʃ(ə)n ˈtɛrəs/ [n] តេរ៉ាស់ (ដីរាបស្មើ) ដែលជាលទ្ធផលនៃការរអិលចុះនៃដីលើជម្រាលក្នុងពេលដីសើមខ្លាំង
- spur terrace /spəː ˈtɛrəs/ [n] តេរ៉ាស់សម្រាប់ទប់ទឹកមិនឱ្យហូរច្រោះ
- step terrace /stɛp ˈtɛrəs/ [n] សូមមើលពាក្យ៖ terrace
- valley terrace /ˈvaliˈtɛrəs/ [n] តេរ៉ាស់តាមបណ្ដោយជ្រលងទឹក

**terracing** /ˈtɛrəsɪŋ/ [n] ទង្វើថ្នាក់ដី, ការសាងសង់ថ្នាក់ដី

**terrain** /tɛˈreɪn/ [n] លក្ខណៈភូមិសាស្ត្រដី

- sand terrain /sand tɛˈreɪn/ [n] ដីខ្សាច់

**terrestrial** /təˈrɛstrɪəl/ [adj] រស់នៅលើគោក

**terrier** /ˈtɛrɪə/ [n] ឆ្កែសម្រាប់បរបាញ់

**terrigenous** /tɛˈrɪdʒɪnəs/ [adj] ដែលកើតពីដី

**testa** /ˈtɛstə/ [n] សម្បកគ្រាប់ផ្នែកខាងក្រៅ, សម្បកគ្រាប់ (ភ្នាសការពារដែលស្ថិតនៅព័ទ្ធជុំវិញគ្រាប់ ជាធម្មតាវារឹង និងស្វិត ប៉ុន្តែវាអាចមានភាពទន់ ចំពោះប្រភេទខ្លះ)

**test** /tɛst/ [n]

១. ការពិនិត្យ (ឧ. blood test, TB test, agglutination test)

២. សូមមើលពាក្យ៖ trial

- blood test /blʌd tɛst/ [n] ការវិភាគឈាម
- clonal test /ˈkləʊn(ə)l tɛst/ [n] ការសាកល្បងកូនបំបៅ, ការពិសោធកូនបំបៅ (ការប្រៀបធៀបនិងការវាយតម្លៃកូនឈើក្លូនមួយចំនួនក្នុងការធ្វើពិសោធន៍ជាច្រើនគំរូ។ ការពិសោធន៍ផ្ដល់ នូវការប៉ាន់ស្មានសេណូទីបនីមួយៗ ប៉ុន្តែមិនមែនជាព័ត៌មានស្ដីពីលក្ខណៈបង្កាត់ពូជឡើយ។)
- complementation test /kɒmplɪmɛnˈteɪʃn tɛst/ [n] តេស្តបំពេញគ្នា (តេស្តសេនេទិច ដើម្បីកំណត់ថាតើមុយតាស្យុងពីរកើតឡើងក្នុងពន្ធុដូចគ្នា ឬទេ)
- cutting test /ˈkʌtɪŋ tɛst/ [n] ការពិសោធកាត់គ្រាប់-ផ្លែមើលលទ្ធភាពដុះរបស់គ្រាប់
- farmer-manage tests /ˈfɑːmə ˈmanɪdʒ tɛsts/ [n pl] ការពិសោធកសិករគ្រប់គ្រង (ការពិសោធលើកូនស្រែដែលគ្រប់គ្រងកសិករដោយផ្ទាល់)
- germination test /dʒəːmɪˈneɪʃ(ə)n tɛst/ [n] (សទិសន័យ៖ viability test) ការសាកល្បងដំណុះ
- health test /hɛlθ tɛst/ [n] ការពិសោធសុខភាព (ការពិសោធន៍ពិសេសលើគ្រាប់ ដើម្បីពិនិត្យមើលការឆ្លងរោគរបស់គ្រាប់)
- hiltner test [n] ការពិសោធពលសម្បទា (វិធីពិសោធមើលពលសម្បទាដែលក្នុងនោះសមត្ថភាពរបស់ពន្លកប្រឹងឈ្នះការសង្កត់រូប (physical stress) ត្រូវបានគេវាយតម្លៃតាមរយៈការបណ្ដុះគ្រាប់នៅក្រោមស្រទាប់កំទេចថ្ម-គ្រួស)
- progeny test /ˈprɒdʒəni tɛst/ [n] (សទិសន័យ៖ progeny trial) ការដាំសាកល្បងកូន
- provenance test /ˈprɒv(ə)nəns tɛst/ [n] (សទិសន័យ៖ provenance trial) ការសាកល្បងប្រភពកំណើត
- species elimination test /ˈspiːʃiːz ɪlɪmɪˈneɪʃ(ə)n tɛst/ [n] (សទិសន័យ៖ species elimination trial) ការដាំសាកល្បងជ្រើសពូជ
- species test /ˈspiːʃiːz tɛst/ [n] (សទិសន័យ៖ species trial) ការដាំសាកល្បងពូជ, ការដាំពិសោធន៍ពូជ (ការប្រៀបធៀបក្នុងគ្រោងការណ៍ដាំសាកល្បងយ៉ាងហ្មត់ចត់ល្អមួយនូវប្រភេទពូជជម្រើស ត្រូវបានដាំនៅក្នុងបរិស្ថាន ២ប្រភេទ ឬច្រើន ដើម្បីសិក្សា តើពូជមួយណាដុះកបបំផុតនៅទីចម្ការណាមួយ។ គេប្រើវិធីសាកល្បងនេះជាមុន ទើបនាំចូលប្រភេទពូជថ្មីមកដាំនៅតំបន់ណាមួយ ហើយធ្វើមុនឬធ្វើគួបផ្សំការដាំសាកល្បងប្រភពកំណើត។)
- squash test /skwɒʃ tɛst/ [n] វិធីពិសោធន៍លទ្ធភាពដំណុះគ្រាប់ (ដោយច្របាច់បំបែកគ្រាប់) (ជាវិធីពិសោធន៍លទ្ធភាពដុះរបស់គ្រាប់ដោយប្រយោល និងសាមញ្ញមួយដែលជាដំបូងគ្រាប់ដាក់ឱ្យស្រូបទឹក បន្ទាប់មកប្រើតំបៀតច្របាច់បំបែកគ្រាប់ដើម្បីពិនិត្យមើលស្ថានភាពរបស់អំប្រ៊ីយ៉ុង។ ចំនួននៃគ្រាប់ដែលបង្ហាញថាស្រស់ និងសុខភាពល្អក្នុង១ខ្នាតទម្ងន់នៃគ្រាប់បូកគ្រាប់ស្លៀត ឬក្នុង១០០គ្រាប់ (ប្រភេទគ្រាប់ធំ) គ្រាន់តែធ្វើការប៉ាន់ស្មានពីលទ្ធភាពដំណុះរបស់វា។)

- topcross test [n] ការពិសោធន៍កូនកាត់ (ការសាកល្បងកូនដែលបានមកពីការបង្កាត់មេបានីមួយៗជាមួយលម្អងសាកល្បងដូចគ្នា។ លម្អងអាចបានមកពីដើមនៅក្នុងឡូត៍មួយ ឬជាបាយពីដើមឈើមួយចំនួននៃដើមបេក្ខភាពសាកល្បង ប៉ុន្តែមិនត្រូវរារាំងការចូលរួមរបស់មេបាពិសោធទេ។)
- urine test /ˈjʊərɪn tɛst/ [n] ការធ្វើតេស្តទឹកនោម, ការធ្វើវិភាគទឹកនោម
- viability test /vʌɪəˈbɪlɪti tɛst/ [n] សូមមើលពាក្យ៖ germination test
- vigour test /ˈvɪgə tɛst/ [n] ការពិសោធពលសម្បទាដំណុះរបស់គ្រាប់ (ជាធម្មតាការពិសោធដំណុះត្រូវបានធ្វើឡើងនៅក្រោមលក្ខខណ្ឌមិនប្រសើរទេ (ខ្វះខាត) ឬក្រោយពីបង្កើនអាយុរួច ដើម្បីបង្ហាញឱ្យឃើញនូវការខូចខាតរបស់កញ្ចប់គ្រាប់ពូជ។ ការពិសោធដំណុះក្នុងលក្ខខណ្ឌធម្មតាគេមិនអាចប៉ាន់ស្មានដឹងទេ។)

**testicle** /ˈtɛstɪk(ə)l/ [n] ពងស្វាស, ក្រពេញទឹកកាម (ឈ្មោល)

**testing** /ˈtɛstɪŋ/ [n] ការសាកល្បង, ការធ្វើតេស្ត

- multi-locational testing / ˈmʌlti lə(ʊ)ˈkeɪʃ(ə)nəl ˈtɛstɪŋ/ [n] ការសាកល្បងពហុដ្ឋាន (បច្ចេកទេសថ្មីដែលបានរកឃើញក្នុងមជ្ឈមណ្ឌលស្រាវជ្រាវមួយហើយត្រូវបានធ្វើការសាកល្បងនៅទីកន្លែងជាច្រើនទៀត ដើម្បីរកឱ្យឃើញអ្វីដែលសមស្រប មុននឹងផ្សព្វផ្សាយយ៉ាងទូលំទូលាយ)
- pump testing /pʌmp ˈtɛstɪŋ/ [n] ពិសោធម៉ាស៊ីនបូមទឹក
- seed testing /siːd ˈtɛstɪŋ/ [n] ការពិសោធគ្រាប់ពូជ (ការត្រួតពិនិត្យគុណភាពសរីរៈរបស់គ្រាប់នៃកញ្ចប់គ្រាប់ពូជមួយ ជាធម្មតា វាមាន៤ប៉ារ៉ាម៉ែត្រគំរូ ពោលគឺ ភាពសុទ្ធ ទម្ងន់គ្រាប់ បន្ទុកសំណើម និងលទ្ធភាពរស់ឬភាគរយដំណុះ។ ជួនកាលអាចមានប៉ារ៉ាម៉ែត្រពិសេស មួយទៀត ដូចជា ការពិសោធភាពរឹងមាំ ឬសុខភាព។ ច្បាប់គំរូនិងនិតិវិធីសម្រាប់ធ្វើការពិសោធគ្រាប់ចេញ ដោយ ISTA (Europe) ឬ AOSA (America)។)
- soil testing /sɔɪl ˈtɛstɪŋ/ [n] វិសោធនកម្មដី (ការកំណត់នូវលក្ខណៈរូប និងគីមីនៃដី។ លទ្ធផលនៃការធ្វើតេស្តដីមានប្រយោជន៍ណាស់សម្រាប់ការណែនាំឱ្យប្រើប្រាស់ដី។)
- varietal testing /vəˈrʌɪət(ə)l ˈtɛstɪŋ/ [n] ការពិសោធពូជ

**testis** /ˈtɛstɪs/ [n pl] ពងស្វាសច្រើន

**testosterone** /tɛˈstɒstərəʊn/ [n] តេស្តូស្តេរ៉ូន (អ័រម៉ូនភេទឈ្មោល)

**testudinate** [adj] មានសម្បករឹង (មានសម្បកការពាររឹងមាំដូចជាស្នូកអណ្តើក)

**tetanus** /ˈtɛt(ə)nəs/ [n] តេតាណូស

**tetany** /ˈtɛt(ə)ni/ [n] ញាក់សាច់, អតុល្យភាពនៃជាតិកាល់ស្យូម បណ្តាលឱ្យកន្ត្រាក់សាច់ដុំ, ក្តាមកាច់, ប្រកាច់ឈឺក្នុងសាច់ដុំ

**tether** /ˈtɛðə/ [v] ចង

***Tetragnatha maxillosa*** [sci.n] ពីងពាងថ្គាមវែង

**tetraploid** /ˈtɛtrəplɔɪd/ [n] តេត្រាប្លូអ៊ីត (មានក្រូម៉ូសូម 4n)

**tetrapoda** /ˈtɛtrəpɒd/ [n] ចតុបាទ

**tetrapterous** /tɪˈtrapt(ə)rəs/ [adj] ដែលមានស្លាបបួន

***Tetrastichus schoenobii*** [sci.n] ពួកឌីម៉ាល់ (បារាសិតបំពារលើដង្កូវស៊ីរូងដើម)

**tetrazolium (TTZ)** /ˌtɛtrəˈzəʊlɪəm/ [n] សារធាតុគីមីម្យ៉ាងឈ្មោះតេត្រាសូដ្យូម

**texture** /ˈtɛkstʃə/ [n] វាយនភាព

- clastic texture /ˈklastɪkˈtɛkstʃə/ [n] វាយនភាពជាកម្ទេចថ្ម
- coarse texture /kɔːs ˈtɛkstʃə/ [n] វាយនភាពគ្រើម, គ្រាប់ធំ, គ្រាប់គ្រើម
- fragmental texture /ˌfragˈmɛnt(ə)l ˈtɛkstʃə/ [n] សភាពជាដុំៗ ឬជាគ្រាប់ៗ
- soil texture /sɔɪl ˈtɛkstʃə/ [n] វាយនភាពដី (សមាមាត្រភាពពិតមួយរបស់ដីទៅតាមបរិមាណភាគល្អិតរបស់វា)

**Thai gizzard shad** [n] ត្រីកាមួយ (ឈ្មោះវិទ្យាសាស្ត្រ *Anodontostoma thailandae*)

**Thai mahseer** [n] ត្រីក្ងោរ (ឈ្មោះវិទ្យាសាស្ត្រ *Tor tambroides*)

**Thai river sprat** /tʌɪ ˈrɪvə sprat/ [n] ត្រីបណ្តូលល្ពៅ (ឈ្មោះវិទ្យាសាស្ត្រ *Clupeichthys aesarnensis*)

**Thalamus** /ˈθaləməs/ [n] ភាគមួយនៃខួរក្បាល

**Thallium** /ˈθalɪəm/ [n] តាល្យូម (និមិត្តសញ្ញាគីមី Tl)

**thallus** /ˈθaləs/ [n] (ពហុវចនៈ៖ thalli) សរីរាង្គលូតលាស់, តាល់ (សារពាង្គកាយរុក្ខជាតិគ្មានសរសៃនាំ)

- intracellular thallus /ˌɪntrəˈsɛljʊlə ˈθaləs/ [n] សរីរាង្គលូតលាស់របស់ផ្សិត

**thalweg** /ˈtɑːlvɛg/ [n] បាតស្ទឹង,បាតជ្រលង

**thatch** /θatʃ/ [n] ស្បូវ

***Thea sinensis*** [sci.n] សូមមើលពាក្យ៖ tea

***Theobroma cacao*** [sci.n] សូមមើលពាក្យ៖ cacao

**theorem** /ˈθɪərəm/ [n] ទ្រឹស្តីបទ

**theory** /ˈθɪəri/ [n] ទ្រឹស្តី

- cell theory /sɛl ˈθɪəri/ [n] ទ្រឹស្តីកោសិកា
- chromosome theory /ˈkrəʊməsəʊm ˈθɪəri/ [n] ទ្រឹស្តីក្រូម៉ូសូម (គំនិតដែលថាសែនស្ថិតនៅលើក្រូម៉ូសូម)

**therapeutic** /ˌθɛrəˈpjuːtɪk/ [adj] ដែលទាក់ទងព្យាបាល, ខាងការព្យាបាលរោគ

- therapeutic abortion /ˌθɛrəˈpjuːtɪk əˈbɔːʃ(ə)n/ [n] ការពន្លូតកូនដើម្បីរក្សាសុខភាពម្តាយ, ការរលូតកូនដោយស្របច្បាប់ដើម្បីសុខភាពម្តាយក៏រិតព្យាបាល
- therapeutic agent [n] ភ្នាក់ងារព្យាបាល (សមាសធាតុដែលត្រូវបានគេប្រើសម្រាប់ការព្យាបាលជំងឺមួយ ឬសម្រាប់ធ្វើអោយប្រសើរឡើងនូវផាសុខភាពនៃសារពាង្គកាយមួយ)
- therapeutic dose /ˌθɛrəˈpjuːtɪk dəʊs/ [n] កម្រិតព្យាបាល

**therapy** /ˈθɛrəpi/ [n] វិធីព្យាបាល, ការព្យាបាល

- physical therapy /ˈfɪzɪk(ə)l ˈθɛrəpi/ [n] វិធីព្យាបាលកាយិទុក្ខ (របៀបព្យាបាលនៃសេចក្តីលំបាកខាងរូបកាយ)
- occupational therapy /ɒkjʊˈpeɪʃ(ə)n(ə)l ˈθɛrəpi/ [n] វិធីព្យាបាលអាជីវប្បវត្តិ, របៀបព្យាបាលខាងមុខរបរចិញ្ចឹមជីវិត

**therm-** /θəːm/ [prefix] (សទិសន័យ៖ heat) បុព្វបទមានន័យថា កម្តៅ

**thermal** /ˈθəːm(ə)l/ [adj] ទាក់ទងកម្តៅ

**thermometer** /θəˈmɒmɪtə/ [n] ទែម៉ូម៉ែត្រ

**thermonasty** /θəːmə(ʊ)ˈnɑːsti/ [n] តំណាបនឹងកម្តៅ (តំណាបរបស់រុក្ខជាតិទៅនឹងរំញោចសីតុណ្ហភាពទូទៅ)

**thermophilic** /θəːmə(ʊ)ˈfɪlɪk/ [adj] រស់នៅក្នុងសីតុណ្ហភាពខ្ពស់

**thermophobic** /θəːmə(ʊ)ˈfəʊbɪk/ [adj] រស់នៅក្នុងសីតុណ្ហភាពទាប

**thermosphere** /ˈθəːməsfɪə/ [n] ទែម៉ូស្វែ, ស្រទាប់កម្តៅ

**thermostat** /ˈθəːməstat/ [n] ទែម៉ូស្តា

**Thermotogales** [n] ថឺម៉ូថូហ្គេល (សាខាបាក់តេរីចំណូលក្តៅ ដែលមានលីពីតមិនធម្មតា)

**therophyte** /ˌθəːrəʊfʌɪt/ [n] តេរ៉ូហ្វិត (តិណជាតិដែលអាចនៅរស់បានក្នុងរដូវត្រជាក់ ឬក្នុងលក្ខខណ្ឌមិនប្រកបផ្សេងៗទៀតក្នុងទម្រង់ជាគ្រាប់)

**thick** /θɪk/ [adj] ក្រាស់

**thicket** /ˈθɪkɪt/ [n] កន្លែងស៊ុបទ្រុប

**thickness** /ˈθɪknəs/ [n] កម្រាស់, ភាពខាប់, ភាពណែនណាន់តាន់តាប់

**thigh** /θʌɪ/ [n] ភ្លៅ

**thigmokinesis** [n] ចលនាតបនឹងការប៉ះ

**thin** /θɪn/ [v] ធ្វើឱ្យរាវ, ធ្វើឱ្យស្តើង

**thin** /θɪn/ [adj] ស្តើង, ស្គម

**thinning** [n] ការធ្វើឱ្យកាន់តែស្តួច ឬតូច, រំលោះ, ការកាប់រំលោះ (កូនឈើ) (ការកាប់ដោយផ្ទេកនូវប្រភេទឈើដែលមិនទាន់ពេញវ័យ ដើម្បីបង្កើតនូវផលឈើតាមរយៈការផ្តោតជាសំខាន់ទៅលើឈើមួយៗ។ ការធ្វើប្រព្រឹត្តកម្មដើមឈើដោយកាត់បន្ថយដង់ស៊ីតេរបស់ដើមដើម្បីបង្កើនការលូតលាស់ធ្វើឱ្យមានសុខភាពល្អ និងកាត់បន្ថយអត្រាស្លាប់។)

**thirst** /θəːst/ [n] ការស្រេក (ទឹក)

**thirsty** /ˈθəːsti/ [adj] ស្រេក (ទឹក)

**thoracentesis** [n] ការចាក់ម្ជុលបូមទឹកពីក្នុងទ្រូង

**thoracic** /θɔːˈrasɪk/ [adj] ដែលទាក់ទងនឹងទ្រូង

**thoracocentesis** [n] ការបូមទឹកចេញពីសួត

**thorax** /ˈθɔːraks/ [n] (ពហុវចនៈ៖ thoraces) ទ្រូងនៃសត្វល្អិត

**Thorium** /ˈθɔːrɪəm/ [n] តូរ្យ៉ូម (និមិត្តសញ្ញាគីមី Th)

**thorn** /θɔːn/ [n] បន្លា (ដើម ឬមែកកំណែប្រែមានចុងស្រួច)

**thread** /θrɛd/ [n] សរសៃ (អំបោះ), ចេស, អំបោះដេរ

- silk thread /sɪlk θrɛd/ [n] អំបោះសូត្រ

**three-leaf cayratia** [n] វល្លិត្រដឹត (ឈ្មោះវិទ្យាសាស្ត្រ *Cayratia trifolia*)

**three-lobe morning glory** [n] ដើមសណ្តាជូ (ឈ្មោះវិទ្យាសាស្ត្រ *Ipomoea triloba*)

**threespot gourami** [n] ត្រីកំភ្លាញស្រែ (ឈ្មោះវិទ្យាសាស្ត្រ *Trichogaster trichopterus*)

**thresh** /θrɛʃ/ [v] បោកបែន (ស្រូវ)

**threshability** /θrɛʃəˈbɪlɪti/ [n] លទ្ធភាពបោកបែន (ភាពស្វិត ឬងាយរុះរបស់គ្រាប់ធញ្ញជាតិនៅពេលបោក ឬបែន)

**threshing** /θrɛʃɪŋ/ [n] ការប្រលេះយកគ្រាប់ (បោក បែន ជាន់ ដំ) (ការបំបែក និងការយកគ្រាប់ ផ្លែស្ងួតតាមវិធីមេកានិចទៅលើផ្លែ ឧ. បោក វាយដំ ជាន់បែនជាន់ទន្រ្ទាំ ឬប្រើម៉ាស៊ីនបោកបែន)

**threshold** /ˈθrɛʃˌhəʊld/ [n] កម្រិត, ព្រំ, ចំណុចចាប់ផ្តើម

- action threshold /ˈakʃ(ə)n ˈθrɛʃəʊld/ [n] កម្រិតពិចារណា
- economic threshold /ˌiːkəˈnɒmɪk ˈθrɛʃəʊld/ [n] កម្រិតទ្វារសេដ្ឋកិច្ច, កម្រិតច្រកទ្វារសេដ្ឋកិច្ច, កម្រិតមាត់ទ្វារសេដ្ឋកិច្ច (កម្រិត ឬដង់ស៊ីតេនៃពួកសត្វល្អិតធ្វើការបំផ្លាញដំណាំនៅក្បែរៗទ្វារសេដ្ឋកិច្ចប៉ុណ្ណោះ ហើយក៏ជាពេលវេលាដែលកសិករត្រូវមានវិធានការការពារ ឬរាំងស្កាត់កុំឱ្យវាបំផ្លាញជាបន្តទៅទៀតបាន)
- climate threshold /ˈklʌɪmət ˈθrɛʃəʊld/ [n] ចំណុចចាប់ផ្តើមនៃអាកាសធាតុ

**thrips** /θrɪps/ [n] ទ្រីប, ចៃជញ្ជក់រុក្ខរស

***Thrips tabaci*** [sci.n] ទ្រីបថ្នាំជក់

**throat** /θrəʊt/ [n] បំពង់ក

**throb** /θrɒb/ [n] ដំណើរញាប់ញ័រ, ដំណើរលោតនៃជីពចរ

**thrombin** /ˈθrɒmbɪn/ [n] ត្រុមប៊ិន (អង់ស៊ីមដែលកើតនៅពេលឈាមហូរ មកក្រៅ ហើយដែលជួយបង្កកឈាម)

**thrombophlebitis** [n] ជំងឺរលាកសរសៃឈាម ដោយការកកើតនៃការកកឈាមនៅក្នុងសរសៃឈាម

**thrombosis** /θrɒmˈbəʊsɪs/ [n] ការកកើត ឬមានឈាមកកនៅក្នុងសរសៃឈាម

**thrombus** /ˈθrɒmbəs/ [n] ដុំឈាម

**thrombus** /ˈθrɒmbəs/ [n] ការមានកកឈាមក្នុងសរសៃឈាម

- coronary thrombus /ˈkɒr(ə)n(ə)ri ˈθrɒmbəs/ [n] ការរាំងស្ទះនៃសរសៃឈាមចញ្ចឹមបេះដូង

**thrum-eyed** /θrʌm ʌɪd/ [adj] (ចំពោះរុក្ខជាតិ) ស្រាំអាយ (ដែលមានកេសរញីខ្លី និងកញ្ចុំកេសរឈ្មោលវែង)

**thrush** /θrʌʃ/ [n] ជំងឺច្រាំងមាត់

***Thryssocypris tonlesapensis*** [sci.n] ត្រីកាប

**Thulium** /ˈθ(j)uːlɪəm/ [n] ទុយល្យូម (និមិត្តសញ្ញាគីមី Tm)

**thymus** /ˈθʌɪməs/ [n] សរីរាង្គតូចមួយមានរាងដូចក្រពេញបិតនៅចន្លោះកនឹងទ្រូង, ទីមុស

***Thynnichthys thynnoides*** [sci.n] ត្រីលិញ

**thyroid** /ˈθʌɪrɔɪd/ [n] ក្រពេញទីរ៉ូអ៊ីត (ក្រពេញបិតនៅក)

**thyroiddectomy** /ˈθʌɪrɔɪdˈɛktəmi/ [n] ការវះកាត់យកក្រពេញទីរ៉ូអ៊ីត

**Thysanoptera** /ˌθʌɪsəˈnɒpt(ə)rə/ [n] ធីរ៉ាណូផ្តេរ៉ា (លំដាប់សត្វល្អិតរួមមានទ្រីប សត្វល្អិតចង្រៃលើដំណាំ និងរុក្ខជាតិហូបផ្លែ)

**Thysanura** /ˌθʌɪsəˈn(j)ʊərə/ [n] ធីសានូរ៉ា (លំដាប់សត្វល្អិត រួមមានប្រីសថលថេល ដែលជាសត្វល្អិតគ្មានស្លាប រស់នៅក្នុងដី និងគំនរស្លឹករុក្ខជាតិ)

**tibia** /ˈtɪbɪə/ [n] (ពហុវចនៈ៖ tibiae) (សទិសន័យ៖ shank) ឆ្អឹងធំនៃស្មងជើង, ឆ្អឹងស្មងជើង (ស្មងជើងសត្វល្អិតនៃកង់ទី៤ ដែលស្ថិតនៅចន្លោះភ្លៅ និងកជើង ឬប្រអប់ជើង)

**tick** /tɪk/ [n] (សទិសន័យ៖ dermacentor, Rhipicephalus) សត្វចៃ (ឆ្កែ), ដង្កែ, ខែម៉ាសង់ទ័រ

**tidal pufferfish** /ˈtʌɪd(ə)l ˈpʌfəfɪʃ/ [n] ត្រីកំពត (ឈ្មោះវិទ្យាសាស្ត្រ *Chelonodon fluviatilis*)

**tide** /tʌɪd/ [n] ជំនោរ (ទឹក)

**tide gauge** /tʌɪd ɡeɪdʒ/ [n] រង្វាស់ទឹកជៀរ-នាច

**tidy** /ˈtʌɪdi/ [adj] រៀបរយ, ស្អាតបាត

**tie** /tʌɪ/ [n] ចំណង

**tie** /tʌɪ/ [v] ចង

**tigerfish** /ˈtʌɪɡə fɪʃ/ ពពួកត្រីកខ្លា

- barred tigerfish /bɑːd ˈtʌɪɡə fɪʃ/ [n] ត្រីខ្លា (ឈ្មោះវិទ្យាសាស្ត្រ *Datnioides quadrifasciatus*)
- finescale tigerfish /fʌɪnskeɪl ˈtʌɪɡəfɪʃ/ [n] ត្រីខ្លា (ឈ្មោះវិទ្យាសាស្ត្រ *Datnioides microlepis*)

**tight** /tʌɪt/ [adj] សូមមើលពាក្យ៖ compact

**tilapia** /tɪˈleɪpɪə/ [n] ត្រីទីឡាព្យា

***Tilapia mozambicus*** [sci.n] ត្រីទីឡាព្យាឆ្នូត, ត្រីទីឡាព្យាម៉ូសាំប៊ិក

***Tilapia nilotica*** [sci.n] ត្រីទីឡាព្យាខ្មៅ, ត្រីទីឡាព្យានីឡូទីកា

**tile** /tʌɪl/ [n] ក្បឿង ឬឥដ្ឋស្តើងៗ

**till** /tɪl/ [v] កាប់គាស់ភ្ជួររាស់ដី, ភ្ជួរស្រែ

**till** /tɪl/ [n] ការភ្ជួរបំបែក (ការភ្ជួរ ឬរៀបចំដីសម្រាប់ដាំដុះ និងធ្វើកសិកម្ម)

**tillage** /ˈtɪlɪdʒ/ [n]

១. (សទិសន័យ៖ mellowing) ការធ្វើឱ្យដីផុស, ការធ្វើដីឱ្យល្អ

២. ការភ្ជួររាស់ដី (ការកែប្រែដោយកម្លាំងមេកានិចដើម្បីឱ្យលក្ខណៈរូបនៃដីផ្តល់នូវលក្ខខណ្ឌសមស្របធ្វើឱ្យដំណាំដុះលូតលាស់ងាយស្រួល)

- contour tillage /ˈkɒntʊə ˈtɪlɪdʒ/ [n] សូមមើលពាក្យ៖ contour strip cropping
- primary tillage /ˈprʌɪm(ə)ri ˈtɪlɪdʒ/ [n] ការរៀបចំដីដំបូង (ការភ្ជួរដីភ្លាមៗ បន្ទាប់ពីការច្រូតកាត់ប្រមូលផលរួច ឬចាប់ផ្តើមដាំ (ជារួមសំដៅលើការភ្ជួរ))
- secondary tillage /ˈsɛk(ə)nd(ə)ri ˈtɪlɪdʒ/ [n] ការធ្វើដីលើកទីពីរ (ការធ្វើដីបន្ទាប់ពីបានភ្ជួរលើកទីមួយរួចកន្លងមកក្នុងបំណងបំបែកដីធំៗឱ្យល្អិតដោយបង្កប់បញ្ចូលកម្ទេចរុក្ខជាតិជាមួយដី និងពង្រាបដី។ ជាទូទៅ គេហៅថាការរាស់ ឬជ្រោយដី)
- wetland tillage /ˈwɛtlənd ˈtɪlɪdʒ/ [n] ការភ្ជួររាស់លើដីសើម
- zero tillage /ˈzɪərəʊ ˈtɪlɪdʒ/ [n] ការមិនភ្ជួររាស់ (ការអនុវត្ត ឬដាំដុះមួយដែលនៅទីនោះ ការដាំដុះត្រូវបានធ្វើឡើងដោយផ្ទាល់ដោយមិនចាំបាច់រៀបចំដី (ភ្ជួររាស់))

**tilled** /tɪld/ [adj] ដែលដាំ

**tiller** /ˈtɪlə/ [n]

១. ដើមពន្លក, ដើមបែក (ដើមដែលដុះចេញពីថ្នាំងខាងក្រោមនៃដើមមេ)

២. អ្នកកាប់គាស់ភ្ជួររាស់ដី

- power tiller /ˈpaʊə ˈtɪlə/ [n] (សទិសន័យ៖ iron baffalo) គោយន្ត
- rotary tiller /ˈrəʊt(ə)ri ˈtɪlə/ [n] នង្គ័លថាស
- secondary tiller /ˈsɛk(ə)nd(ə)ri ˈtɪlə/ [n] ដើមបែកទីពីរ (ដើមបែកទីពីរនៃដើមស្រូវ ឬខ្នែងទីពីរដែលដុះចេញពីខ្នែងទីមួយ)
- tertiary tiller /ˈtəːʃ(ə)ri ˈtɪlə/ [n] ដើមបែកទីបី (ដើមបែកដែលដុះចេញពីដើមបែកទី ២ នៃស្រូវ)

**tilth** /tɪlθ/ [n]

១. សូមមើលពាក្យ៖ natural tilth

២. ដីបានភ្ជួរបំបែក

- good tilth /gʊd tɪlθ/ [n] (សទិសន័យ៖ friable state) សភាពដី (ទាំងខាងរូបវន្ត ខាងគីមី ខាងជីវសាស្ត្រ) ដែលសមស្របក្នុងការផ្តល់ផលសភាពគ្រាប់ៗនៃទម្រង់ និងដីជាតិដី
- natural tilth /ˈnatʃ(ə)r(ə)l tɪlθ/ [n] (សទិសន័យ៖ tilth) ទម្រង់ល្អ

**timber** /ˈtɪmbə/ [n] ឈើមូល, ឈើហ៊ុប

- standing timber /ˈstandɪŋ ˈtɪmbə/ [n] ឈើហ៊ុប

time /tʌɪm / [n] ពេលវេលា

- bleeding time /ˈbliːdɪŋ tʌɪm/ [n] ការពិសោធឈាម (ដើម្បីឱ្យដឹង ថាតើឈាមអាចនឹងកកក្នុងរយៈប៉ុន្មាននាទី)
- turnaround time /ˈtəːnəraʊnd tʌɪm/ [n] ពេលវេលាក្នុងចន្លោះការច្រូតកាត់រួច និងការដាំដុះដំណាំថ្មីជាបន្តបន្ទាប់
- time bound /tʌɪm baʊnd/ [n] ពេលវេលាកំណត់មួយ

**Tin** /tɪn/ [n] សំណប៉ាហាំង (និមិត្តសញ្ញាគីមី Sn)

**tincture** /ˈtɪŋ(k)tʃə/ [n] ថ្នាំទឹកលាបរបួស, ល្បាយអាល់កុលនឹងថ្នាំ

**tinea** /ˈtɪnɪə/ [n] ជំងឺភ្លឺ

**tinnitus** /ˈtɪnɪtəs/ [n] ហ៊ឹងត្រចៀក

***Tinospora crispa*** [sci.n] បណ្តូលពេជ

**tissue** /ˈtɪsjuː/ [n] ជាលិកា

- adipose tissue /ˈadɪpəʊs ˈtɪʃuː/ [n] ជាលិកាខ្លាញ់

- areolar tissue /əˈriːələ ˈtɪʃuː/ [n] ជាលិកាអារេអូឡា (ជាជាលិកាសន្ទានដែលស្ថិតនៅជាប់ពីក្រោមស្បែក និងនៅចន្លោះជាលិកា ឬសរីរាង្គជាប់គ្នា។ វាបង្កឡើងដោយសារធាតុអន្ទិលៗ ដែលរួមមានកោសិកាផ្សេងៗ ដូចជាកោសិកាម៉ាស កោសិកាស្តុកខ្លាញ់ម៉ាក្រូផាស និងភីប្រូ-ប្លាសធំៗ ដែលសំយោគកូឡាសែន សរសៃស និងសរសៃយឺតពណ៌ស្វាយ)
- connective tissue /kəˈnɛktɪv ˈtɪʃuː/ [n] ជាលិកាសន្ទាន, ជាលិកាភ្ជាប់
- epithelial tissue /ˌɛpɪˈθiːlɪ(ə)l ˈtɪʃuː/ [n] ជាលិកាអេពីតេល្យូម (ក្រុមកោសិកាឯកទេសដែលគ្របដណ្តប់ផ្ទៃខាងក្នុង និងខាងក្រៅនៃសារពាង្គកាយ)
- mesophyll tissue /ˈmɛsə(ʊ)fɪl ˈtɪʃuː/ [n] ជាលិកាស្លឹកដែលនៅចន្លោះកណ្តាលនៃអេពីឌែមស្លឹកផ្នែកខាងលើ និងអេពីឌែមផ្នែកខាងក្រោមនៃស្លឹក
- transfusion tissue /transˈfjuːʒ(ə)n tissue/ [n] ជាលិកាដឹកនាំ (ជាលិកាស្ថិតនៅសងខាងបាច់សរសៃនាំ របស់ស្លឹកស៊ីមណូស្ពែម។ វាបង្កឡើងពីកោសិកាប៉ារ៉ង់ស៊ីមទទេដែលមានទម្រង់ផត និងមានភ្នាសគ្រោងក្រាស់)

**Titanium** /tʌɪˈteɪnɪəm/ [n] ទីតាន (និមិត្តសញ្ញាគីមី Ti)

**titre** /ˈtiːtə/ [n] អត្រា, ប័ណ្ណ

**toad** /təʊd/ [n] សត្វគីង្គក់

**toadstool** /ˈtəʊdstuːl/ [n] ផ្សិតពុល

**tobacco** /təˈbakəʊ/ [n] ថ្នាំជក់ (ឈ្មោះវិទ្យាសាស្ត្រ *Nicotiana tabacum*)

**tobacco shop** /təˈbakəʊ ʃɒp/ [n] ហាងលក់បារី ឬថ្នាំជក់

**toe** /təʊ/ [n] ម្រាមជើង

**toenail** /ˈtəʊneɪl/ [n] ក្រចកជើង

**tolerance** /ˈtɒl(ə)r(ə)ns/ [n] ភាពអត់ទ្រាំ, ភាពធន់, ការអនុគ្រោះ (វិសាលភាពនៃបរិស្ថានមួយ ដែលសារពាង្គកាយមានជីវិតអាចរស់នៅក្នុងនោះបាន ឧ. ការធន់នឹងសីតុណ្ហភាពការធន់នឹងសំណើម។ នៅក្នុងការពិសោធន៍គ្រាប់ពូជ ការអនុញ្ញាតឱ្យភាពលំអៀង (បូក ឬដក) មានក្នុងបទដ្ឋានគំរូ។)

- drought tolerance /draʊt ˈtɒl(ə)r(ə)ns/ [n] ភាពធន់នឹងភាពរាំងស្ងួត, ភាពអត់ទ្រាំនឹងការរាំងស្ងួត (លទ្ធភាពដែលរុក្ខជាតិអាចទ្រាំនឹងការរាំងស្ងួតបាន)
- heat tolerance /hiːt ˈtɒl(ə)r(ə)ns/ [n] ភាពអត់ទ្រាំនឹងកម្តៅ (លទ្ធភាពទ្រាំទ្រនឹងកម្តៅខ្លាំង ដែលមិនធម្មតាសម្រាប់ការលូតលាស់របស់ជីវករ)
- shade tolerance /ʃeɪd ˈtɒl(ə)r(ə)ns/ [n] ភាពធន់នឹងម្លប់

**tolerant** /ˈtɒl(ə)r(ə)nt/ [adj] ដែលធន់ទ្រាំនឹង

- heat tolerant /hiːt ˈtɒl(ə)r(ə)nt/ [adj] ដែលធន់នឹងកម្តៅ
- salt tolerant /sɔːlt ˈtɒl(ə)r(ə)ns/ [adj] ដែលធន់នឹងជាតិប្រៃ ឬអំបិល (ឧ. ប្រភេទដើមកោងកាង)
- shade tolerant /ʃeɪd ˈtɒl(ə)r(ə)nt/ [adj] ធន់នឹងម្លប់ (ជាសមត្ថភាពរុក្ខជាតិក្នុងដុះលូតលាស់នៅក្រោមម្លប់)

**tolerate** /ˈtɒləreɪt/ [v] ធន់, អត់ធន់ (បាន), មិនប្រឆាំងនឹង (ឧ. ថ្នាំ)

**toli shad** [n] ត្រីប៉ាលូង (ឈ្មោះវិទ្យាសាស្ត្រ *Tenualosa toli*)

**tomato** /təˈmɑːtəʊ/ [n] ប៉េងប៉ោះ (ឈ្មោះវិទ្យាសាស្ត្រ *Solanum lycopersicum*)

- cherry tomato /ˈtʃɛri təˈmɑːtəʊ/ [n] ប៉េងប៉ោះផ្លែតូចៗ (ឈ្មោះវិទ្យាសាស្ត្រ *Lycopersicon esculentum*)

**tomato yellow leaf curl virus** /təˈmɑːtəʊ ˈjɛləʊ liːf kəːl ˈvʌɪrəs/ [n] ជំងឺលឿងស្លឹកដោយវីរុស (ជំងឺកើតភាគច្រើននៅលើដំណាំប៉េងប៉ោះ)

**tomentose** /təˈmɛntəʊs/ [adj] មានរោមច្រើន, ដែលដុះរោមច្រើន (ប្រភេទរោមលើស្លឹក)

***Tomosvaryella oryzaetora*** [sci.n] ពួករុយក្បាលធំ (បរាសិតលើពួកមមាចបំផ្លាញស្លឹក)

***Tomosvaryella subvirescens*** [sci.n] ពួករុយក្បាលធំ (បរាសិតលើពួកមមាចបំផ្លាញស្លឹក)

**tone** /təʊn/ [n] កម្លាំង (សាច់ដុំ)

**tongue** /tʌŋ/ [n] អណ្តាត

**tonic** /ˈtɒnɪk/ [n] ថ្នាំលើកកម្លាំង

**tonsil** /ˈtɒnsɪl/ [n] ដុំសាច់មួយគូនៅក្រោយបំពង់ក ផ្នែកខាងលើ, ដុំក្រពេញអ្វីផ្សេងទៀតដែលស្រដៀង, អាមីដាល

**tonsillectomy** /ˌtɒnsɪˈlɛktəmi/ [n] ការវះកាត់ដុំសាច់ក្នុងបំពង់ក

**tonsillitis** /tɒnsɪˈlʌɪtɪs/ [n] ជំងឺរលាកដុំសាច់ក្នុងបំពង់ក

**tool** /tuːl/ [n] វិធីសាស្ត្រ, មធ្យោបាយ, ឧបករណ៍
- hand tools /hand tuːls/ [n pl] ហត្ថឧបករណ៍ (ឧបករណ៍ប្រើដោយដៃ)
- surveying tool /səˈveɪ ɪŋ tuːl/ [n] វិធីសាស្ត្រអង្កេត
- wooden tools /ˈwʊd(ə)n tuːlz/ [n pl] សម្ភារៈដែលមានជាតិឈើ ឬផលិតមកពីឈើ (ឧ. សម្ភារកសិកម្ម ដែលធ្វើពីឈើដូចជា នង្គ័ល ដងរណា ចបជាដើម)

**tooling action** /ˈtuːlɪŋ ˈakʃ(ə)n/ [n] សូមមើលពាក្យ៖ corrosion

**tooth** /tuːθ/ [n] (ពហុវចនៈ៖ teeth) ធ្មេញ
- canine tooth /ˈkeɪnʌɪn tuːθ/ [n] ចង្កូម
- egg tooth /ɛg tuːθ/ [n] ធ្មេញស៊ុត
- primary teeth /ˈprʌɪm(ə)ri tiːθ/ [n pl] ធ្មេញទឹកដោះ

**top** /tɒp/ [n] ផ្នែកខាងលើ, កំពូល, ចុង (ឈើ), ស្រទាប់លើ (ដី)
- capillary layer top /kəˈpɪləri ˈleɪə tɒp/ [n] កម្រិតខាងលើដែលទឹកកាពីលែរ អាចឡើងដល់ (ទឹកក្នុងដី)

**topdressing** /tɒpˈdrɛsɪŋ/ [n] ការបាចដីបំប៉ន (ការបាចដីបន្ទាប់ពីការដាំ ឬស្ទូង ឬបន្ទាប់ពីដំណាំដែលដុះលូតលាស់ហើយ)

**top-heavy** /tɒp ˈhɛvi/ [adj] ដែលធ្ងន់ខាងលើពេក

**topical** /ˈtɒpɪk(ə)l/ [adj] ថ្នាំរីត

**topocline** /təʊpəʊclʌɪn/ [n] បម្រែបម្រួលតាមតំបន់ភូមិសាស្ត្រ

**topography** /təˈpɒgrəfi/ [n] ឋានលេខវិទ្យា, ឋានលេខសាស្ត្រ (លក្ខណៈស្ថានភាពផ្ទៃដីនៃតំបន់កំណត់ណាមួយ)

**topophysis** [n] (សទិសន័យ៖ plagiotrophy) បាតុភូតដុះតាមទម្លាប់ (បាតុភូតលូតលាស់របស់ចុងបំបៅ ពន្លកត្រួយ និងកំណាត់មែក ដែលនៅរក្សាទម្លាប់លូតលាស់តាមទិសរបស់វា។ ដូចជាមែកផ្សាំកាត់ពីមែកត្រង់ពេលយកទៅដាំ វាលូតត្រង់កាលណាកាត់ពីមែកចំហៀង ពេលដាំវាដុះទៅចំហៀង។)

**troposphere** /ˈtrɒpə(ʊ)sfɪə/ [n] ត្រូប៉ូស្វែរ ឬ មណ្ឌលអាកាសរចល់ (ផ្នែកនៅទាបជាងគេនៃបរិយាកាសគិតចាប់ពីផ្ទៃដីរហូតចម្ងាយប្រមាណ ១០គ.ម គិតជារយៈកម្ពស់នៅក្នុងតំបន់ដែលមានរយៈទទឹងមធ្យម (ប្រែប្រួលពី ៩គ.មនៅកន្លែងមានរយៈទទឹងខ្ពស់ ដល់១៦គ.ម ជាមធ្យម នៅតំបន់ត្រូពិច) ដែលកើតមានបាតុភូតពពក និងអាកាសធាតុ។ នៅក្នុងតំបន់នេះ ជាទូទៅសីតុណ្ហភាពថយចុះ កាលណាគេឡើងកាន់តែខ្ពស់។)

***Tor sinensis*** [sci.n] ត្រីក្ងោរ

***Tor tambroides*** [sci.n] សូមមើលពាក្យ៖ Thai mahseer

**torch** /tɔːtʃ/ [n] ចន្លុះ, ពិល

**torpor** /ˈtɔːpə/ [n] អសកម្មភាព (ស្ថានភាពអសកម្មភាពដែលសត្វថេរកម្តៅខ្លះប្រើប្រាស់ដើម្បីរក្សាថាមពល)

**torrent** /ˈtɒr(ə)nt/ [n] ជ្រោះ

**torsion** /ˈtɔːʃ(ə)n/ [n] ការរមួល

**torticollis** /ˌtɔːtɪˈkɒlɪs/ [n] (សទិសន័យ៖ wryneck) ថ្លោះសរសៃក

**tortoise** /ˈtɔːtɔɪz/ [n] អណ្តើក

**totipotency** /tə'tɪpəʊ t(ə)nt si/ [n] សក្តានុពលកោសិកាអាចដុះជាដើមឈើ (សមត្ថភាពនៃប្រភេទណាមួយនៃកោសិកា រុក្ខជាតិដែលអាចបំបែក បង្កើតជាដើមរុក្ខជាតិមួយបាន។ ដើម្បីដឹងពីសក្តានុពលនេះ គេកាត់កោសិកាមួយដុំចេញពីរុក្ខជាតិនេះហើយដាក់វាក្នុងសារធាតុចិញ្ចឹមដែលវាត្រូវការ តើវាអាចដុះ ឬទេ។)

**touch** /tʌtʃ/ [v] ស្ទាប
- organ of touch /ˈɔːg(ə)n ɒv tʌtʃ/ [n] សរីរាង្គកាយវិញ្ញាណ

toundra polygon /ˈtʌndrəˈpɒlɪg(ə)n/ [n] ពហុកោណវាលស្មៅទុងដ្រា

**tourniquet** /ˈtɔːnɪkeɪ/ [n] ឃ្នាបសរសៃឈាមកុំឱ្យហូរចេញ ឬក៏ដើម្បីងាយបញ្ចូលម្ជុល, ក្រណាត់សម្រាប់ចងឃាត់ឈាម

**toxemia** /tɒkˈsiːmɪə/ [n] គ្រោះថ្នាក់បណ្តាលពីជាតិពុលក្នុងឈាម (លក្ខណៈមិនធម្មតា ជាប់ទាក់ទងនឹងការមានសារធាតុពុលនៅក្នុងឈាម

**toxic** /ˈtɒksɪk/ [adj] មានជាតិពុល

**toxicity** /tɒkˈsɪsɪti/ [n] ពំនុល, ភាពពុល
- acute toxicity /əˈkjuːt tɒkˈsɪsɪti/ [n] ពំនុលខ្លាំង
- alkaline toxicity /ˈalkəlʌɪn sɔɪl tɒkˈsɪsɪti/ [n] ជាតិពុលអាល់កាឡាំង

- aluminium toxicity /ˌæl j ʊˈmɪniəm/ [n] ការពុលអាលុយមីញ៉ូម
- boron toxicity /ˈbɔːrɒn tɒkˈsɪsɪti/ [n] ការពុលដោយសារជាតុប៉័រ
- chronic toxicity /ˈkrɒnɪk tɒkˈsɪsɪti/ [n] ពំនុលរ៉ាំរ៉ៃ
- dermal toxicity /ˈdəːm(ə)l tɒkˈsɪsɪti/ [n] ពុលតាមស្បែក (ភាពពុលបណ្តាលមកពីការជ្រាបចូលរបស់ថ្នាំពុលទៅតាមស្បែក)
- ingestion toxicity /ɪnˈdʒɛstʃ(ə)n tɒkˈsɪsɪti/ [n] ពំនុលដោយលេបចូល
- inhalation toxicity /ɪnhəˈleɪʃ(ə)n ˈtɒksɪkˈsɪti/ [n] ពំនុលដោយដំណកដង្ហើម (ដំណើរការពុលទៅតាមការដកដង្ហើមចូល)
- iron toxicity /ˈʌɪən tɒkˈsɪsɪti/ [n] ការពុលជាតិដែក (បាតុភូតនេះកើតឡើងកាលណាកំហាប់នៃសូលុយស្យុងដែកខ្ពស់នៅក្នុងដី ឬក្នុងទឹកពេលដីស្ថិតក្នុងស្ថានភាពលិចទឹក។ ប្រភេទអាស៊ីតខ្លាំងដែលច្រើនជួបប្រទះក្នុងដីមានដូចជា អាស៊ីតស៊ុលហ្វាត ដែលមានរោគសញ្ញារបស់វា គឺមានស្នាមអុតត្នោតលើស្លឹកចាស់ពីចុងស្លឹករាលដាលដល់តួស្លឹករហូតដល់ងាប់ផ្នែកខាងក្រោម។)
- manganese toxicity /ˈmaŋgəniːz tɒkˈsɪsɪti/ [n] ការពុលម៉ង់កាណែស
- oral toxicity /ˈɔːr(ə)l tɒkˈsɪsɪti/ [n] ការពុលតាមមាត់ (ដំណើរការពុលតាមរយៈការលេបចូលតាមមាត់)

toxicology /ˌtɒksɪˈkɒlədʒi/ [n] វិសសាស្ត្រ, ពំនុលវិទ្យា, ជាតិពុលវិទ្យា

**toxin** /ˈtɒksɪn/ [n] ជីវជាតុពុល

**toxoid** /ˈtɒksɔɪd/ [n] អស់ជាតិពុល ឧ. tetanus toxoid អស់ជាតិតេតាណូស

***Toxotes chatareus*** [sci.n] សូមមើលពាក្យ៖ largescale archerfish

***Toxotes microlepis*** [sci.n] សូមមើលពាក្យ៖ smallscale archerfish

**trace** /treɪs/ [n] ដាន, ស្លាកស្នាម, ចំនួនដ៏តិចបំផុត

**trachea** /ˈtreɪkɪə/ [n] (ពហុវចនៈ៖ tracheae) (សទិសន័យ៖ windpipe) បំពង់ខ្យល់

**tracheitis** /ˌtreɪkɪˈʌɪtɪs/ [n] ជំងឺរលាកបំពង់ខ្យល់

**tracheophyte** /trakːkɪˈɒfʌɪt/ [n] ត្រាកេអូភីត (រុក្ខជាតិដែលមានជាលិកាសរសៃនាំ)

**tracheostomy** /ˌtrakɪˈɒtəmi/ [n] ការវះកាត់បើកប្រហោងក្នុងបំពង់ខ្យល់(ដើម្បីជួយស្រូបខ្យល់ ឱ្យចូលទៅក្នុងសួតបានគ្រប់គ្រាន់)

**tract** /trakt/ [n] ប្រព័ន្ធនៃអវយវៈឬសរីរាង្គ ដែលធ្វើការរួមគ្នា

- alimentary tract /alɪˈmɛnt(ə)ri trakt/ [n] គ្រឿងរំលាយអាហារ
- forest track /ˈfɒrɪst trak/ [n] (សទិសន័យ៖ wood haulage way) ផ្លូវក្នុងព្រៃ
- gastrointestinal tract /ˌgastrəʊɪnˈtɛstɪn(ə)l trakt/ [n] (សទិសន័យ៖ gastrovascular canal)បំពង់រំលាយអាហារ

**traction** /ˈtrakʃ(ə)n/ [n]

១. ទំនាញភាព

២. បរិធានសម្រាប់ទាញឆ្អឹងឱ្យត្រង់

animal traction /ˈanɪm(ə)l ˈtrakʃ(ə)n/ [n] ការប្រើសត្វចិញ្ចឹមជាកម្លាំងអូសទាញ

**tractor** /ˈtraktə/ [n] ត្រាក់ទ័រ

- walking tractor /wɔːkɪŋ ˈtraktə/ [n] គោយន្ត

**trail** /treɪl/ [n] ផ្លូវលំជនបទ

**trailer** /ˈtreɪlə/ [n] រថសណ្តោង, រ៉ឺម៉កសណ្តោង

**trainee** /treɪˈniː/ [n] សិក្ខាកាម

**training** /ˈtreɪnɪŋ/ [n] ការបណ្តុះបណ្តាល

- degree training /dɪˈgriː ˈtreɪnɪŋ/ [n] វគ្គបណ្តុះបណ្តាលមានសញ្ញាបត្រ (ការសិក្សាដែលទទួលបានសញ្ញាបត្រអនុបរិញ្ញា ឬមហាបរិញ្ញាបត្រ ឬបណ្ឌិតនៅក្រោយពេលបញ្ចប់វគ្គសិក្សារបស់ខ្លួន)
- training programme schedule /ˈtreɪnɪŋ ˈprəʊgram ˈʃɛdjuːl/ [n] កាលវិភាគកម្មវិធីវគ្គបណ្តុះបណ្តាល
- training brochure /ˈtreɪnɪŋ ˈbrəʊʃə/ [n] កូនសៀវភៅសម្រាប់វគ្គបណ្តុះបណ្តាល
- training course /ˈtreɪnɪŋ kɔːs/ [n] វគ្គបណ្តុះបណ្តាល
- training division /ˈtreɪnɪŋ dɪˈvɪʒ(ə)n/ [n] ផ្នែកបណ្តុះបណ្តាល
- training manual /ˈtreɪnɪŋ ˈmanjʊ(ə)l/ [n] សៀវភៅគម្រូសម្រាប់វគ្គបណ្តុះបណ្តាល
- training room /ˈtreɪnɪŋ ruːm/ [n] បន្ទប់វគ្គបណ្តុះបណ្តាល

- training supplies /ˈtreɪnɪŋ səˈplʌɪs/ [n] សម្ភារសម្រាប់ប្រើប្រាស់ក្នុងវគ្គបណ្តុះបណ្តាល

**trait** /treɪt/ [n] លក្ខណៈ (ផេណូទីប), លក្ខណៈជម្រើស (កេតនភណ្ឌនៃសរីរាង្គដែលបានមកពីអន្តរអំពើរវាងពន្ធុ និងបរិស្ថាន)

**tranquilizer** /ˈtraŋkwɪlʌɪzə/ [n] ថ្នាំរំងាប់ចិត្ត

**market transaction** /ˈmɑːkɪt tranˈzakʃ(ə)n/ [n] ការទាក់ទងលក់ទិញ

**transcription** /tranˈskrɪpʃ(ə)n/ [n] ការចម្លង (ដំណើរការដែល RNA នាំសារមួយ ត្រូវបានបង្កើតជាកញ្ចាក់ឆ្លុះមួយនៃ DNA របស់មេបា នេះ នៅកំឡុងពេលសំយោគប្រូតេអ៊ីន ហើយនិងការតំរៀបតាមក្រមសេនេទិច)

**transfer** /transˈfəː/ [n] ការផ្ទេរ

**transformation** /transfəˈmeɪʃ(ə)n/ [n] បំប្លែង, ការប្រែក្លាយ

- transformation into brown earth /transfəˈmeɪʃ(ə)n ˈɪntʊ braʊn əːθ/ ការប្រែក្លាយទៅជាដីសម្បុរត្នោត
- transformation into marshland /transfəˈmeɪʃ(ə)n ˈɪntʊ ˈmɑːʃlənd/ ការប្រែក្លាយទៅជាទីទំនាបបឹង

**transfuse** /transˈfjuːz/ [v] បញ្ជូនឈាម

**transfusion** /transˈfjʊːʒ(ə)n/ [n] ការបញ្ជូនឈាម, ការបញ្ចូលវត្ថុធាតុរាវ

**transgression** /trɑːnsˈgrɛʃn/ [n] រង្វាតសមុទ្រ

**translation** /transˈleɪʃ(ə)n/ [n] ការបកប្រែ

**translucent** /transˈluːs(ə)nt/ [n] ភាពឆ្លុះ

**transmission** /tranzˈmɪʃ(ə)n/ [n] ការបញ្ជូន, ការចម្លង

- virus transmission /ˈvʌɪrəs tranzˈmɪʃ(ə)n/ [n] ការចម្លងវីរុស (ការចម្លងវីរុសទៅរុក្ខជាតិដោយសត្វល្អិតដែលផ្ទុកជំងឺ)

**transmit** /tranzˈmɪt/ [v] បញ្ជូន, ចម្លង

**transparent** /tranˈspar(ə)nt/ [adj] ថ្លាឆ្លុះ

**transpiration** /transpɪˈreɪʃ(ə)n/ [n] រុក្ខបំភាយ, ដំណើរការបាត់បង់ទឹកដោយដំណាកដង្ហើមរុក្ខជាតិ, រំភាយចំហាយទឹក (ការបាត់បង់ទឹកពីស្លឹករុក្ខជាតិតាមស្តូម៉ាត និងឡង់ទីសេលដោយរំហួត)

**transplant** /transˈplɑːnt/ [v] ស្ទូង

- disease-free transplant /dɪˈziːz friː transˈplɑːnt/ [n] ដាំកូនដំណាំគ្មានជំងឺ
- rice transplanter /rʌɪs transˈplɑːntə/ [n] ម៉ាស៊ីនស្ទូង (ម៉ាស៊ីនស្ទូងស្រូវប្រើសំណាបដាប៉ុក ឬសំណាបថ្នាលឡាំងឈើ)

**transplanting** /transˈplɑːntɪŋ/ [n] ការស្ទូង

**transport** /tranˈspɔːt/ [n, v] ដឹកជញ្ជូន

- active transport /ˈaktɪv tranˈspɔːt/ [n] ដំណឹកនាំសកម្ម (ចលនាសារធាតុរលាយឆ្លងកាត់ភ្នាសកោសិកាពីកន្លែងដែលមានកំហាប់ទាបជាងទៅខ្ពស់ ដោយត្រូវការថាមពលកោសិកា)
- nutrient transport /ˈnjuːtrɪənt tranˈspɔːt/ [n] ការដឹកជញ្ជូនសារធាតុចិញ្ចឹម
- passive transport /ˈpasɪv tranˈspɔːt/ [n] ការដឹកនាំអកម្ម (ចលនារបស់ម៉ូលេគុលឆ្លងកាត់ភ្នាសដោយគ្មានប្រើថាមពលកោសិកា)
- polar transport /ˈpəʊlə tranˈspɔːt/ [n] ការដឹកជញ្ជូនប៉ូល ចលនាផ្ទាល់នៃសារធាតុនៅក្នុងរុក្ខជាតិ (ជាទូទៅ គឺជានិយ័តករលូតលាស់ក្នុង រុក្ខជាតិ) ភាគច្រើននៅក្នុងទិសដៅតែមួយ ដែលការដឹកជញ្ជូនប៉ូលទទួលបានជោគជ័យសម្រាប់ចែកចាយទៅគ្រប់ទិសដៅទាំងអស់

**transverse** /tranzˈvəːs/ [adj] នៃបន្ទាត់ពុះ

**trauma** /ˈtrɔːmə/ [n] ការរងរបួស, គ្រាំ, របួស, ការខូចជាលិកាដែលរស់

- acoustic trauma /əˈkuːstɪk ˈtrɔːmə/ [n] ការរងរបួសដោយសំឡេង

**travertine** /ˈtravətɪn/ [n] (សទិសន័យ៖ fresh-water limestone) ថ្មកំបោរដែលកើតនៅក្នុងទឹកសាប

**treat** /triːt/ [v] ធ្វើប្រព្រឹត្តិកម្ម, ព្យាបាល

**treatment** /ˈtriːtm(ə)nt/ [n]

១. សូមមើលពាក្យ៖ prescription
២. ប្រព្រឹត្តិកម្ម
៣. ការថែទាំ, ការដាំពិសោធពូជ
៤. បច្ច័យ (អ្វីៗដែលបានយកមកធ្វើការពិសោធតាមដានលក្ខណៈស្ថានភាពផ្ទៃដីនៃតំបន់កំណត់ណាមួយលើលក្ខណៈ ឬឥទ្ធិពលរបស់វា (ឧ. ពូជ កម្រិត ឬប្រភេទដីកម្រិត ឬប្រភេទថ្នាំពុល))
៥. ការព្យាបាល, វិធីព្យាបាល

- activated sludge treatment /ˈaktɪveɪtɪd ˈslʌdʒ ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មដោយភក់សកម្ម
- aerobic treatment /ɛːˈrəʊbɪk ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មដោយអាកាសកម្ម
- anaerobic treatment /ˌanɛːˈrəʊbɪk ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មដោយគ្មានខ្យល់
- biological treatment /bʌɪə(ʊ)ˈlɒdʒɪk(ə)l ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មជីវៈ
- carbon treatment /ˈkɑːb(ə)n ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មដោយធ្យូងសកម្ម
- chemical treatment /ˈkɛmɪk(ə)l ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មដោយគីមី
- effluent treatment /ˈɛflʊənt ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មដោយសំណល់រាវ
- physical treatment /ˈfɪzɪk(ə)l ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មរូប
- pre-treatment /ˈpriː ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្ម (ប្រភេទណាមួយនៃប្រព្រឹត្តកម្ម ដែលបានធ្វើទៅលើគ្រាប់ ដើម្បីបំបែកភាពសំងំ និងជំរុញឱ្យដំណុះលឿន។ ឧ. ការដាក់សំដិលនៅកន្លែងត្រជាក់ ការធ្វើឱ្យមានស្នាមប្រេះ ការធ្វើឱ្យចុះត្រជាក់។)
- primary treatment /ˈprʌɪm(ə)ri ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មដំណាក់កាលដំបូង
- secondary treatment /ˈsɛk(ə)nd(ə)ri ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មដំណាក់កាលទីពីរ
- seed treatment /siːd ˈtriːtm(ə)nt/ [n] ការដាក់ថ្នាំពុលលាយក្នុងគ្រាប់
- sewage treatment /ˈsuːɪdʒ ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មទឹកលូសម្អុយ
- shot-gun treatment /ʃɒt gʌn ˈtriːtm(ə)nt/ [n] ព្យាបាលថ្នាំចម្រុះ
- solid waste treatment /ˈsɒlɪd weɪst ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មសំណល់រឹង
- tertiary treatment /ˈtəːʃ(ə)ri ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មដំណាក់កាលទីបី
- thermal treatment /ˈθəːm(ə)l ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មកម្តៅ
- waste treatment /weɪst ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មសំណល់
- wastewater treatment /weɪstˈwɔːtə ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មសំណល់រាវ
- water treatment /ˈwɔːtə ˈtriːtm(ə)nt/ [n] ប្រព្រឹត្តិកម្មទឹក

**treble** /ˈtrɛb(ə)l/ [v] កើនឡើងត្រីគុណ

**tree** /triː/ [n] ដើមឈើ

- air-layered tree /ɛːˈleɪəd triː/ [n] ដើមឈើដែលបានបំបៅ ឬផ្សាំ
- banyan tree /ˈbanjən triː/ [n] ឈើបានយ៉ាន, ពោធិ៍ (ឈ្មោះវិទ្យាសាស្ត្រ *Ficus benghalensis*)
- candidate tree /ˈkandɪdeɪt triː/ [n] ដើមឈើបេក្ខភាព ( ជាដើមឈើដែលត្រូវបានជ្រើសរើសសម្រាប់ចាត់ថ្នាក់គុណភាព ពិនិត្យមើលតាមគុណភាពរូបខាងក្រៅ (phenotype) ប៉ុន្តែមិនទាន់បានវាយតម្លៃឬដាំសាកល្បងនៅឡើយ។)
- check tree /tʃɛk triː/ [n] សូមមើលពាក្យ៖ Comparinson tree
- comparison tree /kəmˈparɪs(ə)n triː/ [n] (ទសីសស ន័យ៖ check tree) ការប្រៀបធៀបដើមឈើ
- deciduous tree /dɪˈsɪdjʊəs triː/ [n] ដើមឈើដែលជម្រុះស្លឹកមួយឆ្នាំម្តង
- elite tree /eɪˈliːt triː/ [n] ដើមឈើសម្រាំង (ដើមឈើមួយដែលបានឆ្លងកាត់ការធ្វើពិសោធន៍សមស្រប ថាជាមានលក្ខណៈល្អបំផុត ឬសមតាមបំណងគេ ត្រូវការសម្រាប់ដាំក្នុងបរិស្ថានជាក់លាក់ណាមួយនិងសម្រាប់កម្មវិធីបង្កាត់ពូជ។ ឧត្តមភាពនៃមេបាកូនកាត់ត្រូវ បានកំណត់ដោយការសាកល្បងកូន ហើយបើជាដើមក្លូន ធ្វើការសាកល្បងក្លូន។)
- fig tree /fɪg triː/ [n] ដើមល្វា
- fodder tree /ˈfɒdə triː/ [n] ប្រភេទរុក្ខជាតិ ជាចំណីសត្វនៅក្នុងស្រុក
- fruit tree /fruːt triː/ [n] ដំណាំឈើហូបផ្លែ, ឈើហូបផ្លែ (ប្រភេទដើមឈើដែលគេដាំសម្រាប់យកផ្លែហូបដូចជាស្វាយ ក្រូចជាដើម)
- giant sensitive tree /ˈdʒʌɪənt ˈsɛnsɪtɪv triː/ [n] បន្លាយួន, ព្រះខ្លបយក្ស (ឈ្មោះវិទ្យាសាស្ត្រ *Mimosa pigra*)
- grafted tree /grɑːftɪd triː/ [n] ដើមឈើដែលផ្សាំ

- hummingbird tree /ˈhʌmɪŋbəːd triː/ [n] អង្គាដី (ឈ្មោះវិទ្យាសាស្ត្រ *Sesbania grandiflora*)
- marian plum tree /ˈmɛːrɪən plʌm triː/ [n] មាក់ប្រេង (ឈ្មោះវិទ្យាសាស្ត្រ *Bouea burmanica*)
- mulberry tree /ˈmʌlb(ə)ri triː/ [n] មន (ឈ្មោះវិទ្យាសាស្ត្រ *Morus alba*)
- multi-purpose tree /ˈmʌlti ˈpəːpəs triː/ [n] ឈើពហុបយោជន៍ (ឈើប្រើប្រាស់បានច្រើនមុខ ដូចជាធ្វើអុសដុតចំណីអាហារ ឬម្លប់ជាដើម)
- overmature tree /ˈəʊvəməˈtʃʊə triː/ [n] ដើមឈើចាស់ហួស
- plus tree /plʌs triː/ [n] ដើមមេ
- rain tree /reɪn triː/ [n] ដើមអម្ពិលបារាំង, ដើមចាមរី (ឈ្មោះវិទ្យាសាស្ត្រ៖ *Sanaanea saman*)
- seed tree /siːd triː/ [n] កូនឈើ
- select plus tree /sɪˈlɛkt plʌs triː/ [n] (សទិសន័យ៖ select superior tree) ជ្រើសរើសដើមឈើវិជ្ជមាន, ជ្រើសរើសគុណភាពល្អជាងគេ (ដើមឈើមួយដែលគេបានចាត់គុណភាព និងផ្តល់អនុសាសន៍ឱ្យប្រើប្រាស់ក្នុងការផលិត ឬធ្វើចម្ការបង្កាត់ពូជ។ វាមានផេណូទីបល្អជាងគេខាងការលូតលាស់ ទម្រង់ដើម គុណភាពឈើ ឬបណ្តាលក្ខណៈផ្សេងៗទៀតដែល គេចង់បាន និងមានលទ្ធភាពអាចផ្សាំបាន។ វាអាចមិនទាន់ត្រូវបានគេធ្វើការពិសោធន៍មើលអំពីតម្លៃសេនេទិចរបស់វា ប៉ុន្តែគេគិតថា វាអាចមានសេណូទិបមានលក្ខណៈសម្បត្តិខ្ពស់ និងមានលទ្ធភាពតំណពូជខ្ពស់)
- select superior tree /sɪˈlɛkt suːˈpɪərɪə triː/ [n] សូមមើលពាក្យ៖ select plus tree
- shady tree /ˈʃeɪdi triː/ [n] ដើមឈើផ្តល់ម្លប់
- sugar palm tree /ˈʃʊɡə pɑːm triː/ [n] ដើមត្នោត
- suppressed tree /səˈprɛst triː/ [n] ដើមឈើរងការសង្កត់
- twisted tree /ˈtwɪstɪd triː/ [n] ដើមរមួល

**tree stump** /triː stʌmp/ [n] គល់ (គល់ឈើដែលសល់ពីកាប់ដើម)

**trematoda** /ˌtrɛməˈtəʊdə/ [n] សូមមើលពាក្យ៖ flatworm

**tremble** /ˈtrɛmb(ə)l/ [v] សូមមើលពាក្យ៖ shake

**tremor** /ˈtrɛmə/ [n] ញាក់សាច់, ការញ័រ

**trench** /trɛn(t)ʃ/ [n] ប្រឡាយស្នាមភ្លោះ

- draining trench /dreɪnɪŋ trɛn(t)ʃ/ [n] បង្ហូរ, ប្រឡាយបញ្ចេញទឹក

**trenching** /trɛn(t)ʃin/ [n] សូមមើលពាក្យ៖ gullying

**trend** /trɛnd/ [n] និន្នាការ

- forest trend /ˈfɒrɪst trɛnd/ [n] និន្នាការព្រៃឈើ

**trephine** /trɪˈfʌɪn/ [n] រណារម៉្យាងសម្រាប់កាត់ឆ្អឹងមួយផ្នែកនៃ លលាដ៍ក្បាល ឱ្យមានជុំរាងមូល

**trespass** /ˈtrɛspəs/ [n] ការទន្ទ្រាន, ការបំពាន

**tri-** /trʌɪ/ [prefix] (សទិសន័យ៖ three) បុព្វបទមានន័យថាបី

**trial** /ˈtrʌɪəl/ [n] (សទិសន័យ៖ test) ការពិសោធ, ការដាំសាកល្បង

- advanced yield trial /adˈvɑːnstd jiːld ˈtrʌɪəl/ [n] ពិសោធជម្រើសទិន្នផល (ជាប្រភេទពិសោធដែលមានសារច្រើនលើសពីពីរ)
- observational yield trial (OYT) /ɒbzəˈveɪʃ(ə)n(ə)l jiːld ˈtrʌɪəl/ [n] ពិសោធតាមដានទិន្នផល (ថ្នាលពិសោធតាមដានដំបូងទៅលើការលូតលាស់ និងទិន្នផលនៃពូជថ្មីៗដែលទើបនឹងនាំចូល ឬពូជសម្ងហកម្មដែលបានប្រមូលពីបណ្តាខេត្តនានា។ នៅក្នុងពិសោធនេះគ្មានសាទេ។)
- on-farm adaptive trial (OFAT) /ɒn fɑːm əˈdaptɪv ˈtrʌɪəl/ [n] ពិសោធបន្សាំលើស្រែកសិករ (ពិសោធងាយសាមញ្ញដែលធ្វើក្នុងស្រែកសិករ ដោយកសិករផ្ទាល់ តែបានទទួលការណែនាំ និងជ្រោមជ្រែងពីអ្នកពិសោធ)
- on-farm trial /ɒn fɑːm ˈtrʌɪəl/ [n] ការពិសោធលើស្រែកសិករ (ការពិសោធលើស្រែកសិករ ដោយកសិករបានព្យាយាម ឬសាកល្បងនូវបច្ចេកវិជ្ជាថ្មី ដែលទើបតែបានបង្កើតឡើង)
- preliminary yield trial (PYT) /prɪˈlɪmɪn(ə)ri jiːld ˈtrʌɪəl/ [n] ពិសោធប្រៀបធៀបទិន្នផលបឋម (ប្រភេទពិសោធ ដែលមានចំនួនសាត្រឹមពីរ ហើយពូជដែលបានជម្រើសពីក្នុងពិសោធនេះ នឹងដាក់បញ្ចូលទៅក្នុងពិសោធជម្រើសទិន្នផល)
- progeny trial /ˈprɒdʒəni ˈtrʌɪəl/ [n] សូមមើលពាក្យ៖ progeny test
- provenance trial /ˈprɒv(ə)nəns ˈtrʌɪəl/ [n] សូមមើលពាក្យ៖ provenance test

- species elimination trial /ˈspiːʃiːz ɪlɪmɪˈneɪʃ(ə)n ˈtrʌɪəl/ [n] សូមមើលពាក្យ៖ species elimination test
- species trial /ˈspiːʃiːz ˈtrʌɪəl/ [n] សូមមើលពាក្យ៖ species test
- superimposed trial /ˌsuːp(ə)rɪmˈpəʊzd ˈtrʌɪəl/ [n] ការពិសោធពហុបច្ចេកវិជ្ជា (ប្រភេទពិសោធមានមួយសាលើការសាកល្បងបញ្ចូលបច្ចេកវិទ្យាច្រើនក្នុងគំរូដាំដុះណា១)

**triangular-tail horseshoe crab** /traɪˈaŋgjʊlə teɪl hɔsʃu krab/ [n] ប្រឡាំងកាស (ឈ្មោះវិទ្យាសាស្ត្រ *Tachypleus gigas*)

***Trianthema portulacastrum*** [sci.n] សូមមើលពាក្យ៖ giant pigweed, horse purslane

**Triassic** /trʌɪˈasɪk/ [n] ទ្រីយ៉ាល់

**tribe** /trʌɪb/ [n] កុលសម្ពន្ធ

**tributary** /ˈtrɪbjʊt(ə)ri/ [n] ដៃទន្លេ

**trich-** /trɪtʃ/ [prefix] (សទិសន័យ៖ hair) បុព្វបទមានន័យថា ដូចសក់

**trichinella (trichinosis)** /ˈtrɪkɪnələ/ [n] ទ្រីគីន (បរាសិត)

**trichinosis** /ˌtrɪkɪˈnəʊsɪs/ [n] រោគសាច់ដុះដែលបណ្ដាលមកពីដង្កូវក្នុងសាច់ជ្រូក

***Trichogaster microlepis*** [sci.n] សូមមើលពាក្យ៖ moonlight gourami

***Trichogaster pectoralis*** [sci.n] សូមមើលពាក្យ៖ snakeskin gourami

***Trichogaster trichopterus*** [sci.n] សូមមើលពាក្យ៖ threespot gourami

***Trichomalopsis apanteloctena*** [sci.n] ឱម៉ាល់ (បរា-សិតលើពង និងដុកដឿ)

***Trichomma cnaphalocrosis*** [sci.n] ពួកឱម៉ាល់ (បរា-សិតលើដង្កូវមូរស្លឹក)

**trichomonas (vaginalis)** /ˌtrɪkə(ʊ)məˈnʌs/ [n] ធ្លាក់ស

***Trichomonas foetus*** [sci.n] សូមមើលពាក្យ៖ trichomoniasis

**trichomoniasis** /ˌtrɪkə(ʊ)məˈnʌɪəsɪs/ [n] (សទិសន័យ៖ Trichomonas foetus) ទ្រីកូមូណាស (មេរោគបណ្ដាលឱ្យរាគ និងធ្លាក់ស)

***Trichopoda* spp.** [sci.n] រុយជើងធំ

***Trichopsis pumila*** [sci.n] សូមមើលពាក្យ៖ pygmy gourami

***Trichopsis vittata*** [sci.n] សូមមើលពាក្យ៖ croaking gourami

**Trichuris** /ˈwɪpwəːm/ [n] ទ្រីគួ (ដង្កូវពោះវៀន)

***Tridacna crocea*** [sci.n] សូមមើលពាក្យ៖ crocus giant clam

***Tridacna gigas*** [sci.n] សូមមើលពាក្យ៖ giant clam

***Tridacna squamosa*** [sci.n] សូមមើលពាក្យ៖ fluted giant clam

***Tridax procumbens*** [sci.n] សូមមើលពាក្យ៖ coat buttons

**triecious** /triːʃəs/ [adj] ផ្កាញី ផ្កាឈ្មោល ផ្កាទ្វេភេទលើដើមផ្សេងគ្នា

**trier** /ˈtrʌɪə/ [n] ឧបករណ៍សម្រាប់ចាក់យកប៉ាន់គ្រាប់ពូជ (ឧបករណ៍មួយដូចបំពង់សម្រាប់ចាក់យកគំរូប៉ាន់គ្រាប់ពីកញ្ចប់គ្រាប់ពូជ។ ឧបករណ៍នេះមានបំពង់២ បំពង់មួយស្រូកខាងក្នុងបំពង់មួយទៀត។ មានរន្ធជាច្រើននៅតាមបណ្ដោយបំពង់ទាំង២ ដើម្បីឱ្យគ្រាប់ធ្លាក់ចូលក្នុងបំពង់នៅពេលណារន្ធទាំង២នៅត្រូវគ្នា ហើយរន្ធនេះអាចបិទជិតវិញ នៅពេលគេមួលបំពង់ខាងក្នុងទៅឆ្វេង ឬស្ដាំ។)

**trifoliate** /trʌɪˈfəʊlɪət/ [n] រុក្ខជាតិដែលមានស្លឹកបែកជាបី

**trigonous** /ˈtrɪgənəs/ [adj] មានបីជ្រុង (មានមុំបី ឧ. ដើមរុក្ខជាតិ ឬអូរ៉េ)

**trimming** /ˈtrɪmɪŋ/ [n] ការកាត់

**trimonoecious** /trɪməʊnəʊˈeɪʃəs/ [adj] ផ្កាញី ផ្កាឈ្មោល, ផ្កាទ្វេភេទលើដើមតែមួយ

**triple** /ˈtrɪp(ə)l/ [adj] ត្រីគុណ

**triploid** /ˈtrɪplɔɪd/ [n] ទ្រីប្លូអ៊ីត (មានក្រូម៉ូសូម ៣n)

***Trissolcus basalis*** [sci.n] ឱម៉ាល់បរាសិតស៊ីពង

***Triticum sativum*** [sci.n] សូមមើលពាក្យ៖ wheat

**tritium** /ˈtrɪtɪəm/ [n] ទ្រីចូម (T)

**trocar** /ˈtrəʊkɑː/ [n] ត្រូកា (ម្ជុលបូម)

**troglodyte** /ˈtrɒglədʌɪt/ [n] ភាវរស់រស់នៅក្នុងរូងភ្នំ

**tropic ageratum** /ˈtrɒp ɪk ˌadʒ əˈreɪ təm [n] ទន្រានខេត្តស្វាយ (ឈ្មោះវិទ្យាសាស្ត្រ *Ageratum conyzoides*)

**tropical** /ˈtrɒpɪk(ə)l/ [adj] នៃតំបន់ត្រូពិច

**tropical chicken flea** /ˈtrɒpɪk(ə)l ˈtʃɪkɪn fliː/ [n] (សទិសន័យ៖ Siphonaptera) ចៃមាន់ (ឈ្មោះវិទ្យាសាស្ត្រ៖ *Echidnophaga gallinacea*)

**tropical Mexican clover** /ˈtrɒpɪk(ə)l ˈmɛk sɪ kən/ [n] ម្អមភ្នំឈ្មោល (ឈ្មោះវិទ្យាសាស្ត្រ *Richardia brasiliensis*)

**tropical spiderwort** /ˈtrɒpɪk(ə)l ˈspaɪ dərˌwɜrt/ [n] ស្មៅស្លាបទា (ឈ្មោះវិទ្យាសាស្ត្រ *Commelina benghalensis*)

**tropism** /ˈtrəʊpɪz(ə)m/ [n] តំនបរំញោច, ទំនោរទិស

- animal tropism /ˈanɪm(ə)l ˈtrəʊpɪz(ə)m/ [n] តំនបរំញោចសត្វ
- geotropism /ˌdʒiːə(ʊ)ˈtrəʊpɪz(ə)m/ [n] (សទិសន័យ ៖gravitropism) ការរងាកបែររកទិសនៃដើមឈើ (ជាការលូតលាស់ដែលមានរាង កោងចុះក្រោម ដោយសារភូវិពលផែនដី (ទំនាញផែនដី)។)
- gravitropism /ˈgravɪˈtrəʊpɪz(ə)m/ [n] សូមមើលពាក្យ ៖ geotropism
- phototropism /fəʊtəʊ trəʊpɪz(ə)m/ [n] គឺជាទំនោរនៃរុក្ខជាតិដើម្បីតម្រង់ទិសលូតលាស់ទៅរកពន្លឺ។
- plant tropism /plɑːnt ˈtrəʊpɪz(ə)m/ [n] តំនបរំញោចរុក្ខជាតិ

**tropophyte** /ˈtrɒp əˌfaɪt/ [n] ត្រូប៉ូភីត (រុក្ខជាតិដែលមិនអាចបន្សាំបាននឹងការប្រែប្រួលសីតុណ្ហភាព ភ្លៀងធ្លាក់ជាដើម)

**troposphere** /ˈtrɒpə(ʊ)sfɪə/ [n] ត្រូប៉ូស្វៃ, មណ្ឌលអាកាសរចល់

**trough** /trɒf/ [n] ស្នូក (សម្រាប់ដាក់បាយជ្រូកជាដើម), កន្លែងឱ្យសត្វផឹកទឹក

- glacial trough /ˈgleɪsɪəl trɒf/ [n] ជ្រលងទឹកកក

**trowel** /ˈtraʊəl/ [n] ប្រដាប់គាស់កូនឈើយកទៅដាំ, ស្លាបព្រាបាយអ

**truncate** /trʌŋˈkeɪt/ [adj] កំបុត (អំពីទម្រង់របស់រុក្ខជាតិ), ទម្រង់ចុងស្លឹកកំបុតស្មើ,ទម្រង់គល់ស្លឹកកំបុតស្មើ

**trunk** /trʌŋk/ [n]

១. ដើម (តួដើមសំខាន់របស់រុក្ខជាតិ)

២. តួខ្លួន (ដងខ្លួនដោយមិនរាប់បញ្ចូល ក្បាល ក និង អវយវៈ)

៣. ទ្រូង (របស់សត្វល្អិត)

៤. តួ (តួសំខាន់របស់ប្រសាទ ឬរបស់សរសៃឈាម)

៥. សូមមើលពាក្យ៖ tusk

***Trypanosoma theileri*** [sci.n] សូមមើលពាក្យ៖ trypanosomiasis

**trypanosomiasis** /ˌtrɪp(ə)nə(ʊ)sə(ʊ)ˈmʌɪəsɪs/ [n] ទ្រីប៉ាណូសូម តេឡីរី (បរាសិតក្នុងឈាម) (ឈ្មោះវិទ្យាសាស្ត្រ *Trypanosoma theileri*)

**tsunami** /tsuːˈnɑːmi/ [n] រលកសមុទ្រយក្ស (កម្ពស់រហូតដល់ ២០ ឬ៣០ម បង្កដោយការរំជួលផែនដីក្នុងមហាសមុទ្រ)

**tuber** /ˈtjuːbə/ [n] មើម (សរីរាង្គនៅក្រោមដីសម្រាប់ស្តុកអាហារចិញ្ចឹមដល់ដើម និងឫស ឱ្យរីកលូតលាស់)

**tubercle** /ˈtjuːbək(ə)l/ [n] កំពករាងមូល, រាងពងក្រពើ

**tuberculate** /tjuːˈbəːkjʊlət/ [adj] មានកំពក ឬមានមើម (ចំពោះរុក្ខជាតិ)

**tuberculin** /tjʊˈbəːkjʊlɪn/ [n] ទុយប៊ែកូលីន (ថ្នាំពិសោធរោគរបេង)

**tuberculosis (TB)** /tjʊˌbəːkjʊˈləʊsɪs/ [n] ជំងឺរបេង

**tuberose** /ˈtjuːbərəʊz/ [n] ផ្កាចន្ទ (ឈ្មោះវិទ្យាសាស្ត្រ *Polianthes tuberosa*)

**tubular** /ˈtjuːbjʊlə/ [adj] ប្រភេទផ្កាមានត្របកជាប់រាងបំពង់

**tubule** /ˈtjuːbjuːl/ [n] បំពង់តូច

**tubuliflorous** /tubjuːlɪflʊərəs/ [adj] កញ្ចុំស្រទាប់ផ្ការាងបំពង់ (អំពីរុក្ខជាតិ)

**tufa** /ˈt(j)uːfə/ [n] (សទិសន័យ៖ volcanic tuff) ទូហ្វភ្នំភ្លើង, គំនរផេះភ្នំភ្លើងដែលគរជាស្រទាប់ៗ

**tuff** /tʌf/ [n] (សទិសន័យ៖ tuffaceous limestone, calcareous tufa) ស្រទាប់កំបោរដែលរឹង

- vitric tuff /ˈvɪ trɪk tʌf/ [n] ថ្មប្រហោងច្រើន ឬស្រាលកើតមកពីផេះភ្នំភ្លើងដែលផ្សាភ្ជាប់គ្នា
- volcanic tuff /vɒlˈkanɪk tʌf/ [n] សូមមើលពាក្យ៖ tuff

**tuffaceous** /tʌˈfeɪʃəs/ [adj] ដែលជាទូហ្វ

**tufted** /ˈtʌftɪd/ [adj] ដុះជាកញ្ចុំ (ជាសណ្ឋានរបស់រុក្ខជាតិណាមានដើមដុះជាគុម្ពៗ)

**tumbling** /ˈtʌmb(ə)lɪŋ/ [n] វិធីជម្រុះគ្រាប់ក្នុងធុងបង្វិល (ប្រតិបត្តិការដែលកោន ឬផ្លែត្រូវបានគេដាក់នៅក្នុងធុងបង្វិលមួយ ដែលធ្វើឱ្យគ្រាប់រមៀល និងបោក ហើយធ្វើឱ្យគ្រាប់ជ្រុះចេញពីផ្លែ។ វិធីបង្វិលក្រឡុកនេះ គេអាចប្រើគួបផ្សំជាមួយការបញ្ចូលកម្ដៅជាមួយ ដូចជាឡបង្វិលផងដែរ។)

**tumor** /ˈtjuːmə/ [n] ដុំ, ពក, ផ្លែ, ការដុះថ្មីនៃជាលិកាប្លែកពីធម្មតា, សាច់ដុះ, ពកសាច់

**tundra** /ˈtʌndrə/ [n] ទុងដ្រា (ទិដ្ឋភាពតំបន់ប៉ូលដែលមានដើមឈើមួយៗ ស្មៅ និងស្លែ)

**tungro** /ˈtʌŋ groʊ/ [n] ជំងឺទុងគ្រោ (ជំងឺវីរុសដែលចម្លងដោយពពួកមមាចបៃតង ឬមមាចខ្មៅ (*Nephotettix sp.*) និងមមាចពព្រុស (*Recilia dorsalis*)។ រុក្ខជាតិដែលមានជំងឺមានដើមទាប ការបែកគុម្ពខ្សោយ ពណ៌ស្លឹកប្រែពីលឿងទៅលឿងទឹកក្រូច ដោយចាប់រាលពីចុងស្លឹកទៅគល់។ កួរស្រូវជាទូទៅពុំបានលូតលាស់ពេញលេញទេ។ គ្រាប់ស្រូវត្រូវបានគ្រប ឬពាសដោយស្នាមពណ៌ត្នោតចាស់។)

**Tungsten** /ˈtʌŋst(ə)n/ [n] តង់ស្តែន (និមិត្តសញ្ញាគីមី W)

**turbidity** /təːˈbɪdɪti/ [n] ភាពល្អក់

**turbinate** /ˈtəːbɪnət/ [adj] (ចំពោះរុក្ខជាតិ) រាងកោណបញ្ច្រាស

**turf** /təːf/ [n]

១. (សទិសន័យ៖ sod, sward) វាលស្មៅ

២. ប្រភេទស្មៅដែលប្រើក្នុងតារាងបាល់ទាត់)

៣. សូមមើលពាក្យ៖ muck

**turfy** /ˈtəːfi/ [adj] ដែលជាពើក

**turgidity** /ˈtəːdʒɪdli/ [n] ការតឹង, ការហើម, ប៉ោងខ្លាំង

**turkey** /ˈtəːki/ [n] មាន់បារាំង

**turmeric** /ˈtəːmərɪk/ [n] រមៀត, ល្មៀត

**turning into steppe** /ˈtəːnɪŋ ˈɪntʊ stɛp/ [n] ការក្លាយជាស្តែប (វាលស្មៅផចរឹល)

**turnip** /ˈtəːnɪp/ [n] ស្ពៃមើម (ឆៃថាវមើមមូលៗ)

***Tursiops aduncus*** [sci.n] សូមមើលពាក្យ៖ Indo-Pacific bottlenose dolphin

***Tursiops truncates*** [sci.n] សូមមើលពាក្យ៖ common bottlenose dolphin

**turtle** /ˈtəːt(ə)l/ [n] (ស្នូករឹង) សត្វអណ្ដើក, (ស្នូកទន់) សត្វកន្ធាយ

- green turtle /griːn ˈtəːt(ə)l/ [n] ល្មិច (ឈ្មោះវិទ្យាសាស្ត្រ *Chelonia mydas*)
- hawksbill turtle /ˈhɔːksbɪl ˈtəːt(ə)l/ [n] ក្រាស (ឈ្មោះវិទ្យាសាស្ត្រ *Eretmochelys imbricata*)
- leatherback turtle /ˈlɛðəbak ˈtəːt(ə)l/ [n] ល្មិចព្រុយបី, ល្មិចស្បែក (ឈ្មោះវិទ្យាសាស្ត្រ *Dermochelys coriacea*)
- loggerhead turtle /ˈlɒgəhɛd ˈtəːt(ə)l/ [n] ល្មិចក្បាលធំ (ឈ្មោះវិទ្យាសាស្ត្រ *Caretta caretta*)
- olive ridley turtle /ˈɒlɪv ˈrɪdli ˈtəːt(ə)l/ [n] ល្មិចប្រផេះ (ឈ្មោះវិទ្យាសាស្ត្រ *Lepidochelys olivacea*)
- yellow-leaded temple turtle /ˈjɛləʊ ˈlɛdɪd ˈlɛdɪd ˈtɛmp(ə)l ˈtəːt(ə)l/ [n] អណ្ដើកសង្កល់ (ឈ្មោះវិទ្យាសាស្ត្រ *Heosemys annandalli*)

**tusk** /tʌsk/ [n] (សទិសន័យ៖ trunk) ភ្លុកដំរី

**twig** /twɪg/ [n] មែកតូចៗ

**twins** /twɪnz/ [n pl] កូនភ្លោះ, ភ្លោះ

**twitch** /twɪtʃ/ [v] ទ័រណេ (ប្រដាប់មួលច្រមុះសេះ)

**tympanites** /ˌtɪmpəˈnʌɪtiːz/ [n] ការតឹង, កំប៉ោង

**tympanum** /ˈtɪmpənəm/ [n] តាំប៉ានុម (សរីរាង្គសោតវិញ្ញាណរបស់សត្វល្អិត)

**tympany** /ˈtɪmpəni/ [n] ការប៉ោងតឹងពោះដោយមានខ្យល់ខាងក្នុង

**type** /tʌɪp/ [n] ក្រុម, ប្រភេទ

- endosperm type /ˈɛndə(ʊ)spəːm tʌɪp/ [n] ប្រភេទសាច់គ្រាប់, ប្រភេទអង់ដូស្ពែម (ប្រភេទអង្ករខ្សាយ ឬដំណើបចំពោះដំណាំស្រូវ)
- fruit type /fruːt tʌɪp/ [n] ប្រភេទផ្លែឈើ (ពាក្យសំដៅទៅលើរូបរាងទូទៅ និងទម្រង់របស់ផ្លែឧទាហរណ៍ ប្រភេទផ្លែក្រូច និងផ្លែសាច់ជាដើម)
- grain type /greɪn tʌɪp/ [n] ប្រភេទគ្រាប់ (អនុបាត (ទំនាក់ទំនង)រវាងប្រវែង និងទទឹងគ្រាប់។ គ្រាប់អាចជាប្រភេទរលួន(ឆ្មារ) ខ្លី ឬមូល។)
- root type /ruːt tʌɪp/ [n] សូមមើលពាក្យ៖ root pattern
- soil type /sɔɪl tʌɪp/ [n] ប្រភេទដី
- subtype /ˈsʌbtʌɪp/ [n] (សទិសន័យ៖ undertype, sub-variety) អនុប្រភេទ

***Typhlachirus elongatus*** [sci.n] សូមមើលពាក្យ៖ Mekong blind sole

**typhoid** /ˈtʌɪfɔɪd/ [n] គ្រុនពោះវៀន

**typhoon** /tʌɪˈfuːn/ [n] ព្យុះទីហ្វុង

**typhus** /ˈtʌɪfəs/ [n] គ្រុនទីភុស, គ្រុនសន្និ, គ្រុនធាល

U

**udder** /ˈʌdə/ [n] កន្សោមដោះសត្វ (ឧ. មេគោ មេពពែ)

- fore udder /fɔː ˈʌdə/ [n] ដោះសត្វផ្នែកខាងមុខ
- rear udder /rɪə ˈʌdə/ [n] កន្សោមដោះផ្នែកខាងក្រោយ

**ulcer** /ˈʌlsə/ [n] ដំបៅក្រពះ, រោគដំបៅរលួយ, អ៊ុលសែ

- decubital ulcer /dɪˈkjuːbɪt(ə)l ˈʌlsə/ [n] ដំបៅរលាក (ដោយសារការកកិតចំកន្លែងដដែលៗ)
- peptic ulcer /ˈpɛptɪk ˈʌlsə/ [n] ដំបៅក្រពះ, ដំបៅផ្នែកដើមនៃពោះវៀនតូច

**ulna** /ˈʌlnə/ [n] ឆ្អឹងធំកំភួនដៃ, ឆ្អឹងស្មងដៃខាងក្រោម

**ultra-** /ˈʌltrə/ [prefix] (សទិសន័យ៖ beyond) ជាបុព្វបទមានន័យថា ហួស, លើស

**ultrasound** /ˈʌltrəsaʊnd/ [n] សូរអ៊ុលត្រា, ការពិនិត្យស្តាប់សំឡេងរចនា នៃគ្រឿងក្នុងប្រាណ

**ultraviolet** /ʌltrəˈvʌɪələt/ [n] ស្វាយអ៊ុលត្រា (កាំរស្មី)

**umbel** /ˈʌmb(ə)l/ [n] ផ្កាចង្កោមកញ្ចុំ, ផ្ការាងឆត្រ (កំពូលផ្កាមានរាងឆត្រ)

**umbellate** /ˈʌmbəleɪt/ [adj] ផ្កាជាចង្កោម (ផ្កាដែលមានក្បាលផ្កាដែលមានរាងដូចឆ័ត្រ និងផ្កាមួយៗ មានទងខ្លី ៗ)

**umbilical cord** /ʌmbɪlɪklˈkɔːd/ [n] ទងផ្ចិត, ទងសុក

**umbilicus** /ʌmˈbɪlɪkəs/ [n] សូមមើលពាក្យ៖ navel

**umbrella sedge** /ʌmˈbrɛlə sɛdʒ/ [n] កក់ឆត្រ

**unarmed** /ʌnˈɑːmd/ [adj] គ្មានបន្លា (អំពីទម្រង់របស់រុក្ខជាតិ)

**uncemented** /ˈʌnsɪmentɪd/ [adj] ធូរ(ដី), ស្រទន់, ស្រួលធ្វើការភ្ជួរ

**unconscious** /ʌnˈkɒnʃəs/ [adj] មិនដឹងខ្លួន, អញ្ញាណ, បាត់បង់វិញ្ញាណ, សន្លប់ស្មារតី

**underbrush** /ˈʌndəbrʌʃ/ [n] សូមមើលពាក្យ៖ underwood

**undercutting** /ʌndəˈkʌtɪŋ/ [n] (សទិសន័យ៖ undermining) ការគាស់រលំ

**underground** /ʌndəˈgraʊnd/ [n] សូមមើលពាក្យ៖ deep subsoil

**undermining** /ʌndəˈmʌɪnɪŋ/ [n] សូមមើលពាក្យ៖ undercutting

**undernorishment** /ˌʌndəˈnʌrɪʃm(ə)nt/ [n] កង្វះសារធាតុចិញ្ចឹម, សារធាតុចិញ្ចឹមខ្សត់ខ្សោយ

**undernourished** /ʌndəˈnʌrɪʃt/ [adj] (សទិសន័យ៖ food deprived) ខ្វះអាហារូបត្ថម្ភ, ខ្វះស្បៀង

**undernutrition** /ˌʌndə njʊˈtrɪʃ(ə)n/ [n] កង្វះអាហារូបត្ថម្ភ ឬអាហារូបត្ថម្ភខ្សត់ខ្សោយ

**undertype** /ˈʌndətʌɪp/ [n] សូមមើលពាក្យ៖ subtype

**underwood** /ˈʌndəwʊd/ [n] (សទិសន័យ៖ underbrush) ឈើតូចៗដុះពីក្រោមឈើធំៗ

**undulate** /ˈʌndjʊlət/ [adj] ទម្រង់តែមស្លឹកទឹករលក

**undulating** /ˈʌndjʊleɪtɪŋ/ [adj] រាងជាទឹករលក, សភាពខ្ពស់ទាបខ្លាំង (មិនរាបស្មើ)

**uneven-aged** /ʌnˈiːv(ə)n eɪdʒd/ [adj] ដែលមានអាយុខុសៗគ្នា (ចំណាត់ថ្នាក់អាយុឈើចាប់ពីបីឡើងទៅ និងចម្រុះចំណាត់ថ្នាក់)

- uneven-aged forest /ʌnˈiːv(ə)n eɪdʒd ˈfɒrɪst/ [n] ព្រៃអាយុមិនស្មើគ្នា
- uneven-aged stand /ʌnˈiːv(ə)n eɪdʒd stand/ [n] ឈើដែលមានអាយុខុសៗគ្នា ចំណាត់ថ្នាក់អាយុចាប់ពីបីឡើងទៅ និងចម្រុះចំណាត់ថ្នាក់
- uneven-aged stand /ʌnˈiːv(ə)n eɪdʒd ˈsɪstəm/ [n] ការធ្វើផែនការដាំដុះឈើឱ្យមានលំដាប់អាយុច្រើនជាងបីថ្នាក់ខុសៗគ្នា

**unguent** /ˈʌŋgwənt/ [n] សូមមើលពាក្យ៖ ointment

**ungulate** /ˈʌŋgjʊlət/ [n] សន្តានសត្វដែលមានក្រចកក្រញ៉ាំ

**uni-** /ˈjuːni/ [prefix] ជាបុព្វបទមានន័យថា មួយ (សទិសន័យ៖ one)

**unicell** /ˈjuːnisɛl/ [n] ក្លូន

**unilateral** /juːnɪˈlat(ə)r(ə)l/ [adj] ឯកតោភាគ, តែម្ខាង

**unique** /juːˈniːk/ [adj] តែមួយ

**unisexual** /juːnɪˈsɛkʃʊəl/ [adj] ឯកភេទ, មានភេទតែមួយ, ផ្កាដែលមានតែកេសរញី, ផ្កាមានតែកេសរឈ្មោល

**unit** /ˈjuːnɪt/ [n] ខ្នងរាយ, ឯកត្តា, ខ្នាត (ឧ. ខ្នាតនៃប្រវែងគឺម៉ែត្រ (m))

- soil unit /sɔɪl ˈjuːnɪt/ [n] ពួកដី

**unsaturated** /ʌnˈsatʃʊreɪtɪd/ [adj] មិនទាន់ឆ្អែត, មិនខាប់, មិនពេញ, មិនលើសកំណត់

**unstable** /ʌnˈsteɪb(ə)l/ [adj] គ្មានលំនឹង, គ្មានស្ថិរភាព

**untilled** /ənˈtɪld/ [adj] ដែលមិនដាំ

**untoothed** /ənˈtu:θt/ [adj] បន្ទះស្លឹកដែលរលោង និងគ្មានធ្មេញនៅជាយស្លឹក

**Ununbium** /əˈnʌn bi əm/ [n] អ៊ុយនុយប្យូម (និមិត្តសញ្ញាគីមី Uub)

**Ununium** /ˌʌn əˈni əm/ [n] អ៊ុយនុយនុយន្យូម (និមិត្តសញ្ញាគីមី Uuu)

**Ununnilium** /ˌʌn əˈnɪl i əm/ [n] អ៊ុយនុយនីល្យូម (និមិត្តសញ្ញាគីមី Uun)

**Ununquadium** /ˌʌn ənˈkwɑ di əm/ [n] អ៊ុយនុយកាដ្យូម (និមិត្តសញ្ញាគីមី Uuq)

**unwater** /ʌnˈwɔ:tə/ [v] សូមមើលពាក្យ៖ drain

**unweaned** /ʌnˈwi:nd/ [adj] ដែលមិនបានផ្តាច់ដោះ

**upgrading** /ʌpˈgreɪdɪŋ/ [n] ការបង្កើនគុណភាព (ការធ្វើឱ្យប្រសើរឡើងនូវគុណភាពមធ្យម ឬការសម្តែងឡើងដោយធ្វើការបំបាត់ឯកត្តៈអន់ៗ ន័យទាក់ទងនឹងគ្រាប់ពូជ គឺជាការបង្កើនលទ្ធភាពរស់ និងសុខភាពរឹងមាំរបស់កញ្ចប់គ្រាប់ដោយការសម្រិតសម្រាំងចេញនូវគ្រាប់តូចៗ មិនទុំ ស្កៀត និងម៉្យាងទៀតគ្រាប់ពូជអន់ចេញពីកញ្ចប់គ្រាប់ពូជ។ ន័យទាក់ទងនឹងប្រភព ផលិតគ្រាប់ពូជ គឺកាប់ចេញនូវដើមដែលមានផេណូទីបអន់ ដើម្បីបង្កើនគុណភាពសេនេទិច ឧ. ការបង្កើតតំបន់ផលិតគ្រាប់ពូជ។)

**upland** /ˈʌplənd/ [n] ខ្ពង់រាប, ដីខ្ពស់, ដីទួល

**uplifting** /ʌpˈlɪftɪŋ/ [n] ការឡើងពីក្រោមមកលើនូវសារធាតុរលាយក្នុងដី

**uproot** /ʌpˈru:t/ [v] ដកទាំងឫស

**upstream** /ˈʌpstri:m/ [adj] ខាងលើទឹក

**water uptake** /ˈwɔ:tə ˈʌpteɪk/ [n] ការស្រូបទឹកឡើង

**upwarping** /ˈʌpwɔ:pin/ [n] កន្លែងកំពុងឡើងប៉ោង

**urachus** /ˈɒrətʃʌs/ [n] អ៊ុយរ៉ាគុស (ទងភ្ជាប់ពីប្លោកនោមទៅអាឡង់តូរបស់ទារក)

**Uranium** /jʊˈreɪnɪəm/ [n] អ៊ុយរ៉ានីញ៉ូម (និមិត្តសញ្ញាគីមី U)

**urban** /ˈə:b(ə)n/ [n] (សទិសន័យ៖ built-up area) ទីប្រជុំជន

**urbanization** /ə:b(ə)nʌɪˈzeɪʃ(ə)n/ [n] នគរូបនីយកម្ម

**urceolate** /ˈɜr si əleɪt/ [adj] ប្រភេទផ្កាមានត្របកជាប់ឌីទិនស្រា, ប្រភេទផ្កាមានរាងដូចក្អម

**urea** /jʊˈri:ə/ [n] អ៊ុយរេ, វត្ថុធាតុក្នុងខ្លួនដែលបញ្ចេញចោលក្នុងទឹកនោម

**uremia** /jʊˈri:mɪə/ [n] ពុលទឹកនោម, ការកើនចំនួនជាតិពុលក្នុងឈាម (តាមធម្មតា វក្កបានបញ្ចេញចោលក្នុងទឹកនោម)

***Urena lobata*** [sci.n] សូមមើលពាក្យ៖ caesar weed

**ureter** /ˈjʊərɪtə/ [n] បំពង់ទឹកមូត្រ, បំពង់នោម

**urethra** /jʊˈri:θrə/ [n] រន្ធ, ទ្វារ, បង្ហួរ (នោម)

**arthrography** /ɑrˈθrɒg rə fi/ [n] ការពិនិត្យមើលរន្ធ ឬទ្វារនោម ដោយរស្មីអិក្ស

**urinate** /ˈjʊərɪneɪt/ [v] នោម

**urine** /ˈjʊərʌɪn/ [n] ទឹកនោម

**urine collector** /ˈjʊərɪn kəˈlɛktə/ [n] ប្លោកដាក់ទឹកនោម

**uro-** /ˈjʊərəʊ/ [prefix] ជាបុព្វបទមានន័យថា អំពើអ្វីដែលទាក់ទង នឹងគ្រឿងនោម

**urogenital** /ˌjʊərə(ʊ)ˈdʒɛnɪt(ə)l/ [adj] ដែលទាក់ទងនឹងប្រដាប់បន្តពូជ, ដែលទាក់ទងនឹងប្រដាប់នោម

**urticaria** /ˌə:tɪˈkɛ:rɪə/ [n] (សទិសន័យ៖ hives, rash) ជំងឺកន្ទាលត្រអាក (ការប៉ោងស្បែកយ៉ាង រហ័ស ដោយសារការរមាស់ខ្លាំង ប្រហែលដោយ ព្រោះមានប្រតិកម្ម)

**use** /ju:z/ [n] (សទិសន័យ៖ utilization) ការប្រើប្រាស់

- domestic use /dəˈmɛstɪk ju:z/ [n] ការប្រើប្រាស់ក្នុងស្រុក
- sustainable use /səˈsteɪnəb(ə)l ju:s/ [n] ការប្រើប្រាស់ប្រកបដោយនិរន្តរភាព (ការប្រើប្រាស់សមាសភាពនៃជីវចម្រុះតាមវិធីមួយ និងក្នុងអត្រាមួយដែលមិនបណ្តាលឱ្យជីវចម្រុះធ្លាក់ចុះនាអនាគតយូរអង្វែងឡើយ ហេតុនេះវានៅរក្សាសក្តានុពលរបស់វាឆ្លើយតបនឹងតម្រូវការ និងសេចក្តីប្រាថ្នាក្នុងជំនាន់បច្ចុប្បន្ន និងអនាគត)

**useful** /ˈju:sfʊl/ [adj] ដែលមានប្រយោជន៍

**uterine** /ˈjuːtərɪn/ [n] នៃស្បូន

**uterus** /ˈjuːt(ə)rəs/ [n] (សទិសន័យ៖ womb) ស្បូន

**utilise** /ˈjuːtɪlʌɪz/ [v] ប្រើប្រាស់

**utilization** /ˈjuːtɪlʌɪ'zeɪʃ(ə)n/ [n] សូមមើលពាក្យ៖ use

**uvula** /ˈjuːvjʊlə/ [n] កន្លើត

# V

**vaccinate** /ˈvaksɪneɪt/ [v] ចាក់វ៉ាក់សាំង, ចាក់ថ្នាំបង្ការរោគ

**vaccination** /vaksɪˈneɪʃ(ə)n/ [n] ការចាក់វ៉ាក់សាំង, ការផ្ដល់ថ្នាំបង្ការ

**vaccinator** /ˈvaksɪneɪtə/ [n] អ្នកចាក់ថ្នាំបង្ការរោគ

**vaccine** /ˈvaksɪn/ [n] ថ្នាំបង្ការរោគ, វ៉ាក់សាំង

**vaccinia** /vakˈsɪnɪə/ [n] សូមមើលពាក្យ៖ cowpox

**vacuum** /ˈvakjuːm/ [n] សុញ្ញាកាស (កន្លែងគ្មានខ្យល់), បូម

**vagina** /vəˈdʒʌɪnə/ [n] ផ្លូវយោនី, រន្ធយោនី

**vaginal** /vəˈdʒʌɪn(ə)l/ [adj] នៃប្រដាប់ភេទស្រី ឬសត្វញី

**vaginate** /ˈvadʒə ˈneɪt/ [adj] ស្ថិតនៅក្នុងស្រោម

**vagotomy** /veɪˈgɒtəmi/ [n] ការវះកាត់សរសៃប្រសាទនៃ "ប្រព័ន្ធសរសៃប្រសាទស្វ័យភាព" ដើម្បីព្យាបាល ដំបៅក្រពះ

**vagus** /ˈveɪgəs/ [n] សរសៃប្រសាទមួយនៃ "ប្រព័ន្ធសរសៃប្រសាទស្វ័យភាព"

**valence** /ˈveɪl(ə)ns/ [n] វ៉ាឡង់

**valley** /ˈvali/ [n] ជ្រលង

- desert dry valley /dɪˈzəːt drʌɪ vali/ [n] ជ្រលងនៅតំបន់សមុទ្រខ្សាច់ដែលមានទឹកហូរម្ដងៗពេលភ្លៀងខ្លាំង
- flat-bottomed valley /ˈflat ˈbɒtəmd vali/ [n] ជ្រលងដែលមានបាតរាបស្មើ
- glacial valley /ˈgleɪsɪəl ˈvali/ [n] ជ្រលងដែលមានបាតស្មើ, ជម្រាលចោត (ជ្រលងទឹកកក)
- small valley /smɔːl ˈvali/ [n] សូមមើលពាក្យ៖ swale

**valvate** /ˈvalveɪt/ [adj] (អំពីអង្គត់របស់បរិបុប្ផា) វ៉ាល់វ៉ែរ (មានគែមប៉ះជាប់ជាមួយត្រួយពន្លក ប៉ុន្តែមិនត្រួតលើគ្នាទេ), តម្រៀបនៃគល់ត្របកផ្កាសន្ទះគ្រប

**valve** /valv/ [n]

១. វ៉ាល់

២. ផ្នែកនៃគ្រាប់ដែលមានផ្លែគួរ (ការចែកសម្បកគ្រាប់ ឬផ្លែឱ្យចេញពីគ្នា)

៣. សន្ទះបំពង់កេស (សន្ទះដើរតួនាទីជាគម្រប បំពង់កេស)

៤. ផ្នែកនៃជញ្ជាំងកោសិកាមានពីរផ្នែក ហើយ silica មិនអាចជ្រាបចូលបានដែលវាមានលក្ខណៈជាគម្របរបស់ប្រអប់

**Vanadium** /vəˈneɪdɪəm/ [n] វ៉ាណាដ្យូម (និមិត្តសញ្ញាគីមី V)

**vapor** /ˈveɪpə/ [n] ចំហាយ (ទឹក)

- water vapor /ˈwɔːtə ˈveɪpə/ [n] សូមមើលពាក្យ៖ water steam

**vaporise** /ˈveɪpərʌɪz/ [n] បង្ហួត, ហួត

**variability** /vɛːrɪəˈbɪlɪti/ [n] វិសមរូប, វិបរិតការ, លទ្ធភាពបម្រែបម្រួល (សេនេទិច)

- climate variability /ˈklʌɪmət vɛːrɪəˈbɪlɪti/ [n] វិសមរូបអាកាសធាតុ

**variable** /ˈvɛːrɪəb(ə)l/ [n] វិបរិតរូប, អថេរ (រូបលក្ខណៈដែលអាចមានតម្លៃខុសគ្នានៅកន្លែងផ្សេងៗគ្នា)

**variance** /ˈvɛːrɪəns/ [n] ការប្រែប្រួល, ការប្រែប្រួលវ៉ារ្យង់, វិបរិតភាព (រង្វាស់នៃការប្រែប្រួលរបស់ប្រជាករតាមទ្រឹស្ដីនៃការបែងចែកធម្មតា)

**variant** /ˈvɛːrɪənt/ [n] ប្រភេទមិនទាន់មានឈ្មោះ

**variation** /vɛːrɪˈeɪʃ(ə)n/ [n] ការប្រែប្រួល, ការផ្លាស់ប្ដូរ, អថេរភាព, វិបរិតកម្ម, បម្រែបម្រួល (១. ការខុសគ្នារវាងឯកត្តៈនៅក្នុងប្រជាករមួយ ឬក៏ជាការខុសគ្នារវាងមេបា និងកូន ២. ភាពខុសប្លែកគ្នានៃការសម្ដែងឡើង និងលក្ខណៈរបស់ឯកត្តៈដោយសារតែកត្តាខាងក្នុង និងខាងក្រៅ។ នៅក្នុងក្រុមពូជធម្មជាតិមួយ បម្រែបម្រួលផេណូទីប គឺលទ្ធផលនៃការវិវត្តន៍បម្រែបម្រួលទាំងបរិស្ថាន និងសេនេទិច។ នៅក្នុងការពិសោធន៍បម្រែបម្រួលគំរូ និងលទ្ធផលលំអៀងនៃការពិសោធន៍ បង្កើតបានជាគំលាតបម្រែបម្រួល។)

- antigenic variation /antɪˈdʒɛnɪk vɛːrɪˈeɪʃ(ə)n/ [n] បម្លាស់ប្ដូរអង់ទីសែនជាបន្តបន្ទាប់
- geographic variation /dʒiːəˈgrafɪk vɛːrɪˈeɪʃ(ə)n/ [n] បម្រែបម្រួលភូមិសាស្ត្រ (ការខុសគ្នាខាងផេណូទីបក្នុងចំណោមដើមឈើកំណើតដែលដុះនៅទីកន្លែងផ្សេងៗនៃលំដាប់ប្រភេទពូជមួយ។ បើសិនជា ការខុសប្លែកគ្នានេះ វាមានលក្ខណៈលំអៀងខ្លាំងខាងសេនេទិចជាងបរិស្ថាននោះ បម្រែបម្រួលនេះ ជាធម្មតាវាបញ្ជាក់ថាជាពូជ (race) ប្រភេទបរិស្ថាន (ecotype) ឬភាពស្រដៀង (cline)។)
- non-inherited variation /nɒn ɪnˈhɛrɪtɪd vɛːrɪˈeɪʃ(ə)n/ [n] សូមមើលពាក្យ៖ accommodation
- qualitative variation /ˈkwɒlɪtətɪv vɛːrɪˈeɪʃ(ə)n/ [n] បម្រែបម្រួលគុណភាព

- quantitative variation /ˈkwɒntɪtətɪv vɛːrɪˈeɪʃ(ə)n/ [n] បម្រែបម្រួលបរិមាណ

**variegation** /vɛːrɪəˈgeɪʃ(ə)n/ [n] បម្រែបម្រួលពណ៌ (បម្រែបម្រួលពណ៌ក្នុងផ្នែកផ្សេងៗគ្នានៃស្លឹក ឬផ្កា)

**varietal recommendation committee** /vəˈrʌɪət(ə)l ˌrɛkəmɛnˈdeɪʃ(ə)n kəmɪti/ [n] គណៈកម្មាធិការអនុសាសន៍ពូជ

**variety** /vəˈrʌɪəti/ [n] ពូជ, ភាពប្លែកៗ, នានាភាព (១. ការបែងចែកលំដាប់ថ្នាក់នៃរុក្ខជាតិនៃប្រភេទមួយ ដែលផ្អែកទៅលើលក្ខណៈបន្ទាប់បន្សំ ហើយជារឿយៗមិនគិតពីទីតាំងភូមិសាស្ត្រទេ។ លំដាប់ថ្នាក់ពូជ (ភាពប្លែកៗ) នៅក្រោមប្រភេទពូជ ប៉ុន្តែនៅខាងលើលំដាប់ថ្នាក់ នៅក្នុងឋានានុក្រមវគ្គីករណ៍។ ២. ការផ្គុំគ្នាមួយនៃឯកត្តៈដែលគេដាំ ខុសប្លែកគ្នាតាមសារៈប្រយោជន៍ណាមួយ លក្ខណៈអាចបន្តពូជ។)

- high yielding varieties (HYVs) /hʌɪ ˈjiːldɪŋ vəˈrʌɪətis/ [n pl] ប្រភេទស្រូវដែលមានទិន្នផលខ្ពស់
- improved variety /ɪmˈpruːvd vəˈrʌɪəti/ [n] ពូជបរិជ្ជ (ពូជ ដែលបានសម្រិតសម្រាំង និងជ្រើសរើសលើលក្ខណៈចង់បានណាមួយនៃឯកត្តៈ ឬសេណូទីប ដែលមានគូសម្ពន្ធករដូចគ្នាក្នុងពន្ធុរបស់វា (ឧ. Aa))
- popular variety /ˈpɒpjʊlə vəˈrʌɪəti/ [n] ពូជប្រជាប្រិយ (ពូជដែលកសិករនិយមចូលចិត្តដាំនៅក្នុងតំបន់របស់គាត់)
- recommended variety /rɛkəˈmɛndɪd vəˈrʌɪəti/ [n] ពូជណែនាំ, ពូជអនុសាសន៍ (ពូជដែលបានអនុញ្ញាតឱ្យប្រើប្រាស់ដោយគណៈកម្មការអនុសាសន៍ពូជ)
- released variety /rɪˈliːsd vəˈrʌɪəti/ [n] ពូជរំដោះ (ពូជដែលបញ្ចេញឱ្យប្រើប្រាស់ដោយគណៈកម្មការអនុសាសន៍ពូជ)
- resistant variety /rɪˈzɪstənt vəˈrʌɪəti/ [n] ពូជធន់
- semi-dwarf variety /ˈsɛmi dwɔːf vəˈrʌɪəti/ [n] ពូជកម្ពស់មធ្យម
- short-strawed variety /ʃɔːt strɔːd vəˈrʌɪəti/ [n] ពូជជញ្ជ្រាំងខ្លី
- sub-variety /sʌb-vəˈrʌɪəti/ [n] សូមមើលពាក្យ៖ subtype
- traditional variety /trəˈdɪʃ(ə)n(ə)l vəˈrʌɪəti/ [n] ពូជប្រពៃណី (ពូជដែលទទួលការដាំដុះ និងថែទាំនៅក្នុងតំបន់មួយដោយកសិករ)

**varve** /vɑːv/ [n] ល្បាប់កករដែលកកឆ្លាស់គ្នាជាស្រទាប់ល្អិត និងស្រទាប់គ្រើម

**vary** /ˈvɛːri/ [v] ប្រែប្រួល

**vas deferens** /vas ˈdɛfərɛnz/ [n] សូមមើលពាក្យ៖ ductus deferens

**vascectomy** /vəˈsɛktəmi/ [n] ការវះកាត់យកបំពង់នោមចេញ

**vasoconstrictor** /ˌveɪzəʊkənˈstrɪktə/ [n] ប្រដាប់បង្រួមសរសៃប្រសាទ,ថ្នាំបង្រួមសរសៃឈាម

**vasodilator** /ˌveɪzəʊdʌɪˈleɪtə/ [n] ប្រដាប់ពង្រីកសរសៃប្រសាទ,ថ្នាំពង្រីកសរសៃឈាម

**vascular** /ˈvaskjʊlə/ [n] សរសៃឈាម (សត្វ), សរសៃនាំ (រុក្ខជាតិ)

**vascular** /ˈvaskjʊlə/ [adj] នៃសរសៃ

**vasectomy** /vəˈsɛktəmi/ [n] ការកាត់បំពង់មេជីវិតរបស់បុរសចោល

**vaso-** /ˈveɪzəʊ/ [prefix] (សទិសន័យ៖ vassel) ជាបុព្វបទមានន័យថា សរសៃ, បំពង់

**vasomotor** /ˈveɪzəʊməʊtə/ [adj] វ៉ាសូ, ចលករ

**veal** /viːl/ [n] កូនគោឈ្មោល, សាច់កូនគោ

**vector** /ˈvɛktə/ [n] ភ្នាក់ងារចម្លងជំងឺ

- cloning vector /kloʊnɪŋ ˈvɛktə/ [n] វិចទ័រសម្រាប់ក្លូន
- pollen vector /ˈpɒlən ˈvɛktə/ [n] វិចទ័រលម្អង, មធ្យោបាយបញ្ជូនលម្អង ( ភ្នាក់ងារឬមធ្យោបាយបញ្ជូនឬពាំនាំលម្អងពីផ្កាឈ្មោល ឬពី strobili ឈ្មោលទៅឱ្យផ្កាញី ឬ strobili ញី ឧ. ខ្យល់ ទឹក សត្វពាហនៈ បក្សី សត្វល្អិត។ ការចម្លងលម្អងតាមសត្វ ជាធម្មតា គេហៅវាថា Pollinator (សត្វនាំលម្អង)។)

**vegeculture** /ˈvɛdʒˈkʌltʃə/ [n] ការដាំដុះដំណាំយកមើមក្នុងគ្រួសារ Araceae

**vegetable** /ˈvɛdʒtəb(ə)l/ [n] បន្លែ

- leafy vegetable /ˈliːfi ˈvɛdʒtəb(ə)l/ [n] សូមមើលពាក្យ៖ leaf vegetable
- vegetable covering /ˈvɛdʒtəb(ə)l ˈkʌv(ə)rɪŋ/ [n] កម្រេបរស់ (រុក្ខជាតិរស់)
- vegetable gardening /ˈvɛdʒtəb(ə)l ˈgɑːd(ə)nɪŋ/ [n] ការធ្វើសួនបន្លែ

**vegetarian** /vɛdʒɪˈtɛːrɪən/ [n] អ្នកតមអាហារសាច់

**vegetarianism** /vɛdʒɪˈtɛːrɪənɪz(ə)m/ [n] ការតមអាហារសាច់

**vegetation** /vɛdʒɪˈteɪʃ(ə)n/ [n] រុក្ខជាតិ, សារពើរុក្ខជាតិ

- desert vegetation /ˈdɛzət vɛdʒɪˈteɪʃ(ə)n/ [n] សារពើរុក្ខជាតិលំហ
- hydrophytic vegetation /ˈhʌɪdrəfʌɪtɪk vɛdʒɪˈteɪʃ(ə)n/ [n] សូមមើលពាក្យ៖ hydrophyte
- mesophytic vegetation /ˈmɛsə(ʊ)fʌɪtɪk vɛdʒɪˈteɪʃ(ə)n/ [n] រុក្ខជាតិដែលចូលចិត្តទឹកជាមធ្យម
- xerophytic vegetation /ˈzɪərəʊfʌɪtɪk vɛdʒɪˈteɪʃ(ə)n/ [n] រុក្ខជាតិដែលអាចរស់ ឬធន់នៅកន្លែងស្ងួត

**vegetative** /ˈvɛdʒɪtətɪv/ [adj] នៃសរីរាង្គលូតលាស់

**veil** /veɪl/ [n] របាំងការពារមុខ (សម្រាប់ចាប់ឃ្មុំ), គម្របពីលើ (ស្រទាប់ស្លឹក ឬមែកឈើមិនទាន់រលួយ)

**vein** /veɪn/ [n]

១. (សទិសន័យ៖ seam) សរសៃ (ចំពោះធរណីវិទ្យា)

២. សរសៃឈាមខ្មៅ, សរសៃវ៉ែន (ចំពោះមនុស្ស សត្វ)

៣. ទ្រនុងស្លឹក (ចំពោះរុក្ខជាតិ)

- groundwater vein /ˈgraʊn(d)wɔːtə veɪn/ [n] សរសៃទឹកក្នុងជម្រៅដី
- longitudinal parallel vein /ˌlɒngɪˈtjuːdɪn(ə)l ˈparəlɛl veɪn/ [n] ទ្រនុងស្របបណ្ដោយ (ប្រភេទទ្រនុងស្លឹក)
- palmately reticulated vein /ˈpalmeɪtli rɪˈtɪkjʊleɪtɪd veɪn/ [n] ប្រភេទទ្រនុងស្លឹកសំណាញ់ដូចម្រាមដៃ
- reticulated vein /rɪˈtɪkjʊleɪtɪd veɪn/ [n] ប្រភេទទ្រនង់ស្លឹកក្រឡាសំណាញ់
- varicose vein /ˈvarɪkəʊs veɪn/ [n] សរសៃឈាមប៉ោង ឬយឺត

**velutinous** /vəˈlut n əs/ [adj] រោមកាំម្វី (ប្រភេទរោមលើស្លឹក)

**vena cava** /ˌviːnə ˈkeɪvə/ [n] សូមមើលពាក្យ៖ cava

**venation** /vɪˈneɪʃ(ə)n/ [n] ការតម្រៀបទ្រនុងស្លឹក

- palmate venation /ˈpalmeɪt vɪˈneɪʃ(ə)n/ [n] ទ្រនុងកង្ហារ (ប្រភេទតម្រៀបទ្រនុងស្លឹក ដែលកូនស្លឹកទាំងអស់ភ្ជាប់ទៅនឹងទងស្លឹកចំកន្លែងតែមួយ)
- pinnate venation /ˈpɪneɪt vɪˈneɪʃ(ə)n/ [n] ទ្រនុងស្និត (ប្រភេទតម្រៀបទ្រនុងស្លឹក ដែលទ្រនុងតូចៗបែកមែកចេញពីទ្រនុងធំមួយ)

**veneer** /vɪˈnɪə/ [n] វីនា (សន្លឹកឈើស្តើងៗ ដែលរួមបញ្ចូលគ្នាឱ្យមានកម្រាស់ក្រាស់តាមរយៈការកាត់ជាចំណិតៗ ដោយរណា)

**venereal** /vɪˈnɪərɪəl/ [adj] ជាប់ទាក់ទង ឬលទ្ធផលចេញពីការ រួមដំណេក

**venipuncture** /ˈvɛnɪˌpʌŋ(k)tʃə/ [n] ការចាក់ម្ជុលទម្លាយសរសៃឈាម(ដើម្បីបូមយកឈាមចេញ ឬបញ្ចូលថ្នាំ)

**venom** /ˈvɛnəm/ [n] ពិស

**ventifact** /ˈvɛntɪfakt/ [n] សូមមើលពាក្យ៖ polished pebble

**ventilation** /ˌvɛntɪˈleɪʃ(ə)n/ [n] ចរន្តខ្យល់, ការបញ្ចេញបញ្ចូលខ្យល់, ការបើកផ្លូវខ្យល់

**ventilator** /ˈvɛntɪleɪtə/ [n] ប្រដាប់ធ្វើឱ្យមានខ្យល់ចេញចូល, ប្រដាប់បើកផ្លូវខ្យល់

**ventral** /ˈvɛntr(ə)l/ [adj] នៃផ្នែកពោះ, នៃផ្នែកខាងក្រោម (ឧ. សត្វ រុក្ខជាតិ)

**ventricle** /ˈvɛntrɪk(ə)l/ [n] ថតក្រោម (បេះដូង)

**verge** /vəːdʒ/ [n] ព្រំប្រទល់, ជាយ (នៅតាមថ្នល់ សួន)

**vermicide** /ˈvəːmɪsʌɪd/ [n] ថ្នាំសម្លាប់ដង្កូវ

**vermiform** /ˈvəːmɪfɔːm/ [adj] រាងដូចដង្កូវ

**vermifuge** /ˈvəːmɪfjuːdʒ/ [n] ថ្នាំទម្លាក់ដង្កូវព្រូន

**vernalization** /vəːn(ə)lʌɪˈzeɪʃ(ə)n/ [n] រីកពេលត្រជាក់ (ការចេញផ្កាបណ្ដាលមកពីអាកាសធាតុត្រជាក់)

**vernix caseosa** /ˈvəːnɪks keɪsɪˈəʊsə/ [n] រំអិលទារកនៅពេលកើតមក

***Vernonia cinerea*** [sci.n] សូមមើលពាក្យ៖ little ironweed

**vertebra** /ˈvəːtɪbrə/ [n] (ពហុវចនៈ៖ vertebrae) ឆ្អឹងកង, កំណាត់មួយនៃជួរឆ្អឹងខ្នង

**vertebrate** /ˈvəːtɪbrət/ [n] សត្វឆ្អឹងកង

**vertebrate** /ˈvəːtɪbrət/ [adj] នៃកំណាត់មួយជួររបស់ឆ្អឹងខ្នង

**vertex** /ˈvəːtɛks/ [n] កំពូល, ចំណុចនៃមុម, ចំណុចជួបគ្នាពីរនៅលើក្បាល

**vertigo** /ˈvəːtɪgəʊ/ [n] វិលមុខ (ជំងឺ), ដំណើរវិលមុខ, ការវឹងវេង, ការភាន់

**vesicle** /ˈvɛsɪk(ə)l/ [n] ពងទឹករងៃ

**vessel** /ˈvɛs(ə)l/ [n]

១. សរសៃ (ទម្រង់នៃបំពង់នាំទឹកនៅក្នុងរុក្ខជាតិ កើតមាន ចំពោះរុក្ខជាតិមានផ្កា និងពពួក ferns ដែលនាំទឹក និង សារធាតុរ៉ែ ដែលរលាយ ឆ្លងកាត់រុក្ខជាតិបង្កើតជាផ្នែក នៃជាលិកា xylem)

២. សរសៃឈាម, នហារូ

- wood vessel /wʊd ˈvɛs(ə)l/ [n] បំពង់ដែលមានជាតិ ឈើ (មាននាទីនាំទឹកនៅក្នុងរុក្ខជាតិ ឬនាំយកនូវសារធាតុរ៉ែ ដែលរលាយឆ្លងកាត់រុក្ខជាតិ)

**vestige** /ˈvɛstɪdʒ/ [n] ដំណែល (ផ្នែកនៃសរីរាង្គរបស់ភាវ រស់ (រុក្ខជាតិ សត្វ) ដែលក្លាយជាគ្មានតួនាទីក្នុងការវិវត្ត)

**vestigial** /vɛˈstɪdʒɪəl/ [adj] នៃដំណែល

**veterinarian** /ˌvɛt(ə)rɪˈnɛːrɪən/ [n] បសុពេទ្យ (ពេទ្យសត្វ)

**veterinary** /ˈvɛt(ə)rɪn(ə)ri/ [adj] នៃវេជ្ជសាស្ត្រសត្វ, នៃ ពេទ្យសត្វ

**veterinary service** /ˈvɛt(ə)rɪn(ə)ri ˈsəːvɪs/ [n] សេវា ព្យាបាលជំងឺសត្វ

**viability** /vʌɪəˈbɪlɪti/ [n] លទ្ធភាពរស់, លទ្ធភាពដំណុះ, ដំណុះភាព, លទ្ធភាពរស់បាន (លទ្ធភាពដែលគ្រាប់ពូជមួយ អាចដុះ និងអភិវឌ្ឍន៍ទៅជាសរីរាង្គពេញលេញមួយបាន)

- seed viability /siːd vʌɪəˈbɪlɪti/ [n] ដំណុះភាពនៃគ្រាប់ (លទ្ធភាពដំណុះពន្លកនៃគ្រាប់ពូជ ក្រោមលក្ខខណ្ឌសម ស្រប ហើយជាសំណាបមានលក្ខណៈល្អធម្មតា)

**viable** /ˈvʌɪəb(ə)l/ [adj] ដែលអាចរស់បាន

**viable** /ˈvʌɪəb(ə)l/ [adj] អាចរស់

- viable cell count /ˈvʌɪəb(ə)l sɛl kaʊnt/ [n] ចំនួន កោសិការស់

**vial** /ˈvʌɪəl/ [n] (សទិសន័យ៖ small bottle) ដបតូច (ឧ. សម្រាប់ដាក់ថ្នាំ)

**vibration** /vʌɪˈbreɪʃ(ə)n/ [n] រំញ័រ

**vibrio fetus** (ˈvɪbrɪəʊ ˈfiːtəs) [n] សូមមើលពាក្យ៖ vibrio

**vibrio** /ˈvɪbrɪəʊ/ [n] (សទិសន័យ៖ vibrio fetus) វីប្រីយ៉ុង (ពពួកមេរោគដែលមានរាងដូចគំនូសក្បៀស)

**vice** /vʌɪs/ [n] អង្គំ (ឧបករណ៍សម្រាប់ចាប់កៀបវត្ថុផ្សេងៗ), វង (ព្រឹទ្ធបុរសវង)

**view** /vjuː/ [n] ប្លង់ (មើល), ទេសភាព, គំហើញ, ទស្សនីយភាព ការមើលទៅឃើញ

- front view /frʌnt vjuː/ [n] ប្លង់មុខ (ប្លង់ដែលយើងមើល ពីមុខ)
- side view /sʌɪd vjuː/ [n] ប្លង់ចំហៀង
- top view /tɒp vjuː/ [n] ប្លង់លើ (ប្លង់ដែលយើងមើលពីលើ)

***Vigna radiata*** [sci.n] សូមមើលពាក្យ៖ mung bean

***Vigna unguiculata* ssp. *Sinensis*** [sci.n] សូមមើលពាក្យ៖ cowpea

***Vigna unguiculata* subsp. *Sesquipedalis*** [sci.n] សូមមើលពាក្យ៖ yardlong bean

**vigour** /ˈvɪgə/ [n] កម្លាំងលូតលាស់, ពលសម្បទា, សុខ ភាពរឹងមាំ (លក្ខណៈសម្បត្តិរបស់គ្រាប់ពូជទាំងឡាយណា ដែលកំណត់ពីសក្តានុពលដុះពន្លក និងវិវត្តន៍លឿន និងស្រុះ គ្នារបស់កូនឈើធម្មតា នៅក្រោមលក្ខខណ្ឌទីវាលខុសគ្នាច្រើ ន។ ជាធម្មតា ការបាត់បង់ពលសម្បទាគឺកើតឡើងមុន មុន ការបាត់បង់លទ្ធភាពដំណុះ ហេតុដូច្នេះ យើងឃើញខ្សែកោង ចុះយ៉ាងលឿន (ឧ. ដូចវាស់នៅក្នុងការពិសោធន៍ដំណុះនៅ ក្រោមលក្ខខណ្ឌលំបាកជាងខ្សែកោងលទ្ធភាពដំណុះ (ឧ. វាស់នៅក្រោមលក្ខខណ្ឌដំណុះប្រសើរ)។)

- hybrid vigour /ˈhʌɪbrɪd ˈvɪgə/ [n] ពលសម្បទានកូន កាត់
- seedling vigour /siːdɪŋ ˈvɪgə/ [n] កម្លាំងលូតលាស់ នៃរុក្ខជាតិ (ប្រពលភាពនៃការដុះលូតលាស់របស់សំណាប)

**villous** /ˈvɪləs/ [adj] មានរោមពេញ (អំពីរុក្ខជាតិ)

**villus** /ˈvɪləs/ [n] (ពហុវចនៈ៖ villi) រោមស្រមូវ, ជ្រាំង (ពោះវៀន), ការលយចេញពីផ្ទៃស្រទាប់ស្លេស្ម ដែលមាននៅ តាមពោះវៀន

**villus biopsy** /ˈvɪləs ˈbʌɪɒpsi/ [n] ការយកជាលិកាបន្តិច មកពិនិត្យ មើលជំងឺពោះវៀនតូច

**vinegar** /ˈvɪnɪgə/ [n] ទឹកខ្មេះ

**vineyard** /ˈvɪnjɑːd/ [n] ចម្ការទំពាំងបាយជូរ

**vining** /ˈvʌɪnɪŋ/ [n] ការច្រូតកាត់ពពួកសណ្តែក (ឧ. សណ្តែកបារាំង)

**vinomous** /ˈvɛnəməs/ [adj] ដែលមានពិស

**violet** /ˈvʌɪələt/ [n] ពណ៌ស្វាយ

**viral** /ˈvʌɪr(ə)l/ [adj] ដែលបណ្ដាលមកពីវីរុស

**virescence** /vɪˈrɛs(ə)ns/ [n] ការកើតឡើងក្លរ៉ូភីលក្នុងជាលិកាដែលធម្មតាគ្មានក្លរ៉ូភីល, ភាពប្រែពណ៌បៃតង

**virescent** /vɪˈrɛs(ə)nt/ [adj] ប្រែពណ៌បៃតង (សំណាបខ្ចីដែលមានពណ៌ស ឬក៏លឿងខ្ចីជាលទ្ធផលមួយបង្កឡើងដោយសារការពន្យាការកកើត ឬអភិវឌ្ឍន៍នៃជាតិពណ៌បៃតង។ ក្រោយមកវាប្រែពណ៌ជាបៃតងវិញ។)

**virulence** /ˈvɪrʊl(ə)ns/ [n] រាលដាលភាព (សមត្ថភាពនៃពួកបង្កជំងឺ ឬសត្វល្អិតដើម្បីបង្កើតជំងឺ)

**virulent** /ˈvɪrjʊl(ə)nt/ [adj] សហ័ស (ឆ្លងខ្លាំង), ដែលខ្លាំងហើយឆាប់រាលដាល, ដែលកំណាច, ដែលសាហាវ

**viruliferous** [adj] មេជំងឺ (មេចម្លង ឬសត្វល្អិតចង្រៃដែលផ្ទុកទៅដោយវីរុស។ វាមានឈ្មោះថាជាសត្វល្អិតដែលបានផ្ដល់ប្រភពវីរុសដល់ដំណាំ។)

**virus** /ˈvʌɪrəs/ [n] វីរុស (មេរោគដែលតូចក្រៃលែង)

- defective virus /dɪˈfɛktɪv ˈvʌɪrəs/ [n] វីរុសខ្វះលក្ខណៈ (វីរុសដែលអាចឆ្លងចូលទៅក្នុងធ្មួលបាន តែខ្វះមុខងារសំខាន់មួយ ឬច្រើន សម្រាប់ដំណើរការស្វ័យតំឡើងទ្វេរបស់វា ហើយវាអាចស្វ័យតំឡើងទ្វេបាន ករណីមានវត្តមានរបស់វីរុសមានគ្រប់លក្ខណៈ (វីរុសជួយ) ដែលអាចផ្ដល់ឱ្យនូវមុខងារដែលគ្មាន)
- non-persistent virus /nɒnpəˈsɪst(ə)nt ˈvʌɪrəs/ [n] វីរុសខ្សោយ (វីរុសដែលពេលវេលានៃការចម្លងខ្លី ឬមិនឆ្លងតាមឈាមជរនៃសត្វល្អិត ឬមិនចម្លងតាមរយៈសំណាកនៃមេចម្លង ឬកាលណាបន្សុទ្ធហើយបញ្ចូលវាទៅក្នុងឈាមជរ វាមិនអាចបង្កើតជាភ្នាក់ងារចម្លងរោគឡើយ)
- persistent virus /pəˈsɪst(ə)nt ˈvʌɪrəs/ [n] វីរុសរ៉ាំរ៉ៃ (១. វីរុសដែលមានពេលវេលាចម្លងវែង ២. វាក្លាយជាវីរុសចម្លងវិញ ដោយសារឈាមជរនៃសត្វល្អិតដែលវារស់នៅ ៣. វាឆ្លងតាមរយៈសំណល់ភ្នាក់ងារចម្លង ៤. ពេលណាបន្សុទ្ធ និងចាក់ចម្លងនៅក្នុងឈាម វាធ្វើឱ្យភ្នាក់ងារក្លាយទៅជាមានសមត្ថភាពឆ្លងជំងឺ)
- plant virus /plɑːnt ˈvʌɪrəs/ [n] វីរុសរុក្ខជាតិ

**viscera** /ˈvɪs(ə)rə/ [n pl] (ឯកវចនៈ៖ viscus) អាការៈក្នុង (ឧ. ផ្នែកខាងក្នុងនៃពោះមានពោះវៀនជាដើម)

**viscid** /ˈvɪsɪd/ [adj] ស្អិតអន្ទិល (អំពីផ្ទៃករបស់រុក្ខជាតិ)

**viscosity** /vɪˈskɒsɪti/ [n] ភាពអន្ទិល, ភាពខាប់

**viscous** /ˈvɪskəs/ [adj] ដែលអន្ទិល, ដែលខាប់

**vision** /ˈvɪʒ(ə)n/ [n] ទស្សនៈវិស័យ (នៅក្នុងបរិបទនៃការអភិវឌ្ឍន៍ និងគោលនយោបាយ សេចក្ដីប្រកាសសង្ខេបអំពីគោលដៅរយៈពេលយូរអង្វែងរបស់គោលនយោបាយ ឬកម្មវិធី។ គោលដៅប្រកបដោយក្ដីប៉ងប្រាថ្នាមួយដែល គេអាចអនុវត្តបានទៅតាមគ្រប់ទិដ្ឋភាពទាំងអស់នៃ គោលនយោបាយ ឬកម្មវិធី។ ពាក្យនេះក៏ចង់និយាយសំដៅផងដែរថាជាសេចក្ដីថ្លែងការពីទស្សនៈវិស័យ (របស់កម្មវិធី អ្វីមួយ)។)

**vision** /ˈvɪʒ(ə)n/ [n] សូមមើលពាក្យ៖ eyesight

**vital** /ˈvʌɪt(ə)l/ [adj] ដែលទាក់ទងនឹងជីវិត, ជីវិតសម្ខន, ជីវថាម (ភាវរស់ដែលមានសារសំខាន់ខ្លាំង)

**vitamin** /ˈvʌɪtəmɪn/ [n] វីតាមីន, ជីវជាតិ

**vitamin B12** /ˈvɪtəmɪn biː twɛlv/ [n] សូមមើលពាក្យ៖ cobalamin

**vitamin C** /ˈvɪtəmɪn siː/ [n] វីតាមីនសេ

**viviparous** /vɪˈvɪp(ə)rəs/ [adj] ដែលដុះពន្លកក្នុងផ្លែ, ដែលដុះពន្លលពេលមិនទាន់ជ្រុះពីដើម (ការដុះពន្លកគ្រាប់នៅខណៈផ្លែវានៅជាប់លើដើមមេនៅឡើយ ឧ. *Rhizophora spp.*។ ប្រភេទគ្រាប់នេះពិបាកថែទុកដាក់ខ្លាំងណាស់។)

**voice** /vɔɪs/ [n] សំឡេង

**void** /vɔɪd/ [n]

១. សូមមើលពាក្យ៖ pore

២. បន្ទោទឹក នោម, ជុះនោម

**volar** /ˈvəʊlə/ [adj] ដែលទាក់ទងនឹងបាតដៃ

**volatilization** /vəlatɪlʌɪˈzeɪʃ(ə)n/ [n] ចំហាយកម្ម (ប្ដូរពីទម្រង់រាវ ទៅជាចំហាយ ឬឧស្ម័ន)

- ammonia volatilization /əˈməʊnɪə vəlatɪlʌɪˈzeɪʃ(ə)n/ [n] បំភាយអាម៉ូញាក់ (បាតុភូតដែលក្នុងនោះអាសូត បានត្រូវបំភាយចេញពីដីក្នុងទម្រង់ជាឧស្ម័នអាម៉ូញាក់)

**volcanism** /ˈvɒlkənɪz(ə)m/ [n] ព្រឹត្តិកម្មភ្នំភ្លើង

**volcano** /vɒlˈkeɪnəʊ/ [n] ភ្នំភ្លើង

- mud volcano /mʌd vɒlˈkeɪnəʊ/ [n] ភ្នំភ្លើងដែលចេញជាភក់

**volume** /ˈvɒljuːm/ [n] មាឌ, វ៉ុល្លូម

**volunteer** /ˌvɒlənˈtɪə/ [n] អ្នកស្ម័គ្រចិត្ត, កម្មិកសមាជិក (អ្នកឧស្សាហ៍ស្ម័គ្រ ឬអ្នកធ្វើការដោយស្ម័គ្រចិត្ត)

***Volvariella volvacea*** [sci.n] សូមមើលពាក្យ៖ straw mushroom

**volvulus** /ˈvɒlvjʊləs/ [n] រមួល (ឧ. ការមួលគ្នានៃពោះវៀន និងពោះវៀនតូច)

**vomit** /ˈvɒmɪt/ [n, v] ក្អួត

**vomitus** /ˈvɒmɪtəs/ [adj] នៃកម្អួត

**vulnerability** /vʌln(ə)rəˈbɪlɪti/ [n] ភាពងាយរងគ្រោះ (ភាពងាយរងគ្រោះ គឺជាដំណើរការនៃការសំដៅទៅរកការងាយ ឬ ឆាប់ទទួល និងការអាចប្រែប្រួលដើបឡើងវិញបានយ៉ាងរហ័សទៅនឹងហានិភ័យ ឬព្រឹត្តិការណ៍ដ៏គួរឱ្យតក់ស្លុតដែលនឹងបណ្ដាលឱ្យមានលទ្ធភាពកើតមានលទ្ធផលជាអវិជ្ជមាន)

**vulnerable** /ˈvʌln(ə)rəb(ə)l/ [adj] ងាយរងគ្រោះ

**vulture** /ˈvʌltʃə/ [n] សត្វត្មាត

**vulva** /ˈvʌlvə/ [n] យោនី, អង្គជាតស្ត្រី

**W**

**wade** /weɪd/ [v] ដើរឆ្លង, លុយទឹកឆ្លងកាត់

**wader** /ˈweɪdə/ [n] ពួកបក្សីជើងវែង និងកវែងដែលរស់ក្បែរទឹក និងស៊ីត្រី (សត្វកុក សត្វក្រសារជាដើម)

**waist** /weɪst/ [n] ចង្កេះ

- waist-deep /weɪstdiːp/ [adj] ជ្រៅត្រឹមចង្កេះ
- waist-high /weɪst hʌɪ/ [adj] ខ្ពស់ត្រឹមចង្កេះ

**wall** /wɔːl/ [n] ជញ្ជាំង, កំពែង, របង, កំផែង

- breast-wall /brɛst wɔːl/ [n] ជញ្ជាំងទប់ (ទប់ដី ឬទឹក)
- cell wall /sɛl wɔːl/ [n] ភ្នាសគ្រោង
- chest wall /tʃɛst wɔːl/ [n] សូមមើលពាក្យ៖ chest
- retaining wall /rɪˈteɪnɪŋ wɔːl/ [n] ជញ្ជាំងទប់ (សម្រាប់ទប់ដី ឬទឹក)
- revetment wall /rɪˈvɛtm(ə)nt wɔːl/ [n] ជញ្ជាំងពាស (សម្រាប់ពង្រឹង ឬលម្អ) ឬទប់ដីកុំឱ្យបាក់
- sea wall /siː wɔːl/ [n] ទំនប់រលក (សមុទ្រ)

***Wallago attu*** [sci.n] ត្រីសណ្ដាយ

***Wallago leeri*** [sci.n] ត្រីស្ទក់

**Wallow** /ˈwɒləʊ/ [v] កត់, ដេកត្រាំភក់, ននៀលភក់

**warehouse** /ˈwɛːhaʊs/ [n] សូមមើលពាក្យ៖ godown

**warp** /wɔːp/ [n] សូមមើលពាក្យ៖ flood deposit

**warp-anmoor** [n] សូមមើលពាក្យ៖ muck

**short warping** /ʃɔːt wɔːpɪŋ/ [n] កករល្បាយនៅពីក្រៅ

**warping** /wɔːpɪŋ/ [n] ការអន្ទោងអំបោះ, ការធ្វើឱ្យកោង

**wart** /wɔːt/ [n] ឬស, ប្រជ្រុយដុះ

**wash** /wɒʃ/ [v] លាង, បោក, គក់, ងូតទឹកឱ្យ

- sheat wash /ʃiːt wɒʃ/ [n] ការហូរច្រោះលើផ្ទៃដីលើជម្រាល

**washing off** /wɒʃɪŋ ɒf/ [n] ការនាំចេញទៅដោយទឹក

**washing out** /wɒʃɪŋ aʊt/ [n] ការផ្ដាច់ដីដោយទឹកសើខាងលើ

**wasp** /wɒsp/ [n] ឪម៉ាល់

**waste** /weɪst/ [n] សំណល់

animal waste /ˈanɪm(ə)l weɪst/ [n] សំណល់សត្វ

city waste /ˈsɪti weɪst/ [n] សំណល់ទីក្រុង

coarse waste /kɔːs weɪst/ [n] សម្ភារដែលជាកម្ទេចកំទីធំៗ

- combustible waste /kəmˈbʌstɪb(ə)l weɪst/ [n] សំណល់ឥន្ធនៈ
- commercial waste /kəˈməːʃ(ə)l weɪst/ [n] សំណល់ជំនួញ, សំណល់ពាណិជ្ជកម្ម
- construction waste /kənˈstrʌkʃ(ə)n weɪst/ [n] សំណល់សំណង់
- domestic waste /dəˈmɛstɪk weɪst/ [n] សំណល់លំនៅឋាន
- farm waste /fɑːm weɪst/ [n] សំណល់កសិកម្ម
- food waste /fuːd weɪst/ [n] សំណល់ចំណីអាហារ
- gaseous waste /ˈgasɪəs weɪst/ [n] សំណល់ឧស្ម័ន
- hazardous waste /ˈhazədəs weɪst/ [n] សំណល់ប្រកបដោយគ្រោះថ្នាក់
- hillside waste /ˈhɪlsʌɪd weɪst/ [n] ស្រទាប់កម្ទេចកំទីដែលគ្របពីលើដី
- humic matter /ˈhjuːmɪk ˈmatə/ [n] សរីរាង្គមមោក
- industrial waste /ɪnˈdʌstrɪəl weɪst/ [n] សំណល់ឧស្សាហកម្ម
- inorganic solid waste /ɪnɔːˈganɪk ˈsɒlɪd weɪst/ [n] សំណល់រឹងអសរីរាង្គ
- liquid waste /ˈlɪkwɪd weɪst/ [n] សំណល់រាវ
- manufacturing waste /manjʊˈfaktʃərɪŋ weɪst/ [n] សំណល់ឧស្សាហកម្ម
- mine waste /mʌɪn weɪst/ [n] សំណល់អណ្ដូងរ៉ែ
- mountain waste /ˈmaʊntɪn weɪst/ [n] (សទិសន័យ៖ rock waste) កម្ទេចថ្មបែកបាក់ធ្លាក់ចុះមកក្រោម
- nitrogenous waste /nʌɪˈtrɒdʒɪnəs weɪst/ [n] កាកសំណល់អាសូត
- nuclear waste /ˈnjuːklɪə weɪst/ [n] សំណល់នុយក្លេអ៊ែ
- organic waste /ɔːˈganɪk weɪst/ [n] សំណល់សរីរាង្គ
- pathological waste /paθəˈlɒdʒɪk(ə)l weɪst/ [n] សំណល់បង្ករោគ
- radioactive waste /ˌreɪdɪəʊˈaktɪv weɪst/ [n] សំណល់វិទ្យុសកម្ម
- rock waste /rɒk weɪst/ [n]
  ១. សូមមើលពាក្យ៖ debris
  ២. សូមមើលពាក្យ៖ mountain waste

- small waste /smɔːl weɪst/ [n] សម្ភារកម្ទេចកំទីល្អិតៗ
- solid waste /ˈsɒlɪd weɪst/ [n] សំណល់រឹង
- toxic waste /ˈtɒksɪk weɪst/ [n] សំណល់ពុល
- trade waste /treɪd weɪst/ [n] សំណល់ពាណិជ្ជកម្ម

**wasteland** /ˈweɪs(t)land/ [n] ដីទំនេរ

